## អ្នកស្រី គីម-ធីអ៊ុយ
(ហៅ យាយទៀង)

# អង្គការប៉ានរណា?

## ភាគ១

រក្សាសិទ្ធិគ្រប់យ៉ាង

# វាចាអ្នកបោះពុម្ព

ដោយសារព្រឹត្តិការណ៍ខ្មែរកំពុងឆ្លងចូលមកដល់ដំណាក់ការយ៉ាងសំខាន់នៃប្រវត្តិសាស្ត្រជាតិ គឺបញ្ហារៀបចំការកាត់ទោសខ្មែរក្រហម សារពត៌មាន «អង្គរបូរី» មានកិត្តិយសលើកយកឯកសារដ៏អស្ចារ្យមួយរបស់អ្នកស្រីគីម-ធីអ៊ូយ ហៅយាយទៀង ដែលមានចំណងជើងថា ៖ «អង្គការជានរណា?» មកចុះផ្សាយសារជាថ្មីម្តងទៀត (លើកទី៣) ។

ឯកសារនេះធ្លាប់បានទទួលនូវការកោតសរសើរ ពីសំណាក់មិត្តអ្នកអាននិងជនរួមជាតិយ៉ាងច្រើនរួចមកហើយ ។ វត្ថុបំណងរបស់យើង គឺសំរាប់ជួយជាជំនួយស្មារតី ដល់មិត្តអ្នកអាននិងជនរួមជាតិ ដើម្បីជាការក្រើនរំលឹកអំពីឃាតកម្មដ៏មហាឃោរឃៅមួយដែលក្រាំងសាវតាជាតិយើងបានកត់ត្រាទុកជានិច្ចរហូតទៅ ។

យើងសូមជំរាបមិត្តអ្នកអាននិងបងប្អូនរួមជាតិថា បន្ទាប់ពីចងក្រងឯកសារនេះ អ្នកស្រីគីម-ធីអ៊ូយ ហៅយាយទៀង ដែលសព្វថ្ងៃកំពុងស្នាក់នៅឯប្រទេសបារាំង បានជួបប្រទះនឹងការលំបាកក្នុងជីវភាពរស់នៅប្រចាំថ្ងៃយ៉ាងខ្លាំង ដោយអ្នកស្រីត្រូវផ្លាស់ប្តូរអស័-យដ្ឋានជាញឹកញាប់ ដើម្បីចៀសវាងការតាមព្យាបាទពីសំណាក់ភ្នាក់ឃ្លួនកុម្មុយនិស្ត ។ សៀវភៅឯកសារទាំងពក្បាលរបស់អ្នកស្រីទៀតសោត ក៏បានត្រូវគេហាមលក់ទូទាំងប្រទេសកម្ពុជាផងដែរ ។ នេះហើយឆាកជីវិតដ៏គ្រោតគ្រាតនៃខ្មែរអ្នកជាតិនិយម ។

«អង្គរបូរី»
សម្លេងខ្មែរនៅបរទេស

# អារម្ភកថា

ហេតុអ្វីបានជាខ្ញុំចងក្រងកំរងឯកសារប្រវត្តិសាស្ត្រ « អង្គការជានរណា ? » ខ្ញុំយល់ឃើញថា ៖

★ ដើម្បីការពារមាតុភូមិកម្ពុជា !

★ ដើម្បីកសាងសន្តិភាពមាតុភូមិកម្ពុជា !

យើងត្រូវប្រមូលប្រជាពលរដ្ឋខ្មែរឲ្យរួបរួមសាមគ្គីគ្នាពិតៗ ស្មោះត្រង់ចំពោះគ្នាពិតៗ ឲ្យបានស្អិតល្មួតជាធ្លុងមួយ ។

ដើម្បីសាមគ្គីគ្នាយ៉ាងនេះបាន លុះត្រាតែយើងចេះពន្យល់ឲ្យប្រជាពលរដ្ឋខ្មែរយល់ឲ្យបានច្បាស់ ថាតើសាសន៍ណាជាសត្រូវចំពោះជាតិខ្មែរ ? ជាពិសេសប្រជាពលរដ្ឋខ្មែរត្រូវតែស្គាល់ ត្រូវតែដឹង ថាតើអង្គការជានរណា ?

ជាចាំបាច់ ត្រូវយល់ឲ្យច្បាស់ជាងនេះទៅទៀត អំពីលក្ខណៈនៃសង្គ្រាមពិតៗក្នុងប្រទេសកម្ពុជា ព្រោះសង្គ្រាមនេះបើយើងក្រឡេកមើលតែមួយភ្លែតទៅ យើងឃើញថាជាសង្គ្រាមរវាងខ្មែរនឹងខ្មែរ ។ ប៉ុន្តែបើយើងសិក្សាអំពីនយោបាយវាតទីឈ្លានពានរបស់យួនហាណូយ យើងនឹងយល់បានយ៉ាងងាយថា សង្គ្រាមនេះជាសង្គ្រាមរវាងយួនហាណូយនឹងខ្មែរ ដែលមានចិនប៉េកាំងស៊ីគ្រលុំជាមួយផង ។

កលល្បិចលេបទឹកដីកម្ពុជានេះ យួនហាណូយនិងចិនប៉េកាំងបានរៀបចំគំរោងការជាដំណាក់ៗគឺ ៖

ទី១- លេបយកកម្ពុជាតាមរយៈកម្លាំងយោធាឈ្លានពាន

ទី២- បង្កប់ភ្នាក់ងារយួន « ជាពិសេសបួដួយធ្លាក់វិន័យមិនគោរពលក្ខណ៍ ដែលត្រូវនៅស្រុកខ្មែររហូត » ក្នុងជួររបបភ្នំពេញ ដើម្បីងាយកំទេចកម្លាំងជាតិនិយមខ្មែរ ។

ទី៣- លួចបង្កប់និគមយួនក្នុងប្រទេសកម្ពុជា ដោយលួចបន្លំធ្វើជាខ្មែរ ដើម្បីឈ្លានពានតាមរយៈសន្លឹកឆ្នោត ។

ទី៤- វាកំពុងបង្កើតខ្មែរថ្មី នាំយកមកជំនួសខ្មែរយើង ។

ទី៥- វាមានបង្កើតក្រុមឃាតករអាថ៌កំបាំង ដាក់ឈ្មោះជាអាថ៌កំបាំងគឺ « បង្អែកបដិវត្តន៍ » ។

ទី៦- ចំណែកឯចិនប៉េកាំងវិញ វាប្រើកលល្បិចជាបញ្ញោស់ជាបណ្តោយ នរណាក៏ដឹងដែរថា ចិនប៉េកាំងកំពុងតែឧបត្ថម្ភស្តេចសីហនុ « គឺវាប្រើសង្គ្រាមត្រជាក់ » តែវាបែរជាផ្តល់អាវុធឲ្យខ្មែរក្រហម « គឺវាប្រើសង្គ្រាមក្តៅ » ។

មូលហេតុនេះ ទើបខ្ញុំខំស្រាវជ្រាវអស់រយៈជាង១៣ឆ្នាំ ខ្ញុំរកបានឯកសារជាភស្តុតាង មានលក្ខណៈដ៏ត្រឹមត្រូវពិតប្រាកដនេះមិនខ្វះឡើយ ។ ខ្ញុំព្យាយាមសរសេរក្នុងរយៈពេលជាងប្រាំបីឆ្នាំទើបចប់ ខ្ញុំក៏សំរេចដាក់ចំណងជើង « អង្គការជានរណា? »

កម្រងឯកសារប្រវត្តិសាស្ត្រនេះជារឿងពិត ។ ដូច្នេះខ្ញុំសូមអំពាវនាវដល់បងប្អូនខ្មែររួមឈាម សូមអានឯកសារនេះ ។ បងប្អូនខ្មែររួមឈាមមុខតែនឹងស្គាល់ថា សាសន៍ណាជាចោរចូលមកប្លន់ទ្រព្យសម្បត្តិប្រទេសកម្ពុជា ។ ជាពិសេស បងប្អូននឹងជ្រាបអំពីលក្ខណៈនៃសង្គ្រាមពិតៗ ដែលកើតឡើងនៅក្នុងប្រទេសកម្ពុជាជាទីស្នេហារបស់យើង ។

ប៉ារីស៍, ថ្ងៃទី១ តុលា ១៩៩៣
អ្នកស្រី គីម-ធីអ៊ួយ

## គំនុំស្ត្រីខ្មែរ

ថ្ងៃរះក្តៅហែង ងងិតម្នាក់ឯង កណ្តាលវាលធំ
សំបកក្រៅសើច ឈាមក្នុងស្រែកឃុំ កណ្តាលវាលធំ
យំក្នុងសើចក្រៅ ។

មួយនឹកដល់ប្តី ដែលចោរអប្រីយ៍ ខាងជើងចាប់ទៅ
មួយនឹកដល់កូន មាសស្ងួនឆោមឆ្មៅ ខាងត្បូងលួចទៅ
យូរខែឆ្នាំហើយ ។

ឱ!សែនសង្វេគ ប្តីកូនកែវភ្នែក សម្លាញ់ខ្ញុំអើយ
តើព្រាត់ជួបវិញ ឬមិនជួបឡើយ ខ្មែរទុក្ខឥតស្បើយ
ទុក្ខអើយទុក្ខធំ។

ថ្ងៃរះក្តៅហែង ងងិតម្នាក់ឯង កណ្តាលវាលធំ
សំបកក្រៅសើច បេះដូងទួញយំ ខ្មែរបៀមគំនុំ
យំក្នុងសើចក្រៅ ។៚

# សេចក្ដីផ្ដើម

## គួរឲ្យចម្លែកណាស់ !

ប្រទេសខ្មែរកំពុងតែបានសុខក្សេមក្សាន្ត... ស្រាប់តែមានព្រឹត្តិការណ៍ដ៏មហាចង្រៃមួយផ្ទុះឡើង ។ នៅថ្ងៃ១៧មេសា១៩៧៥, ប្រទេសខ្មែរក្លាយទៅជាលានមរណៈភ្លាម ។ ខ្មែរមួយក្រុមក្លាយទៅឃាតករលើសាសន៍ខ្លួនយ៉ាងព្រៃផ្សៃ ។ ប៉ុន្តែមេបញ្ជាការគឺ « អង្គការអនាមិក » មិនមែនសម្ដេចន. សីហនុ ឬលោកខៀវ-សំផនទេ... គួរឲ្យចម្លែកណាស់ ! ។ គូបដិបក្ខច្បាំងគ្នាក្នុងកំឡុងពេល៥ឆ្នាំ១ខែ ត្រូវចាញ់ទាំងអស់គ្នា ។ មើលចុះ... លោកលន់-នល់សុំចាញ់ ស្ម័គ្រចិត្តដើរចាកចោលស្រុក, សម្ដេចសីហនុបែរជាជាប់ឃុំឃាំងទៅវិញ, រីឯខៀវ-សំផន... គ្មានឮឈ្មោះ ។

សំនួរ ៖ តើនរណាជាអ្នកឈ្នះ ?

ចម្លើយ ៖ គឺក្រុមសម្ងាត់ជាអ្នកឈ្នះ... រួចវាលួចបន្លំប្រើឈ្មោះ « អង្គការ » ។ ជាដំបូងអង្គការចាត់ការសម្លាប់ជាបន្ទាន់ នូវបញ្ញវ័ន្ត, ព្រះសង្ឃ រួចហើយវាលើកបន្ទុបចោរសិន ។ កាលណោះអង្គការគ្រប់គ្រងប្រទេសខ្មែរប្រើរបបចោរ គឺយើងឃើញចោរក្ដាប់អំណាចយ៉ាងពេញលេញ ប៉ុន្តែវាប្រើឃីហោខ្មែរក្រហម ។ ខ្មែរក្រហមធុននេះដើរប្លន់បាញ់សម្លាប់ខ្មែរដោយសេរី ។ វាកែទម្រង់ពាក្យប្លន់ជាពាក្យ ស្មើ ។ ប៉ុន្តែពាក្យស្មើនេះសាហាវយង់ឃ្នងជាងពាក្យប្លន់ទៅទៀត ។ ព្រោះរដ្ឋធម្មនុញ្ញរបស់អង្គការ ការពារចោរដើរស្មើ... បើម្ចាស់ទ្រព្យមិនព្រមឲ្យចោរ គឺមិនព្រមឲ្យចោរខ្មែរក្រហមធុននោះ វាសម្លាប់ចោលដោយសេរី រួចចោទថាក្បត់អង្គការ ។ អង្គការដេញប្រជាពលរដ្ឋខ្មែរក្នុងមួយនគរ ឲ្យចាកចេញពីទីលំនៅ ត្រូវចោលទ្រព្យសម្បត្តិយ៉ាងច្រើនឥតគណនា ។ អង្គការឆ្វេររដ្ឋធានីភ្នំពេញនិងទីក្រុងទាំងឡាយ ឲ្យក្លាយទៅជាទីក្រុងខ្មោច ។ ពេលនោះអង្គការបែរជាបញ្ចូលចិនបញ្ចូលយួនមកកាន់ប្រទេសខ្មែរ, ប្រមូលទ្រព្យសម្បត្តិរបស់ខ្មែរ, ប្លន់ដឹកនាំចេញដោយសេរី, សេសសល់បន្តិចបន្តួចអង្គការបញ្ជាឲ្យបំផ្លាញចោល ។ អង្គការធ្វើទារុណកម្មដល់រាស្ត្រខ្មែរគ្រប់បែបយ៉ាង គឺធ្វើដូចម្ដេចក៏ដោយឲ្យតែដល់ស្លាប់ រួចវាចាត់ក្រុមឃាតករអាថ៌កំបាំង ឲ្យចេញមកសម្លាប់ខ្មែរជាដំណាក់ៗ ។

មើលចុះ... បងប្អូនខ្មែរយើងដែលមិនទាន់ដល់វេនស្លាប់ កំពុងរួសនង្គ័លរនាស់ ហាលក្ដៅហាលភ្លៀង ស្ទើរឆ្កួតវង្វេង ឈប់ចេះនិយាយ ឈប់ចេះសើច, ឈប់ចេះយំ... ស្រាប់តែឮអង្គការបញ្ជាឲ្យដកអាវុធ ពីក្រុមខ្មែរក្រហមអតិតចោរអស់រលីង ។ ហើយស្រាប់តែនៅថ្ងៃទី២០ តុលា ១៩៧៨ ម៉ោងប្រហែលប្រាំបីយប់

មានក្រុមឃាតករអាថ៌កំបាំង ចូលមកវាយសម្លាប់ក្រុមខ្មែរក្រហមអតិតចោរនោះស្លាប់អស់រលីង ។ ស្រាប់តែឮថា ៖ មានក្រុមអាថ៌កំបាំងចេញមកព័ទ្ធបាញ់ខ្មែរក្រហមនិន្នាការខ្មែរ ឃើញតែខ្មោចដេកស្លាប់ពាសពេញព្រៃ ។ ស្រាប់តែឮថា ៖ អង្គការបញ្ជាឲ្យចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហម ដែលមាននិន្នាការខ្មែរ ដូចជាលោក ខៃក-ប៉ែន ហៅមិត្តស៊ូនិងប្រពន្ធ, លោក ជា-ហួន ហៅមិត្តវ៉ាញ, លោក ហ៊ូ-នឹមនិងប្រពន្ធ, លោកពេញ-ធួក ហៅវ៉ន-វ៉េតនិងប្រពន្ធ, កែវ-មាស, កុយ-ធួន ជាដើម... នាំទៅបញ្ចូលគុកទួលស្លែង ធ្វើទារុណកម្មជាច្រើនខែ រួចសម្លាប់ចោលនៅទីនោះអស់ទៅ ។

លុះសម្លាប់ខ្មែរក្រហមនិន្នាការខ្មែរជិតអស់ អ្នកនៅសល់រស់បន្តិចបន្តួច ក៏រត់របាត់របាយអស់ ។ ពេលនោះអង្គការចាត់តែងតាំងអតិតខ្មែរវៀតមិញក្រុមទី២ ឲ្យសម្លាប់បំបាត់ពូជខ្មែរតទៅទៀត ។ វាប្រើឃីហោខ្មែរក្រហមដដែល ប្រកាសតាំងក្រុមខ្លួនជាតំណាងអង្គការដដែល គឺ « ក្រុមខ្មែរក្រហមនីរតី » ។

នៅចុងខែធ្នូឆ្នាំ១៩៧៨ ស្រាប់តែឮថាអង្គការបញ្ជូន « យោធាស្រឡាញ់សម្តេចឪ » ចំនួនបួនម៉ឺននាក់ ឲ្យចូលចំអន្ទាក់ខ្សែត្រៀមរបស់បូដូយ ។ បូដូយបាញ់សម្លាប់ចោលខ្ទេចអស់ ។ល។ និង ។ល។

ដូច្នេះចុងខែធ្នូឆ្នាំ១៩៧៨ ប្រទេសកម្ពុជាចំហធ្លុង... ខ្មោចយោធាមិនកៀរកប់មិនទាន់ស្រេចបាច់ផង... នៅថ្ងៃទី២៥ ធ្នូ ១៩៧៨ ជាថ្ងៃបុណ្យណូអែល... យួនហាណូយបញ្ជាឲ្យបូដូយដើរចេញពីព្រៃ ចូលមកលុកលុយរាតត្បាតពាសពេញទីក្រុងខ្មែរ ។

ភារកិច្ចជាដំបូង វាបើកបរទ្បានដើរប្រមូលខ្មែរក្រហម ដែលមាននិន្នាការយួន ដែលជាអតិតខ្មែរវៀតមិញក្រុមទី១ នាំយកមកបំពាក់បុណ្យស័ក្តិឲ្យឡើងវិញ ។

ក្រុមទី១បំពាក់អាវុធឲ្យឡើងវិញ ។ ដើម្បីបង្វែងដាន, យួនហាណូយបានបញ្ជាឲ្យផ្លាស់ឈ្មោះបក្ស ឈ្មោះកងកម្លាំងខ្ទេចខ្ទីអស់...។ មានឧទាហរណ៍ដូចតទៅ ៖

★ <u>បក្សប្រជាជនបដិវត្តន៍</u> « អតិតខ្មែរវៀតមិញ» ដែលហូ-ជីមិញបញ្ជាឲ្យសឺងង៉ុកមិញ បង្កើតពីថ្ងៃ២៨ មិថុនា ១៩៥១ រួចចាត់តែងតាំងឲ្យធ្វើជាប្រធានក្នុងរបបហេង-សំរិន... យួនហាណូយបញ្ជាឲ្យប្រែឈ្មោះជា « បក្សប្រជាជនបដិវត្តន៍កម្ពុជា » រួចវាចាត់តាំងហេង-សំរិន ជាអគ្គលេខាធិការគណកម្មាធិការមជ្ឈឹមបក្ស ។ លោកហេង-សំរិននេះ កាលពីឆ្នាំ១៩៧០ដល់១៩៧៨ ជាវរសេនិយឯកដឹកនាំកងពលធំលេខ៦នៅភូមិភាគបូព៌ា ។ ក្នុងពេលអ៊ុនតាក់ចូលរៀបចំស្រុកខ្មែរ បក្សប្រជាជនបដិវត្តន៍កម្ពុជា ប្រែឈ្មោះជា « គណបក្សប្រជាជនកម្ពុជា » រួចចាត់តាំងមិត្តជាស៊ីម ជាប្រធាន ។

★ កងកម្លាំងប្រដាប់អាវុធឯកភាពរបស់កម្ពុជា « អតិតខ្មែរវៀតមិញក្រុមទី២ » ដែលហូ-ជីមិញបញ្ជាឲ្យសឺង-ង៉ុកមិញបង្កើតពីថ្ងៃទី១៩ ឧសភា ១៩៥១ រួចចាត់តាំងអាចារ្យសុខ ហៅមិត្តទូ-សាមុត ជាមេបញ្ជាការនោះ... បច្ចុប្បន្នប្រែឈ្មោះជា កងកម្លាំងប្រដាប់អាវុធប្រជាជនបដិវត្តន៍កម្ពុជា ( ក្នុងរបបអង្គការ កងកម្លាំងនេះប្រើឃើហៅខ្មែរក្រហមនិរតី ), រួចយួនហាណូយកែឆ្នៃឲ្យក្លាយទៅជាចោរ « ក្នុងរបបអង្គការ...ក្រុមនេះដើរស្មើ - ក្នុងរបបយួនហាណូយរាតត្បាតលុកលុយប្រទេសកម្ពុជា...ក្រុមនេះដើរប្លន់ » ។

ចោរប្លន់ក្នុងរបបយួនហាណូយលុកលុយប្រទេសកម្ពុជា សាហាវខ្លាំងណាស់ គឺសាហាវជាងសាហាវទៅទៀត ដោយវាចាប់ចងរាស្ត្រខ្មែរ រួចអារកបន្តិចម្តងៗរកមាសពេជ្រ... ទោះមានឲ្យក៏ស្លាប់ ទោះគ្មានឲ្យក៏ស្លាប់... គឺស្លាប់យ៉ាងសែនវេទនាជាទីបំផុត ។ « ខ្លួនខ្ញុំផ្ទាល់ដែលចាកចេញចោលមាតុភូមិកម្ពុជា គឺបណ្តាលមកពីក្រុមចោរ ជាកូនចៅយួនហាណូយចូលមកប្លន់វាយធ្វើបាប ចំនួនបួនលើកមកហើយ ។ល។ » ។

មើលចុះបងប្អូនខ្មែរយើងអើយ!... អង្គការក្តី យួនហាណូយក្តី វាចូលមកលុកលុយរាតត្បាតប្រទេសកម្ពុជា ។ វាលើកបន្តុបតែក្រុមខ្មែរជាអតិតខ្មែរវៀតមិញ រួចបញ្ជាឲ្យត្រួតត្រាប្រទេសខ្មែរតាមរបៀបចោរ ។ គួរឲ្យចម្លែកណាស់ៗ!... មើលចុះ! បើប្រជាពលរដ្ឋរបស់ប្រទេសនានាក្នុងពិភពលោកត្រូវរងគ្រោះស្លាប់... ទ្រព្យសម្បត្តិរបស់គេត្រូវវិនាសហិនហោចតែក្នុងពេលមានសង្គ្រាមប៉ុណ្ណោះ... ផ្ទុយទៅវិញនៅប្រទេសកម្ពុជា ប្រជាពលរដ្ឋខ្មែរត្រូវរត់ចោលស្រុក ត្រូវរងគ្រោះស្លាប់ជាច្រើនលាននាក់ ជាពិសេសអ្នកចេះដឹង ។

ចំណែកឯទ្រព្យសម្បត្តិ ឃើញតែចោរចូលមកប្លន់ដឹកនាំចេញ... នៅសេសសល់បន្តិចបន្តួច វាវាយបំផ្លាញចោលខ្ទេច... មិនមែនក្នុងពេលកំពុងធ្វើសង្គ្រាមទេ គឺនៅក្នុងពេលដែលអង្គការនិងយួនហាណូយទទួលជ័យជំនះមហាលោតផ្លោះទៅវិញ ។

ខ្ញុំជាខ្មែរដ៏ស្លូតត្រង់, ខ្ញុំជាម្ចាស់ទឹកដីកម្ពុជា, ខ្ញុំត្រូវទទួលទារុណកម្មផ្ទាល់ខ្លួន និងបានឃើញផ្ទាល់ភ្នែក នូវគ្រប់ៗឧបករណ៍ដ៏ចង្រៃឧបទ្រពមិនទំនងទាំងនោះ បៀមជាប់ជានិច្ចកប់យ៉ាងជ្រៅ ក្នុងបេះដូងនៃការឈឺចុកចាប់សោកសង្រេងពីការព្រាត់ប្រាស់គ្រួសារ, ពីការស្តាយទ្រព្យសម្បត្តិ, ពីការស្តាយមាតុភូមិជាទីស្នេហា... ដូច្នេះខ្ញុំឆ្ងល់សែនឆ្ងល់, ខ្ញុំចង់ដឹង, ខ្ញុំចង់ស្គាល់ថាតើអង្គការជានរណា ?

ដោយសារមូលហេតុនេះហើយ ទើបខ្ញុំខំស្រាវជ្រាវ, ខ្ញុំរកឃើញភស្តុតាងជាឧទាហរណ៍មិនខ្វះឡើយ ព្រមទាំងមានឯកសារខ្លះៗ បើកបង្ហាញឲ្យឃើញនូវមុខ

មាត់របស់អង្គការ ។

★★ មើលចុះ! ក្នុងរបបរបស់អង្គការ, ចិនបញ្ជូនក្រសួងសម្ងាត់ អ្នកជំនាញការយោធា អ្នកបច្ចេកទេស អ្នកឯកទេសចំនួន៤,៣៨១នាក់ ចូលមកកាន់ស្រុកខ្មែរ ដើម្បីឲ្យជួយធ្វើការអង្គការ ។ ឧទាហរណ៍អង្គការសម្លាប់វេជ្ជបណ្ឌិតជាតិខ្មែរ, សម្លាប់ប្រធានរោងចក្រជាតិខ្មែរ ...បែរជាបញ្ចេញចិនមកជំនួសទាំងអស់ ។ ម៉្យាងមួយវិញទៀត ចិននាំស្នៀតរបស់ម៉ៅ-សេទុង ដែលធ្វើទារុណកម្មប្រជាពលរដ្ឋចិនជំនាន់បដិវត្តន៍វប្បធម៌ (១៩៦៦-៦៨) យកមកឲ្យអង្គការអនុវត្តធ្វើទារុណកម្មលើខ្មែរ ។ ចិនបានបញ្ជូនឡានកាម៉្យុងពណ៌បៃតងចាស់ជាច្រើនគ្រឿង ចូលមកកាន់ប្រទេស ខ្មែរ រួចប្រមូលទ្រព្យសម្បត្តិខ្មែរដាក់ឡាននោះ ដឹកនាំយកទៅបញ្ចូលកប៉ាល់ធំៗ របស់វាដែលឈប់សំចតត្រៀបត្រានៅកំពង់ផែកំពង់សោម ។ គួរឲ្យចម្លែកណាស់ ទៅទៀតបងប្អូនខ្មែរគួរតែដឹង ! កាលណោះ លើកលែងតែកប៉ាល់ហោះរបស់ ចិនកប៉ាល់ហោះរបស់យួនហាណូយ អាចមកចុះចតឈប់ត្រៀបត្រា នៅចំណតអាកាសយានដ្ឋានពោធិចិនតុង យ៉ាងទៀតទាត់មិនដែលដាច់ ។ កប៉ាល់ចិនទី១ដឹកម្ហូបចំណីមកផ្តល់ឲ្យបុគ្គលិករបស់វា... កប៉ាល់ហោះទី២ ឆ្លៀតពេលនោះដឹកទ្រព្យសម្បត្តិខ្មែរទៅកាន់ប្រទេសរបស់វា ។ កប៉ាល់ហោះទី៣ ថ្ងៃសៅរ៍ថ្ងៃអាទិត្យ វាដឹកនាំបុគ្គលិករបស់វា ដែលកំពុងជួយធ្វើការឲ្យអង្គការនៅក្នុងស្រុកខ្មែរនោះ ដើរលេងលំហែកាយទៅប្រទេសនេះឬប្រទេសនោះយ៉ាងសប្បាយ ។

ចំណែកឯក្រុមខ្មែរអាយ៉ងយួន ដូចជាប៉ុល-ពត, ហេង-សំរិន, ហ៊ុន-សែន, ជា-ស៊ីមជាដើម វាគិតតែពីសម្លាប់... វាគិតតែពីកំទេចបងប្អូនជាតិខ្មែររបស់ខ្លួន ឲ្យរត់ចោលស្រុក ទុកទឹកដីឲ្យចៅហ្វាយរបស់វា ។ល។

ក្រឡេកមើលលោកខៀវ-សំផន, លោកសឺន-សេនវិញ ជាមនុស្សចោលម្សៀតគ្មានសមត្ថភាពអ្វីទាំងអស់...។ មើលចុះ! សូម្បីតែអង្គការបញ្ជាឲ្យចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមបក្សរបស់លោក, ចាប់គណរដ្ឋមន្ត្រី, សហការីរបស់លោកសឹងទាំងអស់បញ្ជូនកគុកទួលស្លែង... អង្គការបញ្ជាឲ្យធ្វើទារុណកម្មយ៉ាងធ្ងន់ រួចទើបសម្លាប់ចោល... លោកទាំងពីរនាក់ដូចជាសោះអង្កើយគ្មានយល់ គ្មានដឹងអ្វីទាំងអស់ ។ល។ និង ។ល។

❑ ❑

❑

# ជំពូកទី១

★ ហេតុដូចម្តេចបានជាបារាំងចូលឧបត្ថម្ភការពារខ្មែរ ?
★ យួនវាតទីយកនគរចាម !
★ យួនវាតទីយកទឹកដីកម្ពុជាក្រោម !
★ ប្រយ័ត្នកំពប់តែអុង !

## ហេតុដូចម្តេចបានជាបារាំងចូលឧបត្ថម្ភការពារខ្មែរ?

ការដែលយើងលើកយករឿងពីអតិតកាលដ៏ឈឺចុកចាប់ជូរចត់ខ្លះៗ មកពណ៌-នារលឹកត្រួសៗ គឺដើម្បីបំភ្លឺការវិវត្តន៍នៃប្រវត្តិសាស្ត្រប្រទេសកម្ពុជាយើង ដើម្បីគ្រាន់ជាពន្លឺដល់សតិសម្បជញ្ញៈបងប្អូនខ្មែររួមឈាមគ្រប់ៗរូប ដើម្បីរំលឹកបង្ហាញនូវមេរៀនខ្លះៗដែលប្រវត្តិសាស្ត្របានធ្លាប់ស្គាល់ ព្រមទាំងមានការពិសោធន៍ជាច្រើនលើករួចមកហើយ ។ ឧទាហរណ៍ដែលមានលក្ខណៈត្រឹមត្រូវនោះ មិនខ្វះឡើយ ។

យួនហាណូយជាឃាតករសម្លាប់បំបាត់ពូជខ្មែរ, ជាសត្រូវស្ទួរពូជនៃប្រជាជនខ្មែរ មិនមែនតែបច្ចុប្បន្ននេះទេ គឺតាំងពី៣០០ឆ្នាំម៉្លេះ ។ យួនហាណូយមានដើមកំណើតនៅតុងកឹង ក្នុងសតវត្សទី១០ ។ ទីក្រុងធំគឺហាណូយ ។ បារាំងហៅជាតិយួនជំនាន់នោះថា ៖ តុងគីន័រ ( Tonkinois ) ។ របររកស៊ីរបស់យួនតុងកឹង គឺដើរឈ្លានពានប្រទេសជិតខាង... ធ្វើចោរប្លន់ទ្រព្យសម្បត្តិរបស់គេមកចិញ្ចឹមជីវិត និងវាតទីពង្រីកទឹកដីរបស់ខ្លួន...។

មើលចុះ! ក្នុងសតវត្សទី១៤ យួនឈ្លានពានចូលមកតាំងទីលំនៅក្នុងខេត្តខាងជើងនៃនគរចំប៉ា គឺក្នុងខេត្តក្វាងបិញ, ក្វាងទ្រី និងទូរ៉េន សព្វថ្ងៃហៅដាណាង ។ ពីសតវត្សទី១៥ដល់ទី១៧ យួនតុងកឹងចូលរាតត្បាតយ៉ាងព្រៃផ្សៃក្នុងប្រទេសចាម សម្លាប់បំបាត់ពូជចាម ដូច្នេះនគរចំប៉ាទាំងមូល ត្រូវយួនវាតទីលេបយកទាំងអស់ពីជើងរហូតដល់ត្បូង ។ នគរចំប៉ាក៏ត្រូវរលាយបាត់ឈ្មោះពីផែនទីពិភពលោកក្នុងឆ្នាំ១៦៩៦ ។

យួនតុងកឹងប្រែឈ្មោះនគរចំប៉ានេះជា «អណ្ណាម» ដែលមានរាជធានីឈ្មោះ «ហ្វេ» ។

យួនតុងកឹងវាតទីចូលលុកលុយនគរចំប៉ា មិនទាន់បានរៀបចំទីលំនៅបានស្រួលបួលផង...វាចាប់ផ្ដើមរុលសំរុកវាតទីចូលមកទឹកដីកម្ពុជាក្រោមជាបន្តៗ ពីព្រោះវាដឹងថា ជាដីទំនាបប្រកបដោយជីរជាតិគ្រប់បែបយ៉ាង សម្បូរណ៍ដោយធនធានកសិកម្ម ស្រូវ ត្រី និងបន្លែគ្រប់មុខ ជាតំបន់កំពង់ផែសមុទ្រ...។

នៅចុងសតវត្សទី១៧ ប្រជាជនខ្មែរកម្ពុជាក្រោមមានតែបួនម៉ឺនគ្រួសារទេ គឺប្រហែលជា២សែននាក់ប៉ុណ្ណោះ រស់នៅលើផ្ទៃដីទំហំ៦៧,៧០០គីឡូម៉ែត្រក្រឡា ។

នៅឆ្នាំ១៦៥១ ស្ដេចខ្មែរឈ្លោះគ្នាពីរឿងដណ្ដើមបល្ល័ង្ករាជ្យ ។ ស្ដេចខ្មែរដ៏ឆ្កួតម្នាងនោះ ក៏រត់ទៅសុំជំនួយពីស្ដេចយួនឈ្មោះ ង្វៀង-វូង ។ ស្ដេចយួននេះក៏ឆ្លៀតឱកាសវាយកំទេចស្ដេចខ្មែរ ឈ្លានពានរំលោភចូលមកតាំងទីលំនៅ ក្នុងអាណាខេត្តប៉ែកខាងកើតនៃទឹកដីកម្ពុជាក្រោម ក្នុងខេត្តព្រះសួគ៌ា និងខេត្តព្រះចង្វា ។

ក្នុងឆ្នាំ១៦៩៦ អាណាខេត្តព្រៃនគរត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃយួនទៀត ។ លុះមកដល់ដើមសតវត្សទី១៨ យួនតុងកឹងវាតទីមកដល់ទន្លេមេគង្គ រួចរុលសំរុកយកខេត្តពាម និងខេត្តក្រមួនស ។ ក្នុងឆ្នាំ១៧៣១ វារុលសំរុកយកខេត្តមេ-ស និងខេត្តឡុងហោ ។ ក្នុងឆ្នាំ១៧៥៧ វាវាតទីយកខេត្តផ្សារដែក និងខេត្តមាត់ជ្រូក ។ ដូច្នេះអាណាខេត្តក្នុងកម្ពុជាក្រោមទាំងមូល ត្រូវរបេះម្ដងមួយៗធ្លាក់ទៅក្នុងកណ្ដាប់ដៃយួនជាបន្តបន្ទាប់លុះត្រាតែជិតអស់ក្នុងឆ្នាំ១៧៦៥...។ នៅសល់ខេត្តព្រះត្រពាំង, ខេត្តទ្រាំង និងខេត្តជ្រោយទឹកខ្មៅ ។ ជិត១០០ឆ្នាំក្រោយមក ខេត្តទាំងបីនេះក៏ធ្លាក់ក្នុងកណ្ដាប់ដៃយួនដាច់ស្រេចនៅឆ្នាំ១៨៤០ ។

ក្នុងរយៈសង្គ្រាមយួនរាតត្បាតលុកលុយវាតទីកម្ពុជាក្រោមនេះ យួនធ្វើទារុកម្មខ្មែរកម្ពុជាក្រោមសាហាវជាងសាហាវ ដូចជាកាលពីឆ្នាំ១៨១៥ដល់១៨២០ យួនកេណ្ឌខ្មែរកម្ពុជាក្រោមប្រមូលនាំយកទៅបង្ខំឲ្យធ្វើការយ៉ាងធ្ងន់ ទាំងថ្ងៃទាំងយប់ទាំងក្ដៅទាំងភ្លៀង ឲ្យជីកព្រែកមួយមានបណ្ដោយ៥៣គ.ម. ទទឹង៣០ម៉ែត្រ ជំរៅ ២.៦០ម៉ែត្រ ចាប់ពីខេត្តមាត់ជ្រូកចេញទៅកាន់មាត់សមុទ្រខាងជើងទីក្រុងពាម ដើម្បីធ្វើជាខណ្ឌព្រំសីមាបែងចែករវាងកម្ពុជាកណ្ដាលនិងកម្ពុជាក្រោម ។

ព្រែកជីកនោះឈ្មោះ « ព្រែកវិញតេ » ។ ពេលកំពុងជីកព្រែកនោះ បើមានខ្មែរណាធ្វើការលែងកើត យួនចាប់ខ្មែរអភ័ព្វទាំងនោះ ម្ដង៣នាក់ឲ្យជីករណ្ដៅខ្លួនឯង រួចចុះអង្គុយក្នុងរណ្ដៅកប់ខ្លួនបន្សល់តែក្បាល ធ្វើជាមុមជើងក្រានសំរាប់ដាំតែឲ្យអុង ។ ភ្លើងនេះក្ដៅខ្លាំងណាស់ បណ្ដាលឲ្យខ្មែររងគ្រោះខំរើបំរះរេក្បាលធ្វើឲ្យកំពប់តែ ។ ដូច្នេះទើបមានពាក្យមួយឃ្លាជាអនុស្សាវរីយ៍ដ៏ជូរចត់ រហូតទល់សព្វ

ថ្ងៃនេះថា ៖ « ចូរកុំភ្លេច... ប្រយ័ត្នកំពុបតែអុង ! » ។

ចុងឆ្នាំ១៨២០ ពេលជីកព្រែកវិញតេ្សច យួនក៏ដាក់ខ្នោះជើងខ្មែរជាអ្នកជីកព្រែកទាំងអស់ស្ថិតនៅកណ្ដាលព្រែក ដែលមានជំរៅ២.៦០ម៉ែត្រ រួចវាទម្លាយទំនប់ទឹកសមុទ្រឲ្យហូរចូលព្រែកវិញតែនោះ ។ អនិច្ចាបងប្អូនខ្មែរយើងដែលជាប់ចំណងត្រូវលង់ទឹកស្លាប់ទាំងអស់ ។ល។ និង ។ល។ យួនវាតទីយកនគរចំប៉ាក្ដី យកកម្ពុជាក្រោមក្ដី ...វាវាតទៅដល់ខេត្តណា ទីកន្លែងណា វាក៏ប្រែឈ្មោះជាយួនភ្លាមដែរ ។

ហេតុដែលបណ្ដាលឲ្យយួនវាតទីលេបកម្ពុជាក្រោមបានដោយងាយយ៉ាងនេះមកពី ៖

ទី១- រាស្ត្រខ្មែរកម្ពុជាក្រោមមានការធ្វេសប្រហែស ពីព្រោះខ្មែរស្លូតត្រង់ ទន់ភ្លន់ សុភាព មានចិត្តសប្បុរស មានមេត្តាធម៌ ធ្វើបុណ្យដាក់ទាន... មានពេលខ្លះឃើញយួនក្ររហេមរហាម ដើរសុំទានគ្មានទីលំនៅ ខ្មែរតែងតែដាក់ទាន ជួយទំនុកបំរុងឧបត្ថម្ភឲ្យសង់ខ្ទមនៅក្បែរៗខ្លួន ។ ផ្ទុយទៅវិញសាសន៍យួននេះ ជាសាសន៍អកត្តញ្ញូ, កំណាច, ថោកទាប, ក្រឡិចក្រឡុច, ឡូឡា ជាចោរលួចតាំងពីជី ស្លឹកគ្រៃ ម្ទេសជាដើម... ញ៉ាំងឲ្យខ្មែរធុញទ្រាន់ក៏នាំគ្រួសារថយចាកចេញបោះបង់ចោលកន្លែងនោះ ទៅកាន់ទីកន្លែងផ្សេងវិញ ព្រោះទឹកដីនៅទូលំទូលាយ ។

ទី២- កំហុសដ៏ធ្ងន់ជាងគេ គឺស្ដេចកើតវិវាទច្បាំងគ្នាដណ្ដើមរាជបល្ល័ង្ក ។ ស្ដេចឯណោះរត់ទៅពឹងយួន ស្ដេចឯណោះរត់ទៅពឹងសៀម ។ កាលណោះប្រទេសកម្ពុជាយើងមានលក្ខណៈដូចជាដែកទ្រនាប់តូចមួយ តើអាចទ្រទ្រង់ទប់ទល់នឹងញញួរធំៗដល់ទៅ២ដែរឬទេ ? ពីព្រោះម្ខាងជាយួន ! ម្ខាងទៀតជាសៀម ! ។

ពីព្រោះតែមូលហេតុនេះហើយ បានជាក្នុងរជ្ជកាលស្ដេចអង្គដួង ពីឆ្នាំ១៨៤៥ ដល់១៨៥៩ ពេលព្រះអង្គឡើងសោយរាជ្យ ទ្រង់ឈ្វេងយល់ថា ដល់ពេលផុតពីព្រះអង្គទៅ ប្រទេសកម្ពុជាមុខជាត្រូវរងគ្រោះដោយសារយួននិងសៀម ពុះដីខ្មែរចែកគ្នាមិនខាន ។

កាលណោះ ដោយសារសម្ដេចមីស ( Miche ) ជាមេគណៈនៃសាសនាកាតូលិក ជាអ្នកជួយខ្នះខ្នែងនិងឧបត្ថម្ភ... ព្រះបាទអង្គដួងក៏សំរេចស្នើសុំដោយសម្ងាត់ឲ្យប្រទេសបារាំងជួយទំនុកបំរុងការពារ ។

ក្នុងខែវិច្ឆិកា១៨៥៣ ព្រះអង្គបានបញ្ជូនអ្នកមានបណ្ដាស័ក្ដិខាងសាសនាកាតូ-លិក២នាក់គឺ លោកកុយ-ដឺម៉ុងតេរ៉ូ និងលោកប៉ែន ធ្វើដំណើរទៅជួបកុងស៊ុលបារាំងប្រចាំក្រុងសឹង្ហបូរី សុំជួយបញ្ជូនសារលិខិតរបស់ព្រះអង្គ ជាភាសាបារាំងសរ-សេរដោយសម្ដេចមីស ទៅថ្វាយស្ដេចណាប៉ូឡេអុងទី៣នៃប្រទេសបារាំង ។

អស់រយៈពេលពីរឆ្នាំ គឺរហូតដល់ឆ្នាំ១៨៥៥ ទើបព្រះចៅណាប៉ូឡេអុងទី៣ចាត់លោក ដឺម៉ុងទីញី ដែលជារដ្ឋមន្ត្រីទទួលបេសកកម្មនៅប្រទេសសៀមនិងប្រទេសចិន ឲ្យរៀបចាត់ចែងធ្វើសន្ធិសញ្ញាសម្ព័ន្ធភាពនិងពាណិជ្ជកម្មជាមួយព្រះអង្គដួង ។ ព្រះបាទនរោត្តម ដែលជាព្រះរាជបុត្ររបស់ព្រះអង្គដួង យាងចេញមកពីបាងកករួចឡើងសោយរាជ្យបន្តក្នុងឆ្នាំ១៨៥៩ ។

ថ្ងៃទី១១សីហា១៨៦៣ ក៏មានការចុះហត្ថលេខាព្រមព្រៀងគ្នារវាងបារាំងនិងខ្មែរ « អនុញ្ញាតឲ្យបារាំងចូលមកជួយការពារឧបត្ថម្ភទំនុកបំរុង » ។ បន្ទាប់ពីពេលនោះមក... របៀបរៀបចំស្រុកទេសតាមបែបសម័យទំនើប បានត្រូវព្រះបាទនរោ-ត្តម ទទួលយកមកអនុវត្តទាំងស្រុង ។

ដូច្នេះ ចាប់តាំងពីបារាំងចូលមកជួយការពារឧបត្ថម្ភទំនុកបំរុង ពីឆ្នាំ១៨៦៣ដល់ឆ្នាំ១៩៥៣ ក្នុងរយៈពេល៩០ឆ្នាំ នាំមកឲ្យប្រជាពលរដ្ឋខ្មែរនិងប្រទេសកម្ពុជានូវសណ្តាប់ធ្នាប់ របៀបរៀបរយ សំបូរសប្បាយ រុងរឿង និងសន្តិភាព « គឺដូចជាប្រាំងទិព្វមួយ ទប់ឃ្មួននិងសៀម ផ្អាករាតត្បាតលុកលុយប្រទេសខ្មែរ » ។

ការរួមរស់ជាមួយគ្នា រវាងបារាំងនិងខ្មែរ ក្នុងរយៈពេល៩០ឆ្នាំនេះ មិនមានឧ-ប្បត្តិហេតុអ្វីកើតឡើងជាធំដុំទេ ។ ក្នុងប្រវត្តិសាស្ត្រ គេអាចកក់ត្រាជាប់ជានិច្ចថាជាមិត្តដ៏ល្អទៅវិញទៅមក ។

❑ ❑
❑

# ជំពូកទី២

★ យួនចាប់ផ្ដើមរុករានប្រទេសជិតខាង !
★ ហូ-ជីមិញបង្កើតបក្សកុម្មុយនិស្តឥណ្ឌូចិន !
★ យួនបង្កើតពួកវៀតមិញ និងបង្កើតខ្មែរវៀតមិញ !
★ សន្ធិសិទហ្សឺណែវបញ្ចប់សង្គ្រាមឥណ្ឌូចិន !
★ យួនចង់ពុះប្រទេសខ្មែរជាពីរចំណែក !
★ យួនហាណូយបង្កើតវៀតកុង !

## យួនចាប់ផ្ដើមវាយលុកប្រទេសជិតខាង

បារាំងគ្រប់គ្រងឥណ្ឌូចិន ដូចជាប្រាំងទិព្វទប់យួន មិនឲ្យដើរឈ្លានពានប្រទេសជិតខាងអស់រយៈពេល៦៥ឆ្នាំ ។

ស្រាប់តែនៅឆ្នាំ១៩២៥... មានយួនម្នាក់ឈ្មោះ ង្វៀង-អាយគួក ប្រែឈ្មោះជា ហូ-ជីមិញ ចាប់ផ្ដើមបង្កើត «បដិវត្តន៍វៀតណាម» ។ លុះដល់ឆ្នាំ១៩២៩, ហូ-ជីមិញក៏ឆ្លៃប្រឌិតឲ្យទៅជា « បក្សកុម្មុយនិស្តវៀតណាម » ។

ហូ-ជីមិញដុះគំនិតលោភលន់ ចង់វាទទីយកទឹកដីកម្ពុជាក្រោម, កម្ពុជាកណ្ដាល និងលាវ ។ គឺដោយសារមូលហេតុនេះហើយ ទើបវាបង្កើត « បក្សកុម្មុយនិស្តឥណ្ឌូចិន » នៅថ្ងៃទី៣ កុម្ភៈ ឆ្នាំ១៩៣០ ។

ដើម្បីសំរាលបន្ទុករបស់វា វាត្រូវតែញុះញង់ឲ្យខ្មែរបែកបាក់គ្នា រួចហើយខ្ចីដៃខ្មែរច្បាំងជាមួយខ្មែរ ។

ដូច្នេះ ក្នុងឆ្នាំ១៩៣៥... ហូ-ជីមិញសុំជួបលោកសឺង-ង៉ុកថាញ់ ។ វានិយាយទន់ភ្លន់បបួលលោក, សុំលោករួបរួមធ្វើការជាមួយយួន ដើម្បីបង្កើតចលនាតស៊ូរំដោះឥណ្ឌូចិនពីនឹមបារាំង ។ លោកសឺង-ង៉ុកថាញ់ជាខ្មែរក្រោម, លោកស្គាល់ច្បាស់នូវកលល្បិចក្រទ្បិចក្រឡុចកក្រខ្វក់របស់យួន ដែលតែងតែមានជាបញ្ញោស់ជា

បណ្តោយ....។ ពេលនោះលោកឆ្លើយយ៉ាងខ្លីថា រឿងយួនត្រូវយួនដោះស្រាយដោយខ្លួនឯងចុះ... ចំណែករឿងខ្មែរត្រូវទុកឲ្យខ្មែរដោះស្រាយដោយខ្លួនឯង...។

នៅថ្ងៃទី៩ មិនា ឆ្នាំ១៩៤៥, ជប៉ុនចូលលុកលុយឧបទ្វីបឥណ្ឌូចិនមួយរយៈ ។ ហូ-ជីមិញឆ្លៀតយកឱកាសដ៏ល្អនេះ ប្រកាសវៀតណាមឯករាជ្យនៅខែកញ្ញា ឆ្នាំ១៩៤៥... រួចបង្កើត « រណសិរ្សវៀតណាមឯករាជ្យសម្ព័ន្ធភាព » ហៅកាត់ថា « វៀតមិញ » ។

ហូ-ជីមិញចាប់ផ្តើមបញ្ចេញសកម្មភាពជាលំដាប់លំដោយ គោលបំណងទី១ មានរៀបចំគ្រោងការណ៍ទុកជាស្រេច ។ បើពេលណាបារាំងត្រូវចាញ់ ត្រូវថយចេញពីឥណ្ឌូចិន យួនត្រូវតែវាតទីយកទឹកដីកម្ពុជាក្រោមឲ្យបានភ្លាមជាលើកទី២...។

ដូច្នេះចាប់ពីឆ្នាំ១៩៤៥, យួនហាណូយញុះញង់ខ្ចីដៃយួនខាងត្បូង ឲ្យលោតសម្លាប់កំចាយរាស្ត្រខ្មែរកម្ពុជាក្រោម ជាពិសេសពួកអ្នកចេះដឹង ញ៉ាំងឲ្យខ្លាច ក៏នាំគ្រួសាររត់ចោលស្រុកចោលទឹកដីទុកឲ្យវា ។ វាប្រើសង្គ្រាមក្តៅ ។ ហូ-ជីមិញលៃលកឈានមួយជំហានម្តងៗ កំទេចខ្មែរមួយផ្នែកម្តងៗ តាមគំរោងការណ៍របស់វាដែលមានព្រាងទុកមកជាស្រេច ។

មើលចុះ ! នៅប្រទេសកម្ពុជាកណ្តាល យួនចាត់ការប្រើសង្គ្រាមត្រជាក់... ដូច្នេះក្នុងខែកញ្ញាឆ្នាំ១៩៤៥ដដែល ហូ-ជីមិញបែរជាបញ្ជូន «បូដូយ» ចូលមកកាន់ប្រទេសកម្ពុជា ដោយយកលេសថា យួនស្ម័គ្រចិត្តចូលមកជួយខ្មែរដេញបារាំង ។ បូដូយចាប់តាំងមូលដ្ឋាននៅខេត្តនានាដូចជា មណ្ឌលគិរី, រតនគិរី, កោះកុង, សៀម-រាប, បាត់ដំបង និងតំបន់និរតីទិស ។ កាលណោះបូដូយស្ថិតនៅក្នុងព្រៃជ្រៅ វាចាប់ផ្តើមទាក់ទងក្រុមចោរព្រៃ, ទាក់ទងរាស្ត្រខ្មែរក្រៗនៅតាមជនបទ និងទីប្រជុំជនព្រៃភ្នំឆ្ងាយដាច់ស្រយាល ។ វានិយាយទន់ភ្លន់ផ្អែមល្ហែម ។ វាខំឃោសនាកុ-ហកថា បូដូយស្ម័គ្រចិត្តចូលមកស្លាប់ជាមួយខ្មែរ ដើម្បីវាយដេញបារាំង ។

វាលៃធ្វើការស្រួបៗជាមួយក្រុមខ្មែរឥស្សរៈ ដែលកំពុងប្រឆាំងតទល់ចំពោះបារាំង ដើម្បីទាមទារឯករាជ្យជូនប្រទេសកម្ពុជា ។

ឆ្លៀតពេលនោះវាបញ្ជូនចារកិច្ចរបស់វាគ្រប់ធុនចូលកាន់ប្រទេសកម្ពុជា ។ ក្រុមចារកិច្ចនោះខំរៀនសូត្រ ឲ្យស្គាល់គ្រប់ជ្រុងជ្រោយភូមិយុទ្ធសាស្ត្រ ។ ស្គាល់ច្បាស់ផែនទីព្រៃព្រឹក្សាក្នុងប្រទេសខ្មែរ ។ ផ្នែកចិត្តសាស្ត្រ វាខំរៀនសូត្រឲ្យស្គាល់ចរិតចិត្តគំនិត និងចំណុចខ្សោយរបស់ប្រជាពលរដ្ឋខ្មែរ ចាប់តាំងពីអ្នកស្រុកព្រៃភ្នំ អ្នកស្រែចំការជនបទ មេទាហាន នាម៉ឺនខ្មែរ រហូតដល់នាម៉ឺនក្នុងវាំង ។ល។ វាខំដិកស្រង់ការពិសោធន៍នានា ។ វាតាំងខ្លួនល្អណាស់ សូម្បីតែជីស្លឹកគ្រៃ ម្ទេសរបស់ខ្មែរ ក៏វាមិនប៉ះពាល់ឡើយ ។

នៅពេលនោះហូ-ជីមិញឆ្លៀតឆ្លារកមេដឹកនាំខ្មែរ ស្រាប់តែវាដឹងថា នៅថ្ងៃទី១៦/១០/៤៥ បារាំងចាប់ខ្លួនលោកសឺង-ង៉ុកថាញ់ នាំយកទៅដាក់គុកនៅខែត្រព័រទ្បេរ (Poitier) ស្រុកបារាំង ។ ហូ-ជីមិញក៏សំរាំងជ្រើសរើសបានយួនម្នាក់ឈ្មោះ ង្វៀង វ៉ាន់មៀន ហៅអាចារ្យមៀន ដែលបួសជាលោកសង្ឃខ្មែរ បានរៀនសូត្ររបៀបរបប ទំនៀមទំលាប់ខ្មែរយ៉ាងជ្រៅជ្រះ អាចលួចបន្លំធ្វើជាខ្មែរ ។ ដូច្នេះហូ-ជីមិញសំរេចដាក់ឈ្មោះយួននោះថា « សឺង-ង៉ុកមិញ » រួចផ្សាយភរបន្ថែមថា ជាប្អូនប្រុសបង្កើតរបស់លោកសឺង-ង៉ុកថាញ់ ។

នៅខែមេសាឆ្នាំ១៩៥០ ហូ-ជីមិញចាត់បញ្ជូនឲ្យអាចារ្យមៀន ប្រែឈ្មោះជាសឺង-ង៉ុកមិញ ។ វាចាត់តែងតាំងជាស្រេចជាប្រធានរដ្ឋាភិបាលខ្មែរតស៊ូ ទទួលបន្ទុកជានាយករដ្ឋមន្ត្រី » ឲ្យចូលកាន់ប្រទេសខ្មែរ ចាប់ដៃរួបរួមជាមួយអាចារ្យសុខ ប្រែឈ្មោះជាទូ-សាមុត ( ដែលហូ-ជីមិញចាត់តែងតាំងជាប្រធានរណៈសិរ្សជាតិឯកភាពរួចហើយ ) ។ ដូច្នេះសឺង-ង៉ុកមិញនិងទូ-សាមុតចាប់ផ្ដើមអនុវត្តឃ្លោងឃ្លា « បំបែកបំបាក់ដើម្បីគ្រប់គ្រង» ។ វាចាប់ផ្ដើមញុះញង់ពន្យល់ក្រុមចោរព្រៃ, រាស្ត្រខ្មែរដែលក្រលូងនៅតាមជនបទ, ប្រជាជនព្រៃភ្នំដាច់ស្រយាល តាមចំណុចខ្សោយនានា ជាពិសេសវាវែកញែកនូវរឿងវណ្ណៈ ញ៉ាំងឲ្យងាកចេញពីក្រុមខ្មែរឥស្សរៈ, ឲ្យងាកឈប់គោរពរដ្ឋាភិបាលរបស់ខ្លួន ។ ជំរុញឲ្យខ្មែរបែកបាក់គ្នា រួចបង្កបង្កើតជាសង្គ្រាមធ្វើឲ្យខ្មែរច្បាំងគ្នា ។ ម៉្យាងវិញទៀត ខ្មែរផុននោះយល់ច្រឡំយ៉ាងធ្ងន់ថាសឺង-ង៉ុកមិញជាប្អូនបង្កើតរបស់លោកសឺង-ង៉ុកថាញ់... ប្រសើរណាស់ៗ ! ។

លុះហូ-ជីមិញទទួលសេចក្ដីរាយការណ៍ពីសឺង-ង៉ុកមិញដឹងថា រាស្ត្រខ្មែរថ្លាក់ទាបធ្លាក់ចូលក្នុងអន្ទាក់របស់វាហើយ ហូ-ជីមិញក៏ចាប់បើកអង្គប្រជុំបក្សកុម្មុយនិស្តឥណ្ឌូចិនជាលើកទី២ ចាប់តាំងពីថ្ងៃទី១១/២/៥១ ដល់ថ្ងៃទី១៩/២/៥១ ។ ទីបញ្ចប់ក៏បំបែកបក្សកុម្មុយនិស្តឥណ្ឌូចិនជាបក្សសាខាបីគឺ ៖ យួន, ខ្មែរ, លាវដាច់ៗពីគ្នា ។

- ខាងយួន, អង្គប្រជុំសំរេចដាក់ឈ្មោះភ្លាមគឺ « បក្សពលករវៀតណាម » ដែលក្លាយមកជា «បក្សកុម្មុយនិស្តវៀតណាម» ក្នុងបច្ចុប្បន្ននេះ ។

★ ចំណែកខាងខ្មែរ វាបង្កើត ៖

ក)- កងកម្លាំងប្រដាប់អាវុធបដិវត្តន៍ឯកភាពរបស់កម្ពុជា ដែលចាប់បដិសន្ធិឡើងកាលពីថ្ងៃទី១៩/៦/៥១ ដែលហូ-ជីមិញចាត់តាំងទូ-សាមុតជាមេបញ្ជាការ ។ ឆ្នាំ១៩៦៣ ទូ-សាមុតត្រូវគេសម្លាប់... ហូ-ជីមិញចាត់តាំងសាឡុត-សរ ឬប៉ុល-ពតយ៉ាងសម្ងាត់បំផុត ឲ្យឡើងធ្វើជាមេទ័ពជំនួស ។

ចាប់ពីឆ្នាំ១៩៧០ដល់១៩៧៥ កងទ័ពនេះប្រែឈ្មោះថា « កងកម្លាំងប្រដាប់អាវុធស្នេហាជាតិកម្ពុជា » ដែលមានអនុប្រធានមេបញ្ជាការជាន់ខ្ពស់ គឺប្រពន្ធរបស់

ប៉ុល-ពតឈ្មោះ ខៀវ-ប៉ុណ្ណារី ។ ក្នុងរបបរបស់អង្គការ កងកម្លាំងនេះបន្តប្រើឈ្មោះហៅខ្មែរក្រហម « ក្រុមនិរតី » ។ ក្នុងរបបខ្មែរអាយ៉ងយួន... ក្រុមហេងសំរិន-ហ៊ុនសែនប្រែឈ្មោះជា «កងកម្លាំងប្រដាប់អាវុធបដិវត្តន៍កម្ពុជា» ។

ខ)- « បក្សប្រជាជនបដិវត្តន៍ខ្មែរ » ចាប់បដិសន្ធិឡើងនៅថ្ងៃទី២៨/៦/៥១ ដែកហូ-ជីមិញចាត់តាំងសឺង-ង៉ុកមិញជាប្រធាន ។

ក្នុងរបបរបស់អង្គការ ពីឆ្នាំ១៩៧៦ដល់ឆ្នាំ១៩៧៨ អង្គការចាត់តែងតាំងសមាជិករបស់បក្សនេះ ឲ្យធ្វើជាប្រធានសហករណ៍, ជាគណៈតំបន់, ជាតំណាងរាស្ត្រ ។ កាលណោះខ្មែរស្គាល់ត្រឹមតែគណៈតំបន់ប៉ុណ្ណោះ ។ លុះមកដល់របបខ្មែរអាយ៉ងយួន... បក្សប្រជាជនបដិវត្តន៍ខ្មែរ ប្រែឈ្មោះជា « បក្សប្រជាជនបដិវត្តន៍កម្ពុជា »។ យួនហាណូយចាត់តាំងហេង-សំរិន ជាអគ្គលេខាគណកម្មាធិការមជ្ឈិមបក្ស ។ ចំណែកឯមិត្តៗដូចជា ហ៊ុន-សែន, ជា-ស៊ីម, ជា-សុទ្ធ ជាដើម... យួនហាណូយចាត់តែងតាំងជាសមាជិកការិយាល័យនយោបាយមជ្ឈិមបក្ស ។ បច្ចុប្បន្ននេះ « បក្សប្រជាជនបដិវត្តន៍កម្ពុជា » ប្រែឈ្មោះថា « បក្សប្រជាជនកម្ពុជា » ដែលមានជា-ស៊ីមជាប្រធាន ។

នេះជាប្រវត្តិខ្មែរអាយ៉ងយួន ដែលខ្មែរយើងតែងតែហៅថា « ខ្មែរវៀតមិញ » តាំងពីខែមិថុនា១៩៥១នោះមក ។

នៅថ្ងៃទី២២/៣/៥៥ ទើបបក្សប្រជាជនបដិវត្តន៍លាវកើតឡើង ។ ទោះបីបង្កើតបក្សសាខាបីដាច់ដោយឡែកពីគ្នាយ៉ាងនេះក៏ដោយ ក៏នៅតែមានប្រភពរួមតែមួយ គឺបក្សកុម្មុយនិស្តឥណ្ឌូចិនដដែល ។ មានន័យថា ៖ បក្សខ្មែរ លាវ ត្រូវតែគោរពធ្វើតាមបញ្ជារបស់ហូ-ជីមិញដដែល ។ ដំណាក់ការជាដំបូងរបស់បក្សសាខាទាំងបីគឺត្រូវតែកំទេចសក្តិភូមិ និងចក្រពត្តិ ។ ក្នុងខែមិនាឆ្នាំ១៩៥២ ហូ-ជីមិញដឹងថាលោកសឺង-ង៉ុកថាញ់វិលត្រឡប់មកពីប្រទេសបារាំងវិញហើយ រួចលោករត់ចូលព្រៃចាប់ដៃរួបរួមជាមួយក្រុមខ្មែរឥស្សរៈ ដើម្បីកំទេចដេញបារាំងតទៅទៀត ។

ហូ-ជីមិញឆ្លៀតចាត់ចែងបញ្ជូនតំណាងបួននាក់ គឺខ្មែរ២នាក់ យួន២នាក់ ទៅកាន់ភូមិអូរស្មាច់ សុំជួបលោកសឺង-ង៉ុកថាញ់ ។

លោកសឺង-ង៉ុកថាញ់អនុញ្ញាតឲ្យតែខ្មែរ២នាក់ចូលជួបជាមួយលោក ។ ពេលនោះខ្មែរតំណាងរបស់ហូ-ជីមិញ ស្នើរសុំតាមសំណើរបស់ហូ-ជីមិញដូចតទៅ ៖

ខ១- សុំបញ្ជូនបូដូយបន្ថែមចូលកាន់ស្រុកខ្មែរ ដើម្បីជួយច្បាំងដេញបារាំងឲ្យចេញពីស្រុកខ្មែរ ។

ខ២- សុំឲ្យខ្មែរជួយផ្តល់ស្បៀងអាហារ ដល់បូដូយនៅស្រុកយួន ។

ខ៣- សុំសិទ្ធិឲ្យបូដូយដើរត្រួតត្រាចុះឡើងតាមបណ្តោយព្រំដែនខ្មែរ-យួនដោ

យសេរី ។

ពេលនោះលោកសឹង-ង៉ុកថាញ់បដិសេធសំណើនេះ ព្រមទាំងឆ្លៀតឱកាសនោះ ខំពន្យល់ខ្មែរវៀតមិញទាំង២នាក់ ឲ្យយល់នូវគំរោងការណ៍ដ៏ក្រខ្វក់របស់យួនហាណូយ ដែលវាចេះប្រើកលល្បិច មានជាបញ្ឆោតមានជាបណ្តោយជានិច្ច... ចូរកុំទុកចិត្តឲ្យសោះ ។ លោកបញ្ជាក់ថា ប្រជាពលរដ្ឋខ្មែរសុភាពស្ងប់ស្ងៀម ស្លូតបូតសុចរិត ស្រឡាញ់សេរីភាព ៩០%កាន់ព្រះពុទ្ធសាសនា ។ យើងមិនអាចលោតកញ្ឆោលដូចភ្នំភ្លើង ប្រើធម៌ក្តៅដូចយួនដូចយួនវៀតមិញបានឡើយ ។ ដីធ្លីប្រទេសខ្មែរយើងមានជីវជាតិល្អធំទូលាយណាស់ សំរាប់បង្កើនផល ។ យើងធ្វើស្រែតែម្តងមួយឆ្នាំ រួចយើងសំរាក៥-៦ខែយ៉ាងស្រួល ។ ចំណែកព្រៃឈើដ៏មានតម្លៃ មានដល់ទៅ ៧៣% នៃដីធ្លីទាំងអស់ ។ ទន្លេសាប ទន្លេមេគង្គ ផ្តល់ត្រីបានគ្រប់គ្រាន់ ។ ក្រឡេកមើលទៅត្បូងដ៏មានតម្លៃវិញ យើងមានយ៉ាងច្រើន...។ល។

ដូច្នេះយើងគ្រាន់តែរួបរួមគ្នាបំបាត់ឈ្មួញកណ្តាល បំបាត់សំណូកសូកប៉ាន់ យើងអាចដោះស្រាយបញ្ហាជីវភាពកសិករខ្មែរបានយ៉ាងងាយ ។ល។ និង ។ល។ ខ្មែរទាំង២នាក់នោះវិលត្រឡប់ទៅជួបវា ។ ហូ-ជីមិញចេញបញ្ជាឲ្យគេសម្លាប់អ្នកទាំងពីរនោះចោល ដើម្បីចៀសវាងកុំឲ្យបែកការណ៍របស់វា ។ សង្គ្រាម៥៧ថ្ងៃផ្ទុះឡើងយ៉ាងខ្លាំងក្លានៅឌៀនបៀនភូ ។ កងទ័ពបារាំងនិងបូដូយព័ទ្ធវាយគ្នាយ៉ាងស្វិតគឺស៊ីសាច់ហុតឈាមគ្នា ។ ទិន្នានុប្បវត្តិបារាំងមួយឈ្មោះ HISTORAMA បានផ្សាយថា នៅពេលនោះកងទ័ពបារាំងមានស្លាប់និងបាត់ខ្លួនចំនួនជាផ្លូវការ ប្រាំម៉ឺនប្រាំពីរពាន់ប្រាំបួនរយកៅសិបប្រាំបីនាក់ (៥៧,៩៩៨នាក់) ។ ទើបពិភពលោកបើកសន្និសិទមួយនៅក្រុងហ្សឺណែវ ចាប់ពីខែមេសាឆ្នាំ១៩៥៤ ដើម្បីចរចាបញ្ចប់សង្គ្រាមនៅជ្រោយឧបទ្វីបឥណ្ឌូចិន ។

ដូច្នេះសន្និសិទនេះបានសំរេចនៅថ្ងៃទី២០/៧/៥៤ ត្រូវបញ្ចប់សង្គ្រាមនៅលើជ្រោយឧបទ្វីបឥណ្ឌូចិន ថែមទាំងយល់ព្រមឲ្យប្រទេសកម្ពុជា, យួន, លាវឯករាជ្យ បញ្ជាក់បន្ថែមទៀតថា ទ័ពបរទេសទាំងអស់ត្រូវដកថយចេញឲ្យអស់ពីប្រទេសទាំងបីនោះជាដាច់ខាត ។

ប៉ុន្តែអភ័ព្វខ្មែរយើង... យើងត្រូវបាត់បង់ទឹកដីកម្ពុជាក្រោមជាលើកទី២ ។ ត្រូវបាត់បង់ប្រជាជនចំនួន៤លាននាក់, ត្រូវលះបង់វត្តចំនួន៥៥៦ ដែលមានព្រះសង្ឃជាជាតិខ្មែរ កាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួនចំនួន២ម៉ឺន៥ពាន់អង្គ ។ ( រឿងខ្មែរយើងត្រូវបាត់បង់ទឹកដីកម្ពុជាក្រោមនេះ, បារាំងដូចជាគ្មានកំហុសទេ ព្រោះកាលណោះ បើបារាំងប្រគល់ទឹកដីកម្ពុជាក្រោមឲ្យខ្មែរ គេអាចស្មានបានថា មុខជាដូចស្វាបានផ្លែដូងហើយ ! ) ។ គួរឲ្យស្តាយណាស់... ទឹកដីកម្ពុជាក្រោមស្ថិតនៅក្រោម

អាណានិគមបារាំងអស់រយៈពេលចំនួន៩០ឆ្នាំ ។ រាជការខ្មែរសោះអង្គើយ គ្មានគំរោងការរំដោះទាល់តែសោះ ! ។ ផ្ទុយទៅវិញ យួនមានផែនការគ្រោងទុកជាស្រេចតាំងពីឆ្នាំ១៩៤៥ ដើម្បីគ្រប់គ្រងនគរកម្ពុជាក្រោម ។ មើលចុះ ! បារាំងប្រគល់ទឹកដីកម្ពុជាក្រោមឲ្យវាភ្លាម... វាមានកងទ័ពដែលមានការពិសោធន៍ដ៏គ្រប់គ្រាន់... វាមាននាម៉ឺនចេះដឹងជ្រៅជ្រះ... វាមានអ្នកបច្ចេកទេសដ៏ត្រឹមត្រូវ នាំយកមកដាក់គ្រប់ៗក្រសួង, គ្រប់ៗផ្នែកភ្លាមៗ ។ល។

បារាំងបានប្រគល់ឯករាជ្យឲ្យប្រទេសកម្ពុជាតាំងពីថ្ងៃទី៩វិច្ឆិកា១៩៥៣ ។ យួនវៀតមិញចង់ពុះប្រទេសកម្ពុជាជាពីរ... ដូច្នេះឆ្លៀតពេលដែលបូដូយតាំងមូលដ្ឋាននៅពាសពេញស្រុកខ្មែរយ៉ាងនេះ វាបែរជាបញ្ជាឲ្យបូដូយលួចវាយកំទេចកងខេមរភូមិន្ទនៅស្រុកប៉ៃលិន, ក្រចេះ, ស្រែជេស, វ៉ឺនសៃ ជាដើម ក្នុងខែមេសាឆ្នាំ១៩៥៤ ។ ពេលនោះកងទ័ពជាតិយើងវាយតបទៅវិញ បណ្តាយឲ្យបូដូយត្រូវស្លាប់តាយហោងចោលខ្មោចពាសពេញព្រៃ ។

មើលចុះបងប្អូនខ្មែរអើយ ! កងទ័ពខ្មែរយើងមិនមែនអន់ឯណា ! ។ ក្នុងឆ្នាំ១៩៥៤, បូដូយមានកម្លាំងទ័ពនិងមានអាវុធដ៏ខ្លាំងក្លា, វាអាចដណ្តើមយកជ័យជំនះពីបារាំងនៅដៀនបៀនភូ ក៏ប៉ុន្តែវាត្រូវបរាជ័យគួរឲ្យអាម៉ាស់នៅចំពោះមុខកងខេមរភូមិន្ទ ។ លុះត្រូវបរាជ័យយ៉ាងនេះ ទើបវាយល់ថា បើប្រើតែអាវុធនិងកម្លាំងបាយធ្វើសង្គ្រាមជាមួយខ្មែរ វាមិនអាចយកជ័យជំនះពីខ្មែរបានឡើយ ។ ព្រោះប្រជាជនខ្មែររឹងប៉ឹងស្វិតស្វាញពូកែអត់ទ្រាំនូវការលំបាកគ្រប់បែបយ៉ាង ។ មើលចុះខ្មែរម្នាក់អាចទប់ទល់នឹងយួន៥នាក់បានយ៉ាងងាយ ។ បន្តសង្គ្រាមតទៅទៀតមិនកើតទេ ត្រូវតែដកថយរកឧបាយកលផ្សេង ។ យួនស្គាល់ចរិតនិងចំណុចខ្សោយរបស់មេដឹកនាំប្រទេសខ្មែរ គឺចូលចិត្តស៊ីជោរ, ចូលចិត្តឲ្យគេបញ្ជោរ, ឲ្យគេបញ្ចើចបញ្ចើររណោបរណើប... ឯងភរអញក៏ភរទៅចុះ ឲ្យតែត្រូវចិត្តអញ ! ឲ្យតែអញល្បីឈ្មោះ (ឡើងបុណ្យស័ក្តិ) មានប្រយោជន៍ដល់គ្រួសារអញ ។ល។ ដូច្នេះយួនហាណូយត្រូវតែបន្ថែមអាវុធចិត្តសាស្ត្រ និងកលល្បិចថែមទៀត រួចហើយវាក៏ចាប់ផ្តើមអនុវត្តឃ្លោងឃ្លា « បំបែកបំបាក់ដើម្បីគ្រប់គ្រង » ។

យួនវៀតមិញកំពុងស្លន់ស្លោរកឧបាយកល ស្រាប់តែវាដឹងថាសន្និសិទនៅទីក្រុងហ្សឺណែវសំរេចបញ្ឈប់សង្គ្រាមនៅឧបទ្វីបឥណ្ឌូចិន ។ ឱកាសល្អមកដល់យ៉ាងនេះ, នៅថ្ងៃទី៦/៨/៥៤, យួនហាណូយចេញបញ្ជាឲ្យចេញពីព្រៃតំរៀបជួរឡើងឡានទាំងមុខញញឹម រួចលើកដៃបក់អិចៗ «សុំលាបងប្អូនខ្មែរ» វិលត្រឡប់ទៅកាន់ប្រទេសវៀតណាមវិញ ។ វាស្រែកហ៊ោរកញ្ជ្រៀវសប្បាយរីករាយ ញញឹមមានន័យជាងខ្មែរម្ចាស់ស្រុកទៅទៀត ។

ចាប់តាំងពីខែកញ្ញា១៩៥៤រហូតបន្តបន្ទាប់មក បូដូយលបលួចចូលមកកាន់ប្រទេសខ្មែរ ។ វាដើរថ្មើរជើងស្ងាត់ច្រៀប ។ ផ្ទុយទៅវិញ នៅថ្ងៃទី៦/៨/៥៤ បូដូយត្រូវដកថយចេញពីស្រុកខ្មែរ ស្រាប់តែបូដូយតំរៀបជួរគ្នាឡើងឡាន យ៉ាងគគ្រឹកគគ្រេង ធ្វើឲ្យផ្អើលដល់ពិភពលោកនិងប្រជាជនខ្មែរ ។ នេះជាកលល្បិចថ្លិនភ្លែកដ៏ប្រសប់អស្ចារ្យ ។ វាបង្ហាញឲ្យឃើញផ្ទាល់ភ្នែកជាក់ស្តែងថា ពេលបារាំងថយចេញពីប្រទេសខ្មែរ បូដូយក៏ដកថយចេញដែរ ។ ដូច្នេះខ្មែរដែលមិនបានពិចារណា ក៏យល់ច្រឡំយ៉ាងធ្ងន់ថា ៖ បូដូយស្ម័គ្រចិត្តចូលមកស្លាប់ជួយខ្មែរមែន ព្រោះបងប្អូនខ្មែរយើងស្មានយល់តាមតែការមើលឃើញប៉ុណ្ណោះ ។

គឺបុព្វហេតុដែលបានរៀបរាប់មកនេះហើយ បានជាខ្មែរអាយ៉ងយួនហេង-សំរិន, ហ៊ុន-សែន, ជា-ស៊ីមសន្និដ្ឋានថា យួនចូលមកជួយខ្មែរជាលើកទី១ ។

ចំណែកយួនវៀតមិញដែលបានសំរេចជោគជ័យដ៏ធំធេង នូវផែនការទី១នេះហើយ ដូច្នេះវាអាចលេបទឹកដីកម្ពុជាក្រោម ដែលជាផែនការទី២របស់វាបានយ៉ាងងាយ ។ នោឯកម្ពុជាកណ្តាលឯណោះវិញ វាបង្កើតបានជាខ្មែររយៈបង្កប់ទុកជាស្រេច មានសមាជិកខ្មែរវៀតមិញទាំងអស់ចំនួនប្រាំពាន់នាក់ ផ្តរផ្តាច់យ៉ាងស្អិតរមួតបំរើវា ។ ពេលបូដូយដកទ័ពចេញពីប្រទេសខ្មែរ វាសំរាំងជ្រើសរើសក្នុងចំណោមសមាជិកទាំងនោះចំនួនមួយពាន់នាក់ នាំយកទៅជាមួយ ។ ចំណែកបួនពាន់នាក់ទៀត វាឲ្យរំសាយជួរសម្ងំក្នុងទីងងឹត សំរាប់ទុកធ្វើខ្មែររយៈរង់ចាំឱកាសល្អវិលត្រឡប់មកវិញ ។ គ្មាននរណាម្នាក់ចូលសុំសារភាពបំរើរាជការខ្មែរទេ ។ ចំណែកឯក្រុមខ្មែរឥស្សរៈ... ចាប់តាំងពីស្រុកខ្មែរបានឯករាជ្យ ក៏ស្ម័គ្រចិត្តចូលមកសុំសារភាពរួបរួមបំរើជាតិទាំងអស់ ។

ក្នុងរយៈពេល៩ឆ្នាំដែលបូដូយតាំងមូលដ្ឋាននៅក្នុងស្រុកខ្មែរ យួនហាណូយជាវៀតមិញខំរៀនសូត្រស្គាល់គ្រប់ជ្រុងជ្រោយភូមិយុទ្ធសាស្ត្រព្រៃព្រឹក្សានៅក្នុងស្រុកខ្មែរ ។ ស្គាល់ទីកន្លែងត្បូងមានតម្លៃ ជាពិសេសវាឆ្លៀតដឹកនាំអាវុធចូលយកមកកប់លាក់ទុកក្នុងព្រៃស្រុកខ្មែរយ៉ាងច្រើន ។ ឧទាហរណ៍នៅភូមិសំឡូតខេត្តបាត់ដំបង មានបីរយដើម ។ មេធំៗពីរនាក់ ដែលថែរក្សាអាវុធទាំងនោះឈ្មោះ មូល-សម្បិត្ត ហៅតាប៉ែត និងរស់-ញឹម ហៅតាកៅ ។

យួនបានត្រួតត្រាប្រទេសបីគឺ តុងកឹង, អណ្ណាម និងកម្ពុជាក្រោម ។ វាហ៊ានរំលោភច្បាប់អន្តរជាតិ, រំលោភសិទ្ធិមនុស្ស, វាហ៊ានចេញច្បាប់ឲ្យខ្មែរកម្ពុជាក្រោមចំនួន៨លាននាក់កាន់កាតយួន ។ កាលណោះព្រះសង្ឃកម្ពុជាក្រោមធ្វើបាតុកម្មយ៉ាងខ្លាំងក្លា ប្រឆាំងនឹងអំពើព្រៃផ្សៃរំលោភសិទ្ធិមនុស្សនេះ ។

ដើម្បីបំបាត់ដានប្រវត្តិសាស្ត្រនិងភូមិសាស្ត្ររបស់ខ្មែរកម្ពុជាក្រោម យួនបាន

ផ្លាស់ឈ្មោះភូមិ ឃុំ ស្រុក និងខេត្តខ្មែចខ្ទីអស់ រួចវាថែមទាំងផ្លាស់ឈ្មោះនគរទាំងបីនោះទៅជា «វៀតណាម» ទៀតផង ។ វាបានពុះជាពីរ ដោយយកខ្សែបន្ទាត់ស្រប ទី១៧ ជាព្រំប្រទល់ គឺវៀតណាមខាងជើងជាកុម្មុយនិស្ត ចាត់តែងតាំងហូ-ជីមិញជាប្រធាន និងវៀតណាមខាងត្បូងជាសេរីចាត់តាំងង៉ោ-ឌិនយៀម ជាប្រធានាធិបតី ។

គេអាចប្រដូចការអនុវត្តន៍ផែនការរបស់យួនរបៀបនេះ ទៅនឹងការជ្រើសរើសត្រីរស់ ដែលនៅរស់ស្រស់ល្អក្នុងក្រឡមួយ, ត្រីរស់ស្លាប់ស្អុយ គឺពួកយួនពុករលួយសេរីនិយម ពួកចោរព្រៃខាងត្បូងនៅក្នុងក្រឡមួយផ្សេងទៀតជាស្រេច ដើម្បីងាយអនុវត្តផែនការទី២ជាបន្ទាន់ ។

ដើម្បីចៀសវាងកុំឲ្យខុសច្បាប់អន្តរជាតិ ដែលមានចែងក្នុងសន្ធិសញ្ញានៃសន្និសិទនៅក្រុងហ្សឺណែវខែកក្កដាឆ្នាំ១៩៥៤ ដែលយួនហាណូយជាវៀតមិញ បានចុះហត្ថលេខាទទួលយល់ព្រមជាមួយ សន្យាថាឈប់ដើរឈ្លានពានប្រទេសជិតខាងនោះ... ដូច្នេះក្នុងឆ្នាំ១៩៥៤, យួនហាណូយឆ្លៃប្រឌិតជាវៀតកុងវិញ រួចចាត់តែងតាំង « ង្វៀង-ហ៊ូថូ » ជាប្រធាន ។ ប៉ុន្តែត្រូវតែស្តាប់ ត្រូវតែគោរពតាមបញ្ជាហូ-ជីមិញដដែល ។ « វៀតកុងកំពុងឆ្លៃឆ្លារកលេស ! » ។

ក្នុងឆ្នាំ១៩៦៣, ឆ្លៀតពេលដែលបញ្ញវ័ន្តខ្មែររញ៉ីរញ៉ៃរត់ចូលព្រៃ, ឆ្លៀតពេលដែលសម្តេចសីហនុទាត់ចោលជំនួយអាមេរិកាំងនៅថ្ងៃទី១០វិច្ឆិកា១៩៦៣ ឱកាសល្អមកដល់យ៉ាងនេះ យួនហាណូយជាអតិតវៀតមិញ និងជាបច្ចុប្បន្នវៀតកុងក៏ចាប់ផ្តើមអនុវត្តគំរោងការទី២ភ្លាម ។ វាចាប់ផ្តើមទាក់ទងសម្តេចសីហនុ រួចវាបញ្ជូនបូដូយវិលត្រឡប់ចូលមកកាន់ប្រទេសកម្ពុជា, ចាប់ផ្តើមតាំងមូលដ្ឋានទ័ពកន្លែងចាស់ដដែលឡើងវិញ ។ វាយកលេសសុំដីតាំងមូលដ្ឋានទ័ព ដើម្បីកំទេចអាមេរិកាំងរំដោះទឹកដីវៀតណាមខាងត្បូង ។ នេះហើយជាខ្លាចាស់ចូលមកកាន់សិលនៅវត្តដដែលវិញ ។ វាប៉ិនប្រសប់ធ្វើបុកទន់ភ្លន់ សូកប៉ាន់នាម៉ឺនខ្មែរដែលទទួលខុសត្រូវក្នុងវាំង រហូតដល់គ្រួសាររបស់សម្តេចសីហនុ ។ល។

ក្នុងឆ្នាំ១៩៦៥ វៀតណាមខាងត្បូងបានទទួលអន្តរាគមន៍ពីកងទ័ពអាមេរិកាំងគ្រប់ៗផ្នែកមានចំនួន២សែននាក់ ។ ឆ្លៀតឱកាសនោះយួនហាណូយជាវៀតកុងក៏បញ្ជូនបូដូយមកកាន់ប្រទេសខ្មែរដែរ ដើម្បីឲ្យមានចំនួនស្មើគ្នា ។ វាយកលេសដដែលៗថា ៖ « សុំដីស្នាក់នៅដើម្បីកំទេចកងទ័ពអាមេរិកាំងរំដោះទឹកដីវៀតណាមខាងត្បូង » ។

ឆ្លៀតពេលនោះ វាបញ្ជូនក្រុមចិត្តសាស្ត្រ ចូលមកប្រទេសខ្មែរយ៉ាងច្រើន ។ ក្រុមនេះចាប់ផ្តើមធ្វើសកម្មភាពទាក់ទងរឹតចំណងមិត្តភាព រវាងសមាជិកបក្សប្រ-

ជាជនបដិវត្តន៍ខ្មែរ គឺពួកអតិតខ្មែរវៀតមិញ ដែលហូ-ជីមិញបញ្ជាឲ្យសឹង-ង៉ុកមិញ បង្កើតពីឆ្នាំ១៩៥១ រួចបង្កប់លាក់ខ្លួនទុកក្នុងស្រុកមានចំនួន៤ពាន់នាក់នោះឡើងវិញ ។ ជាពិសេសវាចាប់ផ្ដើមពង្រឹងពង្រីកកងកម្លាំងប្រដាប់អាវុធបដិវត្តន៍ឯកភាពរបស់កម្ពុជា (អតិតខ្មែរវៀតមិញ) ឲ្យរឹងមាំ ។ វាសំរាំងជំរើសតែយុវជនខ្មែរដែលគ្រួសារត្រូវវរងគ្រោះ បណ្ដាលមកពីអំពើអយុត្តិធម៌ណាមួយ ពីស្នាដៃនាម៉ឺនរាជការជិះជាន់ រួចវាញុះញង់ចាក់ចុចតាមចំណុចខ្សោយនានានោះឲ្យដុះចិត្តត្រូវតែសងសឹក... រួចទើបវាបញ្ចូលក្នុងអង្គភាពយោធា ។ល។

❑ ❑

❑

# ជំពូកទី៣

## ★ ហេតុដូចម្តេចបានមានព្រឹត្តិការណ៍១៨មិនា១៩៧០ ?
## ★ ការបង្កើតរាជរដ្ឋាភិបាលស្រោចស្រង់ជាតិ !
## ★ សម្តេចសីហនុរត់ចោលស្រុក !
## ★ លោកលន់-នល់ចាត់តំណាងទៅជួបសម្តេចសីហនុ !

### ហេតុដូចម្តេចបានមានព្រឹត្តិការណ៍១៨មិនា១៩៧០ ?

លោកលន់-នល់ជារដ្ឋមន្ត្រីនិងជានាយអគ្គមេបញ្ជាការកងទ័ពជាតិ ។ តំណែងនេះ លោកធ្លាប់កាន់កាប់រហូតមកដល់ឆ្នាំ១៩៦៧ ។ ចាប់តាំងពីឆ្នាំ១៩៦៩ លោកសុំដកខ្លួនថយចេញពីមុខដំណែងទាំងអស់ គឺលោកមានបំណងថ្វាយសម្តេចសីហនុចញ្ចៀញថ្មីព្រះហត្ថចុះ ។ ម៉្យាងទៀតលោកកំពុងមានកង្វល់ ដោយសារមរណភាពថ្មីៗរបស់លោកស្រីខេង ដែលជាភរិយាដ៏កំសត់កម្រុរបស់លោក ។

ពេលនោះ សម្តេចសីហនុកំពុងបង្ក្រាបពួកឆ្វេងផង ពួកស្តាំផង ញាំងឲ្យសេដ្ឋកិច្ចចុះដុនដាប បន្ថែមលើឥទ្ធិពលសង្គ្រាមនៅប្រទេសវៀតណាម កំពុងជះមកលើជាយ៉ាងខ្លាំង និងបញ្ហាលំនឹងនយោបាយ លំនឹងមនោគមវិជ្ជា ត្រូវចោទយ៉ាងធ្ងន់ក្នុងប្រទេសខ្មែរ ។ មូលហេតុនេះ... ក្នុងឆ្នាំ១៩៦៩ សម្តេចទ្រង់ទទួលស្គាល់បរាជ័យនៃនយោបាយខាងផ្នែកសេដ្ឋកិច្ច និងកំហុសដែលយល់ព្រមឲ្យវៀតកុងតាំងមូលដ្ឋានបួដ្ឋយក្នុងទឹកដីខ្មែរ ។ នៅពេលនោះ វាកំពុងបញ្ជូនបួដ្ឋយ បញ្ជូនអាវុធចូ-លមកច្រើនឡើងៗដូចទឹកបាក់ទំនប់ ( កាលណោះវៀតកុងកាន់កាប់ទឹកដីខ្មែរអស់ចំនួនពីរភាគបី ២/៣ ទៅហើយ ) ។ វាឆ្លៀតពង្រឹងពង្រីកកងកម្លាំងអតិតខ្មែរវៀត-មិញឡើងវិញ ។ល។

ដូច្នេះខែសីហា១៩៦៩... សម្តេចទ្រង់បើកសមាជពិសេសមួយ រួចសំរេចចាត់តាំងលោកលន់-នល់ ជាមេដឹកនាំ « រដ្ឋាភិបាលស្រោចស្រង់ជាតិ » ។ កាលណោះមរតកកម្ពុជា ដែលពោរពេញទៅដោយវិបត្តិ ក៏ត្រូវធ្លាក់ទៅលើស្មាលោកលន់-នល់ទាំងស្រុង ។

លោកខ្វល់សែនខ្វល់ព្រោះលោកយល់ថា ៖

★ បើអាមេរិកាំងដកថយចេញពីយួនខាងត្បូង តើរាជការខ្មែរដេញបូជួយឲ្យថយចេញពីស្រុកខ្មែររបៀបដូចម្ដេចទៅ ? ធ្វើការចរចាប្រាប់វាឲ្យដកថយចេញ ? វាច្បាស់ជាឆ្លើយថា ទេ ! ។ យើងប្រើអាវុធ ? កងខេមរភូមិន្ទមានតែ២ម៉ឺន៧ពាន់នាក់ ? ។

បើសិនជាប្រទេសវៀតណាមខាងជើងរួមគ្នាជាមួយវៀតណាមខាងត្បូងវិញ ប្រទេសនេះនឹងក្លាយទៅជាប្រទេសមួយយ៉ាងមាំខាងផ្នែកសង្គ្រាម ព្រោះរបររកស៊ីរបស់វាគឺធ្វើសង្គ្រាម ។ វាធ្វើសង្គ្រាមបន្តៗជាមួយបរទេស និងជាមួយពួកយួនគ្នាវាគ្មានស្រាកស្រាន្ត ។ តទៅអនាគត វាមុខជាឆ្លៀតបន្តសង្គ្រាម ដើម្បីពង្រីកទឹកដីរបស់វាបន្ថែមទៀត ។

ព្រោះប្រទេសវៀតណាមមានទំហំក្រឡាផ្ទៃចំនួន៣៣០,០០០គម២ គឺធំជាងស្រុកខ្មែរជិតដល់ទៅ២ដង ។ មានចម្ងាយពីខាងជើងទៅខាងត្បូង ប្រវែង២,០០០ គ.ម. ។ ក្នុងឆ្នាំ១៩៦៩ វៀតណាមទាំងពីរមានប្រជាជនចំនួន៣៤លាននាក់ ( ២០លាននាក់នៅខាងជើង និង១៤លាននាក់នៅខាងត្បូង ) ។ ប្រទេសវៀតណាមសំបូរទៅដោយព្រៃភ្នំឥតប្រយោជន៍គ្របដណ្ដប់ ។ ៨០%នៃផ្ទៃក្រឡាទាំងមូល (២៦០,០០០គម២)... នៅសល់តែ២០% គឺ៦៦,០០០គម២ប៉ុណ្ណោះ ដែលជាដីអាចរស់នៅបាន ។ ស្ថានភាពប្រជាជនយួនមានចំនួន ៦០០នាក់ក្នុងផ្ទៃដី១គម២ ។

ប្រជាជនវៀតណាមមានយ៉ាងច្រើន នៅលើផ្ទៃដីដ៏ចង្អៀតចង្អល់បែបនេះ នឹងអាចបណ្ដាលឲ្យទៅជាទម្ងន់មួយដ៏ធ្ងន់ឥតគណនាដល់ប្រទេសកម្ពុជា ដែលមានព្រំប្រទល់ជាប់គ្នា ព្រោះយើងមិនអាចបឹទបាំងព្រំប្រទល់ប្រទេសទាំងពីរ ដែលគ្មានរបាំងធម្មជាតិជួយការពារឲ្យមានប្រសិទ្ធិភាពបានទេ ។ សព្វថ្ងៃនេះ យួនចេះតែវាតទី ចូលមកតាំងនៅលើដីខ្មែរដែលទំនេរជាហូរហែរ ។ ក្នុងឆ្នាំ១៩៦៩ យួនចូលមកតាំងទីលំនៅតាមច្បាប់មានចំនួន៥០ម៉ឺននាក់ ក្នុងចំណោមខ្មែរដែលជាម្ចាស់ទឹកដីចំនួន៧លាននាក់ ។បើសព្វថ្ងៃបូជួយនិងរាស្ត្រយួនកំពុងលបលួចចូលបន្តមកទៀតនោះ ដូច្នេះខ្មែរយើងពិបាកសន្និដ្ឋានណាស់ចំពោះផលវិបាកផ្នែកខាងសេដ្ឋកិច្ច និងនយោបាយ ដែលប្រទេសខ្មែរនឹងត្រូវទទួលរងគ្រោះនៅពេលអនាគតខាងមុខជាពិសេសអណិកជនជាតិយួនមានចំណងខាងផ្លូវចិត្ត និងនយោបាយជាមួយមាតុប្រទេសដើមរបស់វាជានិច្ច ។

លោកយល់ទៀតថា ៖ ការរួមគ្នាឡើងវិញនៃប្រទេសយួន ជាមហន្តរាយឥតអ្វីប្រកែកបាន ចំពោះភ័ព្វវាសនានៃប្រទេសកម្ពុជា ។ សង្គ្រាមមុខតែនឹងផ្ទុះរវាងខ្មែរនិងយួន មិនងាយចៀសវាងផុតឡើយ ។

លោកលន់-នល់ហ៊ានអះអាងទទួលស្គាល់ថា ជនជាតិយួនដោយមានសង្គ្រាមជាប់ៗមកដូច្នេះ ញាំងឲ្យវាមានចរិតរឹងប៉ឹង ចេះអត់ធ្មត់នូវការលំបាកគ្រប់បែបយ៉ាង ។ រីឯខាងយោធា វាមានឋាមពលដ៏ខ្លាំងពូកែ មានការពិសោធន៍ដ៏ត្រឹមត្រូវក្នុងភ្លក់ភ្លើងសង្គ្រាម ថែមទាំងមានគុណសម្បត្តិខាងផ្លូវបញ្ញា ទាំងខាងផ្លូវកលល្បិច ។ ដូច្នេះបញ្ជាក់ឲ្យឃើញថា យួនទៅអនាគត ផ្នែកយោធាអាចពូកែក្នុងចំណោមប្រជាជាតិទាំងឡាយនៅជ្រោយឥណ្ឌូចិន និងនៅក្នុងអាស៊ីអគ្នេយ៍ជាមិនខាន ។

ក្នុងឆ្នាំ១៩៧០ បូដូយមានចំនួន២សែននាក់ តាំងមូលដ្ឋានពាសពេញព្រៃនៃប្រទេសខ្មែរ ។ ចំណែកកងខេមរភូមិន្ទវិញ មានតែ២ម៉ឺន៧ពាន់នាក់តែប៉ុណ្ណោះ គឺមានចំនួនតិចជាងយួនបូដូយដល់ទៅជាង៧ដង ! ។ នេះមិននិយាយដល់ចំនួននិងគុណភាពនៃអាវុធយុទ្ធភ័ណ្ឌផង ។

លោកលន់-នល់យល់ដូច្នេះ មានការព្រួយបារម្ភយ៉ាងខ្លាំង ។ សម្តេចសីហនុបែរជារត់ចោលតំណែង, រត់ចោលមាតុភូមិ, រត់ចោលរាស្ត្រខ្មែរ យករួចខ្លួន ហើយទម្លាក់អំរែកនេះទៅលើលោកទៅវិញ ។ លោកលន់-នល់គ្មានគំនិតក្បត់សម្តេចសីហនុទេ ប៉ុន្តែលោកត្រូវតែទទួលថ្នបាក់នេះដោយស្វ័យប្រវត្តិ ទើបជំរុញឲ្យមានព្រឹត្តិការណ៍១៨មិនា១៩៧០ វេលាម៉ោង១រសៀលនេះឡើង ។

ប៉ុន្តែគួរឲ្យស្តាយណាស់ កាលនោះប្រៀបដូចជាយើងធ្វេសប្រហែស បណ្តោយឲ្យទឹកជំនន់ជន់លិចដល់ដំបូលផ្ទះទៅហើយ ទើបប្រវេប្រវារកទីជំរក ក៏ក្លាយទៅជាលិចលង់វិនាសអន្តរាយដល់ភាពអស់សង្ឃឹមរហូតដល់សព្វថ្ងៃនេះ ។ ម្យ៉ាងវិញទៀត... ខ្មែរយើងអភ័ព្វណាស់... មើលចុះលោកលន់-នល់ឡើងជាប្រមុខរដ្ឋគ្រប់គ្រងសាធារណរដ្ឋខ្មែរ មិនបានបំរើប្រទេសឲ្យបានពេញលេញទេ ព្រោះលោកមានរោគាពាធធ្ងន់ធ្ងរដាបណាស់ទៅហើយ ។ ពេលនោះ លោកដូចជាអ្នកកាន់អំណាចឯទៀតៗដែរ លោកមានគុណសម្បត្តិនិងគុណវិបត្តិគួរឲ្យកត់សម្គាល់ ។ នរណាចង់ចោទលោកថាដូចម្តេច ក៏លោកគ្មានឆ្លើយតបទេ ។ លោកបន្សល់ទុកកិត្តិយសរបស់លោកផ្ញើក្នុងដៃរាស្ត្រខ្មែរ ដែលចេះគិតពិចារណា ចេះប្រៀបធៀបឲ្យឆ្លើយជំនួសចុះ ។

ថ្ងៃទី១៨មិនា១៩៧០កន្លងផុតទៅពេលណា លោកសេនាប្រមុខលន់-នល់ជួបលោកសឺង-ង៉ុកថាញ់ លោកតែងតែពោលដំអូញថា ៖ « គួរឲ្យស្តាយណាស់ៗ មិនគួរឲ្យមានព្រឹត្តិការណ៍ដោយចៃដន្យយ៉ាងនេះទេ នាំឲ្យលោកជាប់ឈ្មោះក្នុងប្រវត្តិសាស្ត្រ ថាលោកជាអ្នកដណ្តើមអំណាចពីសម្តេចសីហនុ » ។ តាំងពីដើមទីមកលោកគោរពនិងស្មោះត្រង់ចំពោះសម្តេចអស់ពីដួងចិត្ត លោកគ្មាននឹកនាក្បត់ឬដណ្តើមអំណាចពីព្រះអង្គទាល់តែសោះ ។

ចុះបើព្រះអង្គរត់ចោលតំណែង រត់ចោលកូនៗទៅហើយ តើឲ្យធ្វើដូចម្ដេចទៅ ? ដូ-ច្នេះវាសនាជំរុញគេចមិនផុត លោកត្រូវតែផ្សងព្រេងជាចុងក្រោយបង្អស់ ត្រូវតែលះបង់អ្វីៗទាំងអស់ដើម្បីជាតិ ។

ក្នុងពេលដែលប្រទេសខ្មែរកំពុងឆ្លងកាត់ភ្នក់សង្គ្រាម លោកសេនាប្រមុខលន់-នល់យល់ច្បាស់ណាស់ថា គឺយួនហាណូយទៅដែលឆ្លៀតឱកាសនេះ បញ្ជាឲ្យប្អូនដូយវាយកំទេចសម្លាប់ខ្មែរ ព្រោះវាមានតែផែនការព្រាងទុកជាស្រេច ត្រូវតែក្រឡែមុខប្រទេសកម្ពុជា ឲ្យទៅជាកុម្មុយនិស្តឥណ្ឌូចិន « មិនមែនធ្វើសង្គ្រាមជាមួយសម្ដេចសីហនុទេ! » ។

ដូច្នេះគ្រប់ៗសុន្ទរកថារបស់លោក លោកតែងតែដាស់តឿនរំលឹកប្រជាពលរដ្ឋខ្មែរថា យើងត្រូវប្រយ័ត្ននូវគ្រោះថ្នាក់នៃពួកទមិឡ ! ។ បើពេលណាពួកវាទទួលជ័យជំនះ វានឹងប្ដូរមុខកម្ពុជាទៅតាមមនោគមវិជ្ជារបស់វា ។ វានឹងកសាងកម្ពុជាថ្មីលើគំនរផេះគំនរឆ្អឹងនៃរាស្ត្រខ្មែរជាមិនខាន ។ « តើយោបល់ ពាក្យដំបូន្មានរបស់លោកត្រូវឬទេនៅពេលនេះ ? » ។

ដើម្បីបញ្ជាក់សម្ដេចសីហនុឲ្យយល់នូវភ្នក់ភ្លើងសង្គ្រាមដ៏ពិតប្រាកដក្នុងទឹកដីខ្មែរ ដែលកំពុងផ្ទុះឡើងនោះ... ដូច្នេះក្រោយថ្ងៃ១៨មិនា១៩៧០ ព្រះមហាក្សត្រីយានីនិងរដ្ឋសភាខ្មែរ បានចាត់តំណាង២រូប គឺព្រះអង្គម្ចាស់នរោត្តម-កន្តុល ជាតំណាងព្រះរាជវាំង, លោកយ៉ែម-សំបួរ ជាតំណាងខាងផ្នែករដ្ឋាភិបាល បញ្ជូនទៅគាល់សម្ដេចសីហនុនៅទីក្រុងប៉ារីស៍ គឺសូមសម្ដេចសំណាក់នៅប្រទេសបារាំងសំរាកព្រះកាយគង់នៅស្ងៀមសិនចុះ ទំរាំកូនៗរៀបចំចាត់ចែងស្ថានការណ៍ឲ្យបានរៀបរយស្រួលបួលសិន ...កូនៗនឹងសូមយាងសម្ដេចឱរិលត្រឡប់ទៅកាន់ទីក្រុងភ្នំពេ-ញ ក្នុងឋានៈជាព្រមុខរដ្ឋដដែលវិញ ។

ប៉ុន្តែសម្ដេចសីហនុចចេស ក៏បដិសេធចោលសេចក្ដីសុំនេះទាំងស្រុង ដោយមិនព្រមជួបតំណាងទាំង២រូបនោះឡើយ រួចប្រកាសដឹកលទុកថា រដ្ឋាភិបាលសាធារណរដ្ឋខ្មែរនិងសភាក្បត់ជាតិ ក្បត់រាជបល្លង្កទៅវិញ ។

កាលណោះអតីតសហភាពសូវៀតថ្វាយយោបល់ សុំកុំឲ្យសម្ដេចយាងទៅកាន់ស្រុកចិនឡើយ...។ « អតីតសហភាពសូវៀតគាំទ្រលោកសេនាប្រមុខលន់-នល់នៅថ្ងៃទី១៧មេសា១៩៧៥ » ។

❑ ❑

❑

# ជំពូកទី៤

★ ចិននិងយួនហាណូយបើកកលល្បិចបោកសម្ដេចសីហនុ !
★ ចិននិងយួនបើកអង្គប្រជុំបង្កើតរណសិរ្សប្រជាជនទាំងបីនៃឧបទ្វីបឥណ្ឌូចិន ( FUTPI ) !
★ ចិន យួន និងលាវ គាំទ្រសម្ដេច !
★ សកម្មភាពបួដូឃយវាយកំទេចខ្មែរលន់-នល់ !

## ចិននិងយួនហាណូយបើកកលល្បិចបោកសម្ដេចសីហនុ !

នៅវេលាម៉ោងមួយរសៀលនៃថ្ងៃទី១៨មិនា១៩៧០ រដ្ឋសភាខ្មែរបានប្រកាសទម្លាក់សម្ដេចសីហនុចេញពីតំណែងប្រមុខរដ្ឋ នៅពេលដែលសម្ដេចកំពុងតែសំណាក់នៅឯទីក្រុងម៉ូស្គូនៃអតីតសហភាពសូវៀត ។

ជូ-អេនឡាយលើកទឹកចិត្តសម្ដេចសីហនុនិងផាំ-យ៉ាំងដុងរដ្ឋមន្ត្រីក្រសួងការបរទេសវៀតណាមខាងជើង ឲ្យបង្កើតរណសិរ្សមួយ ដែលគេនឹងប្រកាសបង្កើតនាខែមេសាមួយខែក្រោយមកទៀត ។ ថ្ងៃទី២៥មិនា, សម្ដេចសីហនុក៏បង្កើតរណសិរ្សមួយដែលមានឈ្មោះថា ៖ «រណសិរ្សរួបរួមជាតិកម្ពុជា» ដែលមានខៀវ-សំផន, ហ៊ូ-យន់, ហ៊ូ-នឹម ជាអ្នកគាំទ្រឥតលក្ខណ ដើម្បីប្រឆាំងនឹងរដ្ឋាភិបាលលន់-នល់ ។

នៅថ្ងៃ២៥-២៦មេសា, ក្រោមការផ្ដើមគំនិតរបស់សម្ដេចសីហនុ និងក្រោមអធិបតីភាពរបស់រដ្ឋមន្ត្រីទី១ចិនជូ-អេនឡាយ, មានការបើកប្រជុំមួយទៀត ដើម្បីបង្កើត «រណសិរ្សរួបរួមជាតិទាំង៣នៃឧបទ្វីបឥណ្ឌូចិន» ដែលមានទ្រង់សុផានុវង្ស (លាវ), ផាំ-យ៉ាំងដុង (វៀតណាមខាងជើង), ង្វៀង-ហ៊ូថូ (វៀតណាមខាងត្បូង) ជាអ្នកចូលរួមប្រជុំ ។

បើតាមសេចក្ដីប្រកាសរួម... ទីកន្លែងប្រជុំនេះស្ថិតនៅចំព្រំដែននៃប្រទេសទាំងបីគឺ ចិន, លាវ និងវៀតណាម ។ តែបើយោងតាមសេចក្ដីសម្ភាសន៍មួយរបស់ទ្រង់សុផានុវង្ស ជាមួយអ្នកកាសែតស្រីជាតិប៉ូឡូញម្នាក់, ទ្រង់សុផានុវង្សបានអះអាងថា ការប្រជុំនេះបានប្រព្រឹត្តឡើងនៅទីកន្លែងមួយនៃខេត្តកង់តុងស្រុកចិន ។

ជាមួយគ្នានេះ, ចិនប៉េកាំងចាត់បេសកជនពិសេសឲ្យទៅជួបលោកលន់-នល់នៅឯភ្នំពេញដើម្បីសុំចរចា ។ ចិនសុំឲ្យលោកលន់-នល់គិត ហើយសំរេចនូវកិច្ចសន្យា៣ខ រហូតដល់ដំណាច់ខែមេសា ។

កិច្ចសន្យា៣ខនោះគឺ ៖

១- សុំឲ្យរដ្ឋាភិបាលលោកលន់-នល់សំរួលការដឹកស្បៀង និងអាវុធគ្រប់យ៉ាងទៅឲ្យយៀកកុងកាត់តាមស្រុកខ្មែរ ដើម្បីវាយសឹកជាមួយវៀតណាមខាងត្បូង។

២- យល់ព្រមឲ្យយួនខាងជើងដាក់ទ័ពនៅស្រុកខ្មែរ ។

៣- យល់ព្រមទទួលស្គាល់បរិវារចិន ហើយសុខចិត្តធ្វើឃោសនាឲ្យពួកនេះតាមគ្រប់មធ្យោបាយ ។

បើលោកលន់-នល់ទទួលស្គាល់ខទាំងបីនេះ ប៉េកាំងនឹងទាត់ចោលសម្តេចសីហនុ ហើយទទួលស្គាល់សាធារណរដ្ឋខ្មែរវិញ ។ តែលោកលន់-នល់មិនព្រម ។ ស្អែកឡើងថ្ងៃទី១៥សភា១៩៧០ ចិនប្រកាសទទួលស្គាល់សម្តេចសីហនុ ។ ម៉ៅ-សេទុងប្រកាសជាឧឡារិកថា ចិនស្ម័គ្រចិត្តផ្តល់ជំនួយជាទឹកប្រាក់ « តាមសម្តេចត្រូវការ » ព្រមទាំងប្រកាសថា ដល់ពេលណាសម្តេចទទួលជ័យជំនះសិនសឹមសងចិនវិញ... ចិនមិនគិតការប្រាក់ទេ ! ។

៥ថ្ងៃក្រោយមកទៀត គេក៏បានបង្កើតរដ្ឋាភិបាលមួយដែលមានឈ្មោះថា « រដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា » ដែលមានសម្តេចប៉ែន-នុតជានាយក, ចៅ-សេងជារដ្ឋមន្ត្រីទទួលបន្ទុកខាងបេសកកម្មពិសេស ដែលដើរទាក់ទងគ្រប់បរទេ-ស ពិសេសពួកបស្ចឹមប្រទេស ។

ចិននិងយួនយៀកកុងជួយសម្តេចសីហនុដូច្នេះមិនទំនងទាល់តែសោះ ព្រោះខ្ញុំនៅចាំមាត់នៅឡើយថា ក្នុងបក្សកុម្មុយនិស្តឥណ្ឌូចិន គេបានចែងច្បាប់យ៉ាងច្បាស់លាស់ណាស់ថា ដំណាក់ការជាដំបូងត្រូវកំទេចសក្តិភូមិ... ចុះឥឡូវនេះហេតុដូចម្តេចបានជាបក្សកុម្មុយនិស្តឥណ្ឌូចិនបែរជាគាំទ្រសម្តេចសីហនុ ដែលជាសក្តិភូមិទៅវិញ ? ។

ចំណែកឯខៀវ-សំផន មេខ្មែរក្រហមដែលមាននិន្នាការខ្មែរ ហើយដែលរត់ចោលស្រុកដោយសារការចោទប្រកាន់របស់សម្តេចសីហនុ ថាជាសត្រូវក្បត់ជាតិនោះ បែរជាស្លន់ស្លោឆ្លេឆ្លាបបួលគ្នាចុះហត្ថលេខាគាំទ្រសម្តេចសីហនុនៅថ្ងៃទី២៦-៣-៧០ នឹងគេដែរ ។

បុព្វហេតុដែលមានជាបញ្ហាស់បណ្តោយ ដូចបានអធិប្បាយមកខាងលើនេះក៏ដូចជាការនាំសាំងជាច្រើនពាន់តោន ទៅចាក់ស្រោចដុតប្រទេសកម្ពុជាតែម្តង ។ ព្រោះផាំ-យ៉ាំងដុងបានត្រៀមខ្លួនរង់ចាំឱកាសនេះជាយូរមកហើយ ។ លុះឱកាស

ល្អមកដល់យ៉ាងនេះ វាបញ្ជាឲ្យបូដូយបន្លំប្រើឃើហោខ្មែរក្រហម នៅលើដើមទ្រូងពាក់រូបសម្ដេចសីហនុគ្រប់ៗគ្នា យកលេសហាក់លោតកញ្ជ្រោលដូចភ្នំភ្លើង វាយសំរុកកំទេចសម្លាប់ខ្មែរលន់-នល់ ដែលជាម្ចាស់ទឹកដីកម្ពុជាពិតៗ ព្រមទាំងស្រែកជយោសម្ដេចឪ ! ( កាលណោះសម្ដេចឪរត់ចោលកូនខ្មែរ ទៅធ្វើជាឪយួនយៀកកុងជាបូដូយវិញ ) ។

ខ្ញុំខំស្រាវជ្រាវរកពត៌មានខ្លះៗ ដែលស្ដីអំពីការដែលបូដូយបានចេញមុខវាយកំទេចប្រទេសខ្មែរដូចតទៅ ៖

★ កងពលធំលេខ១ ៖ កងវរសេនាធំលេខ101D មានបូដូយ២ពាន់នាក់តាំងនៅមូលដ្ឋានអង្គរបូរី (ខេត្តតាកែវ) ។

★ កងពលធំលេខ៥ ៖ កងវរសេនាធំលេខ174-05 និង 275 មានបូដូយប្រាំពាន់នាក់តាំងមូលដ្ឋាននៅស្នួល (ខេត្តក្រចេះ) ។

★ កងពលធំលេខ៧ ៖ កងវរសេនាធំលេខ141 165 និង 209 មានបូដូយប្រាំមួយពាន់ពីររយនាក់ តាំងមូលដ្ឋាននៅមេមត់ (ខេត្តកំពង់ចាម) ។

★ កងពលធំលេខ៩ ៖ កងវរសេនាធំលេខ95C 271 និង 272 មានបូដូយ៦ពាន់នាក់ តាំងមូលដ្ឋាននៅជប់ (ខេត្តកំពង់ចាម) ។

★ កងទ័ពលេខ B3 ៖ កងវរសេនាធំលេខ24 28 40 65 និង 95 មានបូដូយ១ម៉ឺន៨រយនាក់ តាំងមូលដ្ឋាននៅបរកែវ (ខេត្តរតនគិរី) បន្ថែមលើអង្គភាពនេះ នៅអមសេនាធិការ មានបូដូយ១ម៉ឺន២ពាន់នាក់ ។ ចំណែកឯក្រុមដឹកជញ្ជូនភស្តុភារសឹកមានបូដូយ២ម៉ឺន៣ពាន់នាក់ ។

★ កងពលធំលេខ៥០៩ ៖ តាំងមូលដ្ឋាននៅក្រែក-ស្នួល (ខេត្តក្រចេះ) យ៉ាងច្រើនមិនដឹងចំនួនពិតប្រាកដ ។ បូករួមទាំងអស់មាន ៖ ៦ម៉ឺន៥ពាន់នាក់ (ដោយមិនគិតកងពលធំលេខ៥០៩) ។

## សកម្មភាពបូដូយវាយកំទេចខ្មែរលន់-នល់ !

ថ្ងៃទី២៧-៤-១៩៧០, បូដូយចេញមុខពេញទីវាយកំទេចខ្មែរជាលើកទី១ នៅឈើខ្មៅ ស្រុកកោះធំ (ខេត្តកណ្ដាល) ។ បូដូយរុករានចូលយ៉ាងលឿន ធ្លាយមកដល់តាខ្មៅ រហូតដល់ក្បាលថ្នល់ ។

នៅថ្ងៃទី១៥មិថុនា១៩៧០, បូដូយចេញមុខពេញទីវាយកំទេចខ្មែរនៅខេត្តកំព-ង់ធំ... យើងមើលពីកប៉ាល់ហោះ ឃើញច្បាស់បូដូយជាច្រើនម៉ឺនក្បាល ច្បាំងទល់

តួជាមួយកងទ័ពជាតិខ្មែរ ។ ទល់តួយ៉ាងនេះ បូដួយត្រូវស្លាប់គរលើគ្នាជាច្រើនពាន់ក្បាល, ចោលខ្មោចពាសពេញព្រៃដូច្នេះ, បូដូយត្រូវបរាជ័យដកថយ ។

នៅថ្ងៃទី២៨កញ្ញា១៩៧១, បូដួយចេញមុខពេញទីវាយកំទេចបំផ្លាញទំនប់ទឹកព្រែកត្នោត ។

នៅថ្ងៃទី៥ឧសភា១៩៧២, បូដួយចេញមុខពេញទីវាយកំទេចបំផ្លាញស្ពានព្រះមុនីវង្ស ។

ពីថ្ងៃទី១ដល់ថ្ងៃទី១២កក្កដា បូដួយចេញមុខពេញទីវាយកំទេចខ្មែរនៅស្រុកអង្គតាសោម (ខេត្តតាកែវ) ។

ក្នុងខែសីហា, បូដួយចេញមុខពេញទីវាយកំទេចខ្មែរនៅកំពង់ត្របែក ។

នៅយប់ថ្ងៃទី៦ទៅ៧តុលា បូដួយជាច្រើនពាន់ក្បាលចេញមុខពេញទីវាយកំទេចបំផ្លាញស្ពានជ្រោយចង្វារ ។

នៅយប់ថ្ងៃទី៦ទៅ៧តុលា បូដួយជាច្រើនពាន់ក្បាលចេញមុខពេញទីវាយកំទេចបំផ្លាញស្ពានជ្រោយចង្វារ ។ ពេលវាដកថយទៅវិញ វាចោលខ្មោចនៅក្នុងសមរភូមិ៨៣ក្បាលឆល និងត្រូវកងទ័ពជាតិខ្មែរចាប់បាន៧ក្បាល ។

នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៤ បូដួយជាច្រើនម៉ឺនក្បាលចេញមុខពេញទី ព័ទ្ធវាយកំទេចភូមិប្រសូតមានចម្ងាយប្រមាណ២គ.ម.ពីទីក្រុងស្វាយរៀង ។

★★★ គឺវិបត្តិខាងលើនេះហើយ ដែលខ្មែរអាយ៉ងយួនក្រុមហេង-សរិន, ហ៊ុនសែនជាដើម វាសន្និដ្ឋានថា យួនមកជួយខ្មែរជាលើកទី២ ។

❑ ❑

❑

# ជំពូកទី៥

★ យួនញុះញង់ខ្មែរឲ្យប្រឆាំងនឹងរដ្ឋាភិបាលលន់-នល់ ។
★ ស្មៀតយួនប្រើឈ្មោះសម្តេចសីហនុដើម្បីជ្រើសរើសយោធា ។
★ សហរដ្ឋអាមេរិកជួយខ្មែរលន់-នល់ពីរលើក ។
★ យោធាខ្មែរក្រហមបំបែកជា៣ក្រុម ។
★ វៀតកុងសុីវិលត្រឡប់ទៅស្រុកវិញ ។
★ យួនហាណូយបញ្ជូនខ្មែរវៀតមិញ៣ពាន់នាក់ មកកាន់ស្រុកខ្មែរ ។

## យួនញុះញង់ខ្មែរឲ្យប្រឆាំងនឹងរដ្ឋាភិបាលលន់-នល់

យួនហាណូយជាវៀតកុងស្គាល់ចំណុចខ្សោយរាស្ត្រខ្មែរ ដែលជាអ្នកគោរពស្រឡាញ់សម្តេចឪ, វាបញ្ជាឲ្យអតិតខ្មែរវៀតមិញប្រើយីហោខ្មែរក្រហម ដើរចំបះចំបោររាស្ត្រខ្មែរ ប្រឆាំងតទល់នឹងរដ្ឋាភិបាលលន់-នល់ ដោយវាយកលេសថា គាំទ្រសម្តេចឪ ។ កាលណោះរាស្ត្រខ្មែរអ្នកស្រែចំការដាច់ស្រយាលនិងអ្នកស្រុកព្រៃភ្នំ ខ្វះការពិចារណា ក៏ស្ម័គ្រចិត្តគាំទ្រអតិតខ្មែរវៀតមិញ, ចំណែកឯយុវជនក៏ស្ម័គ្រគាំទ្រពួកនេះដែរ ដោយចូលធ្វើជាយោធាខ្មែរក្រហម ។

ចំណែករាស្ត្រខ្មែរអ្នកចេះដឹង ជាពិសេសអ្នករដ្ឋការដែលចេះត្រិះរិះពិចារណាក៏យល់ថា ប្រទេសខ្មែរនៅពេលនេះមានគ្រោះថ្នាក់មកដល់ហើយ ក៏នាំគ្រួសាររត់ភៀសខ្លួនចូលកាន់ទីក្រុង ដែលមានរដ្ឋាភិបាលសាធារណរដ្ឋជាអ្នកគ្រប់គ្រង ។

បញ្ហារាស្ត្រខ្មែររត់ចាកចេញពីទីកន្លែងដែលវារំដោះរួចហើយ នោះវាត្រេកអរណាស់, វាត្រូវតែអនុវត្តផែនការតឹងរ៉ឹងបន្ថែម គឺកំចាយបន្ថែម, ឧបមាដូចជាវារើសត្រីស្រស់ដាក់កញ្ជើផ្សេង ត្រីស្អុយដាក់កញ្ជើមួយផ្សេងទៀតជាស្រេច ដើម្បីអនុវត្តផែនការទី២ ។

ពេលនោះយួនហាណូយប្រើអាវុធ២យ៉ាង ដើម្បីសម្លាប់បំបាត់ពូជខ្មែរជាម្ចាស់ទឹកដីកម្ពុជាពិតៗ ។ អាវុធកម្លាំង វាប្រើសំរាប់សម្លាប់ខ្មែរលន់-នល់... អាវុធចិត្តសាស្ត្រ វាប្រើសំរាប់កំទេចខ្មែរសីហនុ ។

មើលចុះ ! ចាប់តាំងពីថ្ងៃទី១៨ មិនា ១៩៧០ ផ្ទុះឡើងភ្លាម, យួនហាណូយបង្កើតចលាចលខ្លាំងឡើងៗ ។ វាប្រើខ្មែរអាយ៉ងរបស់វាឲ្យទៅកាន់ភូមិខ្មែរ ដែលនៅតាមបណ្តោយព្រំដែនខ្មែរ-យួន ដើម្បីញុះញង់បំបះបំបោរខ្មែរ ជំរុញឲ្យធ្វើបាតុកម្មគាំទ្រសម្តេចឪជាញឹកញាប់ ។ ឧប្បត្តិហេតុនេះកើតឡើងពេលណា ខាងក្រសួងសន្តិសុខជាតិតែងតែហាមឃាត់... ដូច្នេះក្លាយទៅជាកើតវិវាទរវាងពួកបាតុករនិងអាជ្ញាធរ ដែលបណ្តាលឲ្យមានការវាយតប់តទល់គ្នារហូតដល់របួសនិងស្លាប់ជាច្រើន ។

ដូចជានៅថ្ងៃទី២៩ មិនា ១៩៧០... នៅខេត្តកំពង់ចាម, វៀតកុងនិងអតិតខ្មែរវៀតមិញបបួលខ្មែរឥស្លាមនិងអ្នកស្រុកខ្មែរលើ (ព្រៃភ្នំ) មានចំនួន៤ម៉ឺននាក់ នាំគ្នាចូលទៅកាន់ភូមិនានា ញុះញង់បំបះបំបោររាស្ត្រខ្មែរស្លូតត្រង់ ហើយហែរជាក្បួនបាតុកម្មសំដៅចូលទៅកាន់ទីក្រុងកំពង់ចាម ដោយយកលេសថា ទៅគាំទ្រសម្តេចឪ ។ តែក្រុមបាតុករដុតដំណាក់សម្តេចសីហនុ ដុតសាលាដំបូង...។ ពេលនោះមានតំណាងរាស្ត្រពីរនាក់ស្ម័គ្រចិត្តទទួលបន្ទុកចេញទៅជួបក្រុមបាតុករ ដើម្បីធ្វើអន្តរាគមន៍សំរុះសំរួល... តែមានឃាតករអាថ៌កំបាំងសម្លាប់លោកតំណាងរាស្ត្រទាំងពីរនោះចោលភ្លាមទៅ ។ ក្រុមបាតុករចូលព័ទ្ធសាលាខេត្តកំពង់ចាម ស្រែកកំហែងបង្ខំតម្រូវឲ្យកេណ្ឌឡាន ដើម្បីដឹកនាំក្រុមវាទៅកាន់រដ្ឋធានីភ្នំពេញ ។ កំហែងបានហើយ ក្បួនឡានក៏ធ្វើដំណើរទៅកាន់រដ្ឋធានីភ្លាម ។ មកដល់ភូមិគគី ចំពេលបឹទចរាចរ ។ ភ្នាក់ងារយាមល្បាតក៏ហាមឃាត់ តែពួកបាតុករដ៏សាហាវអស់នោះមិនព្រមស្តាប់ ជាហេតុធ្វើឲ្យភ្នាក់ងារយាមល្បាតបាញ់រះទៅលើបាតុករ បណ្តាលឲ្យស្លាប់និងរបួសជាច្រើន ។ គេឃើញខ្មោចស្លាប់នៅនឹងកន្លែងកើតហេតុចំនួន៤០នាក់ ។ អ្នកដែលត្រូវរបួសធ្ងន់ៗ ក៏វិលត្រឡប់ទៅខេត្តកំពង់ចាមវិញ ហើយក៏ស្លាប់ដោយរបួសធ្ងន់នោះអស់៦០នាក់ទៀត ។ ក្រុមបាតុករក៏បំបែកជួរ រួចវិលត្រឡប់ទៅកាន់លំនៅរៀងៗខ្លួនវិញ ដោយនាំទាំងគំនុំគុំគួនក្តៅក្រហាយទៅជាមួយផងហើយសន្យានឹងសងសឹកឲ្យបងប្អូន មិត្តភ័ក្តិដែលត្រូវគ្រាប់កាំភ្លើងរបស់កងទ័ពជាតិ...។

ឆ្លៀតឱកាសនោះ អតិតខ្មែរវៀតមិញញុះញង់បន្ថែម រួចសំរាំងជំរើសបានទាហានយ៉ាងច្រើន ដែលដុះចិត្តយ៉ាងមុតថា ត្រូវតែសងសឹកជំនួសគ្រួសារ និងដណ្តើមអំណាចពីលន់-នល់យកមកថ្វាយសម្តេចឪវិញ ។

ដូច្នេះសង្គ្រាមក្នុងប្រទេសខ្មែរ ដែលផ្ទុះឡើងចាប់ពីឆ្នាំ១៩៧០ដល់ចុងឆ្នាំ១៩-៧៣ គឺបូដួយទៅវាយកំទេចខ្មែរ... ប៉ុន្តែមតិខ្មែរនិងបរទេសជាច្រើនបានយល់ច្រឡំនៅពេលនោះថា ខ្មែរសីហនុវាយកំទេចខ្មែរលន់-នល់ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ពួកបូដួយដែលហ៊ាន « យកបាយមកលាបមាត់ពពែ » នៅពេលនោះក៏ព្រោះតែមានការស្រែកអំពាវនាវរបស់សម្តេចសីហនុ តាមវិទ្យុពីប៉េកាំងមកឲ្យរាស្ត្រខ្មែរក្រោកឡើងប្រឆាំងនឹងពួក «អាក្បត់ឆ្កែបំរើអាមេរិកាំង » ។

ក្នុងឆ្នាំ១៩៧០, តាមទីក្រុងនានានៃប្រទេសខ្មែរ មានកើតចលាចលដ៏ប្លែកៗ គឺកូនសិស្សអនុវិទ្យាល័យនិងវិទ្យាល័យ បះបោរធ្វើបាតុកម្មវាយអាណិកជនជាតិយួ ន ។ ព្រឹត្តិការណ៍ប្លែកៗទាំងនេះមិនដឹងចេញពីប្រភពណាទេ ។ លុះមានរឿងមិនទំនងយ៉ាងនេះ អាណិកជនជាតិយួនដែលមានលទ្ធភាពនិងមធ្យោបាយគ្រប់គ្រាន់ ក៏នាំគ្រួសារធ្វើមាតុភូមិនិវត្តន៍ទៅកាន់ស្រុកយួនវិញ មានចំនួននៅពេលនោះប្រមា-ណ១០ម៉ឺននាក់ ។ ឆ្លៀតឱកាសដ៏ល្អនេះ វៀតកុងសំរាំងជ្រើសរើសយុវជនយួនក្មេងៗដែលរៀនសូត្រចេះអក្សរ ចេះភាសាខ្មែរជ្រៅជ្រះ បានជាច្រើនពាន់នាក់ រួចបញ្ជូនបញ្ចូលសាលាយោធា ។ លុះរៀនចេះចប់យុទ្ធវិធីកលល្បិចនិងមនោគមវិជ្ជាកុម្មុយនិស្តស្រេចបាច់... វាបំពាក់ស័ក្តិជាអនុសេនិយត្រី (ស័ក្តិ១) ដល់ពួកនោះហើយក៏ប្រែដាក់ឈ្មោះជាខ្មែរ រួចបញ្ជូនវិលត្រឡប់ចូលមកកាន់ប្រទេសខ្មែរវិញចាត់តែងតាំងជាមេកាន់ក្តាប់យោធាខ្មែរក្រហមដែលស្រឡាញ់សម្តេចឳ គឺផ្លាស់មកជំនួសបូដួយដែលមិនចេះភាសាខ្មែរ ។

ក្រុមស័ក្តិ១នេះត្រេកអរណាស់ ព្រោះបានវិលមកសងសឹកចំពោះខ្មែរ ដែលពេលមុនមានពួកអាថ៌កំបាំងបាននាំធ្វើបាតុកម្មវាយគ្រួសាររបស់វាកាលពីវានៅក្មេ-ងៗ ។

ពីរដ្ឋធានីវ៉ាស៊ិនតោន លោកប្រធានាធិបតីអាមេរិកាំងនិចសុន ដែលមិនស្គាល់គំនិតខូចរបស់យួន បានចេញបញ្ជាប្រើកងទ័ពយួនខាងត្បូង ឲ្យចូលមកធ្វើប្រតិ-បត្តិការបោសសំអាតក្នុងដែនដីខ្មែរជំរៅ៤០គ.ម. ចាប់តាំងពីថ្ងៃទី៣០-៤-៧០ ដល់ថ្ងៃ៣០-៦-៧០ ។ ឱកាសល្អមកដល់យ៉ាងនេះ យួនខាងត្បូងបញ្ជូនកងទ័ពរថក្រោះកាំភ្លើងធុនធ្ងន់ចំនួន២ម៉ឺនប្រាំពាន់នាក់ ចូលតាមចំពុះទា (ខេត្តស្វាយរៀង) មករាតត្បាតស្រុកខ្មែរ, វាយកំទេចសម្លាប់ខ្មែរស្លូតត្រង់ ដើម្បីនឹងសងសឹកឲ្យជនជាតិវាដែលត្រូវរងគ្រោះដោយសារបាតុកម្មរបស់និស្សិតខ្មែរនោះ ។ ទំហំនៃការសងសឹកនេះមានកំរិតលើសពីបាតុកម្មចំនួន១០០ដង ។

មើលចុះ! វាបាញ់សម្លាប់រាស្ត្រខ្មែរស្លូតត្រង់ដែលមានទីលំនៅតាមបណ្តោយព្រំដែនខ្មែរ-យួនយ៉ាងចេញមុខ យ៉ាងស្របច្បាប់ ។ ប្រមូលទ្រព្យសម្បត្តិគ្រប់បែ

បយ៉ាង ប្លន់ដឹកជញ្ជូនតាមឡាន តាមឧទ្ធម្ភាគចក្រប្រកបដោយជោគជ័យ... រួចវាដុតបំផ្លាញផ្ទះខ្មែរខ្ទេច ។ល។

ដូច្នេះបង្ហាញឲ្យឃើញថា យួនណាក៏ដូចជាយួនណា គឺជាសត្រូវស្នូរពូជរបស់ខ្មែរយើងជានិច្ច ។

ពីរដ្ឋធានីវ៉ាស៊ិនតោន លោកប្រធានាធិបតីនិចសុនប្រកាសជាឧឡារិក ថាជួយសាធារណរដ្ឋខ្មែរម្តងទៀត ។ ដូច្នេះចាប់ពីថ្ងៃ៧-៣-៧៣ ដល់ថ្ងៃ១៥-៨-៧៣ អាមេរិកាំងក៏ដឹកគ្រាប់បែកមកសាបព្រួសលើប្រទេសកម្ពុជាចំនួន៤ម៉ឺនតោនក្នុងមួយខែៗ ក្នុងគោលបំណងជួយបញ្ចប់សង្គ្រាមឲ្យបានឆាប់ ។

ប៉ុន្តែផ្ទុយទៅវិញ ដូចវាយទឹកបង្អើលត្រី គឺបានប្រយោជន៍ទៅវៀតកុងទាំងអស់ ព្រោះបូដូយមានការពិសោធន៍យ៉ាងហ្មត់ចត់ វាអាចគេចចាកផុតគ្រោះថ្នាក់បានយ៉ាងងាយ ។

មើលចុះ ! អាមេរិកាំងជួយខ្មែរពីរលើក... រាស្ត្រខ្មែរត្រូវរងគ្រោះស្លាប់អស់ចំនួនម្ភៃម៉ឺន (២០០,០០០) នាក់ ។

រីឯរាស្ត្រខ្មែរជាច្រើនសែននាក់ទៀតដែលនៅសល់ពីស្លាប់ ក៏ខ្វះទីជំរក ខ្វះទីពំនឹង ។ បើរត់ចូលទៅកាន់ទីក្រុង ច្បាស់ជាដាច់ពោះស្លាប់, ព្រោះគ្មានលុយកាក់, គ្មានអ្វីនឹងបរិភោគ, ទំនិញឡើងថ្លៃហួសក៏រឹត...

អុញ... បើដើរដល់ច្រកទ័លយ៉ាងនេះ តើរត់ទៅជ្រកឯណាទៅ ? ។ ដូច្នេះរាស្ត្រខ្មែរទាំងឡាយនោះ ត្រូវតែបង្ខំចិត្តផ្សងព្រេងរត់ចូលព្រៃ ពឹងវៀតកុង ពឹងអតិតខ្មែរវៀតមិញ ។ ពេលនោះវៀតកុងស្រង់យកប្រយោជន៍ ប្រកបដោយជោគជ័យដ៏ធំធេង ។ វៀតកុងនិងខ្មែរអាយ៉ងយួនតម្រៀបជួរគ្នាឈរចាំទទួលរាស្ត្រខ្មែរអភ័ព្វទាំងឡាយនោះ ដោយទឹកមុខញញឹមសប្បាយរីករាយ ។ វៀតកុងបានដៃក៏ឆ្លៀតញុះញង់បន្ថែមធ្វើឲ្យរាស្ត្រខ្មែរទាំងអស់នោះយល់ច្រឡំព្រមទាំងមានទីអាង ក៏តាំងដុះចិត្តជាសត្រូវចំពោះជាតិរបស់ខ្លួន ។ ត្រូវតែសងសឹកចំពោះសាធារណរដ្ឋ ត្រូវតែកំទេចសាធារណរដ្ឋ ដណ្តើមអំណាចមកថ្វាយសម្តេចឪវិញ ។

ពេលនោះយុវជនខ្មែរក៏ស្ម័គ្រចិត្តចូលបំរើវា គឺចូលជាយោធាយ៉ាងច្រើនលើសលប់ ។

❑

# វៀតកុងចាត់បំបែកយោធាជាបីក្រុម

ក្រុមទី១ ៖ កុមារតូចៗអាយុពី៩ទៅ១៣ឆ្នាំ ដាក់ឈ្មោះជាក្រុមត្រីកញ្ចុះ ដែលមានមេកាន់ក្តាប់ គឺអតិតចោរព្រៃឬមនុស្សយង់ឃ្នងខ្វះសីលធម៌ ។

ក្រុមទី២ ៖ យុវជនពេញវ័យ ស្ម័គ្រចិត្តកំទេចខ្មែរលន់-នល់ ដណ្តើមអំណាចមកថ្វាយសម្តេចឪ មានចំនួនជាងបួនម៉ឺននាក់ ។

ក្រុមទី៣ ៖ យុវជនដែលថ្លែងការណ៍ស្មោះត្រង់ប្រាប់វៀតកុង ថាខ្លួនស្ម័គ្រចិត្តកំទេចសក្តិភូមិនិងចក្រពត្តិ ។ ក្រុមនេះមិនដឹងចំនួនទេ ។ វៀតកុងដឹកនាំទៅកាន់ទីអាថ៌កំបាំង ។

នៅចុងឆ្នាំ១៩៧៣... គំរោងការទី១របស់វាបានសំរេចជោគជ័យដ៏ធំធេង ព្រោះយោធាក្រុមទី២អាចបន្តសង្គ្រាមកំទេចខ្មែរលន-នល់ជំនួសវាបានហើយ ។ វៀតកុងធ្វើពុតសុំលាយោធាដ៏កំសត់នោះ វិលត្រឡប់ទៅស្រុកវាវិញ ។ ពេលលាគ្នានោះ បូដូយឱបយោធាខ្មែរក្រហម យំសស្រាក់ថ្លែងសំដីផ្អែមល្ហែកថា ៖ ឥឡូវនេះមិត្តៗរឹងដៃរឹងជើង មានមធ្យោបាយគ្រប់គ្រាន់ អាចទប់ទល់ចំពោះសត្រូវដោយខ្លួនឯងបានហើយ... មិត្តពុំចាំបាច់ពឹងផ្អែកពួកខ្ញុំទៀតទេ... ពួកខ្ញុំលាសិនហើយ ដើម្បីចៀសវៀងកុំឲ្យខ្មែរវង្វេង ចោទពួកខ្ញុំថាចូលមកឈ្លានពាន ។ បើមិត្តត្រូវការអាវុធ ពួកខ្ញុំនឹងផ្តល់ជូន... បើទៅអនាគតមិត្តត្រូវការពួកខ្ញុំ ពួកខ្ញុំនឹងចូលមកជួយភ្លាម ។

ពេលនោះយោធាខ្មែរក្រហមក៏យំ, បូដូយក៏យំ, ឱបគ្នាសំលាគ្នា ។ ខ្មែរនិងយួនយំចេញទឹកភ្នែកដូចគ្នា ប៉ុន្តែមានន័យខុសគ្នាស្រឡះ ។

យោធាខ្មែរក្រហមយំដោយស្តាយបែកចេញពីមិត្តដ៏មានគុណ ដែលខំចំណាយពេលជួយបង្ហាត់ចង្រៀនយុទ្ធវិធី ព្រមទាំងផ្តល់អាវុធឲ្យក្រុមខ្លួនយ៉ាងគ្រប់គ្រាន់ រួចវិលត្រឡប់ទៅស្រុកវិញដែនទេ ។ល។

ចំណែកវៀតកុង, ជាពិសេសបូដូយ, វាយំព្រោះវាត្រេកអរជាក្រៃលែង នូវមហាជោគជ័យនៃគំរោងការទី២ ដែលយួនហាណូយអត់ធ្មត់ព្យាយាមញុះញង់ពន្យល់ខ្មែរ ឲ្យយល់ច្រឡំបែកបាក់គ្នា ក្នុងរយៈ១០ឆ្នាំទើបបានសំរេចជាស្ថាពរនៅពេលនេះ ។ ដូច្នេះវារុញក្បាលឲ្យសម្លាប់គ្នាសិនចុះ ។ មុនពេលវៀតកុងបញ្ជាឲ្យបូដូយបែកចេញពីយោធាខ្មែរក្រហម, ហាណូយដឹកជញ្ជូនខ្មែរក្លែងក្លាយមួយក្រុម ជាច្រើនពាន់នាក់ ឲ្យចូលមកកាន់ក្តាប់យោធាខ្មែរក្រហមជំនួសវា រួចរួបរួមធ្វើការជាមួយអតិតខ្មែរវៀតមិញបន្តសង្គ្រាមតទៅទៀត...។

« ក្រុមខ្មែរក្លែងក្លាយនេះ គឺក្រុមយុវជនអណិកជនជាតិយួន ដែលបានរៀន

សូត្រចេះជ្រៅជ្រះ ទាំងភាសាទាំងអក្សរខ្មែរ ដែលធ្វើមាតុភូមិនិវត្តន៍ពីឆ្នាំ១៩៧០-១៩៧១ ទៅកាន់វៀតណាម ដែលបានដុះគំនិតយ៉ាងមាំ ត្រូវតែវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញ ដើម្បីសងសឹកចំពោះខ្មែរ ។ យុវជនយួនទាំងឡាយនោះ ដាក់ឈ្មោះខ្លួនជាខ្មែរ ភរថាខ្លួនជាជាតិខ្មែរ » ។

( កកន ៖ រហូតមកទល់បច្ចុប្បន្ន ពួកនេះបានក្លាយខ្លួនជាមេដឹកនាំសំខាន់ៗនៅក្នុងជួររាជរដ្ឋាភិបាលចំរុះ ឬក៏និងជួរកងទ័ពជាតិខ្មែរ ។ ពួកគេបង្កឲ្យមានអំពើចលាចលអំពើពុករលួយ និងគ្មានវិន័យអ្វីទាំងអស់ ។ ហ៊ុន-សែនមិនហ៊ានប៉ះពាល់ពួកទាំងអស់នេះទេ សូម្បីតែរោមជើងក៏មិនហ៊ានផង ។ បើពួកនេះផ្តល់យោបល់អ្វី ហ៊ុន-ធ្វើភ្លាម ដូចកូនប្រដៅតាមបែបបទ ។ ពួកនេះមានអាយុចន្លោះពី៤០ទៅ៥០ឆ្នាំ ) ។

ពេលជាមួយគ្នានេះ... យួនហាណូយបានបញ្ជូនក្រុមខ្មែរវៀតមិញ ដែលយួនហាណូយជាវៀតមិញជ្រើសរើស នាំយកទៅរៀននៅប៉េកាំងនិងនៅហាណូយ តាំងពីមុនឆ្នាំ១៩៥៤ ចំនួន៣ពាន់នាក់ ឲ្យនិវត្តចូលកម្ពុជាវិញ បន្តសង្គ្រាមជាមួយសាធារណរដ្ឋខ្មែរ... គឺឲ្យមកធ្វើសង្គ្រាមជំនួសវៀតកុង ។ ចំណែកវៀតកុងវិញ វាថយទៅសំរាកច្រត់ចង្កេះឈរមើលខ្មែរសម្លាប់ខ្មែរគ្នាឯងយ៉ាងវក់វី ។

ផ្ទុយទៅវិញ... ក្រុមខ្មែរនេះមិនដែលមានចិត្តគំនុំចំពោះខ្មែរ បែរជាមានសតិសម្បជញ្ញៈមុតជ្រៅស្នេហាជាតិទៅវិញ ។ ក្រុមនេះរៀនសូត្រផ្ទាល់ជាមួយចិន ផ្ទាល់ជាមួយយួនហាណូយ... ក៏ដឹងគំរោងការរបស់ចិន-យួន សម្លាប់បំផុតពូជខ្មែរ ដើម្បីវាតទីយកទឹកដីកម្ពុជាបញ្ចូលទៅក្នុងរបបកុម្មុយនិស្ត ។ ដូច្នេះក្រុមខ្មែរទើបមកដល់ ក៏ប្រឆាំងនូវគំរោងការដ៏សាហាវនេះ ។ ក្រុមនេះនិយាយតវ៉ាដោយសមហេតុសមផលថា ខ្មែរត្រូវចរចារវាងខ្មែរនិងខ្មែរដើម្បីបញ្ចប់សង្គ្រាម, ដើម្បីបញ្ឈប់ការបង្ហូរឈាម ។ ក្រុមនេះបញ្ជាក់ថា បញ្ហាខ្មែរត្រូវទុកឲ្យខ្មែរដោះស្រាយ វាងខ្មែរនិងខ្មែរ ។ល។

ក្នុងឆ្នាំ១៩៧៣... គំរោងការនិងកលល្បិចដែលវៀតកុងប្រតិបត្តិការនៅក្នុងផ្ទៃស្រុកខ្មែរ បានចំរើនលូតលាស់លើសលប់ពីការគ្រោងទុកទៅទៀត ។ ដូច្នេះវាត្រូវតែកែទម្រង់ខ្លះៗ... ឧទាហរណ៍ដូចជាគំនិតហូ-ជីមិញ វាខំជ្រើសរើសយុវជនខ្មែរទាំងខ្មែរកម្ពុជាក្រោម ទាំងខ្មែរកម្ពុជាកណ្តាល ដើម្បីបញ្ជូនទៅរៀននៅប៉េកាំង ឬនៅហាណូយ ចាប់តាំងពីឆ្នាំ១៩៤៨ និងបញ្ជូនជាបន្តៗ ដើម្បីអប់រំលាងខួរក្បាលបញ្ចូលមនោគមវិជ្ជារបស់វា រួចកែឆ្នៃប្រឌិតឲ្យទៅជាខ្មែរថ្មី ម្ចាស់ទឹកដីកម្ពុជាថ្មី ។

នៅឆ្នាំ១៩៧៣... យួនហាណូយបានទទួលលទ្ធផលដ៏គាប់ប្រសើរ ចំពោះស្ថានការណ៍ប្រតិបត្តិការផ្ទៃក្នុងស្រុកខ្មែរ ។ ដូច្នេះវាឈប់ត្រូវការខ្មែរជំនាន់ហូ-ជីមិញទៀតហើយ ។ វាផ្លាស់ប្តូរកែទម្រង់ភ្លាម គឺត្រូវសម្លាប់ខ្មែរធុននេះចោលវិញ ។

គិតឃើញដូច្នេះហើយ... វាចេញបញ្ជាក្នុងនាមអង្គការ ដោយប្រើមិត្តសូ-ភឹម ជាមេដឹកនាំក្រុមឃាតករអាថ៌កំបាំង ដើរព័ទ្ធចាប់ បាញ់សម្លាប់ ក្រុមខ្មែរដែលគេបញ្ជូនមកពីប៉េកាំងនិងមកពីហាណូយ ត្រូវស្លាប់អស់ជិតបីពាន់នាក់ « ដូចក្នុងក្រប័ខណ្ឌសមាជិកបក្សប្រជាជនបដិវត្តន៍ខ្មែរ គឺខ្មែរវៀតមិញនៅកម្ពុជាកណ្តាលក្នុងឆ្នាំ១៩៥៤, យួនវៀតមិញជ្រើសរើសនាំយកទៅជាងមួយ១ពាន់នាក់... ឥឡូវនេះនៅសល់តែ៥៥នាក់ប៉ុណ្ណោះ » ។ យួនហាណូយអនុវត្តបានត្រឹមត្រូវនូវពាក្យមួយឃ្លាថា ៖ « ការសម្លាប់អ្នកឥតទោស ប្រសើរជាងការទុកជីវិតឲ្យសត្រូវ » ។

វាបញ្ជាឲ្យយួនរៀនភាសាខ្មែរ អក្សរខ្មែរ រួចក្លែងខ្លួនបន្លំធ្វើជាខ្មែរ ធ្វើជាម្ចាស់ទឹកដីកម្ពុជាថ្មីប្រសើរជាង ។ ជាពិសេស ប្អូនដូយត្រូវរៀនសូត្រភាសាខ្មែរ អក្សរខ្មែរជាដាច់ខាត... ព្រោះថាបើប្អូនដូយណាធ្លាក់លេខ ត្រូវនៅក្នុងស្រុកខ្មែររហូត ត្រូវបន្លំធ្វើជាខ្មែររហូត ។

យួនវៀតកុងសុំលាខ្មែរក្រហមលើកនេះ មិនមែនដើរចេញចោលស្រុកខ្មែរដូចជាយួនវៀតមិញសុំលាស្តេចសីហនុកាលពីឆ្នាំ១៩៥៤នោះទេ... គឺវាគ្រាន់តែថយទៅពួនលាក់ខ្លួនតាមបណ្តោយព្រំដែនខ្មែរ-យួន-លាវ រួចចេញបញ្ជាពីចម្ងាយបង្ខំឲ្យអតីតខ្មែរវៀតមិញ ដឹកនាំយោធាខ្មែរក្រហមដែលស្រឡាញ់សម្តេចឪ ចូលកំទេចសាធារណរដ្ឋខ្មែរជំនួសវា ។ ចំណែកពួកវា វាសំរាក... ប៉ុន្តែត្រៀមខ្លួនជានិច្ចគ្មានប្រហែស ។ តាំងពីពេលនោះមក មានតែក្រុមខ្មែរវៀតមិញទេដែលអាចទៅ ជួបលុតក្រាប ដើម្បីទទួលបញ្ជាពីវៀតកុងផ្ទាល់ ។ ដូច្នេះ, នៅពេលណាវាត្រូវឡើងទៅទទួលបញ្ជាពីមេវា វាតែងតែភរយោធាខ្មែរក្រហមថា « ក្រុមវាត្រូវទៅរៀនសូត្រនៅអង្គការលើ » ។

សូមបញ្ជាក់ថា ៖ « ពាក្យអង្គការ » ចាប់កំណើតតាំងពីពេលនោះមកហើយ គឺចាប់ពីខែសីហាឆ្នាំ១៩៧៣ ! ។

គួរឲ្យអាណោចអធម៌ដល់យោធាខ្មែរក្រហម ដែលស្រឡាញ់សម្តេចឪចំនួនបួនម៉ឺននាក់នោះណាស់ ដោយពុំបានដឹងខ្លួនថា ក្រុមខ្លួនកំពុងធ្លាក់ចូលក្នុងអន្ទាក់យួនវៀតកុងទាល់តែសោះ ។ ពេលឮថា ពួកមេបញ្ជាការរបស់ខ្លួនទៅរៀនសូត្រនៅអង្គការលើ បែរជាត្រេកអរណាស់ ព្រោះគ្រប់ៗគ្នាយល់ច្រឡំយ៉ាងធ្ងន់ជាងធ្ងន់ដោយនឹកស្មានតែទៅជួបសម្តេចឪ ទៅជួបខៀវ-សំផន, ហ៊ូ-នឹម, ហ៊ូ-យន់ ។ល។

ព្រោះយោធាទាំងបួនម៉ឺននាក់ ភាគច្រើនជាអ្នកស្រែចំការ អ្នកស្រុកព្រៃភ្នំ ជាអ្នកល្ងង់ខ្លៅ មិនយល់ស្ថានការណ៍ គ្មានការពិសោធន៍និងការពិចារណា, ជឿតែតាមពាក្យញុះញង់របស់យួនវៀតកុង ។ ដូចមានជាឧទាហរណ៍មួយ, យាយទៀងបានជួបយុវជនម្នាក់ឈ្មោះរ៉ា ។ នៅថ្ងៃទី២៣-១-៩៣ វេលាម៉ោង១រសៀល យុវជន

រ៉ាបានរ៉ាយរ៉ាប់ប្រាប់យាយទៀងនូវកលល្បិចវៀតកុងដូចតទៅ ៖

កាលពីខែមិថុនា១៩៧០, ឃើញវៀតកុងចូលមកកាន់ភូមិពោធិវង្ស នៅខេត្តស្វាយរៀងដែលកុមាររ៉ាបានរស់នៅពីតូច ។ វាដើរអុងអាត់ពាសពេញភូមិ, លុះវៀតកុងថយចេញផុត ស្រាប់តែកប៉ាល់ហោះយួនខាងត្បូងហោះមកទម្លាក់គ្រាប់បែកបាញ់រះបំផ្លាញខ្ទេចខ្ទីភូមិនោះទៅ ។ កប៉ាល់ហោះចេញផុត វៀតកុងក៏ចូលមកវិញ រួចវាប្រមូលប្រជាជនខ្មែរទាំងអស់ឲ្យទៅនៅកន្លែងមួយដែលវារំដោះបានរួចហើយ វារៀបចំបាយទឹកឲ្យជនរងគ្រោះបរិភោគយ៉ាងបរិបូណ៌... ប៉ុន្តែមិនយូរប៉ុន្មានទេ ស្រាប់តែមានក្រុមអាថ៌កំបាំងចូលមកព័ទ្ធបាញ់សម្លាប់យ៉ាងសាហាវ ។ វាសម្លាប់តែមនុស្សចាស់ៗ តែវាទុកជីវិតឲ្យយុវជននិងក្មេងតូចៗ ។ លុះក្រុមនេះចេញផុតបែរជាឃើញវៀតកុងដដែលវិលត្រឡប់មកវិញ ។ វាប្រមូលយុវជននិងកុមារ នាំទៅបង្ហាត់យុទ្ធវិធី រួចបញ្ចូលក្នុងកងយោធាខ្មែរក្រហម ។ ពេលនោះកុមាររ៉ាទើបបានអាយុ៩ឆ្នាំ ត្រូវបានវៀតកុងកេណ្ឌឲ្យទៅធ្វើយោធាជាមួយនឹងគេដែរ ។ វៀតកុងបញ្ចូលទៅក្នុងកងត្រីកញ្ចុះ វាបំបែកក្មេងៗជាក្រុមៗ មានគ្នា១៥នាក់ក្នុងមួយក្រុម ៗ វារុញឲ្យដើរមុខទ័ព ។

ថ្ងៃមួយនៅក្នុងឆ្នាំ១៩៧២ ក្រុមរបស់រ៉ាត្រូវស្លាប់អស់១៤នាក់ សល់តែរ៉ាម្នាក់ឯងគត់ ។ រ៉ាតក់ស្លុតជាខ្លាំង ទើបដាច់ចិត្តផ្សងព្រេងរត់គេចចេញទាល់តែបាននៅរស់រហូតទាល់សព្វថ្ងៃនេះ ។

រ៉ាបញ្ជាក់ទៀតថា ៖ វៀតកុងញុះញង់ពន្យល់ថា សង្គ្រាមនេះបណ្តាលមកពីលោកលន់-នល់និងអាមេរិកាំងដណ្តើមអំណាចពីសម្តេចឪ ។ល។ ដោយសារមូ-លហេតុនេះ បានជាយោធាខ្មែរក្រហមទាំងនោះដុះគំនិតយ៉ាងមុតជ្រៅ ថាត្រូវតែកំទេចខ្មែរលន់-នល់, កំទេចចក្រពត្តិអាមេរិកាំង, រំដោះដែនដីយកមកថ្វាយសម្តេចឪវិញតែប៉ុណ្ណោះ ។

តាំងពីបូដូយដកថយទៅលាក់ខ្លួនយ៉ាងនេះមក, យួនវៀតកុងចាត់ចែងតែងតាំងគណៈកម្មការពិសេស លបលួចចូលមកកាន់ស្រុកខ្មែរពិនិត្យស្ថានការណ៍សឹក... ដូច្នេះបើរាស្ត្រខ្មែរស្លូតត្រង់ណាភ័ន្តច្រឡំ ដើរទៅឃើញវាដោយចៃដន្យ អង្គការបញ្ជាឲ្យចាប់រាស្ត្រខ្មែរដ៏អភ័ព្វនោះ ដោយចោទថាដើរខុសខ្សែត្រៀម ។ វាវាយធ្វើទារុណកម្មយ៉ាងសាហាវ រួចហើយសម្លាប់ចោលដើម្បីបំបាត់ភស្តុតាង ។ ប្រជាជនខ្មែររងគ្រោះដោយសារអង្គការបញ្ជាឲ្យសម្លាប់តាមរបៀបនេះយ៉ាងច្រើន ។ល។

❑ ❑

❑

# ជំពូកទី៦

★ ប្រតិកម្មលោកសឺង-ង៉ុកថាញ់ក្រោយព្រឹត្តិការណ៍១៨មិនា !

★ លោកលន់-នល់ចាត់តាំងលោកសឺង-ង៉ុកថាញ់ ជានាយក-រដ្ឋមន្ត្រី !

★ ប្រវត្តិសង្ខេបរបស់លោកសឺង-ង៉ុកថាញ់ !

## ប្រតិកម្មលោកសឺង-ង៉ុកថាញ់ក្រោយព្រឹត្តិការណ៍១៨មិនា៧០

លោកសឺង-ង៉ុកថាញ់ជាអ្នកបង្កើតចលនាខ្មែរសេរី ។ ដំណាក់កាលជាដំបូងនៃចលនាខ្មែរសេរី គឺការពារប្រជាជនខ្មែរភាគតិចដែលរស់នៅរប៉ាត់រប៉ាយឥតទីពឹងដូចជាខ្មែរកម្ពុជាក្រោមជាដើម ។ ក្នុងឆ្នាំ១៩៧០ ចលនាខ្មែរសេរីមានកងទ័ពចំនួន៣ម៉ឺននាក់ ។ ក្រោយព្រឹត្តិការណ៍ថ្ងៃ១៨មិនា៧០, លោកសឺន-ង៉ុកថាញ់ទទួលពត៌មានដ៏ច្បាស់ការណ៍ថា ប្រទេសខ្មែរកើតសង្គ្រាម គឺបូជួយជាច្រើនម៉ឺននាក់ប្រើឃីហោខ្មែរក្រហម នៅលើដើមទ្រូងពាក់រូបស្តេចសីហនុស្រែកជយោសម្តេចឪ រួចលោតវាយកំទេចសម្លាប់ខ្មែរលន់-នល់ដែលជាម្ចាស់ទឹកដីពិតៗ ។

ស្រាប់តែនៅថ្ងៃ២៧-៨-៧០, លោកសឺន-ង៉ុកថាញ់ទទួលពត៌មានច្បាស់ការណ៍មកទៀតថា បូជួយចេញមុខពេញទីវាយកំទេចសម្លាប់ខ្មែរ ។ នៅឈើខ្មៅខេត្តកណ្តាល បូជួយរុករានចូលយ៉ាងលឿនធ្លាយមកដល់តាខ្មៅរហូតដល់ក្បាលថ្នល់ ។ល។ ដូច្នេះលោកសឺន-ង៉ុកថាញ់សំរេចជាបន្ទាន់ត្រូវតែបញ្ជូនកងទ័ពខ្មែរ ដើម្បីជួយការពារទឹកដី ។ បញ្ជូនលើកទីមួយនៅថ្ងៃទី៣០-៨-៧០ ។ បន្ទាប់មកលោកទទួលពត៌មានមកថា នៅថ្ងៃទី១៥-៦-៧០ បូជួយជាច្រើនម៉ឺនក្បាលចេញមុខវាយកំទេចសម្លាប់ខ្មែរនៅខេត្តកំពង់ធំ ។ ពេលនោះច្បាំងទល់តួនឹងកងទ័ពជាតិខ្មែរ ។ ដូច្នេះលោកសឺន-ង៉ុកថាញ់បញ្ជូនកងទ័ពខ្មែរដើម្បីជួយការពារទឹកដីម្តងទៀត ។ បញ្ជូនលើកទី២នៅថ្ងៃទី៣០-៦-៧០ ។

បន្ទាប់មកទៀត, លោកតាមដានសង្កេតដឹងច្បាស់ថាសង្គ្រាមក្នុងស្រុកខ្មែរគឺយួនជាវៀតកុងវាយកំទេចសម្លាប់ខ្មែរសាហាវជាងសាហាវ លោកឈប់រារែក

លោកសំរេចធ្វើពលិកម្មលប់ចលនាខ្មែរសេរី រួចលោកប្រមូលកងទ័ពខ្មែរសេរីទាំងអស់បញ្ជូនចូលកាន់ស្រុកខ្មែរជាលើកទី៣នៅថ្ងៃទី៩-៩-៧០ ប្រគល់ជូនលោកលន់-នល់ រួចសំរេចដាក់ឈ្មោះថា « ម៉ែកហ្វ៉ក » ( MIKE FORCE ) ។

បើយើងប្រៀបធៀបលោកសឺន-ង៉ុកថាញ់និងលោកលន់-នល់លោកទាំងពីរនេះមានបុកពារប្រហាក់ប្រហែលគ្នា ។ លោកសឺន-ង៉ុកថាញ់ជាមនុស្សហ្លឹងហ្លួរ មិនចេះខឹងច្រឡោត លោកនិយាយតិចប៉ុន្តែមានន័យទូលំទូលាយ លោកមិនចំណាយពេលលេងសើច លោកមិនដែលប្រព្រឹត្តអ្វីឲ្យខូចប្រយោជន៍ជាតិឡើយ ។ ក្នុងមួយជីវិតរបស់លោក លោកធ្វើពលិកម្មលះបង់កិច្ចការផ្ទាល់ខ្លួនដើម្បីជាតិជានិច្ច ។

ប្រទេសកម្ពុជាយើងជំនាន់នោះ មានលោកសឺន-ង៉ុកថាញ់ខំការពារកសាងជាតិពីបាតដៃទទេនៅក្រៅប្រទេស ។ លោកទាំងពីរនាក់ជាវីរជនខ្មែរ មានសតិសម្បជញ្ញៈស្នេហាជាតិពិតៗ ។ លោកទាំងពីរនាក់គ្មានគំនិតរើសរវាយចង់ដឹកនាំប្រទេសជាតិនិងរាស្ត្រខ្មែរឲ្យចុះញ៉មធ្វើជាខ្ញុំកញ្ជះបរទេសណាមួយទេ ! ។

គួរឲ្យស្តាយណាស់ ព្រឹត្តិការណ៍ថ្ងៃទី១៨មិនា៧០កើតឡើងយឺតពេលណាស់ទៅហើយ, ព្រោះពេលនោះបូជួយកាន់កាប់ទឹកដីខ្មែរអស់ចំនួន២ភាគ៣ទៅហើយ ។ ឧទាហរណ៍ដូចជាយើងរង់ចាំទឹកជំនន់ ឡើងលិចដំបូលផ្ទះទៅហើយទើបនាំគ្នាប្រវេប្រវារកទីជំរក ក៏ក្លាយដល់នូវសេចក្តីវិនាសហិនហោចដល់ទីសង្ឃឹមតែម្តង ។

នៅខែមិនា១៩៧២, លោកសេនាប្រមុខលន់-នល់ចាត់តែងតាំងលោកសឺន-ង៉ុកថាញ់ជានាយករដ្ឋមន្ត្រី ។

នៅខែកញ្ញា១៩៧០ លោកសឺន-ង៉ុកថាញ់មានបើកអង្គប្រជុំមួយនៅទីក្រុងពោធិសាត់ លោកខំពន្យល់រាស្ត្រខ្មែរអោយយល់នូវសង្គ្រាម ដែលកំពុងកើតឡើងយ៉ាងស៊ីសាច់ហុតឈាមគ្នាយ៉ាងនេះ គឺយើងច្បាំងជាមួយអាទមិឡដែលជាយួនវៀតកុង មូលហេតុនេះទើបលោកសំរេចលប់ចលនាខ្មែរសេរី រួចលោកប្រមូលកងទ័ពខ្មែរសេរីទាំងអស់នាំយកមកប្រគល់ ជូនលោកសេនាប្រមុខលន់-នល់ដើម្បីការពារទឹកដីខ្មែរវិញ ។

ពេលនោះមានសាស្ត្រាចារ្យម្នាក់ ក្នុងនាមរាស្ត្រខ្មែរខេត្តពោធិសាត់ ក្រោកឡើងសុំសួរលោកសឺន-ង៉ុកថាញ់ថា ហេតុដូចម្តេចបានជាលោកមិនឈរឈ្មោះជាបេក្ខជនប្រធានាធិបតី ?

លោកសឺន-ង៉ុកថាញ់ញញឹមព្រមទាំងឆ្លើយពន្យល់វែកញែកថា ៖ អ្នកស្នេហាជាតិមិនមែនមានតែលោកប្រធានាធិបតីទេ ! អ្នកការពារកសាងជាតិក៏មិនមែនមានតែប្រធានាធិបតីដែរ ! គឺត្រូវមានយើងរាល់គ្នារួបរួមសាមគ្គីយ៉ាងស្មោះត្រង់អស់ពីដួងចិត្ត ជួយលោកទើបអាចការទឹកដីជាតិសាសនាបានគង់វង់... « ដូចមានពាក្យ

បូរាណាមួយដែលបានចែងថា អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន... » ។

លោកសឺន-ង៉ុកថាញ់បញ្ជាក់បន្ថែមថា ៖ ខ្លួនរបស់លោកនិងលោកសេនាប្រមុខលន់-នលដូចមនុស្សតែម្នាក់ ។ លោកសេនាប្រមុខហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីការពារទឹកដី ជាតិ សាសនានៅក្នុងប្រទេស... ចំណែកលោកៗស្ម័គ្រចិត្តបំពើនៅក្រៅប្រទេស ។ នៅឆ្នាំ១៩៧២, យួនហាណូយបញ្ជាបូដូយឲ្យវាយកំទេចបំផ្លាញស្រុកខ្មែរដោយយកលេស ថាចូលមកជួយសម្តេចសីហនុ ។ ដូច្នេះលោកត្រូវតែធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីជួយលោកសេនាប្រមុខលន់-នល់ ការពារជាតិ ទឹកដី និងសាសនា ។

លុះលោកសឺង-ង៉ុកថាញ់ថ្លែងចប់នូវពាក្យពេចន៍ដ៏មានខ្លឹមសារនេះហើយ ប្រជារាស្ត្រខ្មែរទះដៃព្ទកងរំពង សរសើរមិនដាច់ពីមាត់ កេរ្តិ៍ឈ្មោះរបស់លោកព្ទល្បីសុះសាយ ញាំងឲ្យនាម៉ឺនពុករលួយដែលអង្គុយចាំតែអេតាមខ្យល់នៅជុំវិញលោកសេនាប្រមុខ ទាស់ចិត្ត មានសេចក្តីបារម្ភ និងច្រណែនឈ្នានិស ។

ពួកនេះក៏បង្កើតឃាតករអាថ៌កំបាំងមួយក្រុមឲ្យតាមសម្លាប់លោក ។ ថ្ងៃមួយក្រុមឃាតករលបពួនក្បែរវាំងខាងកើតវាលមេរុ លួចបាញ់សម្លាប់លោក តែគ្រាប់កាំភ្លើងក៏ជ្រលួសទៅត្រូវអង្គរក្សរបស់លោកស្លាប់ភ្លាមនៅនឹងកន្លែង ។ លុះលោកត្រឡប់មកកាន់ទីលំនៅរបស់លោកវិញ យប់នោះលោកអង្គុយបញ្ឈរជង្គង់ យកដៃទ្រចង្កាទល់ភ្លឺ ។ លោកស្រមៃឃើញឡើងវិញនូវអនុស្សាវរីយ៍ទាំងអស់ ដែលលោកខំធ្វើពលិកម្មដើម្បីកម្ពុជាឯករាជ្យ ដូចកាលពីឆ្នាំ១៩៤៣ លោកមានសេចក្តីក្លាហានដឹកនាំព្រះសង្ឃនិងរាស្ត្រខ្មែរ ធ្វើបាតុកម្មដេញបារាំង ជាហេតុធ្វើឲ្យបារាំងរកចាប់ខ្លួនលោក លោកក៏រត់គេចទៅជ្រកសំណាក់នៅឯប្រទេសជប៉ុន ។

នៅថ្ងៃទី៩-៥-១៩៤៥ លោកបានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ ។ ថ្ងៃទី៦-១០-១៩៤៥ ស្តេចសីហនុយល់ព្រមឲ្យបារាំងចាប់ខ្លួនលោក ទៅកាន់ខេត្តព័រទៀរនៃប្រទេសបារាំង អស់រយៈពេល៦ឆ្នាំ ។ នៅថ្ងៃទី២០-១០-១៩៥១ បារាំងប្រគល់សេរីភាពឲ្យលោក លោកក៏វិលត្រឡប់ចូលមកកាន់ប្រទេសកម្ពុជាម្តងទៀត ។ មកដល់មាតុភូមិភ្លាម លោកបង្កើតសារពត៌មានមួយឈ្មោះ « ខ្មែរក្រោក » ដើម្បីដាស់តឿនរាស្ត្រខ្មែរឲ្យក្រោកឡើងរួបរួមចងបាច់គ្នាដេញបារាំង ។ ក្រោយនោះមកបន្តិច ក្រុមរាជវាំងឃុបឃិតជាមួយបារាំងបីទកាសែតនោះ រួចគេបំរុងចាប់ខ្លួនលោកម្តងទៀត ។ លោកដឹងខ្លួនទាន់ក៏រត់ភៀសខ្លួនទៅកាន់ភ្នំដងរែក នៅថ្ងៃទី៩-៣-១៩៥២ ចូលរួបរួមជាមួយក្រុមខ្មែរឥស្សរៈ ដើម្បីវាយកំទេចដេញបារាំងទាមទារកម្ពុជាឯករាជ្យ ។

ប្រទេសកម្ពុជាបានឯករាជ្យបរិបូណ៌នៅថ្ងៃទី៩-១១-១៩៥៤ លោកសឺង-ង៉ុកថាញ់រៀបចំខ្លួនចូលមករួបរួមក្នុងសង្គមជាតិដែរ ប៉ុន្តែស្តេចសីហនុជឿអាម៉ីអាថោងជិទាស់មិនទទួល ។

លោកញញឹមដើរចាកចេញពីកម្ពុជា ទុកឲ្យអស់លោក ។ លោកមានវិចារណ-ញ្ញាណគិតដល់អនាគតនៃប្រជាជនខ្មែរភាគតិច ដែលរស់នៅរប៉ាត់រប៉ាយក្នុងប្រ-ទេសសៀម និងមួយភាគធំនៅកម្ពុជាក្រោមឯណោះ ដូចកូនកំព្រា ។ ដូច្នេះកាលណោះ ជួនកាលលោកសំណាក់នៅកម្ពុជាក្រោម ដើម្បីរកមធ្យោបាយជួយការពារប្រជាជនខ្មែរកំព្រាអស់ទាំងនោះ ។

លុះដល់ឆ្នាំ១៩៥៨ ទើបលោកចាប់ផ្តើមបង្កើតចលនាខ្មែរសេរី ពីបាតដៃទទេគ្មានអ្វីជាធនធានទាល់តែសោះ ។ លោកមានសេចក្តីក្លាហានធ្វើពលិកម្មគ្រាប់បែបយ៉ាង សំអាងទៅលើសេចក្តីស្នេហាជាតិដ៏មុតដែលចេញពីបេះដូងដ៏ស្មោះត្រង់ពិតប្រាកដរបស់លោកជាគំរូតែប៉ុណ្ណោះ ។

ជាដំបូងមានគ្នាតែ១៨០នាក់... បន្តៗមកលោកបង្កើតបានកងទ័ពខ្មែរសេរីនៅប្រទេសថៃបានជាច្រើនរយនាក់... លុះក្រោយមកលោកយល់ថា ស្ថានការណ៍រវាងថៃនិងខ្មែរ គ្មានអ្វីគួរឲ្យព្រួយបារម្ភទេ លោកក៏ចេញបញ្ជាឲ្យមេកងទ័ពខ្មែរសេរីនៅប្រទេសថៃនាំកងទ័ពទាំងអស់ សុំចុះចូលរាជការភ្នំពេញចុះ ។ ចំណែកលោកលោកខំប្រឹងពង្រឹងពង្រីកកងទ័ពខ្មែរសេរីស្ថិតនៅកម្ពុជាក្រោម ឲ្យបានរឹងប៉ឹងនិងស្និតស្នាញ ។ កាលណោះ ទោះស្តេចសីហនុស្រែកជេរប្រទេចតាមវិទ្យុចោទថាក្បត់យ៉ាងណា ក៏លោកសឺង-ង៉ុកថាញ់មិនដែលឆ្លើយតបទាល់តែសោះ ។

នៅពេលណាដែលអ្នកកាសែតសួរលោក លោកឆ្លើយថា ÷ អ្នកស្នេហាជាតិមិនចាំបាច់អួតអាងទេ... យើងខំតែធ្វើការឲ្យស្មោះត្រង់ចំពោះជាតិ មុខជាភ្នែកនៃប្រជាជនខ្មែរសម្លឹងឃើញ... គេអាចយល់, គេនឹងគាំទ្រ, គេនឹងឆ្លើយជំនួសយើងជាមិនខាន ។

លោកសឺង-ង៉ុកថាញ់នឹករឿងអតិតកាលដល់ត្រឹមណោះ លោកក៏គ្រវីក្បាលដំអូញថា «ឱបងប្អូនខ្មែរអើយ ! ដំណាក់ការយ៉ាងនេះទៅហើយ ចរិតនៅដដែល! » ។

មើលចុះលើកទី១ លោកខំតស៊ូគ្រប់បែបយ៉ាង លុះត្រាតែកម្ពុជាបានឯករាជ្យដ៏បរិបូណ៌ ។ ដោយសារតែចរិតច្រណែននិន្ទាឈ្នានិសគ្នា ទើបលោកត្រូវចាកចេ-ញចោលប្រទេសកម្ពុជា រហូតដល់លោកបង្កើតបានចលនាខ្មែរសេរី ។

ឥឡូវនេះប្រទេសខ្មែរកំពុងត្រូវរងគ្រោះយ៉ាងធ្ងន់ក្រៃលែង ព្រោះគូបដិបក្ខដែលត្រូវវាយកំទេចប្រទេសខ្មែរ គឺយួនហាណូយដែលរង់ចាំឱកាសនេះយូរហើយដើម្បីប្រើយីហោខ្មែរក្រហម ដោយយកលេសថា មកជួយស្តេចសីហនុ ។

ឱទេវតាអើយ ! ធ្វើយ៉ាងដូចម្ដេចទៅ ? តែដើម្បីជីវិតរបស់លោក លោកត្រូវតែចាកចេញពីប្រទេសកម្ពុជាម្ដងទៀតជាដាច់ខាត ។

ព្រឹកស្អែកលោកសឺង-ង៉ុកថាញ់ក៏ចូលទៅជួបលោកសេនាប្រមុខលន់-នល់ សុំលាឈប់ចេញពីមុខដំណែងនាយករដ្ឋមន្ត្រីទី១ ។ លោកបន្សល់កងទ័ពខ្មែរសេរីទាំងអស់ចំនួន៣ម៉ឺននាក់ ដែលលោកខំតស៊ូខំបង្កើតយ៉ាងលំបាក ទុកឲ្យនៅជួយប្រទេសខ្មែរ ។ លោកសុំផ្ដាំនិងពន្យល់លោកសេនាប្រមុខថា ៖ « កងទ័ពខ្មែរសេរីមានសតិសម្បជញ្ញៈស្នេហាជាតិពិតៗ គឺតាំងពីកកើតឡើងស្ម័គ្រចិត្តបំរើជាតិមិនដែលទាមទារប្រាក់ខែ មិនពុករលួយទេ មានសាមគ្គីយ៉ាងរមួត ។ ក្រុមនេះដូចសត្វខ្លា ប៉ុន្តែមិនដែលស្គាល់ឬស៊ីសាច់ទេ ! ត្រូវប្រយ័ត្នកុំបង្អាប់ឲ្យខ្លានេះស៊ីសាច់ ! ។ ជាពិសេសលោកធំៗជាមេបញ្ជាការ ត្រូវមានយុត្តិធម៌ ត្រូវស្គាល់តម្លៃក្រុមនេះ ។ ព្រោះក្រុមនេះមានឫកពាឆ្មើង មិនចេះលុតក្រាប មិនចេះអែបអប មិនចេះបញ្ចើចបញ្ចើទេ ប៉ុន្តែផ្នែកវាយសឹកមានការពិសោធន៍យ៉ាងគ្រប់គ្រាន់ ស្ទាត់ជំនាញ រឹងប៉ឹងព្រមទាំងស្គាល់ច្បាស់លាស់នូវកលល្បិចខ្មាំង គឺបួដួយ ។ ក្រុមនេះចេះបំពេញករណីកិច្ចនិងភារៈកិច្ចយ៉ាងពេញលេញ ដឹងច្បាស់ថាខ្លួនជាទាហាន ត្រូវតែកំទេចខ្មាំងដើម្បីការពារជាតិ ទឹកដី និងសាសនា ។

ជាសរុបសេចក្ដីទៅ បើមេបញ្ជាការចេះដឹង គេអាចនឹងទទួលផលដ៏គាប់ប្រសើរបាន » ។

លោកសឺង-ង៉ុកថាញ់ផ្ដាំផ្ញើសព្វគ្រប់រួចហើយ លោកក៏ឱបលោកសេនាប្រមុខលន់-នល់ សុំលាទៅកាន់ប្រទេសវៀតណាមខាងត្បូង គឺកម្ពុជាក្រោម ។ លោកចាកចេញពីប្រទេសកម្ពុជា ចាកចេញពីលោកសេនាប្រមុខលន់-នល់ ចាកចេញពីកងទ័ពខ្មែរសេរីរបស់លោកចំនួន៣ម៉ឺននាក់ ទៅតែបាតដៃទទេជាមួយអង្គរក្សរបស់លោកឈ្មោះថាច់-ទឿង នៅខែតុលាឆ្នាំ១៩៧២ ។

❑ ❑

❑

# ជំពូកទី៧

★ ប្រតិកម្មពីប្រជាពលរដ្ឋខ្មែរក្រោយព្រឹត្តិការណ៍១៨មិនា៧០ !
★ រាជការខ្មែរមិនអើពើនឹងជីវភាពរាស្ត្រ !
★ អំពើពុករលួយផ្នែកកងទ័ព !
★ ការសម្លាប់លោកថាច់-ជា !
★ លោកសុទ្ធ-ប៉ូលិនត្រូវរត់ចោលស្រុក !

## ប្រតិកម្មពីប្រជាពលរដ្ឋខ្មែរក្រោយព្រឹត្តិការណ៍១៨មិនា៧០!

នៅថ្ងៃទី១៨-៣-១៩៧០ វេលាម៉ោង១រសៀល ប្រជាពលរដ្ឋខ្មែរគ្រប់ជាន់ថ្នាក់គ្រប់វណ្ណៈ មានការភ្ញាក់រំភើបញ្ជាប់ញ័រមួយភ្លែត ព្រោះមិនស្មានទាល់តែសោះថាប្រទេសខ្មែរបែរទៅជាមានព្រឹត្តិការណ៍ទម្លាក់សម្ដេចសីហនុ ពីតំណែងប្រមុខរដ្ឋយ៉ាងនេះ ។

ប៉ុន្តែរាស្ត្រខ្មែរចូលចិត្តរស់នៅដោយស្ងប់ស្ងៀម មិនចេះក្បត់ ឬរិះគន់លោកធំៗ ដែលជាមេដឹកនាំប្រទេសជាតិទេ ។ មេៗដឹកនាំចង់ធ្វើអ្វីក៏ធ្វើទៅចុះ ព្រោះប្រជារាស្ត្រខ្មែរភាគច្រើនមិនយកចិត្តទុកដាក់ខាងផ្នែកនយោបាយឡើយ ។ រាស្ត្រនិងនាម៉ឺនមិនសូវមានការទាក់ទងជិតដិតរវាងគ្នានិងគ្នាទេ ។

មើលចុះ ! គ្រួសារណាមានកូនពី១០ទៅ១៨នាក់ក៏ដោយ... ចិញ្ចឹមខ្លួនឯងចុះ ! រាជការគ្មានអើពើនឹកនាឧបត្ថម្ភអ្វីទេ ។ គ្រួសារណាចង់ឲ្យកូនរៀន នាំទៅចុះ... គ្រួសារណានាំកូនទៅស៊ីឈ្នួល ឬនាំទៅលក់ឲ្យធ្វើខ្ញុំកញ្ជះគេ ក៏នាំទៅចុះ ។ បើកូនឈឺគ្រួសារអ្នកមានទ្រព្យនាំកូនទៅរកពេទ្យឈ្នួលដោយខ្លួនឯង ចំណែកឯគ្រួសារអ្នកក្រខ្សត់ ចិញ្ចឹមកូនរស់ដោយផ្សងព្រេងសំណាងទាំងអស់, រាជការគ្មានអើពើឡើយ ។ ដូច្នេះរាស្ត្រខ្មែរដែលសុចរិត គិតតែពីប្រកបរបរកសិកម្ម គឺកាប់គាស់ដាំដុះ ដើម្បីរកភោគផលមកចិញ្ចឹមគ្រួសារតាមយកថាកម្មតែប៉ុណ្ណោះ ។

មូលហេតុនេះ ពេលរាស្ត្រខ្មែរទទួលដំណឹងថាលោកលន់-នល់ទម្លាក់សម្ដេចសីហនុ ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ដែលរស់នៅក្នុងតំបន់សាធារណរដ្ឋ មាន

ការសោកស្តាយសម្តេចតែមួយភ្លែតប៉ុណ្ណោះ រួចហើយក៏បំភ្លេចទៅ ។ គ្រប់ៗគ្នាមានលំនឹងនឹងនរ ខំកាប់គាស់ដាំដុះ ខំរស់ស៊ីចិញ្ចឹមគ្រួសារវិញទៅ ។

ម្យ៉ាងវិញទៀត ប្រជាពលរដ្ឋខ្មែរស្គាល់លោកលន់-នល់យ៉ាងច្បាស់លាស់ មានសេចក្តីសង្ឃឹមនិងទុកចិត្តលើលោក ។

លោកជាវីរជនដ៏ស្អាតស្អំ, លោកមានសតិសម្បជញ្ញៈស្នេហាជាតិ, លោកស្មោះត្រង់ចំពោះជាតិ, លោកថែមទាំងគិតចង់រំដោះកម្ពុជាក្រោមទៀតផង។ លោកមិនចេះអួតអាង មិនចេះខឹងច្រឡោត លោកមិនសូវបានរោះហាទេ ។

លោកមានដើមកំណើតពីរាស្ត្រធម្មតា មុខជាលោកនាំមកនូវយុត្តិធម៌ជូនរាស្ត្រខ្មែរជាមិនខាន ។ ប៉ុន្តែជារឿងគួរឲ្យស្តាយណាស់ ព្រោះព្រឹត្តិការណ៍ថ្ងៃ១៨មិនា ១៩៧០ វាយឺតពេលណាស់ទៅហើយ, យួនហាណូយជាវៀតកុងបានកាន់កាប់ទឹកដីខ្មែរអស់២ភាគ៣រួចទៅហើយ ។ ម្យ៉ាងវិញទៀតពេលលោកលន់-នល់ឡើងជាមេដឹកនាំខ្មែរ រូបលោកត្រូវរោគាពាធបៀតបៀនយ៉ាងធ្ងន់ មិនអនុញ្ញាតឲ្យលោកបំពេញករណិយកិច្ចបានដិតដល់ ឲ្យបានពេញលេញ បណ្តាលឲ្យក្រុមនាម៉ឺនពុករលួយឆ្លៀតឱកាសព័ទ្ធលោកជុំជិត ។ រីឯលោកអ្នកស្អាតស្អំមិនអាចចូលជួបលោកជំរាបការពិតបានឡើយ ។ បើលោកអ្នកណាហ៊ានចូលជួបជំរាបការពិត គឺត្រូវក្រុមវាសម្លាប់ មានឧទាហរណ៍ខ្លះៗដូចតទៅ ៖

មានវរសេនិយទោម្នាក់ឈ្មោះ ដាញ់-ដួ ជាតិខ្មែរកម្ពុជាក្រោម ។ លោកជាចៅហ្វាយស្រុកត្រាកូវ ខេត្តត្រាវិញ កម្ពុជាក្រោម ។ លោកដឹងនិងយល់ច្បាស់ថា សង្គ្រាមក្នុងស្រុកខ្មែរពេលនេះ គឺដើមហេតុបណ្តាលមកពីយួនហាណូយជាវៀតកុងវាអនុវត្តតាមបណ្តាំខ្មោចហូ-ជីមិញដែលថា ៖ « ត្រូវតែព្យាយាមយកទឹកដីកម្ពុជាដើម្បីពង្រីកបក្សកុម្មុយនិស្តឥណ្ឌូចិន » ។ ដូច្នេះលោកវរសេនិយទោសុខចិត្តរត់ចោលមុខតំណែង រត់ចោលបុណ្យស័ក្តិដ៏ឧត្តុងឧត្តម លះបង់ចោលគ្រួសារ ស្ម័គ្រចិត្តបូជាជីវិត ធ្វើពលិកម្មមកជួយរំដោះទឹកដីខ្មែរ ។ កាលណោះលោកសេនាប្រមុខលន់-នល់ទទួលលោកយ៉ាងរីករាយ ព្រមទាំងបំពាក់ស័ក្តិដដែលជូនលោកវិញ ប្រែឈ្មោះជា ដាញ់-វឌ្ឍនា រួចចាត់តែងតាំងលោកជាមេបញ្ជាការកងវរសេនាធំ ។ លោកដាញ់-វឌ្ឍនាស្ម័គ្រចិត្តនាំទ័ពចេញទៅទប់ទល់ចំពោះខ្មាំងជានិច្ច ។ លោកល្បីឈ្មោះពីរឿងតតបចំពោះខ្មាំង ទទួលជ័យជំនះដ៏គាប់ប្រសើរ ។ កាលណោះខ្មាំងគឺយួនហាណូយជាប្ញដ្ឋយប្រើឃីហោខ្មែរក្រហម ។

កេរ្តិ៍ឈ្មោះលោកដាញ់-វឌ្ឍនាញ៉ាំងឲ្យមេទ័ពដែលពាក់ស័ក្តិពេញលើស្មា អង្គុយតែក្នុងការិយាល័យចាំរេតាមខ្យល់ កើតក្តីច្រណែនឈ្នានិស ។

មានថ្ងៃមួយ, កងទ័ពរបស់លោកដាញ់-វឌ្ឍនាកំពុងជាប់ដៃស្និតវាយជាមួយបូដួយនៅជួរភ្នំប្រសិទ្ធិ ពេលនោះកងទ័ពជិតអស់គ្រាប់ លោកធ្វើដំណើរចូលកាន់រដ្ឋធានីភ្នំពេញ ដើម្បីសុំបន្ថែមគ្រាប់រំសេវ ។ ស្រាប់តែលោកធំទទួលខុសត្រូវខាងគ្រឿងសាស្ត្រាវុធ បែរជាទារថ្លៃទឹកតែសិន... មានពាក្យចចាមអារាមថា ទារ៥០ម៉ឺនរៀល ។ លោកដាញ់-វឌ្ឍនាភ្ញាក់សឹងតែសន្លប់ ព្រោះលោកពុំដឹងជាទៅរកលុយដ៏ច្រើនលើសលប់នេះនៅឯណា ។ លោកឈរឱបដៃគិតថា គួរឲ្យឈឺចិត្តណាស់... លោកខំប្តូរជីវិតមកជួយកម្ពុជា សុខចិត្តលះបង់ចាកចោលគ្រួសារ មុខងារនិងបុណ្យស័ក្តិពិតៗ មកពាក់ស័ក្តិវរសេនិយទោ ដែលនៅស្រុកខ្មែរជាស័ក្តិគេទិញពាក់ព្រោងព្រាតដើរពេញតែផ្សារ ។ នឹកឃើញសព្វគ្រប់ លោកមួម៉ៅក៏ទះកំភ្លៀងឧត្តមសេនិយម្នាក់ដែលជាអ្នកទទួលខុសត្រូវបរិក្ខាទាំងនោះ ព្រមទាំងបញ្ជាក់ថា ៖ នេះ ៥០ម៉ឺនរៀលទទួលយកសិនចុះ ! ។

លោកដាញ់-វឌ្ឍនាអភ័ព្វមានរឿងដដែលៗ២ដងទៀត ។ បន្ទាប់ពីរឿងទី៣ លោកក៏បានទទួលលិខិតមួយច្បាប់ពីការិយាល័យប្រមុខរដ្ឋ ដែលមានហត្ថលេខាផ្ទាល់ដៃរបស់លោកសេនាប្រមុខផង បញ្ឈប់ផ្អាកលោកមិនឲ្យធ្វើការតទៅទៀត ។

កាលណោះក្នុងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ កងទ័ពដែលមានចំនួនគ្រប់ត្រឹមត្រូវ ដោយគុណបំណាច់សង្គ្រាម ដែលបានទទួលការអប់រំផ្នែកយុទ្ធសាស្ត្រយ៉ាងត្រឹមត្រូវ ចេះចាត់ចែងមានទម្រង់ប្រសើរ មានការពិសោធន៍ដ៏គ្រប់គ្រាន់ ដែលល្បីចេះច្បាំងតទល់ចំពោះខ្មាំង ព្រមទាំងស្គាល់កលល្បិចខ្មាំង ជាពិសេសស្គាល់និងគោរពករណីយកិច្ច ៖ គឺយល់ថាធ្វើទាហានត្រូវហ៊ានពលិកម្មជីវិត ដើម្បីការពារជាតិ ទឹកដី សាសនា ព្រមទាំងមានស្មារតីរឹងប៉ឹង តស៊ូស្វិតស្វាញ គឺកងទ័ពម៉ែកហ្វ័ក្សអតីតកងទ័ពខ្មែរសេរី ដែលមានចំនួន៣ម៉ឺននាក់, ហ៊ានលះបង់ចោលគ្រួសារ ស្ម័គ្រចិត្តធ្វើពលិកម្មបូជាសាច់ឈាមមកជួយការពារប្រទេសកម្ពុជា មានកេរ្តិ៍ឈ្មោះល្បីល្បាញអស្ចារ្យ ទទួលជោគជ័យសឹងគ្រប់សមរភូមិ គួឲ្យមានសង្ឃឹម ។ កងទ័ពនេះមានកំហុសមួយតូចគឺមិនចេះលុតក្រាប អែបអប បញ្ចើចបញ្ចើរ តែគោរពករណីយកិច្ចកំទេចខ្មាំងគឺយួនបូដួយ ដើម្បីការពារទឹកដី ជាតិ សាសនាតែប៉ុណ្ណោះ ។

មូលហេតុនេះញ៉ាំងឲ្យមេទ័ពនៅកម្ពុជាកណ្តាលមិនពេញចិត្ត ថែមទាំងកើតសេចក្តីច្រណែន ។ មើលចុះកងទ័ពម៉ែកហ្វ័ក្សជាប់ដៃស្និតកំពុងកំទេចខ្មាំង ជិតអស់គ្រាប់រំសេវ ក៏ចាត់តំណាងចូលកាន់រដ្ឋធានីភ្នំពេញសុំជំនួយ ស្រាប់តែអស់លោកដែលជាអ្នកទទួលខុសត្រូវផ្នែកបរិក្ខាទាំងនោះ បែរជាទារថ្លៃទឹកតែ៥០ម៉ឺនរៀលទៅវិញ ។ មើលចុះ ! គេចាប់ផ្តើមបង្គាប់ខ្លាឲ្យចេះស៊ីសាច់ហើយ ! ។

បញ្ហាដ៏ស្មុគស្មាញរបៀបនេះកើតមានលើងជាញឹកញាប់ ទើបមានលោកវរសេ

និយទោដ៏ក្មេងម្នាក់ឈ្មោះ <ថាច់-ជា> លោកអត់ទ្រាំមិនបាននឹងអំពើអយុត្តិធម៌អស់ទាំងនេះ ។ លោកក៏ចូលទៅកាន់ការិយាល័យបរិក្ខាទាំងនោះ ហើយហ៊ានស្តីបន្ទោសឧត្តមសេនិយខ្លះដែលជាអ្នកទទួលខុសត្រូវ ។ ព្រឹកស្អែកលោកក៏ប្រថុយជីវិតចូលទៅជួបលោកសេនាប្រមុខលន់-នល់ ដើម្បីរាយការណ៍ជំរាបរឿងទាំងអស់នេះ ។ ឆ្លៀតឱកាសជំរាបបន្ថែមពីរឿងទំនិញនានាឡើងថ្លៃពី១ទៅ១០០ ទើបលោកដឹងថាកងវរសេនាតូចនិមួយៗ មានតែមេទាហានចំណែកឯកូនទាហានមិនគ្រប់ចំនួនទេ ។ ក្រោយបន្តិចមក ដោយនាម៉ឺនពុករលួយមានគ្នាច្រើនលើសលប់ វាក៏ញុះញង់ឲ្យកូនសិស្សធ្វើបាតុកម្ម រកលេសផ្សេងៗ ដើម្បីវាយសម្លាប់លោកវរសេនិយទោដ៏ក្មេងនិងដ៏ក្លាហាននេះ ។ ពួកវាបានសំរេចគំរោងការណ៍ ដោយសម្លាប់លោកបាននៅកណ្តាលទីក្រុងភ្នំពេញនាថ្ងៃទី៤ មិថុនា ឆ្នាំ១៩៧៤ រួចហើយវាបោះខ្មោចលោកវរសេនិយទោចោលទៅក្នុងទន្លេបួនមុខទៅ ។

លោកវរសេនិយទោ ថាច់-ជា ត្រូវពួកនាម៉ឺនពុករលួយសម្លាប់បាត់ទៅ រីឯបងប្អូនមិត្តភក្តិរបស់លោកមិនហ៊ានហើបមាត់ទេ ព្រោះខ្លាចអំណាចក្រុមពុករលួយតាមព្យាបាទ ។

ពេលនោះលោក សុទ្ធ-ប៉ូលិន ចាងហ្វាងកាសែតនគរធំ ( កកន ៖ លោកសុទ្ធប៉ូលិនត្រូវជាមិត្តភក្តិយ៉ាងជិតស្និទ្ធជាមួយលោកថាច់-ជា ហើយជាអ្នកបានដឹងរឿងរ៉ាវទាំងអស់នេះយ៉ាងច្បាស់លាស់ ) មានសេចក្តីក្លាហាន ធ្វើពលិកម្មសរសេរវែកញែកនូវឃាតកម្មដ៏សាហាវមិនដែលមានក្នុងប្រវត្តិសាស្ត្រ នៃស្នាដៃក្រុមនាម៉ឺនពុករលួយ ចុះក្នុងកាសែតនគរធំ លេខពិសេសមួយ ដែលមានច្រើនទំព័រ ។ ក្រុមពុករលួយយកការណ៍ដឹង វាចំរុងចាប់ខ្លួនលោក លោកក៏បញ្ចេញកាសែតលក់ផ្សាយមុនថ្ងៃកំណត់ រួចលោកចាកចេញពីស្រុករហូតមកដល់សព្វថ្ងៃនេះ ។

លោកថាច់-ជាត្រូវគេសម្លាប់បាត់ទៅ, លោកសុទ្ធ-ប៉ូលិនត្រូវរត់ចោលស្រុក, នាម៉ឺនស្អាតស្អំទៅជាគាំងមាត់គ្មានហ៊ានកំរើក ។ ក្រុមនាម៉ឺនពុករលួយក៏ព័ទ្ធលោកលន់-នល់យ៉ាងជុំជិត ។ តាំងពីពេលនោះមក លោកសេនាប្រមុខលែងបានទទួលពត៌មានអ្វីពិតទាល់តែសោះ ។ ក្រុមពុករលួយជាពិសេសផ្នែកកងទ័ពចាប់ផ្តើមធ្វើជំនួញ គឺលក់លេខកងវរសេនាតូច លក់បុណ្យស័ក្តិក្នុងឆ្នាំ១៩៧៤-១៩៧៥ គឺឧបមាបើមានមេបញ្ជាការណាម្នាក់ស្លាប់ គេចាត់ការលក់ឈ្មោះ ស័ក្តិ កងវរសេនាតូចនោះភ្លាម ។ នៅកាលណោះ តំណាងរាស្ត្រ សាស្ត្រាចារ្យ គ្រូបង្រៀន មេឃុំរត់ចោលកន្លែងបែរជាទៅទិញស័ក្តិពាក់ព្រោងព្រាត ។ តើពាក់ស័ក្តិនាំទាហានទៅកំចាត់ខ្មាំងឬ ?... ទេ ! ទេ ! មិនមែននាំទាហានទៅវាយខ្មាំងទេ ។

មើលចុះលោកមេបញ្ជាការទិញស័ក្តិពាក់ពេញលើស្មា រួចចាប់ចាត់ចែងធ្វើបញ្ជី

កូនទាហានដែលមានតែឈ្មោះ មានតែរូបថត គ្មានមនុស្សទេ ដើម្បីបើកលុយចេញពីឃ្លាំងយកទៅសងថ្លៃកងវរសេនាតូច សងថ្លៃស័ក្តិដែលខ្លួនបានទិញ...

មានលោកខ្លះពាក់ស័ក្តិពេញលើស្មា តែទៅអង្គុយរត់ពន្ធទៅវិញ ។ លុះអំពើពុករលួយគ្មានព្រំដែនក្នុងកងទ័ពកើតមានឡើងក្នុងរបៀបនោះ បណ្តាលឲ្យលុយកាក់កាន់តែថោកទៅៗ ព្រោះឈ្មួលចិនឆ្លៀតឱកាសនោះគិតតែពីពីតតម្លើងថ្លៃទំនិញក្រឹតៗ ។

ឧទាហរណ៍កាលពីឆ្នាំ១៩៧០ សាច់ជ្រូកមួយគីឡូថ្លៃ១២រៀល, គុយទាវមួយចានថ្លៃ៥រៀល, អង្ករមួយបាវទម្ងន់១០០គីឡូថ្លៃ៣០០រៀល ។ នៅឆ្នាំ១៩៧៥ សាច់ជ្រូកមួយគីឡូថ្លៃ១២៥០រៀល, គុយទាវមួយចានថ្លៃ៥០០រៀល, អង្ករមួយបាវទម្ងន់១០០គីឡូថ្លៃ៣៥,០០០រៀល ។ ដូច្នេះទំនិញទូទៅឡើងថ្លៃជាង១០០ដង ។ លោកលន់-នល់គ្មានដឹងអ្វីទាល់តែសោះ ។ ពេលនោះអ្នករដ្ឋការស្អាតស្អំស្លូតត្រង់ចំពោះជាតិ ដល់ពេលដាច់ពោះស្លាប់ ព្រោះប្រាក់ខែទិញតែអង្ករមួយបាវមិនគ្រប់ផង ។ គ្រប់ៗគ្នាឆ្លៀតពេលចិញ្ចឹមមាន់ ទា ជ្រូក ។

ចំណែកលោកធំៗដូចជាលោករដ្ឋមន្ត្រី លោកឧត្តមសេនិយ លោកវរសេនិយទោ លោកវរសេនិយឯក លោកវរសេនីយត្រី លោកសាស្ត្រាចារ្យ លោកវិស្វករ លោកវេជ្ជបណ្ឌិត និងគ្រូពេទ្យជាដើម ក្នុងក្របខ័ណ្ឌពិតៗដែលធ្វើការបំរើជាតិតាមបច្ចេកទេសរៀងៗខ្លួនយ៉ាងសុចរិតនោះ មិនអាចប្រព្រឹត្តនូវអំពើពុករលួយដូចនាម៉ឺនជំនាន់ថ្មី គឺលោតមិនទាន់គេ ក៏ធ្លាក់ទឹកចិត្តអស់សង្ឃឹម ក៏ដុះចិត្តរើរវាយ អង្គុយរង់ចាំរេតាមខ្យល់វិញ ។ គ្រប់ៗគ្នាយល់ច្រឡំយ៉ាងធ្ងន់ជាងធ្ងន់ថា របបណាក៏ដោយគេត្រូវការអ្នកចេះដឹង ដែលមានបច្ចេកទេសយ៉ាងគ្រប់គ្រាន់ ទោះបីសម្តេចសីហនុ ដែលមានលោកខៀវ-សំផនគាំទ្រដណ្តើមបានអំណាចពីលោកលន់-នល់វិលត្រឡប់មកគ្រប់គ្រងប្រទេសកម្ពុជាវិញក៏ដោយ កិច្ចការរដ្ឋត្រូវតែធ្លាក់មកលើក្រុមខ្លួនដដែល ។ មើលចុះ ! លោកធំៗទាំងនោះមិនដឹងខ្យល់ទាល់តែសោះ ការពិតសង្គ្រាមនេះមានគូបដិបក្ខអាថ៌កំបាំង គឺក្រុមអាតិតខ្មែរវៀតមិញ និងបូដួយជាច្រើនម៉ឺននាក់ ដែលបន្លំប្រើឃីហោខ្មែរក្រហម ឬប្រើឃីហោសម្តេចឪឯណោះទៅវិញទេ ។

មានលោកធំៗមួយភាគពេលនោះ ត្រូវទទួលវេរាគឺកម្មផល ព្រោះលោកធ្លាប់អង្គុយរេតាមខ្យល់ រួចបោកខ្មែរឥស្សរៈ មានលោកសឺង-ង៉ុកថាញ់, លោកដាប-ឈួន, លោកកៅ-តក់ជាដើម ។

មើលចុះ ! ពីឆ្នាំ១៩៤៥ដល់១៩៥៣ លោកដាប-ឈួននិងលោកកៅ-តក់ជាមេដឹកនាំខ្មែរឥស្សរៈ លោកទាំងពីរនាក់សំណាក់នៅតែក្នុងព្រៃ ត្រូវមុសទាកខាំ ខំតស៊ូ

ប្រឆាំងដេញបារាំង លុះត្រាតែនគរខ្មែរបានឯករាជ្យបរិបូណ៌នៅថ្ងៃទី៩-១១-៥៣ ។ នគរកម្ពុជាបានឯករាជ្យភ្លាម ក្រុមខ្មែរឥស្សរៈសុំចុះចូលក្នុងសង្គមខ្មែរដើម្បីកសាងកម្ពុជាថ្មីទាំងអស់គ្នា ។ ពេលនោះលោកធំៗដែលអង្គុយរង់ចាំរេតាមខ្យល់ ដែលចេះតែលុតក្រាប ក៏បានសំរេចទទួលជោគជ័យមែន ។ គ្រប់ៗគ្នាបានឡើងស័ក្តិ រួចបំភ្លេចគុណអ្នកតស៊ូ មិនចេះអត់ឱនអនុគ្រោះអប់រំគ្នា ដើម្បីទុកជួយការពារប្រទេសទៅអនាគតទេ បែរជាមានចរិតច្រណែនក្រេងគេល្បីជាងខ្លួន ក៏នាំគ្នាចោទអ្នកតស៊ូថាជាអ្នកក្បត់ជាតិ រួចហើយក៏លើកទ័ពទៅព័ទ្ធបាញ់សម្លាប់ចោលខ្ទេច ។

( រឿងគេព័ទ្ធបាញ់សម្លាប់លោកដាប-ឈួននៅឆ្នាំ១៩៥៩ ដោយចោទថាក្បត់នោះ ខ្ញុំមិនដឹងថាជារឿងពិតឬទេ... សូមបងប្អូនខ្មែរមេត្តាពិចារណាដោយខ្លួនឯងចុះ ប៉ុន្តែការពិតនោះ ដូចជារូបលោកសឺង-ង៉ុកថាញ់ក៏គេមិនឲ្យចូលស្រុកដែរ ) ។

ប៉ុន្តែខ្ញុំស្តាយអស់លោកទាំងនោះណាស់ ដែលបង្ករឿងឈ្លោះគ្នាតែជាមួយខ្មែរគ្នាឯង ដែលជាអ្នកបំរើខ្មែរពិតៗ ។ ចំណែកឯខ្មែរអាយ៉ងបំរើយួនហាណូយគឺអតិតខ្មែរវៀតមិញ ដែលជាសត្រូវស៊ីសាច់ហុតឈាមរបស់ខ្មែរ ដែលជាអ្នកសម្លាប់បំបាត់ពូជខ្មែរ គ្មានលោកធំខ្មែរទាំងអស់នោះមានសមត្ថភាពស្រាវជ្រាវរកឃើញ ឬធ្វើឲ្យក្រុមក្បត់ជាតិពិតៗនោះព្រឺរោមវាឡើយ ។

មើលចុះ ! ក្រោយសន្និសិទហ្សឺណែវក្នុងខែកក្កដាឆ្នាំ១៩៥៤ ដែលបានសំរេចឲ្យវៀតមិញដកថយចេញពីប្រទេសខ្មែរ យួនហាណូយជាវៀតមិញឆ្លៀតពេលនោះសំរាំងជ្រើសរើសខ្មែរវៀតមិញចំនួន១,០០០នាក់ នាំយកទៅជាមួយ ដើម្បីបំពាក់គោលជំហរកុម្មុយនិស្តឲ្យបានឆ្អិនឆ្អៅ ។ ចំណែក៤ពាន់នាក់ទៀត វាបន្សល់ទុកពាសពេញស្រុកខ្មែរ ដើម្បីធ្វើជាខ្សែរយៈទៅអនាគត ។ វាបញ្ជាឲ្យរំលាយក្រុមចូលសម្ងំឈឹងក្នុងទីងងឹត រង់ចាំពេលវេលាល្អមកដល់ ។ ( វាគ្មានចូលសុំចំណុះក្នុងសង្គមខ្មែរឯករាជ្យទេ) ។ មានមេបញ្ជាការមួយភាគស្រឡាញ់និងស្មោះត្រង់ចំពោះជាតិ គ្មានស៊ីគ្រលុំជាមួយបនពុករលួយទេ ។ លោកតែងតែនាំទ័ពទៅទប់ទល់ជាមួ-យខ្មាំង... ប៉ុន្តែចាប់តាំងពីចុងឆ្នាំ១៩៧៣មក ក្នុងសមរភូមិនិមួយៗគេឃើញតែខ្មោចខ្មែរពាសពេញព្រៃ មិនឃើញខ្មោចបូដួយដូចពេលមុនៗទេ ។ ដូច្នេះមានអារម្មណ៍រវាតចិត្តចង់ឈប់បន្តសង្គ្រាម ព្រោះមិនចង់ឃើញឈាមបងប្អូនខ្មែរហូតទៅថ្ងៃមុខទៀត ។

ចំណែកឯរាស្រ្តខ្មែរអ្នកស្រែចំការ ពេលនោះក៏គ្មានឃើញអ្វីប្លែកពីជំនាន់មុនមកជំនាន់ក្រោយ គឺឃើញតែបន្ថែមទម្ងន់ជារៀងរាល់ថ្ងៃ ក៏ប្រែចិត្តរេរីរវាយ ហើយក៏នឹកថា បើបានសម្តេចឪដែលមានលោកខៀវ-សំផនជាមេខ្មែរក្រហមគាំទ្រ បានវិលត្រឡប់មកគ្រប់គ្រងប្រទេសខ្មែរវិញប្រសើរណាស់ ។

មើលចុះនៅពេលនោះ ! ប្រជាពលរដ្ឋខ្មែរទូទៅទាំងរាស្ត្រទាំងនាម៉ឺនអ្នករដ្ឋការគ្រប់ៗផ្នែក គ្រប់ជាន់ថ្នាក់ ទាំងទាហាន ទាំងស៊ីវិល យល់ច្រឡំយ៉ាងធ្ងន់ជាង ធ្ងន់ដោយស្មានថាភ្ជក់ភ្លើងសង្គ្រាមនេះ គឺខ្មែរលន់-នល់ម្ខាងច្បាំងជាមួយខ្មែរសីហនុ-ខៀវសំផនម្ខាងទៀត ។ ប្រជាពលរដ្ឋខ្មែរមិនដឹងទាល់តែសោះថា មានគូបដិបក្ខអាថ៌កំបាំងពួនលាក់ខ្លួនក្នុងទីងងឹត លួចប្រើឃីហោខ្មែរក្រហម លួចប្រើឃីហោសម្តេចសីហនុ រង់ចាំឱកាសល្អទើបវាក្រោកឡើងម្តងមួយដំណាក់ៗ បន្លំសម្លាប់បំបាត់ពូជខ្មែរ ។ តើនរណាជាគូបដិបក្ខអាថ៌កំបាំងនេះ ? គឺអតិតវៀតមិញដែលឃួនហាណូយជាវៀតកុងជាមេដឹកនាំ ជាអ្នកផ្តល់អាវុធឲ្យគ្រប់ធុន ព្រមទាំងមានបូជួយជាង១សែននាក់ ត្រៀមខ្លួនរង់ចាំផ្តល់កម្លាំងសម្ងាត់ ដែលជាកម្លាំងអមតៈ ដែលវាមានអាវុធប្រសើរជាងខ្មែរយើង វាមានខ្សែរយៈតែមួយគត់យ៉ាងត្រឹមត្រូវហ្មត់ចត់ វាចាត់ចែងមានទម្រង់ប្រសើរជាងខ្មែរយើង ។ ឧទាហរណ៍ថា ថ្ងៃនេះ ខែនេះ ឆ្នាំនេះ តើវាត្រូវបញ្ចេញខ្មែរធុនណា ? តើខ្មែរធុននោះត្រូវធ្វើអ្វី ? ។ល។ វាប៉ិនប្រសប់ប្រើកលល្បិច ជាបញ្ឆោតជាបណ្តោយ វាចេះចាត់ការបានយ៉ាងដិតដល់នៅលើពិភពលោក គ្មានសាសន៍ណាអាចធ្វើដូចវាបានឡើយ ។ ក្នុងឆ្នាំ១៩៧៤ វាកាន់កាប់ទឹកដីព្រៃព្រឹក្សារបស់ខ្មែរបានសឹង៣ភាគ៤ទៅហើយ ។ល។

❑　　　　❑

❑

# ជំពូកទី៨

★ ហេតុដូចម្តេចបានជាមានព្រឹត្តិការណ៍ថ្ងៃ១៧មេសា១៩៧៥ ?

★ ការបង្កើតគណៈកម្មាធិការពិសេសចរចាបញ្ចប់សង្គ្រាម ។

★ លោកសេនាប្រមុខលន់-នល់ចាកចេញពីស្រុកខ្មែរ ។

★ អង្គការត្រួតត្រាប្រទេសខ្មែរ ។

★ វិបត្តិនៃរដ្ឋធានីភ្នំពេញក្រោយព្រឹត្តិការណ៍១៧មេសា១៩៧៥

★ វិបត្តិនៃខេត្តបាត់ដំបងក្រោយព្រឹត្តិការណ៍១៧មេសា១៩៧៥

★ វិបត្តិស្រុកប៉ៃលិនក្រោយព្រឹត្តិការណ៍១៧មេសា១៩៧៥ ។

★ អង្គការដេញប្រជាជនចេញពីលំនៅ ។

ក្នុងឆ្នាំ១៩៧៤-១៩៧៥ សង្គ្រាមកាន់តែឆេះខ្លាំងឡើងៗ រាស្ត្រខ្មែរអ្នកស្រែចំការត្រូវខ្មាំងសម្លាប់កំចាយគ្មានត្រាប្រណី ដូច្នេះត្រូវតែនាំគ្រួសាររត់ភៀសខ្លួនចូលកាន់ទីក្រុងជ្រកសំណាក់ច្រើនឥតគណនា ។ មូលហេតុនេះបណ្តាលឲ្យការខ្វះស្បៀងអាហារបានចោទឡើងយ៉ាងខ្លាំង ។ ម៉្យាងវិញទៀត រាស្ត្រខ្មែរអ្នកស្រែចំការមិនធ្លាប់រស់នៅចង្អៀតចង្អល់ជាន់កលើគ្នា និងអត់ការងារធ្វើយ៉ាងនេះ កំពុងធុញថប់ ធុញទ្រាន់ជិនណាយនឹងសង្គ្រាម... ស្រាប់តែទទួលបានពត៌មានច្បាស់ការណ៍គួរឲ្យកក់ក្តៅ គួរឲ្យមានសង្ឃឹមមកថា ៖ តាមរយៈប្រទេសអេស៊ានជាមិត្ត គេជួយធ្វើអន្តរាគមន៍បើកកិច្ចចរចាដើម្បីបញ្ចប់សង្គ្រាម ។

នៅពេលនោះលោកឡុង-បូរ៉េត ជារដ្ឋមន្ត្រីទី១នៃរដ្ឋាភិបាលសាធារណរដ្ឋខ្មែរក៏ចាប់ផ្តើមចាត់តាំងគណៈកម្មាធិការពិសេសមួយមានសមាជិក១៣នាក់គឺ ៖

១- ឧត្តមសេនិយ សូកាំ-ខូយ ប្រធានព្រឹទ្ធសភា

| | |
|---|---|
| ២- លោក អ៊ីង-ប៊ុនហោ | ប្រធានរដ្ឋសភា |
| ៣- លោក ឡុង-បូរ៉េត | នាយករដ្ឋមន្ត្រី |
| ៤- លោក ហង្ស-ធុនហាក់ | ឧបនាយករដ្ឋមន្ត្រី |
| ៥- ឧត្តមសេនិយ សក់-ស៊ុតសាខន | ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ, នាយសេនាធិការដ្ឋានកងទ័ពជាតិ |
| ៦- លោក ប៉ាន់-សូធី | ឧបនាយករដ្ឋមន្ត្រី |
| ៧- លោក ឡុង-បុត្តា | រដ្ឋមន្ត្រី |
| ៨- លោក ថៅង-លីមហួង | រដ្ឋមន្ត្រី |
| ៩- លោក គាំ-រ៉េត | រដ្ឋមន្ត្រី |
| ១០- ឧត្តមសេនិយ លន់-ណុន | |
| ១១- ឧត្តមសេនិយ ឡេស-កូសែម | |
| ១២- លោកគីម-ងួនត្រាច | ទេសាភិបាលធនាគារជាតិកម្ពុជា |
| ១៣- ឧត្តមនារី វង់-សារ៉េនឌី | |

កំពុងរៀបចំកិច្ចការជាមួយគូបដិប័ក្ខ គឺសម្តេចសីហនុនិងលោកខៀវ-សំផន ដើម្បីបញ្ចប់សង្គ្រាម ។

ពេលនោះប្រទេសអេស៊ានជាមិត្តឲ្យយោបល់ថា ៖ បើលោកសេនាប្រមុខស្ថិតនៅក្នុងប្រទេសកម្ពុជាដដែល កិច្ចការពិភាក្សានេះនឹងអាចមានឧបស័គ្គរារាំងមិនឲ្យប្រព្រឹត្តទៅបាន ។

ដូច្នេះឧត្តមសេនិយសូ-កាំខូយ, ឧត្តមសេនិយសក់-ស៊ុតសាខន, លោកអ៊ីងប៊ុនហោ, លោកឡុង-បូរ៉េត និងលោកហង្ស-ធុនហាក់ ស្ម័គ្រចិត្តនាំពាក្យនាំយោបល់របស់គណកម្មាធិការបន្តអំណាច ដើម្បីរាយការណ៍ជំរាបលោកសេនាប្រមុខលន់-នល់ ព្រមទាំងស្នើសុំឲ្យលោកថយចាកចេញពីស្រុកខ្មែរ ដើម្បីទៅព្យាបាលរោគឯបរទេសសិន...។

លោកសេនាប្រមុខលន់-នល់គាំងមាត់សឹងរកពាក្យឆ្លើយឆ្លងមិនរួច ។ តាមយោបល់របស់លោក លោកយល់ច្បាស់ណាស់ថា ភ្លើងសង្គ្រាមដែលកំពុងឆេះគគុកពេញប្រទេសខ្មែរ គឺបណ្តាលមកពីពួកអាទមិឡ វាមានបំណងប្តូរមុខប្រទេសកម្ពុជា ឲ្យក្លាយទៅជាប្រទេសរណបរបស់វា ។ បើវាលេបបានទឹកដីកម្ពុជា វានឹងកសាងកម្ពុជាមួយថ្មីលើគំនរផេះគំនរឆ្អឹងរបស់រាស្ត្រខ្មែរយ៉ាងពិតប្រាកដ ។

ប៉ុន្តែលោកនឹកគិតថា ៖ គួរឲ្យចម្លែក គួរឲ្យឆ្ងល់ណាស់ ព្រោះតាមពត៌មានច្បាស់ការណ៍រាយការណ៍មកថា តាំងពីចុងឆ្នាំ១៩៧៣ ក្នុងសមរភូមិនិមួយៗ គេឃើញ

តែទាហាននិងយោធាជាតិខ្មែរស្លាប់គរលើគ្នា គ្មានឃើញខ្មោចបូដូយដូចពីមុនៗឡើយ ។

ម្យ៉ាងវិញទៀត រោគាពាធកំពុងយាយីរូបលោក, លោកមិនអាចបំពេញភារកិច្ចករណិយកិច្ចបំរើជាតិឲ្យបានពេញលេញ ។ ពេលនោះលោកអង្គុយគិតសញ្ជឹងមួយសន្ទុះធំ ដើម្បីប្រទេសជាតិ លោកសំរេចចិត្តយល់ព្រមតាមសេចក្តីស្នើនោះ ។ លោកត្រូវតែផ្សងព្រេងចាកចេញចោលមាតុភូមិជាទីស្រឡាញ់គួរឲ្យសោកស្តាយ។ លោកខ្វល់សែនខ្វល់ពីអនាគតនៃប្រទេសនិងប្រជាជនខ្មែរ ។ល។

លោកសេនាប្រមុខចេញដំណើរទៅកាន់សហរដ្ឋអាមេរិកនៅថ្ងៃទី១មេសាឆ្នាំ១៩៧៥ ។

មើលចុះគ្រប់ៗបេសកកម្មរបស់លោកសេនាប្រមុខលន់-នល់ លោកធ្វើឡើងដោយពេញកិត្តិយសថ្លៃថ្នូរ និងសមហេតុសមផលជានិច្ច ។

ឆ្លៀតឱកាសនោះយួនហាណូយ និងខ្មែរអាយ៉ងយួន ដែលជាសមាជិកបក្សប្រជាជនបដិវត្តន៍ខ្មែរ គឺអតិតខ្មែរវៀតមិញ មានហេង-សំរិន, ហ៊ុន-សែន, ជា-ស៊ីមជាដើម លោតកញ្ឆក់យកជ័យជំនះនៅថ្ងៃ១៧មេសា១៩៧៥ភ្លាម ។ ពួកវាកែទម្រង់ប្រទេសកម្ពុជាឲ្យក្លាយទៅជាលានមរណៈដ៏ធំធេង ។

ដើម្បីលាក់បំបាំង, ដើម្បីបំភ័ន្តមតិអន្តរជាតិនិងរាស្ត្រខ្មែរ វាបង្កើតឈ្មោះដ៏ចម្លែកនេះគឺ « អង្គការអនាមិក » ដែលជាមេបញ្ជាការយ៉ាងងងឹតអន្ធការ ។

មើលចុះក្នុងនាមអង្គការផ្សាយតាមវិទ្យុនៅរដ្ឋធានីភ្នំពេញនៅល្ងាចថ្ងៃទី១៧មេសា១៩៧៥, វានិយាយច្រំដែលៗគួរឲ្យធុញទ្រាន់ថា ជ័យជំនះថ្ងៃទី១៧មេសា១៩៧៥នេះមិនមែនបានមកដោយសារការចរចាទេ គឺបានដោយការដណ្តើមដោយអាវុធរបស់កងកម្លាំងប្រដាប់អាវុធរបស់យើង ។ កាលណោះខ្មែរគ្រប់ៗគ្នាឮដែរ ប៉ុន្តែអ្នកខ្លះមិនសូវយកចិត្តទុកដាក់តាមដានព្រឹត្តិការណ៍បានជាពេលនោះយើងមិនសូវយល់ន័យនេះឡើយ ។

មើលចុះអង្គការអនាមិកដែលអត់រូបអត់រាង ហើយមានតែឈ្មោះដូចបិសាចនេះ តើហេតុអ្វីក៏វាមានឥទ្ធិពលខ្លាំងក្លាគួរឲ្យចម្លែកម្លេះ ? សូមឆ្លើយបញ្ជាក់បំភ្លឺជំរាបបងប្អូនខ្មែរថា ព្រោះមានបូដូយជាច្រើនម៉ឺននាក់ ដែលជាកម្លាំងអមតៈដ៏មុតស្វិតស្វាញត្រៀមខ្លួនជាស្រេចរង់ចាំផ្តល់កម្លាំងសម្ងាត់ឲ្យអង្គការ ។

❑

# វិបត្តិនៅភ្នំពេញក្រោយព្រឹត្តិការណ៍ថ្ងៃ១៧មេសា៧៥

ភ្នំពេញជារដ្ឋធានីនៃប្រទេសកម្ពុជា ។ ផ្លូវជាតិលេខ១ចងភ្ជាប់រដ្ឋធានីភ្នំពេញទៅរដ្ឋធានីព្រៃនគរ ( សៃហ្គុង-ក្រុងហូ-ជីមិញ ) ។ ផ្លូវជាតិលេខ៥ចងភ្ជាប់រដ្ឋធានីភ្នំពេញ ទៅស្រុកអូរជ្រៅកាត់តាមខេត្តកំពង់ឆ្នាំង, ពោធិ៍សាត់ និងបាត់ដំបង ។ នៅខាងកើតរដ្ឋធានីភ្នំពេញមានទន្លេមួយយ៉ាងធំហៅថាទន្លេបួនមុខ ( ទន្លេចតុមុខ ) ។ កប៉ាល់តូចល្មមអាចបើកបរជាហូរហែរ ។ រហូតដល់ឆ្នាំ១៩៧៥ ភ្នំពេញជារដ្ឋធានីរៀបចំទាន់សម័យទំនើប មានប្រជាជនចំនួន៦០ម៉ឺននាក់ ភាគច្រើនជាអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ។

ក្នុងរយៈពេល៥ឆ្នាំ ដោយសារសង្គ្រាម រាស្ត្រខ្មែរអ្នកស្រែចំការភ័យខ្លាច ក៏នាំគ្រួសាររត់ចូលកាន់ទីក្រុងភ្នំពេញយ៉ាងច្រើនលើសលប់ ។ នៅឆ្នាំ១៩៧៥ ប្រជាជនមានចំនួនជាង៣លាននាក់ ។ វិបត្តិនៃស្បៀងអាហារបានចោទឡើងគួរឲ្យបារម្ភក្រៃលែង ។ សហរដ្ឋអាមេរិកជួយផ្តល់ជំនួយមនុស្សធម៌ ជាគ្រឿងឧបភោគ បរិភោគចំនួនពី៣ទៅ៤ម៉ឺនតោនក្នុងមួយខែ ។ ពីរឬបីថ្ងៃមុនព្រឹត្តិការ១៧មេសា១៩៧៥ អ្នកស្រុកក្នុងរដ្ឋធានីភ្នំពេញទាំងអស់មានការជ្រួលច្របល់, ភ័យតក់ស្លុត, អស់សង្ឃឹមព្រោះបានទទួលពត៌មានដ៏ច្បាស់ការណ៍មកថា លោកសេនាប្រមុខលន់-នល់បានចាកចេញពីប្រទេសខ្មែរទៅហើយ ។ កិច្ចការរដ្ឋទាំងមូលត្រូវតែធ្លាក់ទៅក្នុងកណ្តាប់ដៃពួកនាម៉ឺន ដែលភាគច្រើនជាអ្នកពុករលួយនិងខ្វះសមត្ថភាព ។

ពេលនោះខ្មាំងបាញ់កាំភ្លើងបំផ្លោងស្រោចលើរដ្ឋធានីដូចរន្ទះ អ្នកស្រុកអន្ទះសារចង់ដឹងលទ្ធផលនៃការពិភាក្សារវាងសាធារណរដ្ឋខ្មែរ, សម្តេចសីហនុ និងលោកខៀវ-សំផន ។ ស្រាប់តែនៅថ្ងៃទី១៧មេសា១៩៧៥ ម៉ោង៧កន្លះមានដំណឹងបន្តមកទៀតថា មានចៅហ្វាយថ្មីចូលមកគ្រប់គ្រងប្រទេសកម្ពុជាហើយ...។ គ្រប់ៗគ្នាយល់ច្រឡំស្មានតែកិច្ចចរចាបានសំរេច ដោយថ្វាយអំណាចដល់សម្តេចឪ លោកអាចយាងត្រឡប់មកគ្រប់គ្រងរាស្ត្រខ្មែរឡើងវិញហើយ!... ប្រសើរណាស់ៗ!...

ពេលនោះរាស្ត្រខ្មែរអន្ទះសារអង្គុយភ័យផងអរផង ព្រោះមិនដឹងថាដំណឹងនេះពិតឬមិនពិតទេ ។ កំពុងមើលផ្លូវសម្តេចឪ ស្រាប់តែមានការត្រេកអរដោយក្រឡេកឃើញមនុស្សម្នាក់មុខមូលមាំ ស្លៀកពាក់ខ្មៅ គ្មានអាវុធដើរមុខគេយ៉ាងស្វាហាប់ មានយុវជនក្មេងៗចំនួនជាង២រយនាក់ស្លៀកពាក់ខ្មៅគ្មានអាវុធ ដើរតាមក្រោយហោរជាក្បួនលើចិញ្ចើមថ្នល់តម្រង់ទៅកាន់សណ្ឋាគារ « ឡឺភ្នំ » ដែលមាន

កងទ័ពរថក្រោះជាច្រើនរយនាក់នៅទីនោះត្រៀមខ្លួនរង់ចាំទប់ទល់នឹងខ្មាំង ។ កងទ័ពរថក្រោះក្រឡេកឃើញមនុស្សចម្លែកមកដល់ ក៏លោតចុះពីរថក្រោះរត់ស្រ មកជួបជជែកគ្នាមួយសន្ទុះ ស្រាប់តែលោតឱបគ្នា បង្ហាញនូវសេចក្តីត្រេកអរជាអនេកដោយជឿតាមសំដីអ្នកក្លាហាននេះប្រាប់ថា « សង្គ្រាមចប់ត្រឹមនេះហើយ! » ។

មនុស្សចម្លែកក៏ឡើងលើរថក្រោះមួយគ្រឿង លើកដៃធ្វើសញ្ញាចេញបញ្ជាឲ្យដឹកនាំគាត់ទៅកាន់ទីក្រុងភ្នំពេញ រួចទៅកាន់គ្រប់ទីកន្លែងដែលមានទ័ពយ៉ាងច្រើនដាក់ខ្សែត្រៀមរង់ចាំទប់ទល់នឹងខ្មាំង ។ ពេលទៅដល់សមរភូមិនិមួយៗ អ្នកក្លាហានដ៏ចម្លែកនេះ លោតចុះពីរថក្រោះដើរតែម្នាក់ឯង គ្មានអាវុធ រួចលើកដៃជាសញ្ញាបញ្ជាឲ្យកងទ័ពទាំងអស់ដាក់អាវុធ ព្រមទាំងនិយាយបញ្ជាក់តែពាក្យដដែលៗថា « សង្គ្រាមចប់ហើយៗ!!! » ។

ចំណែកប្រជាជនខ្មែរនិងបរទេស ដែលបានឃើញមនុស្សជាង២០០នាក់ដ៏ក្លាហានដើរចូលសមរភូមិគ្មានអាវុធយ៉ាងនេះ មានភាគច្រើនស្មានថា ជាគណៈប្រតិភូរបស់សម្តេចឬខ្មែរក្រហម ចូលមកចរចាជាមួយនាម៉ឺនបន្តអំណាចពីលោកលន់-នល់ ។ល។

កំពុងសម្លឹងភ្លឹកនឹកស្មានៗយ៉ាងនេះ... ពេលជាមួយគ្នាស្រាប់តែឃើញមានឡានហ្ស៊ីប២គ្រឿងបរយឺតៗ មានមេខ្មែរក្រហម៨នាក់ជិះក្នុងឡាននោះ ។ ឡាននោះដោតទង់ពណ៌ក្រហមនិងខៀវ មានរូបខ្លែងជើងក្អែកនៅពីលើ ។ មានយោធាខ្មែរក្រហមក្មេងៗ អាយុមិនលើសពី១៥ឆ្នាំចំនួន៣០០នាក់ ស្លៀកពាក់ខ្មៅ ពាក់ស្បែកជើងធ្វើពីកៅស៊ូកង់ឡានតាមហូ-ជីមិញ ។ ជុំវិញចង្កេះព្យួរគ្រាប់បែកចិនរណោងរណោងធុន B-40, AK-47 ពាក់ឆៀងគ្រាប់កាំភ្លើងពេញដើមទ្រូង ។ ពួកយោធាក្មេងៗនេះដើរតាមក្រោយឡានហ្ស៊ីបពីរគ្រឿងនោះ ចូលមកយ៉ាងស្ងប់ស្ងៀមមើលទៅដូចជាអស់កម្លាំងណាស់ទៅហើយ ។ ក្រុមនេះខុសស្រឡះពីក្រុមមុនៗ ។ ដូច្នេះតើក្រុមនេះចេញមកពីប្រភពណា ? ពីមជ្ឈដ្ឋានណា ?

ក្រោយបន្តិចមកទើបមានពត៌មានមកថា មនុស្សក្លាហានដ៏ចម្លែកនោះ គឺលោកឧត្តមសេនិយ ហែម-កេតតារា ជាកូនរបស់លោកហែម-កេតសាណា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ លោកឧត្តមសេនិយហែម-កេតតារាធ្វើតាមបញ្ជាលោកលន់-ណុនប្អូនបង្កើតលោកលន់-នល់ ដើរបញ្ជាឲ្យទាហានគ្រប់ៗសមរភូមិដាក់អាវុធព្រមទាំងនិយាយតែឃ្លាដដែលៗថា « សង្គ្រាមចប់ហើយៗ! » ...

ក្រុមលោកលន់-ណុនលៃលកឲ្យទាន់ខ្យល់មួយរយៈពេលសិន ។ ប៉ុន្តែគួរឲ្យស្តាយណាស់ ដែលអស់លោកទាំងនេះមិនបានរៀនសូត្រខាងផ្នែកសង្គ្រាមឲ្យដឹងទាល់តែសោះ ថាអ្នកឈ្នះពេលនេះជាក្រុមអាថ៌កំបាំង វាកញ្ឆក់យកជ័យជំនះ វា

ពួនលាក់ខ្លួនក្រោយឈ្មោះអង្គការអនាមិក ប្រើយីហោខ្មែរក្រហមនោះទេ ។

ម៉ោង១០កន្លះថ្ងៃដដែល, លោកហែម-កេតតារានិងយុវជនជាង២០០នាក់មកដល់ក្រសួងឃោសនាការមុនគេទាំងអស់ ។ លោកឆ្លេឆ្លាដោយចាត់ទុកខ្លួនថាជាមេបញ្ជាការ ដោយយល់ច្រឡំធ្ងន់ទៅលើពួកខ្មែរក្រហមទាំងនោះថា ជាមនុស្សព្រៃមិនចេះដល់ក្រុមអញទេ ! ពេលនេះក្រុមអញយកគាប់យកគួរសេឲ្យទាន់ខ្យល់មួយពេលសិន... ពាក្យចាស់លោកតែងតំណាលថា ៖ «ចេះឯងឲ្យក្រែងចេះគេ! »

នៅថ្ងៃទី១៧មេសានេះ វិទ្យុកម្ពុជាសម្ងំស្ងៀមឈឹងតាំងពីព្រលឹម លុះដល់ម៉ោង១០ ទើបឮសម្លេងសម្តេចព្រះសង្ឃរាជ ហួត-តាត ផ្សាយអំពាវនាវឲ្យរាស្ត្រខ្មែរទូទាំងប្រទេសតាំងចិត្តឲ្យស្ងប់ស្ងៀមនៅផ្ទះរៀងៗខ្លួន... សង្គ្រាមចប់ត្រឹមហ្នឹងហើយ... យើងត្រូវតែបញ្ឈប់ការបង្ហូរឈាមរវាងខ្មែរនិងខ្មែរ ។ល។

មួយសន្ទុះទើបឮសូរសម្លេងឧត្តមសេនិយ ម៉ី-ស៊ីចន ជានាយការិយាល័យទី៣នៃអគ្គបញ្ជាការកងទ័ពខ្មែរ ថ្លែងបញ្ជាបង្គាប់ទៅកងទ័ពគ្រប់ផ្នែកឲ្យដាក់អាវុធចុះព្រោះការចរចាបានបញ្ចប់សង្គ្រាមត្រឹមណេះហើយ ។ ចំណែករាស្ត្រអ្នកស្រែចំការអាចវិលត្រឡប់ទៅកាន់ភូមិស្រុកទីលំនៅ ប្រកបការងារធ្វើស្រែចំការឡើងវិញដូចពីដើម ។

នៅម៉ោង៣រសៀលនៃថ្ងៃដដែល វិទ្យុចាប់ផ្សាយបោកបញ្ឆោតមេបញ្ជាការនិងរដ្ឋមន្ត្រីគ្រប់ៗក្រសួង ដែលមានជាអាថ៌ដូចតទៅ ៖

« ទីនេះវិទ្យុផ្សាយសម្លេងរណសិរ្សរួមរួមជាតិកម្ពុជា... យើងខ្ញុំនៅរង់ចាំមិត្តៗក្នុងមន្ទីររដ្ឋមន្ត្រីក្រសួងឃោសនាការ ។ នៅជាមួយនឹងយើងមានសម្តេចព្រះសង្ឃរាជ ហួត-តាត, លោកម៉ី-ស៊ីចន, លោកលន់-ណុន, លោកហែម-កេតតារា ។ យើងសូមអញ្ជើញរដ្ឋមន្ត្រីគ្រប់ៗក្រសួង, ឧត្តមសេនិយទាំងអស់ មកជួបយើងជាបន្ទាន់បំផុត ដើម្បីជួយយើងរៀបចំកសាងជាតិ » ។

ឮដូច្នេះភ្លាម នាម៉ឺនចំនួន៤០០នាក់ដែលខ្វះការពិសោធន៍ ដោយមោហ៍បាំងនោះ មានទឹកមុខញញឹមត្រេកអរជាក្រៃលែង ក៏ស្លៀកពាក់ឯកសណ្ឋានយ៉ាងស្អាតធ្វើដំណើរទៅកាន់មន្ទីរឃោសនាការភ្លាម ដោយគ្មាននរណាម្នាក់នឹកភ្នកគិតថា កំពុងចាញ់បោកខ្លាំងនោះទេ ។ ក្នុងចំណោម៤០០នាក់នេះមាន ៖ ឧត្តមសេនិយឈឹម-ឈួន, លន់-ណុន, ប៉ូល-លីតែសួន, លីតែសួន-អែមេ, ម៉ី-ស៊ីចន ជាដើមស្លៀកពាក់សមតាមយសស័ក្តិស្អាតៗ លើកលែងតែលោកហែម-កេតតារា និងយុវជនក្មេងៗជាង២០០នាក់ចេញ ដែលស្លៀកពាក់ខ្មៅ ។

ចំណែកលោកឡុង-បូរ៉េត រដ្ឋមន្ត្រីទី១មកដល់យឺតជាងគេ ។ លោកចំណាយពេលជិតអស់មួយថ្ងៃទើបបានសំរេច ព្រោះយោធាខ្មែរក្រហមក្មេងៗ យាមយ៉ាង

ហ្មត់ចត់ ឃាត់ឃាំងមិនឲ្យលោកដើរទៅកាន់ក្រសួងឃោសនាការ ។ លោកអស់សង្ឃឹម ខំទាក់ទងទំរាំមានគេបើកឡានហ្ស៊ីបមកទទួលលោក ។ លុះលោកមកដល់ក្រសួងឃោសនាការ ម៉ោងប្រហែល៥រសៀល ចំលើពេលដែលវិទ្យុផ្សាយសម្លេងត្រង់ពាក្យមួយឃ្លាដែលនិយាយថា ៖ « យើងឈ្នះដោយសារកង់កម្លាំងប្រដាប់អាវុធស្នេហាជាតិកម្ពុជា... គឺយើងឈ្នះដោយអាវុធ តែពុំមែនដោយការចរចាទេ » ។ លោកឡុង-បូរ៉េតឮដូច្នោះក៏ផ្លាក់ថ្លើមក្ដុកកិះតែដួលសន្លប់ « ឱ! ខ្មែរអាយ៉ងយួនទេតើ ! » លោកក៏ដើរទៅចាប់ដៃអស់លោកវរៈជនគ្រប់ៗគ្នានៅទីនោះ ។ ពេលទៅចាប់ដៃលោកឧត្តមសេនិយហែម-កេតតារាជាចុងក្រោយគេបង្អស់ លោកទាំងពីរកាន់ដៃគ្នាយ៉ាងមាំ សម្លឹងមុខគ្នាយ៉ាងយូរនៅស្ងៀម គ្រាន់តែបង្ហាញសភាពខាងក្រៅឲ្យយល់ថា « អញក៏ឆ្កួត ឯងក៏ឆ្កួត... មិនគួរអីយើងដើរបញ្ជាឲ្យទាហានដាក់អាវុធចុះមុនច្បាំងយ៉ាងនេះឡើយ !!! » ។ល។

ប្រហែលម៉ោង៧ល្ងាច តំណាងអង្គការដឹកនាំឧត្តមសេនិយ, រដ្ឋមន្ត្រី ព្រមទាំងនិស្សិត២០០នាក់ទៅជួបអង្គការ គឺនាំយកទៅបាញ់សម្លាប់ចោលខ្ទេច ។

( សុំបើកវង្ងង់ក្រចកបន្តិច, មុនពេលដែលប្រទេសខ្មែរត្រូវធ្លាក់វិនាសហិនហោច៣-៤ថ្ងៃ, លោកឡុង-បូរ៉េតធ្វើដំណើរទៅកាន់ប្រទេសហ្វីលីពីន ជួបលោកសេនាប្រមុខលន់-នល់ ដើម្បីសុំដំបូន្មាននិងយោបល់ ។ លោកវិលត្រឡប់មកកាន់រដ្ឋធានីភ្នំពេញវិញ ចំពេលព្រឹកថ្ងៃទី១២-៤-៧៥ គឺជាថ្ងៃដែលលោកឯកអគ្គរដ្ឋទូតយ៉ុន-ខាន់ថីឌីន មកអញ្ជើញលោកឡើងកប៉ាល់ហោះភៀសខ្លួនទៅកាន់សហរដ្ឋអាមេរិកមួយរយៈសិន ។ លោកប្រកែកមិនព្រមទៅ ហើយថែមទាំងឆ្លើយទៅវិញថា ៖ « ខ្ញុំមិនមែនជាអ្នកស៊ីឈ្នួលច្បាំងទេ » ។ ដូច្នេះកន្លែងដែលទុកជូនលោកឡុង-បូរ៉េតនោះ ក៏ត្រូវបានទៅទៅលោកសូកាំ-ខូយ ដែលមានវាសនាចាកចេញផុតពីគ្រោះថ្នាក់ ហើយសំណាក់នៅសហរដ្ឋអាមេរិករហូតដល់សព្វថ្ងៃនេះ ។

មើលចុះលោកឡុង-បូរ៉េតជានាយករដ្ឋមន្ត្រី ជាអ្នកចាត់តែងតាំងគណៈកម្មាធិការពិសេស ដើម្បីចរចារកផ្លូវបញ្ចប់សង្គ្រាមនៅស្រុកខ្មែរ ។ មើលចុះអស់លោកឧត្តមសេនិយខ្លះ គ្មានយល់អ្វីទាំងអស់អំពីរឿងសង្គ្រាមក្នុងស្រុកខ្មែរ ។ គ្រប់ៗគ្នាបណ្ដោយខ្លួនចាញ់បោកខ្មាំងធ្ងន់ជាងធ្ងន់សឹងរកពាក្យខ្មែរសរសេរគ្មាន។ បណ្ដោយខ្លួនឲ្យខ្មាំងប្រមូលយកទៅបាញ់សម្លាប់ចោលបានយ៉ាងងាយ ដូចគេបេះពុទ្រាទុំ ។

ឱទេវតាអើយ ! គួរអាសូរដល់រាស្ត្រខ្មែរកើតជំនាន់នេះណាស់, តើវាសនាក្លាយជាអ្វីទៅ ?

មើលចុះ ! នៅថ្ងៃទី១៧-៤-៧៥, វេលាម៉ោង៤រសៀល មានឡានហ្ស៊ីបជាច្រើនគ្រឿង ដាក់ឧគ្ឃោសនសព្ទ បើកបរពីកន្លែងមួយទៅកន្លែងមួយទៀតពាសពេញ

រដ្ឋធានី ផ្សាយជាដំណឹងតាមបញ្ជាដ៏ដាច់ណាត់របស់អង្គការ ដេញប្រជាជនទាំងអស់ឲ្យចេញពីរដ្ឋធានីក្នុងរយៈ២៤ម៉ោង ដោយយកលេសថា អាមេរិកាំងនឹងចូលមកទម្លាក់គ្រាប់បែកក្នុងពេលឆាប់ៗនេះ...។

នៅពេលនោះប្រជាជនជិត៣លាននាក់ ត្រូវតែថយចេញពីរដ្ឋធានីភ្នំពេញដ៏ធំធេង ចោលទ្រព្យសម្បត្តិដ៏ច្រើនមហិមា គ្មានពាក្យតវ៉ាឡើយ ។ អ្នកខ្លះពរកូនតូច ដឹកដៃកូនបន្ទាប់ មានតែកូនសំពាយនៅលើខ្នង ។ អ្នកខ្លះសែងមនុស្សចាស់ជរា សែងប្រពន្ធទើបសំរាលកូនហើយថ្មីៗ, សែងប្រពន្ធកំពុងតែឈឺពោះបំរុងនឹងសំរាលកូន ។ល។ អ្នកមានរថយន្តក៏រៀបចំទ្រព្យសម្បត្តិដ៏ចាំបាច់ដាក់ក្នុងរថយន្ត រួចនាំប្រពន្ធកូនរុញ ព្រោះផ្លូវចង្អៀតមិនអាចបើកបរបាន ។ ចំណែកថៅកែមាសពេជ្រខ្លះ ដោយបន្ទាន់ខ្លាំងពេក ក៏កើបមាសពេជ្របញ្ចូកក្នុងធុងទឹកឡាន រួចនាំប្រពន្ធកូនរុញចេញពីហាងទៅ ។ ប៉ុន្តែឡានទាំងអស់នោះ មិនទាន់ចេញផុតពីរដ្ឋធានីភ្នំពេញផង ក៏ត្រូវក្រុមយោធាក្មេងៗភ្ជង់កាំភ្លើងស្នើយកឡានទុកឲ្យអង្គការទាំងអស់ ។

លុះយប់មកដល់, ប្រជាជនទាំងបីលាននាក់នោះ ត្រូវតែដេកផ្ទាល់ដី កណ្ដាលវាលស្រែ អត់បាយ អត់ទឹក ចម្ងាយពីរដ្ឋធានីត្រឹមតែ១ទៅ៣គីឡូម៉ែត្រប៉ុណ្ណោះ ។ ដោយសារតែចំនួនមនុស្សច្រើនពេក ដើមមិនបានលឿនទៅមុខទេ ។ គ្រប់ៗរូបគាំងមាត់រកពាក្យថ្លែងគ្មាន ។ ក្នុងពេលដើរពាក់ពពូនគ្មានទីដៅនេះ មានបងប្អូនខ្មែរខ្លះ ត្រូវព្រាត់ប្រាស់ប្ដីប្រពន្ធកូនរហូតដល់សព្វថ្ងៃនេះ ។ ឆ្លៀត « ឱកាសដ៏ល្អនេះ » អង្គការអនុវត្តកលល្បិចដ៏ខ្មៅក្រខ្វក់ ដោយបោករដ្ឋមន្ត្រី, នាយទាហាន និងនាម៉ឺនធំៗ ចាក់ឲ្យចំចំណុចខ្សោយរបស់អស់លោកទាំងអស់ដែលអង្គុយរេចាំតាមខ្យល់ ។

មើលចុះ ! ព្រលឹមថ្ងៃទី១៩មេសា, គេឃើញមានប្រកាសបិទព្រោងព្រាតលើបន្ទះក្ដារពណ៌ខ្មៅ ចងព្យួរជាប់នឹងដើមឈើសឹងគ្រប់ទីកន្លែង នៅជុំវិញរដ្ឋធានី ដែលមានសេចក្ដីជាអាទិថា ៖ « អង្គការសូមអញ្ជើញនាយទាហាន ពីអនុសេនិយត្រីឡើងទៅ, សូមអញ្ជើញរដ្ឋមន្ត្រីគ្រប់ៗក្រសួង ចូលមកចុះឈ្មោះនៅទីនេះ ដើម្បីចូលកាន់រដ្ឋធានីភ្នំពេញវិញ ជួយរៀបចំកសាងជាតិ » ។ នៅពេលនោះអស់លោកធំៗភាគច្រើន ត្រូវធ្លាក់ក្នុងអន្ទាក់អង្គការ ដោយយល់ច្រឡំយ៉ាងធ្ងន់ថា ខ្មែរក្រហមដែលជាមនុស្សព្រៃ ល្ងង់ខ្លៅ ឥតតំរេះវិជ្ជា ម៉េចក៏មិនត្រូវការអញ ? ។ ត្រូវចំចំណុចខ្សោយនេះ ក៏បបួលគ្នារត់ប្រញាប់ទៅតម្រង់ជួរសុំចុះឈ្មោះ ប្រាប់ពីអតីតមុខងាររបស់ខ្លួនដោយត្រង់ៗ ដើម្បីឆាប់ឲ្យគេដឹកចូលទៅកាន់រដ្ឋធានី នឹងអាលបានកាន់មុខតំណែងដូចពីដើម, ចៀសវាងការដេកហាលភ្លៀង ហាលថ្ងៃដូច្នេះ វាវេទនាណាស់ ។

លោកណាចុះឈ្មោះរួចអង្គការផ្តល់អង្ករម្ហូបឲ្យគ្រប់គ្រាន់ភ្លាម ។ អង្គការអនុវត្តកលល្បិចរបៀបនេះ តែពីរ-បីថ្ងៃ អាចបោកប្រមូលពួកនាយទាហាន រដ្ឋមន្ត្រីនានា និងនាម៉ឺនខ្មែរដែលអង្គុយរង់ចាំរេតាមខ្យល់នោះ ដឹកនាំយកទៅបាញ់សម្លាប់ចោលខ្ទេចបានយ៉ាងងាយ ត្រូវស្លាប់យ៉ាងច្រើនឥតគណនា ។ គេបានឃើញអស់លោកខ្លះៗដូចជាលោកអ៊ុំរ៉ុង (អ្នកនាំពាក្យរដ្ឋាភិបាល), លោកវរសេនិយលី-តេក, កៅ-អុល និងនាង-សន, លោកវរសេនិយទោ ញូង-ច័ន្ទសារ៉ាត និងស៊ី-តេក, មេធាវីស៊ី-សាថៃ, លោកឧត្តមសេនិយឆាយ-ឡាយ, ប៉ែន-តារា, លោកទេព-ឈីវខេង (រដ្ឋមន្ត្រីក្រសួងឃោសនាការ), លោកប៉ាន់-សុធី (អតិតរដ្ឋមន្ត្រីទី១), លោកភី-ធានឡាយ (អតិតរដ្ឋអាជ្ញា), លោកហង្ស-ធុនហាក់, លោកអ៊ុក-យុន និងអ្នកអម្ចាស់ស៊ីសុវត្ថិ-ដួងជីវិន ។

នៅថ្ងៃទី១៨មេសាវេលាម៉ោង១០ អង្គការចេញបញ្ជាឲ្យនាំប្រជាជនខ្មែរដែលសំណាក់នៅស្ថានទូតបារាំងចំនួន៨០០នាក់ យកចេញទៅដាក់ក្នុងបរិវេណកីឡា-ដ្ឋានឡាំប៉ែរ ដែលមានចម្ងាយ២០០ម៉ែត្រពីស្ថានទូត ។ ក្នុងចំណោម៨០០នាក់នេះភាគច្រើនមានរដ្ឋមន្ត្រី, វិស្វករ, នាយទាហាន ។ វាបញ្ជាឲ្យធ្វើប្រវត្តិរូប រួចបំបែកឲ្យនៅតាមផ្នែកៗ ។ មានគេបានឃើញនិងបានស្គាល់ដូចជា លោកវរសេនិយទោអ៊ុំ-ប៊ុនសួរ, លោកមេបញ្ជាការតាន់-ជា, មន្ត្រីជាន់ខ្ពស់ដូចជាលោកឌី-បែលឡុង, លោកឌី-បែលឡែន និងលោកផ្លែក-ភឿន ជាដើម ។ វាដឹកនាំអ្នកទាំងអស់នេះជាបន្តៗយកទៅជួបអង្គការ គឺនាំយកទៅបាញ់សម្លាប់ចោលទាំងអស់ ។

នៅថ្ងៃទី១៩មេសាម៉ោង៣រសៀល តំណាងរបស់អង្គការចូលមកកាន់ស្ថានទូតបារាំង ចាប់លោកអ៊ឹង-ប៊ុនហោ ប្រធានរដ្ឋសភា, លោកលឿង-ណាល់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល, ទ្រង់សិរិមតៈ, ម៉មលាវ ជាមហេសីមួយរបស់សម្តេចសីហនុ ។ ទ្រង់និងអស់លោកទាំងអស់មានបុកពារថ្លៃថ្នូរ ចាប់ដៃសុំលានិងថ្លែងអំណរគុ-ណដល់បុគ្គលិកស្ថានទូតបារាំងទាំងអស់ ដែលបានយល់ព្រមឲ្យក្រុមខ្លួនសំណាក់នៅក្នុងស្ថានទូតមួយរយៈ រួចបណ្តើរគ្នាចេញទៅប្រគល់ខ្លួនឲ្យតំណាងអង្គការ ដែលមានឡានហ្ស៊ីបមួយគ្រឿងនិងឡានហ្សេអ៊ឹមសេមួយគ្រឿងចតឈប់រង់ចាំនៅមាត់ទ្វារខាងក្រៅ ។

ពេលនោះលោកកុងស៊ុលរងបារាំងឈ្មោះ ឌីរ៉ាក់ ក៏បានជូនដំណើរវរជនទាំងនោះដល់ក្លោងទ្វារស្ថានទូត ។ លោកមិនអាចទប់នូវមនោសញ្ចេតនារបស់លោកបានទេ ។

មន្ទីរពេទ្យព្រះកេតុមាលាជាមន្ទីរពេទ្យមួយដ៏ធំនៅរដ្ឋធានីភ្នំពេញ ។ នៅឆ្នាំ១៩៧៥ មានអ្នកជម្ងឺធ្ងន់ជាងពីរម៉ឺននាក់ ជាពិសេសអ្នកជម្ងឺធ្ងន់ដែលបណ្តាលមកពី

សង្គ្រាម ។ នៅថ្ងៃ១៧មេសា អង្គការចេញបញ្ជាដាច់ណាត់ឲ្យបង្ខំដេញអ្នកជម្ងឺទាំងអស់ចេញពីមន្ទីរពេទ្យភ្លាមៗ ។ អ្នករបួសធ្ងន់ៗជាច្រើនពាន់នាក់ កាន់ឈើច្រត់ទប់ខ្លួន ដើរដោយវេទនា អ្នកខ្លះមានបងប្អូនគ្រាបណ្តើរ, អ្នកដែលនៅសន្លប់មិនទាន់ដឹងខ្លួន មានបងប្អូនរុញគ្រែនាំចេញទៅ ។ ប៉ុន្តែយើងមិនអាចភ្លេចបាននូវអ្នកពិការឥតដៃឥតជើងគ្មានបងប្អូនជួយ ដែលវាដូចសត្វជន្លេន ដែលត្រូវគេកាត់ជាពីរឬបីកំណាត់ តើវាយ៉ាងម្តេចទៅវិញ ? ។

យើងគួរនឹកឃើញហើយសួរថា តើនៅមានជនពិការដូចនេះប៉ុន្មាននាក់ទៀតពេញផ្ទៃស្រុកខ្មែរ ដែលត្រូវរងទុក្ខវេទនាដោយសារអង្គការនៅពេលនេះ ?

នៅរដ្ឋធានីភ្នំពេញ កងទ័ពដែលមិនរេតាមខ្យល់ គឺទ័ពម៉ែកហ្វ៍ក្ស ដែលជាអតីតកងទ័ពខ្មែរសេរី ។ កងទ័ពខ្មែរសេរី មានការអប់រំយ៉ាងហ្មត់ចត់ ។ លោកសឹង-ង៉ុកថាញ់ពន្យល់បំពាក់គោលជំហរ ឲ្យស្គាល់ករណិយកិច្ចនិងភារកិច្ចជាទាហាន គឺត្រូវច្បាំងតទល់នឹងសត្រូវ ដើម្បីការពារជាតិនិងប្រទេស ។ ម៉្យាងទៀត លោកពន្យល់ឲ្យស្គាល់ច្បាស់ នូវសត្រូវនិងមិត្តរបស់ជាតិខ្មែរ ។ កងទ័ពនេះរឹងប៉ឹងស្ទិតស្ទាញ មានការតស៊ូធន់ទ្រាំនឹងការលំបាកគ្រប់បែបយ៉ាង បើប្រៀបធៀបទៅនឹងបូដូយ គឺខ្លាំងជាងពួកនេះ ។ អង្គការរៀនសូត្រស្គាល់គ្រប់ជ្រុងជ្រោយក្នុងផ្ទៃកកងទ័ពសាធារណរដ្ឋខ្មែរ ។ អង្គការស្គាល់ច្បាស់ថា ៖ មេៗចូលធ្វើទាហានដើម្បីតែពាក់ស័ក្តិ, អាងធ្វើធំ អង្គុយរង់ចាំរេតាមខ្យល់... រីឯកូនៗវិញចូលធ្វើទាហានដើម្បីបើកប្រាក់ខែចិញ្ចឹមគ្រួសារ ។ អ្នកអស់នេះមិនស្គាល់ភារកិច្ចនិងករណិយកិច្ចឡើយ ។ ដូច្នេះមានតែកងទ័ពម៉ែកហ្វ៍ក្សមួយគត់ដែលអង្គការត្រូវតែប្រុងប្រយ័ត្ន ត្រូវតែកំទេចអាវុធជាកាំភ្លើង ព្រោះកងទ័ពនេះមិនចុះញមនឹងសត្រូវទេ ។ មូលហេតុនេះ អង្គការអនាមិកចាត់បញ្ជូនយោធាយ៉ាងច្រើនលើសលប់ មកព័ទ្ធមូលដ្ឋាននៅបូរីកីឡា និងមូលដ្ឋាន១០០ខ្នង ចាប់តាំងពីម៉ោង៥ព្រឹកនៅថ្ងៃទី១៦មេសា ។ លុះយប់មកដល់ក៏ចាប់បាញ់គ្រាប់បំផ្លោង ស្រោចមកលើមូលដ្ឋានបូរីកីឡាដូចរន្ទះ ។

ស្អែកឡើងម៉ោង៧ព្រឹកនៃថ្ងៃទី១៧មេសា ខ្មាំងចូលកាន់កាប់មូលដ្ឋានទាំងពីរនោះទាំងស្រុង ។ អង្គការបញ្ជាឲ្យសម្លាប់ចោលទាំងអស់ ទាំងប្រពន្ធទាំងកូន ។ តាំងពីព្រឹត្តិការណ៍នោះមក យើងមិនដែលបានជួបកងទ័ពម៉ែកហ្វ៍ក្សណា សូម្បីមួយនាក់ក៏ទេឡើយ...។

ក្រៅពីកងទ័ពម៉ែកហ្វ៍ក្សនោះ អង្គការប្រើតែកលល្បិចដែលចុចចំចំណុចខ្សោយ ទាំងទាហានទាំងរដ្ឋមន្ត្រី ទៅឈរតំរៀបគ្នាជាជួរ ឲ្យគេយកទៅសម្លាប់ចោលដោយមិនបាច់ប្រើខ្ចោះឃ្នាងច្រវាក់ផង...។

នឹកៗឡើងគួរឲ្យខ្មាស់អៀនជាក្រៃលែង !...

ខេត្តបាត់ដំបងជាខេត្តទី២នៃប្រទេសកម្ពុជា, សំបូរទៅដោយត្រីគ្រប់យ៉ាង ផ្លែឈើគ្រប់មុខ និងព្រៃឈើដ៏មានតម្លៃ ។ ដីមានជីវជាតិ, បើអ្នកណាព្យាយាមកាប់គាស់ដាំដុះបង្កើតផល អ្នកនោះតែងទទួលផលដ៏គាប់ប្រសើរជានិច្ច ។ ទាំងប្រជាជនខ្មែរទាំងបរទេសរស់នៅសែនសុខក្សេមក្សាន្ត ។

ទីក្រុងបាត់ដំបងរៀបចំទាន់សម័យទំនើប គួរឲ្យគយគន់មិនចាញ់ទីក្រុងបរទេសឡើយ ។ មានហាងលក់ទំនិញគ្រប់មុខ គ្មានខ្វះអ្វីឡើយ ។ ព្រំប្រទល់ខេត្តបាត់ដំបងជាប់នឹងប្រទេសថៃ ។ មានស្ទឹងមួយឈ្មោះស្ទឹងសង្កែ អាចផ្តល់ទឹកបានគ្រប់គ្រាន់ ព្រមទាំងមានត្រីដ៏បរិបូណ៌ ។ ប្រជាជនដែលមានលំនៅតាមដងស្ទឹងនេះអាចនេសាទត្រីសំរាប់ធ្វើជាអាហារចិញ្ចឹមជីវិតជាអចិន្ត្រៃយ៍ដោយសេរី ។

ពីមុនសង្គ្រាម ទីក្រុងបាត់ដំបងមានប្រជាជនប្រហែលបួនម៉ឺននាក់ ។ ក្នុងរយៈ៥ឆ្នាំដែលសង្គ្រាមផ្ទុះឡើង ប្រជាជនអ្នកស្រែចំការដែលភ័យតក់ស្លុតខ្លាំងពេក ក៏នាំគ្រួសាររត់ចេញចោលទីលំនៅ ភៀសខ្លួនមកជ្រកនៅទីក្រុង ។ នៅឆ្នាំ១៩៧៥ ទីក្រុងបាត់ដំបងមានមនុស្សប្រហែល១លាននាក់ ។ ប្រជាជនទាំងឡាយនោះកំពុងតែព្រួយបារម្ភនឹងការអត់ឃ្លាន ស្រាប់តែនៅវេលាម៉ោង១១នៃថ្ងៃទី១៧មេសា១៩-៧៥ មានចៅហ្វាយថ្មីចូលមកជំនួសលោកសេនាប្រមុខលន់-នល់ ។ គេស្រាប់តែឮសម្លេងរបស់លោកខៀវ-សំផនថ្លែងអួតថ្ងៃដែលៗចំនួន៣ថ្ងៃ ពីជ័យជំនះដ៏មហាអស្ចារ្យនេះតាមរយៈវិទ្យុរណសិរ្សរួបរួមជាតិកម្ពុជា ។

មូលហេតុនេះ ខ្មែរនៅបាត់ដំបងត្រេកអរជាក្រៃលែង ព្រោះស្មានថាជ័យជំនះដ៏មហាអស្ចារ្យនេះ គឺជាស្នាព្រះហស្តរបស់សម្តេចឪ ដែលមានលោកខៀវ-សំផនមេខ្មែរក្រហមជាអ្នកគាំទ្រ ។ ប្រសើរណាស់ៗ !!! ។

ម៉ោងប្រហែល៨ល្ងាចនៃថ្ងៃទី១៧មេសា ប្រជាពលរដ្ឋខ្មែរនៅទីក្រុងបាត់ដំបងបបួលគ្នារៀបក្បួនរ៉ឺម៉ក ដឹកលប់រូបថតសម្តេចឪយ៉ាងធំៗ ហែរព័ទ្ធទីក្រុង វាយធុងវាយឡាំង ស្រែកជយោសម្តេចឪយ៉ាងកងរំពង ។

យប់នោះអ្នកមានអាវុធក៏បាញ់ទៅលើអាកាសស្រែកអបអរសាទរសប្បាយរីករាយទទួលជ័យជំនះក្លែងបន្លំនេះ ។ យុវជន យុវនារីបបួលគ្នាច្រៀងរាំយ៉ាងសប្បាយ ដោយជឿនិងសង្ឃឹមថា ស្អែកៗនេះប្រទេសកម្ពុជានឹងបានសន្តិភាពឡើងវិញហើយ ។ អ្នកស្រែចំការត្រេកអរជាក្រៃលែង ដោយសង្ឃឹមយ៉ាងមាំថា ស្អែកនេះអាចនាំគ្រួសារវិលត្រឡប់ទៅកាន់ទីលំនៅប្រកបកសិកម្មឡើងវិញដោយសេរី ។

មើលចុះបងប្អូនរួមឈាមអើយ ! នឹកឃើញរឿងនេះឡើងគួរឲ្យខ្មាស់អៀនយ៉ាងខ្លាំង មិនគួរមេដឹកនាំខ្មែរទាំងសក្តិភូមិ ទាំងខ្មែរក្រហមខ្វះសមត្ថភាព បណ្តោយឲ្យប្រជាពលរដ្ឋខ្មែរ វរល់តែស្មានយល់ច្រឡំយ៉ាងនេះឡើយ ?!?! ។

ចំណែកឯអង្គការវិញ វាតាមដានរកចំណុចខ្សោយនៃប្រជាពលរដ្ឋខ្មែរគ្រប់ៗ ជំហាន ពេលនេះវាជ្រើសបានអាវុធមួយយ៉ាងសក្តិសិទ្ធិ ដើម្បីសម្លាប់នាម៉ឺនខ្មែរគ្រប់ៗផ្នែកនៅខេត្តបាត់ដំបង ព្រោះវាឃើញប្រជាពលរដ្ឋខ្មែរជាទូទៅស្រឡាញ់សម្តេចឪយ៉ាងមុតមាំណាស់ ។ ដូច្នេះត្រូវសម្លាប់នាម៉ឺនទាំងនោះឲ្យទាន់ពេលវេលា ពន្យាពេលមិនកើតទេ នាំបណ្តាលឲ្យមានឧបសគ្គជាពុំខាន...ដូច្នេះត្រូវតែប្រើឈ្មោះសម្តេចឪធ្វើជានុយ ធ្វើជាអាវុធ... ប្រសើរណាស់ៗ !!! ។

អង្គការយល់យ៉ាងនេះភ្លាម ក៏ខ្ចីមាត់លោកឡេង-រ៉ាអុល ជាវរសេនិយឯកនិងជាមេបញ្ជាការសឹករងខេត្តបាត់ដំបង ដែលពេលនេះត្រូវទទួលងារជាបន្ថែម គឺត្រូវឡើងជំនួសមេបញ្ជាការធំ ដែលរត់គេចចោលដំណែងតាំងពីម៉ោង២រសៀលមកម្ល៉េះ ឲ្យចេញបញ្ជាបន្លំបោកបញ្ឆោតដូចតទៅនេះ ៖

ចាប់តាំងពីថ្ងៃទី១៧មេសាវេលាម៉ោង១០យប់ទៅ ឡេង-រ៉ាអុលជាមួយមេខ្មែរក្រហម បណ្តាក់គ្នាផ្សាយតាមវិទ្យុខេត្របាត់ដំបង ចេញបញ្ជាជាដាច់ណាត់ ដល់នាយទាហាន នាយទាហានរង និងពលទាហានគ្រប់ៗផ្នែក ត្រូវនៅស្ងប់ស្ងៀមចាំស្តាប់បញ្ជាជាថ្មី ។ បញ្ជាថ្លែងបន្ថែមទៀតថា ស្អែកឡើងថ្ងៃទី១៨មេសា ត្រូវប្រមូលអាវុធទាំងអស់ចងជាបាច់ រួចដឹកនាំយកមកប្រគល់ឲ្យទីបញ្ជាការការិយាល័យទី៣ជាកំហិត រួចទៅជួបជុំទាំងអស់គ្នា នៅសាលាខេត្តបាត់ដំបងជាដាច់ខាត រង់ចាំទទួលបញ្ជាជាថ្មី ។ ចំណែកខាងស៊ីវិលទូទៅ ក៏ត្រូវនាំអាវុធផ្ទាល់ខ្លួនយកមកប្រគល់ឲ្យអង្គការនៅសាលាខេត្តបាត់ដំបងចាប់តាំងពីម៉ោង៨ស្អែកនេះដែរ ព្រោះសង្គ្រាមចប់ត្រឹមណោះហើយ ។ លុះព្រលឹមឡើង នាយទាហាន នាយទាហានរងមកជួបជុំកកកុញនៅទីកំណត់, ស្រាប់តែស្ងាត់ច្រៀប គ្មានឃើញថៅហ្វាយថ្មីឡើយ ។ រីឯជនស៊ីវិលក៏យកអាវុធទៅគរទុកមួយគំនរធំនៅមុខវិមានលោកអភិបាលខេត្តបាត់ដំបង ។ ប៉ុន្តែឃើតតែយោធាក្មេងៗចំនួន១៥នាក់កាន់កាំភ្លើងអាអ៊ែរកែងគ្រប់ដៃឈរចាំទទួលអាវុធទាំងនោះ ។ ល្ងាចឡើងថ្ងៃដដែល ប្រជាពលរដ្ឋខេត្តបាត់ដំបងបែរជាអស់សង្ឃឹមគ្រប់ៗរូបភ័យតក់ស្លុតស្លន់ស្លោ ព្រោះកងទ័ពដែលចូលមកគ្រប់គ្រងខេត្តបាត់ដំបង ជាអតិតចោរព្រៃ ដែលជាអ្នកដឹកនាំយោធាក្មេងៗ ដែលមានអាយុជាមធ្យមតែ១៥ឆ្នាំប៉ុណ្ណោះ, ស្លៀកពាក់ខ្មៅ បង់ក្រមានៅក ស្បែកជើងកង់ឡាន កាន់កាំភ្លើងអាអ៊ែរកែងគ្រប់ដៃ, មានទឹកមុខយ៉ាងសាហាវ ដូចមានគំនុំមកពីនាយ ។ ឈរគ្រប់ផ្លូវជាក្រុមៗ មកដល់ជាដំបូង ក៏ចាប់ប្រតិបត្តិការគ្រប់គ្រងប្រទេសកម្ពុជា តាមបច្ចេកទេសដែលធ្លាប់ធ្វើជាចោរប្លន់ ។ ប៉ុន្តែពាក្យប្លន់បានប្រែជាពាក្យស្មើ ដែលកាចសាហាវឃោរឃៅជាងពាក្យប្លន់ទៅទៀត ព្រោះច្បាប់របស់អង្គការប្រគល់អភ័យឯកសិទ្ធិឲ្យចោរដើរស្មើ, បើម្ចាស់រឹងទទឹង សម្លាប់ចោលចុះរួច

ចោទថាក្បត់អង្គការ...។

ទ្រព្យដែលស្នើជាដំបូងនោះគឺ ឡាន, ម៉ូតូ, កង់, វិទ្យុ, នាឡិកាដៃ, ស្ទីឡូ ។ល។ គ្រប់ៗទីកន្លែង ។ ចោរយោធាក្មេងៗទាំងនោះរៀនស្ទាត់ចាំមាត់តែពាក្យមួយឃ្លា និយាយទៅកាន់ម្ចាស់ទ្រព្យដូចៗគ្នាថា ៖

« អង្គការសុំស្នើមួយរយៈសិន សឹមសងវិញថ្ងៃក្រោយ » ។ ព្រលឹមថ្ងៃទី១៩ មេសា ទទួលពត៌មានដ៏ច្បាស់ការណ៍មកថា អង្គការបញ្ជាឲ្យឃាតករបាញ់សម្លាប់ លោកវររសេនិយឯក តាន់-ប៉ុក ជាវេជ្ជបណ្ឌិតមន្ទីរពេទ្យទាហាន ព្រមទាំងសហការី១២នាក់ នៅភូមិបឹងព្រីង ស្ថិតនៅចម្ងាយ៥គីឡូម៉ែត្រ ខាងលិចទីក្រុងបាត់ដំបង ។ បន្ទាប់មកទទួលដំណឹងអកុសលមកថា ៖ មានឡានកាម៉្មុងបីគ្រឿងដឹកនាយទាហាននិងទាហានខ្លះ នាំយកទៅបាញ់ចោលខាងត្បូងភូមិឈ្លៀវចម្ងាយ៣គ.ម. ខាងកើតភ្នំធិបតី ។ ថ្ងៃដដែលម៉ោង៣រសៀល មានឡានកាម៉្មុង៤គ្រឿងបរចូលមក ដឹកនាយទាហាននិងទាហានខ្លះ ដែលសំណាក់នៅក្នុងបរិវេណវិទ្យាល័យបាត់ដំបង នាំយកទៅបាញ់សម្លាប់ចោលនៅភូមិដង្កោខ្មើយ ខាងលិចផ្លូវជាតិលេខ៥ ចម្ងាយ៥០០ម៉ែត្រ ។ ពេលឃាតករអាចកំបាំងបាញ់គ្រាប់សាចព្រូដូចរន្ទះគ្មានអាសូរ នោះ មានលោកស័ក្តិប្រាំ គាំ-គីរី និងលោកស័ក្តិ៤ ភឹម-អូន និងអ្នកបើកបរឡាន ម្នាក់ឈ្មោះ ថាច់-ស៊ុនលីបានគេចរត់រួច ។ នៅល្ងាចថ្ងៃទី១៩មេសា ប្រជាពលរដ្ឋ ខ្មែរនៅក្នុងទីក្រុងបាត់ដំបងកើតចលាចលតក់ស្លុតយ៉ាងខ្លាំង ព្រោះទទួលដំណឹង បន្ថែមមិនគួរឲ្យជឿថា ប្រជាពលរដ្ឋដែលមានទីលំនៅនៅជិតទីក្រុង នាំគ្រួសារទៅ កាន់ផ្ទះសំបែង ស្រាប់តែត្រូវយោធាក្មេងៗសុំស្នើទ្រព្យសម្បត្តិអស់រលីងពីខ្លួន រួច ដេញមិនឲ្យចូលផ្ទះ ។ល។ ពេលនោះទីក្រុងបាត់ដំបងមានមនុស្សកកកុញជាច្រើន លើសលប់ដើរទៅដើរមក ប្រជ្រៀតខ្សឹបខ្សៀវសួរគ្នាថា ៖ តើនរណាទទួលជ័យជំនះនេះ ? មិនមែនសម្តេចឪ មិនមែនខៀវ-សំផនទេឬ ? ប្រហែលជាចោរទេដឹង ? កំពុងជ្រួលច្របល់ ស្រាប់តែទទួលដំណឹងគួរឲ្យកក់ក្តៅមកថា ពីព្រឹកមិញម៉ោង៩ មានឈ្មោះ សូកូ ហៅមិត្តស៊ុយ និងលោកខែក-ប៉ែន ហៅមិត្តស៊ូ ផ្នែកយោធានិង ផ្នែកនយោបាយ មានបើកអង្គប្រជុំជាលើកទីមួយនៅមហាវិទ្យាល័យចំពោះមុខ សាស្ត្រាចារ្យ គ្រូបង្រៀន និងនិស្សិត ។ ល្ងាចនេះម៉ោង៤រសៀល មានបើកអង្គ ប្រជុំជាលើកទី២ នៅបន្ទាយកងទ័ពផ្នែកចិត្តសាស្ត្រ ចំពោះនាយទាហានគ្រប់ៗ ផ្នែក ។ ស្អែកថ្ងៃទី២០មេសា ម៉ោង៩នឹងមានបើកអង្គប្រជុំជាលើកទី៣នៅសាលា ខេត្តបាត់ដំបង ចំពោះនាម៉ឺនអ្នករដ្ឋការគ្រប់ៗផ្នែក ទាំងផ្នែកស៊ីវិល ទាំងផ្នែកប្រជាពលរដ្ឋទូទៅ ។

ពេលវេលាបើកអង្គប្រជុំទូទៅមកដល់ ប្រជាពលរដ្ឋខ្មែររត់ប្រញាប់ អររផង

ភ័យផង ទៅជួបនិងទៅទទួលចៅហ្វាយថ្មី ទៅស្តាប់ផែនការម្ចាស់ថ្មី ។ ប្រជាពលរដ្ឋខ្មែរមានចំនួនប្រហែលជាង៥ពាន់នាក់ ប្រជ្រៀតគ្នាចូលកាន់សាលាខេត្តគ្រប់ៗរូប មានទឹកមុខក្រៀមស្ងួត ។

ម៉ោង១០គត់ មិត្តស៊ូផ្នែកនយោបាយ និងមិត្តស៊ុយផ្នែកយោធាចូលមកដល់ស្លៀកពាក់ខ្មៅ ក្រមារ៉ណ្ណក ស្បែកជើងធ្វើពីកង់ឡាន ។

មិត្តស៊ូក៏បើកអង្គប្រជុំប្រកាសថា ខ្ញុំនិងមិត្តស៊ុយមកជួបមិត្តទាំងអស់នេះ ជាតំណាងអង្គការផ្ទាល់...។ ពេលឮឈ្មោះអង្គការ ប្រជាពលរដ្ឋទាំងអស់ភ្ញាក់ ក៏កេះខ្សឹបៗសួរគ្នាថា តើអង្គការជានរណាអេះ ? ។ ដូច្នេះមិនមែនសម្តេចឪ មិនមែនលោកខៀវ-សំផនទេឬ ដែលត្រូវទទួលជ័យជំនះនេះ ? ។ មិត្តស៊ូបានឮពាក្យខ្សឹបខ្សៀវនេះច្បាស់លាស់ណាស់ ប៉ុន្តែវាធ្វើថ្លង់ហើយខំនិយាយកុហកតាមកលល្បិចនិងផែនការរបស់អង្គការដែលព្រាងទុកឲ្យជាស្រេច សមដូចពាក្យបូរាណមួយឃ្លាដែលបានចែងថា ៖ « អូសទូកកុំឲ្យល្អាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក » ។

ពាក្យកុហករបស់មិត្តស៊ូដែលខ្ញុំបានឮផ្ទាល់ត្រចៀក មានជាអាទិដូចតទៅ ៖

« មិត្តរួមជាតិជាទីស្នេហាទាំងឡាយ ! អង្គការចាត់បញ្ជូនខ្ញុំនិងមិត្តស៊ុយមកកាន់ទីនេះ ដើម្បីបើកការប្រជុំជាលើកទី៣ក្នុងទីក្រុងបាត់ដំបង ។ ពួកខ្ញុំនាំពាក្យរបស់អង្គការផ្ទាល់មកជំរាបមិត្តទាំងអស់ សុំកុំតក់ស្លុតឆ្ងល់ពីរឿងដែលអង្គការបានបញ្ជាឲ្យសម្លាប់នាយទាហាននិងទាហានខ្លះៗនោះឲ្យសោះ ។ ព្រោះនៅថ្ងៃទី១៨មេសាម៉ោង១០ យោធាយើងចាប់បានថ្នាំពេទ្យមួយឡានឡង់រ៉ូវែរ បរឆ្លងស្ពានថ្មថ្មីទៅកាន់ផ្លូវលេខ៥ បំរុងរត់ចេញពីប្រទេសខ្មែរ ។ មេទាហានដែលប្រព្រឹត្តបទល្មើសនោះ គឺលោកតាន់-ប៉ុក និងមិត្ត១២នាក់ ។ ចំណែកនាយទាហាននិងទាហាន៧ឡានកាម៉្ញង ដែលអង្គការចេញបញ្ជាឲ្យនាំយកទៅសម្លាប់ចោលជាបន្ទាន់នោះព្រោះមិត្តទាំងអស់នោះក្បត់អង្គការ មានលាក់អាវុធបំរុងតបតចំពោះអង្គការ ដែលជាអ្នកមានគុណដ៏លើសលប់ចំពោះប្រជាពលរដ្ឋខ្មែរ ។ ដូច្នេះត្រូវតែសម្លាប់ ដើម្បីការពារឧបស័គ្គនិងទុកជាគំរូ » ។

មិត្តស៊ូនិយាយកុហកយ៉ាងវែង លុះចប់ក៏សម្លឹងមុខមិត្តស៊ុយជាសញ្ញាឲ្យនិយាយតរបន្ត ។ មិត្តស៊ុយក៏ចាប់ផ្តើមនិយាយកំញើញថា ៖

« នែ ! មិត្តអើយ... មិត្តមិនអាចធ្វើអ្វីៗកំបាំងភ្នែករបស់អង្គការបានឡើយ អង្គការមានភ្នែកដូចផ្លែម្នាស់ ។ ចូរមិត្តកុំយកតម្រាប់តាមអាក្បត់ទាំងឡាយនោះឲ្យ សោះ យើងត្រូវតែឃើញនិងដឹងគុណអង្គការ ។ មើលចុះប្រទេសយើងតូចមែន ពិតតែដោយសារអង្គការ យើងអាចសំរេចជោគជ័យវាយឈ្នះជប៉ុន, បារាំង, អាមេរិកាំង ជាមហាអំណាចក្នុងពិភពលោក និងបរិវារវា ។ ជោគជ័យនេះយើងអង្គុយ

រង់ចាំ២ពាន់ឆ្នាំមកហើយ ។ល។ ចាប់ពីពេលនេះទៅ អង្គការប្រកាសជាឱឡារិកលើកលែងឈប់ប្រកាន់ទោសប្រជាជនខ្មែរទាំងអស់ ទោះជានាយទាហាន ទាហា ន អ្នករដ្ឋការគ្រប់ផ្នែក គ្រប់ៗជាន់ថ្នាក់ យើងត្រូវចាប់ដៃបង្រួបបង្រួមសាមគ្គីគ្នាកសាងប្រទេសជាតិមាតុភូមិសារជាថ្មី ។ ប្រជាជនអ្នកស្រែចំការអាចនាំគ្រួសារ គោក្របីវិលត្រឡប់ទៅកាន់ទីលំនៅរៀងៗខ្លួនបាន ព្រោះរដូវធ្វើស្រែជិតមកដល់ហើ-យ ។ អង្គការមានចាត់ការបង្កើតជាសមរភូមិដើម្បីវាយសំរុក ដើម្បីកសាងជាតិ »។

លុះពោលចប់នូវពាក្យកុហកនេះហើយ មិត្តស៊ុយបញ្ជាឲ្យប្រជាជនស្រែកតាមវាថា ៖ ជយោអង្គការដ៏មហិមា ! ជយោមហាលោតផ្លោះ មហាអស្ចារ្យ ! ។ ប្រជាជនទាំងនោះក៏ស្រែកបន្ទរតាមទាំងទឹកមុខក្រៀមក្រំ ព្រោះមិនយល់ន័យរបស់ពា-ក្យ «សមរភូមិ, វាយសំរុក» មិនដឹងថាតើមិត្តស៊ុយនិងមិត្តស៊ូនេះចង់និយាយថាដូ-ម្តេច ! ម៉្យាងទៀតមិនស្គាល់ថានរណាជាអង្គការផង ។ លុះវិលត្រឡប់មកជួបគ្រួ-សារវិញ ប្រជាជនទាំងឡាយនោះក៏អង្គុយត្របោមក្បាលជង្គង់គ្រវីតែក្បាលគ្មានពាក្យឆ្លើយនឹងសំនួររបស់ប្រពន្ធកូន, ព្រោះសេចក្តីថ្លែងការណ៍របស់វាទាំងពីរ នោះដូចជាងងឹតអន្ធកា មានលាក់ពុតយ៉ាងអាថ៌កំបាំងគួរឲ្យសង្ស័យជាយ៉ាងខ្លាំង ។

ចំណែកមិត្តស៊ូនិងមិត្តស៊ុយវាប្រមូលអ្នករដ្ឋការគ្រប់ផ្នែក ទាំងកងទ័ពទាំងស៊ីវិល រួចបំបែកតាមក្រុម និយាយយ៉ាងផ្អែមត្រជាក់កុហកថា គឺដើម្បីងាយការពារសន្តិសុខនិងចែកស្បៀងអាហារ ព្រោះអង្គការផ្អាកចាយលុយមួយរយៈសិន ។

ដូច្នេះក្រុមទី១ជានាយទាហានត្រូវសំណាក់នៅក្នុងបរិវេណសាលា សោហឺ, ក្រុមទី២ជានាយទាហានរង ត្រូវសំណាក់នៅក្នុងបរិវេណវិទ្យាល័យអ៊ាបយុត ។ ក្រុមទី៣ សមណាក់នៅក្នុងបរិវេណវិទ្យាល័យព្រះមុនីវង្ស ។ ក្រុមទី៤ជាពួកនាម៉ឺនអ្នករដ្ឋការស៊ីវិលគ្រប់ផ្នែក សំណាក់នៅក្នុងបរិវេណសាលាខេត្តបាត់ដំបង ។

ថ្ងៃទី២០មេសា ពេលដែលមិត្តស៊ុយនិងមិត្តស៊ូ កំពុងតែបើកសម័យប្រជុំនៅសាលាខេត្តបាត់ដំបង នៅឯវិទ្យាល័យព្រះមុនីវង្សឯណោះ ទាហានប្រមាណ ១,៣៥០នាក់ កំពុងតែតម្រៀបជួរគ្នាឡើងឡានកាម៉្យុង១៥គ្រឿង ។ ម៉ោង៣រសៀលថ្ងៃដដែល កន្លែងដដែល មានឡានកាម៉្យុង១១គ្រឿងចូលទៅដឹកទាហាន៩០០នាក់ទៀត ។ ក្បួនឡានទាំង២លើកបរឆ្លងកាត់ស្ពឹងសង្កែ តាមស្ពានថ្មថ្មី ទៅកាន់ផ្លូវជា-តិលេខ៥ ដឹកយកទៅចូលកណ្តាលអន្ទាក់ ដែលក្រុមឃាតករអាថ៌កំបាំងរៀបចំខ្សែត្រៀមរង់ចាំជាស្រេចនៅផ្លូវចូលនិគមសម្តេចឪស្វាយដូនកែវ ត្រូវក្រុមនេះបាញ់សម្លាប់ចោលខ្ទេច ។

នៅថ្ងៃទី២៣មេសា ម៉ោងប្រហែល៩ព្រឹក មិត្តស៊ុយជាតំណាងអង្គការ មានវរសេនិយឯក ឡេង-វ៉ាអ៊ុល ស្លៀកពាក់ឯកសណ្ឋានយ៉ាងស្អាតដើរជាមួយ មានកាន់

បញ្ជីមួយសន្លឹកក្នុងដៃ បណ្ដើរគ្នាចូលទៅកាន់សាលាសោហី រួចហៅឈ្មោះនាយទាហានជាលំដាប់លំដោយ រួចចេញបញ្ជាឲ្យទៅកាន់ទីលំនៅរៀងៗខ្លួនយ៉ាងយូរកន្លះម៉ោង ដើម្បីស្លៀកពាក់ឯកសណ្ឋានឲ្យបានត្រឹមត្រូវ ដើម្បីទៅទទួលសម្ដេចឪដែលព្រះអង្គយាងមកតាមឧទ្ធម្ភាគចក្រចុះចតនៅក្បែរភ្នំធិបតី ។ លុះនាយទាហានទាំងអស់នោះវិលមកជួបជុំគ្រប់ចំនួនតាមបញ្ជីស្រេចបាច់ ក៏ហែរក្បួនពីសាលាសោហីទៅកាន់សាលាខេត្តបាត់ដំបង ដែលមានឡានកាម៉ុង៦គ្រឿងរៀបជាក្បួនរង់ចាំនៅទីនោះជាស្រេច ។ នាយទាហានទាំងអស់នោះក៏ឡើងឡានទាំងទឹកមុខញញឹម ។

ថ្ងៃដដែលម៉ោង១កន្លះរសៀល ក្បួនឡានកាម៉ុងទាំង៦គ្រឿងដដែលដឹកនាយទាហានស្លៀកពាក់ឯកសណ្ឋានយ៉ាងស្អាតជាច្រើនរយនាក់ទៀត ខ្លះឈរ ខ្លះអង្គុយ ខ្លះជិះលើដំបូល ប្រជ្រៀតជាន់លើគ្នា ។ នៅខាងមុខក្បួនមានឡានហ្សីបមួយគ្រឿងនិងឡង់រ៉ូវែរមួយគ្រឿង ដែលមានមេខ្មែរក្រហម១០នាក់ជិះជាអ្នកនាំផ្លូវ មានកាំភ្លើងខ្លីនៅចង្កេះគ្រប់ៗគ្នា ។ ខាងក្រោយក្បួន មានឡានកាម៉ុងមួយគ្រឿងផ្ទុកយោធាក្មេងៗប្រមាណ៣០នាក់ កាន់កាំភ្លើងអាអ៊ែរកែងនៅដៃគ្រប់ៗគ្នា ជាអ្នកហែរហមការពារ ។ យោធាក្មេងៗទាំងនេះមុខញញឹម សើចស្ញេញស្ញាញដូចស្វាបានចេកសប្បាយរីករាយត្រេកអរណាស់ ព្រោះនឹកស្មានថាបានជួបឃើញសម្ដេចឪមុនគេ...។ យោធាក្មេងៗទាំងនោះមិនបានដឹងទាល់តែសោះនូវកលល្បិចរបស់អង្គការដែលបញ្ឆោតប្រមូលជនជាតិរបស់ខ្លួនសុទ្ធតែនាយទាហានធំៗ ដឹកយកទៅសម្លាប់ចោលលេងៗទទេៗយ៉ាងនោះទេ ។ ក្បួនឡានទាំង៩គ្រឿង ( ឡាននាំមុខ២ ហ្សីប និង ឡង់រ៉ូវែរ, ឡានកាម៉ុងទាំង៦គ្រឿងដឹកទាហាន, ឡានកាម៉ុងមួយគ្រឿងខាងក្រោយដឹកយោធាក្មេងៗ ) ហែរចាកចេញពីសាលាខេត្តបាត់ដំបង បរឆ្លងស្ពឹងសង្កែតាមស្ពានចាស់ ទៅកាន់ផ្លូវជាតិលេខ៥ ។ លុះក្បួនឡានបរចេញផុតពីស្ពានលោកវរសេនិយឯកមូល-សារី និយាយខ្សឹបៗជំរាបលោកឡេង-រ៉ាអ៊ុលថា ៖ ព្រះតេជគុណ អាអស់នេះបញ្ឆោតនាំពួកយើងយកទៅសម្លាប់ទេ ។ លោកឡេង-រ៉ាអ៊ុលព្រមានថា ៖ មាត់ស៊ីអំបិលប្រហុក មិនត្រូវនិយាយដូច្នេះទេណ៎ា ។

ក្បួនឡានទាំង៩គ្រឿងបើកបរបានតែ៣០គ.ម.ក្នុង១ម៉ោងតែប៉ុណ្ណោះ ព្រោះផ្លូវជាតិលេខ៥ខូចខាតមិនដែលបានជួសជុលឡើងវិញទេ ក្នុងរយៈពេល៥ឆ្នាំនៃសង្គ្រាមនេះ ។ ឡានរលាក់ធ្វើឲ្យអ្នកជិះម្នាក់ស្ទើរធ្លាក់ពីលើឡាន ក្បាលនិងក្បាលទង្គិចគ្នាជាញឹកញាប់ ។ ឥឡូវនេះក្បួនឡានក៏មកដល់ភូមិកាច់រទេះ ឡានរលាក់ខ្លាំងពេក ក្បាលមូល-សារីក៏ស្រាប់តែទង្គិចក្បាលឡេង-រ៉ាអ៊ុលយ៉ាងខ្លាំង ។ មូល-សារីយកដៃអង្អែលក្បាលបណ្ដើរ ភ្នែកសម្លឹងទេសភាពភូមិកាច់រទេះដ៏ស្ងាត់ច្រៀប

បណ្តើរ ។ លោកធ្លាប់ចេញចូលភូមិនេះគ្រប់ច្រកល្ហក ។ លោកក៏កេះលោកឡេង-វ៉ាអ៊ុលម្តងទៀតព្រមទាំងខ្សឹបថា ព្រះតេជគុណកុំទុកចិត្តពួកវាឲ្យសោះ ! យើងគួរលៃលករំដោះខ្លួនណា៎ ។ ទីនេះជាភូមិកាច់រទេះមានសភាពស្ងាត់ល្ហណាស់ ទាំងប្រជាជន ទាំងខ្មែរក្រហម គ្មានឃើញម្នាក់ឡើយ ។ ពួកយើងមានគ្នាច្រើនរយនាក់ អ្នកបើកបរឡានក៏គ្នាយើង ក្រុមវាមានតែ៤០នាក់ប៉ុណ្ណោះទេ ។ល។

ពេលនោះលោកឡេង-វ៉ាអ៊ុលបែរជាមួរម៉ៅ ក៏ទះកំភ្លៀងលោកមូល-សារីមួយដៃយ៉ាងដំណំ រួចក៏ច្រានដេញចុះពីឡាន ។ លោកមូល-សារីត្រូវតែបង្ខំចិត្តនៅស្ងៀមម្តងទៀត...។

ក្បួនឡានទាំង៩គ្រឿងបរមកដល់ផ្លូវបំបែកទៅស្តៅ ក៏កាច់ចូលទៅកាន់ភ្នំធិបតី នាយទាហានដែលជិះឡានកាម៉្ញុងទាំង៥គ្រឿងផ្សេងនោះមានទឹកមុខញញឹមព្រោះសង្ឃឹមថា មានតែក្រុមខ្លួនទេដែលបានលុតក្រាបសម្តេចឪមុនគេ ។ ដើម្បីជារង្វាន់លើកទឹកចិត្ត សម្តេចឪមុខតែនឹងដម្លើងឲ្យអាត្មាអញបានមួយក្រឹតទៀតជាពុំខាន ។ ចំណែកនាយទាហានដែលជិះក្នុងកាម៉្ញុងជាមួយមូល-សារី ដោយបានឮពាក្យខ្សឹប-ខ្សៀវ ក៏ប្រែទឹកមុខទៅជាជូរដូចស៊ីក្រូចឆ្មាទៅវិញ ។

ក្បួនឡានទាំង៩គ្រឿងក៏ឈប់សំចតនៅភូមិឈៀវ ចម្ងាយ៣គ.ម.ខាងកើតភ្នំធិបតី ។ ពេលនោះឡានហ្ស៊ីបនិងឡង់រ៉ូវែរដែលមេខ្មែរក្រហមទាំង១០នាក់ជិះនោះក៏បរត្រឡប់មកក្រោយ រួចស្រែកបញ្ជាដេញឲ្យពួកនាយទាហានទាំងនោះចុះពីឡា-ន ព្រមទាំងហាមថា មិនបាច់ឲ្យយកអ្វីៗមកតាមខ្លួនឡើយ ។ ចូរសំរាកនៅទីនេះសិនចុះ ចំណែកយើងៗនាំឡានទាំងអស់ទៅទីក្រុងបាត់ដំបង ដើម្បីនឹងដឹកនាំអ្នករដ្ឋការផ្សេងៗមកបន្ថែមទៀត ។ លុះក្បួនឡានទាំង៩គ្រឿងបរចេញផុតបន្តិច លោកមូល-សារីអត់ទ្រាំមិនបានក៏ស្រែកបញ្ជាថា ៖ ព្រះតេជគុណទាំងអស់គ្នា ក្នុងនាមខ្ញុំជាមេទ័ពម្នាក់ ខ្ញុំសូមចេញបញ្ជាជំនួសលោកឡេង-វ៉ាអ៊ុល ! ពេលនេះអាសន្នមកដល់យើងទាំងអស់គ្នាហើយ ! ដូច្នេះបើមានគ្រាប់កាំភ្លើងបាញ់ស្រោចមកលើយើង សូមលោកដែលមិនទាន់ស្លាប់ ត្រូវតែរួមកម្លាំងគ្នារត់សំរុកចូលដណ្តើមអាវុធពីខ្មាំងមកវិញ ដើម្បីតទល់រួចពីក្តីស្លាប់ ។ ពាក្យបញ្ជាក៏ត្រូវចប់ត្រឹមណោះ ព្រោះឃាតករចាប់ផ្តើមបាញ់កាំភ្លើងធំឮដូចរន្ទះ ស្រោចមកលើ ចេញមកពីទិសទាំង៨ ។ គ្រាប់មានគ្រប់ធុន ៣០ម.ម., ៦០ម.ម., ៨១ម.ម. និង អាកា៤៧ ។ នាយទាហានទាំងអស់នោះដួលស្លាប់គរលើគ្នា ។

ចំណែកលោកមូល-សារី លុះគ្រាអាសន្នមកដល់យ៉ាងនេះ លោកក៏ដោះអាវយ័ន្តលើកទូលលើក្បាល មាត់ជីបអូចៗនឹកគុណមាតាបិតា អំពាវនាវគ្រប់បែបយ៉ាងដៃរបស់លោកអូសទាញនាយទាហាន៣នាក់ឲ្យរត់តាមលោកគឺ វរសេនិយឯកប៉ុល

-សឿន, លោកអនុសេនិយទោយុន និងលោកម្នាក់ទៀតមិនស្គាល់ឈ្មោះ ។ លុះគេចចេញផុតពីលានមរណៈហើយ យប់នោះនាយទាហានទាំងបួននាក់ ក៏សំរេចបំបែកគ្នាទៅកាន់ទីដៅរៀងៗខ្លួន ។ ក្រោយមក លោកអនុសេនិយទោយុន ត្រូវខ្មែរក្រហមចាប់ខ្លួនបាន ហើយបាញ់សម្លាប់ចោលនៅភ្នំសំពៅ ។ ចំណែកលោកមូលសារី បានទៅពួនសំណាក់នៅក្នុងភូមិរនាម-ដូនសំ ។ អង្គការដាក់ទិសឲ្យលោកឃ្វាលគោអស់រយៈពេលបួនឆ្នាំ ។ ចំណែកលោកប៉ុល-សឿននិងមេទ័ពម្នាក់ទៀតនោះបាត់មុខរហូត ។ ក្បួនឡានទាំង៩គ្រឿងក៏បរត្រឡប់ចេញមកកាន់ផ្លូវជាតិលេខ៥វិញ ។ មកដល់ហើយក៏ឈប់សំចតនៅទីនោះមួយសន្ទុះ ។ ស្រាប់តែមានឡានឡង់រ៉ូវែរមួយគ្រឿងបរមកឈប់សំចតទល់ពីមុខ រួចបញ្ចេញអ្នកបើកបរ៦នាក់ថ្មីជំនួសអ្នកមុន ដែលគេដឹកយកទៅបាញ់ចោលនៅខាងត្បូងនោះបន្តិច ។ មេខ្មែរក្រហមបង្គាប់ឲ្យអ្នកបើកបរ៦នាក់ថ្មីដោះលេខឡានគ្រវាត់ចោល រួចបញ្ជាឲ្យបើកបរចូលទៅកាន់ទីក្រុងបាត់ដំបងវិញតាមពួកវា ។

ថ្ងៃដដែលវេលាម៉ោង ២រសៀល មានឡានកាម៉្មុង៩គ្រឿងបរចូលបរិវេណសាលាខេត្តបាត់ដំបង រៀបក្បួនដឹកនាំនាម៉ឺនអ្នករដ្ឋការស៊ីវិល ដូចជាលោកភូឈួយខេត្តទី១-ទី២, នាយការិយាល័យទាំងអស់, ព្រឹទ្ធនាយកមហាវិទ្យាល័យ, នាយកវិទ្យាល័យ និងអ្នកមុខអ្នកការ ទាំងអស់ក្នុងទីក្រុងបាត់ដំបង ។ ពេលនោះលោកៗទាំងអស់ស្លៀកពាក់តាមឯកសណ្ឋាន តាមយសស័ក្តិរៀងៗខ្លួនយ៉ាងត្រឹមត្រូវស្អាតបាតគ្រប់ៗ ញញឹមត្រៀមខ្លួនរង់ចាំនៅទីនោះជាស្រេច ដើម្បីទទួលសម្តេចឪជាទីនឹករលឹក ។

ក្បួនឡានទាំងបួនគ្រឿងហែរចេញពីសាលាខេត្តបាត់ដំបង រួចបរឆ្លងស្ពឹងសង្កែតាមស្ពានថ្មចាស់ទៅកាន់ផ្លូវជាតិលេខ៥ ពេលនោះមានតែឡានហ្សីបមួយគ្រឿងគត់បើកបរពីមុខនាំផ្លូវ ។ ក្នុងឡានហ្សីបមានតែមេខ្មែរក្រហមម្នាក់ មានកាំភ្លើងខ្លីនៅនឹងចង្កេះអង្គុំក្បែរអ្នកបើកបរ ។ នៅបាំងខាងក្រោយមានយោធាក្មេងៗ៣នាក់កាន់កាំភ្លើងអាកែរកែងគ្រប់ៗដៃជាអ្នកការពារ ។

មើលចុះ, វាគ្មានប្រុងប្រយ័ត្នទេ ព្រោះវារៀនសូត្របានស្គាល់ចំណុចខ្សោយនៃវរៈជនខ្មែរទាំងនោះច្បាស់ណាស់, វាមើលងាយ, វាសន្និដ្ឋានលោកទាំងអស់នោះជាកូនទន្សាយអត់ឃ្លាន ឮតែឈ្មោះសម្តេចឪក៏បោលសំរុកចូលអន្ទាក់ដូចឃើញចេកទុំ ។ មានលោកធំខ្លះដែលមិនទាន់មានឈ្មោះក្នុងបញ្ជី ដោយមកពីខ្លួនទើបនឹងផ្លាស់មកដល់ខេត្តបាត់ដំបង ក៏ទៅទទូចសុំគេទៅជាមួយដែរ ។

ក្បួនឡានទាំងប្រាំគ្រឿងបរតាមផ្លូវជាតិលេខ៥ ។ លុះទៅដល់ភូមិអូរតាមៀវស្រុកមោងឫស្សី មានផ្លូវលំមួយកាច់បត់ទៅឆ្វេងទៅកាន់ភូមិជ្រៃ ។ មេខ្មែរក្រហមបញ្ឈប់ឡានហ្សីប រួចលោតចុះធ្វើសញ្ញាបញ្ឈប់ឡានកាម៉្មុងទាំង៩គ្រឿង ព្រមទាំង

ស្រែកបញ្ជាឲ្យអ្នកជិះទាំងអស់ព្រមទាំងអ្នកបើកបរ ចុះពីឡានមិនបាច់យកអ្វីតាមខ្លួនទេ រួចវាបញ្ជាឲ្យបណ្តើរគ្នាទៅកាន់ភូមិជ្រៃ ព្រោះសម្តេចឪចុះឧទ្ធម្ភាគចក្រនៅទីនោះ ។

លុះក្បួនដំណើរដើរផុតតែពីថ្នល់ជាតិបានចម្ងាយតែ៣០០ម៉ែត្រប៉ុណ្ណោះ គឺចំកណ្តាលអន្ទាក់នៃក្រុមឃាតករអាថ៌កំបាំង ដែលអង្គការបញ្ជាឲ្យរៀបចំខ្សែត្រៀមពួនរង់ចាំជាស្រេចយ៉ាងហ្មត់ចត់ ។ ពេលនោះកាំភ្លើងត្បាល់ធុន៣០០ម៉ែត្រប៉ុណ្ណោះ គឺចំកណ្តាលអន្ទាក់នៃក្រុមឃាតករអាថ៌កំបាំងដែលអង្គការបញ្ជាឲ្យរៀបចំខ្សែត្រៀមពួនរង់ចាំជាស្រេចយ៉ាងហ្មត់ចត់ ។ ពេលនោះកាំភ្លើងត្បាល់ធុន៣០ម.ម., ៨១ម.ម និងអាកា៤៧ បាញ់ចេញពីទិសទាំង៤ ស្រោចគ្រាប់មកពីលើដូចរន្ទះ អ្នករងគ្រោះស្លាប់គរលើគ្នាគ្មានសេសសល់ដល់ម្នាក់ឡើយ ។

ខ្មោចទាំងនោះមានគេបានឃើញផ្ទាល់ភ្នែកនិងស្គាល់ គឺលោកភូឈួយខេត្តទី១, ទី២, លោកនួន-សាមិនជាចាងហ្វាងពន្ធនាគារ, លោកស៊ិន-សារ៉ាតជាចៅហ្វាយស្រុកសង្កែរ, លោកនន-នារ៉ាជានាយកវិទ្យាល័យ, លោកយស់-រ៉ែនជានាយកមហាវិទ្យាល័យ, លោកតូច-ឃឿមជាសាស្ត្រាចារ្យ, លោកកែវ-យូឡុងជានាយកផ្នែកហិរញ្ញវត្ថុខេត្ត, លោកស៊ាន-ថូមេឃុំស្វាយប៉ោ, លោកគី-ស៊ានហូ និងហូ-តុងហាន ជាថៅកែរោងចក្រអារឈើ ។ល។

មួយសន្ទុះមានឡានឡង់រ៉ូវែរមួយគ្រឿងមកដល់ ក៏បញ្ចេញអ្នកបើកបរថ្មី៤នាក់ រួចមេខ្មែរក្រហមបញ្ជាឲ្យដោះលេខឡានកាម៉ុងគ្រវាត់ចោល រួចឡើងបើកបរឡាននោះតាមឡានហ្ស៊ីបរបស់វាចូលកាន់ទីក្រុងបាត់ដំបងវិញ ។

ថ្ងៃដដែលម៉ោងប្រហែល៣រសៀល មានឡានធំៗគ្រប់ធុនប្រមាណ៣០គ្រឿងតំរៀបចួរខាងជើងវិទ្យាល័យព្រះមុនីវង្ស និងមួយជួរទៀតខាងលិចរហូតដល់វត្តភីភិត ដើម្បីដឹកទាហានចេញពីវិទ្យាល័យនេះបញ្ឆោតថា គួរតែចេញពីទីក្រុងបាត់ដំបងភ្លាមៗ ព្រោះអាមេរិកាំងមកទម្លាក់គ្រាប់បែកក្នុងពេលឆាប់នេះ ។

ក្បួនឡានចំនួន៣០គ្រឿងនេះដឹកនាំទាហានទៅកាន់និគមសម្តេចឪ ឃុំតាម៉ឺន មានទាហានម្នាក់ឈ្មោះសឿនសល់នៅរស់បានអធិប្បាយថា ៖ ពេលនោះម៉ោងប្រហែល៥រសៀល តំណាងអង្គការឲ្យសញ្ញាបញ្ឈប់ឡានទាំងអស់ជាហូរហែរតាមផ្លូវជាតិលេខ៥, វាស្រែកបញ្ជាឲ្យទាហានទាំងអស់ចុះពីឡាន ព្រមទាំងប្រាប់បន្ថែមថា មិនបាច់យកអ្វីៗតាមខ្លួនឡើយ... វាបញ្ជាឲ្យចូលទៅកាន់និគមសម្តេចឪ ។ លុះដើរផុតតែបន្តិចពីថ្នល់ជាតិតែប៉ុណ្ណោះ វាបញ្ជាឲ្យដើរចុះទៅវាលស្រែខាងឆ្វេងដៃ វាបញ្ជាឲ្យតំរៀបជួរគ្នាឲ្យបានត្រឹមត្រូវ ។ ការពិតកន្លែងនោះជាកណ្តាលអន្ទាក់ខ្សែត្រៀមនៃឃាតករអាថ៌កំបាំង, វាព័ទ្ធរង់ចាំបាញ់សម្លាប់ចោលជាស្រេច ។ ដូច្នេះ

១០នាទីក្រោយពីការតំរៀបជួរ ស្រាប់តែកាំភ្លើងគ្រប់ធុនបាញ់ស្រោចគ្រាប់ដូចរន្ទះ សម្លាប់ទាហានដ៏កំសត់ទាំងនោះគ្មានមេត្តា, ត្រូវស្លាប់គរលើគ្នា ។ សឿនដែលនៅរស់ដោយមកពីចេះក្រាបបន្លំជាមួយខ្មោច រហូតដល់ពាក់កណ្តាលយប់ជ្រៅទើបលួនវារចេញមកពីទីនោះមកបាន ។ ថ្ងៃទី២៣មេសាដដែល ប្រហែលម៉ោង៨រសៀល មានឡានកាម៉្យុង១០គ្រឿងរៀបក្បួននៅផ្លូវជាតិលេខ៥ នៅមុខវិទ្យាល័យអ៊ាប-ឃុត, ពេលនោះឃើញមិត្តស៊ុយលោតចុះពីឡានហ្ស៊ីប មានបញ្ជីមួយសន្លឹកនៅដៃដើរចូលទៅកាន់បរិវេណសាលាដែលមានអស់លោកនាយទាហានរង ដែលត្រូវគេប្រមូលមកពីគ្រប់ទិសទីចំនួន៨០០នាក់ តំរៀបជួរជាស្រេចរង់ចាំនៅទីនោះ ។ មិត្តស៊ុយក៏ហៅឈ្មោះ រួចបញ្ជាឲ្យដើរចេញទៅឡើងឡានជាហូរហែរ ដោយកុហកថានាំយកទៅរៀនសូត្រនៅខេត្តសៀមរាប ។ ក្បួនឡាននេះបរឆ្លងស្ទឹងសង្កែរតាមស្ពានថ្មីទៅកាន់ផ្លូវជាតិលេខ៥ បរឆ្ពោះទៅខេត្តសៀមរាប ។ មុខក្បួនឡាននេះ មានឡានហ្ស៊ីបមួយគ្រឿង ដែលមានមេខ្មែរក្រហមបួននាក់ជិះនៅក្នុងនោះបើកបរនាំផ្លូវ ។ ខាងក្រោយមានឡានឡង់រ៉ូវែរពីរគ្រឿង មានយោធាក្មេងៗប្រហែល១៨នាក់កាន់កាំភ្លើងអាអ៊ែរកែងគ្រប់ដៃ ជាអ្នកការពារជូនដំណើរ ។ លុះក្បួនឡានទៅដល់ភូមិបាត់កង ឡានហ្ស៊ីបឈប់ មេខ្មែរក្រហមលើកដៃជាសញ្ញាបញ្ជាឲ្យឡានទាំងអស់ឈប់... មេខ្មែរក្រហមលោតចុះពីឡាន រួចស្រែកបញ្ជាឲ្យនាយទាហានរងទាំងនោះចុះពីឡាន តំរៀបគ្នាជាជួរ៤ៗនាក់តាមបណ្តោយថ្នល់ ។ ស្រាប់តែរំពេជនោះមានក្រុមអាថ៌កំបាំងដ៏ច្រើនលើសលប់ចេញមកបង្ហាញខ្លួន ស្លៀកពាក់ខ្មៅ មាឌតូចៗ មុខមាត់មិនមែនជាខ្មែរទេ មានអាវុធគ្រប់ធុនព័ទ្ធជាប់ជាស្រេច ។

ពេលនោះមានមនុស្សប្រហែល១០០នាក់ ឥតអាវុធលោតចេញមក រួចចាប់ទាហានរងអស់ទាំងនោះចងស្លាបសេកបួនៗនាក់ផ្ដោបគ្នា រួចហើយក៏បាញ់សម្លាប់ចោលនៅទីនោះទៅ ។

ស្រុកមង្គលបូរី មានកសិដ្ឋានខ្មែរ-ជប៉ុនមួយស្ថិតនៅក្បែរផ្លូវជាតិលេខ៥ ។ ចាប់តាំងពីប្រទេសកម្ពុជាកើតសង្គ្រាម គេយកកន្លែងនោះជាទីតាំងកងទ័ពជាតិ ។

នៅថ្ងៃទី១៩មេសា មានក្រុមឃាតករអាថ៌កំបាំងដ៏ច្រើនលើសលប់ចេញមកព័ទ្ធទីនោះជាប់តាំងពីព្រលឹម ។ លុះដល់ម៉ោង៩ មេរបស់វាស្រែកតាមមេក្រូ បញ្ជាឲ្យនាយនិងកូនទាហាន ព្រមទាំងប្រពន្ធកូន ឲ្យចេញពីផ្ទះប្រមូលគ្នាជួបជុំកណ្តាលវាលកសិដ្ឋាន ។ លុះចេញមកជួបជុំស្រេចបាច់ហើយ វាបញ្ជាឲ្យបាញ់ចំរុះទៅលើជនរងគ្រោះអស់ទាំងនោះ ។ គ្រាប់ស្រោចព្រួដូចរន្ទះ ជនរងគ្រោះដួលស្លាប់គងជើងលើគ្នាគ្មានសល់ដល់ម្នាក់ឡើយ ។

❑

# អង្គការដេញប្រជាជនឲ្យថយចេញពីទីក្រុងបាត់ដំបង

នៅថ្ងៃទី២៣មេសា ម៉ោងប្រហែល៥រសៀល ក្រោយពីដឹកនាំនាយទាហាន នាយទាហានរង នាម៉ឺនអ្នករដ្ឋការស៊ីវិល និងអ្នកមុខអ្នកការចេញផុតពីទីក្រុងអស់ស្រាប់តែមានឡានហ្ស៊ីបជាច្រើនគ្រឿងបើកបរពាសពេញទីក្រុង ស្រែកបំពងសម្លេងតាមមេក្រូ ចេញបញ្ជាជាដាច់ណាត់ ដេញប្រជាជនទាំងអស់ ឲ្យថយចេញពីទីក្រុងឲ្យអស់ក្នុងរយៈពេល២៤ម៉ោង ។

លុះឮផ្ទាល់ត្រចៀកនូវបញ្ជាជាដាច់ណាត់ដ៏ចម្លែករបស់អង្គការ ដែលគ្មានខ្មែរណាស្គាល់ជានរណានោះ មានប្រជាជនខ្មែរខ្លះភ័យតក់ស្លុតខ្លាំងពេកក៏ស្លាប់ភ្លាម ឧទាហរណ៍ដូចលោកហេង-ឡាង ចាងហ្វាងសាលាដំបូង លោកគាំងបេះដូងស្លាប់មួយរំពេច ។ មានស្រីជាច្រើនសន្លប់បាត់ស្មារតី មានរូបខ្ញុំជាដើមដែលសន្លប់បាត់ស្មារតីជាច្រើនម៉ោង លុះដឹងខ្លួនឡើងវិញទើបយំដូចមនុស្សឆ្កួត ។ មានប្រជាជនខ្លះរត់ទៅដេកកណ្តាលថ្នល់ សម្លាប់ខ្លួនឲ្យឡានកិន ។ មានស្រីជាច្រើនពាន់នាក់ដែលត្រូវអង្គការបំបែកប្តី នាំទៅទីអាថ៌កំបាំង កំពុងអង្គុយសំកុកឱបកូនសំរក់ទឹកភ្នែក កើតទុក្ខសឹងបាត់វិញ្ញាណ ព្រោះសង្ស័យស្មានថា អង្គការនាំប្តីអញទៅសម្លាប់ទេដឹង ?

ស្រាប់តែឮថាអង្គការចេញបញ្ជាដេញប្រជាជនឲ្យថយចេញពីទីក្រុង ដូច្នេះទុក្ខមួយជាន់ដ៏ធ្ងន់ មកសង្កត់លើទុក្ខមួយជាន់ទៀត ។ មានស្រីខ្លះមានផ្ទៃពោះគ្រប់ខែ.. កូនច្បងកំពុងឈឺក្រោកមិនរួច ប្តីត្រូវអង្គការនាំយកទៅទទួលសម្តេចឪ... ស្រាប់តែឥឡូវនេះត្រូវគេដេញឲ្យថយចាកចេញពីទីលំនៅ... ឱវាសនានៃប្រជាជនខ្មែរ ! នៃស្ត្រីខ្មែរដ៏កំសត់អើយ... តើទៅជាយ៉ាងណាទៅ ?

នៅក្នុងកាលៈទេសៈនេះ គ្មាននរណាអាចជួយនរណាបានឡើយ ។ ព្រលឹមថ្ងៃទី២៤មេសា ប្រជាជនជិតមួយលាននាក់ ត្រូវតែថយចេញពីទីក្រុងបាត់ដំបង ។ ដៃម្ខាងពរកូនតូច ដៃម្ខាងទៀតដឹកដៃកូនធំ មានតែសំពាយមួយនៅលើខ្នង សឹងតែបាតដៃទទេទាំងអស់គ្នា ។ ប្រជាជនទាំងអស់ដើរថ្មើរជើង ព្រោះអង្គការស្ទើរថយន្ត ម៉ូតូ រ៉ឺម៉ក កង់ តាំងពីថ្ងៃទី១៩មេសាអស់រលីងទៅហើយ ។ មានគ្រួសារខ្លះត្រូវសែងម៉ែឪចាស់ជរា, សែងប្រពន្ធដែលទើបសំរាលកូនហើយ, សែងបងប្អូនឈឺធ្ងន់ឬពិការ បណ្តើរទៅគ្មានទីដៅ ។

នៅថ្ងៃទី២៧មេសា អង្គការចេញបញ្ជាជាដាច់ណាត់បន្ថែមមកទៀត គឺដេញ

ប្រជាជនទាំងអស់ ឲ្យថយចេញឲ្យផុតពីថ្នល់ជាតិ ពីដងស្ទឹងចម្ងាយយ៉ាងតិចពីរគីឡូម៉ែត្រ ព្រោះអង្គការបង្វែងដានកុំឲ្យខ្មែរឃើញពួកយៀកកុងចូលមកប្រមូលអានិកជនយួន និងទ្រព្យសម្បត្តិប្រទេសខ្មែរ ដឹកយកទៅស្រុកយួន ។ ពេលនោះរាស្ត្រអ្នកស្រែ ត្រូវថយចេញពីលំនៅទាំងអស់គ្នា ។

ឱពុទ្ធោអើយ ! តើខ្មែរជាម្ចាស់ទឹកដីរាប់លាននាក់នោះ នាំកូនតូចៗ ម៉ែឪចាស់ជរា ទៅជ្រកនៅឯណា ? ។ ខែមេសាជារដូវក្ដៅ សីតុណ្ហភាពឡើងដល់ក៏រិត៤៥អង្សារ ។ ខ្មែររស់នៅកណ្ដាលវាលល្ហល្ហេវ, កណ្ដាលព្រៃស្មសាន ពឹងដីជាគ្រែ ពឹងមេឃជាដំបូល ។ កន្លែងខ្លះគ្មានទឹក កន្លែងខ្លះគ្មានអុស... ។ កំពុងអស់សង្ឃឹមដោយត្រូវដេកចាំពេលស្លាប់ព្រោះអត់ទឹក ពេលនោះមានប្រផ្នូលមួយដ៏អស្ចារ្យ មើលចុះកំពុងក្ដៅហែងអន្ទះសារ មេឃស្រទ្បះធេងគ្មានពពក ស្រាប់តែនៅថ្ងៃទី២៩មេសាម៉ោង៣រសៀល មានភ្លៀងមួយមេយ៉ាងធំ ក្នុងរយៈពេលប្រហែលបីម៉ោង ។ ដូច្នេះតាមវាលស្រែ ទឹកមានកំពស់១៥សង់ទីម៉ែត្រ ។ នៅតាមអណ្ដូងនានាមានទឹកហូរយ៉ាងពេញៗ ។ ប៉ុន្តែនឹកទៅគួរឲ្យអាណោចអាធម៍ដល់ខ្មែរទាំងអស់នោះណាស់ ទាំងចាស់ ទាំងក្មេង ទាំងអ្នកឈឺ ទាំងអ្នកជា ស្រីៗទើបនឹងសំរាលកូនរួច ជាពិសេសអ្នកនៅទីក្រុង ដែលមិនធ្លាប់ជួបប្រទះនូវស្ថានភាពបែបនេះ លុះត្រូវនៅកណ្ដាលភ្លៀងកណ្ដាលខ្យល់ជិត៣ម៉ោងដូច្នេះ ក៏រងារញាក់ញ័រដូចគ្រុនចាញ់គ្រប់ៗគ្នា ។ អ្នកខ្លះស្រែកថ្ងូរថា ៖ « ឱទេវតាលោកអើយ ! តើរស់នៅយ៉ាងដូចម្ដេចទៅសូមលោកជួយផងៗ ! » ។ វេទនារបៀបនេះ យើងធ្លាប់ឃើញតែក្នុងរឿងកុនទេ តែពេលនេះអង្គការធ្វើឲ្យខ្មែររាប់លាននាក់ ប្រទះសេចក្ដីវេទនាផ្ទាល់ៗភ្នែក ។ យប់នោះ គ្មាននរណាទទួលទានដំណេកកើតទេ គ្រប់ៗគ្នាបណ្ដើរគ្រួសាររកដីទួលខ្ពស់មិនលិចទឹកដើម្បីនឹងអង្គុយត្របោមក្បាលក្បាលជង្គង់ទល់ភ្លឺ...។

ប្រជាជនខ្មែរដែលភៀសខ្លួនទៅកាន់ភូមិកាច់រទេះ ក្នុងកងបឹងធំសហករណ៍ព្រៃតូចជាច្រើនពាន់នាក់ ដើរដេកពាសវាល ខាងកើតថ្នល់ជាតិលេខ៥មានចម្ងាយពី២គ.ម. គ្មានទីជំរកទាល់តែសោះ ។ គ្រប់ៗគ្នាភ័យតក់ស្លុតជាក្រៃលែង ព្រោះច្រើនថ្ងៃទៅហើយ គ្មាននរណាទទួលខុសត្រូវការពារសន្តិសុខឡើយ ។

នៅថ្ងៃទី១៩ឧសភា ម៉ោងប្រហែល៣រសៀល បានទទួលដំណឹងថា មានអ្នកកាន់ក្ដាប់មកដល់ហើយ ។ គ្រប់ៗគ្នាត្រេកអរណាស់ រត់ប្រញាប់ទៅទទួលចៅហ្វាយថ្មី ចង់ដឹងផែនការថ្មី ។ អង្គប្រជុំបើកនៅកណ្ដាលវាលល្ហល្ហេវ កណ្ដាលថ្ងៃក្ដៅ ។ លុះប្រជាជនជាច្រើនពាន់នាក់មកជួបជុំហើយ មួយសន្ទុះធំទើបឃើញមិត្តឡាំ, មិត្តគិន, មិត្តទិត ។ មិត្តទាំងបីនាក់នេះជាមេចោរយ៉ាងកាចសាហាវ សំណាក់នៅតែក្នុងព្រៃរនាមខាងកើតភូមិបឹងធំនិងភូមិកាច់រទេះ ។ ពេលនោះមានយោធា

ក្មេងៗ អាយុប្រហែល១៥ឆ្នាំ មានស្រីពនាក់ ប្រុសពនាក់ កាន់កាំភ្លើងអាអ៊ែរកែង គ្រប់ៗដៃតាមការពារ ។ យោធាទាំងនោះមានទឹកមុខមាំ ហាក់ដូចជាមានគំនុំរាប់ រយជាតិមកហើយ ឬហាក់ដូចជាស្រេកឃ្លានសាច់ឈាមស្រស់ៗមកពីនាយ ។

មិត្តឡាំភ្នែកក្រហមឆ្អៅ ចាប់ផ្ដើមនិយាយថា ៖ « ក្រុមខ្ញុំជាតំណាងអង្គការផ្ទាល់ ។ អង្គការដាក់ទិសបញ្ជូនក្រុមខ្ញុំមកកាន់ក្ដាប់មិត្តទាំងអស់នៅកងបឹងធំនេះ ។ យើងត្រូវតែបើកសមរភូមិវាយសំរុក ធ្វើស្រែប្រាំង ធ្វើស្រែវស្សា ។ ពីព្រោះមិត្តទាំងអស់គ្នាហូបបាយ, បាយកើតមកពីស្រែ, ដូច្នេះយើងត្រូវតែដាំស្រូវ ។ តាំងពីដូនតាមក មិនដែលឃើញនរណាហូបក្រដាស់ ដែលសក្ដិភូមិនិងចក្រពត្តិបង្កើតជាឪប្លមនោះបានឡើយ ។ ដងប៉ាក្កាដែលគេអង្គុយសរសេរលើតុ ក៏ហូបមិនកើត ដែរ ។ ដូច្នេះចាប់ពីថ្ងៃនេះទៅ អង្គការបង្កើតដងប៉ាក្កានិងស៊ីឡូថ្មី គឺនង្គ័ល រនាស់ ប៉ែល ចប ខ្វែវ ។ល។ » ។ ពេលនោះមានមិត្ត២នាក់ផ្សេងទៀត ដើរចូលមកកាន់ អង្គប្រជុំ ភ្នែកក្រហមឆ្អៅ មុខកាចឃោរឃៅដ៏អស្ចារ្យ ។ មិត្តឡាំលើកដៃចង្អុល ហើយប្រាប់ប្រជាជនថា ៖ « នេះមិត្តហៀក នោះមិត្តយិន ។ អង្គការចាត់តាំងជាឈ្លបមើលការខុសត្រូវសហករណ៍នៅព្រៃតូចយើងនេះ » ។

លុះចប់អង្គប្រជុំដ៏ក្រៀមក្រំនេះ មិត្តឡាំចាប់ផ្ដើមប្លន់ដោយប្រើពាក្យស្នើជំនួស ។ មិត្តឡាំប្រកាសស្នើនាឡិកាដៃ វិទ្យុ ម៉ូតូ កង់ ម៉ាស៊ីនដេរ ។ ពាក្យស្នើសាហាវជាងពាក្យប្លន់ ព្រោះអង្គការឲ្យអភ័យឯកសិទ្ធិយ៉ាងពេញលេញដល់ចោរដើរស្នើ ។ បើម្ចាស់ទ្រព្យបដិសេធមិនឲ្យចោរទេ អង្គការអនុញ្ញាតឲ្យសម្លាប់ចោលចុះ រួចចោទថាក្បត់អង្គការ ។

ចាប់តាំងពីថ្ងៃនោះមក ក្រុមនេះត្រួតត្រារាស្ត្រខ្មែរតាមរបបចោរ គឺដើរស្នើខ្ចៅខ្ចី រួចសម្លាប់ចោល ។ល។ និង ។ល។

❑

# រឿងចម្លែកដែលកូនខ្មែរត្រូវតែដឹង

នៅថ្ងៃទី២៣មេសា ម៉ោង៥កន្លះរសៀល អង្គការកំពុងអនុវត្តផែនការប្រើកលល្បិចភរបោកអ្នករដ្ឋការនៅខេត្តបាត់ដំបងគ្រប់ៗផ្នែក ដឹកនាំយកទៅចូលអន្ទាក់ដែលក្រុមឃាតករអាថ៌កំបាំង រៀបចំខ្សែត្រៀមរង់ចាំបាញ់សម្លាប់ចោល...។

ចំណែកមិត្តស្ញូបែរជាទៅខ្សិបបុគ្គលិកពេទ្យក្រសួងរថភ្លើង និងកម្មកររោងចក្រតំបាញ ថាមិត្តទាំងអស់ត្រូវនៅឲ្យស្ងៀមមួយកន្លែងសិន ចាំស្តាប់បញ្ជាសារជាថ្មី ។

នៅថ្ងៃទី២៤មេសា ម៉ោងប្រហែល១០ព្រឹក អង្គការបញ្ជាឲ្យហៅបុគ្គលិកពេទ្យទាំងអស់ព្រមទាំងគ្រួសារ ប្រមូលគ្នាទៅជួបជុំនៅក្នុងមន្ទីរពេទ្យធំនៅបាត់ដំបង ។ លុះមកជួបជុំស្រេចបាច់ ក៏ឃើញមិត្តស្ញូបើកឡានឡង់រ៉ូវែរមកឈប់នៅទីនោះល្មម មិត្តស្ញូចុះពីឡាន រួចលើកដៃចង្អុលឡានកាម៉ុង៣គ្រឿង ដែលរៀបក្បួនរង់ចាំជាស្រេច ព្រមទាំងចេញបញ្ជាជាដាច់ណាត់ទាំងបង្ខំ ដល់បុគ្គលិកពេទ្យព្រមទាំងគ្រួសារ ត្រូវតែឡើងឡាននោះ ។

បុគ្គលិកពេទ្យទាំងអស់ទៅជាគាំងមាត់ គ្មានពាក្យតវ៉ា ត្រូវតែផ្សងព្រេងដឹកដៃកូន បណ្តើរប្រពន្ធ តំរៀបជួរឡើងឡានតាមបញ្ជាដាច់ណាត់នេះដោយដៃទទេគ្រប់គ្នា ។

មានបុគ្គលិកពេទ្យខ្លះជាអ្នកយាម ពេលនោះត្រូវតែឡើងឡានភ្លាម ដូច្នេះជាប់តាមខ្លួនមានតែខោអាវយាមប៉ុណ្ណោះ រីឯប្រពន្ធកូន ក៏ត្រូវបែកគ្នារហូត តាំងពីថ្ងៃនោះមក ។

ក្បួនឡានហែរចេញពីមន្ទីរពេទ្យ ដោយមានឡានឡង់រ៉ូវែរបើកបរដោយមិត្តស្ញូជាអ្នកនាំផ្លូវ រួចទៅឈប់សំចតនៅវត្តសុភី ។ មកដល់ទីនេះ មិត្តស្ញូលោតចុះពីឡានព្រមទាំងនិយាយថា ចូរនៅសំណាក់ទីនេះសិនចុះ ចាំស្តាប់បញ្ជាជាថ្មី ។ រួចហើយមិត្តស្ញូក៏ដឹកនាំក្បួនឡានទទេនោះត្រឡប់ទៅវិញបាត់ ។

ព្រឹកថ្ងៃទី២៧មេសា ឃើញមិត្តស្ញូមកជួបបុគ្គលិកពេទ្យ ដែលគេយកមកចាក់ចោលនៅវត្តសុភីទាំងអស់នោះ ។ លោកពីង-គិមស៊ា ជាវេជ្ជបណ្ឌិតនិងជានាយកពេទ្យធំនៅខេត្តបាត់ដំបង ជាមិត្តជិតស្និទ្ធមិត្តស្ញូ លោកតែងតែឧបត្ថម្ភដល់ប្រពន្ធកូមមិត្តស្ញូ ពេលដែលមិត្តស្ញូរត់ចោលស្រុក ។ ដូច្នេះលោកពីង-គិមស៊ាបានស្តីបន្ទោសមិត្តស្ញូយ៉ាងស្មោះថា ៖ ដ៏ស្ញូ ! តើអង្គការជានរណាគេ ? អង្គការរបស់ស្ញូ

ឯងអនុវត្តផែនការដ៏ឆ្កួតលីលា ។ ការជន្លៀសប្រជាជនយ៉ាងនេះ គឺសម្លាប់និងបំផ្លាញជាតិឯងទេណា៎... ទ្រព្យសម្បត្តិ ដើមឈើ ដំណាំដាំដុះដែលម្ចាស់ដើរចោល ត្រូវវិនាសហិនហោចទាំងអស់ហើយក្នុងពេលនេះ ។

ពេលនោះមិត្តស៊ូធ្វើមុខស្លូត ក៏លើកដៃស្តាំកៀកដៃឆ្វេងលោកគិមស៊ា រួចបណ្តើរទៅឆ្ងាយផុតពីបុគ្គលិកទាំងឡាយ រួចឈរខ្សិបគ្នាយ៉ាងយូរ ទើបដឹកដៃគ្នាមកកាន់កន្លែងដដែលវិញ ។

លោកគិមស៊ាមុខស្លូត មានអារម្មណ៍អន្ទះសារជាខ្លាំង ។ លោកសម្លឹងសហការីរបស់លោកមួយសន្ទុះធំ ទើបលោកនិយាយថា ៖ ខ្ញុំសូមលាលោកៗទៅធ្វើការនៅវត្តជ្រៃស្រុកមោងឫស្សីហើយ...។

ព្រលឹមថ្ងៃ២៨មេសា លោកពីង-គិមស៊ាបណ្តើរកូនប្រពន្ធដើរថ្មើរជើងទៅកាន់វត្តជ្រៃ ។ លោកត្រូវដើរកាត់ភូមិកាច់រទេះ ហើយបានជួបលោកឃី-វិញទ្រី ជានាយកសាលពិសោធន៍នៅមន្ទីរពេទ្យធំនៃទីក្រុងបាត់ដំបង ។ លោកទាំងពីរនាក់បណ្តើរគ្នាគេចចូលក្នុងព្រៃស្បាត រួចជជែកគ្នាយ៉ាងយូរ ។ លោកគិមស៊ាប្រាប់លោកវិញទ្រីថា ៖ មិត្តស៊ូកំញើញព្រមទាំងព្រមានលោកដូចតទៅ ៖ ង៉ែស៊ា បើចង់រស់នៅតទៅទៀត ត្រូវចេះអត់ធ្មត់ ត្រូវចេះធ្វើគរធ្វើថ្លង់ ត្រូវចេះកសាងខ្លួន ជំរះការឯកជនណា៎ ។ ស៊ាឯងជាមិត្តជិតស្និទ្ធនឹងខ្ញុំ ធ្លាប់ជួយថែទាំគ្រួសាររបស់ខ្ញុំ ដូច្នេះខ្ញុំប្រាប់នូវគំរោងការណ៍អាថ៌កំបាំងមួយជាពិសេស គឺអង្គការគ្រោងទុកខ្មែរតែបួនម៉ឺននាក់ ឲ្យធ្វើជាម្ចាស់ទឹកដីកម្ពុជាតែប៉ុណ្ណោះ ។ ក្រៅពីនោះត្រូវយកចេញ ។ លោកវេជ្ជបណ្ឌិតពីង-គិមស៊ានិទានដល់ត្រឹមហ្នឹង លោកស្រក់ទឹកភ្នែកច្រោកៗ រួចក៏បន្តទៅទៀត ។ លុះឮយ៉ាងនេះ ខ្ញុំក៏សម្លក់សម្លឹងមិត្តស៊ូព្រមទាំងគំហកសួរថា តើលោកៗដែលទៅទទួលសម្តេចឪពីថ្ងៃមុននោះយ៉ាងម៉េចទៅហើយ ! » ។ ពេលនេះដើម្បីសង្គ្រោះស៊ាឯង ដែលជាអ្នកមានគុណដ៏លើសលប់ចំពោះគ្រួសារខ្ញុំ ទើបខ្ញុំលៃលកដាក់ទិសបញ្ជូនស៊ាឯងឲ្យទៅធ្វើការនៅវត្តជ្រៃជាបន្ទាន់នេះ ។ល។ និង ។ល់។

ពេលនោះលោកពីង-គិមស៊ាឱបលោកទ្រីព្រមទាំងថ្ងូរខ្សឹបៗថា តើជឿឬទេ ? ឱទ្រីអើយខ្ញុំមានអារម្មណ៍តក់ស្លុតណាស់... ង៉ែទ្រី... មានតែទ្រីឯងទេទើបខ្ញុំប្រាប់ណា៎ !...។ ចំណែកលោកទ្រីលុះបានស្តាប់នូវអព្ភូតហេតុមិនគួរឲ្យជឿ តែជារឿងពិត លោកក៏ស្រក់ទឹកភ្នែកច្រោកៗ ដោយស្រណោះលោកស៊ាបណ្តើរប្តីប្រពន្ធកាត់ ភូមិកាត់វាល កាត់ព្រៃ ផ្សងព្រេងទៅកាន់វត្តជ្រៃ ស្ថិតនៅមាត់ព្រៃរនាម បាតដៃទទេមិនដឹងជាវាសនាអនាគតវានឹងទៅជាយ៉ាងណា ?

ពេលលោកទ្រីយកជាយអាវជូតទឹកភ្នែក ព្រមទាំងអត្ថាធិប្បាយបញ្ជាក់អព្ភូតហេតុដ៏អាក្រក់ដូចគ្នានេះជំរាបលោកស៊ាថា ៖ « ខ្ញុំបាទតែងតែទៅចាក់ថ្នាំឲ្យគ្រួសារ

គណស្រុកឈ្មោះកក់ នៅភូមិព្រៃតូចខាងត្បូងនេះ ។ មិត្តកក់ក៏ព្រមានខ្ញុំបាទថា ឲ្យចេះធ្វើខ្វាក់ ធ្វើថ្លង់ធ្វើគ ទើបអាចឆ្លងផុតមហាគ្រោះកាចនេះ ព្រោះអង្គការមានគំរោងការសម្ងាត់ទុករាស្ត្រខ្មែរឲ្យនៅសល់តែ៤ម៉ឺននាក់អញ្ចឹងដែរ ។

ពេលនោះលោកទាំងពីរមានអារម្មណ៍តក់ស្លុតជាយ៉ាងខ្លាំង ទៅជាគាំងមាត់រកពាក្យនិយាយតទៅទៀតលែងកើត ។ សម្លឹងមុខគ្នាយ៉ាងយូរអស់សង្ឃឹម ក៏សុំលាបែកគ្នាទៅកាន់ទីដៅរៀងៗខ្លួន ។

ក្នុងពេលបែកគ្នាជាចុងក្រោយនេះ លោកទាំងពីរអង្គុយក្ដុកក្ដួលក្នុងចិត្តពុំអាចរកពាក្យពេចន៍ឯណាមកពណ៌នាបានឡើយ ។ លោកទាំងពីរនាក់បែកគ្នារហូត !... ព្រោះនៅទីបញ្ចប់, អ្នកព្រមានគេក្ដី អ្នកត្រូវគេព្រមានក្ដី ត្រូវអង្គការចេញបញ្ជាឲ្យសម្លាប់ចោលជាបន្តបន្ទាប់ ...ដូចជាមិត្តកក់ដែលគណស្រុក ហើយដែលពីអតីតកាលជាគ្រូលីវ៉ែកដី និងជាចោរលួចមាន់ទា បានត្រូវអង្គការចាត់ឲ្យគេសម្លាប់ចោលនៅថ្ងៃទី២០ តុលា ឆ្នាំ១៩៧៨ វេលាម៉ោង៨យប់ ។

មិត្តស៊ូត្រូវគេចាប់ខ្លួននៅថ្ងៃទី២១ឧសភា១៩៧៧ ។ បួនខែក្រោយមក ប្រពន្ធមិត្តស៊ូត្រូវគេចាប់ខ្លួនទៀត គឺនៅថ្ងៃទី៨កញ្ញាឆ្នាំដដែល ។ អង្គការចេញបញ្ជាឲ្យយកទៅដាក់គុកទួលស្លែង ធ្វើទារុណកម្មសិនទើបសម្លាប់ចោលទាំងពីរនាក់នៅថ្ងៃទី១៨តុលា១៩៧៧ ។

- អង្គការឲ្យគេចាប់ខ្លួនលោកពីង-គិមស៊ានៅយប់ថ្ងៃទី១១ វិច្ឆិកា ១៩៧៦ នាំយកទៅដាក់គុកទួលស្លែង ។ ដោយសារទារុណកម្មលើខ្លួន លោកក៏ស្លាប់នៅថ្ងៃ៦ ឧសភា ១៩៧៧ ទៅ ។

- អង្គការបញ្ជាឲ្យគេសម្លាប់លោកពេទ្យឃឺ-វិញទ្រីនៅថ្ងៃទី១១ វិច្ឆិកា ១៩៧៦ ។

❑ ❑

❑

## អព្ភូតហេតុដែលបងប្អូនខ្មែរត្រូវតែដឹង ដើម្បីយកមកត្រិះរិះពិចារណា

- ថ្ងៃទី២៣មេសា១៩៧៥ នៅខេត្តបាត់ដំបង ខ្មែរដែលជាម្ចាស់ទឹកដីកំពុងត្រូវរងគ្រោះ ។ អ្នករដ្ឋការគ្រប់ផ្នែក អ្នកមុខអ្នកការ ត្រូវអង្គការប្រមូលនាំយកទៅសម្លាប់ចោលភ្លាមៗ ។ ខ្មែរជាង១លាននាក់ដែលមិនទាន់ដល់វេនស្លាប់ ត្រូវអង្គការដេញឲ្យចាកចេញពីលំនៅដ្ឋាន ចោលទីកន្លែង ត្រូវថយចេញឆ្ងាយពីទីក្រុង ពីផ្លូវគមនាគមន៍ ទាំងផ្លូវគោក ទាំងផ្លូវទឹក ( ចម្ងាយយ៉ាងតិច២គ.ម.ពីផ្លូវជាតិ និងពីទន្លេ ) ។ល។ និង ។ល។

- ផ្ទុយទៅវិញ នៅថ្ងៃដដែលម៉ោង១រសៀល អង្គការបែរជាចាត់មនុស្សអាថ៌កំបាំងយ៉ាងស្ងាត់បំផុត ទៅឱ្យប្រាប់អនិកជនយួនក្នុងខេត្តបាត់ដំបងទាំងមូលគ្រប់ជំរំ គ្រប់ៗទីកន្លែង ថាចូរឲ្យនៅស្ងៀមមួយកន្លែងសិន ចាំស្តាប់បញ្ជាអង្គការជាថ្មី ។ ពេលនោះមានយួនម្នាក់ឈ្មោះឡាង នៅជំរំយួនមួយស្ថិតនៅចម្ងាយ១០០ម៉ែត្រខាងត្បូងផ្ទះខ្ញុំ ។ អ្នកស្រីយួននេះស្ទុះស្ទារត់មកជួបខ្ញុំហើយឱ្យប្រាប់ថា ៖ « គួរតែខ្ញុំប្រមូលគ្រួសារចូលកាន់ជំរំយួន ព្រោះអង្គការរៀបចំដឹកជញ្ជូនអនិកជនយួនទៅកាន់ប្រទេសយួនវិញហើយ » ។ ចំណែកខ្ញុំកំពុងវង្វេងស៊ុងគិតអ្វីលែងឃើញទៅហើយ, ខ្ញុំមិនទុកចិត្ត ក៏បដិសេធមិនចូលជំរំយួននោះទេ ។ល។

អង្គការបញ្ជាឲ្យប្រមូលអនិកជនយួនក្នុងខេត្តបាត់ដំបងទាំងអស់យ៉ាងស្ងាត់ ដឹកនាំចេញបីលើក យកទៅលាក់ទុកក្នុងប្រទេសយួន ចាកផុតពីគ្រោះថ្នាក់... ទុកលួចបន្លំធ្វើខ្មែរនៅលើកក្រោយវិញ ។

## វិបត្តិនៅប៉ៃលិនក្រោយព្រឹត្តិការណ៍១៧មេសា៧៧

ប៉ៃលិនជាក្រុងមួយដ៏សែនមនោរម្យ ដ៏សែនសុខសាន្ត ស្ថិតនៅចម្ងាយ៨០គ.ម. ខាងលិចខេត្តបាត់ដំបង ។ ប៉ៃលិនសំបូរទៅដោយត្បូងដ៏មានតម្លៃពណ៌ក្រហម បៃតង ខៀវតាមធម្មជាតិ និងផ្លែឈើប្លែកៗដូចជា ក្រូចចិន, សាវម៉ាវ, ធូរេនជាដើម ។ ក្នុងឆ្នាំ១៩៧៥ ក្រុងប៉ៃលិនមានប្រជាជនប្រមាណ១សែននាក់ ភាគច្រើនជាអ្នក

មានទ្រព្យសម្បត្តិដ៏ស្តុកស្តម្ភ ។

នៅថ្ងៃ១៧មេសា លោកហ៊ុល-តោនអភិបាលខេត្តប៉ៃលិនបើកអង្គប្រជុំ រវាងនាយទាហានទាំងអស់ នៅក្នុងបរិវេណសាលាខេត្ត ។ លោកប្រកាសអំពាវនាវថា យើងត្រូវតែការពារក្រុងប៉ៃលិន រហូតដល់ដង្ហើមចុងក្រោយបង្អស់ ! ។ ពេលនោះនាយទាហានខ្លះលើកដៃតវ៉ា សុំផ្អាកឈប់បន្តសង្គ្រាម ព្រោះមិនចង់ឃើញឈាមខ្មែរហូរតទៅទៀត មិនចង់ឃើញខ្មែរសម្លាប់ខ្មែរតទៅទៀត ។

មើលចុះគួរឲ្យស្តាយណាស់ៗ ! គ្មានលោកណាយល់នូវលក្ខណៈពិតប្រាកដរបស់សង្គ្រាមដែលផ្ទុះក្នុងស្រុកខ្មែរឡើយ... គ្មានលោកណាដឹងនូវគ្រោះភយន្តរាយ ដែលបំរុងនឹងកើតឡើងនៅពេលឆាប់ៗខាងមុខនេះទេ ។ គ្រប់ៗគ្នា ទាំងរាស្ត្រទាំងនាម៉ឺន ទាំងព្រះសង្ឃ ទាំងគ្រហស្ថ ទាំងទាហាន ទាំងស៊ីវិលយល់ច្រឡំថា ខ្មែរសីហនុ-ខៀវសំផនច្បាំងគ្នាជាមួយខ្មែរលន់-នល់ ។

នៅថ្ងៃដដែល ម៉ោងប្រហែល៣កន្លះរសៀល មានខ្មែរជាច្រើននាក់ នាំគ្រួសាររត់ទៅកាន់អូរឡាក់ រួចឆ្លងដែនទៅកាន់ប្រទេសថៃ ។ ថ្ងៃទី១៨មេសា១៩៧៥ ខ្មែរដែលមានចិត្តស្រឡាញ់ប្តូរផ្តាច់ទឹកដី នាំគ្នាចាត់ចែងតាំងគណកម្មាធិការពិសេស-សមួយ រង់ចាំទទួលចៅហ្វាយថ្មី ។ ក្រុមនេះមិនមែនអង្គុយរេតាមខ្យល់ គឺរៀបចំទទួលដោយស្មោះស្ម័គ្រ ស្មោះត្រង់ និងរីករាយ ។ ព្រោះពួកនាម៉ឺនដែលបន្តដំណែងពីលោកលន់-នល់ ប្រព្រឹត្តអំពើពុករលួយយ៉ាងខ្លាំង រស់នៅសឹងតែមិនកើតទៅហើយ ។ គ្រប់ៗគ្នាយល់ច្រឡំយ៉ាងខ្លាំងនឹកស្មានៗថា បើមានសម្តេចឪយាងត្រឡប់មកគ្រប់គ្រងប្រទេសកម្ពុជាវិញ ដោយមានខៀវ-សំផនជាអ្នកគាំទ្រផងនោះ វាជាការប្រសើរណាស់ ។

គណៈកម្មាធិការនេះអង្គុយមិនសុខបក់មិនរហើយ ឈរមិននឹងដោយអន្ទះសាររង់ចាំមើលផ្លូវម្ចាស់ថ្មី ។ លុះស្អែកឡើង នៅថ្ងៃទី១៩មេសា វេលាម៉ោង២រសៀល ទើបឃើញពួកយោធាក្មេងៗមួយក្រុមអាយុប្រហែល១៥ឆ្នាំ មានចំនួនប្រមាណ៣០នាក់ មានស្រីមានប្រុស ស្លៀកពាក់ខ្មៅ ពាក់ស្បែកជើងកៅស៊ូកង់ឡាន កាន់អាវុធគ្រប់ៗដៃ ។ មេដឹកនាំឈ្មោះមិត្តប៊ុន ជាអតិតមេចោរយ៉ាងសាហាវ ។ មិត្តប៊ុនជាតំណាងអង្គការបានដើរទៅជួបគណកម្មាធិការ ដែលកំពុងរៀបចំភ្លេងកំដរ ព្រមទាំងនាំគ្នាតំរៀបជួរចាំទទួល...។ មិនបានអបអរសាទរនឹងការទទួលនេះទេ ផ្ទុយទៅវិញក្រុមមិត្តប៊ុន បែរជាធ្វើមុខមាំ ដូចចងគំនុំចង់ស៊ីសាច់ហុតឈាមមកពីនាយ ។

មិត្តប៊ុនសម្លក់សម្លឹងគណកម្មាធិការមួយសន្ទុះ ( នេះគឺស្វាបានឡើងសោយរាជ្យ ) រួចចេញបញ្ជាយ៉ាងកំបុតកំបុយ ហាមឃាត់ឈប់ឲ្យធ្វើចរាចរជាដាច់ខាត ។

នៅព្រលឹមថ្ងៃទី២២មេសា មានប្រកាសបើកអង្គប្រជុំមួយនៅសាលាស្រុកប៉ៃ

លិន ។ ខ្មែរក្រហមអរណាស់ប្រមូលគ្នាឈូឆរមកស្តាប់ផែនការម្ចាស់ថ្មីយ៉ាងកុះករ ។ មួយសន្ទុះឃើញមេចោរម្នាក់ឈ្មោះមិត្តលក ចេញបង្ហាញខ្លួនកណ្តាលអង្គប្រជុំ ប្រកាសថាខ្លួនជាតំណាងអង្គការ ( នៅទីណាក៏ដោយ ពេលឮឈ្មោះអង្គការ ប្រជាជនតែងតែបែរសម្លឹងមើលមុខគ្នា រួចលួចខ្សឹបសួរគ្នាថា ជានរណាអេះ ? ដូច្នេះជ័យចំនះមិនមែនរបស់សម្តេចឪនិងខៀវ-សំផនទេឬ ? ) ។

មិត្តលកក៏បញ្ឆោតតាមកលល្បិច ដែលអង្គការដាក់ទិសឲ្យជាស្រេច ។ មើលចុះ មិត្តលកប្រកាសថា ៖ មិត្តៗជាទីគោរពទាំងអស់ អង្គការត្រូវការនាយទាហានដើម្បីជួយបង្ហាត់បង្រៀនយុទ្ធជន យុទ្ធនារីបដិវត្តន៍ក្មេងៗ ដែលនៅល្ងង់ខ្លៅឲ្យចេះប្រើកាំភ្លើងធំ វិទ្យុ បើករថក្រោះ ឬបើកកប៉ាល់ហោះជាដើម ។ល។ ដូច្នេះព្រឹកស្អែកនេះ មិត្តនាយទាហានទាំងអស់ត្រូវស្លៀកពាក់ជាឯកសណ្ឋាន តាមបុណ្យស័ក្តិរួចមកជួបជុំគ្នានៅមុខសាលាខេត្តវេលាម៉ោង៧កន្លះជាកំហិត ។ ចំណែកនាយទាហានរងនិងពលទាហាន ត្រូវរង់ចាំទទួលបញ្ជារបស់អង្គការជាថ្មី ។

ថ្ងៃទី២៣មេសាវេលាម៉ោង៧កន្លះ នៅមុខសាលាខេត្តប៉ៃលិន គេឃើញឡានកាម៉្យុង១២គ្រឿងរៀបក្បួនជាស្រេច ។ ពេលនោះនាយទាហានចំនួន៣៥០នាក់ស្លៀកពាក់ឯកសណ្ឋានយ៉ាងស្អាតរៀងៗខ្លួន មុខញញឹមតំរៀបជួរឡើងឡាននោះ ។ មានឡានឡង់រ៉ូវែរមួយគ្រឿង និងឡានហ្ស៊ីបមួយគ្រឿង មានខ្មែរក្រហម១០នាក់កាន់អាវុធគ្រប់ដៃ បរមុខក្បួននាំផ្លូវ ។ « ភរថាទៅកាន់ខេត្តបាត់ដំបង ព្រោះខេត្តបាត់ដំបងខ្វះសម្ភារៈបង្ហាត់បង្រៀនយោធាបដិវត្តន៍ » ។

បន្ទាប់មក គេឃើញនាយទាហានទាំង៣៥០នាក់នេះស្លាប់គរលើគ្នា ហើមស្អឹងៗត្រង់ផ្លូវបំបែកទៅស្តាំចូលទៅកាន់ភូមិសំឡូត ។ ក្នុងចំណោមនាយទាហានទាំងអស់នេះ គេបានស្គាល់ ៖ លោកវរៈសេនិយទោហែម-អក្កាសេរី, លោកមេបញ្ជាការស្រ៊ុន-លី, លោកអនុសេនិយទោជា-ត្រី, ឡៅ-សុង, សួន-មាច, ឃួន-សាប៊ិន សែន-សេង, ម៉ែន-ហួន ។

ថ្ងៃដដែលវេលាម៉ោង១១ ឡានកាម៉្យុង១០គ្រឿងដឹកនាយទាហានរងជាង៣០០នាក់ នាំយកទៅបាញ់ចោលនៅត្រង់ត្រពាំងកៃ ។

ថ្ងៃដដែលម៉ោង២រសៀល មានឡានកាម៉្យុង៧គ្រឿង ដឹកទាហានចំនួន៣០០នាក់ នាំយកទៅបាញ់ចោលនៅកណ្តាលព្រៃចំចន្លោះភូមិត្រែងនិងសំឡូត ។

នៅថ្ងៃទី២៧មេសា មានឡានហ្ស៊ីប៤គ្រឿងដាក់ឧគ្ឃោសនស័ព្ទ បរពីកន្លែងមួយទៅកន្លែងមួយ ស្រែកប្រកាសនូវបញ្ជារបស់អង្គការ ដេញយ៉ាងបង្ខំឲ្យប្រជាជនទាំងអស់ ចាកចេញពីទីក្រុងប៉ៃលិនក្នុងរយៈពេល៣ថ្ងៃ ។ ដូច្នេះវាសនាខ្មែរនៅប៉ៃលិនក៏ដូចជាវាសនាខ្មែរទាំងអស់នៅគ្រប់ទីប្រជុំធំៗនៃស្រុកខ្មែរដែរ គឺត្រូវពរកូន

តូច ដឹកដៃកូនបន្ទាប់ សែងភរិយាជិតសំរាលកូន ឬសំរាលកូនហើយនៅថ្មីៗ សែងឪពុកម្តាយចាស់ជរា ។ល។

ចាប់តាំងពីថ្ងៃទី២៥ដល់ថ្ងៃទី២៨មេសា អង្គការចេញបញ្ជាឲ្យកេណ្ឌមនុស្សដើរប្រមូលអាវុធគ្រប់ធុនបានយ៉ាងច្រើនលើសលប់ លើករៀបដាក់ឡាន រួចដឹកនាំចេញទៅកាន់ទីអាថ៌កំបាំង ។ គេមិនបានឃើញអ្នកបើកបរឡានវិលត្រឡប់មកជួបជុំគ្រួសារវិញទេ ។ ទាំងឡាន ទាំងអាវុធ ទាំងអ្នកបើកបរ... ទៅបាត់សូន្យ ។

ថ្ងៃទី២៩មេសាវេលាម៉ោង១០កន្លះ មានឡានកាម៉្មុងមួយគ្រឿងបរមកឈប់នៅមុខសាលាខេត្តប៉ៃលិន ។ អង្គការបញ្ជាឲ្យហៅអ្នករដ្ឋការជាន់ខ្ពស់ និងអ្នករដ្ឋការឯទៀតៗជាបន្ទាន់ មានចំនួន២៥នាក់ ដោយកុហកថាទៅចូលរួមមីទិញនៅខេត្តបាត់ដំបង ។ ឡានហ្ស៊ីបមួយគ្រឿងដឹកខ្មែរក្រហម៥នាក់ កាន់អាវុធគ្រប់ដៃបរនាំ ផ្លូវ ។ ក្រោយមក គេឃើញខ្មោចទាំង២៥នេះ ដៃជាប់ចំណង នៅភូមិត្រែង លើចិញ្ចើមថ្នល់ខាងស្តាំដៃ ។

នៅល្ងាចថ្ងៃទី៣០មេសាវេលាម៉ោង៩រសៀល អង្គការចេញបញ្ជាត្រូវបោសសំអាតក្រុងប៉ៃលិន ...បើប្រជាជនណារឹងទទឹងមិនព្រមថយចេញពីទីលំនៅ មិនព្រមថយចេញពីទីក្រុង ត្រូវបាញ់សម្លាប់ចោលភ្លាម ។ ក្នុងពេលជាមួយគ្នានេះ អង្គការបញ្ជាដល់គ្រួសារនៃគណៈកម្មការជាអ្នករង់ចាំទទួលចៅហ្វាយថ្មីនោះ ត្រូវប្រមូលគ្រួសារទាំងអស់ មកជួបជុំគ្នានៅសាលាខេត្តប៉ៃលិន រួចអង្គការកុហកថា ៖ មិត្តទាំងអស់ត្រូវចេញឲ្យផុតពីទីក្រុងជាបន្ទាន់ ព្រោះអាមេរិកាំងមកទម្លាក់គ្រាប់បែកក្នុងពេលឆាប់ៗនេះ ។ ដូច្នេះគ្រួសារនៃគណកម្មការនេះ មានឡានកាម៉្មុង៣គ្រឿងដឹកនាំយកទៅបាញ់សម្លាប់ចោល ទាំងប្តីទាំងប្រពន្ធកូន នៅត្រង់ត្រពាំងកែ រួមទាំងជនជាតិបារាំងម្នាក់ឈ្មោះ ប៉ុងឌី-សេរីយាង ក៏ត្រូវគេបាញ់សម្លាប់នៅត្រង់ទីនោះដែរ ។

ថ្ងៃនិងម៉ោងដដែល អង្គការបញ្ជាឲ្យនាំអ្នកទោសដែលរត់ឆ្លងដែនទៅកាន់ប្រទេសថៃ ដែលខ្មែរក្រហមស្កាត់ចាប់ខ្លួនបាននៅអូរឡាក់ចំនួន៣៣ឡាន ជាពិសេសឡានមែរសីដែស និងឡានពីហ្សូកាត់សង់កាត់ គ្រប់សញ្ជាតិ ជាចៅកែត្បូង ជាអ្នកមានស្តុកស្តម្ភ នាំយកទៅបាញ់ចោលនៅមាត់ជ្រោះបរតាំងស៊ូ រួចបរត្រាក់ទ័រឈូសទាំងខ្មោច ទាំងមនុស្សដែលនៅរស់ មានកូនក្មេង មានមនុស្សចាស់ ទាំងឡានទម្លាក់ជ្រោះទាំងអស់...។ មានអ្នកចំការម្នាក់នៅបរតាំងស៊ូឈ្មោះសុត-ញ៉ានបានឃើញផ្ទាល់ភ្នែក គាត់រ៉ាយរ៉ាប់រឿងនេះបណ្តើរ គាត់គ្រវីក្បាលស្រក់ទឹកភ្នែកបណ្តើរព្រមទាំងបញ្ជាក់ថា នឹកទៅគួរឲ្យអាណោចអធម៌ដល់កូនក្មេងទាំងឡាយនោះណាស់ ពេលធ្លាក់ចូលក្នុងជ្រោះដ៏ជ្រៅយ៉ាងនោះទៅហើយ នៅឮសូរសម្លេងស្រែកយំ

គ្រលួច...។ល។

អង្គការចាត់ការសម្លាប់ខ្មែរបានយ៉ាងងាយតាមល្បិចចិត្តសាស្ត្រ និងតាមចំ-ណុចខ្សោយនានា ឧទាហរណ៍ដូចជា ៖

- នៅខេត្តបាត់ដំបង អង្គការដឹងនិងស្គាល់ចំណុចខ្សោយនាម៉ឺនខ្មែរគ្រប់ផ្នែក គ្រប់ជាន់ថ្នាក់ស្រឡាញ់សម្ដេចឪ ដូច្នេះវាត្រូវប្រើឈ្មោះសម្ដេចឪជានុយ ។ ពេលនោះវាប្រើពាក្យមួយឃ្លាថា ៖

★★★ « សុំអញ្ជើញអស់លោកទៅទទួលសម្ដេចឪ » ឃ្លានេះស័ក្តិសិទ្ធិអស្ចារ្យណាស់... អ្នកណាទៅគឺស្លាប់ ។

- នៅរដ្ឋធានីភ្នំពេញ អង្គការដឹងនិងស្គាល់ចំណុចខ្សោយនាម៉ឺនខ្មែរគ្រប់ផ្នែក គ្រប់ជាន់ថ្នាក់ ដែលស្អាតស្អំ អង្គុយរង់ចាំរេតាមខ្យល់ ដោយយល់ថា « តើរបបណាមិនត្រូវការអ្នកចេះ ? » ពេលនោះវាប្រើតែពាក្យមួយឃ្លាថា ៖

★ « សុំអញ្ជើញអស់លោកចូលខ្លួនមកជួយកសាងជាតិ » អ្នកចូលគឺស្លាប់ ។

- នៅស្រុកប៉ៃលិនក៏ដូច្នោះដែរ វាប្រើតែពាក្យមួយឃ្លាឲ្យត្រូវចំចំណុចខ្សោយរបស់នាយទាហានគឺ ៖

★★★ « សុំអញ្ជើញមេទ័ពទៅជួយបង្ហាត់បង្រៀនយោធាខ្មែរក្រហមល្ងង់ៗ » នរណាទៅតាមវាគឺស្លាប់ ។

មើលចុះ ! ពាក្យតែបីឃ្លាជាអាវុធដ៏ស័ក្តិសិទ្ធិអស្ចារ្យ អង្គការអាចបោកនាម៉ឺនខ្មែរគ្រប់ៗផ្នែក គ្រប់ៗជាន់ថ្នាក់ ប្រមូលនាំយកទៅបាញ់ចោលបានយ៉ាងងាយ មិនពិបាកបង្ខំ មិនពិបាកចង...។

អង្គការចាត់ការសម្លាប់ខ្មែរស្លូតត្រង់ គ្មានកំហុសដែលជាម្ចាស់ទឹកដីពិតៗ គ្មានជំនុំជំរះ មានភាពត្រឹមត្រូវតាមលំនាំពាក្យប្រៀបប្រដៅរបស់ខ្មោចហូ-ជីមិញ ទូន្មានកូនចៅរបស់វាថា ត្រូវសម្លាប់មនុស្សសុចរិត វាប្រសើរជាងទុកសត្រូវឲ្យរស់នៅ ព្រោះវាសន្និដ្ឋានថា ខ្មែរជាសត្រូវរបស់វា ។

អង្គការអនុវត្តបានត្រឹមត្រូវនូវពាក្យបណ្ដាំរបស់ហូ-ជីមិញមួយឃ្លាទៀតដែលនិយាយថា ៖ បើធ្វើសង្គ្រាមជាមួយខ្មែរ « ឈ្នះគ្រប់គ្រង... ចាញ់ធ្វើសេដ្ឋី » កាលណោះអង្គការបញ្ជូនវៀតកុងចូលមកកាន់ប្រទេសខ្មែរ ប្រមូលប្លន់ទ្រព្យសម្បត្តិនគរខ្មែរ ដឹកជញ្ជូនទៅកាន់ស្រុកយួនដោយសេរី ។ល។ និង ។ល។

ម្យ៉ាងវិញទៀត ជាដំបូង, អង្គការចាប់ក្បាលខ្មែរនិងខ្មែរឲ្យប្រជល់គ្នា ឲ្យសម្លាប់គ្នាសិន ។ កាលណោះបក្សខ្មែរក្រហមរបស់ខៀវ-សំផនធ្វេសប្រហែស បណ្ដោយខ្លួនឲ្យចាញ់បោកអង្គការធ្ងន់ជាងធ្ងន់ ។ ក្នុងរយៈពេល១៣ថ្ងៃដំបូង ឆ្កួតវក់វី ដើរអញ្ជើញប្រមូលទាហាន មន្ត្រី អ្នករដ្ឋការគ្រប់ជាន់ថ្នាក់ ព្រមទាំងព្រះសង្ឃដែល

ចេះចាំវិន័យជ្រៅជ្រះ ដឹកនាំយកទៅចូលក្នុងអន្ទាក់ខ្សែត្រៀមរបស់ឃាតករអាថ៌កំបាំង ...ត្រូវក្រុមនេះសម្លាប់ចោលខ្ទេច ។

❑ ❑
❑

## យួនខាងជើងបោកយួនខាងត្បូង

បើយើងធ្វើការប្រៀបធៀបអំពីកលល្បិចបោករបស់យួនខាងជើងមកលើយួនខាងត្បូង ទៅនឹងកលល្បិចបោកប្រមូលនាម៉ឺនខ្មែរ ទាំងទាហានទាំងស៊ីវិលនៅរដ្ឋធានីភ្នំពេញនិងនៅប៉ៃលិន យើងឃើញថារបៀបទាំងពីរនេះមានសភាពដូចគ្នា។ តែយួនមិនសម្លាប់សាសន៍យួនទេ ។

១៣ថ្ងៃក្រោយព្រឹត្តិការណ៍នៅស្រុកខ្មែរ គឺនៅថ្ងៃទី១៣មេសា១៩៧៥ យួនហាណូយចូលកាន់កាប់ទឹកដីយួនខាងត្បូង ។

៤ឬ៥ថ្ងៃក្រោយព្រឹត្តិការណ៍នៅព្រៃនគរ (សៃហ្គន) ពួករដ្ឋការយួនខាងត្បូងគ្រប់ៗរូប ខំសម្ងំលាក់ខ្លួន ។ ចំណែកយួនហាណូយមានលកលល្បិចព្រាងទុកជាស្រេចយ៉ាងហ្មត់ចត់ ។ នៅពេលទើបចូលមកដល់ វាមិនទាន់បញ្ចេញសកម្មភាពឃោរឃៅភ្លាមទេ ។ វាទុកឲ្យអ្នករដ្ឋការទាំងអស់នោះពួនឲ្យអស់ចិត្ត ឲ្យអស់សង្ឃឹម ព្រោះវាដឹងថា ពួកអ្នករដ្ឋការយួនខាងត្បូង ទាំងផ្នែកទាហាម ទាំងផ្នែកស៊ីវិល ដល់ពេលដាច់ខែ « គឺដល់ពេលដាច់ខ្យល់... អស់លុយ អស់ស្បៀង » ។ល។

ប្រាំថ្ងៃក្រោយមក ស្រាប់តែមានឡានហ្ស៊ីបជាច្រើនគ្រឿង ដាក់ឧគ្ឃោសនសព្ទបើកបរពាសពេញក្រុងនិងខេត្តនានា និងរដ្ឋធានីព្រៃនគរ ស្រែកផ្សាយថា ៖ មិត្តជាទីស្រឡាញ់, អង្គការប្រកាសលើកលែងទោសមិត្តទាំងអស់ ទោះមានថានៈជាអ្វីក៏ដោយ ។ ឥឡូវអង្គការសុំអញ្ជើញមិត្តទាំងអស់ ចូលមកចុះឈ្មោះតាមក្រសួងរៀងៗខ្លួន ដើម្បីទៅហាត់រៀនតាមរបៀបថ្មី តាមផ្នែកៗ មានរយៈពេល១ខែឬ២ ខែ រួចសឹមវិលត្រឡប់មកជួយធ្វើការបំរើជាតិឡើងវិញ តាមក្រសួងរៀងៗខ្លួនដ-ដែល... ព្រោះបូជួយជាប់រវល់ធ្វើសង្គ្រាម មិនបានរៀនសូត្រ... អង្គការលើខ្វះអ្នកចេះដឹង ។ល។ ចំណែកឯនាយទាហាននិងនាយទាហានរង សូមអញ្ជើញមកជួយបង្ហាត់បង្រៀនបូជួយឲ្យចេះប្រើរថក្រោះ ឲ្យចេះកាន់កាំភ្លើងធំ ឲ្យចេះប្រើវិទ្យុ...

ជាពិសេសឲ្យចេះបើកកប៉ាល់ហោះ ។

ពួករដ្ឋការយួនខាងត្បូងកំពុងអស់សង្ឃឹម លុះឮសេចក្ដីប្រកាសយ៉ាងផ្អែមទន់ភ្លន់ និងដ៏សមរម្យយ៉ាងនេះ ក៏លង់ខ្លួនធ្លាក់ចូលអន្ទាក់យួនកុម្មុយនិស្តសឹងទាំងអស់គ្នា ដោយដើរចេញពីទីជម្រកលាក់ខ្លួនដោយខ្លួនឯង មកបង្ហាញខ្លួនស្ម័គ្រចិត្តសុំចុះឈ្មោះ ប្រាប់មុខតំណែងត្រង់ៗ ដើម្បីបានទៅរៀនសូត្រតាមរបៀបថ្មី ប្រញាប់នឹងបានវិលត្រឡប់មកធ្វើការដូចដើមវិញ...។

ដំណាងរបស់អង្គការលើញញឹមទទួលដោយរីករាយ ព្រមទាំងប្រាប់កំរិតថ្ងៃ និងម៉ោងដែលត្រូវចេញដំណើរ ។ លុះដល់ពេលវេលាមកដល់ហើយ នៅរដ្ឋធានីព្រៃនគរ និងនៅគ្រប់ទីរួមខេត្តនានា មានឡានគ្រប់ធុនទាំងតូចទាំងធំ រៀបជាក្បួនចាំជាស្រេច ។ លុះអ្នករដ្ឋការទាំងនោះឡើងឡានតែខ្លួនទទេចប់សព្វគ្រប់ហើយ យួនកុម្មុយននិស្តក៏ដឹក «អ្នកទោស» ទាំងនោះយកទៅដាក់គុកដាក់ច្រវាក់ទាំងអស់ ដោយបំបែកគ្នាជាក្រុមៗតាមផ្នែក តាមធុន តាមឋានន្តរស័ក្តិ ។ល។

មើលចុះ ! កលល្បិចដែលដូចគ្នាយ៉ាងនេះ តើអង្គការអនាមិករៀនពីយួនហាណូយ ឬយួនហាណូយរៀនពីអង្គការអនាមិក ឬមួយក៏ជាស្នៀតកលល្បិចដែលមានប្រភពតែមួយ ?

## សកម្មភាពសម្ដេចសីហនុក្រោយព្រឹត្តិការណ៍ ថ្ងៃទី១៧មេសា១៩៧៥

ខ្មែរភាគច្រើននៅក្នុងស្រុកយល់ដោយស្មានៗថា ព្រឹត្តិការណ៍ថ្ងៃទី១៧មេសានេះ បានមកដោយសារស្នាព្រះហស្ថរបស់សម្ដេចឪ ។ តែចំណែកឯសម្ដេចឪវិញនៅបរទេសឯណោះ ធ្វើហាក់ដូចជាគ្មានដឹង គ្មានយល់អ្វីទាំងអស់ ។

ថ្ងៃទី១៧មេសា១៩៧៥ សម្ដេចឪកំពុងធ្វើបដិសណ្ឋារកិច្ចភ្ញៀវកិត្តិយសក្នុងស្ថានទូតអារ៉ាប់ ។ សម្ដេចឪបានទទួលដំណឹងជាផ្លូវការអំពីជោគជ័យដ៏ចម្លែកនេះ ។ តាមអ្នកសង្កេតការណ៍បរទេសដែលបានតាមដានពីរឿងនេះ គេបានសរសេរបញ្ជាក់ថា សម្ដេចសីហនុមិនបានបញ្ចេញប្រតិកម្មឲ្យឃើញថា សម្ដេចមានការភ័យព្រួយឬសប្បាយរីករាយឡើយ ។ តែផ្ទុយទៅវិញ ជាឯកជន សម្ដេចស្លន់ស្លោតក់ស្លុតជាក្រៃលែង ។ សម្ដេចអន្ទះសារយ៉ាងខ្លាំង រង់ចាំដំណឹងពិតប្រាកដជាផ្លូវការពីប្រទេសកម្ពុជាជាបន្តមកទៀត ។ តែបែរជាងងឹតអន្ធកា គ្មានទទួលអ្វីជាបន្ថែមមកទៀតទាល់តែសោះ...។ អ្នកកាសែតនានាតាមសួរដេញដោលសម្ដេចសីហនុ ពីរឿង

ជោគជ័យដ៏ចម្លែកនេះ ។ សម្តេចសីហនុរកពាក្យឆ្លើយយ៉ាងខ្លីថា ៖ « សម្តេចម៉ែអាពាធ ធ្វើឲ្យសម្តេចយាងត្រឡប់ចូលកាន់មាតុភូមិមិនបាន » ។ល។ ព្រះមហាក្សត្រីយានីសោយទិវង្គតនៅចុងខែមេសា១៩៧៥ ។

នៅថ្ងៃទី៨ឧសភា សម្តេចសីហនុបានថ្លែងប្រាប់អ្នកកាសែតជាតិអាល់ហ្សេរីម្នាក់ថា ៖

« ខ្ញុំគ្មានការចាំបាច់នឹងចូលទៅកាន់ប្រទេសកម្ពុជាទេ... ខ្ញុំត្រូវតែថយឲ្យឆ្ងាយពីប្រទេសខ្ញុំ... ខ្ញុំមិនត្រូវភ្ជាប់ខ្លួនក្នុងកិច្ចការនៃខ្មែរក្រហមទាំងនោះឡើយ... ខ្ញុំសំរេចិត្តនិរទេសខ្លួនទៅសំណាក់នៅទីក្រុងព្យុងយ៉ាងនៃប្រទេសកូរ៉េខាងជើង... រស់ដោយសន្តិភាពឆ្ងាយពីបញ្ហាដ៏ស្មុគស្មាញនេះ » ។

នៅចុងខែឧសភា១៩៧៥, សម្តេចសីហនុបានបញ្ជាក់ប្រាប់អ្នកកាសែតបរទេសបន្ថែមទៀតថា ៖ សម្តេចមិនវិលចូលកាន់មាតុភូមិកម្ពុជាជាដាច់ខាត ។ គេបានដឹងថា នៅចុងខែឧសភានេះ នៅព្យុងយ៉ាង, សម្តេចសីហនុបានតែងបទចំរៀងមួយដែលមានឈ្មោះថា « លាហើយកម្ពុជា » ។

ថ្ងៃទី១៨កក្កដា, លោកសារិន-ឆាក់និងលោកជួន-ប្រសិទ្ធិធ្វើដំណើរទៅកាន់ក្រុងព្យុងយ៉ាង សុំក្រាបថ្វាយបង្គំយាងសម្តេចសីហនុត្រឡប់ចូលកាន់ប្រទេសកម្ពុជាវិញ ។ ពេលនោះសម្តេចសីហនុបដិសេធយ៉ាងដាច់ខាត ។ មួយខែក្រោយមកទៀត គឺនៅថ្ងៃទី១៨សីហា, សម្តេចប៉ែន-នុតនិងលោកខៀវ-សំផនធ្វើដំណើរទៅកាន់ក្រុងព្យុងយ៉ាង សូមយាងសម្តេចវិលត្រឡប់ចូលកាន់ប្រទេសកម្ពុជាម្តងទៀតដោយអះអាងថា នឹងប្រគល់តំណែងប្រមុខរដ្ឋថ្វាយសម្តេចឱ្យរហូតអស់មួយជីវិត ។ ពេលនោះសម្តេចឪត្រេកអរណាស់ ហើយទទួលយល់ព្រមដោយគ្មានរារែក ។ សម្តេចសីហនុយាងទៅប៉េកាំងដើម្បីសុំលារដ្ឋមន្ត្រីទី១ចិនជូ-អេនឡាយ ដែលកំពុងតែព្យាបាលជម្ងឺនៅមន្ទីរពេទ្យ ។ សម្តេចមានបន្ទូលយ៉ាងស្និទស្នាលថា ៖ ដែលសម្តេចយល់ព្រមចូលទៅកាន់ប្រទេសកម្ពុជានោះ គឺមិនមែនមានន័យថា សម្តេចយល់ព្រមទទួលស្គាល់ខ្មែរក្រហមទាំងនោះទេ តែជាពលិកម្មដើម្បីជាកិត្តិយសដល់ប្រទេសចិន ហើយជាពិសេសដល់លោកជូ-អេនឡាយ ដែលបានជួយប្រទេសខ្មែរនិងសម្តេចយ៉ាងច្រើនលើសលប់ ។ល។

សម្តេចយាងទៅដល់ក្រុងភ្នំពេញនៅថ្ងៃទី៩កញ្ញា១៩៧៥ ដោយកាត់តាមទីក្រុងហាណូយ ដើម្បីធ្វើទស្សនកិច្ចយ៉ាងខ្លីនៅទីនោះផង ។

ពេលនោះ នៅចំណាតអាកាសយានពោធិចិនតុង មានក្រាលកំរាលក្រហមឆ្អៅ មានព្រះសង្ឃគង់រង់ចាំថ្វាយព្រះពរជយន្តោ, មានស្រីក្រមុំក្មេងៗ ឈររង់ចាំថ្វាយបាច់ផ្កា, មានយោធាខ្មែរក្រហមស្លៀកពាក់ជាឯកសណ្ឋាន និងស្លៀកពាក់ជាស៊ីវិល

ឈរចាំជារបងកិត្តិយសថ្វាយសម្តេចឪ ។ល។

លុះទ្វារយន្តហោះបើកឡើង សម្តេចរន្ធត់ធ្លាក់ថ្លើមក្តុក ខកព្រះទ័យ ដោយឃើញបរិយាកាសនិងបដិសណ្ឋារកិច្ចដ៏សោះកក្រោះរង់ចាំទទួល ។ សម្តេចរារែកថយក្រោយពីរបីជំហាន មួយសន្ទុះទើបយាងចុះពីយន្តហោះ ។ អង្គការក៏យាងសម្តេចទៅទស្សនា «សមរភូមិមុខ» គឺការជីកដីធ្វើទំនប់, លើកភ្លឺស្រែ ។ បន្ទាប់មកទៀត អង្គការយាងសម្តេចទៅសម្ពោធរោងចក្រតម្បាញ ។ ពេលសម្តេចយាងចូលទៅដល់ កម្មករជាច្រើននាក់រត់ឈ្លូរឆមកថ្វាយបង្គំថ្លែងសារទុក្ខទាំងយំគគ្រូកព្រោះរង់ចាំតែសម្តេចយាងមកដល់សង្គ្រោះ ។ មានកម្មករខ្លះលួចថ្វាយលិខិតដែលមានចែងនូវអំពើព្រៃផ្សៃនិងការធ្វើទារុណកម្ម ពីសំណាក់ខ្មែរក្រហមមកលើជនជាតិខ្មែរដែលជាកូនចៅទាំងអស់កំពុងតែទទួល ។ល។

សម្តេចខូចទឹកចិត្តជាខ្លាំងដោយឃើញស្ថានការណ៍បែបនេះ ។ មិនតែប៉ុណ្ណោះសោត អង្គការហាមប្រាមមិនឲ្យសម្តេចយាងទៅណាដោយសេរីខុសពីបញ្ជាតិរបស់អង្គការឡើយ ។

បីអាទិត្យក្រោយមក ដើម្បីឲ្យអំណាចគ្រប់គ្រងរបស់អង្គការមានលក្ខណៈស្របច្បាប់ អង្គការតម្រូវឲ្យសម្តេចយាងទៅកាន់អង្គការសហប្រជាជាតិ ដើម្បីបង្ហាញខ្លួនក្នុងឋានៈ ជាតំណាងរដ្ឋាភិបាលកម្ពុជារបស់ខ្មែរក្រហម ដែលចំហាទំនេរនៅទីក្រុងញូវយ៉ក តាំងពីឆ្នាំ១៩៧០មកម្ល៉េះ ។

ក្នុងឱកាសប្រជុំជាឧឡារិកនៅអ.ស.ប. សម្តេចមានបន្ទូលយ៉ាងក្រអឺត ដែលមានន័យជាអាទិថា ៖

« ...ប្រទេសខ្មែរតូចពិតមែន ប៉ុន្តែអាចកំចាត់ចក្រពត្តិអាមេរិកាំង ដែលជាមហាអំណាចលើពិភពលោក ឲ្យខូចគោលបំណងដែលចង់ចូលមកឈ្លានពានប្រទេសកម្ពុជារបស់សម្តេចតទៅទៀត... » ។ល។

ចប់សុន្ទរកថាដ៏គួរឲ្យខ្មាស់អៀននេះ មានអ្នកតំណាងប្រទេសខ្លះ មានចំនួន១ភាគ៣ ដែលមិនដឹងច្បាស់ពីស្ថានការណ៍ផ្ទៃក្នុងនៃប្រទេសកម្ពុជា បានទះដៃអបអរសាទរ នូវជោគជ័យដ៏មហិមាក្លែងក្លាយនេះ ។

សម្តេចយាងត្រឡប់ទៅកាន់ប្រទេសកម្ពុជាវិញ កាត់តាមប្រទេសបារាំង ដោយទ្រង់សំណាក់នៅទីក្រុងប៉ារីស៍អស់មួយរយៈ ។ សម្តេចបានជួបលោកប្រធានាធិបតីបារាំង វ៉ាលេរី-ហ្ស៊ីស្កា ដេស្តាំង នៅថ្ងៃទី៩តុលា៧៥ ។

លុះសម្តេចយាងចូលដល់ប្រទេសកម្ពុជា សម្តេចសំរាកតែមួយរយៈយ៉ាងខ្លីលោកក៏ធ្វើដំណើរដោយចិត្តឯង ដោយគ្មានពិគ្រោះជាមួយអង្គការទេ ។ សម្តេចយាងទៅធ្វើទស្សនកិច្ចប្រទេស១១នៅថ្ងៃទី១៥វិច្ឆិកា១៩៧៥ ។ អង្គការឃើញសក-

ម្នភាពរបស់សម្ដេចយ៉ាងដូច្នេះ មិនសប្បាយចិត្តទាល់តែសោះ ដើម្បីព្រមាននូវការមិនពេញចិត្តនេះ អង្គការទទួលសម្ដេចនៅពេលសម្ដេចយាងចូលប្រទេសកម្ពុជាវិញ នៅថ្ងៃ៣១ធ្នូ១៩៧៥ ក្នុងថានៈជាវរជនជាន់ខ្ពស់មួយរូបតែប៉ុណ្ណោះ ។

## តើអង្គការជានរណា ?

ក្នុងរយៈពេល៣ឆ្នាំ៨ខែ២០ថ្ងៃក្នុងរបបអង្គការ គ្មានខ្មែរណាស្គាល់ថា តើអង្គ-ការជានរណាទេ ។ អង្គការគ្មានរូបរាងដូចខ្មោចព្រាយបិសាច ចេះប្រើឧបាយកលយ៉ាងអាថ៌កំបាំង អាចឆ្លែប្រឌិតក្រុមចោរឲ្យក្លាយទៅជាក្រុមបដិវត្តន៍ អាចឆ្លែក្រឡៃពួកខ្មែរក្រហម ដែលបង្កើតដោយខៀវ-សំផន ឲ្យក្លាយទៅជាឃាតករដ៏ឃោរឃៅ ។ អាចបង្វិលខួរក្បាលខ្មែរសឹងមួយនគរ ឲ្យមានសភាពងងឹតអន្ធការដោយការយល់បានត្រឹមតែស្មានៗតែប៉ុណ្ណោះ ។ សូម្បីតែសម្ដេចសីហនុ ក៏លោកយល់ច្រឡំយ៉ាងធ្ងន់ជាងធ្ងន់ ។ មើលចុះ ! នៅថ្ងៃទី២មេសា១៩៧៦ លោកថ្លែងជាភាសាបារាំងសរសើរអរគុណអង្គការអនាមិកដូចមានសេចក្ដីជាអាទិថា ៖

«... ពួកអាក្បត់បានធ្វើទុក្ខបុកម្នេញ និងប្រមាថកាតទានដល់រូបខ្ញុំ ព្រមទាំងប្រទាញប្រទង់ខ្ញុំ ឲ្យធ្លាក់ចុះទៅក្នុងភក់ជ្រាំនៃភាពអាម៉ាស់របស់ពួកវា ។ ខ្ញុំមានអំ-ណរគុណជាភយ្យោភាពដល់អស់លោកវិរបុរស, វិរនារី នៃអង្គការបដិវត្តន៍ទាំងនោះណាស់ ដែលបានលុបលាងរូបខ្ញុំឲ្យរួចចាកពីភក់ជ្រាំនេះ ហើយដែលធ្វើឲ្យខ្ញុំមាននិតិសម្បទាវិញចំពោះមុខប្រវត្តិសាស្ត្រ... » ។

ដូច្នេះសម្ដេចសីហនុបណ្ដោយខ្លួនឲ្យចាញ់បោកអង្គការ ដែលនឹកទៅគួរឲ្យអៀនខ្មាស់ជាក្រៃលែង ។

លុះប្រទេសកម្ពុជាមានកៅអីស្រួលបួលនៅអ.ស.ប. គឺប្រទេសខ្មែរបានសំរេចពេញលក្ខណៈស្របច្បាប់អន្តរជាតិ ដោយស្ដាព្រះហស្ថជាស្ថាពរ ស្រាប់តែអង្គការចេញបញ្ជាឲ្យសម្ដេចប្រមូលព្រះរាជបុត្រទាំងអស់ ធ្វើមាតុភូមិនិវត្តន៍ចូលស្រុកខ្មែរវិញ ។ លុះព្រះរាជបុត្រទាំងឡាយនោះ ចូលដល់រដ្ឋធានីភ្នំពេញ ជួនជុំគ្នាស្រេចបាច់ហើយ អង្គការក៏ចេញបញ្ជាបំបែកព្រះរាជបុត្រ ឲ្យទៅធ្វើការរួមទាំងបង្ខំ ដូចប្រជាជនទូទៅទាំងប្រទេសដែរ... ដូច្នេះព្រះរាជបុត្រក៏បានស្លាប់អស់ជាច្រើន ។ អង្គការចេញបញ្ជាបង្ខំឲ្យសម្ដេចសីហនុ ធ្វើពាក្យសុំលាលែងពីមុខតំណែងប្រមុខរដ្ឋខ្មែរក្នុងខែមិនា១៩៧៦ ។

សួរ ៖ ហេតុដូចម្តេចបានជាអង្គការមិនសម្លាប់សីហនុ ? ។

ឆ្លើយ ៖ អង្គការរក្សាសម្តេចសីហនុទុកធ្វើជានុយ ដើម្បីទាក់ទាញប្រជាជន ខ្មែរដែលនៅស្នេហាសម្តេចឱ្យតទៅទៀត...។

❑ ❑

❑

# ជំពូកទី១១

★ ចម្ងល់របស់បរទេសនានាចំពោះវត្តមាននៃអង្គការ ។
★ កូនយោធាខ្មែរក្រហមចាប់ចងភ្នាក់ងារទូតអតិតសហភាពសូវៀតជារៀមច្បង ។

## ចម្ងល់របស់បរទេសនានាចំពោះវត្តមាននៃអង្គការ

អង្គការក្រឡុកលេងសើចដាក់ភ្នាក់ងារទូតនានា មានភ្នាក់ងារទូតអតិតសហភាពសង្គមនិយមសូវៀតជាដើម ។ នៅថ្ងៃទី១៩មេសា ពេលល្ងាច ស្ថានទូតអតិតសហភាពសូវៀត បានព្យួរផ្លាកមួយជាប់នឹងមាត់ទ្វារ សរសេរអក្សរបារាំងធំៗ មានសេចក្តីជាអាទិ៍ថា ៖ យើងសង្គមនិយមជាមិត្ត ជាបងប្អូន សូមមិត្តអញ្ជើញមកជួបបងប្អូនយើង យើងចាំមិត្តនៅទីនេះ គឺក្នុងស្ថានទូត ។ សូមមិត្តនាំអ្នកចេះនិយាយភាសាបារាំងមកជាមួយផង ។ល។

នៅពេលដែលតំណាងអង្គការមកដល់ ពួកនេះមិនខ្វីរវល់អើពើនឹងមើលផ្លាកនៅមាត់ទ្វាររបស់ស្ថានទូតនេះទេ តែតំណាងរបស់អង្គការបែរជាកេះកៃកាំភ្លើងបេ-៤០ ដែលជាកាំភ្លើងបានដោយសារជំនួយរបស់អតិតសហភាពសូវៀតនេះឯង បាញ់ចំសោរដើម្បីបើកទ្វារឲ្យបានទាន់ចិត្ត ។ ពេលចូលទៅដល់ស្ថានទូត មានមនុស្សប្រុស៥នាក់ ស្រី៣នាក់ ។ ពួកនេះក៏ចាប់ភ្នាក់ងារទូតទាំងអស់នោះចងស្លាបសេកហើយបណ្តើរទៅកាន់បន្ទប់បាយ ។ ពេលបើកទូរទឹកកកឡើងឃើញមានពងមាន់នៅក្នុងនោះ តំណាងអង្គការយកមកបោកចោលនៅចំពោះមុខអ្នកជាប់ចំណង ព្រមទាំងស្តីបន្ទោសថា ៖

« នៅក្នុងរបបសង្គមនិយមដ៏ពិតប្រាកដ និងដ៏ឆ្លិនឆ្លៅរបស់អង្គការ គេមិនហូបបំផ្លាញពងមាន់យ៉ាងនេះទេ គេត្រូវតែយកវាទៅភ្ញាស់សិន រួចយកមេមាន់មកចែកគ្នាហូប...។ល។

ភ្នាក់ងារទូតអតិតសហភាពសូវៀតជាសង្គមនិយមរៀមច្បងដ៏ខ្លាំងពូកែលើលោកធ្វើភ្នែកឡឹងឡង់ ។ ដោយយល់តាមកាយវិការខ្លះៗ ក៏នឹកថា ៖ ឱអង្គការចង់

ធ្វើការសើរើនិយមទេដឹង ? ភ្នាក់ងារជាប់ចំណងទាំងអស់គ្រវីក្បាល ដោយមកពីមិនយល់អស់នូវន័យដែលគេនិយាយពន្យល់ តែគេនឹកក្នុងចិត្តថា សង្គមនិយមរបស់អង្គការស្ទើគេនេះប្រហែលជាឥតប្រយោជន៍ និងធ្វើឲ្យវិនាសហិនហោចទេដឹង ? គ្រាន់តែមានក្នុងការស្រមៃតែមិនដឹងថាគេចង់ធ្វើអ្វី ? តើអង្គការជានរណាទៅអេះ ?

ចាប់ពីថ្ងៃទី២០កុម្ភៈដល់៦មេសា១៩៧៦ មានភ្នាក់ងារទូតជាតិស៊ុយអែដម្នាក់ឈ្មោះកាហ្សិក មានឱកាសបានទៅធ្វើទស្សនកិច្ចរបបសង្គមនិយមចម្លែករបស់អង្គការ ។ លោកធ្វើអធិប្បាយថា ៖ បដិវត្តន៍ខ្មែរដែលមានឈ្មោះអង្គការអនាមិកជាមេដឹកនាំគួរឲ្យចម្លែកអស្ចារ្យ គឺប្លែកពីបដិវត្តន៍នៃប្រទេសមហាអំណាចនានា ដូចជាប្រទេសចិន ឬអតិតសហភាពសូវៀតជាដើមឆ្ងាយណាស់ គឺការបំផ្លាញខ្ទេចបំផ្លាញខ្ទី ញ៉ាំងឲ្យពិភពលោកភ្ញាក់ផ្អើល នូវអំពើឃោរឃៅកាប់សម្លាប់ ដែលមានភាពពុះពោរហាក់កញ្ជ្រោលដូចភ្នំភ្លើង ។ល។

លោកមានការឆ្ងល់សែនឆ្ងល់ ព្រោះរាស្ត្រខ្មែរជាអ្នកកាន់ពុទ្ធសាសនា ដែលមិនហ៊ានទាំងសម្លាប់សត្វមុសឬរុយមួយផង តើហេតុអ្វីបានជាមានការកាប់សម្លាប់យ៉ាងរង្គាលបែបនេះ ? ។

អ្នកស្រីឡូរ៉ង់ពិច, ជាតិបារាំង, មានប្តីជាកម្មាភិបាលជាន់ខ្ពស់របស់ខ្មែរក្រហមឈ្មោះមិត្តសួង-ស៊ីគឿន បានត្រូវទទួលទារុណកម្មយ៉ាងធ្ងន់ពីសំណាក់របបអង្គការ ។ អ្នកស្រីនេះបានអះអាងធ្វើជាសាក្សីចំពោះអំពើឃោរឃៅរបស់របបនេះ ។ អ្នកស្រីថែមទាំងបានសរសេរអធិប្បាយយ៉ាងពិស្តារនៅក្នុងឯកសាររបស់គាត់ទៀតផង ។

ជាសរុបសេចក្តីទៅ អ្នកស្រីសរសេរបញ្ជាក់ថា ៖ អង្គការជាបិសាច អាចចូលសណ្ឋិតក្នុងបុគ្គលណាដែលលោភអំណាច ស៊ីជោរ ។ កាលបើបិសាចនោះចូលសណ្ឋិតក្នុងបុគ្គលណាហើយ បុគ្គលនោះភ្លេចអស់ហើយនូវម៉ែឪ ប្រពន្ធកូន ញាតិ មិត្ត ជាពិសេសជាតិរបស់ខ្លួន ។ តួយ៉ាងដូចរឿងមិត្តសួង-សាគឿនប្តីរបស់អ្នកស្រីស្រាប់ ដែលធ្វើទារុណកម្មលើប្រពន្ធកូនរបស់ខ្លួន ។ល។ អ្នកស្រីបានបញ្ជាក់ទៀតថា សូម្បីតែថានៈអ្នកស្រីជាភរិយារបស់កម្មាភិបាលជាន់ខ្ពស់ផង អ្នកស្រីទទួលទារុណកម្មយ៉ាងវេទនារកពាក្យសរសេរមិនបានផង ចុះទំរាំដល់ប្រជាជនគ្មានបុណ្យស័ក្តិ ឬងារអ្វីនឹងគេនោះ តើត្រូវរងទុក្ខជាងនេះប៉ុន្មានដងទៅទៀត ។ អ្នកស្រីបានជំរុញថា ៖ គួរឲ្យអាសូរអ្នកដែលជួបប្រទះនឹងរឿងនេះណាស់ ហើយនៅទីបញ្ចប់អ្នកស្រីធ្វើសំនួរមួយដែរថា ៖

តើនរណាជាអង្គការ ?

❑

# ជំពូកទី១២

★ កំណើតរដ្ឋាភិបាលទីងមោងកម្ពុជាប្រជាធិបតេយ្យ ។
★ អង្គការចាត់តែងតាំងខ្មែរវៀតមិញជាគណៈតំបន់ ជាតំណាងរាស្ត្រ ។
★ មុខងាររបស់ក្រសួងសុខាភិបាល និងក្រសួងអប់រំរបស់អង្គការ ។
★ អង្គការបង្កើតឃាតករជាប្រាំក្រុម ។
★ ខ្មែរវៀតមិញដើរប្រមូលមាសពេជ្រនិងលុយកាក់ ។
★ អង្គការបង្កើតក្រុមនិងកងសហករណ៍តំបន់ ។

## កំណើតរដ្ឋាភិបាលទីងមោងកម្ពុជាប្រជាធិបតេយ្យ

ថ្ងៃទី១៧មេសា១៩៧៥ អង្គការទទួលជ័យជំនះ ហើយចូលមកលុកលុយប្រទេសកម្ពុជាភ្លាម ។ ជាដំបូងអង្គការច្រានតែក្បាលខ្មែរក្រហមនិន្នាការខ្មែរពីរក្រុម ។ ក្រុមទី១គឺបក្សខ្មែរក្រហមរបស់លោកខៀវ-សំផន ។ ក្រុមទី២គឺអតិតចោរ ដែលអង្គការកែឆ្នៃជាក្រុមខ្មែរក្រហមដែរ និងក្រុមទី៣ ជាក្រុមឃាតករអាថ៌កំបាំង ដែលរាស្ត្រខ្មែរមិនស្គាល់ថាជាសាសន៍អ្វីទេ ។

ឃាតករទាំងបីក្រុមនេះអនុវត្តតាមបញ្ជារបស់អង្គការ សម្លាប់ប្រជារាស្ត្រខ្មែរស្លូតត្រង់ ជាពិសេសអ្នកចេះដឹង ដោយគ្មានជំនុំជំរះអ្វីទេ ។ សម្លាប់ក្នុងរយៈពេល ១០ខែ អ្នកចេះដឹងស្លាប់ជិតអស់ ។ អ្នកដែលមិនទាន់ដល់វេនស្លាប់ ខ្លាចបាក់ស្បាតមិនហ៊ានកំរើក ទើបអង្គការបញ្ចេញអតីតខ្មែរយៀកមិញ គឺសមាជិកបក្សប្រជាជនបដិវត្តន៍ខ្មែរ ។ អង្គការចាត់តែងជាស្រេចជាប្រធានសហករណ៍ ជាគណៈតំបន់ និងជាតំណាងរាស្ត្រ រួចបន្លំប្រើឃីហោខ្មែរក្រហមតទៅទៀត ដែលមានជាឧទាហរណ៍ខ្លះៗដូចតទៅ ៖

- នៅថ្ងៃទី២០ ខែមិនា ឆ្នាំ១៩៧៦ ជាថ្ងៃជ្រើសរើសតំណាងរាស្ត្រ អង្គការអ-នាមិកចេញបញ្ជាឲ្យហៅប្រជាពលរដ្ឋទាំងអស់នៅសហករណ៍លក់ជ្រៀវ ឲ្យមកជួបជុំនៅកងលេខ៣ ភូមិព្រៃស្វាយខាងលិច ។ លុះជួបជុំជាច្រើនពាន់នាក់ហើយ មានតំណាងរបស់អង្គការចុះមកពីថ្នាក់លើ ចេញបញ្ជាទាំងបង្ខំឲ្យប្រជាជនខ្មែរទាំងអស់លើកដៃយល់ព្រមចាត់តាំងមិត្ត មូល-សម្បត្តិ ហៅតាប៉ែត ជាតំណាងរាស្ត្រនៅតំបន់ទី១ ។

តាប៉ែតមានមុខតំណែងមួយទៀត គឺគណៈតំបន់ទី១, អង្គភាពជាមួយមិត្ត រស់-ញឹម ហៅតាកៅ ។ លុះមានតំណាងរាស្ត្ររួចស្រេចបាច់ហើយ គេក៏ប្រកាសបង្កើតរដ្ឋាភិបាលទីងមោងមួយនៅថ្ងៃទី១៤ មេសា ឆ្នាំ១៩៧៦ គឺមួយឆ្នាំគត់ក្រោយថ្ងៃដែលអង្គការលុកលុយរាតត្បាតប្រទេសកម្ពុជា ។ រីឯសមាសភាពនៃរដ្ឋាភិបាលនោះគឺ ៖

| | |
|---|---|
| - ខៀវ-សំផន | ប្រធាន |
| - សូ-ភឹម | អនុប្រធាន |
| - រស់-ញឹម | អនុប្រធាន |
| - នួន-ជា | ប្រធានគណកម្មការអចិន្ត្រៃយ៍ នៅរដ្ឋសភាកាលពីសម័យប៉ុល-ពត, នួន-ជា ( ឬឡៅ-ប៊ុនគន ឬឡុងរិុត ) ជាមេបញ្ជាការជាន់ខ្ពស់នៃកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា និងជាប្រធានការិយាល័យនយោបាយ ។ |
| - ប៉ុល-ពត | បានត្រូវតែងតាំងជារដ្ឋមន្ត្រីទី១ ទទួលបន្ទុកផ្នែកការបរទេស ។ |
| - អៀង-សារី | អនុរដ្ឋមន្ត្រីទី១ទទួលបន្ទុកការបរទេស ។ |

- អ្នកស្រីខៀវ-ធីរិទ្ធិ ( ប្រពន្ធអៀង-សារី ) រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ។

| | |
|---|---|
| - វ៉ន-វេត | អនុរដ្ឋមន្ត្រីទី១ទទួលបន្ទុកផ្នែកសេដ្ឋកិច្ចនិងឧស្សាហកម្ម ។ |
| - សឺន-សេន | អនុរដ្ឋមន្ត្រីទី១ ទទួលបន្ទុកផ្នែកការពារផ្ទៃប្រទេស ។ |

- អ្នកស្រីយ៉ុន-យ៉ាត ( ប្រពន្ធសឺន-សេន ) រដ្ឋមន្ត្រីក្រសួងអប់រំ និងវប្បធម៌

| | |
|---|---|
| - ហ៊ូ-នឹម | រដ្ឋមន្ត្រីក្រសួងឃោសនាការ ។ |
| - ជួន-ជឿន | រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ |

ក្រៅពីរដ្ឋមន្ត្រីទាំងនោះ គេមានបង្កើតគណៈកម្មការ៦ ដែលនៅអបអនុប្រធាន

ទទួលខុសត្រូវផ្នែកសេដ្ឋកិច្ច កសិកម្ម ឧស្សាហកម្ម ចំការកៅស៊ូ ពាណិជ្ជកម្ម គមនាគមន៍ និងថាមពល ។ គណៈកម្មការនេះមានសមាជិក៥នាក់គឺ ៖ ប៉ុល-ពត, អៀងសារី, សឺន-សេន, មិត្តនួន និងមិត្តយ៉ាង ។ មិត្តនួននិងមិត្តយ៉ាន គ្រាន់តែជាឈ្មោះតែគ្មានមនុស្សត្រឹមត្រូវទេ ។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អ្នកមានអំណាចយ៉ាងខ្លាំងហើយបញ្ចេញសកម្មភាពយ៉ាងអាថ៌កំបាំងគឺ ប៉ុល-ពត និងប្រពន្ធ ។

ប្រពន្ធប៉ុល-ពតឈ្មោះ ខៀវ-ប៉ុណ្ណារី ជាបងបង្កើតរបស់ខៀវ-ធីរិទ្ធិ ( ប្រពន្ធអៀង-សារី) ជាអ្នកកាន់ក្ដាប់អំណាចយ៉ាងខ្លាំងអស្ចារ្យ ។ ក្នុងរយៈពេល៥ឆ្នាំដែលធ្វើសង្គ្រាម ខៀវ-ប៉ុណ្ណារីត្រូវបានគេចាត់តាំងជាអនុប្រធានមេបញ្ជាការជាន់ខ្ពស់នៃកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា (ជំនួសប្ដី) និងជាមេការិយាល័យទាហាន ។

ចាប់តាំងពីថ្ងៃទី៣០ កញ្ញា ១៩៧២ អ្នកស្រីត្រូវបានគេចាត់តាំងបន្ថែមជាអគ្គលេខាធិការបក្សកុម្មុយនិស្តខ្មែរ ។

បងប្អូនខ្មែរអើយ... មើលចុះរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យស្អីគេនេះ លើកបន្តុបតែបងប្អូនប្ដីប្រពន្ធ២-៣គ្រួសារ ចាត់តែងតាំងជារដ្ឋមន្ត្រី ។ សមាជិកខ្លះមានតែឈ្មោះក្នុងក្រដាស់តែគ្មានមនុស្សទេ ។ អង្គការឆ្នៃប្រឌិតបង្កើតឡើងយ៉ាងនេះដើម្បីបោលពិភពលោកនិងអន្តរជាតិឲ្យយល់ច្រឡំស្មានតែខ្មែរក្រហមគ្រប់គ្រងប្រទេសខ្មែរ និងមានរដ្ឋាភិបាលត្រឹមត្រូវ ។ រយៈវេលានោះ នៅក្នុងតឹកដីនៃប្រទេសកម្ពុជា បរិយាកាសសែនងងឹតអន្ធកា ។ គ្មានរាស្ត្រខ្មែរណាម្នាក់ដឹងថា មានបង្កើតរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យស្អីៗយ៉ាងនោះទេ...។

គេមិនដែលឮខ្មែរក្រហមណានិយាយនឹកឈ្មោះ ខៀវ-សំផន, ហ៊ូ-នឹម, ហ៊ូ-យន់ ឬឈ្មោះស្អីៗផ្សេងៗទៀតនោះទេ ។ ឈ្មោះសាឡុត-សរ ហៅប៉ុល-ពត ប្រជាពលរដ្ឋខ្មែរមិនស្គាល់ទាល់តែសោះ...។

ចំណែកឈ្មោះសម្ដេចឪ ជាគូបដិបក្សជាមួយលន់-នល់ បើរាស្ត្រខ្មែរណាហ៊ានរំលឹកឈ្មោះនេះ រាស្ត្រនោះត្រូវស្លាប់ភ្លាម ។

កម្មវិធីកំទេចបំផ្លាញប្រទេសខ្មែរ, កម្មវិធីសម្លាប់បំផុតពូជខ្មែរ ព្រមទាំងធ្វើទារុណកម្មយ៉ាងឃោរឃៅព្រៃផ្សៃដល់ប្រជាពលរដ្ឋខ្មែរក្នុងមួយនគរ គឺធ្វើយ៉ាងម៉េចក៏ដោយឲ្យតែដល់ស្លាប់ ។ យើងឮថាគេធ្វើតាមបញ្ជារបស់អង្គការ ។

ក្នុងរយៈ៤៤ខែ អង្គការគ្រប់គ្រងប្រទេសកម្ពុជា អង្គការបង្កើតក្រសួងតែ២ទេគឺ ៖ ក្រសួងសុខាភិបាល និងក្រសួងអប់រំ ។

តើក្រសួងសុខាភិបាលក្នុងរបបរបស់អង្គការគេធ្វើអ្វី ?

ក្រសួងសុខាភិបាលក្នុងរបបរបស់អង្គការ គឺបន្លំធ្វើជាគិញ បន្លំធ្វើជាគុក ។ បុ

គ្លលិកពេទ្យភាគច្រើនជាស្ត្រីក្មេងៗអាយុត្រឹមតែ១៨ឆ្នាំ ។ ភារកិច្ចត្រូវតែតាមដាននិងស៊ើបអង្កេត ត្រូវតែពិនិត្យមើល ថាតើអ្នកជម្ងឺឈឺពិតប្រាកដ ឬឈឺបណ្ដាមកពីសតិអារម្មណ៍ ? ។ បើសង្ស័យថាអ្នកជម្ងឺឈឺបណ្ដាលមកពីសតិអារម្មណ៍ គឺត្រូវបាត់ខ្លួនភ្លាម ។ កិច្ចការវាល់បបរចែកឲ្យអ្នកជម្ងឺ ។ អ្នកជម្ងឺម្នាក់ៗត្រូវបានទឹកបបរតែពីរវែកនិងអំបិលប្រាំគ្រាប់យ៉ាងច្រើន ។ ដូច្នេះអ្នកជម្ងឺឈឺល្មមៗ ត្រូវតែចេញធ្វើការដើម្បីបានបបរហូប ។ ចំណែកអ្នកជម្ងឺដែលចេញពលិកម្មមិនរួច ត្រូវតែឈឺធ្ងន់ទៅៗលុះត្រាតែស្លាប់ ។ វាមានបង្កើតកន្លែងសំរាប់អ្នកជម្ងឺឈឺធ្ងន់ៗនិងមនុស្សចាស់ជរា ។ វាប្រមូលយកមកឃុំឃាំងទុកឲ្យនៅទីនោះទៅ មិនឲ្យញាតិសារលោហិតចូលទៅសួរសុខទុក្ខឡើយ ។ អ្នកជម្ងឺទាំងអស់ ដេកតែក្នុងអង្រឹងបាវ មានកន្លែងខ្លះដេកកណ្ដាលព្រៃកណ្ដាលវាលគ្មានដំបូលជ្រក, គ្មានថ្នាំអ្វីក្រៅពីឫសឈើបុកយ៉ាងម៉ដ្តច្របល់ជាមួយបាយម៉ាន ប៉ាតណាប៉ាតណី រួចលុញជាដុំតូចៗហាលឲ្យស្ងួត ។ ថ្នាំធុននេះ ឈឺអ្វីៗលេបបានទាំងអស់ ។ អ្នកជម្ងឺណាឈឺរ៉ាំរ៉ៃ ពេទ្យរបស់អង្គការចាត់ការចាក់បញ្ចូលទឹកដូងខ្ទីឲ្យ ទោះជម្ងឺអ្វីក៏ដោយ ។ល។ និង ។ល។

តើក្រសួងអប់រំក្នុងរបបរបស់អង្គការបង្កើតឡើងដើម្បីអ្វី ?

អង្គការបង្កើតក្រសួងអប់រំ ដើម្បីប្រមូលកុមារាកុមារី ដែលមានអាយុចាប់ពី៦ទៅ១៣ឆ្នាំ នាំយកមកលុតដំឲ្យដល់កំពូល ដូចគេលុតដំដែកដើម្បីធ្វើពូថៅធ្វើកាំបិតដែលត្រូវគេដុតឲ្យដល់កំដៅ ។ យ៉ាងណាមិញបញ្ហានេះក៏ជាផែនការរបស់អង្គការដែលបានបំរុងទុកមកជាស្រេចហើយដែរ ។

កាលៈទេសៈនោះអង្គការចាត់តែងតាំងប្រជាជនថ្មីដែលមានវ័យជរាគ្មានចំណេះមិនដែលស្គាល់សាលារៀន ឲ្យមកធ្វើជាគ្រូបង្រៀន ។

លោកគ្រូនេះស្គាល់លេខមិនដល់១០ អានអក្សរប្រកបបណ្តើរ !

នេះជាភារកិច្ចរបស់លោកគ្រូ ៖

ម៉ោង៥ព្រឹក, លោកគ្រូត្រូវតែប្រមូលកូនសិស្សនាំយកទៅបង្ខំឲ្យធ្វើការដូចជាលើកភ្លឺស្រែ ទូលសំណាប ដើររើសអាចម៍គោ ដើររើសលាមក ប្រមូលផ្សំធ្វើជាជីរ ។ល។

ម៉ោង១១, លោកគ្រូប្រមូលកូនសិស្ស រួចនាំយកទៅចង្ក្រានបាយរួម ហូបទឹកបបរជាមួយអំបិល ។ ហូបរួចម៉ោង១២ទើបចូលរៀន ។ សាលារៀនស្ថិតនៅក្រោមដើមស្វាយមួយឬពីរដើមធំៗ ដែលមានម្លប់ដ៏ត្រជាក់ កណ្តាលវាលខ្យល់កំពុងបក់មកត្រសៀកៗ កូនសិស្សអង្គុយផ្ទាល់ដី កាន់ក្តារឈ្នួនម្នាក់មួយ និងមានធ្យូងម្នាក់មួយដុំ ផ្អែកគ្នាគ្មានសណ្តាប់ធ្នាប់ ស្វាបបណ្តើរងោកបណ្តើរ ។

ចំណែកលោកគ្រូកាន់ធ្យូងមួយដុំនៅដៃ ឈរក្បែរក្តារខៀនមួយចងព្យួរជាប

ដើមស្វាយ ។ លោកគ្រូចាប់ផ្ដើមសរសេរអក្សរ «ក» រួចនឹកអក្សរ «ខ» ។ ចាប់ផ្ដើមសរសេរស្រៈ មិនដឹងជាស្រៈ «ឿ» សរសេរយ៉ាងម៉េច ។ ដូច្នេះលោកគ្រូរវល់តែសរសេរលុបៗ ។ ដោយសារម្លប់ស្វាយត្រជាក់ល្អ ខ្យល់កណ្ដាលវាលបក់មករសៀកៗយ៉ាងស្រួល លោកគ្រូស្វាបហមៗ បែរក្រោយមើលកូនសិស្ស... ឱពុទ្ធោ! កូនសិស្សដេកលក់ជាងពាក់កណ្ដាលទៅហើយ ។ល។

ម៉ោង២កន្លះរសៀលព្វាយជួងជាសញ្ញាឲ្យប្រមូលកូនសិស្សចេញធ្វើពលិកម្មបន្តកិច្ចការដដែលតទៅទៀត ។ ពេលយប់ត្រូវប្រមូលកូនសិស្សអាយុ១០ឆ្នាំដល់១៣ឆ្នាំចេញពលិកម្ម ដូចជាលើកភ្លឺស្រែជាដើម ។ ពីម៉ោង៨យប់ដល់ម៉ោង១០ឬ១១ជិតអាធ្រាត ។ វាធ្វើទារុណកម្មធ្មើយហាត់យ៉ាងនេះ កូនសិស្សទាំងឡាយនោះដេកលក់តែពាសវាលស្រែ ។

កូនសិស្សទាំងអស់ស្លៀកពាក់ដាច់រយ៉ៃសឹងគ្រប់ៗគ្នា គ្មានភួយដណ្ដប់ មានតែបាវមួយម្នាក់ៗប៉ុណ្ណោះ ។ បាវនេះរដូវប្រាំងចងធ្វើជាអង្រឹងដេក រដូវរងារបែរជាយកមកដណ្ដប់ ។

ស្រាប់តែនៅខែមករាឆ្នាំ១៩៧៧ មានឧប្បត្តិហេតុមួយកើតមានឡើងគួរឲ្យចម្លែកព្រៃផ្សៃដ៏អស្ចារ្យ គឺអង្គការចេញបញ្ជាដាច់ណាត់ ត្រូវដកហូតបាវទាំងអស់ប្រមូលដាក់ចោលឲ្យកណ្ដៀរស៊ីខ្ទេច ។

ឱទេវតាអើយ ! តើកូនសិស្សទាំងឡាយនោះធ្វើយ៉ាងម៉េច ? បើខែមករា កុម្ភៈជារដូវយ៉ាងណា ? ។ កូនសិស្សទាំងអស់ ពេលយប់ត្រូវលួនចូលដេកក្នុងចំបើងដូចសត្វ វេទនាដ៏មហិមាសឹងរកពាក្យខ្មែរសរសេរគ្មាន ។ល។

ដូច្នេះក្នុងរយៈ៨៤ខែ កូនសិស្សអភ័ព្វទាំងឡាយនោះ ដែលសេសសល់នៅរស់គ្មានចេះអ្វីទាំងអស់ ចេះតែធ្វើចោរ ជាពិសេសចេះលួចស្រូវ, លួចហូបក្អែប, លួចហូបដង្កូវឈើគ្រប់មុខ លួចតេះសំបកខ្យង សំបកក្ដាម និងលួចហូបស្លឹកឈើគ្រប់ធុន ។ល។

ក្នុងរយៈ៨៤ខែត្រូវអង្គការលុតដំដល់កំពូល មានដុះចិត្តជាស្វ័យប្រវត្តិថា ត្រូវតែសងសឹកចំពោះខ្មែរក្រហមមិនអាចបំភ្លេចបានឡើយ ។

ក្រៅពីក្រសួងសុខាភិបាលនិងអប់រំ អង្គការគ្មានបង្កើតក្រសួងអ្វីទាំងអស់ ។ អង្គការបង្កើតតែឃាតករ៥ក្រុម រួចបំបែកដាច់ៗឡែកពីគ្នា រួចវាបញ្ជាឲ្យសម្លាប់បំផុតពូជខ្មែរជាដំណាក់ៗ កំណត់ពេលវេលាយ៉ាងត្រឹមត្រូវ ។ តើពួកណាត្រូវសម្លាប់វាស្រ្តខ្មែរធុនណា ? បន្តទៅមុខទៀតត្រូវបញ្ចេញក្រុមណាឲ្យទៅសម្លាប់ខ្មែរធុនណាទៀត ? ។ មានលំនាំយ៉ាងស្អាតយ៉ាងស្ទាត់ គ្មានមជ្ឈដ្ឋានខ្មែរណាគេចរួចទាន់ឡើយ ។

មើលចុះ ! ក្រុមទី១គឺក្រុមឃាតករអាថ៌កំបាំង ( យើងខ្មែរមិនស្គាល់ឃាតករនេះជាសាសន៍អ្វីទេ ) ។ ជាដំបូងវារៀបអន្ទាក់ជាខ្សែត្រៀមរង់ចាំបាញ់សម្លាប់នាម៉ឺនអ្នករដ្ឋការគ្រប់ៗផ្នែកគ្រប់ជាន់ថ្នាក់ ដែលប្រមូលនាំចូលកណ្តាលអន្ទាក់នោះ ។ ក្រុមនេះដូចខ្មោចព្រាយបិសាច វាពួនសម្ងំលាក់ខ្លួននៅទីងងឹត លួចបន្លំសម្លាប់បំផុតពូជខ្មែរដោយប្រើឈ្មោះខ្មែរក្រហម ។

ក្រុមទី២គឺជាកូនចៅរបស់លោកខៀវ-សំផន ឧទាហរណ៍នៅខេត្តបាត់ដំបងមានមិត្តស៊ូនិងមិត្តស៊ុយ ចេញមុខមុនគេតាំងរៀបចំក្បួនឡានកាម៉្យុងជាក្រុមៗ រួចដើរអញ្ជើញប្រមូលនាម៉ឺនអ្នករដ្ឋការគ្រប់ៗផ្នែក ដឹកនាំចូលទៅក្នុងខ្សែអន្ទាក់ត្រៀមរបស់ក្រុមឃាតករអាថ៌កំបាំង ត្រូវក្រុមនេះបាញ់សម្លាប់ចោលខ្ទេច ។

ក្រុមទី៣ចេញមុខមុនគេដែរ គឺសុទ្ធជាអតីតចោរព្រៃដែលអង្គការឆ្នៃប្រឌិតឲ្យទៅជាខ្មែរក្រហម រួចអង្គការបំបែកជា៣ពួក ៖

- ពួកទី១ ជាមេកាន់ក្កាប់ឃោធាក្មេងៗអាយុសឹងមិនដល់១៥ឆ្នាំផង ។
- ពួកទី២ ចាត់តាំងជាឈ្លប ។
- ពួកទី៣ ជាគណៈកម្មការកង ។ អង្គការឲ្យអភ័យឯកសិទ្ធិដល់ក្រុមនេះយ៉ាងពេញលេញ ៖

ក/ ដើរប្លន់ប្រើពាក្យស្នើរ ( ពាក្យស្នើរសាហាវជាងប្លន់ ពីព្រោះអង្គការចែងច្បាប់ការពារចោរដើរស្នើរ បើម្ចាស់ទ្រព្យរឹងទទឹង បាញ់សម្លាប់ចោលចុះ ) ។

ខ/ អាចសម្លាប់រាស្ត្រខ្មែរដោយសេរី តាមសាលក្រមកាត់ទោសរួចហើយ ទុកក៏មិនចំណេញ យកចេញក៏មិនខាត ។

គ/ ត្រូវធ្វើទារុណកម្មយ៉ាងដូចម្តេចក៏ដោយឲ្យតែរាស្ត្រខ្មែរស្លាប់ ។ ជាបង្រួមសេចក្តីមក អង្គការឲ្យសិទ្ធិក្រុមនេះយ៉ាងពេញលេញត្រួតត្រាប្រទេសខ្មែរតាមបច្ចេកទេសចោរ ។ល។ និង ។ល។

- ពួកទី៤ គឺអតីតខ្មែរវៀតមិញជាសមាជិកបក្សប្រជាជនបដិវត្តន៍ខ្មែរ ។ អង្គការបញ្ចេញក្រុមនេះនៅដើមឆ្នាំ១៩៧៦ ចាត់តែងតាំងជាស្រេចជាប្រធានសហករណ៍ ជាគណៈតំបន់ បន្តមកជាតំណាងរាស្ត្រដែលមានតាប៉ែត, តាកៅ, មិត្តលក, មិត្តលៃ និងមិត្តលី (ជាតិយួន) កាន់នៅតំបន់ទី១នៃខេត្តបាត់ដំបងដែលខ្ញុំស្គាល់និងឃើញច្បាស់នឹងភ្នែក ។

- ពួកទី៥ គឺអតីតខ្មែរវៀតមិញដែរ កងកម្លាំងប្រដាប់អាវុធបដិវត្តន៍ឯកភាពរបស់ប្រទេសកម្ពុជា ដែលសឺង-ង៉ុកមិញទទួលបញ្ជាពីហូ-ជីមិញ បង្កើតពីថ្ងៃទី១៩មិថុនា១៩៥១ លួចបង្កប់ទុកពាសពេញព្រៃនៃប្រទេសខ្មែរ ។ អង្គការបញ្ចេញក្រុមនេះជាចុងក្រោយបង្អស់នៅចុងឆ្នាំ១៩៧៧ ។ ភារកិច្ចក្រុមនេះ គឺរួមកម្លាំងជាម

ួយក្រុមឃាតករអាចកំបាំងបណ្ដាក់គ្នាសម្លាប់ខ្មែរក្រហមនិន្នាការខ្មែរ មានមិត្តស៊ូជាដើម ។ សម្លាប់គណាកម្មការកង, សម្លាប់ឈ្លបដែលជាខ្មែរក្រហមកើតមកពីចោរជាពិសេសសម្លាប់យុវជនចល័ត ។

តាមសេចក្ដីរ៉ាយរ៉ាប់ពីយុវជនខ្មែរដ៏ក្មេងម្នាក់នាមត្រកូលនួន ជាកូនប្រុសទោលរបស់លោកនួន-សាមិន ជាចាងហ្វាងពន្ធនាគារខេត្តបាត់ដំបង « មានខ្មែរក្រហមម្នាក់លួចបណ្ដោះនាំយកទៅជាមួយ » ។

យុវជននេះបាននិយាយអះអាងបញ្ជាក់ប្រាប់យាយទៀងផ្ទាល់ថា ៖ មុននឹងអង្គការបញ្ចេញឃាតករជាបន្តៗ ជាលំដាប់លំដោយ ឲ្យចេញមកសម្លាប់បំផុតពូជខ្មែរ អង្គការកាត់ទោសជាមុនរួចស្រេចទៅហើយ ។

អង្គការបញ្ជាឲ្យសម្លាប់ជាបន្ទាន់បំផុតដូចជា ៖ នាយទាហាន នាយទាហានរងនិងទាហានគ្រប់ៗផ្នែក ។ អ្នករដ្ឋការស៊ីវិលគ្រប់ៗផ្នែកគ្រប់ៗជាន់ថ្នាក់ ដូចជាបុគ្គលិកពន្ធនាគារ, តុលាការ, ក្រសួងគយ, នាម៉ឺនរដ្ឋបាល, សាស្ត្រាចារ្យ, គ្រូបង្រៀន, គ្រូពេទ្យជាដើម ។ល។ និង ។ល។

ពេលនោះមានមិត្តខ្លះលាន់មាត់សួរថា ៖ ហេតុដូចម្ដេចបានជាសម្លាប់ពេទ្យសាស្ត្រាចារ្យ និងគ្រូបង្រៀន ?

អង្គការធ្វើអត្ថាធិប្បាយវែកញែកថា ៖ សាស្ត្រាចារ្យនិងគ្រូបង្រៀន ឃើញតែបង្ហាត់បង្រៀនកូនពួកសក្ដិភូមិ កូនពួកចក្រពត្តិ និងកូនពួកនាយទុន ។ លុះក្រុមនេះរៀនចេះចប់ក៏ប្រឱតច្បាប់ជិះជាន់សង្កត់សង្កិនរាស្ត្រខ្មែរក្រីក្រល្ងង់ខ្លៅតែប៉ុណ្ណោះ ។ល។ ចំណែកបុគ្គលិកពេទ្យដូចជាវេជ្ជបណ្ឌិតជាដើម ឃើញថែទាំមើលជម្ងឺតែសក្ដិភូមិ ចក្រពត្តិនិងនាយទុន យើងមិនដែលឃើញវេជ្ជបណ្ឌិតណាចិត្តល្អជួយមើលថែទាំអ្នកជម្ងឺជារាស្ត្រក្រីក្រឡើយ ។ ពេលនេះយើងត្រូវតែកំទេចខ្ញុំកញ្ជះនេះជាមុន ។ល។ និង ។ល។ មិត្តណាដែលមានអារម្មណ៍ឆ្ងល់យ៉ាងនេះ ក្រោយមកត្រូវបាត់ខ្លួនទាំងអស់ ។ សាលក្រមរបស់អង្គការអនាមិកនិយាយតែមាត់ទទេ គឺពាំពីមាត់មួយទៅមាត់មួយទៀតតែប៉ុណ្ណោះ ។

ច្បាប់របស់អង្គការអនាមិក បង្រៀនមិត្តៗជាតំណាងគ្រប់ៗក្រុម ត្រូវរៀនស្ទាត់ចាំមាត់តែពាក្យមួយឃ្លាៗ គឺដូចជាផ្នែកបង្ខំឲ្យធ្វើការមានមួយឃ្លាគឺ « នរណាហួបអ្នកនោះត្រូវធ្វើការ » ។ ផ្នែកសន្តិសុខមានមួយឃ្លាគឺ « សម្លាប់មនុស្សសុចរិតប្រសើរជាងទុកសត្រូវឲ្យនៅរស់ » ។ ផ្នែកតុលាការមានមួយឃ្លាគឺ « ទុកក៏មិនចំណេញ យកចេញក៏មិនខាត » ។

ឧទាហរណ៍នៅខេត្តបាត់ដំបង អង្គការប្រើឈ្មោះសម្ដេចឳធ្វើជានុយ ធ្វើជាអាវុធ ។ អង្គការអាចប្រមូលនាម៉ឺនខ្មែរ ទាំងស៊ីវិលទាំងទាហាន គ្រប់ជាន់ថ្នាក់ដែល

ស្រឡាញ់សម្តេចឪ ដឹកនាំយកទៅសម្លាប់ចោលបានយ៉ាងងាយ មិនបាច់បង្ខំ មិន មិនបាច់ចង មិនបាច់ដាក់ខ្នោះ គឺប្រើពាក្យតែមួយឃ្លា សុំអញ្ជើញអស់លោកទៅទទួលសម្តេចឪ គឺទៅស្លាប់ ។

អង្គការអនុវត្តគ្រប់មធ្យោបាយគ្រប់វិស័យ ញុាំងឲ្យរាស្ត្រខ្មែរស្លាប់ជាបន្តៗ ។ ឧទាហរណ៍ដូចជាដេញប្រជាពលរដ្ឋខ្មែរក្នុងមួយនគរ ជាច្រើនលាននាក់ ឲ្យថយចាកចេញចោលទីកន្លែងចោលទីលំនៅ ឲ្យថយចេញឆ្ងាយពីផ្លូវជាតិ ពីដងស្ទឹង មានចម្ងាយពីរគីឡូម៉ែត្រយ៉ាងតិច ។ រាស្ត្រខ្មែរត្រូវនាំគ្រួសារដើរដេកពាសវាលពាសព្រៃ ពឹងព្រះធរណីជាគ្រែ ពឹងមេឃជាដំបូល ។ មធ្យោបាយនេះធ្វើឲ្យស្លាប់ដោយមិនបាច់ប្រើអាវុធទេ ។ ប្រជាពលរដ្ឋខ្មែរត្រូវតែស្លាប់ជាបន្តៗ ដូចជាមនុស្សចាស់ជរា ឬអ្នកមានជម្ងឺធ្ងន់ កូនក្មេងតូចៗគ្មានទឹកដោះគោត្រូវស្លាប់ទាំងអស់ ។ល។

អង្គការធ្វើទារុណកម្ម ដាក់ទិសឲ្យធ្វើការទាំងយប់ទាំងថ្ងៃ ហាលក្តៅកណ្តាលភ្លៀង ឲ្យហូបតែទឹកបបរជាមួយអំបិលពីរឬបីគ្រាប់ ឈឺគ្មានថ្នាំទាល់តែសោះ ជាពិសេសរាស្ត្រខ្មែរអ្នកទីក្រុង មិនធ្លាប់រស់នៅស្ថានភាពលំបាកវេទនាយ៉ាងនេះ ក៏បន្តកន្ទុយគ្នាស្លាប់យ៉ាងច្រើនឥតគណនា ។ មានមួយភាគមិនអាចទ្រាំនូវអំពើឃោរឃៅព្រៃផ្សៃយ៉ាងនេះក៏ស្លាប់ខ្លួនទៅ ។

## ការបំបែកប្រជាជនតាមអាយុ ៖

អង្គការបំបែកគ្រួសារចេញពីគ្នា តាមអាយុជាក្រុមៗ ។ កុមារាកុមារីតូចៗអាយុពី៦ឆ្នាំទៅ១៣ឆ្នាំ អង្គការសន្និដ្ឋានទុកជាកូនសិស្ស ។ យុវជន យុវនារី អាយុពី១៤ឆ្នាំដល់៣០ឆ្នាំ នៅលីវ អង្គការប្រមូលបង្កើតជាក្រុមដាច់ខាត ឬហៅថាកងចល័ត ។ ក្រុមនេះមិនឲ្យជួបម៉ែឪឡើយ « ត្រូវធ្វើការទាំងយប់ទាំងថ្ងៃ ហាលក្តៅកណ្តាលភ្លៀង ហូបតែបបរនិងអំបិលមួយចិបៗតែប៉ុណ្ណោះ » ។

ចំណែករាស្ត្រខ្មែរមានគ្រួសាររួចហើយ អាយុពី១៧ឆ្នាំដល់៤០ឆ្នាំ ប្តីប្រពន្ធត្រូវបែកចេញពីគ្នា ទៅបំពេញភារកិច្ចរៀងៗខ្លួននៅសមរភូមិមុខ ។ លើកលែងតែស្ត្រីដែលមានគភ៌ពី៧ខែឡើង និងស្ត្រីមានកូនខ្ចីអាយុក្រោមបួនខែ ទើបបានទៅសំរាកតាមកង ។

អាយុពី៥៦ឆ្នាំឡើង គឺជាកម្លាំងទី៣ ។ ប្រុសៗត្រូវធ្វើរទេះនង្គ័លរនាស់និងត្បាញកញ្ជើ ។ ស្រីៗត្រូវមើលថែទាំកូនក្មេង ។

អង្គការឆ្នៃប្រឌិតបង្កើតសមរភូមិមុខ បង្ខំឲ្យប្រជាជនខ្មែរធ្វើការទាំងយប់ទាំងថ្ងៃ កណ្តាលភ្លៀងមានជាគំរូខ្លះៗដូចតទៅ ៖

– នៅជីក្រែង, មានប្រជាជនចូលរួមធ្វើការចំនួនពីរម៉ឺនប្រាំពាន់នាក់លើកភ្លឺស្រែ ។

- នៅព្រៃឈរខេត្តកំពង់ចាម, មានប្រជាជនចូលរួមធ្វើការចំនួន២៥,០០០នាក់ លើកភ្លឺស្រែ ។

- នៅខេត្តពោធិសាត់, មានប្រជាជនចូលរួមធ្វើការចំនួន២០,០០០នាក់ ត្រូវជីកព្រែកមួយមានចម្ងាយ២០គ.ម. ។

- លើកអាងទឹកមួយនៅភូមិរាមគន់ ស្រុកមោងឫស្សី ខេត្តបាត់ដំបង មានប្រជាជនចូលរួមធ្វើការចំនួន២៥,០០០នាក់ ។

- លើកអាងទឹកមួយនៅខាងលិចភូមិស្វាយជាតិ ខេត្តបាត់ដំបង មានប្រជាជនចូលរួមធ្វើការចំនួន៣០,០០០នាក់ ។

- ធ្វើទំនប់ទឹកនៅស្ទឹង ភូមិកង្កត ខេត្តបាត់ដំបង មានកម្លាំងពិសេសពីកងចល័តបូករួមកម្លាំងទី១ចូលរួមធ្វើការប្រហែល២៥,០០០នាក់ ។

- កាប់ឆ្ការបំផ្លាញព្រៃឈើយកដីធ្វើស្រែ នៅភូមិតាបែន ស្ថិតនៅខាងកើតភូមិកង្កត ។ ប្រមូលកម្លាំងទី១ ទី២ ទី៣ ជាពិសេសស្រីៗមេម៉ាយចំនួន៨៥,០០០នាក់ ។

ស្រីៗមេម៉ាយដែលមានកូនតូចៗអាយុពី៥ឆ្នាំចុះ ត្រូវនាំយកទៅទាំងអស់ ។

អង្គការបញ្ជាឲ្យសង់ខ្ទម មានតែដំបូល សំរាប់ឲ្យកូនក្មេងៗជ្រក ប៉ុន្តែដេកផ្ទាល់ដីទាំងអស់ ។ ចំណែកប្រជាជនទូទៅ ដេកតែក្នុងអគ្រឹងបាវហាលក្ដៅ កណ្ដាលភ្លៀងគ្មានទីជម្រកឡើយ ។ ត្រូវចេញធ្វើការទាំងថ្ងៃទាំងយប់ ។ ពេលយប់បើភ្លៀងធ្លាក់ខ្លាំងចេញពលិកម្មមិនកើត តំណាងរបស់អង្គការវាយជួងបើកអង្គប្រជុំជីវភាពភ្លាម ។ ការពិតគឺហៅមកជេរដៀលត្មះ និយាយច្រំដែលៗថា អ្នកចេះដឹងបញ្ញវ័ន្តខំរៀនសូត្រយកសញ្ញាប័ត្រជាក្រដាស់ ដើម្បីជិះជាន់រាស្ត្រល្ងង់ខ្លៅ ។ ឧទាហរណ៍ដូចជាវិស្វករជាដើម ឃើញច្រត់តែចង្កេះចង្អុលប្រើគេ មិនដែលឃើញវិស្វករណាចេះលាយបាយអរឡើយ ។ល។

តើសញ្ញាប័ត្រជាក្រដាស់នោះមានប្រយោជន៍អ្វីខ្លះ ? គ្មានឃើញនរណាហូបក្រដាស់នោះសោះ ! គ្រប់ៗគ្នាហូបតែបាយ ។ ចំណែកដងប៉ាក្កាដែលសរសេរក៏ហូបមិនកើត ។ ឥឡូវចាប់តាំងពីថ្ងៃនេះទៅ អង្គការបង្កើតដងប៉ាក្កាថ្មីគឺ នង្គ័ល រនាស់ ចប ប៉ែល ។ល។ បើយើងហូបបាយ យើងត្រូវតែដាំស្រូវ ដើម្បីកសាងជាតិឲ្យបានឆាប់លូតលាស់ចំរើនជឿនលឿន ។ យើងត្រូវធ្វើការរួម នេះជាកិច្ចការស្មើភាពគ្នាដ៏ថ្លៃថ្នូរគួរឲ្យគោរព ។ល។

ប៉ុន្តែខ្ញុំតាមដានពិនិត្យ រួចលើកយកមកពិចារណាត្រិះរិះប្រៀបធៀបក៏ឃើញថា កិច្ចការទាំងឡាយដែលអង្គការឆ្នៃប្រឌិតឡើង រួចបង្ខំឲ្យរាស្ត្រខ្មែរធ្វើនោះ គឺបំផ្លាញទាំងអស់ ព្រោះមិនស្គាល់ស្ថានភាពដី គ្មានបច្ចេកទេសអ្វីទាំងអស់ គឺធ្វើប៉ាតណាប៉ាតណី ។ ឧទាហរណ៍ដូចជាលើកភ្លឺស្រែជាដើម តាំងពីដូនតាមកតើគេលើក

ភ្លឺស្រែដើម្បីអ្វី ? ។ ចម្លើយគឺដើម្បីទប់ទឹកវាលស្រែខ្ពស់ៗ កុំឲ្យហូរទៅកាន់ដីវាលស្រែទំនាប ។ ចំណែកអង្គការឆ្វេងប្រឌិតបង្កើតស្រែថ្មី ដែលមានទំហំពី៥០ទៅ១០០ម៉ែត្របួនជ្រុង ដោយលប់ភ្លឺស្រែចាស់ចោល ហើយលើកភ្លឺស្រែថ្មី ។

លុះភ្លៀងធ្លាក់មកខ្លាំង ទឹកក៏ហូរច្រោះទៅកាន់ដីទំនាប បណ្តាលឲ្យលិចសន្ទូងខូចខ្ទេច ។ ចំណែកឯដីខ្ពស់ឯណោះ ក៏ស្ងួតថែសគ្មានទឹកទាល់តែសោះ ។ ម៉្យាងទៀតតាំងពីដូនតាមក កិច្ចការលើកភ្លឺស្រែ គឺគេធ្វើនៅក្នុងរដូវភ្លៀងជោគជាំដីល្បប់នោះទន់ ទើបគេចាប់ផ្តើមលើកភ្លឺស្រែតាមបច្ចេកទេស ដែលគេហៅថាស្ទូងឆ្វេង ។ រួចគេលើកដីល្បប់បន្តគ្នា យកជើងធាប់បង្ហាប់ ទើបបានស្ថិតល្អ ។ល។

ចំណែកអង្គការបែរជាដាក់ទិសបង្ខំរាស្ត្រខ្មែរឲ្យលើកភ្លឺស្រែក្នុងរដូវប្រាំងរីងស្ងួត គឺខែមិនា មេសា ដីរឹងដូចថ្មមិនអាចបង្ហាប់ឲ្យជាប់ស្ថិតឡើយ ។ លុះភ្លៀងធ្លាក់មកយ៉ាងខ្លាំង ភ្លឺស្រែទាំងនោះក៏បាក់ស្រុតក្រហេងក្រហូងមិនអាចទប់ទឹកជាប់ឡើយ ។ ចំណែកអាងទឹកក៏ធ្វើដូចភ្លឺស្រែដែរ ដូច្នេះពេលភ្លៀងធ្លាក់មកខ្លាំង ទំនប់ទឹកនោះក៏បាក់ស្រុត លុះដល់រដូវប្រាំង វាលស្រែរីងស្ងួតអាងទឹកនោះក៏ស្ងួតទៅដែរ ពីព្រោះផ្ទៃទឹករាបស្មើគ្នា ។ល។

ផ្នែកធ្វើទំនប់ទឹកក៏គ្មានបច្ចេកទេសអ្វីទាំងអស់ ឧទាហរណ៍ដូចជាឆ្វេងប្រឌិតបង្កើតទំនប់ទឹកនៅស្ទឹងភូមិកង្កតជាដើម ។ កន្លែងកំពុងធ្វើទំនប់ទឹកនោះជាដីខ្សាច់ទាំងអស់ ។ ក្នុងខែសីហាឆ្នាំ១៩៧៧ រដូវទឹកជោរជន់ឡើងខ្លាំង ទំនប់ទឹកធ្វើខ្វះបច្ចេកទេស មិនត្រូវក្បួនខ្នាត ក៏បណ្តាលឲ្យទឹកហូរហៀរលិចដំណាំនៅក្នុងភូមិកង្កតខ្ទេច ។ លុះខែកញ្ញាឆ្នាំ១៩៧៧ ទឹកជំនន់ខ្លាំងឡើងៗ ក៏ហូរទៅកាន់ទីទំនាប កម្លាំងទឹករុញច្រានហូរយ៉ាងខ្លាំង ក៏ក្លាយទៅជាស្ទឹងមួយយ៉ាងធំក្បែរទំនប់ទឹកនោះ ។ ម៉្យាងទៀតដូចជាប្រមូលស្រីៗមេម៉ាយព្រមទាំងកូនតូចៗទៅកាន់ព្រៃតាបែន រួចបង្ខំឲ្យកាប់ឆ្ការបំផ្លាញព្រៃឈើ និងលប់បឹងយកដីធ្វើស្រែ ។

រឿងនេះក៏មិនទំនងទាល់តែសោះ ពីព្រោះប្រទេសខ្មែរជាពិសេសខេត្តបាត់ដំបងមិនខ្វះវាលស្រែឡើយ ។ ហេតុដូចម្តេចក៏អង្គការបញ្ជាឲ្យលប់បឹងយកដីធ្វើស្រែទៅវិញ ? ផ្ទុយទៅវិញមានកន្លែងខ្លះ អង្គការបែរជាបញ្ជាឲ្យជីកស្រះ ។

ទីកន្លែងដែលអង្គការឆ្វេងប្រឌិតបង្កើតការងារភាគច្រើនជាតំបន់គ្រុនចាញ់យ៉ាងសាហាវ ដូចជាភូមិកង្កតនិងព្រៃតាបែនជាដើម ។ ដូច្នេះប្រជារាស្ត្រខ្មែរត្រូវស្លាប់យ៉ាងច្រើន ពីព្រោះជម្ងឺគ្រុនចាញ់គ្មានថ្នាំទាល់តែសោះ ។ ក្នុងពេលកំពុងធ្វើពលកម្មរួម ដែលមានមនុស្សច្រើនកកកុញយ៉ាងលើសលប់នេះ គេក៏តែងឃើញក្រុមឃាតករអាថ៌កំបាំងចូលមកចាប់ចងរាស្ត្រខ្មែរដ៏ស្លូតត្រង់ជាបន្តបន្ទាប់ នាំយកទៅបាត់ៗយ៉ាងច្រើនមិនដឹងចំនួនឡើយ ។

មានបងប្អូនរួមឈាមយើងខ្លះគ្រាន់តែថ្ងូរក៏ត្រូវបាត់ខ្លួនភ្លាម ។ ជាសរុបសេចក្ដីទៅ កិច្ចការដែលអង្គការបង្កើតឡើងបង្ខំឲ្យរាស្ត្រខ្មែរធ្វើការទាំងយប់ទាំងថ្ងៃជំនាន់នោះ គឺជាការឥតប្រយោជន៍ទាំងអស់ គឺវាកំទេចបំផ្លាញ ធ្វើឲ្យប្រទេសខ្មែរហិនហោចទាំងអស់ ។ គឺវាធ្វើទារុណកម្មរាស្ត្រខ្មែរ រហូតទាល់តែខ្មែរជាម្ចាស់ទឹកដីកម្ពុជាស្លាប់អស់តែប៉ុណ្ណោះ ។ល។

# គុកតាបែន

អង្គការបង្កើតគុកមួយនៅក្នុងព្រៃតាបែន ស្ថិតនៅខាងកើតភូមិកង្កុត ជាព្រៃដាច់ស្រយាល ជាតំបន់គ្រុនចាញ់យ៉ាងសាហាវ ។ គុកនេះសង់នៅលើដំបូកមួយយ៉ាងធំ ខែវស្សាមកដល់ ទឹកលិចជុំវិញដំបូកត្រឹមចង្កេះ ។ អង្គការបញ្ជាឲ្យខ្មែរក្រហមដែលកើតមកពីចោរ ត្រូវតាមដានស្រីៗមេម៉ាយជាច្រើនម៉ឺននាក់ ដែលកំពុងចេញពលកម្មរួមកាប់ឆ្ការព្រៃតាបែន ។ បើដឹងថាស្រីណាជាប្រពន្ធអតីតអ្នករដ្ឋការដែលអង្គការសម្លាប់ប្ដីរួចហើយ ត្រូវចាប់បញ្ជូលទៅក្នុងគុកនោះជាមួយកូនតូចៗអាយុ៥ឆ្នាំចុះ ។

អង្គការបញ្ជាឲ្យធ្វើទារុណកម្មបន្ថែម ញាំងឲ្យស្លាប់និងដាច់ពោះ ញាំងឲ្យស្លាប់នឹងឈឺគ្រុនចាញ់គ្មានថ្នាំព្យាបាលទាល់តែសោះ ញាំងឲ្យស្លាប់នឹងទម្ងន់កិច្ចការ ។ ស្រីៗមេម៉ាយដែលរងគ្រោះជាប់គុកតាបែន មានរូបខ្ញុំម្នាក់ដែរដែលត្រូវជាប់គុកនេះអស់រយៈ៩ខែ ចងចាំជានិច្ចមិនអាចបំភ្លេចបាន នូវទារុណកម្មទាំងឡាយដែលត្រូវទទួល គឺត្រូវធ្វើការទាំងថ្ងៃទាំងយប់ ហាលក្ដៅហាលភ្លៀង ត្រូវកាប់ឆ្ការព្រៃឲ្យស្អាត ។ កិច្ចដែលធ្ងន់ជាងគេនោះ គឺអង្គការបញ្ជាឲ្យកាប់ដើមឈើ រួចហើយត្រូវគាស់គល់ឈើធំៗនោះនៅកណ្ដាលព្រៃរហោស្ថាន ដោយវាយកលេសថាយកដីធ្វើស្រែ ។

លុះវិលត្រឡប់មកកាន់គុកវិញ ទទួលបានតែទឹកបបរមួយកូនចានតូចហុតជាមួយអំបិល២-៣គ្រាប់តែប៉ុណ្ណោះ ។ មានអ្នកស្រីខ្លះមានកូនតូចៗ២ឬបីនាក់កំពុងឈឺយ៉ាងធ្ងន់ ដេកននាលលើរនាបដែលធ្វើអំពីដើមរាំងប៊ិនៗកំភួនជើង ទាំងសំបកគគ្រោតគគ្រើមគ្មានឈូសគ្មានចាំងអ្វីទាំងអស់ ។ គ្មានកន្ទេលក្រាល គ្មានភួយដណ្ដប់ គ្មានមុងការពារ មានតែសង្កើចប៊ិនៗចុងចង្កើះចេញមកខាំទាំងថ្ងៃ ។

កុមារទាំងឡាយនោះឈឺត្រដាបត្រដួសជិតដាច់ខ្យល់ស្លាប់ ។ ជម្ងឺធ្ងន់ៗមិនអាច

ថែទាំឲ្យជាបាន គឺជម្ងឺគ្រុនចាញ់និងរាគមួល ។ ភាគច្រើននៃកុមារទាំងឡាយនោះឈឺរាគមួល ធ្លាក់ឈាមស្រស់ៗ ព្រោះអត់ឃ្លានខ្លាំងពេក មិនអាចអត់ទ្រាំបាន ក៏បបួលគ្នាដើររើសសំបកក្តាមសំបកខ្យងយកមកដុតឲ្យឈ្ងុយ រួចនាំគ្នាហូប ។ មានកុមារខ្លះ ដោយមកពីជម្ងឺរាគខ្លាំងពេកងើបលែងរួច ក៏ត្រូវរុយពងដាក់រួចក្លាយជាដង្កូវ ។ ដង្កូវនោះចូលរុកសាច់ទាំងរស់ ។ ទំរាំនឹងស្លាប់ កុមារទាំងនោះសែនវេទនាគួរឲ្យអាណោចអាធម៌ណាស់ ។ ពេលទំនេរ ពិសេសពេលយប់ យាយទៀងតែងតែជួយថែទាំកុមារទាំងនោះ លុះមិត្តហាចជាមេគុកដឹងក៏បើកអង្គប្រជុំ ។

អ្នកទោសស្រីៗទាំងអស់ប្រកាសតែងតាំងយាយទៀងជាយាយកុមារ ដើម្បីការពារកុមារទាំងនោះ កុំឲ្យលួចហូបស្លកក្តាមសំបកខ្យងទៀតឡើយ ។ ប៉ុន្តែពុទ្ធោអើយ ! យាយទៀងការពារមិនឈ្នះទេ ព្រោះរវល់តែមើលក្រុមខាងណោះ អ្នកនៅឯក្រុមខាងណេះហូប លុះរត់មកមើលក្រុមឯណេះ អ្នកក្រុមឯណោះហូប ។ល។

ថ្ងៃមួយមានអ្នកទោសម្នាក់កំពុងលួចអាំងសាច់គោង៉ៀត ធុំក្លិនឈ្ងុយស្រាប់តែកុមារសំគមៗទាំងនោះរត់មកព័ទ្ធជុំវិញឈរសម្លឹងមើល ហើយលេបទឹកមាត់គ្រប់ៗគ្នា ។ លុះសាច់ឆ្អិនហើយ អ្នកស្រីដែលអាំងសាច់ង៉ៀតនោះក៏ដោះង៉ៀតចេញពីដំបៀត រួចក៏គ្រវាត់ដំបៀតចោល ដើរចាកចេញបាត់ទៅ ។ ឱអនិច្ចាអើយ ! មើលចុះកុមារសំគមៗទាំងនោះ ក៏រើសដំបៀតចែកគ្នាលិទ្ធ ។ លិទ្ធហើយលិទ្ធទៀតបន្តពីម្នាក់ទៅម្នាក់ ខ្ញុំជាអ្នកថែទាំងកុមារទាំងនោះ ឃើញផ្ទាល់នឹងភ្នែក ចងចាំជាប់ជានិច្ចក្នុងខួរក្បាលមិនអាចបំភ្លេចបានឡើយ ។

មានអ្នកខ្លះឈឺជុះមិនហ៊ានជុះទេ គឺរក្សាលាមកគ្រាន់ចិញ្ចឹមក្រពះយកកម្លាំងដើរទៅធ្វើការសិន លុះបានទឹកបបរហុតទើបហ៊ានទៅជុះ ។ មានមនុស្សជរាខ្លះ ពេលជិតដាច់ខ្យល់ស្លាប់ ក៏ស្រែកដំអូញថា ៖ ស្តាយណាស់មិនបានហូបបាយមួយចំអែតមុននឹងស្លាប់ ។ អ្នកទោសទាំងអស់អស់សង្ឃឹមដេកចាំតែពេលស្លាប់ គ្មានអ្វីជាទីពឹងទេ ។ គ្រប់ៗគ្នាលួចបន់ស្រន់តែក្នុងចិត្ត សូមព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះឥន្ទ ព្រះព្រហ្ម និងទេវតាជួយផង !!!

អស្ចារ្យមែន ស្រាប់តែនៅចុងខែសីហាឆ្នាំ១៩៧៧ មានអ្នកទោសម្នាក់ឈ្មោះម៉ាត្រូវខ្មោចចូលសណ្ឋិត ។ យាយទៀងជាអ្នកទទួលថែទាំអ្នកស្រីម៉ា ។ គាត់លួងលោមអ្នកស្រីម៉ាឲ្យហូបទឹកបបរ ។ ខ្មោចកំពុងចូលនេះនិយាយប្រាប់យាយទៀង ថា ៖ ខ្ញុំមិនអាចហូបបបរបានទេ ព្រោះមិត្តកោតបានវះពោះខ្ញុំយកក្រពះនិងពោះវៀនទៅហូបអស់ទៅហើយ ។ តែខ្ញុំអាចជក់បារីបាន ខ្ញុំសុំបារីមួយដើម ។ ខ្មោច

នោះប្រាប់យាយទៀងទៀតថា ៖ ខ្ញុំជាប្តីអ្នកស្រីម៉ា ខ្ញុំមកប្រាប់អ្នកទោសទាំងអស់ « ចូរកុំព្រួយ ខែក្រោយនេះបានរួចខ្លួនហើយ » ព្រោះជិតដល់វេនគេសម្លាប់វាវិញហើយ ។

ចំនួនពីរថ្ងៃ ខ្មោចនេះចេញបាត់ទៅ ។ អ្នកស្រីម៉ាដឹងស្មារតីឡើងវិញ ។ ក្រោយមកអ្នកស្រីម៉ាលួចប្រាប់យាយទៀងថា ៖ នៅចុងខែធ្នូឆ្នាំ១៩៧៦ ប្រហែលម៉ោង ១០យប់ មិត្តកោតមកស្រែកហៅប្តីរបស់ខ្ញុំឲ្យចេញពីខ្ទមទៅជួបវា ។ វាវាយគាត់សម្លាប់ចោលភ្លាម វាវះពោះ រួចយកបេះដូង សួត ថ្លើម ក្រពះ ពោះវៀនអស់រលីង រួចវាជីករណ្តៅកប់ក្បែរខ្ទមនោះទៅ ។ កន្លងផុតតែដប់ថ្ងៃ មិត្តកោតចាប់ខ្ញុំចងនាំយកមកដាក់គុកនេះ ។

អង្គការប្រើគ្រប់មធ្យោបាយរកមុខរាស្ត្រខ្មែរអ្នកចេះដឹង រកមុខរាស្ត្រខ្មែរមានសតិសម្បជញ្ញៈស្នេហាជាតិដើម្បីសម្លាប់ចោល ។

ក្នុងខែមិថុនាឆ្នាំ១៩៧៥ អង្គការចាប់ផ្តើមបង្កើតក្រុមដាច់ខាតរួចភរកុហកថា ៖ នឹងបង្ហាត់បង្រៀនឲ្យបានក្លាយជាយោធាដ៏ចំណាន ដើម្បីការពារប្រទេស ។ រំពេជនោះមានយុវជនក្មេងៗ ភាគច្រើនគឺសិស្សវិទ្យាល័យ នាំគ្នាស្ម័គ្រចិត្តចូលបំរើយ៉ាងស្មោះត្រង់ មានចំនួន៥ពាន់នាក់ ។

ពីព្រោះយុវជនទាំងអស់នេះលបលួចស្រឡាញ់បក្សខ្មែរក្រហមរបស់លោកខៀវ-សំផនជាយូរហើយ ។ ពេលនេះយល់ច្រឡំស្មានតែជ័យជំនះនេះ ជាជ័យជំនះរបស់លោកខៀវ-សំផនទាំងស្រុង ។ល។

ពេលនោះអង្គការញញឹមបីទមាត់មិនជិត ក៏ចាប់តាំងមូលដ្ឋានមួយធំស្ថិតនៅខាងត្បូងជាប់ជើងភ្នំធិបតី រៀបចំកន្លែងយ៉ាងស្អាត ឧបត្ថម្ភអាហារដ៏បរិបូណ៌ ។ លុះដល់ខែកុម្ភៈឆ្នាំ១៩៧៦ រាល់ៗល្ងាចអង្គការចាត់តំណាងសម្ងាត់ចូលទៅសំរាំងជ្រើសរើសពី១៥ទៅ២០ឬ៣០នាក់ នាំយកចេញពីមូលដ្ឋាននោះដោយភរថា យកទៅរៀនសូត្រ ។

ក្នុងខែតុលាឆ្នាំ១៩៧៦ មានយុវជនម្នាក់ដែលអង្គការនាំយកទៅជាចុងក្រោយមានវាសនាគេចរួច ក៏បានវិលមកជួបមិត្តភក្តិ ហើយលួចខ្សឹបថា មិត្តយើងជាច្រើនពាន់នាក់ដែលអង្គការនាំយកទៅនោះ ត្រូវអង្គការសម្លាប់ចោលអស់ទៅហើយ ។ ពេលនោះយុវជនចំនួន៣០០នាក់ ដែលមិនទាន់ដល់វេនស្លាប់ ក៏លបលួចខ្សឹបខ្សៀវ បបួលគ្នាបំបែកហ្វូងផ្សេងព្រៃងរត់គេចទៅកាន់ភូមិឆ្ងាយៗ រួចប្រែឈ្មោះផ្សេងៗរៀងៗខ្លួន ។

ក្នុងខែមិថុនាឆ្នាំ១៩៧៥ មានទាហានកងពិសេសក្មេងៗ២០០នាក់ និងក្រុមរៀនបើកយន្តហោះ៨៨នាក់ ដែលរដ្ឋាភិបាលសាធារណរដ្ឋខ្មែរបញ្ជូនទៅធ្វើកម្មសិក្សា

នៅប្រទេសហ្វីលីពីន ក៏យល់ច្រឡំដូចយុវជនក្រុមដាច់ខាតដែរ ។ ស្រាប់តែស្ម័គ្រចិត្តវិលត្រឡប់ចូលកាន់មាតុភូមិ ដើម្បីបំរើលោកខៀវ-សំផននិងសម្តេចឪ ។ ពេលនោះមានក្បួនកាម៉្យុងជាច្រើនគ្រឿងរៀបក្បួនចាំជាស្រេចនៅទីប្រជុំជនស្រុកអូរជ្រៅ ។ លុះមកជួបជុំតំរៀបជួរឡើងឡានជាស្រេចបាច់ ក្បួនឡានក៏បើកបរចូលទៅកាន់ប្រទេសខ្មែរ ។

ក្បួនឡាននេះមកឈប់ចតនៅខាងត្បូងភូមិនិមិត្ត ។ តំណាងរបស់អង្គការបញ្ជាបង្ខំយុវជនទាំង២៨៨នាក់ចុះពីឡាន បញ្ជាឲ្យដោះខោអាវ រួចក៏បាញ់សម្លាប់ចោលនៅទីនោះព្រមទាំងនិយាយថា ៖ មនុស្សចុងនេះកុំទុកនាំធ្ងន់ផែនដីទេ ! ។

ចុងឆ្នាំ១៩៧៥ មាននិស្សិតខ្លះ មានបញ្ញវ័ន្តខ្មែរមកធ្វើកម្មសិក្សានៅប្រទេសបារាំង មានជាច្រើនរយនាក់ មានបញ្ញវ័ន្តខ្លះត្រូវជាប់ចោទថាជាខ្មែរក្រហមមិនហ៊ានវិលត្រឡប់ទៅកាន់ស្រុកខ្មែរជាយូរឆ្នាំមកហើយ ។ មាននិស្សិតខ្លះចប់កម្មសិក្សាត្រូវតែនិវត្តចូលទៅកាន់មាតុភូមិវិញ ។ ពេលនោះគ្រប់ៗរូបយល់ច្រឡំស្មានតែជ័យជំនះដ៏មហាអស្ចារ្យនេះ បានមកដោយសារស្នាព្រះហស្តដ៏ឆ្នើមរបស់សម្តេចឪ ដែលមានលោកខៀវ-សំផនជាមេខ្មែរក្រហមគាំទ្រប្រសើរណាស់ៗ ។ ដូច្នេះគ្រប់ៗរូបមានសេចក្តីសង្ឃឹមយ៉ាងមាំថា ប្រទេសខ្មែរបានសន្តិភាពឡើងវិញហើយ ពីព្រោះសម្តេចសីហនុជាស្តេចនិងខ្មែរក្រហមត្រូវគ្នាយ៉ាងនេះ ?!

និស្សិតនិងបញ្ញវ័ន្តទាំងឡាយនោះ ចេញដំណើរពីប្រទេសបារាំងបីលើក តាមយន្តហោះចូលមកកាន់ទីក្រុងប៉េកាំង រួចបន្តដំណើរចូលមកប្រទេសកម្ពុជា ។ មានវេជ្ជបណ្ឌិតម្នាក់នៅរស់ សព្វថ្ងៃសំណាក់នៅស្រុកឌីហ្សុងនៃប្រទេសបារាំង លោកធ្វើអត្ថាធិប្បាយថា ៖ លោកនិវត្តចូលកាន់ប្រទេសខ្មែរជាលើកទី៣ ។ ពេលចុះពីយន្តហោះភ្លាម ខ្មែរក្រហមក្មេងៗបញ្ជូនទៅធ្វើការទាំងបង្ខំ ទាំងយប់ទាំងថ្ងៃភ្លាម គឺលើកទំនប់ លើកភ្លឺស្រែ ។ល។ មានស្រីម្នាក់នាមត្រកូល «ទឹម» ជាវេជ្ជបណ្ឌិតសព្វថ្ងៃភៀសខ្លួនទៅកាន់សហរដ្ឋអាមេរិក ។ នៅថ្ងៃទី២/១០/១៩៨១ នាងបានថ្លែងប្រាប់យាយទៀងនៅក្នុងជំរំស្នួលភ្លូនៃប្រទេសថៃថា ៖ ខ្លួននាងនិងប្តីបានធ្វើកម្មសិក្សាផ្នែកវេជ្ជសាស្ត្រនៅប្រទេសបារាំង ។ ...ចុងឆ្នាំ១៩៧៥ ស្ម័គ្រចិត្តនិវត្តចូលកាន់ប្រទេសខ្មែរវិញតាមយន្តហោះលើកទី២ ។ ចុះពីយន្តហោះភ្លាម នាងខ្ញុំស្លុតចិត្តស្ទឹងសន្ធប់ ពីព្រោះឃើញអាកាសយានស្ងាត់ច្រៀប គ្មានឃើញម៉ែឪមកចាំទទួល នាងខ្ញុំស្រែកយំដូចកូនក្មេង ។ ពេលនោះខ្មែរក្រហមចូលមកដកហូតយកឥវ៉ាន់អស់រលីង រួចគេបំបែកប្តីរបស់នាងខ្ញុំនាំយកទៅបាត់រហូត ។ នាងមានកូនស្រីម្នាក់អាយុ១៣ខែ ចំណែកម៉ែឪបងប្អូនគ្មានទទួលដំណឹងអ្វីទាល់តែសោះ ។ គួរឲ្យស្តាយណាស់ បញ្ញវ័ន្តនិងនិស្សិតខ្មែរដ៏ស្លូតត្រង់ជាច្រើនរយនាក់នោះ មុខជាអង្គការស-

ម្លាប់ចោលសឹងតែទាំងអស់ ។ អង្គការដឹងថាវាស្រ្តខ្មែរអ្នកចេះដឹង គឺអ្នកទីក្រុងភ្នំពេញ ដូច្នេះអង្គការប្រើគ្រប់មធ្យោបាយ ញ៉ាំងឲ្យស្លាប់បន្តៗ ដោយមិនចាំបាច់ប្រើអាវុធទេ ។ មើលចុះ ! ក្នុងខែកញ្ញាឆ្នាំ១៩៧៥ អង្គការប្រកាសថា ៖ ប្រជាជនខ្មែរអ្នកទីក្រុងភ្នំពេញ ដែលភៀសខ្លួនទៅនៅខេត្តតាកែវ ខេត្តកំពង់ស្ពឺ ត្រូវនាំគ្រួសារទៅជួបជុំគ្នានៅព្រៃនរ ដើម្បីវិលត្រឡប់ទៅកាន់រដ្ឋធានីភ្នំពេញវិញ ព្រមទាំងប្រាប់ថា ៖ មិនបាច់យកអ្វីៗតាមខ្លួនទេ ព្រោះអង្គការបានរៀបចំផ្ទះឲ្យមានភាពដូចៗគ្នារួចជាស្រេចហើយ ។

វាស្រ្តខ្មែរដែលបានមកដល់ព្រៃនរជាលើកទី១ មានចំនួន៩ពាន់នាក់ បាតដៃទទេទាំងអស់ ដោយត្រេកអរជាយ៉ាងខ្លាំង ព្រោះបានវិលត្រឡប់ចូលរដ្ឋធានីភ្នំពេញវិញ ។ ប្រសើរណាស់មិនបាច់យកអ្វីក៏បានដែរ ។

គ្រប់ៗគ្នាក៏នាំគ្រួសារតំរៀបជួរឡើងឡានកាម៉្មុង ដែលរៀបជាក្បួន មានចំនួន៩០គ្រឿងរង់ចាំជាស្រេចនៅទីនោះ ។ ក្នុងឡាននិមួយៗមានមនុស្សជិត១០០នាក់ ។ នរណាមានយកឥវ៉ាន់បន្តិចបន្តួចតាមខ្លួន ត្រូវខ្មែរក្រហមដកហូតទាំងអស់ វាទុកឲ្យតែឆ្នាំងមួយ និងអង្ករមួយគីឡូម្នាក់តែប៉ុណ្ណោះ ។ ឡានរោទិ៍ម៉ាស៊ីនរៀបចេ-ញដំណើរ ស្រាប់តែឃើញប្រជាជនទើបមកដល់លើកទី២ជាងមួយម៉ឺននាក់ទៀត។ ប៉ុន្តែក្បួនឡាននេះ ត្រូវបរចាកចេញពីព្រៃនរទៅ ។ ឡានទាំងនោះរលាក់បណ្តាលឲ្យទង្គិចក្បាលគ្នាដូចសត្វជ្រូកក្នុងទ្រុង...។

ក្បួនឡានបរតាមផ្លូវជាតិលេខ២ រួចបត់បន្តដំណើរតាមផ្លូវជាតិលេខ៣ ចូលកាន់រដ្ឋធានីភ្នំពេញ ។ អ្នកខ្លះមានទឹកមុខញញឹមសង្ឃឹមថា បន្តិចទៀតដល់ផ្ទះរបស់ខ្លួនហើយ ។ មានអ្នកខ្លះមុខជូរ ព្រោះសង្កេតឃើញអាកប្បកិរិយាខ្មែរក្រហមដែលគ្មានសីលធម៌ដឹបន្តិបន្តួចសោះ ។

លុះក្បួនឡានមកដល់ទីក្រុងភ្នំពេញ ស្រាប់តែបរទៅចូលទួលគក រហូតទៅកាន់ផ្លូវជាតិលេខ៥ ។ ពេលនោះប្រជាជនញ័រតក់ស្លុតសឹងដាច់ដង្ហើមស្លាប់ ។ យប់ងងឹតក៏មកដល់ កុមារតូចៗឃ្លានបាយយំពេញឡាន ។ ម៉ោងប្រហែល៨យប់ ក្បួនឡាននោះចូលមកចតឈប់នៅលង្វែក ដើម្បីឲ្យប្រជាជនដណ្តាំបាយ ។

ញ៉ាំបាយមិនទាន់រួចស្រួលបួលផង ខ្មែរក្រហមបញ្ជាឲ្យឡើងឡានបន្តដំណើរទៅមុខទៀត ។ ម៉ោងប្រហែល២ភ្លឺ ក្បួនឡានចូលចតឈប់នៅមុខស្ថានិយរថភ្លើងខេត្តពោធិសាត់ ។ តំណាងអង្គការប្រកាសតាមឧគ្ឃោសនសព្ទដេញប្រជាជនឲ្យចុះពីឡាន រួចត្រូវនាំគ្រួសារទៅដេកតាមបណ្តោយផ្លូវរថភ្លើង ដែលមានប្រជាជនច្រើនម៉ឺននាក់កៀរមកពីគ្រប់ទិសទីដេកពាសពេញនៅទីនោះដែរ ។

ព្រលឹមស្អែកថ្ងៃមិនទាន់រះផង តំណាងអង្គការដើរឆែកឆេរដកហូតយកទ្រព្យ

សម្បត្តិរបស់ប្រជាជនមួយលើកទៀត ស្រាប់តែឃើញរថភ្លើងជាច្រើនខ្សែ បន្តជាច្រើនសិបទូរមកដល់ល្មម ។ តំណាងអង្គការដើរដេញប្រជាជនឲ្យឡើងរថភ្លើងដូចហ្វូងគោ ។ មួយទូរៗមានមនុស្សជាង១០០នាក់ជិះជាន់លើគ្នា ។ ម៉ោងប្រហែល៥រសៀលថ្ងៃដដែល រថភ្លើងឈប់នៅស្ថានិយស្រុកស៊ីសូផុន ។ មានតំណាងអង្គការឈររង់ចាំនៅទីនោះជាស្រេច ។ វាក៏ប្រកាសតាមឧគ្ឃោសនស័ព្ទបញ្ជាឲ្យប្រជាជនចុះពីរថភ្លើង រួចវាប្រកាសរកអ្នកបច្ចេកទេស វេជ្ជបណ្ឌិត សាស្ត្រាចារ្យ គ្រូបង្រៀន និងនិស្សិត ។ ពេលនោះគ្មាននរណាហ៊ានចេញមុខទេ ។ តំណាងអង្គការក៏ដើរមើលមុខ។ វាសំរាំងជ្រើសរើសបានចំនួន៣៩៧នាក់ រួចភរផ្អែមត្រជាក់ថា ៖ អង្គការឈប់សម្លាប់ហើយ កុំខ្លាចអី ។ វាក៏បញ្ជាឲ្យប្រជាជនដែលមានអាយុចាស់ៗឡើងជិះរ៉ឺម៉កត្រាក់ទ័រ ។ ក្មេងៗខ្លះដើរ ខ្លះជិះរទេះគោ ដើម្បីបន្តដំណើរទៅកាន់ភ្នំស្រុក

ចំណែកប្រជាជនទាំង៣៩៧នាក់នោះ ត្រូវពួកវាបញ្ជូនទៅកាន់ស្រុកព្រះនេត្រព្រះ ។ ទទួលបញ្ជាពីអង្គការបីថ្ងៃ បន្ទាប់បញ្ជូនមកភូមិជប់ រួចបើកសិទ្ធិឲ្យឡើងថ្លែងការណ៍ដោយសេរី ។

មានអ្នកខ្លះនិយាយទិតៀនរឿងអង្គការបិទសាលារៀន និងជម្លៀសប្រជាជនមិនទំនង ។ ពេលនោះតំណាងអង្គការគ្មានតបតមួយម៉ាត់ទេ ។ លុះព្រលឹមស្អែកឡើង ថ្ងៃមិនទាន់រះផង ស្រាប់តែឃើញប្រជាជនដែលហ៊ានរិះគន់ដល់អង្គការចំនួន៣៥នាក់ ត្រូវជាប់ចំណងដៃនៅក្រោយខ្នង ( ជាប់ចំណងស្លាបសេក ) រួចត្រូវគេបណ្តើរចេញទៅបាត់ ។

ព្រលឹមថ្ងៃទី៦មករា១៩៧៦ តំណាងអង្គការហៅឈ្មោះចំនួន២០០នាក់ បញ្ជាឲ្យឡើងឡានដឹកចេញទៅបាត់ ។ ថ្ងៃបន្ទាប់មក ហៅឈ្មោះឡើងឡានដឹកចេញទៅមួយលើកទៀត ។ ឥឡូវនៅសល់៤៥នាក់ អង្គការបញ្ជាឲ្យធ្វើជីវប្រវត្តិ រួចដឹកនាំយកទៅដាក់គុកនៅបាត់ដំបង ។ ឃុំក្នុងគុកនេះអស់រយៈពេល២ខែ រួចហើយតំណាងអង្គការដឹកនាំចេញជាបន្តបន្ទាប់លុះត្រានៅសល់តែ១៥នាក់ ។ វាបញ្ជាឲ្យធ្វើជីវប្រវត្តិមួយលើកទៀត រួចដឹកយកទៅឃុំទុកនៅវត្តពោធិវាល ។ ថ្ងៃក្រោយមកតំណាងអង្គការមកឈរមើល បញ្ជាឲ្យធ្វើជីវប្រវត្តិជាលើកចុងក្រោយបង្អស់ ។

ថ្ងៃទី៦មេសា១៩៧៦ វាមកចង៨នាក់ ដឹកដូចគោ បណ្តើរបាត់ទៅទៀត ។ ពេលនោះនៅសល់៧នាក់ ស្រាប់តែវាឲ្យសំលៀកបំពាក់ខ្មៅមួយបន្លាស់ម្នាក់ រួចបញ្ជូនទៅឃុំគោកឃ្មុំ ឲ្យជួយធ្វើស្រែរួម ។ យុវជន សារួន ថ្លែងថា ៖ ទាំង៧នាក់នោះគ្មាននរណាម្នាក់ចេះអក្សរទេ ។ ពេលអង្គការបញ្ជាឲ្យធ្វើជីវប្រវត្តិម្តងៗ ភ័យសឹងបាត់ស្មារតី សុំអង្វរករពឹងឲ្យគេជួយសរសេរ ។

ចំណែកប្រជាជនជាង១ម៉ឺននាក់ដែលជិះត្រាក់ទ័រ ជិះរទេះគោ និងដើរថ្មើរជើង

នោះ ទៅដល់មាត់ព្រៃនៃឃុំពង្រ ប្រហែលជាម៉ោង៦ល្ងាចទៅហើយ ។ គ្រោះអាក្រក់មកដល់ គឺភ្លៀងធ្លាក់ដូចគេចាក់ទឹកពីលើមេឃ ។ គ្រប់ៗរូបរងារញាក់ដូចគ្រុនចាញ់ វេទនាសឹងរកពាក្យខ្មែរសរសេរគ្មាន ។ ក្នុងរយៈពេលធ្វើដំណើរ និងត្រូវនៅកណ្ដាលភ្លៀង ព្រមទាំងអត់បាយយ៉ាងនេះ មានស្លាប់ប្រហែល១២ភាគរយ ។ យប់នោះប្រជាជនត្រូវអង្គុយទល់ភ្លឺព្រោះដីសើមមិនអាចទទួលទានដំណេកកើត។

បីថ្ងៃបន្ទាប់មក មានមនុស្សដែលគេដឹកមកតាមរថភ្លើងជាលើកទី២ មានស្លាប់យ៉ាងច្រើនរាប់មិនអស់ ។ គេបានដឹងចំនួនប្រជាជនខ្មែរ ដែលអស់សង្ឃឹមក៏លូនចូលដេកក្រោមរថភ្លើង រថភ្លើងក៏កិនស្លាប់ចំនួន២៥៧នាក់ ។

នៅថ្ងៃទី២០មករា១៩៧៦ លោកគីម-ងួនត្រាច អតិតទេសាភិបាលអនាគារជាតិកម្ពុជា បានថ្លែងប្រាប់មិត្តភក្តិនិងក្មួយៗថា ៖

នៅខែកញ្ញាឆ្នាំ១៩៧៥ប្រជាជនខ្មែរអ្នកទីក្រុងភ្នំពេញចំនួន១ម៉ឺន៥ពាន់នាក់ ដែលភៀសខ្លួនទៅខេត្តកំពង់ស្ពឺនិងខេត្តតាកែវ ស្រាប់តែទទួលបញ្ជាពីអង្គការឲ្យប្រមូលគ្រួសារវិលត្រឡប់ទៅកាន់រដ្ឋធានីភ្នំពេញវិញ ។ មិត្តៗមិនបាច់យកឥវ៉ាន់តាមខ្លួនទេ ពីព្រោះអង្គការបានរៀបចំផ្ទះឲ្យនៅដូចៗគ្នារួចហើយ ។ ដូច្នេះគ្រប់ៗគ្នាត្រេកអរស្ទើរឆ្កួត ។ ណ្ហើយចុះ ! មិនបាច់យកឥវ៉ាន់តាមខ្លួនក៏បានដែរ ពីព្រោះផ្លូវដើរសែនឆ្ងាយពិបាករែក ពិបាកពុន បានអង្គការអនុគ្រោះឲ្យវិលត្រឡប់ចូលកាន់រដ្ឋធានីភ្នំពេញវិញប្រសើរហើយ ។ តំណាងអង្គការចេញបញ្ជាឲ្យប្រជាជនត្រូវចេញដំណើរទាំងយប់ម៉ោងប្រហែល១០ ស្អែកព្រលឹមឡើងត្រូវជួបជុំគ្នានៅព្រៃនរ ។ ប្រជាជនទាំងចាស់ទាំងក្មេងចំនួន១ម៉ឺន៥ពាន់នាក់ចេញដំណើរទាំងយប់វេទនាគ្មានពាក្យសរសេរទេ ព្រោះប្រទេសខ្មែរនាខែកញ្ញាជារដូវភ្លៀងរលឹមស្រិចៗទាំងយប់ទាំងថ្ងៃ ។ ព្រលឹមស្អែកម៉ោងប្រហែល៩ក៏បានជួបជុំគ្នានៅព្រៃនរ ។ ប៉ុន្តែពុទ្ធោអើយ ! ឃើញឡានកាម្មុងជាង៤០គ្រឿង មានមនុស្សជិះពេញៗសឹងជាន់លើគ្នាជាស្រេចទៅហើយ ។ ឡានក៏រេទីម៉ាស៊ីនបើកបរចាកចេញពីទីនោះទៅ ។

ពេលនោះតំណាងអង្គការក្មេងៗអាយុសឹងមិនទាន់១៥ឆ្នាំ ឆ្វេចឆ្វាចនិយាយចចេកចចាចមួយសន្ទុះ ស្រាប់តែស្រែកតាមមេក្រូបញ្ជាថា ៖ ចូរមិត្តៗវិលត្រឡប់ទៅកាន់កងវិញចុះ ពីព្រោះអង្គការខ្វះឡាន ។ ដូច្នេះប្រជាជនចំនួន១ម៉ឺន៥ពាន់នាក់នោះត្រូវតែត្រឡប់វិលទៅកាន់កងរៀងៗខ្លួនវិញ ។ យប់ជ្រៅទើបទៅដល់កូនខ្ទម។

ពេលនោះគ្រប់ៗគ្រួសារស្លុតចិត្តស្ទើរបាត់ស្មារតី ព្រោះកូនខ្ទមទាំងនោះសល់តែដំបូល អ្វីៗបាក់បែកអស់រលីង ។ សូម្បីតែស្លឹកគ្រៃ ជី ម្ទេសក៏ត្រូវគេបំផ្លាញ ដោយបេះបោចឬដកខ្ទេចខ្ទីអស់ ។

គ្រប់ៗរូបអង្គុយត្របោមក្បាលជង្គង់យំគោក ។ តើបានអ្វីបរិភោគ បើអត់បាយ

មួយថ្ងៃទៅហើយ ? ។

បីបួនថ្ងៃបន្ទាប់មក កូនក្មេងនិងមនុស្សចាស់ជរាក៏ស្លាប់បន្តកន្ទុយគ្នា ។ និទានដល់ត្រឹមហ្នឹង លោកគីម-ងួនត្រាចធ្វើមុខស្លូតព្រមទាំងបញ្ជាក់ថា កូនស្រីរបស់លោកពីរនាក់តូចៗក៏ស្លាប់នៅពេលនោះដែរ ។

ចុងខែតុលាឆ្នាំ១៩៧៥ អង្គការចេញបញ្ជាម្តងទៀត បង្ខំឲ្យប្រជាជនទាំងអស់នោះត្រូវនាំគ្រួសារជួបជុំគ្នានៅព្រៃនរ ជាលើកទី២ ។ លុះទៅដល់ព្រៃនរហើយ គ្រប់ៗគ្នាត្រេកអរជាក្រៃលែង ព្រោះឃើញឡានធំៗគ្រប់ធុនជាច្រើនរយគ្រឿង ។ ឃើញឡានកាម៉្យុងរបស់ចិនពណ៌បៃតងចំនួនជាង១០០គ្រឿង រៀបជាក្បួនរង់ចាំនៅទីនោះជាស្រេច ។

ពេលនោះមានប្រជាជនដែលគេប្រមូលមកពីគ្រប់ទិសទី មានប្រមាណ១ម៉ឺន៧ពាន់នាក់ តំរៀបជាជួរឡើងឡានទាំងទឹកមុខញញឹម ដោយសង្ឃឹមរៀងៗខ្លួនថាល្ងាចនេះបានចូលទៅផ្ទះវិញហើយ ។

ក្បួនឡានក៏បរតាមផ្លូវជាតិលេខ២ រួចតាមផ្លូវជាតិលេខ៣ ចូលកាន់រដ្ឋធានីភ្នំ-ពេញ...។ ប៉ុន្តែពុទ្ធោអើយ ! ក្បួនឡាននេះបែរជាបរវាងទីក្រុង ហើយសំដៅទៅសង្កាត់ទួលគក រួចហើយបរតាមផ្លូវជាតិលេខ៥ទៅវិញ ។ យប់មកដល់ល្វេម ប្រជាជនទាំងអស់ជ្រួលច្របល់ក្នុងចិត្តសឹងដាច់ដង្ហើមស្លាប់ ។ កុមារតូចៗយំពេញឡានដោយសារស្រេកឃ្លាន...។

ក្បួនឡានបន្តដំណើរទៅដល់ស្ថានីយរថភ្លើងខេត្តកំពង់ឆ្នាំងនៅពេលពាក់ក-ណ្តាលអាធ្រាត ។ តំណាងរបស់អង្គការដែលរង់ចាំនៅទីនោះ ក៏ស្រែកបញ្ជាតាមឧគ្ឃោសនសព្ទ ដេញប្រជាជនឲ្យចុះពីឡាន ព្រមទាំងបញ្ជាក់ថា មិត្តៗដែលនៅលីវដែលមានអាយុពី១៣ទៅ២៥ឆ្នាំ ត្រូវចេញមកឈរតាមបណ្តោយផ្លូវរថភ្លើងខាងឆ្វេងដៃ ក្រៅពីនេះត្រូវនៅខាងស្តាំដៃ ។ ដូច្នេះប្រជាជនទាំង១ម៉ឺន៧ពាន់នាក់ ត្រូវចែកជាពីរក្រុម ។ រួចវាបញ្ជាឲ្យនាំគ្នាទៅដេកនៅតាមបណ្តោយផ្លូវដែក ព្រោះនៅរដូវភ្លៀងយ៉ាងនេះ គឺមានតែផ្លូវដែកទេដែលមិនលិចទឹក ។

សូមលោកអ្នកអានមេត្តាជួយគិតមើលថា តើទំហំនៃទុក្ខវេទនារបស់ប្រជាជនខ្មែរនៅពេលនោះមានដល់កំរិតណា ? នាំគ្នាដេកផ្ទាល់ដី លើថ្ម យកថ្មល់ដែកជាខ្នើយ យកកំរាលថ្មរទេះភ្លើងជាកន្ទេល ។ នៅជាប់នឹងខ្លួនមានតែខោអាវកណ្តាចមួយបន្លាស់ ព្រោះអង្គការហូតយកឥវ៉ាន់ចេញពីខ្លួនមុនពេលឡើងឡានអស់ទៅហើយ ។

ស្អែកឡើង ម៉ោង៦ព្រលឹម តំណាងអង្គការចែកអង្ករឲ្យមួយកំប៉ុងម្នាក់ ។ កំពុងតែជ្រួលច្របល់រកមធ្យោបាយនឹងដណ្តាំបាយបបរ ស្រាប់តែរថភ្លើងជាច្រើន

ខ្មែរបរមកឈប់សំចតជាច្រើនសិបទូរ ។ តំណាងអង្គការដេញប្រជាជនដែលមានគ្រួសាររួចហើយ ឲ្យឡើងទូររទេះភ្លើងដូចហ្វូងគោ ។ ចំណែកឯអ្នកដែលនៅលីវត្រូវរង់ចាំជើងក្រោយ ។ ម៉ោងមួយរសៀល ក្បួនរថភ្លើងមកឈប់សំចតនៅស្ថានិយភ្នំធិបតី ។ តំណាងអង្គការដែលរង់ចាំនៅទីនោះស្រាប់តែស្រែកប្រកាសតាមឧគ្ឃោសនស័ព្ទ ដេញប្រជាជនជាង១ម៉ឺននាក់ ឲ្យចុះពីរថភ្លើង ។ វាបញ្ជាក់ថា រថភ្លើងបន្ទាន់នឹងវិលត្រឡប់ទៅដឹកពួកនៅលីវៗទៀត ។ តែរថភ្លើងបើកបរទៅរហូត ឥតត្រឡប់ ។ ដូច្នេះម៉ែឪត្រូវព្រាត់ប្រាស់កូនកម្លោះក្រមុំ... បងត្រូវព្រាត់ប្អូន ក្មួយព្រាត់មីងមា ព្រាត់គ្នារហូត ! ។

ប្រជាជនទាំង១ម៉ឺននាក់នោះ ត្រូវតំណាងអង្គការបញ្ជូនឲ្យទៅនៅបណ្ដោះអាសន្ននៅភូមិស្រែអូរ ភូមិចៃហួយសិន រង់ចាំដល់បំណាច់ខែកុម្ភៈទើបអង្គការបញ្ជូនទៅឲ្យស្លាប់នៅភូមិក្បាលសាយ ។

ភូមិក្បាលសាយស្ថិតនៅដាច់ស្រយាលពីទីប្រជុំជន នៅរដូវវស្សាទឹកលិច នៅរដូវប្រាំងដីគោកប្រេះបែកក្រហែង ដាំដំណាំអ្វីក៏មិនកើត រកអ្វីៗមកទទួលទានជំនួសបាយមិនបានឡើយ ក្រៅពីដើមស្លែងដែលមានជាតិពុលយ៉ាងសាហាវ ។ ដូច្នេះប្រជាជនដែលគេជន្លៀសមកពីខេត្តតាកែវ កំពង់ស្ពឺ ចំនួនជាង១ម៉ឺននាក់ បូករួមទាំងអ្នកមកខេត្តនានាទាំងអស់ជាង៣ម៉ឺននាក់ ត្រូវរងគ្រោះដោយការដាច់ពោះស្លាប់ និងជាពិសេសដោយជម្ងឺអាសន្នរោគ ដែលគ្មានថ្នាំសង្កូវអ្វីមកព្យាបាល ។

លោកគីម-ងួនត្រាចរ៉ាយរ៉ាប់បញ្ជាក់ថា ៖ គ្រួសាររបស់លោកត្រូវអង្គការបញ្ជូនទៅនៅភូមិចៃហួយជាបណ្ដោះអាសន្នសិន ។ ក្រោយលោកទទួលពត៌មានថាបន្ទាប់មកទៀតអង្គការនឹងបញ្ជូនបន្តទៅកាន់ភូមិក្បាលសាយ ។ លោកយល់ឃើញថា ឱ ! អង្គការបញ្ជូនឲ្យទៅស្លាប់ហើយទេតើ ! ទើបលោកផ្សងព្រេងនាំគ្រួសាររត់គេចតាមសំណាក់នៅកងលេខ៤ ភូមិព្រៃស្វាយខាងកើត ក្នុងសហករណ៍លក់ជ្រៀវ តំបន់ទី១ ។

លោកគីម-ងួនត្រាចមកដល់កងព្រៃស្វាយ លោកបានជួបអតិតអ្នករដ្ឋការមួយចំនួន ដែលមិនទាន់ដល់វេនគេសម្លាប់នៅឡើយ ហើយដែលលោកធ្លាប់ស្គាល់យ៉ាងជិតដិត ។ ដោយសារតែលោកធ្លាប់ស្គាល់យ៉ាងនេះ ទើបលោកឆ្លៀតឱកាសភាពប្រាប់លោកៗនោះថា ៖ លោកយល់ច្រឡំយ៉ាងធ្ងន់ដូចបងប្អូនខ្មែរទូទាំងប្រទេសអញ្ចឹងដែរ គឺ «លោកមិនព្រមរត់ចោលស្រុក» ។

មើលចុះ ! អាមេរិកាំងមកហៅលោកជាច្រើនលើក សូមឲ្យលោកគេចខ្លួនមួយរយៈសិន ទៅសំណាក់នៅសហរដ្ឋអាមេរិក ។ នៅលើកក្រោយបង្អស់ មានឧទ្ធម្ភាគចក្រមួយគ្រឿងមកចុះខាងកើតវិមានឯករាជ្យ រួចគេមកអញ្ជើញលោកម្ដងទៀត

តែលោកមិនព្រមទៅតាមគេ ។ ព្រោះលោកយល់ស្ថានការណ៍ពេលនោះខុសទាំងស្រុង ។ លោកយល់ថា ដោយហេតុថាថានៈលោកជាទេសាភិបាលធនាគារកម្ពុជា បើសិនណាជាលោករត់ចោលមុខតំណែង ប្រាក់កាសទាំងឡាយនៅក្នុងធនាគារទាំងប៉ុន្មាននឹងត្រូវខាតបង់ ហើយលោកនឹងត្រូវគេចោទប្រកាន់ថា ជាអ្នកលួចលុយជាតិដើម្បីយកទៅធ្វើជាអ្នកមាននៅបរទេស ។ ដូច្នេះលោកប្តូរផ្តាច់នៅរង់ចាំជួបសម្តេច ជួបលោកខៀវ-សំផនសិន ។ បើសិនណាសម្តេចក្តី លោកខៀវ-សំផនក្តី លែងត្រូវការលោក នៅពេលនោះលោកនឹងលាលែងចេញពីមុខតំណែងភ្លាម ព្រោះពេលនោះអាយុលោក៦១ឆ្នាំទៅហើយ ។ លោកយល់ច្រឡំយ៉ាងធ្ងន់ម៉្យាងទៀត ព្រោះលោកស៊ីគ្រលុំលួចលាក់គាំទ្រលោកខៀវ-សំផនជាយូរឆ្នាំមកហើយ ទាំងយោបល់ ទាំងលុយកាក់ ។ ចុងបំផុត លោកបានទទួលពាក្យបណ្តាំពីលោកខៀវ-សំផនផ្ទាល់ « ត្រូវជួយឧបត្ថម្ភភ្នាក់ងារសម្ងាត់របស់បក្សម្នាក់ឈ្មោះ គីម-យៀម ហៅមិត្តយ៉ា ពាក់លេខ៧ » ។ ក្នុងសករាជស្តេចសីហនុ មិត្តយ៉ាត្រូវជាប់ឃុំឃាំងជាញឹកញាប់ ព្រោះមិត្តយ៉ាស្ម័គ្រចិត្តចេញឈ្មោះជំនួសអ្នកសរសេរអត្ថបទនានា ដែលតិះទៀនរាជរដ្ឋាភិបាលនៅក្នុងទំព័រកាសែត « ប្រជាជន » ។

ដូច្នេះពេលណាមិត្តយ៉ាត្រូវជាប់គុក លោកគីម-ងួនត្រាចត្រូវតែគិតគូរជួយដោះស្រាយ ជាពិសេសតែងតែជួយផ្តល់លុយកាក់ចិញ្ចឹមអ្នកស្រីអ៊ូចជាប្រពន្ធ និងយុវជនគីម-លាក់ ជាកូនប្រុសទោលរបស់គីម-យៀម ហៅមិត្តយ៉ាជានិច្ច ។

ក្នុងរយៈពេល៥ខែដែលលោកភៀសខ្លួនទៅសំណាក់នៅឯខេត្តតាកែវ ឆ្លៀតពេលដែលអង្គការដាក់ទិសឲ្យលោកអតីតទេសាភិបាលធនាគារជាតិកម្ពុជាដើររើសអាចម៍គោយកមកធ្វើជី លោកប្រើគ្រប់មធ្យោបាយ ដើម្បីសាកសួររកអស់លោកៗដូចជាខៀវ-សំផន, ហ៊ូ-យន់, ហ៊ូ-នឹម, សឺន-សេន, ភោគ-ឆាយ, អៀង-សារី គីម-យៀម ហៅមិត្តយ៉ាជាដើម ។ ប៉ុន្តែពុទ្ធោអើយ ! ពេលនោះតំណាងរបស់អង្គការ ម្នាក់ៗសុទ្ធតែមានអាយុសឹងមិនដល់១៥ឆ្នាំផង ធ្វើភ្នែកឡឹនឡង់ៗហើយសួរគ្នាថា តើអ្នកណាគេទៅអេះជាខៀវ-សំផននោះ ? ។

លោកគីម-ងួនត្រាចបញ្ជាក់ហើយបញ្ជាក់ទៀតថា លោកឆ្ងល់ណាស់ព្រោះលោកស្គាល់សមាជិកជាន់ខ្ពស់របស់បក្សខ្មែរក្រហមជាច្រើន ហើយយ៉ាងជិតដិតណាស់ ប៉ុន្តែតាំងពីពេលលោកបានត្រូវគេជម្លៀសចេញពីភ្នំពេញលុះសព្វថ្ងៃ លោកខំព្យាយាមស្រាវជ្រាវរកអស់លោកទាំងនោះ តែលោកគ្មានបានដំណឹងអ្វីពីអ្នកណាម្នាក់ទាល់តែសោះ ។

ដូច្នេះជ័យជំនះថ្ងៃទី១៧មេសា១៩៧៥នេះ ដូចជាមិនមែនរបស់បក្សខ្មែរក្រហមនៃខៀវ-សំផនទេ ...តែជាជ័យជំនះមួយដែលត្រូវគេក្លែងបន្លំ ហើយដែលមាន

សភាពយ៉ាងសែនងងឹតអន្ធកា ។

មើលចុះ ! វាបែរជាប្រើឈ្មោះអង្គការអនាមិកដាក់ធ្វើជាមេបញ្ជាការទៅវិញ ។ ជាដំបូងអង្គការបញ្ជាឲ្យសម្លាប់បញ្ញវ័ន្តនិងព្រះសង្ឃជាបន្ទាន់ ។ ក្នុងរយៈពេលតែ ១៣ថ្ងៃ ខ្មែរនៅក្នុងស្រុកស្លាប់ស្ទើរតែទាំងអស់ ព្រោះខ្មាំងបានបង្កប់ពួកចារបុរស-ចារនារីនៅតាមគ្រប់ស្រទាប់បណ្ដាជនខ្មែរទាំងមួយនគរ ។ គឺដោយសារតែពួកចារបុរស-ចារនារីទាំងនេះហើយ ដែលខ្មាំងអាចយកការណ៍បានថា អ្នកដែលមិនរត់ចោលស្រុកភាគច្រើនជាអ្នកស្នេហាជាតិ ។ ដូច្នេះកម្មវិធីជាបន្ទាន់ គឺត្រូវកំទេចពួកនេះចោលឲ្យអស់ ដើម្បីកុំឲ្យពួកនេះមានមធ្យោបាយណានឹងរវខ្លួនទាន់ ។ កាលសម្លាប់ពួកនេះអស់រួចហើយ ត្រូវដាក់ពួកមេចោរ ពួកពួងចុងស្រុក ឲ្យត្រួតត្រាជាប្រញាប់ក្នុងមួយរយៈសិន ។

ពួកចោរភ្លើដែលគេតម្លើងឲ្យធ្វើ «មេ» ទាំងនោះបានដៃ ក៏ស្រែកហ៊ោរតាមអង្គការថា ជយោមហាអស្ចារ្យ ! ជយោមហាលោតផ្លោះ ! ហើយគិតតែពីសម្លាប់សាសន៍ឯងឥតរួញរា ។

ខ្មែរដែលនៅសល់ពីស្លាប់ ត្រូវអង្គការដេញឲ្យចេញពីលំនៅសឹងបាតដៃទទេ ចោលទ្រព្យសម្បត្តិដែលខំកសាងកកើកកន្លាំងអស់មួយជីវិតមកហើយ ហើយនាំគ្នាមកដេកនឹងដី កណ្ដាលភ្លៀង កណ្ដាលផ្គរ ក្នុងព្រៃទាំងរងាររញ្ជាក់រញ្ជ័រ...។

អង្គការបញ្ជាឲ្យធ្វើទារុណកម្មបន្ថែម ដោយបង្ខំឲ្យធ្វើការទាំងយប់ទាំងថ្ងៃ ក្រោមកំដៅ ក្រោមទឹកភ្លៀង រួចឲ្យហូបតែទឹកបបរលាយជាមួយអំបិលតែ២-៣គ្រាប់ក្នុងមួយពេល ។

បើដូច្នេះ តើហេតុយ៉ាងដូចម្ដេចបានជាវាបញ្ជាឲ្យយើងស្រែកបន្ទរថា « ជយោមហាលោតផ្លោះ, ជយោមហាអស្ចារ្យ » ឯណោះទៅវិញ ? គ្រប់ៗគ្នាស្រែកតាមវាទាំងមុខជូរហ្មញដូចស៊ីក្រូចឆ្មា... ឆ្ងល់សែនឆ្ងល់ !? ។ លោកគីម-ង្ហួនត្រាចបន្ថែមថា ចូរប្អូនៗកុំសង្ស័យធ្វើអ្វី ព្រោះពាក្យដែលអង្គការឲ្យយើងស្រែកបន្ទរនេះ មិនមែនឥតប្រយោជន៍ទេ គឺយើងស្រែកបន្ទរឲ្យពួកអ្នកឈ្នះ ដែលលាក់ខ្លួនពួនអាត្មាក្រោមវនាំងសម្ងាត់ដែលមានឈ្មោះអង្គការជាអ្នកនៅបាំងពីមុខបំបាត់ដាន ! ។ ខ្មាំងវាលែលកធ្វើការឲ្យស្របៗតាមបក្សខ្មែរក្រហមរបស់លោកខៀវ-សំផន ។ វាសម្ងំរង់ចាំឱកាសឲ្យត្រូវសង្វាក់ ដើម្បីនឹងសម្លាប់ខ្មែរឲ្យបានងាយ ហើយនៅតែលាក់មុខបានជិតដដែល ។

មើលចុះ ! រាល់យប់ថ្ងៃ តែងតែមានក្រុមឃាតករអាថ៌កំបាំងមកបន្លំខ្លួនប្រើយីហោខ្មែរក្រហមដើម្បីចូលមកចាប់ចងរាស្ត្រខ្មែរ ជាពិសេសពួកបញ្ញវ័ន្ត ។ ធ្វើដូច្នេះដើម្បីឲ្យខ្មែរនិងអន្តរជាតិយល់ច្រឡំថាខ្មែរក្រហមសម្លាប់ខ្មែរ ។

ការពណ៌នានេះមិនមែនបានសេចក្ដីថា ជាការលប់បំបាត់កំហុសខ្មែរក្រហមនោះទេ ព្រោះមានពេលខ្លះយើងបានឃើញផ្ទាល់ភ្នែក នូវពួកខ្មែរក្រហមដែលកើតមកពីចោរ ក៏បានចាប់អូសទាញខ្មែរទៅសម្លាប់ចោលដែរ ។

ប៉ុន្តែយើងគ្រាន់តែចង់បញ្ជាក់ឲ្យច្បាស់ថា អ្នកទទួលខុសត្រូវក្នុងការបង្កើតគំរោងការណ៍ដ៏ខ្មៅក្រខ្វក់ ដើម្បីវាយបំបែកខ្មែរនិងខ្មែរនោះ គឺមិនមែនខ្មែរទេ ។ ព្រោះនៅស្រុកខ្មែរយើង គ្រប់ៗព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ គេតែងតែឃើញពួកយួនហាណូយចូលមកជ្រៀតជ្រែក អំពីបញ្ហាផ្ទៃក្នុងរបស់ខ្មែរជានិច្ច ។ សូមរំឭកឡើងវិញ ៖

១/ ឆ្នាំ១៩៤៥-១៩៥៤ ៖ ព្រឹត្តិការណ៍ខ្មែរឥស្សរៈទាមទារឯករាជ្យពីអាណានិគមនិយមបារាំង ។ គេឃើញពួកបូដូយតាំងមូលដ្ឋាននៅពាសពេញប្រទេសខ្មែរ ដោយយកលេសថា ចូលមកស្លាប់ជួយខ្មែរដេញបារាំង ។ ការពិតវាចូលមកញុះញង់បំបែកបំបាក់ខ្មែរ ដើម្បីបង្កើតខ្មែរវៀតមិញបានសំរេចដូចបំណងរបស់វា ។

២/ ឆ្នាំ១៩៧០-១៩៧៥ ៖ ព្រឹត្តិការណ៍ថ្ងៃ១៨មិនា១៩៧០ រដ្ឋសភាទម្លាក់ប្រមុខរដ្ឋ-សម្ដេចសីហនុ- ដែលបានអនុញ្ញាតឲ្យយៀកកុង ចូលនៅតាមបណ្ដោយព្រំប្រទល់ និងទីកន្លែងផ្សេងទៀតក្នុងដីខ្មែរ ។ បន្ទាប់ពីការអំពាវនាវតាមវិទ្យុពីក្រុងប៉េកាំងនៃប្រទេសចិនរបស់សម្ដេចសីហនុធ្លាក់បុណ្យមក យួនបូដូយចេញពីព្រៃដើរពាសពេញដីខ្មែរ ហក់លោតប្រហារវាយកំទេចទ័ពខ្មែរសាធារណរដ្ឋ តាមសំរែករបស់សម្ដេចសីហនុ ។ យួនបូដូយបានលេស ក៏កំទេចទ័ពខ្មែរស្នេហាជាតិដោយយកលេសថា ចូលមកជួយសម្ដេចឪ ។ ការពិតគឺជាកាលៈទេសៈដ៏ល្អរបស់វា ដើម្បីកំទេចខ្មែរផង (សង្គ្រាមក្ដៅ) និងបានឱកាសពង្រឹងពង្រីកក្រុមក្បាលយួនខ្លួនខ្មែរវៀតមិញ (សង្គ្រាមត្រជាក់) ដើម្បីលៃលួចបន្លំប្រើឃីហោខ្មែរក្រហមរហូត ។

ដូច្នេះ «ជ័យជំនះ» ថ្ងៃ១៧មេសា១៩៧៥នេះ ច្បាស់ជាមានការគៃបន្លំ ឆ្លៀតបំផ្លាញមកលើខ្មែរ ពីសំណាក់យួនហាណូយជាដាច់ខាត ។

លោកគឹម-ងួនត្រាចបានបន្ថែមថា ៖ ចូរប្អូនៗមើលចុះ ! តាំងពីឆ្នាំ១៩៧៦មក យើងគ្មានឃើញសមាជិកខ្មែរក្រហមរបស់ខៀវ-សំផនឡើយ តែបែរជាឃើញក្រុមពួកក្បាលយួនខ្លួនខ្មែរវៀតមិញ ចេញមុខព្រោងព្រាតយ៉ាងច្បាស់ក្រឡែត ដែលអង្គការបានចាត់តែងតាំងរួចជាស្រេច ឲ្យធ្វើជាប្រធានសហករណ៍, ជាគណៈតំបន់, ជាតំណាងរាស្ត្រ ។ ដូចយើងឃើញផ្ទាល់ភ្នែកស្រាប់ហើយ តាប៉ែត, តាកៅ, មិត្តកើត, មិត្តលក (ជាតិយួន), មិត្តលី (ជាតិយួន), មិត្តលៃ (ជាតិយួន) ជាដើម ។

ចំណែកអ្នកនៅក្រោមបង្គាប់របស់វា គឺជាពួកចោរព្រៃដែលអង្គការឆ្នៃប្រឌិតឲ្យទៅជាខ្មែរក្រហម ដែលកាចសាហាវជាងសាហាវ ។

ជាសរុបសេចក្តីមក ព្រឹត្តិការណ៍ថ្ងៃទី១៧មេសា១៩៧៥នេះ ជាព្រឹត្តិការណ៍អាថ៌កំបាំងណាស់ អ្នកទទួលជ័យជំនះបានបន្លំប្រើឈ្មោះអង្គការអនាមិក ។ វាលើកបន្តុបខ្មែរវៀតមិញមកបំបាំង រួចវាប្រើខ្មែររងគ្រោះឲ្យស្រែកជយោមហាអស្ចារ្យមហាលោតផ្លោះជំនួសវា ។ល។ និង ។ល។

លោកគីម-ងួនត្រាចបញ្ជាក់ថា ៖ យួនវៀតមិញក្តី យួនវៀតកុងក្តី ពេលដែលវាចូលមករាតត្បាតប្រទេសកម្ពុជា វាតែងតែអរបង្វែងជានថាមកជួយខ្មែរ ។ តែការពិត គឺវាចូលមកញុះញង់បំបែកបំបាក់រុញខ្មែរឲ្យច្បាំងនិងខ្មែរ រហូតត្រាតែផុតពូជ ដើម្បីស្រួលវាចូលមកលេបយកទឹកដីខ្មែរឲ្យអស់តែម្តង ។ ព្រោះបើច្បាំងយកតាមកម្លាំងបាយ វាឃើញថាវាមិនអាចនឹងយកជ័យជំនះឲ្យបានពីលើខ្មែរទេ មានជាឧទាហរណ៍រួច២លើកមកហើយ ដែលវាទទួលបរាជ័យយ៉ាងអាម៉ាស់ជាទីបំផុត ៖

- លើកទី១នៅកម្ពុជាក្រោម ឆ្នាំ១៩៤៥-៤៦
- លើកទី២ នៅឆ្នាំ១៩៥៤ វាចង់ពុះប្រទេសកម្ពុជាជាពីរ ។

លោកបន្តទៅទៀតថា ៖ អូនៗមើលចុះ ! ប្រទេសខ្មែរយើងបានឯករាជ្យតាំងពីថ្ងៃទី៩/១១/៥៣មកម្ល៉េះ ។ ក្នុងខែមេសា១៩៥៤ ឆ្លៀតពេលដែលបូដួយតាំងមូលដ្ឋាននៅពាសពេញស្រុកខ្មែរ យួនវៀតមិញបែរជាបញ្ជាឲ្យបូដួយព័ទ្ធវាយកំទេចមូលដ្ឋានកងយោធពលខេមរភូមិន្ទនៅប៉ៃលិន, ស្រែជេស្ធ, រ៉ុនសៃ ជាដើមទៅវិញ ។ កាលណោះយួនវៀតមិញមានកម្លាំងយ៉ាងខ្លាំង ដោយសំអាងទៅលើគ្រឿងអាវុធយុទ្ធភ័ណ្ឌដែលវាកំពុងតែវាយបារាំងយកជ័យជំនះនៅឌៀន-បៀនភូ ។ តែនៅចំពោះមុខកងយោធពលខេមរភូមិន្ទ ពួកវាក៏ត្រូវបង្ខំចិត្តដកថយទៅវិញ ដោយចោលខ្មោចជាច្រើននៅលើទឹកដីខ្មែរ ។ លុះមានការពិសោធន៍ពីរដងយ៉ាងនេះហើយ ពួកវាក៏យល់ថា បើចង់វាតទីយកទឹកដីខ្មែរ មិនត្រូវធ្វើសង្គ្រាមក្តៅទេ តែត្រូវបន្ថែមសង្គ្រាមចិត្តសាស្ត្រនិងកលល្បិច ។ ដូច្នេះវាត្រូវតែអនុវត្តឃ្លោងឃ្លា « បំបែកបំបាក់ដើម្បីគ្រប់គ្រង» ។ គឺវាលៃលកញុះញង់ខ្មែរទៅតាមចំណុចខ្សោយនានា ញុាំងឲ្យខ្មែរបែកជាច្រើនក្រុម ។ « ថ្ងៃនេះវាជួយខ្មែរក្រុមនេះ... ថ្ងៃក្រោយវាជួយខ្មែរក្រុមឯណោះទៅវិញ» ។

ចំណែកឯខ្មែរវិញ ចាប់នេះចាប់នោះមិនឆ្លោះត្រង់ណា ។ មកពីអ្នកដឹកនាំខ្វះសមត្ថភាព បណ្តោយឲ្យខ្មែរយល់ច្រឡំរក៏វី និងមិនដឹងថានរណាជាមិត្តនរណាជាសត្រូវទេ ។

ចុងបំផុតខ្មែរលោតសម្លាប់តែគ្នាឯងទាំងមិនដឹងខ្លួន ។

រឿងអង្គការដេញប្រជាជនឲ្យថយចេញពីលំនៅ ត្រូវចោលទ្រព្យសម្បត្តិយ៉ាងច្រើនឥតគណនា និងឥតសមហេតុផលនេះ គឺសត្រូវស្មួរពូជរបស់ខ្មែរមានគំរោង

ផែនការព្រាងទុកមកជាស្រេច ៖

១- ញ៉ាំងឲ្យរាស្ត្រខ្មែរស្លាប់បន្តកន្ទុយគ្នា «មិនពិបាកវាសម្លាប់» ដូចជាអ្នកជម្ងឺ ឬអ្នករបួសធ្ងន់ៗបណ្តាលមកពីសង្គ្រាម, មនុស្សចាស់ជរា, កូនក្មេងបៅទឹកដោះគោ « ពេលនោះគ្មានទឹកដោះគោទាល់តែសោះ » ។ ជាពិសេសអ្នកទីក្រុងមិនធ្លាប់ដើរ ដេកពាសវាលពាសព្រៃផ្ទាល់ដី, ហាលខ្យល់ហាលក្តៅកណ្តាលភ្លៀង និងផឹកទឹកអណ្តូងបណ្តាលឲ្យទៅជាមានរោគរាគមួល «គ្មានថ្នាំទាល់តែសោះ» ។ មានមួយភាគបណ្តាលមកពីការអស់សង្ឃឹម ក៏សម្លាប់ខ្លួនចោលទៅ ។

២- វាចូលមកប្រមូលប្លន់ទ្រព្យសម្បត្តិក្នុងប្រទេសខ្មែរ ដឹកជញ្ជូនទៅកាន់ប្រទេសវាដោយសេរី និងយ៉ាងងាយបំផុត ។ វាប្រយ័ត្នណាស់ វាមិនបណ្តោយឲ្យយើងឃើញវាងាយៗទេ ។ ជួនជាមានខ្មែរណាម្នាក់បានជួបក្រុមវាដោយចៃដន្យ ខ្មែរអភ័ព្វនោះត្រូវវាចោទថា ដើរខុសខ្សែត្រៀម អង្គការធ្វើទារុណកម្មរហូតដល់ស្លាប់។

លោកគឹម-ងួនត្រាចបញ្ជាក់ទៀតថា ៖ សត្រូវស្ទួរពូជរបស់យើងកំពុងតែសម្លាប់បំផុតពូជខ្មែរ, កំពុងតែប្លន់ទ្រព្យសម្បត្តិខ្មែរ ដោយសារតែឈ្មោះអង្គការអនាមិក វាអាចលាក់មុខបានយ៉ាងជិតដដែល ។

លោកគឹម-ងួនត្រាចជាខ្មែរកម្ពុជាក្រោម, ជាអ្នកនយោបាយដ៏នឹងនរម្នាក់ ដែលធ្លាប់ធ្វើការនៅក្រោមបង្គាប់លោកសឺង-ង៉ុកថាញ់ ។ លោកស្គាល់គ្រប់ស្នៀតនិងកលល្បិចរបស់វៀតមិញ ដែលធ្លាប់បានលេបយកទឹកដីកម្ពុជាក្រោម ។ ពេលនេះលោកពន្យល់អ្នកអង្គុយស្តាប់ទាំងអស់ថា ៖ នៅបច្ចុប្បន្ននេះ វៀតកុងកំពុងប្រមូលកលល្បិចដដែលនោះ មកឲ្យអង្គការទាំងអស់ ដោយកែទម្រង់តែបន្តិចបន្តួចប៉ុណ្ណោះ ។ ឥឡូវអង្គការកំពុងតែអនុវត្តកលល្បិចនេះ ដើម្បីវាតទីលេបទឹកដីកម្ពុជាកណ្តាលទៀត ។

ពេលនោះដោយអស់សង្ឃឹម លោកគឹម-ងួនត្រាចគ្រវីក្បាលហើយថ្ងូរថា ៖ « បើលោកធំៗខ្មែរបានគេចរួចទៅកាន់បរទេស មិនខំរៀនសូត្រឲ្យស្គាល់កលល្បិចសត្រូវ, មិនខំពន្យល់គ្នាឲ្យយល់ថាប្រទេសខ្មែរត្រូវរលាយ នេះគឺស្នាដៃយួនហាណូយ, បើយើងចេះតែបណ្តោយឲ្យរាស្ត្រខ្មែរបន្តការយល់ច្រឡំ យកសត្រូវធ្វើជាមិត្តម្យ៉ាងទៀតយើងមិនចេះអប់រំខ្មែរឲ្យចេះសាមគ្គីគ្នា... តើកាលណាទៅទើបយើងអាចរំដោះទឹកដីកម្ពុជាបាន ? » ។

លោកគឹម-ងួនត្រាចទទួលសារភាពថា ៖ លោកក៏យល់ច្រឡំយ៉ាងធ្ងន់ដែរ ។ លោកមិនព្រមរត់ចោលទឹកដី ឥឡូវភ្លាត់ស្នៀតធ្លាក់ខ្លួនក្នុងគ្រោះថ្នាក់យ៉ាងធ្ងន់ជាងធ្ងន់ ។ បើយើងមិនបានឃើញផ្ទាល់ភ្នែកទេ នូវឧប្បត្តិហេតុដ៏ចម្លែកៗ ដូចជាសម្លាប់រង្គាលដ៏អស្ចារ្យមិនទំនងយ៉ាងនេះ, បើយើងមិនបានឃើញអតីតមេខ្មែរវៀតមិញ

ដូចជាតាប៉ែត, តាកៅជាដើមចេញមុខមកកាន់អំណាចយ៉ាងនេះទេ យើងមិនអាចយល់និងទទួលស្គាល់ថា ៖ មេដឹកនាំខ្មែរចាញ់បោកយួនហាណូយឡើយ ។

ឥឡូវនេះទោះយើងយល់ច្បាស់យ៉ាងនេះក៏ដោយ ក៏វាចួចជាយឺតពេលណាស់ទៅហើយ ។ ខ្លួនរបស់លោកៗក៏សន្និដ្ឋានទុកដូចជាស្លាប់ទៅហើយ អង្គការមិនអនុគ្រោះទុកឲ្យលោកនៅរស់តទៅទៀតឡើយ ។

លោកក៏បន្ថែមទៀតថា មុននឹងស្លាប់ខ្ញុំសុំទូន្មាននឹងផ្តាំទៅប្អូនៗឲ្យចេះធ្វើខ្វាក់ធ្វើគ ធ្វើថ្លង់ និងចេះអត់ធ្មត់ទើបមានសង្ឃឹមអាចគេចផុតពីគ្រោះថ្នាក់ដ៏ឧត្បាតនេះបាន ។ ម្យ៉ាងទៀតបើប្អូនៗណាសេសសល់នៅរស់ ត្រូវតែធ្វើពលិកម្មតាមដានស្រាវជ្រាវរកហេតុពិតនិងតាមរកមុខឲ្យឃើញច្បាស់ថា ៖ តើអង្គការជានរណា ? បើតាមរកឃើញដូចយោបល់ខ្ញុំមែន ចូរកុំព្រងើយកន្តើយឲ្យសោះ គឺត្រូវសរសេរទុកជាឯកសារជាបណ្តាំដល់កូនខ្មែរជំនាន់ក្រោយឲ្យដឹង ឲ្យយល់រឿងពិតថា « តើមេឃាតករជាសាសន៍ណា ? សុំកុំឲ្យកូនខ្មែរក្រោយៗចាញ់បោកយួនហាណូយដូចជាខ្មែរអភ័ព្វ ដែលកើតមកចំជំនាន់សម្តេចសីហនុនិងខៀវ-សំផនឲ្យសោះ » ។

លោកអ្នកដែលមានវាសនាអង្គុយស្តាប់ពាក្យពេចន៍ដ៏មានខ្លឹមសាររបស់លោកគិម-ងួនត្រាចពេលនោះគឺ ៖

- លោកឃឹ-វិញទ្រី ជានាយកទីពិសោធន៍
- លោកថាច់-សាកាន ជាសាស្ត្រាចារ្យ
- លោកថាច់-ក្មើង ជាអនុសេនិយទោ
- លោកគិម-ភួង ជាអនុសេនិយឯក
- លោកសឺន-តុន ជាភ្នាក់ងារក្រសួងរថភ្លើង
- លោកគិម-ចន្ទ ជាសាស្ត្រាចារ្យ
- យាយទៀង ជានាយការិយាល័យរបៀបនិងជានាយការិយាល័យឯកសារ

អ្នកទាំងអស់នេះលើកដៃប្តេជ្ញាទទួលបណ្តាំរបស់លោកគិម-ងួនត្រាច ។ ប៉ុន្តែលោកទាំងប៉ុន្មាននេះ ត្រូវក្រុមឃាតករអាថ៌កំបាំងចូលមកចាប់ចងយកទៅសម្លាប់ចោលម្តងមួយៗជាបន្តបន្ទាប់គ្នា...

- លោកគិម-ងួនត្រាចត្រូវគេចាប់ខ្លួននៅដើមខែតុលាឆ្នាំ១៩៧៦ ។
- លោកគិម-ចន្ទ ត្រូវគេចាប់ខ្លួននៅល្ងាចថ្ងៃ២៥-១០-៧៦ ។
- លោកឃឹ-វិញទ្រី, ថាច់-សាកាន, សឺន-តុន និងគិម-ភួង ត្រូវគេចាប់ខ្លួននៅថ្ងៃទី១១-១១-៧៦ វេលាម៉ោង៨យប់ ។
- លោកថាច់-ក្មើង ត្រូវគេចាប់ខ្លួននៅថ្ងៃទី២០-៤-៧៨ ជាមួយប្រជាជនចំនួន៣០០នាក់ រួចបណ្តើរនាំយកទៅសម្លាប់ចោលនៅខាងលិចភូមិកង្កួត ។

- យាយទៀង ត្រូវគេចាប់ខ្លួននៅថ្ងៃទី២-១-៧៧ នាំយកទៅដាក់គុកក្នុងព្រៃតាបែន ស្ថិតនៅខាងកើតភូមិកង្កួត ខាងលិចភ្នំជើងទេញ ដែលសល់នៅរស់ដល់សព្វថ្ងៃ ...អាចសរសេរឯកសារនេះជូនខ្មែរទាំងឡាយដើម្បីជាគតិតទៅអនាគត ។

លោកកើតនៅឆ្នាំ១៩១៥ នៅភូមិឬស្សីមួយគុម្ព ឃុំឡុងហៀប ស្រុកត្រាកូវ ខេត្តត្រាវិញ កម្ពុជាក្រោម ។

ជាកូនប្រុសទីមួយរបស់តាកែនិងយាយផា ។ លោករៀននៅមហាវិទ្យាល័យនៅទីក្រុងហាណូយផ្នែកហិរញ្ញវត្ថុ ។ លុះរៀនចេះចប់ លោកក៏វិលត្រឡប់ទៅកាន់ខេត្តត្រាវិញវិញ ។ លោកមិនអាចទ្រាំនៅក្នុងនគរកំណើតបាន ដោយសារការធ្វើបាបកៀបសង្កត់ពីសំណាក់យួនវៀតមិញ មកលើខ្មែរអ្នកចេះដឹងទូទៅ មានរូបលោកជាដើម ។ លោកក៏ចាកចោលទឹកដីកំណើតជាមួយគ្រួសារ មកតាំងទីលំនៅនៅរាជធានីភ្នំពេញក្នុងឆ្នាំ១៩៤៥ ។ ក្នុងរាជព្រះបាទសីហនុ លោកជាអគ្គលេខាធិការនៅរតនាគារជាតិ ។ នៅសម័យសាធារណរដ្ឋ លោកជាទេសាភិបាលនៃធនាគារជាតិកម្ពុជា ។ នៅសម័យអង្គការឆ្នាំ១៩៧៥ គេដាក់ទិសលោកឲ្យដើររើសអាចម៍គោយកមកធ្វើជីរ ។ លុះឆ្នាំ១៩៧៦ លោកភៀសខ្លួនមកខេត្តបាត់ដំបង សំណាក់នៅកងលេខ៩ ភូមិព្រៃស្វាយ នៅខាងកើតសហករណ៍លក់ជ្រៀវ ។ អង្គការបំបែកលោកចេញពីប្រពន្ធកូនតែឯងឯកា នៅលើខ្លួនមានតែខោខ្លីដាច់ដាចមួយបន្លាស់ គ្មានអាវពាក់ឡើយ ។ អង្គការដាក់ទិសឲ្យលោករែកទឹកស្រោចបន្លែ ។

❏

# ដំណាក់ការត្រូវសម្លាប់បុគ្គលិកពេទ្យ ភ្នាក់ងាររថភ្លើង និងជាងតម្បាញ

នៅថ្ងៃទី២៣-៤-៧៥ អង្គការបញ្ជាឲ្យមនុស្សទៅប្រាប់បុគ្គលិករថភ្លើងនិងជាងតម្បាញនៅខេត្តបាត់ដំបងទាំងអស់ថា ត្រូវនៅសម្ងំស្ងៀមធ្វើការជាធម្មតា ។ ចំណែកមិត្តស៊ូទៅប្រាប់បុគ្គលិកពេទ្យនៅមន្ទីរពេទ្យធំទីក្រុងបាត់ដំបងថា ត្រូវនៅស្ងប់ស្ងៀមមួយកន្លែងសិន ។

ចំពោះរឿងដ៏ចម្លែកនេះ គឺពុំមែនមកពីអង្គការមានចិត្តសប្បុរសទុកជីវិតលោកទេ តែនេះជាកលល្បិចថ្លិនភ្លែករបស់អង្គការ ។ វាទុកបុគ្គលិកទាំងបីផ្នែកនេះឲ្យជួយបង្ហាត់បង្រៀនយោធាក្មេងៗ និងក្រុមប្រជាជនចាស់របស់វា ញ៉ាំងឲ្យក្រុមនោះយល់ច្រឡំស៊ីជោរជួយសម្លាប់និងធ្វើទារុណកម្ម ជាពិសេសជួយស៊ើបការណ៍ផ្សេងពីប្រជាជនថ្មីផ្តល់ឲ្យអង្គការជាបណ្តោះអាសន្នសិន ។

មើលចុះ ! ចុងឆ្នាំ១៩៧៦ អង្គការបញ្ជាឲ្យក្រុមឃាតករអាថ៌កំបាំងចូលមកកាន់កងគ្រប់ៗកងក្នុងខេត្តបាត់ដំបង ចាប់ចងបុគ្គលិកពេទ្យចំនួន២៥នាក់ នាំយកទៅបាត់ខ្លួនរហូត ។ ក្នុងចំណោមបុគ្គលិកទាំងនោះ យើងស្គាល់លោកវេជ្ជបណ្ឌិតពឹងគឹមស៊ា, ម៉ែន-ហួន, អួន-ឈួត និងលោកឃី-វិញទ្រី ជានាយកមន្ទីរពិសោធន៍ ។

ក្នុងខែកុម្ភៈឆ្នាំ១៩៧៧ ស្រាប់តែឃើញឡានកាម្មីង៨គ្រឿងចតជាក្បួននៅមុខស្ថានីយរថភ្លើងទីក្រុងបាត់ដំបង ។ ពេលនោះគេឃើញបុគ្គលិកក្រសួងរថភ្លើងទាំងនាយទាំងកម្មករចំនួន១៧៥នាក់កំពុងតំរៀបជួរឡើងឡាន ។

ពេលនោះគេឃើញនាយក្រសួងម្នាក់ស្រែកលាភរិយាពីលើឡាន អ្នកស្រីភរិយាយល់ឃើញការមិនស្រួលដោយដឹងហេតុការណ៍ថា អង្គការច្បាស់ជាយកប្តីអ្នកស្រីទៅសម្លាប់ហើយ អ្នកស្រីក៏តោងឡើងលើឡានទៅស្លាប់ជាមួយប្តីដែរ ។ តែអង្គការបានកុហកថា យកអ្នកអស់នោះទៅរៀនសូត្រ...

ថ្ងៃដដែលវេលាម៉ោង៣រសៀល មានឡានកាម្មីងចំនួន៩គ្រឿងតំរៀបជាជួរជាក្បួននៅមុខរោងចក្រតម្បាញភូមិទួលតាឯក ទីក្រុងបាត់ដំបង ។ ពេលនោះគេឃើញនយោជិកតម្បាញប្រុសៗចំនួន៣៥០នាក់ តំរៀបជួរគ្នាឡើងឡាន ។ អង្គការកុហកថា យកអ្នកតាំងនោះទៅរៀនសូត្រដែរ ។ តែជីវិតនៃនយោជិកទាំង៣៥០នាក់នោះ បានរលត់ជាមួយគ្រាប់កាំភ្លើងរបស់អង្គការទៅហើយ...

ចំណែកឯប្រពន្ធនិងកូនរបស់ជនអភ័ព្វទាំងនោះវិញ អង្គការចាប់គ្នាដឹកតាមរទេះគោយកទៅបញ្ចូលគុកស្រីមេម៉ាយក្នុងព្រៃតាបែន ដែលជាទីរហោស្ថាន ។ រួចហើយអង្គការធ្វើទារុណកម្មដោយដាក់ឲ្យធ្វើការជាទម្ងន់ បង្អត់បាយទឹក ។ ម្ល៉ោះហើយអ្នកទាំងនោះត្រូវស្លាប់នឹងការស្រេកឃ្លាន និងជម្ងឺគ្រុនចាញ់យ៉ាងអាណោចអាធម៌ណាស់...។

## ដំណាក់ការត្រូវធ្វើទារុណកម្មលុតដំសម្លាប់ យោធាក្មេងៗនិងមេកាន់ក្តាប់

ចាប់តាំងពីថ្ងៃ១៧-៤-៧៥ អង្គការលាក់បំពួនយោធាយ៉ាងច្រើននៅព្រៃកទាល់ជាតំបន់ដែលមានផ្ទះសង់នៅលើទឹក ។

ប្រជាជនថ្មីត្រូវគេហាមមិនឲ្យភៀសខ្លួនមកតំបន់នេះទេ ។ រីឯពួកយោធាដែលនៅព្រៃកទាល់វិញក៏គ្មានសិទ្ធិមកជួបម៉ែឪ ឬប្រជាជនថ្មីជាដាច់ខាត ។ ដោយសារការកាត់ផ្តាច់ទំនាក់ទំនងនឹងពិភពក្រៅយ៉ាងនេះ ពួកយោធាទាំងអស់នោះមិនបានដឹងទាល់តែសោះ ថាអង្គការបញ្ជាឲ្យសម្លាប់បងប្អូនខ្មែររាប់លាននាក់ មិនបានដឹងថាទីប្រជុំជននានាមានរដ្ឋធានីភ្នំពេញ ទីរួមខេត្តបាត់ដំបង... ទាំងនោះក្លាយទៅជាទីរហោស្ថាន មិនបានដឹងថាពួកវៀតកុងលួចដឹកជញ្ជូនទ្រព្យសម្បត្តិខ្មែរទាំងមួយនគរទៅប្រទេសវានោះឡើយ ។ល។

តំបន់ព្រៃកទាល់សម្បូរណ៍ទៅដោយត្រី ។ ក្នុងខែមេសាឆ្នាំ១៩៧៨ អង្គការចេញបញ្ជាឲ្យបញ្ជូនមនុស្សម្នាក់ក្នុងមួយកងទៅតំបន់នោះជាបន្ទាន់ដើម្បីជួយនេសាទរួម ។

ក្នុងកងលេខ៤ នៅភូមិព្រៃស្វាយខាងកើត, យុវជន ជន ត្រូវគេចាត់បញ្ជូនឲ្យទៅបំពេញបេសកកម្មនេះ ។ ១៥ថ្ងៃក្រោយមក យុវជនជនវិលត្រឡប់មកកាន់កងវិញ ។ ជនខ្សឹបប្រាប់យាយទៀងថា ៖ ជនបានឃើញគេប្រមូលយោធាក្មេងៗអាយុចាប់ពី១៥ទៅ១៧ឆ្នាំ មានចំនួន៥ពាន់នាក់ ជួបជុំគ្នានៅព្រៃកទាល់ ។ ពេលនោះមានមនុស្សដ៏ចម្លែកចំនួន១០នាក់ អាយុប្រហែលពី៣០ទៅ៤០ឆ្នាំ ។ ពេលខ្យល់បក់មួកធ្លាក់ពីក្បាល ជនឃើញទម្រង់មុខពួកនោះដូចជាយួន ។ មានយោធាពិសេសចំនួន២០០នាក់ ជាអ្នកការពារសន្តិសុខ មានអាវុធគ្រប់ដៃ មានរបៀបរៀបរយយ៉ាងប្រុងប្រយ័ត្ន អ្នកខ្លះមានមុខមាត់ដូចជាយួន ។ ពេលនោះជនឃើញមេៗឈរខ្សឹបគ្នាម

ួយសន្ទុះស្រាប់តែមានម្នាក់មាឌមាំសក់រួញ ដើរចេញមកឈរចំពីមុខយោធាក្មេងៗ ចាប់ផ្ដើមប្រកាសជាភាសាខ្មែរយ៉ាងផ្អែមល្ហែមថា ៖

« មិត្តជាទីស្នេហាទាំងឡាយ... ប្រទេសយើងតូចមែនពិត ប៉ុន្តែយើងអាចសំរេចដណ្ដើមយកបានជ័យជំនះដ៏ធំធេង ពីចក្រពត្តិអាមេរិកាំងនិងបរិវាររាជាស្ដាពរ ។ ជ័យជំនះនេះបានដោយសារស្នាដៃ នៃយោធាបដិវត្តន៍ដ៏ក្លាហានរបស់យើង ។ ឥឡូវ រៀមច្បងស្ម័គ្រចិត្តរៀបចំចេញទៅរំដោះទឹកដីកម្ពុជាក្រោម ដែលជាកេរ្ដិ៍មរតកពីដូនតារបស់យើង ដែលបារាំងបានច្រឡំប្រគល់ឲ្យទៅយួនពីឆ្នាំ១៩៤៩ ។ ចំណែកឯប្អូនៗ អង្គការរៀបចំកន្លែងសំរាប់បង្ហាត់បង្រៀនអប់រំនៅភូមិកកោះ ស្រែអូរ ចែ-ហួយ និងចាមល្មា ដើម្បីជាអនាគតអ្នកដឹកនាំខ្មែរថ្មី ។ ចំណែកអាវុធត្រូវលាក់ទុកមួយអន្លើសិន ...» ។

លុះដកអាវុធរួចស្រេចបាច់ហើយ យោធាទាំងអស់ក៏តម្រៀបជួរគ្នាចុះទូកធំៗសណ្ដោងដោយសារកាណូត ដែលអង្គការបញ្ជាឲ្យរៀបជាក្បួនរង់ចាំជាស្រេចតាមទន្លេ រួចដឹកនាំចេញទៅកាន់តីក្រុងបាត់ដំបងភ្លាម ។ រីឯមេៗកាន់ក្ដាប់យោធាក្មេងៗទាំង៤០០នាក់នោះ ដែលភាគច្រើនជាអតិតចោរព្រៃ ត្រូវបានអង្គការបញ្ជាឲ្យបំបែកចេញពីយោធា រួចដកអាវុធទុកមួយអន្លើសិន ហើយរង់ចាំស្ដាប់បញ្ជារបស់អង្គ-ការជាថ្មីដែរ ។

លុះក្បួនកាណូតសណ្ដោងទូកយោធាចាកចេញផុតពីព្រែកទាល់បានមួយម៉ោងហើយ អង្គការចេញបញ្ជាឲ្យបាញ់សម្លាប់មេៗយោធាទាំង៤០០នាក់នោះ រួចក៏ធាក់ទម្លាក់ទឹកទន្លេសាបជាចំណីត្រីទាំងអស់ ។

ចំណែកឯយោធាក្មេងៗ ដែលគេដឹកនាំយកទៅកាន់ទីក្រុងបាត់ដំបង ត្រូវគេយកទៅលត់ដំ ធ្វើទារុណកម្ម បង្ខំឲ្យធ្វើការទាំងយប់ទាំងថ្ងៃ ហាលក្ដៅ ហាលភ្លៀង គ្មានទីជំរក ដេកតែពាសវាល ហុតទឹកបបរជាមួយអំបិល ឈឺឥតថ្នាំព្យាបាល ។ អ្នកនៅសល់ពីស្លាប់ មានតែស្បែកដណ្ដប់ឆ្អឹង ។

ក្នុងចំណោមយោធាក្មេងៗទាំងនេះ បើមានអ្នកណាម្នាក់ហ៊ានផ្សងព្រេងរត់ចោលអង្គភាព មិនយូរប៉ុន្មានទេ អង្គការបញ្ជាឲ្យឃាតករតាមសម្លាប់ទាល់តែបាន ។

ឧទាហរណ៍មួយយ៉ាងជាក់ស្ដែងដែលខ្ញុំបានឃើញផ្ទាល់ភ្នែក ៖

★★★មានមិត្តនារីម្នាក់ឈ្មោះ កិច្ច, ឪពុកឈ្មោះ គឹម, ម្ដាយឈ្មោះប៉េស ។ មិត្តនារីនេះកើតនៅភូមិកាច់រទេះ, ឃុំកំពង់ព្រះ, ស្រុកសង្កែ, ខេត្តបាត់ដំបង ។ នៅឆ្នាំ១៩៧៣ មិត្តនារីកិច្ច មានអាយុ១៥ឆ្នាំ ។ នាងតែងតែដេញគោឲ្យស៊ីស្មៅនៅតាមព្រៃរនាម ស្ថិតនៅខាងកើតភូមិ ។ ថ្ងៃមួយ វៀតកុង (ប្រើឃីហោខ្មែរក្រហម) ចេញពីព្រៃមកប្លន់គោនាងអស់ រួចបំភ័យបន្លាចនាងតាមកលល្បិចផ្សេងៗ ធ្វើឲ្យនាងភ័យ

ខ្លាចមិនហ៊ានវិលត្រឡប់ទៅជួបម៉ែឪវិញទេ ។ ដូច្នេះខ្មែរក្រហមស្មើរជាយួនស្មើរជាចោរនេះ ក៏នាំនាងកិច្ចចូលព្រៃ រួចក៏បញ្ចូលនាងទៅក្នុងអង្គភាពយោធាក្មេងៗតាំងពីពេលនោះមក ។ ក្នុងឆ្នាំ១៩៧៨ មិត្តនារីកិច្ចក៏រៀបការជាមួយយោធាក្មេងៗដូចគ្នា ។ ពេលអង្គការប្រមូលយោធាក្មេងៗនាំយកទៅលត់ដំ ។ មិត្តនារីកិច្ចក៏នាំប្តីទៅជាមួយគេដែរ ។ នៅខែកុម្ភៈឆ្នាំ១៩៧៩ មិត្តនារីកិច្ចសំរាលបានកូនស្រីម្នាក់ ។ ដោយមិនអាចទ្រាំទ្រនឹងទារុណកម្មដ៏ធ្ងន់ធ្ងររបស់អង្គការបាន ពីរនាក់ប្តីប្រពន្ធក៏សំរេចចិត្តពរកូនខ្ចីអាយុ២ខែរត់ចេញពីអង្គភាព ទៅពួនជ្រកនៅជាមួយប្អូនស្រីបង្កើត ឈ្មោះកាយ ជាប្រជាជនថ្មី ។

នៅថ្ងៃ១៦-៤-៧៩ ម៉ោងប្រហែល១១ជិតអាធ្រាត មានក្រុមពិឃាតអាថ៌កំបាំងតាមរកឃើញគ្រួសារមិត្តកិច្ចក្នុងព្រៃរនាម ស្ថិតនៅខាងកើតភូមិជ្រៃ ស្រុកមោងឫស្សី ។ ក្រុមឃាតករដ៏ឃោរឃៅនេះក៏សម្លាប់ប្តីប្រពន្ធមិត្តកិច្ចនិងកូនខ្ចី ព្រមទាំងគ្រួសាររបស់ប្អូនមិត្តកិច្ចទាំងអស់គ្នា មានប្តីនាងកាយ, នាងកាយ, កូនប្រុសអាយុ២ឆ្នាំ ។ មិនតែប៉ុណ្ណោះ ឃាតករសម្លាប់ប្រជាជនថ្មីចំនួន៣០នាក់ទៀត ដោយចោទថាជាអ្នកស៊ុំគ្រលុំលាក់បំពួនគ្រួសារមិត្តកិច្ច ។

## ដំណាក់ការដែលត្រូវសម្លាប់អានិកជនយួន

ក្រោយពីដឹកជញ្ជូនយោធាក្មេងៗចេញផុតអស់ពីព្រៃកទាល់ និងបាញ់សម្លាប់មេៗយោធាចំនួនជាង៤០០នាក់នោះរួចហើយ ព្រលឹមស្អែកឡើង អង្គការហៅប្រជុំប្រជាជនដែលបានទៅជួយនេសាទត្រីទាំងអស់ រួចបញ្ជាឲ្យវិលត្រឡប់ទៅកាន់កងរៀងៗខ្លួនវិញចុះ ។

ក្រុមយុវជនជនមានគ្នា១៥នាក់ តំរៀបជួរគ្នាចុះកាណូតមួយ រួចបើកបរចេញទៅកាន់ទីក្រុងបាត់ដំបង ។ លុះបើកបរមកដល់ភូមិបាក់អង្រែក ពួកគេក្រឡេកឃើញចំការពោតមួយ ស្ថិតនៅខាងឆ្វេងដៃដ៏ធំល្វឹងល្វើយមានសភាពស្ងាត់ច្រៀប មានផ្លែល្មមកាច់មកស្ងោរហូបបាន ។ ពួកគេត្រេកអរណាស់ ក៏បើកកាណូតសំដៅចំការ ។ ស្រាប់តែគ្រប់គ្នាភ្ញាក់ញ័ររន្ធត់ តក់ស្លុត ដោយឃើញខ្មោចមួយគំនរធំ ដែលគេទើបសម្លាប់ថ្មីៗ មានស្រី ប្រុស ក្មេង ចាស់ ចំនួនប្រហែល៥០០នាក់ ។ ពេលនោះឃើញយាយម្នាក់ជាតិយួន អាយុប្រហែល៦៥ឆ្នាំ និងកុមារម្នាក់អាយុប្រហែល៨ឆ្នាំ នៅរស់សល់ពីគេសម្លាប់ តែអ្នកទាំងពីរមានរបួសជាទម្ងន់ ។ យាយយួនត្រ-

ដរនិយាយប្រាប់យុវជនជនថា ៖ «...ឃាតករដែលកុហកដឹកនាំយួនយកមកសម្លាប់នេះ មិនមែនខ្មែរក្រហមទេ !! គឺជាជាតិយួន វាមានគ្នាទាំងអស់២៥នាក់ មេធំរបស់វាឈ្មោះ ទីបាភុក » ។

ទីបាភុកបង្កប់ខ្លួនបំរើយួនហាណូយជាយូរឆ្នាំមកហើយ ! ថ្ងៃដែលមានអំពើឧក្រិដ្ឋកម្មនេះ យួនទាំងអស់នៅតំបន់បាក់ព្រា ទទួលបញ្ជាពីទីបាភុក ឲ្យនាំគ្នាមកប្រជុំនៅចំការពោតនេះ ។ លុះជួបជុំហើយ ស្រាប់តែឮសម្លេងគ្រាប់កាំភ្លើងស្រោចមកលើខ្លួនគាត់និងខ្មោចអស់ទាំងនេះ ចេញមកពីគ្រប់ទិស !! ។ ខ្លួនគាត់ត្រូវគ្រាប់កាំភ្លើងមីត្រៃយ៉ែត បាញ់ចំបាក់ភ្លៅសន្លប់បាត់ស្មារតី ទើបនឹងដឹងខ្លួនមុនពេលដែលពួកយុវជនជនទើបនឹងមកដល់ប៉ុណ្ណោះ ។

ក្រុមជនមិនហ៊ានកាច់ពោតនោះទេ ដោយអាណិតយាយយួនខ្លាំងពេក ក៏លើកបីគាត់ដាក់ទៅលើទូកមួយផ្សេងជាមួយក្មេងប្រុសនោះ រួចចងខ្សែសណ្តោងជាមួយកាណូតហើយក៏បរចាកចេញពីទីនោះសំដៅទៅទីក្រុងបាត់ដំបង ។

លុះបើកចាកចេញបីចំការពោតនោះបានចម្ងាយប្រហែល២គ.ម. ស្រាប់តែឃើញខ្មោចអណ្តែតពេញស្ទឹង ហូរតាមទឹកចុះទៅកាន់ទន្លេសាប ។

ក្រុមជនពិនិត្យយ៉ាងហ្មត់ចត់ទៅលើខ្មោចអណ្តែតទឹកនោះ គឺជាខ្មោចយួនទាំងអស់ ។ ក្រុមជនភ្ញាក់តក់ស្លុតម្តងទៀត សម្លឹងមុខគ្នា ។ ជនក៏បញ្ចេញយោបល់ថា ចុះបើអង្គការសម្លាប់យួន ចំណែកឯយើងបែជាជួយសង្គ្រោះទៅវិញ ! យើមិនកើតទេ... យើងត្រូវតែកាត់ខ្សែទូកចោលយាយយួននិងកុមារកំសត់ដេកថ្ងូរក្នុងទូកកណ្តាលថ្លុកឈាម នៅលើស្ទឹងនេះទៅចុះ... រួចហើយជនក៏កាត់ខ្សែទូកនោះទៅ ដើម្បីសន្តិសុខមួយគ្រាសិន ។

## ហេតុយ៉ាងដូចម្តេចបានជាអង្គការទើបតែនឹកឃើញសម្លាប់អនិកជនយួន?

បើខ្មែរយើងចេះតាមដាន ហើយស្គាល់នូវល្បិចកលរបស់អង្គការ យើងអាចរកឃើញចម្លើយចំពោះសំនួរនេះ ។ អង្គការមានគំរោងទុកមកជាយូរហើយ គឺមិនមែនចេះតែធ្វើតាមចិត្តនឹកឃើញភ្លាមៗនោះទេ ។ គោលដៅរបស់វាគឺជាល្បិចកលបង្វែងដាន បង្វិលខួរក្បាលខ្មែរ និងអន្តរជាតិឲ្យច្រឡំវីវក់ ។

មើលចុះក្នុងឆ្នាំ១៩៧៥ អង្គការបញ្ជាឲ្យឃាតករសម្លាប់ខ្មែរវីវក់ ។ ខ្មែរដែលមិន

ទាន់ដល់វេនស្លាប់រាប់លាននាក់ ត្រូវអង្គការដេញឲ្យចាកចោលទីលំនៅ បណ្តើរគ្រួសារដោយជើងទៅដេកពាសវាលពាសព្រៃ អត់បាយក្រហាយទឹក ។ល។

ផ្ទុយទៅវិញ នៅពេលជាមួយគ្នា អង្គការបែជាមានចិត្តសប្បុរសសណ្តោសប្រណីដល់អនិកជនយួនទៅវិញ... គួរឲ្យចម្លែកណាស់ ។

នៅទីក្រុងបាត់ដំបង ខាងជើងវត្តលាភ មានជំរំអនិកជនយួនមួយដែលមានយួនចំនួន៤,៦០០នាក់ ។

នៅល្ងាចថ្ងៃទី២៣-៤-៧៥ អង្គការចាត់តំណាងយ៉ាងស្វាត់បំផុតទៅខ្សឹបប្រាប់អ្នកទាំងនោះថា ៖ « ត្រូវនៅឲ្យស្ងៀមសិន ចាំទទួលបញ្ជាថ្មី » ។

- នៅដំណាច់ខែឧសភា១៩៧៥ ( ពីរខែក្រោយមក ) អង្គការបញ្ជាឲ្យប្រមូលអនិកជនយួន ដែលសំណាក់នៅលើទូកតាមបណ្តោយដងស្ទឹងសង្កែ និងអនិកជនយួនដែលមានទីលំនៅនៅភូមិខ្សាច់ពោយ ប្រមូលគ្នាទាំងអស់បានចំនួន១១ម៉ឺន៥០០នាក់ ។

- ក្បួនកាណូតលើកទី១នេះ រៀបតាមដងស្ទឹងសង្កែ ត្រង់ភូមិខ្វិត ឃុំព្រែកខ្ពប រួចដឹកជញ្ជូនយួនទាំងអស់នោះទៅកាន់ប្រទេសវៀតណាម ។ នៅក្នុងក្បួននេះ មានយាយយួនម្នាក់ឈ្មោះ ទ្បេ-ធីប៊ិញ បានវិលត្រឡប់មកកាន់អតិតជំរំរបស់គាត់វិញ គឺអតិតជំរំអនិកជនយួនក្បែរវត្តលាភក្នុងឆ្នាំ១៩៧៩ ដើម្បីមកគាស់ដីរកមាសពេជ្រ ដែលគាត់បានលាក់កប់នៅទីនោះ ។

- នៅក្នុងខែកក្កដា១៩៧៥ មានក្បួនកាណូតសណ្តោងទូកធំៗជាលើកទី២ ។ ក្បួននេះបើកបរចេញពីភូមិខ្វិត ឃុំព្រែកខ្ពប តាមដងស្ទឹងសង្កែដដែល មានអនិកជនយួនចំនួន៥ពាន់នាក់ ប្រមូលមកពីស្រុកព្រះនេត្រព្រះ ស៊ីសុផុន មង្គលបូរី និងថ្មគោល ។ នៅក្នុងក្បួនកាណូតលើកនេះ មានស្ត្រីខ្មែរម្នាក់ឈ្មោះ ណាត់ មានប្តីជាតិយួន បានវិលត្រឡប់មកកាន់ស្រុកខ្មែរវិញ នៅដើមឆ្នាំ១៩៨០ ។

- នៅក្នុងខែកញ្ញា១៩៧៥ មានក្បួនកាណូតសណ្តោងទូកធំៗជាលើកទី៣ ។ ក្បួននេះបើកបរចេញពីភូមិខ្វិត ឃុំព្រែកខ្ពប តាមដងស្ទឹងសង្កែដដែល មានអនិកជនយួនចំនួន៧ពាន់នាក់ ប្រមូលមកពីស្រុកក្បាលគោល ទួលព្រំ តាលាស់ កំពង់ព្រះ និងខុំវាំងកេសី ។ នៅក្នុងក្បួនកាណូតលើកនេះ មានខ្មែរបន្លំធ្វើជាយួននៅជាមួយខ្លះៗ ។ មានស្ត្រីយួនម្នាក់ឈ្មោះ ង្វៀង-ធីឡាញ និងខ្មែរម្នាក់ឈ្មោះយាយសាខុន ដែលមានប្តីជាតិយួន បានវិលត្រឡប់មកកាន់ប្រទេសខ្មែរវិញក្នុងឆ្នាំ១៩-៨០ ។

- នៅក្នុងទីក្រុងភ្នំពេញ ថ្ងៃ១៨-៤-៧៥ អង្គការចិត្តឃោរឃៅដេញប្រជាជនទាំង៣លាននាក់ ឲ្យថយចេញចម្ងាយ២០គ.ម.ពីទីលំនៅ ។ ឆ្លៀតពេលចលាចល នេះ

អង្គការជញ្ជូននាយទាហានវៀតកុងមកភ្នំពេញវិញ ។ វាដើរប្រមូលអនិកជនយួនដោយស្ងាត់ៗ ដាក់តាមក្រុមៗ មានច្រើនម៉ឺននាក់ ហើយខ្សឹបខ្សៀវឲ្យសម្ងំនៅស្ងៀមតាមកន្លែងសិនចាំស្តាប់បញ្ជាថ្មី ។

- ក្នុងខែមិថុនា១៩៧៥ ស្រាប់តែឃើញឡានធំៗគ្រប់ចុនយ៉ាងច្រើន តំរៀបជួរជាក្បួន ហើយដឹកពួកអនិកជនយួនទាំងឡាយនោះចេញពីភ្នំពេញតាមផ្លូវជាតិលេខ១ ឆ្លងព្រែកអ្នកលឿងនាំចេញទៅកាន់ប្រទេសវៀតណាម ។

- នៅថ្ងៃទី៣០-៦-៧៥ នាយទាហានវៀតកុងចូលមកស្រុកចំការលើ ជួបផ្ទាល់ខ្មែរក្រហម សុំប្រមូលអនិកជនយួនចំនួន៥ពាន់នាក់ នាំចេញទៅកាន់ប្រទេសវៀតណាម ។

- ក្នុងខែកក្កដា១៩៧៥ មានគណប្រតិភូវៀតកុងចូលមកភូមិតាខ្មៅ ចេញបញ្ជាឲ្យខ្មែរក្រហមប្រមូលអនិកជនយួនឲ្យវា ។ គណប្រតិភូវៀតកុងនេះនិយាយទៅកាន់ខ្មែរក្រហមថា ៖ ជនជាតិវៀតណាមដែលនៅក្នុងស្រុកខ្មែរ អាចមានលទ្ធភាពនឹងធ្វើមាតុភូមិនិវត្តន៍ទៅមាតុប្រទេសរបស់គេវិញ ។ ស្នែកឡើងទូកធំៗសណ្តោងដោយកាណូត តម្រៀបជាក្បួនតាមដងស្ទឹងតាខ្មៅ ផ្ទុកយួនចំនួន១ម៉ឺន៥ពាន់នាក់ នាំចេញទៅកាន់ប្រទេសវៀតណាម ។

- ក្នុងខែវិច្ឆិកា១៩៧៥ នៅភូមិក្រូចឆ្មា អង្គការអនុញ្ញាតឲ្យអនិកជនយួនជាច្រើនពាន់នាក់ ធ្វើមាតុភូមិនិវត្តន៍ដោយសេរី ។

- ថ្ងៃទី៣០-១១-៧៥ នៅតាមបណ្តោយព្រំដែនខ្មែរ-យួន មាននាយទាហានវៀតកុងចូលមកកាន់ដីខ្មែរ រួចចេញបញ្ជាក្នុងនាមអង្គការ ឲ្យខ្មែរក្រហមប្រមូលអនិកជនយួនឲ្យវា ។ វានិយាយដដែលថា ៖ ជនជាតិយួនដែលនៅស្រុកខ្មែរ អាចមានលទ្ធភាពនឹងធ្វើមាតុភូមិនិវត្តន៍ទៅមាតុប្រទេសរបស់គេវិញ ។ ពេលនោះខ្មែរក្រហមស្តាប់បង្គាប់យួន វាដើរប្រមូលអនិកជនយួនជាច្រើនម៉ឺននាក់ ប្រគល់ឲ្យនាយទាហានវៀតកុង ។ នាយទាហានវៀតកុងបណ្តើរអនិកជនយួនដោយថ្មើរជើងទៅកាន់ប្រទេសវៀតណាម ។

- នៅដើមឆ្នាំ១៩៧៧ នាយទាហានវៀតកុងចូលមកកាន់ភូមិម៉ាឡៃ ក្នុងខេត្តតាកែវ បានចេញបញ្ជាដាច់ណាត់ក្នុងនាមអង្គការបង្ខំឲ្យខ្មែរក្រហមស្រាវជ្រាវរកយុវជនយួន ដែលច្រឡំបល់ក្នុងកងចល័ត ត្រូវនាំមកប្រគល់ឲ្យវាវិញ ។ ខ្មែរក្រហមរកបានយុវជនយួនចំនួន១៧នាក់ ដែលមានអាយុពី១០ទៅ១៣ឆ្នាំ លើកលែងតែយុវជនម្នាក់ឈ្មោះ ប៊ូ-ថាញ់មិញ ចេញ ដែលមានអាយុ២៣ឆ្នាំ ។

ពេលឃើញអង្គការដឹកជញ្ជូនយួនយ៉ាងនេះ ខ្មែរដែលធ្លាប់តែមានចិត្តមេត្តាករុណាគ្រប់គ្រាន់ ក៏សំរក់ទឹកភ្នែកអាណិតអនិកជនយួន ដោយយល់ច្រឡំថាអង្គការ

យកពួកនេះទៅសម្លាប់ហើយ ។ គឺព្រោះតែការយល់ច្រឡំថាអង្គការយកទៅសម្លាប់នេះហើយ បានជាប្រទេសខ្មែរត្រូវវលាយអស់៣លាននាក់ !? ។ តាមសេចក្ដីរាយការណ៍ពីអ្នកស្រីណាត់, ពីយាយយួនឡេ-ធីប៉ិញ, ពីអ្នកស្រីយួនង្វៀង-ធីឡាញ និងបីយាយសុខុន ដែលនាំគ្រួសារភៀសខ្លួនទៅតាមក្បូនទូក ឆ្ពោះទៅប្រទេសវៀតណាមទាំងបីលើកនោះថា ៖ អង្គការបញ្ជាឲ្យខ្មែរក្រហមផ្ទុកស្បៀងដាក់ក្បូនទូកឲ្យបានគ្រប់គ្រាន់ មានអង្ករ, អំបិល និងម្ហូប ទៅតាមចំនួនមនុស្ស និងតាមរយៈពេលដែលត្រូវធ្វើដំណើរ ។ មិនតែប៉ុណ្ណោះ ខ្មែរក្រហមត្រូវតែជូនដំណើរក្បូនទូកទាំង៣លើកនោះ រហូតដល់កោះទៀវ ។ វៀតកុងត្រៀមក្បូនកាណូតសណ្ដោងទូកធំៗនៅទីនោះរួចជាស្រេច ។ ដូច្នេះកិច្ចការជន្លៀសអនិកជនយួនចេញពីស្រុកខ្មែរពុំមែនជារឿងចៃដន្យទេ ! គឺអង្គការមានគំរោងការណ៍រួចជាស្រេច ដើម្បីធ្វើអ្វីនិមួយៗ ទៅតាមដំណាក់ការរបស់វា ( ឥឡូវត្រូវធ្វើនេះ រួចហើយត្រូវធ្វើនោះទៅទៀត)

ពីខេត្តបាត់ដំបងទៅកោះទៀវមានចម្ងាយឆ្ងាយសែនឆ្ងាយ ។ នៅខែមករាឆ្នាំ១៩៨១ នៅជំរំឈុនបុរីនៃប្រទេសថៃ យាយទៀងបានជួបយាយសុខុន ។ យាយសុខុនបានរៀបរាប់ប្រាប់យាយទៀងថា ៖ គាត់មានទីលំនៅនៅឃុំទួលព្រុំ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ គាត់មានប្ដីជាតិយួន ។ នៅយប់មួយនៃខែកញ្ញាឆ្នាំ១៩៧៥ អនិកជនយួននៅឃុំទួលព្រុំ កំពុងតម្រៀបជួរគ្នាឡើងឡាន ដែលអង្គការរៀបចំជន្លៀសចេញទៅកាន់ភូមិខ្ទិត ។

នៅពេលនោះស្រាប់តែឃើញយុវជនឃឺ-ទ្រីគិមវណ្ណៈជាកូនច្បងរបស់យាយទៀងរត់មកឡើងឡានអង្គុយទន្ទឹមនឹងគាត់ ។ វណ្ណៈជាអនុសេនិយទោ ឱនខ្សឹបប្រាប់គាត់ថា ខ្មែរក្រហមតាមរកចាប់ខ្លួនដោយចោទថាគេជាទាហាន ។ មានហេតុកើតឡើងជាចៃដន្យយ៉ាងនេះ គាត់ក៏សំរេចចិត្តទទួលវណ្ណៈថាជាកូនច្បងរបស់គាត់...។

គ្រួសារយាយសុខុនត្រូវគេដឹកតាមទូកទៅដល់កោះទៀវ ។ ពេលទៅដល់ទីដៅមុននឹងឡើងលើទូកវៀតកុង ពួកវាបានធ្វើការពិសោធន៍ចំណេះភាសាយួនទៅលើអនិកជនម្ដងម្នាក់ៗ ។ ដល់វេនគ្រួសារយាយសុខុន ! ឱពុទ្ធោអើយ ! វណ្ណៈមិនចេះយួនមួយម៉ាត់សោះ វៀតកុងបដិសេធមិនទទួល ។ ពេលនោះយាយសុខុនខំតវ៉ាយ៉ាងសន្ធឹកណាស់ វិះតែនឹងត្រូវវៀតកុងដេញគ្រួសារវាឲ្យចុះពីទូកវាវិញ ។ និ-យាយមកដល់ត្រឹមនេះ យាយសុខុនឱបយាយទៀងហើយត្អូញថា « ស្ដាយណាស់មិនដឹងជាវាសនារបស់វណ្ណៈនឹងក្លាយទៅជាយ៉ាងណាហើយទេ » ។

ប្រជាជនខ្មែរដែលបានភៀសខ្លួនទៅកាន់ប្រទេសវៀតណាម លុះដល់ឆ្នាំ១៩-៧៩-៨០ បានវិលត្រឡប់មកកាន់ប្រទេសខ្មែរវិញ ក៏និយាយរែកញែកថា ៖

★★★ តាមជើងទឹក ៖

- គួរឲ្យឆ្ងល់ជាក្រៃលែង ព្រោះពេលក្បួនកាណូតសណ្តោងទូកធំៗទាំងសង ខាងបានជួបគ្នា (ក្បួនពីស្រុកខ្មែរ-ក្បួនវៀតកុង), វៀតកុងឈរច្រត់ចង្កេះត្រួតនិង ចេញបញ្ជាទៅខ្មែរក្រហម ដោយមើលងាយជាងខ្ញុំកញ្ជះវាទៅទៀត ឲ្យខ្មែរក្រហម លើកបាវអង្ករពីទូកខ្មែរទៅដាក់ក្នុងទូកវា ។

★★★ តាមជើងគោក ៖

- ប៉ូយ-គឹមឡុងបាននិយាយរែកញែកថា គេឆ្ងល់សែនឆ្ងល់ដោយធ្លាប់បាន ឃើញផ្ទាល់ភ្នែក នូវអំពើកាចសាហាវរបស់ខ្មែរក្រហម ដែលលោតចាក់សម្លាប់ប្រ ជាជនខ្មែរគ្នាឯងដូចភ្នំភ្លើង តែនៅពេលដែលពួកខ្មែរក្រហមទទួលបញ្ជាពីនាយទា ហានវៀតកុង ឲ្យចូនពួកយុវជនយួនទាំង១៧នាក់ទៅកាន់ភូមិម៉ាឡៃនៅប្រទេសយួន ខ្មែរក្រហមទាំងនោះរត់ខ្វែងដៃខ្វែងជើងរកអង្កររកម្ហូប រួចហើយរែកជូនដំណើរ ពួកវៀតកុង ។ លុះទៅដល់ព្រំដែនខ្មែរ-យួន វៀតកុងចេញបញ្ជាបង្ខំឲ្យខ្មែរក្រហម អស់តាំងនោះកប់អាវុធលាក់ទុកក្នុងដីខ្មែរសិន ដើម្បីរែកអង្ករជូនដំណើរពួកវាចូល ទៅកាន់ប្រទេសយួន ។ ហេតុអ្វីបានជាចាំលាក់កប់អាវុធ រួចទើបចូលស្រុកយួន បាន ? ឬមួយយួនខ្លាចខ្មែរក្រហមតដៃ ? ឬមួយលោកបងយួនខ្លាចលោកប្អូនខ្មែរ ក្រហមហត់ដោយលីកាំភ្លើងផង ខំរែកអង្ករផង ? ។

ចំណែកឯរឿងសម្លាប់អនិកជនយួននៅខែមេសា១៩៧៨ និងសម្លាប់ជាបន្តប ន្ទាប់មកទៀតនោះ គឺជាគំរោងការណ៍របស់អង្គការលើទេតើ ! អង្គការយល់ថា អនិ កជនយួនដែលមិនព្រមទៅតាមវៀតកុងនោះ គឺជាយួនចោលម្សៀត (យួនស្រឡា ញ់ខ្មែរ) បើរក្សាទុកក៏វាមិនចំណេញ ហើយបើសម្លាប់ចោលវាអាចមានប្រយោជន៍ ច្រើន ៖

១- អាចបំភ័ន្តមតិខ្មែរខ្លះឲ្យយល់ថា អង្គការសម្លាប់ទាំងខ្មែរ សម្លាប់ទាំងយួន ។

២- នៅឯហាណូយ វាតាំងស្រែកជេរប្រាប់គេឯងថា ខ្មែរក្រហមសម្លាប់យួន ឧទាហរណ៍នៅក្នុងខែកក្កដា១៩៨២នេះ ពួកទាហានក្រុមខ្មែរក្រហមអាយ៉ង ចាប់ ផ្តើមសម្លាប់អនិកជនយួន រួចហើយស្រែកថា ខ្មែរក្រហមៗ ! ធ្វើដូច្នេះ ហាណូយ អាចនឹងបញ្ជូនបួដួយមកលុកលុយស្រុកខ្មែរតាមផ្លូវច្បាប់ទៀត ។

៣- ដើម្បីនឹងសម្លាប់ខ្មែរកម្ពុជាក្រោម ដែលរត់មកជ្រកកោននៅកម្ពុជាកណ្តាល អង្គការធ្វើជាច្រឡំសម្លាប់ទាំងក្មេងទាំងចាស់ រួចស្រែកចោទថា ពួកនេះជាពួក យួន ឬជាខ្មែរបណ្តាញរបស់យួន ។

នេះហើយជាកលល្បិចរបស់យួនដើម្បីបំបាត់ពូជខ្មែរឲ្យឆាប់អស់ ។ ស្នៀតរប ស់វាតែងតែកេងប្រវ័ញ្ចលើខ្មែរជានិច្ច ។

នេះហើយជាកលល្បិចរបស់យួនដើម្បីបំបាត់ពូជខ្មែរឲ្យឆាប់អស់ ។ ស្នៀតរបស់

វាតែងតែកេងប្រវ័ញ្ចលើខ្មែរជានិច្ច ។

ដូច្នេះបើយើងលើកយកព្រឹត្តិការណ៍នានា ដូចបានអត្ថាធិប្បាយខាងលើនេះ មកត្រិះរិះពិចារណា យើងអាចយល់បានថា ៖

អ្នកដឹកនាំខ្មែរគ្រប់ៗនិន្នាការគ្មានសមត្ថភាពអ្វីទាំងអស់ ទ្វេសប្រហែសបណ្តោយខ្លួនឲ្យចាញ់បោកយួន ចាញ់បោកចិនយ៉ាងធ្ងន់ជាងធ្ងន់ ! ។

## សម្លាប់យុវជនចល័តដើម្បីបំបាត់ភស្តុតាង

ក្នុងខែកញ្ញា១៩៧៧ ក្នុងពេលកំពុងចលាចលសម្លាប់ខ្មែរក្រហម ដែលមាននិន្នាការខ្មែររឹរក់ ស្រាប់តែមានគណកម្មាធិការជាន់ខ្ពស់ចំនួន១២នាក់ ចុះមកពីអង្គការលើដើរត្រួតពិនិត្យនូវកិច្ចការផ្សេងៗ ដែលប្រជាជនកំពុងបញ្ចេញពលិកម្មរួមនៅភូមិកង្កត ។

នៅពេលដែលកំពុងពិនិត្យការងារធ្វើទំនប់ទឹករបស់ក្រុមចល័តដាច់ខាតចំនួន៥០នាក់ មានបុរសមានមាឌតូចល្អិតចេញមុខមកសួរពត៌មានផ្សេងៗផ្ទាល់ពីពួកចល័ត ។ ពេលនោះមានខ្យល់បក់មកយ៉ាងខ្លាំង បណ្តាលឲ្យជ្រុះមួកពីក្បាលបុរស នោះញាំងឲ្យយុវជនទាំងអស់ភ្ញាក់ ដោយឃើញមុខបុរសនោះជាយួន ក៏លាន់មាត់តិចៗថា ៖ ឱយួនទេតើ ! ។ល។

ពេលយប់មកដល់ មានឃាតករអាថ៌កំបាំងមួយក្រុមយ៉ាងច្រើន កាន់អាវុធគ្រប់ដៃ ចេញមកព័ទ្ធផ្ទះក្បឿងមួយខ្នងបីល្វែង ស្ថិតនៅជាប់ខាងត្បូងមាត់ស្ទឹងកង្កតដែលមានយុវជនចល័តទាំង៥០នាក់នោះសំណាក់នៅ ។ ពួកឃាតករចាប់ចងយុវជនបាន៤៩នាក់ហើយយកទៅសម្លាប់ចោលទាំងអស់ ។ យុវជនរុំ មានភ័ព្វវាសនាបានគេចខ្លួននៅពេលនោះ ហើយបានអះអាងប្រាប់យាយទៀងដោយផ្ទាល់មាត់ពីរឿងនេះនៅក្នុងខែធ្នូ១៩៨៥ នៅទីក្រុងប៉ារីស៍ ។

ក្នុងខែកុម្ភៈឆ្នាំ១៩៧៨ មានយុវជនចល័តដាច់ខាតមួយក្រុមចំនួន២០០នាក់ កំពុងបុកបែនស្រូវនៅស្រែវាលទ្រា ។ ស្រាប់តែមានគណកម្មាធិការជាន់ខ្ពស់ចំនួន១៤នាក់ ចុះមកពីអង្គការលើដើរត្រួតពិនិត្យស្រូវ ។

នៅពេលនោះ មនុស្ស៣នាក់ដើរមកសាកសួរផ្ទាល់មាត់ចល័តអំពីលទ្ធផលស្រូវ។ យុវជនទាំងនោះក៏លាន់មាត់ដូចគ្នាថា ៖ យួនទេតើ! ។ នៅពេលយប់មកដល់ ពួកយុវជនកងចល័តទាំងនោះត្រូវគេព័ទ្ធចាប់យកទៅសម្លាប់ចោលទាំងអស់លើកលែងតែយុវជនម្នាក់ឈ្មោះ ថ ដែលបានរត់គេចរួច ហើយបានជួបប្រាប់យាយទៀងអំពីរឿងនេះដោយផ្ទាល់មាត់ នៅក្រោយវត្តរំដួល ក្រុងបាត់ដំបង នៅខែឧសភាឆ្នាំ១៩៧៩ ។

# កលល្បិចសម្លាប់ខ្មែរមួយបែបទៀត

នៅពេលដែលអង្គការចូលមកលុកលុយប្រទេសខ្មែរភ្លាម អង្គការចេញបញ្ជាឲ្យប្រមូលអតីតជើងឈ្នួលទាំងអស់ ដើម្បីបង្កើតជាឃាតករពិសេស បំពាក់អាវុធឲ្យភ្លាម រួចហើយញុះញង់ឲ្យបាញ់សម្លាប់អតីតចៅហ្វាយនាយ ។ ដូច្នេះខ្មែរជាច្រើនក៏ត្រូវស្លាប់ដោយសារកលល្បិចនេះ ។ ឧទាហរណ៍គ្រួសាររបស់យាយទៀង ៖

នៅថ្ងៃទី២៤-៤-៧៥ យាយទៀងនិងស្វាមីនិងកូនប្រាំនាក់ចាកចេញពីទីលំនៅសំដៅទៅមាត់ព្រៃនាម ខាងកើតភូមិកាច់រទេះ ក្នុងកងបឹងធំ សហករណ៍ព្រៃតូចតំបន់៤ ខេត្តបាត់ដំបង ។ យាយទៀងនាំអ្នកបំរើប្រុសម្នាក់ឈ្មោះ សារួន អាយុ១៣ឆ្នាំយកទៅជាមួយ ។

ខែកក្កដាឆ្នាំ១៩៧៥ អង្គការចេញបញ្ជាឲ្យបំបែកសារួនចេញពីគ្រួសាររបស់យាយទៀង បំពាក់អាវុធឲ្យ រួចក៏បញ្ចូលក្នុងក្រុមឃាតករពិសេស ។ ក្រុមនេះជាក្រុមអតីតអ្នកបំរើ ដែលត្រូវគេញុះញង់ឲ្យហក់លោតសម្លាប់អតីតចៅហ្វាយ ។

យប់ថ្ងៃទី៣-១០-៧៥ សារួននាំមិត្តមួយក្រុមកាន់អាវុធគ្រប់ដៃ ជាឃាតករសម្លាប់ចៅហ្វាយរៀងៗខ្លួនរួចហើយ មកកាន់ខ្ទមយាយទៀង ។ សារួននិយាយទៅមិត្តៗរបស់គេ ព្រមទាំងលើកដៃចង្អុលទៅយាយតាហើយនិយាយថា ៖ « សូមបង្ហាញមិត្តៗឲ្យស្គាល់ នេះយាយទៀង តាទ្រី សូមមិត្តៗទាំងអស់ជួយការពារយាយតារបស់ខ្ញុំផង ! » ។ និយាយបានតែត្រឹមហ្នឹង សារួនក៏លាយាយតាបណ្ដើរមិត្តៗត្រឡប់ទៅវិញ ។ ចំណែកឯក្រុមឃាតករពិសេស ទៅជាស្រឡាំងកាំង ក៏បើកភ្នែកធំៗសម្លឹងមើលមុខគ្នា ព្រោះស្មានតែសារួននាំពួកគេឲ្យមកជួយសម្លាប់ ! ។ កំពុងតែឆ្ងល់យ៉ាងនេះ សារួនក៏បន្លឺសម្លេងឡើងថា ៖ « ម្ដាយរបស់ខ្ញុំឈ្មោះអាអួនអាយុបាន១០ឆ្នាំ ជីដូនខ្ញុំនាំយកមកឲ្យនៅបំរើយាយទៀង ជាថ្នូរនឹងប្រាក់កាសដែលគាត់ត្រូវការ ។ យាយទៀងទំនុកបំរុងថែទាំម្ដាយខ្ញុំដូចកូនបង្កើត ។ បានអាយុ២០ឆ្នាំ គាត់រៀបចំផ្សំផ្គុំម្ដាយខ្ញុំនិងឪពុកខ្ញុំ ។ ខ្ញុំកើតមកបានអាយុ១០ឆ្នាំ ក៏ស្ម័គ្រចិត្តមករស់នៅជាមួយគាត់ដូចជាយាយនិងតារបស់ខ្ញុំបង្កើត ។ អ្នកទាំងពីរនេះទំនុកបំរុងបង្ហាត់បង្រៀនខ្ញុំឲ្យចេះមើលសរសេរអក្សរ ។ល។ គឺព្រោះតែហេតុនេះហើយបានជាខ្ញុំលើកដៃសម្លាប់គាត់មិនរួចទេ ! » ។

រឿងសារួនដែលជាអតិតអ្នកបំរើមិនបានសម្លាប់ចៅហ្វាយ ញាំងឲ្យគណកម្មាធិការកងបឹងធំទាំងមូលផ្ទាក់ផ្អើល បើកអង្គប្រជុំជាសម្ងាត់មួយរំពេច ។ នៅទីប្រជុំ

គេឃើញមានមិត្តឡាំ ជាប្រធាន, មិត្តទិត, មិត្តឃិន និងមិត្តហៀក ។ អ្នកទាំងបួននាក់នេះជាអតិតចោរព្រៃធ្លាប់រស់នៅតែក្នុងព្រៃរនាម ។ ឥឡូវនេះអង្គការចាត់តែងតាំងជាគណកម្មាធិការកងជាឈ្លប ហើយជាពិសេសជាតំណាងរបស់អង្គការ ។ ក្រុមនេះហៅសារួនមកសួររកហេតុផល ។ មិត្តឡាំបញ្ជាឲ្យសារួនថ្លែងការស្មោះត្រង់ ។

សារួនក៏ចាប់អត្ថាធិប្បាយជាហូរហែ រួចក៏បញ្ចប់សេចក្តីថា ៖ ទោះបីហូបបាយទឹកក៏ខ្ញុំហូបរួមជាមួយយាយតាដែរ ។ ខ្ញុំហៅគាត់ទាំងពីរជាយាយតា តាំងតែពីតូចមក ។

មិត្តឡាំបញ្ជាឲ្យសារួនថ្លែងបន្ថែមពីជីវប្រវត្តិរបស់ខ្លួនឲ្យច្បាស់លាស់ ។ លុះថ្លែងចប់... មិត្តទិតក៏បន្លឺឡើងដោយភ្ញាក់ថា ៖ អាហ៎ ! បើអីចឹងមិត្តឯងជាកូនអាអួននៅភូមិព្រៃតូចនោះឬ ? សារួនបែភ្នែកសម្លឹងមិត្តទិតបន្តិច រួចឆ្លើយថា ៖ បាទ ! ។

មិត្តទិតយកដៃអង្អែលក្បាលសារួន រួចក៏សុំបញ្ចេញយោបល់ក្នុងអង្គប្រជុំថា ការដែលសារួនមិនបានសម្លាប់មិត្តទ្រីនិងយាយទៀងនេះ ជាការសមរម្យណាស់។ ខ្ញុំស្គាល់មិត្តទ្រីច្បាស់លាស់ ហើយដែលនៅរស់ដល់សព្វថ្ងៃនេះ ក៏ដោយសារតែសប្បុរសធម៌របស់មិត្តទ្រី ។ មិត្តទិតរ៉ាយរ៉ាប់ទៀតថា ៖ នៅឆ្នាំ១៩៦៥ ខ្ញុំមានអាយុ២៥ឆ្នាំ ហើយបំរើបក្សក្នុងព្រៃរនាម ។ នៅពេលមួយនោះ ដោយសារពោះវៀនដុះខ្នែង ខ្ញុំឈឺចុកចាប់ក្នុងពោះយ៉ាងខ្លាំងសឹងដាច់ដង្ហើម ។ មិត្តខ្លះៗក៏ដឹកខ្ញុំយកមកនៅផ្ទះកំណើតនៅឯព្រៃតូច ។ អាអួនជាម្តាយរបស់សារួន ហើយដែលត្រូវជាបងជីដូនមួយរបស់ខ្ញុំ ក៏ឡើងឡានឈ្នួលជាប្រញាប់សំដៅទៅកាន់ពេទ្យធំឯទីក្រុងបាត់ដំបងសុំពឹងមិត្តទ្រី ។ មិត្តទ្រីក៏បើកឡានផ្ទាល់ខ្លួនមកដឹកខ្ញុំយកទៅកាន់មន្ទីរពេទ្យធំភ្លាម ។ វេជ្ជបណ្ឌិតក៏សំរេចវះកាត់យកខ្នាយនោះចេញទៅ ។ លុះជាស្រួលបួលហើយកាលណា មិត្តទ្រីក៏ដឹកខ្ញុំមកផ្ទះនៅភូមិព្រៃតូចវិញ ។ មិនតែប៉ុណ្ណោះសោត គាត់ឲ្យប្រាក់ខ្ញុំចំនួន២០០០រៀលជាមួយខោអាវដែលខ្ញុំពាក់ជាប់នឹងខ្លួននេះ ។ មិត្តទិតនិយាយបណ្តើរលាត់អាវបណ្តើរដើម្បីបង្ហាញស្លាកស្នាមនៅនឹងពោះទៅអង្គប្រជុំ ។ ពេលនោះមិត្តឡាំដែលកំពុងដែលកំពុងស្រេកឈាម បើកភ្នែកក្រហមត្លែ បែសម្លឹងមុខឃាតករពីរនាក់ទៀតគឺ មិត្តឃិន និងមិត្តហៀក ដើម្បីសួរយោបល់ ។

មិត្តឃិនបែមុខគេចចេញពីភ្នែកមិត្តប្រធានឡាំ សម្លឹងព្រៃរនាមមួយសន្ទុះធំទើបរកពាក្យឃើញឆ្លើយទាំងរដឹបរដុបថា ៖ ពេទ្យទ្រីមានចិត្តសប្បុរសណាស់ ។ ក្នុងពេលមានសង្គ្រាម ខ្ញុំនៅតែក្នុងព្រៃរនាមទេ ។ នៅពេលដែលគ្រួសាររបស់ខ្ញុំ ឈឺមិត្តទ្រីតែងតែជួយព្យាបាលជានិច្ច ។ ពេលនោះមិត្តហៀកសម្លឹងមុខមិត្តឃិនយ៉ាងក្តៅក្រហាយជាទីបំផុត រួចលាន់មាត់ថា ៖ ហ៊ិះ ! ។ រួចហើយនៅស្ងៀម ។

កាលៈទេសៈនោះ មិត្តទាំងបួននាក់នេះកំពុងជក់ដៃសម្លាប់ប្រជាជនថ្មីក្នុងកងបឹង

ធំយ៉ាងវិវក់ ។ ចំណែកឯតាទ្រីនិងយាយទៀងវិញបានរួចខ្លួនមួយគ្រាដោយសារសារួន ។ ពេលអង្គការបញ្ជាឲ្យប្រមូលឃោធាក្មេងៗយកទៅលត់ជំឲ្យស្លាប់ យុវជនសារួនបានត្រូវទទួលទារុណកម្មនឹងគេដែរ ។ ពេលយួនចូលមករាតត្បាតប្រទេសខ្មែរ វាបើកបរឡានទៅប្រមូលក្រុមសារួនដែលសេសសល់នៅរស់ នាំយកទៅបំពាក់អាវុធឲ្យ រួចបញ្ចូលក្នុងកងកម្លាំងបដិវត្តន៍កម្ពុជា...។

ឆ្លៀតឱកាសដ៏ល្អនេះ សារួនព្យាយាមដើរសួររកយាយទៀង ។ សារួនបានជួបយាយទៀងនៅថ្ងៃទី៣-៣-៨០ នៅក្រោយវត្តរំដួលនៃទីក្រុងបាត់ដំបង ។ យុវជនសារួនសំរក់ទឹកភ្នែកអាណិតយាយទៀងរបស់វាណាស់ ព្រមទាំងយំសោកស្តាយ តាដែលមិនអាចគេចចាកពីការសម្លាប់របស់អង្គការបាន ។

បាយល្ងាចរួចហើយ សារួនឱបរួចសំពះលាយាយទៀងចាកចោលទឹកដីកម្ពុជាទៅកាន់ប្រទេសថៃ ដើម្បីគេចមិនបំរើយួនតទៅទៀត ។

❏ ❏

❏

## ~ ភាគ២ ~

### តើទ្រព្យសម្បត្តិពេញស្រុកខ្មែរទៅណាអស់ ? កលល្បិចឃ្លួនហាណូយសម្លាប់កំចាយខ្មែរ នៅកម្ពុជាក្រោម !

## ជំពូកទី១៥

★ ដំណាក់ការដែលត្រូវសម្លាប់ខ្មែរក្រហមនិន្នាការខ្មែរ
★ ដំណាក់ការដែលត្រូវសម្លាប់កម្មាភិបាលជាន់ខ្ពស់បក្សខ្មែរក្រហមនិន្នាការខ្មែរ
★ ដំណាក់ការដែលត្រូវសម្លាប់គណរដ្ឋមន្ត្រីនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ
★ នរណាបង្កើតគុកទួលស្លែង

# ដំណាក់ការដែលត្រូវសម្លាប់ខ្មែរក្រហមនិន្នាការខ្មែរ

ក្នុងរយៈពេល២៧ខែអង្គការច្រានក្បាលខ្មែរក្រហមនិន្នាការខ្មែរនិងខ្ញីដៃឲ្យស-ម្លាប់គ្នាឯងយ៉ាងវក់វី ញ៉ាំងឲ្យខ្មែរដែលមិនទាន់ដល់វេនស្លាប់ ខ្លាចបាក់ស្បាត ឈប់

ចេះនិយាយ ឈប់ចេះសើច ឈប់ចេះយំ ខំប្រឹងតែអួសនង្គ័ល រនាស់ ជំនួស គោក្របី កណ្ដាលភ្លៀង កណ្ដាលផ្គរ កណ្ដាលថ្ងៃក្ដៅស្ទើរឆេះ...។

ស្រាប់តែនៅល្ងាចមួយនោះ មានក្រុមឃាតករអាថ៌កំបាំងយ៉ាងច្រើនលើសលប់ចេញមកព័ទ្ធបាញ់សម្លាប់ពួកខ្មែរក្រហមនិន្នាការខ្មែរក្រុមទី១ ធ្វើឲ្យចលាចលពេញព្រៃ ។

ក្នុងខែកញ្ញាឆ្នាំ១៩៧៧ នៅថ្ងៃបុណ្យភ្ជុំបិណ្ឌ យាយទៀងបានឃើញព្រឹត្តិការណ៍ដ៏ចម្លែកមួយដោយផ្ទាល់ភ្នែក ។ ពេលនោះប្រជាជនភ័យស្រឡាំងកាំង ដោយឃើញមនុស្សជាច្រើនក្រុមដេញបាញ់គ្នា ដោយទុកខ្មោចឲ្យស្លាប់ពាសពេញព្រៃ ។ ក្រោយមកបន្តិចទើបគេដឹងថា មានក្រុមឃាតករអាថ៌កំបាំងចេញមកយ៉ាងច្រើនលើសលប់ព័ទ្ធបាញ់សម្លាប់យោធាខ្មែរក្រហម ដែលស្ថិតនៅក្រោមបញ្ជាការរបស់ **ជាឃួន** ហៅមិត្តវ៉ាញ ដែលតាំងមូលដ្ឋាននៅខាងជើងភ្នំធិបតី អស់ចំនួនប្រហែល៧០០នាក់ ។

ចំណែកមិត្តវ៉ាញ អង្គការឲ្យចាប់ខ្លួនតាំងពីថ្ងៃទី៩-៨-៧៧ នាំយកទៅដាក់គុកទួលស្លែង ។ បន្ទាប់ពីបានធ្វើទារុណកម្មយ៉ាងឃោរឃៅទៅលើមិត្តវ៉ាញអស់រយៈពេលជាងពីរខែមក អង្គការក៏នាំយកមិត្តនេះទៅសម្លាប់ចោលនៅថ្ងៃទី១៨-១០-៧៧។ មិត្តវ៉ាញជាសហការីរបស់ខៀវ-សំផន ។ ក្នុងពេលជាមួយគ្នានេះ មូលដ្ឋានខ្មែរក្រហមនិន្នាការខ្មែរជាច្រើនកន្លែងទៀត ក៏រងគ្រោះថ្នាក់ដូចមូលដ្ឋានមិត្តវ៉ាញដែរ ។ មានឧទាហរណ៍ដូចជានៅមូលដ្ឋានភូមិកូនក្រៀល ដែលស្ថិតនៅចម្ងាយ១៥គ.ម.ពីខេត្តព្រះវិហារ មាន«ប្រជាជនចាស់»ចំនួន១១៨នាក់ និងយោធាខ្មែរក្រហមនិន្នាការខ្មែរចំនួន២០២នាក់ បានរត់គេចចាកផុតគ្រោះថ្នាក់សល់នៅរស់ទៅកាន់ជំរំលំពុកនៃប្រទេសថៃ ។ នៅក្នុងចំណោមមិត្តទាំងនោះ យាយទៀងបានជួបមិត្តម្នាក់ ឈ្មោះជេត អាយុជាង៣០ឆ្នាំ មានដើមកំណើតនៅរដ្ឋធានីភ្នំពេញ ។ ជេតដែលជាអ្នក រៀនសូត្រចេះដឹងម្នាក់ បាននិយាយប្រាប់យាយទៀងដោយផ្ទាល់ថា ៖ ក្រុមខ្លួនស្ម័គ្រចិត្តបំរើអង្គការ ក្នុងពេលដែលកំពុងសង្គ្រាមយ៉ាងវេទនាក្រៃលែង។ ប៉ុន្តែជឿអង្គការដែលនិយាយច្រំដែលៗថា ពេលណាអង្គការបានសំរេចជោគជ័យ អង្គការផ្ដល់សេរីភាពយ៉ាងរុងរឿង និងសុភមង្គលឲ្យមិត្តទាំងអស់សប្បាយរីករាយ ។

លុះដល់ថ្ងៃទី១៧-៤-៧៥ អង្គការសំរេចបាន «ជ័យជំនះដ៏មហាអស្ចារ្យ» ហើយក៏បំភ្លេចពាក្យសន្យាចោល ។ មិនតែប៉ុណ្ណោះថែមទាំងដាក់វិន័យយ៉ាងតឹងរឹងជាងពេលកំពុងមានសង្គ្រាមទៅទៀត ។ ទាំង«ប្រជាជនចាស់», ទាំងយោធា អង្គការសន្និដ្ឋានដូចអ្នកទោស គឺបញ្ជាឲ្យធ្វើពលិកម្មទាំងយប់ទាំងថ្ងៃ ។ រីឯលទ្ធផលដែលធ្វើបាន ឃើញតែប្រមូលដឹកនាំចេញទៅកាន់ទីកន្លែងអាថ៌កំបាំងអស់រលីង ។ ការ

អត់ឃ្លានកាន់តែមានសភាពធ្ងន់ធ្ងរជាងពេលកំពុងមានសង្គ្រាមទៅទៀត ។ ជាពិសេសអង្គការហាមឃាត់ មិនឲ្យមានការជួបប្រស្រ័យទាក់ទងនឹង « ប្រជាជនថ្មី » ឡើយ ។

ស្រាប់តែនៅចុងខែកញ្ញាឆ្នាំ១៩៧៧ មានក្រុមឃាតករអាថ៌កំបាំង ដែលគេមិនដឹងចេញមកពីប្រភពណា មានចំនួនច្រើនលើសលប់ព័ទ្ធបាញ់សម្លាប់ក្រុមរបស់ជេត ដែលមិនបានដឹងខ្លួនជាមុន ។ គ្មានការប្រុងប្រយ័ត្នក្រុមជេតក៏ត្រូវស្លាប់ទៅជាមួយខ្មោចដួលដេកស្តូកស្តឹងពាសពេញព្រៃ ។

ចំណែកឯអ្នកដែលសេសសល់នៅរស់ដោយសាររត់គេចភៀសខ្លួនទាន់ ក៏បានចូលមកកាន់ប្រទេសថៃនេះ ។ល។

មិត្តជេតក៏បន្តទៀតថា ៖ នឹកៗទៅគួរឲ្យស្តាយណាស់ ព្រោះគ្រួសាររបស់ខ្ញុំយល់ច្រឡំយ៉ាងធ្ងន់ ។ ឪពុកខ្ញុំជានាម៉ឺនធំធ្វើការនៅរដ្ឋធានីភ្នំពេញ, បងៗរបស់ខ្ញុំជាសាស្ត្រាចារ្យ, ជាវេជ្ជបណ្ឌិត ។ គាត់មានការជិនណាយនឹងសភាពពុករលួយនៃរបបសាធារណរដ្ឋ ។ នៅពេលដែលឮសូរសេចក្តីអំពាវនាវរបស់សម្តេចសីហនុ ឪពុកខ្ញុំក៏សំរេចលះបង់អ្វីៗទាំងអស់ ហើយដឹកនាំគ្រួសារចូលព្រៃស្ម័គ្រចិត្តបំរើសម្តេចឪ ... ប៉ុន្តែប៉ះចំលើខ្មែរក្រហមដែលមានមេបញ្ជាការលើគឺអង្គការអនាមិកទៅវិញ ។ អង្គការបំបែកគ្រួសារខ្ញុំឲ្យព្រាត់ប្រាស់គ្នាអស់រលីង ។ ចំណែកឯខ្ញុំដែលឃ្លាតពីគ្រួសារនៅម្នាក់ឯង ក៏មិនដែលបានឮនរណានិយាយពីឈ្មោះខៀវ-សំផន សម្តេចឪឡើយ ។ នៅពេលនោះខ្ញុំមិនដឹងទាល់តែសោះថាមានខ្មែរក្រហមដែលមាននិន្នាការយួនចូលមកបន្លំប្រើឃើហៅខ្មែរក្រហមដូចៗគ្នាយ៉ាងនេះទេ ។

លុះមានឧប្បត្តិហេតុបាញ់សម្លាប់ខ្មែរក្រហមនិន្នាការខ្មែរយ៉ាងនេះកើតមានឡើង ក្រោយមកបន្តិចទើបដឹងថា ក្រុមឃាតកគតអាថ៌កំបាំងនេះគឺជាខ្មែរក្រហមនិន្នាការយួន ដែលមានការគាំទ្រយ៉ាងពេញទំហឹងពីបូដួយ ។

មិត្តជេតបញ្ជាក់ថា ក្នុងឆ្នាំ១៩៧៨ ក្រុមឃាតករអាថ៌កំបាំងទាំងនោះ ចេញមកព័ទ្ធបាញ់សម្លាប់ខ្មែរក្រហមនិន្នាការខ្មែរដែលមានខៀវ-សំផនជាមេដឹកនាំ មានចំនួន២ឬ៣លើកទៀត ។ ដូច្នេះខ្មែរក្រហមស្ទើរភ្លើងនេះ ត្រូវអង្គការចាត់ការឲ្យសម្លាប់ជាបន្តៗអស់ចំនួនប្រមាណជាង២ម៉ឺននាក់ ។ អង្គការបញ្ជាឲ្យសម្លាប់ទាំងគណរដ្ឋមន្ត្រីដូចជា ស្វូ-ភឹម, ញឹម-រស់, ហ៊ូ-នឹម, ពេញ-ធួក ហៅមិត្តវ៉ន-វ៉េត ជាដើម ។

មិត្តជេតបណ្តើរប្អូនស្រីរត់គេចភៀសខ្លួនចូលកាន់ប្រទេសថៃ ។ ចំណែកឪពុកម្តាយនិងបងៗត្រូវក្រុមឃាតករអាថ៌កំបាំងសម្លាប់ចោលអស់រលីង ។ លុះចេញផុតពីប្រភពដ៏វឹ្តតលីលានេះ មិត្តជេតបានជួបបងប្អូនខ្មែរថ្មី ។ នៅពេលនោះ ជេតក៏ដឹងថា អង្គការអនាមិកចាត់ការសម្លាប់បងប្អូនខ្មែររួមឈាមរបស់ខ្លួន ដែលមានពួក

បញ្ញវ័ន្តជាពិសេស អស់ចំនួនជិតពាលាននាក់ ។ ដឹងថាទីប្រជុំខែត្រទាំង២០បានក្លាយទៅជារហោស្ថាន រីឯទ្រព្យសម្បត្តិសឹងពេញមួយនគរខ្មែរ ក៏ត្រូវពួកចោរហារយប្រមូលយកទៅស្រុកវាអស់ ។ មិត្តជេតទន្ទេញថា គួរឲ្យឈឺចាប់ជាក្រៃលែង មិនគួរមេដឹកនាំខ្មែរនៅសម័យនោះ ផ្ទេសប្រហែសចាញ់បោកយួនហាណូយបណ្តាលឲ្យខ្មែរធ្លាក់ដល់នូវវិនាសកម្ម ទាំងប្រជាជនទាំងទ្រព្យសម្បត្តិ ហើយជាពិសេសធ្វើឲ្យខ្មែរយល់ច្រឡំវង្វេងបណ្តើរគ្នាចាកចេញពីមាតុភូមិ ទុកទឹកដីព្រៃព្រឹក្សាឲ្យយួនហាណូយនិងអាយ៉ងរបស់វាត្រួតត្រា ហើយមិនតែប៉ុណ្ណោះសោត ខ្មែរខ្លះថែមទាំងថ្លែងអំណរគុណយួនថែមទៀតផង ដែលជាការមួយគួរឲ្យអៀនខ្មាស់យ៉ាងក្រៃលែង ។ ជាទីបញ្ចប់ ជេតក៏បន្ថែមថា « ស្តាយអើយសែនស្តាយទឹកដីកម្ពុជា » ។

ជេតមកដល់សាធារណរដ្ឋបារាំងនៅថ្ងៃ ៧/១០/៨១ ។ ចំណែកឯប្អូនស្រីក៏តាមប្តីទៅរស់នៅឯប្រទេសកាណាដា ។

## ជំណាក់ការដែលត្រូវសម្លាប់កម្មាភិបាលជាន់ខ្ពស់បក្សខ្មែរក្រហមនិន្នាការខ្មែរ

ក្នុងឆ្នាំ១៩៧៧-៧៨ គុកទួលស្លែងជាកន្លែងដែលអង្គការធ្វើទារុណកម្ម និងសម្លាប់កម្មាភិបាលជាន់ខ្ពស់បក្សខ្មែរក្រហមនិន្នាការខ្មែរអស់ចំនួនយ៉ាងច្រើន ។ មានភស្តុតាងខ្លះៗដូចតទៅ ៖

★ នៅថ្ងៃទី២៥-១-៧៧ អង្គការចេញបញ្ជាឲ្យចាប់ខ្លួនមិត្តកុយ-ធួន កម្មាភិបាលជាន់ខ្ពស់ នាំយកទៅដាក់គុកទួលស្លែង ។ បន្ទាប់ពីបានធ្វើទារុណកម្មអស់ចំនួនពេល៣ខែមក អង្គការចាត់ចែងថតរូបទុក រួចក៏សម្លាប់ចោលទៅ ។

★ នៅខែមិនាឆ្នាំ១៩៧៧ អង្គការចេញបញ្ជាឲ្យចាប់ខ្លួនខ្មែរក្រហមនិន្នាការខ្មែរនៅភូមិភាគបូព៌ា មានចំនួន៤០០នាក់ នាំយកទៅបញ្ចូលគុកទួលស្លែង ។ ឌុចជាមេគុកចាត់ការធ្វើទារុណកម្មយ៉ាងឃោរឃៅ បង្ខំឲ្យសរសេរសារភាពទទួលកំហុសថាក្រុមខ្លួនជាភ្នាក់ងារវៀតកុង ហើយចុះហត្ថលេខាយ៉ាងត្រឹមត្រូវ ថតរូបទុកជាឯកសារ រួចទើបសម្លាប់ចោល ។

★ នៅថ្ងៃទី២១-៦-៧៧ អង្គការចេញបញ្ជាឲ្យចាប់ខ្លួនខែក-ប៉ែន ហៅមិត្តស៊ូជាគណៈតំបន់៤ នាំយកទៅដាក់គុកទួលស្លែង ។ ឯប្រពន្ធរបស់មិត្តស៊ូនេះ ត្រូវគេចាប់ខ្លួននៅថ្ងៃ៨-៩-៧៧ ។ ឌុចចាត់ការធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ រួចហើយសម្លាប់ទាំងពីរនាក់ប្តីប្រពន្ធចោលនៅថ្ងៃ១៨-១០-៧៧ ។

★ នៅថ្ងៃទី៨-៨-៧៧ អង្គការចេញបញ្ជាឲ្យចាប់ខ្លួនជា-ហួន ហៅមិត្តវ៉ាញ ជាមេ

កាន់ក្កាប់យោធាខ្មែរក្រហមនិន្នាការខ្មែរ មានមូលដ្ឋានស្ថិតនៅភ្នំធិបតី នាំយកទៅបញ្ចូលគុកទួលស្លែង ។ ឧុចចាត់ការធ្វើទារុណកម្មអស់រយៈពេល២ខែ រួចទើបបញ្ជាឲ្យគេសម្លាប់ចោលនៅថ្ងៃទី១៨-១០-៧៧ ។

★ ចំណែកហ៊ូ-យន់ មេខ្មែរក្រហមនិន្នាការខ្មែរដ៏ល្បីល្បាញ បានត្រូវអង្គ- ការ-ចាប់ខ្លួន តាំងពីឆ្នាំ១៩៧៥ម្ល៉េះ ។ មិត្តកែវ-មាសនិងមិត្តយ៉ា ត្រូវអង្គការចេញបញ្ជាឲ្យចាប់ខ្លួននៅថ្ងៃ២០-៩-៧៦ ។ មិត្តទាំង៣នាក់នេះក៏ត្រូវគេយកទៅបញ្ចូលគុកទួលស្លែង ហើយក៏ត្រូវគេសម្លាប់ចោលដែរ ។

★ ភោគ-ឆាយ ត្រូវអង្គការចាប់ខ្លួនបញ្ចូលគុកទួលស្លែងនៅថ្ងៃ១៣-៣-៧៧ ត្រូវគេសម្លាប់ចោលនៅថ្ងៃ៦-៧-៧៧ ។

❑ ❑

❑

## ដំណាក់ការដែលត្រូវសម្លាប់គណៈរដ្ឋមន្ត្រីនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

នៅថ្ងៃ ១០-៤-៧៧, អង្គការចេញបញ្ជាឲ្យចាប់ហ៊ូ-នឹម រដ្ឋមន្ត្រីក្រសួងឃោសនាការនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ នាំយកទៅបញ្ចូលគុកទួលស្លែង ។ ឌុចចាត់ការធ្វើទារុណកម្មយ៉ាងឃោរឃៅ ។ ក្នុងរយៈពេល៣ខែ គេបង្ខំឲ្យជនជាប់ទោសនេះសរសេរសារភាពថាជាសេអ៊ីអា ដោយមានចុះហត្ថលេខាយ៉ាងត្រឹមត្រូវ ។ មុននឹងសម្លាប់នៅថ្ងៃទី ៦-៧-៧៧ គេថតរូបទុកជាឯកសារសិន ។ ចំណែកឯប្រពន្ធហ៊ូ-នឹមវិញ គេចាប់ខ្លួននៅថ្ងៃទី១៤-៤-៧៧ រួចសម្លាប់ចោលនៅថ្ងៃ១២-៥-៧៧ ។ ជំនាន់នោះខ្មែរភាគច្រើនស្គាល់និងដឹងថា ហ៊ូ-នឹមជាសហការីរបស់ខៀវ-សំផន និងហ៊ូ-យន់ ។

នៅថ្ងៃទី២-១១-៧៨ អង្គការចេញបញ្ជាឲ្យចាប់ខ្លួន ពេញ-ធួក ហៅមិត្តវ៉ន-វ៉េត អនុរដ្ឋមន្ត្រីទី១ទទួលបន្ទុកខាងផ្នែកសេដ្ឋកិច្ចនិងឧស្សាហកម្មនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។ ប្រពន្ធវ៉ន-វ៉េតត្រូវគេចាប់ខ្លួននៅថ្ងៃ៦-១២-៧៨ អ្នកទាំងពីរត្រូវគេបញ្ចូលគុកទួលស្លែង... បាត់ខ្លួនរហូត ។

ក្នុងពេលជាមួយគ្នានេះអង្គការចេញបញ្ជាឲ្យចាប់ខ្លួនប្រធានរោងចក្រគ្រប់ប្រភេទ បញ្ចូលគុកទួលស្លែង រួចសម្លាប់ចោលអស់ ដូចមានជាឧទាហរណ៍ខ្លះៗនៅក្នុងតារាងខាងក្រោមនេះ ៖

| ឈ្មោះ | ប្រធានរោងចក្រ | ថ្ងៃចូលគុក | ថ្ងៃសម្លាប់ |
|---|---|---|---|
| យ៉ាន-កន | ម្សៅមី | ២១/១១/៧៨ | ៣១/១២/៧៨ |
| ម៉ៅ-ម៉ែត្រ | ដ-២ | ៣០/១១/៧៨ | ៣១/១២/៧៨ |
| ចឹប-ឆេង | ដ-១ | ៣០/១២/៧៨ | ៣១/១២/៧៨ |
| ខាន់-តាំង | ដ-៩ | ៣០/១១/៧៨ | ៣១/១២/៧៨ |
| អ៊ឹម-ខន | ក-១០ | ៣០/១១/៧៨ | ៣១/១២/៧៨ |
| ស៊ុន-សៀក | ដែកគោលដ-៨ | ៣០/១១/៧៨ | ៣១/១២/៧៨ |
| ស៊ុន-ដោត | ក្តារបន្ទះ | ០២/១២/៧៨ | ៣១/១២/៧៨ |
| ហ៊ុន-ឃន | ចំហុយស្រា | ៣០/១១/៧៨ | ៣១/១២/៧៨ |
| កែ-ផៃ | កៅស៊ូកង់ | ០៦/១២/៧៨ | ៣១/១២/៧៨ |
| ណុប-គង | ប្រេងកន្ទក់ | ០៦/១២/៧៨ | ៣១/១២/៧៨ |
| ទេព-សាញ | ប៉ះកង់ឡាន | ០៧/១២/៧៨ | ៣១/១២/៧៨ |
| ដែក-ប៉ុង | ទឹក | ១០/១២/៧៨ | ៣១/១២/៧៨ |
| អ៊ឹម-សំអុល | អគ្គីសនី | ១៥/១២/៧៨ | ៣១/១២/៧៨ |
| យស់-សេង | ហ្វីប្រូស៊ីម៉ង់ត៍ | ២០/១២/៧៨ | ៣១/១២/៧៨ |
| ប្រាក់-មឿង | ដែកគោលង-៥ | ២១/១២/៧៨ | ៣១/១២/៧៨ |
| សែម-គង់ | ប្លាស្ទិកប-៣ | ១២/១២/៧៨ | ៣១/១២/៧៨ |
| ពេជ-មុិញ | បារីប-៤ | ២១/១២/៧៨ | ៣១/១២/៧៨ |
| វង់-ឈុំ | ទឹកក្រូចទ-៣ | ២៩/១២/៧៨ | ៣១/១២/៧៨ |
| ម៉ក់-ឆាយ | ទឹកដោះគោឆ | ២៩/១២/៧៨ | ៣១/១២/៧៨ |
| យូ-ទុយ | អិដ្ឋ | ២៩/១២/៧៨ | ៣១/១២/៧៨ |
| សាយ-ធិម | បាវ | ២៩/១២/៧៨ | ៣១/១២/៧៨ |

អង្គការចេញបញ្ជាឲ្យចាប់ប្រធានរោងចក្រស៊ីម៉ង់ត៍, រោងចក្រតម្បាញ និងអភិបាលរថភ្លើង ប្រមូលបញ្ចូលគុកទួលស្លែងទាំងអស់ ។ ឌុចចាត់ការធ្វើទារុណកម្មបង្ខំឲ្យសរសេរសារភាពទទួលទោសថា ក្រុមខ្លួនជាសេអ៊ីអាជាង១០ឆ្នាំមកហើយ។ សរសេរទទួលទោស ចុះហត្ថលេខាត្រឹមត្រូវ ថតរូបទុកជាឯកសារ រួចទើបសម្លាប់ចោលនៅថ្ងៃទី៣១-១២-៧៨ ។

សូមបញ្ជាក់ថា ប្រធានរោងចក្រទាំងអស់នេះ គឺជាកម្មាភិបាលជាន់ខ្ពស់ទាំងអស់របស់បក្សខ្មែរក្រហមនិន្នាការខ្មែរ ។ ចំណែកនិយោជិករោងចក្រទាំងអស់ នោះអង្គការចេញបញ្ជាឲ្យបំបែកជាពីរពួក គឺប្រជាជនថ្មីនិងប្រជាជនចាស់ ។

- និយោជិកជាប្រជាជនថ្មី ៖ អង្គការចេញបញ្ជាហៅជាបន្តបន្ទាប់ ភរថានាំយកទៅរៀនសូត្រ ។ ការពិតអង្គការនាំយកទៅសម្លាប់ចោលទាំងអស់ ហើយតែងតាំងប្រជាជនចាស់ជំនួស ។

- និយោជិកជាប្រជាជនចាស់ ៖ អង្គការចេញបញ្ជាហៅជាបន្តបន្ទាប់ នាំយកទៅដាក់គុកទួលស្លែងខ្លះ ហើយមានមួយភាគធំបញ្ជាឲ្យសម្លាប់ចោលភ្លាម នៅក្នុងខែវិច្ឆិកានិងធ្នូឆ្នាំ១៩៧៨ ។ លុះដល់ថ្ងៃ៣១-១២-៧៨ ដើម្បីបញ្ចប់បេសកកម្មរបស់ខ្លួនមួយវគ្គ អង្គការបញ្ជាឲ្យសម្លាប់អ្នកទោសទួលស្លែងទាំងអស់ ។

ដូច្នេះប្រធាននិងនិយោជិករោងចក្រគ្រប់ប្រភេទក្នុងប្រទេសកម្ពុជា ទាំងប្រជាជនថ្មីទាំងប្រជាជនចាស់ ត្រូវអង្គការចេញបញ្ជាឲ្យសម្លាប់ចោលអស់ចំនួន៦ម៉ឺន១ពាន់ (៦១,០០០) នាក់ ។

ហេតុយ៉ាងដូចម្តេចបានជាគុកទួលស្លែងមានលំនាំរៀបចំយ៉ាងហ្មត់ចត់ត្រឹមត្រូវម្ល៉េះ ? ។

មើលចុះ ! អ្នកទោសជាប់គុកទួលស្លែង ត្រូវតែសរសេរសារភាពទទួលទោសចុះហត្ថលេខាត្រឹមត្រូវ ថតរូបទុកជាឯកសារ ដែលមានជាច្រើនម៉ឺនទំព័រ មុននឹងត្រូវគេសម្លាប់ចោល ។

គុកនេះត្រូវគេបង្កើតឡើងសំរាប់ធ្វើទារុណកម្ម និងសម្លាប់បំផុតពូជខ្មែរអ្នកចេះដឹង មានបញ្ញវ័ន្តគ្រប់ប្រភេទ សមាជិកជាន់ខ្ពស់ និងកម្មាភិបាលខ្មែរក្រហមនិន្នាការខ្មែរជាដើម ។

ដូច្នេះបើខ្មែរយើងចេះតាមដានគ្រប់ៗអព្ភូតហេតុ គ្រប់ឧបករណ៍ ចាប់តាំងពីថ្ងៃទី១៧-៤-៧៥តៗមក យើងអាចយល់ភ្លាមបានថា គឺក្រុមខ្មែរអាយ៉ងយួនជាអ្នកបង្កើតគុកទួលស្លែង ។ ព្រោះជារៀងរាល់ឆ្នាំនៅថ្ងៃទី១៧មេសា ឫកវាតែងលើកតំកល់តម្កើងបុណ្យអនុស្សាវរីយ៍នេះជានិច្ច ។

នៅឱកាសបើកពិធីបុណ្យម្តងៗ ហេង-សំរិនប្រធានក្រុមប្រឹក្សារដ្ឋ និងជាអគ្គលេខាធិការគណកម្មាធិការមជ្ឈិមបក្ស ឡើងថ្លែងសុន្ទរកថាយ៉ាងវែង អួតអាងភ្លេចខ្លួន ទទួលសារភាពថា បក្សរបស់ខ្លួនបានកំទេចខ្មែរលន់-នល់ រហូតបានជ័យជំនះលើកទី១នៅថ្ងៃទី១៧-៤-៧៥ និងលើកទី២ថ្ងៃទី៧-១-៧៩ ដែលបានកំទេចខ្មែរក្រហម ។

នៅចុងឆ្នាំ១៩៧៨ អង្គការបញ្ជាឲ្យសម្លាប់មិត្ត សូ-ភឹម រួចឲ្យដឹកខ្មោចទៅបង្ហាញគ្រប់ៗសហករណ៍នៅជិតៗនោះ ។ ថ្ងៃកប់ខ្មោចសូ-ភឹម អង្គការចេញបញ្ជាឲ្យចាប់ចងទាំងប្រពន្ធ ទាំងកូនយកទៅសម្លាប់ រួចកប់រួមផ្នូរជាមួយ ។

នរណាជាសូ-ភឹម ?

សូ-ភឹមជាអនុប្រធានរបស់ខៀវ-សំផន ក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេ-យ្យ ហើយនៅពេលនោះ សូ-ភឹមជាដៃស្តាំរបស់ប៉ុល-ពត, ជាឃាតករយ៉ាងសាហាវ គឺរូបនេះហើយដែលនាំក្រុមឃាតករអាថ៌កំបាំងទៅតាមព័ទ្ធបាញ់ខ្មែរ ដែលវិលត្រឡ-ប់មកពីប៉េកាំងនិងហាណូយនៅឆ្នាំ១៩៧៣ នៅក្នុងខេត្តមណ្ឌលគិរី ។

នៅឆ្នាំ១៩៧៧-១៩៧៨ កិច្ចការធ្វើទារុណកម្មយ៉ាងសាហាវឃោរឃៅ និងការសម្លាប់អ្នកទោសក្នុងគុកទួលស្លែងភាគច្រើន គឺសមាជិកនិងកម្មាភិបាលជាន់ខ្ពស់របស់បក្សខ្មែរក្រហមដែលមាននិន្នាការខ្មែរទៅវិញ ។

មកដល់ឆ្នាំ១៩៧៨ ខ្មែរដែលសេសសល់នៅរស់ ក៏ក្លាយទៅជាគ្រឿងម៉ាស៊ីនរបស់អង្គការ ។ ទោះជាយួនហាន្ទយទទួលជ័យជំនះយ៉ាងធំធេងយ៉ាងនេះក៏ដោយ ក៏វានៅតែលាក់មុខដដែល វានៅតែប្រើឃីហោខ្មែរក្រហមបន្តទៅទៀត ដើម្បីចាត់ការសម្លាប់កំចាត់ខ្មែរក្រហមនិន្នាការខ្មែរឲ្យអស់សិន ។

❑ ❑

❑

# ជំពូកទី១៦

★ ដំណាក់ការដែលអង្គការត្រូវបញ្ចេញក្រុមឃាតករទី៥
★ ហេតុម្ដេចក្រុមខ្មែរក្រហមនិរតីមិនកាន់អាវុធជាកាំភ្លើង ?
★ ដំណាក់ការដែលត្រូវសម្លាប់គណកម្មការកងនិងឈ្លបជាអតិតចោរ
★ ដំណាក់ការដែលត្រូវសម្លាប់ខ្មែរដោយអាវុធធម្មជាតិ
★ ដំណាក់ការដែលត្រូវសម្លាប់យុវជនចល័ត

## ដំណាក់ការដែលអង្គការត្រូវបញ្ចេញឃាតករក្រុមទីប្រាំ

ក្នុងខែសីហាឆ្នាំ១៩៧៨ ស្រាប់តែឃើញក្រុមខ្មែរក្រហមនិរតី បន្ថែមមកយ៉ាងច្រើនគ្រប់កង មានស្រី មានប្រុស អាយុពី២០ដល់៤៥ឆ្នាំ ។ ក្រុមនេះគ្មានឃើញកាន់កាំភ្លើងទេ តែកាន់ខ្សែវគ្រប់ៗគ្នាជាអាវុធ ។ មកដល់មុនដំបូង ពួកនេះបង្ហាញឫកពាសុភាពរាបសារទន់ភ្លន់ បណ្ដើរគ្នាទៅបង្ហាញខ្លួនដល់គណៈកម្មការកង ដែលជាអតីតចោរ ។ ថ្លែងបន្ទាបខ្លួនថា ៖ « អង្គការបញ្ជូនក្រុមខ្លួនឲ្យមកសុំរៀនសូត្រពីមិត្តបងៗ ដើម្បីដកស្រង់ការពិសោធន៍ យកមកគោរពអនុវត្តកសាងប្រទេសជាតិ» ក្រុមនេះបង្ហាញឲ្យឃើញដូចជាមានលាក់ការប៉ិនប្រសប់ណាស់ ព្រោះបើគេក្រឡេកខាងក្រៅទៅ មានសភាពខាងក្រៅដូចជាមនុស្សព្រៃ មនុស្សល្ងង់ មានភាគច្រើនមិនទាំងស្គាល់ឆ្នាំងអ៊ុត ម៉ាស៊ីនដេរ ឬសាប៊ូផង ។ ចំណែកឯពួកស្រីៗ អង្គុយផតសណ្ដាប់ធ្នាប់ បបូរមាត់ខ្មៅព្រឹកដោយទំពារស្លាមិនឈប់ ស្ដោះទឹកមាត់ពាសវាលពាសកាល ។

ប៉ុន្តែផ្ទុយទៅវិញ ក្នុងអង្គប្រជុំនិមួយៗ ទាំងប្រុសទាំងស្រីបណ្ដាក់គ្នាក្រោកឡើងនិយាយពីទ្រឹស្ដីស្នេហាជាតិ មានវគ្គមានឃ្លានិងទំនាក់ទំនងហាក់ដូចជាអ្នកចេះដឹងយ៉ាងជ្រៅជ្រះដ៏អស្ចារ្យ ដោយមកពីការនិយាយគ្មានរអាក់រអួល គ្មានទើសគ្មានទាល់ ។ តែបើគេស្ដាប់យូរៗទៅ ពួកនេះសូត្រដូចសត្វសេកតាមម្ចាស់វានិយាយភាសារបស់វានៅតែដដែលៗដូចជា ៖

- អ្នកណាហូប អ្នកនោះចេញពលិកម្ម !
- ទុកមិនចំណេញ ដកចេញមិនខាត !

ក្រុមនេះបបួលគ្នាចេញធ្វើពលិកម្មរួមជាមួយប្រជាជនថ្មីយ៉ាងស្វាហាប់ ថៅរ៉ៅរួសរាយ រាក់ទាក់ ទន់ភ្លន់ និយាយលួងលោម លោតលេងសប្បាយ សើចក្អាកក្អាយនិយាយរំពុកសោកស្ដាយថា ៖

- ពីជំនាន់សម្ដេចឪ យើងសំបូរសប្បាយ មានសេរីភាពពេញលេញ... ដើរលេងរាំរ៉ែក ច្រៀង មើលកុនល្ខោន បរិភោគឆ្ងាញ់ ។

ចំណែកប្រជាជនថ្មីកំពុងទទួលទារុណកម្ម កំពុងធ្វើការទាំងយប់ទាំងថ្ងៃ កណ្ដាលភ្លៀង និងថ្ងៃក្ដៅ ហុតតែបបរសឹងតែរកអំបិលគ្មានផង ដេកពាសវាលពាសព្រៃ យកមេឃជាដំបូល ភ្លីស្រែជាខ្នើយ ក្លាយទៅជាមនុស្សថ្លង់គ ទៅហើយ ។ មិត្តឯងនិយាយស្អីក៏និយាយចុះ គ្មាននរណាឆ្លើយតបទេ ។

ម៉្យាងវិញទៀត ប្រជាជនខ្មែរបានឃើញផ្ទាល់ភ្នែក បានស្ដាប់ផ្ទាល់ត្រចៀកនូវអាកប្បកិរិយា នូវសំដីដែលគ្មានទំនាក់ទំនង ។ ស្ដាប់ៗទៅគួរឲ្យចម្លែកណាស់ ។ ហេតុយ៉ាងដូចម្ដេចក៏ផ្លាស់ប្ដូរភ្លាមៗយ៉ាងហ្នឹង ?

បើអង្គការអនាមិកនៅតែជាអង្គការអនាមិកដដែល... ក្រុមខ្មែរក្រហមកើតចេញមកពីអតីតខ្មែរវៀតមិញ ដែលអង្គការចាត់តែងតាំងជាប្រធានសហករណ៍ ជាគណៈតំបន់ និងជាតំណាងរាស្ត្រ ក៏នៅតែដដែល ។

« យី ! អង្គការ អ្នកឯងប្រើឧបាយកលចុចរកមុខដើម្បីឲ្យដឹងថា តើនៅសល់ខ្មែរប៉ុន្មាននាក់ទៀតដែលស្រឡាញ់សម្ដេចឪ ដើម្បីនឹងសម្លាប់ចោលទេតើ ! » ។

យើងខ្មែរគួរនឹកឡើងវិញថា ចាប់តាំងពីឆ្នាំ១៩៧៥ដល់ចុងឆ្នាំ១៩៧៧ បក្សខ្មែរក្រហមរបស់ខៀវ-សំផន ធ្វេសប្រហែសចាញ់បោកអង្គការ ដោយបានរួមសហប្រតិបត្តិការជាមួយខ្មែរក្រហមដែលកើតចេញពីអតីតខ្មែរវៀតមិញ ហក់កញ្ជ្រោលលោតសម្លាប់ប្រជាជនខ្មែរវក់វី ។ នៅពេលនោះបើមានអ្នកណាម្នាក់ហ៊ានរំពុកឈ្មោះសម្ដេចសីហនុ ឬមួយហ៊ានរំលឹកថា ពីដើមធ្លាប់សំបូរសប្បាយ មានអ្វីៗបរិភោគសព្វគ្រប់យ៉ាងឆ្ងាញ់ពិសារ អ្នកនោះឯងត្រូវអង្គការចេញបញ្ជាឲ្យសម្លាប់ចោ-

លក្លាម ។

បន្ទាប់ក្រោយមកបន្តិច ទើបដឹងច្បាស់ថាក្រុមខ្មែរក្រហមនិរតីនេះចេញពីប្រភពខ្មែរវៀតមិញ ដែលជាកងកម្លាំងប្រដាប់អាវុធបដិវត្តន៍ឯកភាពរបស់កម្ពុជា ដែលបង្កើតឡើងដោយសឺង-ង៉ុកមិញ ក្រោមបញ្ជាការរបស់ហូ-ជីមិញ បង្កើតឡើងពីថ្ងៃ១៩-៦-៥១ ហើយបង្កប់លាកញ់ទុកពាសពេញព្រៃនៃប្រទេសកម្ពុជា ។

ដូច្នេះក្រុមខ្មែរក្រហមនិរតី មានការអប់រំបំពាក់គោលជំហរយ៉ាងឆ្អិនឆ្អៅ ណែនាំឲ្យដើរតាមខ្សែបន្ទាត់យ៉ាងត្រឹមត្រូវ មានគូសផែនការព្រាងទុកឲ្យជាស្រេចៗ គឺថ្ងៃនេះក្រុមត្រូវធ្វើអ្វី ហើយថ្ងៃក្រោយត្រូវធ្វើអ្វីទៀត ។ល។

## ហេតុយ៉ាងដូចម្ដេចបានជាក្រុមខ្មែរក្រហមនិរតីមិនកាន់កាំភ្លើងជាអាវុធ?

អង្គការចង់បំភ័ន្តមតិខ្មែរដោយអនុវត្តសំរបផែនការដែលវាបានព្រាងទុក ចេញបញ្ជាឲ្យដកអាវុធពីឈ្លបជាអតីតចោរ ។

សរុបសេចក្ដីមក សត្រូវសួរពូជរបស់យើងចេះឆ្លៃប្រឌិតខ្មែរជាក្រុមៗ តាមធុនញុះញង់ទៅតាមចំណុចខ្សោយរបស់មនុស្សម្នាក់ៗ រួចទើបបញ្ចេញតាមកាលវេលាយ៉ាងត្រឹមត្រូវ ឲ្យហក់លោតសម្លាប់បំផុតពូជខ្មែរជាដំណាក់ៗ ។ គ្រប់ៗអង្គប្រជុំ ក្រុមខ្មែរក្រហមនិរតីនិយាយច្រំដែលៗថា កងកម្លាំងប្រដាប់អាវុធស្នេហាជាតិកម្ពុជារបស់យើងកំពុងល្បីល្បាញមហាអស្ចារ្យពេញពិភពលោក ព្រោះយោធាយើងអាចដណ្ដើមយកជ័យជំនះពីអាមេរិកាំងជាមហាអំណាច ។ ឥឡូវនេះអង្គការកំពុងរៀបចំទ័ពដែលមានយោធាចំនួនបួនម៉ឺននាក់ ស្ម័គ្រចិត្តទៅវាយកំទេចយួនដើម្បីរំដោះទឹកដីកម្ពុជាក្រោម ដែលបារាំងច្រឡំប្រគល់ទៅឲ្យយួនពីឆ្នាំ១៩៤៩ នោះយកមកគ្របរួមបញ្ចូលជាមួយកម្ពុជាយើងវិញ ។ យោធាដ៏ក្លាហានរបស់យើងតិចពិតមែន ប៉ុន្តែម្នាក់ៗអាចកំទេចបួដួយពី៥ទៅ១០នាក់បានយ៉ាងងាយ ។ល។

រាល់ៗល្ងាចគេវាយជួងហៅប្រជុំ រួចចាប់សូត្រឃ្លាដដែលៗថារត់មាត់ថា ៖ « តៅវាយយួនដើម្បីរំដោះទឹកដីកម្ពុជាក្រោមៗៗៗ » ។

ប៉ុន្តែបងប្អូនខ្មែរអើយ ! ឃ្លានេះមិនមែនអង្គការធ្វើដោយងងឹតងងល់ទេ អង្គ-

ការបញ្ជាឲ្យខ្មែរក្រហមនិរតីនិយាយរលើរវាយស្មើរឆ្លុតលីលាមួយអន្លើសិន ដោយទុកផែនការរបស់វាមួយទៀតដែលកំពុងតែដាក់ទិសឲ្យគ្នាវាមួយក្រុមទៀតសម្លាប់ចំបាត់ពូជខ្មែរក្រហមនិរតីនិន្នាការខ្មែរមួយផ្នែកៗ ជាបន្តទៅទៀត ។

## ដំណាក់ការដែលអង្គការត្រូវសម្លាប់គណៈកម្មការកងនិងឈ្លបជាអតីតចោរ

ដើមខែតុលាឆ្នាំ១៩៧៤ អង្គការចេញបញ្ជាឲ្យដកអាវុធពីឈ្លបដោយបោកបញ្ឆោតថា ប្រទេសយើងបានសន្តិភាពហើយ មិត្តយើងមិនបាច់កាន់កាំភ្លើងច្រង៉េងច្រង៉ាង នាំឲ្យប្រជាជនភ័យខ្លាចឡើយ ។

នៅយប់ថ្ងៃទី២០-១០-៧៤ ម៉ោងប្រហែល៨យប់ មានក្រុមឃាតករអាថ៌កំបាំងចេញមកកាន់គ្រប់ៗកង ស្រែកហៅចំៗឈ្មោះ មេកងនិងឈ្លប ឲ្យចេញមកជួបរួចវាវាយសម្លាប់ចោលភ្លាមគ្មានសួរអ្វីមួយម៉ាត់ទេ ! ។ ឧទាហរណ៍មួយយ៉ាងជាក់ស្តែងមានដូចតទៅ ៖

- ប្រធានសហករណ៍លក់ជ្រៀវ តំបន់១ ខេត្តបាត់ដំបង ឈ្មោះមិត្តលី ជាតិយួនបន្លំយកសញ្ជាតិជាខ្មែរ ជាអតីតសមាជិកបក្សប្រជាជនបដិវត្តន៍ខ្មែរ គឺជាអតីតខ្មែរវៀតមិញ ។ ប្រធានសហករណ៍នេះមានឈ្លបពីរនាក់ គឺមិត្តកោដិ និងមិត្តរ៉េត ។

- មិត្តកោដិរស់នៅតែក្នុងព្រៃ ខាងត្បូងភូមិកង្កួត តាំងតែពីក្មេងមក មានចរិកជាចោរផង ជាខ្មែរក្រហមផង ។

នៅពេលដែលអង្គការដណ្តើមបានក្រុងភ្នំពេញភ្លាម អង្គការបញ្ជូនមិត្តកោដិមកកាន់សហករណ៍លក់ជ្រៀវ ចាត់តែងតាំងជាស្រេចជាឈ្លបប៉ែកខាងជើង ព្រមទាំងប្រគល់អភ័យឯកសិទ្ធិ អាចស្មើនិងសម្លាប់ខ្មែរដោយសេរី ។

ដូច្នេះនៅពេលនោះ មិត្តកោដិជាកញ្ជ្រោងអត់ឃ្លានដែលចូលចំទ្រុងមាន់ ។ កោដិក្លាយទៅជាឃាតករដ៏សាហាវអស្ចារ្យម្នាក់ ។ ប្រជាជនខ្មែរណាដែលលួចដូររបស់ផ្សេងៗដើម្បីរកម្ហូបអាហារទប់ការអត់ឃ្លាន ត្រូវបានកោដិនាំយកទៅសម្លាប់ចោលភ្លាមៗដោយគ្មានសួរយោបល់អ្នកណាម្នាក់ឡើយ ។ សេចក្តីសំរេចរបស់វាមានតែពាក្យមួយម៉ាត់ ៖ « ទុកមិនចំណេញ ដកចេញក៏មិនខាត » ។

ដើម្បីជាគំរូ កោដិហ៊ានធ្វើពលិកម្មឲ្យឃាតករចូលចាប់ឪពុកក្មេកតាញ៉ យកទៅសម្លាប់ និងម្តាយក្មេករបស់ខ្លួនយកទៅដាក់គុកស្រីមេម៉ាយនៅព្រៃតាបែន ។

ប្រជាជននៅសហករណ៍លក់ជ្រៀវទាំងមូលបាក់ស្បាត ខ្លាចកោដិស្ទើរបាក់លោង ដូចកូនសេះឃើញខ្លា...។

មិត្តកោដិរស់នៅជាមួយគ្រួសារមិត្តពាច ក្នុងផ្ទះមួយស្ថិតនៅកងលេខ៣ ភូមិព្រៃស្វាយខាងលិច ក្នុងសហករណ៍លក់ជ្រៀវតំបន់១ ។

នៅយប់ថ្ងៃទី២០-១០-៧៨ ព្រឹត្តិការណ៍មួយក៏កើតមានឡើងនៅផ្ទះមិត្តកោដិ ។ ម៉ោង៨យប់ ស្រាប់តែមានមនុស្សក្រុមចំនួន៥នាក់ កាន់អាវុធគ្រប់ដៃដើរមកឈប់នៅមុខកាំជណ្តើរផ្ទះ ។ មនុស្សម្នាក់ស្រែកហៅមិត្តកោដិ ។ ឮដូច្នេះមិត្តកោដិប្រញាប់ប្រញាល់ចុះមកទទួលភ្ញៀវទាំងញញឹមញញែម ។ តែអនិច្ចាមិត្តកោដិណាស់! ចុះមិនទាន់ដល់ដីផង នៅសល់ពីរកាំទៀត មនុស្សម្នាក់មាឌមាំបោះក្រមាទាក់កមិត្តកោដិ អូសទាញទម្លាក់ដីរួចទាត់ធាក់គ្មានប្រណីដោយឥតហេតុ ។

មិត្តពាចជាប្រពន្ធភ័យស្លន់ស្លោ និយាយទៅកាន់ឃាតករបណ្តើរយំបណ្តើរថា មិត្តអើយ ! វាយសម្លាប់គ្រួសារខ្ញុំដូច្នេះច្រឡំខុសហើយ គ្រួសារខ្ញុំនេះឈ្មោះកោដិណា៎ ! គាត់ជាឈ្លបក្នុងសហករណ៍លក់ជ្រៀវ ! គាត់ជាកូនបង្កើតរបស់មិត្តកើត ។ ទាំងឪពុកទាំងកូន បំរើអង្គការពេញ៥ឆ្នាំ១ខែហើយ ។ ឃាតករវាយសម្លាប់កោដិបណ្តើរ ឆ្លើយតបទៅមិត្តពាចបណ្តើរយ៉ាងកំបុតកំបុយថា ៖ ឥឡូវនេះដល់វេនមិត្តកោដិហើយ ! ។

វាយសម្លាប់មិត្តកោដិរួចហើយ ឃាតករក៏កប់នៅជើងជណ្តើរផ្ទះ ដោយទុកបន្សល់ជើងម្ខាងនៅលើដី ហើយដើរចេញទៅ...

ក្នុងយប់តែមួយ វេលាម៉ោងដដែល ក្នុងកងចែភ្លយ ស្ថិតនៅខាងត្បូងសហករណ៍លក់ជ្រៀវដដែល មានមនុស្សមួយក្រុមចំនួន៥នាក់ដូចគ្នា កាន់អាវុធគ្រប់ដៃសំដៅទៅកាន់ផ្ទះមិត្តវ៉េត ។ ម្ចាស់ផ្ទះក៏ចេញមកជួបក្រុមនេះ ។ ពួកឃាតករវាយប្រហារមិត្តវ៉េតភ្លាមដោយគ្មាននិយាយមួយម៉ាត់ទេ ។ សម្លាប់រួចហើយ ឃាតករក៏យកអន្ទាក់ចងកខ្មោច រួចអូសដូចខ្មោចឆ្កែយកទៅកប់នៅចំផ្លូវបំបែកជា៤ ដែលស្ថិតនៅខាងលិចភូមិចែភ្លយ ។ ម្តងនេះវាកប់ខ្មោចទុកត្រឹមក្បាល សំរាប់បង្ហាញប្រជាជន ។

តាំងពីដើមមក មិត្តវ៉េតជាចោរដ៏សាហាវឃោរឃៅ មានទីលំនៅនៅភ្នំវាយចាប។

នៅពេលដែលអង្គការដណ្តើមបានក្រុងភ្នំពេញភ្លាម អង្គការបញ្ជូនមិត្តវ៉េតមកកាន់សហករណ៍លក់ជ្រៀវ ចាត់តែងតាំងជាស្រេចជាឈ្លបប៉ែកខាងត្បូង ព្រមទាំងប្រគល់អភ័យឯកសិទ្ធិ អាចស្ទើនិងសម្លាប់ខ្មែរដោយសេរី ។ មិត្តវ៉េតសំរេចកាត់

ទោសប្រជាជនថ្មីមានភាពសាហាវជាងមិត្តកោដិទៅទៀត ។ សេចក្ដីសំរេចរបស់វាមានតែមាត់ទទេថា ៖ ទុកមិនចំណេញ ដកចេញក៏មិនខាត !

កាលពីនៅរស់ មិត្តរ៉េតបានបញ្ចេញចម្ងល់របស់ខ្លួនឲ្យយើងដឹងថា ខ្មែរយើងដែលម្ចាស់ព្រៃដ៏ធំធេងទាំងនេះ មិនដែលបានស្គាល់គ្រប់ជ្រុងជ្រោយឡើយ ។ រីឯពួកបូដូយវិញ ម្នាក់ៗមានផែនទីស្រុកយើងគ្រប់ដៃ ដែលជាហេតុឲ្យពួកវាស្គាល់ព្រៃព្រឹក្សាស្រុកខ្មែរគ្មានចន្លោះ ។

ពីឆ្នាំ១៩៦៣ទៅ១៩៧៣ ក្នុងរយៈវេលា១០ឆ្នាំនេះ មិត្តរ៉េតរស់នៅជាមួយបូដូយហើយជាពិសេសសំណាក់នៅលើភ្នំ៧ជាន់អស់រយៈពេល៧ឆ្នាំ ។ មិត្តរ៉េតឃើញបូដូយស្លាប់យ៉ាងច្រើនបណ្ដាលមកពីជម្ងឺគ្រុនចាញ់ ផឹកទឹកជ្រោះមិនស្អាត ដោយគ្មានអនាម័យគ្រប់គ្រាន់ និងស្លាប់ដោយសារចំបាំងដើម្បីជួយខ្មែរក្រហមវាយទ័ពលន់-នល់ ។

លុះដល់ចុងឆ្នាំ១៩៧៣ ស្រាប់តែបាត់មុខបូដូយអស់រលីង បែរជាចេញឈ្មោះអង្គការអនាមិកជាមេបញ្ជាការទៅវិញ ។ ដូច្នេះចាប់តាំងពីពេលនោះមក អង្គការអនាមិកសន្យាជាឧឡារិកច្រំដែលៗថា ៖

« ពេលណាអង្គការបានទទួលជ័យជំនះលើរបបលន់-នល់ហើយ អង្គការនឹងផ្ដល់សុភមង្គល សេរីភាព ការសប្បាយរុងរឿងដល់មិត្តទាំងអស់ » ។

ឆ្នាំ១៩៧៥ អង្គការដណ្ដើមបាន «ជោគជ័យ» ហើយ ។ តែស្ថានការណ៍កាន់តែតានតឹងឡើងៗ ទុរភិក្សអត់ឃ្លានកាន់តែខ្លាំង ជាពិសេសសង្គ្រាមកាន់តែវាយប្រហារធ្ងន់ធ្ងរជាងមុនទៅទៀត ។ គួរឲ្យចម្លែកណាស់ អង្គការបែរជាបញ្ជាឲ្យធ្វើទារុណកម្មទៅលើរាស្ត្រខ្មែរយ៉ាងងឹតអន្ធការទៅវិញ ។

នេះជាសំដីរបស់មិត្តរ៉េតដែលបានថ្លែងប្រាប់ទៅលោកគ្រូពេទ្យទ្រី នៅពេលដែលគាត់ទៅព្យាបាលជម្ងឺឲ្យគ្រួសាររបស់មិត្តរ៉េតម្ដងៗ ។ មិនតែប៉ុណ្ណោះ មិត្តរ៉េតថែមទាំងទូន្មានឲ្យគ្រូពេទ្យប្រុងប្រយ័ត្នខ្លួនទៀតផង ។

ឧទាហរណ៍យ៉ាងជាក់ស្ដែងមួយទៀតមានដូចតទៅ ៖

- នៅសហករណ៍ព្រៃតូច តំបន់៤ ខេត្តបាត់ដំបង មានឈ្លប២នាក់ជាឃាតករយ៉ាងឃោរឃៅនិងសាហាវអស្ចារ្យ ។ ម្នាក់ឈ្មោះមិត្តយិន មិត្តម្នាក់ទៀតឈ្មោះហ៊ាក ។ មិត្តទាំងពីរនេះកើតនៅភូមិកាច់រទេះ ស្រុកសង្កែ ខេត្តបាត់ដំបង ឪពុកម្ដាយរបស់មិត្តទាំងពីរនាក់នេះជាខ្មែរកម្ពុជាក្រោម ។ យិននិងហ៊ាកជាចោររស់នៅតែក្នុងព្រៃរនាមស្ថិតនៅខាងកើតភូមិកាច់រទេះ ។ វាតែងតែចូលមកប្លន់រាស្ត្រខ្មែរនៅភូមិកាច់រទេះជារឿយៗ ជាមួយនិងពួកចោរគ្នាវាចំនួនពី១០ទៅ១៥នាក់កាំភ្លើងគ្រប់ដៃ ។ វាប្លន់គោរទេះ ប្រមូលទ្រព្យសម្បត្តិរៀបដាក់រទេះហើយវាដុតផ្ទះអ្នកស្រុក ចោល

ជាទីបញ្ចប់វាក៏បាញ់សម្លាប់ម្ចាស់ផ្ទះចោលគ្មានត្រាប្រណីទេ ។ ជួនកាល វាប្រមូលម្ចាស់ផ្ទះបានមួយចំនួន ហើយវាក៏បោះគ្រាប់បែកដៃទៅលើក្រុមមនុស្សអភ័ព្វទាំងនោះតែម្តង ។

នៅពេលដែលអង្គការដណ្តើមបានក្រុងភ្នំពេញភ្លាម អង្គការចាត់តែងតាំងមិត្តយិននិងមិត្តហ៊ាកជាស្រេច ជាឈ្លបរួចបញ្ជូនមកកាន់សហករណ៍ព្រៃតូច តំបន់៤ ខេត្តបាត់ដំបង ព្រមទាំងប្រគល់អភ័យឯកសិទ្ធិ ឲ្យ«ស្ទើរ»និងសម្លាប់រាស្ត្រខ្មែរដោយសេរីតាមសាលក្រមតែពាក្យមួយឃ្លាដដែល ៖ «ទុកមិនចំណេញ ដកចេញក៏មិនខាត » ។

មិត្តទាំងពីរនាក់នេះមានតាំងទីលំនៅនៅភូមិកាច់រទេះវិញ ។ ដោយបានទទួលអភ័យឯកសិទ្ធិពីអង្គការលើដ៏មហិមា ឃាតករទាំងពីរនាក់នេះក៏តាំងសំដែងឫទ្ធិយ៉ាងសាហាវចាប់ចងប្រជាជនខ្មែរ ជាពិសេសភេទប្រុសៗ នាំយកទៅសម្លាប់ចោលជាហូរហែ ។ សូម្បីតែបងប្អូនបង្កើត បងប្អូនជីដូនមួយ ក្មួយៗបង្កើតរបស់វា ក៏វាសម្លាប់ឥតញញើតដៃទេ ។ ដោយសារអំពើយង់ឃ្នងរបស់មេឃាតករទាំងពីរនាក់នេះ ភូមិកាច់រទេះទាំងមូលក៏កើតចលាចលជាខ្លាំង ប្រជាជនថ្មីភេទប្រុសៗក៏នាំគ្នាផ្សងព្រេងរត់ចោលភូមិ ព្រាត់ប្រាស់និវាសគ្រួសារសឹងអស់រលីង ។ អ្នកភូមិកាច់រទេះដែលនៅរស់ដល់សព្វថ្ងៃមកពីបានគេចខ្លួនរួចទៅភូមិឆ្ងាយៗ ហើយដូរឈ្មោះផ្សេងទៅវិញ ។

នៅយប់ថ្ងៃទី២០-១០-៧៨ មានក្រុមឃាតករអាថ៌កំបាំងយ៉ាងច្រើនលើសល ប់ចេញពីព្រៃនាមកាន់អាវុធគ្រប់ដៃ សំដៅមកសហករណ៍ព្រៃតូច ដើម្បីសម្លាប់គណកម្មការកងនិងឈ្លបជាអតីតចោរ ដែលគ្មានពេលនឹងរើខ្លួនរំដោះរួចបានឡើយ ។ ក្រុមឃាតករទាំងនេះមិនភ្លេចមិត្តហ៊ាកនិងមិត្តយិនទេ, ពួកវាចូលភូមិកាច់រទេះចាប់មិត្តហ៊ាកសម្លាប់ចោលភ្លាមមួយរំពេច ។ ក្រុមឃាតករអាថ៌កំបាំងមួយទៀតចាប់មិត្តយិនចង រួចវះថ្គាល់ទាំងសងខាង កាត់ម្រាមដៃម្រាមជើង នាំយកទៅឃុំទុកក្នុងព្រះវិហារកាច់រទេះ បង្អត់បាយទឹក រុយពងដាក់ដំបៅ ហើយក្លាយទៅជាដង្កូវរុក ញាំងឲ្យមិត្តយិនឈឺចាប់ស្រែករោទិ៍មុននឹងស្លាប់យ៉ាងវេទនា និងគួរឲ្យចម្លែកណាស់ ! ។

ចំណែកឯប្រជាជនថ្មីក្នុងសហករណ៍ទាំងពីរនោះ លុះបានឃើញផ្ទាល់ភ្នែកនូវទារុណកម្មនិងឃាតកម្មយ៉ាងចម្លែកដូច្នេះ ហើយនាំគ្នារកតែពុទ្ធោប៉ុណ្ណោះ ហើយខាំមាត់សម្ងំស្ងៀមខំសំរុកធ្វើការប្តូរជីវិត ។ គ្រប់ៗគ្នាគ្មានអារម្មណ៍ថានឹងត្រូវអរឬត្រូវភ័យអ្វីនោះទេ ព្រោះមិនដឹងថា អង្គការបញ្ចេញផែនការអ្វីតទៅមុខទៀតយ៉ាងដូចម្តេច ។ ចំណែកឯមិត្តលី អតីតខ្មែររៀតមិញហើយជាបច្ចុប្បន្នប្រធានសហ-

ករណ៍លក់ជ្រៀវ ធ្វើព្រងើយគ្មានបញ្ចេញសកម្មភាពភ្ញាក់ផ្អើលឬប្រតិកម្មអ្វីសោះឡើយ ។ រីឯបក្សខ្មែរក្រហមនិរតី វាចេញធ្វើពលិកម្មរួមធ្វើព្រងើយ ។ អង្គការចាត់ការសម្លាប់របៀបនេះអស់មួយរយៈយ៉ាងខ្លី ។ លទ្ធផលគឺក្រុមអតីតចោរដែលអង្គការឆ្នៃប្រឌិតជាខ្មែរក្រហមនោះ ត្រូវស្លាប់សឹងផុតពូជអស់ពីប្រទេសខ្មែរ ។ រួចហើយមិត្តលីប្រធានសហករណ៍បច្ចុប្បន្ន ក៏ចាប់ជ្រើសរើសគណកម្មការកងថ្មីក្នុងចំណោមប្រជាជនថ្មី ដើម្បីចាត់ការគៀបសង្កត់ប្រជាជនឲ្យអូសនង្គ័ល អូសរនាស់ ដកស្ទូងច្រូតកាត់ កុំឲ្យរអាក់រអួលការងារ ។

ក្នុងខែវិច្ឆិកា១៩៧៨ មានក្រុមឃាតករអាថ៌កំបាំងចេញមកសម្លាប់គណៈកម្មការកងដែលទើបនឹងជ្រើសរើសនោះអស់មួយលើកទៀត ។

ក្បួនឡានក៏ដឹកនាំជន្លៀសប្រជាជនចេញពីសមរភូមិ «ឆ្នៃប្រឌិត» នេះទៅមានចម្ងាយយ៉ាងតិច២០គ.ម. ដើម្បីទុកឱកាសឲ្យបូដូយរៀបចំអន្ទាក់យ៉ាងហ្មត់ចត់និងត្រឹមត្រូវ មានផ្លូវចេញចូល រួចអាចបិទមកវិញតាមចិត្តចង់...។

ចុងឆ្នាំ១៩៧៨ យោធាខ្មែរក្រហមបណ្ដើរគ្នាដើរចូលចំកណ្ដាលអន្ទាក់ខ្សែត្រៀមរបស់បូដូយជាហូរហែរ ។ អង្គការលើបានឱកាសហើយ ក៏បញ្ជាឲ្យបូដូយបាញ់ចម្រុះទាំង១០ទិសស្រោចមកលើយោធាខ្មែរក្រហម ។ នៅជុំវិញខ្សែត្រៀមមានរថក្រោះព័ទ្ធជុំជិត ។ នៅពីលើក្បាល កប៉ាល់ហោះចាំទម្លាក់គ្រាប់បែកនិងបាញ់រះដូចរន្ទះមកពីខាងលើ ។ ក្រឡេកមើលមកយោធាខ្មែរក្រហមវិញ ម្នាក់ៗស្ពាយកាំភ្លើងមួយកូនដើម ជាមួយខ្សែគ្រាប់មួយកូនជួរ ដើរដោយជើងទទេ ។ តើពួកនេះមានកម្លាំងឯណានឹងទប់ទល់ជាមួយពួកបូដូយ ដែលមានកម្លាំងសព្វាវុធដូចដែលបានរៀបរាប់មកពីខាងលើនេះ ? ។ ង៉ោ-វាន់ឌឹកបញ្ជាក់ថា កាលណោះខ្លួនវានេះជាបូដូយម្នាក់ ក្នុងចំណោមបូដូយឯទៀតដែលបានបាញ់រះទៅលើយោធាខ្មែរក្រហមនៅសមរភូមិមីឡាយ ។ ពេលនោះយោធាខ្មែរក្រហមត្រូវស្លាប់គរជើងលើគ្នា ។

នៅថ្ងៃទី៥-១-៧៩ ក្រុមឌឹកត្រូវអង្គការលើបញ្ជូនទៅកាន់ប្រទេសកម្ពុជាវិញ ។ ក្រុមឌឹកដើរចូលមកប្រទេសកម្ពុជា វាងតាមប្រទេសលាវ-ប្រទេសសៀម តាមផ្លូវសម្ងាត់ក្នុងរូងភ្នំដងរែក រួចកាត់តាមស្រុកសិរីសោភ័ណ (ឬស៊ីសុផុន) ខេត្តបាត់ដំបង ដើម្បីចូលមកស្រុកខ្មែរ ។

ដោយធុញទ្រាន់នឹងវិន័យយ៉ាងតឹងរ៉ឹងរបស់អង្គការលើ ដែលចេញបញ្ជាយ៉ាងបង្ខំឲ្យរៀនអក្សរខ្មែរដើម្បីបន្លំធ្វើជាខ្មែរ, ស៊ីបាយវាល់ចានចែកឲ្យតែជាមួយផ្ទីរឬត្រកួនស្ងោរ បង់តែអំបិលយ៉ាងនេះ... ឌឹកក៏សំរេចចិត្តរត់គេចខ្លួនចូលកាន់ជំរំ N.W.9 នៃប្រទេសថៃ មកចងអគ្រឹងដេកក្បែរអគ្រឹងយាយទៀង ( កកន: កាលណោះយាយទៀងប្រាប់កាកបាទក្រហមអន្តរជាតិថាគាត់ជាជាតិយួន ។ ជំរំ NW-9 ជាជំរំសំរាប់

ដាក់ជនភៀសខ្លួនជាតិយួនទេ) ។ យុវជន ប៊ុយ-គីមឡុង ជាតិយួនកើតនៅទីក្រុងតាកែវ អាយុ១៩ឆ្នាំ និយាយប្រាប់យាយទៀងថា វាបានឃើញផ្ទាល់ភ្នែករបស់វានៅចុងខែធ្នូ១៩៧៨ យោធាខ្មែរក្រហមបណ្ដើរគ្នាចូលទៅឈ្លានពានភូមិមីឡាយដើរចូលចំកណ្ដាលអន្ទាក់ខ្សែត្រៀមរបស់បូដូយ ។ យោធាទាំង៧,០០០នាក់នោះត្រូវបូដូយសម្លាប់ចោលអស់ ។ ឈ្មោះកុត ជាយោធាខ្មែរក្រហម អាយុប្រហែល២៥ឆ្នាំ ដែលស្ម័គ្រចិត្តទៅវាយយួនរំដោះទឹកដីកម្ពុជាក្រោម បានប្រាប់យាយទៀង ថា ៖ នៅចុងឆ្នាំ១៩៧៨ អង្គការបញ្ជូនយោធាក្រុមខ្លួនទៅវាយយួន ។ យោធាចំនួនរាប់ពាន់នាក់ដើរសំដៅទៅសមរភូមិដោយជើង ។ តាំងពីព្រលប់រហូតទល់ភ្លឺ ទើបបានទៅដល់ព្រៃកមួយយ៉ាងធំ ដែលមានទឹកជោរជន់ហួរយ៉ាងខ្លាំង ។ កំពុងតែរកមធ្យោបាយឆ្លងព្រៃក ស្រាប់តែគ្រាប់កាំភ្លើងរបស់បូដូយលាន់ឮដូចរន្ទះចេញមកពីគ្រប់ទិសទី ស្រោចទៅលើយោធារបស់កុត រកច្រកចេញពុំរួចនឹងទៅមុខក៏ពុំកើតនឹងថយក្រោយក៏ពុំបាន ព្រោះត្រូវបូដូយខ្ទប់ផ្លូវគ្រប់ច្រកល្ហក ។ នៅលើអាកាសកប៉ាល់ហោះចាប់ទម្លាក់គ្រាប់បែក ។ កុតត្រូវគ្រាប់កាំភ្លើងចំភ្លៅ រហ័សដូចភ្លេកបន្ទោរ គ្រវែងកាំភ្លើងនិងខ្សែគ្រាប់ចោលទៅដី កុតក៏លោតចុះទឹកប្រឹងបណ្តែតខ្លួនតាមសំណាងក្នុងទឹក ។ ចៃដន្យកុតបណ្តែតខ្លួនទៅប៉ះចំលើទូកមួយដែលអ្នកនេសាទកំពុងតែនេសាទត្រី គេក៏លើកកុតដាក់លើទូក ។ កុតចេះនិយាយភាសាយួនយ៉ាងច្បាស់ ចេះហែលទឹកយ៉ាងស្ទាត់ជំនាញ ព្រោះកុតធ្លាប់ធ្វើគូលីចាប់ត្រីឲ្យយួននៅព្រៃកទាល់កាលពីដើម ។ កុតភរវៀតកុងថាខ្លួនជាជនជាតិយួន ដើម្បីឲ្យគេដឹកខ្លួនទៅកាន់មន្ទីរពេទ្យព្រៃនគរ ។ ពេទ្យយួនកាត់ជើងស្ដាំដែលរបួសនោះចោលទៅដោយមកពីដំបៅវារលេះរលួយព្យាបាលលែងកើតទៅហើយ ។ នៅទីបញ្ចប់ កុតនិយាយប្រាប់យាយទៀងដោយគ្រវីក្បាលថា ខ្ញុំមិនដឹងជាយោធាដែលរងគ្រោះនៅក្នុងក្រុមជាមួយខ្លួននោះមានចំនួនពិតប្រាកដប៉ុន្មានឡើយ ។ ប៉ុន្តែតាំងពីថ្ងៃនោះមកទល់នឹងថ្ងៃដែលកុតបានជួបនឹងយាយទៀង បុរសនេះមិនបានជួបឬឃើញមិត្តរួមអាវុធរបស់ខ្លួនណាម្នាក់ទេ ។

ចុះនៅអង្គការសហប្រជាជាតិវិញ... មានអ្វីប្លែក ?

អ្នកតំណាងយួននៅអង្គការសហប្រជាជាតិឆ្លើយប្រាប់សកលលោកថា ៖ « ទ័ពរបស់ខ្លួនធ្វើការបានល្អណាស់ ក្នុងនាទីរបស់ខ្លួនជាអ្នកទប់ទល់ ប៉ុន្តែនៅចំមុខសត្រូវដ៏ចចេសស្វិតស្វាញ ទ័ពរបស់វៀតណាមគ្មានមធ្យោបាយណាក្រៅពីជាន់ឈ្លីកម្លាំងឈ្លានពាននិងកំទេចមូលដ្ឋានទ័ពរបស់សត្រូវឡើយ » ។

❑

ក្នុងរយៈពេល៤៨ខែ គឺចាប់តាំងពីថ្ងៃ១៧-៤-៧៥ រហូតមកទល់នឹងបំណាច់ឆ្នាំ ១៩៧៨ អង្គការអនាមិកចាត់ការសម្លាប់ប្រជាជនខ្មែរនៅលើទឹកដីខ្មែរជាដំណាក់ៗ យ៉ាងស្អាតជាទីបំផុត ។

នៅខែកក្កដាឆ្នាំ១៩៧៩ បូដូយប្រមូលខ្មោះពីគ្រប់ទិសទីនៅក្នុងស្រុកខ្មែរមក កាន់ខេត្តបាត់ដំបង ។ គឺជាខ្មោះដែលអង្គការដឹកចូលមកតាំងពីឆ្នាំ១៩៧៨ សំរាប់ធ្វើ ទារុណកម្មលើប្រជាជនខ្មែរ ។ ខ្មោះទាំងនោះមានចំនួន៥ឡានកាម៉្យុង ដែលត្រូវពួក បូដូយតាំងដឹកលល់ទុកបង្ហាញសាធារណជន ព្រមជាមួយការឃោសនាថា ៖ « បើ សិនជាយួនចូលមកជួយស្រុកខ្មែរមិនទាន់ទេ រាស្ត្រខ្មែរមុខតែស្លាប់ក្នុងខ្មោះទាំង នេះជាមិនខាន » ។

ម៉្យាងទៀតអង្គការមានគំរោងការសម្លាប់ខ្មែរដោយដាក់ថ្នាំបំពុលក្នុងទឹកសម្ល ធំបញ្ចុក ។ តែគំរោងការនេះត្រូវបានផ្អាកសិន ដោយវាយកការណ៍បានថា លោក សឺន-សានបំរុងបង្កើតសមាគមមួយឈ្មោះ « សមាគមខ្មែរនៅបរទេស » ដោយ មានការឧបត្ថម្ភពីរាជរដ្ឋាភិបាលថៃនិងអង់គ្លេស ហើយបន្ទាប់មកទៀតបំរុងបង្កើត « រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (រជរបខ) » ។

ដូច្នេះអង្គការត្រូវផ្លាស់ប្តូរផែនការភ្លាម ។ នៅឯស្រុកស្រែងណោះ បក្សខ្មែរ ក្រហមនិរតីជាអតីតខ្មែរវៀតមិញក្រុមទី២ ក្រោកឡើងព្រោងព្រាត ដោយប្រើឃី-ហោខ្មែរក្រហមដដែល វាប្រកាសតែងតាំងក្រុមរបស់វាជាតំណាងអង្គការដដែល តែបុកពារលាក់ពុតដ៏ស្លូតបូតរបស់វាត្រូវដូរទៅជាកាចសាហាវតាមកំណើតវិញ ។ វាចាប់ផ្តើមចាប់ចងរាស្ត្រទាំងក្មេងទាំងចាស់យកទៅសម្លាប់ចោល ទាំងក្រុមៗ ដោយប្រើតែដាវនិងខ្វែវជាអាវុធ ។ ការសម្លាប់មនុស្សរបស់ក្រុមចោរនេះ គឺកាត់កទម្លាក់ក្បាលពីលើស្មា ។ នៅពេលនោះ គ្រប់ៗគ្នារន្ធត់ចិត្ត ស្លុតស្មារតីជាក្រៃលែង ដោយសារអំពើសាហាវយង់ឃ្នងរបស់ពួកក្រុមខ្មែរក្រហមនិរតីនេះ ។ ប្រុសៗដែល នៅសល់ពីស្លាប់ក៏ផ្សងព្រេងរត់ចូលព្រៃ ដងខ្លួនទទេ គ្មានអ្វីទៅតាមខ្លួនសោះឡើយ ។ ចំណែកឯស្រីៗវិញ អង្គុយរង់ចាំពេលស្លាប់ទាំងភ័យរន្ធត់ញាប់ញ័រ ។

ចុះនៅពេលនោះ អតីតសមាជិកបក្សប្រជាជនបដិវត្តន៍ខ្មែរដែលជាអតីតខ្មែរ វៀតមិញក្រុមទី១ដែលមាន ៖ តាប៉ែត, តាកៅ, មិត្តលី, មិត្តលៃ, មិត្តរឿន ហើយដែលសុទ្ធជាប្រធានសហករណ៍ ជាគណៈតំបន់ និងជាតំណាងរាស្ត្រ... តើអង្គការជាក់ទិសទៅណាអស់ហើយ ?

ស្ងាត់ឈឹង ! បាត់អស់ដូចគេសន្មត់ !?!? ។

# ដំណាក់ការដែលអង្គការត្រូវសម្លាប់ប្រជាជនខ្មែរ ដោយអាវុធធម្មជាតិម្តងទៀត

ក្នុងខែមករា១៩៧៩ បក្សខ្មែរក្រហមនិរតីកាន់អំណាចបានទាំងស្រុង ។ វាបង្ខំខ្មែរឲ្យច្រូតកាត់ បោកបែន បញ្ជាន់ទាំងយប់ទាំងថ្ងៃ ប្រមូលស្រូវច្រកបាវ រួចដឹកទៅកាន់ទីអាថ៌កំបាំងអស់រលីង ។ រួចហើយវាដុតចំបើងចោលភ្លាម ។ លុះវាដឹកស្រូវនិងដុតចំបើងរួចរាល់ស្រេចបាច់ហើយ ទើបវាចាប់កៀរប្រជាជនថ្មីជាច្រើនសែននាក់ឲ្យដើរតាមវា ។ ប្រជាជនទាំងនោះត្រូវវាកៀរមកពីតំបន់សហករណ៍នានាដូចជា ៖ សហករណ៍ព្រៃតូច, កំពង់ព្រះ, វាំងកេសី, អូរស្រឡៅ, អូរដំបង, អាចម៍សេះ, លក់ជ្រៀវ, ភ្នំធិបតី ។ល។ វាកៀរទៅសំណាក់នៅ ៖

| | |
|---|---|
| - ភូមិចែហួយ | ចំនួន១២យប់ |
| - ភ្នំជើងទេញ | ចំនួន១៥ថ្ងៃ |
| - បឹងជីមក់ | ចំនួន១០ថ្ងៃ |
| - ភូមិឈ្លាវ | ចំនួន១០ថ្ងៃ |
| - ត្រឡប់មកភូមិចែហួយ | ចំនួន៦ថ្ងៃ |
| - ភូមិចាមល្អ | ចំនួន៩ថ្ងៃ |
| - ក្បាលសាយ | ចំនួន៣ថ្ងៃ |

រួចហើយវាកៀរត្រឡប់ថយក្រោយវិញ ដើរទាំងយប់ទាំងថ្ងៃ កាត់តាមភូមិចាមល្អនិងចែហួយ ហើយវាកៀរមកសំណាក់នៅភូមិស្រែអូរអស់ចំនួន៧ថ្ងៃ ។ សូមបញ្ជាក់ថា ភូមិទាំងអស់នេះ ស្ថិតនៅខាងលិចផ្លូវជាតិលេខ៥ ។ នៅថ្ងៃ៥-៤-៧៩ ពេលថ្ងៃត្រង់ វាកៀរប្រជាជនមកដល់ផ្លូវជាតិលេខ៥ សំដៅទៅភូមិកកោះ ភូមិអូរតាម៉ៀវ រួចវាកៀរបន្តទៅកាន់ឃុំទួលព្រាំ, ឃុំជ្រៃ និងមាត់ព្រៃរនាម ដែលស្ថិតនៅចម្ងាយជាច្រើនគីឡូម៉ែត្រខាងកើតផ្លូវជាតិលេខ៥ ។ វាកៀរទៅកៀរមកតាមបណ្តោយព្រៃរនាមអស់រយៈពេល១០ថ្ងៃទៀត ។ រួចហើយស្រាប់តែវាកៀរត្រឡប់មកផ្លូវជាតិលេខ៥វិញ ។ លទ្ធផលគឺនៅពេលនោះ មនុស្សចាស់ជរា អ្នកមានជម្ងឺធ្ងន់ និងកូនក្មេងអាយុក្រោម៣ឆ្នាំ ត្រូវស្លាប់ជាបន្តបន្ទាប់គ្នា ។ សូមបងប្អូនខ្មែរមេត្តាពិចារណាមើលថា តើក្នុងរយៈពេល៣ខែ ដែលពួកវាគៀបប្រជាជន ម្តងឲ្យទៅមុខ ម្តងឲ្យថយក្រោយនោះ តើអ្នករងគ្រោះបានអ្វីបរិភោគ ? តើបានភ្លើងឯណាមកដុតកំ-

ដៅខ្លួនដើម្បីទប់ទល់នឹងធាតុអាកាសរងាររញ៉េរញ៉ៃក់នៅពេលយប់ ? ឱទេវតាអើយ ហេតុអ្វីក៏យើងវេទនាម្ល៉េះ ?

នៅពេលនោះអ្នកណាដែលរកបានស្រូវបន្តិចបន្តួច ក៏ជីកដីធ្វើត្បាល់ដើម្បីបុកស្រូវយកអង្ករ ដោយផ្ទំអង្កាមបង្កើរចេញពីរន្ធដី រួចរើសយកអង្ករមួយចិបៗនោះមកដាំបបរសាប ឥតអំបិល ចែកគ្នាបរិភោគ ។

ពេលភ្លៀងធ្លាក់មកម្តងៗ នាំគ្នាអង្គុយត្របោមក្បាលជង្គង់កំប្រោនៗកណ្តាលវាល កណ្តាលព្រៃ ហាលខ្យល់ ។ លុះដល់ភ្លៀងធ្លាក់រួចហើយ ទើបនាំគ្នាដើររកអុសដុត ដើម្បីឆ្អើរខោអាវឲ្យស្រពាប់ស្ងួត ដើម្បីដើរតាមឲ្យគេកៀរតទៅទៀត ។ ឥឡូវកំណែនមនុស្សបានមកដល់ស្រុកមោងឫស្សី ក្បែរផ្លូវជាតិលេខ៥ម្តងទៀត ។ ប្រជាជនខ្លះៗដែលគ្មានរទេះគោជាជំនួយកម្លាំង ហើយដែលខំរែកសំបុកសម្បត្តិបន្តិចបន្តួចលើស្មា ក៏ដួលដេកនៅលើដីយ៉ាងខ្លោចផ្សា ។ អ្នកដែលនៅឈរបាន ក៏ត្រូវគេកៀរបន្តទៅទៀតជាហូរហែរ ។ លុះដើរថយក្រោយមកដល់ឫស្សីក្រាំងនិងភូមិព្រៃខ្លូត ទើបគ្រប់ៗគ្នាភ្ញាក់ដឹងថា ៖

ឱ ! អង្គការនាំយើងមកឲ្យស្លាប់ដោយអារុំធធម្មជាតិទេតើ ! ហេតុអ្វី ? ព្រោះភូមិនេះជារហោស្ថាន គ្មានស្រូវ គ្មានទឹកទាល់តែសោះ ! ប្រជាជនខ្លះត្រូវស្លាប់ដោយខ្សោះជាតិទឹកអស់ពីខ្លួន រកទឹកមិនបាន ។ មានអ្នកខ្លះប្រថុយផឹកទឹកនោម អ្នកខ្លះទៀតត្រងទឹកនោមគោយកមកផឹក ! គឺវេទនាអស្ចារ្យណាស់ ។ល។ ចុះអស់មិត្តៗបក្សខ្មែរក្រហមនិរតី អតីតខ្មែររៀតមិញក្រុមទី២ ដែលជាអ្នកដឹកនាំវិញ នៅពេលដែលប្រជាជនកំពុងតែចលាចលរកពុទ្ធោយ៉ាងនេះ តើគេធ្វើអ្វី ?

★ បាត់ស្រមោល ! គេមិនដឹងថានៅពេលណាទេដែលពួកវាគេចខ្លួនបោះបង់ពួកប្រជាជនទាំងនោះ ក៏នាំគ្នាបកវិលត្រឡប់មកកាន់ផ្លូវជាតិលេខ៥នៅវត្តស្វាយវិញ ។

★ នឹកៗទៅគួរឲ្យអាសូរដល់ប្រជាជនខ្មែរជាក្រៃលែង កំពុងតែរងទុក្ខវេទនាដើរតាមកំណែនពាសវាលពាសកាល ពេញព្រៃយ៉ាងដូច្នេះ... អ្នកខ្លះត្រូវជួបបងជួបប្អូន មាមីងដោយចៃដន្យ ក៏លោតឱបគ្នាយ៉ាងស្ងួត មិនដឹងថាត្រូវសើចឬត្រូវ យំ ។ ពេលជួបគ្នានេះក៏រ៉ាយរ៉ាប់ប្រាប់បងប្អូនថា ក្រុមខ្លួនជាច្រើនម៉ឺននាក់ត្រូវអង្គ-ការជម្លៀសចេញពីខេត្តនានា មានខេត្តកំពង់សោម កំពង់ស្ពឺ មណ្ឌលគិរី រតនគិរី ជាដើម តាំងពីខែវិច្ឆិកា១៩៧៨ ប្រាប់ថាឲ្យមកកាន់ខេត្តបាត់ដំបង ។ នៅតាមផ្លូវរាប់ខែ អ្នកដើរត្រូវស្លាប់ដោយការអត់បាយ អត់ទឹក ដោយសារជម្ងឺគ្រុនចាញ់។ គ្រួសារខ្លះត្រូវស្លាប់ផុតពូជ គ្រួសារខ្លះនៅសល់តែប្តី គ្រួសារខ្លះនៅសល់តែប្រពន្ធ ឬកូន។ មានបុរសខ្លះស្រាប់តែបានជួបអតីតប្រពន្ធរបស់ខ្លួន តែ! អង្គការបាន «ផ្សំផ្គុំ» ប្រ

ពន្ធរបស់ខ្លួនឲ្យទៅបុរសម្នាក់ទៀតរួចទៅហើយ ។ ឯស្ត្រីខ្លះទៀត ក៏អង្គការបានចាប់ប្តីជាទីស្រឡាញ់របស់ខ្លួន រៀបការទៅនារីផ្សេងទៀតទៅវិញហើយ ។ តើទុក្ខសោកនៃជនទាំងនោះមានទំហំប៉ុនណា ? លទ្ធផល...អ្នកខ្លះក៏ធ្វើឃាតទៅ !

ទោះជាបានជួបគ្នាយ៉ាងណាក៏ដោយ អង្គការនៅតែបន្តកំណែនមនុស្សឲ្យទៅតាមកងរៀងៗខ្លួនតទៅទៀត ។

❑ ❑

❑

## ដំណាក់ការដែលត្រូវសម្លាប់យុវជនចល័ត

យាយទៀងត្រូវគេកៀរនៅក្នុងកងមួយជាមួយអ្នកឯទៀត ។ គាត់ដើរតាមគេតាមឯង អស់បងប្អូន កូនចៅប្តីក្មួយ រលីងពីខ្លួនហើយ...។

នៅម៉ោង១រសៀលនៃថ្ងៃ១៣-២-៧៩ គាត់ក្រឡេកឃើញដំបូកធំមួយ ដែលមើលពីចម្ងាយទៅមានម្លប់ត្រឈៃ គួរបានជាទីកន្លែងមួយសំរាប់ធ្វើទីសំរាកជ្រកកំដៅថ្ងៃដ៏ក្តៅ ។ គាត់ក៏ដើរសំដៅទៅ«រមណីយដ្ឋាន»នោះ ដើម្បីសំរាកយកកម្លាំងមុននឹងបន្តដំណើរទៅមុខទៀត ។

ទៅដល់ដំបូក ! ពុទ្ធោ ! ខ្មោចយុវជនមួយគំនរស្លាប់គរជើងលើគ្នា មានទាំងដំបងមួយគំនរធំប្រឡាក់ឈាមនៅស្រស់ៗនៅឡើយ...។ គាត់ភ័យរន្ធត់ឥតឧបមាដោយឃើញខ្មោច ជាពិសេសដោយឃើញដំបងដែលជាអាវុធរបស់ខ្មាំងសំរាប់វាយកញ្ចក់សម្លាប់ខ្មោចទាំងនោះ ។

កំពុងតែស្លន់ស្លោបែបនេះ សម្លេងក្មេងស្រីម្នាក់ក៏បន្លឺឡើងនៅក្រោយខ្នងគាត់ ៖ « ម៉ាក់ៗ » ។ នារីក៏ស្ទុះមកឱបម្តាយដោយក្តីនឹករឭក ។ គឺឃឿទ្រីវ៉ាជា កូនស្រីទី២របស់យាយទៀងដែលអង្គការបំបែកចេញពីគាត់ទៅ តាំងពីខែឧសភា១៩៧៥ម្ល៉េះ ។ វ៉ាជាក៏បណ្តើរម្តាយចុះពីស្ថាននរកនេះ ហើយឧទានឡើងថា ៖ ម៉ាក់អើយ! ខ្មោចទាំងនេះគឺជាខ្មោចពួកចល័តដែលអង្គការប្រមូល មកវាយសម្លាប់នៅយប់មិញនេះឯង ។

យាយទៀងគិតថា ៖ ក្នុងរយៈពេលបីខែដែលអង្គការធ្វើទារុណកម្ម ដោយកៀរប្រជាជនឲ្យដើរទៅមុខ រួចថយក្រោយ រួចទៅមុខបែបនេះ, ក្រុមឃាតករអាថ៌

កំបាំងមួយក្រុម ក៏កំពុងតែសម្លាប់យុវជនចល័តដែរ ។ ( នៅពេលនោះ យាយទៀងបាត់កូនកម្លោះទី៤របស់គាត់ឈ្មោះ យឺទ្រីភូម៉ារ៉ា ។ ក្មួយកម្លោះបង្កើតរបស់គាត់ត្រូវវាវាយសម្លាប់ចោល ) ។ តែនៅក្នុងពេលដ៏សែនវេទនាបែបនេះ គ្រប់ៗគ្នាខំត្រដររយោងអាត្មាទៅមុខ គ្មានបានឮ គ្មានបានដឹង អំពីកលល្បិចដ៏ថោកទាបនិងព្រៃផ្សៃរបស់អង្គការចិត្តឃោរឃៅ ដែលចាត់ការសម្លាប់យុវជនចល័តជាចុងក្រោយនោះឡើយ ។

រ៉ាដាក៏កាត់អារម្មណ៍របស់ម្ដាយដោយនិយាយបន្តថា ៖ ចំណែកខ្ញុំ... ខ្ញុំរត់ចេញមកពីអង្គភាពនៅយប់មិញនេះ បានជួបមីងភឹននេះ... រួចនាងក៏ចង្អុលមកស្រីម្នាក់អាយុប្រហែល៣៧ឆ្នាំ ដែលឈរនៅក្បែរនោះ ។ មីងភឹនប្រាប់ខ្ញុំថាម៉ែដើរមកកាន់ទីនេះ ហេតុនេះហើយបានជាខ្ញុំមកឃើញម៉ាក់...។ ម៉ែ និងកូនព្រមទាំងភឹន ក៏បណ្ដើរគ្នាទៅតាមកំណែនតទៅទៀត ។

នៅថ្ងៃទី១៨-៣-៧៩ នៅពេលដែលគេកៀរពួកយើងមកដល់ក្បាលសាយ យាយទៀងបានឃើញកូនប្រុសទី៥ ដែលអង្គការបំបែកចេញតាំងតែពីខែឧសភា ១៩៧៥ដែរ ។ នៅពេលដែលបានឃើញគ្នា ទាំងពីរនាក់ម៉ែកូន គាំងមាត់រកនិយាយមិនចេញ បានត្រឹមតែសម្លឹងមុខគ្នា រួចហើយកូនប្រុសនិងម្ដាយ ក៏ត្រូវព្រាត់គ្នាតទៅទៀតតាមកំណែនរបស់ក្រុមរៀងៗខ្លួន ។

នៅថ្ងៃទី១៦-៤-៧៩ ម៉ោងប្រហែលមួយរសៀល ស្រាប់តែឮស្នូរកាំភ្លើងធំបាញ់ផ្ទក់ជុំទិស មិនដឹងជានរណាបាញ់នរណា ហើយមានគោលដៅធ្វើអ្វីទេ ។ លុះមានព្រឹត្តិការណ៍ចម្លែកយ៉ាងនេះ ប្រជាជនខ្លះដែលសំណាក់នៅក្នុងវត្តស្វាយ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ដោយធុញទ្រាន់លែងចង់រស់តទៀតហើយ ក៏ស្រែកឡើងថា ៖

– មិត្តអើយ បាញ់ទៅ ! បាញ់ទៅ ! កុំសំរាក ! បាញ់ទៀតទៅ ! ខ្ញុំវេទនាណាស់ បាញ់ទៀតទៅ ! បើស្លាប់ក៏ស្លាប់ឲ្យហើយទៅ... កុំឲ្យខ្ញុំរស់យ៉ាងនេះទៀត ! ។

ស្នូរកាំភ្លើងត្បាល់លាន់ឮបន្តទៅទៀត ម្ដងញាប់រន្ថើន ម្ដងរង្វើល ម្ដងស្ងាត់ឈឹង រួចហើយក៏ស្រែកគ្រហឹមតទៅទៀត អស់រយៈពេល២ថ្ងៃ២យប់ ដោយមិនដឹងជាមានហេតុអ្វី ។

នៅពេលនោះ បក្សខ្មែរក្រហមនិរតីដែលជាអតីតខ្មែរវៀតមិញក្រុមទី២ ហើយដែលជាតំណាងអង្គការអនាមិកចុងក្រោយបង្អស់ បានរត់គេចមុខបាត់អស់រលីងទៅហើយ ។

❑ ❑

❑

# ជំពូកទី១៧

★ ប្រជាជនខ្មែរបានរួចខ្លួនពីកណ្ដាប់ដៃអង្គការ
★ វត្តមាននៃបូជួយ១៧នាក់
★ ហេតុយ៉ាងដូចម្ដេចបានជាហូ-ជីមិញបង្កើតបក្សកុម្មុយនិស្ដឥណ្ឌូចិន ?

## ប្រជាជនខ្មែរបានរួចខ្លួនពីកណ្ដាប់ដៃអង្គការ

នៅល្ងាចថ្ងៃទី១៨-៤-៧៩ វេលាម៉ោង៥រសៀល ស្រាប់តែឃើញមនុស្សម្នាក់មាឌមាំ មុខផ្គាមខ្លា ស្លៀកពាក់ខ្មៅ ក្រមាវ័ណ្ឌក អាយុប្រហែល៣៥ឆ្នាំ ផាយលើខ្នងសេះយ៉ាងលឿន ស្រែកប្រកាសវាមមីក្រូប្រាប់ប្រជាជនថា ៖

– សង្គ្រាមចប់ហើយ... យើងរួចខ្លួនហើយ យើងអាចចូលទីក្រុងបាត់ដំបងបាន !... ប៉ុន្តែ ! មនុស្សដឹចម្លែកនេះ ហាមមិនឲ្យដើរតាមផ្លូវជាតិលេខ៥ទេ ។ វាបញ្ជាឲ្យដើរវៀងទៅកាន់ភូមិអន្លង់កូប ។ យើងត្រូវចំណាយពេលអស់មួយយប់និងកន្លះថ្ងៃ គឺនៅថ្ងៃទី១៩-៤-៧៩ ពេលថ្ងៃត្រង់ ទើបយើងដើរទៅដល់ ។

ទៅដល់ស្រុកអន្លង់កូប ឃើញមនុស្ស៤នាក់ ស្លៀកពាក់ខ្មៅ ក្រមាវ័ណ្ឌក ដូចតែខ្មែរក្រហមដដែល ឈរចេញបញ្ជាយ៉ាងដាច់ណាត់ ឲ្យចុះឆ្លងស្ទឹងតែតាមកន្លែងមួយ ដែលមានប្រវែងផ្លូវទទឹងប្រហែលជា៥ម៉ែត្រប៉ុណ្ណោះ ។ ប្រជាជនរាប់ម៉ឺននាក់ត្រូវឈរចាំវេនដើម្បីឆ្លង នៅក្រោមកំដៅថ្ងៃនៃខែមេសា ដែលជាខែក្ដៅហួតហែងខ្លាំងបំផុតនៅស្រុកខ្មែរ...។

រួចហើយត្រូវឆ្លងស្ទឹង ពីត្រើយខាងកើតទៅត្រើយខាងលិច ដើម្បីសំដៅទៅទីប្រជុំជនស្រុកមោងឫស្សី ដោយដើរតាមផ្លូវថ្នល់ស្របបណ្ដោយមាត់ស្ទឹង ។

❑

# វត្តមានរបស់ប៉ូជ្វយ១៧នាក់

នៅពេលដែលយើងចុះទៅដល់កណ្តាលស្ទឹង ខ្មែរទាំងអស់ភ្ញាក់ព្រើត ដោយឃើញឡាន GMC មួយគ្រឿងដែលជាប់ផុងនៅកណ្តាលស្ទឹង ។ នៅក្បែរនោះ គេឃើញកូនឃ្មួនហាណូយចំនួន១៧នាក់ មានអាយុមិនលើសពី២០ឆ្នាំ មានអាវុធមិនគ្រប់គ្នាទេ ។ ក្មេងៗយួនទាំងនេះស្រែកចេកចាចដូចសត្វស្វា សួររកអ្នកចេះផាសាយួន សុំជួយអំពាវនាវរកមនុស្សជួយរុញឡានសំដៅទៅត្រើយខាងកើត ។

ចំណែកប្រជាជនខ្មែរដែលបានឃើញប៉ូជ្វយទាំង១៧នាក់ ក៏ឈរមើលភ្លឹក ម្នាក់ៗមានយោបល់ខុសគ្នា ៖

★ ក្រុមទី១ ៖ ជាមនុស្សដែលមិនបានត្រិះរិះពិចារណាឲ្យបានដិតដល់ ក៏ញញឹមត្រេកអរ មានមនោសញ្ចេតនាសរសើរកោតក្រែងប៉ូជ្វយដ៏ក្លាហាន ដែលស្ម័គ្រចិត្តមកជួយខ្មែរ ឲ្យចាកផុតពីចង្កូមមច្ចុរាជគឺអង្គការ ។

★ ក្រុមទី២ ៖ ជាមនុស្សដែលបាក់ស្បាត ក៏ភ័យស្លន់ស្លោខ្លាចក្រែងអង្គការដ៏មហិមា មានបង្កប់អាថ៌កំបាំងអ្វីទៀត ដើម្បីសម្លាប់ប្រជាជន ហើយកៀរពួកខ្លួនឲ្យត្រឡប់ថយក្រោយទៀត ។

★ ក្រុមទី៣ ៖ កេះគ្នាឈរសម្លឹងកូនយួនហាណូយទាំង១៧នាក់ ដែកហ៊ានមកជួយរំដោះខ្មែរនោះ នឹកក្នុងចិត្តរៀងៗខ្លួនថា ចុះហេតុម្តេចបានជាអង្គការមិនចេញមកធ្វើអន្តរាគមន៍ដេញកំចាត់កូនយួន ដែលជាបរទេសនេះឲ្យចេញពីស្រុកខ្មែរទៅ ? តើអង្គការអង្គការរវល់ធ្វើអ្វីនៅពេលនេះ ?

ក្នុងចំណោមមនុស្សក្រុមទី៣នេះ មានស្រីមេម៉ាយចំនួន១៤នាក់ បបួលគ្នាសម្លឹងកូនយួនហាណូយយ៉ាងយកចិត្តទុកដាក់ ។ មួយស្របក់ទើបនាំគ្នាឆ្លងស្ទឹងទៅកាន់ត្រើយខាងលិច រួចហើយទើបបបួលគ្នាឈប់សំរាក ។ ស្រីៗខ្លះអង្គុយឱបក្បាលជង្គង់ ខ្លះទម្រេតខ្លួនយកដៃទ្រក្បាល ខ្លះដេកផ្ងាល់ដីកើយដៃ នាំគ្នាអស់សង្ឃឹមព្រោះទើបនឹងបានចេញផុតពីកណ្តាប់ដៃអង្គការ ស្រាប់តែឥឡូវមកចូលស៊ងចំកណ្តាប់ដៃយួនហាណូយទៀត។ ម៉ោងប្រហែលបួនរសៀល ស្រីៗទាំងនោះក៏បបួលគ្នាបំរុងនឹងធ្វើដំណើរទៅមុខទៀត ។ យាយទៀងដែលមានអាយុជាង៥០នៅពេលនោះ គាត់មានអាយុច្រើនជាងគេនៅក្នុងចំណោមក៏គ្រវីក្បាល ព្រមទាំងឆ្លើយថា ចាំគាត់គិតមើលសិន ។ គាត់គិតថា ៖ ចំពោះក្មេងៗយួនទាំង១៧នាក់ ដែលមានអាវុធមិនគ្រប់គ្នាផងនេះ ហើយវាហ៊ានមក«អុងអាត់» នៅស្រុកខ្មែរកណ្តាលព្រៃដាច់ស្រ

យ៉ាលដោយសេរី ដូចជាមិមសមទំនងទាល់តែសោះ ។ នេះគឺជាកញ្ចក់ទិព្វមួយដែ-លអាចចង្អុលឲ្យយើងឃើញនូវព្រឹត្តិការណ៍នានា ដែលបណ្តាលឲ្យស្រុកខ្មែរវិនាស ហិនហោចទាំងប្រជាជន ទាំងទ្រព្យសម្បត្តិដល់ថ្នាក់នេះ ។

គាត់ក៏នឹកទៅដល់សេចក្តីប្រកាសជាផ្លូវការរបស់ហូ-ជីមិញ ដែលបានថ្លែងកា-លពីថ្ងៃ២០-៩-៥២ថា «ត្រូវតែវាតទឹកដី យកឧបទ្វីបឥណ្ឌូចិន ចាប់តាំងពីមាត់ទ្វារនៃប្រទេសចិនភាគខាងត្បូង រហូតទៅដល់ជ្រោយទឹកខ្មៅ ចាប់តាំងពីជួរភ្នំឥណ្ឌូចិនប៉ែកខាងកើត រហូតទៅទល់នឹងត្រើយទន្លេមេគង្គ... រួចត្រូវកែឆ្នៃប្រទេសទាំងបីនៃឧបទ្វីបនេះឲ្យទៅជាកុម្មុយនិស្តឥណ្ឌូចិនជាស្ថាពរ ។ល។» ។

យាយទៀតគិតមកដល់ត្រឹមណោះ គាត់មានការឈឺចាប់ជាក្រៃលែង គាត់ខកខូចចិត្ត ទៅមុខលែងរួច ទៅក្រោយលែងកើត ។ គាត់អង្គុយឱបក្បាលជង្គង់ ខំនឹកឡើងវិញ នូវទារុណកម្មទាំងឡាយដែលប្រជាពលរដ្ឋខ្មែរ ត្រូវទទួលរងគ្រោះក្នុងរយៈពេល៨ឆ្នាំគត់ ព្រោះតាំងពីដូនតាមក ខ្មែរមានចរិកសុភាព ទន់ភ្លន់ ស្លូតបូត សុចរិត ។ ជាពិសេសមានសីលធម៌ មេត្តាធម៌ និងសប្បុរសធម៌ ដោយមកពីខ្មែរជាអ្នកកាន់ពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន ។ តែហេតុយ៉ាងដូចម្តេចបានជាក្នុងកំឡុងបួនឆ្នាំនេះខ្មែរដែលគ្រាន់តែពាក់ឃីហៅខ្មែរក្រហម គ្រាន់តែជាតំណាងរបស់អង្គការ ក៏ក្លាយទៅឃាតករយ៉ាងសាហាវ ហ៊ានសម្លាប់ម៉ែឪឯង បងបង្កើត ប្អូនបង្កើតរបស់ខ្លួនឯងរហូតដល់សាសន៍ខ្មែរគ្នាឯងទាំងមូលដូច្នេះទៅវិញ ? មិនសមទេ ! ។ គាត់ពិចារ-ណាតទៅទៀតថា ៖ អ្នកដែលរងគ្រោះថ្នាក់ស្លាប់នោះ គឺអ្នកចេះដឹង មានគតិបណ្ឌិតស្នេហាជាតិយ៉ាងមោះមុត គឺជាអ្នកប្រាជ្ញ ទាំងព្រះសង្ឃទាំងគ្រហស្ថ រួមសេចក្តីមក គឺជាមនុស្សដែលជាភ្នែកច្រមុះរបស់ខ្មែរ ។ វាទុកឲ្យនៅរស់ ហើយលើកបន្តុប់តែពួកខ្លៅ ដើម្បីស្រួលញាក់ខ្សែ ។ គាត់នឹកទៅដល់ឆ្នាំ១៩៤៥ ដែលគាត់បានឃើញផ្ទាល់ភ្នែកនៅកម្ពុជាក្រោម ដែលនៅពេលនោះយួនហាណូយជាវៀតមិញ បានញុះញង់ខ្ញីដៃយួនខាងត្បូង ឲ្យសម្លាប់បំផុតពូជខ្មែរកម្ពុជាក្រោមនិងប្លន់ទ្រព្យសម្បត្តិដុតផ្ទះចោលវីវក់ ។

ឥឡូវនេះ, ថ្ងៃទី១៩-៤-៧៩ ម៉ោងប្រហែល៩រសៀល, វត្តមានរបស់កូនយួនទាំង១៧នាក់នេះ អាចឆ្លុះបំបាត់ចម្ងល់របស់យាយទៀងពីអម្ពតហេតុទាំងឡាយដែលកើតឡើងនៅស្រុកខ្មែរ តាំងពីបួនឆ្នាំមកហើយ ហើយគាត់យល់ថា តាំងនេះមិនមែនកើតឡើងដោយចៃដន្យទេ មុខជាមានអាថ៌កំបាំងអ្វីមួយរបស់យួនហាណូយដែលលាក់បង្កប់នៅក្នុងនោះជាមិនខាន ។ ឧទាហរណ៍ដែលបានរៀបរាប់រួចហើយនៅតំបន់១ នៃខេត្តបាត់ដំបង កាលពីឆ្នាំ១៩៧៦ ជាភស្តុតាងស្រាប់ ។ គឺយាយទៀងបានឃើញផ្ទាល់ភ្នែកនូវអតីតខ្មែរវៀតមិញ ដែលមានតាប៉ែត តាកៅ មិត្តលីជាដើម

ដែលចេញមុខមកកាន់តំណែងជាប្រធានសហករណ៍ ជាគណៈតំបន់ រួចបន្តមកទៀតជាតំណាងរាស្ត្រ...។ គាត់គិតទៅដល់បណ្តាំចុងក្រោយរបស់លោកគីម-ង្គួនត្រាច ដែលជាហេតុធ្វើឲ្យគាត់ដុះគំនិត ត្រូវតែស្រាវជ្រាវរែកញែករកមុខអង្គការអនាមិកឲ្យឃើញ ។ គាត់នឹកឃើញដល់ខ្មែរមួយនគរ ដែលត្រូវរងគ្រោះថ្នាក់ទាំងគ្រួ ហើយដែលភាគច្រើនបានឃើញដោយផ្ទាល់ភ្នែក នូវឃាតករដែលចាប់ចងឪពុកម្តាយ កូនក្មួយ ប្រពន្ធ ប្តីរបស់ខ្លួន ដោយគ្មានជំនុំជំរះអ្វីទាំងអស់ ក្រៅតែពីពាក្យមួយម៉ាត់ថា គេធ្វើតាមបញ្ជាអង្គការ ឬទុកមិនចំណេញ...។ រួមសេចក្តីមក ខ្មែរដែលត្រូវគេសម្លាប់អស់ជិត៣លាននាក់ មិនទាន់បានដឹងថា ខ្លួនមានកំហុសអ្វីនៅឡើយទេ ។

អស្ចារ្យណាស់ៗ អង្គការគ្មានរូបគ្មានរាងទេ តែហេតុម៉េចក៏អង្គការបញ្ចេញគ្នាវាជាក្រុមៗ ជាដំណាក់ៗ អាចសម្លាប់ខ្មែរបានដោយសេរី តាមពេលវេលា តាមកំណត់បានយ៉ាងនេះ ? អង្គការអាចដឹងថាតើក្រុមណាត្រូវសម្លាប់ខ្មែរយោធាស្រឡាញ់សម្តេចឪ តើក្រុមណាត្រូវសម្លាប់ខ្មែរក្រហមដែលកើតមកពីចោរ, តើក្រុមណាត្រូវសម្លាប់ខ្មែរក្រហមរបស់ខៀវ-សំផន, តើក្រុមណាត្រូវនាំយោធាក្មេងៗទៅលត់ដំ ? ។ល។ ទីបំផុតតើអង្គការត្រូវដាក់អ្នកណាឲ្យកាន់កាប់ស្រុកខ្មែរ នៅក្នុងកាលៈទេសៈជាបន្តមកទៀត ? តើខ្មែរក្រហមនិរតីដែលសម្លាប់ខ្មែរក្រហមជំនាន់មុននោះ មិនមែនជាគំរោងរបស់អង្គការទេឬអ្វី ? បន្ទាប់ពីវត្តមានរបស់ខ្មែរក្រហមនិរតីមក ហេតុអ្វីក៏មានយួនចូលមកជួយរំដោះខ្មែរពីខ្មែរក្រហម ? ។ វាយកលេសថាចូលមកជួយខ្មែរជាលើកទី៣ ។ តែទីបញ្ចប់គាត់យល់ថា នេះជាកលល្បិចរបស់យួនហាណូយទាំងស្រុង ដែលវាគោរពធ្វើតាមបញ្ជាហូ-ជីមិញ ដើម្បីពង្រឹងពង្រីកជ្រោយឧបទ្វីបឥណ្ឌូចិន ឲ្យក្លាយទៅជាកម្លាំងអមតៈ មានអនុភាពខ្លាំងក្លានៅតំបន់អាស៊ីអគ្នេយ៍ ។ យាយទៀងនឹកឃើញមកដល់ត្រង់ណេះ ក៏ចោលផ្នែកសម្លឹងរកមើលកូនយួនទាំង ១៧នាក់ម្តងទៀត តែ ! បាត់ស្រមោល, ពួកវាឆ្លងស្ទឹងហួសទៅហើយ ។ ដូចភ្ញាក់ពីយលសប្តិ គាត់ក៏ស្រែកឡើងថា ខ្ញុំយល់ហើយ ! ខ្ញុំយល់ហើយ ! ។

មិត្តស្រីមេម៉ាយៗមើលមុខយាយទៀង ហើយកាត់យល់ថា គាត់ច្បាស់ជាយល់ពីរឿងវត្តមានរបស់កូនយួននោះហើយ។ គេមិនឆ្លើយតបអ្វីទេ។ តែនៅក្បែរនោះ ភិនក៏*អ៊ូឡើងថា ៖ «តើអង្គការក្តី, ខ្មែរក្រហមជាឃាតករដ(សាហាវយង់ឃ្នងក្តី វាងាប់តែហោងទៅណាអស់ហើយ បានជាវាមិនមកយកថ្លើមអាកូនយួនទាំង១៧នាក់នៅទៅស៊ីទៅ ?» ។

- ភិនអើយ ! សំនួរនេះពេញចិត្តបងណាស់ ! យាយទៀងតបទៅនាងភិនវិញ ។ ដូច្នេះនៅយប់នេះ យើងត្រូវតែសំរាកនៅទីនេះសិន ហើយដើម្បីនឹងតាមដានពួកកូនយួនទាំងនេះមើលថា តើវាមកធ្វើអ្វីនៅស្រុកយើង ។ តើវាមានជួបឧបសគ្គអ្វីទេ

**ថាបើវាគ្មានឧបសគ្គអ្វីទេនោះ យើងអាចសន្និដ្ឋានថា អង្គការអនាមិកជាយួនហាណូយយ៉ាងពិតប្រាកដ ។**

យប់នោះយាយទៀងដេកផ្ងាល់ដី ក្បាលកើយលើបង្វិចដែលជាទ្រព្យសម្បត្តិសំណល់ចុងក្រោយរបស់គាត់ ។ គាត់យកដៃគងថ្ងាសសម្លឹងមើលមេឃនារាត្រីដោយបណ្ដែតអារម្មណ៍របស់គាត់ឆ្ងាយទៅៗ ដែលមិនដឹងថា តើស្នែកនេះគាត់ត្រូវដើរទៅទីណាវិញទេ បើពេលនេះ ចេញពីមាត់អង្គការ តែបែរជាចូលមកជាប់អន្ទាក់យួនហាណូយទៅវិញ ។

❑ ❑

❑

# បក្សកុម្មុយនិស្តឥណ្ឌូចិន

នៅពេលនោះមានមិត្តរបស់គាត់ម្នាក់ក៏សួរឡើងថា ៖ បង ! ហេតុម៉េចបានជាហូ-ជីមិញបង្កើតបក្សកុម្មុយនិស្តឥណ្ឌូចិន ?

★ យួនហាណូយជាសាសន៍ព្រៃផ្សៃ វាតែងតែដើររំលោភរាតត្បាតលុកលុយប្រទេសជិតខាង ជាច្រើនសតវត្សមកហើយ ។ វាបង្កើតបក្សនេះដើម្បីរកទឹកដីឲ្យកូនចៅវានៅ ។ ហូ-ជីមិញដឹងថា នៅក្នុងឆ្នាំ២០០០ ប្រទេសយួនមានចំនួនប្រជាជនជាង៦០លាននាក់ ។ ផ្ទៃដីទាំងអស់មាន៣៣០,០០០គីឡូម៉ែត្រក្រឡា តែផ្ទៃដីដែលអាចរស់នៅដើម្បីប្រកបអាជីវកម្មបានគឺមានតែ២០%តែប៉ុណ្ណោះ ដែលត្រូវនឹងទំហំ៦៦,០០០គម២ ។ ៦០លាននាក់ នៅលើផ្ទៃដី៦៦,០០០គម២ បានសេចក្ដីថា មានប្រជាជនយួន៩១០នាក់ ក្នុង១គម២ ។ ចំណែកនៅស្រុកខ្មែរវិញ ១គម២មានខ្មែរជាង៣០នាក់ (៣០ដងតិចជាង) ។ ផ្ទៃដីនៅសល់ច្រើនណាស់នៅស្រុកខ្មែរ ។ មូលហេតុនេះទើបនៅថ្ងៃទី៣-២-៣០ ហូ-ជីមិញសំរេចបង្កើតបក្សកុម្មុយនិស្តឥណ្ឌូចិន ក្នុងគោលគំនិតដ៏លោភលន់អស្ចារ្យ ដែលវាស្រមៃថា ពេលណាគោលបំណងរបស់វាបានសំរេចជាស្ថាពរ យួនហាណូយដែលមានខ្លួនវាជាមេដឹកនាំ នឹងក្លាយទៅជាសាសន៍មួយដ៏ខ្លាំងពូកែដាច់គេនៅអាស៊ីអាគ្នេយ៍នេះ ។ កាលណោះប្រជាជននៅក្នុង«ដែនដីរំដោះ» ត្រូវតែស្រែកបន្ទថា ៖ ហូ-ជីមិញនឹងមានអាយុមួយម៉ឺនឆ្នាំ ! « Hô

Chi Minh sông muôn nam !» ។

ដូច្នេះហើយ ដើម្បីអនុវត្តគំរោងការរបស់វាឲ្យឆាប់បានសំរេច និងដើម្បីសំរាលអំរែករបស់យួនហាណូយ ហូ-ជីមិញក៏បញ្ជូនយួនម្នាក់ដែលមានឈ្មោះ ង្វៀង-យ៉ាំងមៀន ទៅក្រឡៃឲ្យបួសរៀននៅវត្តមួយនៃទីក្រុងភ្នំពេញ ដាក់ឈ្មោះខ្មែរថា ៖ អាចារ្យមៀន ។

បន្ទាប់មកទៀត វាក៏ដាក់ឈ្មោះយួននេះជាខ្មែរក្រោម ៖ សឹង-ង៉ុកមិញ ដើម្បីបន្លំធ្វើប្អូនលោកសឹង-ង៉ុកថាញ់ ។ សឹង-ង៉ុកមិញ ត្រូវហូ-ជីមិញតែងតាំងជា ប្រធានខ្មែរឥស្សរៈ ទទួលបន្ទុកជានាយករដ្ឋមន្ត្រី ឲ្យចូលកាន់ប្រទេសកម្ពុជាជាមួយ ទូ-សាមុត ។

នៅថ្ងៃទី១៩-៦-៥១ ង្វៀង-យ៉ាំងមៀនបង្កើតបានកងកម្លាំងប្រដាប់អាវុធបដិវត្តន៍ឯកភាពរបស់កម្ពុជា ។ នៅថ្ងៃទី២៨-៦-៥១ ជននេះបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរ ដែលតាំងពីនោះមកគេហៅថា «ខ្មែរវៀតមិញ» ហើយដែលនៅពីដំបូងទីសមាជិករបស់បក្សភាគច្រើនជា ជនជាតិយួនបន្លំធ្វើខ្មែរ ។ បន្តបន្ទាប់មកទើបវាទាក់ទងញុះញង់ខ្មែរៗដែលនៅចុងកាត់មាត់ញក ដែលត្រូវរាជរដ្ឋាភិបាលបំភ្លេចចោលឲ្យចូលមកធ្វើការជាមួយវា ដោយឃោសនាទៅតាមចំណុចខ្សោយនានារបស់មនុស្សម្នាក់ៗ ។ មុនដំបូងវាបង្កបង្កើតសង្គ្រាមវណ្ណៈ វាធ្វើឲ្យខ្មែរទាំងនោះរវាតចិត្តឆ្ងាយពីសង្គមខ្មែរ ។ រួចហើយ នៅពេលដែលខ្មែរទាំងនោះចូលក្នុងអន្ទាក់វាហើយ វាក៏ប្រមូលបញ្ចូលក្នុងសាលានយោបាយ ដើម្បីអប់រំបំពាក់គោលជំហរបន្ថែមថា ៖ ត្រូវតែកំទេចសក្តិភូមិ ចក្រពត្តិ និងនាយទុន ។ ឃ្លោងឃ្លាដែលវាបង្ខំឲ្យរៀនស្ទាត់ចាំមាត់មានខ្លះៗដូចតទៅ ៖

- មានបដិវត្តន៍កើតឡើង ទើបជឿនលឿន
- បដិវត្តន៍ម្តង ជឿនលឿនម្តង
- បំបែកបំបាក់ដើម្បីគ្រប់គ្រង
- ឈ្នះបានគ្រប់គ្រង (ឬធ្វើស្តេច) ចាញ់ធ្វើសេដ្ឋី ។ ( ឃ្លោងឃ្លានេះក្រុមខ្មែរអាយ៉ងយួនហេង-សំរិន, ហ៊ុន-សែន, ជា-ស៊ីម កំពុងអនុវត្តយ៉ាងហ្មត់ចត់) ។
- សម្លាប់មនុស្សសុចរិត ប្រសើរជាងទុកសត្រូវឲ្យនៅរស់ ។
- ត្រូវធ្វើឲ្យអស់សង្ឃឹម រួចសឹមជួយឲ្យមានសង្ឃឹមមកវិញ ។

អ្នកស្តាប់ទាំងប៉ុន្មានលាន់មាត់គ្រប់ៗគ្នា អាហ៍ អាហ៍...។ ពេលនោះអ្នកសុផានីនិយាយកាត់ឡើងថា ៖ គួរឲ្យចម្លែកមែនៗ ឃ្លោងឃ្លានេះជាពាក្យញុះញង់បំផុសបំផុលរបស់បក្សកុម្មុយនិស្តឥណ្ឌូចិន ហេតុម៉េចក៏អង្គការអនាមិកអនុវត្តបានហ្មត់ចត់ត្រឹមត្រូវអ្វីម្លេះ ?

– អូនៗមើលចុះ, យាយទៀងបន្ត, ដូចជាឃ្លាដែលថា «បដិវត្តន៍ម្តង, ជឿនលឿនម្តង» បដិវត្តន៍ទី១នៅស្រុកខ្មែរយើងថ្ងៃទី១៨-៣-៧០, លើកទី២ គេធ្វើបដិវត្តន៍ថ្ងៃទី១៧-៤-៧៥, លើកទី៣ថ្ងៃទី៧-១-៧៩ ជាទីបំផុតបក្សប្រជាជនបដិវត្តន៍ខ្មែរ ដែលជាអតីតខ្មែរវៀតមិញ ហើយឥឡូវនេះប្រែឈ្មោះជា បក្សប្រជាជនបដិវត្តន៍កម្ពុជា ដែលមានហេង-សំរិនជាអគ្គលេខាគណៈកម្មាធិការមជ្ឈិមបក្ស និងជាប្រធាន ហើយដែលមានពួកបូជួយជាច្រើនសែននាក់គាំទ្រ បានទទួលជ័យជំនះជាស្ថាពរមែន ។

★ ដូចឃ្លាដែលថា «បំបែកបំបាក់ដើម្បីគ្រប់គ្រង» អូនៗគិតមើលចុះ, អង្គការបំបែកខ្មែរជាច្រើនក្រុម ដោយប្រើឃីហោខ្មែរក្រហមតែមួយ ។ ឃាតករក្រុមទី១, ទី២ ទទួលភារកិច្ចសម្លាប់ប្រជាពលរដ្ឋខ្មែរ ។ ឃាតករក្រុមទី៣, ទី៤, ទី៥ ទទួលបន្ទុកសម្លាប់ក្រុមឃាតករមុន គឺក្រុមទី១, ទី២ឲ្យអស់ ដើម្បីបំបាត់ភស្តុតាង ។

ចំណែករឿងយោធា, អង្គការបំបែកយោធាជា៣ក្រុម ៖

ក្រុមយោធាទី១ ៖ យោធាក្មេងៗដែលមានអាយុមិនលើសពី១៥ឆ្នាំទេ ជាដំបូងអង្គការបញ្ចេញយោធាក្រុមនេះឲ្យត្រួតត្រាប្រទេសខ្មែរ តាមរបបចោរ ដោយប្រើពាក្យស្នើ ដើម្បីប្លន់ទ្រព្យសម្បត្តិខ្មែរពេញនគរ ។ រួចប្លន់អស់ចិត្តបាន៣ឆ្នាំរួចហើយអង្គការក៏ចាត់ការប្រមូលយកទៅលត់ដំឲ្យស្លាប់ ។

ក្រុមយោធាទី២ ៖ ជាយោធាដែលស្រឡាញ់សម្តេចឪ ស្ម័គ្រចិត្តកំទេចយោធាខ្មែរលន់-នល់, លុះអង្គការទទួលជ័យជំនះហើយ វាបែរជាប្រមូលយោធាក្រុមនេះឲ្យដើរចូលខ្សែអន្ទាក់ត្រៀមរបស់វា ទុកឲ្យបូជួយបាញ់រះសម្លាប់ចោលទាំងអស់ចុងឆ្នាំ១៩៧៨ ។

ក្រុមយោធាទី៣ ៖ ជាយោធាថ្លៃងការស្មោះត្រង់ចំពោះអង្គការ ស្ម័គ្រចិត្តកំទេចសក្តិភូមិនិងចក្រពត្តិ ។ ក្រុមនេះអង្គការយកទៅលាក់ទុកក្នុងទីអាថ៌កំបាំង សំរាប់បំពើវាដោយប្រការណាមួយផ្សេងទៀត ឬដោយបំពាក់ឃីហោជាខ្មែរក្រហមដដែលនៅថ្ងៃក្រោយ មិនដឹងចំនួន ។

★ ដូចជាឃ្លាដែលថា «សម្លាប់មនុស្សសុចរិត ប្រសើរជាងទុកសត្រូវឲ្យនៅរស់» អូនៗទាំងអស់គ្នាដឹងស្រាប់ហើយថា អង្គការសម្លាប់ខ្មែរស្លូតត្រង់អស់រាប់លាននាក់ ដោយគ្មានជំនុំជំរះមួយម៉ាត់ទេ ហើយនៅក្នុងនោះ មានដោយទាំងក្រុមខ្មែរក្រហមនិន្នាការខ្មែរជាង២ម៉ឺននាក់ផង ដែលមានហ៊ូ-យន់, ហ៊ូ-នឹម, មិត្តស៊ូ ជាដើម ។ សរុបសេចក្តីទៅ អង្គការអនាមិកសន្និដ្ឋានថា ខ្មែរដែលជាម្ចាស់ទឹកដីកម្ពុជាពិតៗ ថាជាសត្រូវរបស់វា ។

★ ដូចជាឃ្លាដែលថា «ឈ្នះក្រប់គ្រងឬធ្វើស្តេច, ចាញ់ធ្វើអ្នកមានឬសេដ្ឋី» អូនៗមើលចុះ អង្គការអនាមិកឈ្នះខ្មែរលន់-នល់ បន្ទាប់មកបោកស្តេចសីហនុបាន

ឈ្មោះទៀត, អង្គការបានគ្រប់គ្រងប្រទេសខ្មែរ ។ លុះដល់វេនហាណូយចេញលុកលុយរាតត្បាតប្រទេសខ្មែរដោយសេរីហើយ, អង្គការក៏រលាយបាត់ឈ្មោះទៅឯងៗ គឺធ្វើជាចាញ់សិន ប៉ុន្តែទ្រព្យសម្បត្តិក្នុងមួយនគរខ្មែរ ក៏ត្រូវអង្គការប្រមូលដឹកនាំយកទៅធ្វើសេដ្ឋីនៅស្រុកយួនអស់ទៅហើយ ។

★ ដូចឃ្លាដែលថា «ត្រូវធ្វើឲ្យអស់សង្ឃឹម រួមសឹមជួយមានសង្ឃឹមឡើងវិញ» យួនហាណូយប្រើឈ្មោះអង្គការអនាមិក ដើម្បីគ្រប់គ្រងប្រទេសខ្មែរអស់រយៈ៤ឆ្នាំគត់ (គឺរយៈពេលដែលខ្ញុំត្រូវរងគ្រោះជាមួយបងប្អូនខ្មែរទាំងអស់ដែលនៅសល់ពីស្លាប់) ។ អង្គការប្រើគ្រប់មធ្យោបាយ ដើម្បីធ្វើយ៉ាងណាឲ្យតែខ្មែរស្លាប់ ។ អ្នកដែលសេសសល់នៅរស់ ក៏ដេកអស់សង្ឃឹមរង់ចាំសេចក្ដីស្លាប់ ដែលយល់ថាដល់ពេលនេះទៅហើយ ស្លាប់ប្រសើរជាងរស់នៅក្នុងក្ដីវេទនា ។

ស្រាប់តែលេចមុខយួនចូលមក «ស្រោចស្រង់» ខ្មែរច្បាស់ក្រឡែតទៅវិញ ។ នេះហើយគេហៅថា ជួយឲ្យមានសង្ឃឹមឡើងវិញ ។

ដូច្នេះចំពោះអ្នកណាដែលមិនបានគិតដិតដល់ អាចយល់ច្រឡំថាយួនមានគុណមែន ! ។

អ្នកសុផានីទះស្មាយាយទៀងតិចៗ រួចនិយាយថា ៖ ខ្ញុំយល់ហើយៗថានរណាជាអង្គការ ដែលវាបាត់ពាក្យមួយឃ្លាដ៏ល្បី «ទុកក៏មិនចំណេញ ដកចេញមិនខាត» ។

ឃ្លានេះអង្គការទើបនឹងបង្កើតឡើងនៅសម័យ១៩៧០នេះទេ ។

ចុះហេតុយ៉ាងដូចម្ដេចបានជាម៉ាក់ដឹងគំពោងផែនការរបស់ហូ-ជីមិញ ? វ៉ាជាសួរម្ដាយ ។

ដើម្បីនឹងពន្យល់កូនស្រីឲ្យយល់ ម៉ែនឹងនិទានប្រវត្តិយួនវាយកំចាយ សម្លាប់ខ្មែរនៅកម្ពុជាក្រោម ឲ្យកូននិងអូនៗបានដឹង...

❑ ❑

❑

# ជំពូកទី១៨

★ កលល្បិចវៀតមិញសម្លាប់កំចាយខ្មែរកម្ពុជាក្រោម
★ វៀតមិញប្រមូលខ្មែរកម្ពុជាក្រោមផុតសម្លាប់ក្នុងជង្រុកស្រូវ
★ ការចាកចេញពីស្រុកកំណើតដោយចៃដន្យនៅឆ្នាំ១៩៤៩

## វៀតមិញសម្លាប់កំចាយខ្មែរកម្ពុជាក្រោម

យាយទៀងនិទានប្រវត្តិដ៏ឈឺចាប់ខ្លោចផ្សារបស់គាត់ ក្នុងចន្លោះឆ្នាំ១៩៤៦ដល់ឆ្នាំ១៩៥៤ ។ គាត់សំអាងទៅលើការឃើញប្រត្យក្សនឹងភ្នែកគាត់ ដែលស្តីពីការបាត់បង់ទឹកដីកម្ពុជាក្រោមនោលើកទី២ ។ ឆ្នាំសិក្សា១៩៤៥-១៩៤៦ នាងទៀងរៀននៅសាលាគរុកោសល្យក្រុងត្រាវិញកម្ពុជាក្រោម ។

នៅថ្ងៃទី៩-៣-១៩៤៥ ជប៉ុនចូលឈ្លានពានលុកលុយឧបទ្វីបឥណ្ឌូចិនមួយរយៈ, បារាំងត្រូវដកថយ...។

នៅខែតុលា១៩៤៥ ជប៉ុនត្រូវបរាជ័យ... បារាំងចូលមកកាន់កាប់ឥណ្ឌូចិនឡើងវិញ...។

ឆ្លៀតឱកាសដ៏ចលាចលនេះ ហូ-ជីមិញប្រធានៃបក្សកុម្មុយនិស្តឥណ្ឌូចិនប្រកាសវៀតណាមឯករាជ្យនៅថ្ងៃទី២-៩-១៩៤៥ រួចសំរេចបង្កើតរណសិរ្សវៀត-ណាមឯករាជ្យសម្ពន្ធភាព ហៅឲ្យខ្លីមកថា «វៀតមិញ» ។

សង្គ្រាមកាន់តែរីកធំឡើងៗនៅឧបទ្វីបឥណ្ឌូចិន ។ ហូ-ជីមិញមានគំរោងការទុករួចជាស្រេចថា បើពេលណាបារាំងត្រូវបរាជ័យ ត្រូវដកថយចេញពីឥណ្ឌូចិនយួនត្រូវតែវាតយកទឹកដីកម្ពុជាក្រោមឲ្យបានភ្លាម ។ ដូច្នេះយួនហាណូយក៏ញុះញង់ខ្លីដៃតួនខាងត្បូងឲ្យសម្លាប់កំចាយជនជាតិខ្មែរនៅកម្ពុជាក្រោម « ជាពិសេសអ្នកចេះដឹង » យ៉ាងឃោរឃៅ ។

អ្នកមានមធ្យោបាយក៏រត់ភៀសខ្លួន នាំគ្រួសារចាកចេញពីទឹកដីកម្ពុជាក្រោមជាហូរហែរនៅលើកទី១ ។ ស្នៀតនេះប្រសើរណាស់ គេហៅថា « ស្នៀតវាយទឹកបង្អើ

លត្រី» ។

ស្តៀតសម្លាប់យ៉ឧងព្រៃផ្សៃ យ៉ាងឃោរឃៅមានខ្លះៗដូចតទៅ ៖

– វៀតមិញតែងតែមកអញ្ជើញរាស្ត្រខ្មែរកម្ពុជាក្រោមអ្នកចេះដឹង ឲ្យទៅជួយធ្វើការអង្គការលើ ។ តែអ្នកណាដែលបានទៅជួយធ្វើការអង្គការលើ មិនដែលបានវិលត្រឡប់មកជួបគ្រួសារវិញឡើយ ។ យូរៗម្តងទើបក្រុមគ្រួសារបានទទួលសំបុត្ររបស់ជនរងគ្រោះនោះដែលផ្ញើមកសួរសុខទុក្ខ ។ តែតួអក្សរដែលសរសេរនោះមិនមែនជារបស់សាមីខ្លួនទេ ។

នៅដើមខែធ្នូឆ្នាំ១៩៤៥ តំណាងអង្គការលើមកអញ្ជើញលោកគឹម-ហោ ទៅជួយធ្វើការជាមួយអង្គការលើ ។ លោកគឹម-ហោមានទីលំនៅនៅឃុំភឿកហឹង ស្រុកត្រាកូវ ខេត្តត្រាវិញ កម្ពុជាក្រោម ។ លុះវានាំមកដល់មាត់ពាមខាងលិចភូមិបេនឃឿ ជាកន្លែងដែលពួកវាតែងកាប់ក្បាលរាស្ត្រខ្មែរកម្ពុជាក្រោមទម្លាក់ទឹកទន្លេ ទើបឃាតករពីរនាក់ចាប់លោកចងស្លាបសេក បំរុងនឹងបញ្ចូលទៅក្នុងផ្ទះទឹកដើម្បីកាត់ក្បាល ។ តែនៅពេលនោះពេជ្ឈឃាតភ្លេចយកអាវុធទៅតាមខ្លួន ។ ឃាតករម្នាក់ក៏វិលត្រឡប់ទៅយកអាវុធនៅឯភូមិវិញ ។

ចំណែកលោកគឹម-ហោដឹងដូច្នេះ ក៏ខំប្រឹងផ្សងព្រេងពីរបំរះចំណងលុះត្រាតែបានរួចខ្លួន ។ លោកស្រាយចំណងរួចភ្លែត ហើយក៏វាយសម្លាប់ឃាតករដែលនៅចាំយាមឲ្យស្លាប់នៅនឹងកន្លែងមួយរំពេច ។ រួចហើយលោកក៏លោតចុះទន្លេបណ្តែតខ្លួនតាមខ្សែទឹក រហូតបានជួបទូកអ្នកនេសាទមួយ ។ ម្ចាស់ទូកក៏ជួយចម្លងលោករហូតដល់ត្រើយទន្លេប៉ែកខាងលិច ។ល។

លោកគឹម-ហោក៏ចាប់ផ្សាយដំណឹងនេះ ឲ្យជ្រួតជ្រាបដល់បងប្អូនខ្មែរកម្ពុជាក្រោម ឲ្យដឹងនូវពុតត្បុតកំហូចរបស់យួនវៀតមិញ ដែលជាឃាតករដ៏ឃោរឃៅកំណាចថោកទាបនេះ ។ ដូច្នេះ សង្គ្រាមរវាងខ្មែរកម្ពុជាក្រោមនិងយួនវៀតមិញក៏ផ្ទុះឡើងយ៉ាងសាហាវអស្ចារ្យ ។

នៅពេលនោះ នៅតាមដងទន្លេ តាមព្រែកនានា គេឃើញតែខ្មោចឥតក្បាលអណ្តែតទៅមកៗតាមទឹកជោរនាជ គួរឲ្យស្លុតចិត្តណាស់ ។

នឹកទៅគួរឲ្យអាណោចអធម៌ដល់បងប្អូនខ្មែរកម្ពុជាក្រោមក្នុងគ្រាអាសន្ននោះណាស់ ។ ខាងយួនវៀតមិញ វាមានកាំភ្លើងមូស្កឹតុង ជាអាវុធ ។ ចំណែកខាងខ្មែរពួកគេនាំគ្នាដុតដែកធ្វើដាវ កាំបិត ខ្វែវជាអាវុធ ។ ជាអភ័ព្វណាស់ទៅទៀត នៅពេលដ៏មានអាសន្ននោះ បងប្អូនខ្មែរកម្ពុជាក្រោមគ្មានអ្នកដឹកនាំទេ ។ គ្រប់ៗគ្នាគោរពបានហ្មត់ចត់តាមដំបូន្មានលោកតាឧកញ៉ាសឺង-គុយ ដែលមានលំនាំយ៉ាងប្រសើរថា ៖

១- អាវុធដ៏មុត ដ៏ខ្លាំងក្លានិងដ៏ស័ក្ដិសិទ្ធិអាចការពារជាតិបាន គឺខ្មែរយើងត្រូវតែចេះរួបរួមសាមគ្គីពិតៗឲ្យបានស្អិតល្មួត ។

២- គ្មានជាតិណាស្រឡាញ់ជាតិខ្មែរជាងខ្មែរឡើយ ។

៣- បើខ្មែរមិនចេះជួយខ្មែរ គ្មានសាសន៍ណាអាចជួយខ្មែរជាងខ្មែរឡើយ ។

ដូច្នោះពេលដែលត្រូវរងគ្រោះដ៏ឧត្បាតនោះ បងប្អូនខ្មែរកម្ពុជាក្រោមបានរួបរួមសាមគ្គីគ្នាពិតៗ គេបំពេញករណិយកិច្ច ភារៈកិច្ចយ៉ាងត្រឹមត្រូវហ្មត់ចត់ ជាពិសេសគេស្គាល់ច្បាស់ណាស់ ថាសាសន៍ណាជាសត្រូវនិងជាឃាតករមកលើសាសន៍ខ្មែរ ។ ទោះយួនវៀតមិញធ្វើអ្វីៗក៏ដោយ បងប្អូនខ្មែរកម្ពុជាក្រោមមិនចុះញ៉មជាដាច់ខាត ។ នៅពេលនោះព្រះសង្ឃដាក់ធម៌ប៉ាណាចុះ ចងក្បិន ទទូរស្បែកគោទទឹកដើម្បីការពារខ្លួនទប់ទល់នឹងគ្រាប់កាំភ្លើងរបស់សត្រូវ កាន់ដាវរត់សំរុកចូលដេញកំទេចកំចាត់យួនវៀតមិញ ដែលលើកគ្នាចូលមកប្លន់ ដុតផ្ទះ ដុតវត្តអារាមខ្មែរ ។ បងប្អូនខ្មែរតស៊ូ ដើម្បីការពារជាតិនិងសាសនា ។

នៅខេត្តឃ្លាំនិងពលលាវ មានភូមិខ្មែរខ្លះដែលនៅឆ្ងាយដាច់ស្រយាល ដូចជាភូមិកោះប្រហាត យ៉ារ៉ាយ ព្នៅអណ្ដែត ដាំគិន ដាំឃើយ និងព្រៃកហូរផុងជាដើម ហើយមិនទាន់បានដឹងព្រឹត្តិការណ៍នៃការតស៊ូរបស់បងប្អូនខ្មែរនៅខេត្តត្រាវិញនៅឡើយ ។ យួនវៀតមិញយល់ថា ពន្យាពេលទុកយូរទៅទៀតមិនបានទេ អាចបណ្ដាលឲ្យមានគ្រោះថ្នាក់ដល់វាធ្ងន់ណាស់ ម្យ៉ាងទៀតបារាំងកំពុងវាយលុកសង្វើញចូលកាន់កាប់យកទីក្រុងនានាសឹងទាំងអស់ឡើងវិញហើយ ។ យួនវៀតមិញអនុវត្តស្នៀតមួយយ៉ាងទំនើបជាបន្ទាន់ដោយចាត់ការឲ្យអញ្ជើញរាស្ត្រខ្មែរកម្ពុជាក្រោមភេទប្រុសទៅរួមប្រជុំមិទិញក្នុងជង្រុកស្រូវ ។

ជង្រុកស្រូវនិមួយៗអាចដាក់មនុស្សបានពី១៧០ទៅ២០០នាក់ ។ លុះរាស្ត្រខ្មែរកម្ពុជាក្រោមចូលជួបជុំគ្នាហើយ វៀតមិញខ្ទាស់ជង្រុកស្រូវឲ្យជាប់ពីខាងក្រៅ រួចហើយក៏ដុតចំបើងដែលពួកវាបានរោយនៅជុំវិញជង្រុកនិមួយៗ ព្រមទាំងបានបង្កប់ធុងសាំងជាស្រេចនោះ ឲ្យឆេះសន្ធោរសន្ធៅដូចភ្នំភ្លើង ។ ដូច្នេះបងប្អូនខ្មែរយើងរងគ្រោះស្លាប់យ៉ាងសែនវេទនា ។

ក្នុងខែកុម្ភៈឆ្នាំ១៩៤៦ ដោយមានខ្មែរកម្ពុជាក្រោមស្ម័គ្រចិត្តបូជាជីវិតចូលធ្វើទាហានជំនួយបំរើបារាំង ដែលមានសេចក្ដីក្លាហានដ៏ស្វិតស្វាញ ដ៏រឹងប៉ឹង ដ៏ស្មោះត្រង់ចំពោះបារាំង « សូមបារាំងជ្រាប » រដ្ឋបាលបារាំងក៏អាចទទួលជ័យជំនះចូលកាន់ខេត្តត្រាវិញទាំងមូលឡើងវិញ ។

ពេលនោះកងទ័ពផ្នែកវាយសឹកក៏ប្រមូលទាហានជំនួយជាជាតិខ្មែរកម្ពុជាក្រោមទៅជួយបោសសំអាតយួនវៀតមិញនៅខេត្តផ្សេងៗទៀត ។ រដ្ឋបារាំងត្រូវបញ្ជូន

ផ្នែករៀបចំរដ្ឋាភិបាលនិងផ្នែកចិត្តសាស្ត្រចូលមកកាន់ខេត្តត្រាវិញជំនួសវិញ ។

ដូច្នេះបារាំងចេញប្រកាសផ្សាយអំពាវនាវរកខ្មែរកម្ពុជាក្រោមចូលជួយធ្វើការ ប៉ុន្តែគួរឲ្យស្តាយណាស់ ពាស្រុខ្មែរកម្ពុជាក្រោមដែលចេះដឹងហើយសល់ពីស្លាប់ បានរត់ភៀសខ្លួនទៅកម្ពុជាកណ្តាលសឹងអស់ទៅហើយ ។ អ្នកដែលសល់នៅរស់ គឺច្រើនតែគ្រូបង្រៀនប៉ុណ្ណោះ ។

ដោយសារការខ្វះបុគ្គលិកយ៉ាងនេះ រដ្ឋាភិបាលបារាំងបានបិទប្រកាសផ្សាយគ្រប់ទីកន្លែង អំពាវនាវរកអ្នកធ្វើការដែលមានសេចក្តីជាអាទិថា ៖

« បារាំងលើកលែងទោសឲ្យយួនគ្រប់ៗវណ្ណៈ ដែលថ្លោះធ្លោយបានទៅបំរើវៀតមិញ ។ ឥឡូវនេះអាចវិលត្រឡប់ចូលមកកាន់ទីលំនៅរៀងៗខ្លួនវិញបានដោយសេរី ។ ចំណែកអតីតអ្នករដ្ឋការអាចចូលមកសុំអនុកូលភាព រួចអាចសុំចូលធ្វើការតាមក្រសួងដើមនានារៀងៗខ្លួនវិញបាន ចាប់តាំងពីថ្ងៃបិទប្រកាសផ្សាយនេះទៅ » ។

ពួកវៀតមិញបានឃើញប្រកាសនេះរួចក៏ផ្លាស់ប្តូរផែនការរបស់វាភ្លាម ។ វាសំរេចចិត្តប្រើអាវុធចិត្តសាស្ត្រនិងកលល្បិចត្រជាក់ម្តងវិញ ។ វាក៏លៃលកញុះញង់បំបែកបំបាក់ខ្មែរទាហានជំនួយ ឲ្យបែកចេញពីបារាំងសិន ។ ព្រោះតាំងពី៧-៨ខែ ដែលកន្លងផុតមកហើយនេះ វៀតមិញប្រើតែអាវុធជាកាំភ្លើង ដែលធ្វើឲ្យពួកបួដូយស្លាប់យ៉ាងច្រើន ដោយហេតុថាពួកទាហានខ្មែរជំនួយបារាំងអស់ទាំងនោះមានការតស៊ូស្វិតស្វាញ ហើយមានប្រៀបខាងកម្លាំងសឹកលើសបួដូយច្រើនណាស់ ។ ដូច្នេះពួកវៀតមិញបញ្ជាឲ្យគ្នាវាំរំលាយក្រុម រំលាយកង ហើយលាក់អាវុធទុកមួយកន្លែងសិន ។

ឆ្លៀតពេលដែលបារាំងបោះខិតប័ណ្ណអំពាវនាវហៅយួនឲ្យធ្វើការឡើងវិញដោយសេរីនេះ វៀតមិញចាប់ផ្តើមបញ្ជូនចារកិច្ចរបស់វាដែលសុទ្ធតែជាអ្នកចេះដឹងជ្រៅជ្រះ ដែលខ្លះជាអតីតអ្នករដ្ឋការ ឲ្យមកសុំចូលធ្វើការជាមួយបារាំងឡើងវិញ តាមមុខងាររបស់ខ្លួនពីដើម ។

នឹកទៅគួរអាសូរទាហានខ្មែរកម្ពុជាក្រោមជំនួយបារាំង ដែលធ្វើពលិកម្មបូជាជីវិតដើម្បីបំរើបារាំងជំនាន់នោះណាស់ ។ អ្នកទាំងនោះមិនចេះនិយាយនិងអានអក្សរយួន មិនចេះនិយាយភាសាបារាំង ។ ម្ល៉ោះហើយបើនិយាយឆ្លើយឆ្លងជាមួយចៅហ្វាយ គឺគ្នាធ្វើបានត្រឹមកាយវិការ ។ ពួកគេចេះពិតប្រាកដតែរឿងវាយកំចាត់ដេញវៀតមិញឈ្លានពាន តែមិនបានដឹងថាស្ថានការណ៍ប្រែប្រួលភ្លាមៗយ៉ាងនេះឡើយ ។

ឆ្នាំ១៩៤៦, ខែមេសា, ជាទិវាបុណ្យចូលឆ្នាំខ្មែរ ។ ទាហានជំនួយខ្មែរកម្ពុជាក្រោ

មមួយចំនួនបានច្បាប់អនុញ្ញាតឲ្យឈប់សំរាក ហើយក៏ធ្វើដំណើរវិលត្រឡប់ចូលកាន់ទីក្រុងវិញ ។ ស្រាប់តែភ្ញាក់ដោយឃើញមេៗវៀតមិញដែលតែងតែចាប់ចងខ្មែរកម្ពុជាក្រោមនាំយកទៅសម្លាប់ ដែលតែងតែចូលមកប្លន់យកទ្រព្យសម្បត្តិនិងដុតផ្ទះខ្មែរ បែរជាដើព្រោងព្រាតកណ្តាលទីក្រុងធ្វើព្រងើយ ។ដោយមានបំណងចង់ផ្តាប់ចិត្តថៅហ្វាយបារាំងផង និងដោយចង់សងសឹកឲ្យបងប្អូនខ្មែរដែលត្រូវពួកវាសម្លាប់ពីមុនៗមកផង ទាហានជំនួយទាំងនោះក៏វាយសម្លាប់ពួកវៀតមិញចោ-លកណ្តាលទីក្រុងភ្លាមៗគ្មានរារែក ។ រឿងដែលមានបឹទប្រកាសថា លើកលែងទោសឲ្យពួកវៀតមិញយ៉ាងណាៗនោះ ពួកទាហានជំនួយអស់ទាំងនោះមិនទាន់ចង់ដឹងនៅឡើយទេ ។

ការវាយសម្លាប់របៀបនេះមានកើតឡើងជាញឹកញាប់ ដែលពេលខ្លះនាងទៀងបានឃើញផ្ទាល់នឹងភ្នែក ។

នៅថ្ងៃទី១២-៤-៤៦ វេលាម៉ោង១១កន្លះ នាងទៀងបណ្តើរកង់ចេញពីសាលាគរុកោសល្យ ។ នៅផ្លូវខាងលិចជាប់សាលារៀន មានពួកទាហានជំនួយខ្មែរកម្ពុជាក្រោមចំនួន១០នាក់ ដៃជាប់ខ្នោះមួយគូៗ ត្រូវគេបណ្តើរចេញពីគុកធំដែលស្ថិតនៅក្រោយសាលាខេត្តត្រាវិញ ។ ជនជាប់ខ្នោះទាំងនោះត្រូវគេរុញបង្ខំឲ្យឡើងឡាន GMC មួយគ្រឿងដែលមានឡានហ្ស៊ីបមួយទៀតចតនៅពីមុខ ។ ក្នុងចំណោមជនជាប់ខ្នោះដៃនោះ មនុស្សម្នាក់ឈ្មោះខែម ដែលនាងទៀងបានស្គាល់ច្បាស់ បានស្រែកផ្តែផ្តាំមកនាងទៀងថា ៖

« អាទៀងអាហ៎ នៅពេលស្អែកដែលអូនឯងបានឈប់សំរាកនៅពេលបុណ្យចូលឆ្នាំនេះ ដល់ពេលដែលអូនឯងវិលទៅកាន់ភូមិយើង ចូរអូនឯងប្រាប់ប្រពន្ធរបស់បងផងថា កុំឲ្យចាំមើលផ្លូវបងអី ព្រោះបងជាប់ឃុំណា៎ ! » ។

នាងទៀងស្តាប់ឮបានតែត្រឹមហ្នឹង ក្បួនឡានទាំងពីរក៏ដឹកអ្នកជាប់ទោសទាំង១០នាក់នោះចេញបាត់ទៅ ។

ស្អែកឡើងពេលព្រលឹម នាងទៀងធ្វើដំណើរចេញពីទីក្រុងត្រាវិញទៅកាន់ភូមិចុងព្រៃ ជាស្រុកកំណើតដែលមានចម្ងាយ២០គ.ម.ពីទីក្រុងត្រាវិញ ។ នាងទៀងជិះកង់កាត់តាមភូមិកំពង់ទូកគ្រោត ឃុំតឹងម៉ី ស្ថិតនៅចម្ងាយ៧គ.ម.ខាងត្បូងទីក្រុងត្រាវិញ ។ នៅពេលដែលនាងទៀងជិះកង់មកដល់លានទាត់បាល់មួយខាងត្បូងផ្សារកំពង់ទូកគ្រោត នាងក៏ចុះពីលើកង់បណ្តើរកាត់ហ្វូងប្រជាជនខ្មែរយ៉ាងច្រើនកកកុញដែលមានទឹកមុខស្រងូតស្រងាត់ របៀបភិតភ័យតក់ស្លុត អ្នកខ្លះមានទឹកភ្នែករហាម...។

នាងទៀងក៏ក្រឡេកទៅតាមខ្សែភ្នែកប្រជាជនទាំងនោះដែរ ។ ពុទ្ធោ ! នាងទៀ

ងស្មើរដួលសន្លប់ ដោយឃើញជនជាប់ខ្នោះដៃទាំង១០នាក់ពីម្សិលមិញត្រូវគេចង បាញ់សម្លាប់ចោល ខ្លួននៅជាប់នឹងបង្គោលសសរលើទីលានទាត់បាល់នោះ ។ នាងទៀងសម្លឹងរក «បងខែម» របស់នាង ។ បើរាប់ពីឆ្វេងដៃ ខ្មោចបងខែមនៅជាប់បង្គោលទី៥ ស្លាប់ទន់ករងៀកគួរឲ្យអនិច្ចាណាស់ ។ គេចងព្យួរក្តារបន្ទះមួយពណ៌ខ្មៅសរសេរអក្សរយួនធំៗនៅនឹងករបស់ខ្មោចបងខែម ដែលមានសេចក្តីថា ៖ ត្រូវតែសម្លាប់មនុស្សធុននេះជាគំរូ ។ ខ្មោចទាំង១០នេះ ត្រូវគេតាំងទុកឲ្យបណ្តាជនមើលចំនួន៨ថ្ងៃទើបគេយកទៅបញ្ចុះ ។

ល្បិចកលរបស់យួនសម្លាប់ខ្មែរកម្ពុជាក្រោមស្របច្បាប់នេះមានច្រើនកន្លែង ។ សម្លាប់បណ្តើរចោទបណ្តើរថា ប្រជាជនខ្មែរកម្ពុជាក្រោមជាអ្នកដឹកនាំបះបោរញុំាងឲ្យមានចលាចលពេញស្រុក ។ ចោទថាជាឃាតករ ចោទជាចោរ ។ល។ ពេលនោះយួនជាអតីតវៀតមិញ បច្ចុប្បន្នបំរើបារាំង ទទួលអំណាចយ៉ាងគ្រប់គ្រាន់ក៏ប-ញ្ចេញឫទ្ធិដូចអាយ៉តយក្ស ដែលបានទទួលសិលពីព្រះឥសូរ ។ វាបញ្ចេញសកម្មភាពកំចាយខ្មែរកម្ពុជាក្រោមដោយផ្សាយខ្សឹបខ្សៀវថា ត្រូវសម្លាប់ឲ្យអស់នូវខ្មែរណាដែលធ្លាប់បានសម្លាប់យួន ខ្មែរណាដែលធ្លាប់បានប្លន់ទ្រព្យសម្បត្តិយួន ។ វាចាត់ក្រសួងមានសមត្ថកិច្ច ឲ្យដើរឆែកឆេរផ្ទះខ្មែរតាមអំពើចិត្ត ។ តើវាសនាខ្មែរកម្ពុជាក្រោមទៅជាយ៉ាងណាទៅ បើអ្នករដ្ឋការថីបកភាសាក៏ជាយួន ពួកវៀតមិញក៏ជាយួន ? ។ ពេលនោះខ្មែរកម្ពុជាក្រោមដើរដល់ច្រកទាល់ « ចុះទឹកក្រពើឡើងលើខ្លា » ។ ដូច្នេះអ្នកដែលមានមធ្យោបាយគ្រប់គ្រាន់ ក៏ដឹកកូនជញ្ជូនចៅគេចចេញពីស្រុកភូមិម្តងទៀតជាលើកទី២ ។

មានសំនួរថា « ហេតុយ៉ាងដូចម្តេចបានជាបារាំងបែរជាបណ្តោយឲ្យក្រុមយួនជាអតីតវៀតមិញដែលសុំចំណុះទាំងឡាយនោះ មានអំណាចសម្លាប់ពួកទាហានជំនួយខ្មែរក្រោម ដែលធ្លាប់តែស្មោះត្រង់នឹងបារាំងនោះទៅវិញ ? » ។

សូមឆ្លើយយ៉ាងខ្លីថា ៖ នេះជាការខ្វះសមត្ថភាពរបស់បារាំងទាំងស្រុង ។ បា-រាំងមិនបានស្គាល់កលល្បិចក្រឡិចក្រឡុចរបស់យួនដែលតែងតែមានជាបញ្ឆោសជាបណ្តោយនោះឡើយ ។ បារាំងមិនបានដឹងទាល់តែសោះថា ក្នុងចំណោមពួកយួនដែលបំរើបារាំងនោះ មួយចំនួនធំជាចារបុរសរបស់យួនវៀតមិញនោះទេ ។ បារាំងជឿវាណាស់ ព្រោះវាប៉ិនប្រសប់អែបអប ។ បណ្តាលមកពីចារកិច្ចនេះ បារាំងគ្រាន់តែវេខ្លួន យួនវៀតមិញចាត់ការកំទេចទាន់ពេលវេលាគ្មានខុសចំណុច ។ មូលហេតុនេះហើយបានជាបារាំងត្រូវបរាជ័យរត់ចោលឧបទ្វីបឥណ្ឌូចិន ។

ចំណែកខ្មែរកម្ពុជាក្រោម, គោរព ស្រឡាញ់និងស្មោះត្រង់ចំពោះបារាំងមួយរយភាគរយ ។ ព្រោះខ្មែរជាសាសន៍ស្គាល់គុណ គឺដោយសារបារាំងចូលមកគ្រប់

គ្រងការពារឧបត្ថម្ភ ទើបខ្មែរកម្ពុជាក្រោមបានទទួលសេចក្ដីសុខ បាននៅជាជាតិខ្មែរនៅកម្ពុជាក្រោមដដែលជិតមួយសតវត្ស ។

ដើម្បីតបស្នងសងគុណបារាំង ទ័ពជំនួយទាំងនោះដឹងតែបំពេញករណីយកិច្ចកំទេចវៀតមិញ ដើម្បីការពារបារាំងនិងបងប្អូនខ្មែរកម្ពុជាក្រោមតែប៉ុណ្ណោះ ។ ម្យ៉ាងទៀតពួកទ័ពជំនួយទាំងឡាយនោះ រវល់ជាប់បំពេញបេសកកម្មជួយបារាំងបោសសំអាតវៀតមិញនៅតាមជនបទនានា មិនបានដឹងថា នៅតាមទីក្រុងបារាំងបែរជាចែងច្បាប់លើកលែងទោសវៀតមិញយ៉ាងនោះឡើយ ។ មិនបានដឹងថាបារាំងធ្វេសប្រហែសឲ្យចាញ់បោកយួនវៀតមិញយ៉ាងនោះឡើយ ។ល។

ដោយមកពី «បងខែម» ស្គាល់មេៗវៀតមិញដ៏ឃោរឃៅច្បាស់, ម្យ៉ាងទៀតដោយមកពីគាត់ចង់ផ្ដាច់ចិត្តបារាំង ទើបគាត់នាំគ្នាវាយសម្លាប់មេៗវៀតមិញសុំចំ-ណុះបំរើបារាំងនោះ ។ បានលេសនេះ យួនឆ្លៀតឱកាសសម្លាប់ទ័ពជំនួយស្របច្បាប់របស់បារាំងវិញ...។ល។

កាលណោះមានសល់ខ្មែរកម្ពុជាក្រោមអ្នកចេះដឹងតស៊ូនៅជួយធ្វើការបារាំងដែរ ។ ប៉ុន្តែត្រូវយួនជាអតីតវៀតមិញសុំចំណុះបំរើបារាំងប្រើគ្រប់មធ្យោបាយសម្លាប់ជាបន្តបន្ទាប់ មានឧទាហរណ៍ខ្លះៗដូចតទៅ ៖

ក្នុងឆ្នាំ១៩៤៧ លោកគឹម-ហើស ជាចៅតំបន់នៅប៉ុស្តិ៍វត្តធំ ស្រុកកូវង៉ាង ខេត្តត្រាវិញ ។ មានថ្ងៃមួយវៀតមិញព័ទ្ធបាញ់ប៉ុស្តិ៍នេះ ។ លោកគឹម-ហើសត្រូវរបួសធ្ងន់ ។ ក្រសួងកងទ័ពក៏ដឹកនាំលោកទៅចូលព្យាបាលក្នុងមន្ទីរពេទ្យធំទីក្រុងត្រាវិញ ។ ពេលនោះមានវេជ្ជបណ្ឌិតជាជាតិយួនម្នាក់ឈរសម្លក់សម្លឹងលោកគឹម-ហើសយ៉ាងយូរ បន្ទាប់មកវាក៏ចាក់ថ្នាំសម្លាប់អ្នករបួសនោះនៅចំពោះមុខប្រពន្ធ គឺអ្នកស្រីគឹម ។

អ្នកស្រីគឹមឈឺចិត្តណាស់ កាត់ក៏ចូលកាន់ដែនដីរំដោះដែលមានយួនជាវៀតមិញ ។ល។

« នឹកទៅគួរឲ្យស្ដាយណាស់ ! ក្នុងរយៈពេលជិត១០០ឆ្នាំដែលបារាំងបានគ្រប់គ្រងកម្ពុជាក្រោម គេមិនដែលឃើញមានការកើតវិវាទរវាងបារាំងនិងខ្មែរទាល់តែសោះ ។ ផ្ទុយទៅវិញយួននិងបារាំងសម្លាប់គ្នាទៅវិញទៅមកដូចសម្លាប់មូស ។ មានឧទាហរណ៍ជាប្រវត្តិសាស្ត្រនៅដៀនបៀនភូ ដែលស្លាប់គរជើងលើគ្នាជាភស្តុតាងស្រាប់ ។ មិនគួរបារាំងថយចាកចេញពីកម្ពុជាក្រោម ហើយបែរជាប្រគល់ទឹកដីនេះឲ្យយួនទៅវិញទេ » ។

ឆ្លៀតឱកាសយួនជាអតីតវៀតមិញសុំចំណុះបំរើបារាំងកំពុងចាត់ការសម្លា-ប់ខ្មែរកម្ពុជាក្រោមស្របច្បាប់យ៉ាងនោះ... ចំណែកយួនជាវៀតមិញបែរជាប្ដូរនយោ

បាយត្រជាក់ទៅវិញ...។ វាក៏ចេញប្រកាសបិទព្រោងព្រាតមានសេចក្ដីជាអាទិថា ៖ បើបងប្អូនខ្មែរណាបានជាជ្រួលខ្លួនទៅបំពីរបារាំង ឥឡូវនេះស៊ីវិលត្រឡប់មកកាន់ទីលំនៅរៀងៗខ្លួនវិញចុះ រដ្ឋាភិបាលស្រោចស្រង់ជាតិឈប់ប្រកាន់យកទោស ចាប់តាំងពីថ្ងៃចេញប្រកាសនេះទៅ ។

មានជាឧទាហរណ៍មួយដ៏អស្ចារ្យ, យាយទៀងបានចាំជានិច្ចដូចតទៅ ៖

– ថ្ងៃដែលអ្នកស្រីកឹមចូលដល់ដែនដីរំដោះ យួនវៀតមិញបែរជាចាប់ខ្លួនគាត់នាំយកទៅឃុំឃាំងទៅវិញ ។ លុះថ្ងៃតុលាការរបស់វៀតមិញនាំខ្លួនគាត់មកកាត់ទោស គាត់មិនចេះភាសាយួន វៀតមិញក៏ហៅនាងទៀងចូលទៅបកប្រែ ។ ទីបំផុតតុលាការកាត់សេចក្ដីថា ៖ Tu Hin សម្លាប់ចោល ! ។ នាងទៀងឮពាក្យនេះញ័រញាក់បកប្រែមិនកើត...

ស្រាប់តែលោកចាងហ្វាងបែរភ្នែកសម្លឹងនាងទៀង ព្រមទាំងឧទានថា ៖ «សុំយោបល់មិត្តទៀង ! Xin y Kien don chi Tien ! » ។ ពេលនោះនាងទៀងខំប្រមូលអារម្មណ៍ឲ្យបាននឹងនរ រួចនិយាយវែកញែករដិបរដុបថា ៖ « តាមយោបល់របស់ខ្ញុំ បើបក្សសម្លាប់បងកឹមក៏គ្មានប្រយោជន៍អ្វីដល់បក្សទាល់តែសោះ ! តែបើយើងលើកលែងទោសឲ្យគាត់រួចខ្លួនវិញ ការនេះនឹងមានប្រយោជន៍ច្រើនដល់បក្ស គឺយើងឲ្យតម្លៃដល់ប្រកាសដែលយើងកំពុងបិទព្រោងព្រាត អំពាវនាវលើកលែងទោសខ្មែរដែលយល់ច្រឡំទៅបំពីរបារាំងនោះ... » ។ ពេលនោះតុលាការក៏ផ្អាកដកថយទៅជំនុំគ្នាយ៉ាងស្ងាត់មួយសន្ទុះធំ ទើបចេញមកវិញ ។ លោកចាងហ្វាងញញឹមបែរភ្នែកសម្លឹងនាងទៀងព្រមទាំងនិយាយថា ៖ « ត្រូវ ! យោបល់របស់សមមិត្តទៀងពិតជាត្រូវ បើយើងសម្លាប់មិត្តកឹម ប្រកាសដែលយើងចេញផ្សាយនោះពិតជាឥតប្រយោជន៍ ។ល។ ពេលនេះយើងសំរេចឲ្យមិត្តកឹមរួចខ្លួន ! » ។

ប៉ុន្តែតុលាការបង្ខំឲ្យនាងទៀងចុះហត្ថលេខាធានាមិត្តកឹមយ៉ាងស្ងាត់បំផុត បើបងកឹមបែរជាក្បត់វៀតមិញ នាងទៀងត្រូវទទួលទោសស្លាប់ជំនួស ។

ចាប់តាំងពីថ្ងៃប្រកាសលើកលែងទោសខ្មែរនោះមក វៀតមិញបង្កើតបង្កើនភ្នាក់ងារចិត្តសាស្ត្រអប់រំយ៉ាងហ្មត់ចត់តាមផែនការថ្មី រួចបញ្ជាឲ្យដើរឃោសនានៅគ្រប់ៗភូមិដែលខ្មែរកម្ពុជាក្រោមកំពុងអង្គុយអស់សង្ឃឹម, វាលែធ្វើឲ្យមានសង្ឃឹមឡើងវិញ ។

ភ្នាក់ងារទាំងឡាយនោះ ពេលយប់តែងតែចូលទៅកាន់ភូមិខ្មែរឬជំរុំខ្មែរស្ថិតនៅក្បែរៗប៉ុស្តិ៍បារាំង ខំឃោសនានិយាយយ៉ាងទន់ភ្លន់ ផ្អែមល្ហែម វែកញែកញុះញង់ពន្យល់នូវវិបត្តិដ៏ពិតជាក់ស្តែងដែលកំពុងកើតមានឡើងរាល់ថ្ងៃនោះថា ៖ មិត្តៗឃើញទេ ! មិត្តៗរត់ចោលផ្ទះសំបែង រត់ចោលស្រែចំការ លះបង់ចោលទ្រព្យ

សម្បត្តិ, មានអ្នកខ្លះលះបង់ចោលគ្រួសារ ស្ម័គ្រចិត្តបូជាជីវិតចូលធ្វើទ័ពជំនួយបំរើបារាំងកំទេចវៀតមិញ... ផ្ទុយទៅវិញពេលបារាំងទទួលជ័យជំនះនៅឆ្នាំ១៩៤៦ បារាំងបែរជាប្រគល់អំណាចឲ្យក្រុម Viet Gian យួនក្បត់, ចោទសម្លាប់បងប្អូនខ្មែរវិរវក់ទៅវិញ ។ល។ ចំណែកភ្នាក់ងារវៀតមិញក្រុមមុននោះ ខ្វះការអប់រំមិនចេះធ្វើការមិនចេះដឹកនាំ បណ្តោយឲ្យកើតវិវាទរវាងបងប្អូនខ្មែរនិងយួនកាប់សម្លាប់គ្នា ។ អពួតហេតុនេះបណ្តាលឲ្យបាត់បង់ពេលវេលានិងនាំឲ្យយើងខាតប្រយោជន៍យ៉ាងច្រើន ។ កំហុសដ៏ធ្ងន់ៗនេះ ភ្នាក់ងារមុនត្រូវទទួល ។ ដូច្នេះអង្គការលើចេញបញ្ជាឲ្យចាប់ប្រមូលភ្នាក់ងារដែលប្រព្រឹត្តខុសនោះនាំយកទៅលត់ដំ ។

អង្គការលើបញ្ជូនមិត្តថ្មីៗ ដែលបានទទួលការអប់រំត្រឹមត្រូវ ឲ្យស្គាល់និងសន្និដ្ឋានរាស្ត្រខ្មែរកម្ពុជាក្រោមទុកដូចជាបងប្អូនមកជំនួស ។ ព្រោះយួននិងខ្មែរយើងមានកំណើតលើដីឥណ្ឌូចិន, យើងជាម្ចាស់ទឹកដីឥណ្ឌូចិន... រឿងអ្វីយើងទាស់ទែងគ្នា ? បែរជាទុកពេលឲ្យបារាំងជាជាតិបរទេសចូលមករាតត្បាតជិះជាន់, ឥឡូវជិត ១០០ឆ្នាំទៅហើយយើងជាប់នឹមបារាំងនេះ ។ មូលហេតុនេះ បាក់ហូ (ពាក្យយួនហៅហូ-ជីមិញថា អ៊ុំហូ ) ជាប្រធានបក្សកុម្មុយនិស្តឥណ្ឌូចិនសំរេចបង្កើតសមាគមមិត្តភាពយួន-ខ្មែរ-លាវ ដើម្បីរួបរួមសាមគ្គីឲ្យបានមាំរឹងប៉ឹង រួចកំទេចដេញបារាំងដែលជាសត្រូវរួមរបស់មិត្តយើងដើម្បីរំដោះប្រទេសរៀងៗខ្លួន ។ល។ និង ។ល។

មានបងប្អូនខ្មែរយើងខ្លះមិនស្គាល់កលល្បិចយួនក៏សួរថា « ហេតុយ៉ាងដូចម្តេចបានជាយួនវៀតមិញមិនឆ្លៀតឱកាសនោះសម្លាប់បំផុតពូជខ្មែរឲ្យអស់ទៅ ? ឬមួយក៏វាមានកលល្បិចយ៉ាងដូចម្តេចទៅទៀត ? » ។

ចម្លើយ ៖ យួនវៀតមិញដែលមានការពិសោធន៍ជាច្រើនឆ្នាំមិនញញើតនឹងធ្វើសង្គ្រាមជាមួយបារាំងទេ ។ យួនស្គាល់ចំណុចខ្សោយរបស់បារាំងដែលជាជនជាតិចាញ់អាកាសធាតុក្តៅនៅឧបទ្វីបឥណ្ឌូចិន មិនអាចធន់ទ្រាំនិងចំណីអាហារ, ទឹក និងរោគផ្សេងៗបានទេ ។ យួនបកស្រាយពន្យល់សមាជិកបក្សរបស់វាថា « បើសង្គ្រាមពន្យាពេលយូរវារីតតែប្រសើរសំរាប់នគរយួន ព្រោះបារាំងនាំអាវុធមកឲ្យនគរយួនទេតើ ! » ។

យួនវៀតមិញទទួលស្គាល់គុណសម្បត្តិរបស់ខ្មែរកម្ពុជាក្រោម ដែលជាជនជាតិមានចរិករឹងប៉ឹង អត់ធ្មត់ តស៊ូ ស្និតស្នាញ ចេះធន់ទ្រាំនូវការលំបាកគ្រប់បែបយ៉ាង ហើយដែលភាគច្រើនជាអ្នកធ្វើស្រែចំការ, ចិញ្ចឹមសត្វ, នេសាទត្រី, បង្កង, បង្គារទៅលក់នៅតាមទីផ្សារនិងទីប្រជុំជននានា ដែលមានពួកជនជាតិយួនជាអ្នករស់នៅប្រកបរបរជាអ្នករង្គការ ។

លុះដល់ពេលខ្មែរចូលខ្លួនទៅធ្វើជាទាហានជំនួយបារាំងអស់ទៅ យួនវៀតមិញ

ត្រូវទទួលវិបត្តិយ៉ាងធ្ងន់២យ៉ាង ៖

វិបត្តិទី១ ៖ យួនវៀតមិញត្រូវចំណាយជីវិតបូដួយអស់ជាច្រើន ដើម្បីទប់ទល់សង្គ្រាមនឹងបារាំង ។

វិបត្តិទី២ ៖ យួនវៀតមិញត្រូវខ្វះអ្នកធ្វើស្រែចំការ, នេសាទ ដើម្បីផ្តល់ភោគផលឲ្យប្រជាជនវានៅទីក្រុង ។

យល់ដូច្នេះភ្លាម យួនវៀតមិញត្រូវតែចាត់វិធានការបំបែកបំបាក់, ពួកទាហានជំនួយខ្មែរកម្ពុជាក្រោមចេញពីបារាំង ។ វាក៏កប់លាក់អាវុធឈប់ធ្វើសង្គ្រាមមួយរយៈសិនដើម្បីផ្លាស់ប្តូរនយោបាយ និងរកកលល្បិចថ្មីបោកខ្មែរកម្ពុជាក្រោមតទៅទៀត ។

មែន ! ហូ-ជីមិញចេញបញ្ជាឲ្យបង្កើតសមាគមមិត្តភាពយួន-ខ្មែរ-លាវ ដើម្បីបញ្ឆោលើកទឹកចិត្តខ្មែរកម្ពុជាក្រោមភ្លាម ។ ការពិតនោះវាប្រើគ្រប់មធ្យោបាយនៃអំពើព្រៃផ្សៃដើម្បីសម្លាប់ខ្មែរកម្ពុជាក្រោម ដែលជាអ្នកចេះដឹងខ្វះចខ្វីអស់ទៅហើយទុកតែខ្មែរដែលល្ងង់ខ្លៅដើម្បីស្រួលវាប្រើធ្វើខ្ញុំកញ្ជះវាតែប៉ុណ្ណោះ ។ រីឯយួនវៀតមិញដែលសុំចំណុះបំរើបារាំងឯណោះវិញ វាក៏បញ្ចេញចង្កូមយ៉ាងសាហាវបន្ថែមទៀតដើម្បីឲ្យបារាំងជួយកំចាត់ខ្មែរទាហានជំនួយចេញពីខ្លួន ។

កលល្បិចដ៏ចម្លែកអស្ចារ្យមួយមានដូចតទៅ ៖

- ក្នុងខែមិថុនា១៩៤៦, ស្រាប់តែឃើញគេចាប់ស្រីៗខ្មែរកម្ពុជាក្រោម១៤នាក់ដែលជាអ្នកលក់អង្ករ ហើយត្រូវគេបណ្តើរជាជួរយកទៅឃុំក្នុងគុកធំ ស្ថិតនៅខាងក្រោយសាលាខេត្តត្រាវិញ ។ បន្ទាប់មកទើបដឹងថា យួនដែលជាខ្ញុំបំរើបារាំងបានចោទស្រីៗទាំងនោះថា លក់អង្ករមានអំបែងដបងមបែងកែវ ។ លុះទាហានជំនួយខ្មែរកម្ពុជាក្រោមទិញអង្ករនោះយកទៅដណ្តាំបាយបរិភោគ ក៏បណ្តាលឲ្យអ្នកបរិ-ភោគតាំងនោះត្រូវរបួសដាច់ក្រពះស្លាប់យ៉ាងវេទនាជាទីបំផុត ។

ចុះហេតុយ៉ាងម៉េចបានជាអង្ករមានអំបែងដបអំបែងកែវ ? លុះយូរលង់មកទើបយើងខ្មែរកម្ពុជាក្រោមដឹងថារឿងដ៏ចម្លែកនេះជាកលល្បិចរបស់ក្រុមយួនអតីតវៀតមិញដែលសុំចំណុះបំរើបារាំង ។ វិច្ឆេតកម្មនេះមានប្រយោជន៍ពីរយ៉ាងដល់យួន ៖

១- វាធ្វើឲ្យមានចលាចលដើម្បីបន្លាចស្រីៗខ្មែរអ្នកលក់អង្ករឲ្យឈប់ប្រកបរបរនេះ ។

២- បើគ្មានអ្នកលក់ហើយ អង្ករត្រូវខ្វះខាត ដូច្នេះទាហានជំនួយដែលបំរើបារាំងទាំងនោះ ត្រូវតែនាំគ្នាវិលត្រឡប់មកធ្វើស្រែចំការវិញ ។ សូមជំរាបថា នៅក្នុងកាលៈទេសៈនោះ នៅកម្ពុជាក្រោមមិនទាន់មានម៉ាស៊ីនកិនស្រូវ ឲ្យបានគ្រប់គ្រាន់

នៅឡើយទេ ។ ស្រីៗនាំគ្នាកិនស្រូវដោយដៃ ជាន់អង្ករដោយជើង រួចរែងរើសយ៉ាងស្អាតដាក់ក្នុងកញ្ជើធំៗ រែកយកទៅលក់ឲ្យទាហានជំនួយនៅក្នុងបន្ទាយ ។ នៅតាមដងផ្លូវមានស្រីៗយួនធ្វើវិច្ឆេទកម្មធ្វើពុតសុំទិញអង្ករ ដោយលួចបន្លំដាក់អំបែងដបអំបែងកែវចូលក្នុងអង្ករនោះ ។ ខ្ញុំសូមលើករឿងមួយយកមកជូនបងប្អូនខ្មែរពិចារណាពីកលល្បិចយួនហាណូយជាវៀតណាមជាអតីតវៀតមិញ ជាអតីតវៀតកុងដែលនាំយកមកសាបព្រួសក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ១៩៨២ ដើម្បីកំចាយខ្មែរដូចតទៅ ៖

តាមសេចក្ដីរាយរ៉ាប់របស់យាយផុន ដែលមកដល់ប្រទេសបារាំង កាលពីថ្ងៃ ២-១១-៨៥ បានបញ្ជាក់ប្រាប់យាយទៀងផ្ទាល់ថា គាត់ក៏យល់ច្រឡំដូចបងប្អូនខ្មែរដទៃទៀតដែរ ដែលស្មានថាយួនចូលមកជួយខ្មែរ ។ ស្រាប់តែឆ្នាំ១៩៨២មានព្រឹត្តិការណ៍ដ៏ចម្លែកមួយបានកើតឡើងគួរឲ្យតក់ស្លុត ។ យួនបានបញ្ជូនស្រីយួនក្មេងៗទុកក្រចកវែងៗលាបថ្នាំក្រចកពណ៌ក្រហមចាស់ ដែលនៅក្នុងក្រចកនោះមានបង្កប់លាក់ថ្នាំបំពុលយ៉ាងសាហាវ ។ ក្នុងខែមេសា១៩៨២ នៅរដ្ឋធានីភ្នំពេញមានកើតចលាចលយ៉ាងខ្លាំង ដែលបណ្ដាលមកពីអង្ករ នំបញ្ចុក នំពោត បន្លែ ផ្លែឈើផ្សេងៗ មានជាតិពុលដែលសម្លាប់អ្នកបរិភោគឲ្យស្លាប់ជាហូរហែ ។ មានស្រីយួនមួយក្រុមទៀតនាំផ្លែត្របែកបីស្រុកយួន ដែលមានបង្កប់ជាតិពុលនៅខាងក្នុង ហើយយកមកលក់នៅភ្នំពេញ ។ អ្នកបរិភោគត្រូវស្លាប់ជាបន្តៗ ។ យាយផុនបញ្ជាក់ថាបានឃើញផ្ទាល់ភ្នែកនូវជនជាតិបរទេសពីរនាក់ ដែលមានលំនៅនៅក្បែរផ្ទះគាត់ ហើយដែលបានបរិភោគផ្លែត្របែកនោះប្រកាច់ស្លាប់នៅនឹងកន្លែងមួយរំពេចយ៉ាងសែនវេទនា ។ គាត់បន្តទៅទៀតថា គាត់មានអាយុ៧១ឆ្នាំហើយ គាត់មិនដែលនឹកនាថានឹងចាកចោលស្រុកទេ តែដោយសារការឃើញនឹងភ្នែកគាត់យ៉ាងប្រត្យក្សបែបនេះ ព្រមទាំងឃើញបងប្អូនខ្មែរយ៉ាងច្រើនលើសលប់ ដែលខ្លាចថ្នាំពុលកំពុងតែដឹកកូនជញ្ជូនចៅភៀសខ្លួនជាហូរហែ គាត់ក៏កើតសេចក្ដីតក់ស្លុតជាខ្លាំង ក៏សំរេចចិត្តកាន់ឈើច្រត់ទប់ខ្លួនចាកចោលស្រុកខ្មែរមកតាមគេឯងដែរទៅ ។

ចំណែកឯខ្មែរកម្ពុជាក្រោមវិញគេបានស្គាល់កលល្បិចអមនុស្សធម៌របស់វៀតមិញនេះច្បាស់ណាស់ ។ ប៉ុន្តែ « ចុះទឹកក្រពើ, ឡើងលើខ្លា » ខ្មែរកម្ពុជាក្រោមនៅពេលនោះជាកូមកំព្រាដែលប្រៀបបីដូចជាត្រីដែលគេចាប់បញ្ចូកពាងទុករួចទៅហើយ... មិនចេះភាសាយួន ភាសាបារាំង គ្មានមធ្យោបាយចាកចេញពីស្រុករកសន្តិភាព សេរីភាពនឹងគេ ម្ល៉ោះហើយក៏សម្ងំស្ងៀមបិទមាត់ធ្វើស្រែចំការជាធម្មតាទៅ ។ ចំណែកឯអង្គការលើរបស់វៀតមិញវិញ ក៏បញ្ជូនភ្នាក់ងារថ្មីមកជំនួសគ្រប់ទីកន្លែងទាំងអស់ ដោយប្រើអាកប្បកិរិយាទន់ភ្លន់ សំដីផ្អែមត្រជាក់ចូលមកទាក់

ទងមិត្តភាពជាមួយខ្មែរយ៉ាងជិតស្និទ្ធនៅតាមទីលំនៅ ។ វាហៅមនុស្សចាស់ថា ម៉ែឪ ឬអ៊ុំ, ហៅក្មេងៗថាសមមិត្ត ។

នៅពេលបើកអង្គប្រជុំម្តងៗ ប្រធានតែងតែដើរស្ទាបអង្អែលចាស់ទុំខ្មែរធ្វើហាក់ដូចជាស្រឡាញ់ណាស់ ។ វាញុះញង់ដោយនិយាយច្រំដែលៗថា បារាំងជាសត្រូវរួមរបស់យើង យើងជាប់នឹមអាណានិគមបារាំងជិត១០០ឆ្នាំទៅហើយ ។ ពេលនេះយើងត្រូវតែរើបំរះចេញពីនឹមនេះដើម្បីសេរីភាព ឯភារៈកិច្ចដែលត្រូវវាយកំទេចបារាំងគឺក្រុមខ្ញុំបួដួយជាអ្នកធ្វើ ។ សមមិត្តខ្មែរមិនបាច់ហត់នឿយដោយកាន់អាវុធទេ ។ អង្គការលើសូមសមមិត្តតាំងចិត្តឲ្យនឹងនរបន្តកិច្ចការធ្វើស្រែ ធ្វើចំការចិញ្ចឹមសត្វ នេសាទត្រីបង្កងទៅបានហើយ ។ អង្គការលើសុំអំពាវនាវដល់សមមិត្ត ឲ្យជួយបរិច្ចាគធ្វើវិភាគទាន ដោយបង់ប្រាក់ក្នុងម្នាក់ៗចំនួន 0,50 Piastre ព្រមទាំងអង្ករ២០លីត្រ (គឺ១តៅ) ។

❑ ❑
❑

ក្នុងខែកញ្ញា១៩៤៦ រដ្ឋមន្ត្រីក្រសួងសិក្សាធិការនិងអប់រំនៅព្រៃនគរ បានចេញប្រកាសតែងតាំងកញ្ញាទៀងជាគ្រូបង្រៀន ព្រមទាំងបញ្ជូននាងមកកាន់ខេត្តត្រាវិញ ។ តាំងពីដើមមកមិនដែលមានស្ត្រីខ្មែរជាគ្រូបង្រៀនឡើយ ។ នៅឆ្នាំសិក្សា១៩៤៦-៤៧ មានស្ត្រីខ្មែរកម្ពុជាក្រោម២នាក់ បានត្រូវគេតែងតាំងជាគ្រូបង្រៀន ។ គេបញ្ជូននាងទៀងទៅកាន់ប៉ុស្តិ៍ង៉ាបា ស្រុកត្រាកូវ ដើម្បីបង្រៀនមុខវិជ្ជាភាសាបារាំង-ខ្មែរដល់កូនសិស្សខ្មែរ ។ ស្រុកត្រាកូវមានសុទ្ធតែខ្មែរកម្ពុជាក្រោម ដែលតាំងទីលំនៅពាសពេញតាំងពីច្រើនសតវត្សមកហើយ ។ គេសង្កេតឃើញមានជនជាតិយួនបន្តិចបន្តួច ដែលមានមុខរបរជាអ្នករដ្ឋការ និងជាអ្នកលក់ដូរខ្លះៗដែលតាំងទីលំនៅនៅតាមទីផ្សារតែប៉ុណ្ណោះ ។

វាស្ត្រខ្មែរកម្ពុជាក្រោមនៅស្រុកត្រាកូវ ប្រកាន់មិនឲ្យកូនរៀនសូត្រទេ ព្រោះតាមការកត់សំគាល់ កាលណាកូនចេះដឹងតែងតែមានវិបត្តិផ្សេងៗ ត្រូវតែរត់ចោលស្រុកចោលម៉ែឪ សឹងគ្មាននរណាអាចបានរស់នៅជួបជុំគ្រួសារឡើយ ។ ចំណែកឯកូនស្រី ម្តាយឪពុកមិនឲ្យទៅរៀនសូត្រជាដាច់ខាត ព្រោះយល់ថាកាលណារៀនសូត្រចេះដឹងហើយ មុខតែសរសេរសំបុត្រស្នេហាទៅឲ្យប្រុសៗ...

លោក ប៉ាន-ឡូវ ជាអធិការបឋមសិក្សាជាតិខ្មែរប្រចាំនៅក្នុងអធិការកិច្ចចំរុះខេត្តត្រាវិញ លោកចេញលិខិតបញ្ជា ( Ordre de Service ) ឲ្យនាងទៀងទៅកាន់ទីនោះដើម្បីបង្ហាញជាគំរូ...។ ពេលនោះមានការផ្អើលរំជើបរំជួល វាស្ត្រខ្មែរកម្ពុជា

ក្រោមនៅស្រុកត្រាកួវឈ្មួរឆរចង់ឃើញមុខអ្នកគ្រូជាស្ត្រីខ្មែរកម្ពុជាក្រោម ។

ចំណែកយួនជាយៀកមិញមានការចាប់អារម្មណ៍មកពីវាត្រូវការស្ត្រីខ្មែរកម្ពុជាក្រោមរបៀបនេះជាឈ្មួរហើយ ។

ចុងខែធ្នូឆ្នាំ១៩៨៦ កងទ័ពជំនួយខ្មែរប្រចាំប៉ុស្តិ៍ង៉ាបា រត់ចាកចេញពីបន្ទាយជិតអស់...

ឱកាសមកដល់យ៉ាងនេះ យួនវៀតមិញស្ទុះស្ទាក្រោកឡើងកំទេចបារាំងសារជាថ្មី ។ ដូចនៅយប់ថ្ងៃទី៣១-១២-៤៦ វៀតមិញចាប់ព័ទ្ធវាយកំទេចប៉ុស្តិ៍ង៉ាបា ។ ចំណែកយួនអ្នករដ្ឋការនិងអ្នកលក់ដូរ វាចាត់កំទេចស្បៀងអាហារចោលទាំងអស់រួចវាប្រមូលគ្នាទៅរួមដៃជាមួយវៀតមិញភ្លាម ។

ដូច្នេះនៅថ្ងៃទី៤-១-៤៧ នាយសែហ្សប៉ុស្តិ៍ជាតិបារាំងអាយុប្រហែល៣៣ឆ្នាំ មានអ្នកនៅក្រោមបង្គាប់ទី១ជាជាតិយួនអាយុប្រហែល៥០ឆ្នាំឈ្មោះអុងបាវ ។ អ្នកនៅក្រោមបង្គាប់ទី២ជាជាតិខ្មែរអាយុប្រហែល៣៥ឆ្នាំ ឈ្មោះគឹម-សាញ់ ប្រជុំគ្នាសំរេចជាបន្ទាន់ថាត្រូវតែនសគ្គាដកថយបោះបង់ប៉ុស្តិ៍ង៉ាបាចោល ហើយរត់ទៅកាន់ទីរួមខេត្តត្រាវិញ ដែលមានចម្ងាយជាង៣៧គ.ម. ។ ព្រោះប៉ុស្តិ៍ង៉ាបាត្រូវវៀតមិញកាត់ផ្តាច់ការទាក់ទង ទាំងពត៌មាន ទាំងស្បៀងអាហារ ទាំងគ្រាប់រំសេវ ។ ក្នុងគ្រាអាសន្ននោះ លោកអ្នកដែលប្តូរស្លាប់រស់រត់តាមបារាំងគឺ ៖ អុងបាវ, គឹម-សាញ់, គ្រូបង្រៀនជាតិខ្មែរ៣នាក់គឺ លោកគឹម-ដាក់, ថាច់-ថោន និងកញ្ញាទៀង ព្រមតាំងគ្រួសារទាហានជំនួយខ្មែរកម្ពុជាក្រោមទាំងចាស់ទាំងក្មេងស្រីប្រុសមានចំនួន២០០នាក់ ។

នៅពេលនោះ នៅតាមផ្លូវទៅកាន់ទីរួមខេត្តត្រាវិញ មានឧបសគ្គជាច្រើននិងយ៉ាងធ្ងន់ ។ ព្រោះពីប៉ុស្តិ៍ប៉ាង៉ាទៅទីរួមខេត្តត្រាវិញមានព្រែកធំបីនិងព្រែកតូចបី ។ ដើម្បីនឹងឆ្លងព្រែកនិមួយៗ គេត្រូវកាត់តាមស្ពាន ។

ក្នុងខែធ្នូនិងមករា ទឹកកំពុងជោរជន់លិចមានជំរៅពី២.៥០មឡើងទៅ ទឹកហូរត្របាញ់ «បែកក្បាលត្រែង» វៀតមិញដុតបំផ្លាញស្ពានចោលខ្ទេចខ្ទីអស់ ។ នៅចុងស្ពានម្ខាងៗ វៀតមិញបញ្ជាឲ្យបួដួយជីករណ្តៅបង្កប់ខ្លួនវាចាំលបបាញ់អ្នកដំណើរជាស្រេច ។

នៅព្រលឹមថ្ងៃទី៥-១-៤៧ ពេលពួកយើងបណ្តើរគ្នាចេញពីប៉ុស្តិ៍ង៉ាបា បានចម្ងាយប្រហែលតែមួយគីឡូម៉ែត្រប៉ុណ្ណោះ ក៏ជួបឧបសគ្គទៅហើយ គឺតាំងដំណើរទៅមុខមិនរួច ថយក្រោយក៏មិនកើត ព្រោះមានព្រែកមួយយ៉ាងធំទឹកកំពុងហូរត្របាញ់កាត់ផ្លូវថ្នល់ ស្ពានដែលសំរាប់ដើរឆ្លងកាត់ព្រែកនោះមានប្រវែង៥០ម៉ែត្រ ត្រូវបួដួយដុតឈើបំផ្លាញខ្ទេចនៅសល់តែសសរដែក ។ ពេលនោះមានទ័ពជំនួយខ្មែរខ្លះ

ដែលនៅលើវផ្សេងព្រេងដើរតាមស្ពដែក ក៏ត្រូវបូជួយបាញ់ទម្លាក់ទឹកប្រូងៗ ។ នៅគ្រាអាសន្នធ្ងន់ធ្ងរយ៉ាងនេះ សែហ្វប៉ុស្តិ៍ជាតិបារាំង លោកគ្រូគីម-ដាក់ និងទ័ពជំនួយខ្មែរកម្លោះៗចំនួន២០នាក់ ផ្សេងព្រេងលបលួនចុះក្នុងព្រៃក បណ្ដែតខ្លួនតាមខ្សែទឹកហូររួចឆ្លងទៅកាន់ត្រើយម្ខាង ចាកផុតគ្រោះថ្នាក់នៅលើកទី១ ។ បន្តដំណើរទៅមុខទៀត ! ប៉ុន្តែអស់លោកទាំងឡាយនោះ ដោយឃ្លានបាយផង ដោយស្រេកទឹកផង ក៏នាំគ្នាចូលទៅទាក់ទងនឹងរាស្ត្រខ្មែរកម្ពុជាក្រោមនៅតាមភូមិដូចជា ភូមិចៃឌី, ភូមិចុងព្រៃ, ភូមិកំពង់ទូកត្រោកជាដើម ក៏ដូចជាបណ្ដើរគ្នាចូលអន្ទាក់របស់បូជួយទៅវិញ ។ ព្រោះនៅតាមដងផ្លូវ វៀតមិញបញ្ជាឲ្យបូជួយចាត់ការរៀបចំដាក់អន្ទាក់ពួនស្ទាក់តាមភូមិខ្មែរតាំងទីលំនៅ ។ បើអ្នករៀសខ្លួនទាំងឡាយនោះដើរចូលរកសុំបាយទឹក ត្រូវបូជួយបាញ់សម្លាប់ចោលភ្លាម ។ ដូច្នេះក្រុមនោះត្រូវបូជួយបាញ់សម្លាប់ចោលជាហូរហែរ ។ លុះមកដល់ក្រុងត្រាវិញ សល់នៅរស់តែសែហ្វប៉ុស្តិ៍ជាតិបារាំងនិងលោកគ្រូគីម-ដាក់ពីរនាក់ប៉ុណ្ណោះ ។ ចំណែកអ្នករៀសខ្លួនដែលជាប់កុននៅមាត់ព្រៃកទី១នោះ ត្រូវវៀតមិញចាប់ចងភ្នែកចងដៃ បណ្ដើរនាំទៅកាន់មាត់ទន្លេខាងលិចភូមិបេនឃឿ ។ វៀតមិញចេញបញ្ជាឲ្យទាហានជំនួយខ្មែរកម្ពុជាក្រោមឈរមួយក្រុមៗជាមួយប្រពន្ធកូនចំនួន១៥០នាក់ ទាំងចំណងនៅភ្នែកនិងដៃរួចវារះមីត្រៃយ៉ែតមកស្រោចលើជនអភ័ព្វទាំងនោះស្លាប់យ៉ាងអាណោចអធមជាទីបំផុត ។ ចំណែកអុងបាវ និងគីម-សាញ់ វាបង្គាប់ឲ្យជីករណ្ដៅខ្លួនឯងល្មមអង្គុយត្រឹមក រួចចុះទៅអង្គុយក្នុងរណ្ដៅនោះ ឲ្យបូជួយសម្លាប់ចោលខ្មោចក្នុងរណ្ដៅបង្ហាញសាធារណជនមើលដោយសេរី ទើបយកទៅបញ្ចុះ៤ថ្ងៃក្រោយ ។

## កំណែនវៀតមិញ

នៅពេលព្រលឹមនៃថ្ងៃទី៦-១-៤៧ បូជួយចាប់លោកគ្រូថាច់-ថោន និងអ្នកគ្រូទៀងចងភ្នែកជិតរៀងៗខ្លួន ហើយចងដៃអ្នកទាំងពីរក្នុងចំណងតែមួយ នាំយកទៅកាន់ភូមិបេនឃឿវិញ ។

មកដល់ភូមិបេនឃឿ លោកថាច់-កែនអ្នកស្មគ្រចិត្តបំរើវៀតមិញជាយូរមកហើយៗដែលត្រូវជាឪពុកក្មេកលោកគ្រូថាច់-ថោន បានសុំធានាកូនប្រសារគាត់បំបែកចេញពីអ្នកគ្រូទៀងបាត់ទៅ...។ រីឯនាងកញ្ញាទៀងត្រូវវៀតមិញបង្ខាំងទុកទាំងភ្នែកជាប់ចំណងនៅកន្លែងមួយ ។ ១១ថ្ងៃក្រោយមក គឺនៅពេលព្រលឹមនៃថ្ងៃទី១៧-១-៤៧ នាងទៀងដឹងថា មានមនុស្សម្នាក់ចូលមកស្រាយចំណងចេញពីភ្នែក ។ ចំណងរបើក នាងឃើញមនុស្សម្នាក់ជាតិយួន មាឌស្គមខ្ពស់ សក់រួញអង្គាដី មាន

អាយុប្រហែល៣២ឆ្នាំ ។ បុរសនេះបណ្តើរនាងទៀង (ដៃនិងភ្នែកស្រាយចំណងអស់ហើយ) កាត់វាលស្រែធំល្វឹងល្វើយឆ្ងាយដាច់កន្ទុយភ្នែក ។ នៅតាមផ្លូវគេឃើញតែខ្មោចកំបុតក្បាល...។ គួរឲ្យតក់ស្លុតខ្លាំងណាស់ទៅទៀត បន្ទាប់ពីបានពិនិត្យសំលៀកបំពាក់របស់ខ្មោចមក គេដឹងថាខ្មោចទាំងនោះជាខ្មែរទាំងអស់ ។ នាងទៀងស្រាលខ្លួនដូចសំឡី អារម្មណ៍លែងនៅនឹងខ្លួនទៅហើយ ទោះជើងជំពប់នឹងដុំថ្មហូរឈាមយ៉ាងណាក៏លែងឈឺចាប់អ្វីទៅហើយ ។ នាងយកដៃស្ទាបក្បាលម្តងៗហើយគិតថា ៖ « ឱ ! ក្បាលខ្ញុំមុខជាដាច់ចោលជាមួយនឹងគេនៅទីនេះដែរឬយ៉ាងណា ? » ។

ម៉ោងប្រហែល១២, មេវៀតមិញនេះក៏បែរក្រោយមកប្រាប់នាងទៀងថា ៖ នេះគឺភូមិបឹង ! ។ កញ្ញាភ្ញាក់ហើយលាន់មាត់ថា..ឱ ! ។ ព្រោះនាងដឹងថា ៖ ចាប់ពីភូមិបឹងនេះទៅ នៅខាងកើតគឺភូមិចៃឌី រួចហើយគឺភូមិស្លែង បន្ទាប់ទៅគឺភូមិចុងព្រៃដែលជាស្រុកកំណើត ។ ប្រហែលនៅម៉ោង១រសៀល យួនដ៏អាថ៌កំបាំងនេះនាំនាងទៀងចូលទៅកាន់ខ្ទមស្លឹកមួយស្ថិតនៅក្រោយវត្តចៃឌី ដែលមានគេរៀបចំបាយទឹកថាំទទួលរួចជាស្រេច ។ អ្នកទាំងពីរបរិភោគទល់មុខគ្នា ។ ទោះភ័យបារម្ភយ៉ាងណាក៏ដោយ នៅពេលនោះកញ្ញាអាយុ១៩ឆ្នាំលេបបាយជាមួយនឹងខបង្កងលើកចេញពីឆ្នាំងភ្លាមៗ យ៉ាងក្តៅនិងយ៉ាងឆ្ងាញ់ពិសារ...។ នាងទៀងដឹងថាវៀតមិញនេះលបមើលមុខនាងម្តងៗយ៉ាងយកចិត្តទុកដាក់ ។ លុះបរិភោគអាហារចប់សព្វគ្រប់ហើយកាលណា វៀតមិញក៏និយាយមកកាន់នាងទៀងថា ៖ សមមិត្តទៀងមានបុកពោរស្លូតត្រង់ណាស់ គ្មានកលល្បិចអ្វីទេ តើមិត្តស្គាល់ខ្ញុំឬទេ ? នាងទៀងគ្រវីក្បាលបង្ហាញកាយវិការថា ៖ ទេ ។

យួននេះក៏បន្តទៅទៀតថា ៖ ខ្ញុំឈ្មោះ ផាម-វ៉ាន់ស៊ីវ ជាមេគិញសម្ងាត់ឈានមុខប្រចាំស្រុកត្រាកូវ ។ អង្គការលើ ( Câp Trên ) បញ្ជាឲ្យខ្ញុំចូលប៉ុស្តិ៍ចាប់សមមិត្តឯងជាច្រើនលើក ប៉ុន្តែមិនបានសំរេច ។ ដូច្នេះចំពោះព្រឹត្តិការណ៍ថ្ងៃទី៥-១-៨៧ ខ្ញុំបានចាត់ចែងប្រាប់គេឲ្យការពារសមមិត្តជាមុន ហេតុដូច្នេះហើយបានជាគេមិនសម្លាប់សមមិត្ត ។ អង្គការលើនឹងអប់រំសមមិត្តឲ្យជួយធ្វើការរដ្ឋាភិបាលរំដោះជាតិ ។ សមមិត្តបានរួចជីវិតនេះ ដោយសារតែអង្គការលើ.... ដូច្នេះសមមិត្តត្រូវតែដឹងគុណអង្គការលើ ។ ឥឡូវចូរសមមិត្តលើកដៃស្តាំសច្ចាដោយស្មោះត្រង់ ហើយឆ្លើយនឹងសំនួរដែលអង្គការលើដាក់ទិសមកឲ្យខ្ញុំសួរ ៖

« ហេតុយ៉ាងដូចម្តេចបានជាសមមិត្តរត់តាមបារាំង ? » ។

« ខ្ញុំមិនមែនរត់តាមបារាំងទេ, ខ្ញុំត្រូវជិះកង់តាមផ្លូវនេះទៅផ្ទះរបស់ខ្ញុំនៅឃុំភ្នៀកហ៊ីង ។ ខ្ញុំមិនអាចឆ្លងព្រៃកដ៏ធំនេះបានទេ ព្រោះស្ពានបានឆេះអស់រលីង

ទៅហើយ ។ នៅពេលដែលខ្ញុំកំពុងតែស្ទុះស្ទាររកមធ្យោបាយឆ្លងព្រៃក ស្រាប់តែពួកភៀសខ្លួនអស់ទាំងនោះមកដល់ស្របផ្លូវគ្នាជាមួយខ្ញុំតែម្តងទៅ » ។

« តើសមមិត្តទៀងស្គាល់នរណាជាមិត្ត នរណាជាសត្រូវទេ ? » ។

ពេលនោះកញ្ញាទៀងអង្គុយគិតយ៉ាងយូរទើបនាងឆ្លើយថា ៖

« វៀតណាមនិងខ្មែរជាមិត្ត ជាពិសេសដូចបងដូចប្អូន ព្រោះយើងមានដើមកំណើតក្នុងឥណ្ឌូចិនជាមួយគ្នា ខុសគ្នាតែភាសាប៉ុណ្ណោះ ។ សត្រូវរបស់យើងគឺបារាំង ព្រោះពួកនេះចូលមកឈ្លានពានប្រទេសយើង » ។

« តើសមមិត្តស្ម័គ្រចិត្តលះបង់គ្រួសារចូលបំពើរបបរួម ចូលបំពើរដ្ឋាភិបាលរំដោះជាតិឬទេ ? » ។

« ខ្ញុំសែនស្ម័គ្រចិត្ត ! » ។

អ្នកទាំងពីរនាក់សើចដោយត្រេកអរ និងពេញចិត្តរៀងខ្លួន ។ ប៉ុន្តែសេចក្តីត្រេកអរនោះមានគំនិតផ្សេងៗគ្នាស្រឡះ ។ ផាម-វ៉ាន់ស៊ីវត្រេកអរព្រោះរួចជីវិត ថ្ងៃណាមួយមានឱកាសនាងនឹងរត់ចូលខាងបារាំងវិញ ។ យប់នោះ ផាម-វ៉ាន់ស៊ីវក៏ជូននាងទៀងទៅកាន់ភូមិភឿកហ៊ីង ដើម្បីជួបឪពុកម្តាយនាងវិញ ។

ថ្ងៃទី១៨-១-៤៧ម៉ោង២អាធ្រាត យើងទាំងពីរនាក់បានទៅដល់មុខផ្ទះ ។ តែ ! ទ្វាររបងចេញចូលត្រូវស្ទះបិទជិត... ព្រោះក្នុងកាលៈទេសៈនោះ ខ្មែរកម្ពុជាក្រោមដែលនឹកៗទៅគួរឲ្យអាសូរ ត្រូវបានបារាំងរត់ចោលម្តងទៀត ។ ខ្មែរអភ័ព្វទាំងនោះក៏នាំគ្នាកាប់ឫស្សីបន្លាធ្វើសំរាស់ទ្វាររបងយ៉ាងមាំ ដោយភ័យតក់ស្លុតខ្លាចចោរវៀតមិញមកធ្វើបាប...។

យើងទាំងពីរនាក់ឈរអេរនៅលើថ្នល់ចម្ងាយប្រហែល៣០ម៉ែត្រពីផ្ទះ ។ នាងទៀងក៏ស្រែកហៅឪពុកតាមបញ្ជារបស់ផាម-វ៉ាន់ស៊ីវ... ហៅហើយហៅទៀត តែគ្មានចម្លើយ... មួយស្របក់ស្រាប់តែឃើញភ្លើងចង្កៀងនៅក្នុងផ្ទះ ។ នាងទៀងត្រេកអរណាស់ក៏ស្រែកហៅម្តងទៀត ។ យាយ-តាត្រេកអរណាស់ដោយស្គាល់សម្លេងកូនស្រី ។ គាត់មកជិតទ្វាររបងផ្ទះ ហើយក៏សួរបញ្ជាក់អស់កិច្ចការយ៉ាងយូរទំរាំនឹងបើកទ្វាររបងឲ្យយើងទាំងពីរ ។យាយតានិយាយប្រាប់យើងថា គាត់លង់លក់ក្នុងដំណេក មិនបានឮសម្លេងគេហៅគាត់ភ្លាមៗទេ ដោយមកពីការអត់ងងុយអស់ពេលជាច្រើនយប់មកហើយ ក្នុងការរុករកនិងសោកស្តាយកូនស្រី ។

នៅថ្ងៃដដែល ពេលបាយព្រឹករួច ផាម-វ៉ាន់ស៊ីវ ប្រកាសបើកអង្គប្រជុំមួយយ៉ាងឧឡារិកនៅភូមិចុងព្រៃកន្លែងទីលានទាត់បាល់ ។ ផាម-វ៉ាន់ស៊ីវឃោសនាពន្យល់វែកញែកផានាអះអាងការពារជីវិតខ្មែរកម្ពុជាក្រោម ដែលមានទីលំនៅនៅឃុំភឿកហ៊ីងនេះ ។ គាត់បញ្ជាក់ថា អង្គការលើចាប់ផ្តើមបញ្ជូនភ្នាក់ងារថ្មី ដែលបាន

ទទួលការអប់រំយ៉ាងត្រឹមត្រូវ ទទួលស្គាល់ខ្មែរកម្ពុជាក្រោមជាមិត្ត ជាបងប្អូន យើងត្រូវរួបរួមសាមគ្គីគ្នាកំទេចដេញបារាំងជាសត្រូវរួម ផ្លាស់ចូលមកដឹកនាំបងប្អូនសមមិត្តជំនួសភ្នាក់ងារពីមុន ។

ផាម-វ៉ាន់ស៊ីវកាន់ស្នានាងទៀងបង្ហាញដល់អង្គប្រជុំហើយនិយាយថ្លែងថា ៖ សមមិត្តទៀងពីដើមធ្លាប់បានធ្វើការបំរើបារាំង តែឥឡូវនេះសមមិត្តទៀងបានភ្ញាក់រលឹកស្ម័គ្រចិត្តចូលបំរើរបបរួមវិញហើយ អង្គការលើក៏លើកលែងទោសឲ្យសមមិត្តទៀងភ្លាម ។ រដ្ឋាភិបាលរំដោះជាតិចេញប្រកាសលើកលែងឈប់ប្រកាន់ទោសបងប្អូនខ្មែរចាប់តាំងពីពេលនេះទៅ ។ ចំណែកភ្នាក់ងារវៀតមិញពីមុននោះមានកំហុសធ្ងន់ណាស់ ឥឡូវនេះអង្គការលើប្រមូលនាំយកទៅ «លត់ដំ» ទុកជាគំរូ ។ សូមសមមិត្តទាំងអស់ឈប់ភ័យរត់គេចតទៅទៀត សុំរក្សាសេចក្ដីស្ងប់ស្ងៀម ចូរចេញប្រកបការងារតរៀងទៅ ព្រោះត្រូវរដូវច្រូតមកដល់ហើយ..។ បើមិត្តៗមានការអ្វីគួរឲ្យសៅហ្មង ចូរមករាយការណ៍ប្រាប់សមមិត្តទៀងនេះចុះ សមមិត្តទៀងអាចពាំនាំពាក្យរបស់សមមិត្តទាំងអស់ទៅដល់ខ្ញុំ ខ្ញុំនឹងដោះស្រាយជូនភ្លាម ។ ចាប់តាំងពីថ្ងៃនេះទៅ ខ្ញុំអនុញ្ញាតឲ្យសមមិត្តទៀងចេញចូលជួបខ្ញុំបានគ្រប់ពេលវេលា ។ និយាយរួចហើយ ផាម-វ៉ាន់ស៊ីវលើកដៃស្ទាំទះស្មានាងទៀងព្រមទាំងសួរបញ្ជាក់ថា «តើសមមិត្តយល់ព្រមទេ?» ។ នាងទៀងងក់ក្បាលយល់ព្រមជំនួសចម្លើយ ។ មុននឹងលាចេញពីនាងទៀងទៅ ផាម-វ៉ាន់ស៊ីវបានចុះហត្ថលេខាលើក្រដាស់មួយសន្លឹកតូច រួចហុចឲ្យនាងព្រមទាំងនិយាយខ្សិបៗទៅកាន់នាងថា ៖ អ្នកណាកាន់លិខិតនេះ គឺជាភ្នាក់ងារគិញសម្ងាត់ពិសេស (Trinh xat giên) ។ បើចង់ជួបខ្ញុំ គ្រាន់តែបង្ហាញលិខិតនេះដល់អ្នកនាំផ្លូវ (giao thon) ទៅ គេនឹងនាំសមមិត្តទៅជួបខ្ញុំភ្លាម ។ លុះផាម-វ៉ាន់ស៊ីវលាចេញផុតទៅ នាងទៀងពិនិត្យមើលលិខិតនោះ មានសរសេរលេខ 36X និងអក្សរបីបួនម៉ាត់ទៀតជាពាក្យកាត់សញ្ញាសំគាល់ ដែលនាងទៀងមិនយល់ថាមានន័យយ៉ាងម៉េចទេ ។

តាំងពីថ្ងៃនោះមក នាងទៀងមានកាតព្វកិច្ចចាំបាច់បំផុត គឺត្រូវជួបផាម-វ៉ាន់ស៊ីវជាស្ទាត់បំផុត ដើម្បីធ្វើសេចក្ដីរាយការណ៍ ម្ដងក្នុងមួយខែ ។ នាងទៀងត្រូវដើរម្ដងៗចម្ងាយយ៉ាងតិច២០គ.ម. ដើម្បីទៅជួបមេគិញសម្ងាត់នេះ ។ កន្លែងដែលជួបនិងអ្នកនាំផ្លូវត្រូវប្ដូរជារៀងរាល់ពេល ដោយដើរតាមក្មេងៗ ដែលមានអាយុយ៉ាងច្រើន ១៣ឆ្នាំ ដែលជាអ្នកនាំផ្លូវ ។ ពេលជួបគ្នាម្ដងៗ ផាម-វ៉ាន់ស៊ីវជជីកដេញដោលសួរនាងទៀងពីអាកប្បកិរិយារបស់ខ្មែរនៅឃុំ ភឿកហ៊ីង នេះ ។

ដូច្នេះជីវិតខ្មែរកម្ពុជាក្រោមនៅឃុំភឿកហ៊ីង ស្ថិតនៅក្នុងកណ្ដាប់ដៃនាងទៀង ហើយជីវិតនាងទៀងក៏ស្ថិតនៅក្នុងកណ្ដាប់ដៃខ្មែរទាំងនោះដែរ ។ ព្រោះឧបមាថា

នៅពេលនោះនាងទៀងនិយាយប្រាប់មេគិញថា ខ្មែរនេះទៀងត្រង់នឹងវាទេ តែនៅថ្ងៃក្រោយ អ្នកនោះប្រែជាក្បត់វាទៅវិញ នាងទៀងត្រូវជាប់ចោទពីបទយប់ឃិតស៊ីគ្រលុំជាមួយអ្នកនោះ តើនាងទៀងត្រូវធ្វើដូចម្តេច ? នាងទៀងត្រូវតែស្លាប់ ! ។ ដោយឥតតក់ស្លុតខ្វល់ខ្វាយចំពោះរឿងនេះ នាងទៀងក៏អង្វរឱពុក សុំរត់ចាកចេញពីទីនោះ ។ ប៉ុន្តែតាគីម-វណ្ណៈ ជាឪពុកខំពន្យល់កូនស្រីជាច្រើន ហើយនៅទីបញ្ចប់គាត់និយាយថា ៖

«បើកូនរត់រួចម្នាក់ គ្រួសារយើងទាំងអស់ត្រូវស្លាប់!» ។

នៅថ្ងៃទី២៧-១-៨៧ នាងទៀងបានទទួលសំបុត្រពីក្រសួងអប់រំ ដើម្បីហៅឲ្យចូលរៀនសាលាគរុកោសល្យតាមរបៀបថ្មី ដែលស្ថិតនៅភូមិ បាក់ត្រាង ។ រយៈពេលដែលត្រូវរៀនមានចំនួន១ខែគត់ ទាំងយប់ទាំងថ្ងៃ ។

រួចហើយវាបញ្ជូននាងមកធ្វើគ្រូបង្រៀននៅសាលាបឋមសិក្សាក្នុងឃុំភឿកហ៊ីង វត្តប្រទក្សសិលានិគ្រោធវិញ ។ មុខវិជ្ជាដែលត្រូវបង្រៀនគឺភាសាខ្មែរ-យួនដល់កូនសិស្សជាតិខ្មែរ។ ប្រាក់ខែដែលវៀតមិញបើកឲ្យមានចំនួន១០$ បូករួមទាំងអង្ករ២០លីត្រ និងអំបិល១លីត្រ ។ លុះដល់ខែឧសភា១៩៨៧ វៀតមិញចេញបញ្ជាថ្មីឲ្យនាងបង្រៀនតែពេលព្រឹក, ពេលល្ងាចត្រូវចេញជួយឃោសនាជាមួយភ្នាក់ងារឃោសនាឈានមុខ ។

ពេលនោះជាពេលដែលមានគ្រោះថ្នាក់យ៉ាងធ្ងន់មួយលើកទៀត ។ ព្រោះនៅពេលយប់ ត្រូវទៅឃោសនាពន្យល់វាស្ត្រខ្មែរដែលមានទីលំនៅនៅក្បែរប៉ុស្តិ៍បារាំងឲ្យរត់ថយចេញឲ្យអស់ ។

ដើម្បីផ្តិតភ្នែកខ្មែរកម្ពុជាក្រោមឲ្យគោរពនិងជឿនូវឃ្លា « មិត្តភាពខ្មែរ-យួន-លាវ » ថាមិនមែនជាការបោកប្រាស់, នៅពេលនោះគឺក្នុងឆ្នាំ១៩៨៧ វៀតមិញក្នុងខេត្តត្រាវិញសំរាំងជ្រើសរើសបានខ្មែរកម្ពុជាក្រោមជាអ្នកចេះដឹង ដើម្បីចាត់តែងតាំងទៅតាមក្រសួងនានាដូចជា ៖

- ក្រសួងឃោសនាការ ៖ វាដាក់លោកសឺន-ភឿករដ្ឋ ជាអតីតមេធាវី, លោកឡាំ-ថៃ ( ជាបងថ្លៃរបស់លោកសឺង-ង៉ុកថាញ់ ) និងលោកសឺន-ង៉ុកភឿក ។

- ក្រសួងសន្តិសុខ «គិញ» វាចាត់តែងតាំងលោក សឺង-ង៉ុកសួរ និងអ្នកស្រីផាក ។

- ក្រសួងអប់រំនិងសិក្សាធិការ វាចាត់តែងតាំងលោកថាច់-ថោន, អាចារ្យចែក និងនាងកញ្ញាទៀងជាគ្រូបង្រៀនកូនសិស្សជាតិខ្មែរ បង្រៀនមុខវិជ្ជាភាសាខ្មែរ-យួន ។

❑

នៅពេលនោះមានយួនម្នាក់ឈ្មោះ ង្វៀង-យ៉ាំងមៀង ហៅអាចារ្យមៀន លួចបន្លំដាក់ឈ្មោះជាខ្មែរកម្ពុជាក្រោម សឺង-ង៉ុកមិញ ហើយភរបន្ថែមថាជាប្អូនរបស់សឺង-ង៉ុកថាញ់ ។

តែខ្មែរនៅកម្ពុជាក្រោមស្គាល់អាចារ្យមៀនច្បាស់ណាស់ ។ មនុស្សនេះមានដើមកំណើតជាយួនសុទ្ធ ដែលត្រូវវៀតមិញចាត់តែងតាំង ហើយបញ្ជូនឲ្យទៅបួសរៀននៅរាជធានីភ្នំពេញ សំណាក់នៅវត្តសោមភឿក ។ លោកសង្ឃក្លែងក្លាយនេះខំក្រេបជញ្ជក់រៀនខាងផ្នែកពុទ្ធសាសនារបៀបខ្មែរ ខំរៀនរៀបបុកពារទៅតាមទំនៀមទំលាប់និងប្រពៃណីខ្មែរ ។ នៅឆ្នាំ១៩៤៧ ង្វៀង-យ៉ាំងមៀង ក៏ត្រូវវៀតមិញកោះហៅឲ្យចូលទៅកម្ពុជាក្រោមវិញ គ្រវាត់ស្បង់ចីពរចោល ហើយក៏ចូលបំរើបក្សកម្មុយនិស្តឥណ្ឌូចិន ជាប្រធានផ្នែកខាងខ្មែរ « génial » ។

នៅកម្ពុជាក្រោមជំនាន់នោះ វៀតកុងតែងតែបង្កើតបុណ្យសាធារណៈជារឿយៗ វាចាត់ជាំងគំនូរឲ្យគូររូបស្រីក្រមុំយួនដ៏ក្មេងម្នាក់ឈ្មោះ ឡេ-ធីធិញ កៀកកកញ្ញាទៀងដោយដាក់ចំណងជើងថា ៖ មិត្តភាពយួន-ខ្មែរ ។ នៅគ្រប់ពិធីបុណ្យសាធារណៈគេតែងតែឃើញរូបគំនូរជានិច្ច ។

ខែតុលាឆ្នាំ១៩៤៧ វៀតមិញបង្កើតគណៈកម្មការសម្ងាត់និងពិសេសមួយ ជ្រើសរើសយុវជននិងយុវនារីយួន-ខ្មែរ ដែលមានអាយុក្រោម២០ឆ្នាំ ដើម្បីបញ្ជូនទៅកម្ពុជាកណ្តាល ។ តែក្រោយមកវាប្តូរផែនការដោយរៀបចំយុវជន-យុវនារីទាំងនោះ ឲ្យទៅធ្វើកម្មសិក្សានៅប៉េកាំងទៅវិញ ។ ជំនាន់ទី១ មានបេក្ខជនចំនួន២៩នាក់គឺ ៖

- ផ្នែកខាងយួនមានយុវជនចំនួន២១នាក់ យុវនារីចំនួន២នាក់ឈ្មោះ ឡេ-ធីសង និងង្វៀង-ធីហួង ។
- ផ្នែកខាងខ្មែរមានយុវជនចំនួន៥នាក់ យុវនារីម្នាក់គឺកញ្ញាទៀង ។

មុននឹងចេញដំណើរទៅប៉េកាំង បេក្ខជនទាំងនោះត្រូវចូលរៀនសាលានយោបាយជាន់មធ្យមដែលបង្កើតឡើងដោយវៀតមិញនៅភូមិបឹង, ស្រុកត្រាកូវ ។ រយៈពេលរៀនក្នុងសាលានេះមានចំនួន៤ខែគត់ គឺចាប់ផ្តើមនៅថ្ងៃ១-១១-៤៧ ចប់នៅថ្ងៃ២៨-២-៤៨ ។ ប្រធានធំនៅក្នុងសាលានយោបាយនេះឈ្មោះង្វៀង-វ៉ាន់ទិញ មានសញ្ជាតិជាយួនព្រៃនគរ ។ គ្រូបង្រៀនមាន៣នាក់ជាជាតិយួនហាណូយ ។

កម្មវិធីសិក្សាជាដំបូង គឺវានិយាយច្រំដែលៗឲ្យបេក្ខជនទាំងអស់នោះស្គាល់ករណិយកិច្ចរបស់ពលរដ្ឋឲ្យបានច្បាស់លាស់ ។ ឧទាហរណ៍ ៖ បើយើងជាខ្មែរយើងត្រូវតែចេះស្រឡាញ់និងការពារអ្វីដែលជាខ្មែរ ។

ជារៀងរាល់ពេល នៅមុនពេលបាយព្រឹក-ល្ងាច បេក្ខជនទាំងអស់ត្រូវតែចេះ

ស្ទួរនិងចេះឆ្លើយ ។

- តើនរណាជាមិត្ត ?
- យួន-ខ្មែរ-លាវ ។
- តើនរណាជាសត្រូវ ?
- បារាំង និងជប៉ុន ។

លោកគ្រូសូត្រមេរៀនបន្តទៅទៀតថា ៖ ដើម្បីនឹងកំទេចខ្មាំងបាន យើងត្រូវមានបក្សជាអ្នកដឹកនាំ ។ ព្រោះហេតុនេះហើយបានជាអ៊ុំហូ ដែលជាមនុស្សទី១ សំរេចបង្កើតបក្សកុម្មុយនិស្តឥណ្ឌូចិន ។ អ៊ុំហូមានបំណងតែមួយគត់ គឺបង្រួបបង្រួមប្រជាជនទាំង៣នៃឧបទ្វីបឥណ្ឌូចិន ឲ្យក្លាយទៅជាជាតិតែមួយ នឹងអាចបានទៅជាកម្លាំងអមតៈ ។ ដូច្នេះយើង (យួន-ខ្មែរ-លាវ) ត្រូវតែធ្វើពលិកម្មលះបង់ម៉ែឪ បងប្អូន លះបង់កិច្ចការឯកជន យើងត្រូវតែគិតជានិច្ចនូវប្រយោជន៍រួមរបស់បក្ស ។ ជាពិសេស យើងត្រូវឈប់ប្រកាន់ពូជសាសន៍ គឺយើងត្រូវរៀបការប្តីប្រពន្ធជាមួយគ្នាចាប់ពីពេលនេះទៅ...។

ចាប់ពីពេលឥឡូវនេះទៅ ឪពុករួមរបស់យើងមានតែមួយគត់ គឺអ៊ុំហូ...

❑ ❑

❑

ដើម្បីសំរេចនូវគំរោងផែនការដ៏លោភលន់នេះ យួនហាណូយដែលមានហូ-ជីមិញជាមេដឹកនាំ ក៏ដាក់ទិសយ៉ាងរើសរាយដោយគ្រោងបញ្ជូនយុវជនខ្មែរចំនួនមួយម៉ឺននាក់ (ប្រុស៥ពាន់-ស្រី៥ពាន់) និងយុវជនជាតិយួនចំនួន២ម៉ឺននាក់ (ប្រុស១ម៉ឺន-ស្រី១ម៉ឺន) នាំយកទៅអប់រំនៅប៉េកាំង ។ ពេលវេលាទៅរៀនសូត្រនៅមិនទាន់កំណត់នៅឡើយទេ ។ តែនៅពេលនោះគេបញ្ជាក់ថា កាលណាបេក្ខជនទាំង៤ម៉ឺននាក់នេះរៀនចេះចប់ គេនឹងត្រូវវិលត្រឡប់មកឥណ្ឌូចិនវិញ ហើយចំពោះយួនហាណូយ គេសន្និដ្ឋានជាមុនស្រេចទៅហើយថា គឺពួកអស់នេះហើយដែលជាអនាគតអ្នកដឹកនាំបក្សកុម្មុយនិស្តឥណ្ឌូចិនយ៉ាងខែងរែង ដែលមានអ៊ុំហូជាប្រធាន។ រីឯរដ្ឋធានីថ្មីគេបំរុងស្ថាបនាឡើងនៅត្រង់ភូមិចំពុះទា ។ « យុវជនខ្មែរនិងលាវ ត្រូវតែរៀបការជាមួយយុវជនជាតិយួនជាដាច់ខាត ! » ។

តើហេតុយ៉ាងដូចម្តេចបានជាយួនហាណូយបង្ខំខ្មែរខ្មែរនិងលាវ ឲ្យរៀបការប្តី

ប្រពន្ធជាមួយសាសន៍យួន ?

គំនិតយួនហាណូយក្រឡិចក្រឡុចជានិច្ច ។ គេប្រៀបគំនិតពួកវានេះទៅនឹងមនុស្សដែលខំអង្អែលខ្នងគោដើម្បីយកមកបញ្ចូលនឹម ! ។ ព្រោះពួកវាដឹងថា កូនដែលកើតមកពីឪពុកម្ដាយជាតិយួន វានឹងនិយាយភាសាយួន ប្រកាន់ទំនៀមទំលាប់ផ្គត់គំនិតរបៀបយួន ដូច្នេះជាស្វ័យប្រវត្តិអ្នកដែលកើតនៅតំណក្រោយ មុខតែក្លាយទៅជាយួនយ៉ាងស្រួលមិនបាច់ខំ...។ ចំពោះមតិសកលលោក ប្រទេសខ្មែរ លាវ នៅតែខ្មែរ លាវ តែនៅខាងក្នុងប្រទេស សុទ្ធតែមានឈាមជ័រជាជាតិយួននិយាយភាសាយួន ។

ដោយសារខ្មែរនៅកម្ពុជាក្រោមយល់ឃើញបែបនេះហើយ បានជាឪពុកម្ដាយតែងតែហាមកូនប្រុសស្រីមិនឲ្យរៀបការជាមួយយួនជាដាច់ខាត ។

❑ ❑
❑

ពេលនាងទៀងរៀនចប់សាលានយោបាយជាន់មធ្យម វៀតមិញប្រារព្ធធ្វើពិធីបញ្ចប់វគ្គសិក្សា ។ វាបញ្ជាឲ្យមានសុន្ទរកថាបញ្ជាក់ការរឹតចំណងមិត្តភាពយួន-ខ្មែរ ជាភាសាទាំងពីរសាសន៍ ដែលមានកញ្ញាទៀងជាអ្នកតាក់តែងនិងឡើងថ្លែងសុន្ទរកថាជាភាសាខ្មែរ ។ នៅពេលបញ្ចប់ពិធីបុណ្យ បេក្ខជនគ្រប់ៗរូបត្រូវតែឡើងលើវេទិកា រួចលើកដៃស្ដាំចង្អុលមេឃធ្វើសច្ចាប្រណិធាន ៖

-ទី១ ៖ ត្រូវដឹងគុណ គោរពនិងស្មោះត្រង់ចំពោះអ៊ុំហូ ។

-ទី២ ៖ ត្រូវពង្រឹងគោលជំហរគិតប្រយោជន៍រួមបក្ស ។

-ទី៣ ៖ ត្រូវចេះលាក់ការណ៍អាថ៌កំបាំងទាំងអស់ ដែលបានរៀនសូត្រចេះដឹងពីសាលានយោបាយនេះ ។

លុះចប់ពិធីបញ្ចប់វគ្គសិក្សានេះហើយ មានបើកអង្គប្រជុំមួយជាសម្ងាត់ភ្លាមដើម្បីផ្លាស់ឈ្មោះបេក្ខជនទាំងអស់ ។ ពេលនោះផាម-វ៉ាន់ស៊ីវ ក៏នៅទីនោះដែរ ។ មេគិញសម្ងាត់និងពិសេសនេះ ក្រោកឡើងប្រកាសដាក់ឈ្មោះនាងកញ្ញាតិម-ធីអ៊ូយ ជាបាទៀង ដែលប្រែចេញពីភាសាយួនមកថា «ទេវតា» ។

ការប្ដូរឈ្មោះនេះ យួនវៀតមិញតែងតែធ្វើជារឿងរហូតមក ។ ឧទាហរណ៍នៅឆ្នាំ១៩៥៣ សាឡុត-សរបានចូលមកបំរើបក្សកុម្មុយនិស្តឥណ្ឌូចិន ង៉ៀង-យ៉ាំង-

មៀង ឬអាចារ្យមៀន ឬសឹង-ង៉ុកមិញ ក៏ដូរឈ្មោះជនោះថា ប៉ុល-ពត ដែលសកលោកទាំងមូលស្គាល់ រួចហើយនៅពេលថ្មីៗនេះ ប៉ុល-ពត ក៏បានផ្លាស់ឈ្មោះទៅជា «ល្មុត» រួចទៅហើយ ។

យើងនឹងតាមមើលតទៅទៀតថា បើល្មុតមិនទាន់ដល់ពេលគេសម្លាប់ទេ ឈ្មោះនេះនឹងច្បាស់ជានឹងដូរទៅជាស្អីមួយទៀតជាមិនខាន ។ល។

❑ ❑

❑

នៅយប់ថ្ងៃទី២៨-២-៨៨ វៀតមិញរៀបចំពិធីជប់លៀងមួយដ៏ឧឡារិក ដើម្បីជូនដំណើរបេក្ខជនទាំង២៩នាក់ ទៅរៀននៅប៉េកាំងជាលើកទី១ ។ ពេលទទួលទានភោជនាហារមកដល់ ផាំ-យ៉ាំងអៀង យួនបាណូយអាយុ២៥ឆ្នាំ ជាគ្រូបង្ហាត់សាលានយោបាយនេះ ចាប់ផ្ដើមធ្វើសំនួរដើម្បីបំភ្លឺនូវផែនការធំៗខ្លះនិងជាសម្ងាត់បំផុត ។ យួនអៀងសួរតាប្រធាន ង្វៀង-វ៉ាន់ទិញថា ៖

« ដំណាក់ការជាដំបូងរបស់បក្សកុម្មុយនិស្តឥណ្ឌូចិន ដែលអុំហូបានបង្កើតមកហើយនេះ គឺត្រូវកំទេចសក្ដិភូមិនិងចក្រពត្តិ ។ តើយើងត្រូវដោះស្រាយដូចម្ដេចចំពោះរាជាណាចក្រកម្ពុជានិងលាវ ដែលមានស្ដេចគ្រប់គ្រង ? » ។

តាទិញក្រោកឈរឡើង ញញឹមព្រមទាំងវែកញែកពន្យល់ថា ៖

« បាក់ហូ (ពាក្យយួនប្រែថាអុំហូ) មានផែនការគ្រោងទុករួចជាស្រេច ។ នេះជាការសម្ងាត់មួយដែលខ្ញុំទើបនឹងបានច្បាប់ពន្យល់អ្នកទាំងអស់នៅពេលនេះ ។ បាក់ហូគ្រោងបង្កើតខ្មែរថ្មី លាវថ្មី នាំយកទៅជំនួសខ្មែរនិងលាវនៅក្នុងស្រុកទាំងអស់ ។ អ្នកទាំង២៩នាក់នេះជាឧទាហរណ៍ស្រាប់ គឺជាអនាគតមេដឹកនាំឥណ្ឌូចិន ថ្មី ម៉្យាងទៀតបាក់ហូមានចាត់បញ្ជូនបូដូយឲ្យចូលទៅកាន់កម្ពុជា តាំងមូលដ្ឋានពាសពេញព្រៃ រួចហើយតាំងពីឆ្នាំ១៩៤៥មកម្ល៉េះ ដោយយើងយកលេសថា ជួយខ្មែរវាយកំទេចដេញបារាំង ។ ឆ្លៀតឱកាសដ៏ល្អនេះ បូដូយអាចមានពេលរៀនសូត្រឲ្យស្គាល់ភូមិសាស្ត្រនៃប្រទេសខ្មែរឲ្យបានគ្រប់ជ្រុងជ្រោយ ។ ចំណែកឯភ្នាក់ងារចិត្តសាស្ត្រក៏ខំរៀនសូត្រឲ្យស្គាល់ចិត្តគំនិត ចរិក ជាពិសេសចំណុចខ្សោយរបស់ប្រជាជនខ្មែរឲ្យបានច្បាស់លាស់ ។

ប្រជាជនខ្មែរដែលនៅចុងកាត់មាត់ញក អ្នកស្រែចំការដែលនៅឆ្ងាយដាច់ស្រ-

យាល អ្នកព្រៃភ្នំ ជាពិសេសក្រុមចោរព្រៃ គឺពួកទាំងអស់នោះហើយ ដែលជាអ្នករងគ្រោះដោយសារអំពើអយុត្តិធម៌បណ្តាលមកពីការជិះជាន់របស់រាជការពុករលួយនិងនាម៉ឺនស៊ីសំណូក ។

កាលបើភ្នាក់ងារចារកិច្ចរបស់យើងឲ្យដំណឹងប្រាប់ទីកន្លែងហើយ យើងនឹងបញ្ជូនភ្នាក់ងារចិត្តសាស្ត្រទៅពន្យល់រំដោះយកពួកនោះមកភ្លាម ។ គឺយើងត្រូវចូលទៅញុះញង់ដើម្បីអនុវត្តតាមឃ្លោងឃ្លារបស់បាក់ហូ«បំបែកបំបាក់ដើម្បីគ្រប់គ្រង» រួចហើយយើងនឹងឆ្លៀតបំពាក់នូវគោលជំហរលទ្ធិកុម្មុយនិស្តឥណ្ឌូចិនដែលស្អាតស្អំ ដែលយុត្តិធម៌ ដែលខំរកសេរីភាពឲ្យប្រជាជនក្រីក្រដែលត្រូវគេមើលងាយ ។ នៅតាមទីក្រុង យើងបានបញ្ជូនចារបុរសនិងចារនារី ដែលមានការអប់រំយ៉ាងត្រឹមត្រូវហ្មត់ចត់ មានតាំងពីដុកទ័រ, អាំហ្សេញ៉ូរ, អង់ត្រឺប្រឺន័រ, អ្នករាជការ, ទាហាន, អ្នកលក់ដូរ, ជាងជួសជុលឡាន, អ្នកប៉ះកង់ និងអ្នកលក់ត្រីជាដើម ។ ចារបុរសនិងចារនារីទាំងនោះខំរៀនសូត្រឲ្យស្គាល់គ្រប់ចំណុចខ្សោយរបស់ប្រជាពលរដ្ឋខ្មែរនៅគ្រប់មជ្ឈដ្ឋាន ។ យើងត្រូវចេះអត់ធ្មត់ ឈានមួយជំហានម្តងៗដោយប្រុងប្រយ័ត្ន រង់ចាំឱកាសល្អសឹមយើងកំទេចតាមចំណុចខ្សោយទាំងឡាយនោះ... យើងត្រូវតែលាកការណ៍នេះឲ្យបានជិតជាដរាប ។ សព្វថ្ងៃនេះ បីខែម្តង មិត្តៗរបស់យើងរាយការណ៍មកបក្សជាទៀងទាត់ ។ លទ្ធផលបានមកជាទីគាប់ចិត្ត គឺគ្មានការអ្វីគួរឲ្យព្រួយបារម្ភទេ ! » ។

តាទិញបន្តទៅទៀតថា ៖

« សត្រូវទី១របស់យើងគឺបារាំងដែលមានអាវុធដ៏ខ្លាំងក្លា តែបារាំងនាំអាវុធទាំងនោះមកឲ្យយើងការពារប្រទេសទេតើ ! ។ បូជួយនៅតែមានលទ្ធភាពអាចកំទេចសត្រូវបានជារៀងរាល់ពេលដែលអាចធ្វើទៅបាន ។ បក្សយើងនៅតែសង្ឃឹមជានិច្ចថា អាចដណ្តើមជ័យជំនះបាននៅថ្ងៃណាមួយខាងមុខជាមិនខាន ! ។ ឥឡូវនេះយើងត្រូវតែលៃលកបង្កើតខ្មែរថ្មី លាវថ្មីបណ្តើរៗ ។ នៅពេលដែលយើងឈ្នះអាចដេញកំចាត់បារាំងពីឥណ្ឌូចិនបានហើយ បក្សរបស់យើងត្រូវតែបញ្ចូលនគរខ្មែរ - លាវ មកក្នុងបក្សកុម្មុយនិស្តឥណ្ឌូចិនឲ្យបានទាន់ពេល ដោយមិនបាច់ចំណាយអាវុធនិងទ័ពទេ ។ ប៉ុន្តែយើងត្រូវប្រយ័ត្នចំពោះខ្មែរ ។ យើងត្រូវប្រើអាវុធចិត្តសាស្ត្រឲ្យខ្លាំង ព្រោះយើងមិនអាចយកជ័យជំនះដោយអាវុធទៅលើកងទ័ពខ្មែរបានទេ ។ ពិតមែនតែប្រជាពលរដ្ឋខ្មែរមានចរិកស្លូតបូត ប៉ុន្តែបើធ្វើសង្គ្រាម ខ្មែរជាមនុស្សស្វិតស្វាញ រឹងប៉ឹង ធន់ទ្រាំនូវចំពោះមុខការអត់ឃ្លាន ធាតុអាកាសក្តៅត្រជាក់, ភ្លៀងផ្គរនិងការលំបាកគ្រប់បែបយ៉ាង ។ ដូច្នេះយើងត្រូវតែអនុវត្តតាមឃ្លោងឃ្លាសំខាន់ៗដែលយើងបានរៀនរួចមកហើយ ៖

- បំបែកបំបាក់ដើម្បីគ្រប់គ្រង ( Chia rê dê cai tri ) ។
- មានបដិវត្តន៍កើតឡើងទើបជឿនលឿន ។
  ( Môt lân cach man môt lam tiên hoa ) ។
- ត្រូវធ្វើឲ្យសង្ស័យ រួចសឹមជួយឲ្យមានសង្ស័យឡើងវិញ ។
- សម្លាប់មនុស្សសុច្ចរិត ប្រសើរជាងទុកសត្រូវឲ្យនៅរស់ ។
- ឈ្នះបានគ្រប់គ្រង ចាញ់បានធ្វើជាសេដ្ឋី ។
  ( an lam vua thua lam giau ) » ។

ពេលនោះយួនអៀងលាន់មាត់ថា ៖ « ដូចជាស្រួលពេក ! » ។

តាទិញបន្តទៀតថា ៖

« យើងសន្និដ្ឋានរាស្ត្រខ្មែរសព្វថ្ងៃ (១៩៤៧) ដូចកូនពពែដែលកំពុងដេកលក់ ពុំដែលស្គាល់សង្គ្រាមទេ, ចាំមើលដល់ពេលមានសង្គ្រាមផ្ទុះឡើង គាត់មុខតែលោតដូចត្រីក្នុងទ្រុង ដែលរកផ្លូវចេញមិនឃើញឡើយ ។ ចំណែកឯពួកមេខ្មែរអ្នកដឹកវិញ បក្សយើងមានបង្កប់អ្នកស៊ើបការណ៍ឲ្យនៅធ្វើការជាមួយហើយ ។ បើសង្គ្រាមរវាងខ្មែរនិងយើងបន្តទៅទៀត បានយូរឹតតែប្រសើរ ! គឺយើងមានពេលនឹងបង្កើតខ្មែរថ្មីទៅជំនួស ។ ព្រោះហេតុនេះហើយបានជាបក្សចាប់ផ្តើមជ្រើសរើសយុវជននិងយុវនារីខ្មែរឲ្យទៅរៀននៅប៉េកាំងនេះ » ។ល។

តាទិញនិយាយមកដល់ត្រឹមណោះ ក៏ក្រឡេកមកនាងទៀងនិងយុវជនខ្មែរ៥នាក់ ដែលជាបេក្ខជនលើកទី១ ហើយញញឹមពេញចិត្ត ។

- តើរាស្ត្រខ្មែរគិតទល់នឹងយើងឬ ? សមមិត្តឡេ-ធីសងសួរ ។

- គ្មានអ្វីជាការពិបាកឡើយ ។ តាទិញឆ្លើយព្រមទាំងពេបមាត់ ដោយបញ្ជាក់នូវការប្រមាថរាស្ត្រខ្មែរជាពន់ពេក, ហើយបន្តទៅទៀតថា ៖

« ប៉ុន្តែយើងប្រើពេលយូរបន្តិច ដោយយើងត្រូវចេះប្រើការអត់ធ្មត់នេះឯង ដើម្បីរង់ចាំចារជនរបស់យើង ធ្វើការជាមួយមេដឹកនាំខ្មែរ ។ អ្នកទាំងនោះមានភារកិច្ចនឹងទៅអែបអបបញ្ចុកបន្សី ដើម្បីឆ្លៀតប្រើកលល្បិចធ្វើឲ្យអស់សង្ស័យ រួចសឹមជួយឲ្យមានសង្ស័យវិញ ។ ប៉ុន្តែបើមានបុគ្គលណារឹងទទឹងមុខមាត់ យើងត្រូវតែកំចាត់អ្នកនោះចោលភ្លាម ដើម្បីកុំឲ្យមានគ្រោះថ្នាក់ ។ សម្លាប់មនុស្សសុចរិតប្រសើរជាងទុកសត្រូវឲ្យនៅរស់ » ។

ពេលវេលាកាន់តែខ្លីណាស់ទៅហើយនៅពេលនោះ យួនអៀងធ្វើសំនួរជាចុងក្រោយទៅតាទិញថា ៖

« បក្សយើងធ្វើសង្គ្រាមដេញបារាំង ប្អូនយើងស្លាប់យ៉ាងច្រើន ចំណែកទ្រព្យសម្បត្តិត្រូវរលាយខ្ទេចខ្ទីសឹងអស់រលីង ។ ចំណែកខ្មែរ គេនៅសល់ទាំងទ្រ-

ព្យសម្បត្តិ ទាំងប្រជាពលរដ្ឋ ។ ម៉្យាងទៀតខ្មែរជាអ្នកកាន់ពុទ្ធសាសនា និងគោរពស្តេច ។ មិនទំនងថាយើងអាចកៀរប្រជាពលរដ្ឋគេឲ្យចូលបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលជាបក្សប្រឆាំងនឹងស្តេច និងពុទ្ធសាសនាសោះ ។

« មានបដិវត្តន៍កើតឡើងទើបជឿនលឿន ។ បានសេចក្តីថា យើងត្រូវលៃបន្លំធ្វើឲ្យខ្មែរមានបដិវត្តន៍កើតឡើងព្រោងព្រាត រួចទើបយើងឆ្លៀតបន្លំកំទេច ។ បូដូ-យដែលនៅរស់ ធ្លាប់មានការពិសោធន៍ មានបច្ចេកទេសផ្នែកសង្គ្រាមយ៉ាងត្រឹមត្រូវ ស្គាល់គ្រប់ជ្រុងជ្រោយនៃព្រៃព្រឹក្សាខ្មែរ ។ ដូច្នេះមិត្តបងៗ អាចបង្រៀនការដកស្រង់ពិសោធន៍ទាំងនោះដល់មិត្តប្អូនៗជំនាន់ក្រោយៗ ។ ចំណែកខាងចិត្តសាស្ត្រក៏ដូច្នោះដែរ មិត្តបងៗអាចដកស្រង់ការពិសោធន៍របស់ខ្លួន មកបង្រៀនដល់មិត្តប្អូនៗ ពីចារកិច្ចដែលគេបានស្គាល់ពីចារិកទំនៀមទំលាប់នឹងប្រពៃណីខ្មែរ ។ ចំណែកឯទ្រព្យសម្បត្តិវិញ យើងខាតបង់អស់១ភាគ តែយើងអាចរកមកវិញបាន៥ភាគ ។ គឺនៅពេលណាប្រទេសខ្មែរមានសង្គ្រាមផ្ទុះឡើង ទ្រព្យសម្បត្តិប្រទេសនេះគឺជារបស់យើង ។ ឈ្នះបានគ្រប់គ្រង ចាញ់បានជាសេដ្ឋី ។ ប៉ុន្តែយើងត្រូវតែលាក់មុខឲ្យជិតដោយបញ្ចេញខ្មែរថ្មីជំនួសយើង ចៀសវាងកុំឲ្យខុសច្បាប់អន្តរជាតិ ឥឡូវនេះទ្រព្យសម្បត្តិកុំអាលគិត យើងទុកឲ្យខ្មែរថែរក្សាឲ្យយើងសិនចុះ ។ ម៉្យាងទៀតជារឿងសម្ងាត់បំផុត យើងត្រូវទាក់ទងប្រទេសថៃ សុំឲ្យមេដឹកនាំថៃរក្សាសេចក្តីស្ងប់ស្ងៀម ។ សុំកុំឲ្យថៃលូកដៃក្នុងបញ្ហាខ្មែរនិងយួនឲ្យសោះ ។ បាក់ហូសន្យាថា ពេលណាកុម្មុយនិស្តឥណ្ឌូចិនបានសំរេចគោលបំណងជាស្ថាពរ បាក់ហូនឹងសងគុណថៃឲ្យពេញចិត្ត ដោយប្រគល់ខេត្តខ្មែរដែលថៃធ្លាប់បានកាន់កាប់ឲ្យទៅថៃវិញ » ។ល។

បេក្ខជនទាំង២៩នាក់ដែលអង្គុយស្តាប់ចំហមាត់ បញ្ឈរចង្កើះនិងចានបាយគ្មានយល់ន័យនូវពាក្យព្រោកប្រាជ្ញរបស់តាប្រធានង៉ៀង-វ៉ាន់ទិញឡើយ... ពាក្យ «ប៉េកាំង» ក៏ទើបតែឮនៅពេលនេះទេ ។

ចំណែកកញ្ញាទៀងនៅពេលនោះ ពាក្យដែលតាទិញថា មានបញ្ជូនបូដូយនិងចារបុរស ចារនារី ឲ្យទៅធ្វើសកម្មភាពនៅប្រទេសខ្មែរនោះ នាងគ្មានជឿទាល់តែសោះ ។ រីឯពាក្យ៥ឃ្លាដែលអង្គការលើកបញ្ហាឲ្យទន្ទេញចាំមាត់នោះ នាងទៀងទន្ទេញចាំមាត់ដូចសារិកា តែគ្មានយល់ន័យអ្វីទាំងអស់ ។ តែជាង២៧ឆ្នាំកន្លងមក ! ឆ្នាំ១៩៧៥ យាយទៀងក៏បានភ្លក្សរបបអង្គការនៅស្រុកខ្មែរ បានឃើញការសាបព្រួសនេះដោយផ្ទាល់ភ្នែក ដែលធ្វើឲ្យស្រុកខ្មែររលាយទាំងទ្រព្យសម្បត្តិ ទាំងជីវិតប្រជាជន... យាយទៀងទើបយល់នៅពេលនេះ !...

ចុងបញ្ចប់ តាទិញលើកដៃចង្អុលនាងទៀង ។ នាងទៀងក្រោកឈរឡើងប-

ពេញក្រដាស់មួយសន្លឹក រួចអានឲ្យបេក្ខជនទាំងអស់និយាយតាម ៖

« យើងខ្ញុំសូមលើកដៃស្តាំឡើង សូមសច្ចាប្រណិធានជាលើកទី២ យើងខ្ញុំសូមលាក់អាថ៌កំបាំងនេះលុះត្រាជីវិតក្ស័យ » ។

មុននឹងបែកលាគ្នា យួនហាណូយឈ្មោះអៀងក្រោកឈររំលឹកថា អង្គការលើហាមដាច់ខាតមិនឲ្យមានស្នេហាជាសេរីឡើយ ។ ពេលណាចប់ការសិក្សា បេក្ខជនទាំង២៨នាក់ ត្រូវវិលមកកាន់មាតុភូមិវិញ ដើម្បីនឹងរៀបការគូស្រករជាមួយបេក្ខ-ជនយួនជាដាច់ខាត ។

យួនអៀងថ្លែងព្រមានតទៅទៀតថា ៖

« សមមិត្តទាំងអស់បានរៀនសូត្រដឹងផែនការអាថ៌កំបាំងទាំងអស់ហើយ បើមានសមមិត្តណាម្នាក់ក្បត់លួចរត់ចេញពីខ្សែរយៈ អង្គការលើត្រូវតែចាត់ការតាមសម្លាប់លុះត្រាតែបាន ! » ។

ព្រឹកថ្ងៃទី១-៣-៨៨ នាងកញ្ញាទៀងសុំលាគណាកម្មការនិងមិត្ត ធ្វើដំណើរដោយជើង ទៅកាន់ភូមិចុងព្រៃជាភូមិកំណើត ដើម្បីសុំលាឪពុកម្តាយ បងប្អូន ដើម្បីចេញដំណើរទៅប៉េកាំង ដែលគេគ្រោងទុកនៅថ្ងៃទី៣-៣-៨៨ ។ ពេលបាយល្ងាចមកដល់ យើងជួបជុំគ្នាទទួលទានអាហារ ។ នាងទៀងមានទឹកមុខស្លូត អាថ៌កំបាំងដែលរៀនចេះចាំពីសាលានយោបាយមក នាងមិនហ៊ានប្រាប់នរណាឡើយ ។ នាងទៀងនឹកឃើញឡើងវិញនូវអនុស្សាវរីយ៍ចាស់ៗទាំងប៉ុន្មាន កាលពីនាងនៅតូចធ្លាប់បានតាមឪពុកទៅវត្ត ។ នាងចេះសូត្រធម៌ថ្វាយបង្គំព្រះចាំមាត់តាំងពីអាយុ៦-៧ឆ្នាំ ។ នាងនឹកឃើញនៅថ្ងៃមួយនោះ ពេលដែលតាមឪពុកទៅវត្ត បានឃើញកូនសិស្សលោកប្រុសៗអានសាស្ត្រាស្លឹករឹត ៖ រឿងចៅស្រទបចេក ដែលធ្វើឲ្យនាងអង្គុយស្តាប់យ៉ាងជក់ចិត្ត ។ នាងចង់អានដូចគេដែរ ។ នៅពេលនោះនាងក៏ចូលទៅថ្វាយបង្គំលោកគ្រូសង្ឃរាជព្រះនាម រាជ សួរថាតើធ្វើយ៉ាងម្តេចទើបអានសាស្ត្រានេះកើត ? ព្រះគ្រូសង្ឃរាជទ្រង់ព្រះសំរួល រួចហើយព្រះអង្គទ្រង់មានសង្ឃដីការថា គេត្រូវរៀន ក ខ ន មោ សិន តើនាងចង់រៀនឬទេ ? ។

- ខ្ញុំព្រះករុណាចង់រៀន, នាងទៀងឆ្លើយគ្មានរារែក ។

ព្រះគ្រូទ្រង់ភ្ញាក់ដោយព្ធចម្លើយនេះ ព្រោះតាំងពីដើមមក មិនដែលមាននារីខ្មែរកម្ពុជាក្រោមណារៀនអក្សរទេ ។ ព្រះគ្រូក៏មានសង្ឃដីការសួរយោបល់ទៅតាគិម-វណ្ណៈជាឪពុក ។ គាត់មានចិត្តត្រេកអរជាក្រៃលែង ក៏សំរេចប្រគេនកូនស្រីជាកូនសិស្សលោកគ្រូសង្ឃរាជ ។

នាងទៀងកាត់សក់ឡុងសុងបន្លំធ្វើប្រុស ដើម្បីសំរួលការចូលរៀន ។ ក្នុងរយៈពេលមួយឆ្នាំគត់ នាងទៀងរៀនចេះអាន ចេះសរសេរ ចេះធ្វើលេខនព្វន្ត ។

លោកគ្រូទតឃើញដូច្នេះក៏បញ្ជូនឲ្យនាងទៅរៀននៅសាលារដ្ឋ តទៅទៀតក្នុងឆ្នាំ ១៩៣៨ ។

នៅឆ្នាំ១៩៤០ នាងប្រឡងចូលរៀនសាលាបឋមសិក្សាឥណ្ឌូចិន-បារាំងជាប់បានលេខ២ ។

យាយឡើយជាម្ដាយមានកង្វល់គ្រប់ចំពូក គាត់ក៏ចង់ឲ្យនាងឈប់រៀន តែឪពុកមិនយល់ព្រមដោយផ្ដួរផ្ដាច់ត្រូវតែបញ្ជូនកូនស្រីទៅត្រាវិញ ដើម្បីបន្តការសិក្សាដែលមានចម្ងាយ២០គ.ម.ពីទីលំនៅ គឺឆ្ងាយសែនឆ្ងាយនៅពេលនោះ ។ ដូច្នេះនៅឆ្នាំនោះ នាងទៀងត្រូវតែចាកចេញពីឪពុកម្ដាយដើម្បីបន្តការសិក្សា ។ ជាដំបូង កូនសិស្សក្នុងថ្នាក់ជាមួយគ្នាស្មានថាយាយទៀងជាប្រុស... តែគួរឲ្យឆ្ងល់ដែរ ព្រោះមានឈ្មោះជាស្រី ។ ក្រោយមកយូរបន្តិចទើបនាងទៀងស្លៀកពាក់និងទុកសក់វែងតៀតទៅក្រោយជាស្រីទៅវិញ ។ល។ ចំណែកអ្នកស្រុកជិតខាងនិងញាតិសារលោហិតខ្លះៗ លួចពេបជ្រាយសម្លក់សម្លឹងគ្រួសារតាគឹម-វណ្ណៈ ដែលបណ្ដោយឲ្យកូនស្រីក្រមុំរៀនសូត្រយ៉ាងនេះ ។ ម្ដាយនាងទៀងសំរក់ទឹកភ្នែកជាញឹកញាប់ដោយទ្រាំមិនបានចំពោះពាក្យដៀមដាមនិងប្រមាថពីសំណាក់អ្នកផងទាំងពួង ។ តែឪពុកនាងមិនរវល់ចំពោះរឿងនេះទេ គាត់ថែមទាំងជួលគ្រូយួនមកបង្រៀនភាសាដល់កូនស្រីគាត់នៅគ្រប់ពេលវិស្សមកាលទៀតផង ។ លទ្ធផលបានសំរេចដោយគាត់ឃើញកូនស្រីបានចេញធ្វើគ្រូបង្រៀននៅឆ្នាំ១៩៤៦ ។ល។

រៀបបែកគ្នានេះ នាងទៀងនឹកឃើញអនុស្សាវរីយ៍ដ៏ជូរចត់ ។ នាងនឹកអាណិតឪពុកម្ដាយនាងខ្លាំងពេក ពីព្រោះឪពុកនាងចង់ឲ្យនាងរៀនចេះដឹង ទើបនាងត្រូវព្រាត់ចេញពីគ្រួសារឆ្ងាយសែនឆ្ងាយ ព្រមទាំងគ្មានសង្ឃឹមជួបគ្នាវិញទេ ។ បណ្ដាពីអស់សង្ឃឹម នាងក៏ឱបឪពុកយំហើយយំទៀត ។ ពេលនោះនាងដឹងថាឪពុកនាងក៏តឹងទ្រូងចំពោះនាងដែរ ។ គាត់ជាមនុស្សនឹងនរ និយាយតិច ប៉ុន្តែមានន័យទូលំទូលាយ ។ គាត់សញ្ជឹងគិតមួយសន្ទុះ ទើបគាត់និយាយលួងលោមកូនស្រីរបស់គាត់ថា ៖ អាទៀងអើយ, កុំកើតទុក្ខអី ពេលណាកូនរៀនចេះចប់ កូននឹងវិលត្រឡប់មកជួបឪវិញទេតើ ! ។

ដោយអាណិតឪពុកខ្លាំងពេក នាងកញ្ញាទៀងក៏ស្រែកយំរង្វេងស៊ុងភ្លេចគិតដល់ពាក្យព្រមានរបស់តាង្វៀង-វ៉ាន់ទិញ និងយួនផាំ-វ៉ាន់អៀង ក៏ភ្លាត់មាត់ថ្លែងថា ៖

« ឱ ! ឪអើយ ! ពេលចប់កម្មសិក្សា ខ្ញុំមិនអាចមកជួបម៉ែឪបងប្អូនឡើយ ជាពិសេសខ្ញុំត្រូវរៀបការគូស្រករជាមួយយួនជាដាច់ខាត ។ រឿងលោកកៀង-ឥន្ទ្រជាគូដណ្ដឹងរបស់ខ្ញុំនោះ ត្រូវផ្អាកឈប់តែត្រឹមនេះចុះ » ។

ឮពាក្យរៀបការគូស្រករជាមួយយួនភ្លាម ដូចកាំភ្លើងធំបាញ់ចំក្បាល គ្រប់ៗគ្នា

ម៉ែឪ បងប្អូន ញាតិសារលោហិតជ្រួលច្របល់ ក្តាប់ដៃ ខាំធ្មេញ មានកំហឹងជាយ៉ាងខ្លាំង ចំពោះច្បាប់ឃ្លួនរៀតមិញដែលចេញបង្ខំមិនទំនងយ៉ាងនេះ ។ ដូច្នេះគ្រួសារតាគឹម-វណ្ណៈក៏សំរេចចិត្តជាបន្ទាន់ថា ត្រូវតែបញ្ជូននាងទៀងចេញពី «ដែនដីរំដោះ» ចូលទៅកាន់ទីក្រុងត្រាវិញ ដែលមានរដ្ឋការបារាំងគ្រប់គ្រង ។

❑ ❑

❑

# ការគេចចេញពីកណ្តាប់ដៃវៀតមិញ

ម៉ោងប្រហែល៩យប់ បងប្រុសទី២ក៏បណ្តើរប្អូនស្រីផ្សងព្រេងដើរកាត់វាលមួយយ៉ាងធំដាច់កន្ទុយភ្នែក ទៅកាន់ភូមិបាត្រាច់ ។ ដល់ហើយក៏ប្រគល់ប្អូនស្រីទៅឲ្យនារីម្នាក់ឈ្មោះម៉ឹង ដើម្បីជូនដំណើរតទៅទៀត ។ រីឯបងប្រុសអ្នកជូនដំណើរក៏វិលត្រឡប់ទៅកាន់ភូមិចុងព្រៃវិញភ្លាម ។ ម៉ោង១២អាធ្រាតទៅដល់វត្តបាត្រាច់ រួចដើរកាត់វាលតូចមួយនៅខាងកើតវត្ត ដើម្បីទៅកាន់ភូមិផ្លូវអំពូង ។ នារីម៉ឹងក៏ប្រគល់នាងទៀងបន្តទៅឲ្យតាជាសនិងយាយគឹម ដើម្បីសំដៅទៅភូមិដំបូកបី ។ ម៉ោងប្រហែល២ភ្លឺ តាយាយចិត្តធម៌នេះក៏(បណ្តើរនាងដើរកាត់វាលកាត់ភូមិ ទោះហត់គយូរយ៉ាងណាក៏ដោយ ក៏មិនហ៊ានសំរាកឈប់ឡើយ ។ នៅម៉ោងប្រហែល៩ភ្លឺទើបបានទៅដល់ភូមិដំបូកបី គឺជាពេលដែលអ្នកស្រុកភូមិនេះកំពុងរៀបចំចេញដំណើរ រែកមាន់ទាត្រីអង្ករនិងបន្លែគ្រប់មុខ នាំយកទៅលក់ឲ្យទាហានជំនួយបារាំងនៅផ្សារកំពង់ខ្ទឹង ។ តាជាសយាយគឹមក៏ឱបលានាងទៀងត្រឡប់ថយក្រោយវិញទាំងទឹកភ្នែកសស្រាក់ដោយក្តីអាណិតចំពោះនារី...។

នាងទៀងដើរផ្សងព្រេងតាមអ្នកលក់ដូរតម្រង់ចូលទៅកាន់ប៉ុស្តិ៍កំពង់ខ្ទឹង ។ ក្នុងពេលធ្វើដំណើរតែឯកឯងនេះ នាងទៀងគាំងមាត់រកពាក្យអ្វីនិយាយលែងចេញ ក្រៅពីសំរក់ទឹកភ្នែកដោយមិនដឹងខ្លួន មិនគួរណានៅពេលនេះបែរជាព្រាត់ប្រាស់គ្រួសារយ៉ាងនេះទៅវិញ ។ នាងនឹកអាណិតបងបង្កើតទី២, នាងម៉ឹង, តាជាសយាយគឹម ដែលខំជូននាងដើម្បីគេចចេញពីក្រញាំវៀតមិញ...។ ឥឡូវនេះ មានតែ

ទឹកភ្នែកនេះទេ ដែលជាសាក្សីបង្ហាញថា នាងមានការឈឺចាប់ណាស់...។

នៅថ្ងៃទី២-៣-៨៤ នាងទៀងចូលទៅជួបលោកសែហ្វកុងវ័រ ដើម្បីសុំឡានជិះទៅកាន់ក្រុងត្រាវិញ ។ សែហ្វប៉ុស្តិ៍នេះជាជាតិយួនព្រៃនគរ អាយុប្រហែល៣០ឆ្នាំ រាងខ្ពស់ស្តើង ស្រមុះស្រួច សក់រួញអង្កាដី ។ ពេលឃើញនាងទៀងភ្លាម វាបើកភ្នែកធំៗ សម្លឹងមួយសន្ទុះរួចក៏បើកសៀវភៅមួយដែលមានរូបថតពេញ ។ វាផ្ទៀងផ្ទាត់បើកទំព័រចុះឡើង រួចបិទទៅវិញ ។ វាមើលមុខនាងទៀងម្តងទៀតរួចសួរថា ៖

- កូចង់ទៅកាន់ទីក្រុងត្រាវិញឬ ? »។

« ចាស ! »។

គ្មានសំនួរដេញដោលអ្វីតទៅទៀតទេ វាក៏ចុះហត្ថលេខាលើលិខិតជិះឡានមួយសន្លឹកឥតបង់ថ្លៃ ហុចមកឲ្យនាងទៀង ព្រមទាំងនិយាយថា ព្រឹកស្អែកនេះខ្ញុំទៅជួបកូនៅកន្លែងឡើងជិះឡាន ។ យប់នោះនាងទៀងដេកផ្ទាល់ដី គ្មានអ្វីក្រាល គ្មានអ្វីដណ្តប់ឡើយ ជាមួយអ្នកដំណើរជាច្រើនរយនាក់មកពីគ្រប់ទិសទី ដែលរង់ចាំកុងវ័រមួយអាទិត្យម្តង ។ នាងទៀងដឹងថា នេះជាសំណាងរបស់នាងដែរ ដោយបានមកជួបវេនកុងវ័រក្នុងថ្ងៃនេះ ។

ព្រលឹមថ្ងៃទី៣-៣-៨៤ មានឡានប្រហែល៥០គ្រឿងរៀបក្បួនជាស្រេចនៅតាមបណ្តោយដងផ្លូវ ដែលមានក្បាលឡានបែរមុខឆ្ពោះទៅកាន់ខេត្តត្រាវិញរួចជាស្រេច ។ ម៉ោង៨ព្រឹក កំពុងតែឆ្លេឆ្លារកឡានជិះ ស្រាប់តែឃើញយួនពីម្សិលមិញដើរតម្រង់មក មុខញញឹម រួចនាំនាងទៅបង្ហាញឡានដែលត្រូវឡើងជិះ ។ មានកន្លែងជិះយ៉ាងស្រួលបួល នាងទៀងមានមនោសញ្ចេតនាដឹកអរគុណាយួន ដ៏មានចិត្តល្អដ៏ចម្លែកនេះជាក្រៃលែង ។ ក្បួនឡានក៏ធ្វើដំណើរមកដល់ត្រាវិញនៅម៉ោងប្រហែល៨រសៀល ។ នាងទៀងមានចិត្តរំភើបជាក្រៃលែង ដោយបានមកដល់ទីដៅដោយសុវត្ថិភាព...

ដើរបានប្រហែល១០ជំហាន មនុស្សម្នាក់ចាប់ដៃនាងទាញពីក្រោយជាប់ ។ នាងងាកក្រោយ ឃើញយួនម្នាក់ស្លៀកពាក់ជាប៉ូលីស អាយុប្រហែល២៧ឆ្នាំ ចាប់នាងដឹកដៃបណ្តើរទៅកាន់ឡានហ្ស៊ីបមួយដែលឈប់សំចតនៅក្បែរនោះស្រេច ។ ដល់ឡានហ្ស៊ីបហើយ វាក៏បញ្ជាឲ្យនាងឡើងឡានខាងក្រោយ ដែលនៅលើពូកឡាននោះមានប៉ូលីសម្នាក់ទៀតអង្គុយរង់ចាំនាងទៀងជាយូរមកហើយ ។ ប៉ូលីសនេះក៏ភ្ជង់កាំភ្លើងខ្លីមកលើនាង ហើយក៏បញ្ជាឲ្យអ្នកបើកបរបញ្ឆេះឡានបើកតម្រង់ទៅកាន់ក្រសួងសន្តិសុខជាតិ ដោយសរសៀរតាមមាត់ទន្លេ...។

នាងទៀងស្រាលខ្លួនដូចសំឡី ស្លុតបំពង់ក ចង់ដួលសន្លប់ ។ កំពុងតែភ័យ

តក្កមាក្នុងចិត្ត ស្រាប់តែឮសម្លេងមួយពីចម្ងាយជាភាសាខ្មែរ ៖ « ខ្ញុំមិនជឿទាល់តែសោះ ថាមានស្រីខ្មែរជាមេវៀតមិញ » ។

នាងទៀងបែរភ្នែកទៅរកម្ចាស់សម្លេង នាងឃើញបុរសអាយុប្រហែល៣៨ឆ្នាំ មាឌធំខ្ពស់ សក់រួញអង្កាញ់ មុខវែង ច្រមុះស្រួច សម្បុរខ្មៅ ។ លោកនេះចង្អុលមកនាងទៀងរួចនិយាយបែបកំប្លែងជាមួយប៉ូលីសខ្មែរម្នាក់ដែលដើរជាមួយថា ៖ នាងនេះឬជាមេវៀតមិញ ? ។ លោកឈរច្រត់ចង្កេះសម្លឹងនាងទៀតយ៉ាងយូរ រួចក៏ហៅនាងចូលទៅការិយាល័យរបស់គាត់ ។ លោកចាប់ផ្តើមសួរ ៖

- នាងឈ្មោះអី ? ។
- គឹម-ធីអ៊ូយ ។
- ឈ្មោះឪពុក ? ។
- គឹម-វណ្ណ: ។
- ឈ្មោះម្តាយ ? ។
- ថាច់-ធីឡើយ ។

លោកសម្លឹងមុខនាងទៀង ។

- ស្រុកកំណើត ? ។
- ភូមិចុងព្រៃ ។

ស្រាប់តែលោកនេះដាក់ស្លាបប៉ាក្កាចុះ រត់មកឱបជនជាប់ចោទតាំងទឹកភ្នែកស-ស្រាក់ព្រមទាំងនិយាយថា ៖ ឱ ! អាទៀងអើយ ឯងធំប៉ុណ្ណឹងទៅហើយ ! មាត្រូវជាប្អូនជីដូនមួយរបស់ម្តាយឯង ថាច់-ធីឡើយ ។ មាបែកចេញពីគាត់អស់រយៈពេល១៨ឆ្នាំហើយ ។

លោកនេះឈ្មោះ ថាច់-ទីហុង បានចាកចេញពីស្រុកចុងព្រៃ តាំងពីគាត់មានអាយុ២០ឆ្នាំមកម្ល៉េះ ដើម្បីចូលធ្វើទាហានបារាំងវាយកំទេចកុងសាង ។ នៅឆ្នាំ១៩-៤៧ បារាំងចាត់តែងតាំងលោកជាភ្នាក់ងារសន្តិសុខនៅខេត្តត្រាវិញ ។ ព្រឹកមិញនេះលោកបានទទួលទូរលេខមួយច្បាប់ពីសែហ្វកុងវ័រនៅប៉ុស្តិ៍កំពង់ខ្ទីងមានសេចក្តីជាអាទិថា ៖

« មាននារីខ្មែរវៀតមិញម្នាក់ធ្វើដំណើរចូលកាន់ទីក្រុងត្រាវិញ » ។ លោកថាច់ទីហុងក៏ចាត់ភ្នាក់ទៅរង់ចាំចាប់ ។ កំពុងតែជជែកសួរសុខទុក្ខគ្រួសារ ស្រាប់តែមានគេនាំសំបុត្រមួយមកជូនលោក ។ អ្នកផ្ញើគឺសែហ្វប៉ុស្តិ៍កំពង់ខ្ទីងដដែល ។ លោកថាច់-ទីហុងហែកស្រោមសំបុត្រ រូបគំនូរមួយសន្លឹកក៏ជ្រុះនៅលើតុ ។ លោកថាច់ទីហុងរើសរូបនេះមកមើល រួចហុចឲ្យនាងទៀង ។ នាងឃើញរូបសំបុត្រយំហ្ស៊ូ គឺរូបនាងទៀងថតកៀកកជាមួយស្រីយួន ដែលមានចំណាងជើងជាភាសាយួន ៖ «

មិត្តភាពយួន-ខ្មែរ » ។ នាងទៀងយំបណ្ដើររៀបរាប់ប្រាប់ឪពុកមាបណ្ដើរពីការដែលវៀតមិញបង្ខំឲ្យនាងធ្វើការឲ្យវា ប្រាប់ពីគំរោងការដែលវាចង់រៀបការជាមួយយួន ពីការដែលនាងត្រូវតែបែកពីឪពុកម្ដាយរហូតបានមកជួបរូបគាត់នៅពេលនេះ ។ លោកថាច់-ទីហុងស្ដាប់ក្មួយស្រីយំរៀបរាប់ យល់ហើយ ក៏អស់ការសង្ស័យ ។ គាត់យល់ពីការដែលក្មួយខំរត់រកទីជំរក ។ គាត់យល់ដល់កលល្បិចយួនទាំងនោះ ទោះជាវៀតមិញក្ដី ទោះជាយួនរដ្ឋការបារាំងក្ដី ដែលវាធ្វើបាបខ្មែរ ជំរុញអ្នកចេះដឹងឲ្យដើរដល់សភាពទ័លច្រក រហូតដល់រត់ចោលមាតុភូមិទុកទឹកដីឲ្យវានៅ...។

យប់នោះ ក្រសួងសន្តិសុខជាតិត្រូវតែឃាត់នាងទៀងទុកតាមច្បាប់ ។ លោកថាច់-ទីហុងនៅជាមួយក្មួយទល់ភ្លឺ ។ ស្អែកឡើងលោកថាច់-ទីហុងបណ្ដើរលោកប៉ាន់-ឡូវ អធិការក្រសួងសិក្សាធិការបឋមសិក្សាខ្មែរមកជួបនាងទៀង ។ លោកអធិការឱបនាងទៀងបញ្ជាក់នូវសេចក្ដីអាណិតអាសូរ ។ រួចហើយគាត់ក៏នាំនាងទៀងជាមួយលោកថាច់-ទីហុងបណ្ដើរឡើងឡានហ្ស៊ីបដដែល ដែលបើកបរដោយយួនពីម៉្សិលមិញដដែល ទៅជួបលោកមេបញ្ជាការជាតិបារាំង ដើម្បីសុំធានានាងឲ្យចាកផុតពីក្ដីចោទប្រកាន់របស់យួនបំរើបារាំង ។ បានអនុញ្ញាតពីលោកមេបញ្ជាការហើយ លោកថាច់-ទីហុងក៏នាំនាងទៀងទៅសំណាក់នៅផ្ទះគាត់ ។

❑ ❑

❑

# ការតាមព្យាបាទរបស់វៀតមិញ

បន្ទាប់ពីបានរត់ចេញពីក្រញាំវៀតមិញមក នាងទៀងសំណាក់នៅផ្ទះលោកថាច់-ទីហុងជាឱពុកមាអស់មួយរយៈ ។ ពេលមួយនោះ លោកសង្ឃមួយអង្គព្រះនាម ឌិន បានសាកល្បងសម្លាប់នាងទៀង ។ ក្រោយមកទើបគេដឹងថា លោកសង្ឃក្លែងក្លាយនេះត្រូវវៀតមិញបំបួសដើម្បីឲ្យមកកំចាត់ ។ ដោយមិនអាចធ្វើអ្វីនាងទៀងកើត ដោយសារការឃាមល្បាតយ៉ាងតឹងរ៉ឹងរបស់លោកថាច់-ទីហុង លោកសង្ឃនេះក៏បាត់ខ្លួនទៅ ។ រាប់យប់នាងទៀងតែងតែគេងនៅក្បែរម្តាយបង្កើតរបស់លោកថាច់-ទីហុង ។ គាត់ជាមនុស្សពិការភ្នែក តែមានអារម្មណ៍រហ័សរហួនណាស់ កាលណាឮសូរសើរីបសម្លេងអ្វីមួយកើតឡើង ។

នៅយប់មួយ... វេលាម៉ោងប្រហែល២ទៀបភ្លឺ នាងទៀងកំពុងតែគេងលង់លក់ស្កប់ស្កល់ ជីដូនពិការភ្នែកស្រាប់តែឮសូរសើរីបជើងឡើងលើជណ្តើរផ្ទះ ។ យាយសួរតិចៗថា ៖ នរណា ? នរណា ? ។ មិនឮឆ្លើយ យាយក៏បន្លឺងសម្លេងស្រែកមិនឮឆ្លើយ យាយក៏បន្លឺងសម្លេងស្រែកយ៉ាងខ្លាំង « ជួយផងៗ ! វៀតមិញ ! » ព្រោះនៅកាសៈទេសៈនោះ វៀតមិញតែងតែចូលមកចាប់ចងខ្មែរបំរើបារាំងជារៀងរាល់យប់ ។ លោកថាច់-ទីហុងភ្ញាក់ដោយឮសូរសម្លេងស្រែករបស់ម្តាយ ក៏រត់សំដៅមកកន្លែងកើតហេតុមួយរំពេច ។ មកដល់ភ្លាម គាត់ក៏រួមវាក់ជាមួយឃាតករម្នាក់ដែលជាស្រីយួន ! ស្រីយួនដ៏សាហាវនេះក៏ចាក់គាត់ត្រូវធ្លុះបាតដៃពីម្ខាងទៅម្ខាង គឺគ្មាននរណាក្រៅពីកូនស្រីរបស់ប្រធានវៀតមិញ ទីវ-កឹង ហើយដែលជាថៃដន្យត្រូវជាប្រពន្ធចុងរបស់លោកថាច់-ទីហុងនោះទេ ! ។

ក្រោយមកទៀតគាត់ដឹងថា ស្រីយួននេះត្រូវបន្តបេសកកម្មជំនួសលោកសង្ឃក្លែងក្លាយពីមុន ។

ក្រោយឃើញព្រឹត្តិការណ៍មិនស្រួល ទោះបីជាជីដូននិងឱពុកមាឃាត់ឃាំងយ៉ាងណាក៏ដោយ នាងទៀងសំរេចចិត្តត្រូវចាកចេញពីផ្ទះឱពុកមាជាដាច់ខាត ។ ដើរបណ្តើរយំបណ្តើរ នាងទៀងចេញពីផ្ទះទៅជួបលោកប៉ាន់-ឡូវ រ៉ាយរ៉ាប់ពីការព្យាបាទដែលកើតឡើងផ្ទួនគ្នានេះ ។ កំពុងតែនិយាយស្រាប់តែឃើញលោកថាច់-ទីហុងដើចូលមកដោយនាំទាំងធំ ប៉ោ-សែត្រ មកជាមួយផង ។ ប្រពន្ធរបស់គាត់ឈ្មោះធំសំ ទាំងពីរនាក់មានអាយុជាង៦០ហើយ ។ គាត់មកធានានាងទៀងទៅផ្តត់ផ្គង់បាយទឹក ឲ្យសំណាក់នៅពេលថ្ងៃ តែពេលយប់គាត់មិនហ៊ានធានាទេ ដោ-

យមកពីផ្ទះរបស់គាត់នៅឆ្ងាយដាច់ស្រយាលពីទីប្រជុំជនពេក ។ ទោះបីខ្លួនគាត់ផ្ទាល់និងប្រពន្ធ តែងតែនាំគ្នាទៅជ្រកកោនពួនដេកនៅក្នុងវត្តពោធិសាលរាជ ជារៀងរាល់យប់ដែរ ។

ក្នុងកាលៈទេសៈនោះ គ្រប់ៗខ្មែរកម្ពុជាក្រោមដែលជាអ្នកបំរើបារាំង តែងតែលាក់ខ្លួនពួនអាត្មានៅពេលយប់ដូចសត្វកណ្តុរ ។ ព្រឹកឡើងទើបក្រោកទៅធ្វើការជាធម្មតា ។ នៅក្រុងត្រាវិញពេលនោះ មានតែនាងទៀងម្នាក់ឯងគត់ដែលជាអ្នករដ្ឋការស្រី ។ តើឲ្យនាងទៅជ្រកនៅឯណាបើនៅក្មេងទើបតែបាន២០ឆ្នាំ ? ។

ពេលលោកទាំងបីនាក់កំពុងដើរផ្លូវទាល់ច្រក សម្លេងហ្វ្រាំងបានលាន់ឮង៉ឺតនៅមុខផ្ទះ ។ យើងសម្លឹងទៅឃើញមនុស្សម្នាក់មាឌមាំសង្ហារ សក់ស្លូត កាត់ឡុងសុង មុខវែង ច្រមុះស្រួច ឫកពារស្មើរស្រីស្មើរប្រុស ស្លៀកពាក់ទាហាន ។ មនុស្សចម្លែកផ្អែកកង់មិនទាន់ស្រួលបួលផងក៏ស្ទុះមកឱបនាងទៀងទឹកភ្នែកហូរសស្រាក់ ព្រមទាំងនិយាយថា ៖ អាទៀងអើយ ! ខ្ញុំមិននឹកស្មានថាឯងបានគេចផុតពីគ្រោះថ្នាក់យ៉ាងនេះ ហើយបានមកជួបខ្ញុំទេ ។ នាងទៀងក៏ឱបមនុស្សនោះវិញព្រមទាំងនិយាយតិចៗឡើងថា ៖ បងបាៗ !...

ពេលនោះលោកទាំងបីនាក់ទៅជាស្រឡាំងកាំង ដោយឃើញកាយវិការដ៏ចម្លែកនៃយុវជន-យុវនារីខ្មែរកម្ពុជាក្រោមក្មេងៗ ដែលលោតឱបគ្នាយ៉ាងនេះ ។ ព្រោះកាលនៅជំនាន់នោះ កូនខ្មែរនៅកម្ពុជាក្រោមទាំងប្រុសទាំងស្រី មានក្រិត្យវិន័យតឹងរឹងណាស់ សូម្បីតែនិយាយគ្នាក្នុងទីស្ងាត់ក៏ត្រូវហាមឃាត់ដែរ ។ លុះឮនាងទៀងហៅថា បងបាៗ ! ដូច្នេះទើបលោកទាំងអស់ស្គាល់ថា មនុស្សដ៏ចម្លែកនេះគឺ ញ៉ាង-ធីបា ។

ញ៉ាង-ធីបា ជាមនុស្សមានភេទស្មើរប្រុសស្មើរស្រី ។ តាំងពីតូចមក ស្លៀកពាក់ជាស្រី ដើរលេងនិងរស់នៅតែជាមួយស្រី ។ នៅឆ្នាំ១៩៤០ នៅពេលដែលនាងទៀងមករៀននៅទីក្រុងត្រាវិញ នាងទៀងនៅផ្ទះជាមួយនឹង ញ៉ាង-ធីបា នៅភូមិម្រាយ ។ ឆ្នាំ១៩៤៦ នាងទៀងត្រូវចេញទៅធ្វើគ្រូបង្រៀននៅប៉ុស្តិ៍ង៉ាបា ទាំងពីរនាក់ក៏ត្រូវបែកគ្នាតាំងពីនោះរហូតមក ទើបតែបានជួបនៅថ្ងៃនេះ ។

នាងទៀងកាន់ដៃញ៉ាង-ធីបាជាប់ សួរបណ្តើរយំបណ្តើរថា ៖

- បងបាឯងធ្វើអ្វីសព្វថ្ងៃនេះ ?

-កាលពី២-៣ថ្ងៃនេះ ខ្ញុំសំរេចចិត្តចូលធ្វើទាហាន, ជាអ្នកបកប្រែភាសានៅប៉ុស្តិ៍ភូមិម្រាយ ខាងជើងផ្ទះធំប៉ោ-សែត្រ ។ ខ្ញុំមានឋានន្តរស័ក្តិជាពលទោ ។ សព្វថ្ងៃនេះខ្ញុំដាក់ឈ្មោះជាប្រុសវិញថាញ៉ា-បា ។

នាងទៀងបានស្តាប់សព្វគ្រប់ ក៏ដកដៃចេញ ឈរសម្លឹងញ៉ាង-បាស្រឡាំងកាំ

ង គាំងមាត់មួយសន្ទុះនឹកក្នុងចិត្តថា ៖ « យី ! អញឆ្កួតហើយតើ ! លោតឱប្រុសកណ្ដាលវាល, ចំពោះមុខឪពុកមានិងចៅហ្វាយនាយ ត្រូវបង់វិន័យស្រីអស់រលីង » ។ នាងនឹកគួរឲ្យខ្មាស់អៀនជាក្រៃលែង នាងក៏លោតទៅឲ្យឱបឪពុកមាយំសស្រាក់ ព្រមទាំងសំពះសុំទោសនូវកាយវិការដែលនាងបានធ្វើខុសនេះ ។ លោកថាច់-ទីហុង ដៃស្ដាំកាន់ដៃនាងទៀង ដៃឆ្វេងកាន់ស្មាញ៉ាង-បាយ៉ាងត្រេកអរ ព្រមទាំងនិយាយថា ៖ ប្រសើរណាស់ ! ប្រសើរណាស់ ! ។ យើងអាចដោះស្រាយបញ្ហាអាទៀងបានមួយរយៈយ៉ាងងាយ ។ រឿងអាទៀងឯងឱបញ៉ាង-បាអម្បាញ់មិញនេះ គ្មានទោសគ្មានបង់ក្រិត្យវិន័យអ្វីទេ ។ ឥឡូវនេះខ្ញុំសំរេចជាបន្ទាន់ គឺពេលព្រលប់មើលមនុស្សមិនស្គាល់ អាទៀងត្រូវតែស្លៀកពាក់ជាទាហានរង់ចាំញ៉ាង-បា ។ ចំណែកឯញ៉ាង-បា ត្រូវតែមកទទួលអាទៀងនាំយកទៅនៅក្នុងប៉ុស្តិ៍ជាមួយផង ។ នៅពេលព្រលឹមឡើង មុនពេលប្រជាជនក្រោក អាទៀងត្រូវតែក្រោកឡើងទៅសំណាក់នៅឯផ្ទះធំប៉ោ-សែត្រវិញ ។ តើយោបល់ខ្ញុំនេះ ញ៉ាង-បាឯងយល់យ៉ាងម៉េចដែរ ? ។

– ខ្ញុំស្ម័គ្រចិត្តជួយឧបត្ថម្ភអាទៀងគ្រប់ៗមធ្យោបាយ ដែលខ្ញុំអាចធ្វើទៅកើត ។

ចំណែកឯលោកប៉ាន់-ឡូវ ក៏ផានារ៉ាប់រងចាត់តែងតាំងនាងទៀងជាគ្រូបង្រៀនឡើងវិញ ។

ក្នុងខែឧសភា១៩៤៥ អ្នកគ្រូទៀងបង្រៀនកូនសិស្សខ្មែរអំពីមុខវិជ្ជាខ្មែរ-បារាំងនៅសាលាបឋមសិក្សា ដែលតាំងនៅទីក្រុងត្រាវិញ ។ ចំណែកឯវៀតមិញវិញ វាក្ដៅក្រហាយណាស់ដោយមិនគួរភ្លាត់ស្នៀតឲ្យមនុស្សដែលវាទុកចិត្ត ហើយដែលដឹងវិធានការណ៍សម្ងាត់របស់វាអស់ទៅហើយនោះ គេចចេញពីខ្សែរយៈរបស់វាយ៉ាងនេះទេ ។ ដូច្នេះវាគិតថា ត្រូវតែតាមសម្លាប់នាងទៀងលុះត្រាតែបាន ដើម្បីទុកជាគំរូ ។

ថ្ងៃមួយ លោកថាច់-ទីហុងទទួលសំបុត្រពីរច្បាប់របស់តាគីម-វណ្ណៈពីព្រះហស្ដព្រះសង្ឃមួយអង្គព្រះនាម ឡាំ-រឿង ។

សំបុត្រទី១, សំរាប់លោកថាច់-ទីហុង ដែលបញ្ជាក់ប្រាប់ពីអស័យដ្ឋានរបស់គូដណ្ដឹងនាងទៀង, លោកកៀង-ឥន្ទ្រ ។ មិនបង្អង់យូរគាត់ក៏វាយទូរលេខមួយច្បាប់ភ្លាម ។ តែ៤ថ្ងៃក្រោយមក ក្រសួងសន្តិសុខនៅព្រៃនគរបានវាយទូរលេខតបមកវិញថា លោកកៀង-ឥន្ទ្របានផ្លាស់ទៅធ្វើការនៅក្រសួងសន្តិសុខនៅកម្ពុជាកណ្ដាល ខេត្តបាត់ដំបងបាត់ទៅហើយ...។

សំបុត្រទី២, សំរាប់នាងទៀង ។ សំបុត្របានរៀបរាប់ពីការតាមឆាឆៅរបស់វៀតមិញ ។ តាំងពីនាងទៀងគេចចេញមក តាគីម-វណ្ណៈមិនសូវបានធ្វើការងារអ្វី

ទេ ព្រោះវៀតមិញតែងតែហៅគាត់ឲ្យមកមើលការកាប់សម្លាប់របស់ពួកវា ទៅលើប្រជាពលរដ្ឋខ្មែរស្លូតត្រង់ដែលវាចោទថាជាមនុស្សក្បត់ ។ ជារៀងរាល់ពេលសម្លាប់ វៀតកុងតែងតែនិយាយថា បើម៉ែ-អុំលែលកទៅយកអាទៀងវិលចូលដែនដីរំដោះវិញក្នុងពេលឆាប់ៗនេះ វានឹងលើកលែងទោសឲ្យរួចខ្លួន តែបើមិនដូច្នោះទេ នៅពេលណាដែលក្រសួងមានសមត្ថកិច្ចទៅតាមចាប់បាន បក្សត្រូវតែសម្លាប់ចែកគ្នាមើលនិងទុកជាគំរូ ។ល។ ដោយសារតែការសម្លាប់មនុស្សដើម្បីបន្លាចជាផ្ទួនៗយ៉ាងនេះ យាយតាភ័យតក់ស្លុតជាក្រៃលែង ។ គាត់ផ្តាំកូនគាត់ថា ដាច់ខាតត្រូវតែរត់គៀសខ្លួនទៅកម្ពុជាកណ្តាលជាដាច់ខាត ព្រោះវៀតមិញមិនបញ្ឈប់ការព្យាបាទរបស់វាទេ ។ល។

នាងទៀងក៏ផ្ញើសំបុត្រមួយទៀតទៅគូដណ្តឹង តាមអស័យដ្ឋានថ្មី រៀបរាប់ពីទុក្ខវេទនានិងការភិតភ័យអស់រយៈពេល១៩ខែមកហើយ ។

នៅថ្ងៃទី១៧-៧-៩៤ ជាថ្ងៃបញ្ចប់ការសិក្សារបស់កូនសិស្ស ។ នៅសាលារៀនគេប្រារព្ធធ្វើពិធីចែករង្វាន់ដល់អ្នករៀនពូកែ ។ អ្នកគ្រូទៀងចូលផ្ទះនៅម៉ោង១រសៀលយឺតជាងធម្មតា ។ ទៅដល់ផ្ទះ នាងភ្ញាក់ព្រើតភ័យរន្ធត់ដូចឃើញខ្មោចលងព្រោះឃើញមនុស្សចម្លែកម្នាក់អង្គុយក្នុងបន្ទប់ទទួលភ្ញៀវ ។ បុរសនោះមាឌធំមាំខ្ពស់ដូចតាហ្សង់ មុខមូល ពុកមាត់និងពុកចង្កាស្រមូម, សម្បុរខ្មៅឃ្លើច ស្លៀកពាក់ទាហាន ។ បុរសចម្លែកញញឹមឃើញតែធ្មេញសស្គុះ តែនាងទៀងដើរហួសចូលទៅក្នុងបន្ទប់បាត់ដោយនឹកគិតថា ៖ យី ! បើអញមានប្តីរបៀបនេះ ស្លាប់ទៅវិញប្រសើរជាង ! ។

លុះផ្លាស់សំលៀកបំពាក់រួចហើយ នាងក៏ដើរទៅបន្ទប់ចង្ក្រានបាយបំរុងញាំបាយ ។ ស្រាប់តែធំសំដើរមកកាន់ស្មានាងទៀងព្រមទាំងនិយាយថា ៖ អាទៀងអ៊ាំថ្ងៃនេះអុំធ្វើបាយទទួលភ្ញៀវពិសេសម្នាក់ និងមិត្តភ័ក្ត្ររបស់តាពីរបីនាក់ទៀត មានញ៉ាង-ធីបាមករួមជាមួយផង ។

នាងទៀងសម្លឹងមុខធំសំ ហើយសួរថា ៖

- តើនរណាជាភ្ញៀវពិសេសនោះ ?

ធំសំសម្លឹងមុខនាងទៀងយ៉ាងយូរ ទើបឆ្លើយថា ៖

- គឺលោកកៀង-ឥន្ទ្រនោះណា៎ !

- ម្នាក់ខ្មៅគឃ្លើចនោះឬ ?

- ហ្នឹងហើយ !

នាងទៀងដើរទៅកៀនជញ្ជាំង អង្គុយយំបង្ហូរទឹកភ្នែកដូចទឹកនឹកអាណិតខ្លួន។ តែនៅក្នុងបន្ទប់ទទួលភ្ញៀវឯណោះវិញ គេឮសូរតែសំណើចលោកមាថាច់-ទីហ៊ុង

ក្អាកក្អាយជាងគេឯង ។ គាត់សប្បាយដោយឃើញក្មួយគាត់មានវាសនាល្អ សង្ឃឹមថានឹងបានគេចរួចពីគ្រោះថ្នាក់ឡើយ ។ ចំណែកធំប៉ោ-សែត្រក៏ត្រេកអរណាស់ដែរ ។ គាត់ដើរសំដៅមក លើកដៃអង្អែលក្បាលក្មួយស្រីជាទីស្រឡាញ់ ព្រមទាំងនិយាយថា ៖

- ក្មួយសម្លាញ់ ! ស្អែកនេះក្មួយចាកផុតពីទុក្ខភ័យ លែងដើរជ្រកដេកដូចសត្វកណ្ដុរតទៅទៀតហើយ ។ ធំត្រេកអរណាស់ដោយបានឃើញក្មួយរួចពីភ័យ តែធំក៏ស្ដាយណាស់ដែរដោយឃើញក្មួយត្រូវឃ្លាតទៅឆ្ងាយសែនឆ្ងាយយ៉ាងនេះ ។

នាងទៀងឱបធំសែត្រហើយទ្រហោរយំឡើងថា ៖

- ធំអើយ ! វាសនាខ្ញុំអីក៏អភ័ព្វម្ល៉េះ ? ទៅមុខមិនរួច ថយក្រោយក៏មិនកើត ។

រួចហើយក៏យំតទៅទៀត... ធំសែត្រស្រឡាំងកាំងស្មានថាក្មួយច្បាស់ជាបានសប្បាយ ដោយមានគូដណ្ដឹងមកនាំទៅរកសន្តិសុខ ។ ពេលនោះប្រពន្ធគាត់ចាប់ដៃទៅពន្យល់ថា អាទៀងមិនដែលឃើញមុខគូដណ្ដឹងវាទេ ថ្ងៃនេះវាទើបតែឃើញជាលើកទី១ វាគ្មានចិត្តប្រតិព័ទ្ធទេ ។

ធំសែត្រយកដៃទះថ្ងាសហើយនិយាយឡើងតិចៗថា ៖

- វីវរហើយៗ ! ធ្វើម៉េចទៅ ឃើតពេលទៅហើយ !...

ម៉ោង៤រសៀល ភ្ញៀវទាំងអស់ត្រឡប់ទៅវិញ ។ លោកកៀង-ឥន្ទ្រថ្លែងអំណរគុណម្ចាស់ផ្ទះ ជាពិសេសញ៉ាង-ធីបា ។ គាត់និយាយទៅធំសែត្រថា ៖ ស្អែកនេះគាត់នឹងមកនាំអាទៀងចេញដំណើរទៅហើយ ។ កប៉ាល់កុងវ័រចេញទៅនៅវេលាម៉ោង៣រសៀល បើខកខានត្រូវតែចាំមួយអាទិត្យទៀតទើបបាន ។

ស្អែកឡើង អស់លោកៗដដែលមកដល់ផ្ទះធំប៉ោ-សែត្រ ដើម្បីជូនដំណើរអ្នកទាំងពីរ ។ ស្រាប់តែបាត់នាងទៀង... ទាំងអស់គ្នាច្រួលច្របល់ដើររក ។ លោកថាច់-ទីហុងខំដើររកក្មួយ ។ ធំសែត្រខ្សិបប្រាប់គាត់ថា អាទៀងមិនស្រឡាញ់លោកកៀង-ឥន្ទ្រទេ ។

- វីវរហើយ ! ធ្វើម៉េចទៅ ? លោកថាច់-ទីហុងនិយាយឡើង, ចុះបើលោកកៀង-ឥន្ទ្រជាគូដណ្ដឹងតាមប្រពៃណី ខំកាត់ទឹកដីព្រៃទន្លេ កាត់គ្រាប់រំសេវ មកតាមរក ហើយឥឡូវបែរជាដូច្នេះទៅវិញ ? ។

អស់មួយសន្ទុះធំ លោកក៏រកឃើញនាងទៀងនៅក្នុងបន្ទប់ទឹក ។ គាត់ចូលទៅដល់ ចាប់ដៃក្មួយមកដាក់លើទ្រូង រួចនិយាយពន្យល់យ៉ាងច្រើន ទីបំផុតគាត់ប្រាប់នាងទៀងថា បើសិនជាវៀតមិញចាប់នាងបាន ជីវិតរបស់នាងនឹងត្រូវផុតរលត់ហើយ ដូច្នេះនាងត្រូវតែចាកចេញពីទីនេះជាដាច់ខាតកុំបង្អង់ ។

ទីបំផុតនាងទៀងត្រូវតែធ្វើតាមបញ្ជារបស់បងប្អូនចាស់ទុំទាំងទើសទាល់...

កប៉ាល់បន្លឺសម្លេងកញ្ជែមួយយ៉ាងវែង ទូត !.... នៅលើកទី១ ។ លោកថាច់-តីហុងដឹកដៃនាងទៀងចេញពីទីពួន ដើម្បីមកជួបថៅហ្វាយ គឺលោកប៉ាន់-ឡូវ ។ លោកអង្អែលក្បាលនាងទៀងដោយក្ដីអាសូរ ព្រមទាំងប្រគល់លិខិតផ្សេងៗមកនាង ដូចជាសំបុត្រអនុញ្ញាតច្បាប់ជាដើម ។ លោកពន្យល់ថា ៖ ពេលណានាងទៀងទៅដល់បាត់ដំបង នាងត្រូវតែផ្ញើសំបុត្រមួយច្បាប់មកទីស្ដីការរដ្ឋមន្ត្រីក្រសួងសិក្សាធិការជាតិនៅព្រៃនគរជាចាំបាច់ ដើម្បីសុំលាពីមុខតំណែងគ្រូបង្រៀន ។ លោកកៀង-ឥន្ទ្រតឿននាងទៀងឲ្យប្រញាប់គោរពលាបងប្អូនញាតិសន្ដានព្រោះពេលវេលាមកដល់ហើយ ។ នាងទៀងក៏លើកដៃសំពះលាអស់លោកទាំងអស់ ។ នាងឱបញ៉ាង-ធីបាដែលជាមិត្តភក្ដិដ៏កំសត់កំរនឹងគ្នាតាំងពីតូចៗ ហើយថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដែលបានជួយជ្រោមជ្រែងដោយអស់ពីចិត្តថ្លើម ។ នាងគោរពឱបលាធំសៃត្រនិងធំសំ អរគុណលោកមានគុណទាំងពីរយ៉ាងខ្លាំង ។ នាងសំពះលាលោកមាថាច់-ទីហុង និងលោកប៉ាន់-ឡូវដោយគោរព ។

ទូត !... កប៉ាល់បន្លឺសញ្ញាម្ដងទៀតជាលើកទី២ ។ លោកថាច់-ទីហុងក៏អញ្ជើញអ្នកទាំងអស់គ្នាដើរសំដៅទៅកំពង់ផែ ។ ដៃម្ខាង លោកមាហុងកាន់កាបូបខោអាវ ដៃម្ខាងទៀតដឹកដៃក្មួយស្រីឡើងកប៉ាល់ ។ ដល់ហើយលោកក៏ឱបលាក្មួយទាំងពីរដោយអាឡោះអាល័យ រួចលោកក៏ចុះពីកប៉ាល់ទៅជួបអ្នកនៅលើផែវិញ ។

ទូត !... កប៉ាល់បន្លឺសញ្ញាម្ដងទៀតជាលើកទី៣ រួចក៏ធ្វើដំណើរចាកចេញពីកំពង់ផែសន្សឹមៗ ដោយទុកអ្នកជូនដំណើរឲ្យលើកដៃបក់វិចៗមកអ្នកទាំងពីរទាំងអាឡោះអាល័យ ។ នាងទៀងឃើញលោកមាហុងយកដៃឱបក្បាលយំដូចកូនក្មេងលែងខ្មាស់អៀនអ្នកជិតខាង ។ លោកយំព្រោះតូចចិត្តនឹងខ្លួនឯងដែលគ្មានសមត្ថភាពការពារក្មួយស្រី បែរជាបណ្ដោយឲ្យនាងបែកចេញពីខ្លួនទៅតាមប្រុសម្នាក់ដែលនាងមិនដែលស្គាល់និងគ្មានចិត្តស្រឡាញ់បន្តិចសោះ ។

ក្រឡេកមើលមកខាងក្នុងកប៉ាល់ មានសុទ្ធតែទាហានជាតិបារាំង-ខ្មែរតែពីរនាក់ម៉ង់ៗ... ឃើញដូច្នេះ, អ្នកទាំងអស់គ្នាគ្មានអ្វីនិយាយទៀតក្រៅពីសម្រក់ទឹកភ្នែកតែប៉ុណ្ណោះ...

កប៉ាល់បរមកដល់មាត់ពាម កូឡៅកូចៀង រួចហើយ ត្រូវបត់ខាងឆ្វេងដើម្បីសំដៅទៅខេត្តព្រៃកប្បស្សី ។ ស្រាប់តែជួបពួកវៀតមិញដាក់អន្ទាក់រង់ចាំបាញ់ដូចលាជផ្ទុះ ។ ទាហានបារាំងក្រាបស្ងាបគ្រប់ៗគ្នា តែនាងទៀងមិនក្រាបទេ ព្រោះនឹកក្នុងចិត្តថា បើស្លាប់ពេលនេះទៅ វាប្រសើរជាងរស់នៅ ហើយប្រហែលជាបានសុខសាន្តទៀតផង ។ តែនៅខាងមុខកប៉ាល់ធំ មានកប៉ាល់តូចបើកពីមុខផ្ទុកអង្ករពេញ ។ នៅសងខាង មានទូកប៉ុកចាយធំៗផ្ទុកអង្ករពេញដែរ ។ អង្ករនេះជាស្បៀង

ផង តែក៏ជាគ្រឿងសំរាប់ការពារខ្លួននឹងគ្រាប់រំសេវផងដែរ ។ កាំភ្លើងវៀតមិញមិនអាចធ្វើអ្វីពួកយើងកើតទេ ថ្វីត្បិតតែកប៉ាល់បើកមិនលឿនដោយសណ្តោងទូកនិងអង្ករយ៉ាងធ្ងន់ ។ នៅតាមផ្លូវយើងជួបប្រទះការបាញ់រំខានរបស់ពួកវៀតមិញជាញឹកញាប់ តែគ្មានគ្រោះថ្នាក់អ្វីទេ ព្រោះកាំភ្លើងវាជាកាំភ្លើងធុនមូស្កឹតុង ដែលបាញ់មិនអាចធ្លាយរហូតដល់កប៉ាល់យើងបានឡើយ ។ មានពេលខ្លះទាហានបារាំងធុញទ្រាន់ក៏បាញ់តទល់វិញមួយរ៉ាវដោយកាំភ្លើងមីត្រៃយ៉េត បណ្តាលឲ្យប្ញូដូយស្លាប់និងប្រកាច់ស្លាប់បះជើងច្រូង...

ថ្ងៃទី៣, ម៉ោងប្រហែល១១ព្រឹក, ក្បួនកប៉ាលបរមកដល់ខេត្តព្រៃកប្ញស្សី ។ នាយសេហ្វកុងវ័រសំរេចឲ្យអ្នកដំណើរទាំងអស់ចុះពីកប៉ាល់ឡើងរថភ្លើងវិញ ដើម្បីសំរាលកប៉ាល់ដែលត្រូវដឹកអង្ករទៅព្រៃនគរនេះ ។

លោកកៀង-ឥន្ទ្រក៏បណ្តើរនាងទៀងទៅកាន់ស្ថានិយរថភ្លើងព្រៃកប្ញស្សី ។ លុះទាហានបារាំងឡើងលើរថភ្លើងរួចរាល់ហើយ រថភ្លើងកុងវ័រក៏បើកបរចាកចេញពីស្ថានិយភ្លាមសំដៅទៅកាន់រដ្ឋធានីព្រៃនគរ ។

នៅម៉ោង៥រសៀល យើងទាំងពីរនាក់ធ្វើដំណើរមកដល់ព្រៃនគរប្រកបដោយសេចក្តីសុខ ។ លោកកៀង-ឥន្ទ្រយកនាងទៀងទៅផ្ញើនឹងយាយជីនៅវត្តចន្ទ-រង្សីសិន ។ រួចហើយលោកដើរស៊ើបសួររកឡានកុងវ័រដើម្បីធ្វើដំណើរបន្តទៅរាជធានីភ្នំពេញទៀត ។

នៅថ្ងៃទី៣០-៧-៩៥ វេលាម៉ោងប្រហែល១០ព្រឹក លោកកៀង-ឥន្ទ្រមកទទួលនាងទៀងចេញពីវត្ត បណ្តើរទៅកាន់ក្បួនឡានកុងវ័រដែលស្ថិតនៅចម្ងាយប្រ-ហែល៥០០ម៉ែត្រពីវត្ត ។ លោកបង្ហាញនាងទៀងដល់សេហ្វកុងវ័រថា នាងជាប្អូនជីដូនមួយ កំព្រាឪពុកម្តាយ លោកត្រូវនាំនាងទៅបន្តការសិក្សាទៀតនៅភ្នំពេញ ។ លោកសេហ្វកុងវ័រជាតិបារាំងរាវែកបន្តិច តែលោកជាមនុស្សចិត្តធម៌ ក៏យល់ព្រមហើយបង្គាប់ឲ្យនាងទៀងស្លៀកពាក់ជាទាហានដូចគេឯងដែរ ព្រោះឡានកុងវ័រនេះសំរាប់ដឹកតែទាហានទេ ។

នៅពេលដែលទាហានឡើងលើឡានរួចស្រេចបាច់ហើយ ក្បួនឡានក៏ធ្វើដំ-ណើរចេញពីទីនោះ ។

❑ ❑

❑

# មាតុភូមិទី២

បន្ទាប់ពីឆ្លងកាត់ព្រំដែនខ្មែរ-យួនហើយ យើងមកដល់ក្បាលស្ពានព្រះមុនី-វង្ស ។ ឡានកុងវ័រត្រូវឈប់ដើម្បីឲ្យពួកអាវុធហត្ថ ឆែកត្រួតពិនិត្យ ។ គេពិនិត្យគ្រប់ៗឡាន... លុះដល់ឡានមួយគេគេឃើញទាហានស្រីម្នាក់ គេក៏ហៅឲ្យចុះពីឡានយកទៅឃុំទុកដោយគ្មានសួរនាំអ្វីមួយម៉ាត់សោះ ។

ដោយឃើញហេតុមិនស្រួលដូច្នេះ លោកកៀង-ឥន្ទ្រពីងលោកសែហ្វកុងវ័រចេញមុខតវ៉ាសុំធានា ដោយសំអាងថានាងទៀងជាប្រពន្ធរបស់លោក ។

នៅពេលនោះមានការជជែកគ្នាឡើងតឹងសរសៃក តែទីបំផុតគេក៏ដោះលែងនាងទៀងពីទីឃុំឃាំងមកវិញ ។

មានបងប្អូនខ្មែរខ្លះសួរថា ៖ ហេតុម៉េចបងៗខ្មែរថ្លើមខ្មៅម្ល៉េះ ? ។ ចម្លើយ ៖ ព្រោះនាម៉ឺនខ្មែរស៊ីឆ្អាញ់ ដេកលក់ស្រួល ដើរលេងសប្បាយ មិនធ្លាប់ទទួលការជិះជាន់ពីសាសន៍បរទេសណាទេ ។ មេៗនឹកនាំមិនចេះអប់រំកូនចៅ គ្មានដុះមនោសញ្ចេតនាអាណិតឬស្រឡាញ់ជាតិទេ ។ មានមួយភាគតែងតែជិះជាន់គេ ដុះគំនិតតែក្នុងការដណ្តើមអំណាច ចង់ធ្វើធំ ចង់ធ្វើសេដ្ឋីតែប៉ុណ្ណោះ...។ លោកៗមិនអើទទួលដឹងទទួលឮពីទុក្ខវេទនារបស់បងប្អូនខ្មែរកម្ពុជាក្រោម ដែលត្រូវយួនកំពុងតែជិះជាន់ សម្លាប់ និងកំចាយបំផុតពូជនោះឡើយ...។

ក្បួនឡានកុងវ័រមកដល់ខាងលិចវត្តភ្នំ ។ អ្នកទាំងពីរនាក់ចុះពីលើឡាន ហើយក៏ដើរទៅថ្លែងអំណរគុណនិងចំរាបលាលោកសែហ្វកុងវ័រ ដើម្បីទៅរកទីសំណាក់ ។ ម៉ោង៨យប់ យើងបានមកដល់ផ្ទះមួយ ។ លោកកៀង-ឥន្ទ្រគោះទ្វារតុកៗ ទ្វារបើកឡើងលេចយុវជនម្នាក់អាយុ១៧ឆ្នាំ កំពុងតែទទួលទានបាយ គឺយុវជន យឺ-វិញទ្រី ។

អ្នកកម្លោះនេះរសាប់រសល់ឆ្លេឆ្លា រកតែពាក្យសួរសុខទុក្ខមិនឃើញ ព្រោះកាលពីមុនចេញទៅរកនាងទៀង លោកកៀង-ឥន្ទ្របានមកសុំសំណាក់នៅផ្ទះយុវ-ជនទ្រីមួយយប់ ។ ស្អែកឡើង នៅពេលដែលគាត់លាយុវជនទ្រីដើម្បីទៅខេត្តត្រាវិញ គាត់និយាយហាក់ដូចជាលេងក្លាយមែនប្រាប់យុវជនទ្រីថា គាត់នឹងទៅយកនាងទៀងមករៀបការជាមួយ... គេមិននឹកស្មានថាលោកកៀង-ឥន្ទ្រនាំនាងទៀងមកមែនទែនទេ ។

យប់នោះយុវជនវិញទ្រីនិងលោកកៀង-ឥន្ទ្រទទួលទានដំណោកលើកទ្បេល

កាលផ្ទាល់ក្តារក្នុងបន្ទប់ទទួលភ្ញៀវ ។ នាងទៀងគេងក្នុងបន្ទប់លើគ្រែសំពត់មួយតូច ។ ថ្ងៃបន្ទាប់មក លោកកៀង-ឥន្ទ្រចេញទៅបាត់ ។ រីឯយុវជនទ្រីវិញ ក៏ទៅរៀននៅសាលាតិលានុប្បដ្ឋាកជារាល់ថ្ងៃ ។ ថ្ងៃខ្លះមិនបានចូលផ្ទះទេ ព្រោះត្រូវនៅយាមពេទ្យសំរាប់វេនខ្លួនឯងផង ជួនកាលដើម្បីឲ្យបានលុយកាក់ខ្លះផ្សំផង ក៏សុខចិត្តយាមជំនួសគេផ្ទួរនឹងប្រាក់ឈ្នួល ។ នាងទៀងសំរាកនៅផ្ទះយ៉ាងស្ងប់ស្ងាត់ដូច្នេះបានប្រហែលមួយអាទិត្យ ។ ល្ងាចមួយយុវជនទ្រីបណ្តើរលោកកៀង-ឥន្ទ្រមកផ្ទះយួរទាំងកញ្ចប់បីបួនមកជាមួយផង ។ មកដល់បន្ទប់ទទួលភ្ញៀវ ទាំងពីរនាក់ទម្លាក់គញ្ចប់ចុះលើក្តារ ។ យុវជនទ្រីចូលទៅក្នុងផ្លាស់សំលៀកបំពាក់ងូតទឹក ។ លោកកៀង-ឥន្ទ្រស្រែកហៅ ៖

- អាទៀងអា៎ ! ចេញមករៀបបាយញ៉ាំ ។

នាងទៀងលាកញ្ចប់ម្ហូបព្រមទាំងដួសបាយដាក់ចាន ។ អ្នកទាំងបីនាក់ទទួលទានបាយជុំគ្នាជាលើកទីមួយ ។ លោកកៀង-ឥន្ទ្រចាក់ស្រាបៀរបង្ខំឲ្យយុវជនទ្រីផឹក ។ មួយកែវហើយមួយកែវទៀត ! ទ្រាំឯណាមិនស្រវឹង ! ស្រាប់តែយុវជនទ្រីចេះព្រោកប្រាជ្ញ មិនដឹងជាចេញសំដីបែកជាអូរហូរជាស្ទឹងពីណាពីណឹមកទេ !...

អំណាចស្រាបៀរធ្វើឲ្យយុវជនទ្រីហ៊ានទះស្មារៀមច្បង ព្រមទាំងនិយាយថា ៖

- យី ! បងឯងខិលណាស់ ! ទើបរៀបការប្រពន្ធរួចថ្មីៗ ស្រាប់តែទៅនាំបងទៀងយកមកទៀត ។

លោកកៀង-ឥន្ទ្រភ្ញាក់ព្រើត ទម្លាក់ទឹកមុខ ស្ងួតបបូរមាត់រកនិយាយអ្វីមិនរួច ។ ឃើញស្ថានការណ៍បែបនេះ អ្នកទាំងអស់នៅស្ងៀមលែងនិយាយរៀងៗខ្លួន ។ នាងទៀងចាប់អារម្មណ៍នឹងពាក្យយុវជនទ្រីណាស់ ក៏ចាប់ផ្តើមសួរឡើងថា ៖

- នែ ! ប្អូនទ្រី រឿងនេះពិតមែនឬ ? ។

ទ្រីបែរមុខទៅរកលោកកៀង-ឥន្ទ្រជំនួសចម្លើយ ។ លោកឥន្ទ្រសម្លឹងមុខនាងទៀង មានអារម្មណ៍ភ្ញាក់ផ្អើលដោយឃើញនាងទៀងបែរជាញញឹមញញែមទៅវិញ ។ គាត់ឃើញនាងទៀងញញឹមជាលើកទីមួយតាំងពីបានជួបគ្នាមក ។ គាត់ក៏ឆ្លើយឡើងថា ៖

- ពិតមែនហើយអាទៀង, បងរៀបការប្រពន្ធរួចហើយមែន ។ រួចហើយគាត់ក៏បើកកាបូបយករូបថតមួយសន្លឹកហុចមកឲ្យនាងទៀង ។ នាងមើលរូបថតយ៉ាងយកចិត្តទុកដាក់ ។ គឺរូបលោកអង្គុយផ្ទឹមគ្នាក្នុងសំលៀកបំពាក់ប្រពៃណីអាពាហ៍ពិ-ពាហ៍ជាមួយស្រីឃួន ហូ-គីមយ៉ុង ។ នៅក្បែរកូនកម្លោះក្រមុំឃើញរូបអ្នកចែកសំបុត្រប្រៃសណីយហុចទូរលេខមួយច្បាប់មកឲ្យគាត់...។

នាងទៀងហុចរូបថតទៅលោកកៀង-ឥន្ទ្រវិញ បន្ទាប់ពីបានពិនិត្យម្តងទៀត ។

នាងចម្លែកក្នុងចិត្ត ហើយក៏ដណ្ដឹងសួរខ្លួនឯងថា ហេតុម្ដេចក៏នាងស្រីឃ្មួនដ៏ល្អប្រិមប្រិយនេះសុខចិត្តរៀបការជាមួយលោកឥន្ទ្រ ដែលមានរូបរាងខ្មៅឃ្លឹកដូចជ័រមាក់ឃ្លឿទៅវិញ ? នាងមិនមែនខឹងទេ តែនាងមានចម្ងល់ក្រែងលោនេះជាអាថ៌កំបាំងអ្វីមួយក៏មិនដឹង ? ។

នៅពេលនោះលោកកៀង-ឥន្ទ្រនិយាយឡើងថា ៖

- នៅពេលដែលវៀតមិញចាប់ប្អូនឯងទៅបាត់ បងធ្វើការនៅក្រសួងសន្តិសុខនៅព្រៃនគរ ។ បងសុំច្បាប់ទៅរកប្អូនឯងគ្រប់ទីកន្លែងនៅត្រាវិញ គ្មានលេចឮដំណឹងអ្វីទាំងអស់ ។ ទីបំផុតបងបានជួបលោក គីម-ដាក់ (ត្រូវជាប្អូនបង្កើតរបស់លោកគីម-ង្ហួនត្រាច) ដែលរត់រួចមកដល់ត្រាវិញវិញ ។ គាត់ប្រាប់បងថា គាត់គ្មានសង្ឃឹមថាប្អូនឯងនៅរស់ទេ ។ ព្រោះពួកទាហានជំនួយទាំង២០នាក់ ដែលរត់រួចនៅលើកទី១ជាមួយគាត់នោះ បានបាត់បង់ជីវិតដោយសារវៀតមិញអស់ទៅហើយ ។ អ្នកដែលមកដល់ត្រាវិញនេះ មានតែគាត់និងលោកសៃហ្វប៉ុស្ដិ៍ប៉ុណ្ណោះ ។ គាត់និយាយថា គាត់បានឃើញប្អូនឯងជាប់កុន តាំងពីនៅត្រង់ម្ដុំក្បាលស្ពានដែកទី១មកម៉្លេះ ។ បងអស់សង្ឃឹមនឹងរកប្អូនឯងហើយ ។ គាប់ជួនពេលនោះរដ្ឋការបារាំងត្រូវការមនុស្សម្នាក់ដែលចេះភាសាបី ដើម្បីមកធ្វើការនៅខេត្តបាត់ដំបងនេះ បងក៏ស្ម័គ្រចិត្តផ្លាស់មកធ្វើការនៅទីនេះទៅ ។ នៅថ្ងៃដែលបងរៀបការ បងបានទទួលទូរលេខមួយច្បាប់ថា ប្អូនឯងបានរត់គេចរួចពីកណ្ដាប់ដៃវៀតមិញហើយ ។ ៣ខែក្រោយមក បងក៏បានទទួលសំបុត្រប្អូន ដែលថ្លែងថាមានទុក្ខព្រួយជាខ្លាំងដោយខ្លាចវាតាមព្យាបាទ ។ បងក៏ប្រញិបប្រញាប់ទៅយកប្អូនឯងនេះមក ។

- ខ្ញុំសូមអរគុណចំពោះការយកចិត្តទុកដាក់របស់បងមកលើខ្ញុំ, នាងទៀងឆ្លើយដោយមានអារម្មណ៍ធូរស្រាល ។ រឿងខ្ញុំនិងខ្ញុំអាចដោះស្រាយបានហើយ ។

លោកឥន្ទ្រញញឹមដោយដឹងថា នាងមិនស្រឡាញ់លោកទេ ។ រីឯយុវជនទ្រីវិញធ្វើភ្នែកឡឹកឡក់ ឆ្ងល់ថាហេតុអ្វីក៏អ្នកទាំងពីរបែរជាសើចសប្បាយទៅវិញ បើកាលពីមុននេះបន្តិច ម្នាក់ៗមុខស្ងួតមើលតែត្រីយាវហ៊ីក្រៀម ?

កំពុងតែឆ្ងល់ ស្រាប់តែលោកឥន្ទ្រនិយាយឡើងថា ៖

- បងសូមអរគុណប្អូនទ្រីហើយ ថ្ងៃស្អែកនេះម៉ោងប្រាំព្រឹក បងត្រូវឡើងរទេះភ្លើងទៅខេត្តបាត់ដំបងវិញ ។ បងសូមផ្ញើអាទៀងជាមួយប្អូនឯងសិន ។ ថ្ងៃណាមួយបងនឹងវិលមករៀបចំផ្សំផ្គុំអ្នកទាំងពីរ ។

ទ្រីគ្រវីក្បាលញ៉ែរតគាត់ ហើយឆ្លើយឡើងថា ៖

- ទេ ! ទេ ! មិនកើតទេ ! ខ្ញុំមានអាយុតិចជាងបងទៀងដល់ទៅ៣ឆ្នាំ ។ ខ្ញុំហៅគាត់ថាបងៗពេញមាត់តាំងពីតូចមក ។ ធ្វើដូច្នេះម្ដេចកើត ? ។

នាងទៀងឃើញទ្រីភ័យជ្រួលច្របល់យ៉ាងនេះ ក៏ចាប់ដៃយុវជនកាន់ហើយនិយាយឡើងថា ៖

- ចូរប្អូនកុំបារម្ភ ! បងក៏ប្រកែកដូចប្អូនអញ្ចឹងដែរ ។ បងសូមទុកអូនជាប្អូនបង្កើតរបស់បង ។ យើងទាំងពីរនាក់ត្រូវតែគោរពបងឥន្ទ្រ ហើយទុកគាត់ជាបងបង្កើតរបស់យើង ។ នៅពេលនេះ បងត្រូវតែទៅតាមបងឥន្ទ្រ ដើម្បីទៅសួរសុខទុក្ខឪពុកធំបង្កើតរបស់បងនៅឃុំវាំងកេសីសិន ។ បងនឹងសំណាក់នៅទីនោះមួយរយៈ ហើយដើម្បីបង្ហាញសេចក្តីស្មោះត្រង់ចំពោះបងឥន្ទ្រ បងសំរេចថា មិនទាន់យកប្តីទេ ។

ស្អែកឡើង ម៉ោងបួនកន្លះព្រឹក យុវជនទ្រីជូនដំណើរលោកឥន្ទ្រនិងនាងទៀងឡើងរថភ្លើងកុងវ័រ ។ មុនបែកគ្នា លោកឥន្ទ្រអង្អែលក្បាលយុវជនទ្រី ព្រមទាំងនិយាយបញ្ជាក់ថា ខ្ញុំស្រឡាញ់ទ្រីឯងនិងអាទៀងដូចប្អូនបង្កើត ។ ខ្ញុំត្រូវតែផ្សំផ្គុំប្អូនៗទាំងពីរឲ្យបានគ្នាជាប្តីប្រពន្ធជាដាច់ខាត...

ម៉ោង៥គត់ រថភ្លើងបន្លឺសញ្ញាវិុតៗ រួចបើកបរចេញពីស្ថានិយភ្នំពេញ ។ រថភ្លើងរត់លឿនទៅមុខ នាងមានចិត្តរីករាយបន្តិចដោយបានមកអង្គុយក្នុងរថភ្លើងមើលទេសភាពតាមសងខាងផ្លូវ ។ នាងមានអារម្មណ៍រីករាយដោយយល់ថាថ្ងៃនេះនាងមានវាសនាល្អបានគេចចេញរួចពីកណ្តាប់ដៃវៀតមិញ បើពុំដូច្នោះទេ បើកាលណាវៀតមិញចាប់បាន នាងច្បាស់ជាត្រូវស្លាប់យ៉ាងវេទនា ។ នាងសប្បាយម៉្យាងទៀតដោយបានមកឃើញមាតុភូមិទី២ ដែលនាងប្រាថ្នាមកទស្សនាជាយូរហើយ ។ នៅតាមដងផ្លូវរថភ្លើង នាងឃើញចំការផ្លែឈើគ្រប់ជំពូក មានតាំងពីស្វាយ, ដូង, ល្មុត, មៀន, ខ្នុរ, ផ្លែទឹកដោះគោ, ត្របែក, ក្រូចពោធិសាត់, ក្រូចថ្លុង, ក្រូចឆ្មា និងផ្លែឈើផ្សេងៗទៀតយ៉ាងច្រើនឥតគណនា ។ រថភ្លើងបរមកដល់ចំការត្នោតដែលដុះជាច្រើនពាន់ដើម ហើយដែលជាលើកទីមួយដែលនាងទៀងបានឃើញផ្ទាល់ភ្នែក ។ បន្ទាប់មកទៀតនាងឃើញដើមឈើធំៗស្រោងស្រាងខ្ពស់សន្លឹមស្ទើរកប់ពពក ។ មិនខ្វះឈើធ្វើផ្ទះ មិនខ្វះអុសដុតឡើយ ។ បន្ទាប់មកទៀតនាងឃើញវាលស្រែដ៏ធំល្វឹងល្វើយឆ្ងាយដាច់កន្ទុយភ្នែក មានស្រូវដុះពណ៌បៃតងខ្ចី ។ មកដល់ស្ពានស្វាយដូនកែវ នាងទៀងមើលទៅក្នុងស្ទឹង ឃើញអ្នកនេសាទត្រីផ្ទុកត្រីពេញៗទូក ។ មកដល់ភ្នំធិបតី នៅស្របបណ្តោយតាមជើងភ្នំ មានដុំថ្មតូចៗគរជាគំនរដ៏ធំស្កឹមស្កៃ សំរាប់យកទៅក្រាលថ្នល់...

ឱ ! ប្រទេសខ្មែរសំបូរដោយធនធានធម្មជាតិសឹងគ្មានអ្វីខ្វះ ។ ផ្ទុយទៅវិញនៅនគរយួន មានភាពខ្វះមុខខ្វះក្រោយ ។ អ្នកស្រែចំការសឹងតែយកដើមឫស្សីឬដើមអង្ការដីមកធ្វើជាសសរផ្ទះ ។ ដើម្បីដណ្តាំស្ល អ្នកស្រុកសឹងតែយកចំបើងមកដុត

ដោយខ្វះអុស ។ ឱ ! ព្រោះតែហេតុនេះហើយបានជាតាទិញនិយាយប្រាប់ពីគោលបំណងវាតទឹកដីរបស់យួនហាណូយ ថាត្រូវតែយកឲ្យទាល់តែបាន ទោះយូក្តីឆាប់ក្តី ។

កំពុងតែស្រមៃសព្វគ្រប់ លោកកៀង-ឥន្ទ្រក៏មកអង្គុយក្បែរ ហើយប្រាប់នាងទៀងថា ៖ នៅខាងមុខនេះគឺស្ថានិយរាំងកេសី រួចបន្ទាប់មកគឺទីក្រុងបាត់ដំបងហើយ ។ នាងទៀងត្រេកអរជាក្រៃលែង ក្រោកឈររៀបចំវ៉ាលីស បំរុងសុំលាលោកកៀង-ឥន្ទ្រចុះកាន់ស្ថានិយទៅរកឱពុកធំបង្កើត ។ លោកឥន្ទ្រយល់ដូច្នេះក៏និយាយឡើងថា ៖ នៅទីនេះពួកវៀតមិញធ្វើសកម្មភាពខ្លាំងក្លាណាស់ សឹងរាល់ៗយប់វាចូលមកចាប់កូនក្មេង និងយុវជន ទៅកាន់ទីអាថ៌កំបាំង វាកាប់សម្លាប់អ្នកស្រុកឥតឈប់ឈរ ។ ដូច្នេះអាទៀងឯងកំអាលចុះនៅរាំងកេសីនេះអី ត្រូវទៅឲ្យដល់បាត់ដំបងសិនរួចសឹមគិតតទៅទៀត ។

គ្មានតបតអ្វីមួយម៉ាត់ នាងទៀងទន់ដៃទន់ជើង ស្រាលខ្លួនដូចសំឡី នឹកឃើញឡើងវិញជាថ្មីនូវពាក្យតាទិញដែលថា វៀតមិញបានបញ្ជូនបូដូយនិងចារជនដើម្បីមកធ្វើសកម្មភាពនៅលើទឹកដីខ្មែរ ។ ឱ ! ស្តាយសេចក្តីសប្បាយដែលមានចំនួនកន្លះថ្ងៃមកហើយ ត្រូវរលាយអស់ទៅវិញជាមួយនឹងពាក្យលោកឥន្ទ្រប៉ុន្មានម៉ាត់នេះ ។ ឱ ! ពាក្យតាទិញជាពាក្យពិតទេតើ !...

ម៉ោង២កន្លះរសៀល រថភ្លើងបានមកដល់ស្ថានិយបាត់ដំបង ។ យើងទាំងពីរនាក់ដើរសំដៅទៅរកផ្លូវចេញនៅខាងមុខស្ថានិយ ។ លោកឥន្ទ្របង្ហាញនាងទៀងដល់មិត្តបារាំងរបស់គាត់ម្នាក់ ដែលមានអ្នកបើកបរជូនគាត់មកឈប់ឡានរង់ចាំយើងនៅទីនោះ ។ បារាំងញញឹមទទួលយើងទាំងពីរដោយហុចដៃ Bonjour ផង ។ អ្នកបើកបរនាំយើងឆ្លងស្ពានចាស់ ទៅកាន់ត្រើយស្ទឹងខាងកើត ។ បារាំងបញ្ជាឲ្យអ្នកបើកបរបត់ឡានទៅឆ្វេង រួចក៏ឈប់នៅទីនោះ ខាងជ្រុងវត្តសង្កែរជាប់មាត់ស្ទឹង ។ យើងចុះពីឡានហើយក៏ដើរតាមបារាំងទៅកាន់បន្ទប់មួយ មានទំហំបីម៉ែត្រកន្លះបួនជ្រុង ដែលលោកឥន្ទ្របានផ្តាំឲ្យគាត់ជួលទុកឲ្យនាងទៀង ។

តាំងពីពេលនោះមក លោកកៀង-ឥន្ទ្រតែងតែនាំប្រពន្ធមកសួរសុខទុក្ខនាងទៀងជារៀងរាល់ពេល ព្រមទាំងជួយទំនុកបំរុងលុយកាក់ខ្លះៗទៀតផង ។ នាងទៀងតែងតែជៀសវាងមិនចង់ជួបលោកឥន្ទ្រទេ ដើម្បីកុំឲ្យមានការយល់ច្រឡំពីសំណាក់ភរិយាថ្មោងថ្មីរបស់គាត់ ។

បានកន្លែងសំណាក់ស្រួលបួលហើយ នាងទៀងក៏ធ្វើសំបុត្រសុំលាលែងពីមុខដំណែងគ្រូបង្រៀននៅក្រសួងសិក្សាធិការព្រៃនគរ ព្រមទាំងសុំដកសំណុំលិខិតខ្លះទៀតសំរាប់ប្រើការនៅថ្ងៃក្រោយ ។ នៅខែកញ្ញាឆ្នាំ១៩៤៤ នាងទៀងទទួល

បានសំណុំរឿងទាំងអស់ពីក្រសួងអប់រំជាតិផ្ញើមកពីព្រៃនគរ ។ បានសំណុំលិខិតទាំងអស់នេះហើយ នាងទៀងក៏ចូលទៅបង្ហាញខ្លួននៅអធិការដ្ឋានក្រសួងអប់រំជាតិខេត្តបាត់ដំបង ដើម្បីសុំធ្វើជាគ្រូបង្រៀនឡើងវិញ ។ ថ្ងៃទី១២-៩-៨៤ នាងទៀងត្រូវចូលទៅជួបលោកអធិការបឋមសិក្សាតាមកំណត់ ។ លោកអធិការត្រកូល ង៉ោ អង្គុយចាំនាងទៀងក្នុងការិយាល័យ ។ ពេលចូលទៅដល់ លោកអធិការដោះវ៉ែនតា ចេញក្រឡេកមើលនាងទៀងតាំងពីក្បាលដល់ចុងជើង ហើយនិយាយយ៉ាងគំរោះគំរើយថា ៖

- នាងឯងនិយាយខ្មែរមិនច្បាស់ មានឈ្មោះនិងរូបរាងដូចយួន តែក្រសួងអប់រំជាតិនៅភ្នំពេញបានយល់ព្រមជ្រើសរើសនាងហើយ ។ ខ្ញុំសំរេចចិត្តថានឹងបញ្ជូននាងទៅបង្រៀននៅសាលា « ពាមសីមា » ព្រោះនៅទីនោះមានយួនច្រើន ។ លោកពាក់វ៉ែនតាឡើងវិញ សរសេរលើក្រដាស់មួយមានប្រវែង២-៣បន្ទាត់ជាភាសាបារាំង រួចក៏បោះទៅឲ្យស្មៀនដើម្បីធ្វើសំបុត្រជាផ្លូវការ ។

នេះជាសេចក្តីសំរេចចិត្តរបស់មន្ត្រីខ្មែរម្នាក់ ដែលមិនខ្ចីសួរនាំសាមីខ្លួនសូម្បីមួយម៉ាត់ក៏គ្មានផង ។ សេចក្តីសំរេចចិត្តនេះជាអំណាចផ្តាច់ការមួយក្នុងចំណោមអំណាចផ្តាច់ការផ្សេងៗទៀតជាទូទៅនៅក្នុងស្រុកខ្មែរសម័យសក្តិភូមិ ។ លើសពីនេះទៅទៀត គេសង្កេតឃើញសភាពល្ងង់ខ្លៅឥតចេះពិចារណា ការខ្វះធម៌មេត្តារបស់អ្នកដែលមានមុខងារសំខាន់ៗក្នុងការទទួលខុសត្រូវ និងសំរេចចិត្តពីរឿងអ្វីមួយ ។ បើពុំដូច្នោះទេ កាលណាសាមីខ្លួនមានលទ្ធភាពអាចយកជង្វាយមកថ្វាយបាន នេះជាមធ្យោបាយដ៏សក្តិសិទ្ធិមួយដើម្បីរកថវិកាបន្ថែម ! ។

នាងទៀងសុំលាលោកអធិការចេញមកក្រៅរង់ចាំសំបុត្របញ្ជា ។ ម៉ោងប្រហែល១១ លោកស្មៀនក៏ហៅនាងទៅកាន់ការិយាល័យរបស់លោក ដើម្បីចុះហត្ថលេខាទទួលលិខិត ។ លោកស្មៀនខ្សឹបប្រាប់នាងថា សាលារៀននៅពាមសីមាសង់លើទឹក ។ ដើម្បីធ្វើដំណើរទៅកាន់ទីនោះ គេត្រូវជិះទូកសណ្តោងជាមួយកាណូត ។ នៅទីនោះមានខ្មែរពាក់កណ្តាល យួនពាក់កណ្តាល ។ អ្នកគ្រូត្រូវប្រយ័ត្នខ្លួន ព្រោះមានមូលដ្ឋានវៀតមិញមួយយ៉ាងធំនៅទីនោះ ។ គ្រូបង្រៀននៅពាមសីមាត្រូវតែ « គិតគូរ » ជាមួយចៅហ្វាយ ដើម្បីបានវិលមកកន្លែងស្រួលវិញ ។ល។

នាងទៀងត្រូវវិលត្រឡប់មកទីលំនៅវិញដែលមានចម្ងាយ៣គ.ម.ដោយជើងទទេ ។ នាងមិនហ៊ានជិះរ៉ឺម៉កទេ ព្រោះបញ្ហាថវិកា ។ នៅតាមផ្លូវ នាងដើរបណ្តើរយំបណ្តើរនឹកឃើញអាកប្បកិរិយាលោកអធិការ នឹកឃើញសំដីលោកស្មៀន ដែលបង្ហាញផ្លូវដើម្បីម្តេចឲ្យបានមកកាន់បាត់ដំបងវិញ ។ នឹកឃើញការព្រាត់ប្រាស់រត់ចោលឪពុកម្តាយ ដើម្បីគេចខ្លួនពីវៀតមិញ ហើយឥឡូវត្រូវគេបញ្ជូនខ្លួនឲ្យទៅ

តំបន់វៀតមិញដដែល ។ ឱ ! ខ្ញុំអើយ ជាតិនេះកើតមកជាខ្មែរកម្ពុជាក្រោម អ្វីក៏វេទនាម្ល៉េះ ? ។ នៅកម្ពុជាក្រោម វៀតមិញតាមរកចាប់ដោយចោទថាក្បត់វា ...មកដល់កម្ពុជាកណ្តាល គេថាខ្ញុំជាយួន តើខ្ញុំមានសញ្ជាតិជាអ្វី ? ។

នាងដើរតាមផ្លូវលេខ១ស្របមាត់ស្ទឹងសង្កែរ ។ លុះមកដល់ប៉ុស្តិ៍ នាងក៏ចូលទៅទិញតែមប្រៃមួយសន្លឹក ដើម្បីផ្ញើសំបុត្រទៅលោកមាថាច់-ទីហុង ។ នាងក្រឡេកទៅខាងស្តាំបញ្ជរការិយាល័យប៉ុស្តិ៍ ឃើញមានប្រកាសមួយបិទនៅជញ្ជាំងមានសេចក្តីជាអាទិថា ៖

« សាលាខេត្តបាត់ដំបងត្រូវការជ្រើសរើសស្មៀនប្រចាំថ្ងៃម្នាក់ ( *សូមបញ្ជាក់ថានៅជំនាន់នោះ មុខងារស្មៀនស្រីមិនទាន់មានសិទ្ធិពេញលេញចូលក្នុងក្របខ័ណ្ឌក្នុងរាជរដ្ឋាភិបាលនៅឡើយ* ) ក្នុងចំណោមនារីនៅលីវ ដែលមានអាយុពី២០ទៅ២៥ឆ្នាំ ។ ត្រូវចេះនិយាយនិងសរសេរភាសា ខ្មែរ-យួន-បារាំង ហើយត្រូវមានសញ្ញាបត្រ Certificat d'Etudes Primaires Complémentaires Franco-Indochinois » ។

នៅពេលកំពុងយកចិត្តទុកដាក់មើលក្រដាស់នេះ មនុស្សម្នាក់ដើរមកកេះស្មានាងតិចៗហើយសួរថា ៖

- នាង ! នាងជាខ្មែរកម្ពុជាក្រោមឬ ? ។
- ចាស៎ លោក ។
- នាងចេះភាសាយួនឬទេ ? ។
- ចាស៎ ខ្ញុំចេះលោក ! ។
- តើនាងចេះអក្សរបារាំង-ខ្មែរច្បាស់លាស់ឬទេ ? ។

នាងទៀងក៏បង្ហាញលិខិតបញ្ជា ព្រមទាំងបញ្ជាក់សព្វគ្រប់ពីជីវិតរបស់នាងជំរាបលោកកុងត្រូលរប៉ុស្តិ៍ ដែលកំពុងតែនិយាយជាមួយនាង ។ លោកធ្លាប់ទៅធ្វើការក្នុងក្រសួងប្រៃសណីយនៅព្រៃនគរចំនួន៣ឆ្នាំ លោកស្គាល់ខ្មែរកម្ពុជាក្រោមច្បាស់លាស់ណាស់ ។ លោកធ្វើមុខស្លុតបន្ទាប់ពីបានស្តាប់ការរ៉ាយរ៉ាប់របស់នាងមកលោកមានចិត្តអាណិតនាងទៀងជាពន់ពេក ។ លោកចាប់ដៃនាងទៀង ហើយក៏បញ្ជិះនាងខាងក្រោយស្កូឡិចរបស់គាត់ ដើម្បីទៅកាន់សាលាខេត្តបាត់ដំបង ។ ទៅដល់ហើយ លោកប៉ក់-សាម៉េត ក៏នាំនាងទៅជួបលោកចំរើន-ប៊ុនរឿន ដែលជាភូឈ្មួយខេត្តទី១នៅសាលាខេត្តបាត់ដំបង ។ លោកទាំងពីរនិយាយគ្នាមួយសន្ទុះរួចហើយលោកប៊ុនរឿនក៏ដើរមកនិយាយជាមួយនាងទៀងដោយមេត្តាធម៌ថា ៖ ស្អែកនេះ នាងមកធ្វើ «តេស» ជាមួយគេចុះ ។ នាងទៀងដឹងថា លោកយល់ព្រមទាំងទើសទាំងទាល់ ដោយសារតែអន្តរាគមន៍ពីលោកប៉ក់-សាម៉េតតែប៉ុណ្ណោះ

ព្រោះលោកមិនដែលស្គាល់ខ្មែរកម្ពុជាក្រោមទេ លោកក៏ស្មានដូចអ្នកឯទៀតដែរថានាងជាយួន...

ថ្ងៃស្អែកឡើង ទី១៣-៩-៨៨ ពេលនាងទៀងដើរទៅដល់មុខការិយាល័យលោកភូឈួយ នាងឃើញមានយុវនារី៥នាក់អង្គុយចាំនៅទីនោះរួចជាស្រេច ។ នារីទាំងនោះស្លៀកពាក់ស្អាតបាតតាមរបៀបខ្មែរនិយាយខ្សិបខ្សៀវគ្នាពីនេះពីនោះ ។ ចំណែកនាងទៀងស្លៀកខោខ្មៅ ពាក់អាវសកមូលដៃវែង ទុកសក់កៀបទៅក្រោយតាមរបៀបខ្មែរកម្ពុជាក្រោម ។ បុគ្គលិកធ្វើការនៅសាលាខេត្តសម្លឹងនាងគ្រប់ៗគ្នាដោយមិនដែលឃើញទាំងសំលៀកបំពាក់ ទាំងរូបរាង ទាំងសក់មិនមែនយួនមិនមែនចិន ឫកពារសមរម្យដូចជាខ្មែរ ។ នាងមិនហ៊ានចូលទៅជិតគេទេ ដោយឈរនៅក្បែរមាត់ទ្វារបន្ទប់លោកភូឈួយទី១ ផ្អែកខ្នងនឹងជញ្ជាំង...

ពេលម៉ោងធ្វើ «តេស» មកដល់ គណកម្មាធិការហៅបេក្ខនារីទាំង៦នាក់ចូលទៅកាន់បន្ទប់លោកភូឈួយទី១ ។ លោកចំរើន-ប៊ុនរឿនដាក់កៅអីពិសេសមួយនៅខាងឆ្វេងគាត់សំរាប់នាងទៀង ។ វិញ្ញាសារមានបីមុខគឺ ៖ សរសេរតាមសូត្រខ្មែរ, សរសេរតាមសូត្របារាំង និងការសន្ទនាផ្ទាល់មាត់ជាភាសាយួន ។ រួចហើយបេក្ខនារីទាំងអស់ត្រូវនៅអង្គុយស្តាប់លទ្ធផល ។ ប្រហែលមួយម៉ោងក្រោយមកលោកប៊ុនរឿនដើរចេញពីបន្ទប់ ញញឹម ហុចដៃស្តាំកាន់នាងទៀង ដៃឆ្វេងកាន់សំណុំលិខិត ហើយនាំនាងទៅជួបឯកឧត្តម ទេព-ផន ចៅហ្វាយខេត្តបាត់ដំបង ។

លោកសម្លឹងមើលមុខនាងទៀងដោយងឿងឆ្ងល់ តែលោកប៊ុនរឿនក៏ធ្វើសេចក្តីរាយការណ៍ពីជីវប្រវត្តិនិងបញ្ហាផ្សេងៗ រួចមកក៏បង្ហាញលទ្ធផល «តេស» របស់នាង ៖

- សរសេរតាមសូត្រខ្មែរ គ្មានកំហុស ។
- សរសេរតាមសូត្របារាំង គ្មានកំហុស ។
- ភាសាយួនល្អបង្គួរ ។

លោកចៅហ្វាយខេត្តងក់ក្បាលញញឹមពេញចិត្តនឹងលទ្ធផលនេះ ។ លោកក្រោកឡើងដឹកដៃនាងទៀងទៅជួបជុំលេខាធិការទាំងអស់ ដើម្បីសួរយោបល់ ។ ពេលនោះលោកប៉ក់-សាម៉េតក៏មកដល់ល្មម ព្រោះលោកក៏ចង់ដឹងពីលទ្ធផលនៃការប្រឡងជ្រើសរើសនេះដែរ ។ នៅពេលនោះលោកប៉ក់-សាម៉េតក៏លើកដៃធានាអះអាងថា នាងទៀងពិតជាកូនខ្មែរកម្ពុជាក្រោមពិតៗ ។ ចំណែកបុគ្គលិកសាលាខេត្តនៅពេលនោះមាន ៖ លោកវ៉ា-សំផុន, លោកពត-សាអ៊ឹម ( *លោកពត-សាអ៊ឹមត្រូវជាឪពុកក្មេករបស់លោកលី-ឌៀប ចាងហ្វាងសារពត៌មានអង្គរបូរី- ក្រោយមកបានចូលទៅបំរើក្នុងកងយោធពលខេមរភូមិន្ទ* ), លោកទេព-សារិម និងលោក

អ៊ូ-ជំនិត ក៏លើកដៃសុំទទួលស្គាល់និងធានាអះអាងដែរ ។

ឯកឧត្តមទេព-ផន ក៏សំរេចតែងតាំងនាងទៀងជាលេខាធិការប្រចាំថ្ងៃ ( Sécretaire journalière ) ទទួលបន្ទុកខាងកិច្ចការរបៀប ( Service d'Ordre ) ។លោកអ៊ូ-ជំនិតជាអ្នកចាត់ចែងធ្វើសំណុំរឿងនេះ ដើម្បីផ្ញើទៅសុំការយល់ព្រមពីក្រសួងមហាផ្ទៃ ។ ឯកឧត្តមទេព-ផន ធ្វើអំណោយ១០០$ដល់នាង ដើម្បីទិញសំលៀកបំពាក់ជាខ្មែរ ។ លោកប៉ាល់-សំអុល ភូឈ្មួយខេត្តទី២ធ្វើអំណោយ៣០$ ដើម្បីឲ្យនាងទិញស្បែកជើងថ្មីមួយគូជំនួសស្បែកជើងឈើកញ្ចាស់ដែលនៅជាប់នឹងជើងនាង ។ ថ្ងៃទី១១-១១-៤៨ នាងទៀងបានចូលធ្វើការនៅសាលាខេត្តបាត់ដំបងតាំងពីនោះរៀងរហូតមក ។

នៅថ្ងៃទី២០-៤-៥០ លោកកៀង-ឥន្ទ្រត្រូវផ្លាស់ទៅកាន់រាជធានីភ្នំពេញ ។ នៅថ្ងៃទី២៦-៧-៥១ លោកកៀង-ឥន្ទ្រមានបេសកកម្មមកកាន់ទីក្រុងបាត់ដំបង ។ លោកចូលសំរាកដេកផ្ទះឪពុកក្មេកឈ្មោះ ហូ-ថាញ់សុក Hô Thanh Sôc មួយយប់ ។ ព្រឹកឡើងម៉ោង១០ លោកត្រូវធ្វើដំណើរចេញពីខេត្តបាត់ដំបងចូលទៅកាន់ខេត្តពោធិសាត់ ដូចមានលិខិតបញ្ជាក់ ( Attestation ) ជូនភ្ជាប់មកជាមួយនេះ ៖

**SERVICE CENTRAL DE L'ETAT CIVIL
DES SUCCESSIONS ET DES SEPULTU-
RES MILITAIRES**
**----------------**
**139 rue de BERCY 139
PARIS XII$^{0}$**

## ACTE DE DISPARITION

**-------------**

**GROUPE DES UNITES DE GARNISON DE PHNOM PENH
( Compagnie de Garnison )**

**Nous soussignés Lieutenant FERMET Honoré, Officier d'Etat-Civil du Groupe des Unités de Garnison de PHNOM PENH, certifions que le nommé KIEN-INH, fils de KIEN-SREY et de THACH-THI-NHIEU, né le 15 Février 1925 à THION LOI, Canton de TRAVINH, province de TRAVINH, département de Cochinchine,**
**Adjudant-Chef Interprête inscrit sous le n$^{0}$ 303 au régistre matricule, disparu le 27 Juillet 1951 au kilomètre 16 sur la route de PURSAT à LEACH, province de PURSAT (Cambodge), et que depuis cette époque toutes les recherches auxquelles il a été procédé pour découvrir son sort sont demeurées infructueuses.**

**CIRCONSTANCES DE LA DISPARITION**

Le 27 Juillet 1951, l'Adjudant-Chef Interprête KIEN-INH était désigné pour se rendre à LEACH, province de PURSAT pour y effectuer une séance de propagande. Le convoi qui l'escortait quitta PURSAT à 14 heures at arrivé à LEACH à 15 heures. Il en repart à 17 heures, et à 17 heures 30 au kilomètre 16 de la route de PURSAT - LEACH, il tombe dans une embuscade de Viêt-Minh. A l'issue du combat qui s'est déroulé entre les Viêt-Minh et l'escorte, l'Adjudent-Chef KIEN-INH n'a pas reparu; aucun témoignage sur sa mort n'a pu être recueilli. En conséquence, l'Adjudent-Chef KIEN-INH est porté disparu (suite combat) à compter du 28 Juillet 1951 à o heure 1 minute ./.

Vu : Pour la légalisation
de la signature du Lieutenant
d'Etat-
FERMET Officier d'Etat-Civil
PHNOM PENH, le Août 1951
Intendant Militaire de $3^{0}$ Classe
es TC, Chef de Service de l'Intendance
de Phnôm Penh,
Caché et Signé

Fait à PHNOM PENH le 10 AOUT 1951
Le Lieutenant FERMET, Officier
Civil du Groupe des Unités de Garnison
Caché et Signé le Lieutenent FERMET

« ថ្ងៃ២៧-៧-៥១ លោកកៀង-ឥន្ទ្រ នាយរងអគ្គលេខ៣០៣, លេខាធិការបកប្រែ បានត្រូវបញ្ជូនទៅកាន់ស្រុកលាច ខេត្តពោធិសាត់ ដើម្បីធ្វើការឃោសនាពន្យល់ប្រជាជន ។ ក្បួនឡានចាកចេញពីខេត្តពោធិសាត់នៅម៉ោង២រសៀល ទៅដល់លាចនៅម៉ោង៣រសៀល ។ លោកចាកចេញពីលាចមកវិញ នៅម៉ោង៥រសៀល ហើយនៅម៉ោង៥កន្លះ នៅត្រង់គីឡូម៉ែត្រលេខ១៦ លោកត្រូវជាប់ក្នុងការឡោមព័ទ្ធរបស់ពួកវៀតមិញ.... » ។

ពេលច្បាំងតទល់គ្នានេះ វៀតមិញចាប់លោកកៀង-ឥន្ទ្រចង រួចនាំយកទៅបាត់ ។

បារាំងស្តាយលោកកៀង-ឥន្ទ្រណាស់ ព្រោះលោកជាមនុស្សស្មោះត្រង់នឹងចៅហ្វាយនាយ ចេះនិយាយនិងសរសេរបីភាសា ។ ក្រសួងមានសមត្ថកិច្ចបានចាត់លោក ចេង ដែលមានឋានន្តរស័ក្តិជា **Aspirant** និងជាសហការីរបស់លោកឥន្ទ្រឲ្យតាមស៊ើបអង្កេតរឿងនេះ ។ លោក ចេង តាមដានរកអស់៣ឆ្នាំ គ្មានលទ្ធផលអ្វីសោះ ។ នៅឆ្នាំ១៩៥៤ បារាំងត្រូវដកថយពីឥណ្ឌូចិន លោក ចេង ក៏ចូលទៅបំរើក្នុងកងយោធពលខេមរភូមិន្ទ ក្នុងឋានន្តរស័ក្តិជាអនុសេនិយទោ នៅផ្នែកសឹករង

ក្រសួងនគរបាលជាតិខេត្តបាត់ដំបង ។ ថ្ងៃមួយលោកចេងប្រទះឃើញមេខ្មែរវៀតមិញម្នាក់ឈ្មោះ កើត ដើរកណ្ដាលទីក្រុងបាត់ដំបង នៅដៃមានពាក់នាឡិកាលោកឥន្ទ្រ ។

លោកចេងក៏សុំអញ្ជើញលោកកើតទៅការិយាល័យ ដើម្បីសាកសួរពត៌មានផ្សេងៗ ។ ឈ្មោះកើតបានរ៉ាយរ៉ាប់យ៉ាងក្បោះក្បាយដូចតទៅ ៖

« ហេតុដែលវៀតមិញចាត់ការដាក់អន្ទាក់ខ្សែត្រៀមរង់ចាំវាយកំទេចក្បួនកុងវ័របារាំងបានទាន់ពេលវេលា គឺដោយសារវៀតមិញបានបណ្ដុះចារកិច្ចជាខ្សែបណ្ដាញសម្ងាត់មួយនៅកណ្ដាលទីក្រុងបាត់ដំបង ។ ក្រុមចារកិច្ចនេះមាន ៖

- ឈ្មោះង្វៀង-វ៉ាន់រ៉ាំង ជាវេជ្ជបណ្ឌិត មានលំនៅនៅផ្លូវលេខ២ 1/2 ។

- ឈ្មោះង្វៀង-វ៉ាន់បា ជានាយសហគ្រិន ( entrepreneur ) ។

- ឈ្មោះង្វៀង-វ៉ាន់ដាវ ជាស្មៀននៅសាលាខេត្តបាត់ដំបង ។ ឈ្មោះនេះបានបើកសាលារៀនឈ្នួលមួយជាភាសាយួន ដែលមានប្រពន្ធជាគ្រូបង្រៀន ។ សាលានេះជាទីប្រជុំយ៉ាងស្ងៀមស្ងាត់របស់ចារជនវៀតមិញ ។

- ឈ្មោះហូ-ថាញ់សុក ជាប្លង់តុង កាន់កាប់លិខិតចេញនៅសាលាខេត្តបាត់ដំបង ។ កូនស្រីរបស់យួននេះ ឈ្មោះហូ-គឹមយ៉ុង ជាប្រពន្ធរបស់លោកកៀង-ឥន្ទ្រ ។ ហូ-ថាញ់សុកមានភារ:កិច្ចរាយការណ៍ផ្សេងៗទៅប្រាប់វៀតមិញឲ្យទាន់ពេលវេលា ។ នៅយប់ដែលវៀតមិញចាប់លោកកៀង-ឥន្ទ្រ និងកំទេចក្បួនកុងវ័របារាំងនោះ ព្រោះហូ-ថាញ់សុកជាអ្នកឲ្យការណ៍ ហើយដែលមានឈ្មោះកើតនេះ ជាមេបញ្ជាការកងកម្លាំងប្រដាប់អាវុធបដិវត្តន៍ឯកភាពរបស់ប្រទេសកម្ពុជាប្រចាំនៅភូមិលាច » ។

កើតបានពោលបន្តទៅទៀតថា ៖

« ពេលដែលបូដូយចាប់លោកកៀង-ឥន្ទ្របាន វាចងដៃ ចងភ្នែក រួចបណ្ដើរចូលទៅកាន់ព្រៃខាងលិចភូមិលាច ។ វាវាយធ្វើបាបសួរចម្លើយយ៉ាងច្រើន... ទីបំផុតវាសួររកទីលំនៅយុវនារីខ្មែរម្នាក់ឈ្មោះនាងទៀង ដែលលោកកៀង-ឥន្ទ្រជួយរំដោះចេញពីកម្ពុជាក្រោម តាំងពីខែកក្កដាឆ្នាំ១៩៤៨ ។ ពេលនោះ លោកកៀង-ឥន្ទ្រខឹងយ៉ាងខ្លាំងក៏ឆ្លើយយ៉ាងកំបុតកំបុយថា មិនដឹងមិនអីទេ ។ មេវៀតមិញក៏វាយធ្វើទារុណកម្មលើរូបលោកលុះត្រាតែស្លាប់ទៅ ។ មេវៀតមិញក៏ដោះនាឡិកាដៃរបស់ខ្មោចលោកកៀង-ឥន្ទ្រហុចមកឲ្យឈ្មោះកើត ជាអនុស្សាវរីយ៍នៃមហាជោគជ័យនេះ... » ។

លោកអនុសេនិយទោចេង ទំរាំតែដឹងថាមានខ្សែបណ្ដាញវៀតមិញនៅបាត់ដំបង វាហួសពេលទៅហើយ។ វៀតមិញចាកចេញផុតពីទីក្រុងបាត់ទៅហើយ ។ នៅ

សល់តែហូ-ថាញ់សុកម្នាក់គត់ ដែលនៅពេលនោះសាលាខេត្តក៏បានបណ្ដេញចេញពីមុខងារ ហើយនិរទេសពីខេត្តបាត់ដំបងរហូត ។ មានសំនួរសួរឡើងថា ៖

- ហេតុម្ដេចលោកកៀង-ឥន្ទ្រសុខចិត្តស្លាប់ការពារនាងទៀង ?

- លោកកៀង-ឥន្ទ្រ ជាខ្មែរកម្ពុជាក្រោមម្នាក់ ដែលស្គាល់ក្រយៅយួនច្បាស់លាស់ណាស់ ។ បងប្រុសរបស់លោកម្នាក់ត្រូវវៀតមិញសម្លាប់ ។ លោកដឹងថាទោះបីលោកប្រាប់ពីទីកន្លែងនាងទៀងឬមិនប្រាប់ វានៅតែសម្លាប់លោកដដែល ព្រោះវៀតមិញមានគំរោងសម្លាប់អ្នកចេះដឹងខ្មែរឲ្យអស់ផុតពូជ ។

លោកកៀង-ឥន្ទ្រជាកូនប្រុសទី២របស់លោកតាកៀង-ស្រី និងយាយថាច់-ធីញៀវ ។ កើតនៅថ្ងៃទី១៥-២-២៥ នៅភូមិក្នុងស្រុក-ឃុំថ្ងឹងឡើយ, ស្រុកចូវថាញ់, ខេត្តត្រាវិញ ។ ក្រោយពីប្រឡងជាប់ឌីប្លូមនៅសាលានរម៉ាល់ក្រុងភ្នំពេញឆ្នាំ១៩៤៥ លោកស្ម័គ្រចិត្តទៅធ្វើគ្រូបង្រៀននៅសាលាវត្តប្រទក្សិណនិគ្រោតក្នុងឆ្នាំ១៩៤៥-៤៦ ។ ក្នុងខែកញ្ញា១៩៤៦ វៀតមិញចាប់ចងបងប្រុសបង្កើតរបស់លោកជាគ្រូបង្រៀន នាំយកទៅបាត់...។ បន្ទាប់មក វៀតកុងតាមដានចាប់ខ្លួនលោកទៀត ។ ដោយដឹងខ្លួនទាន់ លោកក៏សំរេចចិត្តរត់ចោលតំណែងគ្រូ ចូលធ្វើទាហានបារាំងនៅថ្ងៃទី១៦-១០-៤៦ មានឋានន្តរស័ក្តិជាពលបាលទោ ( Sergent Chef ) និងជាលេខាធិការអ្នកបកប្រែនៅក្រសួងសន្តិសុខជាតិនៃទីក្រុងព្រៃនគរ ។

ចំណែកនាងទៀង នាងធ្លាប់បាក់ស្បាតខ្លាចវៀតមិញ ។ នាងហ៊ានជួលផ្ទះមួយតម្លៃ ២០០$ (ក្នុងប្រាក់ខែទាំងអស់៥០០$) ស្ថិតនៅមុខបន្ទាយទាហានជើងក្រហម « ទាហានបារាំង » ដើម្បីការពារអាយុជីវិត ព្រោះនៅពេលនោះ វៀតមិញបញ្ចេញសកម្មភាពខ្លាំងក្លានិងឃោរឃៅណាស់ ។

ក្នុងរយៈពេលដែលវៀតមិញចាប់ខ្លួនលោកកៀង-ឥន្ទ្រ នាងទៀងឥតបានដឹងរឿងនេះទេ ព្រោះមានទូរលេខមួយច្បាប់ពីឪពុកនាង ឲ្យធ្វើដំណើរទៅខេត្តត្រាវិញជាប្រញាប់ ដើម្បីនឹងទៅយកប្អូនបង្កើត គីម-ច័ន្ទ អាយុ១៤ឆ្នាំ ដែលត្រូវវៀតកុងបំរុងចាប់បញ្ជូនទៅប៉េកាំង និងក្មួយរបស់នាងឈ្មោះគីម-វណ្ណា អាយុទើបបាន៦ឆ្នាំកំព្រាឪពុកម្ដាយ ។ ឪពុករបស់នាងបានលួចបណ្ដោះអ្នកទាំងពីរនេះចេញពីដែនដីរំដោះទៅទីក្រុងត្រាវិញ ហើយឲ្យនាងទៅយកអ្នកទាំងពីរនៅទីនោះ ។ នាងទៀងទៅដល់ជួបជុំប្អូននិងក្មួយនៅផ្ទះលោកមាថាច់-ទីហុង ។ កំពុងតែមានសេចក្ដីត្រេកអរនឹងការជួបជុំគ្នា ស្រាប់តែទទួលដំណឹងមកថា លោកតាគីម-វណ្ណៈ បានចងកសម្លាប់ខ្លួនបាត់ទៅហើយ ដោយមកពីវៀតកុងបញ្ជាឲ្យគាត់ទៅជួបនឹងវានៅយប់ទីបួន ក្រោយពេលដែលគាត់បណ្ដោះអ្នកទាំងពីរចេញទៅត្រាវិញ ។ គាត់ធ្វើអត្តឃាតនេះ ដោយមកពីគាត់ដឹងខ្លួនជាមុនថា វៀតមិញមុខតែនឹងសម្លាប់គាត់ជាពុំខាន...។

នៅថ្ងៃទី២-៨-៥១ នាងទៀងនាំប្អូននិងក្មួយមកដល់ខេត្តបាត់ដំបង ។ នៅពេលនោះលោកចេងក៏ប្រាប់ថា វៀតមិញបានចាប់ខ្លួនលោកកៀង-ឥន្ទ្រទៅបាត់ហើយ ។ នាងទៀងស្ទើរឆ្កួតវង្វេង មិនដឹងគិតយ៉ាងណា ។ ទុក្ខត្រួតលើទុក្ខ មិនខុសគ្នាពីសម័យ១៧-៤-៧៥ មក២៤-៤-៧៩ ( ៤ឆ្នាំ៧ថ្ងៃ ) នេះប៉ុន្មានឡើយ ។

លើសពីនេះទៅទៀត នាងទៀងត្រូវចិញ្ចឹមប្អូនប្រុសនិងក្មួយទើបនឹងមកដល់ ។ ឆ្នាំ១៩៥១-៥២ គីម-ច័ន្ទត្រូវចូលរៀននៅវិទ្យាល័យព្រះមុនីវង្ស ។ គីម-វណ្ណាចូលរៀននៅសាលាបឋមសិក្សានៅផ្សារលើ ។ ខែកញ្ញាជាពេលចូលកង ។ កំពុងតែខ្វល់ខ្វាយព្រួយបារម្ភពីរឿងទិញសៀវភៅនិងប្រដាប់ប្រដារ សំរាប់ប្អូននិងក្មួយស្រាប់តែ ! មានប៉ូលីសមកដល់ផ្ទះ ! បង្ហាញដីការចាប់ខ្លួននាងទៀង ។ ប៉ូលីសបណ្តើរនាងទៀងទៅជូនលោកព្រះរាជអាជ្ញារ ដោយមានអ្នកដើមចោទប្តឹងប្រកាន់ថា « នាងលួចស្រោមខ្នើយគេ ! » ។

ស្រឡាំងកាំង លែងយល់អ្វីទាំងអស់ហើយ ! ។ ពេលទៅដល់លោកគូ-រុនជាព្រះរាជអាជ្ញារ ក៏ហៅអ្នកដើមចោទមកតទល់នៅចំពោះមុខអ្នកចុងចោទ ។

នៅពេលឃើញមុខអ្នកដើមចោទ នាងទៀងភ្ញាក់ស្មុះទៅសំពះសួរដោយគួរសម រួចឱបកយំដំអូញថា ៖ យីបងក្រូចទេតើ ! ឱបងអើយ យើងជាអ្នកកម្ពុជាក្រោមដូចគ្នា ហេតុម្តេចក៏បងមិនមេត្តាខ្ញុំដែលកំព្រាតែលតោលតែម្នាក់ឯងយ៉ាងនេះ ? បងអើយ ! បើខ្ញុំត្រូវជាប់គុក ឬបើរាជការដេញបញ្ឈប់ខ្ញុំឲ្យឈប់ធ្វើការ ប្អូនប្រុសនិងក្មួយខ្ញុំត្រូវដាច់ពោះស្លាប់... ហេតុម្តេចក៏បងធ្វើបាបខ្ញុំយ៉ាងនេះ ? ។ រឿងស្រោមខ្នើយរបស់បងនោះ ខ្ញុំមិនបានដឹងទាល់តែសោះ ខ្ញុំមិនដឹងលួចយកមកធ្វើអ្វី បើខ្ញុំគ្មានទាំងខ្នើយកើយផងនោះ ។ ម្យ៉ាងវិញទៀត ខ្ញុំមិនដែលស្គាល់ផ្ទះរបស់បង ផងតើបងបាត់វានៅកន្លែងណា ? ។ និយាយបណ្តើរយំបណ្តើរ ភ្នែកសម្លឹងលោកព្រះរាជអាជ្ញារជាប់ជានិច្ច ។

លោកព្រះរាជអាជ្ញារនៅពេលនោះមានយុត្តិធម៌ មិនបានសួរអ្នកចុងចោទទេ តែបែរជាសួរពីទីលំនៅរបស់អ្នកដើមចោទទៅវិញ ។ លុះសួរនាំរួចហើយ ទើបគេដឹងថា អ្នកក្រូចជាស្រី «បន» ដែលមានលំនៅនៅមុខស្ថានិយរថភ្លើងបាត់ដំបង ហើយដែលមានមេជាស្រីយួនម្នាក់ឈ្មោះ «ង្វៀង-ធីម៉ុយ» ។ ស្រីយួននេះបានរត់ឆ្វេចឆ្វាច គិតគូរសូកប៉ាន់គេធ្វើម្តេចដើម្បីឲ្យនាងទៀងត្រូវជាប់គុក ដើម្បីសំរេចតាមបំណង ។

ចំណែកឯអ្នកក្រូចរកពាក្យឆ្លើយនឹងព្រះរាជអាជ្ញារមិនរួច រដិបរដុប ក៏ត្រូវព្រះរាជអាជ្ញារដេញចេញពីទីកន្លែងកាត់ទោសនោះទៅ ។ លោកបែរមករកនាងទៀងហើយនិយាយថា ៖ បើតាមច្បាប់ ការដែលមានដីការចាប់ខ្លួនយ៉ាងនេះ តុលាករ

ត្រូវតែឃុំនាងទុកសិន ។ តែបើមានអ្នកណាម្នាក់ចូលមកសុំធានានាង ខ្ញុំឲ្យនាងនៅក្រៅឃុំជាបណ្ដោះអាសន្នបាន ។

កំពុងតែខ្វល់ខ្វាយយ៉ាងនេះ ស្រាប់តែឃើញលោកប៉ក់-សាម៉េតដើរចូលមកជាមួយនិងលោកស្នងការប៉ូលីស តាន់-អុកណាំអៀង ។ នាងទៀងរត់ត្របាញ់ជើងទៅរកលោកទាំងពីរជំរាបពីរឿងអកុសលនេះ ។ លោកទាំងពីរបានស្ដាប់ចប់សព្វគ្រប់ហើយក៏ញញឹមដើរចូលមកកាន់បន្ទប់លោកព្រះរាជអាជ្ញា ។ លោកប៉ក់-សាម៉េតក៏ចុះហត្ថលេខាធានានាងទៀងឲ្យបានរួចខ្លួននៅក្រៅឃុំជាបណ្ដោះអាសន្នសិន ។

នាងទៀងត្រេកអរណាស់ក៏សំពះលាលោកទាំងអស់ វិលចូលកាន់សាលាខេត្តដើម្បីធ្វើការឡើងវិញ ។ ប៉ុន្តែ ! ពុទ្ធោអើយ ! រាជការចេញប្រកាសបញ្ឈប់នាងពីកន្លែងធ្វើការ រង់ចាំការជំនុំជំរះពីតុលាការសិន ។

នៅពេលនោះ នាងត្រូវរស់អង្គុររលីង ។ ថ្ងៃនោះជាថ្ងៃសៅរ៍, គឹម-ច័ន្ទកាន់កូនបាវកញ្ចាស់មួយដើរដោយជើងទៅកាន់ភូមិកាច់រទេះ ដែលមានចម្ងាយ២៥គ.ម. ពីបាត់ដំបង ដើម្បីទៅសុំទានអង្ករពីមាមីងកម្ពុជាក្រោមនៅទីនោះ ។ ស្អែកឡើងថ្ងៃអាទិត្យ ម៉ោងប្រហែល៩ព្រឹក វណ្ណាដើរឱបកមីងទៀងពីក្រោយយំហ៊ិៗ ។

- មីងអើយ ខ្ញុំឃ្លានបាយណាស់ ! ។

ពេលនោះនាងទៀងដើរដល់ច្រកទាល់ហើយ លុយដែលនៅសល់បន្តិចបន្តួចបង់ឈ្នួលផ្ទះអស់រលីង តើធ្វើយ៉ាងម៉េចទៅ ?

នាងទៀងអេះខ្នងក្មួយលួងលោមឲ្យគេងលុះត្រាដេកលក់... មួយសន្ទុះនាងនឹកឃើញមធ្យោបាយមួយ ក៏ដាស់ក្មួយឲ្យក្រោក ។

- វណ្ណាអាហ៍ !

ក្មួយកំសត់ព្វម្ដាយមីងហៅ អរណាស់ក្រោកឡើងសើងមម៉ើងដោយស្មានថាច្បាស់ជាមានអីញ៉ាំហើយ ។ វណ្ណាមើលមុខម្ដាយមីង ។

- ចូរក្មួយស្លៀកពាក់ហើយដើរទៅផ្ទះពូប៊ិម មីងអ៊ឹយទៅ ( គាត់ទាំងពីរនាក់ប្ដីប្រពន្ធនៅភូមិរំដួល មានចម្ងាយ៨គ.ម.ពីកន្លែងនាងទៀងនៅ, ក្រោយមកគាត់ក្លាយជាឪពុកម្ដាយក្មេករបស់គឹម-ច័ន្ទ ) ។ ពេលគាត់រៀបបាយឲ្យកូនៗគាត់ញ៉ាំចូរក្មួយដើរចូលទៅ កុំខ្មាស់អៀន ។ វណ្ណារារែកហើយក៏សួរថា ៖

- តើមីងបានអីពិសារ ?

- មីងអាចអត់ធ្មត់ការអត់ឃ្លានបាន, នាងទៀងអង្អែលក្បាលក្មួយហើយញញឹម លួងចិត្តក្មួយដ៏កំសត់ ។ មីងផឹកតែទឹកស្រះក៏អាចឆ្អែតបានមួយពេលៗដែរ ។

វណ្ណាអល់អែកជាខ្លាំង តែមួយសន្ទុះក៏សុខចិត្តដើរចេញទៅ...

❑

ជាច់ខែកញ្ញា, នាងទៀងគ្មានលុយ២០០$បង់ឈ្នួលផ្ទះទេ ។ នាងត្រូវតែកាត់ការអៀនខ្មាស់ទៅថ្វាយបង្គំលោកគ្រូ កែវ-សាង សង្ឃរាជវត្តកំផែងនិងជាអនុគណខេត្តបាត់ដំបង ហើយដែលត្រូវជាបងចិញ្ចឹមរបស់នាង ។ នាងទូលរៀបរាប់អំពីការព្យាបាទមិនសមទំនង... តែជាពិសេសគឺនាងចង់មកសុំលុយ២០០$ដើម្បីបង់ឈ្នួលផ្ទះ ។

លោកគ្រូកែវ-សាងហុចលុយឲ្យនាង ព្រមទាំងបង្គាប់ឲ្យគេសង់កូនខ្ទមមួយស្ថិតនៅខាងលិចឆៀងខាងជើងវត្តកំផែង ជាប់របបបន្ទាយទាហានជើងខ្មៅ (ទាហានខេមរភូមិន្ទ) ដើម្បីឲ្យជីវិតដ៏កំសត់ទាំងបីរស់នៅជាបណ្ដោះអាសន្នសិន ។

នៅថ្ងៃទី១០-១០-៥១, ម៉ោងប្រហែល៧រសៀល, ស្រាប់តែមានប៉ូលីសក្រុង ២នាក់ចូលមកកាន់កូនខ្ទមនាងទៀង ហើយក៏ចាប់នាងទាំងបង្ខំនាំទៅការិយាល័យនៃស្នងការប៉ូលីសក្រុង ។ ទៅដល់ស្នងការដ្ឋាន ស្រាប់តែឃើញបងក្រួចនិងអ្នកង្វៀង-ធីម៉ឺយញញឹមផ្អើនមករកនាង ។ ភ្នាក់ងារប៉ូលីសគ្មានសួរដេញដោលអ្វីពីនាងទេ, ស្រាប់តែសម្លឹងមុខបងក្រួច អ្នកម៉ឺយ ញាក់មុខដាក់គ្នា រួចចាប់ដៃនាងទាញបណ្ដើរទៅឃុំ ។

លុះឃើញមានអំពើអយុត្តិធម៌យ៉ាងដូច្នេះ នាងទៀងស្រែកឡូឡាសួររកខុសត្រូវ... ប៉ូលីសច្រានតនាងបញ្ចូលក្នុងបន្ទប់ឃុំឃាំង ។ ទ្រាំលែងបាន នាងទៀងក៏តដៃ ដោយសំពងភ្នាក់ងារប៉ូលីសនោះ២-៣ឆ្វេងត្រ ។ ភ្នាក់ងារប៉ូលីសខឹងខ្លាំងណាស់ក៏យារដៃទះកំភ្លៀងនាងទៀង ។ ប៉ុន្តែ ! សម្លេងមួយស្រែកគំហកគំរាម ពីក្រៅស្នងការដ្ឋានមកថា ៖

– ឈប់សិន ! ឈប់សិន !

នាងទៀងមើលតាមសម្លេង គឺលោកតាន់-អុកណាំអៀង ។ លោកស្រែកបណ្ដើរព្រមទាំងចុះពីលើឡានហ្ស៊ីបបណ្ដើរ ។ លោកបក់ដៃហៅភ្នាក់ងារប៉ូលីសចូលកាន់ការិយាល័យ ។ មួយសន្ទុះធំ លោកក៏ចេញមកជួបបងក្រួចនិងអ្នកម៉ឺយ ។ លោកចង្អុលមុខស្រីទាំងពីរនាក់រួចនិយាយសំឡុតថា ៖ អ្នកឯងទាំងពីរនាក់ត្រូវចេញពីទីនេះភ្លាម បើមិនដូច្នោះទេ ខ្ញុំឃុំអ្នកឯងវិញហើយ ។

លោកនាយស្នងការដ្ឋានដើរមកកាន់ដៃនាងទៀង នាំទៅឡើងឡាន ហើយក៏បរចេញទៅ ។ លោកនិយាយថា លោកប៉ក់-សាម៉េតបានជំរាបលោកពីរឿងរ៉ាវដ៏កំសត់របស់នាងទៀងហើយ ។ លោកមានសេចក្តីអាណិតមកលើនាងជាពន់ពេក ។ ចំណែករឿងដែលកើតមានឡើងអម្បាញ់មិញនេះ គឺវាខុសច្បាប់ទាំងស្រុងហើយ ។ ព្រោះសំណុំរឿងដែលអ្នកក្រួចប្ដឹងចោទនាងនោះ កំពុងតែបន្តនៅសាលាដំបូងឯណោះ ។ ដូច្នេះរឿងអម្បាញ់មិញនេះ ភ្នាក់ងារកំហូចរបស់ខ្ញុំវាត្រូវរ៉ូវគ្នាជាមួ-

យអ្នកក្រូច-អ្នកម៉ីយ ដោយឆ្លៀតពេលដែលខ្ញុំចេញទៅបំពេញបេសកកម្មនៅភ្នំពេញ ដើម្បីបំរុងរំលោភធ្វើបាបនាង ។

នាងទៀងលើកដៃសំពះលោកណាំអៀងសុំទោសហើយសួរថា ៖ ហេតុម្តេចលោកមកទាន់ពេលដែលគេបំរុងធ្វើបាបនាង ? ។

លោកណាំអៀងមើលមុខនាងរួចមានប្រសាសន៍ថា ៖

- នាងមានបុណ្យកុសលខ្ពស់ណាស់ ! នៅពេលដែលខ្ញុំទៅដល់ប៉ុស្តិ៍ប៉ូលីសស្រុកមោងឫស្សី គេហុចទូរលេខមួយច្បាប់មកខ្ញុំ ឲ្យវិលមកជួបលោកខេត្តវិញជាបន្ទាន់ ។ ពេលខ្ញុំចូលមកស្នងការដ្ឋាន ខ្ញុំក៏ឃើញព្រឹត្តិការណ៍នេះ ហើយក៏ស្រែកបញ្ឈប់ភ្នាក់ងារនោះទៅ ។ ឥឡូវនេះខ្ញុំត្រូវទៅជួបលោកខេត្ត តែខ្ញុំឆ្លៀតពេល២-៣នាទីជូននាងទៅជួបព្រះរាជអាជ្ញារ ដើម្បីឲ្យលោកជួយដោះស្រាយរឿងបណ្តឹងអ្នកក្រូច-អ្នកម៉ីយ ឲ្យបានដាច់ស្រឡះពីការចោទប្រកាន់ទទឹងទិសនេះ ។

ពីរអាទិត្យក្រោយមក នាងទៀងទទួលដីការកោះហៅពីសាលាដំបូង ឲ្យចូលស្តាប់ការជំនុំជំរះ ។ តុលាការកាត់សេចក្តីសំរេចថា ៖

- ទី១ នាងទៀងត្រូវរួចខ្លួន ។ ទី២ នាងមានសិទ្ធិប្តឹងតបតទាមទារជម្ងឺចិត្តពីអ្នកដើមចោទវិញ ។

នាងទៀងសុំបដិសេធភ្លាម មិនប្តឹងតវ៉ាអ្វីឡើយ ។ នាងប្រញាប់ប្រញាល់សំពះសុំអរគុណលោកព្រះរាជអាជ្ញារ និងសុំលាទៅកាន់កូនខ្ទម ពាំនាំពត៌មាននេះទៅប្រាប់ប្អូននិងក្មួយ ។ មកដល់ភ្លាម វណ្ណាលោតមកឱបកម្តាយមីង ៖

- តុលាការកាត់សេចក្តីឲ្យមីងបានរួចខ្លួនហើយ ។

វណ្ណាញញឹមត្រេកអរណាស់ តែរួចមកក៏ប្រែធ្វើមុខស្ងួតរួចខ្សិបប្រាប់មីងថា ៖

- មីងអើយ, យើងជិតអស់អង្ករទៀតហើយ ។

- មិនអីទេ, ចាំមីងទៅសុំទានពូ-មីងយើងនៅភូមិកាច់រទេះដោយខ្លួនឯង ។ នាងទៀងអង្អែលក្បាលក្មួយដ៏កំសត់ លួងលោមកុំឲ្យបារម្ភ ។

ព្រលឹមស្អែកឡើង នាងទៀងមូរបាវកញ្ចាស់មួយចងកាន់នៅដៃ ហើយចេញដំណើរទៅភូមិកាច់រទេះ ។ ទៅដល់ភ្លាម បងប្អូនរត់ឈ្វេរឆរមកទទួលសាកសួរសុខទុក្ខ ជាពិសេសចង់ដឹងលទ្ធផលនៃការប្តឹងចោទប្រកាន់របស់អ្នកក្រូច ។ នាងបានរៀបរាប់ប្រាប់បងប្អូនសព្វគ្រប់....

ឃើញបាវកញ្ចាស់នៅដៃ គ្រប់ៗគ្នាយល់ពីរឿងនេះ ក៏នាំគ្នាកើបស្រូវជាន់អង្ករដើម្បីច្រកបាវ ។

កំពុងតែរវីរវល់បុកស្រូវ ស្រាប់តែឃើញអ្នកបរឡានឈ្នួលយកសំបុត្រពីរសន្លឹកមកឲ្យនាង ។ នាងទៀងបើកសំបុត្រទី១ ជារបស់គឹម-ច័ន្ទ ៖

- មកដល់បងជាទីគោរព,

បងអើយ ! មានភ្នាក់ងារប៉ូលីសក្រុងមករកបងទៀតហើយ ។ ឱបងអើយ ! កម្មយើងអីក៏ក្រាស់ម៉្លេះ > ឱទេវតាអើយ ! លោកមានព្រះនេត្រទិព្វ ហេតុម្តេចក៏លោកមិនជួយការពារបងប្អូនខ្ញុំ ជាជនសុចរិតផង ? ។

សំបុត្រទី២ ជាដីការកោះហៅរបស់ក្រសួងប៉ូលីសក្រុង ។

បងប្អូនភ័យឆោឡោ រៀបលុយគ្នារកឡានជូននាងទៀងទៅកាន់ក្រុងបាត់ដំបងជាបន្ទាន់ ។ ទៅដល់ស្នងការដ្ឋាន នាងរត់ញាប់ជើងទាំងភ័យទាំងឆ្ងល់... ស្រាប់តែនាងឃើញលោកណាំអៀងចេញមកទទួល ហើយមានប្រសាសន៍ថា ៖

- សាលាខេត្តបាត់ដំបងហៅនាងឲ្យចូលធ្វើការវិញហើយ ! ។

❑ ❑

❑

នៅពេលដែលអត់ប្រាក់ខែយ៉ាងនេះ តើអ្នកទាំងបីនាក់បានអ្វីបរិភោគ ?

ជីវិតទាំងបីនេះ ជាជីវិតដែលក្រខ្សត់សឹងរកអ្នកប្រដូចគ្មាន ។ តែនៅស្រុកខ្មែរយើងនៅពេលនោះ គេអាចពឹងពាក់គ្នាទៅវិញទៅមកបាន ។ លើសពីការពឹងពាក់នេះ ម្នាក់ៗស្វះស្វែងរកស៊ីឈ្នួលនាយទុនដើម្បីបង្គ្រប់ការខ្វះខាត ។ នៅពេលនោះរាល់ៗយប់ គីម-ច័ន្ទទៅស៊ីឈ្នួលថៅកែកែ-គីមស៊ាន ម្ចាស់រោងចក្រអារឈើនៅផ្សារលើ ។ នាងទៀងបង្រៀនភាសាយួនដល់កូនយួនខ្លះ ។ វណ្ណាដើរតាមឱពុកមារើសសំបកឈើ ទៅស្ទូចត្រី ចាប់ក្តាមខ្យង បេះផ្លែអំពិល ។ល។

លុយកាក់រកបានបន្តិចបន្តួចសំរាប់ទប់ទល់ការខ្វះខាតចាំបាច់ ដូច្នេះយើងទាំងបីនាក់ មិនអាចបរិភោគឲ្យបានគ្រប់គ្រាន់ និងឆ្ងាញ់ពិសារតាមចំណង់បានទេ ។ ពេលបាយ អ្នកទាំងបីអង្គុយផ្ទាល់ដីមុខកូនខ្ទម... ម្ហូបមានតែត្រីអាំងទទួលទានផ្ទាប់ជាមួយអំពិលខ្ចីបុកជាមួយអំបិលម្ទេស ( កាលណោះមិនខ្វះអំពិលទេ ) ។

មានសំនួរសួរថា នាងទៀងមានទុក្ខវេទនាយ៉ាងណាទៅ ?

- ទី១ ពេលទទួលដំណឹងថា ឪពុកធ្វើអត្តឃាតដើម្បីរំដោះកូននិងចៅពីក្រញាំវៀតមិញ ។

- ទី២ ពេលទទួលដំណឹងថា លោកកៀង-ឥន្ទ្រត្រូវវៀតមិញចាប់ទៅហើយ ។

ទុក្ខត្រួតលើទុក្ខ ! កំពុងតែគាំងដើមទ្រូងយំមិនចេញ... ស្រាប់តែអ្នកក្រួចព្រួតដៃជាមួយស្រីយួនង្វៀង-ធីម៉ីយ ប្តឹងចោទប្រកាន់ពីរឿងកំប៉ិកកំប៉ុកដើម្បីតាមព្យាបាទ ឲ្យបាត់បង់ការងារ ឲ្យដាច់ពោះស្លាប់តែប៉ុណ្ណោះ ។ នៅពេលនោះ នាងទៀង

អស់មធ្យោបាយ គឺគិតធ្វើម៉េចឲ្យតែបានអង្ករច្រកឆ្នាំង ដើម្បីចិញ្ចឹមប្អូននិងក្មួយ ។

❑ ❑

❑

នៅចុងខែតុលា១៩៥១ យាយឡើយបានមកតាមកូនស្រីនៅខេត្តបាត់ដំបង ។ មកដល់ភ្លាម យាយឡើយហុចកញ្ចប់មួយយ៉ាងធំឲ្យកូនស្រី ។ នាងទៀងបើកកញ្ចប់ឃើញលុយ៨៥០$ ! ។

ពុទ្ធោ ! នាងសែនរីករាយឥតឧបមា យកដៃអង្អែលលុយ អង្អែលហើយអង្អែលទៀត ស្រាប់តែទឹកភ្នែកមិនដឹងមកពីណាហូរជោគជាំ !!!

នាងសំពះម្ដាយសួរថា ៖ តើម៉ែបានលុយពីណាមកច្រើនម្ល៉េះ ?

– កូនស្រីអើយ ! ក្រោយពេលដែលឪពុកឯងចងកសម្លាប់ខ្លួនហើយ ! វៀតមិញតែងតែកោះហៅម្ដាយ ឲ្យទៅមើលគ្នាវាសម្លាប់មនុស្សដែលវាចោទថា «ក្បត់» សឹងតែរាល់ថ្ងៃ ។ បន្ទាប់មកទៀត វាធ្វើឲ្យម៉ែដឹងថា វាបានដាក់ផែនការតាមធ្វើបាបកូនឯងតាមរយៈស្រីខូច ។ ម៉ែភ័យណាស់មិនដឹងធ្វើយ៉ាងណាទេ ។ ទទួលពេលនោះម្ដាយបានទទួលសំបុត្រលោកឥន្ទ្រមួយច្បាប់ ឲ្យរៀបចំផ្សំផ្គុំកូនឯងជាមួយយី-វិញទ្រី ។ ក្រោយមកទៀតម៉ែបានដឹងថា លោកឥន្ទ្រត្រូវគេចាប់បាត់ទៅហើយ ។ ពេលម៉ែកំពុងតែភ័យព្រួយ ស្រាប់តែលោកថាច់-ទីហុងសរសេរមកប្រាប់ម្ដាយថា ឲ្យទៅជួបលោកអធិការប៉ាន់-ឡូវ ។ ពេលម្ដាយទៅដល់ គាត់ក៏ពន្យល់ប្រាប់បីរឿងប្រាក់បំណាច់ « រ៉ាប់ប៉ែល » របស់កូនឯង ដែលរដ្ឋាភិបាលបារាំងបានបើកឲ្យក្នុងចន្លោះពេលខែធ្នូឆ្នាំ១៩៤៦ដល់ខែកក្កដា១៩៤៨ ។ ហេតុដូច្នេះហើយទើបម៉ែសំរេចចិត្តមកតាមកូននៅបាត់ដំបងនេះ ។

នាងទៀងឱបម្ដាយដើម្បីថ្លែងអំណរគុណ ។ អង្គុយគិតមួយស្របក់ នាងក៏រលីកដៃសំពះ ហើយហុចលុយ៧០០០$ ជូនទៅម្ដាយព្រមទាំងនិយាយថា ៖

– ម៉ែ ! ប្រាក់៤០០០$នេះ សូមម៉ែចាត់ចែងធ្វើចេតិយទុកជូនខ្មោចលោកឪពុកនៅវត្តប្រទក្សិណនិគ្រោធ ។ ប្រាក់៣០០០$ទៀតសូមម៉ែជូនទៅលោកយាយថាច់-ធីញ៉ីវ (ម្ដាយរបស់លោកកៀង-ឥន្ទ្រនៅមេម៉ាយ ប្ដីស្លាប់ចោលតាំងពីក្មេង ឯកូនៗក៏ត្រូវវៀតមិញតាមធ្វើបាបទាំងបងទាំងប្អូន ) ។ ចំណែកខ្ញុំ... ខ្ញុំទុក១៥០០$សំរាប់ចាយវាយ និងលៃលកទិញកងមួយជិះទៅធ្វើការ ។

ថ្ងៃទី១១-១១-៥១ យាយឡើយក៏រៀបអាពាហ៍ពិពាហ៍កូនស្រីគាត់ជាមួយនិងយុវជនយី-វិញទ្រី តាមទំនៀមទំលាប់ប្រពៃណីខ្មែរ នៅផ្ទះពូប៊ីម-មីងអើយ ស្ថិត



ចេតិយលោកគីម-វណ្ណៈ នៅភូមិចុងព្រៃ ខេត្តត្រាវិញ ( កម្ពុជាក្រោម ) ថតនៅថ្ងៃទី៧-៦-៩៣

មុននឹងចេញទៅបំពេញបេសកកម្មនៅភូមិលាច លោកឥន្ទ្របានសរសេរសំបុត្របីច្បាប់ ។ មួយផ្ញើទៅយាយឡើយ មួយទៀតសំរាប់លោកគ្រូពេទ្យឃី-វិញទ្រី ដែលគាត់យកទៅឲ្យផ្ទាល់ដៃនៅកន្លែងធ្វើការនៅមន្ទីរពេទ្យព្រះកេតុមាលា ដែលផ្តាំឲ្យរៀបការជាមួយនាងទៀង ។ មួយច្បាប់ទៀត សំរាប់នាងទៀងផ្ទាល់ ដែលផ្ញើទុកតាមរយៈព្រះគ្រូកែវ-សាង នៅពេលដែលនាងទៀងធ្វើដំណើរទៅយកប្អូននិងក្មួយឯខេត្តត្រាវិញ ។ សំបុត្រមានសេចក្តីជាអាទិថា ៖

« មកដល់អាទៀងជាទីសោកស្តាយ !

អាទៀងអើយ, គ្មានអ្វីសោកស្តាយជាងបងស្តាយអូនទេ ។ មួយជីវិតបងនេះ កើតទុក្ខជាប់ជានិច្ច...។ បេះដូងបងឈឺចាប់ខ្លោចផ្សាដោយការសោកស្តាយនូវសេចក្តីស្នេហាអស់ពីដួងចិត្តរបស់បងមកលើអូន ដែលបងយល់ថាគ្មានស្រីណាប្រដូចបាន ។ ប៉ុន្តែវាសនាអាក្រក់បានតម្រូវបង្វែងជានឲ្យបងជួបនិងស្រីដែលមានឈាមជ័រជាសត្រូវនឹងសាសន៍យើង ។ ណ្ហើយចុះ នេះជារឿងអភ័ព្វរបស់បង ។ ប៉ុន្តែបងគិតរូបអូន បងគិតដល់អូនជានិច្ច ។ ដូច្នេះបងសូមអង្វរ ចូរអូនព្រមរៀបការជាមួយអូនឃី-វិញទ្រីទៅណាអូនណា ។ សូមអូនកុំប្រ=

ឆាំងនឹងបណ្តាំ របស់បងនេះ ។ ធ្វើដូច្នេះ បើបងស្លាប់ទៅ បងនឹងបិទភ្នែកជិត...
ហត្ថលេខា
ឥន្ទ្រ » ។

លោកឃី-វិញទ្រី ជាកូនប្រុសទី៤របស់លោកតា ឃី-តាម និងយាយតាំង-ធី លីវ ។ កើតនៅឆ្នាំ១៩៣១ នៅឃុំង៉ៃសៀង ស្រុកត្រាកូវ ខេត្តត្រាវិញ កម្ពុជាក្រោម ។ លោកប្រឡងជាប់ CEPFI ឆ្នាំ១៩៤៦ ។ នៅឆ្នាំ១៩៤៨ វៀតមិញរៀបចំបញ្ជូនលោកទៅកាន់ប៉េកាំង (ជំនាន់ជាមួយនាងទៀង) ។ ឪពុកម្តាយលោកបានបណ្តោះទៅរាជធានីភ្នំពេញ ។ លោកមានវាសនាប្រឡងចូលរៀននៅសាលាគិលានុបដ្ឋាកជាប់ រួចលោកបន្តវិជ្ជាបច្ចេកទេសផ្នែកទីពិសោធន៍ ។

រៀបអាពាហ៍ពិពាហ៍រួច គូស្វាមីភរិយាថ្មោងថ្មីមានតែហិបឈើនិងគ្រែសំពត់ម្នាក់មួយតែប៉ុណ្ណោះ ។ ក្រសែនក្រ ! ។

❑

ខែមេសាឆ្នាំ១៩៥៣ គ្រួសារដ៏កំសត់នេះបានទទួលសំបុត្រមួយច្បាប់ពីលោកតាឃី-តាម ដែលមានសេចក្តីជាអាទិថា ៖

- វៀតមិញសម្លាប់ក្មួយប្រុសបង្កើតរបស់គាត់ឈ្មោះ ឃី-វិញណាម ។ វៀតមិញកាត់ក្បាល កាត់ដៃ កាត់ជើង ជាកំណាត់ៗ ចោលទុកនៅមុខផ្ទះ ។ គ្មានបងប្អូនម៉ែឪឬអ្នកណាម្នាក់ហ៊ានយំឬមើលមុខខ្មោចទេ ។ លុះយប់ងងឹតមកដល់ ទើបតាតាមហ៊ានដើរទៅប្រមូលកំណាត់ខ្មោចយកមកបញ្ចុះនៅក្រោយផ្ទះ ។ ថ្ងៃបន្ទាប់មកទៀត វៀតមិញចូលមកចាប់កូនប្រុសបង្កើតទី៥របស់គាត់ឈ្មោះ ឃី-ថាញ់តោក ។ របៀបវាសម្លាប់ គឺចាប់ចងដៃភ្ជាប់ជាមួយជើងដូចចងជ្រូក ។ រួចវាចងភ្ជាប់ទៅនឹងបង្គោលកំពស់ប្រហែល១០ម៉ែត្រ ។ រួតខ្សែពីលើទម្លាក់ជនរងគ្រោះមកក្រោម រួចទាញឡើងទម្លាក់ចុះ, ទាញឡើងទម្លាក់ចុះជាច្រើនសារ ។ មុននឹងស្លាប់ ថាញ់តោកវេទនាបាក់ឆ្អឹង បាក់ដៃ បាក់ជើង ស្លាប់ក្នុងគំនរឈាមសែនខ្លោចផ្សារកពាក្យសរសេរមិនត្រូវទេ ។

ហេតុដូចម្តេចបានជាវៀតមិញសម្លាប់ឃី-វិញណាម និងឃី-ថាញ់តោកសាហាវម្ល៉េះ ? ។

- ឃួនអតីតវៀតមិញដែលបំរើបារាំងនៅពេលនោះ ជាចារបុរសរបស់វៀតមិញ ។ វាតែងតែនាំកងទ័ពដើរកាត់តាមចំការដូងរបស់តាតាម ស្ថិតនៅភូមិជ្រោយ

ទន្សា ឃុំង៉ែសៀង ។ ពេលវាដើរកាត់ចំការម្ដងៗ វាតែងតែស៊ីផ្លែដូងខ្ចីជានិច្ច ។ ដើម្បីឲ្យបានស៊ីផ្លែ វាយកពូថៅកាប់បំផ្លាញដើម ផ្ដួលមកដី រួចទើបស៊ីផ្លែ ហុតទឹកយ៉ាងថោកទាបជាទីបំផុត ។ ថ្ងៃមួយពួកវាដើរមកកាត់ចំការ ។ កំពុងតែឆ្លេឆ្លារកកាប់ដើមដូង ឃើញដូច្នោះ ឃី-វិញណាមនិងឃី-ថាញ់តោក ក៏ឡើងបេះដូងទម្លាក់ឲ្យពួកវាស៊ី ។ ស៊ីឆ្អែតស្កប់ស្កល់ហើយ ពួកយម្ទបាលអស់នោះក៏ដើរចេញទៅ...ស្រាប់មួយរំពេជក្រោយមក ពួករៀតមិញក៏ចូលមកដល់ ហើយក៏ចោទថាទាំងពីរនាក់នេះក្បត់នឹងវា ។ បន្តបន្ទាប់មក វៀតមិញក៏យករឿងនេះមកធ្វើជាលេសដើម្បីសម្លាប់បំផុតពូជឃី ។ តាតាមក៏សំរេចចិត្តចាកចោលទីលំនៅ ស្រែចំការ មកជ្រកសំណាក់ជាបណ្ដោះអាសន្នក្នុងវត្តខ្មែរឈ្មោះ « ពោធិសាលរាជ ឬវត្តកំពង់ » ដែលស្ថិតនៅកណ្ដាលទីក្រុងត្រាវិញ ។ លោកតានាំកូនប្រុសទី៧ឈ្មោះឃី-ថាញ់ទីអាយុ ១៣ឆ្នាំ និងចៅប្រុសឈ្មោះ ឡាំ-ក្វានបាន អាយុ៨ឆ្នាំ ដែលត្រូវវៀតមិញនាំឪពុកទៅបាត់ឥតដំណឹង ។

លោកគ្រូពេទ្យទ្រីនិងប្រពន្ធទទួលសំបុត្រនេះភ្លាម ក៏សុំច្បាប់ឈប់សំរាក សុំសំបុត្រដើរផ្លូវ រួចចេញដំណើរទៅខេត្តត្រាវិញភ្លាម ។ ពេលទៅដល់ហើយក៏បានជួបឪពុក ប្អូន និងក្មួយដូចសេចក្ដីប្រាថ្នា ។ នៅទីនោះ មានកុមារម្នាក់ឈ្មោះគីម-បូ អាយុ១២ឆ្នាំ ត្រូវជាក្មួយជីដូនមួយអ្នកស្រីទៀង និងយុវជនម្នាក់ទៀតឈ្មោះគិម-សុងទ្រិញ ហៅគីម-រ៉ែន អង្វរសុំជួយអនុគ្រោះផង ព្រោះពួកខ្លួនត្រូវវៀតមិញបំរុងបញ្ជូនទៅប៉េកាំងឆាប់ៗនេះហើយ ។ លោកគ្រូពេទ្យទ្រីក៏សំរេចនាំយកមកកាន់ខេត្តបាត់ដំបងទាំងអស់ ។ នឹកៗទៅគួរឲ្យអាសូរតាតាមណាស់ នៅពេលដែលគាត់គេចចេញផុតពីគ្រោះថ្នាក់មកដល់បាត់ដំបងហើយ ទើបគាត់នឹកឃើញ «យំ» ។ គាត់យំហើយយំទៀតដើម្បីបន្ធូរទ្រូង ។ ព្រោះគាត់ឃើញផ្ទាល់ភ្នែក នូវការកាប់សម្លាប់របស់វៀតមិញទៅលើកូននិងក្មួយគាត់យ៉ាងសាហាវព្រៃផ្សៃជាទីបំផុត ។ នៅពេលនោះគាត់ភ័យស្លន់ស្លោ ភ្លេចគិតយំ គាំងមាត់ គាំងក និយាយស្ដីលែងចេញ ។ មានស្រីៗជាច្រើននៅពេលនោះ ដែលត្រូវវៀតមិញសម្លាប់ប្ដី កូន ក៏ស្ថិតនៅក្នុងលក្ខណៈដូចគ្នានិងតាតាមនេះដែរ ។

ចំណែកយាយទៀងក៏អញ្ចឹងដែរ បន្ទាប់ពីទទួលការរុកគួនរបស់វៀតមិញមករត់មកជ្រកកោននៅកម្ពុជាកណ្ដាលវៀតមិញ ចាត់គ្នាតាមព្យាបាទរហូតមកដល់សម័យអង្គការ និងរបបអាយ៉ងយួន, ក្នុងកំឡុងពេល៨ឆ្នាំគត់, គាត់ទទួលទុក្ខថែមត្រួតលើទុក្ខរាល់ថ្ងៃ ។ ការតក់សលុត ស្លន់ស្លោ ធ្វើឲ្យគាត់គ្មានពេកយំ ធ្វើឲ្យគាត់ឈប់ចេះយំ ។ លុះមានវាសនាបានមកដល់ប្រទេសទី៣ គាត់មានឱកាសសរសេរប្រវត្តិសាស្ត្រដ៏ជូរចត់និងពិតជាក់ស្ដែងឥតបំផ្លើសនេះ ។ នៅត្រង់វគ្គនេះគាត់ត្រូវឈប់

អង្គុយយំសិន យំទាល់តែអស់ចិត្ត ទើបគាត់ចាប់សរសេរតទៅទៀត ។

❑ ❑
❑

# យួនវៀតមិញបោកខ្មែរកម្ពុជាក្រោម

ថ្ងៃទី២១-៥-៤៩ បារាំងសំរេចប្រគល់ទឹកដីខ្មែរកម្ពុជាក្រោមឲ្យម្ចាស់ដើមវិញ។ ខ្មែរកម្ពុជាក្រោមគ្មានអ្នកចេះដឹងដឹកនាំតវ៉ានឹងគេ ដូច្នេះទឹកដីកម្ពុជាក្រោមត្រូវធ្លាក់ក្នុងកណ្តាប់ដៃយួន ដោយស្របច្បាប់ជាលើកទី២ ។

រឿងនេះបារាំងគ្មានកំហុសទេ ព្រោះកាលណោះបើរាជការខ្មែរបានទឹកដីកម្ពុជាក្រោមពីបារាំង គេអាចប្រៀបបានទៅនឹងសត្វស្វាដែលបានផ្លែដូងអញ្ចឹងដែរ ។ ទឹកដីកម្ពុជាក្រោមស្ថិតនៅក្រោមការត្រួតត្រារបស់បារាំង អស់រយៈពេលជិតមួយសតវត្ស ។ តែរាជការខ្មែរសោះអង្គើយមិនរវល់ខ្វល់នឹងរៀបចំគំរោងផែនការដើម្បីគ្រប់គ្រងទាល់តែសោះ ។

ផ្ទុយទៅវិញ យួនមានផែនការរបស់វា ដោយគ្រោងទុកតាំងពីឆ្នាំ១៩៤៥មកម្ល៉េះ

★ មុនដំបូងវាចាត់ការសម្លាប់ និងកំចាយរាស្ត្រខ្មែរកម្ពុជាក្រោម ជាពិសេសអ្នកចេះដឹងឲ្យស្លាប់អស់ ។ អ្នកដែលនៅសល់ពីស្លាប់ ក៏រត់ខ្ចាត់ខ្ចាយចោលស្រុករប៉ាត់រប៉ាយខ្លោចផ្សា ។

★ បន្ទាប់មក វារៀបចំរបៀបគ្រប់គ្រងដោយបំបែកជាក្រុមៗ ។ វាដឹងថាក្រុមនេះត្រូវធ្វើនេះ ក្រុមនោះត្រូវធ្វើនោះ ។

ព្រោះហេតុដូចនេះហើយ បានជានៅពេលដែលបារាំងដកថយពីកម្ពុជាក្រោមភ្លាម វាមានគ្នាវាពេញគ្រប់ក្រសួង ។ រួចហើយវាក៏អនុវត្តផែនការកំទេចខ្មែរកម្ពុជាក្រោមតទៅទៀត ។

ដើម្បី«តបស្នងសងគុណា» ដែលខ្មែរបានជួយវាកំទេចដេញបារាំង យួនវៀតមិញក៏ប្រមូលខ្មែរកម្ពុជាក្រោមដែលជាសមាជិកសមាគមមិត្តភាពខ្មែរ-យួនទាំងអស់រួចនាំយកទៅទុកឲ្យស្លាប់ចោលផ្ទឹងនៅហាណូយ មានលោកសឺង-ភឿករតន៍ និងលោកឡាំ-ថៃជាដើម ។ រួចហើយវាលប់បំបាត់ឃ្លា «សមាគមមិត្តភាពខ្មែរ-វៀតណាម»ភ្លាមកុំឲ្យបែកការណ៍ ។ តែវារក្សាឃ្លានេះទុកនាំយកមកប្រើ ដើម្បីបោកខ្មែរនៅកម្ពុជាកណ្តាលមួយលើកទៀត ។

★ ដូចយើងឃើញស្រាប់ហើយថា បន្ទាប់ពីបានចូលមករាតត្បាតក្នុងស្រុកខ្មែរ ដោយដាក់បន្ទុកអាយ៉ងវារួចស្រេចបាច់ក្នុងថ្ងៃ៧-១-៧៩, នៅថ្ងៃ១៨-២-៧៩ យួនហាណូយកុម្មុយនិស្តក៏នាំឃ្លា«មិត្តភាពវៀតណាម-កម្ពុជា» មកឡើងវិញភ្លាម ដើម្បីបោកខ្មែរម្ដងទៀត ។ ប្លែកតែពាក្យមួយម៉ាត់គឺវាថា «កម្ពុជា» ជំនួស «ខ្មែរ» តែប៉ុណ្ណោះ ។

ដើម្បី «តបស្នងសងគុណ» រាស្ត្រខ្មែរកម្ពុជាក្រោមដែលខំធ្វើស្រែ ធ្វើចំការ ចិញ្ចឹមសត្វ រួចបង់ពន្ធ (Nguyêt Phi) ឲ្យវានោះ, វាបិទសាលារៀនជាភាសាខ្មែរភ្លាម។ បន្ទាប់មកទៀត វាចេញប្រកាសបិតគ្រប់ទីកន្លែងថា ជនជាតិខ្មែរទាំងអស់ ជាជនជាតិយួន ទោះបីអ្នកណាចេះឬមិនចេះភាសាយួនក៏ដោយ ។ រឿងនេះព្រះសង្ឃខ្មែរកម្ពុជាក្រោម បានធ្វើបាតុកម្មប្រឆាំងយ៉ាងខ្លាំងក្លាណាស់ ។

ផែនការទី១របស់វាបានសំរេចដូចបំណង ។ រួចហើយនៅខែមិនា១៩៥៨ វាក៏ប្រែឈ្មោះពីវៀតមិញថាជាវៀតកុងទៅវិញ តែវាជាក្រុមដដែល ជាយួនហាណូយដដែល ដែលធ្វើតាមបញ្ជាផែនការរបស់ហូ-ជីមិញទាំងអស់ ដើម្បីនិងវាតទីយកទឹកដីកម្ពុជាកណ្ដាលតទៅទៀត ។

ក្រោយពីសឹង-ង៉ុកមិញបង្កើតបានខ្មែរវៀតមិញនៅថ្ងៃទី១៩ និងទី២៨ ខែមិថុនា ១៩៥១មក, នៅថ្ងៃ២០-៩-៥២ ហូ-ជីមិញបានប្រកាសជាឧឡារិកនិងដាច់ណាត់ដើម្បីជាបណ្ដាំថា ៖

គោលជំហរយុទ្ធសាស្ត្ររបស់យើង គឺត្រូវយកវៀតណាមឲ្យបានទាំងមូល ព្រមទាំងប្រទេសលាវ និងប្រទេសខ្មែរ ចាប់តាំងពីមាត់ទ្វារនៃប្រទេសចិនភាគខាងត្បូង រហូតទៅដល់ជ្រោយទឹកខ្មៅ, ពីជួរភ្នំឥណ្ឌូចិនប៉ែកខាងកើត រហូតទៅទល់ត្រើយទន្លេមេគង្គ ( **Notre objectif stratégique est de reprendre tout le Viêt Nam, le Laos et le Cambodge, de la porte de la Chine à la pointe de Camau, de la côte de l'indochine aux rives de Méking** ) ។

ព្រោះហេតុនេះហើយបានជាទាំងវៀតមិញ ទាំងវៀតកុង ទាំងខ្មែរអាយ៉ងដែលជាអតីតខ្មែរវៀតមិញ វាខំប្រឹងប្រែងអនុវត្តតាមបណ្ដាំនេះ ។ ក្នុងកំឡុង២០ឆ្នាំ វាបង្កើតបានឈ្មោះ «អង្គការអនាមិក» ដែលមានសភាពខ្មោងងឹតអន្ធកាជាមេបញ្ជាការរបស់វា ។ អង្គការឥតរូបរាងទេ តែអង្គការមានឥទ្ធិពលយ៉ាងខ្លាំងក្លា អាចប្រមូលកលល្បិចរបស់យួនវៀតមិញ ដែលវាបានសាបព្រួស ដើម្បីសម្លាប់និងកំចាយខ្មែរនៅកម្ពុជាក្រោមពីឆ្នាំ១៩៤៥ដល់១៩៥៨ នោះយកមកអនុវត្តនៅកម្ពុជាកណ្ដាលទៀត ដោយគ្រាន់តែកែទម្រង់បន្តិចបន្តួចប៉ុណ្ណោះ ។ វាអាចសម្លាប់ខ្មែរអ្នកចេះដឹងសឹងតែអស់រលីងទៅហើយ ចំណែកឯអ្នកនៅរស់ក៏រស់ទាំងវង្វេងវង្វាន់

ភាំងភ័គ្គស្មារតី ។

ស្រាប់តែឥឡូវនេះ វាលេចចេញមុខយួនហាណូយជាបូជួយច្បាស់ក្រឡែត ដើរដោយសេរី ធ្វើព្រងើយកណ្តាលព្រៃនៃប្រទេសខ្មែរដូចយើងបានឃើញផ្ទាល់ភ្នែកនេះ ។

យាយទៀងអធិប្បាយមកដល់ត្រឹមហ្នឹង គាត់ក៏ថ្ងូរដំអូញថា ៖ បណ្តាលមកពីយួនហាណូយជាវៀតមិញរករឿងសម្លាប់កំចាយខ្មែរកម្ពុជាក្រោមនេះហើយ ដែលខ្ញុំមិនអាចទ្រាំនៅស្រុកកំណើតបាន ។ ខ្ញុំត្រូវតែនាំប្អូនៗនិងក្មួយៗ ចាកចោលទឹកដីកម្ពុជាក្រោមដែលជាកេរ្តិ៍មរតកពីដូនតា ទុកឲ្យវាកាន់កាប់ ។ ខ្ញុំត្រូវតែគេចខ្លួនមកសំណាក់នៅកម្ពុជាកណ្តាលដោយបាតដៃទទេ ។ ប្រាក់បៀវត្សរ៍បន្តិចបន្តួចយើងខំសន្សំសំចៃដើម្បីបង់ឈ្នួលផ្ទះនិងថ្លៃម្ហូបតែប៉ុណ្ណោះ ។ ក្រៅម៉ោងរៀននិងធ្វើការយើងនាំគ្នាដើររករបរក្រៅផ្សេងៗរួបថែមលើប្រាក់ខែ ។ លទ្ធផលបានមកជាទីគាប់ប្រសើរ ដែលគួរឲ្យសរសើរដល់កូនខ្មែរកម្ពុជាក្រោមទាំងនោះណាស់ ។ គ្នាខំតស៊ូរៀនសូត្រលុះត្រាតែបានមុខងារដ៏សមរម្យរៀងៗខ្លួន ។

- គឹម-ច័ន្ទ ជាសាស្ត្រាចារ្យបង្រៀនភាសាបារាំង (ត្រូវអង្គការសម្លាប់) ។

- គឹម-សុងទ្រិញ ហៅគឹម-រ៉េន ជាសាស្ត្រាចារ្យជាន់ខ្ពស់ និងជាលេខាធិការទូតទី២ នៅស្ថានទូតអារ៉ាប់ ( ត្រូវអង្គការចាប់ខ្លួនទាំងប្តីទាំងប្រពន្ធ បញ្ជូលគុកទួលស្លែងនៅថ្ងៃទី១៥-៦-៧៧ រួចបាត់ខ្លួនរហូតមក ) ។

- យី-ថាញ់ទី ជាវិស្វករខាងលោហធាតុ បានបន្តវិជ្ជានៅសហរដ្ឋអាមេរិកនិងប្រទេសជប៉ុន (បាត់ខ្លួន) ។

- គឹម-វណ្ណា ជាអ្នកបច្ចេកទេសខាងថតរូបទូរទស្សន៍និងភាពយន្ត ធ្វើការនៅការិយាល័យអ្នកនាំពាក្យនៃរដ្ឋាភិបាល ( Porte-parole du gouvernement ) ។

- គឹម-បូ ជាអនុសេនិយឯក ធ្វើការនៅខេត្តកោះកុង ( ត្រូវអង្គការសម្លាប់ ) ។

- ឡាំ-ក្វានបាន ជាអនុសេនិយទោកងទ័ពម៉ារីននៅមូលដ្ឋានជ្រោយចង្វារ ( បាត់ខ្លួន ) ។

ចំណែកឯគ្រួសារខ្ញុំ យើងមិនព្រងើយកន្តើយឡើយ ។ យើងសន្សំប្រាក់ទិញស្រែចំការ ទិញដីភូមិ ដាំដំណាំ ដាំដើមឈើស៊ីផ្លែ ។ យើងចិញ្ចឹមមាន់ទាជ្រូក ។ យើងមានជីកស្រះធំចិញ្ចឹមត្រី ។ រាល់ៗពេលយើងខំប្រឹងធ្វើការ ។ ពេលយប់យើងបូមទឹកស្រោចដំណាំនិងដើមឈើ, ពេលព្រឹកមុននឹងចេញទៅធ្វើការខ្ញុំឲ្យចំណីមាន់ទាជ្រូក ។ ឆ្លៀតពេលវ៉ាកង ខ្ញុំទៅរកមនុស្សធ្វើស្រែ ។ ក្នុងរយៈពេល២០ឆ្នាំគ្រួសារយើងមានទ្រព្យសម្បត្តិដ៏ស្តុកស្តម្ភ ឥតមានខ្វះខាតអ្វីឡើយ ។

ឥឡូវនេះឆ្នាំ១៩៧៩ យួនហាណូយដដែលជាវៀតកុង លួចបន្លំជ្រកក្នុងទីងងឹ

តប្រើឈ្មោះអង្គការ, ខ្ញុំត្រូវរងគ្រោះម្តងទៀតយ៉ាងធ្ងន់ ។ ខ្ញុំត្រូវព្រាត់ប្តី ព្រាត់កូនៗ ព្រាត់ក្មួយៗ ។ល។

មើលចុះ ! គឹម-ច័ន្ទជាសមាជិកបក្សខ្មែរក្រហមរបស់ខៀវ-សំផន, ជាសហការីរបស់មិត្តស៊ូ ត្រូវអង្គការសម្លាប់នៅខែតុលា១៩៧៦ ។ បើសមាជិកខ្មែរក្រហមដែ-លគ្មានកំហុសអ្វីសោះនោះ ត្រូវអង្គការសម្លាប់ទៅហើយ ចុះទំរាំតែអ្នកដែលមិនមែនជាខ្មែរក្រហមវិញ តើវាសនាអ្នកទាំងនោះនឹងទៅជាយ៉ាងណាទៅវិញ ? ។

- ចំណែកឯទ្រព្យសម្បត្តិរបស់ខ្ញុំដែលខំកសាងសន្សំមកតាំងពី២០ឆ្នាំនោះ ក៏ត្រូវម៉ដ្ឋអស់រលីងជាលើកទី២ ។ ឥឡូវនេះខ្ញុំនៅសល់តែបាតដៃទទេម្តងទៀតហើយ ចុះបើខ្ញុំអាយុជាង៥០ឆ្នាំទៅហើយ តើឲ្យខ្ញុំធ្វើយ៉ាងម៉េចទៅ ? ។

និទានដល់ត្រឹមហ្នឹង យាយទៀងតឹងបេះដូង តាំងចំពង់កដោយឈឺចាប់ ខឹងនឹងយួនហាណូយ គាត់ដួលប្រួសទៅលើដី ដេកស្តូកស្តឹងនៅមួយកន្លែង ។

ពេលនោះ នាងយី-ទ្រីរ៉ាជាភ័យស្លន់ស្លោរត់ទៅឱបម្តាយទាំងយំហ៊ឹ...ហ៊ឹ ! ។ ឆ្នាំនេះរ៉ាជាអាយុបាន២៩ឆ្នាំហើយ ។ នាងជាអតីតនិស្សិតវេជ្ជបណ្ឌិត ។ តាំងពីដឹងក្តីកាលណាមក នាងតែងតែឃើញឪពុកម្តាយសំណាក់នៅខាងក្រោយវត្តវំដួល ក្រុងបាត់ដំបង ក្នុងភូមិគ្រឹះដ៏ធំស្កឹមស្កៃមួយ ដែលសម្ងំនៅកណ្តាលចំការផ្លែឈើគ្រប់មុខ ។ ខាងក្រោយផ្ទះ មានស្រះបីធំៗ ។ មានកន្លែងចិញ្ចឹមសត្វ និងមានស្រែចំ-ការជាច្រើនទៀត ។ គាត់មានការងារធ្វើដ៏សមរម្យ មានរថយន្ត Peugot 404 លេខ ភ.ព.៤២៩២ សំរាប់ជិះទៅធ្វើការយ៉ាងមនោរម្យ ។

រ៉ាជាមិនដែលឮម្តាយឬឪពុកនាងនិទានរឿងដ៏កំសត់ឈឺចាប់នេះទាល់តែសោះ ។ នាងក៏ឱបម្តាយយំហើយយំទៀត នឹកអាណិតម្តាយមិនគួរអីមកធ្លាក់ខ្លួនដល់ថ្នាក់ហ្នឹងសោះ ។ ពេលនោះថ្ងៃក៏រះល្មម !

❏ ❏

❏

# ជំពូកទី១៩

យាយទៀងក៏លើកអំរែកទ្រព្យសម្បត្តិ ដែលគាត់ខំប្តូរជីវិតលួចលាក់ទុកយ៉ាងលំបាក ( ទ្រព្យនេះបើអាទមិឡឃើញ វាសម្លាប់គាត់ចោលភ្លាម ) ដាក់លើស្មា រួចបណ្តើរមិត្តភក្តិតាមផ្លូវស្របមាត់ស្ទឹង ចូលកាន់ទីប្រជុំជនស្រុកមោងឫស្សី ។ ដើរបណ្តើរយាយទៀងគយគន់បណ្តើរមើលទេសភាពនៃចំការផ្លែឈើគ្រប់ជំពូកមានដូង ស្វាយ ល្មុត ខ្នុរ មៀន ដើមទឹកដោះគោ ក្រូចគ្រប់ធុន ដែលដុះនៅជាប់ជិតមាត់ស្ទឹង ដែលត្រូវឆេះខ្លោចសល់តែដើម វិនាសហិនហោចដោយចំបាំងគួរឲ្យស្តាយ ។ ផ្ទះនិងភូមិគ្រឹះធំៗ ត្រូវពួកអាទមិឡរុះរើដឹកនាំចេញអស់រលីង ។ សល់តែជណ្តើរធ្វើពីអិដ្ឋនិងកំទេចអិដ្ឋ ។ យាយទៀងមានអារម្មណ៍នឹកឃើញបក្សខ្មែរក្រហមរបស់ខៀវ-សំផន ធ្វេសប្រហែសត្រូវចាញ់បោកអង្គការអនាមិកធ្ងន់សែនធ្ងន់ គ្មានកសាងជាតិអ្វីទាល់តែសោះ គិតតែពីបំផ្លាញនិងសម្លាប់ជាតិខ្លួន ទីបញ្ចប់ក្រុមខ្មែរក្រហមដ៏ឆ្កួតលីលានេះ ត្រូវអង្គការបញ្ឆោឲ្យសម្លាប់ចោលខ្ទេច ។ ចំណែកប្រជាពលរដ្ឋខ្មែរក្នុងមួយនគរ ដែលសេសសល់នៅរស់ត្រូវអង្គការច្បូតយកទ្រព្យសម្បត្តិអស់រលីង គ្រប់ៗគ្នាសល់តែបាតដៃទទេ ទីបញ្ចប់ត្រូវអង្គការកៀរដើរពាសព្រៃស្មើរស្លាប់ស្មើររង្វេង ។

យាយទៀងរវើរវាយនឹកដល់ត្រឹមហ្នឹង ស្រាប់តែប្អូនស្រីរបស់គាត់ស្រែកប្រាប់ថា ៖ ម៉ាក់អើយ ! យើងចូលសំរាកក្នុងចំការផ្លែឈើខាងឆ្វេងដៃ យើងបបរហូបសិន ។ ស្រីៗទាំង១៥នាក់ក៏បណ្តើរគ្នាចូលកាន់ចំការដ៏ធំល្វឹងល្វើយ មានដើមឈើស៊ីផ្លែគ្រប់មុខប៉ុន្តែសល់តែដើម មែកនិងស្លឹកស្វិតក្រញង់ៗ ។ ពេលនោះរ៉ាដាវាល់អង្ករពីរកំប៉ុងកន្លះបបរចែកគ្នាហូប ។ ស្រីៗទាំង១៥នាក់កំពុងហុតទឹកបបរស្រាប់តែឮមនុស្សច្រៀងបទហូ-ជីមិញត្រង់ឃ្លា « អូនៗសង្ឃឹមថាអុំហូអាយុមួយម៉ឺនឆ្នាំ » ។

យាយទៀងបែរភ្នែកសម្លឹងមិត្តៗរបស់គាត់មួយសន្ទុះ រួចក៏ដាក់ចានបបរចុះព្រមទាំងនិយាយថា ៖ « ខ្ញុំទៅមើលនរណាច្រៀងបទហ្នឹង » ។ យាយទៀងដើរតម្រង់សម្លេងនោះ ។ អុញគាត់ភ្ញាក់ស្រឡាំងកាំង ដោយឃើញបួដួយក្មេងៗបីនាក់នៅលើដើមឈើ បីនាក់ផ្សេងទៀតឈរនៅនឹងដីកំពុងបញ្ចេញសកម្មភាពបន្តខ្សែលួស ។ បួដួយទាំងនោះមានអាយុយ៉ាងច្រើន១៨ឆ្នាំប៉ុណ្ណោះ ។ យាយទៀងនិយាយទៅកាន់បួដួយថា ៖

- គោរពកូនៗ កូនៗសុខសប្បាយទេឬ ? កូនៗធ្វើអីហ្នឹង ? ។

បូជ្ជយបង្ហាញអាកប្បកិរិយាភ្ញាក់ផ្អើលក៏សួររបៀបខុសទំនងថា ៖

- ម៉ែ ! ម៉ែធ្វើម៉េចងាកផុតពីស្លាប់ ? ពីព្រោះអង្គការត្រូវតែសម្លាប់ឃួនដែលកើតនៅស្រុកខ្មែរ ហើយដែលមិនព្រមទៅតាមវៀតកុងឲ្យអស់ ។ បូជ្ជយម្នាក់នៅក្បែរនោះធ្លាក់ទឹកមុខ ក៏ឆ្លើយកែតម្រូវថា ៖

- ពួកកូនមិនស្មានទាល់តែសោះថាមានឃួនសល់នៅរស់...

យាយទៀងមានអារម្មណ៍សង្ស័យនូវអាកប្បកិរិយានេះ គាត់សង្ស័យក៏បង្វែងជានសួរថា ៖

-តើកូនៗធ្វើអ្វី ? ។

- ក្រុមយើងកំពុងបន្តខ្សែលួស ពីទីប្រជុំជនស្រុកមោងឫស្សីទៅកាន់ភូមិនានាដូចជាស្រែអូរ ចាមល្អា ជាដើម ។

យាយទៀងឈរសម្លឹងកាយវិការរបស់កូនឃួនហាណូយទាំង៦នាក់ក្មេងៗមានកាំភ្លើងដៃតែ៣ដើម កំពុងបំពេញបេសកកម្មបន្តខ្សែលួសដោយសេរីកណ្ដាលព្រៃស្ងាត់ក្នុងប្រទេសកម្ពុជាមិនទំនងយ៉ាងនេះ គាត់ចង់ស្រែកសួរឲ្យបែកមេឃបែកដី បែកព្រៃព្រឹក្សាថា តើអង្គការរវល់ទៅណា ? តើខ្មែរក្រហមគ្រប់ៗក្រុមស្លាប់តែហោងអស់ទៅហើយឬ ? ហេតុម៉េចក៏ចាញ់ឥទ្ធិពលអាកូនឃួនហាណូយតែ៦នាក់ក្មេងៗមិនទំនងយ៉ាងនេះ ? ។ យាយទៀងគ្រវីក្បាលរួចសុំលាបូជ្ជយវិលត្រឡប់ទៅជួបមិត្តៗរបស់គាត់ ។

ពេលនោះក៏ឃើញអ្នកស្រីបូរីដើរតម្រង់មករកគាត់ ព្រមទាំងលើកដៃចង្អុល ។ យាយទៀងក្រឡេកភ្នែកសម្លឹងតាមដៃចង្អុលនោះ គាត់ឃើញនៅលើថ្នល់មានរទេះគោ២ផ្ទុកសុទ្ធតែលួស មានបូជ្ជយ៤នាក់មានកាំភ្លើងដៃ២ដើមកំពុងបររទេះចៀសចេញពីផ្លូវ ដើម្បីឲ្យឡានមួយគ្រឿងបើកបរឆ្លងកាត់ ។ គឺឡានដែលជាប់ផុងកណ្ដាលស្ទឹងនៅភូមិអន្លង់កូប ពីម្សិលមិញនោះឯង ។ ថ្ងៃនេះឡាននេះត្រឡប់វិលមកវិញមានខ្មែរក្រហមនិរតីចំនួន៣០នាក់ មានស្រីមានប្រុសជិះជាមួយបូជ្ជយមុខញញឹមរីករាយ ។

ពេលនោះរាស្ត្រខ្មែរបានឃើញខ្មែរនិរតីជិះឡានជាមួយបូជ្ជយ ក៏មានគំនិតយល់ផ្សេងៗខុសគ្នា ។

- មានរាស្ត្រខ្មែរមួយភាគដែលពិចារណាមិនជិតដល់ ក៏ទះគូថស្រែកដោយត្រេកអរ ។ ពីព្រោះយល់ច្រឡំយ៉ាងធ្ងន់ស្មានតែខ្មែរក្រហមនិរតី៣០នាក់នេះត្រូវបូជ្ជយចាប់ ។

- មានមួយភាគទៀតដូចក្រុមយាយទៀងជាដើម កេះគ្នាឈរសម្លឹងគ្រប់ៗគ្នា

តូចចិត្តធ្វើមុខស្ងួត ពីព្រោះយល់ថាជាកលល្បិចថ្មីមួយទៀត របស់យួនហាណូយ វាបើកបរទ្បានប្រមូលខ្មែរនិរតីនាំយកទៅចិញ្ចឹមបំពាក់គោលជំហរតាមផែនការថ្មី បំពាក់អាវុធឲ្យឡើងវិញ ប្រែឈ្មោះថ្មីរួចបញ្ចេញឲ្យស៊ីសាច់ហុតឈាមរាស្ត្រខ្មែរជំនួសវាតទៅទៀត ។ ថ្ងៃ២២មេសា១៩៧៩ ម៉ោង២រសៀល ក្រុមយាយទៀងបណ្ដើរគ្នាបន្តដំណើរចូលកាន់ទីប្រជុំជនស្រុកមោងឫស្សី ។ យាយទៀងតែងតែគយគន់មើលទេសភាពស្របបណ្ដោយដងផ្លូវ ឃើញចំការផ្លែឈើគ្រប់ធុនដែលចោលគ្នានៃនរណាថែទាំក្នុងរយៈពេលបួនឆ្នាំក៏ស្វិតស្រពោនជាំពាសពេញ ។ ចំណែកផ្ទះកន្លែងណាក៏ដូចកន្លែងណា ឃើញសល់តែកំទេចឥដ្ឋនិងផេះគួរឲ្យស្ដាយសែនស្ដាយ...

យាយទៀងក៏រអើរវាយនឹកឃើញពីយប់ថ្ងៃទី២៨ កុម្ភៈ ១៩៤៨ គាត់ទើបអាយុ ២០ឆ្នាំ គាត់បានអង្គុយស្ដាប់ង្វៀង-វ៉ាន់ទិញជាមេវៀតមិញពន្យល់ថា បើធ្វើសង្គ្រាមជាមួយខ្មែរ គឺយួនត្រូវប្រើមធ្យោបាយទើបឈ្នះ ។ យើងត្រូវប្រើកលល្បិចបំបែកបំបាក់ញ៉ាំងឲ្យយល់ច្រឡំកាប់ចាក់សម្លាប់គ្នា ធ្វើឲ្យអស់សង្ឃឹម រួចសឹមយើងចេញមុខបង្ហាញថា យើងមកជួយធ្វើឲ្យមានសង្ឃឹមឡើងវិញ ។

បច្ចុប្បន្ននេះត្រូវមែន ដូច្នេះយួនហាណូយមិនងាយបោះបង់ចោលគំនិតលេបយកកម្ពុជាឡើយ ។ យួនហាណូយត្រូវតែពន្យាពេលឲ្យយូរ ដោយខ្ចីដៃអាយ៉ងពីមួយទៅមួយទៀត ឲ្យបាញ់កាប់សម្លាប់តែគ្នាឯងវក់វីតទៅទៀត ។

នៅពេលដែលនាងទៀងរត់មកដល់ប្រទេសកម្ពុជា នាងតែងតែរ៉ៃកញ្ឆេកប្រាប់រៀមច្បងអំពីឧបាយកលរបស់យួនវៀតមិញ ដែលនាងបានអង្គុយស្ដាប់ដោយផ្ទាល់ត្រចៀក នូវអត្ថាធិប្បាយរបស់ង្វៀង-វ៉ាន់ទិញ តាំងពីឆ្នាំ១៩៤៨មកម្ល៉េះ ។ ប៉ុន្តែគ្មានបងៗណាម្នាក់យកចិត្តទុកដាក់ស្ដាប់ឡើយ ។ នាងទៀងខំពន្យល់បង្ហាញអក្សរពិសេសដែលវៀតមិញឆ្នៃប្រឌិតដាក់ឈ្មោះភូមិ, ឃុំ, ស្រុក, ខេត្ត, នគរនៃប្រទេសខ្មែរ សំរាប់ចារកិច្ចរបស់វាប្រើ ។ ឧទាហរណ៍ ៖

A -> កម្ពុជា, A+B -> ភ្នំពេញ, A+B1 -> បាត់ដំបង, A+B1+A -> ស្រុកសង្កែ A+B1+A1 -> ឃុំស្វាយប៉ោ, A+B1+A2 -> ឃុំអន្លង់វិល ។ល។

ក្នុងឆ្នាំ១៩៧៣ ផ្នែកសឹកខេត្តបាត់ដំបងចាប់បានបូដូយជាយួនហាណូយម្នាក់ អាយុ១៨ឆ្នាំ ជាក្រុមកាំភ្លើងធំ ។ ពេលនោះលោកវរៈសេនិយឯក វ៉ន-ស្វាង ជាអ្នកទទួលខុសត្រូវសួរចម្លើយបូដូយនេះ បានសុំពឹងយាយទៀងជួយពិនិត្យសៀវភៅដែលនៅជាប់នឹងខ្លួនវា ( នៅក្នុងសៀវភៅនោះមានអក្សរសម្ងាត់ដូចដែលបានរៀបរាប់នៅខាងខាងលើស្រាប់ ) ។ ឆ្លៀតពេលដ៏ល្អនោះ យាយទៀងខំរ៉ៃកញ្ឆេកនូវកលល្បិចនិងផែនការរបស់យួនហាណូយជាវៀតមិញដាក់ទិស ត្រូវតែវាតទីយក

ទឹកដីកម្ពុជាឲ្យបានបញ្ចូលក្នុងសហព័ន្ធឥណ្ឌូចិន ។ ប៉ុន្តែពេលណាក៏ដូចពេលណាដែរ នៅពេលដែលយាយទៀងខំពន្យល់ពីរឿងនេះ អស់លោកទាំងនោះតែងតែសើចកាច់កកាច់ស្រង់រួចឆ្លើយថា ៖

« យួនហាណូយជាវៀតមិញក្ដីជាវៀតកុងក្ដី វាយលសប្ដិទេតើ ! តើវាធ្វើអីយើងកើត បើសព្វថ្ងៃវារកតែបាយស៊ីគ្មានផង ! » ។

មានលោកខ្លះធ្វើឫកក្រអឺតសំឡក់សំឡឹងយាយទៀង ពីក្បាលដល់ចុងជើង មើលងាយពេបជ្រាយឆ្លើយរបៀបស្ដីបន្ទោសថា ៖

« ហ៊ឺ ! បងឯងឲ្យតម្លៃយួនហាណូយណាស់ ! » ។

គួរឲ្យស្ដាយអស់លោកទាំងនោះណាស់ ដោយមិនដឹងទាល់តែសោះថា យួនហាណូយមានពាក្យមួយឃ្លាថែងថា ៖

« បើសិនជាអ្នកមិនទៅវាយសឹកនៅកម្ពុជា អ្នកនឹងដាច់ពោះស្លាប់ – តែបើអ្នកទៅយកបាយរបស់កម្ពុជា អ្នកនឹងមានភ័ព្វវាសនា អាចរស់នៅជាបន្តទៅទៀត ! » ( Si tu ne va pas te battre au Kampuchea, tu mourras de faim ! Si tu y va prendre son riz, tu auras de chance de survivre ) ។

ចំណែកយាយទៀងគាត់យល់ថា បងៗខ្មែរចិត្តរាយមាយណាស់ ខ្មែរមើលងាយសត្រូវ មើលងាយអ្នករាយការណ៍ហួសហេតុយ៉ាងនេះ គាត់ក៏បោះបង់ឈប់នឹកនារហូតមក ។

ឥឡូវមានឈ្មោះអង្គការអនាមិក អាចប្រានក្បាលខ្មែរក្រហមគ្រប់និន្នាការឲ្យនាំកលល្បិចរបស់ហូ-ជីមិញ យកមកសាបព្រួសពាសពេញប្រទេសខ្មែរ ក្នុងរយៈពេលតែបួនឆ្នាំ ញ៉ាំងឲ្យនគរខ្មែរទាំងមូលដែលសំបូរដោយសុភមង្គល ដោយទ្រព្យធនធាន ឲ្យរលាយទៅជាផេះ ។ ខ្មែរកំពុងអស់សង្ឃឹម ស្រាប់តែយួនហាណូយជាវៀតណាមចូលមកជួយឲ្យមានសង្ឃឹមឡើងវិញ ។

កំពុងរវើរវាយនឹកឃើញរឿងអតីតកាល ស្រាប់តែមានអ្នកស្រែកឡើងថា ៖

« យើងមកដល់ផ្សារស្រុកមោងឫស្សីហើយ » ។

យាយទៀងឮសំដីនេះ ក៏ក្រឡេកភ្នែកសម្លឹងមួយត្រួស គាត់លាន់មាត់ថ្ងូរថា ៖

« ឱទេវតាអើយ ! មើលចុះទីប្រជុំជនស្រុកមួយទាំងមូល សល់តែកំទេចឥដ្ឋនិងផេះ ឃើញតែមេឃនិងដី ។ យាយទៀងបណ្ដើរមិត្តៗរបស់គាត់ដើរកាត់ស្ពានិយរថភ្លើង ក៏ឃើញទូររទេះភ្លើងជាច្រើនឥតគណនាត្រូវអង្គការដុតបំផ្លាញចោល ។ ឆ្ងាយពីទីនោះបន្តិច ខាងស្ដាំដៃមានវត្តបុរាណមួយ ត្រូវអង្គការវាយបំផ្លាញចោលខូចខាតខ្ទេចខ្ទី ។ នៅក្នុងបរិវេណវត្តនោះ ឃើញសុទ្ធតែខ្មោចឡានគ្មានម៉ាស៊ីនគ្រប់ធុនជាច្រើនពាន់គ្រឿងរប៉ាត់រប៉ាយពាសពេញ ។

ស្រីៗមេម៉ាយទាំង១៥នាក់ ក៏បណ្តើរគ្នាដើរវៀងទីនោះមកកាន់ផ្លូវជាតិលេខ៥ ។ ថ្ងៃទី២២-៤-៧៩ ម៉ោងប្រហែល១០យប់ យើងដេកសំរាកលើថ្មីញើមថ្នល់ផ្លូវលេខ៥ខាងស្តាំដៃទៅកាន់ទីក្រុងបាត់ដំបង ។ ដេកផ្ទាល់ដី ពឹងដីជាកន្ទេល ពឹងមេឃជាដំបូល ក្បាលកើយទ្រព្យសំណល់ជាចុងក្រោយបង្អស់ ។ យាយទៀងសម្លឹងមើលរាស្ត្រខ្មែរជាច្រើនសែននាក់ដើរពេញថ្នល់ បាតដៃទទេដូចគេទើបចេញពីរោងកុន ។ ដើរគ្មានទិសដៅទាំងយប់ទាំងថ្ងៃពីមោងឫស្សីទៅបាត់ដំបង ដែលមានចម្ងាយជាង៥០គ.ម. ។ គឺមួយជួរខាងស្តាំ ដើរចូលកាន់ទីក្រុងបាត់ដំបង មួយជួរខាងឆ្វេងដើរចេញពីបាត់ដំបងទៅមោងឫស្សីវិញ ។

ព្រលឹមថ្ងៃទី២៣-៤-៧៩ យាយទៀងបបួលមិត្តៗរបស់គាត់បន្តដំណើរតាមផ្លូវជាតិលេខ៥ទៅកាន់ទីក្រុងបាត់ដំបង ។ ម៉ោងប្រហែល១០ព្រឹក ក្រុមយាយទៀងមកដល់ភូមិ កកោះ គាត់បានឃើញបូដូយ៣នាក់កំពុងតោងបេះផ្លែស្វាយ ។ ខាងជើងបន្តិច ៣នាក់ទៀតនៅក្រោមដើមក្រសាំង មុខញញឹម ឈរផ្ញឹមចង្កេះមើលខ្មែរ «រត់សឹក» ។ បូដូយជាយួនហាណូយក្មេងៗទាំងនេះគ្មានអាវុធទេ ។

នឹកគួរឲ្យសើចគោកមែន ! ហេតុម៉េចកូនយួនហាណូយមានវាសនាមកផ្ញឹមចង្កេះមើលខ្មែរជាម្ចាស់ស្រុក ជាច្រើនសែននាក់កំពុងស្លន់ស្លោភៀសខ្លួនរត់ចេញពីព្រៃ រត់ចេញពីកណ្តាប់ដៃខ្មែរក្រហម បាតដៃទទេគ្រប់ៗគ្នាយ៉ាងនេះទៅវិញ ? ។

យាយទៀងក៏បបួលគ្នាចុះទៅសំរាកក្រោមដើមក្រសាំងនោះដែរ ។ បូដូយក៏សួរថា ៖ តើមានម៉ែណាចេះនិយាយភាសាយួនទេ ? ។ ពេលនោះយាយទៀងគាត់អះអាងថា គាត់ចេះនិយាយយួន ! គាត់ជាជាតិយួន !

បូដូយសំដែងឫកពារដូចជាភ្ញាក់ វាសម្លឹងមុខគ្នាមួយសន្ទុះរួចវានិយាយដូចក្រុមបូដូយមុនដែរ ។ វាសួរយាយទៀងថា ៖

- ហេតុម៉េចម៉ែឯងសល់នៅរស់ ? ពីព្រោះអង្គការត្រូវសម្លាប់អាណិកជនយួនឲ្យអស់ណា ! ។

យាយទៀងមានអារម្មណ៍ឆ្ងល់សែនឆ្ងល់ នូវឫកពារបូដូយទាំងនេះ ។ ប៉ុន្តែគាត់ធ្វើដូចជាត្រេកអរជាក្រៃលែង ដែលបានជួបយួនសាសន៍ជាមួយគ្នា គាត់សុំសួរសេចក្តីសុខទុក្ខពីនេះពីនោះបន្តិច រួចប្រញាប់សុំលាបូដូយបន្តដំណើរទៅមុខទៀត ។ នៅពេលនោះគាត់ឃើញ អាបូដូយម្នាក់គេចទៅជួបគ្នាវាដែលកំពុងបេះស្វាយ ឈរខ្សឹបគ្នាមួយសន្ទុះ រួចក៏បណ្តើរគ្នាទាំងបួននាក់ទៅជួបជុំគ្នាក្រោមដើមក្រសាំង ។ មានបូដូយម្នាក់និយាយទន់ភ្លន់លួងលោមយាយទៀងនិងយី-ទ្រីវ៉ាដា ឲ្យនៅសំរាកជាមួយពួកវាមួយយប់សិន ។ យាយទៀងយល់ថាមិនស្រួលទេ ពីព្រោះឫកពារបូដូយទាំង៦នាក់នេះគួរឲ្យសង្ស័យណាស់ ។ មិនបង្អង់គាត់ក៏សុំលាក្រុមវាចេញដំ-

ណើរភ្លាម ។

ម៉ោងប្រហែល៦ល្ងាច ក្រុមយាយទៀងមកដល់គីឡូម៉ែត្រលេខ៣០ គឺភូមិព្រៃដីរី ចំក្បាលស្រែរបស់គាត់ដែលមានទំហំ២០០ម.x១០០០ម. ។ ពេលនោះយាយទៀងគាត់ស្រែកយំដូចកូនក្មេង យំហូរទឹកភ្នែកជោកថ្ពាល់ គាត់យំហើយយំទៀត ពីព្រោះតាំងពីបីឆ្នាំមកហើយគាត់ភ្លេចយំ គឺចាប់តាំងពីពេលដែលអង្គការបញ្ជាឲ្យខ្មែរក្រហមចូលមកចាប់ចងលោកឃី-វិញទ្រី ជាប្ដីរបស់គាត់នាំយកទៅសម្លាប់ សេចក្ដីតក់ស្លុតរន្ធត់ដ៏ហួសហេតុនេះញ៉ាំងឲ្យយាយទៀងដួលសន្លប់បាត់ស្មារតីជាច្រើនម៉ោង លុះគាត់ភ្ញាក់ដឹងខ្លួនឡើងវិញ គាត់ភ្លេចយំរហូត ។ ទើបថ្ងៃទី២៣-៤-៧៩ នេះស្រាប់តែគាត់នឹកឃើញចេះយំ គាត់យំចេញទឹកភ្នែក គាត់យំបណ្ដើរគាត់និយាយបណ្ដើររ៉ាយរ៉ាប់ប្រាប់មិត្តៗរបស់គាត់បណ្ដើរថា ដីស្រែនេះមានទំហំ២០ហិកតា ជាទ្រព្យដ៏សំឡាញ់របស់គាត់ ។ គាត់រកស៊ីលូតលាស់ដោយសារដីស្រែនេះ ។ ពីសករាជសម្ដេចនិងលោកលន់-នល់ គាត់និងប្ដីតែងតែនាំកូនទាំង៦នាក់ជិះឡានផ្ទាល់ខ្លួនមកកាន់ស្រែនេះសឹងរាល់ថ្ងៃអាទិត្យ នាំគ្រួសារញ៉ាំបាយ ។ កូនទាំង៦នាក់ស្រែកច្រៀងលោតរាំលេងកណ្ដាលវាលល្ហល្ហេវ មហាសែនសប្បាយរីករាយមនោរម្យ ប្រកបដោយសុភមង្គលដ៏បរិបូណ៌ ។ គាត់មិនស្មានទាល់តែសោះថានឹងមានគ្រោះថ្នាក់ដល់នូវវិនាសហិនហោចជាលើកទី២ដូច្នេះឡើយ។ ពេលនោះយាយទៀងលើកដៃចង្អុលវាលស្រែដ៏ធំល្វឹងល្វើយជាប់តាមបណ្ដោយផ្លូវជាតិលេខ៥ ព្រមទាំងធ្វើអត្ថាធិប្បាយថា ៖

- អូនៗមើលចុះប្រទេសកម្ពុជាយើង មិនខ្វះវាលស្រែទាល់តែសោះ មានស្រាប់ៗ មើលដាច់កន្ទុយភ្នែក ហេតុម្ដេចអង្គការទុកចោលឲ្យស្មៅដុះទ្រុបទ្រុលយ៉ាងនេះ ? ហេតុម៉េច អង្គការបែរជាដាក់កំណែនឲ្យខ្មែរទៅលុបបឹង ទៅកាប់ឆ្ការបំផ្លាញព្រៃឈើល្អៗដោយយកលេសថា យកដីធ្វើស្រែទៅវិញ ? ជាពិសេសទៅទៀតកន្លែងទាំងឡាយនោះភាគច្រើនជាកន្លែងគ្រុនចាញ់ ត្រូវឈឺស្លាប់យ៉ាងសាហាវព្រោះគ្មានថ្នាំការពារទាល់តែសោះ ។

យាយទៀងបបួលមិត្តៗរបស់គាត់ដេកសំរាកនៅលើវាលស្រែដ៏កំសត់របស់គាត់មួយយប់សិន ។ យាយទៀងដេកផ្ទាល់ដី ក្បាលកើយភ្លឺស្រែ សំឡឹងមើលមេឃខែចេត្រ ខ្ពស់ត្រដែតខៀវស្រងាត់គ្មានពពក ។ ចិត្តរបស់គាត់នឹកទៅដល់ប្ដីដែលធ្លាប់កំសត់កំរជាមួយគ្នា ។

គាត់នឹកឃើញថា ទម្រាំនឹងរៀនបានជានាយមន្ទីរពិសោធន៍ បងទ្រីត្រូវរៀនអស់ជាច្រើនឆ្នាំ ។ បងទ្រីមិនដែលកាន់កាំភ្លើងតទល់ចំពោះគូបដិបក្ខណាទាល់តែសោះ ។ បងទ្រីថែទាំតែអ្នកជម្ងឺនៅមន្ទីរពេទ្យធំបាត់ដំបងតាំងពីឆ្នាំ១៩៥១ដល់១៩

៧៥ ។

អ្នកស្រុកនៅក្រុងបាត់ដំបង ភាគច្រើនទាំងខ្មែរទាំងបរទេសទទួលស្គាល់បងទ្រីជាពេទ្យមានបច្ចេកទេសដ៏ត្រឹមត្រូវ មានចិត្តចេះជួយអ្នកក្រខ្សត់ដែលរងគ្រោះថ្នាក់ ជួយឧបត្ថម្ភអ្នកជម្ងឺធ្ងន់ៗដែលគ្មានបងប្អូន រើសក្មេងកំព្រាយកមកចិញ្ចឹម ។ ចំណែកបងប្អូនខ្មែរកម្ពុជាក្រោម បងទ្រីជួយមើលជម្ងឺដោយឥតគិតថ្លៃ ជួយចិញ្ចឹមឲ្យរៀនសូត្រ ។

រាល់ៗពេលមកកាន់ភូមិព្រៃដីរនេះ បងទ្រីតែងតែនាំយកមកនូវថ្នាំដូចជា Ganidans, Aspirines, Pénicillines ជាដើម ព្រមទាំងនំចំណីនិងសំពត់ខោអាវ ដាក់ទានឲ្យអ្នកស្រុក ។ បងទ្រីមានចិត្តសប្បុរសយ៉ាងនេះ ហេតុម្ដេចបានជាអង្គការសម្លាប់បងទ្រី ? រឿងគួរឲ្យចម្លែក ប្រជាជននៅកងព្រៃស្វាយ ទាំងប្រជាជនថ្មីទាំងប្រជាជនចាស់ ទាំងគណៈកម្មការកង ទាំងឈ្លប មានមិត្តកោដិ មិត្តរ៉េតជាដើម ពេលដឹងថាមានក្រុមឃាតករអាថ៌កំបាំង ចូលមកចាប់ចងបងទ្រីនាំយកទៅសម្លាប់ ក៏យំសោកស្ដាយគ្រប់ៗគ្នា ។ មិត្តកោដិនិយាយប្រាប់មិត្តរ៉េតនៅចំពោះមុខយាយទៀងថា ខ្លួនគាត់ចង់រំដោះមិត្តទ្រីដែរ តែគួរឲ្យស្ដាយណាស់ គាត់លែលកធ្វើមិនទាន់ ។ មិត្តកោដិបញ្ជាក់ថា មិត្តទ្រីចេះកសាងខ្លួនល្អណាស់ គាត់គ្រាន់តែជាពេទ្យ ហេតុម្ដេចក៏អង្គការបញ្ជាឲ្យសម្លាប់គាត់អញ្ចឹង ?...

យប់នោះយាយទៀងដេកមិនលក់ទាល់តែសោះ គាត់នឹកដល់សោកនាដកម្មដែលអង្គការធ្វើមកលើប្ដីគាត់ ។ គាត់នឹកដល់ការព្រាត់ពីប្ដី ដែលស្ថិតនៅជាប់ជានិច្ចក្នុងបេះដូងរបស់គាត់ ។

ព្រលឹមថ្ងៃទី២៨-៧-១៩៧៩ យាយទៀងបបួលមិត្តៗរបស់គាត់បន្តដំណើរទៅមុខទៀត ។ គាត់មានវិចារណញ្ញាណនឹកអាណោចអធម៌អាសូរដល់រាស្ត្រខ្មែរដែលជាសាសន៍ស្លូតបូត សុចរិត សុភាពទន់ភ្លន់ គ្រប់ៗរូបមានទ្រព្យសម្បត្តិមធ្យម ។ គ្រប់ៗគ្រួសាររស់នៅសុខក្សេមក្សាន្តយ៉ាងស្រួល ដោយមានវត្ថុធម្មជាតិស្ថិតនៅជុំវិញទីលំនៅគ្មានខ្វះអ្វីឡើយ ។ ជាពិសេសមិនដែលអត់ឃ្លាន មិនដែលលំបាកវេទនាឡើយ ។

មកតែពីប្រមុខរដ្ឋ ទាំងសក្ដិភូមិ ទាំងខ្មែរក្រហម ខ្វះសមត្ថភាព ធ្វេសប្រហែសបណ្ដោយខ្លួនឲ្យចាញ់កលឧបាយរបស់អង្គការអនាមិក ញាំងឲ្យប្រជាជនខ្មែរមួយនគរ ដែលសេសសល់ពីស្លាប់ ទៅជាក្ររហេមរហាមបាតដៃទទេ មានតែអាវខោមួយបន្លាស់ជាប់នឹងខ្លួន បណ្ដើរគ្នាដើរទៅ គ្មានទិស គ្មានដៅ ពឹងដីជាគ្រែ ជាកន្ទេល ពឹងមេឃជាដំបូល រស់នៅក្រោមក្ដៅ កណ្ដាលភ្លៀង កណ្ដាលខ្យល់ ។

យាយទៀងកំពុងរវើរវាយនឹកឃើញសេចក្ដីរងទុក្ខវេទនានៃរាស្ត្រខ្មែរ ស្រាប់

តែព្រាដា កូនស្រីរបស់គាត់ស្រែកហៅថា ៖ ម៉ាក់អើយ ! យើងមកដល់ភូមិកាច់រទេះហើយ ។

យាយទៀងឈប់ឈរទ្រឹងមួយសន្ទុះ គាត់ក្រឡេកភ្នែកគយគន់មើលភូមិនេះមួយត្រួស ពេលនោះបេះដូងគាត់កញ្ជ្រោលស្រែកយំទប់មិនឈ្នះ ។ យាយទៀងយំដូចមនុស្សឆ្កួត យំហើយយំទៀត ពីព្រោះភូមិកាច់រទេះនេះ គាត់សន្និដ្ឋានទុកជាស្រុកកំណើតរបស់គាត់ ។ រាស្ត្រខ្មែរនៅភូមិនេះគឺខ្មែរកម្ពុជាក្រោមទាំងអស់ ដែលនាំគ្រួសាររត់គេចពីអំពើព្រៃផ្សៃរបស់វៀតមិញ រកជ្រើងសម្លាប់បំផុតពូជ មកជ្រកនៅសុខសាន្តជាយូរឆ្នាំមកហើយ ។ យាយទៀងគោរពស្រឡាញ់រាប់អានអ្នកស្រុកភូមិនេះដូចបងប្អូនបង្កើត ។ ភូមិនេះស្ថិតនៅស្របបណ្តោយផ្លូវជាតិលេខ៥ មានចម្ងាយពីក្រុងបាត់ដំបងប្រហែល២៥គ.ម. ។

ពីមុនឆ្នាំ១៩៧៥ ភូមិនេះមានផ្ទះវីឡាល្អៗជាច្រើនគ្រឿង ភាគច្រើនធ្វើអំពីឈើ មានដើមឈើស៊ីផ្លែគ្រប់ធុន ដាំជាជួរៗព័ទ្ធជុំវិញផ្ទះទាំងនោះ ។

នៅថ្ងៃនេះ ភូមិកាច់រទេះក្លាយទៅជាព្រៃរល្លិព័ទ្ធ ។ វីឡាទាំងឡាយនេះឃើញតែកំទេចឥដ្ឋ ។ ចំណែកដើមឈើស៊ីផ្លែគ្រប់ៗធុនស្វិតក្រញង់ ភ្លើងឆេះខ្លោចគួរឲ្យសោកស្តាយណាស់ ។ អ្នកស្រុកភេទប្រុសនៅភូមិនេះ ត្រូវអង្គការសម្លាប់ចោលជាច្រើនពាន់នាក់ ព្រោះតែគ្នាមានដើមកំណើតជាខ្មែរកម្ពុជាក្រោម ។ យាយទៀងនឹកឃើញកាលពីបួនឆ្នាំកន្លងផុតទៅ ពេលដែលអង្គការចេញបញ្ជាដេញប្រជាជនឲ្យថយចេញពីទីលំនៅ ពេលនោះយាយទៀង-តាទ្រី នាំកូនតូចៗប្រាំនាក់ភៀសខ្លួនមកកាន់ភូមិនេះនៅម៉ោងប្រហែល១០ ថ្ងៃទី២៩ មេសា ១៩៧៥ ។

មកដល់ដំបូងគាត់ភ័តតក់ស្លុតសឹងសន្លប់ ព្រោះគ្មានឃើញនរណាទទួលខុសត្រូវទាល់តែសោះ ។ គាត់ដេកយំសោកស្តាយទ្រព្យសម្បត្តិ ។ ប៉ុន្តែកាលណោះយាយទៀងនៅសល់ទ្រព្យដ៏សំខាន់ គឺកូនប្រាំនាក់និងប្តី ។ ឥឡូវថ្ងៃនេះ ម៉ោងដដែល ថ្ងៃដដែល ខុសតែឆ្នាំ គាត់មកដល់ភូមិដដែល តែគាត់នៅសល់តែកូនស្រីទី២ម្នាក់តែប៉ុណ្ណោះ ។ ពេលនោះយាយទៀងស្រែកយំម្តងទៀត ដើម្បីបន្ធូរទ្រូងដែលកំពុងឈឺចាប់ខ្លោចផ្សា ។ មានតែទឹកភ្នែកទេដែលជួយលួងលោមគាត់ឲ្យភ្លេចនូវអនុស្សាវរីយ៍នានាដែលកន្លងហួសទៅ ។ យាយទៀងយំបណ្តើរព្រមទាំងបបួលមិត្តៗខំស្រូតដំណើរទៅកាន់ទីក្រុងបាត់ដំបង ដែលមានចម្ងាយតែ២៣គ.ម.ទៀតតែប៉ុណ្ណោះ ។

យាយទៀងមិនហ៊ានសំរាកទេ គាត់ខំស្រូតដំណើរ ពីព្រោះគាត់ស្រមៃថាល្ងាចនេះ គាត់នឹងឃើញផ្ទះវីឡានិងចំការផ្លែឈើគ្រប់មុខរបស់គាត់ ។

យាយទៀងមានទឹកភ្នែកជាប់ជានិច្ច ពីព្រោះផ្លូវជាតិលេខ៥ មានអនុស្សាវរីយ៍

យ៉ាងច្រើនឥតគណនា ។ កាលពីដើមគ្រួសាររបស់គាត់តែងតែនាំកូនៗជិះឡាន ដើរលេងកំសាន្តតាមផ្លូវនេះរាល់ៗថ្ងៃអាទិត្យ ។

❑ ❑

❑

# ជំពូកទី២០

★ យាយទៀងមកដល់ទីក្រុងបាត់ដំបង

★ ជួបតាអាង

★ ប្រវត្តិ FULRO, កងទ័ពកន្សែងស, ម៉ែកហ្វ័ក្ស

★ ប្រវត្តិឳកញ៉ា សឺន-គុយ

★ យួនបង្កើតខ្មែរថ្មី

★ យួនមានអាវុធយ៉ាងច្រើន

ថ្ងៃទី២៨-៨-៧៩ ម៉ោងប្រហែល៧ល្ងាច ក្រុមស្រីមេម៉ាយយើងទាំង១៨នាក់ក៏មកដល់ភូមិវត្តរំដួល ដែលស្ថិតនៅខាងកើតទីក្រុងបាត់ដំបង ។

យាយទៀងត្រេកអរណាស់ គាត់អន្ទះសារឆ្លេឆ្លា រកផ្លូវចូលទៅកាន់ចំការនិងផ្ទះរបស់គាត់ ។ យាយទៀងវង្វេងច្រឡំរកផ្លូវចូលមិនឃើញ ពីព្រោះអង្គការអនាមិកកែឆ្នៃវត្តរំដួល ឲ្យខុសស្ថានភាពពីបួនឆ្នាំមុន ។

កាលពីបួនឆ្នាំមុន ភូមិក្រោយវត្តរំដួលមានសង់ផ្ទះវីឡាល្អៗយ៉ាងសមរម្យ គួរឲ្យគយគន់ គួរឲ្យសប្បាយរីករាយ ។ ផ្ទៃកជាប់នឹងដីធ្វើអំពីឥដ្ឋ ជាន់ទីមួយធ្វើអំពីឈើ ។ ព័ទ្ធជុំវិញនៃវីឡាទាំងនេះ គឺដើមឈើស៊ីផ្លែដូចជា ដូង, ស្វាយ, ខ្នុរ, ល្មុតមៀន, សូកូឡា, ផ្លែទឹកដោះគោ, ក្រូចគ្រប់ធុន និងស្វាយចន្ទីជាដើម ។ ឥឡូវដើមឈើស៊ីផ្លែទាំងនេះស្ងិតងាប់ពាសពេញ ភ្លើងឆេះខ្លោច ។ ព្រោះតំណាងរបស់អង្គ

ការ បើគេចង់ហូបផ្លែដូង ត្រូវតែកាប់ដើមដូង បើចង់ហូបផ្លែឈើផ្សេងៗ គេត្រូវតែកាប់មែក ។

នៅមុខផ្ទះវីឡារបស់យាយទៀងមានផ្លូវថ្នល់មួយ ខាងត្បូងថ្នល់នេះចម្ងាយប្រហែល៥០ម៉ែត្រ មានថ្នល់មួយទៀត ។ ផ្លូវថ្នល់ទាំងនេះ ភ្ជាប់ពីផ្លូវថ្នល់មាត់ស្ទឹងសង្កែ ឆ្លងកាត់ទម្លុះចំការផ្លែឈើនិងផ្ទះវីឡានានា រហូតដល់ផ្លូវជាតិលេខ៥ ។

ឥឡូវនេះ អង្គការបញ្ជាឲ្យជីកបំផ្លាញផ្លូវថ្នល់ទាំងពីរចំកណ្តាល ដោយយកលេសថាធ្វើផ្លូវទឹក ។ អមសង្ខាងផ្លូវទាំងពីរនេះមានផ្ទះវីឡាចំនួន៣០០ខ្នង អង្គការបញ្ជាឲ្យរុះរើនាំចេញអស់រលីងឃើញនៅសល់តែកំទេចឥដ្ឋនិងជណ្តើរ ។

ខាងត្បូងវត្តរំដួល ក្បែរវត្តលាបមានផ្សារមួយឈ្មោះផ្សារវត្តលាប អង្គការបញ្ជាឲ្យរុះរើដឹកនាំចេញអស់រលីង ក្លាយទៅជាវាលស្មៅទ្រូបទ្រូល ដូច្នេះភូមិវត្តរំដួលក្លាយទៅជាភូមិមួយដែលមានព្រៃព័ទ្ធ គ្មានអ្វីជាសំគាល់ ។ យាយទៀងបណ្តើរមិត្តរបស់គាត់ដើរចុះដើរឡើង ទទឹសទទាសយ៉ាងយូរ ចៃដន្យបានជួបនាង ថ ។ នាងស្គាល់ផ្លូវ ក៏នាំស្រីៗមេម៉ាយទាំង១៨នាក់តោះចូលទៅកាន់ចំការយាយទៀង ។ ទៅដល់ភ្លាម យាយទៀងស្លុតចិត្ត មាត់ស្រែកថា ៖ ពុទ្ធោៗ ! រួចដួលប្រួសលើគំនរឥដ្ឋ



ខ្មោចភូមិគ្រឹះ (វីឡា) របស់យាយទៀង (ថតនៅថ្ងៃទី១-១-១៩៨៣)

ដែលបាក់បែកខ្ទេចខ្ទីនោះ ។ គាត់គាំងមាត់ស្លុតបំពង់ក និយាយមិនចេញ ។ ពី-ព្រោះផ្ទះវីឡារបស់គាត់សល់តែកំទេចឥដ្ឋ និងបន្ទប់បង្គន់មួយទំហំ៣ម៉ែត្របួនជ្រុង ។ ផ្ទះវីឡានេះមាន២ជាន់ ទទឹង១០,៥០ម. បណ្ដោយ១៦ម. ។ ជាន់ក្រោមធ្វើអំពី ឥដ្ឋជញ្ជាំងថ្មដុះថ្មលាង ។ ជាន់លើធ្វើពីឈើកកោះនិងសុក្រម ស្ថាបនាពីរឆ្នាំទើបរួចស្រេចនៅចុងឆ្នាំ១៩៧០ ។ ចំណែកដើមដូងត្រូវគេកាប់រំលំខ្ទេចខ្ទី ។ ដើមឈើស៊ីផ្លែផ្សេងៗទៀត ត្រូវកាប់មែកអស់នៅសល់តែដើមស្ងិតក្រញង់ ។

មួយសន្ទុះយាយទៀងក្រោកដើរទៅអង្គុយលើជណ្ដើរបាក់បែកត្របោមក្បា-លជង្គង់ គាត់នឹកឃើញគួរឆ្ងល់សែនឆ្ងល់ ពីព្រោះទ្រព្យសម្បត្តិនៃប្រទេសខ្មែរត្រូវហិនហោចពេលចប់សង្គ្រាមទៅវិញ ពេលអង្គការអនាមិកទទួលជ័យជំនះទៅវិញ អង្គការបំផ្លាញខ្ទេចបំផ្លាញខ្ទីទាំងអស់ ។

យាយទៀងកំពុងអស់សង្ឃឹម ខ្លួនគាត់ស្រោលដូចសំឡី មិនដឹងជាថ្ងៃស្អែកនេះ គាត់ត្រូវដើរទៅកាន់ទីណាវិញ ។ ស្រាប់តែសម្លេងពីរបានបន្លឺឡើងថា ៖ « បង! » និង « ម៉ាក់ ! » ។

យាយទៀងបែរភ្នែកសម្លឹងទៅតាមសូរស័ព្ទនោះ យាយទៀងក៏លោតទៅឱបលោកតាម្នាក់អាយុប្រហែល៥០ឆ្នាំ ដែលគាត់ហៅថា បង! គឺលោកតា អាង ជាដៃគូរបស់លោកគ្រួយី-វិញទ្រី ធ្លាប់ធ្វើការផ្នែក FULRO រួចគាត់លោតទៅឱបនារីម្នាក់អាយុ១៨ឆ្នាំគឺ យី-ទ្រីអង្គរ៉ា កូនស្រីពៅរបស់គាត់ ។ ពេលនោះយាយទៀងបង្ហាញកូនស្រីដ៏កំសត់នេះដល់មិត្តៗ ព្រមទាំងយំបណ្ដើរអធិប្បាយថា ៖

- ខ្ញុំមិនស្មានទាល់តែសោះថា នឹងមានវាសនាបានជួបកូនស្រីនេះទេ ! ។ ព្រោះនៅថ្ងៃទី១៥-៣-១៩៧៨ អង្គរ៉ានឹកខ្ញុំពេក ក៏រត់ចេញពីអង្គការចល័តមករកខ្ញុំនៅភូមិព្រៃស្វាយ ។ អង្គការបញ្ជាឲ្យឃាតករមួយក្រុមចំនួន៧នាក់ អាវុធគ្រប់ដៃមកតាមចាប់នាងយកទៅសម្លាប់ បង្ហាញជាគំរូដល់នារីផ្សេងៗទៀត ។ យាយទៀងបន្តទៀតថា ៖

- ពេលនោះខ្ញុំជាប់ពលិកម្មទៅវែងកន្ទក់នៅកងទួលស្គួល ។ ពេលខ្ញុំទទួលដំណឹងអកុសលនេះភ្លាម ខ្ញុំរត់កាត់ព្រៃពីកងទួលស្គួល ទៅកាន់កងព្រៃស្វាយ មានចម្ងាយប្រមាណ៤គ.ម. ។ ទៅដល់ស្របពេលល្មមបានជួបក្រុមឃាតករកំពុងប-ណ្ដើរអង្គរ៉ា ចេញពីកងព្រៃស្វាយ ។ ខ្ញុំក៏លោតឱបមេឃាតករសុំអង្វរថា ៖

« សុំកូនសម្លាប់ម៉ែជាមួយកូនស្រីនេះចុះ ! ។ ឱកូនៗអើយ ! អង្គរ៉ានេះជាកូនស្រីពៅ នាងបែកចេញពីម៉ែតាំងពីអាយុ១០ឆ្នាំ ។ ឱកូនៗអើយ ! អ្វីៗអាចលះបង់បានទាំងអស់ ចំណែកកូនក្មេងអាយុប៉ុណ្ណោះមិនអាចលះបង់មិននឹកម្ដាយបានឡើ-យ ។ មកពីនឹកម្ដាយខ្លាំងពេកទ្រាំមិនបាន ទើបនាងប្ដូរជីវិតរត់មករកម៉ែ ទោះជាត្រូ

វស្លាប់ក៏ដោយ ។ ចំណែកម៉ែ ម៉ែជាប់ពលិកម្មនៅឯកងទួលស្លួលឯណោះ ។ តាំងពីកូនស្រីនេះមកដល់កងព្រៃស្វាយ ម៉ែទើបជួបនាងពេលនេះ ។ ដូច្នេះបើកូនៗមិនអាចអនុគ្រោះទុកជីវិតឲ្យនាងទេ ដោយសារនាងប្រព្រឹត្តខុស ម៉ែសុំស្នើឲ្យកូនៗសម្លាប់ម៉ែជាមួយកូនស្រីនេះចុះ ។ ម៉ែសុំស្លាប់ជាមួយកូននេះហើយ ! ម៉ែសុំស្លាប់ជាមួយកូននេះហើយ ! ។

ក្រុមឃាតករនេះជាបក្សខ្មែរក្រហមនិរតី គ្រប់ៗគ្នាធ្វើមុខស្លូត បង្ហាញឥរិយាបថអាណិតខ្ញុំដែរ ។ លុះគេបណ្ដើរខ្ញុំនិងអង្គរ៉ាទៅដល់កងទួលស្លួល ខ្ញុំត្រូវបែកចេញពីក្រុមឃាតករ ខ្ញុំត្រូវបែកចេញពីកូនស្រីទៅកាន់កន្លែងវែងកន្ទក់ ។ ខ្ញុំឈានបានតែ២-៣ជំហានប៉ុណ្ណោះ ខ្ញុំដួលសន្លប់ស្ដូកទៅ ។ ល្ងាចទើបដឹងខ្លួនឡើងវិញ មេកាន់ក្ដាប់ផ្នែកកិនស្រូវប្រាប់ខ្ញុំថា ក្រុមឃាតករយល់ព្រមលើកលែងទោសឲ្យអង្គរ៉ាហើយ ។ តាំងពីពេលនោះមកបាត់ដំណឹងរហូត » ។

យាយទៀងឱបកូនស្រីយំបន្តទៅទៀត ។ ចំណែកអង្គរ៉ាក៏ឱបម្ដាយយំហ៊ីៗ ព្រមទាំងអធិប្បាយរឿងដ៏កំសត់របស់នាងដូចតទៅ ៖

- ថ្ងៃល្ងាចនោះ ក្រុមឃាតករបណ្ដើរខ្ញុំ ហើយសួរដេញដោលថា តើជាង២ឆ្នាំមកហើយ មិត្តមិនដែលជួបម៉ែទេឬ ?

- ខ្ញុំទើបជួបអំបាញ់មិញនេះ ។

ក្រុមនេះបណ្ដើរខ្ញុំទៅដល់មូលដ្ឋាន បឹងកី គេក៏ទៅជួបជុំពិភាក្សាគ្នាយ៉ាងយូរ ស្រាប់តែហៅបណ្ដើរខ្ញុំចូលទៅកាន់ព្រៃជ្រៅ ដើរទៅៗតាំងយប់គ្មានសំរាកឡើយ។ ជិតភ្លឺក៏ទៅដល់ជើងភ្នំមួយ រួចគេប្រគល់ខ្ញុំឲ្យក្រុមយោធាដាក់ទិសឲ្យខ្ញុំសែងខ្មោច ។ ខ្ញុំនៅជាប់ជាមួយយោធារហូត ។

ឆ្លៀតពេលយោធាបាញ់សម្លាប់គ្នា ឃើញតែខ្មោចពាសព្រៃ ខ្ញុំក៏ផ្សងព្រេងរត់ចាកចេញពីទីនោះ ។ ខ្ញុំរត់កាត់ព្រៃជាច្រើនយប់ច្រើនថ្ងៃ ទើបមកដល់ទីក្រុងបាត់ដំបងនៅថ្ងៃទី២៣-៣-១៩៧៩ ។

ម៉ែនិងកូនស្រី២នាក់បានមកជួបជុំគ្នាលើកំទេចឥដ្ឋ ទាំងអស់គ្នាមានតែទឹកភ្នែក បង្ហាញថា «កំសត់ណាស់ៗ» ។ អង្គរ៉ាមានតែខោនិងអាវដាច់ដាចមួយបន្លះជាប់តាមខ្លួន ។

តាអាងឃើញបរិយាកាសសែនអាប់អួរដូច្នេះ គាត់ក៏ដើរមកអង្អែលខ្នងយាយទៀង ភ្នែកសម្លឹងក្មួយស្រីទាំងពីរដែលកំពុងត្រេកអរមានវាសនាបានជួបបងប្អូនវិញ។ ដើម្បីលើកទឹកចិត្តយាយទៀង លោកតាអាងចាប់ផ្ដើមនិយាយល្ហួងលោមថា៖

- បងមានភ័ព្វវាសនាខ្ពស់ណាស់ ដែលអាចរួចចាកផុតពីគ្រោះចង្រៃអស់នេះ

មិនតែប៉ុណ្ណោះសោត បងបានជួបកូនស្រីទាំងពីរនាក់ទៀត ។ លោកតាអង្អែលខ្នងយាយទៀងម្តងទៀត រួចនិយាយបន្តថា ៖

– កាលពីថ្ងៃទី២៨-៤-១៩៧៥ ម៉ោងប្រហែល១០ មានឃាតករដឹចម្លែកមួយក្រុមគ្នា១០នាក់ មានអាវុធគ្រប់ដៃ ចូលមករកសម្លាប់គ្រួសាររបស់បង ។ វាសនា ល្អ បងនាំគ្រួសារចាកចេញផុតទៅហើយ ។ ក្រុមឃាតករដឹចម្លែកនេះបណ្តើរគ្នាវិលត្រឡប់ទៅវិញ ដោយកាត់តាមវត្តរំដួល ។ ពួកវាបានជួបនឹងខ្ញុំកំពុងស្រង់ទឹកខាងត្បូងព្រះវិហារ ( កាលណោះតាអាងនៅជាព្រះសង្ឃនៅឡើយ ) ជាប់ផ្លូវដើរចេញពីវត្ត ។ មិត្តជាមេសួរខ្ញុំថា តើឃើញគ្រួសារពេទ្យទ្រីឬទេ ? នៅពេលដែលមេវាកំពុងសួរខ្ញុំនោះ គ្នាវាម្នាក់ដែលដើរជាមួយនិយាយឡើងថា ត្រូវតាមសម្លាប់គ្រួ-សារពេទ្យទ្រីចោលទាំងអស់ ព្រោះជាបំរើលន់-នល់ ជាមេរើសទ័ពកន្សែងស ជាមេរើសទាហានលន់-នល់ ។ កូនច្បងរបស់វាជាទាហានពាក់ស័ក្តិពីរ ។

ពេលជាមួយគ្នានេះ ឮសំនួររបស់មេគេផង ! ឮការជជែកគ្នាដូច្នេះផង ! ខ្ញុំក៏លៃលកឆ្លើយបង្វែងដានថា អាត្មាឃើញយោធាមួយក្រុមចូលមកនាំយកចេញទៅតាំងពីព្រលឹម ។ អាត្មាបានឃើញពិតៗ តែថាលោកទ្រីជាពេទ្យ បែបគេនាំលោកយកទៅពេទ្យទេដឹង ! ។ ពេលនោះគ្មាននរណាឆ្លើយ ឬវែកញែកអ្វីទេ គេគ្រាន់តែសម្លឹងខ្ញុំដូចចង់លេបទាំងរស់ ។ មិត្តមេដដែលនោះនិយាយថា ត្រូវតែកំទេចផ្ទះវី-ឡានេះ » ។ លោកតានិយាយដល់ត្រឹមនេះ ក៏លើកដៃចង្អុលកំទេចឥដ្ឋ ។

❑ ❑

❑

ពេលនោះបរិយាកាសស្ងាត់ច្រៀបមួយលើកទៀត មួយសន្ទុះឮអ្នកស្រីបូរីសួរថា ៖

– បងទៀងអាំ ! តើកងទ័ពកន្សែងសជាកងទ័ពស្អី ?

យាយទៀងលើកដៃចង្អុលលោកតាអាង ព្រមទាំងនិយាយប្រាប់មិត្តៗរបស់គាត់ថា លោកតាបួសជាព្រះសង្ឃតាំងពីក្មេង លោកជាព្រះសង្ឃពិសេសដ៏អស្ចា-រ្យ ។ លោកតាមានសតិសម្បជញ្ញៈស្នេហានិងអាណិតខ្មែរកម្ពុជាក្រោម ។ លោកតាហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាងជួយឧបត្ថម្ភដល់កងទ័ពកន្សែងស ។ ដូច្នេះខ្ញុំទុកភារកិច្ចនេះជូនលោកតាជួយពន្យល់ប្អូនស្រីៗនិងកូនទាំងអស់ ឲ្យស្គាល់ករណីយ-កិច្ច និងប្រវត្តិកងទ័ពកន្សែងស ។ ចំណែកខ្ញុំ ខ្ញុំសុំសំរាកបន្តិច ។ លោកតាអាងចាប់ផ្តើមអធិប្បាយរ៉ាយរ៉ាប់ថា ៖

– ក្រោយពីសន្និសិទឥណ្ឌូចិននៅភ្នំពេញឆ្នាំ១៩៦៥រួចមក ប្រជាជនភាគតិចដែលត្រូវគេជិះជាន់ ក៏ក្រោកឡើងបង្រួបបង្រួមគ្នាបង្កើតជារណសិរ្សមួយដែលមានឈ្មោះថា ៖ ហ្វ៊ុលរ៉ូ ( FULRO: Front Uni de Libération des Races Oprimées ) ។ ខ្មែរកម្ពុជាក្រោមយើងក៏ស្ម័គ្រចិត្តចូលជាសមាជិកហ្វ៊ុលរ៉ូនេះដែរ ។ ប្រជាជនខ្មែរកម្ពុជាក្រោមដែលរត់គេចពីអំពើព្រៃផ្សៃនៃយួនសម្លាប់កំចាយ មកជ្រកសំណាក់នៅក្នុងខេត្តបាត់ដំបង ដែលមានខ្ញុំជាអ្នកដឹកនាំ ក៏បោះឆ្នោតជ្រើសរើសតែងតាំងបងទៀងជាអនុប្រធាន ( ដែលមានលោករាជ-ខូន ជាប្រធាននៅពេលនោះ ) ។ ទីស្នាក់ការស្ថិតនៅក្នុងវិទ្យាបងទៀងនេះ ។

បងទ្រី បងទៀង ធ្វើពលិកម្មគ្រប់បែបយ៉ាង ឆ្លៀតថ្ងៃអាទិត្យបំពេញករណិយកិច្ច ចេញទៅកាន់ភូមិនានាដែលមានខ្មែរកម្ពុជាក្រោមរត់មកជ្រកសំណាក់នៅ គាត់ខំពន្យល់ណែនាំឲ្យស្គាល់ឲ្យយល់នូវគោលបំណងនៃរណសិរ្ស គឺដំណាក់ការជាដំបូង ត្រូវការពារប្រជាជនភាគតិចដែលត្រូវគេជិះជាន់ ។ ដូច្នេះខ្មែរកម្ពុជាក្រោម ដែលកំពុងត្រូវយួនជិះជាន់បំបាត់ពូជសាសន៍ យើងត្រូវតែស្ម័គ្រចិត្តចូលជាសមាជិកដើម្បីការពារពូជសាសន៍ខ្មែរកម្ពុជាក្រោមឲ្យគង់វង់ យើងត្រូវតែខំផ្សាយឲ្យពិភព-លោកដឹងស្គាល់តាមរណសិរ្សហ្វ៊ុលរ៉ូនេះថា ខ្មែរកម្ពុជាក្រោមគឺជាម្ចាស់ទឹកដីកម្ពុ-ជាពិតៗ មិនមែនយួនទេ ។ ពីឆ្នាំ១៩៤៩ បារាំងយល់ព្រមប្រគល់ឲ្យទៅយួន ។ យួនវាតទីយកដាច់ស្រេចនៅឆ្នាំ១៩៥៤ ក្រោយពីបារាំងចាកចេញពីឥណ្ឌូចិន វាបំបាត់ពូជខ្មែរកម្ពុជាក្រោម គឺវាបិទសាលារៀនជាភាសាខ្មែរ វាចេញប្រកាសបង្ខំរាស្ត្រខ្មែរកម្ពុជាក្រោមចំនួន៩លាននាក់ ដែលជាម្ចាស់ទឹកដីកម្ពុជាក្រោមពិតៗ ឲ្យកាន់កាតជាជាតិយួនទាំងអស់ ។ ការពិតខ្មែរកម្ពុជាក្រោមទាំងនេះមានមួយភាគច្រើនកាន់កាតយួន ប៉ុន្តែមិនចេះភាសាយួនទាល់តែសោះ ។ ដូច្នេះដើម្បីគាំទ្រហ្វ៊ុលរ៉ូ យើងក៏បានបង្កើតកងទ័ពនេះឡើង ។ មូលហេតុនេះទើបអង្គការបញ្ជាឲ្យកំទេចផ្ទះវិទ្យានេះ ។ យុវជនស្ម័គ្រចិត្តចូលបំរើកងទ័ពកន្សែងស ភាគច្រើនគឺខ្មែរកម្ពុជាក្រោម ។ មធ្យោបាយជ្រើសរើស និងបញ្ជូនទៅកាន់មូលដ្ឋានរំដោះនៅខេត្តបាត់ដំបងនេះ គឺនៅលើសមាគមខ្មែរកម្ពុជាក្រោម និងរណសិរ្សហ្វ៊ុលរ៉ូប្រចាំខេត្តបាត់ដំបង ដែលមានខ្ញុំបងទ្រី និងបងទៀងជាអ្នកទទួលខុសត្រូវ ។

ក្នុងឆ្នាំ១៩៧០ ប្រទេសកម្ពុជាត្រូវវង់គ្រោះ សង្គ្រាមផ្ទុះឡើង កងទ័ពកន្សែងសដឹងច្បាស់ថា បណ្តាលមកពីសម្តេចន.សីហនុត្រូវចាញ់បោកយួនហាណូយ ជាវៀតកុង កងទ័ពកន្សែងសក៏ស្ម័គ្រចិត្តរំលាយជួរក្នុងខែឧសភាឆ្នាំ១៩៧០ រួចចូលមករួបរួមបំរើកងទ័ពជាតិសាធារណរដ្ឋ ដែលមានលោកលន់-នល់ជាមេដឹកនាំ ។

ក្នុងឆ្នាំ១៩៧២ អតីតកងទ័ពកន្សែងស មានភាគច្រើនរត់ចេញពីកងទ័ពរដ្ឋាភិបាល វិលមកជួបខ្ញុំ បងទ្រី បងទៀង ថ្លែងសេចក្តីស្មោះត្រង់សោកស្តាយនិងសារភាពថា ក្នុងកងទ័ពរដ្ឋាភិបាលរញើរញៀប្រកាន់បក្សពួក ។ មួយកងវរៈសេនាតូច ឃើញតែនាំគ្នាពាក់ស័ក្តិ ខ្លះជាអតីតមេឃុំ ជាសាស្ត្រាចារ្យ មានខ្លះជាតំណាងរាស្ត្រ ។ល។ អស់លោកទាំងនោះ ស្រឡាញ់ស័ក្តិណាស់ ពាក់ស័ក្តិពេញៗលើស្មា ។ ប៉ុន្តែមិនសូវមានលោកណាក្លាហានហ៊ានបូជាជីវិតនាំទ័ពចេញទៅបង្ក្រាបខ្មាំងដើម្បីការពារទឹកដីឡើយ ។ ពួកគេច្រើនរយនាក់ដែលរត់ចោលជួរកងទ័ព បណ្តាលមកពីអំពើអយុត្តិធម៌នានា ។ ប៉ុន្តែក្រុមគេនៅតែគាំទ្រ ទទួលស្គាល់ គោរពស្រឡាញ់លោកសេនាប្រមុខលន់-នល់ដដែល ។ ក្រុមគេមានបំណងដ៏មោះមុតស្ម័គ្រចិត្តបូជាជីវិតការពារប្រទេសកម្ពុជា ដែលមានលោកសេនាប្រមុខជាអ្នកដឹកនាំ ។

❑ ❑

❑

នៅពេលនោះក្រុមអតីតកងទ័ពកន្សែងស ដែលមានលោកគីម-ង្វួនត្រាច និងថាច់-ជា ជាអតីតមេទ័ពកន្សែងស បានស្រុះស្រួលគំនិតគ្នាធ្វើពាក្យមួយមានចុះហត្ថលេខាគាំទ្រ ផ្ញើទៅសុំអនុញ្ញាតពីលោកលន់-នល់ ចាត់តែងតាំងបងទ្រីជាវរៈសេនិយត្រី ដើម្បីទទួលខុសត្រូវលើកងវរៈសេនាតូច ដែលក្រុមអតីតកងទ័ពកន្សែងសស្ម័គ្រចិត្តបំរើ ។

កន្លងផុតតែជាងកន្លះខែ បងទ្រីទទួលទូរលេខមួយពីក្រសួងជ្រើសរើសកងទ័ព អញ្ជើញបងទ្រី បងទៀងទៅសួរយោបល់ ។

ពេលនោះលោកគីម-ង្វួនត្រាចជូនទៅជាមួយដែរ ។ បងទ្រី បងទៀងឆ្លើយដោយសមរម្យថា គាត់មិនហ៊ានទទួលបុណ្យស័ក្តិដ៏ធំសំបើមនេះទេ ពីព្រោះគាត់ខ្វះសមត្ថភាព ។ ប៉ុន្តែរឿងជួយជាតិ មិនមែនរត់ចូលមកពាក់ស័ក្តិ ទើបហៅថាជួយជាតិនោះទេ ! ។

បងទ្រី បងទៀងស្ម័គ្រចិត្តជួយជាតិតាមសមត្ថភាព និងបច្ចេកទេសដែលគាត់មានពិតប្រាកដ ប្រសើរណាស់ទៅហើយ ទោះគាត់មិនពាក់ស័ក្តិដូចគេក៏ដោយ ក៏គាត់សន្យាថា គាត់នៅតែបន្តការឧបត្ថម្ភទំនុកបំរុងអតីតកងទ័ពកន្សែងសជានិច្ច តាមសមត្ថភាពដែលគាត់អាចទៅធ្វើទៅបាន ។ ព្រោះពាក្យ «កងទ័ពកន្សែសនិងពាក្យខ្មែរកម្ពុជាក្រោម»បានចារកប់នៅក្នុងបេះដូងរបស់គាត់ គាត់មិនអាចលះបង់ឬបំភ្លេចបានឡើយ ។ កន្លងផុតប្រហែលមួយខែ បងទ្រី បងទៀងទទួលបានសេចក្តី

បញ្ហាបេសកកម្មសម្ងាត់មួយ ចុះហត្ថលេខាផ្ទាល់ដៃរបស់លោកលន់-នល់ ចាត់តែងតាំងបងទ្រី ជាប្រធានជ្រើសរើសកងទ័ពក្នុងចំណោមអតីតកងទ័ពកន្សែងស គឺតែអតីតកងទ័ពកន្សែងស ។ មានសេចក្ដីបញ្ជាមួយទៀត ចាត់តាំងអនុសេនិយឯកពីរនាក់គឺ លោកថាច់-ជុង និងថាច់-អៀង និងព្រិន្ទបាលទោម្នាក់ទៀតគឺ ថាច់-វង់ មកជួយធ្វើការអមបងទ្រី ។ ទីចាត់ការនិងសំណាក់នៅ នៅក្នុងផ្ទះវីឡាបងទៀងនេះ ។ ចំណែកកូនទាហាន សំណាក់នៅក្នុងវត្តវំដួលនិងវត្តលាប ។ ទាហានទាំងឡាយនេះត្រូវបញ្ជូនបញ្ចូលក្នុងកងម៉ែកហ្វ័ក្ស ( Mike's Force ) ដែលទើបបង្កើតកងវរៈសេនាតូចថ្មីៗបន្ថែម ។ ក្នុងខែមេសាឆ្នាំ១៩៧៥ ទាហានដែលបងទ្រីជ្រើសរើសថ្មីសំណាក់នៅវត្តលាបចំនួន៣០០នាក់ សំណាក់នៅវត្តវំដួលជាង៣០០នាក់ ។

មូលហេតុនេះទើបអង្គការឲ្យឃាតករតាមសម្លាប់បំផុតពូជបងទ្រី ។ ពេលនេះអ្នកស្រីភិន សុំសួរលោកតាអាងថា ៖

– កងទ័ពម៉ែកហ្វ័ក្សល្បីល្បាញពូកែស្វិតស្វាញផ្នែកវាយសឹក ហេតុម្ដេចក៏បណ្ដោយឲ្យប្រទេសខ្មែរវិនាសហិនហោចដល់ថ្នាក់នេះ ? ។

លោកតាអាងអធិប្បាយបន្ត ៖ កងទ័ពម៉ែកហ្វ័ក្ស គឺអតីតកងទ័ពខ្មែរសេរី គឺសុទ្ធតែខ្មែរកម្ពុជាក្រោម គឺជាកូនចៅរបស់លោកសឺន-ង៉ុកថាញ់ ។ លោកសឺន-ង៉ុកថាញ់ពន្យល់ឲ្យស្គាល់ករណិយកិច្ច គឺកំទេចសត្រូវដើម្បីការពារជាតិនិងទឹកដី លោកពន្យល់ឲ្យស្គាល់ច្បាស់ យួនហាណូយជាសត្រូវសួរពូជរបស់ជាតិខ្មែរ ។ លោកអប់រំបណ្ដុះសតិសម្បជញ្ញៈស្នេហាជាតិយ៉ាងមុត ។ លោកលត់ដំដល់កំពូល ញាំងឲ្យកងទ័ពម៉ែកហ្វ័ក្សមានចរិតរឹងប៉ឹង ស្វាហាប់ក្លាហាន ជាពិសេសបំផុតមានចិត្តតស៊ូស្វិតស្វាញ ចេះអត់ធ្មត់នូវការលំបាកគ្រប់យ៉ាង ។ គ្រប់ៗរូបលះបង់ចោលគ្រួសារទៅនៅព្រៃ មិនដែលស្គាល់ស៊ីឆ្ងាញ់-ដេកស្រួលទេ ។

ក្នុងឆ្នាំ១៩៧០ ប្រទេសខ្មែរធ្លាក់ចូលក្នុងភ្នក់ភ្លើងសង្គ្រាម ស្រាប់តែលោកសឺនង៉ុកថាញ់ទទួលដំណឹងថា នៅថ្ងៃទី២៧មេសា១៩៧០ បូដូយចេញមុខវាយកំទេចខ្មែរលន់-នល់វិញ ។ ដូច្នេះលោកធ្វើពលិកម្មសំរេចលប់កងទ័ពខ្មែរសេរី លោកឲ្យឈ្មោះជាកងទ័ពម៉ែកហ្វ័ក្ស រួចលោកបញ្ជូនមកកាន់ប្រទេសកម្ពុជាជាលើកទី១នៅថ្ងៃទី៣០មេសា១៩៧០ ។ ក្នុងខែមិថុនា១៩៧០ លោកបានទទួលដំណឹងទៀតថា បូដូយជាច្រើនម៉ឺនក្បាលចេញមុខវាយកំទេចខេត្តកំពង់ធំ ច្បាំងខ្លួនទល់នឹងខ្លួនជាមួយកងទ័ពជាតិខ្មែរ ។ មូលហេតុនេះលោកសំរេចបញ្ជូនកងទ័ពម៉ែកហ្វ័ក្សចូលមកជួយខ្មែរនៅថ្ងៃទី៣០មិថុនា១៩៧០ ។

ជាលើកទី៣នៅថ្ងៃទី១៩កញ្ញា១៩៧០ ។ ទីបំផុតលោកបញ្ជូនទាំងអស់ ប្រគល់ជូនលោកលន់-នល់ ។ លោកសឺន-ង៉ុកថាញ់មានដំបូន្មានបន្តិចបន្តួចផ្ដាំទុកថា កូន

ចៅរបស់ខ្ញុំនេះស្គាល់ករណិយកិច្ច និងភារកិច្ចយ៉ាងច្បាស់ណាស់ ។ ប៉ុន្តែក្រុមនេះឧបមាដូចសត្វខ្លាមិនដែលស្គាល់សាច់ទេ ។ សុំកុំបង្គាប់ឲ្យវាចេះស៊ីសាច់ឲ្យសោះ។ មុនដំបូងជាកងទ័ពស្អាតស្អំ មួយកងវរៈសេនាតូច មានទាហានគ្រប់ចំនួនយ៉ាងត្រឹមត្រូវ យ៉ាងរៀបរយ ជាពិសេសស្គាល់ករណិយកិច្ចក្នុងសមរភូមិនិមួយៗ កំទេចខ្មាំងឲ្យបរាជ័យ ឲ្យបាក់មុខ ។ ទ័ពនេះក៏ចាប់ល្បីឈ្មោះពេញប្រទេសខ្មែរ ញ៉ាំងឲ្យមេទ័ពផ្សេងៗខ្លះទៀតដែលខ្លួនពាក់តែស័ក្តិ អង្គុយតែក្នុងការិយាល័យ កើតមានសេចក្តីច្រណែន ។ មានពេលខ្លះ កងទ័ពកំពុងជាប់ដៃប្រយុទ្ធជាមួយខ្មាំងជិតអស់គ្រាប់រំសេវ ចាត់តំណាងចូលកាន់រដ្ឋធានីភ្នំពេញសុំជំនួយ លោកដែលទទួលខុសត្រូវគ្រឿងសម្ភារៈបែរជាទារ «ថ្លៃទឹកតែ» ទៅវិញ ។

មានមេទ័ពចិត្តអាក្រក់ខ្លះ បែរជាឲ្យពាក្យសម្ងាត់ ( Mot de passe ou Password ) ទៅខ្មាំង បណ្តាលឲ្យកងទ័ពម៉ែកហ្វ៊ក្សត្រូវរងគ្រោះស្លាប់យ៉ាងច្រើន ។ មានពេលខ្លះការច្រណែននេះកើតជាវិវាទវាយតប់គ្នាពាសពេញរដ្ឋធានីភ្នំពេញ ។

បន្ទាប់មក មានចេញបញ្ជាបង្ខំឲ្យបង្កើតកងវរៈសេនាតូចបន្ថែម ។ ប៉ុន្តែលេខកងវរៈសេនាតូចនិមួយៗតម្លៃ៥០ម៉ឺនរៀលយ៉ាងតិច ។ តើលុយដ៏ធំធេងនេះ មេបញ្ជាការកងវរៈសេនាតូចទាំងឡាយនោះទៅរកឯណា ? ។ មូលហេតុនេះ កងទ័ពម៉ែកហ្វ៊ក្សត្រូវបង្ខំរៀនប្រព្រឹត្តអំពើពុករលួយតាមរៀមច្បង ។ នេះហើយបង្គាប់ឲ្យខ្លាចេះស៊ីសាច់ ដូចពាក្យបណ្តាំលោកសឺន-ង៉ុកថាញ់មែន ។

លុះកងទ័ពម៉ែកហ្វ៊ក្សចេះពុករលួយ ស្រាប់តែចេះជាងគ្រូទៅទៀត គឺឆ្លាតជាងរៀមច្បងឆ្ងាយណាស់ គឺពុករលួយជាអន្តរជាតិ ។ ក្រុមនេះចាប់ផ្តើមរកស៊ីម្តង ។ រឿងវាយសឹកត្រូវផ្អាកសិន ។ ក្រុមនេះចាប់ផ្តើមបញ្ជូនចោរស្របច្បាប់ទៅកាន់ស្រុកយួន រួចលួចឡានហ្ស៊ីប JEEP A1 ពីព្រៃនគរ បើកបរចូលមកកាន់ប្រទេសខ្មែរធ្វើព្រងើយ ញ៉ាំងឲ្យផ្អើលឆោឡោដល់អាមេរិកាំង ។ ចំណែកនៅព្រំដែនខ្មែរ-ថៃស្រាប់តែមានក្បួនឡាន GMC ៥ឬ៦គ្រឿងតម្រៀបជួរចេញពីរដ្ឋធានីភ្នំពេញ មានលិខិតបញ្ជា Ordre de Mission ត្រឹមត្រូវទៅដឹកអតីតកងទ័ពកន្សែងស ។ ប៉ុន្តែក្បួនឡានទាំងនោះ បររហូតទៅដល់ស្រុកអូរជ្រៅវិញ ស៊ីឈ្នួលដឹកនាំទំនិញរត់ពន្ធ ។ លុះក្បួនឡានវិលត្រឡប់មកពីអូរជ្រៅវិញ ក៏បរចូលមកឈប់នៅវត្តលាបខ្លះ ចូលមកឈប់នៅវត្តរំដួលខ្លះ ។

អស់លោកមេទ័ពរត់ស្ទុះស្ទាមកជួបបងទៀងបង្ហាញលិខិតបញ្ជាសុំដឹកទាហាន ។ គេរើសមួយចំនួនតូច តម្រៀបជួរឡើងឡាន ចំណែកទាហានដែលនៅសល់ច្រើនរយនាក់នេះ គេសុំថតយកតែរូបទៅបង្ហាញថ្នាក់លើ គិតលុយចែកគ្នាសិន ។ ទាហានដែលដឹកនាំយកទៅនោះ លុះដល់ភ្នំពេញក៏ហៅចុះពីឡាន ចោលរាយមា

យគ្មានរៀបចំបណ្តុះបណ្តាលបង្ហាត់ហ្វឹកហ្វឺនអ្វីទេ ។ ព្រោះមេៗរវល់តែទៅគិតថ្លៃឈ្នួលរត់ពន្ធ ដើម្បីយកលុយទៅសងថ្លៃទិញលេខកងវរៈសេនាតូច ។

ដូច្នេះទាហានទាំងនេះ ត្រូវវិលត្រឡប់មកកាន់ខេត្តបាត់ដំបងវិញ រួចវិលទៅជួបលោកថាច់-ជុង, ថាច់-អៀងសុំចុះឈ្មោះធ្វើទាហានម្តងទៀត តែលួចកែឈ្មោះផ្សេង ។

កងទ័ពម៉ែកហ្វ័ក្សទៅជារាយមាយ មានមេៗខ្លះមានប្រពន្ធពីរ ប្រពន្ធនិមួយៗត្រូវមានវីឡា ត្រូវមានឡាន មានអ្នកបើកបរ ។

មានពេលមួយនោះ កងវរៈសេនាតូចមួយ « លេខចុង៨៩ » ខ្វះកូនទាហានច្រើនពេក ស្រាប់តែឃើញមេៗ ដូចជាវរៈសេនិយទោ វរៈសេនិយត្រី មានខ្មែរកម្ពុជាកណ្តាលលាយជាមួយ បើកបរឡានហ្ស៊ីបមកចតឈប់ព្រោងព្រាតនៅមុខផ្ទះវិឡាបងទៀងនេះ ។ ស្មុះស្មារមករកបងទ្រី បងទៀង សុំកន្លែងប្រជុំនិយោជិករោងម៉ាស៊ីនកិនស្រូវនៅខេត្របាត់ដំបង ។ គេសុំថតយករូបទេ ។ និយោជិកម្នាក់ៗត្រូវឲ្យឈ្នួល៥០០រៀល ។ ថ្ងៃនោះ ថតចុះថតឡើងក៏ថតទាំងកូនប្រុសទី៣និងទី៤របស់បងទៀងយកទៅផង ។

លុះគណកម្មការពិនិត្យមើលរូបថត គេចាប់អារម្មណ៍នូវរូបថតកូនប្រុសរបស់បងទៀង២នាក់នៅក្មេងណាស់ គេហៅគ្នាពិនិត្យចុះពិនិត្យឡើង ពេលនោះលោកថាច់-ជានៅកន្លែងនោះដែរ លោកក្រឡេកឃើញស្គាល់ច្បាស់ជាកូនប្រុសរបស់បងទៀង លោកលូកដៃដកយករូបថតទាំង៤សន្លឹកផ្ញើមកបងទៀងវិញ ។ ដូច្នេះកងវរៈសេនាតូចនិមួយៗក្នុងបញ្ជីមានរូបថត មានឈ្មោះគ្រប់ចំនួនត្រឹមត្រូវ ប៉ុន្តែគ្មានទាហានតាមបញ្ជីនោះឡើយ ។ ដូចមានជាឧទាហរណ៍មួយ នៅថ្ងៃទី២៩កុម្ភៈ ១៩៧៤ នៅភូមិប្រសូត្រ ចម្ងាយ១០គ.ម. ពីទីក្រុងស្វាយរៀង យួនហាណូយបើកការវាយប្រហារយ៉ាងធំមួយ ។ វាបញ្ជូនបូដូយយ៉ាងច្រើនឲ្យចូលមកព័ទ្ធវាយកំទេចកងទ័ពជាតិនៅលើដើមទ្រូងមានពាក់រូបសម្តេចគ្រប់ៗគ្នា ។ ពេលនោះមានលោកមេបញ្ជាការកងវរៈសេនាតូចក្នុងកងវរៈសេនាធំម៉ែកហ្វ័ក្ស នាមត្រកូលថាច់ ទទួលបញ្ជាត្រូវនាំទាហានចេញទៅតទល់ចំពោះខ្មាំង ។ កងវរៈសេនាតូចអភ័ព្វនេះ មានទាហានតែ៦០នាក់ ។ លុះទៅដល់សមរភូមិឃើញខ្មាំងសុទ្ធតែបូដូយយ៉ាងច្រើនលើសលប់ក៏សំរេចចិត្តភ្លាម បញ្ជាឲ្យកូនទាហានរត់គេចចាកចេញចោលសមរភូមិទៅចុះ ។ ចំណែកមេបញ្ជាការថាច់ក៏បាញ់សម្លាប់ខ្លួននៅនឹងកន្លែងដើម្បីសងអំពើពុករលួយនេះ ។

ពេលនោះស្រីៗមេម៉ាយទាំងអស់ក៏លាន់មាត់ថា ៖ ឱ ! បើដូច្នេះសង្គ្រាមនៅក្នុងស្រុកខ្មែរ យួនហាណូយឆ្លៀតពេលប្រើយីហោសម្តេចឪ រួចបញ្ជាឲ្យបូដូយវា-

យកំទេចខ្មែរលន់-នល់ ជាម្ចាស់ទឹកដីកម្ពុជាពិតៗទេតើ ! ។ លោកតាអាងងក់ក្បាលព្រមទាំងបញ្ជាក់ថា យួនហាណូយបញ្ជាឲ្យបួដួយវាយកំទេចខ្មែរចាប់តាំងពីឆ្នាំ ១៩៧០ និងបន្តៗមក ។

នាងអង្គារ៉ាសុំសួរលោកតាអាងថា ហេតុម្តេចមានខ្មែរខ្លះលើកតំកើងយួនហាណូយ ទុកជាអ្នកមានឧបការគុណអញ្ចឹង ? ។

លោកតាដកដង្ហើមធំព្រោះពុថា ខ្មែរអរគុណមេឃាតករ មេចោរ... លោកតាតឹងទ្រូងណាស់ ។ ចំណែកលោកតាក៏យល់ច្បាស់ណាស់ ថាប្រទេសខ្មែរវិនាសហិនហោច ត្រូវរលាយទៅជាផេះនេះ គឺបណ្តាលមកពីយួនហាណូយទាំងអស់ ។ លោកតាក៏អធិប្បាយវែកញែកថា យួនហាណូយមានការពិសោធន៍ វាច្បាំងជាមួយខ្មែរពីរលើករួចមកហើយពីឆ្នាំ១៩៤៥ នៅកម្ពុជាក្រោម នៅឆ្នាំ១៩៥៤ នៅកម្ពុជាកណ្តាល ។ វាប្រើកម្លាំងបាយ វាប្រើកម្លាំងអាវុធជាកាំភ្លើង វាត្រូវស្លាប់តែហោង ត្រូវចាញ់ខ្មែរបោរមុខ វាក៏ដកទ័ពថយ វាយល់ថាបើធ្វើសង្គ្រាមជាមួយខ្មែរ ចង់ដណ្តើមជោគជ័យពីខ្មែរ ត្រូវតែប្រើកលល្បិច ត្រូវតែប្រើអាវុធចិត្តសាស្ត្រ ជាពិសេសត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវពាក្យមួយឃ្លា ៖

– បំបែកបំបាក់ដើម្បីគ្រប់គ្រង !

វាក៏ចាប់ផ្តើមអប់រំចារកិច្ចរបស់វា រួចបញ្ជូនបញ្ចូលគ្រប់សរសៃគ្រប់ស្រទាប់នៃប្រជាពលរដ្ឋខ្មែរ តាំងពីរាស្ត្រព្រៃភ្នំរហូតនាម៉ឺនក្នុងវាំង រហូតដល់មេដឹកនាំខ្មែរឲ្យសម្ងំរៀនសូត្រ ឲ្យស្គាល់ចរិតនិងចំណុចខ្សោយនានា ។ វាចេះសំរបខ្លួនឲ្យត្រូវចិត្តនាម៉ឺនខ្មែរ ឲ្យត្រូវចិត្តមេដឹកនាំខ្មែរ ។

មើលភាពខាងក្រៅឃើញថា យួនទន់ភ្លន់គោរពខ្មែរណាស់ ។ មូលហេតុនេះបានជាមេដឹកនាំខ្មែរ ទាំងសក្តិភូមិទាំងខ្មែរក្រហមត្រូវចាញ់បោកយួនហាណូយធ្ងន់សែនធ្ងន់ ។ ពីព្រោះជឿតែតាមត្រចៀក ជឿតែតាមភ្នែក មិនចេះប្រើខួរក្បាលប្រៀបធៀបរកហេតុផល ។ មិនចេះខំរៀនសូត្រឲ្យស្គាលគោលដៅ និងជំរៅឧបាយកលរបស់យួនហាណូយ ដើម្បីនាំយកមកពន្យល់បំភ្លឺដល់រាស្ត្រខ្មែរ បែរជាបណ្តោយឲ្យរាស្ត្រយល់ច្រឡំកាន់តែជ្រៅទៅៗ ។ លើកតំកើងសត្រូវសួរពូជដែលជាមេឃាតករ ដែលជាចោរបារយ ទុកជាអ្នកមានគុណទៅវិញ ។

តើមានអ្វីគួរឲ្យខ្មាស់អៀនជាងនេះទៅទៀត ? បើយើងបណ្តោយឲ្យរាស្ត្រខ្មែរបន្តការយល់ច្រឡំនេះ តើរាស្ត្រខ្មែរមានកម្លាំងកាយកម្លាំងចិត្តឯណាកំទេចយួនហាណូយនិងខ្មែរអាយ៉ង ដើម្បីរំដោះទឹកដីកម្ពុជា ? ។ យួនហាណូយវាចេះប៉ិនប្រសប់លាក់ពុត ប្រើឧបាយកលបង្ហាញឲ្យរាស្ត្រខ្មែរឬពិភពលោកឃើញថា វាសម្លាប់ខ្មែរឬធ្វើសង្គ្រាមជាមួយខ្មែរទេ វាលែលកបំបែកបំបាក់ខ្មែរជាក្រុមៗ រួចប្រើដៃខ្មែរ

អាយ៉ងពីក្រុមមួយរួចផ្លាស់ទៅក្រុមមួយទៀត បណ្តាក់គ្នាសម្លាប់បំផុតពូជខ្មែរជាដំណាក់ៗបានយ៉ាងស្អាត់ជំនួសវា ។ យួនហាណូយធ្វើព្រងើយសំរាកសម្ងំរង់ចាំឱកាសល្អទើបវាឈានមួយជំហានៗ យ៉ាងអាថ៌កំបាំងហាក់ក្រោកឡើង កញ្ឆក់យកជោគជ័យតែម្តង ។ ដូចជាថ្ងៃទី១៧មេសា១៩៧៥ជាដើម គឺយួនហាណូយជាវៀតកុងទេតើ ជាអ្នកទទួលជ័យជំនះដ៏មហាអស្ចារ្យមហាលោតផ្លោះនោះ ។ ប៉ុន្តែវាប្រើឈ្មោះអង្គការអនាមិកជាមេបញ្ជាការយ៉ាងជិតអន្ធកាជាស្ថាពរ ។

អង្គការគិតតែពីសម្លាប់បំផុតពូជខ្មែរ ហើយនៅពេលជាមួយគ្នានេះដែរ អង្គការបែរជាបញ្ចូលវៀតកុងមកកាន់ប្រទេសខ្មែរទាំងក្រុមៗ ។ ក្រុមខ្លះដើរប្រមូលអណិកជនយួន ដឹកនាំយកទៅទុកនៅស្រុកយួន ទុកធ្វើប្រឌិតបន្លំធ្វើជាខ្មែរទៅអនាគត ក្រុមផ្សេងទៀតដើរប្រមូលទ្រព្យសម្បត្តិ ក្នុងមួយនគរខ្មែរ ប្លន់ដឹកនាំចេញដោយសេរី ។ ទីបំផុតអង្គការបំផ្លាញប្រទេសខ្មែរឲ្យរលាយទៅជាផេះ ។ វាបង្កើតឃាតករជាច្រើនក្រុម ដាច់ៗដោយឡែកពីគ្នា ។ វាមានបង្កើតក្រុមឃាតករអាថ៌កំបាំង រួចទើបវាបញ្ចេញជាលំដាប់លំដោយ កំណត់ថ្ងៃខែឆ្នាំយ៉ាងត្រឹមត្រូវ ។

★ ដូចជាឃាតករក្រុមទី១ ៖ ត្រូវសម្លាប់ខ្មែរលន់-នល់, ខ្មែរសីហនុ ជាពិសេសសម្លាប់អតីតអ្នករដ្ឋការគ្រប់ផ្នែក គ្រប់ជាន់ថ្នាក់ អ្នកចេះដឹង និស្សិត បញ្ញវ័ន្ត និងព្រះសង្ឃជាដើម ។

★ ឃាតករក្រុមទី២ ៖ មានភារកិច្ចត្រូវសម្លាប់ឃាតករក្រុមទី១វិញ គឺសម្លាប់បក្សខ្មែរក្រហមនិន្នាការខ្មែរ មានខ្មែរក្រហមក្រុមខៀវ-សំផន និងក្រុមខ្មែរក្រហមកើតមកពីចោរព្រៃ ។ ដូច្នេះក្នុងរយៈពេល៩៩ខែ អង្គការចាត់ការសម្លាប់បំផុតពូជខ្មែរ ជាដំណាក់ៗមានលំនាំយ៉ាងស្អាត ។

លុះដល់ឆ្នាំ១៩៧៨ ប្រទេសខ្មែរចំហធ្លុង ។ ឱកាសល្អមកដល់យ៉ាងនេះ យួនហាណូយជាវៀតណាមឈានជំហានទី២ វាក៏បញ្ជាឲ្យបូដូយចេញពីព្រៃ ចូលមកវាតត្បាតលុកលុយពាសពេញទីក្រុងនៃប្រទេសកម្ពុជា ដោយយកលេសថា ចូលមកកំទេចខ្មែរក្រហម ដើម្បីរំដោះខ្មែរ ញ៉ាំងឲ្យរាស្ត្រខ្មែរដែលមិនបានសិក្សានយោបាយ មិនបានតាមដានកលល្បិចខ្មាំង មិនចេះត្រិះរិះពិចារណា ក៏ជឿយួន យល់ច្រឡំយ៉ាងធ្ងន់សែនធ្ងន់ក៏សន្និដ្ឋានថា យួនស្មគ្រចិត្តមកស្លាប់ និងមកជួយខ្មែរជាលើកទី៣ ។ ខ្មែរទាំងនេះក៏ដឹកលល់ដំកើងយួនហាណូយជាវៀតកុង ដែលជាមេឃាតករដែលជាចោរ ទុកជាអ្នកមានឧបការគុណទៅវិញ ។

- ឱ ! បងប្អូនខ្មែរអើយ ! ហេតុអ្វីក៏ស្លូតស្លាប់ម្ល៉េះ ?
- ឱ ! មេដឹកនាំខ្មែរអើយ ! ត្រូវចេះភ្ញាក់រលឹកឡើង !
- បើបណ្តោយឲ្យរាស្ត្រខ្មែរយល់ច្រឡំយ៉ាងនេះ តើធ្វើម្តេចរាស្ត្រខ្មែរចេះប្រុង

ប្រយ័ត្ន ?

– តើធ្វើម្ដេចរាស្ត្រខ្មែរមានកម្លាំងកាយ កម្លាំងចិត្ត លើកដៃកំទេចខ្មាំង កំទេចចោរ ដើម្បីរំដោះមាតុភូមិកម្ពុជា ?

លោកតាអាងនិយាយដល់ត្រឹមហ្នឹង រ៉ាដាក៏សុំសួរយោបល់លោកតាអាងថា ហេតុម្ដេចបានជាអង្គការដេញប្រជាជន ក្នុងមួយនគរជាច្រើនលាននាក់ ឲ្យចេញចោលទីលំនៅឆ្ងាយពីផ្លូវជាតិ ពីដងស្ទឹង មានចម្ងាយយ៉ាងតិច២គ.ម. ? ។

ឮសំនួរដ៏មានខ្លឹមសារនេះ លោកតាអាងមានការឈឺចាប់យ៉ាងក្រៃលែង ។ លោកតាធ្វើមុខស្លូត ទើបវែកញែកពន្យល់ដូចតទៅ ៖

រឿងនេះអស្ចារ្យណាស់, កាលណោះអាណិកជនយួនវាបែរជាបញ្ជូនមនុស្សអាថ៌កំបាំងទៅប្រាប់ថា ចូរនៅឲ្យស្ងៀម តាមទីកន្លែងរៀងៗខ្លួនសិន ។ វាជន្លៀសតែប្រជាពលរដ្ឋខ្មែរទេ ។ ដូច្នេះរឿងមិនសមទំនងបែបនេះ គឺអង្គការអនាមិកមានព្រៀងគំរោងការណ៍ជាស្រេច ។

ទី១– សម្លាប់ប្រជាពលរដ្ឋខ្មែរដោយមិនបាច់ប្រើអាវុធ ។

ទី២– បញ្ជូលវៀតកុងមកកាន់ប្រទេសខ្មែរប្រមូលអាណិកជនយួនរំដោះ នាំយកទៅលាក់ទុកឯប្រទេសយួន ។

ទី៣– ប្លន់ទ្រព្យសម្បត្តិរបស់ខ្មែរ ដឹកនាំយកទៅកាន់ស្រុកយួន ។

មើលចុះ ! ប្រជាពលរដ្ឋខ្មែរក្នុងមួយនគរដែលមិនទាន់ដល់វេនស្លាប់ ត្រូវតែចេញចោលទីលំនៅ ត្រូវចោលទ្រព្យសម្បត្តិយ៉ាងច្រើនឥតគណនា ។ កំពុងដឹកដៃកូនចៅ សែងមនុស្សចាស់ជរា សែងអ្នកជម្ងឺធ្ងន់ សែងប្រពន្ធទើបកើតកូនរួច ដើរដោយជើងនាំគ្រួសារទៅដេកពាសព្រៃ ពឹងដីជាគ្រែ ពឹងមេឃជាដំបូល កំពុងបន្តកន្ទុយគ្នាស្លាប់ បណ្ដាលមកពីឈឺគ្មានថ្នាំ បណ្ដាលមកពីដាច់ពោះ បណ្ដាលមកពីអស់សង្ឃឹមក៏សម្លាប់ខ្លួន ។

ឆ្លៀតពេលចលាចលនេះ អង្គការបែរជាបញ្ជូនវៀតកុងដែលចេះភាសាខ្មែរ ជាក្រុមៗចូលមកកាន់ស្រុកខ្មែរ ។ ក្រុមខ្លះដើរប្រមូលអាណិកជនយួន ដែលមានទីលំនៅនៅស្រុកខ្មែរ ឲ្យតម្រៀបជួរឡើងឡាននិងចុះទូក មានទំនុកបំរុងបាយទឹកយ៉ាងគ្រប់គ្រាន់ រួចដឹកនាំយកទៅលាក់ទុកឯស្រុកយួន មានចំនួនជាង២សែននាក់ ទុកសំរាប់វាកែឆ្នៃបន្លំធ្វើជាខ្មែរទៅអនាគត ។

ចំណែកឯក្រុមផ្សេងទៀតដើរប្រមូលឡានធំៗ ទូកធំៗ សណ្ដោងជាមួយកាណូត រួចប្រមូលទ្រព្យសម្បត្តិនគរខ្មែរទាំងអស់ រៀបឡើងឡាន រៀបចុះទូក ដឹកនាំចេញជាហូរហែរទៅកាន់ប្រទេសយួន ។

ក្បួនឡានទាំងឡាយនោះដឹកតែពេលយប់ ចំណែកក្បួនទូកធំៗ សណ្ដោងជា

មួយកាណូតបើកបរ ទាំងថ្ងៃទាំងយប់ ។

ក្នុងរយៈពេល៣ឆ្នាំ ទ្រព្យសម្បត្តិប្រទេសខ្មែរត្រូវយួនហាណូយជាវៀតកុងប្រមូលដឹកប្លន់ដឹកនាំចេញអស់រលីង ។ ចូលឆ្នាំ១៩៧៨ អង្គការបញ្ជាឲ្យរុះរើវីឡាធ្វើពីគ្រឿងឈើ ។ លោកតានិយាយដល់ត្រឹមនេះ ក៏លើកដៃចង្អុលកំទេចឥដ្ឋផ្ទះវីឡារបស់យាយទៀង ព្រមទាំងធ្វើអត្ថាធិប្បាយបង្ហាញជាឧទាហរណ៍ ថាដូចជាផ្ទះវីឡារបស់បងទៀងជាដើម និងផ្ទះវីឡាគ្រឿងឈើសង់ស្ថិតនៅភូមិក្រោយវត្តរំដួលជាច្រើនរយគ្រឿង ត្រូវរុះរើ រួចប្រមូលបញ្ចុះទូកដែលឈប់ចតជាហូរហែរនៅដងស្ទឹងសង្កែរមុខវត្តរំដួល ចាប់តាំងពីខែកុម្ភៈឆ្នាំ១៩៧៨និងបន្តៗមក ។ ក្រុមរុះរើផ្ទះទាំងនោះ និងអ្នកទទួលខុសត្រូវក្បួនទូក គឺយួនទាំងអស់ ។

ចុងឆ្នាំ១៩៧៧ និងក្នុងឆ្នាំ១៩៧៨ អង្គការបញ្ជាឲ្យប្រជាជនខ្មែរ ដើរប្រមូលតុជើងម៉ា និងទូរក្នុងសាលារៀននានា បញ្ចុះក្នុងទូកធំៗសណ្តោងជាមួយកាណូតដែលឈប់ចតជាហូរហែរមុខមន្ទីរពេទ្យធំបាត់ដំបង ដឹកនាំចេញជាចុងបង្ហើយ អ្នកទទួលខុសត្រូវក្បួនទាំងនោះ ក៏សុទ្ធតែយួនទាំងអស់ដែរ ។

លោកតាអាងបញ្ជាក់ថា មានរឿងមួយគួរឲ្យចម្លែកណាស់ គឺក្នុងខែមេសាឆ្នាំ១៩៧៨ បង្គការបញ្ជាឲ្យក្រុមឃាតករអាថ៌កំបាំងសម្លាប់អាណិកជនយួន ដែលពួនលាក់ខ្លួននៅក្នុងស្រុកខ្មែរវិញ ។ ឮដូច្នេះយាយគក់សុំសួរកាត់លោកតាអាងថា ៖

– ហេតុម្តេចក៏សម្លាប់យួន បើយើងសន្និដ្ឋានថា អង្គការអនាមិកជាយួននោះ ?

– នេះជាកលល្បិចឆ្លិនភ្នែកប៉ិនប្រសប់យ៉ាងអស្ចារ្យ ។ អង្គការគោរពតាមពាក្យមួយឃ្លា គឺទុកមិនចំណេញដកចេញមិនខាត ពីព្រោះយួនផុននេះជាយួនចោលម្សៀត មិនព្រមទៅតាមវៀតកុង ។ ដូច្នេះអង្គការត្រូវតែសម្លាប់ចោល ដើម្បីបង្វែងនិងលប់ដាន បំភ័ន្តមតិរាស្ត្រខ្មែរ អង្គការសម្លាប់ទាំងខ្មែរ សម្លាប់ទាំងយួន ។ ម៉្យាងទៀតយកលេសដើម្បីយួនហាណូយបញ្ជូនបូដូយចូលមកលុកលុយប្រទេសកម្ពុជា ។ ពេលសម្លាប់អាណិកជនយួននេះ អង្គការលែបខ្លំសម្លាប់ទាំងខ្មែរកម្ពុជាក្រោមទាំងចាស់ទាំងក្មេងទាំងស្រី ចោទថាជាបណ្តាញរបស់យួន ។

ការពិតអង្គការយកចិត្តទុកដាក់តាមដានខ្មែរកម្ពុជាក្រោមជានិច្ច ពីព្រោះអង្គការស្គាល់ជំរៅចិត្តនៃរាស្ត្រខ្មែរកម្ពុជាក្រោម ដែលនាំគ្រួសាររត់ចោលទឹកដីកម្ពុជាក្រោមទុកឲ្យយួន ហើយមកជ្រកសំណាក់នៅកម្ពុជាកណ្តាល ។ គ្រប់ៗរូបនាំមកនូវសេចក្តីឈឺចាប់គំនុំសងសឹកចំពោះយួន ដែលជាសាសន៍ព្រៃផ្សៃ ជាមេឃាតករជាចោរប្លន់ទឹកដី ជាចោរសម្លាប់ជាតិសាសន៍ ដូចជាតាំងពីថ្ងៃទី២១ឧសភា១៩៤៩ យួនលេបទឹកដីកម្ពុជាក្រោមជាលើកទី២ ។ យួនហ៊ានបំពានច្បាប់អន្តរជាតិ យួនប្រកាសថា ខ្មែរកម្ពុជាក្រោមចំនួន៤លាននាក់ដែលជាម្ចាស់ទឹកដី ជាជាតិយួនទាំង

អស់ ទោះគ្នាមិនចេះភាសាយួនមួយម៉ាត់ក៏ដោយ ។ អំពើអយុត្តិធម៌នេះញ៉ាំងឲ្យរាស្រ្តខ្មែរកម្ពុជាក្រោមដែលមានមធ្យោបាយរត់ ក៏នាំគ្រួសាររត់គេចចាកចេញពីកណ្តាប់ដៃចោរប្លន់ទឹកដី ចោរប្លន់ជាតិសាសន៍ យកជ្រករស់នៅកម្ពុជាកណ្តាល ដើម្បីរក្សាឲ្យគង់វង់ពូជអំបូរជាជាតិខ្មែរដដែល ។

អង្គការយល់ជំរៅចិត្តរាស្រ្តខ្មែរកម្ពុជាក្រោម ដែលភៀសខ្លួនមកជ្រកនៅកម្ពុជាកណ្តាល បើពេលណាឃើញយួនហាណូយជាវៀតកុង ចូលមកលុកលុយប្រទេសកម្ពុជា មុខជាខ្មែរក្រោមទាំងនោះក្រៅឡើងចង្អុលមុខយួនហាណូយជាវៀតកុង ស្រែកចោទភ្លាម នេះជាអង្គការអនាមិក នេះជាមេឃាតករ ។ មុខជាខ្មែរកម្ពុជាក្រោមយល់ថា វិបត្តិក្នុងប្រទេសខ្មែរ បណ្តាលឲ្យរាស្រ្តខ្មែរត្រូវស្លាប់ជាច្រើនលាននាក់មិនទំនងនេះ គឺយួនហាណូយបន្លំកែឆ្នៃដើម្បីលេបប្រទេសកម្ពុជា បញ្ចូលក្នុងសងព័ន្ធឥណ្ឌូចិនទេតើ ! ។ ពីព្រោះរាស្រ្តខ្មែរកម្ពុជាក្រោមស្គាល់ច្បាស់ស្នៀតរបស់យួនហាណូយ វាប៉ិនប្រសប់ប្រើល្បិចកល មានជាបញ្ញោស់មានជាបណ្តោយ គឺដៃមួយអង្អែល ដៃមួយទៀតសំពង សឹងគ្មានសាសន៍ណានៅលើពិភពលោកធ្វើបានដូចវាឡើយ ។ ព្រោះខ្មែរកម្ពុជាក្រោមត្រូវទទួលរងគ្រោះជាច្រើនលើកច្រើនសារដូចជាជំនាន់ « កំពប់តែអុង », ជំនាន់ « លោកឧកញ៉ាសឹន-គុយ », ជំនាន់ « យួនវៀតមិញប្រមូលខ្មែរកម្ពុជាក្រោមដុតក្នុងជង្រុកស្រូវ » ដូច្នេះខ្មែរកម្ពុជាក្រោមមិនជឿដាច់ខាតថា « បូដូយចិត្តល្អស្ម័គ្រចិត្តមកងាប់ជួយខ្មែរឡើយ » ។

អង្គការយល់ថា ខ្មែរកម្ពុជាក្រោមទាំងឡាយនោះ មុខជាមិនឱបដៃនៅស្ងៀមមិនស្រែកអរគុណយួនដូចបងប្អូនខ្មែរខ្លះនៅកម្ពុជាកណ្តាលឡើយ ។ មូលហេតុនេះ ដើម្បីចៀសវាងកុំឲ្យមានឧបសគ្គរាំងដល់យួនហាណូយជាវៀតកុង អង្គការធ្វើជាច្រឡំសម្លាប់រាស្រ្តខ្មែរកម្ពុជាក្រោមវីវក់ ចោទថាជាយួន ចោទថាជាបណ្តាញរបស់យួន ។

ហេតុការណ៍ដែលលោកតាអាងខំស្រាវជ្រាវ រួចធ្វើអត្ថាធិប្បាយវែកញែកជាហូរហែរមកនេះ អាចបញ្ជាក់បង្ហាញឲ្យខ្មែរយើងយល់ថា អង្គការអនាមិកនិងយួនហាណូយមានផែនការព្រាងទុកជាស្រេចៗ គឺក្នុងរបបរបស់អង្គការ តើយួនត្រូវធ្វើអ្វីបន្តទៅទៀត ? ។ មិនមែនឧប្បត្តិហេតុនៃប្រទេសខ្មែរកើតមានឡើងដោយចៃដន្យឡើយ ។

លោកតាអាងបញ្ជាក់ទៀតថា យួនហាណូយចូលមកលុកលុយប្រទេសខ្មែរជាលើកទី៣ នៅថ្ងៃទី៧មករា១៩៧៩ គឺវាមកជំនួសអង្គការអនាមិកយ៉ាងពិតប្រាកដ ។ មើលចុះ ! បូដូយកំពុងបើកបរឡានដើរប្រមូលយោធាខ្មែរក្រហមក្មេងៗ ដែលអង្គការលត់ដំដល់កំពូលរួចហើយ និងប្រមូលក្រុមខ្មែរក្រហមនិរតី នាំយកមកបំ-

ពាក់អាវុធឲ្យឡើងវិញ ។ ប៉ុន្តែមិនទាន់ឲ្យប្រាក់ខែនៅឡើយទេ គឺឆ្អែប្រឱតក្រុមនេះឲ្យទៅជាចោរសិន ពីព្រោះពេលនោះមាសពេជ្រមានតម្លៃឡើងវិញ ទំនិញនានាក៏លក់ទិញដោយសេរីឡើងវិញ គឺទិញតែនឹងមាស ។ ដូច្នេះជំរុញក្រុមនេះឲ្យក្លាយទៅជាឃាតករមួយលើកទៀត ។ ស្នៀតនេះគឺជាស្នៀតវាយទឹកកំចាយត្រី ។ ស្នៀតនេះប្រសើរណាស់ យួនហាណូយជាវៀតមិញប្រើស្នៀតនេះកំចាយខ្មែរកម្ពុជា-ក្រោមមួយលើកហើយ ចាប់ពីឆ្នាំ១៩៤៥ដល់ឆ្នាំ១៩៥៤ ។ កាលណោះយួនហាណូយជាវៀតមិញខ្ចីដៃយួនខាងត្បូង ឲ្យសម្លាប់កំចាយ ប្លន់ដុតផ្ទះ ញាំងឲ្យរាស្ត្រខ្មែរកម្ពុជាក្រោមអ្នកចេះដឹង អ្នកមានមធ្យោបាយ ត្រូវតែបង្ខំចិត្តនាំគ្រួសាររត់ចោលទឹកដីជាកេរ្តិ៍មរតកទុកឲ្យយួនៗនៅគរទៅហើយ ។

ឥឡូវស្នៀតដដែលនេះ គឺយួនហាណូយជាវៀតណាមដដែលកំពុងនាំយកមកសាបព្រួសពាសពេញក្នុងប្រទេសខ្មែរ ។ ប៉ុន្តែវាប្រើកលល្បិចប្រយោល គឺតាមខ្សែរយៈអតីតខ្មែរក្រហមជាខ្មែរអាយ៉ងរបស់វាប្រើស្នៀតចោរ ។ មូលហេតុនេះប្រជាពលរដ្ឋខ្មែរជាម្ចាស់ទឹកដីកម្ពុជាពិតៗ អស់សង្ឃឹមគ្មានទីពឹង ត្រូវតែបង្ខំចិត្តនាំគ្រួសារដែលសេសសល់នៅរស់បន្តិចបន្តួច ដើរចេញចោលប្រទេសកម្ពុជាជាហូរហែរ បោះបង់ដីជាកេរ្តិ៍មរតកទុកឲ្យយួននៅមួយនគរទៀត ។ ចំណែកយួនហាណូយវាសម្ងំស្ងៀម វាខ្ចីដៃខ្មែរអាយ៉ងជាចោរឲ្យកំទេចខ្មែរសិនចុះ ។ ឆ្លៀតពេលនេះ វាជាចោរយ៉ាងចេញមុខ ។

- មើលចុះ ! វាកំពុងប្រមូលទ្រព្យសម្បត្តិខ្មែរ លើកដាក់ឡានដឹកនាំចេញទៅកាន់ប្រទេសយួនជាហូរហែរដោយសេរី ។ សរុបសេចក្តី យួនហាណូយជាសត្រូវសួរពូជនៃជាតិខ្មែរយើង ជាច្រើនសតវត្សមកហើយ ។ វាប្រើគ្រប់កលល្បិចសម្លាប់បំផុតពូជខ្មែរ ! វាប្រើគ្រប់កលល្បិចដើម្បីកំចាយខ្មែរឲ្យរត់ចោលទឹកដី ! ប៉ុន្តែមាត់របស់វាស្រែកបង្ហែងដាន បំភ័ន្តមតិរាស្ត្រខ្មែរ បំភ័ន្តមតិអន្តរជាតិថា បូជួយស្មោគ្រចិត្តបូជាឈាមស្រស់សាច់ស្រស់ចូលមកជួយខ្មែរ ។ ការពិតវាចូលមកមួយលើក ៗ វាខំញុះញង់បំបែកបំបាក់ខ្មែរ វាបង្កើតខ្មែរថ្មី គឺខ្មែរអាយ៉ងរបស់វាដូចជា ៖

- សឺន-ង៉ុកមិញ
- ទូ-សាមុត
- ប៉ុល-ពត
- ហេង-សំរិន
- ជា-ស៊ីមជាដើម នាំយកមកជំនួសខ្មែរយើងជាម្ចាស់ទឹកដីកម្ពុជាពិតៗ ។ គ្រប់ៗឧបករណ៍វាសម្ងំលាក់ពុតក្រោយខ្នងខ្មែរអាយ៉ងរបស់វា រង់ចាំឱកាសល្អមកដល់ ទើបវាឈានមួយជំហានៗក្រោកឡើងកំទេចខ្មែរបានយ៉ាងស្អាតវាលាក់មុខបាន

យ៉ាងជិតដដែល ។ ឧទាហរណ៍ដូចជា វាប្រើតែឈ្មោះអង្គការ វាអាចសម្លាប់ប្រជាពលរដ្ឋខ្មែរស្លូតត្រង់ ជាពិសេសអ្នកចេះដឹងចំនួន៣លាននាក់ ។

លុះចូលឆ្នាំ១៩៧៩ ប្រទេសកម្ពុជាចំហផ្លូង យួនហាណូយដើរ៉ុយចូលមកលុកលុយរាតត្បាតប្រទេសកម្ពុជាយ៉ាងពេញមុខធ្វើព្រងើយ ។

ចំណែកមេដឹកនាំខ្មែរគ្រប់ៗបក្សបះកន្ទុយច្រូង បោលរត់យករួចខ្លួន ប៉ុណ្ណឹងទៅហើយមិនទាន់ភ្ញាក់រលឹកទៀត ។ ចំណែករាស្ត្រខ្មែររត់គេចបីកណ្តាប់ដៃរបស់អង្គការ បែរជាចូលចំកណ្តាប់ដៃបូដួយត្រូវបូដួយចង្អុលមុខសំឡុត សួររកប៉ុលពត ដែលរាស្ត្រខ្មែរមិនដែលស្គាល់ទាល់តែសោះនោះទៅវិញ ។ មើលចុះ ! សង្គ្រាមក្នុងប្រទេសកម្ពុជាសែនងងឹតអន្ធកា ញាំងឲ្យប្រទេសកម្ពុជារលាយទៅជាផេះទៅហើយ មិនទាន់ដឹងថាអ្នកណាច្បាំងជាមួយអ្នកណា ? ។ មូលហេតុនេះ ទើបខ្ញុំខំស្រាវជ្រាវទាល់តែរកឃើញអំពីលក្ខណៈនៃសង្គ្រាមក្នុងប្រទេសកម្ពុជា ។ គឺសង្គ្រាមរវាងយួននិងខ្មែរ ! ។

ពេលនោះរ៉ាដាសុំសួរបញ្ជាក់លោកតាអាងថា ៖

- បើអញ្ចឹងអង្គការ គឺយួនហាណូយឬ ?

លោកតាងក់ក្បាលបង្ហាញកាយវិការថា អញ្ចឹងមែន ! ។

រ៉ាដាសុំសួរលោកតាទៀតថា ៖

- ចុះរឿងយួនយកក្បាលខ្មែរធ្វើជាជើងក្រានដាំតែឲ្យអុងនោះ តើជារឿងពិតឬលោកតា ? ។

- សំនួរនេះត្រូវចិត្តគាត់ណាស់ ព្រោះគាត់ចង់ផ្សាយឲ្យកូនចៅខ្មែរជំនាន់ក្រោយដឹងនិងស្គាល់ នូវអំពើឃោរឃៅរបស់យួនចំពោះខ្មែរ ដែលមានសភាពសាហាវជាងសាហាវទៅទៀត ។ លោកតាលើកដៃស្ទាំអង្អែលក្បាលរ៉ាដា ព្រមទាំងឆ្លើយថា

- រឿងនេះជារឿងពិតណាស់ ! ។

គាត់ធ្វើអត្ថាធិប្បាយពីប្រវត្តិ «កំពុបតែអុង» ឲ្យអ្នកទាំងអស់គ្នាស្តាប់ ។

ពេលនោះស្រីៗមេម៉ាយទាំងអស់ដែលអង្គុយស្តាប់ ក៏លាន់មាត់ថា ៖

- ឱ ! ពុទ្ធោៗ យួនសម្លាប់ខ្មែរសាហាវមែនៗ ! ។

លោកតាអាងនិទានបន្តទៅទៀតថា លុះចុងសតវត្សទី១៩ គឺក្នុងឆ្នាំ១៨៧១ ក្នុងរបបបារាំងគ្រប់គ្រងឥណ្ឌូចិន ស្រាប់តែមានអុងយួនម្នាក់ចេញប្រកាស៣ខ បង្ខំឲ្យខ្មែរកម្ពុជាក្រោមគោរពតាមវាជាដាច់ខាត ៖

ខទី១- បង្ខំឲ្យខ្មែរកម្ពុជាក្រោមនិយាយភាសាយួន

ខទី២- បង្ខំឲ្យខ្មែរកម្ពុជាក្រោមស្លៀកពាក់របៀបយួន

ខទី៣- បង្ខំឲ្យព្រះសង្ឃខ្មែរកម្ពុជាក្រោមដោះស្បង់ចីពរចោល ត្រូវតែស្លៀក

ខោពាក់អាវដូចលោកយួន ។ ពេលសូត្រធម៌ត្រូវវាយត្រដោកក្បាលត្រីម៉ុកៗ ដូចលោកយួន ។

កាលណោះរាស្ត្រខ្មែរកម្ពុជាក្រោម ក៏ចលាចលក្ដៅក្រហាយ នឹងប្រកាសជាច្បាប់ព្រៃផ្សៃរំលោភសិទ្ធិមនុស្សនេះ ។ កំពុងអស់សង្ឃឹម ស្រាប់តែទទួលដំណឹងថា មានវិរៈបុរសខ្មែរម្នាក់ ឈ្មោះឧកញ៉ាសឺន-គុយ ជាចៅហ្វាយខេត្តខេត្តត្រាវិញ-ព្រះត្រពាំង កំពុងចូលទៅតវ៉ាប្រឆាំងជំទាស់ជាមួយអុងយួនដ៏អប្រិយ ដែលចេញប្រកាសនេះ ។

ក្នុងពេលលោកឧកញ៉ាសឺន-គុយចូលទៅតវ៉ានឹងវា អុងយួនអប្រិយសើចរ-លាក់ដូចយក្ស ព្រមតាំងសួរតបយ៉ាងព្រហើនថា ៖

- តើលោកឧកញ៉ាស្ម័គ្រចិត្តយកជីវិតរបស់លោក ទៅប្ដូរនឹងលក្ខ័ណទាំងបីនេះឬទេ ? ។

វិរៈបុរសខ្មែរយើងក៏សើច សើចហើយសើចទៀត គឺសើចចំអកតបឲ្យអុងយួននោះវិញ រួចលើកដៃទះទ្រូងឆ្លើយតបយ៉ាងខ្លីថា ៖

- សុខចិត្ត ! ។

អុងយួនភ្ញាក់ ! វាក៏និយាយទូរលេខទៅសុំយោបល់ពីអគ្គទេសាភិបាលឥណ្ឌូចិនប្រចាំការនៅហាណូយ ជាពិសេសវាសុំអនុញ្ញាតកាត់ក្បាលលោកឧកញ៉ាសឺន-គុយ ។

លោកឧកញ៉ាសឺន-គុយ ជាវិរៈបុរសខ្មែរដ៏ក្លាហានធ្វើពលិកម្មប្ដូរជីវិតរបស់លោកនឹងលក្ខ័ណទាំងបីខរបស់យួន ដើម្បីរក្សាខ្មែរកម្ពុជាក្រោមឲ្យនៅជាខ្មែរ ទាំងភាសា ទាំងទំនៀមទំលាប់ ទាំងវប្បធម៌ ជាពិសេសព្រះពុទ្ធសាសនា ។

ពេលនោះមហាវិរៈបុរសខ្មែរយើង សុំអនុញ្ញាតពីអុងយួនរៀបចំបាយ នំចំណីនិងផ្លែឈើគ្រប់មុខ មានចំនួន៥ស្លែក ដំកល់ថ្វាយគ្រប់ទិសទាំង៨ រួចលោកចាប់ផ្ដើមពិធីបួងសួង ឧទ្ទិសថ្វាយដល់ទេវតា សុំលោកធ្វើជាសាក្សីដល់ខ្លួនរបស់លោកហ៊ានធ្វើពលិកម្ម យកជីវិតរបស់លោកដូរនឹងខទាំងបីរបស់អុងយួននោះ ។ ប៉ុន្តែមុននឹងប្រារព្ធពិធីបួងសួង លោកស្រែកប្រកាសហាមកូនចៅខ្មែរកម្ពុជាក្រោម មិនឲ្យរៀបការជាមួយយួនជាដាច់ខាត ។ លោកទូន្មានកូនចៅខ្មែរជំនាន់ក្រោយ ៖

- ឲ្យខំកសាងវត្ត ។
- ត្រូវគោរពស្ដាប់បង្គាប់ព្រះសង្ឃ ដែលជាគ្រូដើម ។

លោកស្គាល់ច្បាស់នូវឫសគល់ខ្មែរ ទំនៀមទំលាប់ អារ្យធម៌ និងវប្បធម៌ខ្មែរ។

- ព្រះសង្ឃត្រូវខំគោរពវិន័យ ។
- ស្រីៗត្រូវចេះគោរពក្រិត្យក្រមប្រពៃណីខ្មែរ ។

លោកឧកញ៉ាំរំលឹកទូន្មានដាស់តឿនកូនចៅខ្មែរកម្ពុជាក្រោមថា ៖

- អាវុធដ៏មុតស័ក្តិសិទ្ធិដែលអាចការពារជាតិបាន គឺខ្មែរត្រូវចេះសាមគ្គីគ្នាពិត ៗ ត្រូវចេះរួបរួមចងបាច់គ្នាឲ្យបានស្អិត ពួតដៃគ្នាជាធ្លុងមួយ ត្រូវចេះអត់ឱនគ្នា ទើបខ្មែរអាចរក្សាជាតិខ្មែរបានគង់វង់ទៅអនាគត ។

- គ្មានសាសន៍ណាស្រឡាញ់ជាតិខ្មែរជាងខ្មែរខ្លួនឯងទេ ! ។

- បើខ្មែរមិនចេះជួយខ្មែរ ក៏មិនដឹងជាសង្ឃឹមលើសាសន៍ណាឲ្យគេមកជួយខ្មែរបានឡើយ ។

- ចូរកុំជឿ កុំទុកចិត្តសាសន៍ដទៃឲ្យសោះ ។

លុះមហាវិរៈបុរសសឺន-គុយទូន្មានផ្តែផ្តាំកូនចៅខ្មែរកម្ពុជាក្រោមរួច លោកក៏ប្រកាសបួងសួងដល់ទេវតាទាំង៨ទិស លោកអំពាវនាវសុំផ្តាំផ្ញើនូវវាសនាអនាគតនៃកូនចៅខ្មែរកម្ពុជាក្រោម ។ លោកសុំទេវតាជួយថែរក្សាការពារកូនចៅខ្មែរកម្ពុជាក្រោមណាដែលស្មោះត្រង់ចំពោះជាតិ ចេះស្នេហាជាតិ ចេះជួយទុក្ខធុរៈខ្មែរ សូមកូនចៅខ្មែរទាំងនោះចាកផុតពីគ្រោះថ្នាក់គ្រប់បែបយ៉ាង សូមប្រកបតែសេចក្តីសុខចំរើន និងអាចឈ្នះសត្រូវទាំង៨ទិស ។ ផ្ទុយទៅវិញ សូមទេវតាផ្តន្ទាទោសយ៉ាងធ្ងន់ដល់ខ្មែរណាដែលក្បត់ខ្មែរ ។

លុះប្រារព្ធពិធីបួងសួងចប់សព្វគ្រប់ហើយ មហាវីរៈបុរសយើងនឹងឃើញឈឺចិត្ត អំពីបញ្ហាកំពប់តែអុង អំពីបញ្ហាយួនលេបទឹកដីកម្ពុជាក្រោមក្នុងឆ្នាំ១៨៤០ នៅក្តៅហុយៗ ។ ឥឡូវខ្លួនរបស់លោកត្រូវចំណាយជីវិតដូរនឹងច្បាប់ព្រៃផ្សៃរបស់យួនអប្រិយបីខនេះទៀត ។ លោកឧកញ៉ាខឹងនឹងយួនណាស់ ក៏ជេរដាក់បណ្តាសារយ៉ាងធ្ងន់ៗដល់អាចោរយួនប្លន់ទឹកដី ជាពិសេសជេរអាអុងយួនអប្រិយដែលជាអ្នកចេញប្រកាសនោះ ។ ព្រជេរយ៉ាងដូច្នោះ អុងយួនក៏ដើរទៅមើលលោកឧកញ៉ា ស្រាប់តែស្តកទាំង៨ហោះរឹងៗប្រាវៗមករកក្បាលវា ។ អុងយួនខឹងដាច់ក្បាលដាច់កន្ទុយ ក៏បញ្ជាឲ្យកូនចៅរបស់វាចាប់លោកឧកញ៉ាសឺន-គុយច្រានចូលក្នុងម៉ាស៊ីនកាត់ក ( កាលខ្ញុំនៅតូច ជីតារបស់ខ្ញុំដែលជានាម៉ឺនបំរើផ្ទាល់លោកឧកញ៉ាតែងតែប្រាប់ខ្ញុំថា ម៉ាស៊ីនកាត់កនោះតាំងនៅក្រោមដើមត្នោតក្នុងភូមិបន្ទាយក្រ ។ ប៉ុន្តែលោកតាអាងបានអះអាងថា ម៉ាស៊ីននោះតាំងនៅមុខសាលាឃុំឡុងឌឹកវិញ ) ដែលវាតាំងនៅមុខសាលាឃុំឡុងឌឹក កណ្តាលទីក្រុងព្រះត្រពាំង ។

ក្រោយពេលដែលមហាវីរៈបុរសខ្មែរកម្ពុជាក្រោមចាកស្ថានចោលយើងទៅ ស្រាប់តែមានទូរលេខពីអគ្គទេសាភិបាលឥណ្ឌូចិន ឆ្លើយតបមកពីហាណូយថា ៖

- សេចក្តីតវ៉ារបស់លោកឧកញ៉ាសឺន-គុយ គឺសមរម្យត្រឹមត្រូវតាមលំនាំច្បាប់ ដូច្នេះត្រូវតែយល់ព្រមតាមសុំ ។

ពេលនោះស្រីៗទាំងអស់លាន់មាត់ថា ៖

- តើធ្វើម្ដេចទៅ? បើអុងយួនអប្រិយសម្លាប់លោកឧកញ៉ាផុតទៅហើយនោះ?

លោកតាអាងនិទានបន្ត ៖

- លោកអគ្គទេសាភិបាលឥណ្ឌូចិនមិនព្រងើយកន្តើយទេ លោករកយុត្តិធម៌ឲ្យខ្មែរកម្ពុជាក្រោមដែរ គឺលោកសំរេចឲ្យចាប់អុងយួននោះ ប្រានចូលទៅក្នុងម៉ាស៊ីនដង្ដែល ដើម្បីបូជាវិញ្ញាណក្ខន្ធវីរៈបុរសខ្មែរយើងវិញ ។

អគ្គទេសាភិបាលឥណ្ឌូចិនអនុញ្ញាតឲ្យរាស្ត្រខ្មែរកម្ពុជាក្រោម ដែលមានលំនៅនៅខេត្តព្រះត្រពាំង ស្ថាបនាចេតិយមួយមានរាងបួនជ្រុងស្មើ ជ្រុងនិមួយៗមានប្រវែង១៥ម៉ែត្រ កំពស់២ម៉ែត្រ ជញ្ជាំងធ្វើអំពីថ្មភ្នំស្ថិតនៅក្នុងវត្តពោធិសាលរាជកំពង់ត្រង់ផ្លូវចូលខាងស្ដាំដៃ កណ្ដាលទីក្រុងព្រះត្រពាំង ដើម្បីដំកល់សាកសពមហាវីរៈបុរសខ្មែរកម្ពុជាក្រោមយើង ។

នៅលើផ្លានោះ ពុទ្ធបរិស័ទខ្មែរកម្ពុជាក្រោមតែងតែមកជួបជុំក្នុងមួយឆ្នាំ២ដង គឺថ្ងៃភ្ជុំបិណ្ឌសែនដូនតា និងពិធីបុណ្យចូលឆ្នាំថ្មី ដើម្បីគោរពពិធីបង្សុកូលឧទ្ទិសចំពោះវិញ្ញាណក្ខន្ធលោកឧកញ៉ាសឺន-គុយ ។

ចាប់តាំងពីពេលនោះមក ខ្មែរកម្ពុជាក្រោមគោរពស្រឡាញ់និងអរគុណបារាំងយ៉ាងជ្រាលជ្រៅ និងស្មោះត្រង់ក្រៃលែង ។

គួររំលឹកឡើងវិញ មើលចុះជិត១០០ឆ្នាំ ខ្មែរកម្ពុជាក្រោមនៅគង់វង់ជាជាតិខ្មែរព្រមទាំងទទួលសេចក្ដីសុខសាន្ត គឺដោយសារបារាំងឧបត្ថម្ភការពារក្នុងរយៈបារាំងគ្រប់គ្រងឥណ្ឌូចិន ក៏ដូចជាប្រាំងទិព្វអាចទប់ទល់នូវអំពើព្រៃផ្សៃរបស់យួនដែលព្យាយាមបំបាត់ពូជខ្មែរកម្ពុជាក្រោម ។ បារាំងបង្កើតសាលារៀនបង្រៀនភាសាខ្មែរអក្សរខ្មែរគ្រប់ៗខេត្ត ដែលខ្មែរកម្ពុជាក្រោមតាំងទីលំនៅ ។ មានបង្កើតអនុវិទ្យាល័យមួយនៅខេត្តកាន់ថើ សំរាប់តែកូនខ្មែរ ។

ដើម្បីរំលឹកនូវឧបការគុណបារាំង សិស្សខ្មែរកម្ពុជាក្រោមតែងតែរៀនមេសូត្រចាំមាត់ដូចតទៅ ៖

« កញ្ចាញ់ចេកអើយ　　លោតទុំចុងស្វាយ
ស្រុកយើងសប្បាយ　　ដោយសារបារាំង ។
កាលដើមពិបាក　　ព្រោះមានចំបាំង
អ្នកស្រុកភ័យខ្លាំង　　រត់ចូលតែព្រៃ ។
តាំងពីបានលោក　　ចូលមកអាស្រ័យ
ទុក្ខសោករោគភ័យ　　វិនាសខ្ចាត់ខ្ចាយ ។

មានផ្លូវមានស្ពាន មានយានទាំងឡាយ
ចេញចូលសព្វសាយ ទាំងសព្វទំនិញ ។
យកមកលក់ដូរ ហូរហែរពាសពេញ
តាមចូលចិត្តទិញ ស៊ីចុកស្លៀកពាក់ ។
ប្រជាប់ប្រជារ គ្មានខ្វះគ្មានអាក់
ទាំងមាសទាំងប្រាក់ សំបូរច្រើនអើយ » ។

មេរៀនសូត្រចាំមាត់នេះ មានន័យទូលំទូលាយ ជាសាក្សីរំលឹកដាស់តឿនពន្យល់បង្ហាញឲ្យកូនចៅខ្មែរទូទៅចេះភ្ញាក់រលឹកឲ្យដឹងថា កាលពីដើមយួនប្រើគ្រប់មធ្យោបាយសម្លាប់បំផុតពូជខ្មែរយ៉ាងសាហាវ ។ កាលណោះខ្មែរយើងរវល់តែរត់ចូលព្រៃ ។ បច្ចុប្បន្ននេះនៅប្រទេសកម្ពុជា ត្រូវរលាយទៅជាផេះ ប្រជាពលរដ្ឋខ្មែររវល់តែរត់ចោលស្រុក រវល់តែរត់ចោលព្រៃ បណ្ដាលមកពីសត្រូវ ។ ឯណោះយួន ឯណោះចិន ។ ឥឡូវឆ្នាំ១៩៩២ សៀមឬថៃចាប់ផ្ដើមជាសត្រូវនឹងខ្មែរយើងទៀត ។

ពីព្រោះខ្មែរយើងសុភាពសប្បុរស ចូលចិត្តរស់នៅដោយស្ងប់ស្ងៀម យើងមិនចេះលោភលន់ យើងមិនចេះបង្ករឿងហេតុនឹងប្រទេសជិតខាងឡើយ សូម្បីតែយើងជាពិសេសខ្មែរកម្ពុជាក្រោម រួមរស់ជាមួយបារាំងជិត១០០ឆ្នាំ យើងមិនដែលវិវាទជាមួយបារាំងឡើយ អាចរក្សាទុកជាមិត្តល្អទៅវិញទៅមកក្នុងប្រវត្តិសាស្ត្រ។

ផ្ទុយទៅវិញយួនឈ្លានពាន គឺយួនវាមិននៅស្ងៀមទេ វារៀបចំផែនការ មានទំរង់ជារដ្ឋាភិបាល ទុកបំរុងជាស្រេចៗ ចាប់តាំងពីឆ្នាំ១៩៤៥ វាដាក់គំរោងការយ៉ាងមាំ បើពេលណាបារាំងត្រូវចាញ់ដកថយចេញពីឥណ្ឌូចិន យួនត្រូវតែលេបទឹកដីកម្ពុជាក្រោមជាលើកទី២ភ្លាម ហើយស្របច្បាប់អន្តរជាតិទៀតផង ។

កាលនោះយួនវៀតមិញកំពុងវាយដេញបារាំង ឆ្លៀតពេលចលាចលនោះ វាឆ្លៀតសម្លាប់កំទេចរាស្ត្រខ្មែរកម្ពុជាក្រោម ជាពិសេសអ្នកចេះដឹង គឺវាប្រើស្លៀតវាយទឹកកំចាយត្រី ។ ត្រូវមែន ! បារាំងត្រូវចាញ់ ត្រូវដកថយចេញពីឥណ្ឌូចិននៅខែសីហាឆ្នាំ១៩៥៤ យួនលេបទឹកដីកម្ពុជាក្រោមបាត់ស្រមោល...

យួនចេញបញ្ជាឲ្យបិទទ្វារសាលារៀនជាភាសាខ្មែរភ្លាម ។ វាលៃលកបំបាត់ពូជខ្មែរកម្ពុជាក្រោមជាដំណាក់ៗ ។ មុនដំបូងវាបង្ខំខ្មែរកម្ពុជាក្រោមកាន់កាតដាក់សញ្ជាតិជាយួនដើមកំណើតខ្មែរ ។ ក្នុងរបបង្វៀង-វាន់ធីវ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋវៀតណាម ត្រង់មាត្រាទី២, ២២, ២៤ និង៣០ ចុះថ្ងៃទី១-៤-៦៧ សំរេចទុកខ្មែរកម្ពុជាក្រោម ជាជនជាតិភាគតិចក្នុងសហគមវៀតណាម ។ លុះដល់ថ្ងៃទី៨-១០-៦៩ រដ្ឋសភានៃសាធារណរដ្ឋវៀតណាមសំរេចជាថ្មីបំបាត់ជាតិខ្មែរ ។

**ទាសន្និដ្ឋានថាខ្មែរកម្ពុជាក្រោមទាំងអស់ជាជាតិយួន !**

នឹកគួរឲ្យស្ដាយទឹកដីកម្ពុជាក្រោមជាក្រៃលែង ។ នឹកគួរឲ្យស្ដាយប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមជាក្រៃលែង ។ ពីឆ្នាំ១៩៦៩ តាមសេចក្ដីប្រកាសផ្ទាល់មាត់របស់ង្វៀង-វាន់ធីវបានឲ្យដឹងថា រាស្ត្រខ្មែរកម្ពុជាក្រោមមានចំនួន៤,០៤៧,៥០០នាក់ ។

សៀវភៅមួយមានចំណងជើងថា « Le Viet Nam » សរសេរដោយលោក Pierre Richard Feray បញ្ជាក់ឲ្យដឹងថាក្នុងឆ្នាំ១៩៨៥ រាស្ត្រខ្មែរកម្ពុជាក្រោមមានចំនួន៦,៧២០,០០០នាក់ រស់នៅជុំវិញវត្តមានចំនួន៥៥៦ ។ ព្រះសង្ឃមានចំនួន២៥,០០០អង្គ ។

នឹកទៅគួរឲ្យអាណោចអធម៌បងប្អូនខ្មែរកម្ពុជាក្រោមណាស់ យួនបង្ខំឲ្យកាន់កាតជាជាតិយួន ប៉ុន្តែមានមួយភាគច្រើនមិនចេះអក្សរយួន មិនចេះភាសាយួនទាល់តែសោះ ។

ពេលបារាំងដកថយចេញចោលខ្មែរកម្ពុជាក្រោមពីឆ្នាំ១៩៥៤ បងប្អូនខ្មែរកម្ពុជាក្រោមយើងមួយភាគច្រើន យំសោកស្ដាយបារាំងជាក្រៃលែង ពីព្រោះដឹងជាមុនថា មុខជាត្រូវរងគ្រោះ ត្រូវយួនសម្លាប់បំផុតពូជ ត្រូវយួនធ្វើទារុណកម្ម ដូចពីសតវត្សទី១៩សារឡើងវិញជាមិនខាន ។

មែន ! យួនចាត់ការសម្លាប់ធ្វើទារុណកម្មខ្មែរសាហាវជាងពីសតវត្សទី១៩ សាហាវជាងពីជំនាន់ « ប្រយ័ត្នកំពប់តែអុង » ទៅទៀត ។

ឧទាហរណ៍វាប្រើតែឈ្មោះអង្គការអនាមិក វាឆ្វៃប្រទេសកម្ពុជាមួយទាំងមូលឲ្យក្លាយទៅជាគំនរឆ្អឹងជាគំនរផេះ យើងបានឃើញផ្ទាល់នឹងភ្នែក ។

ចំណែកបងប្អូនខ្មែរកម្ពុជាក្រោម ត្រូវបាត់សញ្ជាតិ ទោះយួនមានប្រៀបយ៉ាងណាក៏ដោយ បងប្អូនខ្មែរកម្ពុជាក្រោមនៅតែគោរពតាមបណ្ដាំរបស់វិរៈបុរសសឺនគុយជានិច្ច ។ គេសាមគ្គីយ៉ាងរឹមួត គេកាន់បានខ្ជាប់ខ្ជួននូវទំនៀមទំលាប់ខ្មែរ និងព្រះពុទ្ធសាសនា ។ គ្រប់ៗពិធីបុណ្យប្រពៃណី គេនាំគ្រួសារទៅជួបជុំគ្នាក្នុងវត្តទាំងប្រុសទាំងស្រី ទាំងចាស់ទាំងក្មេង រួមគ្នាសូត្រធម៌រួចស្ដាប់ធម៌ទេសនា ។ រាល់ៗថ្ងៃសិល ចាស់ៗទាំងតាទាំងយាយ ទៅជួបជុំគ្នាក្នុងវត្ត សូត្រធម៌សុំសិល រួចសំរានក្នុងវត្តមួយយប់ ។ យុវជនខ្មែរកម្ពុជាក្រោមភាគច្រើន មុននឹងរៀបអាពាហ៍ពិពាហ៍តែងតែបួសជាព្រះសង្ឃយ៉ាងតិចមួយវស្សាសិន ដើម្បីរៀនអក្សរ ប្រពៃណីទំនៀមទំលាប់ខ្មែរពីព្រះសង្ឃចាស់ទុំ ។ ឧទាហរណ៍បងទ្រី និងប្អូនគីម-ច័ន្ទ មុននឹងបន្តវិជ្ជា ក៏បានបួសជាសង្ឃម្នាក់ៗបាន២វស្សាដែរ ។ រាស្ត្រខ្មែរកម្ពុជាក្រោមនិយាយតែភាសាខ្មែរ ភាគច្រើនរៀបការប្ដីប្រពន្ធតែជាមួយខ្មែរតាមប្រពៃណីទំនៀមទំលាប់ខ្មែរជានិច្ច ។

លោកតាអាងនិទានដល់វគ្គនេះ ស្រីៗទាំង១៨នាក់ក៏លាន់មាត់គ្រប់គ្នាប្រសើរ

មែនៗ ។ មើលចុះ ! យួនកៀបសង្កត់ជិត២០០ឆ្នាំទៅហើយ ដោយសារខ្មែរកម្ពុជាក្រោមចេះសាមគ្គី ក៏អាចរក្សាភាសានិងទំនៀមទំលាប់បានគង់វង្សដដែល ។ ចំណែកបងប្អូនខ្មែរកម្ពុជាកណ្តាលយើងដូចជាជ្រាយទន់ល្អូកម្ល៉េះ ។ មានប្រុសៗខ្លះលះបង់ប្រពន្ធជាតិខ្មែររបស់ខ្លួន ទៅយកស្រីយួន - ហើយចំណែកឯស្រីៗខ្មែរខ្លះក៏ស្រាប់តែលោតផ្លោះទៅយកប្តីយួនទៅវិញក៏មានដែរ មានឧទាហរណ៍ ប្រពន្ធអតីតតំណាងរាស្ត្រម្នាក់ជាដើម...

តើអនាគតខ្មែរធុននោះនឹងក្លាយទៅជាជាតិអ្វីទៅ ?

អង្គរ៉ាសុំសួរលោកតាអាងថា ៖

- ហេតុម្តេចយួនហាណូយប្រមូលក្មេងៗច្រើនម្ល៉េះ ? ខ្ញុំដឹងថាវាដឹកនាំយកទៅហាណូយច្រើនម៉ឺនរួចហើយ ។

លោកតាធ្វើមុខស្លូតឆ្លើយថា ៖

- ខ្ញុំបានឃើញផ្ទាល់ភ្នែក ឃើញបូដូយបើកបរឡាន ដើរប្រមូលកូនខ្មែរកំព្រាអាយុពី៨ដល់១៤ឆ្នាំ ដាក់ឈ្មោះថា « ក្រុមកុមារសងឈាម » ( ក្រោយមកប្រែឈ្មោះថា « ក្រុមកុមារឈានមុខ » ទៅវិញ ។ នៅថ្ងៃទី២៤-១១-៨៤ ហ៊ុន-សែនប្រកាសប្រាប់អ្នកកាសែតបរទេសថា ក្រុមកុមារឈានមុខមានទាំងអស់ពីរសែននាក់ ។ សូមបញ្ជាក់ថា មកដល់សព្វថ្ងៃនេះ ពួកក្មេងៗទាំងអស់នោះមានអាយុចន្លោះពី៣៥ទៅ៥០ឆ្នាំហើយ ហើយមួយភាគធំកំពុងធ្វើការនៅក្នុងជួររាជរដ្ឋាភិបាលខ្មែរ និងនៅក្នុងជួរកងយោធពលខេមរភូមិ ) ដឹកនាំចេញពីប្រទេសខ្មែរ យកទៅកាន់ហាណូយ ។ សព្វថ្ងៃគ្រូបង្ហាត់បង្រៀនក្រុមកុមារសងឈាមពីសូន្យឡើងទៅគឺសុទ្ធទេជាយួនហាណូយទាំងអស់ ។ ជាពិសេសវាខំបំពោកគោលជំហរ ដំណាក់ការជាដំបូងត្រូវសងសឹកចំពោះខ្មែរក្រហម វាប៉ិនប្រសប់ញុះញង់បង្ហាញភាពជាក់ស្តែង ដែលកុមារទាំងនោះត្រូវទទួលទារុណកម្មរួចហើយ ។ យួនហាណូយរំពូកហូរហែរបណ្តុះគំនិតសងសឹកនេះឲ្យរកប់ចូលយ៉ាងជ្រៅឲ្យជាប់ជានិច្ចក្នុងបេះដូង ។

រាល់ៗពេលបាយព្រឹក-ល្ងាច វាបង្កើតសំនួរថា ៖

- តើនរណាជាមិត្ត ?

- តើនរណាជាសត្រូវសម្លាប់ឪម៉ែវា ? ។

*ដូច្នេះកុមារសងឈាមទាំងនោះត្រូវតែយល់ច្រឡំយ៉ាងធ្ងន់ មុខតែដឹកលង់ដំកើងនិងគោរពយួនជាមិត្ត ជាអ្នកមានគុណ ហើយច្បាស់ជាសងសឹកខ្មែរក្រហមជំនួសយួនហាណូយជាមិនខាន ។*

វាបង្កើតកលល្បិចញុះញង់ មានជាឧទាហរណ៍ដូចតទៅ ៖

- គ្រប់ៗពេល យួនហាណូយសំរាំងជ្រើសរើសកុមារកំព្រា ដែលមានមូល-

ដ្ឋានស្ថិតនៅក្នុងបរិវេណអតីតវិទ្យាល័យព្រះមុនីវង្ស (បាត់ដំបង) បានត្រឹមត្រូវតាមលក្ខណៈហើយ ក៏បង្គាប់ឲ្យតម្រៀបជួរឡើងឡាន ។

ក្បួនឡានកាម្មុងទាំងនោះ មាន៥ឬ៦គ្រឿង ឈប់សំចតនៅតាមបណ្តោយផ្លូវលេខ២ ខាងកើតវិទ្យាល័យ រួចបើកបរទៅកាន់ផ្លូវជាតិលេខ៥ ឆ្លងតាមស្ពានថ្មថ្មី ។ លុះក្បួនឡានទាំងនោះបរទៅដល់វាលបែកចាន យួនហាណូយបញ្ឈប់ក្បួនឡាន រួចបញ្ជាឲ្យកុមារកំសត់ទាំងអស់ចុះពីឡាន រួចតម្រៀបជួរដើរតាមវាទៅកាន់វាលមួយ ស្ថិតនៅខាងកើតចំណតអាកាសយាន ដែលមានម្លប់ដើមឈើពីរដើមធំៗ គឺដើមអំពិលខាងលិច ដើមពុទ្រាខាងកើត ។ នៅចំចន្លោះដើមឈើទាំងពីរដើមនោះមានផ្នូរខ្មោចបីទន្ទឹមគ្នា ។ រាល់ៗពេល មានយួនហាណូយម្នាក់ អាយុប្រហែល៤០ឆ្នាំ មុខសំប៉ែត ច្រមុះកំពិត មាត់ច្របូញ ថ្ពាមខ្លា សក់កាត់ខ្លី ទាបតឿ មានកាំភ្លើងខ្លីមួយដើមនៅចង្កេះ ឈរចាំនៅទីនោះជាស្រេច ។ ពេលកុមារឈានមុខជាច្រើនរយនាក់បណ្តើរគ្នាទៅដល់ យួននេះសើចទទួលយ៉ាងរាក់ទាក់ និយាយទៅកាន់កុមារទាំងអស់នោះជាភាសាខ្មែរដោយប្រើវាក្យស័ព្ទតាមលំនាំសម័យអង្គការអនាមិក ។ វាចាប់ផ្តើមញុះញង់ដោយលើកដៃចង្អុលផ្នូរខ្មោចទាំង៣នោះថា ៖

– នេះជាផ្នូរព្រះសង្ឃបីអង្គ ដែលត្រូវខ្មែរក្រហមវាយសម្លាប់កាលពីថ្ងៃ២៤-៤-៧៥ នៅម៉ោង៣រសៀល ។ ថ្ងៃវាយសម្លាប់នោះ ខ្មែរក្រហមជីករណ្តៅបីនេះ រួចមេធំបញ្ជាដល់មិត្តទុយថា ៖

– ចូរឯងទៅកាន់ខ្ទមខាងលិច ។ យួននិយាយបណ្តើរលើកដៃចង្អុលបណ្តើរទៅកាន់ខ្ទម... រួចបន្ត ៖

– ដើម្បីដឹកអាគោបីក្បាលយកមកចាត់ការ ។ ពេលនោះមិត្តទុយហារមាត់ចំហបើកភ្នែកធំៗ ឆ្ងល់សែនឆ្ងល់ ព្រោះខ្លួននៅទីនេះមិនដែលប្រទះឃើញគោទាល់តែសោះ ។ ប៉ុន្តែមិនហ៊ានសួរដេញដោលនូវបញ្ហាដាច់ណាត់នេះ ។

លុះទៅដល់ មិត្តទុយក៏បើកទ្វារខ្ទម ។ ឱពុទ្ធោអើយ ! មិនមែនគោទេ ! គឺព្រះសង្ឃបីអង្គដែលរាស្ត្រខ្មែរនៅខេត្តបាត់ដំបងស្គាល់ច្បាស់ តែងតែគោរពប្រណិបត្តិសន្និដ្ឋានទុកដូចជាព្រះពុទ្ធ ។ ព្រះសង្ឃទី១ព្រះនាម ប៊ុន-សំភាជ ជាព្រះមេគណខេត្តបាត់ដំបង ។ ព្រះសង្ឃទី២មានព្រះនាម កែវ-សាន ជាអនុគណខេត្តបាត់ដំបង និងជាចៅអធិការវត្តកំផែង ។ ព្រះសង្ឃទី៣មិនស្គាល់ព្រះនាម ជាអនុគណស្រុកសង្កែរ ។ ព្រះសង្ឃជាន់ខ្ពស់ទាំងបីអង្គ ជាប់ចំណងជាស្រេច ។ មិត្តទុយក៏ដឹកព្រះសង្ឃទាំងបីអង្គដូចដឹកគោមែន នាំមកកាន់រណ្តៅ ។ មេឃាតករសួរព្រះសង្ឃតាំងបីអង្គថា ៖

– តើចង់និយាយស្អីឬទេ មុននឹងស្លាប់ ? ។

ពេលនោះមានតែព្រះមេគណទេដែលនៅសល់វិញ្ញាណ និងស្មារតីរឹងប៉ឹង លោកឆ្លើយធ្វើព្រងើយថា ៖

- អាត្មាជឿកម្មនិងផល អ្នកណាប្រព្រឹត្ត អ្នកនោះត្រូវតែទទួល ។ តែសុំតែម៉្យាង គឺដល់ពេលសម្លាប់អាត្មារួច សុំបត់ស្បង់ចីពរដាក់លើផ្នូរតាមសមគួរផង ។

មេឃាតករចិត្តយក្សក៏សំរាតស្បង់ពីព្រះសង្ឃទាំងបីអង្គ វាយសំពងនឹងដំបងសង្កែរទាំងបន្លា រួចធាក់ទម្លាក់រណ្តៅរៀងៗខ្លួន ។ ស្លាប់ឬមិនស្លាប់មិនដឹងទេ រួចហើយខ្មែរក្រហមក៏កាយដីលប់ចោលទៅ...

យួនហាណូយកន្មៀនិយាយដល់វគ្គនេះ ក៏លើកដៃចង្អុលដើមអំពិលនិងពុទ្រាព្រមទាំងបន្តការញុះញង់ថា ៖

-ខ្មែរក្រហមក៏ចងស្បង់ចីពរទាំងបីភ្ជាប់គ្នាធ្វើជាខ្សែ ហើយចងទាញពីមែកអំពិលទៅមែកពុទ្រា ទុកចោលឲ្យខ្យល់បក់រំភើយជាល្បែង...

លុះញុះញង់ចប់ហើយ យួននេះក៏សម្លឹងកុមារអ្នកស្តាប់ ដោយញញឹមយ៉ាងពេញចិត្តនូវកលល្បិចញុះញង់របស់វា ដែលវាយល់ថាសមហេតុសមផល មានភស្តុតាងជាក់ស្តែង អាចដុតចិត្តកុមារកំព្រាទាំងឡាយនោះ ឲ្យឆេះក្តៅងំជានិច្ច ត្រូវតែសងសឹកចំពោះខ្មែរក្រហមជាដាច់ខាត ។

ពេលនោះក្រុមកុមារឈានមុខមានទឹកមុខប្រពាប់ស្រពោន មានខ្លះចេញទឹកភ្នែករលីងរលោង ដោយការឈឺចាប់ខ្លោចផ្សា នឹកឃើញអំពើឃោរឃៅរបស់ខ្មែរក្រហមចាប់ចងឪម៉ែរបស់ខ្លួននាំយកទៅសម្លាប់អញ្ចឹងដែរ ។

គួរឲ្យចម្លែកដែរ ! ចុះហេតុយ៉ាងដូចម្តេចបានជាយួនហាណូយនេះដឹងរឿងខ្មែរក្រហមសម្លាប់ព្រះសង្ឃទាំងបីអង្គច្បាស់លាស់ម្ល៉េះ ? ការអធិប្បាយព្រមទាំងកាយវិការដែលវាបញ្ចេញមកនេះ ធ្វើឲ្យយើងនឹកសង្ស័យថា នៅពេលធ្វើឃាតព្រះសង្ឃទាំងបីអង្គ ច្បាស់ជាមានវានៅទីនោះដែរហើយមើលទៅ ? ព្រោះនៅថ្ងៃទី២៤-៤-៧៥ គ្មានប្រជាជនថ្មីណាអាចដើរកាត់វាលចំណតអាកាសយានវាលបែកចានបានទេ ! ដូច្នេះខ្មែរយើងត្រូវតែលើកយកមកត្រិះរិះរកហេតុផល ។

ស្នៀតនេះជាធាតុភ្លើង មានឥទ្ធិពលដ៏ស័ក្តិសិទ្ធិ អាចដុតកំដៅឲ្យឆេះងំជានិច្ចកប់យ៉ាងជ្រៅក្នុងបេះដូងកុមាកំព្រា ។ ដូច្នេះពីថ្ងៃនេះទៅ ឲ្យតែឮឈ្មោះខ្មែរក្រហមកុមារឈានមុខត្រូវតែកំទេចចោលភ្លាម ។

មានពេលខ្លះវាដឹកកុមារទាំងនោះទៅបង្ហាញក្បាលខ្មោចរាប់ពាន់ឬដល់ម៉ឺន ដែលវាគាស់រៀបតាំងជាស្រេច ។ លុះបង្ហាញនិងញុះញង់រួចហើយ វាក៏ដឹកក្មេងទាំងនោះទៅកាន់ទីអាថ៌កំបាំងដោយនិយាយថា វានាំយកទៅរៀននៅហាណូយ ?!?!

ចូលឆ្នាំ១៩៧៩ភ្លាម យួនហាណូយចាប់ផ្តើមបញ្ជូនយោធាខ្មែរក្រហមក្រុមទី៣

ឲ្យវិលត្រឡប់មកតាមមូលដ្ឋានចាស់ៗជាហូរហែរ ពាសពេញព្រៃនៃប្រទេសខ្មែរឡើងវិញ ។ យោធាខ្មែរក្រហមក្រុមទី៣នេះ គឺជាពួកដែលយួនហាណូយរើសសំរាំងចេញមកពីពួកស្នប់សក្តិភូមិនិងចក្រពត្តិ ព្រោះក្រុមទាំងនេះមានការឈឺចាប់ ដោយបានឃើញផ្ទាល់ភ្នែក ដែលបណ្តាលមកពីស្តេចនិងចក្រពត្តិ ច្បាំងដណ្តើមអំណាចគ្នា ទើបក្រុមវាត្រូវកំព្រា ត្រូវព្រាត់ប្រាស់ម៉ែឪ ខ្វះទីលំនៅ ។ ក្រុមនេះក៏ដូចជាកូនសិស្សយួនហាណូយដែរ មានយួនបង្ហោត់បង្រៀនពីសូន្យឡើងទៅ ឆ្លៀតឱកាសញុះញង់ហែកហួរបំពាក់គោលជំហរយ៉ាងមុតថា ត្រូវតែកំទេចសក្តិភូមិនិងចក្រពត្តិ ។ ផ្ទុយទៅវិញ ក្រុមយោធាខ្មែរក្រហមទី៣នេះ ត្រូវតែដឹងគុណយួនហាណូយ ដូចក្រុមកុមារឈានមុខដែរ ។ មេដឹកនាំក្រុមនេះសុទ្ធតែមានសញ្ជាតិជាយួន តែវាយកឈ្មោះខ្មែរដាក់បន្លំទាំងអស់ ។ ស្តាប់ដល់ត្រឹមហ្នឹង យាយទៀងសុំសួរលោកតាអាងថា ៖

- បើអញ្ចឹងយួនហាណូយលៃលកឲ្យខ្មែរមានសត្រូវរវាងគ្នានិងគ្នា ។ បានសេចក្តីថា ក្រុមកុមារឈានមុខជាអ្នកកំទេចខ្មែរក្រហម រីឯក្រុមខ្មែរក្រហមទី៣ ជាអ្នកកំទេចខ្មែរសក្តិភូមិនិងខ្មែរចក្រពត្តិ ឲ្យយួនហាណូយ ។

លោកតាអាងងក់ក្បាលបញ្ជាក់ថាពិតជាអញ្ចឹងមែន ។ លោកតាបន្តទៅទៀតថា ៖

- បើខ្មែរយើងដោះស្រាយមិនទាន់ពេលវេលាទេ ដោយបណ្តោយឲ្យសង្គ្រាមរវាងក្រុមទាំងពីរនេះផ្ទុះឡើង សត្រូវទាំងសង្ខាងមុខជាបាញ់សម្លាប់គ្នាទាំងងងឹតងងល់ គ្មានអាណិតអាសូរ ដោយសារកំហឹងទោសៈនៃការសងសឹកផ្ទាល់ខ្លួនផង ដោយយល់ថាត្រូវតែកំទេចខ្មាំង ដើម្បីរំដោះមាតុភូមិផង ។ តាអាងបន្តទៅទៀតថា

- បងៗឃើញទេ យួនហាណូយវាយកឃ្លា បំបែកបំបាក់ដើម្បីគ្រប់គ្រងមកអនុវត្តទៀតហើយ ។ ចូច្រេះចំពោះវិបត្តិនៃប្រទេសកម្ពុជា សូមកុំជឿតែត្រចៀកនិងភ្នែក ។ យើងត្រូវប្រើខួរក្បាលត្រិះរិះពិចារណាឲ្យបានជិតដល់ ។ សភាពខាងក្រៅរបស់យួនមានលក្ខណៈទន់ភ្លន់ធ្វើពុតចំពោះខ្មែរជានិច្ច ។ ពាក្យបុរាណមួយឃ្លាមានចែងមកហើយថា ៖ « សៀមមិនចោលក្បួន យួនមិនចោលពុត ខ្មែរស៊ុតទ្រុឌមិនចោលចៃចូរ » ។ ដោយសារមូលហេតុនេះ ទើបខ្ញុំខំស្រាវជ្រាវដើម្បីដាស់សតិកូនខ្មែរឲ្យភ្ញាក់រលឹកឡើងវិញ ឈប់ដេកលក់ ឈប់ក្បត់គ្នាទៅវិញទៅមក ព្រោះខ្មាំងវាមុខតែយកពេលដែលយើងឈ្លោះកាប់ចាក់គ្នានេះហើយ ឆ្លៀតដណ្តើមដីកម្ពុជាកណ្តាលឲ្យអស់ ។ ខ្ញុំសូមរំលឹកបងៗឡើងវិញថា ៖

- នៅឆ្នាំ១៩៤៥ យួនជាវៀតមិញវាបញ្ជូនបូជួយចូលមកតាំងមូលដ្ឋានពាសពេញផ្ទៃដីនៃប្រទេសកម្ពុជា ដោយយកលេសថា វាស្ម័គ្រចិត្តចូលមកស្លាប់ជួយខ្មែរ

ដេញបារាំង ។ តែតាមការពិត វាចូលមកញុះញង់បំបែកបំបាក់ខ្មែរ ដើម្បីបង្កើតខ្មែរវៀតមិញឯណោះទេវិញទេ ។ តើយួនឯណាដែលស្ម័គ្រចិត្តស្លាប់ជួសខ្មែរនោះ ? ព្រោះនៅឯកម្ពុជាក្រោមឯណោះ ក្នុងពេលដែលវាថាចូលមកជួយខ្មែរ (ឆ្នាំ១៩៤៥) គ្នាវាក្រុមផ្សេងៗទៀតកំពុងតែចាត់ការវាយកាប់សម្លាប់បំផុតពូជខ្មែរឲ្យអស់ ។ ខ្មែរក្រោកឡើងតស៊ូកាប់ចាក់វាវិញ ធ្វើឲ្យវាស្លាប់បាត់បង់ជីវិតយ៉ាងច្រើន ។ ខ្មែរកម្ពុជាក្រោមឈប់លក់អង្ករ ម្ហូបបន្លែ និងគ្រឿងឧបភោគនានាឲ្យវៀតមិញ ។ ឃើញដូ-ច្នេះវាក៏ផ្លាស់នយោបាយ ដោយប្រើស្នៀតបោកប្រាស់វិញម្តង ។

– នៅឆ្នាំ១៩៤៦ វាចាប់ផ្តើមបន្ថែមអាវុធចិត្តសាស្ត្រ គឺភាពខាងក្រៅវាប្រើឥរិ-យាបថល្អទន់ភ្លន់ ផ្អែមត្រជាក់រវាងខ្មែរកម្ពុជាក្រោម ។

– នៅដើមឆ្នាំ១៩៤៧ វាសំរេចបង្កើតសមាគមមិត្តភាពយួន-ខ្មែរ-លាវ ។ ប៉ុន្តែមេដឹកនាំផ្នែកខាងខ្មែរគឺយួនង្វៀង-យ៉ាំងម៉ៀង ឬសឺង-ង៉ុកមិញ ឬអាចារ្យម្យៀន ។ លោកតាអាងនិយាយមកដល់ត្រឹមនេះ ក៏បែរមុខសម្លឹងយាយទៀងព្រមទាំងនិយាយថា សូមបងទៀងធ្វើជាសាក្សីនិយាយបន្តចុះ ព្រោះកាលណោះគាត់ជាសមាជិកជាមួយនឹងគេដែរ ។

យាយទៀងក៏ចាប់វែកញែកបន្តថា ៖

– ខ្មែរនៅកម្ពុជាក្រោមដឹងនិងយល់ថា នេះជាកលល្បិចបោកប្រាស់របស់វៀតមិញដែរ ប៉ុន្តែមិនដឹងជាធ្វើយ៉ាងដូចម្តេច បើខ្មែរកម្ពុជាក្រោមដូចជាកូនកំព្រា ត្រូវតែផ្សងព្រេងសម្ងំស្ងៀមទៅ ។ មានបងប្អូនអ្នកចេះដឹងខ្លះហ៊ានធ្វើពលិកម្មចូលជាសមាជិកសមាគមមិត្តភាពខ្មែរ-យួន-លាវនេះ ដើម្បីរក្សាសេចក្តីស្ងប់ស្ងៀមនិងសេចក្តីសុខសាន្តជូនបងប្អូនខ្មែរកម្ពុជាក្រោម តាមពេលវេលានោះទៅ ។ ប៉ុន្តែត្រូវចេះប្រុងប្រយ័ត្ន ព្រោះបើវាសង្កេតឃើញសមាជិកខ្មែរណា មានសតិសម្បជញ្ញៈស្នេហាជាតិពិតៗត្រូវយួនហាណូយអញ្ជើញឲ្យទៅ «ជួយធ្វើការ» អង្គការលើ ។ ខ្មែរអភ័ព្វទាំងនោះ ត្រូវបាត់ខ្លួនរហូត ។

លុះថ្ងៃទី២១-៥-៤៩ យួនទទួលជ័យជំនះមហាអស្ចារ្យ យួនលេបនគរកម្ពុជាក្រោមជាលើកទី២បាត់ស្រមោល ។ ចំណែកឯសមាគមមិត្តភាពយួន-ខ្មែរ-លាវវិញ ក៏ត្រូវរលាយដោយស្វ័យប្រវត្តិ ។ រីឯខ្មែរកម្ពុជាក្រោម ដែលជាសមាជិករបស់សមាគម ដែលបានរួបរួមជាមួយវៀតមិញដើម្បីដេញបារាំង ក៏ត្រូវយួនហាណូយប្រមូលនិងនាំទៅទុកឲ្យស្លាប់ចោលឆ្អឹងនៅឯហាណូយឯណោះរហូត ។

ចំណែកនៅឯកម្ពុជាកណ្តាលឯណោះវិញ ហូ-ជីមិញក៏បែរជាបញ្ជូនង្វៀង-យ៉ាំងម៉ៀង ក្លែងជាសឺង-ង៉ុកមិញ ចាត់តែងតាំងជាស្រេច ដើម្បីបន្លំធ្វើជាប្រធានខ្មែរតស៊ូ ។ វារក្សាឃ្លា សមាគមមិត្តភាពយួន-ខ្មែរ ទុកយកមកបោកខ្មែរកណ្តាល

មួយលើកទៀត ។

យាយទៀងនិយាយមកដល់ត្រឹមហ្នឹង ក៏បែរមកតាអាងសុំឲ្យគាត់បន្តការអធិប្បាយរបស់គាត់តទៅទៀត ។ លោកតាអាងនិទានបន្ត ៖

- បច្ចុប្បន្ននេះយួនហាណូយដដែលប្រែឈ្មោះជាវៀតណាម ចូលមកលុកលុយប្រទេសកម្ពុជា ដោយចាត់ការបង្កើតជាបន្ទាន់នូវសមាគមមួយដែលមានឈ្មោះថា សមាគមមិត្តភាពកម្ពុជា-វៀតណាម នៅថ្ងៃទី១៨-២-៧៩ ដើម្បីបោកខ្មែរមែន ។

មើលចុះ ! ក្នុងកាសែតនិងសេចក្ដីថ្លែងការណ៍នានា វាតែងតែប្រើឃ្លាមិត្តភាពកម្ពុជា-វៀតណាមៗៗច្រំដែលៗ ។ ប៉ុន្តែរបៀបគ្រប់គ្រងត្រួតត្រា យួនហាណូយមិនដែលភ្លេចឃ្លា «បំបែកបំបាក់ដើម្បីគ្រប់គ្រង»នោះទេ ។ វាអនុវត្តបានត្រឹមត្រូវតាមឃ្លានេះ ដោយបំបែកខ្មែរបានជាច្រើនក្រុម វាចាត់តែងតាំងខ្មែរដែលស៊ីជោរឲ្យឡើងជាឈ្លបជាចារជន ដើម្បីស៊ើបយកការណ៍ឲ្យវា ។ ឥឡូវនេះមានខ្មែរខ្លះៗកំពុងតែដើរស៊ើបការណ៍ពីខ្មែរគ្នាឯង ទៅឲ្យយួនហាណូយទៅវិញហើយ ។ ពីក្រុមមួយទៅក្រុមមួយក៏ដូច្នេះដែរ ត្រូវតែស៊ើបការណ៍ក្នុងក្រុមផ្ដល់ទៅឲ្យយួនហាណូ-យ...

ដូច្នេះឃ្លាដែលថែងថា «មិត្តភាពកម្ពុជា-វៀតណាម» នៅឆ្នាំ១៩៧៩នេះ ក៏វាមិនខុសគ្នាពីឃ្លា «មិត្តភាពខ្មែរ-យួន-លាវ» នៅឆ្នាំ១៩៤៧នោះទេ ។ នេះគ្រាន់តែជាការលួងលោមបោកបញ្ឆោត ដែលគេអាចប្រៀបប្រដូចទៅនឹងការអង្អែលខ្នងសត្វពាហនៈបញ្ចូលនឹមតែប៉ុណ្ណោះ ។

ចាប់តាំងពីថ្ងៃស្អែកនេះទៅ ខ្មែរយើងត្រូវតែតាមដានសង្កេតមើលនូវកលល្បិចរបស់យួនហាណូយ ដើម្បីឲ្យដឹងថា តើមានស្នៀតអីទៀតនឹងបញ្ចេញមកបោកខ្មែរ និងមតិសកលលោក ដើម្បីលេបយកទឹកដីកម្ពុជាកណ្ដាលយើងនេះ ឲ្យបានស្របច្បាប់អន្តរជាតិ ។ ព្រោះទឹកដីប្រទេសកម្ពុជារបស់ខ្មែរ មតិពិភពលោកទទួលស្គាល់នៅលើផែនទីរួចទៅស្រេចទៅហើយ ។ យួនខ្លួនវាក៏បានទទួលស្គាល់ដោយចុះហត្ថលេខាលើកិច្ចសន្យាសន្និសញ្ញាក្រុងហ្សឺណែវ តាំងពីខែកក្កដាឆ្នាំ១៩៥៤មកម្ល៉េះ ។ ដូច្នេះវាមិនអាចលេបទឹកដីកម្ពុជាកណ្ដាលបានងាយៗដូចនគរកម្ពុជាក្រោមឡើយ ។

ឥឡូវនេះ យួនហាណូយកំពុងតែប្រើស្នៀតចោរ ដោយសម្លាប់ និងកំចាយខ្មែរជាម្ចាស់ទឹកដីពិតៗ ។ ស្នៀតចោរនេះប្រសើរណាស់ ព្រោះទោះបីបងប្អូនខ្មែរណាដែលមិនចង់រត់ចោលទឹកដីក៏ដោយ ក៏ពេលនេះត្រូវតែរត់... យ៉ាងហោចណាស់ក៏មួយគ្រាសិនដែរ...

ហើយយើងក៏មិនត្រូវភ្លេចថា ព្រមពេលជាមួយគ្នានេះ វាកំពុងតែឆ្លេឆ្លាបង្កើត

ខ្មែរថ្មី នាំយកមកជំនួសខ្មែរយើងដែលចាកចោលស្រុកនោះឡើយ ។ ការបង្កើតខ្មែរថ្មីដែលយួនហាណូយកំពុងតែធ្វើសព្វថ្ងៃនេះ មានជាភស្តុតាងដូចតទៅ ៖

ក្រុមទី១- វាបើកឡានដើរប្រមូលកុមារខ្មែរកំព្រា ដែលមានអាយុចាប់ពី៨ទៅ១៨ឆ្នាំ ដើម្បីប្រមូលដឹកនាំចេញពីប្រទេសខ្មែរ ដោយប្រាប់ថា នាំយកទៅរៀននៅហាណូយ ។

ក្រុមទី២- គឺអាណិកជនយួនដែលកើតនិងមានលំនៅនៅប្រទេសខ្មែរពីឆ្នាំ១៩៧០ដល់១៩៧១ និង១៩៧៥ ។ វាធ្វើមាតុភូមិនិវត្តន៍ចូលមកស្រុកខ្មែរវិញហើយ ដែលមានចំនួន៣សែននាក់ ។ ក្មេងដែលកើតនៅជំនាន់នោះ នឹងនាំយកមកជាមួយវានូវគំនុំសងសឹកចំពោះខ្មែរ ។ ព្រោះនៅសម័យរដ្ឋាភិបាលសាធារណរដ្ឋ មានបាតុកម្មមួយដែលធ្វើឡើងដើម្បីវាយពួកយួន គឺម៉ែឪវា ។ តើនរណាជាអ្នកបង្កើតបាតុកម្មនេះ ? យើងគួរតែត្រិះរិះពិចារណាដែរ ។ ព្រោះថានៅស្រុកខ្មែរយើង បាតុកម្មមួយៗសុទ្ធតែមានអ្នកដឹកនាំចាត់ចែងធ្វើទាំងអស់ ។ រីឯអ្នកដែលដើរតាមបាតុកម្មនោះ មិនទាំងដឹងថាខ្លួនទៅណា ឬទៅធ្វើអ្វីផង...

ឥឡូវអាណិកជនយួនទាំងនោះបន្លំដាក់ឈ្មោះជាខ្មែរ យកសញ្ជាតិបន្លំជាខ្មែរទាំងអស់ ហើយដែលមានមួយភាគស្ម័គ្រចិត្តកាន់ក្តាប់យោធាខ្មែរក្រហមក្រុមទី៣ ដែលសព្វថ្ងៃនេះមានតាំងមូលដ្ឋាននៅកន្លែងចាស់ឡើងវិញ ។

ក្រុមទី៣- គឺក្រុមបូជ្ជូយដែលមានភារកិច្ចមកបំពេញបេសកកម្មនៅស្រុកខ្មែរ ត្រូវគោរពវិន័យតាមលក្ខណៈដ៏ត្រឹមត្រូវ។ ម្នាក់ៗត្រូវធ្វើការនៅស្រុកខ្មែរក្នុងរយៈប្រាំឆ្នាំ ។ បើក្នុងរយៈប្រាំឆ្នាំនេះ វាគោរពវិន័យមិនបានត្រឹមត្រូវទេ វាត្រូវតែនៅស្រុកខ្មែរដល់ទៅ១០ឆ្នាំ ។បើក្នុងរយៈ១០ឆ្នាំ ធ្លាក់លេខម្តងទៀត ពួកបូជ្ជូយទាំងនោះត្រូវតែនៅស្រុកខ្មែររហូត... គឺវាសន្និដ្ឋានទុកដូចជាខ្មែរ ។ ឥឡូវនេះយួនហាណូយបង្ខំពួកបូជ្ជូយអស់ទាំងនោះ ឲ្យរៀនសូត្រអក្សរខ្មែរជាដាច់ខាត ។ ពួកបូជ្ជូយម្នាក់ៗទទួលកូនសៀវភៅមួយពីអង្គការលើ មានប្រវែងបណ្តោយ១៣សង់ទីម៉ែត្រ និងទទឹង៩សង់ទីម៉ែត្រ មាន១០៨ទំព័រទាំងក្រប ។ នៅលើក្របមានអក្សរយួន៣ម៉ាត់ ៖

- រៀនផ្ទាល់ខ្លួន ( Hoc ca nhan ) ។

ក្នុងរយៈពេល២ថ្ងៃ ត្រូវរៀនស្រៈនិងព្យញ្ជនៈខ្មែរមួយទំព័រ ។ ក្នុងរយៈប្រាំថ្ងៃ ត្រូវរៀនឲ្យចេះភាសាខ្មែរមួយទំព័រ ។ ក្នុងរយៈប៉ុន្មានៗខែ ត្រូវរៀនឲ្យចប់មួយសៀវភៅ១០០ទំព័រនេះ ។ រៀនចប់រួចហើយត្រូវទៅកាន់អង្គការលើ ទទួលយកកូនសៀវភៅថ្មី ចាប់រៀនសូត្របន្តទៅទៀត ។ល។

ពេលនោះលោកតាអាងថ្លែងថា ៖

- បងប្អូនខ្មែរអើយ ដើម្បីវាតទីយកទឹកដីខ្មែរ យួនហាណូយប្រើកលល្បិច

យ៉ាងល្អិតល្អន់ ។ វាមានគុណសម្បត្តិគ្រប់វិស័យ វាគោរពវិន័យបានយ៉ាងហ្មត់ចត់ វាធ្វើការតាមខ្សែរយៈយ៉ាងត្រឹមត្រូវ វាប៉ិនលាក់ការណ៍បានយ៉ាងជិត ។ ផ្នែកនយោបាយវាចេះប្រើកលល្បិចដ៏ឆ្នើម មានបញ្ឆោតមានបណ្តោយ វានិយាយក្រឡិចក្រឡុចឥតអៀនខ្មាស់គ្មានសាសន៍ណានៅលើពិភពលោកអាចធ្វើបានដូចវាឡើយ ។

ផ្នែកកងទ័ពវាមានជាង១លានក្បាល បច្ចេកទេសផ្នែកធ្វើសង្គ្រាម វាប៉ិនអប់រំឲ្យអត់ទ្រាំ ស៊ីបាយរួមវាល់ចែកជាមួយផ្ទីរនិងត្រកួនស្ងោរបង់តែអំបិល ។

ផ្នែកគ្រឿងអាវុធ ក្នុងឆ្នាំ១៩៧៥ ចប់សង្គ្រាមភ្លាម ប្រទេសយួនមានគ្រឿងសម្ភារៈយ៉ាងច្រើនសំបើម ៖

- កាំភ្លើង មានចំនួន១លាន៦សែនដើម
- ស្បៀងអាហារ មានចំនួន១៣ម៉ឺនតោន
- ឡានកាម៉្យុង មានចំនួន៤ម៉ឺន២ពាន់
- ឡានដឹកទ័ព មានចំនួន១ម៉ឺន២ពាន់
- អាវុធការពាររទេះតង់ មានចំនួន៦ម៉ឺន២ពាន់គ្រឿង
- នាវាចំបាំង មានចំនួនរាប់ពាន់គ្រឿង
- ព្រមទាំងកប៉ាល់ហោះចំបាំងមួយចំនួន ដែលភាគច្រើនជាកប៉ាល់ហោះប្រដេញធុនប្រតិកម្ម ។

មើលចុះ ! យួនមានគ្រឿងចំបាំងដ៏ច្រើនលើសលប់ ក្នុងចំណោមប្រទេសទាំងបីនៅជ្រោយឥណ្ឌូចិនក្នុងអាស៊ីភាគអគ្នេយ៍នេះ ។ វាមានប្រជាជនច្រើនកុះករស្ថិតនៅលើផ្ទៃដីដ៏ចង្អៀតចង្អល់ ក្រៀមក្រោះឥតជីវជាតិ ។ មូលហេតុនេះ វាមិនទុកឲ្យយើងបានសុខឡើយ ។

យួនហាណូយមិនមែនគ្រាន់តែបោកស្តេចសីហនុប៉ុណ្ណោះទេ វាអាចបង្វែងដានបំភ័ន្តមតិពិភពលោក មតិអន្តរជាតិឲ្យយល់ច្រឡំថា សង្គ្រាមក្នុងប្រទេសខ្មែរ គឺខ្មែរក្រហមសម្លាប់ខ្មែរ ។ ចំណែកវាស្ត្រខ្មែរដែលត្រូវទទួលរងគ្រោះ ក៏បានឃើញនឹងភ្នែកដូច្នេះដែរ ។ យាយទៀងសុំបញ្ជាក់ថា គាត់បានឃើញផ្ទាល់នឹងភ្នែក ខ្មែរក្រហមនាំក្រុមឃាតករអាថ៌កំបាំងចូលមកចាប់ចងប្តីរបស់គាត់ និងបងប្អូនខ្មែរនៅកងព្រៃស្វាយ នាំយកទៅសម្លាប់ជាបន្តបន្ទាប់ លុះជិតចប់បេសកកម្ម អង្គការចាត់ការសម្លាប់ខ្មែរក្រហមទាំងនោះវិញចោលខ្ទេច នេះជារឿងដ៏ចម្លែកណាស់ យើងជាខ្មែរគួរតែលើកយកមកត្រិះរិះពិចារណា ។

ដូច្នេះគ្រប់ៗអព្ភូតហេតុ គ្រប់ៗឧបករណ៍នានា កើតមានឡើងមិនទំនងក្នុងប្រទេសខ្មែរនេះ បើយើងខ្មែរចេះតាមដាន រួចប្រើខួរក្បាលត្រិះរិះពិចារណាប្រៀបធៀប យើងអាចរកឃើញមុខអង្គការអនាមិកនៅកណ្តាលវាលស្រឡះធេង គឺយួនហា

ណហ្វយ ។
លោកតាអាងបញ្ជាក់ថា ពិម្សិលមិញយើងធ្វេសប្រហែស យើងត្រូវបាត់បង់ទឹកដីកម្ពុជាក្រោមមួយនគរទៅហើយ ។ ថ្ងៃស្អែកនេះបើខ្មែរយើងមិនចេះពន្យល់គ្នាឲ្យស្គាល់កលល្បិចយួនហាណូយ បើយើងមិនភ្ញាក់រលឹកស្មុះក្រោកឡើងរួបរួមសាមគ្គីចងបាច់គ្នាជាធ្លុងមួយ ឲ្យបានរហ័សទាន់ពេលវេលាទេនោះ ប្រយ័ត្ន ! យើងនឹងបាត់បង់ទឹកដីកម្ពុជាកណ្តាលមួយនគរទៀតជាមិនខាន ។ សព្វថ្ងៃដែលយើងនៅសល់ដង្ហើមផ្អឹកៗ គឺដោយសារពិភពលោកជួយការពារយើង ។ ចុះបើយើងបណ្តែតបណ្តោយឲ្យអន្តរជាតិ ឬពិភពលោកយល់ច្រឡំទទួលស្គាល់ខ្មែរក្លែងក្លាយដែលយួនហាណូយកំពុងបង្កើតនោះ ពេលនោះយើងខ្មែរពិតៗត្រូវតែផុតពូជហើយ...

❑ ❑

❑

នៅយប់ថ្ងៃទី២៤ មេសា ១៩៧៩ នៅក្នុងក្រុមយាយទៀងគ្មាននរណាម្នាក់ដេកលក់ទេ ។ គ្រប់ៗរូបទើបនឹងមានវាសនាបានស្តាប់ បានដឹងថាយួនវាប្រើតែកលល្បិច វាអាចលេបនគរកម្ពុជាក្រោមមួយបានយ៉ាងងាយ ឥឡូវយួនដដែលកំពុងប្រមូលលកល្បិចនោះយកមកអនុវត្ត ដើម្បីវាតទីយកនគរកម្ពុជាកណ្តាលមួយទៀត ។ ពួកយើងទើបតែយល់អំពីលក្ខណៈសង្គ្រាមក្នុងស្រុកខ្មែរនៅពេលនេះទេ ។ គឺសង្គ្រាមរវាងយួននិងខ្មែរ ។

ម៉ោង៩ ថ្ងៃទី២៥ មេសា ១៩៧៩ លោកតាអាងសុំលាយាយទៀងទៅកាន់បន្ទាយអំពិល ។ លោកតាចង់បំរើវណាសិរ្សណាមួយដើម្បីកំទេចយួនរំដោះមាតុភូមិកម្ពុជា ។ ពេលនោះស្រីៗមេម៉ាយទាំងអស់ ក៏បបួលយាយទៀងទៅតាមលោកតាអាង ។ ពីព្រោះពេលនោះគេចាយតែមាសនិងពេជ្រ បើស្រីៗទាំងអស់នេះមានតែខោអាវមួយបន្លាស់ដាច់ដាចជាប់នឹងខ្លួនយ៉ាងនេះ តើមានអ្វីទៅទិញអង្ករ ? ។

ក្នុងឆ្នាំ១៩៧៩ ប្រជាពលរដ្ឋខ្មែរកំពុងអត់បាយ អត់ជំរក ស្រាប់តែឮថា អង្គការមនុស្សធម៌អន្តរជាតិទទូចអង្វរយួននិងខ្មែរអាយ៉ង សុំដឹកជំនួយជាស្បៀងទៅជួយខ្មែរ ប៉ុន្តែយួនវាបដិសេធមិនព្រមទទួល រឿងនេះអស្ចារ្យណាស់ ។ ដូច្នេះប្រជាជនខ្មែរត្រូវតែដើរថ្មើរជើង ពីទីក្រុងបាត់ដំបងទៅកាន់ជំរំនាងស្ថិតនៅតាមបណ្តោយព្រំដែនខ្មែរ-ថៃ ដោយមានចម្ងាយ១០០គ.ម. ដើម្បីសុំអង្ករដែលអង្គការមនុស្ស

ធម៌អន្តរជាតិដាក់ទានឲ្យខ្មែរនៅទីនោះ រួចវែកមកកាន់ទីក្រុងបាត់ដំបងវិញ ។ ប៉ុន្តែពុទ្ធោអើយ ! មានវិបត្តិមួយយ៉ាងធ្ងន់ទៀត គឺពេលវែកចូលជិតដល់ភូមិនិមិត្ត ក៏ត្រូវប្លន្ដយដែលឈរចាំនៅទីនោះស្ទាក់ប្លន់យកអស់រលីង ។

ប្រជាជនខ្មែរកំពុងអស់សង្ឃឹម ស្រាប់តែឮខ្សឹបៗគ្នាថា ៖

- ត្រូវតែវែកឆ្នាំងទៅរកអង្ករ មិនបាច់ទៅវែកអង្ករមករកឆ្នាំងឡើយ... ឃ្លានេះគឺសត្រូវវាបង្កើតឡើងដើម្បីកំចាយខ្មែរ ។ ខ្មែរក៏បណ្ដើរគ្នាដូចហៃរកបិន វែកឆ្នាំងទៅរកអង្ករមែន ! ។

ចំណែកយាយទៀង ពេលមិត្តៗរបស់គាត់បបួលចាកចេញចោលទឹកដីកម្ពុជា គាត់តាំងមាត់រកពាក្យឆ្លើយតបសឹងគ្មាន ។ គាត់ត្រូវតែព្រាត់ប្រាស់បែកចេញពីមិត្តៗដ៏កំសត់នេះជាដាច់ខាត ។ គាត់យំបណ្ដើរ គាត់និយាយនូវគោលបំណងរបស់គាត់បណ្ដើរ ៖

ទី១- គាត់ត្រូវនៅរង់ចាំដំណឹងកូនប្រុស៤នាក់ទៀត តាមបណ្ដាំប្ដីរបស់គាត់ដែលបានផ្ដាំមុននឹងអង្គការនាំយកទៅសម្លាប់ ថាបើនរណាបានរួចចេញពីនឹមដែកនេះ ត្រូវតែមករង់ចាំជួបជុំគ្នានៅផ្ទះរបស់យើងនេះ ។

ទី២- ខ្ញុំបានទទួលបណ្ដាំពីបងគីម-ងួនត្រាចថា បើខ្ញុំសល់នៅរស់ ត្រូវតែតាមដានរកស៊ើបឲ្យឃើញអំពីលក្ខណៈនៃវិបត្តិ ដែលកើតមានឡើងក្នុងប្រទេសកម្ពុជាបណ្ដាលឲ្យវិនាសហិនហោចខ្លោចផ្សាមិនទំនងយ៉ាងនេះ ។ បើខ្ញុំស្រាវជ្រាវទៅរកឃើញដូចយោបល់របស់លោក ខ្ញុំត្រូវសរសេរទុកជាប្រវត្តិសាស្ត្រ ជាមេរៀនសំរាប់កូនខ្មែរ ជាពិសេសមេដឹកនាំខ្មែរនៅជំនាន់ក្រោយ ឲ្យបានដឹងយ៉ាងច្បាស់លាស់ថា ៖

- អង្គការអនាមិកជានរណា ?

- តើក្រុមឃាតករអាថ៌កំបាំងជាសាសន៍ណា ?

មូលហេតុនេះ យាយទៀងក៏សំរេចចិត្តត្រូវតែទ្រាំនៅក្នុងស្រុកខ្មែរ តស៊ូស្រាវជ្រាវឲ្យបានដឹងច្បាស់ជាងនេះតទៅទៀត ពីឧបាយកលរបស់យួនហាណូយ ដែលស្រាប់តែបណ្ដើរគ្នាដើររ៉ុយចូលមករាតត្បាតប្រទេសខ្មែរយ៉ាងស្រួលគ្មានហាត់នឿយ គ្មានពិបាកធ្វើសង្គ្រាមយ៉ាងនេះ ។

គំរោងការទី១របស់ហូ-ជីមិញបានសំរេចជាស្ថាពរហើយ គឺត្រូវតាមលំនាំពាក្យទូន្មានរបស់តាប្រធានទិញ ដែលបាននិយាយពីយប់ថ្ងៃទី២៨ កុម្ភៈ ១៩៨៨ថា ៖

- ច្បាំងជាមួយខ្មែរ បើឈ្នះបានគ្រប់គ្រង បើចាញ់ធ្វើសេដ្ឋី ដែលកាលណោះយាយទៀងអង្គុយស្ដាប់ជាមួយនឹងគេដែរ ។ ម្យ៉ាងទៀតត្រូវតាមលំនាំពាក្យខ្សិបខ្សៀវរបស់យួនដែលថា ៖

- បើឯងមិនទៅតទល់ធ្វើចំបាំងនៅកម្ពុជាទេ ឯងនឹងស្លាប់ដោយការអត់ឃ្លាន តែបើឯងទៅយកបាយវាស៊ី ឯងអាចនៅមានសំណាងនឹងនៅរស់តទៅទៀត...

យាយទៀងនឹកឃើញសព្វគ្រប់ក៏ស្រក់ទឹកភ្នែកច្រោកៗ ព្រមទាំងរ៉ាយរាប់ប្រាប់មិត្តៗរបស់គាត់ថា ៖

-ក្នុងមួយជីវិតនេះ ខ្ញុំត្រូវវិនាសព្រាត់ប្រាស់បងប្អូនគ្រួសារ រងទុក្ខវេទនារហូតតាំងពីអាយុ២០ឆ្នាំរហូតមកដល់ថ្ងៃនេះ ដោយសារតែយួនហាណូយតាមរកសម្លាប់ ពីព្រោះខ្ញុំគេចមិនបំរើវា ។ កាលណោះភាគច្រើនព្រាត់រស់ ។

តែឥឡូវនេះបណ្តាលមកតែពីយួនហាណូយដដែល ដែលលួចបន្លំប្រើឈ្មោះអង្គការអនាមិក ខ្ញុំត្រូវព្រាត់ប្រាស់ប្តីកូនៗប្អូនៗក្មួយៗ ហើយដែលភាគច្រើនគឺព្រាត់ស្លាប់ ។

- គ្មានការតក់ស្លុតឈឺចាប់ខ្លោចផ្សាអ្វីជាងការឃើញផ្ទាល់ភ្នែក នូវក្រុមឃាតករដែលមកចាប់ចងប្តីរបស់ខ្លួន នាំយកទៅសម្លាប់ឡើយ ! ចំណែកទ្រព្យសម្បត្តិត្រូវរលាយអស់រលីង ខ្ញុំសល់តែបាតដៃទទេជាលើកទី២ ។

យាយទៀងលើកដៃបន់ស្រន់អស់វត្ថុស័ក្តិសិទ្ធិទាំងឡាយ សូមជួយណែនាំការស្រាវជ្រាវរបស់គាត់ឲ្យឆាប់បានសំរេច ។

គាត់នឹកទៅដល់សកម្មភាពរបស់ហ៊ីត្លែ ដែលគេស្គាល់ពេញពិភពលោក... តែហ៊ីត្លែសម្លាប់បរទេសដើម្បីពង្រីកប្រទេសរបស់ខ្លួន ដើម្បីត្រួតត្រាពិភពលោក ។ ចំណែកឯខ្មែរវិញ ក៏ស្រាប់តែគេផ្អើលពេញពិភពលោកដែរថា ខ្មែរកាចសាហាវជាងហ៊ីត្លែទៅទៀត ។

ប៉ុន្តែបើយើងពិនិត្យឲ្យហ្មត់ចត់ទៅ អ្នកដែលសម្លាប់ខ្មែរ ជាអង្គការអនាមិក ជាខ្មែរល្ងង់ខ្លៅ ជាចោរព្រៃ ដែលកើតឡើងពីការញុះញង់ ហើយដែលត្រូវឃាតករអាថ៌កំបាំងសម្លាប់បន្តទៅទៀត រហូតដល់អស់សាសន៍ខ្មែរ នៅថ្ងៃណាមួយជាមិនខាន ។ ឃាតករជាអង្គការអនាមិក គ្មានរូបគ្មានរាង ប្រើឃីហោខ្មែរក្រហម អួតក្អេងក្អាង តាំងខ្លួនជាតំណាងរបស់អង្គការ ដើរអញ្ជើញភូតកុហក ចុចឲ្យចំៗចំណុចខ្សោយនៃនាម៉ឺនអ្នករដ្ឋការខ្មែរ រួចប្រមូលដឹកនាំយកទៅចូលចំកណ្តាលអន្ទាក់ខ្សែត្រៀមនៃក្រុមឃាតករអាថ៌កំបាំង ឲ្យក្រុមនេះបាញ់សម្លាប់ចោលលេងៗ គ្មានពិបាកបង្ខំ គ្មានពិបាកចង... គ្រប់ៗរូបស្លៀកពាក់ឯកសណ្ឋានតាមយសស័ក្តិស្អាតៗ « មិនមែនស្រាតខោ ដោះអាវ រួចបញ្ជូកចូលក្នុងបន្ទប់ឧស្ម័ន នាំឲ្យលំបាកវេទនា ដូចហ៊ីត្លែសម្លាប់ជាតិហ្ស៊ីវឡើយ » ។

ក្នុងរយៈ៤ឆ្នាំគត់ យាយទៀងទទួលទារុណកម្មក្នុងស្ថាននរកលោកិយ ។ គាត់ឆ្ងល់សែនឆ្ងល់ថា ហេតុយ៉ាងដូចម្តេចបានជាខ្មែរដែលជាអ្នកកាន់ព្រះពុទ្ធសាសនា

ដែលធ្លាប់តែស្លូតត្រង់ សឹងមិនហ៊ានទះមូសឬរុយផងនោះ គ្រាន់តែជាតំណាងអង្គការអនាមិក ក៏ក្លាយទៅជាឃាតករយ៉ាងសាហាវឧក្រិដ្ឋម្ល៉េះ ? ហេតុយ៉ាងដូចម្ដេចបានជាបែរទៅសម្លាប់ព្រះសង្ឃដែលខ្លួនធ្លាប់តែគោរពស្មើព្រះសម្មាសម្ពុទ្ធ ? ហេតុយ៉ាងដូចម្ដេចបានជាសម្លាប់បញ្ញវ័ន្ត រួចទៅលើកបន្ទុបពួកចោរព្រៃទៅវិញ (?!) ។

គេសំគាល់ឃើញថា នៅក្នុងរយៈពេល៤ឆ្នាំនោះ អង្គការសម្លាប់ ៖

- ខ្មែរសាធារណរដ្ឋ
- ខ្មែរស្រឡាញ់សម្ដេចឪ ដែលនៅក្នុងនោះមានយោធាចំនួន៤ម៉ឺននាក់,
- ខ្មែរក្រហមក្រុមខៀវ-សំផន, នៅទីបញ្ចប់
- ខ្មែរក្រហមដែលកើតមកពីចោរ ដោយគ្មានជំនុំជំរះអ្វីឡើយ ។

« បើមិនបានឃើញផ្ទាល់ភ្នែក សឹងមិនជឿ » ។

ជាទីបញ្ចប់ លោតាអាងក៏បញ្ជាក់ថា អង្គការគឺយួនហាណូយ ។ យាយទៀងនឹកឃើញឡើងវិញ នៅពេលដែលគាត់ធ្វើដំណើរពីវត្តស្វាយមកភូមិអន្លង់កូប បន្តមកដល់បាត់ដំបង ដោយកាត់តាមស្រុកមោងឫស្សី ដែលមានចម្ងាយ១២០គីឡូម៉ែត្រ ។ គាត់បានឃើញក្មេងៗប្ញដូយចំនួន៣៣នាក់ ដែលជាកូនយួនហាណូយ មានអាវុធសឹងមិនគ្រប់ដៃ កំពុងបញ្ចេញសកម្មភាពដោយសេរី ។ មានក្រុមខ្លះច្រត់ចង្កេះឈរមើលសើចចំអកប្រមាថខ្មែរជាច្រើនសែននាក់ ដែលដើរទៅដើរមកគ្មានទិសដៅ មានតែខោអាវដាច់ដាចមួយបន្លាស់ជាប់នឹងខ្លួន បាតដៃទទេ ។ មូលហេតុទាំងអស់នេះជាពន្លឺអាចបញ្ចាំងលេចចេញនូវកលល្បិចនិងនយោបាយរបស់យួនហាណូយ ដែលវាតទីយកទឹកដីកម្ពុជា...

លុះមានពន្លឺខ្លះៗយ៉ាងនេះ យាយទៀងក៏ប្រាប់មិត្តៗរបស់គាត់ថា ៖

« ខ្ញុំមិនចាកចេញចោលស្រុកខ្មែរជាដាច់ខាត ខ្ញុំប្ដូរជីវិតនៅស្រុកខ្មែរ ខំព្យាយាមស្រាវជ្រាវឲ្យបានដឹងច្បាស់លើសពីនេះទៅទៀត » ។ នៅពេលខ្ញុំរកឃើញ ខ្ញុំនឹងសរសេរទុកជាឯកសារ ជាពិសេសទុកជាបណ្ដាំដល់ខ្មែរជំនាន់ក្រោយគ្រប់ៗស្រទាប់ តាំងពីមេដឹកនាំរហូតដល់កូនខ្មែរទូទៅ ឲ្យបានដឹងហើយនាំគ្នារិះរកមធ្យោបាយដោះស្រាយស្រោចស្រង់ជាតិយើងឡើងវិញ ។

- ត្រូវបបួលគ្នាសិក្សាអំពីនយោបាយ
- ត្រូវបបួលគ្នាត្រិះរិះពិចារណា ដោយមិនបណ្ដែតបណ្ដោយឲ្យចាញ់បោកឥទ្ធិពលនយោបាយបរទេស មានចិននិងយួនជាដើម ។
- ត្រូវចេះខ្មាស់អៀនចំពោះអំពើថោកទាបទាំងឡាយ ឈប់យល់ច្រឡំដោយឥតពិចារណា ដូចខ្មែរដែលកើតឡើងចំជំនាន់ស្ដេចសីហនុ និងមេខ្មែរក្រហមខៀវសំផន ។

- ត្រូវយល់ថា គ្មានសាសន៍ណាស្រឡាញ់ខ្មែរជាងខ្មែរឡើយ ។

- បើខ្មែរមិនចេះជួយខ្មែរទេ គ្មានសាសន៍ដទៃណាអាចមកជួយខ្មែរបានឡើយ (ខ្លួនទីពឹងខ្លួន ឬអត្តាហិអត្តនោនាថោ) ។

- អាវុធដ៏ស័ក្តិសិទ្ធិខ្លាំងក្លាអាចការពារជាតិបាន គឺខ្មែរគ្រប់រូប គ្រប់មជ្ឈដ្ឋាន ត្រូវភ្ញាក់រលឹកក្រោកឡើង រួបរួមគ្នាដោយស្មោះត្រង់ ជាពិសេសត្រូវចេះលះបង់ចោលឲ្យអស់នូវគំនុំផ្ទាល់ខ្លួន មិនត្រូវនិយាយរំលឹកច្រំដែលៗ នូវកំហុសទាំងឡាយដែលវរជនខ្មែរបានប្រព្រឹត្តខុសពីមុនៗនោះឡើយ ។ល។

នៅពេលដែលលោកតាអាងស្តាប់សំដីអះអាងរបស់យាយទៀងបានមកដល់ត្រឹមហ្នឹង គាត់មានការរំភើបចិត្តយ៉ាងខ្លាំង ក៏លើកដៃអង្អែលស្មាយាយទៀង ព្រមទាំងនិយាយថា ៖

- ប្រសើរណាស់ ! ប្រសើរណាស់ ! នេះជាកំនិតដ៏ល្អឯក ។ ខ្ញុំសុំគាំទ្រនិងជូនពរដល់បង សូមទេវតាជួយបងឲ្យបានសំរេចនូវគោលបំណងដ៏ឆ្នើមនេះ... ខ្ញុំសុំធានាជូនស្រីៗទាំង១៣នាក់ ចេញដំណើរទៅកាន់បន្ទាយអំពិល ។

ក្នុងឱកាសបែកគ្នាជាចុងក្រោយនេះ គ្រប់ៗរូបតឹងទ្រូងស្ទើរប្រេះ ក្តុកក្តួលក្នុងចិត្ត ពុំអាចរកពាក្យពេចន៍ឯណាមកពណ៌នាឲ្យអស់សេចក្តីបានឡើយ ។ ទាំងអស់គ្នាមានតែទឹកភ្នែកជំនួសសំដី ដែលជាសាក្សីនៃសេចក្តីឈឺចាប់ខ្លោចផ្សាសោកសង្រេង ។ មិត្តៗដ៏កំសត់ទាំងអស់ក៏បែកគ្នារហូត តាំងពីពេលនោះមក ។

❑ ❑

❑

# ជំពូកទី២១

★ ការរស់នៅក្នុងរបបឃុំឃាំងនិស្ស
★ ការចាត់តែងតាំងជាគិញសម្ងាត់
★ ដើម្បីបង្កើតខ្មែរថ្មី ប្ដីត្រូវរៀនអក្សរខ្មែរ
★ ចោរប្លន់ជាលើកទីមួយ
★ ជួបមេប្លន់ឈ្មោះវិញ-គិមលៀង និង លឹក
★ ជំរំ«កុមារសងឈាម»
★ ចោរប្លន់ជាលើកទីពីរ
★ ជួបលោក ថាច់-ទ្រឿង និងលោក គឹម-ហ៊ួរ
★ ចោរប្លន់ជាលើកទីបី

## ការរស់នៅក្នុងរបបឃុំឃាំងនិស្ស
### ពីថ្ងៃទី២៥-៤-៧៩ ដល់ថ្ងៃទី១៦-៦-៨០

ថ្ងៃបន្ទាប់ យាយទៀងដើរមើលចំការផ្លែឈើស្ថិតនៅភូមិក្រោយវត្តរំដួលមួយត្រួស ។ គាត់ដើរពីវត្តរំដួលរហូតដល់វត្តពោធិវង្ស គាត់ឃើញដើមឈើស៊ីផ្លែគ្រប់ធុនស្ថិតក្រញង់ៗ ត្រូវផ្លើងឆេះខ្លោចពាសពេញ ។ ចំណែកផ្ទះវីឡាគ្រឿងឈើចំនួន៣០០ខ្នង ត្រូវរុះរើដឹកនាំចេញអស់រលីង សល់តែកំទេចឥដ្ឋនិងជណ្ដើរដែលធ្វើពីថ្ម ។

ពេលនោះយាយទៀងបានជួបតែស្រីមេម៉ាយដូចខ្លួនគាត់ ដែលត្រូវព្រាត់ប្រាស់ប្ដីកូន «គឺព្រាត់ស្លាប់» សំណាក់នៅក្នុងកូនខ្ទមតូចៗប្រក់ស្លឹកដូង គ្មានជញ្ជាំង គ្មានគ្រែ អង្គុយឬដេកផ្ទាល់ដី ។ ពេលជួបគ្នាដោយចៃដន្យនេះ ក៏លោតឱបគ្នាគាំងមាត់ ហារនិយាយសឹងមិនរួច គ្រប់ៗគ្នាគ្រវីក្បាលមានតែទឹកភ្នែកទេជាសំនួរនិងជាចម្លើយ ។

យាយទៀងសួរសុខទុក្ខផ្សេងៗក៏ដឹងថា «គ្រួសារនិមួយៗមានសមាជិក១០នាក់ត្រូវស្លាប់យ៉ាងតិច៨នាក់ ។ មានគ្រួសារខ្លះសល់នៅរស់តែម្នាក់ មានគ្រួសារខ្លះត្រូវស្លាប់ផុតពូជ ។ ពេលនោះយាយទៀងក៏អួតនឹងគេដែរ ។ មើលចុះ ! គ្រួសាររបស់ខ្ញុំ៨នាក់ សល់នៅរស់តែ៥នាក់ ។ គ្រួសារប្អូនបង្កើតរបស់ខ្ញុំ១៣នាក់ សល់នៅរស់៧នាក់ ។ គ្រួសារក្មួយរបស់ខ្ញុំ៩នាក់ សល់នៅរស់តែម្នាក់គត់ ។ គ្រួសាររបស់ប្អូនថ្លៃខ្ញុំ៨នាក់ ត្រូវស្លាប់ផុតពូជ ។ « ខ្ញុំសរសេរជាឧទាហរណ៍នេះចង់បង្ហាញថាខ្មែរយើងត្រូវស្លាប់ជាងពាក់កណ្ដាល » ។ ម្យ៉ាងទៀត អ្នកសេសសល់នៅរស់ក៏ភៀសខ្លួនទៅកាន់ប្រទេសទី៣ ដូចជាគ្រួសារយាយទៀងជាដើម គ្មានសល់នរណាម្នាក់នៅស្រុកខ្មែរទេ ។ល។ និង ។ល។

ថ្ងៃបន្ទាប់មក យាយទៀងដើរមើលទីក្រុងបាត់ដំបងមួយត្រួស ។ គាត់ចេញដំណើរពីផ្សារវត្តលាប ដើរវាងមន្ទីរពេទ្យធំទៅកាន់ផ្លូវលេខ១ ស្របតាមបណ្ដោយដងស្ទឹងសង្កែរ ទៅកាន់ផ្សារលើ ដែលមានចម្ងាយជា៤គីឡូម៉ែត្រ រួចគាត់ត្រឡប់វិលវិញ ដើរតាមផ្លូវលេខ៣ ។

ឱពុទ្ធោអើយ ! ទីក្រុងមួយទាំងមូលសល់តែសំបក ។ ទីក្រុងបាត់ដំបងជាទីក្រុងទី២នៃប្រទេសកម្ពុជា មានបណ្ដោយប្រវែង៦គីឡូម៉ែត្រ ។ ចុងខាងជើងមានផ្សារមួយ គឺផ្សារវត្តលាប ។ ចុងខាងជើងមានផ្សារមួយទៀតគឺផ្សារលើ ។ ផ្សារទាំងពីរនេះត្រូវរុះរើអស់រលីង ។ នៅកណ្ដាលទីក្រុង មានផ្ទះផ្សារសាធារណៈមួយយ៉ាងធំ បណ្ដោយប្រវែង១០០ម៉ែត្រ ទទឹងប្រហែល៨០ម៉ែត្រ មានថ្នល់ព័ទ្ធជុំវិញ ។ ស្របបណ្ដោយថ្នល់នេះ មានហាងលក់ទំនិញគ្រប់មុខ មានទាំងរោងកុន និងឱសថដ្ឋានជាដើម ។ ខាងត្បូងផ្សារធំ ស្របតាមបណ្ដោយផ្លូវលេខ១ លេខ២ លេខ២ក-ន្លះ និងលេខ៣ មានហាងលក់ទំនិញគ្រប់មុខ៦ជួរ បណ្ដោយប្រហែល៥០០ម៉ែត្រ មានទាំងរោងកុន រោងល្ខោន និងឱសថដ្ឋានជាដើមផង ។ ខាងជើងផ្សារមានហាងលក់ទំនិញគ្រប់មុខ៤ជួរ មានទាំងរោងកុន រោងល្ខោន និងឱសថដ្ឋានផងដែរ ។

ថ្ងៃទី១៧-៤-៧៥ ហាងទាំងនេះមានទំនិញគ្រប់មុខពេញៗ ។ ឥឡូវថ្ងៃទី២៨-៩-៧៩ ម៉ោងប្រហែល១១ ទីក្រុងបាត់ដំបងសល់តែសំបក សូម្បីតែទ្វារបង្អួច ត្រូវដោះដឹកនាំចេញអស់រលីង អាចមើលឃើញក្នុងហាងទាំងនោះទទេស្អាត ។ ដូច្នេះ

បង្ហាញឲ្យឃើញជាក់ស្តែងថា ប្រទេសខ្មែរត្រូវវិនាសហិនហោចក្នុងរយៈពេលអង្គការទទួលជ័យជំនះ គឺអង្គការបំផ្លាញខ្ទេចបំផ្លាញខ្ទីទាំងអស់ ។ យាយទៀងដើរមើលបណ្តើររួចធ្វើសំនួរសួរដោយឆ្លល់ថា តើអង្គការអត់រូបអត់រាងនេះធ្វើម្តេចអាចដឹកទំនិញគ្រប់មុខនិងទ្រព្យសម្បត្តិផ្សេងៗដ៏ច្រើនមហិមា ព្រមទាំងទ្វារបង្អួច តុ ទូ ជើងម៉ា គ្រែ ជាដើមទៅកាន់ទីណា ? ។

យាយទៀងដើរទៅដល់ផ្សារធំ ក៏បត់ឆ្វេងដើតាមផ្លូវឡាអេ ( La Haye ) ស្រាប់តែឃើញយាយចាស់ៗបួននាក់អង្គុយផ្ទាល់ដី ឱបក្បាលជង្គង់រៀបអស់សង្ឃឹម យាយទៀងដើរចូលទៅជួប ជំរាបសួរសុខទុក្ខ ។

យាយម្នាក់រ៉ាយរ៉ាប់ថា ៖

- ក្រុមគាត់ទាំងបួននាក់នេះត្រូវព្រាត់ប្រាស់គ្រួសារអស់រលីង ក៏បបួលគ្នាមកសំណាក់នៅទីនេះជាងមួយខែហើយ ព្រោះធ្វើដំណើរទៅមុខទៀតលែងរួច ។ យាយទៀងសួរថា ៖

តើម្ចាស់ហាងទាំងឡាយនោះមានមកកាន់ទីលំនៅឬទេ ? ។ យាយដដែលឆ្លើយឡើងថា ៖

- មានខ្លះៗដែរ ភាគច្រើនស្រីៗ... ប៉ុន្តែមកដល់ឃើញធ្វើមុខស្លូតគ្រវីក្បាល រួចដើរចេញបាត់ទៅ ។ មានអ្នកខ្លះដើរមកដល់ភ្លាម ក៏ចូលក្នុងហាងដើម្បីជីកគាស់រកមាសពេជ្រដែលខ្លួនបានកប់លាក់ទុក ។ ចំណែកបូដូយវាតាមឃ្លាំមើលជានិច្ច ពេលអ្នកទាំងនោះចេញពីហាងមកវិញ វាប្លន់យកអស់រលីង រួចបាញ់សម្លាប់ចោលនៅទីនោះទៅ ។ មានពេលខ្លះវាចាប់ចង រួចអារកម្តងបន្តិចៗ កំញើញរកមាសពេជ្រ ។

ឧទាហរណ៍ដូចក្រុមរបស់គាត់បួននាក់នេះ ត្រូវបូដូយចូលមកចាប់ចងទាំងថ្ងៃ វាវាយធ្វើបាបយ៉ាងទារុណ ។ យាយម្នាក់ខាងនេះមានមាសពេជ្រមួយកញ្ចប់ឲ្យវាទើបពួកខ្ញុំបានរួចខ្លួន ប៉ុន្តែជាអកុសល វាអារកយាយម្នាក់ឯណោះមានរបួសយ៉ាងធ្ងន់ និយាយមិនកើតដើរមិនរួច ។

ម៉្យាងទៀតក្នុងទីក្រុងគ្មានអ្វីទាំងអស់ គ្មានអង្ករ គ្មានអុស គ្មានទឹក ។ យាយនេះលើកដៃចង្អុលព្រមទាំងប្រាប់យាយទៀងថា ៖ « ពេលដណ្តាំស្លត្រូវតែពុះទ្វារបង្អួចបាក់បែកនោះដុត... ត្រូវការទឹកក៏យួរកូនឡាំងតូចមួយនោះទៅដងទឹកស្ទឹង» ។ ដូច្នេះក្រុមរបស់គាត់ទាំងបួននាក់ អង្គុយរង់ចាំពេលស្លាប់តែប៉ុណ្ណោះ ។ល។ និង ។ល។

យាយទៀងស្រក់ទឹកភ្នែកច្រោកៗ អាណិតដល់យាយទាំងនោះណាស់ ។ គាត់នឹកថ្ងូរក្នុងចិត្តថា ៖ ឱខ្មែរអើយ ! មិនគួរធ្លាក់ដុនដាបដល់ថ្នាក់នេះសោះ ។ ក្រ

ហើយទ័លទៀត ។ គ្មាននរណាអាចជួយនរណាបានឡើយ ។ យាយទៀងក៏សំពះសុំលាយាយទាំងបួននាក់នោះ រួចគាត់ដើរទៅមើលរោងល្ខោនបាក់សេង ស្ថិតនៅខាងជើងផ្សារធំ ដែលវៀតកុងបញ្ជាឲ្យបង្កាត់ល្ខោន ។ គេឲ្យឈ្មោះថា ល្ខោនជាតិ។ ក្រុមនេះសំណាក់នៅសែនរហេមរហាម ដេកផ្ទាល់ថ្ម គ្មានកន្ទេល គ្មានមុង ពេលដណ្តាំស្ល ត្រូវតែពុះទ្វារ បង្អួច តុ ទូបាក់បែក ត្រូវការទឹកក៏យួរឡាំងទៅដងទឹកស្ទឹងអញ្ជើងដែរ ។ គ្មាននរណាទៅសំណាក់នៅជាន់ទី២ ឬទី៣ឡើយ ព្រោះជាកន្លែងដែលគេទុកសំរាប់ជុះនោមទៅវិញ ។ យាយទៀងដើរទៅកាន់សាលដែលគេកំពុងបង្កាត់ល្ខោន ។ គាត់ភ្ញាក់រំភើបភ្លឹក ព្រោះនៅមុខសាលបង្កាត់ល្ខោន គាត់ឃើញអំបិលដែលហូរហៀរចេញពីច្រើនរយបាវពុកកញ្ចាស់ ដែលបញ្ជាក់ឲ្យដឹងថា គេបានលាក់ទុកជាយូរឆ្នាំមកហើយ ។ យាយទៀងសួរស្រីយួនហាណូយដ៏ក្មេងម្នាក់ដែលជាអ្នកទទួលខុសត្រូវក្រុមល្ខោនថា ៖

- តើបានអំបិលពីណាច្រើនម្ល៉េះ ?

ស្រីយួននោះសើចកាច់ក ព្រមទាំងឆ្លើយវែកញែកថា ៖

- ប្រទេសខ្មែរមិនខ្វះអំបិលទេ គឺខ្មែរក្រហមប្រមូលយកមកលាក់មិនឲ្យប្រជាជនខ្មែរហូបទេតើ ! ។ សព្វថ្ងៃនេះ អំបិលមានច្រើនរយបាវ ដែលវាលាក់ទុកក្នុងរោងកុនអេដែន និងក្នុងជង្រុកស្ថិតនៅក្បែរស្ថានិយរថភ្លើងជាដើម...។

❑ ❑

❑

ថ្ងៃទី៣០-៤-៧៩ ម៉ោងប្រហែល៩ព្រឹក យាយទៀងធ្វើដំណើរទៅរោងកុនអេដែនម្តងទៀត ។ អំបិលដែលអង្គការចិត្តឃោរឃៅលាក់ទុកក្នុងរយៈពេល៤៤ខែ បង្អត់មិនឲ្យខ្មែរស៊ី ក៏បានត្រូវយួនហាណូយកាប់ទ្វារ បង្ហូរចេញពីបាវកំពុករាប់រយទាំងនោះដូចទឹកបាក់ទំនប់ ឲ្យខ្មែរកើបដោយសេរី ។

« នេះជាឧទាហរណ៍មួយទៀត សមទៅតាមពាក្យរបស់តាង្វៀង-វ៉ាន់ទិញ ដែលបានពន្យល់និស្សិតជំនាន់ទីមួយ កាលពីយប់ថ្ងៃទី២៨-២-៨៤ ដែលគេហៅថា ធ្វើឲ្យអស់សង្ឃឹមរួចជួយឲ្យមានសង្ឃឹមឡើងវិញ ! » ។

ថ្ងៃទី២-៥-៧៩ ម៉ោងប្រហែល៩ព្រឹក យាយទៀងចូលកាន់សាលាខេត្តបាត់ដំបងស៊ើបសួររកការធ្វើ ។ ពេលនោះលោកសឺន-ដាញ់ ( លោកសឺន-ដាញ់ត្រូវយួនចាប់ខ្លួននៅឆ្នាំ១៩៨៤ ) ជាអ្នកបកប្រែភាសាយួន-ខ្មែរ ក្រឡេកឃើញគាត់ ក៏ធ្វើ

កាយវិការប្រាប់យាយទៀងថា «លោកសុំជួបសិន» ។ យាយទៀងក៏ដើរចេញពីជួរទៅឈរក្បែរជញ្ជាំងចាំលោក ។ មួយសន្ទុះ លោកសឹន-ដាញ់ក៏ដើរមកជួបនិយាយទៀងបង្អួរទឹកភ្នែករលីងរលោង រួចខ្សិបប្រាប់គាត់ថា ៖

- សូមបងកុំដាក់ពាក្យធ្វើការឲ្យសោះណា៎ ! វៀតកុងកំពុងតែស៊ើបរកមុខអតីតអ្នករដ្ឋការ ! ។

រួចហើយក៏កៀកកយាយទៀងបណ្ដើរទៅកាន់គំនរអំបិល ។ លោកកើបអំបិលពីរលីត្រច្រកថងហុចឲ្យយាយទៀង ហើយខ្សិបប្រាប់ម្ដងទៀតថា ៖

- ដើម្បីកុំឲ្យយួនវាសង្ស័យ សូមបងយកអំបិលនេះទៅផ្ទះវិញ ខ្ញុំនឹងភរវាថាបងស្រីខ្ញុំមករកសុំអំបិល ។ និយាយបានត្រឹមហ្នឹង លោកសឹន-ដាញ់ក៏សុំលាយាយទៀងចេញទៅ ។ ពេលនោះយាយទៀងភ្ញាក់រំភើបភ្លឹកម្ដងទៀត ព្រោះឃើញប្រជារាស្ត្រខ្មែរជាច្រើនស្លៀកពាក់ដាច់រយ៉ៃឈរបន្តកន្ទុយគ្នាមុខញញឹមចាំទទួលអំណោយអំបិលពីយួន ។

កលល្បិចនេះប្រសើរណាស់ មើលចុះប្រជារាស្ត្រខ្មែរកំពុងតែអស់សង្ឃឹមរង់ចាំពេលស្លាប់ ស្រាប់តែឃើញយួនហាណូយមក«ជួយ»មែន ។ ប្រជារាស្ត្រខ្មែរកំពុងតែអត់អំបិលស៊ី ស្រាប់តែយួនហាណូយយកអំបិលមកចែកឲ្យ ?!?! ។

មូលហេតុនេះ ប្រជារាស្ត្រខ្មែរដែលខ្វះការពិចារណា មិនបានសិក្សានយោបាយឲ្យបានច្បាស់លាស់ បែរជាទះគូថអរគុណយួនហាណូយដែលជាមេឃាតករ និងជាចោរឈ្លានពានប្លន់ទ្រព្យសម្បត្តិនិងទឹកដីខ្មែរទៅវិញ ។ យាយទៀងឈរមើលកាយវិការរបស់យួនលួចអំបិលរបស់ខ្មែរ ហើយកំពុងតែយកមកចែកឲ្យខ្មែរ «ដូរយកគុណ» យ៉ាងឈឺចាប់ ។ គាត់គ្រវីក្បាលរួចក៏វិលត្រឡប់ទៅកាន់កូនខ្ទមនៅក្រោយវត្តរំដួលវិញ ។ គាត់តាំងចិត្តនឹងនរឹងប៉ឹងអត់ធ្មត់ នាំកូនទាំងពីរនាក់កាប់គាស់ដីដាំដំណាំតាមធម្មតា ទោះជាឃើញអ្នកស្រុកផ្អើលឈូឆរបបួលគ្នាដើរចាកចេញចោលស្រុកដូចគេហែរកចិន គឺ «រេកឆ្នាំងទៅរកអង្ករ» ក៏ដោយ ។

❑ ❑

❑

នៅថ្ងៃទី៣-៥-៧៩ ម៉ោងប្រហែល៩ មានបូដូយក្មេងៗ៣នាក់ជាយួនហ្វៀ កាន់អាវុធគ្រប់ដៃដើរពីនិត្យមើលភូមិវត្តរំដួល វាក្រឡេកឃើញយាយទៀងនិងកូនៗរប

ស់គាត់កំពុងដាំពោត វាសង្ស័យជាម្ចាស់ភូមិនេះ គឺជាម្ចាស់ផ្ទះទើបមកដល់ ។

បូដូយទាំង៣នាក់នេះក៏បណ្តើរគ្នាទៅពិនិត្យមើលជណ្តើរ ស្នាបអង្គែលជញ្ជាំងជាថ្មដុំសរលោងស្រិល ដែលសល់ជង្រ្គឹងកណ្តាលវាល មានខ្សែភ្លើងជាប់ខ្វាត់ខ្វែងនៅឡើយ ។ វាសម្លក់សម្លឹងយាយទៀងព្រមទាំងនិយាយគ្នាវាថា ៖

– យាយនេះមានស្តុកស្តម្ភណាស់ Ba nay giau sang lam ផ្ទះនេះបែបល្អស្អាតណាស់ Nha nay tôt dep lam ។ យាយទៀងស្តាប់ឮដូច្នោះ គាត់ក៏ដើរទៅជួបបូដូយទាំងនោះ ។ គាត់លៃលកវេតាមខ្យល់មួយរយៈសិន រួចហើយក៏និយាយថា ៖

– គោរពកូនៗ, កូនៗសុខសប្បាយទេឬ chao con ! con manh gioi ha ? បូដូយតាំងបីនាក់មានអារម្មណ៍ដូចជាភ្ញាក់ វាបើកភ្នែកធំៗសម្លឹងមុខគ្នាមួយសន្ទុះ រួចវាសុំអញ្ជើញយាយទៀងទៅអង្គុយលើជណ្តើរ ។ វាក៏សួរសុខទុក្ខ ព្រមទាំងសួរប្រវត្តិរបស់យាយទៀង ជាពិសេសវាចង់ដឹងថា ហេតុម៉េចយាយទៀងចេះនិយាយភាសាយួន ។

ពេលនោះយាយទៀងលៃលកតថា ឪពុកជាយួន ម្តាយជាខ្មែរ ( ព្រោះពីពេលមុនៗ គាត់ប្រាប់បូដូយថាគាត់ជាជាតិយួន, បូដូយទាំងឡាយនេះតែងតែបង្ហាញអារម្មណ៍ចម្លែកៗណាស់) ចំណែកប្តីរបស់គាត់ឈ្មោះឃី-វិញទ្រី ជាជាតិយួន ទើបអង្គការសម្លាប់ចោល ។ បូដូយឮឈ្មោះនេះវាជឿ១០០ភាគរយ ទើបវានិយាយត្រង់ៗគ្មានលាក់លៀមថា ៖

– គួរឲ្យស្តាយណាស់ៗ ហេតុម្តេចម៉ែមិនប្រមូលគ្រួសារនិវត្តទៅកាន់ប្រទេសវៀតណាម ? កាលពីឆ្នាំ១៩៧៥ បូដូយប្រមូលអាណិកជនយួនបានចំនួន២សែននាក់ ដឹកនាំគេចយកទៅទុកស្រុកយួន ។

មេបូដូយនេះឈ្មោះង្វៀង-វ៉ាន់ទិញ ពាក់ស័ក្តិ៣ជាអ្នកទទួលខុសត្រូវនៅភូមិវត្តរំដួលនេះ ។ វាបញ្ជាក់ថា ពេលណាខ្លះៗដែលបូដូយចូលមកប្រមូលអាណិកជនយួនចំនួនប៉ុន្មានៗ ដឹកនាំយកទៅសំណាក់នៅប្រទេសវៀតណាម ជាពិសេសខេត្តបាត់ដំបង មានបញ្ជូនអាណិកជនយួនទៅកាន់ប្រទេសវៀតណាមចំនួន៣លើក ។ ក្បួនកាណូតសណ្តោងទូកធំៗតំរៀបជួរតាមដងស្ទឹងសង្កែរ ត្រង់ភូមិខ្វិត ឃុំព្រែកខ្ពប់ ។ ង្វៀង-វ៉ាន់ទិញសម្លឹងមុខយាយទៀងព្រមទាំងបញ្ជាក់ទៀតថា ៖

– កាលណោះបើម៉ែនាំគ្រួសារនិវត្តទៅកាន់ប្រទេសវៀតណាម ម៉ែគ្មានបារម្ភភ័យខ្លាចអ្វីទេ ។ តាមទូកតាមក្បួន មានចាត់ចែងគណៈកម្មការរៀបចំបាយទឹកជូន ។ លុះដល់ប្រទេសវៀតណាម អង្គការលើមានចាត់ចែងទីលំនៅឲ្យសំណាក់ជាលំដាប់លំដោយ ។ ចំណែកកូនៗរបស់ម៉ែ អង្គការលើបញ្ជូនឲ្យចូលរៀនដោយសេរីតាមផ្នែកៗ ។ លុះរៀនចេះចប់ អង្គការលើបញ្ជូនឲ្យមកកាន់ប្រទេសកម្ពុជាវិញ ប៉ុន្តែត្រូវ

ប្រែឈ្មោះជាខ្មែរទាំងអស់ ។

លុះស្តាប់ង្វៀង-វ៉ាន់ទិញពណ៌នាសព្វគ្រប់ចម្លែកយ៉ាងនេះ គាត់ក៏សួរបញ្ជាក់ថា ៖

- កូនទិញ, រឿងនេះពិតឬ ? ។

ទិញសើចយ៉ាងរីករាយហើយក៏ឆ្លើយថា ៖

- ពិតណាស់ម៉ែ ! ។

យាយទៀងក៏ឆ្លើយឡើងថា ៖

- ស្តាយណាស់ៗ ! ខ្ញុំខុសអស់រលីង ។ ប៉ុន្តែក្នុងបេះដូងគាត់ឈឺចាប់ឥតឧបមា ។ គាត់នឹកក្នុងចិត្តថា ក្នុងរយៈ៨ឆ្នាំគត់ គាត់ឃើញផ្ទាល់ភ្នែក គាត់បានទទួលទារុគកម្មផ្ទាល់ខ្លួន អង្គការចាត់ការសម្លាប់ចោលភ្លាមៗអ្នកចេះដឹង បញ្ញវ័ន្ត ព្រះសង្ឃជាជាតិខ្មែរ ។ រាស្ត្រខ្មែរណាដែលមិនទាន់ដល់វេនស្លាប់ អង្គការធ្វើទារុណកម្មម៉េចៗក៏ដោយឲ្យតែដល់ស្លាប់, រាស្ត្រខ្មែរសេសសល់នៅរស់ អង្គការច្បូតយកអស់ពីខ្លួន ម្នាក់ៗសល់តែបាតដៃទទេ ។ល។ និង ។ល។ តែនៅពេលនេះ ! ហេតុម្តេចអង្គការបែរជាបញ្ជូនបូដូយមកកាន់ប្រទេសកម្ពុជា ប្រមូលអាណិកជនយួនដឹកនាំយកទៅលាក់ទុកឯស្រុកយួនអញ្ចឹង ? ។ អាណិកជនយួនទាំងឡាយនោះ មានឡាន មានទូក មានកាណូតជិះយ៉ាងស្រួល ព្រមទាំងមានម្ហូប ទឹក ស៊ីផឹកយ៉ាងគ្រប់គ្រាន់ ។ អញ្ចឹងរឿងនេះចម្លែកណាស់ នេះជាពន្លឺលេចចេញយ៉ាងច្បាស់ថា អង្គការគឺយួនហាណូយយ៉ាងពិតប្រាកដ ។

ចាប់តាំងពីថ្ងៃនោះមក ង្វៀង-វ៉ាន់ទិញតែងតែចូលមកកាន់កូនខ្ទមរបស់យាយទៀង សុំសួរសេចក្តីសុខទុក្ខផ្សេងៗ ។ ថ្ងៃមួយទិញសុំតែងតាំងយាយទៀងជាគិញឈ្លបយកការណ៍ ។ ពេលនោះយាយទៀងធ្វើជាល្ងង់សួរវាថា តើគិញឈ្លបនេះគេធ្វើអ្វីទៅ ? ។ ង្វៀង-វ៉ាន់ទិញពេញចិត្តឆ្លើយនឹងសំនួរនេះណាស់ ។ វាញញឹមព្រមទាំងពន្យល់ថា ៖

- ម៉ែត្រូវពិនិត្យសង្កេតយកការណ៍ រួចផ្តល់ពត៌មានឲ្យពួកខ្ញុំ ។ អង្គការលើរបស់វៀតកុងចង់ដឹងថា តើប្រជាជនខ្មែរដែលសំណាក់នៅវត្តរំដួល ភូមិវត្តលាប តើពីដើមជាស្អីៗ ជាពិសេសពួកខ្ញុំចង់ដឹងថា នរណាធ្វើការជំនាន់ស្តេចសីហានុ ជំនាន់លន់-នល់ ជាខ្មែរក្រហម ។

ទិញសន្យាផ្តល់ពោត អង្ករ ឲ្យយាយទៀង ។ នៅពេលនោះគាត់មានការបារម្ភជាខ្លាំង ដោយខ្លួនគាត់ហ្នឹងឯងក៏ជាមនុស្សម្នាក់ដែលអង្គការកំពុងតែរកមុខដែរ ។ ដើម្បីផ្គាប់ចិត្តយាយទៀង សក្តិ៣វៀតកុងទិញយកកាសែតយួនឈ្មោះ «ញ៉ាងយ៉ឹង» (ប្រែមកថា ប្រជាជន) សរសេរជាភាសាយួនមកឲ្យគាត់អានជារៀងរាល់ពេល ។

ដោយសារកាសែតនេះ យាយទៀងបានដឹងថា ៖

- រដ្ឋាភិបាលប្រជាមានិតុកម្ពុជាដែលយួនហាណូយឆ្លៃប្រឌិតបង្កើតឡើង រួចចាត់តែងតាំងហេង-សំរិន (ជាខ្មែរវៀតមិញ... ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៨ ជាមេបញ្ជាការនៅកងពលលេខ៦) ជាអគ្គលេខាធិការមជ្ឈិមបក្សបាំងពីមុខវា តែងតែប្រារព្ធធ្វើមីទិញដ៏មហោឡារិក អបអរសាទរខួបអនុស្សាវរីយ៍ថ្ងៃទី១៧-៤-៧៥ ។ រដ្ឋាភិបាលអាយ៉ងយួនហាណូយដឹកលំដំកើងថ្ងៃទី១៧-៤-៧៥នេះថា ៖

- ជាថ្ងៃដ៏មហាជោគជ័យ

- ជាថ្ងៃមហាលោតផ្លោះ

- ជ័យជំនះនៅថ្ងៃ១៧-៤-៧៥ គឺជា «បំណងប្រាថ្នាដ៏ទទូចប្រកបដោយសេចក្តីសង្ឃឹម ដែលយើងខិតខំពុះពារដោយផ្តូរផ្តាច់ ផ្សាជាប់យ៉ាងស្អិតស្អិតល្មួតជាមួយវៀតណាម » ។

- បុណ្យជាតិរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតុកម្ពុជា គឺបុណ្យខួបអនុស្សាវរីយ៍ថ្ងៃទី៣-២-៣០ គឺជាថ្ងៃកំណើតរបស់បក្សកុម្មុយនិស្តឥណ្ឌូចិន ដែលបង្កើតឡើងដោយហូ-ជីមិញ ។ បុណ្យនេះរដ្ឋាភិបាលប្រជាមានិតុកម្ពុជាប្រារព្ធធ្វើជារៀងរាល់ឆ្នាំ ។

- មហាវិថីនៅក្នុងរដ្ឋធានីភ្នំពេញ បែរជាកែប្រែយកឈ្មោះមេខ្មែរវៀតមិញមកដាក់ទៅវិញ ៖

- មហាវិថីនរោត្តម កែឈ្មោះជាមហាវិថីទូ-សាមុត ។

- មហាវិថីព្រះមុនីវង្ស កែឈ្មោះមកជាមហាវិថីអាចារ្យមៀន ។

- គេឃើញមានផ្លូវហូ-ជីមិញ, ផ្លូវឡេនីន កើតឡើងព្រោងព្រាត ។

យាយទៀងអានកាសែតរួច គាត់អង្គុយសញ្ជប់សញ្ជឹងនឹកឃើញឡើងវិញនូវពាក្យពេចន៍របស់លោកគីម-ងួនត្រាច ដែលបានគូសដៅបញ្ជាក់ថា ជ័យជំនះថ្ងៃទី១៧-៤-៧៥ គឺជាជ័យជំនះរបស់អតីតខ្មែរវៀតមិញ បច្ចុប្បន្នលួចប្រើឈ្មោះខ្មែរក្រហម... មិនមែនជ័យជំនះរបស់បក្សខ្មែរក្រហមខៀវ-សំផនទេ ។

ឥឡូវនេះកាសែតញ៉ាងយ៉ឹងជាភស្តុតាងយ៉ាងជាក់ស្តែង ដែលបញ្ជាក់នូវពាក្យពិតរបស់វៀមច្បងម្នាក់នេះ ។

❑ ❑

❑

នៅពេលនោះស័ក្តិ៣យួនហាណូយង្វៀង-វ៉ាន់ទិញដើរចូលមកកាន់កូនខ្ទមរប

ស់យាយទៀងយ៉ាងលឿនទាំងទឹកមុខញញឹម ។ ទិញហុចកាសែតខ្មែរមួយច្បាប់មកឲ្យយាយទៀង ។ កាសែតនេះមានឈ្មោះថា «កម្ពុជា» ។ កាសែតនេះបានអះអាងបញ្ជាក់ប្រាប់ថា ៖

១- កងកម្លាំងប្រដាប់អាវុធបដិវត្តន៍ឯកភាពរបស់កម្ពុជា ដែលហូ-ជីមិញបញ្ជាឲ្យសឺង-ង៉ុកមិញបង្កើតនៅថ្ងៃទី១៩-៦-៥១នោះ ក្នុងពេលបន្លំធ្វើជាខ្មែរក្រហមដើម្បីបន្លំវាយកំទេចខ្មែរលន់-នល់ពីឆ្នាំ៧០-៧៥ បានកែប្រែឈ្មោះទៅជា « កងកម្លាំងប្រដាប់អាវុធស្នេហាជាតិកម្ពុជា » ។ នៅក្នុងរបបអង្គការអនាមិក កងកម្លាំងនេះឯងក៏ប្រែឈ្មោះទៅជា « បក្សខ្មែរក្រហមនិរតី » ។ បច្ចុប្បន្ននេះបក្សខ្មែរក្រហមនិរតី ក៏ប្រែឈ្មោះទៅជា « កងកម្លាំងប្រដាប់អាវុធប្រជាជនបដិវត្តន៍កម្ពុជា » ។

២- បក្សប្រជាជនបដិវត្តន៍កម្ពុជា ដែលហូ-ជីមិញបញ្ជាឲ្យសឺង-ង៉ុកមិញបង្កើតកាលពីថ្ងៃទី២៨-៦-៥១នោះ ក្នុងរបបអង្គការអនាមិក៧៥-៧៩ អង្គការបានចាត់តាំងសមាជិកបក្សនេះឲ្យធ្វើជាប្រធានសហករណ៍ ជាគណៈតំបន់ និងជាតំណាងរាស្ត្រ ។ បច្ចុប្បន្ននេះប្រែឈ្មោះមកជា « បក្សប្រជាជនបដិវត្តន៍កម្ពុជា » ដែលយួនហាណូយចាត់តែងតាំងហេង-សំរិន ជាអគ្គលេខាធិការគណៈកម្មាធិការមជ្ឈិមបក្ស ។ រួចហើយយួនហាណូយបានចាត់តែងតាំងជា-ស៊ីម, សាយ-ភូថង, ហ៊ុន-សែន, ជា-សុទ្ធជាដើម ឲ្យទៅជាសមាជិកនៃការិយាល័យនយោបាយរបស់មជ្ឈិមបក្សនេះ ។

៣- កាសែតនេះហ៊ានអួតបញ្ចេញអាថ៌កំបាំងនៅកណ្តាលវាលថា ៖ វៀតណាមបានប្រកៀកស្មាជាមួយកម្ពុជា ( ពាក្យកម្ពុជាក្នុងទីនេះ គឺវាចង់សំដៅទៅលើខ្មែរវៀតមិញ ) យើងត្រូវតែប្តេជ្ញាថែរក្សាចំប៉ិនចំណងមិត្តភាពដែលហូ-ជីមិញបានដាំជ្រោយពូនក្នុងថ្នាលសង្គមនិយម ពីមួយថ្ងៃទៅមួយថ្ងៃ កាន់តែផ្សាស្អិតល្អួត ក្លាយទៅកម្លាំងដ៏មហិមា ក្លាយទៅកម្លាំងដ៏អមតៈ ។ ចំណងទំនាក់ទំនងប្រយុទ្ធពិសេសពោរពេញទៅដោយស្មារតីអន្តរជាតិអធនដ៏ថ្លៃថ្លា អាចដណ្តើមបានជ័យជំនះជាស្ថាពរនៅឆ្នាំ១៩៧៥ ។ យើងអាចរុញច្រានខ្មាំងឲ្យថយក្រោយជាជំហានៗ យើងអាចផ្តួលរំលំខ្មាំងមួយផ្នែកៗ រួចឈានឡើងដណ្តើមយកជ័យជំនះបានជាបន្តបន្ទាប់យ៉ាងធំធេង ។ ឧទាហរណ៍ដូចជាយើងកំទេចខ្មែរលន់-នល់ យើងទទួលជ័យជំនះនៅថ្ងៃទី១៧មេសា១៩៧៥ ។ នេះគឺជាជំហានទី១ ។ យើងកំទេចខ្មែរខៀវ-សំផនយើងទទួលជ័យជំនះនៅថ្ងៃទី៧ មករា ១៩៧៩ នេះគឺជាជំហានទី២ ។ល។

សេចក្តីអួតរបស់យួនហាណូយនេះជាសាក្សីបញ្ជាក់ថា យួននេះឯងហើយជាអង្គការអនាមិក ។ ចំណែកឯអាយ៉ងរបស់វា ដូចជាហេង-សំរិន, ជា-ស៊ីម, សាយ-ភូថង, ជា-សុទ្ធ, ហ៊ុន-សែនជាដើម ជាឃាតករលើរាស្ត្រខ្មែរស្លូតត្រង់យ៉ាងពិត

ប្រាកដ ។

កាសែតញ៉ាងយ៉ឹងញ៉ាំងឲ្យយើងឃើញទៀតថា ក្នុងរបបអង្គការអនាមិក យួនហាណូយឧបត្ថម្ភអតីតខ្មែរវៀតមិញ ឲ្យតាំងមូលដ្ឋានពាសពេញព្រៃនៃប្រទេសខ្មែរ ថែមទាំងមានបូដូយយ៉ាងច្រើនម៉ឺននាក់គាំទ្រ ឆ្លៀតឱកាសដ៏ល្អនេះប្រើឃីហោខ្មែរក្រហម រួចចូលមកចាប់ចងរាស្ត្រខ្មែរស្លូតត្រង់នាំយកទៅសម្លាប់រាល់ៗថ្ងៃ ។

៤- កាសែតនេះបញ្ជាក់ថា បក្សប្រជាជនបដិវត្តន៍ខ្មែរ បច្ចុប្បន្នប្រែឈ្មោះជា « បក្សប្រជាជនបដិវត្តន៍កម្ពុជា »... ហេង-សំរិនត្រូវឆ្លងកាត់ដំណាក់ការពីរ ៖

- ដំណាក់ការបដិវត្តន៍ប្រជាធិបតេយ្យនាយទុនបែបថ្មី, បច្ចុប្បន្ននេះហៅថា ៖ បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យប្រជាជន និងដំណាក់ការបដិវត្តន៍សង្គមនិយម ភារៈកិច្ចជាដំបូងត្រូវកំទេចប្រឆាំងចក្រពត្តិ និងសក្តិភូមិ ។ល។

❑ ❑

❑

ង្វៀង-វ៉ាន់ទិញតែងតែនាំបូដូយមកសុំរៀនភាសាខ្មែរពីយាយទៀង ។ បូដូយម្នាក់ៗមានកូនសៀវភៅ «រៀនខ្លួនឯង» មួយក្បាលជាប់តាមខ្លួន ដូចតាអាងបានអះអាងមែន ។

ថ្ងៃមួយង្វៀង-វ៉ាន់ទិញបណ្តើរបូដូយម្នាក់ឈ្មោះទី អាយុប្រហែល២៦ឆ្នាំមកលាយាយទៀង ដើម្បីទៅកាន់ស្រុកហាណូយនៅថ្ងៃស្អែក ។

យាយទៀងសួរថា ហេតុយ៉ាងដូចម្តេចបានជាទីអាចទៅហាណូយវិញបាន ? យួននោះឆ្លើយពន្យល់ពីលក្ខ័ណ៥ឆ្នាំ ១០ឆ្នាំ ឬអស់រហូតមួយជីវិតរបស់បូដូយ ដែលត្រូវកាន់វិន័យដូចដែលតាអាងបានបញ្ជាក់ប្រាប់រួចមកហើយ ។ វាគោរពវិន័យបានត្រឹមត្រូវ ដូច្នេះវាមានច្បាប់វិលត្រឡប់ទៅស្រុកវាវិញក្នុងរយៈពេល៥ឆ្នាំ គឺនៅថ្ងៃស្អែកនេះ ។ ចំណែកឯសក្តិពរៀតកុងង្វៀង-វ៉ាន់ទិញ វាបានប្រាប់យាយទៀងថា វាកើតនៅខេត្តដាណាង ។ យួនហាណូយបញ្ជូនវាមកកាន់ស្រុកខ្មែរកាលពីខែមីនា១៩៧២ ជាមួយពួកយួនគ្នាវាជាច្រើនពាន់នាក់ ។ ឆ្នាំ១៩៧៧ យួនទិញធ្លាក់វិន័យ ៥ឆ្នាំ ដូច្នេះវាត្រូវនៅស្រុកខ្មែរ៥ឆ្នាំតទៅទៀត រហូតដល់ឆ្នាំ១៩៨២ ។ល។

❑ ❑

❑

នៅខែមិថុនាឆ្នាំ១៩៧៩ នៅនាយកដ្ឋានសុខាភិបាលខេត្តបាត់ដំបង គេមានបិទប្រកាសផ្សាយរកនិស្សិតផ្នែកពេទ្យ ដើម្បីបញ្ជូនទៅបន្តវិជ្ជានៅសហភាពសូវៀត ។យាយទៀងក៏នាំរ៉ាដា កូនស្រីទី២របស់គាត់ទៅទីនោះ ដើម្បីសុំចុះឈ្មោះ ។ លោកថាច់-កៅលី ដែលជាអ្នកទទួលខុសត្រូវបានខ្សិបប្រាប់គាត់ថា ៖

- សុំមីងកុំចុះឈ្មោះឲ្យសោះ ព្រោះកូនអតីតអ្នករដ្ឋការដែលបានចុះឈ្មោះពីមុនៗមកបានត្រូវបាត់ខ្លួនរហូត... គេពុំដឹងជាយុវជន យុវនារីទាំងអស់នោះត្រូវគេនាំយកទៅណាទេ ។ តែដើម្បីកុំឲ្យមានការសង្ស័យ លោកកៅលីក៏ហុចក្រដាស់មួយសន្លឹកមកឲ្យយាយទៀងដូចគេឯងដែរ ។

សំនួរនៅលើក្រដាស់មានដូចតទៅ ៖

- ឈ្មោះឪពុក......... ស្រុកកំណើត.........ពីដើមធ្វើអី..........សព្វថ្ងៃនៅឯណាឥឡូវធ្វើអី........ស្លាប់ឬរស់...........? ។

- ឈ្មោះម្តាយ.........ស្រុកកំណើត........ពីដើមធ្វើអី..........សព្វថ្ងៃនៅឯណាឥឡូវធ្វើអី........ស្លាប់ឬរស់...........? ។

- មានមា-មីង-បង-ប្អូននៅបរទេសឬទេ ? បើមានតើឈ្មោះអី.... នៅប្រទេសណា.......នៅស្រុកខ្មែរធ្វើអី.......សព្វថ្ងៃធ្វើអី..........? ។

- មានមិត្តភ័ក្តិឬស្គាល់អ្នកនៅបរទេសឬទេ ? បើមានតែឈ្មោះអី........នៅប្រទេសណា.......នៅស្រុកខ្មែរធ្វើអី................សព្វថ្ងៃធ្វើអី...............? ។

នៅបន្ទាត់ខាងក្រោមគេបង្អស់ មានអក្សរមួយជួរសរសេរថា ៖

« បើថ្លែងប្រាប់មិនបានត្រឹមត្រូវ បេក្ខជនត្រូវទទួលខុសត្រូវផ្ទាល់ខ្លួន » ។ យាយទៀងបានអានពិនិត្យសំនួរដ៏ចម្លែកនេះរួច ក៏នាំកូនស្រីមកខ្ទមវិញ ។

នៅចុងខែមិថុនា យាយទៀងបានជួបឃឺ-ទ្រីវិច្ឆិកា កូនប្រុសទី៥របស់គាត់វិញ គ្រួសារដ៏កំសត់នេះ បានជួបជុំម្តាយនិងកូនបីនាក់ ទើបមានពន្លឺសប្បាយរីករាយបន្តិច ។

តែការរីករាយក្នុងចិត្តនេះមិនបានស្ថិតនៅយូរប៉ុន្មានទេ ។ ព្រោះនៅពេលនោះមានបញ្ហាមួយពីអង្គការលើ ឲ្យបញ្ជូនវិច្ឆិកាទៅធ្វើស្រែរួម ។ ត្រូវរកអង្ករម្ហូបនាំយកទៅបរិភោគខ្លួនឯង ។ ត្រូវដើរដោយជើងពីទីក្រុងបាត់ដំបង តៅឃុំតាម៉ឺនចម្ងាយ ៩០គ.ម. ។ ប្រជាជនខ្មែរទាំងអស់អស់សង្ឃឹម ដោយឃើញបញ្ហាដដែល ដូចជាបញ្ហាសម័យអង្គការ មានការធុញទ្រាន់ក៏បបួលគ្នាចាកចោលទឹកដីកម្ពុជាជាហូរហែរ ។

ចំណែកវិច្ឆិកា ដោយគោរពតាមបណ្តាំឪពុកឲ្យនៅរង់ចាំដំណឹងពីបងៗបីនាក់ទៀត ក៏ស្ម័គ្រចិត្តចេញទៅពលិកម្មធ្វើស្រែរួមនេះ ។ នៅពេលមួយ ស្រាប់តែមាន

ចោរមួយក្រុមចូលមកព័ទ្ធចាប់ចង រួចប្លន់យកគោអស់រលីង ។ វិច្ឆិកាក៏ត្រូវអូស រទេះជំនួសគោ វិលត្រឡប់មកកាន់បាត់ដំបងវិញ រង់ចាំទទួលបញ្ហាថ្មី ។

❑ ❑

❑

# ចោរប្លន់ជាលើកទីពីរ

ក្នុងខែកក្កដា១៩៧៩ នៅខេត្តបាត់ដំបងមានកើតឧប្បត្តិហេតុដ៏អស្ចារ្យ គឺកើតចោរប្លន់កាប់សម្លាប់យ៉ាងសាហាវនៅគ្រប់ទីកន្លែង ។

នៅថ្ងៃទី១៦-៧-៧៩ ម៉ោងប្រហែល៦ល្ងាច មានចោរមួយក្រុម ( ដល់លើកក្រោយមកទើបដឹងថា ក្រុមនេះជាអតីតខ្មែរក្រហមនិរតី ) កាន់អាវុធគ្រប់ដៃ បណ្តើរគ្នាចូលមកកាន់កូនខ្ទមរបស់យាយទៀង ។ វាស្រែកសម្លុតពីចម្ងាយថា ៖

- ណែអ្នកម្ចាស់ខ្ទម ! មានឃើញចោរបីនាក់ដើរកាត់ទីនេះទេ ? ។

ពេលនោះយាយទៀងនិងកូនបីនាក់អើតក្បាលមើលជុំវិញខ្ទមដែលគ្មានជញ្ជាំងស្រឡះផេងនោះ រួចក៏ឆ្លើយដោយគួរសមនិងយ៉ាងស្មោះត្រង់ថា ៖

- មិនឃើញទេ, ក្មួយៗអើយ ។ បើមានមែនពួកអ៊ំមុខតែនឹងឃើញជាមិនខានព្រោះវាលស្រឡះផេង ។ ស្រាប់តែអាចោរម្នាក់បញ្ឈ្មកគ្រាប់កាំភ្លើងភ្ជង់តំរង់មកវិច្ឆិកា ព្រមទាំងកំហ្លើញថា ៖

- ខ្ទមនេះលាក់ចោរ ! ខ្ទមនេះលាក់ចោរ !

បន្ទាប់មកវាក៏ចូលមកចាប់ឆែកឆេរកូនខ្ទមតាមអំពើចិត្ត ពន្យាពេលចាំយប់ងងឹតមកដល់ ដើម្បីធ្វើទារុណកម្មលើម្ចាស់ខ្ទមទាំងបីនាក់នេះ ។ វាប្រើល្បិចកលចោទថាជាចោរ រួចបណ្តើរទាំងចំណងចេញទៅ ។ រ៉ាដាឃើញដូច្នោះក៏សុំអង្វរចោរទៅជាមួយប្អូន ។ ចំណែកយាយទៀងវង្វេងស៊ុង ហើយក៏ដួលសន្លប់បាត់ស្មារតី ដោយភ័យតក់ស្លុតនឹងអំពើព្រៃផ្សៃនេះ...។

កូនស្រីពៅនៅជាមួយម្តាយ ភ័យខ្លាំងពេកយំបណ្តើរដាស់ម្តាយបណ្តើរ ។ លុះគាត់ដឹងខ្លួនឡើងវិញ យប់ងងឹតណាស់ទៅហើយ ។ ពួកចោរវិលត្រឡប់មកប្លន់យាយទៀងវិញ ។ គាត់រត់គេចទៅពួននៅចំការដូងខាងជើងខ្ទម ។ ដោយរក

គាត់មិនឃើញ វាក៏ស្រែកឡូឡាឡើងថា ៖

- ឃើញទេ ! ស៊ីគ្រលុំលាក់ចោរ ។ ឥឡូវវារត់ចោលខ្ទម ! ។

ក្រុមចោរទាំងនោះក៏ថយទៅវិញ រួចស្រាយចំណងលែងវិច្ឆិកា ឲ្យវិលមកកាន់កូនខ្ទម ព្រមទាំងនិយាយទន់ភ្លន់សុំទោសថា ពួកវាចាប់ច្រឡំ ។ ចំណែកយាយទៀង ក៏រត់ទៅប្តឹងក្រុករក្សាសន្តិសុខស្ថិតនៅក្នុងវត្តរំដួល មានបួដួយនិងឈ្លបជាតិខ្មែរដែលជាអតីតខ្មែរក្រហមនិរតីទាំងអស់ ។ ក្រុមនេះធ្វើសោះអង្គើយជិតមួយម៉ោង ទើបធ្វើជានាំគ្នារត់ឆ្វេចឆ្វាចមកកាន់កូនខ្ទមរបស់យាយទៀង ។ វាភរដោយសំដីល្អងលោមថា ៖

- សុំអ៊ុំកុំភ័យបារម្ភអី ពួកក្រុមខ្ញុំចាត់ការយាមល្បាតការពារអ៊ុំហើយ ។

រួចហើយវាក៏ដើរចេញទៅវិញបាត់អស់ ។ ឃើញអាកប្បកិរិយាពួកវាដូច្នេះ យាយទៀងគ្មានទុកចិត្តពួកវាទាល់តែសោះ ។ គាត់ខំកិតរិះរកកន្លែងដើម្បីគេចពួនពីពួកហ្នឹង ។ សេចក្តីខ្វល់ខ្វាយកាន់តែថែមត្រួតឡើងៗ ដោយមិនដឹងជាគេចទៅណាណាមួយភ្លៀងក៏ចាប់ធ្លាក់ជោគជាំ ណាមួយវិច្ឆិកាក៏ស្រែកថ្ងូរដូចព្រាបដោយចុកពោះយ៉ាងខ្លាំង ។ ណេ្ហីយ ! ទ្រាំតាមយថាកម្មទៅចុះ !....

មែន ! ការសង្ស័យរបស់យាយទៀងគ្មានខុសឯណា ។ នៅម៉ោង១២អាធ្រាតក្រុមចោរដដែលក៏មកដល់ល្មម ។ វាមានគ្នា៧នាក់ កាន់ខ្សែបួនចង្វាយនៅដៃរួចជាស្រេច ។ ក្រុមចោរចាប់ចងអង្គរានិងវិច្ឆិកា ហើយយកក្រមាញាត់មាត់អ្នកទាំងពីរ ។ អាចោរជាអតីតខ្មែរក្រហមនិរតីចាប់យាយទៀងចងអូសនាំចូលបង្គន់ វាយធ្វើបាបកំញើញរកមាសពេជ្រទាល់តែបាន ។ យាយទៀងឲ្យកញ្ចប់មួយទៅវា ដែលនៅក្នុងនោះមាន ៖

- ខ្សែដៃមាសទឹកដប់មួយជំឡឹង
- ខ្សែកបួទីន៣ខ្សែ
- ចិញ្ចៀនមួយវង់ មានត្បូងពេជ្រទំហំ៣លីចំនួន១៣គ្រាប់
- និងចិញ្ចៀនមួយវង់ មានត្បូងបប៉ៃលិនទំហំ៦លីចំនួន៥គ្រាប់ ។

ប៉ុណ្ណឹងហើយវាមិនទាន់ពេញចិត្តនៅឡើយទេ វាគំរាមសំឡុតរកថែមទៀត ។ ស្រាប់តែឮសម្លេងស្រែកនៅក្នុងចំការខាងជើងខ្ទមថា ៖

- ជួយផង ! ជួយផង ! ចោរប្លន់ !

ឮដូច្នោះអាមេចោរអតីតខ្មែរក្រហមនិរតីក៏បញ្ឆកគ្រាប់កាំភ្លើងតម្រង់មាត់ត្រៃមករកយាយទៀងដើម្បីនឹងបាញ់សម្លាប់បំបាត់ភស្តុតាង មុននឹងពួកវាចេញពីទីនេះទៅវិញ ។ គ្រាប់កាំភ្លើងក៏ផ្ទុះឡើងលាន់ឮសូរផាំង ! ផ្ទាត់ទៅត្រូវជញ្ជាំងបង្គន់ ដោយ

សារមិនដឹងជាហេតុអីបានជាមានអាគ្នាវាម្នាក់រុញច្រានមាត់ត្រៃកាំភ្លើងពង្វាងទៅខ្លួនយាយទៀងទៅវិញ... រួចហើយពួកវាក៏រត់របាត់របាយអស់ទៅ ។ យាយទៀងក៏រត់ទៅប្ដឹងក្រសួង «សន្តិសុខ» ដដែលជាលើកទី២ ទាំងចំណងនៅដៃ ។ វាបណ្ដោតពេលទុកឲ្យចោរគេចរត់ទៅឆ្ងាយសិន សូម្បីតែចំណងដៃដែលចោរចងគាត់ ក៏គ្មាននរណាមួយអើពើស្រាយឲ្យផង ។ នៅពេលដែលជួបជុំម៉ែកូនឡើងវិញ ទើបដឹងថា នៅពេលដែលអាចោរមួយក្រុមកំពុងតែចាប់ចងយាយទៀង, រ៉ាជានិងវិច្ឆិកាមានអាចោរចិត្តពាលម្នាក់ចាប់អូសកូនស្រីពៅរបស់គាត់អាយុទើបបាន១៤ឆ្នាំ នាំយកទៅកាន់ចំការដូងបំរុងរំលោភ ។

នាងប្ដូរជីវិតរើបំរះពីកណ្ដាប់ដៃអាចោរអប្រិយ៍នេះ ។ វាខឹងខ្លាំងពេក ក៏បោកគ្រាប់បែកដៃមួយគ្រាប់បំរុងសម្លាប់នាងចោល ។ វាសនាល្អណាស់ គ្រាប់បែកដៃមិនផ្ទុះ នាងក៏ស្រែករកគេជួយ ធ្វើឲ្យអាចោរទាំងនោះរត់ផាយចេញទៅវិញទៅ...

គួរឲ្យអាណោចអធម៌ដល់យាយទៀងណាស់ ស៊ូប្ដូរជីវិត ខំលាក់ខំថែរក្សាទ្រព្យសម្បត្តិសំខាន់ៗរបស់គាត់ ដូចជាមាស ពេជ្រ ហួល ផាមួង សំពត់មុយអារនិងរូបថតគ្រប់ផុនដែលថតជាមួយប្ដី-កូនៗតាំងពីក្មេងៗ ជាអនុស្សាវរីយ៍ដ៏សែនមនោរម្យ ។ នៅក្នុងរយៈ៤ឆ្នាំនៃរបបអង្គការ បើតំណាងវាដឹងថាគាត់លាក់របស់អស់ទាំងនេះ វាច្បាស់ជាមិនទុកជីវិតឲ្យទៅ ។ តែទោះជាខំប្រឹងលាក់យ៉ាងណាក៏ដោយ ទីបំផុតគឺចោរវាជិះតយកទាល់តែបាន ។

កិច្ចការលាក់របស់ទាំងនោះមានសភាពវេទនាណាស់ ។ រាល់ៗព្រឹកម៉ោងបួនភ្លឺ ត្រូវយកកញ្ចប់ទ្រព្យនេះទៅកប់ក្នុងរណ្ដៅមួយក្នុងទ្រូងជ្រូក យកដែកសង្កសីមួយបន្ទះគ្របពីលើ ។ រួចហើយកើបអាចម៍ជ្រូកនិងស្លឹកឫស្សីរាយពីលើទៀត ។ យប់ឡើងម៉ោង៩ទើបទៅយកមកទុកជាប់នឹងខ្លួនក្នុងខ្នមវិញ ។ នៅតាមកំណែន ទៅណាមកណា កាត់វាលចូលព្រៃរាប់រយគីឡូម៉ែត្រ ត្រូវលាក់ជាប់នឹងខ្លួនជានិច្ច ។ កន្លងផុតបាន៤ឆ្នាំមកហើយ ស្រាប់តែឥឡូវនេះត្រូវក្រុមចោរជាអាយ៉ងយួនហាណូ-យ ចូលមកប្លន់ទាំងភ្លែកស្រស់ យកអស់រលីងពីខ្លួន សូម្បីតែជីវិតក៏ស៊ីងមិនគង់ទៅទៀត ។ ម្ដាយនិងកូនទាំងបីនៅសល់តែខោអាវមួយបន្លាស់ជាប់នឹងខ្លួនតែប៉ុ-ណ្ណោះ ។

យាយទៀងស្រែកយំថ្ងូរដំអូញថា ឈឺចាប់ណាស់ៗ ! ជីវិតខ្ញុំអស់ន័យហើយ ។ គ្មានអ្វីគួរឲ្យស្ដាយស្រណោះទៀតឡើយទឹកដីកម្ពុជា !

ពេលនោះ រ៉ាជានិយាយមកកាន់ម្ដាយថា ៖

- ម៉ាក់អើយ ប្រទេសខ្មែរសព្វថ្ងៃ ដូចជាកប៉ាល់មួយដែលបើកបរដោយសារមនុស្សដដែល គ្រាន់តែផ្លាស់សំលៀកបំពាក់តាមកាលវេលាតែប៉ុណ្ណោះ រួចហើយ

វាំនាំគ្នាបើកបរទៅកាន់ទិសដៅតែដដែល ។ នាងក៏សុំអង្វរម្ដាយដើម្បីនាំគ្នាចាកចេញពីស្រុកខ្មែរ ។

យាយទៀងតាំងមាត់រកនិយាយថាទៅឬទេមិនកើត ។ ព្រោះគោលបំណងស្រាវជ្រាវរបស់គាត់មិនទាន់បានចប់ចុងចប់ដើមតាមបំណងនៅឡើយ ។

មិនយូរប៉ុន្មាន ស្រាប់តែមានបញ្ជាពីអង្គការលើមកទៀត បង្ខំឲ្យវិច្ឆិកាចេញធ្វើពលិកម្មរួម ដើម្បីកាប់គាស់ដីភ្នួរនឹងចប ជំនួសគោក្របីដែលខ្វះ ។ ទីបំផុតយាយទៀងក៏សំរេចបញ្ជូនរ៉ាដា ( យាយទៀងនិងរ៉ាដាបែកគ្នារហូតតាំងពីពេលនោះមក ) និងវិច្ឆិកាផ្សងព្រេងភៀសខ្លួនទៅប្រទេសថៃ ។

នៅពេលបែកគ្នាជាលើកទី២នេះ ម៉ែកូនៗទឹងទ្រូងស្ទើរប្រេះតាំងមាត់ គ្មានពាក្យនិយាយ ពេលនោះមានតែទឹកភ្នែកទេដែលជាសាក្សីបង្ហាញថាកំសត់ ឈឺចាប់ខ្លោចផ្សា និងក្ដៅក្រហាយណាស់ ។ ចំណែកយាយទៀងរក្សាគោលបំណងមុតដដែល គឺជីវិតចុងក្រោយរបស់គាត់ គាត់ត្រូវតែធ្វើពលិកម្ម ខំស្រាវជ្រាវរកឲ្យឃើញអំពីលក្ខណៈពិតនៃមហន្តរាយនៅកម្ពុជាសម័យនេះ  តទៅទៀតគាត់ចង់កត់ត្រាតាមដាននូវព្រឹត្តិការណ៍នានា ដែលបណ្ដាលឲ្យប្រទេសខ្មែរត្រូវវលាយយ៉ាងនេះ។ ពីព្រោះព្រឹត្តិការណ៍ទាំងឡាយនោះដូចជាចម្លែក មានលាក់អាថ៌កំបាំងជាក្រៃលែង ទោះបានឃើញផ្ទាល់ភ្នែកហើយក៏ដោយ នៅពេលខ្លះសឹងតែមិនចង់ជឿ...

តាំងពីរ៉ាដានិងវិច្ឆិកាចេញផុតទៅ យាយទៀងរស់នៅសែនកំសត់វេទនាជាមួយអង្គរ ព្រោះខ្លាចចោរមកធ្វើទុក្ខបុកម្នេញទៀត ។ ដូច្នេះរាល់ៗយប់ គាត់តែងនាំកូនស្រីលបលួនចូលពួនដេកក្នុងបន្ទប់បង្គន់កណ្ដាលចំការរបស់គាត់ ។ លុះថ្ងៃរះទើបម៉ែកូនលួនចេញមកដាំនិងស្រោចទឹកបន្លែ ។

ក្នុងបន្ទប់បង្គន់នោះ ចន្លោះសំរាប់អង្គរាដេកមានបណ្ដោយ១ម៉ែត្រ ទទឹង៨តឹក ។ កន្លែងម្ដាយដេកមានបណ្ដោយ១ម៉ែត្រ ទទឹងកន្លះម៉ែត្រ ។ ដេកផ្ទាល់ថ្ម គ្មានកន្ទេល គ្មានភួយ គ្មានមុង គ្មានខ្នើយទេ ។ ម្នាក់ៗដេកកើយដៃ អង្កុញជើងក្រវៀនៗ ។

អង្គរាដេកលក់ដង្ហើមស្មើធេង តែយាយទៀងដេកមិនសូវលក់ទេ ។ គាត់នឹកឆ្ងល់ជាប់ជានិច្ច នូវព្រឹត្តិការណ៍នានានៃប្រទេសខ្មែរ ពីព្រោះសង្គ្រាមក្នុងប្រទេសខ្មែរដូចគេលេង «បាយឡុកបាយឡ» ។

គាត់រកនឹកឃើញឡើងវិញថា តើពីខែមេសា១៩៧៥ដល់មករា៧៩ តើអង្គការអនាមិកធ្វើអីខ្លះ ? គាត់ឃើញថា អង្គការគិតតែពីសម្លាប់បំផុតពូជខ្មែរ អង្គការធ្វើទារុណកម្មគ្រប់បែបគ្រប់យ៉ាង គិតយ៉ាងណាឲ្យតែខ្មែរស្លាប់ ។ លុះដល់ជិតចប់បេសកកម្មរបស់វា អង្គការបែរជាបញ្ជាឲ្យសម្លាប់ខ្មែរក្រហមនិន្នាការខ្មែរ ដែលជា

ឃាតករក្រុមទី១ ត្រូវស្លាប់តែហោងអស់ជាងពីរម៉ឺន (២០,០០០) នាក់ ។ ម៉្យាងទៀតអង្គការគិតតែពីបំផ្លាញ ដូច្នេះប្រទេសខ្មែរត្រូវវិនាសហិនហោច ក្នុងពេលដែលអង្គការមានជ័យជំនះ ហើយដែលយួនហាណូយវាកញ្ឆក់បានយ៉ាងងាយ គ្មានចំណាយអ្វីទាំងអស់ពីជ័យជំនះនេះ ។ គាត់នឹកឃើញដល់ខ្មែរយើងខ្លះដែលត្រឡប់ជាអរគុណយួន រហូតដល់ភ្លេចការពារទឹកដី សង្ឃឹមញញឹមឲ្យយួនហាណូយមកការពារជំនួស លុះត្រាតែវិនាសហិនហោច ទាំងប្រជាជន ទាំងទ្រព្យសម្បត្តិអស់រលីងពីនគរ ។ រវើរវាយមកដល់ត្រឹមហ្នឹង យាយទៀងស្រែកទ្រហោយំដូចមនុស្សឆ្កួត ។ តែអារម្មណ៍នៅតែចងចាំជានិច្ច គាត់តែងតែលើកដៃបន់ស្រន់វត្ថុស័ក្តិសិទ្ធិផងទាំងពួង ព្រមទាំងវិញ្ញាណក្ខន្ធខ្មែរទាំងបីលាននាក់ ដែលទទួលទារុណកម្មរហូតដល់បាត់បង់ជីវិត ឲ្យមកជួយណែនាំបំភ្លឺការស្រាវជ្រាវរបស់គាត់ ដើម្បីឲ្យបានដឹងច្បាស់ពីឧបាយកលរបស់យួនហាណូយ ដែលវាតទីយកទឹកដីប្រទេសជិតខាងបានដោយងាយៗយ៉ាងនេះ ? គាត់ចង់ដឹងដោយផ្ទាល់ថា តើយួនហានូយនឹងប្រើកលល្បិចយ៉ាងណាទៅទៀត ដើម្បីកាន់កាប់ត្រួតត្រាស្រុកខ្មែរឲ្យបានស្របច្បាប់មិនខុសច្បាប់អន្តរជាតិ ? ។

ឆ្នាំសិក្សា១៩៧៩-៨០ យាយទៀងនាំកូនស្រីអង្គរាទៅចុះឈ្មោះចូលរៀននៅវិទ្យាល័យស្វាយប៉ោ ។ គាត់រន្ធត់ចិត្តឥតឧបមាដោយឃើញសាស្ត្រាចារ្យ និងសិស្សអង្គុយសិក្សាផ្ទាល់ដី ។ សាស្ត្រាចារ្យពិតប្រាកដ ខ្លះដែលលាក់ខ្លួននៅរស់ ក៏ស្ម័គ្រចិត្តចូលមកជួយបង្រៀន ទោះមានប្រាក់ខែជាអង្ករកំប៉ុងអំបិលកំប៉ុងក៏ដោយ

នៅក្នុងកម្មវិធីសិក្សា គេឃើញមានការបញ្ចូលប្រវត្តិសាស្ត្រដ៏ចម្លែកៗ ដោយបង្ខំកូនសិស្សខ្មែរឲ្យដឹងគុណយួន ពីព្រោះយួនចូលមក «ជួយ» ខ្មែរអស់ចំនួន៣លើករួចមកហើយ ?!?! ។ យួនបញ្ចូលប្រវត្តិសាស្ត្រអាចារ្យមៀនឲ្យកូនខ្មែរទទួលស្គាល់ថាវិរៈបុរសខ្មែរទី១ ដែលបានធ្វើពលិកម្មរំដោះទឹកដីកម្ពុជាពីនឹមបារាំង ។ល។

កម្មវិធីប្រវត្តិសាស្ត្រខ្មែររបៀបនេះ វាផ្ទុយនឹងចំណេះដឹងរបស់សាស្ត្រាចារ្យ និងការពិតទាំងស្រុង ។ ដូច្នេះហើយសាស្ត្រាចារ្យដែលស្គាល់កលល្បិចយួនជាវៀតមិញក្តី ជាវៀតកុងក្តី មិនទទួលស្គាល់កម្មវិធីនេះទេ ។ សាស្ត្រាចារ្យខ្មែរដឹងច្បាស់ថាអាចារ្យមៀនជាយួនបន្លំបួសរៀននៅស្រុកខ្មែរជាចារបុរសឲ្យយួនហាណូយ ។ សាស្ត្រាចារ្យខ្មែរដឹងថា គឺបណ្តាមកពីអាចារ្យមៀននេះឯងហើយដែលធ្វើឲ្យខ្មែរបែកបាក់គ្នា ខ្មែរចេះច្បាំងគ្នារហូតដល់សព្វថ្ងៃ ។ ពេលនោះទើបសាស្ត្រាចារ្យខ្មែរទាំងអស់យល់ថា ក្រុមហេង-សំរិន, ហ៊ុន-សែន ជាខ្មែរអាយ៉ងចេញពីប្រភពខ្មែរវៀតមិញ ទើបយល់នូវកលល្បិចក្រឡិចក្រឡុចរបស់យួនហាណូយដែលចេះ

សំរបឬបន្ទាបខ្លួនតាមព្រឹត្តិការណ៍នានារបស់ប្រទេសខ្មែរ រួចទើបកែឆ្នៃបង្វែងជាន ម្តងបន្តិចៗ ញ៉ាំងឲ្យប្រទេសខ្មែររលាយទាំងពូជ រលាយទាំងប្រវត្តិសាស្ត្រ...

សាស្ត្រាចារ្យទាំងនោះអស់សង្ឃឹមក៏ខ្សឹបបបួលគ្នា ចាកចេញចោលប្រទេសខ្មែរជាហូរហែរ ភៀសខ្លួនទៅកាន់ប្រទេសថៃ ។

ចំណែកឯយួនហាណូយ កាលបើវាដឹងថា ខ្មែរអ្នកចេះដឹងរត់ចោលទឹកដីទុកឲ្យវាយ៉ាងនេះ វាត្រេកអរជាក្រៃលែង ។ វាតែងតែលៃលកយកចំណេញពីលើខ្មែរជានិច្ចជាកាល ។

យាយទៀងឆ្ងល់ណាស់ ដោយឃើញសាស្ត្រាចារ្យនិងកូនសិស្សខ្មែរអង្គុយរៀនផ្ទាល់ដី ។ ទីបំផុតទើបគាត់នឹកឃើញនូវពាក្យមួយឃ្លាដែលយួនហាណូយ ង្វៀង-វ៉ាន់ទិញបានពន្យល់ពួកគាត់កាលពីថ្ងៃ២៨-២-៨៤ ដែលឆ្លើយនឹងសំនួររបស់យួនអៀងថា ៖

« ពេលណាយើង (គឺយួន) បានកាន់កាប់នគរខ្មែរ ទ្រព្យសម្បត្តិនៅនគរខ្មែរទុកដូចជារបស់យើងទាំងអស់ » ។ ប៉ុន្តែចម្លើយរបស់តាទិញកាលណោះ និងកិច្ចការអនុវត្តន៍របស់យួនហាណូយក្នុងបច្ចុប្បន្ននេះ វាកែទម្រង់បន្តិច វាកែឆ្នៃបង្វែងជាន.. មើលចុះ ! ទ្រព្យសម្បត្តិក្នុងមួយនគរកម្ពុជា ត្រូវអង្គការគ្មានរូបគ្មានរាងប្រមូលដឹកនាំចេញអស់រលីង ទើបយួនហាណូយចូលមកលុកលុយរាតត្បាតប្រទេសកម្ពុជា ។

ដូច្នេះសត្រូវស្បូរពូជរបស់ខ្មែរ វាចេះប្រើកលល្បិចយ៉ាងខូចអស្ចារ្យ វាប្លន់ទ្រព្យសម្បត្តិរបស់ខ្មែរបានយ៉ាងស្អាត រកជានសឹងមិនឃើញ ។

❑ ❑

❑

ក្នុងខែវិច្ឆិកា១៩៧៩ ម៉ោងប្រហែល៣រសៀល មានបូដូយមួយក្រុមគ្នា១០ នាក់ បណ្តើរគ្នាចូលកាន់កូនខ្ទមរបស់យាយទៀង ។ នៅពេលនោះស្រាប់តែមានបូដូយស្គមម្នាក់ អាយុប្រហែល២៩ឆ្នាំលោតមកឱបយាយទៀង យំហ៊ីៗ ព្រមទាំងប្រាប់ថា « កុំឲ្យគាត់និយាយភាសាយួនឲ្យសោះ » ។ រួចហើយវាងាកទៅនិយាយប្រាប់មិត្តៗរបស់វាថា ៖

- ខ្ញុំមិននឹកស្មានថាមីងទៀងបែរជាធ្លាក់ខ្លួនក្ររហាមដល់ថ្នាក់នេះសោះ ព្រោះ

កាលពីដើមគាត់ធ្លាប់មានមុខងារនិងទ្រព្យសម្បត្តិដ៏ស្តុកស្តម្ភ ប្រកបដោយចិត្តសប្បុរស តែងតែជួយទុក្ខធុរៈអ្នកក្រខ្សត់ គាត់មិនចេះប្រកាន់ពូជសាសន៍ ។ គ្រួសាររបស់ខ្ញុំតែងតែសុំពឹងមីងទៀង ដូចជាសុំខ្ចីលុយធ្វើដើមទុន រកស៊ីលក់ត្រី និងសុំពឹងធ្វើលិខិតផ្សេងៗសំរាប់គ្រួសារ និងសំរាប់ខ្លួនរបស់ខ្ញុំផ្ទាល់ដើម្បីរៀនសូត្រ ។ យួននេះបន្តទៀតថា ៖

– កាលពីឆ្នាំ១៩៧០ ខ្ញុំអាយុបាន២០ឆ្នាំ រៀននៅថ្នាក់ទីបញ្ចប់នៃវិទ្យាល័យព្រះមុនីវង្ស ។ មានបាតុកម្មមួយដែលគេថាកូនសិស្សខ្មែរជាអ្នកបង្កើត ។ ពួកបាតុករវាយយួន ។ កាលណោះឪពុកខ្ញុំភ័យណាស់ ព្រោះគាត់ជាយួនហាណូយ និងជាចារបុរសរបស់វៀតមិញ ( កាលណោះយាយទៀងមិនបានដឹងទាល់តែសោះថាគ្រួសារយួននេះជាចារជនរបស់វៀតមិញឡើយ ) គាត់ក៏នាំគ្រួសាររត់មកជ្រកពួនក្នុងស្រះគោកមួយនៅខាងក្រោយផ្ទះមីងទៀងនេះ ។ ពួកយើងបានមីងទៀងចាត់ចែងផ្គត់ផ្គង់បាយទឹកម្ហូបចំណីយខាងគ្រប់គ្រាន់ ។ រួចពីហ្នឹងមកទៀត ឪពុកខ្ញុំសុំពឹងមីងទៀងជួយធ្វើអន្តរាគមន៍ជាមួយតំណាងយួននៅខេត្តបាត់ដំបង ដើម្បីសុំធ្វើមាតុភូមិនិវត្តន៍ទៅកាន់ប្រទេសវៀតណាមវិញ ។ ដោយសារការជួយខ្នះខ្នែងពីមីងទៀង គ្រួសាររបស់ខ្ញុំបានទៅរស់នៅខេត្តចូដុករហូតមក ។ ដូច្នេះខ្ញុំគោរពនិងស្រឡាញ់មីងទៀងដូចម្តាយខ្ញុំបង្កើត ។

កំពុងតែស្រឡាំងកាំងឆ្ងល់ថា ហេតុអីក៏យួនបូដូយនេះស្គាល់គាត់ច្បាស់ម្ល៉េះ, ហេតុម៉េចក៏វានិយាយខ្មែរច្បាស់ម្ល៉េះ ? វាក៏បែរមកសួរគាត់ថា ៖

– មីង ! តើមីងស្គាល់ខ្ញុំទេ ? ខ្ញុំឈ្មោះវិញ–គិមលៀង ជាកូនទីមួយរបស់វិញ–វ៉ាន់ឡាង និងយាយឡេ–ធីញ៉ាង ។

ពេលនោះវាក៏ហុចសំបុត្រមួយឲ្យយាយទៀង ព្រមទាំងនិយាយថា ៖

– នេះជាសំបុត្ររបស់ឪពុកម្តាយខ្ញុំដែលផ្ញើមកខ្ញុំពីចូដុកមក ។ យាយទៀងទទួលសំបុត្រមកអាន ៖

– តាឡាងសរសេរមកប្រាប់លៀង ចូរកូនខំស្រាវជ្រាវរកគ្រួសារយាយទៀងណា៎ ពីព្រោះមីងទៀងមានឧបការគុណដ៏ខ្ពង់ខ្ពស់បំផុតដល់គ្រួសារវិញ...

ពេលនោះយាយទៀងក៏លោតឱបលៀង រួចចាប់ផ្តើមសួរសុខទុក្ខទៅវិញទៅមកយ៉ាងច្រើន ។ គឺដោយសារការសន្ទនានេះ យាយទៀតអាចដឹងថា ពីឆ្នាំ១៩៧០ទៅ១៩៧១ អាណិកជនជាតិយួនធ្វើមាតុភូមិនិវត្តន៍ទៅស្រុកយួន មានចំនួនទាំងអស់មួយសែន (១០០,០០០) នាក់ ។ ឆ្លៀតឱកាសនោះ វៀតកុងសំរាំងជ្រើសរើសយុវជនយួន ចេះភាសានិងអក្សរខ្មែរយ៉ាងជ្រៅជ្រះច្បាស់លាស់ ដឹកនាំយកទៅកាន់ដែនដីរំដោះ រួចវាបញ្ចូលឲ្យចូលសាលាយោធា ។ ពេលនោះមានយុវជនអាណិក–

ជនយួនជាច្រើនពាន់នាក់ស្ម័គ្រចិត្តបំរើវៀតកុង ។ ព្រោះវៀតកុងសន្យាថា ពេលណាហាត់ហ្វឹកហ្វឺនចេះចប់ វាបំពាក់ឲ្យឡើងជាស័ក្តិមួយ ប៉ុន្តែត្រូវដាក់ឈ្មោះជាខ្មែរទាំងអស់ ។ វិញ-គីមលៀងក៏ត្រូវដូរឈ្មោះមកមិត្តឡចវិញ ។ បន្ទាប់ពីបានពាក់ស័ក្តិមួយហើយ យួនហាណូយក៏បញ្ជូនយុវជនយួនទាំងនោះ ឲ្យមកវាយខ្មែរលន់-នល់ ។ យុវជនទាំងនោះធ្វើដោយស្ម័គ្រចិត្ត ព្រោះវាត្រូវចំបំណុលសងសឹក ដែលកាលនៅជំនាន់រដ្ឋាភិបាលសាធារណរដ្ឋ លន់-នល់បានកេណ្ឌកូនសិស្សឲ្យធ្វើបាតុកម្មវាយអាណិកជនយួនដែលជាម៉ែឪវា ។ មិត្តឡចបញ្ជាក់ថា នៅចុងឆ្នាំ១៩៧៣ យួនហាណូយបញ្ជូនខ្មែរក្លែងក្លាយរបៀបនេះមានចំនួនបីពាន់នាក់ ចូលកាន់ខេត្តមណ្ឌលគីរី ស្ថិតនៅក្នុងព្រៃជ្រៅៗ រួចចាត់បញ្ជូនឲ្យធ្វើមេកាន់ក្តាប់យោធាខ្មែរក្រហមជាលំដាប់លំដោយ ។ បានសេចក្តីថាមកជំនួសបូដូយ កំទេចខ្មែរលន់-នល់តទៅទៀត ។ យាយទៀងនិយាយទៅកាន់លៀងថា ៖

– ខ្ញុំដឹងថា ក្នុងឆ្នាំ១៩៧៣ បូដូយសុំលាខ្មែរក្រហមវិលត្រឡប់ទៅវៀតណាមវិញហើយតើ ។

លៀងគ្រវីក្បាលហើយឆ្លើយឡើងថា ៖

– មីងអើយ ! នេះជាកលល្បិចរបស់វៀតកុងទេតើ ។ វាដឹងចំណុចខ្សោយរបស់ក្រុមខ្ញុំ ដុះចិត្តគំនិតសងសឹកចំពោះខ្មែរ ។ វាក៏បំពាក់ស័ក្តិមួយឲ្យ រួចញុះញង់បញ្ជោរក្រុមខ្ញុំធ្វើជាខ្មែរ ដើម្បីបំភ័ន្តមតិយោធាខ្មែរក្រហមល្ងង់ៗ រួចបញ្ជាឲ្យក្រុមខ្ញុំដឹកនាំយោធាខ្មែរក្រហមស្រឡាញ់សម្តេចឪកំទេចខ្មែរលន់-នល់ជំនួសវា ។ លៀងបន្តទៀតថា ៖

– មានបូដូយមួយភាគតូចគោរពវិន័យបានយ៉ាងត្រឹមត្រូវតាមលក្ខណៈ ទើបបានវិលត្រឡប់ទៅកាន់ប្រទេសវៀតណាម ។ ចំណែកបូដូយដែលមិនទាន់បានបំពេញករណិយកិច្ចតាមលក្ខ័ណ នៅមានចំនួន១៧០,០០០នាក់ទៀត ដែលសព្វថ្ងៃវាគ្រាន់តែថយទៅពួនលាក់ខ្លួន ដេកស៊ីសំរាកក្នុងព្រៃជ្រៅៗ ឬតាមបណ្តោយព្រំដែនខ្មែរ-យួន-លាវ ។ វាត្រៀមខ្លួនជានិច្ចនិងចេញបញ្ជា ។ លៀងបន្ត ៖

– រឿងមួយទៀតដែលជារឿងសម្ងាត់គឺមានផ្លូវសម្ងាត់មួយសំរាប់ចូលមកប្រ-ទេសខ្មែរបានយ៉ាងលឿនទាន់ចិត្តកាត់តាមប្រទេសលាវនិងប្រទេសថៃ តាមរូងភ្នំដងរែក ។ បើមានជនជាតិខ្មែរជាបូដូយ ស្គាល់មូលដ្ឋាននេះ ហើយមានអាយុ៣៦ឆ្នាំ វាសម្លាប់ចោលភ្លាម ដោយមិនធ្វេសប្រហែសឲ្យបែកការណ៍វាឡើយ ។ល។ លៀងបន្តទៅទៀតថា ៖

– ចំណែកក្រុមខ្ញុំក៏ត្រូវចាញ់បោកវៀតកុងយ៉ាងធ្ងន់ គឺត្រូវធ្វើជាខ្មែរ រួចដឹកនាំយោធាខ្មែរក្រហមបន្តសង្គ្រាមជំនួសវា ។ ឥឡូវពួកខ្ញុំត្រូវស្លាប់សឹងទាំងអស់ ទំរាំ

ដឹងខ្លួនថាចាញ់បោកវា ឃើតពេលណាស់ទៅហើយ ។ មីងមើលចុះ ស័ក្តិពាក់លើស្មាបានតែធ្ងន់ សព្វថ្ងៃស៊ីបាយរាល់ថ្ងៃចែកជាមួយតែផ្ទីរ ឬត្រកួនស្ងោរបង់អំបិល ។ វិន័យតឹងណាស់អើខ្លួនមិនរួច ។ សព្វថ្ងៃខ្ញុំកាន់ក្តាប់មូលដ្ឋានសម្ងាត់មួយនៅប៉ៃលិន មានតែស្វាជាមិត្ត ។ល។ និង ។ល។ ពេលនោះ លៀងឱបសុំលាយាយទៀងព្រមទាំងប្រាប់ថា ៖

- ខ្ញុំមានការច្រើនជំរាបមីង ស្អែកនេះខ្ញុំលួចមកជួបមីងតែម្នាក់ឯង...។

ពេលលៀងចេញផុតទៅ យាយទៀងអង្គុយញញឹមត្រេកអរជាក្រៃលែង ។ គាត់សង្ឃឹមថា គោលបំណងរបស់គាត់មុខជាមានពន្លឺខ្លះៗជាមិនខាន ។ ស្អែកឡើងពេលព្រលឹម គាត់រៀបចំបាយទឹកចាំទទួលលៀង ។ ម៉ោង១០លៀងមកដល់ល្មម ។ ពេលបាយទល់មុខគ្នានេះ លៀងអធិប្បាយវែកញែកនូវកលល្បិចយួនហាណូយ ដែលរៀបចំលេបទឹកដីកម្ពុជា មានលំនាំដូចគ្នានឹងអត្ថាធិប្បាយរបស់តាអាងដែរ ។ យាយទៀងក៏សួរទៅលៀងថា ៖

- តើអតីតខ្មែររៀតមិញមានច្រើនឬតិច ?

- មានចំនួនប្រហែល២ម៉ឺននាក់ ដែលមានមេដឹកនាំជាយួនលួចបន្លំធ្វើខ្មែរ ហើយទាំងអស់គ្នាប្រើឃីហោខ្មែរក្រហម ដូចមានក្រុមខ្ញុំជាឧទាហរណ៍ ។

- តើខ្មែរក្រហមទាំងនោះដឹងឬទេថា មានបូដូយយ៉ាងច្រើនត្រៀមខ្លួននៅពាសពេញព្រៃនៃប្រទេសខ្មែរ ? ។

- រឿងបូដូយសំណាក់នៅពាសពេញព្រៃនៃប្រទេសខ្មែរនោះ គឺជារឿងត្រូវរ៉ូវគ្នាទេតើ ! ពីព្រោះខ្មែរក្រហមនិន្នាការយួនធ្វើការតាមយួនទាំងអស់ លើកលែងតែខ្មែរក្រហមដែលស្រឡាញ់សម្តេចឪចំនួន៨ម៉ឺននាក់ចេញ ដែលអង្គការលាក់មិនឲ្យដឹងជាដាច់ខាត ។ គ្រប់ពេល ក្រុមអតីតខ្មែររៀតមិញ មានក្រុមខ្ញុំជាដើម ត្រូវទៅទទួលបញ្ជាការពីយួនហាណូយ គេនិយាយថាត្រូវទៅរៀនសូត្រនៅអង្គការលើ ។ ដូច្នេះយោធាខ្មែរក្រហមទាំងអស់នោះមិនដឹងថាចៅហ្វាយរបស់ខ្លួនជាខ្ញុំកញ្ជះយួនហាណូយឡើយ ។ រឿងនេះត្រូវលាក់ឲ្យជិត ឧទាហរណ៍ដូចជាខ្ញុំពេលនេះ ត្រូវកាន់ក្តាប់យោធា៣០០នាក់ គេឲ្យខ្ញុំផឹកទឹកសម្បថ ខ្ញុំត្រូវលាក់ការណ៍ឲ្យជិត ខ្ញុំត្រូវភរប្រាប់យោធាទាំងនោះថា ខ្ញុំជាខ្មែរឈ្មោះមិត្តឡុច ។

យាយទៀងសម្លឹងមុខលៀងមួយសន្ទុះ រួចក៏សួរថា ៖

- តើបក្សខ្មែរក្រហមរបស់ខៀវ-សំផន យ៉ាងម៉េចទៅវិញ ?

លៀងឈប់ទ្រឹងយ៉ាងយូររបៀបនឹកទើបឆ្លើយថា ៖

- ក្រុមនេះដូចជាគ្មានបញ្ចេញសកម្មភាពអ្វីសំខាន់ទេ ។ គេខ្សិបខ្សៀវរបៀបពេបជ្រាយថា ជាបក្សខ្មែរក្រហមបញ្ឆវ័ន្ត ។ ព្រោះមិត្តទាំងនោះភាគច្រើនជាអ្នកចេះ

ដឹងជ្រៅជ្រះ ។ អង្គការត្រូវតែលើកដំកើងបក្សខ្មែរក្រហមរបស់ខៀវ-សំផន ប-ញ្ជោរប្រើមួយរយៈសិន អង្គការលើកទឹកចិត្ត រួចញុះញង់ពីក្រោយខ្នង បញ្ជាយោធាខ្មែរក្រហមឲ្យមានកម្លាំងកំទេចខ្មែរលន់-នល់ ទុកពេលឲ្យយួនសំរាកសិន ។ ចំ-ណែកឯមេដឹកនាំខ្មែរក្រហមដែលជាបញ្ញវ័ន្ត មានការធ្វេសប្រហែសដោយឃើញមានយោធាស្រឡាញ់សម្ដេចឪទាំងបួនម៉ឺននាក់រៀបចំបានត្រឹមត្រូវ ស្វាហាប់ ក្លា-ហាន ក៏មានសេចក្ដីសង្ឃឹមថា ពេលណាខ្មែរក្រហមដណ្ដើមបានជ័យជំនះពីខ្មែរលន់-នល់ យោធាទាំងនោះអាចការពារប្រទេសជាតិបានយ៉ាងងាយ ។ លុះដល់ថ្ងៃ ១៧-៤-៧៥ ខ្មែរក្រហមទទួល «ជ័យជំនះ» ដ៏ធំធេង ស្រាប់តែមេបញ្ជាការជាអង្គការអនាមិកទៅវិញ ។ នៅពេលនោះ អង្គការចេញបញ្ជាជាដាច់ណាត់ ហាមដល់យោធាខ្មែរក្រហមទាំង៤ម៉ឺននាក់នោះ ព្រមទាំងក្រុមខ្ញុំជាយួនបន្លំធ្វើជាខ្មែរ មិនឲ្យជួបប្រជាជនថ្មីឡើយ ។ អង្គការប្រាប់ថា ត្រូវសំរាកយកកម្លាំងទៅវាយយួន ដើម្បី « រំដោះទឹកដីកម្ពុជាក្រោម » ។ លុះប្រមូលយោធាទុកមួយអន្លើ អង្គការបញ្ចេញឃាតករអាថ៌កំបាំងយ៉ាងច្រើនលើសលប់ មកព័ទ្ធបាញ់សម្លាប់បក្សខ្មែរក្រហម និន្នាការខ្មែរជាច្រើនលើកច្រើនសារ ឃើញតែខ្មោចដេកស្លាប់នៅពាសពេញ ព្រៃ ។ យាយទៀងសួរថា ៖

– តើបក្សខ្មែរក្រហមរបស់ខៀវ-សំផនគ្មានយោធាការពារទេឬ ?

– មិត្តទាំងនោះមានយោធាការពារតាមក្រុមៗដែរ ប៉ុន្តែអង្គការចាត់ការសម្លាប់យ៉ាងស្ទាត់បំផុត មិនបណ្ដោយឲ្យរេខ្លួនទាន់ឡើយ សូម្បីតែខ្ញុំក៏ខ្ញុំមិនដឹងហេតុផលទាល់តែសោះ ។ មានរឿងចម្លែកមួយដែលខ្ញុំបានឃើញផ្ទាល់ភ្នែកពីការកាប់សម្លាប់នេះ ៖ នៅចុងឆ្នាំ១៩៧៣ វៀតកុងកំពុងប្រើកលល្បិចសុំលាខ្មែរក្រហមថយចេញទៅសំរាក រួចឆ្លៀតសង្គ្រាមក្នុងប្រទេសខ្មែរឲ្យទៅជាសង្គ្រាមរវាងខ្មែរនិងខ្មែរ ។ នៅពេលនោះយួនហាណូយបញ្ជូនខ្មែរមួយក្រុមចំនួន៣ពាន់នាក់ មកពីហាណូយខ្លះមកពីប៉េកាំងខ្លះ មកបន្តសង្គ្រាមជំនួសវា ។ យួនហាណូយបញ្ជាឲ្យក្រុមខ្មែរទើបមកដល់នេះ ដឹកនាំយោធាខ្មែរក្រហមកំទេចខ្មែរលន់-នល់ ។ ក្រុមនេះតវ៉ាប្រឆាំងជាដាច់ខាតថា ៖ រឿងខ្មែរសុំទុកឲ្យខ្មែរដោះស្រាយ គឺខ្មែរសុំសំរុះសំរួលដោយការចរចា មិនត្រូវបង្ហូរឈាមរវាងខ្មែរនិងខ្មែរឡើយ ។

យួនហាណូយភ្ញាក់ដោយឃើញក្រុមនេះក្បាលរឹង មិនលោតតាមខ្សែញាក់របស់វា ហ៊ានប្រឆាំងនឹងបញ្ជារបស់វា វាត្រូវទាល់ច្រក ។ វាក៏ផ្លាស់ផែនការណ៍ភ្លាម ។ ព្រោះយួនហាណូយមានទីអាង គឺមានក្រុមប្ដីប្រពន្ធប៉ុល-ពតជាមេដឹកនាំ និងមានក្រុមខ្មែរជាច្រើនពាន់នាក់ជាជាតិយួនដែលចេះសរសេរ អាន ភាសាខ្មែរដូចខ្មែរ ក្រុមខ្ញុំអាចបន្លំធ្វើជាខ្មែរគ្មានយោធាណាអាចស្គាល់ថាក្រុមខ្ញុំជាយួនទេ ។ ចំណែកឯ

ខ្មែរដែលទើបនឹងមកពីប៉េកាំងនិងហាណូយនោះ និយាយភាសាខ្មែរពិបាកស្តាប់ ខ្ញុំស្តាប់សឹងមិនបាន ។ មូលហេតុនេះយួនហាណូយក៏ពិគ្រោះជាមួយប៉ុល-ពតផ្តាច់ ។ គ្រាប់តែប៉ុល-ពតចេញបញ្ជាឲ្យសូ-ភឹម ជាឃាតករដៃស្តាំរបស់វា ឲ្យដឹកនាំឃាតករអាថ៌កំបាំងមួយក្រុមដើរតាមព័ទ្ធបាញ់ក្រុមខ្មែរក្រហម ដែលមកពីប៉េកាំងនិងហាណូយនោះ សម្លាប់ចោលសឹងអស់រលីង ។ មីងដឹងទេ នៅកម្ពុជាកណ្តាលឆ្នាំ១៩៥៤ វៀតមិញនាំកូនខ្មែរទៅហាណូយចំនួន១ពាន់នាក់ ។ ឥឡូវនេះនៅសល់តែ៥៥នាក់តែប៉ុណ្ណោះ នៅធ្វើការក្នុងក្រុមបខ័ណ្ឌជាសមាជិកបក្សប្រជាជនបដិវត្តន៍ខ្មែរ ( គឺអតីតខ្មែរវៀតមិញ ) ។

ចំណែកសូ-ភឹម ក្រោយពីចាត់ការសម្លាប់ខ្មែរមកពីប៉េកាំងនិងហាណូយរួចហើយ ក៏ត្រូវអង្គការបញ្ជាឲ្យគេសម្លាប់ចោល ដើម្បីបំបាត់ភស្តុតាង ។ យាយទៀងស្តាប់មកដល់ត្រឹមហ្នឹង គាត់ថ្ងូរថា ៖

- ឱទេវតាអើយ ! យួនហាណូយសន្និដ្ឋានជីវិតរាស្ត្រខ្មែរដូចសត្វកណ្តុរកូនបៃសំរាប់សាកល្បងល្បិចកលរបស់វា ដើម្បីវាតទីលេបទឹកដីខ្មែរ ។ បើឃើញខ្មែរណាស៊ីជោរ ដូចជាហេង-សំរិន, ជា-ស៊ីម, ហ៊ុន-សែន ជាដើម... វាទុកប្រើសិន បើឃើញខ្មែរណាប្រើការលែងកើតហើយ វាសម្លាប់ចោលភ្លាម ។ ដូចជានៅក្នុងបច្ចុប្បន្នរបបរបស់ហេង-សំរិនអញ្ជឹង បើឃើញថាខ្មែរអាយ៉ងប្រើការលែងកើត ឬក៏ដើរផ្លូវខុសពីខ្សែញាក់របស់ចិត្តវា ខ្មែរតាំងនោះត្រូវបាត់ខ្លួនភ្លាម មានចៅហ្វាយខេត្តសៀមរាប និងចៅហ្វាយខេត្តបាត់ដំបង ឡាយ-សាម៉ុន ជាដើម ។

- អញ្ជឹងមែនហើយ មីង !

- ម៉េចបានជាក្មួយអាចមកដល់ទីក្រុងបាត់ដំបង ?

លៀងនិយាយបន្តឡើងថា ៖

- នៅក្នុងខែតុលាឆ្នាំ១៩៧៨, អង្គការបំបែកយោធាចេញពីខ្ញុំ ដើម្បីប្រមូលបញ្ជូនទៅ «វាយយួនរំដោះទឹកដីកម្ពុជាក្រោម» ។ ចំណែកខ្ញុំ អង្គការបំពាក់ស័ក្តិបី រួចបញ្ជូនខ្ញុំមកកាន់ខេត្តប៉ៃលិន ចាត់តែងតាំងខ្ញុំជាមេបញ្ជាការលើក្រុមយោធាខ្មែរក្រហម ស្ម័គ្រចិត្តកំទេចស័ក្តិភូមិនិងចក្រពត្តិវិញ ។ ក្នុងខែមករា១៩៧៩ ខ្ញុំក៏បានជួបយោធាទាំងនោះ ទើបខ្ញុំដឹងថាយោធាខ្មែរក្រហមដែលស្រឡាញ់សម្តេចឪ ដែលស្ម័គ្រចិត្តទៅ « រំដោះទឹកដីកម្ពុជាក្រោម » នោះ បែរជាដើរចូលអន្ទាក់ខ្សែត្រៀមរបស់បូជួយ ត្រូវបូជួយសម្លាប់ចោលខ្ទេចនៅចុងខែធ្នូឆ្នាំ១៩៧៨ ។ ស្តាប់មកដល់ត្រឹមហ្នឹង យាយទៀងសម្លឹងមុខលៀងមួយសន្ទុះទើបនិយាយថា ៖

- អញ្ជឹងក្មួយលៀងជាមេខ្មែរក្រហមទេតើ !

លៀងញញឹមអង្អែលខ្នងយាយទៀងហើយឆ្លើយថា ៖

- បាទមីង ! ខ្ញុំជាមេខ្មែរក្រហមមែន ។ ពីឆ្នាំ១៩៧៣ដល់១៩៧៨ ខ្ញុំជាមេយោធាខ្មែរក្រហមស្រឡាញ់សម្ដេចឪ ស្ម័គ្រចិត្តកំទេចខ្មែរលន់-នល់ ។ ឥឡូវនេះខ្ញុំជាមេកាន់ក្ដាប់យោធាខ្មែរក្រហមស្ម័គ្រចិត្តកំទេចសក្តិភូមិនិងចក្រពត្តិវិញនៅខេត្តប៉ៃលិន ក្រោមបញ្ជាការរបស់ល្មូត ដែលប្រែឈ្មោះពីប៉ុល-ពត ។ ខ្ញុំកើតជម្ងឺគ្រុនចាញ់ឈឺជិតស្លាប់ ទើបប្អូនជួយដឹកខ្ញុំមកដេកពេទ្យនៅបាត់ដំបងនេះ ។

យាយទៀងស្ដាប់ដល់ត្រឹមហ្នឹង គាត់មានការឈឺចាប់សឹងតាំងបេះដូង ហើយនឹកក្នុងចិត្តថា យួនហាណូយចេះប្រើកលល្បិចដោយបំបែកខ្មែរជាក្រុមៗ រួចញុះញង់ឲ្យហាក់លោតសម្លាប់តែជាតិរបស់ឯង ។

ពេលនោះយាយទៀងរកសួរសំនួរតទៅទៀតលែងឃើញ, លៀងអង្អែលខ្នងយាយទៀងព្រមទាំងនិយាយថា ៖

- ខ្ញុំគ្មានទុកចិត្តយួនហាណូយទេ, ខ្ញុំមកជួបមីងគឺចង់សួរដំណឹងពីផ្លូវ ដើម្បីរត់ទៅកាន់ប្រទេសថៃ ។

យាយទៀងស្ទាក់ស្ទើរមួយសន្ទុះ ទើបឆ្លើយយ៉ាងខ្លីថា ៖

- មីងគ្មានបំណងរត់ចោលស្រុកទេ ដូច្នេះមីងមិនស្គាល់ មិនដឹងទាល់តែសោះ

- សូមមីងទុកចិត្តខ្ញុំចុះ ពិតមែនតែខ្ញុំជាកូនយួន ប៉ុន្តែតាំងពីកើតមក ខ្ញុំរស់នៅតែជាមួយខ្មែរ រៀនសូត្រតែជាមួយគ្រូខ្មែរ ពួកម៉ាករបស់ខ្ញុំក៏ជាខ្មែរ ខ្ញុំស្គាល់ច្បាស់នូវសប្បុរសធម៌ សីលធម៌ សុភាពស្លូតបូត និងភាពស្និទ្ធស្នាលនៃបងប្អូនខ្មែរ ដូចមីងជាគំរូ ។ ខ្ញុំស្ដាយប្រទេសខ្មែររកស៊ីដោយសេរី ជាពិសេសដែនដីទូលំទូលាយ ។ នៅពេលខ្ញុំមិនទាន់ចាកចេញពីប្រទេសខ្មែរ ខ្ញុំមិនដឹងមិនស្គាល់តម្លៃនេះទេ ។ តែនៅពេលដែលខ្ញុំទៅដល់ប្រទេសយួន ទើបខ្ញុំភ្ញាក់ ព្រោះស្រុកយួន ៖

ទី១- ដែនដីសែនចង្អៀត

ទី២- ផ្នែកនយោបាយសែនក្រឡិចក្រឡុចបោកប្រាស់ ឆ្លៃប្រឌិតតែសង្គ្រាមដើម្បីវាតត្បាតប្រទេសជិតខាង ។ វាឆ្លៃប្រឌិតយុវជនយួនឲ្យបន្លំធ្វើជាខ្មែរ រួចរុញច្រានឲ្យចូលមកសម្លាប់បំផុតពូជខ្មែរ ។ ស្ដាយអើយសែនស្ដាយ ! ប៉ុន្តែយឺតពេលទៅហើយ ! ណ្ហើយចុះ ! ស្ម័គ្រចិត្តធ្វើជាខ្មែរ ដាក់ឈ្មោះខ្មែរបន្លំធ្វើជាមេយោធាខ្មែរក្រហមនឹងគេចុះ ដើម្បីឲ្យបានវិលត្រឡប់មកកាន់ប្រទេសខ្មែរវិញ ។ លុះចុះជាមេយោធារួចហើយ ខ្លួនខ្ញុំដូចជាត្រីដែលជាប់ដុច ពីព្រោះវិន័យតឹងតែងណាស់ រើខ្លួនមិនរួចទេ ។

ស័ក្តិពាក់លើស្មាគ្រាន់តែឲ្យធ្ងន់ទេ ។ ក្នុងរយៈពេលចំនួន៧ឆ្នាំ ខ្ញុំញ៉ាំបាយរួមវាល់ចែកជាមួយតែផ្ទីរ ឬត្រកួនស្ងោរបង់អំបិល នៅក្នុងព្រៃ មិនបានដឹងថា ទ្រព្យសម្បត្តិក្នុងប្រទេសខ្មែរត្រូវវិនាសហិនហោចដល់ថ្នាក់ហ្នឹងទេ ។ គឺនៅពេលដែល

ខ្ញុំឈឺគ្រុនចាញ់ជិតស្លាប់ ទើបបងប្អូនដឹកមកដេកព្យាបាលនៅមន្ទីរពេទ្យធំបាត់ដំបង ។ លុះបានជាគ្រាន់បើ ខ្ញុំក៏ដើរមើលទីក្រុងបាត់ដំបង ។ ខ្ញុំភ្ញាក់ស្លុតចិត្តម្តងទៀត ដោយឃើញបាត់ដំបងបានក្លាយទៅជា «ទីក្រុងខ្មោច» ទៅហើយ ។ ដូច្នេះខ្ញុំសំរេចចិត្តដើររកមីង ។ ពេលមកជួបនឹងឃើញស្ថានភាពរស់នៅរបស់មីង ខ្ញុំរន្ធត់ស្លុតចិត្តដ៏អស្ចារ្យ សឹងមិនជឿភ្នែកដែលបានឃើញ ! មិនគួរមីងធ្លាក់ខ្លួនក្ររហាមដល់ថ្នាក់ហ្នឹងសោះ ! មិនគួរព្រាត់ប្រាស់គ្រួសារអស់រលីងមិនទំនងយ៉ាងហ្នឹងទេ ! ដូច្នេះសូមមីងសំរេចចិត្តភៀសខ្លួនទៅកាន់ប្រទេសថៃជាមួយខ្ញុំទៅ ។

ពេលនោះយាយទៀងមិនឆ្លើយនឹងសំណើររបស់លៀងថា យ៉ាងម៉េចទេ ។ គាត់បែរជាសួរលៀងថា ៖

- ហេតុម៉េចពីម្សិលមិញហាមមីងមិនឲ្យនិយាយភាសាយួន ?

- រឿងនេះអាថ៌កំបាំងណាស់ ខ្ញុំខ្លាចបងប្អូនដែលមកជាមួយខ្ញុំសង្ស័យថាមីងជាយួន ព្រោះមានច្បាប់ជាសម្ងាត់បំផុតថា ៖ « ត្រូវតែសម្លាប់អាណិកជនយួន ដែលគេចមិនព្រមទៅតាមរៀតក្នុងពីឆ្នាំ១៩៧៥ចោលទាំងអស់ » ។

យាយទៀងស្រមៃនឹកឃើញគួរឲ្យភ័យញ្ញាក់សាច់... យីអើ ! ហេតុអីបានជាទៅប្រាប់បងប្អូនមុនៗ ថាខ្លួនឯងជាយួនអញ្ចឹង ?

យាយទៀងសួរលៀងទៀតថា ៖

- នរណាដឹកនាំខ្មែរក្រហមនិរតី ?

- គឺយួនជាមេដឹកនាំ ។ ក្រុមនេះចេញមកពីប្រភពកងកម្លាំងប្រដាប់អាវុធបដិវត្តន៍ឯកភាពរបស់កម្ពុជា ដែលហូ-ជីមិញបញ្ជាឲ្យង្វៀង-យ៉ាំងម៉ៀងបង្កើតនៅថ្ងៃទី១៩-៦-១៩៥១ រួចចាត់តែងតាំងទូ-សាមុតជាមេបញ្ជាការ ។ នៅឆ្នាំ១៩៦៣ ទូ-សាមុតត្រូវគេសម្លាប់ ហូ-ជីមិញបញ្ជាឲ្យផាម-វ៉ាន់បាចាត់តែងតាំងប៉ុល-ពតយ៉ាងស្ងាត់ ឡើងជំនួសជាមេបញ្ជាការវិញ ។ ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ កងកម្លាំងនេះរួបរួមកម្លាំងជាមួយបងប្អូន វាយកំទេចខ្មែរលន់-នល់ ប្រែឈ្មោះជាកងកម្លាំងប្រដាប់អាវុធបដិវត្តន៍ស្នេហាជាតិកម្ពុជា ដែលមានប៊ូ-ថងជាមេបញ្ជាការ ។ លៀងបញ្ជាក់ថា ក្នុងរយៈ៣ឆ្នាំ អង្គការញ្ញាក់តែខ្សែខ្មែរក្រហមដែលជាអតីតចោរ លោតសម្លាប់ខ្មែរវក់វីនាំឲ្យអ្នកដែលសេសសល់នៅរស់បាក់ស្បាតឈប់ហ៊ានកំរើក ។ នៅចុងឆ្នាំ១៩៧៧ ទើបអង្គការបញ្ជូនកងកម្លាំងប្រដាប់អាវុធបដិវត្តន៍ឯកភាពរបស់កម្ពុជាឲ្យចេញមកលុកលុយប្រទេសខ្មែរវិញ ដោយដាក់ឈ្មោះថាជាក្រុមខ្មែរក្រហមនិរតី ។

❑ ❑

❑

# តើក្រុមខ្មែរក្រហមនិរតីត្រូវធ្វើអ្វីខ្លះ ?

ភារកិច្ចក្រុមនេះគឺត្រូវសម្លាប់ខ្មែរក្រហម ដែលកើតមកពីចោរដែលអង្គការចាត់តែងតាំងជាឈ្លបនិងគណាកម្មការកង ។ ក្រុមនេះមានភារកិច្ចជាពិសេសម៉្យាងទៀត គឺត្រូវដាក់ថ្នាំបំពុលក្នុង « នំបញ្ចុកទឹកសម្លខ្មែរ » ដើម្បីសម្លាប់បំផុតពូជខ្មែរជាចុងបង្ហើយ ។

តែជាថៃដន្យ វាយកការណ៍ដឹងថា លោកសឺន-សានកំពុងទាក់ទងប្រទេសអង់គ្លេសនិងថៃ ដើម្បីរៀបចំបង្កើតរណៈសិរ្សមួយឈ្មោះរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ( រ.ជ.រ.ប.ខ ) ។

យួនហាណូយដឹងថា បើរណៈសិរ្សនេះកើតឡើងបានជាស្ថាពរ កងទ័ពនឹងអាចរំដោះទឹកដីកម្ពុជាបានយ៉ាងងាយ ។ ហេតុនេះយួនហាណូយក៏ផ្លាស់ផែនការភ្លាម ដោយបំបាត់ឈ្មោះអង្គការ ហើយបញ្ចេញបូដូយស្ម័គ្រចិត្តពីព្រៃឲ្យទាន់ពេលវេលារួចស្រែកក្អេងក្អាងថា បូដូយស្ម័គ្រចិត្តបូជាសាច់ឈាមមកកំចាត់ខ្មែរក្រហមដើម្បីជួយខ្មែរ ។

ដើម្បីបំភ័ន្តមតិពិភពលោក, មតិអន្តរជាតិនិងមតិរាស្ត្រខ្មែរទូទៅ យួនហាណូយក៏បញ្ជូនប៉ុល-ពត ដែលជាចារកិច្ចពិសេសរបស់វា ឲ្យទៅសំរាកនៅប៉ៃកាំងធ្វើជាអ្នកចាញ់ធ្វើព្រងើយ ។ វាលើកបន្តុបក្រុមហេង-សំរិន, ហ៊ុន-សែន, ជា-ស៊ីមធ្វើជាអ្នកឈ្នះ ។ ការពិតប៉ុល-ពតក្តី, ក្រុមហេង-សំរិនក្តី ជាអាយ៉ងហាណូយដូចតែគ្នា ។

មើលចុះ ! តាំងពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៨ ទាំងអស់គ្នានេះរួមដៃជាមួយបូដូយសម្លាប់ខ្មែរជាម្ចាស់ទឹកដីកម្ពុជាពិតៗដ៏ស្លូតត្រង់វីរក់ ។ កាលណោះហេង-សំរិនមានងារជាវរៈសេនិយឯកដឹកនាំកងពលធំលេខ៦នៅភូមិភាគបូព៌ា ។

លុះបានស្តាប់ពាក្យពេចន៍របស់ហ៊្វិញ-គិមលៀងដែលជាកូនហ៊្វិញ-វ៉ាន់ឡាំងចារជនរបស់យួនហាណូយប្រចាំខេត្តបាត់ដំបងចប់សព្វគ្រប់មក ទើបយាយទៀងសន្និដ្ឋានថា បុរសនេះត្រូវយួនហាណូយបង្ខំឲ្យបន្លំខ្លួនជាខ្មែរដាក់ឈ្មោះថា មិត្តឡូច ពាក់ស័ក្តិ៣ ជាមេកាន់ក្តាប់យោធាខ្មែរក្រហមនិន្នាការយួន ។ គាត់ឈប់សង្ស័យហើយក៏យល់ថា ៖ យួនហាណូយជាអង្គការអនាមិកយ៉ាងពិតប្រាកដ ។

ពេលនោះយាយទៀងមានការឈឺចាប់យ៉ាងក្រៃលែង គាត់ស្រក់ទឹកភ្នែកច្រោកៗ នឹកស្តាយប្តី ប្អូនៗ ក្មួយៗ កូនៗ និងបងប្អូនរួមជាតិខ្មែរដែលត្រូវអង្គការសម្លា

ប់ចោលអស់ចំនួន៣លាននាក់ គ្មានបានតដៃជាមួយខ្មាំងទាល់តែសោះ ។ ស្តាយណាស់ ! បើដឹងថាយួនហាណូយជាមេឃាតករ ម្ល៉េះខ្មែរយើងមិននៅស្ងៀមឱបដៃយ៉ាងដូច្នេះទេ ! ។ កាលណោះរាស្ត្រខ្មែរភាគច្រើនយល់ច្រឡំស្មានៗថាខ្មែរ សីហនុច្បាំងជាមួយខ្មែរលន់-នល់ ទើបបបួលគ្នាដាក់អាវុធចុះ ដោយមិនចង់បង្ហូរឈាមរវាងខ្មែរនិងខ្មែរជាបងប្អូន...

ហ៊ិញ-គីមលៀង បែរមកសំពះសុំលាមីងទៀងទៅវិញ ។

❑ ❑

❑

## តើអ្នកណាត្រូវទទួលកំហុសនៅចំពោះមុខវិបត្តិនេះ ?

ជីវិតកូនខ្មែររាប់លាននាក់ត្រូវរងគ្រោះស្លាប់នៅក្រោមទារុណកម្មរបស់អង្គការដោយមិនទាន់ដឹងខ្លួនផងថា មានកំហុសអីនៅឡើយទេ ។

អ្នកដឹកនាំខ្មែរទាំងអស់ដែលបានចាញ់បោកចិននិងយួនហាណូយ ដែលបណ្តោយឲ្យខ្មែររវល់តែយល់ច្រឡំមិនចេះចប់មិនចេះហើយ រហូតដល់អស់ជីវិតរាប់លាននាក់នេះ ត្រូវទទួលកំហុសទាំងស្រុង ។ ព្រោះពួកខ្លួនបានបណ្តោយស្ថានការណ៍ឲ្យធ្លាក់ដុនដាបមកដល់ថ្នាក់ហ្នឹង ។ គឺពួកអស់លោកត្រូវហ៊ានទទួលសារភាព ហើយរកមធ្យោបាយដោះស្រាយចំណាងដ៏តឹងនេះ ដើម្បីរំដោះប្រទេសកម្ពុជាពីកណ្តាប់ដៃយួនមកវិញ ។ បើមិនដូច្នោះទេ ប្រវត្តិសាស្ត្រនឹងចារទុកថា គឺអស់លោកទាំងនេះហើយ ដែលដឹកនាំប្រទេសឲ្យធ្លាក់ដល់រណ្តៅមរណៈ ក្រោមចង្កូមមច្ចុរាជរបស់យួនហាណូយនិងបរិវាររបស់វា គឺខ្មែរអាយ៉ង ។

ពេលនោះយាយទៀងអង្គុយឆ្ងឹងលែងដឹងខ្លួន ដោយមកពីការឈឺចុកចាប់ ។ គឺមកពីការឈឺចុកចាប់នេះហើយ ដែលជំរុញយាយទៀងឲ្យខំស្រាវជ្រាវ ចងក្រងកំម្រងឯកសារនេះ ។

នៅដើមខែធ្នូឆ្នាំ១៩៧៩ លៀងមកជួបយាយទៀងម្តងទៀត ។ តាំងពីរនាក់ឈរមុខកូនខ្ទម។ លៀងនិយាយខ្សឹបៗថា ៖

- បើមីងមិនភៀសខ្លួនទៅកាន់ប្រទេសថៃទេ ខ្ញុំចង់ជូនមីងទៅនៅជាមួយម្តាយរបស់ខ្ញុំឯចូដុក ព្រោះនៅប្រទេសខ្មែរសង្គ្រាមនឹងផ្ទុះលើងរ៉ាំរ៉ៃគ្មានទីបញ្ចប់ទេ ។ យាយទៀងសួរលៀងថា ៖

- តើសង្គ្រាមផ្ទុះឡើងរវាងនរណានិងនរណា ? ។

លៀងចាប់ដៃមីងទៀងកាន់ព្រមទាំងរែកញែកថា ៖

- តាមដែលខ្ញុំបានដឹង យួនហាណូយបង្កើតជាស្រេចនូវគូបដិបក្សក្នុងស្រុកក្នុងទីក្រុង ក្នុងទីប្រជុំជន ។ វាដុតដៃដុតជើង បង្កើត «ក្រុមកុមារឈានមុខ» ដែលមានមុខនាទីត្រូវតែកំទេចខ្មែរក្រហមនៅក្នុងដំណាក់ការជាដំបូង ។

- ចំណែកនៅក្នុងព្រៃឯណោះ ពួកយោធាខ្មែរក្រហមនិន្នាការយួន ក៏តាំងមូលដ្ឋាននៅកន្លែងចាស់ឡើងវិញ ។ ដំណាក់ការជាដំបូងរបស់វានេះគឺ ត្រូវកំទេចសក្តិភូមិនិចក្រពត្តិ ក្រោមបញ្ជាការរបស់ឈ្មោះល្មុត ដែលជាឈ្មោះបន្លំពីឈ្មោះប៉ុល-ពត បន្លំពីសាឡុត-សរ ទាំងសាច់ទាំងឈាម ។

- ចំណែកក្រៅប្រទេសឯណោះ លោកសឺន-សានកំពុងបង្កើតរណសិរ្សរជរបខ ។ ស្តាប់ដល់ត្រឹមហ្នឹង យាយទៀងមានទឹកមុខស្លួត គាត់ឆ្លើយយ៉ាងខ្លីថា ៖

- ខ្ញុំត្រូវតែនៅក្នុងស្រុកសិន រង់ចាំដំណឹងកូនប្រុសពនាក់ទៀត ។ លៀងក៏សំពះមីងទៀងទៅវិញ...។ នៅចុងខែធ្នូ១៩៧៩ ម៉ោងប្រហែលជា៥ល្ងាច លៀងមកជួបមីងទៀងជាចុងក្រោយបង្អស់ សំពះសុំលាមីងទៀងភៀសខ្លួនទៅកាន់ប្រទេសថៃ ។ មុននឹងបែកគ្នានេះ លៀងឱបមីងទៀងយំព្រមទាំងផ្តាំថា ៖

- មីង ! សុំកុំចូលធ្វើការបំរើយួនឲ្យសោះណា ! ព្រោះវាកំពុងស៊ើបរកអ្នកណាដែលជាអតីតអ្នករដ្ឋការដូចជាមីងអញ្ចឹង ។ ម៉្យាងទៀតវាប្រមូលក្រុមខ្មែរក្រហមនិរតី នាំយកមកបំពាក់អាវុធឲ្យឡើងវិញទៀត ចាត់តែងតាំងជាឈ្លបពាសពេញប្រទេសខ្មែរដដែល ។ ដូច្នេះសូមមីងប្រយ័ត្ន ។ បើឃើញថានឹងមានគ្រោះថ្នាក់ សូមមីងរត់ភៀសខ្លួនជាប្រញាប់...។

លៀងផ្តាំមីងទៀងសព្វគ្រប់ហើយក៏យំឱសសំពះសុំលាជាចុងក្រោយបង្អស់ រួចក៏បណ្តើរពួកម៉ាកពីរនាក់ជាបូដូយយួនខាងត្បូង ក្នុងគោលបំណងភៀសខ្លួនទៅកាន់ព្រំប្រទល់នៃប្រទេសថៃ ។

កន្លងផុតមកជាងកន្លះខែ យាយទៀងបានទទួលដំណឹងដ៏អកុសលថា លៀងនិងមិត្តពីរនាក់នោះ ត្រូវបូដូយតាមដានទាន់នៅកណ្តាលវាល ពីស្រុកស៊ីសូផុនទៅកាន់ភូមិនិម្មិត រួចបូដូយបាញ់សម្លាប់ចោលទៅហើយ ។

លៀងស្លាប់បាត់ទៅមែន ប៉ុន្តែពាក្យសំដីរបស់លៀងនៅឮរងំក្នុងត្រចៀក របស់យាយទៀងជាប់ជានិច្ច ហើយដែលគាត់យល់ថាត្រូវតែជំរាបបងប្អូនខ្មែរទាំងអ-

ស់និងមតិសកលលោកឲ្យបានដឹងពីរឿងនេះ ឯការជឿឬមិនជឿនោះវាស្រេចនៅលើការវិនិច្ឆ័យរបស់អ្នកអានទៅចុះ ។

❑ ❑

❑

# យួនហាណូយប្រើស្មៀតវាយទឹកកំចាយត្រី

ព្រលឹមថ្ងៃទី៩មករា១៩៨០ យាយទៀងក្រោកលួនចេញពីបន្ទប់បង្កន់ ។ ពុទ្ធោអើយ ! ស្រាប់តែឃើញបងប្អូនខ្មែរដែលសំណាក់នៅក្បែរៗគាត់ កំពុងតែប្រមូលគ្គីគ្គា ចាកចេញចោលទឹកដីទៅកាន់ប្រទេសថៃ ។ យាយទៀងឈរទ្រឹងភ្លឹក ខ្លួនស្រាលដូចសំឡី មើលក្បួនមនុស្សដែលដើរកាត់ខ្នមរបស់គាត់ ដូចគេហែរកឋិន។ ពេលនោះឮសម្លេងហៅយ៉ាងស្រាលពីក្រោយខ្នង ៖

– មីង !

គឺលោកសាស្ត្រាចារ្យគឹម-នឿង ជាក្មួយមកបបួលមីងទៀងរត់ចាកចេញចោ-លកម្ពុជា ។ លោកនឿងប្រាប់មីងទៀងថា ៖

– យប់មិញមានចោរជាច្រើនក្រុម អាវុធគ្រប់ដៃដើរប្លន់ ។ វាចាប់ចងអ្នករងគ្រោះ រួចវាអារកបន្តិចម្តងៗ កំញើញរកមាសពេជ្រ ។ មានឲ្យក៏វាសម្លាប់ គ្មានឲ្យក៏វាសម្លាប់ ។ ហើយទំរាំនឹងស្លាប់ គឺស្លាប់យ៉ាងសែបវេទនាជាទីបំផុត ។ ស្រីៗខ្មែរទោះមិនទាន់គ្រប់ការក៏ដោយ ក៏វាចាប់អូសនាំយកទៅរំលោភ រួចវាសម្លាប់ចោលភ្លាម ។

នៅពេលដែលជនរងគ្រោះរត់ទៅប្តឹង ក្រសួងសន្តិសុខធ្វើសោះអង្គើយគ្មានអើពើឡើយ ។

ឥឡូវបងប្អូនខ្មែរអស់សង្ឃឹមគ្មានទីពឹង ព្រោះនគរកម្ពុជាជានគររបស់ចោរទៅហើយ ។ អ្នកទាំងអស់ក៏បបួលគ្នារត់ចេញចោលស្រុក ។ ពេលនោះយាយទៀងស្ងួតបំពង់ក មិនអាចឆ្លើយថាទៅឬក៏ទេបានឡើយ ។ ទាំងពីរនាក់មីងក្មួយ ឈរសម្លឹងមុខគ្នាយ៉ាងយូរ ទើបលោកនឿងឱបម្តាយមីងទាំងទឹកភ្នែករលីងរលោងរួចសំពះសុំលាចេញទៅ...។ មីងនិងក្មួយក៏បែកគ្នាចាប់តាំងពីពេលនោះរហូតមក ។

❑

ក្នុងខែកុម្ភៈឆ្នាំ១៩៨០ មានស័ក្តិ៣វៀតកុងម្នាក់ឈ្មោះលីក ដើរយ៉ាងលឿនចូលមកជួបមីងទៀង សុំគាត់ជួយរកហោរទាយ ។ យាយទៀងក៏នាំគាត់ទៅជួបយាយហោរម្នាក់ ហើយចាំជួយបកប្រែភាសាយួន-ខ្មែរ ។ ពេលនោះ លីកសួរយាយហោរថា តើនៅឆ្នាំទី១០វាអាចជាប់លេខបានវិលត្រឡប់ទៅហាណូយវិញឬទេ ? ។

លីករ៉ាយរ៉ាប់ថា វារៀបការប្រពន្ធតាំងពីចុងឆ្នាំ១៩៦៩, វាការរួចតែបួនខែ ក៏ត្រូវបែកគ្នារហូត ព្រោះវាត្រូវបំពេញករនិយកិច្ចមកកាន់ប្រទេសខ្មែរ ជាមេកាន់ក្តាប់បូដូយក្នុងឆ្នាំ១៩៧០ ។

ពេលនោះយាយហោរអង្គុយស្ញឹងស្ងាធ មើលវាសនាលីក ។ គាត់មើលឃើញអំពីអតីតកាលរបស់លីកយ៉ាងច្រើន ។ គាត់និយាយត្រូវសព្វប្រាប់លីក ។ លីកទទួលថាត្រូវទាំងអស់ ។ យាយហោរអង្គុយស្ញឹងស្ងាធម្តងទៀតយ៉ាងយូរ មើលអនាគតឲ្យលីក ។ រួចគាត់ប្រាប់ថា ៖ លីកមានគ្រោះថ្នាក់បន្តិច ដូច្នេះត្រូវធ្វើពិធីស្រោចទឹកបណ្តេញគ្រោះ ។ យាយហោរនិយាយបន្តថា ចំពោះពិធីស្រោចទឹកនេះ ត្រូវមាន «ទំនាប់» ដូចតទៅនេះ ៖

- សំពត់ទេសឯកសប្រវែង៥ម៉ែត្រ
- ផ្កាឈូកប្រាំ
- ទៀនប្រាំ
- ធូបប្រាំ
- ចេកណាំវ៉ា១ស្និត

ពេលនោះ លីកធ្វើមុខស្ងួតគ្រវីក្បាលថ្ងូរថា តើបានពីណាទៅរបស់ទាំងនេះ ? យាយហោរជាជាតិខ្មែរ មិនដែលស្គាល់របបរបស់យួនហាណូយ ដែលក្រហាមយ៉ាងនោះក៏ឆ្លើយភ្លាមថា មិនខ្វះទេនៅក្នុងផ្សារមានលក់សំបូរហូរហៀរ...។ ស័ក្តិ៣លីកឆ្លើយដោយអស់សង្ឃឹមថា ខ្ញុំគ្មានថ្វីទាល់តែសោះដើម្បីនឹងដូរវត្ថុទាំងនោះ ។

ពេលនោះយាយទៀងជួយចេកណាំវ៉ាមួយស្និត ។ ចំណែកយាយហោរគាត់ជួយរៀបចំឲ្យទាំងអស់ ។ មើលចុះ ! គួរឲ្យអាណិតដល់វាស្ត្រខ្មែរណាស់ មានធម៌សប្បុរសជានិច្ច ទោះដឹងថាមេបូដូយនេះចូលមកលុកលុយរាតត្បាតប្រទេសរបស់ខ្លួនក៏ដោយ ។

នៅដើមខែមិនាឆ្នាំ១៩៨០ លីកដើរយ៉ាងលឿនមកកាន់ខ្ទមយាយទៀង ដើម្បីនិយាយថ្លែងអំណរគុណ ព្រមទាំងសុំលាគាត់និងយាយហោរទៅកាន់ប្រទេសវៀតណាមវិញ...

ពិធីស្រោចទឹកឲ្យមេបូដូយមានប្រសិទ្ធិភាពមែន ព្រោះនៅពេលក្រោយមកចំ

ំនួនតែ៦ថ្ងៃ លីកក៏បានឡើងបុណ្យពាក់ស័ក្តិបួន និងបានជាប់លេខឆ្នាំទី១០ ដើម្បីបានវិលត្រឡប់ទៅកាន់ហាណូយវិញ ។

នៅមុនពេលបែកគ្នា យាយទៀងក៏រៀបបាយទឹកនំចំណីជូនមេបូដូយពិសារមួយពេល ដើម្បីឆ្លៀតសួរបញ្ជាក់ស្រាវជ្រាវរករឿងពិតខ្លះពីមេបូដូយជាយួនហាណូយដោយផ្ទាល់មាត់ ។ ពេលបាយទល់មុខគ្នា យាយទៀងសួរលីកថា ៖

- តើបូដូយម្នាក់ៗត្រូវមកជួយខ្មែរប៉ុន្មានឆ្នាំ ?

លីកញញឹមព្រមទាំងឆ្លើយរ៉ាយរ៉ាប់ដូចបូដូយមុនៗអញ្ចឹងដែរ ។ លីកបញ្ជាក់ថា វាមកកាន់ប្រទេសខ្មែរតាំងពីខែមិនា១៩៧០ ទើបនឹងបានជាប់លេខឆ្នាំទី១០ ដើម្បីវិលទៅកាន់ហាណូយនៅក្នុងខែមិនាឆ្នាំ១៩៨០នេះ ។ បើឆ្នាំទី១០ធ្លាក់លេខម្តងទៀត លីកត្រូវនៅក្នុងប្រទេសកម្ពុជារហូត...។

យាយទៀងឈ្លាតសួរបញ្ហាខ្លះៗ ដែលហ្វិញ-គិមលៀងបានប្រាប់គាត់រួចហើយ ។ ស័ក្តិ៨លីកក៏ឆ្លើយប្រាប់គាត់ដូចលៀងនិយាយអញ្ចឹងដែរ ។ យាយទៀងសុំទោសលីក ហើយសួរពីបញ្ហាមួយទៀត ៖

- ខ្ញុំចង់ដឹងអំពីវត្តមានបងប្អូនខ្មែរ ដែលវៀតមិញបញ្ជូនឲ្យទៅរៀននៅប៉េកាំងនិងនៅហាណូយ ចាប់តាំងពីឆ្នាំ១៩៥៤ ហើយដែលនៅមានបញ្ជូនបន្តៗទៅក្រោយៗទៀត ។ ឥឡូវខ្ញុំទទួលពត៌មានថាមានបញ្ជូនវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញហើយ តើសព្វថ្ងៃនៅឯណា ? ព្រោះខ្ញុំមានប្អូនប្រុសម្នាក់ឈ្មោះ ចៅ-ង៉ុកអាញ់នៅជាមួយនឹងគេដែរ ។ លីកសម្លឹងមុខយាយទៀងយ៉ាងមុត ទើបឆ្លើយរបៀបរដិបរដុបថា ៖

- មិត្តទាំងបីពាន់នាក់នោះ ត្រូវបានគេបញ្ជូនត្រឡប់មកកាន់ប្រទេសកម្ពុជាតាំងពីចុងឆ្នាំ១៩៧៣ម្ល៉េះ ។ ប៉ុន្តែអ្នកទាំងនោះជាមនុស្សចាស់គំរិលហួសសម័យប្រើការលែងកើតហើយ...។

ឥឡូវអង្គការលើចេញបញ្ជាឲ្យបូដូយដើរប្រមូលកុមារកំព្រាជាតិខ្មែរ រួចបញ្ជូនទៅ.... នៅ... ហា... ណូយ... ។ លីកនិយាយរបៀបស្ងាក់ស្ទើរដែលបង្ហាញឲ្យដឹងថា នេះជាអាថ៌កំបាំងពិតប្រាកដណាស់ ។ ពេលនោះយាយទៀងខឹងណាស់ គាត់លួចថាតែក្នុងចិត្តថា ៖

- អាកំភរ, ការពិតពួកអាអែងចាត់ការបាញ់សម្លាប់គេចោលអស់ទៅហើយ ។ កំពុងតែរកលេសបង្វែងដាន ចៃដន្យវាក្រឡេកឃើញកូនស្រីពៅរបស់យាយទៀងទើបនឹងមកពីសាលារៀន វាក៏បែរជាសួរយាយទៀងថា ៖ ម៉ែ ! មិត្តនេះទើបនឹងមកពីសាលារៀនឬ ?

- ចាស៎ !

លឺកបានលេសនេះក៏ព្រោកប្រាជ្ញតទៅទៀត ៖

- ម៉ែ ! ម៉ែដឹងទេថាបូដូយកំពុងតែដើរប្រមូលកុមារកំព្រាជាតិខ្មែរ ដើម្បីបញ្ជូនទៅរៀននៅហាណូយ ? ក្រុមកុមារកំព្រាទាំងនោះវាឲ្យឈ្មោះថា « ក្រុមកុមារសងឈាម » ។

- ហេតុម្ដេចក៏បញ្ជូនទៅរៀនដល់ហាណូយ ?

- គេត្រូវតែបញ្ជូនឲ្យឆ្ងាយបំផុត ដើម្បីកុំឲ្យមានការជាប់ជំពាក់ កុំឲ្យឮពាក្យសៅហ្មងពីចាស់ទុំ ។ ព្រោះកុមារទាំងនោះជាក្មេងថ្មីស្រឡាង ដែលដាច់ស្រឡះគ្មានជំពាក់អ្វីឡើយ ។ អង្គការមានភារកិច្ចលត់ដំ « ក្រុមកុមារសងឈាម » ឲ្យដល់កំពូលដោយពន្យល់ប្រាប់ឲ្យស្គាល់ថានរណាជាមិត្ត នរណាជាសត្រូវ ។ ឧបមាដូចជាគេដុតដែកឲ្យដល់កំដៅ រួចហើយគេអាចឆ្លៃដែកនោះទៅធ្វើជាអ្វីក៏បាន ។

បន្ទាប់ពីការលត់ដំនេះមក តំណាងថ្មីរបស់អង្គការចាត់ទុកក្មេងទាំងនោះថា ជាអនាគតរាស្ត្រខ្មែរថ្មីយ៉ាងពិតប្រាកដ ។ ក្មេងទាំងនោះនឹងដុះគំនិតសងសឹកចំពោះសត្រូវ ។ វាចាត់ចែងរៀបចំក្មេងទាំងនោះដូចតទៅ ៖

លុះដឹកជញ្ជូនដល់ហាណូយហើយ មានគណកម្មការរង់ចាំទទួល រួចចែកតាមផ្នែកៗ តាមការជ្រើសរើសរបស់កុមារទាំងនោះដោយខ្លួនឯង ។ ឧទាហរណ៍ដូចជាកងទ័ពគ្រប់ៗផ្នែក លុះរៀនហាត់ហ្វឹកហ្វឺនចេះចប់ហើយ អង្គការលើនឹងបញ្ជូនវិលត្រឡប់មកកាន់មាតុភូមិកម្ពុជាវិញ គេនឹងរៀបចំអនាគតប្រទេសសារជាថ្មី ជំនួសអ្នកដឹកនាំសព្វថ្ងៃនេះ ។ អង្គការលើឈប់ទទួលស្គាល់ខ្មែរណាផ្សេងក្រៅពីក្រុមកុមារសងឈាមនេះជាដាច់ខាត ទោះខ្មែរនោះរៀនចេះដល់ថ្នាក់ណាក៏ដោយ ។ មកដល់ថ្ងៃហ្នឹង អង្គការបានបញ្ជូនកុមារកំព្រាទៅដល់ហាណូយចំនួនបួនម៉ឺននាក់រួចហើយ ។ ដូច្នេះដើម្បីកសាងអនាគតឲ្យកូនស្រីរបស់ម៉ែ ម៉ែគួរតែបញ្ចូលកូនក្នុងក្រុមកុមារសងឈាមឲ្យទាន់ពេលវេលា ។ល។

យាយទៀងសួរលឹកថា ៖

- តើនៅខេត្តបាត់ដំបង មានគេបង្កើតជំរុំក្រុមកុមារសងឈាមហើយឬនៅ ?

- មានបង្កើតរួចហើយម៉ែ ! លឹកឆ្លើយភ្លាមដោយញញឹមយ៉ាងពេញចិត្ត ។ ទីតាំងជំរុំ គឺនៅក្នុងបរិវេណអតីតវិទ្យាល័យព្រះមុនីវង្ស ។ សព្វថ្ងៃមានក្មេងកំព្រាចំនួន៧,០០០នាក់ ។ បូដូយកំពុងដើរប្រមូលជាបន្តៗទៅទៀត ។

យាយទៀងឮដូច្នេះមានអារម្មណ៍តក់ស្លុតដោយខ្លាចលឹកបំបែកកូនស្រីពីគាត់ ។ ឱ ! យួនហាណូយអង្គុយរង់ចាំឱកាសនេះយូរហើយទេតើ ។ ហេតុដូច្នេះហើយបានជាវាអាចសំរេចគោលបំណងដ៏ធំធេងរបស់វាយ៉ាងនេះបាន ?!?!

ឱ ! វាសនាកូនខ្មែរកំព្រា តើអ្នកដឹងឬទេថា ៖

- អង្គការនឹងលត់ដំដល់កំពូល ដើម្បីឲ្យអ្នកក្លាយទៅជាសត្រូវរបស់មាមីងជីដូនជីតារបស់អ្នក ?

- អង្គការនឹងដឹកនាំអ្នកឲ្យទៅជាប្រជាជនខ្មែរមួយថ្មី ដែលនៅពីក្រោយមានពួកវាជាអ្នកបញ្ជា ?

ឱ ! អនិច្ចាខ្មែរអើយ ! ចូរអ្នកដឹងខ្លួនឡើង ភ្ញាក់ខ្លួនពីការយល់ច្រឡំឡើង មិនដែលមានជនជាតិ ឬអ្នកណាស្រឡាញ់អ្នកជាងបងប្អូនមាមីងរបស់អ្នក ដែលមានជាតិជាខ្មែរដូចអ្នកទេ...

ពេលនោះ លឹកក្រោកដើរមកឱបយាយទៀង ថ្លែងអំណរគុណ ព្រមទាំងសុំលាចាកចេញពីកម្ពុជាទៅកាន់ហាណូយនៅថ្ងៃស្អែកនេះ ។

តាំងពីថ្ងៃនោះមក យាយទៀងមានសេចក្ដីព្រួយបារម្ភចំពោះវាសនារបស់កូនស្រីពៅគាត់ជាខ្លាំង ។ គាត់សំរេចចិត្តទៅមើលជំរំក្រុមកុមារសងឈាមដោយផ្ទាល់ភ្នែក ។ គាត់ចង់ដឹងថា តើការជ្រើសរើសយ៉ាងហ្នឹងមានលក្ខណៈអ្វីប្លែកឬទេ ? តើមានច្រើនឬទេ ? ។

❑ ❑

❑

# ជំរំកុមារឈានមុខ

នៅថ្ងៃទី១៧-៣-៨០, យាយទៀងដើរទៅកាន់ជំរំកុមារកំព្រា ដោយដើរចូលពីជើងទៅកាន់ជំរំ ។ បន្ទះក្ដារធំវែងមួយចងព្យួរជាប់នឹងក្លោងទ្វារសរសេរថា ÷ « ជំរំកុមារឈានមុខ » ។

នៅខាងឆ្វេងដៃមានអាគារមួយជាកន្លែងដណ្ដាំស្ល ។ គាត់បានជួបស្រីយួនម្នាក់ឈ្មោះនី កើតនៅស្រុកខ្មែរ ដែលជាប្រធានទទួលខុសត្រូវរៀបចំបាយទឹកឲ្យក្មេងទាំងនោះ ។ អ្នកនីទទួលយាយទៀងយ៉ាងរាក់ទាក់ រួចនាំគាត់បណ្ដើរចូលទៅមើលកុមាកំព្រាទាំង៧ពាន់នាក់នោះ ដែលកំពុងតែតម្រៀបជួរគ្នាចូលកាន់តុញ៉ាំបាយ ។

ក្មេងទាំងនោះមានអាយុពី៨ទៅ១៤ឆ្នាំ ស្លៀកពាក់ឯកសណ្ឋានពណ៌ផ្ទៃមេឃ

មុខញញឹមរីករាយ ។ លុះចូលជួបជុំហើយ ស្រាប់តែឮសម្លេងស្រែកបញ្ជាតាមមីក្រូជាភាសាយួនថា ៖

– Mac niêm chiên si trân giôn

– « គោរពវិញ្ញាណក្ខន្ធយុទ្ធជនដែលស្លាប់ក្នុងសមរភូមិ » ។

កុមារទាំងអស់ក្រោកឈរឡើងស្ងឹងស្ងាត់ គោរពវិញ្ញាណក្ខន្ធយុទ្ធជនដែលបានបូជាជីវិតក្នុងសមរភូមិចំនួន៣០វិនាទី ។

គេចែកកុមារតាំងនោះជាក្រុមៗ ។ ក្នុងមួយក្រុមៗមានគ្នា១០នាក់ ។ ក្នុងក្រុមនិមួយៗមានម្នាក់ក្រោកឡើងធ្វើសំនួរថា ៖

– តើនរណាជាមិត្តរបស់យើង ?

– មិត្តរបស់យើងគឺ វៀតណាមនិងលាវ !

– តើនរណាជាសត្រូវរបស់យើង ?

– សត្រូវរបស់យើងគឺបារាំង ជប៉ុន អាមេរិកាំង និងខ្មែរក្រហម... យើងត្រូវតែកំទេចខ្មែរក្រហម ។

សំនួរនិងចម្លើយរបៀបហ្នឹងត្រូវតែធ្វើនៅមុនពេលបាយព្រឹកល្ងាចជារៀងរាល់ថ្ងៃ ។ ពេលនោះឃាយទៀងឈរទ្រឹង ស្រក់ទឹកភ្នែកច្រោកៗ នឹកស្តាយអាណិតអាណោចអធម៌ដល់កុមារកំព្រាទាំងនោះយ៉ាងក្រៃលែង ខំរត់គេចពីខ្មែរក្រហមបែរជាមកធ្លាក់ចំកណ្តាប់ដៃយួនហាណូយទៅវិញ ។

មើលចុះ ! វាបើកឡានដើរប្រមូលយកមកធ្វើជាឈ្នាន់មួយលើកទៀត វាប្រើស្មៀតទន់ភ្លន់ កំពុងញុះញង់បំពាក់គោលជំហរ ជាពិសេសពន្យល់វែកញែកបណ្តុះគំនិតសងសឹកស្របតាមបញ្ជាជាក់ស្តែង ដែលកុមារទាំងនោះបានឃើញផ្ទាល់ភ្នែកនិងត្រូវរងគ្រោះផ្ទាល់ខ្លួន គឺឃើញខ្មែរក្រហមចូលមកចាប់ម៉ែឪ មាមីង បងប្អូននាំយកទៅសម្លាប់ចោលពីតៗ...។

ចំណែកកុមារទាំងនោះ ត្រូវខ្មែរក្រហមប្រមូលនាំយកទៅបង្ខំឲ្យធ្វើការទាំងយប់ទាំងថ្ងៃ ហាលភ្លៀងហាលខ្យល់ ទាំងឈឺ ហុតតែទឹកបបរ សឹងគ្មានអំបិលគ្មានអាវ គ្មានខោ មានតែមួយបន្លាស់ជាប់នឹងខ្លួន ។ វាធ្វើទារុណកម្មឃោរឃៅឥតមេត្តាទេ ។

ដល់ពេលឃើញយួនហាណូយមកដល់ ដើរប្រមូលនាំយកមកថែរក្សា ឧបត្ថម្ភ ឲ្យស៊ីចុកយ៉ាងគ្រប់គ្រាន់ ស្លៀកពាក់ឯកសណ្ឋានយ៉ាងស្អាតៗ កំសាន្តលេងយ៉ាងសប្បាយ មានកន្លែងដេកយ៉ាងសមរម្យ គិតតែពីរៀនសូត្រ... បើឃើញច្បាស់យ៉ាងនេះហើយ ម៉េចក៏មិនដឹងគុណ មិនគោរព មិនស្តាប់បង្គាប់ មិនស្រឡាញ់យួនហាណូយ ? ម៉េចមិនស្គាល់ថាខ្មែរក្រហមជាសត្រូវ ? តើគេអាចបំភ្លេចអំពើឃោរ

យៅព្រៃផ្សៃរបស់អ្នកដែលគេហៅថា «ខ្មែរក្រហម» នោះបានឬទេ ? ។

យាយទៀងគ្រវីក្បាលទាំងទឹកភ្នែករហាមទន្ទេញតែពាក្យថា ៖

- គួរឲ្យស្តាយៗ ! តើធ្វើម៉េចទៅ ដើម្បីពន្យល់កុមារកំព្រាទាំងឡាយនោះឲ្យយល់ថា នេះជាកលល្បិចរបស់យួនហាណូយទេ ! ។

គាត់នឹកឃើញនូវសំនួរពីរឃ្លា ដែលកាលណោះរបបយួនវៀតមិញ ពីឆ្នាំ១៩-៨៧ និង១៩៨៨ វាបង្ខំឲ្យបេក្ខជនដែលបំរុងទៅរៀននៅប៉េកាំងទន្ទេញចាំមាត់ ។ ប៉ុន្តែត្រង់សំនួរថា នរណាជាសត្រូវរបស់យើង កាលនោះចម្លើយមានតែបារាំង និងជប៉ុនប៉ុណ្ណោះ ។ កាលណោះយាយទៀងមានអាយុ១៩ឆ្នាំ ចេះសួរ ចេះឆ្លើយ ចចេចចចាចដូចសត្វសារិកា និយាយតាមតែវៀតមិញបង្ខំឲ្យថា ដោយគ្មានយល់ន័យនិងឃ្លាទាំងពីរនោះទេ ។ ផ្ទុយទៅវិញក្រុមកុមារឈាមមុខ អាចយល់ន័យនិងតម្លៃនៃឃ្លាថា ៖

- នរណាជាមិត្ត ? នរណាជាសត្រូវ ? ច្បាស់លាស់ណាស់ ។

យាយទៀងនឹកឃើញឡើងវិញ កាលពីឆ្នាំ១៩៨៨ ក្នុងជំនាន់យួនវៀតមិញព្យាយាមបញ្ជូនកូនខ្មែរទៅរៀននៅប៉េកាំង ខំអប់រំកែឆ្នៃឲ្យទៅជាខ្មែរថ្មី នៅក្នុងរង្វង់អន្ទាក់ខ្សែញាក់របស់វា ។

ប៉ុន្តែកូនខ្មែរមុនៗខ្វះការលត់ដំ គ្មានបណ្តុះគំនិតសង្សឹក លុះរៀនចេះចប់បានវិលត្រឡប់មកកាន់មាតុភូមិវិញ បែរជាដុះសតិសម្បជញ្ញៈចេះស្នេហាជាតិពិតៗយ៉ាងមុតជ្រៅ មិនព្រមលោតតាមខ្សែញាក់របស់វា ។ អ្នកទាំងនោះត្រូវយួនហាណូយសម្លាប់ចោលអស់ ។ ដូច្នេះកិច្ចការជ្រើសរើសកូនខ្មែរនាំយកទៅអប់រំ ដើម្បីកែឆ្នៃជាខ្មែរថ្មី ក្នុងរយៈកាលជាង៣០ឆ្នាំនេះ កូនខ្មែរត្រូវស្លាប់ច្រើនឥតគណនា ។ ឥឡូវយួនហាណូយប្រហែលជាបានសំរេចគោលបំណងវាហើយ ដែលខំព្យាយាម ដែលខំពិសោធជាច្រើនឆ្នាំ ។ វារកឃើញស្នៀតមួយដ៏ឆ្នើម គឺប្រើឈ្មោះអង្គការអនាមិក ជាមេបញ្ជាការលើខ្មែរក្រហម រួចតំណាងអង្គការដោយប្រើឃីហោខ្មែរក្រហមជានិច្ច ។

❑ ❑

❑

កុមារ ទុយ អាយុ៩ឆ្នាំ ជាកូនប្រុសពៅរបស់គ្រួសារមួយដែលមានគ្នា៤នាក់ ។ វាជួបយាយទៀងនៅក្នុងខែមិនាឆ្នាំ១៩៨០ នៅ«វត្តលោកយួន» ស្ថិតនៅក្បែរវត្តលាប ។ កុមារនេះនិយាយបណ្តើរយំបណ្តើរប្រាប់យាយទៀងថា ៖

នៅថ្ងៃមួយក្នុងសម័យអង្គការ ម្តាយខ្ញុំបានយកមាសទៅដូរអង្ករដើម្បីដណ្តាំបាយហូបឲ្យមានកម្លាំង ដើម្បីចេញពលិកម្មបំរើអង្គការ ។ អង្គការចេញបញ្ជាឲ្យខ្មែរក្រហមចាប់ចងម្តាយខ្ញុំ នាំយកទៅសម្លាប់នៅត្រង់ភូមិ សាលាត្រាវ ក្នុងសហករណ៍ព្រៃតូច ។ អង្គការបញ្ជាឲ្យនាំឪពុក, បងប្រុសខ្ញុំ និងខ្ញុំទៅឈរមើល ។ ពេលនោះពេជ្ឈឃាតវាយសំពងម្តាយខ្ញុំ មួយព្រនង់ដើមសង្កែទាំងបន្លា រួចច្រានទម្លាក់គាត់ក្នុងរណ្តៅ ដែលមានជំរៅយ៉ាងជ្រៅ ។ បន្ទាប់មក វាក៏ស្រែកសួរឪពុកខ្ញុំដែលឈរមើលទាំងតាំងមាត់នៅទីនោះថា ៖

- នែមិត្ត អាណិតឬទេ ?

ឪពុកខ្ញុំឆ្លើយសឹងមិនរួច ។ មួយសន្ទុះធំទើបឆ្លើយថា ៖

- អាណិត !...។

ពេជ្ឈឃាតបោយដៃហៅឪពុកខ្ញុំព្រមទាំងនិយាយថា បើអាណិតមកណេះ ! ឪពុកខ្ញុំក៏ដើរទៅជិតមាត់រណ្តៅដែលពេជ្ឈឃាតចង្អុល ដោយបំរុងឈ្ងោកមើលខ្មោចម្តាយខ្ញុំ ដើម្បីឲ្យដឹងថាតើស្លាប់ឬរស់ ?

ពេជ្ឈឃាតក៏សំពងគាត់មួយព្រនង់សង្កែដដែល រួចធាក់គាត់ទម្លាក់បញ្ចូលក្នុងរណ្តៅដដែល ជាមួយខ្មោចម្តាយខ្ញុំបាត់ទៅ ។

-ពេលឃើញពេជ្ឈឃាតសំពង់ឪពុកម្តាយខ្ញុំ, ខ្ញុំនិងបងប្រុសសម្លឹងមុខគ្នាជាសញ្ញា ។ ពេលនោះពេជ្ឈឃាតសួរពួកខ្ញុំភ្លាមថា ៖

- ណែមិត្ត តើអាណិតអាក្បត់នេះឬទេ ?

បងប្អូនខ្ញុំតាំងពីរនាក់ឆ្លើយព្រមគ្នាទាំងគ្រវីក្បាល គ្រវីដៃថា ទេ ! ទេ ! ទេ ! ទេមិត្តពូ ! ខ្ញុំមិនអាណិតមនុស្សក្បត់អង្គការទេ ! ។

ពួកខ្ញុំក៏បានរួចខ្លួនពីស្លាប់ នៅពេលនេះអង្គការក៏បញ្ជូនបងប្អូនខ្ញុំឲ្យចូលទៅក្នុងកងកុមារនៅភូមិព្រៃតូច បង្ខំឲ្យធ្វើការទាំងយប់ទាំងថ្ងៃ កណ្តាលក្តៅកណ្តាលភ្លៀង ហុតតែទឹកបបរសឹងគ្មានអំបិល មានតែខោអាវមួយបន្លាស់ដាច់ដាចជាប់នឹងខ្លួនពេលយប់នាំបងប្អូនលួនចូលដេកក្នុងចំបើង ព្រោះគ្មានភួយដណ្តប់ទេ ។

ឥឡូវនេះបូជ្ជីយនាំបងប្រុសខ្ញុំទៅរៀនឯហាណូយជាងពីរខែហើយ ។ ចំណែកបូជ្ជីយសន្យាថា នឹងបញ្ជូនខ្ញុំទៅហាណូយដែរនៅខែក្រោយៗនេះ ។ កុមារទុយបញ្ជាក់រអ៊ូៗថា ៖

- គួរឲ្យដឹងគុណបូជ្ជីយណាស់ !

មើលទ៉ ! កុមារកំព្រាអរគុណនិងសរសើរហាណូយមែន ! តើទៅអនាគតតមានក្រុមខ្មែរណាអាចមានសមត្ថភាពចូលទៅពន្យល់ដឹកនាំក្រុមកុមារឈានមុខឲ្យចាកចេញពីអន្ទាក់ខ្សែញាក់របស់ប្អូដូយបានទេ ? ។

ពេលនេះក្រុមកុមារឈានមុខកំពុងតែយល់ច្រឡំយ៉ាងសែនជ្រៅទៅក្នុងសភាពការណ៍នេះ !...

យាយទៀងឈរភ្លឹកពិចារណាថា ៖ នេះជាផែនការអាថ៌កំបាំង គឺវាដឹកនាំឲ្យឆ្ងាយផុតពីចាស់ទុំជាតិខ្មែរ ដើម្បីកែឆ្នៃក្រឡៃកុមារកំព្រាឲ្យទៅជាខ្មែរថ្មី ។ វារក្សាទុកកុមាកំព្រាទាំងនោះដើម្បីឆ្លើយទៅចំពោះមុខអន្តរជាតិថា ខ្ញុំជាខ្មែរ ជាម្ចាស់ទឹកដីកម្ពុជា...

ប៉ុន្តែពុទ្ធោអើយ ! តើចិត្តគំនិត របៀបរបប ទំនៀមទម្លាប់ អារ្យធម៌ ភាសា នឹងទៅជាយ៉ាងណាទៅវិញ ?

យួនហាណូយចិញ្ចឹមកុមារទាំងនេះទុក ដើម្បីរៀបចំអនាគតឲ្យក្រុមខ្មែរដឹកនាំកម្ពុជាថ្មី ដើម្បីបំភ័ន្តមតិពិភពលោកឲ្យយល់ច្រឡំ ទទួលស្គាល់ក្រុមកុមារឈានមុខថាជាម្ចាស់ទឹកដីកម្ពុជាស្របច្បាប់ ។

ទៅអនាគតមុខតែយួនហាណូយចាត់តែងតាំងឲ្យនៅគ្រប់ៗក្រសួងក្នុងអនាគតរដ្ឋាភិបាលកម្ពុជា ។ ប៉ុន្តែចៅក្រសួងដឹកនាំគឺពិតជាយួនហាណូយទាំងអស់ ។ ឱរឿងនេះស័ក្តិប្អូនលឹកបានប្រាប់យាយទៀងរួចហើយ ។

ឱ ! វាសនាកុមារកំព្រាខ្មែរអើយ ! អភ័ព្វណាស់ ! ពាក្យបុរាណបានតំណាលតៗមកហើយថា ៖ « ប្រយ័ត្ន ! ប្រាស់ពីដងវែក ទៅផ្អែកចំបង្គន់អាចម៍ ! » ។

តើនរណាត្រូវទទួលកំហុសទាំងអស់នេះ ?

តើត្រូវចោទនរណា ?

មើលចុះ ! នៅក្នុងផ្ទៃប្រទេសខ្មែរ យួនហាណូយដុតដៃដុតជើង បង្កើតខ្មែរថ្មីវាប្រើគ្រប់កលល្បិចលេបទឹកដីកម្ពុជាឲ្យស្រប ឲ្យពេញលក្ខណៈច្បាប់អន្តរជាតិ ។

ចំណែកប្រជាពលរដ្ឋខ្មែរជាម្ចាស់ទឹកដីកម្ពុជាពិតៗវិញកំពុងបះដៃបះជើងនាំគ្រួសារដែលសេសសល់នៅរស់រត់គេចពីកណ្ដាប់ដៃចោរ ភៀសខ្លួនទៅជ្រកសំណាក់នៅប្រទេសទី៣ របាត់របាយដូចត្រីរស់បែកហ្វូង ។ នេះហើយមកពីមេដឹកនាំខ្មែរ ទាំងសក្តិភូមិ ទាំងខ្មែរក្រហម ខ្វះសមត្ថភាពទាំងស្រុង ។

- យាយទៀងកំពុងលង់វិញ្ញាណនឹកសោកស្ដាយកុមារកំព្រាខ្មែរជាច្រើនម៉ឺននាក់ដែលអង្គការលត់ដំដល់កំពូល រួចហើយបែរជាធ្លាក់ក្នុងកណ្ដាប់ដៃយួនហាណូយ ដែលជាឃាតករប្រែឈ្មោះអង្គការនោះទៅវិញ ។ ឱ ! វាសនាប្រទេសខ្មែរអើយ តើទៅអនាគតនឹងទៅជាយ៉ាងណាទៅ ? ។ យាយទៀងភ្ញាក់ដោយអ្នកនីដឹក

ដៃគាត់នាំបណ្តើរទៅមើលកន្លែងដេករបស់កុមារទាំងនោះ ។ កន្ទេល មុង ខ្នើយ ភួយ ត្រូវគេរៀបចំយ៉ាងស្អាត ! ។

អ្នកនីនិយាយសរសើរថា បងឃើញទេកុមារកំព្រាទាំងនេះមានវាសនាល្អណាស់ យួនហាណូយចូលមកជួយទាន់ ឥឡូវគេដើរប្រមូល រួចគេបញ្ជូនឲ្យទៅរៀនសូត្រឯហាណូយ ។ លុះរៀនចេះដឹងហើយ ថ្ងៃក្រោយនឹងវិលត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ អាចសងសឹកចំពោះខ្មែរក្រហមបាន ដោយមានបូជួយជាអ្នកគាំទ្រ ។

អ្នកនីឱនខ្សឹបប្រាប់យាយទៀងព្រមទាំងចង្អុលប្រាប់ថា នេះអាអ៊ុកកូនប្រុសពៅរបស់ខ្ញុំ ។ ខ្ញុំទើបធ្វើសំបុត្របញ្ជាក់ថា វាជាកូនកំព្រា ។ យប់នេះវាត្រូវចេញដំណើរទៅកាន់ហាណូយជាមួយមិត្តរបស់វាចំនួន១០០០នាក់ ។ អ្នកនីនិយាយបណ្តើរព្រមទាំងលើកដៃចង្អុលបង្ហាញឡានកាម៉ុងចំនួន២០គ្រឿងកំពុងរៀបជាក្បួនចតតាមលេខរៀងនៅបណ្តោយផ្លូវលេខ២ ខាងកើតអតីតវិទ្យាល័យព្រះមុនីវង្ស ។ យាយទៀងសួរបញ្ជាក់អ្នកនីថា ៖

- ហេតុម៉េចចាំបាច់មានលិខិតបញ្ជាក់ថាកំព្រា ?

អ្នកនីផ្ទុះសំណើចយ៉ាងស្រួយ កាច់ក រួចទើបអធិប្បាយថា ៖ យួនហាណូយសំរាំងជ្រើសរើសនាំយកទៅមុនគេតែកុមារកំព្រាទាំងឪពុកទាំងម្តាយ ។ បើកុមារណាកំព្រាតែម៉ែ ឬតែឪ គេរក្សាទុកមួយអន្លើសិន ។ គេចាប់ផ្តើមស៊ើបអង្កេត បើកូនកំព្រានោះជាកូនអតីតអ្នករដ្ឋការ គេនឹងលប់ឈ្មោះចោលភ្លាម ។

នៅពេលជជែកសួរ-ឆ្លើយនេះ ស្រីទាំងពីរនាក់មានយោបល់ផ្ទុយគ្នាស្រឡះ។ អ្នកនីដឹកលង់ដំកើងយួនហាណូយ ថាជាអ្នកមានឧបការគុណ ព្រមទាំងធ្វើអំពើល្អចំពោះកុមារកំព្រាខ្មែរ ។ ចំណែកយាយទៀងវិញ គាត់យល់ផ្ទុយស្រឡះពីអ្នកនី ។ ព្រោះបញ្ហាសំរាំងជ្រើសរើសកុមារកំព្រាខ្មែរ ដែលអង្គការលត់ដំដល់កំពូលរួចហើយនេះ គឺជាស្នៀតមួយដ៏ប្រសើរដែលយួនហាណូយសម្ងំរង់ចាំជាច្រើនឆ្នាំមកហើយ ទើបបានសំរេចពេលហ្នឹង ?!?!

យាយទៀងមានអារម្មណ៍ឈឺចាប់សោកស្តាយកុមារកំព្រាទាំងឡាយនោះជាក្រៃលែង ។ គាត់ឈរសម្លឹងក្បួនឡានកាម៉ុងយ៉ាងយូរ ទើបសុំលាអ្នកនីវិលត្រឡប់ទៅកាន់កូនខ្ទមដ៏កំសត់របស់គាត់វិញ ។

❑ ❑

❑

# ចោរប្លន់ជាលើកទី២

ព្រលឹមថ្ងៃទី១០-៤-៨០ យាយទៀងលួនចេញពីបន្ទប់បង្គន់ ដើម្បីយកស្រូវទៅបាចឲ្យមាន់ស៊ី ។ ពុទ្ធោអើយ ! ស្វាត់ជ្រៀប, មាន់ជាង៤០ក្បាលត្រូវចោរលួចខ្ទេច ។ យាយទៀងអស់សង្ឃឹមរលីង ទន់ដៃទន់ជើង ក៏អង្គុយផ្អែកខ្នងទៅនឹងដើមដូងខាងកើតកូនខ្ទម ។

សូរិបជើងមនុស្សដើរក្រោយខ្នង ធ្វើឲ្យគាត់បែរភ្នែកសម្លឹងមើល ។ យួនម្នាក់អាយុប្រហែល៣៥ឆ្នាំ និយាយមកកាន់យាយទៀងថា ៖

- លោកចៅហ្វាយខេត្តសុំអញ្ជើញម៉ែទៅជួបនឹងលោក ។

យាយទៀងក្រោកឈរព្រមទាំងសួរថា ៖

- តើលោកហៅខ្ញុំមានការអី ?
- ខ្ញុំមិនដឹងទេ ។

យាយទៀងបំរុងខ្លួនដើរតាមយួនដ៏ចម្លែកនេះ ។ មុននឹងចេញដំណើរ នាយនាំសារក៏សួរយាយទៀងថា ៖

- ម៉ែមិនផ្លាស់សំលៀកបំពាក់ទេឬ ? ។
- ខ្ញុំមានតែមួយបន្លាស់ជាប់នឹងខ្លួននេះទេ ។
- តើម៉ែចេះភាសាយួនឬទេ ? ។
- អត់ចេះទេ ។

យួនចម្លែកបណ្តើរយាយទៀងដល់ខាងកើតព្រះវិហារវត្តរំដួល ក៏មានឡាន Peugeot 404 ពណ៌ប្រាក់មួយគ្រឿងចតឈប់រង់ចាំនៅទីនោះជាស្រេច ។ អ្នកបើកបរក៏ជាជាតិយួន ។ នៅលើពូកឡានខាងក្រោយ មានបូដូយពីរនាក់មានកាំភ្លើងខ្លីម្នាក់មួយដើម ។ បូដូយបើកទ្វារឡានបញ្ជាឲ្យយាយទៀងចូលអង្គុយកណ្តាល ។ ឡានក៏ពេទីម៉ាស៊ីនបើកបរចាកចេញពីវត្តរំដួល ។ បូដូយដែលអង្គុយខាងឆ្វេងលើកកាំភ្លើងភ្ជង់យាយទៀង ។ ពេលនោះអ្នកបកប្រែភាសានិយាយប្រាប់បូដូយថា ៖

- **Ba nay ngheo mac lam...**

- យាយនេះក្ររហាមណាស់កុំធ្វើបាបគាត់អី ! គាត់មានតែខោអាវមួយបន្លាស់ជាប់នឹងខ្លួនហ្នឹង ។ គាត់សំណាក់នៅនឹងកូនខ្ទមតូចមួយ គ្មានជញ្ជាំងស្រឡះធេងគ្មានអ្វីទាំងអស់ ។ បូដូយបញ្ជាឲ្យបើកឡានមួយជុំទីក្រុងបាត់ដំបង យកពេលសំឡុតយាយទៀងសិន ។ អ្នកបកប្រែភាសាប្រាប់យាយទៀងទៀតថា ម៉ែត្រូវឲ្យ

មាសប្រាំដំឡឹងដល់បូដូយ ទើបគេលែងឲ្យម៉ែទៅផ្ទះវិញ ។

យាយទៀងគ្រវីក្បាលឆ្លើយយ៉ាងថ្លមៗថា ៖

- ខ្ញុំគ្មានមាសទាល់តែសោះ ។

ឡានេះបរតាមផ្លូវលេខ១ ទៅដល់ផ្សារលើចម្ងាយប្រហែល៤គ.ម. រួចកាច់បត់ទៅស្តាំ កាន់ផ្លូវលេខ៣ បរវិលត្រឡប់មកកាន់ផ្សារធំបាត់ដំបងវិញ ។ ពាក្យកំញើញទារមាស៥ដំឡឹង និងពាក្យរបស់យាយទៀងឆ្លើយថាគ្មានទេ ពូរងំពេញឡាន ។ ឡានបរមកដល់ផ្សារធំបាត់ដំបង ក៏បត់ទៅឆ្វេងបន្តិច រួចទៅចតឈប់នៅមុខក្រសួង «សន្តិសុខជាតិ» ។

បូដូយបើកទ្វារឡានច្រានយាយទៀងឲ្យចុះ ។ ពេលនោះឃើញភ្នាក់ងារក្រសួងសន្តិសុខម្នាក់ជាជាតិខ្មែរ ដើរមកជួបអ្នកបកប្រែភាសាឈរខ្សឹបគ្នាយ៉ាងយូរ ។ ភ្នាក់ងារក្រោយនេះបោយដៃហៅយាយទៀង រួចវាបណ្តើរគាត់ចូលទៅក្នុងបន្ទប់សម្ងាត់មួយ ។ វាក៏ចាត់គ្នាចូលមកកញ្ជើញសំឡុតទារមាសប្រាំដំឡឹងដដែល ។ ចំណែកយាយទៀងមានតែពាក្យ២ម៉ាត់គឺ ៖

- គ្មានទេ ។

វាចាត់គ្នាចូលមកសំឡុត... មនុស្សទី១ មនុស្សទី២ ទី៣ ទី៤... សំឡុតហើយតំឡុតទៀត...

- ខ្ញុំគ្មានមាសទេ ។

មនុស្សទី៥ក៏ចូលមកដល់ ៖

- ឱ ! ពុទ្ធោ ៗ ! ប... បង ! បងទេតើ !

ភ្នាក់ងារទី៥នេះមានកំណើតនៅភូមិស្វាយចេក កាលពីដើមមានរបររកស៊ីជាចោរលួចមាន់ ។ នៅឆ្នាំ១៩៥៥ វាឈឺពោះវៀនដុះខ្លែងចុកពោះសឹងដាច់ដង្ហើមជិតងាប់ទៅហើយ ។ កាលណោះលោកទ្រីជាពេទ្យប្រចាំការនៅភូមិស្វាយចេក បានដឹកវាតាមរទេះគោមកកាន់ប្រជុំជនស្រុកស៊ីសុផុន រួចទើបដឹកឡានទៅព្យាបាលនៅពេទ្យធំបាត់ដំបង ដើម្បីវះកាត់ដុំដុះនោះ ។ កាលណោះយាយទៀងផ្តល់បាយម្ហូបចំណីឲ្យលុយថ្លៃជំនិះវិលត្រឡប់ទៅកាន់ភូមិស្វាយចេកវិញ ។

ភ្នាក់ងារទី៥រត់មកឱបយាយទៀងស្រក់ទឹកភ្នែករលីងរលោង រួចក៏ចាក់ផ្តើមសួរសុខទុក្ខ ទើបដឹងថាគ្រួសាររបស់យាយទៀងត្រូវព្រាត់ប្រាស់របាត់របាយអស់រលីង ។ គ្រូពេទ្យទ្រីត្រូវអង្គការសម្លាប់ទៅហើយ ។

មួយសន្ទុះភ្នាក់ងារទី៥ក៏សុំលាយាយទៀងទៅជួបក្រុមរបស់វា ។ នៅពេលត្រឡប់មកវិញ វាឱបយាយទៀងម្តងទៀត ព្រមទាំងថ្លែងសុំទោសនូវអំពើថោកទាបដែលក្រុមវាបានប្រព្រិត្ត ព្រមទាំងសុំអញ្ជើញយាយទៀងទៅពិសារបាយជាមួយគ្នា

វាទាំងអស់ ។

ពេលបរិភោគបាយទល់មុខគ្នា ម្នាក់ៗខំរកពាក្យនិយាយលប់លាងកំហុសរបស់ក្រុមខ្លួន ។ ប៉ុន្តែមានពាក្យមួយសំឡុតថា ៖

- បងត្រូវលាក់រឿងអម្បាញ់មិញនេះណា៎ ! បើបងបណ្តោយឲ្យអ្នកទី២ដឹង ប្រយ័ត្នរងគ្រោះដល់ជីវិត ! ។

ពេលបាយមានម្ហូបយ៉ាងឆ្ងាញ់ ប៉ុន្តែយាយទៀងលេបសឹងមិនចូល ព្រោះមានការឈឺចាប់ជាយ៉ាងខ្លាំង នូវឥរិយាបថអមនុស្ស នៃបងប្អូនខ្មែរដែលបំរើខ្មាំងនេះ។ ឆ្កៀតខ្មាំងបញ្ជោរប្រើ បែរជាសង្កត់សង្កិនជាតិរបស់ខ្លួនទៅវិញ ។

ឱពុទ្ធោអើយ ! ខ្មែរជាច្រើននាក់មុខជាត្រូវរងគ្រោះ ដោយត្រូវគេវាយសំឡុតធ្វើបាបដូចខ្លួនគាត់ជាឧទាហរណ៍ស្រាប់ បានជាខ្មែរត្រូវនាំគ្រួសារចាកចោលស្រុក ។ នៅថ្ងៃនេះ, ចំពោះខ្លួនគាត់ផ្ទាល់បានគេអត់ឱនឲ្យ ចុះដល់ថ្ងៃក្រោយវានឹងទៅជាយ៉ាងម៉េចទៅវិញ ? ។ ចុះចំពោះអ្នកដែលគេមិនស្គាល់នោះ វានឹងទៅជាយ៉ាងណាទៅទៀត ? ។ នៅពេលនោះទើបយាយទៀងយល់ថា ហេតុយ៉ាងដូចម្តេចបានជាខ្មែរនាំគ្នារត់ចោលស្រុក ។

ម៉ោង៣រសៀល យាយទៀងបានត្រូវគេលើកលែងឲ្យរួចខ្លួន ដើម្បីវិលត្រឡប់ទៅកាន់កូនខ្ទមវិញ ដោយដើរតាមផ្លូវលេខ១ ។ ចំណែកកូនស្រីពៅរបស់គាត់ ពេលនាងចេញពីសាលារៀនមកដល់កូនខ្ទម មានយាយជីម្នាក់ប្រាប់ថា មានឡានមួយយួនជិះពេញ បរមកចាប់ម្តាយនាងនាំយកទៅបាត់ហើយ ! ។

នាងយំបណ្តើរលើផ្លូវលេខ៣ រត់រកម្តាយបណ្តើរ អត់បាយអត់ទឹក ។ ស្ត្រីដ៏កំសត់ទាំងពីរនាក់ម៉ែកូនរវល់តែជ្រួសផ្លូវគ្នា ទំរាំងតែបានជួបគ្នា ម៉ោងជាង៥ល្ងាចទៅហើយ... ម៉ែនិងកូនមានតែទឹកភ្នែកទេជំនួសសំនួរនិងចម្លើយ ។

នៅពេលនោះកូនស្រីពៅរបស់គាត់អស់សង្ឃឹម នាងអង្វរម្តាយត្រូវតែចាកចេញពីប្រទេសកម្ពុជា ។ នាងនិយាយថា ៖

- សូមម៉ែកុំទុកចិត្តយួនឲ្យសោះ ! ។

ប៉ុន្តែយាយទៀងនៅតែរារែក ចង់បន្តការស្រាវជ្រាវបន្តិចទៀត ។ គាត់ចង់ដឹងថា តើទៅអនាគត យួនហាណូយប្រើកលល្បិចយ៉ាងម៉េចទៅទៀត ដើម្បីត្រួតត្រាប្រទេសកម្ពុជា ឲ្យពេញកល្លណៈច្បាប់ បើទឹកដីកម្ពុជានេះមានឈ្មោះជាប់ក្នុងផែនទីពិភពលោក ហើយអន្តរជាតិបានទទួលស្គាល់ច្បាស់ថា នគរកម្ពុជាជាទឹកដីរបស់ខ្មែរ ។

ចំណែកអ្នកជិតខាងដែលមានលំនៅជិតយាយទៀង ក៏ផ្អើលឈ្ងួឆរ រត់មកសួរចង់ដឹងហេតុផល ។ ព្រោះគ្រប់ៗគ្នាស្គាល់យាយទៀងច្បាស់ថាគាត់ជាស្រីសែ

នសុចរិត ជាអតីតអ្នករដ្ឋការហេតុម៉េចក៏យួនមកចាប់គាត់ដាក់ឡានអញ្ជើង ? ។

យាយទៀងគ្រវីក្បាលមានតែទឹកភ្នែកជំនួយចម្លើយ ។ ព្រោះបើភរគេ គាត់រកពាក្យមិនឃើញ បើនិយាយការពិត ខ្លាចគេសម្លាប់ ! ពុទ្ធោ ! ពុទ្ធោ !...

❑ ❑

❑

នៅថ្ងៃទី១៦-០៤-៨០ ម៉ោងប្រហែល៩ព្រឹក មានអតីតអនុសេនិយទោក្នុងកងទ័ពម៉ែកហ្វ៊ក្ស និងជាអតីតអង្គរក្សរបស់លោកសឺន-ង៉ុកថាញ់ឈ្មោះថាច់-ទ្រឿង អាយុប្រហែល៣០ឆ្នាំ ដើរចូលមកកាន់កូនខ្ទមរបស់យាយទៀង ។ ថាច់-ទ្រឿងឱបយាយទៀងដោយនឹករលឹក ព្រមទាំងសំរក់ទឹកភ្នែក អាណិតគាត់ដែលត្រូវព្រាត់ប្រាស់គ្រួសារអស់រលីង ហើយមានសភាពក្ររហេមរហាមយ៉ាងនេះ ។ តែមួយសន្ទុះក្រោយមក ថាច់-ទ្រឿងបែរជាសើចញឹមៗ ដោយមានសេចក្ដីត្រេកអរលាយជាមួយ ដោយឃើញថាគាត់នៅមានវាសនា អាចគេចផុតគ្រោះចង្រៃឧបទ្រព្យនេះ ។ មីងនិងក្មួយក៏ចាប់ផ្ដើមសួរសុខទុក្ខគ្នាទៅវិញទៅមក ។ យាយទៀងចាប់អធិប្បាយរឿងកំសត់របស់គាត់ ចាប់តាំងពីថ្ងៃទី១៧-៤-៧៥រហូតមកដល់ថ្ងៃទី១៦-៤-៨០ ។ លុះថាច់-ទ្រឿងបានស្ដាប់ចប់សព្វគ្រប់ហើយ ឲ្យឱបយាយទៀងម្ដងទៀតដោយអាណោចអធម៌ ។

ថាច់-ទ្រឿងក៏ចាប់និទានរឿងផ្ទាល់ខ្លួនរបស់គេដូចតទៅ ៖

- នៅថ្ងៃទី១៧-៤-៧៥ ខ្ញុំបានចេញផុតពីស្រុកខ្មែរហើយ ។ ព្រោះខ្ញុំត្រូវដល់វេនធ្វើអង្គរក្សលោកសឺន-ង៉ុកថាញ់ នៅទីលំនៅរបស់លោកដែលស្ថិតនៅក្បែរវត្តចន្ទរង្សី ( ព្រៃនគរ ) ឯណោះ ។

ចំណែកយាយទៀងឮដំណឹងនេះភ្លាម គាត់មានការរំភើបក៏សួរកាត់ថា ៖

- ឱ ! តើវាសនារបស់លោកសឺន-ង៉ុកថាញ់យ៉ាងម៉េចទៅ ?

ថាច់-ទ្រឿងគ្រវីក្បាល រួចទើបអធិប្បាយបន្តទៀត ៖

- មីងអើយ ! នឹកទៅគួរឲ្យស្ដាយណាស់ នៅមុនពេលដែលអាមេរិកាំងដកចេញពីព្រៃនគរ គេមកសុំអញ្ជើញលោកជាច្រើនលើក សុំឲ្យលោកភៀសខ្លួនទៅកាន់សហរដ្ឋអាមេរិកមួយរយៈសិន ។ លោកប្រកែកជាដាច់ខាតមិនព្រមទៅ ព្រោះលោកជាប់ចិត្តអាណិតអាសូរខ្មែរកម្ពុជាក្រោម ។ លោកមិនដាច់ចិត្តគេចរត់ពួនយកសុខតែម្នាក់ឯងទេ ។ ក្នុងមួយជីវិតរបស់លោក លោកធ្វើពលិកម្មលះបង់កិច្ចការផ្ទាល់

ខ្លួនដើម្បីជាតិជានិច្ច ជាពិសេសចំពោះខ្មែរនៅកម្ពុជាក្រោម ។

ង្វៀង-ហូវថូ មេវៀតកុងនៅស្រុកយួនខាងត្បូងនិងលោក បានធ្វើកិច្ចសន្យាជាសម្ងាត់មួយ មានចុះហត្ថលេខាជាមួយគ្នាយ៉ាងត្រឹមត្រូវ មានសេចក្តីជាអាទិថា ៖

- បើពេលណាអាមេរិកាំងថយចេញពីវៀតណាមខាងត្បូង យួននិងកម្ពុជាក្រោមត្រូវទទួលជ័យជំនះស្មើភាពគ្នា ។ គឺយួនយល់ព្រមប្រគល់ស្វ័យភាព ( Autonomie ) ឲ្យខ្មែរកម្ពុជាក្រោម ។ល។

នៅថ្ងៃទី៥-៥-៧៥ លោកអន្ទះសារជាយ៉ាងខ្លាំង ព្រោះស្ថានការណ៍នៅប្រទេសវៀតណាម ប្រែជាងងឹតអន្ធការច្របូកច្របល់ ដូចឡានបាក់ចង្កូត ។ លោកសឺនង៉ុកថាញ់ក៏យកកិច្ចសន្យានោះមកពិនិត្យមើល រួចក៏បត់ច្រកក្នុងហោប៉ៅអាវប្រថុយផ្សងព្រេងទៅរកជួបង្វៀង-ហូវថូ ។ ពេលនោះខ្ញុំក្តី កូនប្រសារប្រុសរបស់លោកក្តី សំអង្វរលោកឲ្យរត់គេចមួយរយៈសិន ។ លោកគ្រវីក្បាលជំនួសចម្លើយ ។ រួចបណ្តើរកង់មួយជិះចេញបាត់ទៅ...

- ពីរថ្ងៃបន្ទាប់ កូនប្រសារប្រុសរបស់លោកក៏ផ្សងព្រេងទៅរកឪពុកក្មេក...ក៏បាត់ខ្លួនរហូតទៅទៀត ។

បីថ្ងៃមកទៀត គឺថ្ងៃទី១០-៥-៧៥ វៀតកុងចូលមកចាប់ខ្ញុំ នាំយកទៅដាក់ខ្នោះនៅខេត្តដាណាំង ជាមួយជនជាតិយួនមានចំនួន១១ម៉ឺននាក់ ។ និយាយដល់វគ្គនេះថាច់-ទ្រឿងក៏បង្ហាញកជើង ដែលនៅសល់ស្លាកស្នាមបណ្តាលមកពីខ្នោះនោះឲ្យយាយទៀងឃើញជាភស្តុតាង ។ រួចនិយាយបន្តទៅទៀត ៖

- លុះដល់ខែកញ្ញាឆ្នាំ១៩៧៨ វៀតកុងក៏ដោះលែងអ្នកទោសដែលជាប់ខ្នោះនៅខេត្តដាណាំង ហើយដែលដើរបានឲ្យវិលត្រឡប់ទៅកាន់លំនៅរៀងៗខ្លួនវិញ ចំណែកអ្នកទោសជិតមួយម៉ឺននាក់ដែលដើរមិនរួច វៀតកុងនាំយកទៅដាក់ក្នុងជំរំមួយឈ្មោះ Trai Bo គឺជំរំ «វ៉ារ» គឺទុកឲ្យស្លាប់ក្នុងជំរំនោះទៅ ! ។

- លុះខ្ញុំចេញពីទីដាក់ខ្នោះនោះមក ទើបខ្ញុំដឹងថាលោកសឺន-ង៉ុកថាញ់ស្លាប់តាំងពីថ្ងៃទី៨-៨-៧៧ នៅក្នុងគុកជីហ៊្វា ។

ប្រជាជនយួនក្តី ខ្មែរក្តី ទោះបានរួចចេញពីមន្ទីរឃុំឃាំងក៏ដោយ ក៏គ្មានសេរីភាពដែរ ។ គ្រប់ៗគ្នាមកដល់ទីលំនៅ ក៏ត្រូវយួនហាណូយតាមដានគ្រប់ដង្ហើមចេញចូល ។ ដូច្នេះគ្រប់ៗរូបជាពិសេសយួនខាងត្បូង កំពុងលៃលកស្វកប៉ាន់ឲ្យមាសដល់វៀតកុងរួចធ្វើទូកដាក់ម៉ាស៊ីនផ្សងព្រេងរត់ឆ្លងមហាសមុទ្រមកតាមចៅហ្វាយនាយចាស់គឺ បារាំងនិងអាមេរិកាំង ។ ថាច់-ទ្រឿងបន្តទៅទៀតថា ៖

- យួនខាងត្បូងឈឺចិត្តណាស់ ដែលបណ្តោយឲ្យខ្លួនចាញ់បោកយួនហាណូយខំក្បត់ចៅហ្វាយនាយបារាំង និងអាមេរិកាំង ដើម្បីមកបំរើវា ។ ព្រោះការដែល

យួនហាណូយបានឈ្នះលើបារាំងក្តី លើអាមេរិកាំងក្តី ក៏ព្រោះតែនៅពេលនោះ យួនខាងត្បូងជាអ្នកធ្វើចារកិច្ចឲ្យវា ។

ឥឡូវខកខូចចិត្តអស់សង្ឃឹមខំបំរើវាអស់រយៈពេល៣០ឆ្នាំ ហើយនៅទីបំផុត យួនហាណូយបញ្ឆោតនាំយកទៅដាក់គុកដាក់ខ្នោះទៅវិញ ។ល។ ឆ្លៀតឱកាសដែលយួនកំពុងតែចលាចល សូកប៉ាន់យួនហាណូយដោយរត់រញ៉េរញ៉ៃនោះ ខ្ញុំក៏រត់មកកាន់ប្រទេសកម្ពុជានៅចុងខែធ្នូឆ្នាំ១៩៧៩ ។

ក្នុងខែមីនាឆ្នាំ១៩៨០ ខ្ញុំបានជួបលោកគៀង-ទ្រឿង ជាអតីតវរៈសេនិយឯកក្នុងកងទ័ពម៉ែកហ្វ្រក្ស និងលោកទ្រីវ-ចូវ ជាអតីតអនុសេនិយឯកក្នុងកងទ័ពម៉ារីនអាមេរិកាំងនៅព្រៃនគរ ។ លោកទើបនឹងរួចចេញពីគុកនៅហាណូយ ជាមួយនិងអនុសេនិយទោពីរនាក់ទៀត ភ្លេចឈ្មោះ ។ ក្រុមខ្ញុំ៥នាក់ ស្ម័គ្រចិត្តចូលបំរើរជរបខ ដែលមានលោកគៀង-ទ្រឿងជាមេដឹកនាំក្រោមបញ្ជាការរបស់ស្រីម្នាក់ ដែលមានទីចាត់ការនៅកណ្តាលរដ្ឋធានីភ្នំពេញ ។

ក្រុមខ្ញុំមានគ្នា៥នាក់ ធ្វើការជាមួយលោកគៀង-ទ្រឿង ក្រោមបញ្ជាការផ្ទាល់របស់ស្រីម្នាក់នៅភ្នំពេញ ។ ទីស្នាក់ការសម្ងាត់របស់យើង តាំងនៅត្រើយខាងកើតទន្លេមេគង្គ ។ ស្រីមេបញ្ជាការបានផ្តល់មាសឲ្យពួកយើងចាយវាយខ្លះៗ ។ នៅដើមខែមេសាឆ្នាំ១៩៨០ លោកទ្រឿងទទួលបានមាស៥ជីឡឹងពីព្រំដែនខ្មែរ-ថៃ ។ មិនទាន់បានបានជួបជុំចែកគ្នានៅឡើយ ស្រាប់តែបូដូយមកព័ទ្ធចាប់លោកទ្រឿង និងអនុសេនិយទោពីរនាក់ នោះយកទៅបាត់ ។ ចំណែកលោកទ្រីវ-ចូវ រវល់តែទៅជួបអ្នកស្រីមេបញ្ជាការធំនៅភ្នំពេញក៏បាត់ខ្លួនរហូត...។

ចំណែកខ្ញុំៗជាប់បំពេញបេសកកម្មនៅព្រែកតាមាក់ ។ ដឹងខ្លួនទាន់ក៏រត់គេចមកកាន់ខេត្តពោធិសាត់ នៅថ្ងៃទី១៤-៤-៨០ មានបំណងចូលបំរើរ.ជ.រ.ប.ខ.នៅទីនោះ ។

មកដល់ខេត្តពោធិសាត់ ស្វាត់ច្រៀប ពីព្រោះរជរបខខេត្តពោធិសាត់និងខេត្តកំពង់ឆ្នាំង មានកើតឧប្បត្តិហេតុមួយដ៏ចម្លែក ។ រឿងរ៉ាវមានដូចតទៅនេះ ៖

★ នៅយប់ថ្ងៃចូលឆ្នាំខ្មែរទី១៣-៤-៨០ អ្នកដឹកនាំរជរបខនៃខេត្តទាំងពីរបានរួបរួមគ្នាធ្វើពិធីជប់លៀងមួយយ៉ាងធំ ដោយចាត់អញ្ជើញមេៗបូដូយមកស៊ីផឹក ក្នុងន័យនឹងចាត់ការសម្លាប់ពួកវាឲ្យអស់ ។ មេៗបូដូយក៏ចូលមកស៊ីផឹកតាមសេចក្តីអញ្ជើញយ៉ាងសប្បាយរីករាយ ។

៥នាទីមុនពេលកំណត់ ដែលមេដឹកនាំរជរបខបំរុងនឹងចាត់ការចាប់ចងមេៗបូដូយទាំងនោះ ស្រាប់តែមានបូដូយយ៉ាងច្រើនចូលមកព័ទ្ធចាប់អ្នកដឹកនាំរជរបខទាន់ពេលមុនដូចបានព្រៀងទុក ។ វាចាប់បានពួករជរបខមានចំនួនជាង៥០០នាក់

ហើយនាំយកទៅបាត់រហូត...

ថាច់-ទ្រឿងគ្រវីក្បាលថ្ងូរអ៊ូៗថា ៖

- ខ្ញុំឆ្ងល់សែនឆ្ងល់ ព្រោះមិនដឹងជាយ៉ាងម៉េច ក៏បូដ្ឋយពូកែយកការណ៍ម្ល៉េះ? ខ្ញុំក៏បន្តដំណើរទៅកាន់ខេត្តបាត់ដំបង មានបំណងមកបំរើរជរបខនៅខេត្តនេះ ។ យប់មិញនេះ ខ្ញុំទៅជួបមេដឹកនាំរជរបខ តែបន្ទាប់ពីបានស្តាប់សំដីអួតអាងខុសទំ-នងរបស់អស់លោកមេៗនោះមក ខ្ញុំក៏ឈប់ទុកចិត្តហើយអស់សង្ឃឹមរលីងធេង។

យាយទៀងសួរថា ៖

- ម៉េចបានជាអ៊ីចឹងទៅវិញ ?

- ព្រោះមានរឿងដ៏ចម្លែកមួយដែលកើតឡើងនៅផ្ទៃក្នុងក្រុមដឹកនាំ ។ នៅយប់ថ្ងៃទី១៣និង១៤ខែមេសាឆ្នាំ១៩៨០ ឆ្លៀតពេលចូលឆ្នាំខ្មែរ លោកឡាយ-សាម៉ុន ចៅហ្វាយខេត្តដែលយួនទើបបញ្ជូនមកពីហាណូយ ចាត់អញ្ជើញមេៗរជរបខទៅខេត្តបាត់ដំបងទាំងអស់ ឲ្យចូលរួមក្នុងពិធីជប់លៀងមួយ ច្រៀងរាំអស់រយៈពេល២យប់ដើម្បីចងមិត្តភាព ។

លុះចប់ពិធីនេះហើយ លោកឡាយ-សាម៉ុនថ្លែងជាឧឡារិកថា លោកសុំធានាដឹកអង្ករ ដឹកស្បៀងគ្រប់ៗជំពូកផ្តល់ឲ្យកងទ័ពរជរបខ គ្រប់ៗកន្លែងក្នុងខេត្តបាត់ដំបងទាំងមូល ។ លោកសុំតែមិត្តៗមេៗរជរបខប្រាប់ទីកន្លែង និងចំនួនកងទ័ពតែប៉ុណ្ណោះ ។ល។ និង ។ល។

ថាច់-ទ្រឿងនិយាយដល់ត្រឹមណោះ ក៏ងើបមុខសម្លឹងយាយទៀង ព្រមទាំងនិយាយថា ទើបព្រឹកនេះខ្ញុំមករកជួបមីងដើម្បីសុំយោបល់ ។

លុះឮបញ្ហានេះហើយ យាយទៀងអង្គុយគិតមួយសន្ទុះគាត់ក៏ឆ្លើយថា ៖

- គួរឲ្យចម្លែកមែនៗ ដំណាក់ការជាដំបូងរបស់រជរបខ គឺត្រូវតែកំទេចយួនហាណូយនិងអាយ៉ងរបស់វា ដើម្បីរំដោះទឹកដីកម្ពុជា ។ សព្វថ្ងៃ បូដ្ឋយស៊ីបាយវាល់ចាន ម្ហូបមានតែផ្អែរនិងត្រកួនស្ងោរ បង់តែអំបិល ។ ចុះហេតុម្តេចចៅហ្វាយខេត្តអាយ៉ងយួននេះ បែរជាមានអង្ករមានស្បៀងគ្រប់ៗមុខ ដឹកនាំយកទៅផ្តល់ឲ្យរជរបខមិនទំនងបែបនេះ ?

★ កលល្បិចនេះវៀតមិញប្រើម្តងរួចហើយកាលពីឆ្នាំ១៩៤៥ នៅឯកម្ពុជាក្រោមដោយសម្លាប់ខ្មែរយ៉ាងវីវក់ ។ ចំណែកនៅឯប្រទេសកម្ពុជា ក្នុងរយៈពេលតែមួ-យ បូដ្ឋយបានចូលមកតាំងមូលដ្ឋាននៅពាសពេញដោយយកលេសថា មកវាយកំទេចជេញបារាំង ។ តែគឺនៅពេកនោះហើយដែលវាបង្កើតបានអាយ៉ងរបស់វាគឺ «ខ្មែរវៀតមិញ» ។ លុះមកដល់ជំនាន់យួនហាណូយជាវៀតកុង វានាំកលល្បិចនេះមកប្រើទៀត ។

★ មើលចុះ ! វាខំបង្កើតឈ្មោះអង្គការអនាមិក រួចមកអង្គការនេះក៏បង្កើតយោធាស្រឡាញ់សម្ដេចឪ មានចំនួន៩០,០០០នាក់ ឲ្យកំទេចសម្លាប់ខ្មែរលន់-នល់ ដែលជាម្ចាស់ទឹកដីកម្ពុជាពិតៗ ។ លុះបានទទួលជ័យជំនះជាស្ថាពរហើយ អង្គការក៏ប្រមូលយោធាទាំងអស់ បញ្ជូនចូលចំកណ្ដាលអន្ទាក់ខ្សែត្រៀមរបស់បួដួយ ឲ្យវាបាញ់សម្លាប់ចោលអស់រលីង ។

ថាច់-ទ្រឿងពោលឡើងថា ៖

- ពុទ្ធោៗ ខ្ញុំបានឮរឿងនេះដែរ ។ ខ្ញុំឆ្ងល់សែនឆ្ងល់ព្រោះពេលនោះយួនជាវៀតកុងមានទ័ពចំនួនមួយលាន់នាក់ មានបច្ចេកទេសផ្នែកខាងធ្វើសង្គ្រាមយ៉ាងត្រឹមត្រូវ ចំណែកផ្នែកអាវុធមានយ៉ាងច្រើន ។

ថាច់-ទ្រឿងរៀបរាប់ពីចំនួនអាវុធនិងចំនួនស្បៀងអាហាររបស់ទ័ពយួនហាណូយ ដូចដែលតាអាងបានរៀបរាប់ប្រាប់យាយទៀងរួចមកហើយ...

ចំណែកឯយោធាខ្មែរក្រហមមានចំនួន៩ម៉ឺននាក់ ។ បានឈ្នះខ្មែរលន់-នល់ដោយថៃដន្យ ដូច្នេះគ្មានអ្វីជាអស្ចារ្យសោះ ។ ហេតុម៉េចក៏អង្គការបញ្ជូនយោធាទាំងនោះ ទៅរំដោះទឹកដីកម្ពុជាក្រោម ? ម្នាក់ៗស្ពាយគ្រាប់តែមួយសំពាយ និងកាំភ្លើងមួយដើម រួចដើរច្មើរជើងយ៉ាងនោះ ? ។ លុះទទួលដំណឹងថា យោធាខ្មែរក្រហមទាំងអស់នោះ ត្រូវបួដួយបាញ់សម្លាប់ចោលខ្ទេច ខ្ញុំក៏ផ្ដន្ទាថា « ងាប់អស់ទៅចុះ» ព្រោះខ្ញុំមិនបានដឹងថា នេះជាឧបាយកលរបស់អង្គការអនាមិកឡើយ ។

យាយទៀងសម្លឹងមុខថាច់-ទ្រឿងព្រមទាំងបញ្ជាក់ថា ៖

- គ្មានស្នៀតអ្វីប្រសើរជាងស្នៀតនេះឡើយ ។ មើលចុះ ! កាលពីថ្ងៃមុន អង្គការអនាមិកប្រើស្នៀតនេះ សម្លាប់យោធាស្រឡាញ់សម្ដេចឪ ។ ឥឡូវយួនហាណូយកំពុងតែនាំយកស្នៀតដដែលនេះមកប្រើ ដើម្បីសម្លាប់កំទេចរជរបខទៅអនាគតទៀត ។ ដូច្នេះបើយើងជឿតែត្រចៀកនិងភ្នែក យើងឃើញថាយួនល្អណាស់ ។ តែបើយើងចេះត្រិះរិះពិចារណានិងប្រៀបធៀប យើងអាចរកឃើញយ៉ាងងាយនូវកលល្បិចក្រឡិចក្រឡុច ដែលមានជាបញ្ញោស់ជាបណ្ដោយ ដ៏ក្រខ្វក់អាក្រក់ឃោរឃៅរបស់វានេះ ។

ថាច់-ទ្រឿងថ្ងូរអ៊ូៗថា ៖

- តើយើងធ្វើយ៉ាងម៉េចទៅ បើក្រុមរជរបខខេត្តបាត់ដំបងកំពុងតែបណ្ដើរគ្នាចូលអន្ទាក់របស់យួនហាណូយយ៉ាងនេះ ? ស្ដាយអើយសែនស្ដាយ... បើដឹងយ៉ាងនេះហើយ តើធ្វើម្ដេចទៅ ? បើយើងមីង-ក្មួយខ្វះសមត្ថភាពយ៉ាងនេះ ?

ថាច់-ទ្រឿងអង្គុយផ្ទាល់ដីឱបក្បាលជង្គង់សញ្ជឹងគិតមួយសន្ទុះធំ ទើបសុំបបួលមីងទៀងចាកចេញចោលប្រទេសកម្ពុជាទៅកាន់ប្រទេសថៃ ។ យាយទៀងទូន្មា

នថាច់-ទ្រឿងថា ៖

- គួរក្មួយគេចចេញទៅកាន់បរទេសសិនចុះ ចំណែកឯមីង មីងត្រូវតែនៅក្នុងស្រុកខ្មែរ ព្រោះមីងមានគោលបំណងចង់ស្រាវជ្រាវរកមើលកលល្បិចរបស់យួនហាណូយតទៅទៀត ។មីងចង់ដឹងថាតើអំណើះតទៅមុខ វានឹងធ្វើយ៉ាងម៉េចទៀត ដើម្បីលេបយកទឹកដីកម្ពុជា ឲ្យបានយ៉ាងងាយដូចបេះផ្លែពុទ្រាទុំយ៉ាងនោះ ? ម្យ៉ាងវិញទៀត មីងចង់ដឹងថា តើវាធ្វើយ៉ាងម៉េចទៀត ដើម្បីត្រួតត្រាប្រទេសខ្មែរឲ្យស្របច្បាប់អន្តរជាតិ ?

បើមីងស្រាវជ្រាវរកឃើញ មីងនឹងសរសេរទុកជាប្រវត្តិសាស្ត្រ ជូនកូនខ្មែរជំនាន់ក្រោយៗ ជាពិសេសទុកសំរាប់អនាគតអ្នកដឹកនាំប្រទេសខ្មែរ ដើម្បីឲ្យចេះប្រុងប្រយ័ត្នខ្លួន កុំបណ្ដោយឲ្យចាញ់បោកយួនហាណូយ ដូចមេដឹកនាំមុនៗ ។ កុំឲ្យប្រជាពលរដ្ឋខ្មែររងទុក្ខវេទនាដូចអ្នកកើតជំនាន់នេះឲ្យសោះ ! ។

ថាច់-ទ្រឿងដើរមកឱបយាយទៀង ព្រមទាំងនិយាយថា ៖

- គោលបំណងរបស់មីងប្រសើរមែនៗ ! ប៉ុន្តែខ្ញុំមានការបារម្ភដល់អាយុជីវិតរបស់មីងណាស់ ព្រោះអតីតអ្នករដ្ឋការដូចមីងអីចឹង មានបាត់ខ្លួនខ្លះៗទៅហើយ ដូច្នេះសូមមីងប្រយ័ត្នខ្លួនមីងឲ្យមែនទែន ។

ថ្ងៃនេះម៉ោងប្រហែលបីរសៀល ក្រោយពេលបាយល្ងាចរួច ថាច់-ទ្រឿងក៏សំពះសុំលាមីងទៀងចេញដំណើរទៅកាន់ប្រទេសថៃ...

ថ្ងៃទី១៣-៥-៨០ ម៉ោងប្រហែលមួយរសៀល មានអតីតវរៈសេនីយ៍ទោម៉ែក-ហ្វ៊ក្ស និងអតីតមេបញ្ជាការនៅអូរសាជាសខេត្តបាត់ដំបងម្នាក់ឈ្មោះគីម-ហួរ ជាក្មួយរបស់យាយទៀង ដើរចូលមកកាន់កូនខ្ទមរបស់គាត់ ។

ពេលបានជួបគ្នាជាថៃដន្យយ៉ាងនោះ ក៏លោតឱបគ្នា សើចមិនចេញយំមិនចេញ មីងនិងក្មួយកាន់ដៃគ្នាគាំងមាត់រកពាក្យនិយាយគ្មាន ។ មួយសន្ទុះធំទើបលោកគីម-ហួរកៀកស្មាម្ដាយមីងបណ្ដើរទៅកាន់ជណ្ដើរមុខកូនខ្ទម រួចអង្គុយសួរសុខទុក្ខគ្នាទៅវិញទៅមក ។

លោកគីម-ហួរលុះបានស្ដាប់រឿងដ៏កំសត់នៃការនិរាសព្រាត់ប្រាស់របស់មីងចប់សព្វគ្រប់ហើយ ក៏ឱបម្ដាយមីងម្ដងទៀត ព្រមទាំងសំរក់ទឹកភ្នែកច្រោកៗ...។ មួយសន្ទុះក្រោយមក លោកក៏ចាប់និទានរឿងរបស់លោកដូចតទៅ ៖

មុនព្រឹត្តិការណ៍ថ្ងៃទី១៧-៤-៧៥ចំនួន១ខែ ខ្ញុំត្រូវរបួសយ៉ាងធ្ងន់នៅអូរសាជាស ។ ក្រសួងកងទ័ពក៏ដឹកខ្ញុំតាមឧទ្ធម្ភាគចក្រនាំយកទៅដេកពេទ្យព្រះកេតុមាលាភ្នំពេញ ។

នៅថ្ងៃទី១៧-៤-៧៥ ម៉ោង១រសៀល អង្គការអនាមិកចេញបញ្ជាដេញអ្នកជម្ងឺ

អ្នករបួស និងអ្នកពិការចំនួន២ម៉ឺននាក់ ឲ្យចាកចេញពីមន្ទីរពេទ្យជាបន្ទាន់ ។ ខ្ញុំក៏ទប់ខ្លួននឹងឈើច្រត់ បន្លំដើរជាមួយប្រជាជនតាមផ្លូវជាតិលេខ១ មានបំណងរត់គេចទៅកាន់ប្រទេសវៀតណាមខាងត្បូង ។ ពេលនោះតាមផ្លូវជាតិលេខ១ មានប្រជា-ជននិងឡានយ៉ាងណែនណាន់តាន់តាប់ចៀសគ្នាមិនរួច ។ នៅថ្ងៃទី២-៥-៧៥ ខ្ញុំក៏ទៅដល់ភូមិអ្នកលឿង ខ្ញុំទទួលពត៌មានថា យួនហាណូយសំរេចជោគជ័យគ្រប់គ្រងប្រទេសវៀតណាមទាំងមូលជាស្រេច ។ ដូច្នេះខ្ញុំត្រូវតែពួនលាក់ខ្លួនសំណាក់នៅភូមិនេះសិន ។ ខ្ញុំភរក្រុមខ្មែរក្រហមថា ខ្ញុំជាគូលីស៊ីឈ្នួលចាប់ត្រី ចាប់អន្ទង់តាមឡូត៍នេសាទនៅឆ្នុកទ្រូ ។ ខ្ញុំក៏ភរបន្ថែមថា កំពុងចាប់ត្រីស្រាប់តែមានគ្រាប់កាំភ្លើងមួយហើរមកចំភ្លៅខ្ញុំ ខ្ញុំក៏មានរបួសយ៉ាងធ្ងន់នេះ ។ ខ្ញុំចេះព្រោកប្រាជ្ញតាមថានៈជាជើងឈ្នួល ជាគូលី ញ៉ាំងឲ្យវាជឿគ្មានសង្ស័យថា ខ្ញុំជាមេទាហានឡើយ ។ ខ្ញុំមានទេពកោសល្យចេះល្បិចចាប់អន្ទង់យ៉ាងប៉ិនប្រសប់ ។ ខ្មែរក្រហមក៏ដាក់ទិសខ្ញុំឲ្យចាប់អន្ទង់នៅមាត់ទន្លេជិតកំពង់ចម្លងអ្នកលឿង ដែលជាផ្លូវចេញចូលពីស្រុកខ្មែរទៅព្រៃនគរ...

ក្នុងឆ្នាំ១៩៧៥ ខ្ញុំបានឃើញដោយផ្ទាល់ភ្នែកនូវពួកនាយទាហានវៀតកុង ចូលមកកាន់ប្រទេសកម្ពុជា ដើរប្រមូលអាណិកជនយួន ដឹកនាំទៅកាន់ស្រុកវាជាហូរហែរ ។

រាល់ៗយប់ខ្ញុំបានឃើញឡាន Peugeots 404 និង Mercedès ជាច្រើនរយគ្រឿងតំរៀបជាជួរ ចាំបរចុះក្នុងសាឡាងនៅព្រែកអ្នកលឿង ដើម្បីឆ្លងទន្លេបញ្ជូនទៅកាន់ស្រុកយួនជាហូរហែរ ។

ចាប់តាំងពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៧ រាល់ៗយប់មានឡានកាម៉្មុងជាច្រើនបិទបាំងគ្របជិត ដឹកទ្រព្យសម្បត្តិនគរខ្មែរមកឈប់កកកុញរង់ចាំចុះសាឡាងនៅកំពង់ចម្លងអ្នកលឿង ដើម្បីដឹកឆ្ពោះទៅទិសតែមួយ ។

នៅចុងឆ្នាំ១៩៧៧ ជារៀងរាល់ថ្ងៃ ខ្ញុំតែងឃើញឡានកាម៉្មុងជាច្រើន ដឹកឈើមានទ្វារ បង្អួច តុ ទូ កៅអី ក្តារខៀន ។ ឡានទាំងនោះគ្មានបិទបាំងអ្វីទេ ខ្ញុំអាចមើលឃើញច្បាស់ៗនូវឥវ៉ាន់អស់នោះ ដែលពួកវាដឹកយកទៅជាហូរហែរ...

ពេលនោះយាយទៀងចាប់ដៃក្មួយព្រមទាំងនិយាយថា ៖

- គឺព្រោះតែយ៉ាងនេះហើយ បានជាអង្គការចេញបញ្ជាដេញប្រជាជនខ្មែរក្នុងមួយនគរឲ្យថយចេញពីទីលំនៅ និងថយឲ្យឆ្ងាយជាង២គ.ម.ពីផ្លូវជាតិ និងពីដងស្ទឹង ។ ឱ ! ខ្មែរបានលះបង់ចោលទ្រព្យសម្បត្តិយ៉ាងច្រើនឥតគណនា ដើម្បីទុកឲ្យយួនទេតើ ! ។

អង្គការប្រើស្នៀតនេះប្រសើរណាស់ ។ រួចវាបញ្ជូនវៀតកុងជាក្រុមៗ ខ្លះដើរ

ប្រមូលទ្រព្យសម្បត្តិនគរខ្មែរ ប្លន់ដឹកជញ្ជូនទៅកាន់ស្រុកយួនដោយសេរី ។ ផែនការរបស់យួនវៀតមិញព្រាងទុកប្លន់ទ្រព្យសម្បត្តិនៃប្រទេសខ្មែរនេះ មីងបានដឹងច្បាស់តាំងពីឆ្នាំ១៩៨៨មកម្ល៉េះ ដែលវាបាននិយាយថា ៖

- បើធ្វើសង្គ្រាមជាមួយខ្មែរ ឈ្នះបានធ្វើស្តេច ចាញ់បានធ្វើជាសេដ្ឋី ។

បច្ចុប្បន្ននេះ យួនហាណូយពួនតែក្នុងទីងងឹត ដោយប្រើតែឈ្មោះអង្គការ វាអាចប្លន់ទ្រព្យសម្បត្តិនគរខ្មែរយកទៅធ្វើជាសេដ្ឋីបានមែន ។ វាសំរេចផែនការរបស់វាបានយ៉ាងស្អាត ព្រមទាំងលាក់ការណ៍បានយ៉ាងជិតដដែល...

លោកអតីតវរៈសេនីយ៍ទោគីម-ហួរចាប់ដៃម្តាយមីងច្របាច់ស្រាលៗ ព្រមទាំងបញ្ជាក់ថា ៖

- ខ្ញុំក៏យល់ដូចមីងអញ្ចឹងដែរ... ដូច្នេះខ្ញុំសន្និដ្ឋានថា អង្គការអនាមិកគឺយួនហាណូយ ។

ពេលនោះមានកូនចៅរបស់លោកគីម-ហួរ៧នាក់ក៏ចូលមកដល់ បាននាំយកមកជាមួយនូវម្ហូបចំណី ដើម្បីស្រស់ស្រូបបាយល្ងាចនៅក្បែរកូនខ្ទមយាយទៀង ។

ចំណែកលោកគីម-ហួរ បែរមកខ្សិបមីងទៀងថា ក្រុមលោកមានគ្នា៣៦នាក់ស្ម័គ្រចិត្តវិលត្រឡប់មកកាន់ប្រទេសខ្មែរ ដើម្បីរៀបចំផែនការកំទេចយួនហាណូយ ដើម្បីរំដោះទឹកដីកម្ពុជា ។

នៅខេត្តបាត់ដំបង ក្រុមខ្ញុំមានបំណងសូមចាត់តែងតាំងមីងជាប្រធានសម្ងាត់ជាខ្សែរយៈសំរាប់ក្រុមខ្ញុំចេញចូល ។ រណសិរ្សនេះគេឲ្យឈ្មោះថា រ.ជ.រ.ប.ខ. ដែលមានលោកសឺន-សានជាប្រធាន ។ ឥឡូវនេះយើងមានបណ្តុះខ្សែរយៈពាសពេញប្រទេសខ្មែររួចហើយ ។ មេៗដឹកនាំសុទ្ធតែជាស្រីៗ ។ នៅខេត្តបាត់ដំបងនេះក្រុមខ្ញុំមាមសេចក្តីសង្ឃឹមយ៉ាងមាំពីចម្ងាយចំពោះមីង... លោកគីម-ហួរសម្លឹងម្តាយមីងចាំស្តាប់ចម្លើយ...

យាយទៀងឆ្លើយភ្លាមដោយមិនបាច់គិត ៖

- ក្មួយសំឡាញ់មីងអើយ ! មីងស្តាយណាស់នូវសេចក្តីស្នើនេះ តែមីងមិនទទួលទេ ។

សេចក្តីបដិសេធរបស់មីងទៀង ញាំងឲ្យលោកគីម-ហួរឆ្ងល់យ៉ាងខ្លាំង ។ ព្រោះលោកធ្លាប់ដឹងចិត្តគំនិតមីង ដែលជាស្ត្រីម្នាក់ធ្លាប់ដុះសតិសម្បជញ្ញៈយ៉ាងមុតស្នេហាជាតិ ជាពិសេសគាត់ចេះជួយខ្មែរកម្ពុជាក្រោម គាត់ស្គាល់ច្បាស់សត្រូវស្បូវពូជរបស់ខ្មែរ ។ តែហេតុម៉េចពេលនេះ ក៏គាត់មិនជួយឧបត្ថម្ភរជរបខអញ្ចឹង ?

លោកគីម-ហួរកំពុងឆ្ងល់ ស្រាប់តែយាយទៀងទូន្មានថា ៖

- ក្មួយសំឡាញ់មីងអើយ ! កុំអាលបណ្តើរគ្នាដើរចូលអន្ទាក់ខ្មាំង ! យើងមិន

អាចធ្វើការប្រឆាំងចំពោះយួនហាណូយនៅក្រោមច្រមុះវាងាយៗយ៉ាងនេះបានទេ ព្រោះវាមានកលល្បិចក្រឡិចក្រឡុចណាស់ ។ មើលចុះ ! យើងឮតែថាខ្មែរច្បាំងជាមួយខ្មែរ ! យើងឃើញតែខ្មែរក្រហមសម្លាប់ខ្មែរ... ស្រាប់តែយួនហាណូយចូលមកលុកលុយប្រទេសខ្មែរ បានយ៉ាងងាយដូចបេះផ្លែពុទ្រាទុំទៅវិញ ។ គឺវាប្រើតែកលល្បិចគ្មានឈប់គ្មានឈរ...

ពេលនោះបរិយាកាសសែនអាប់អួរ មីងនិងក្មួយធ្វើមុខស្មើរៀងៗខ្លួន...ចំណែកអ្នកអង្គុយស្តាប់ទាំងអស់ក៏គ្មាននរណាពេញចិត្តចំពោះយោបល់របស់យាយទៀងទេ ។

គ្រប់ៗគ្នាមានទឹកមុខស្ងួត ។ យាយទៀងចាប់ដៃក្មួយគឹម-ហួរ ព្រមទាំងនិយាយវែកញែកបន្តទៅទៀតថា ៖

- នេះ ! ជាដំបូន្មានរបស់មីងចំពោះក្មួយគឹម-ហួរផ្ទាល់ មិនមែនមីងនិយាយជាផ្លូវការទេ !... ពីព្រោះក្នុងគ្រួសាររបស់យើង មនុស្សចាស់ៗអ្នកចេះដឹង ត្រូវអង្គការសម្លាប់ចោលខ្ទេចអស់ទៅហើយ គឺនៅសល់តែមីងនិងក្មួយនេះទេ ។ ដូច្នេះយើងត្រូវតែចេះប្រុងប្រយ័ត្នរក្សាជីវិតសិនណា៎ ។ល។

យាយទៀងស្ងេះត្រឹមហ្នឹង គាត់ក៏ក្រោកដើរទៅរៀបបាយទឹកជូនក្មួយៗពិសារ ។ លុះបាយល្ងាចរួច ម៉ោងប្រហែល៦កន្លះ ក្រុមស្ម័គ្រចិត្តហ៊ានធ្វើពលិកម្មបូជាជីវិតដើម្បីរំដោះទឹកដីកម្ពុជាពីយួន ក៏សុំលាយាយទៀង រួចបំបែកជួរទៅកាន់ទីដៅរៀងៗខ្លួន ។ ពេលនោះមានយុវជនពីរនាក់ក្មេងៗ មិនទាន់សុំលាយាយទៀងទេ បែរជាសម្លឹងមុខគាត់ព្រមទាំងស្តីប្រមាថគាត់ថា ៖

- បើមីងមិនជួយចូកជួយចែវទេ សុំកុំយកជើងរាទឹកណា៎ ! ។

យាយទៀងមិនអាក់អន់ចិត្តនឹងពាក្យផ្ដើនខ្វះការគួរសមនេះទេ ។ គាត់ញញឹមជំនួសពាក្យចម្លើយ ហើយក៏នឹកក្នុងចិត្តសរសើរថា ៖

- នេះបានចំជាអ្នកស្នេហាជាតិពិតមែន ៖ ហ៊ានថាហ៊ានធ្វើ ! ប៉ុន្តែគួរឲ្យស្តាយណាស់ សង្ស័យតែបណ្តើរគ្នាចូលក្នុងអន្ទាក់ខ្មាំងទេដឹង ? អ៊ូ ! នេះមកតែពីគ្នាខ្វះការពិសោធន៍ មិនដែលស្គាល់ថ្នាំក្តៅ មិនដែលស្គាល់កលល្បិចយួនហាណូយ...

ចំណែកលោកអតីតវរៈសេនីយ៍ទោគឹម-ហួរ អង្គុយផ្ទាល់ដី ឱបក្បាលជង្គង់កំប្រុនៗ សម្លឹមមើលមុខយាយទៀងរបស់លោកមួយសន្ទុះធំ កំពុងពិចារណានូវពាក្យទូន្មានរបស់ម្តាយមីង ។ លោកគឹម-ហួរអាណិតមីងរបស់លោកខ្លាំងណាស់ ក៏ស្រក់ទឹកភ្នែករលីងរលោង ហើយក្រោកដើរទៅឱបម្តាយមីងព្រមទាំងជំរាបថា

- មីងជាទីគោរពអើយ ! ពិតណាស់ហើយថា យួនហាណូយមានកលល្បិចយ៉ាងល្អិតល្អន់ ខ្ញុំទទួលស្គាល់អញ្ចឹងដែរ ។ យើងមិនងាយធ្វើអ្វីៗប្រឆាំងនឹងវានៅ

ក្រោមច្រមុះវាងាយៗបានទេ ។ ប៉ុន្តែមីងអើយ ! ក្មួយឈឺចិត្តណាស់ ពេលនេះក្មួយផ្សងព្រេងជាចុងក្រោយសាកលមើល ។ ព្រោះបើយើងចេះតែនៅស្ងៀមបណ្តោយឲ្យវាវាតទីយកទឹកដីស្រួលៗយ៉ាងនេះ យើងខ្មែរមានការខ្មាស់អៀនយួនហាណូយជាក្រៃលែង ។

យើងខ្មែរចេះតែនៅស្ងៀម ទើបយើងត្រូវបាត់បង់ទឹកដីកម្ពុជាក្រោមមួយនគរទៅហើយ គ្មាននរណាតដៃជាមួយវាសោះ...

មុននឹងសុំលា លោកគឹម-ហួរថ្លែងសុំទោសម្តាយមីងចំពោះពាក្យផ្តើនត្រគោះបោះបោកខ្វះការគួរសមនៃកូនចៅរបស់លោកអម្បាញ់មិញនេះ ។ មីងនិងក្មួយក៏សុំលាគ្នាទាំងទឹកភ្នែករលីងរលោងត្រឹមណោះ ។

❑ ❑

❑

នៅយប់នោះ យាយទៀងទទួលទានដំណេកមិនលក់ទាល់តែសោះ គាត់ពួនដេកក្នុងបន្ទប់បង្គន់ផ្ទាល់ថ្ម ក្បាលកើយដៃឆ្វេង ដៃស្តាំគងថ្ងាស ។ គាត់ព្រួយបារម្ភនូវការផ្សងព្រេងនៃក្មួយគឹម-ហួររបស់គាត់ ។ ម្យ៉ាងទៀត គាត់នឹកស្រមៃឡើងវិញនូវកលល្បិចរបស់អង្គការអនាមិក និងកលល្បិចរបស់យួនហាណូយ ប្រមូលយកមកប្រៀបធៀប ក៏ឃើញក៏យល់ គឺជាស្ទៀតចេញមកពីប្រភពតែមួយ...។

ឧទាហរណ៍ដូចជារបបរបស់អង្គការ ចាប់តាំងពីថ្ងៃទី១៧-៤-៧៥ ដល់ថ្ងៃទី១៩-៤-៧៩ អង្គការបង្កើតឃាតករប្រាំក្រុម រួចបំបែកដាច់ៗដោយឡែកៗពីគ្នា រួចទើបបញ្ចេញឲ្យសម្លាប់ខ្មែរជាដំណាក់ៗ និងកំណត់ពេលវេលាយ៉ាងត្រឹមត្រូវ... តើក្រុមណាត្រូវចេញនៅពេលណា ត្រូវសម្លាប់ខ្មែរធុនណា ។ល។ និង ។ល។

ចំណែកក្រុមខ្មែរក្រហមវិញ អង្គការបំបែកជា២និន្នាការគឺ ៖

★ ខ្មែរក្រហមនិន្នាការខ្មែរមាន ខៀវ-ប៉ែន ហៅមិត្តស៊ូ និងដា-ហ៊ួន ហៅមិត្តវ៉ាញ ជាដើម ។

★ ខ្មែរក្រហមនិន្នាការយួនមាន តាប៉ែត និងតាកៅជាដើម ។

អង្គការបំបែកយោធាជាពីរក្រុមគឺ ៖

★ ក្រុមទី១ មានយោធាក្មេងៗ អាយុក្រោម១៥ឆ្នាំ ដែលមានមេៗកាន់ក្តាប់ដឹកនាំ ជាអតីតចោរព្រៃ ។

★ ក្រុមទី២ យោធាស្ម័គ្រចិត្តបូជាជីវិតបំរើសម្តេចឪ មានចំនួនបួនម៉ឺននាក់ ។ ក្រោយថ្ងៃទី១៧-៤-៧៥ អង្គការចេញបញ្ជាហាមឃាត់ជាដាច់ខាត មិនឲ្យជួបបងប្អូ

នម៉ែឪ ឬប្រជាជនថ្មីឡើយ ។ ចំណែកប្រជាពលរដ្ឋខ្មែរ អង្គការបំបែកជាពីរគឺ ៖

★ ប្រជាជនចាស់ គឺប្រជាជនដែលបានបំរើអង្គការតាំងពីថ្ងៃទី១៨-៣-៧០មកម្ល៉េះ ។

★ ប្រជាជនថ្មី គឺប្រជាជនដែលអង្គការទើបនឹងបានកាន់កាប់ នៅក្រោយថ្ងៃទី១៧-៤-៧៥ ព្រមទាំងចាត់ទុកដូចជាអ្នកទោសឧក្រិដ្ឋទាំងអស់ ។

ឥឡូវយើងក្រឡេកមើលយួនហាណូយចូលមកលុកលុយរាតត្បាតប្រទេសខ្មែរ វាប្រើកលល្បិចដដែល ដើម្បីបំបែកប្រជាពលរដ្ឋខ្មែរជាច្រើនក្រុម ដើម្បីងាយគ្រប់គ្រង ។

★ ក្រុមទី១ ជាអតីតខ្មែរវៀតមិញ ឬអតីតខ្មែរក្រហមនិន្នាការយួន ដែលមានហេង-សំរិន, ហ៊ុន-សែន, ជា-ស៊ីម, តាប៉ែត ឬ ហេង-ទាវ ។

★ ក្រុមទី២ គឺអតីតខ្មែរវៀតមិញ អតីតខ្មែរក្រហមនិរតី ។ ឃើញបូជួយបរឡានដើរប្រមូលនាំយកមកបំពាក់អាវុធឲ្យឡើងវិញ រួចដាក់ឈ្មោះថា « កងកម្លាំងប្រដាប់អាវុធប្រជាជនបដិវត្តន៍កម្ពុជា » ។

★ ក្រុមទី៣ យោធាខ្មែរក្រហមក្រុមទី៣ ដែលស្ម័គ្រចិត្តកំទេចសក្តិភូមិ និងចក្រពត្តិ មេកាន់កាប់ភាគច្រើនជាជាតិយួនលួចបន្លំដាក់ឈ្មោះជាខ្មែរ បច្ចុប្បន្នវិលត្រឡប់មកតាំងមូលដ្ឋានពាសពេញព្រៃក្នុងប្រទេសខ្មែរឡើងវិញ ប្រើយីហោខ្មែរក្រហមដដែល ។

★ ក្រុមទី៤ ក្រុមកុមារឈានមុខ ដែលស្ម័គ្រចិត្តកំទេចខ្មែរក្រហម ក្រុមនេះមានអាយុពី១៨ទៅ២៥ឆ្នាំ បើគិតត្រឹមឆ្នាំ១៩៨៣នេះ ។ ខ្ញុំដឹងច្បាស់ថា សព្វថ្ងៃនេះមាន២៥ម៉ឺននាក់ ។

★ ក្រុមទី៥ ក្រុមបញ្ញវ័ន្តក្មេងៗមានសញ្ជាតិជាយួន លួចបន្លំធ្វើជាខ្មែរ ដាក់ជាឈ្មោះខ្មែរទាំងអស់ ។

★ ក្រុមទី៦ ខ្មែរឥស្លាម ក្រុមនេះសាហាវណាស់ ។

★ ក្រុមទី៧ មានចំនួន៦ម៉ឺននាក់ លាក់ខ្លួនយ៉ាងស្ងាត់ដាក់ឈ្មោះជាអាថ៌កំបាំងគឺក្រុមបង្កើកបដិវត្តន៍ ។ ក្រុមខ្មែរអាយ៉ងចំណាយថវិកាមួយថ្ងៃៗជាច្រើនលានរៀលចិញ្ចឹមក្រុមហ្នឹង ។ គឺក្រុមឃាតករអាថ៌កំបាំងទៅអនាគត ។

គួរកត់សំគាល់ អង្គការក្តី យួនហាណូយក្តី វាចូលរាតត្បាតលុកលុយប្រទេសខ្មែរ វាប្រើស្នៀតតែមួយ គឺចូលមកជាដំបូងវាមិនទាន់ទុកចិត្តខ្មែរ វាតែងតែលើកបន្តុបខ្មែរពិតៗ ដែលស៊ីជោរឲ្យធ្វើការជំនួសខ្មែរអាយ៉ងវាសិន លុះឃើញថាអស់មានគ្រោះថ្នាក់ហើយ ទើបវាចាត់កំទេចឬដកខ្មែរស៊ីជោរនោះចេញ ទើបវាដាក់ខ្មែរអាយ៉ងរបស់វាវិញ ។ល។

មើលចុះ ! អង្គការចូលលុកប្រទេសខ្មែរក្នុងរយៈ១០ខែដំបូង វាបញ្ចេញតែខ្មែរក្រហមនិន្នាការខ្មែរគឺបក្សខ្មែរក្រហមរបស់ខៀវ-សំផន និងក្រុមខ្មែរក្រហមកើតមកពីចោរ ខ្មែរក្រហមនេះស៊ីជោរលោតសម្លាប់ប្រជាពលរដ្ឋខ្មែររីវរក់ ញាំងឲ្យប្រជារាស្ត្រខ្មែរបាក់ស្បាតឈប់ហ៊ានកំរើក ទើបអង្គការបញ្ចេញងតីតខ្មែរវៀតមិញក្រុមទី១ គឺសមាជិកបក្សប្រជាជនបដិវត្តន៍ខ្មែរ ។ អង្គការចាត់តាំងជាស្រេច ជាប្រធានសហករណ៍ ជាគណៈតំបន់ បន្តមកជាតំណាងរាស្ត្រ ។ នៅចុងឆ្នាំ១៩៧៧ អង្គការឃើញរាស្ត្រខ្មែរក្លាយជាមនុស្សម៉ាស៊ីនអស់ហើយ ទើបអង្គការបញ្ចេញអតីតខ្មែរវៀតមិញក្រុមទី២ គឺកងកម្លាំងប្រដាប់អាវុធបដិវត្តន៍ឯកភាពរបស់កម្ពុជា ។ អង្គការបញ្ជាឲ្យប្រើឃីហោខ្មែរក្រហមនិរតី ។

- ក្រុមនេះមានភារកិច្ចរួមជាមួយក្រុមឃាតករអាថ៌កំបាំង ត្រូវសម្លាប់ខ្មែរក្រហមនិន្នាការខ្មែរ ត្រូវសម្លាប់គណៈរដ្ឋមន្ត្រីនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។ល។

ឥឡូវយើងត្រូវគួរក្រឡេកសម្លឹងមើលយួនហាណូយ ពេលវាចូលលុកលុយប្រទេសខ្មែរ វាអនុវត្តស្នៀតរបស់អង្គការដដែល បានត្រឹមត្រូវ បានហ្មត់ចត់ ។

នៅក្នុងឆ្នាំ១៩៧៩ យួនហាណូយចូលរាតត្បាតប្រទេសខ្មែរជាដំបូង មិនទាន់ទុកចិត្តលើខ្មែរ វាក៏អំពាវនាវរកខ្មែរអ្នកចេះដឹងសុំជួយធ្វើការវា ។ ពេលនោះមានសាស្ត្រាចារ្យជាដើមស្ម័គ្រចិត្តចូលបំរើវា ។ វាក៏ចាត់តែងតាំងជាចៅក្រសួងនានា ។

នៅខេត្តបាត់ដំបង វាចាត់តែងតាំងយុវជនខ្មែរដ៏ក្មេងម្នាក់ឈ្មោះ ស.ក.ត. អាយុប្រហែល២៧ឆ្នាំ ឲ្យធ្វើចៅហ្វាយខេត្តបាត់ដំបង ។ បងប្អូនខ្មែរយើងធ្វេសប្រហែសណាស់ ឲ្យតែមានបុណ្យស័ក្តិហើយ ក៏តាំងភ្លេចខ្លួនភ្លាម គ្មានចេះប្រើខួរក្បាលពិចារណាទាល់តែសោះ ។ ពេលនោះបរិយាកាសសែនងងឹតអន្ធកា យើងមិនទាន់ឃើញច្បាស់ថានរណាទទួលជ័យជំនះនេះទេ ? ព្រោះយើងចេញរួចពីកណ្តាប់ដៃអង្គការ យើងបែរជាចូលអន្ទាក់របស់យួនហាណូយទៅវិញ ។ យើងឃើញផ្ទាល់ភ្នែកថា បូដួយកំពុងតែប្រមូលទ្រព្យសម្បត្តិខ្មែរគ្រប់បែបគ្រប់យ៉ាងដាក់ឡានដឹកចេញដោយសេរី ។

លោកៗដែលយួនហាណូយលើកបន្តុបឲ្យធ្វើជាចៅក្រសួងនានា មានលោកខ្លះស្លូតហួស មានលោកខ្លះវាយបុកហួស ខ្លះឡើងជំនោរបុណ្យស័ក្តិ ស្រាប់រៀបការប្រពន្ធ២-៣ភ្លាម ។ ពេលរៀបការប្រពន្ធនិមួយៗ ក៏នាំមិត្តភក្តិដែលដាច់ពោះវាំជាច្រើនឆ្នាំមកហើយនោះ នាំគ្នាលោតរាំទល់ភ្លឺ ។ល។

ពេលនោះប្រាក់ខែជាអង្ករកំប៉ុងអំបិលកំប៉ុង ។ ចំណែកឯបូដួយជាយួនហាណូយស្ងាត់ច្រៀប ។ វាគោរពវិន័យនិងផែនការយ៉ាងខ្ជាប់ខ្ជួន ។ វាបណ្តោយឲ្យនាម៉ឺនខ្មែរប្រាក់ខ្មែរអង្ករកំប៉ុង-អំបិលកំប៉ុងឈ្លក់បុណ្យសិនចុះ ។

នីកៗទៅគួរឲ្យខ្លាស់អៀនយួនហាណូយជាក្រៃលែង ។ ចំណែកវាៗកំពុងសម្ងំធ្វើការសម្ងាត់របស់វា ដែលវាមានគំរោងផែនការទុកជាស្រេចរួចមកហើយ ។

មើលចុះ ! បូដូយកំពុងបើកបរឡានដើរប្រមូលអតីតខ្មែរវៀតមិញក្រុមទី១មានហេង-សំរិន, ហ៊ុន-សែន, ជា-ស៊ីម, តាប៉ែតជាដើម នាំយកទៅបំពាក់បុណ្យស័ក្តិជាលំដាប់លំដោយ ឲ្យចាត់ការសម្លាប់និងកំចាយរាស្ត្រខ្មែរជាម្ចាស់ទឹកដីពិតៗតទៅទៀត ។

បូដូយកំពុងបើកបរឡានប្រមូលអតីតខ្មែរវៀតមិញក្រុមទី២គឺក្រុមខ្មែរក្រហមនិរតី និងយោធាខ្មែរក្រហមក្មេងៗដែលសេសសល់នៅរស់ នាំយកទៅចិញ្ចឹមរួចបំពាក់អាវុធឲ្យឡើងវិញ ។ ប្រជាជនខ្លះៗខ្វះការពិចារណា បែរជាយល់ច្រឡំស្មានតែយួនហាណូយចាប់ខ្មែរក្រហមទាំងនោះនាំយកមកឃុំឃាំង ។ តាមការពិតទៅវាយកពួកនេះ មកបញ្ចូលក្នុងកងកម្លាំងប្រដាប់អាវុធប្រជាជនបដិវត្តន៍កម្ពុជាទៅវិញទេ ។

យួនហាណូយឆ្នៃប្រឌិតក្រុមនេះ ឲ្យទៅជាចោរដើរប្លន់បាញ់សម្លាប់កំចាយរាស្ត្រខ្មែរជាថ្មីម្តងទៀត សាហាវណាស់ គឺវាប្រើស្នៀតវាយទឹកកំចាយត្រី គ្មានស្នៀតអ្វីប្រសើរជាងស្នៀតនេះឡើយ ។

បើនគរខ្មែរទៅជានគររបស់ចោរយ៉ាងនេះ រាស្ត្រខ្មែរអស់សង្ឃឹមបង្ខំចិត្តត្រូវតែប្រមូលគ្រួសារដែលសេសសល់នៅរស់បន្តិចបន្តួចនោះ បណ្តើរគ្នាទៅកាន់ប្រទេសថៃ បន្សល់ទឹកដីទុកឲ្យយួនហាណូយ ។

បូដូយកំពុងបើកបរឡានដើរប្រមូលក្មេងកំព្រាខ្មែរអាយុ៨ទៅ១៤ឆ្នាំ ដែលអង្គការលត់ដំដល់កំពូលរួចហើយ ដឹកនាំចេញពីប្រទេសខ្មែរ វាប្រាប់ថា វានាំទៅរៀនសូត្រនៅហាណូយ ។

នេះក៏ជាផែនការអាថ៌កំបាំងរបស់យួនហាណូយ ខ្ញុំរ៉ាយរ៉ាប់រួចហើយក្នុងរយៈពេលមួយឆ្នាំ កលល្បិចប្រើស្នៀតចោរមានគុណភាពប្រសើរណាស់ វាឃើញថារាស្ត្រខ្មែរគ្មានប្រតិកម្ម គ្មានឧបសគ្គអ្វីរារាំងដល់វាទៀតទេ ព្រោះឃើញតែបណ្តើរគ្នាចេញចោលទឹកដីជាហូរហែរ ។ល។

យួនហាណូយក៏ចាប់ផ្តើមបញ្ចេញខ្មែរអាយ៉ងរបស់វា គ្រប់គ្រងប្រទេសខ្មែរឲ្យពេញលេញ ។

ក្នុងខែមេសាឆ្នាំ១៩៨០ យួនហាណូយបានបើកអង្គប្រជុំមួយយ៉ាងធំក្នុងវត្តរំដួល ។ អង្គប្រជុំនេះ វាចាត់អញ្ជើញចៅក្រសួងជាជាតិខ្មែរពិតៗក្នុងខេត្តបាត់ដំបងទាំងអស់ មាន ស.គ.ត. ក៏មករួមប្រជុំដែរ ។

លុះជួបជុំគ្នាស្រេចបាច់ហើយ ក៏ឃើញយួនហាណូយម្នាក់តូចទាបតឿ មិនផាត់

មិនស្គម មុខធំច្រមុះកំពិត សក់ស្លួតកាត់ខ្លី អាយុប្រហែល៤៥ឆ្នាំ ស្បៀកពាក់ខ្មៅ ស្បែកជើងកង់ឡាន ចេញមកឈរកណ្ដាលអង្គប្រជុំ រួចចាប់ផ្ដើមថ្លែងការណ៍ជាភាសាខ្មែរ លំនាំវាក្យស័ព្ទភាសាខ្មែរជំនាន់របបអង្គការអនាមិកទាំងអស់ ។

យួនហាណូយនេះប្រកាសជាឧឡារិកប្រាប់ចៅក្រសួងជាតិខ្មែរទាំងឡាយនោះ ព្រមទាំងចៅហ្វាយខេត្ត ស.គ.ត. ថា អង្គប្រជុំថ្ងៃនេះសំរាប់ដកងារចៅក្រសួងណាដែលមានប្រពន្ធពីរ សំរេចបញ្ឈប់មិត្តៗទាំងអស់នោះឲ្យមិនឲ្យធ្វើការចាប់ពីថ្ងៃស្អែកនេះទៅ ។

ពេលនោះឃើញបុរសម្នាក់ចូលមកខ្សិបជាមួយយួនជាប្រធានអង្គប្រជុំមួយសន្ទុះ ប្រធាននេះក៏ក្រឡេកភ្នែកសម្លឹងទៅតាម្នាក់ រួចលើកដៃចង្អុលព្រមទាំងសួរថា ៖ យី ! មិត្តនេះដូចជាមិនដែលឃើញ ? ។

តាមាយដែលត្រូវយួនចង្អុល ក៏មានអារម្មណ៍តក់ស្លុតស្លន់ស្លោជាយ៉ាងខ្លាំង ។ គាត់ឆ្លើយរដិបរដុប បា...ទ ! ខ្ញុំទើបមកពីជំរំខៅអ៊ីដាង ។

យួន ! វាចេះអត់ធ្មត់លាក់ពុតល្អណាស់ ។ វាបង្ហាញនូវសប្បុរសធម៌ជានិច្ចនៅចំពោះមុខប្រជាជនយ៉ាងច្រើនកុះករនេះ ។ វាសំដែងទឹកមុខញញឹម និយាយទន់ភ្លន់ទៅកាន់តាមាយថា ៖

- ឱ ! មិត្តទើបវិលត្រឡប់មក ! តើមានចុះឈ្មោះក្នុងបញ្ជីបើកអង្ករឬនៅ ? ។

យួននេះបោយដៃហៅយួនម្នាក់ ជាអ្នកកាន់បញ្ជីអង្ករ វាបញ្ជាឲ្យសួរឈ្មោះសួរទីលំនៅ រួចបើកអង្ករឲ្យតាមាយ២គីឡូ ។ ប៉ុន្តែក្រោយមក២-៣ថ្ងៃ តាមាយអភ័ព្វនេះ ត្រូវយួនហៅទៅជួប ហើយទាំងពីនោះមកត្រូវបាត់ខ្លួនរហូត...

ព្រឹកស្អែក យួនហាណូយបញ្ចេញខ្មែរអាយ៉ងរបស់វាចាត់តែងតាំងជាស្រេចជាចៅក្រសួងនានា មកជំនួសសឹងគ្រប់ៗក្រសួង ។

យួនហាណូយបញ្ចេញខ្មែរអាយ៉ងរបស់វាម្នាក់ឈ្មោះ ឡាយ-សាម៉ុន តែងតាំងជាចៅហ្វាយខេត្តបាត់ដំបងជំនួស ស.គ.ត. ។ យួននាំឡាយ-សាម៉ុនទៅអប់រំនៅហាណូយតាំងពីឆ្នាំ១៩៦៣ ។ ក្នុងរយៈ១៧ឆ្នាំ ទើបយួនបញ្ជូនឲ្យវិលត្រឡប់មកកាន់ប្រទេសកម្ពុជានៅដើមខែមេសាឆ្នាំ១៩៨០ ជាមួយប្រពន្ធជាតិយួនព្រមទាំងកូនបីនាក់ ។

តាំងពីឡាយ-សាម៉ុនឡើងជាចៅហ្វាយខេត្តមក យួនហាណូយមិនបញ្ចេញឲ្យដើរបើកអង្គប្រជុំផ្ដេសផ្ដាសទេ ។ កាលពី ស.គ.ត.នៅជាចៅហ្វាយខេត្ត គេឃើញតែដើរបើកអង្គប្រជុំពាសពេញទីក្រុងបាត់ដំបងដោយសេរី គ្មានឃើញនរណាយាមការពារឡើយ ។

ចំណែកឡាយ-សាម៉ុន ពេលបើកអង្គប្រជុំម្ដងៗ គេឃើញបុរសរត់ឆ្លេឆ្លាឈរយាមការពារយ៉ាងហ្មត់ចត់ ។ យើងតែងតែឃើញយួនហាណូយដើរបើកអង្គ

ប្រជុំ ប្រកាសតាំងខ្លួនជាតំណាងចៅហ្វាយខេត្ត រួចវាពន្យល់វែកញែកមានកំនាំវាក្យស័ព្ទដូចនៅសម័យអង្គការដដែល ។

គ្រប់ៗអង្គប្រជុំក្នុងរបបនិមួយៗ គេបង្ខំឲ្យយាយទៀងទៅអង្គុយស្តាប់ ។ ដូច្នេះ គាត់បានឃើញផ្ទាល់នឹងភ្នែក គាត់បានស្តាប់ផ្ទាល់ត្រចៀកដូចជា ៖

- នៅថ្ងៃទី២០-៤-៧៥ មិត្តស៊ូនិងមិត្តស៊ុយជាខ្មែរក្រហមនិន្នាការខ្មែរបើកមហាមីទិញនៅសាលាខេត្តបាត់ដំបង ។

- នៅថ្ងៃទី៣១-១០-៧៨ តាប៉ែតនិងមិត្តលីបើកអង្គប្រជុំនៅកងលេខ៣ ភូមិព្រៃស្វាយខាងលិច ។

- នៅថ្ងៃមួយក្នុងឆ្នាំ១៩៧៩ ស.គ.ត.បើកអង្គប្រជុំនៅវត្តរំដួល ឬវត្តលាប ។

តាមការពិនិត្យនិងប្រៀបធៀបរបស់ខ្ញុំ ស្នៀតនេះចេញមកពីប្រភពតែមួយ ។ ព្រោះអង្គការក្តី យួនហាណូយក្តី បើវាសង្ស័យថាកន្លែងណានៅមានគ្រោះថ្នាក់ វាបំពាក់បុណ្យស័ក្តិឲ្យខ្មែរពិតៗមិនដឹងខ្យល់ ស៊ីជោរ បាក់អំនួត ល្មោភអំណាច ចង់ធ្វើធំ វាបន្តុបរួចច្រានក្បាលឲ្យចលាចលកន្លែងនោះសិន ។ លុះវាឃើញថា កន្លែងនោះបានស្រួលរៀបរយគ្មានឧបសគ្គ គ្មានគ្រោះថ្នាក់អ្វីទេ វាក៏ចាត់ការដកចេញ ឬសម្លាប់ចោលភ្លាម រួចវាចោទថាអញ្ចេះឬថាអញ្ចោះ ។ ឧទាហរណ៍ដូចជាខែក-ប៉ែនហៅមិត្តស៊ូ និងស.គ.ត.ជាគំរូ ។

ម្យ៉ាងទៀតយើងគួរតែតាមដាន ។ មើលចុះ ! ទោះបីខ្មែរអាយ៉ងបំរើវាផ្ទាល់ជាខ្មែរក្នុងខ្សែរយៈរបស់វាក៏ដោយ វាបំពាក់បុណ្យស័ក្តិ ចាត់តែងតាំងធ្វើជានាម៉ឺនធំ លុះបានបុណ្យស័ក្តិ ភ្លាត់ស្នៀតភ្លេចគោរពលក្ខណ ឬភ្លេចខ្លួនបង្ហាឲ្យវាឃើញ នូវសតិសម្បជញ្ញៈស្នេហាជាតិខ្មែរពិតៗ យួនហាណូយបញ្ជាឲ្យសម្លាប់ចោលភ្លាម វាគ្មានរារែករក្សាទុកបណ្តាលឲ្យខូចផែនការរបស់វាឡើយ ។ មានជាឧទាហរណ៍ខ្លះៗជាក់ស្តែងដូចតទៅ ៖

- ចៅហ្វាយខេត្តសៀមរាប ជាខ្មែរអាយ៉ងរបស់យួនហាណូយដំណាលគ្នានឹងឡាយ-សាម៉ុន ដែលវាបានបញ្ជូនមកហើយចាត់តែងតាំងរួចជាស្រេច ជាចៅហ្វាយខេត្ត ។ លុះបានធ្វើចៅហ្វាយខេត្តហើយ គ្រាន់តែភ្លាត់ស្នៀ តរៀបការជាមួយស្រីខ្មែរក្នុងខែមីនាឆ្នាំ១៩៨០ ក្រោយបន្តិចមក យួនហាណូយក៏ចាប់ខ្លួនយកទៅបាត់ដោយចោទថាក្បត់វា ។ ចំណែកឯឡាយ-សាម៉ុន យាយទៀងបានទទួលពត៌មានតាមលោកគ្រូបង្រៀនម្នាក់ ដែលភៀសខ្លួនមកដល់ប្រទេសបារាំងនៅចុងឆ្នាំ១៩៨៥ថា យួនហាណូយចាប់ខ្លួននៅដើមឆ្នាំ១៩៨៤ ដោយចោទថាក្បត់វាដែរ ។ កាសែតឈ្មោះ«ស្រុកខ្មែរ» លេខ១៥ ចុះថ្ងៃទី១-១-៨៦ ក៏ឃើញមានចុះផ្សាយពីរឿងយួនចាប់ខ្លួនឡាយ-សាម៉ុននេះដែរ ។

នៅទីក្រុងបាត់ដំបង យួនហាណូយបង្កើតជំរំពីរធំៗ សំរាប់ចិញ្ចឹមខ្មែរក្រហមនិរតី ដែលជាអតីតខ្មែរវៀតមិញក្រុមទី២ ។

– ជំរំទី១ស្ថិតនៅក្នុងបរិវេណអតីតធនាគារឥណ្ឌូចិន ដែលតាំងនៅក្បែរមន្ទីរពេទ្យធំទីក្រុងបាត់ដំបង ។

– ជំរំទី២ស្ថិតនៅក្នុងបរិវេណកុងស៊ីស្រា តាន់-ប៉ាក់ តាំងនៅជិតផ្សារលើ ។ មួយថ្ងៃៗ មានរៀបបាយម្ហូបឲ្យស៊ីពីរពេលយ៉ាងគ្រប់គ្រាន់ ។ រាល់ៗម៉ោង៣រសៀល ខ្មែរក្រហមទាំងឡាយនោះបណ្ដើរគ្នាចុះទៅងូតទឹកស្ទឹង ហែលលោតលេងយ៉ាងសប្បាយ ។

ចំណែកប្រជាពលរដ្ឋខ្មែរជាម្ចាស់ទឹកដីកម្ពុជាពិតៗ ដែលត្រូវទទួលរងគ្រោះត្រូវប្រាស់ព្រាត់អស់គ្រួសារ គឺភាគច្រើនត្រូវព្រាត់ស្លាប់ ។ គឺខ្មែរក្រហមនិរតីនេះជាអ្នកសម្លាប់ ។ ឥឡូវគ្រប់ៗរូបកំពុងអត់បាយ អត់ទីជំរក ។ ផ្ទុយទៅវិញហេតុម្ដេចខ្មែរក្រហមនិរតីជាឃាតករ បែរជាមានការឧបត្ថម្ភទំនុកបំរុងពីយួនហាណូយ បានទទួលសេចក្ដីសុខប្រសើរជាងខ្លួន ? ។ គួរឲ្យចម្លែកណាស់ៗ ! ក៏បបួលគ្នាទៅឈរមើលខ្មែរក្រហមកំពុងស៊ីបាយ កំពុងលោតលេងហែលទឹកស្ទឹងយ៉ាងសប្បាយ ។ ប៉ុន្តែត្រូវបូដូយជាអ្នកឈរយាមខ្មែរក្រហមនោះ ដេញឲ្យថយចេញ ។ ដូច្នេះរាស្ត្រខ្មែរខឹងនិងក្ដៅក្រហាយណាស់ ក៏ជន្ទាលស្រែកជេរពីចម្ងាយ ។ល។ ចំណែកខ្មែរនិរតីវាសើចធ្វើព្រងើយ ព្រមទាំងឆ្លើយចំអកឲ្យថា ៖

– មិត្តអើយជេរសិនចុះ ! តែដល់មិត្តត្រឡប់ទៅផ្ទះ ឬទៅខ្ទមវិញ កុំភ្លេចលាងក្រឡរង់ចាំណា៎ ! ព្រោះយើងត្រូវទៅធ្វើផ្អកសាច់មនុស្សមួយលើកទៀតណា៎... មិត្តៗយើងមកសំរាកឲ្យមានកម្លាំងសិនទេណា៎ ! ។

ក្នុងខែកក្កដាឆ្នាំ១៩៧៩ ថ្ងៃមួយមានបុរសម្នាក់លីដាវមួយយ៉ាងមុត ទៅពួកលបឈរនៅត្រើយស្ទឹងខាងកើត សម្លក់សម្លឹងខ្មែរក្រហមនិរតីកំពុងងូតទឹកស្ទឹងនៅមុខកុងស៊ីស្រាតាន់ប៉ាក់ ។ មួយសន្ទុះក៏លោតចុះទៅក្នុងស្ទឹង កាប់មេខ្មែរក្រហមនិរតីម្នាក់ដាច់ក្បាលធ្លាក់ពីលើស្មាស្លាប់ភ្លាមមួយរំពេច ពីព្រោះបុរសនេះស្គាល់មេខ្មែរក្រហមនេះច្បាស់ថាជាឃាតករដ៏សាហាវឃោរឃៅ ដែលបានចាប់ចងឪពុកម្ដាយបងប្អូនរបស់គាត់ទាំងអស់នាំយកទៅសម្លាប់ចោល ។ ក្នុងគ្រួសាររបស់គាត់ មានតែគាត់ម្នាក់គត់រត់គេចសល់នៅរស់នេះ ។

កន្លងផុតតែបីបួនថ្ងៃ មានស្រីចាមម្នាក់ឈ្មោះ យ៉ាស ។ ស្រីនេះតែងតែទៅឈរលួចមើលខ្មែរក្រហមងូតទឹកនៅមុខជំរំអតីតធនាគារឥណ្ឌូចិន ។ នាងយ៉ាសបានឃើញមេខ្មែរក្រហម និងស្គាល់ច្បាស់ក្រុមនិរតីម្នាក់ ជាឃាតករយ៉ាងសាហាវ

ដែលចាប់ចងប្ដីឪម៉ែបងប្អូនរបស់នាងនាំយកទៅសម្លាប់ចោលទាំងអស់ ។ ក្នុងគ្រួសាររបស់នាង មានតែនាងម្នាក់ឯងគត់រត់រួចសល់នៅរស់ ។ នាងយ៉ាសកាន់គល់ពីងពង់មួយ រួចទៅឈររង់ចាំនៅត្រង់ផ្លូវឡើងច្រាំងស្ទឹងត្រើយខាងលិចក្រោមដើមស្វាយធំពីរដើម ចំកាច់ជ្រុងមន្ទីរពេទ្យធំបាត់ដំបង ។

លុះមេខ្មែរក្រហមជាឃាតករឡើងពីស្ទឹងមកដល់កន្លែងនោះ នាងយ៉ាសវាយសំពងស្លាប់ភ្លាមមួយរំពេជ ។

ចំណែកយួនហាណូយដឹងរឿងនេះភ្លាម ក៏ឆ្លេឆ្លាបើកអង្គប្រជុំនៅគ្រប់ៗទីប្រជុំជនភ្លាម ។ យាយទៀងត្រូវបានគេហៅឲ្យទៅអង្គុយស្ដាប់ក្នុងអង្គប្រជុំមួយឯវត្តរំដួល ។

ប្រធានអង្គប្រជុំជាយួនហាណូយ រាងទាបតឿ មុខធំ ច្រមុះកំពិត សក់កាត់ខ្លី អាយុប្រហែល៤៥ឆ្នាំ ។ វានិយាយវែកញែកជាភាសាខ្មែរយ៉ាងច្បាស់ថា ៖

- យើងវៀតណាមស្ម័គ្រចិត្តបូជាឈាមស្រស់សាច់ស្រស់ ខំធ្វើពលិកម្មមកជួយបងប្អូនខ្មែរ ខំធ្វើអន្តរាគមន៍ឲ្យឈប់កាប់សម្លាប់គ្នា ប៉ុន្តែមានបងប្អូនខ្មែរខ្លះៗមិនទាន់ជំរុះឬលះបង់ដាច់ស្រឡះនូវគំនុំផ្ទាល់ខ្លួន នូវការឈឺចាប់នានា នៅតែចងសងសឹកគ្នាទៅទៀត គួរឲ្យស្ដាយណាស់ ។ ពេលនេះ យើងខ្ញុំវៀតណាមសុំអង្វរចិត្តបងប្អូនខ្មែរ សុំតាំងចិត្តអត់ឱនគ្នា ត្រូវចេះលះបង់គំនុំផ្ទាល់ខ្លួន ដើម្បីកសាងកម្ពុជាថ្មី ។ បើនៅតែបន្តការសម្លាប់សងសឹកគ្នាអញ្ចឹងទៅទៀត ...អស់ហើយខ្មែរ ។

យួនហាណូយទូន្មានដូច្នេះ គឺប្រមាថខ្មែរយើងជាក្រៃលែង ។ យើងខ្មែរនឹកទៅគួរឲ្យខ្មាស់អៀនវាណាស់ ! ។ ការពិតវាចូលមកពង្រឹងពង្រីក បំពាក់គោលជំហរ ជំរុញអតីតខ្មែរវៀតមិញជាអាយ៉ងរបស់វា ឲ្យសម្លាប់កំចាយរាស្ត្រខ្មែរជាម្ចាស់ទឹកដីកម្ពុជាពិតៗទេតើ ។

លុះមានកើតអព្ភូតហេតុកាប់សម្លាប់ខ្មែរក្រហមនិរតីពីរនាក់យ៉ាងនេះ យួនហាណូយបញ្ជាឲ្យបូដូយយកម៉ាស៊ីនបូមទឹកពីស្ទឹងមកដល់ជំរំ ឲ្យខ្មែរក្រហមទាំងអស់នោះប្រើប្រាស់ ងូតលេងសប្បាយតាមចិត្ត ។ បន្តមកយួនហាណូយបំពាក់ឲ្យឡើងវិញទាំងអស់ រួចបញ្ចូលទៅក្នុងកងកម្លាំងប្រដាប់អាវុធប្រជាជនបដិវត្តន៍កម្ពុជា ដែលមានប៊ូ-ថង ជាមេបញ្ជាការ ។

*ដូច្នេះសូមបងប្អូនខ្មែរជ្រាបថា ឃាតករនៅរស់ហើយក្ដាប់អំណាចដដែលរហូតមកដល់សព្វថ្ងៃនេះ ។ មេបញ្ជាការរបស់ពួកវា គឺយួនហាណូយ ដែលចូលមកជំនួសអង្គការ បន្ទាប់ពីបានដូរឈ្មោះបន្លំជានត្រឡប់ត្រឡិន ថាជាក្រុមខ្មែរស្នេហាជាតិវិញ ! ។*

នៅបច្ចុប្បន្ននេះ ការប្រកាសតាមវិទ្យុក្ដី ការសរសេរចុះផ្សាយក្នុងកាសែតក្ដី ព

កវានិយាយច្រំដែលៗថា ជាក្រុមខ្មែរស្នេហាជាតិ ។ ប៉ុន្តែគំរោងព្រាងផែនការទុកអនុវត្តកំចាយសម្លាប់បំផុតពូជខ្មែរជាម្ចាស់ទឹកដីកម្ពុជាពិតៗ នៅតែបន្តទៅទៀតដ-ដែល ។ ប៉ុន្តែម្តងនេះទៀត វាបញ្ចេញស្នៀត «វាយទឹកកំចាយត្រី» ។

វាបំពាក់អាវុធឲ្យក្រុមអតីតខ្មែរក្រហមនិរតីឡើងវិញ ។ មុនដំបូងវាមិនទាន់ឲ្យប្រាក់ខែទេ ។ ទំនិញនានាលក់ទិញដោយសេរី តែគេចាយជាមួយមាស ។ ដូច្នេះមាសនៅតែមានតម្លៃដដែល ។

មូលហេតុនេះក៏រុញច្រានក្រុមអតីតខ្មែរក្រហមនិរតីដែលកាន់អាវុធនោះ ឲ្យក្លាយទៅជាចោរដោយស្វ័យប្រវត្តិ ។

យប់នោះយាយទៀងដេកមិនលក់សោះ គាត់រវើរវាយមមើមមាយទល់ភ្លឺ ។

ព្រលឹមថ្ងៃទី១៩-៥-៨០ យាយទៀងកំពុងច្រោយដីតាមដើមពោត ស្រាប់តែគាត់ភ្ញាក់រន្ធត់ស្មារតី ដោយឃើញបងប្អូនខ្មែរបណ្តើរគ្នាហែរកបិនយ៉ាងច្រើនលើសលប់ ចេញចោលស្រុកខ្មែរមួយលើកទៀត ។

យាយទៀងអស់សង្ឃឹម គាត់ក៏អង្គុយលើដងចបកណ្តាលចំការពោតរបស់គាត់ ថ្ងូរតិចៗដំអូញថា ៖

- ឱ ! បងប្អូនខេមរជាតិអើយ ! យើងមុខក្លាយជាចាម ដើរសុំជ្រកកោនមួយកម្ពោតនៅនគរនេះ មួយកម្ពោតទៀតនៅនគរនោះហើយ ! ។

យប់នោះយាយទៀងរវើរវាយ ស្រមើស្រមៃដូចយប់មិញអញ្ចឹងទៀត គាត់នឹកឃើញកលល្បិចរបស់អង្គការអនាមិក និងកលល្បិចរបស់យួនហាណូយវាប្រើគ្រប់មធ្យោបាយ គឺវាធ្វើយ៉ាងម៉េចក៏ដោយ ឲ្យតែប្រជាពលរដ្ឋខ្មែរ ដែលជាម្ចាស់ទឹកដីពិតប្រាកដ ដល់ស្លាប់និងរត់ចោលស្រុកឲ្យអស់ទុកដីឲ្យវា ។

ចំណែកភ្នែករបស់គាត់សម្លឹងភ្លឹកមើលបងប្អូនខ្មែរ កំពុងបណ្តើរគ្នាដើរចេញចោលទឹកដីទុកឲ្យយួនហាណូយជាហូរហែរ ទៅកាន់ប្រទេសថៃ « មិនមែនរត់គេចទេ គឺដើរចាកចេញដោយសេរី ! » ។ ដូច្នេះបញ្ជាក់ឲ្យឃើញថា គ្រោះថ្នាក់នៃប្រទេសកម្ពុជា នៃប្រជាពលរដ្ឋខ្មែរនៅពេលនេះធ្ងន់ក្រៃលែងធ្ងន់ លើសលប់ជាងពេលណាៗទាំងអស់ ។

ពេលនោះយាយទៀងពួសម្រិបជើងដើរក្រោយខ្នងគាត់ៗក៏បែរភ្នែកសម្លឹងមើល ។ គាត់ក៏ឃើញតាម៉ុកដើរចូលមកទាំងទឹកមុខប្រពាប់ស្រពោន ស្លន់ស្លោរខុសប្លែកពីលើកមុនៗ ។ ជារឿយៗតាម៉ុកចូលមករកយាយទៀង គាត់តែងតែនិយាយរាក់ទាក់ពីចម្ងាយសួរសុខទុក្ខ ញញឹញញញែម កំប្លែងសើចលេង ដើម្បីលើកទឹកចិត្តលួងលោមយាយទៀង ថែមទាំងទូន្មានថា យើងជាអ្នកកាន់ពុទ្ធសាសនាត្រូវតែយកធម៌ព្រះពុទ្ធមកគោរពពិចារណា គឺជីវិតមនុស្សឬសត្វមិនទៀងទាត់ឡើយ ។

កើតរួចស្លាប់...គ្រាន់តែមុនឬក្រោយ...

គាត់សុំយាយទៀងរំងាប់ចិត្តឲ្យនឹងនរ ដូចទើបចាប់កំណើតជាថ្មី ត្រូវទ្រាំនៅក្នុងទឹកដីកម្ពុជាជាមួយក្រុមគាត់ ដើម្បីធ្វើជាម្ចាស់ទឹកដីកម្ពុជា ។ល។

គួរឲ្យចម្លែកណាស់ ថ្ងៃទី១៨-៥-៨០ នេះមុខតាម៉ុកស្ងួត គ្រវីក្បាលពីចម្ងាយដើរមកដល់ក៏ចាប់ដៃយាយទៀង បណ្តើរទៅអង្គុយមុខកូនខ្ទមរួចនិយាយខ្សឹបៗ ថា ៖

- ខ្ញុំមកបបួលបងរត់ចេញពីស្រុកខ្មែរ !

យាយទៀងឮដូច្នេះក៏បើកភ្នែកយ៉ាងធំហារមាត់ជង្រ្គុងតក់ស្លុត ស្រាលខ្លួនដូចសំឡី គ្មានសំនួរគ្មានចម្លើយ...

តាម៉ុកនិយាយបន្តថា ៖

- ខ្ញុំចំណាយមាន៣ជំឡឹង រៀបចំឡានកាម៉្យុងមួយគ្រឿង ដើម្បីរត់ឈ្នួលពីបាត់ដំបងទៅកាន់រដ្ឋធានីភ្នំពេញ ។ ខ្ញុំក៏ធ្វើដំណើរទៅកាន់ភ្នំពេញដើម្បីសុំច្បាប់អនុ-ញ្ញាតចរាចរពីក្រសួងមានសមត្ថកិច្ច ។ គេបដិសេធព្រោះហាមមិនឲ្យមានឡានរត់ស៊ីឈ្នួលជាឯកជនឡើយ ។ ខ្ញុំក៏ទៅជួបមិត្តរបស់ខ្ញុំម្នាក់ឈ្មោះតាប៉ែត បច្ចុប្បន្នប្រែឈ្មោះជា ហេង-ទាវ ជានាម៉ឺនធំប្រចាំការក្នុងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

តាប៉ែតក៏នាំខ្ញុំទៅទទួលទានម្ហូបដ៏ឆ្ងាញ់របស់គេ គឺផ្ទីរនិងត្រកួនស្ងោរ ដែលមានអំបិលបង់យ៉ាងគ្រប់គ្រាន់ ។

លុះបាយល្ងាចរួចហើយ ខ្ញុំក៏ដេកនៅកន្លែងតាប៉ែតមួយយប់ ។ មុនចូលដេកតាប៉ែតក៏ថ្លែងអួតមហាជោគជ័យដែលបក្សកុម្មុយនិស្តវៀតណាមចិនខំព្យាយាមវាតទីយកទឹកដីកម្ពុជាតាំងពីជាង៣០ឆ្នាំមកហើយ ទើបនឹងបានសំរេចបានមួយជំហានដ៏ធំធេងនៅពេលនេះ ។

តាម៉ុកនិយាយបន្តទៀតថា ៖

- ពេលនោះខ្ញុំភ្ញាក់ក៏សួរបញ្ជាក់តាប៉ែតថា បើអញ្ចឹងហេង-សំរិន, ហ៊ុន-សែន, ជា-ស៊ីមជាដើម.. គឺជាអតីតខ្មែរវៀតមិញដែរឬ ? ។

តាប៉ែតសើចហះៗឆ្លើយឡើងថា ៖

- អ្នកធំៗធ្វើការក្នុងរដ្ឋាភិបាលសព្វថ្ងៃគឺជាអតីតខ្មែរវៀតមិញទាំងអស់ ។

ខ្ញុំឮដូច្នេះសឹងគាំងបេះដូងស្លាប់តែម្តង ។ ណ្ហើយចុះ ឈប់គិតរឿងជាតិ យើងគិតរឿងផ្ទាល់ខ្លួនម្តងវិញ ។ ខ្ញុំសុំពឹងតាប៉ែតឲ្យជួយធ្វើអន្តរាគមន៍រឿងសុំអនុញ្ញា-តចរាចរឡានរកស៊ីឈ្នួលនោះ ។

តាប៉ែតបើកភ្នែកធំៗសម្លឹងមើលមុខខ្ញុំ ព្រមទាំងសួរថា ៖

- ឡានអីម៉ុក ? ។

ខ្ញុំក៏អធិប្បាយអំពីគោលបំណងរបស់ខ្ញុំនោះ ។

តាប៉ែតធ្វើមុខស្លុតដោយអាណិតខ្ញុំជាមនុស្សភ្លើ មិនដឹងខ្យល់ មិនយល់ស្ថានការណ៍ ។ មួយសន្ទុះធំតាប៉ែតវែកញែកថា ៖

- ម៉ុកអើយ ! របបសព្វថ្ងៃគឺដូចតែរបបអង្គការដដែល ។ គេគ្រាន់តែកែទម្រង់បន្តិចៗតាមកាលៈទេសៈតែប៉ុណ្ណោះ ។;

ពេលនោះ ខ្ញុំក្តី តាប៉ែតក្តីគាំងមាត់ឈប់និយាយឈប់មានយោបល់តទៅទៀត ព្រលឹមស្អែកឡើង ខ្ញុំក៏សុំលាមិត្តរបស់ខ្ញុំវិលត្រឡប់មកកាន់ទីក្រុងបាត់ដំបងវិញ ។ ស្តាយអើយសែនស្តាយមាសពជំឡឹងនោះ ! ។

លុះមកដល់ខ្ទមរបស់ខ្ញុំនៅចំការសំរោង ពុទ្ធោអើយ ! ប្រពន្ធរបស់ខ្ញុំត្រូវចោរចូលមកប្លន់អារកសម្លាប់ទៅហើយ ! ។

ពេលនោះយាយទៀងថ្ងូរ ៖

- ឱ ! ពុទ្ធោៗ !

តាម៉ុកនិយាយបន្ត ៖

- ល្ងាចម្សិលមិញនេះ ខ្ញុំទទួលដីការកោះពីបូដូយ បញ្ជាឲ្យខ្ញុំចូលខ្លួនជាបន្ទាន់ គេចាត់តែងតាំងខ្ញុំជាតិញសម្ងាត់ គឺត្រូវដើរយកការណ៍ឲ្យបូដូយ ។ ព្រោះវាត្រូវតែដឹងថា តើប្រជាជនខ្មែរនៅទីក្រុងបាត់ដំបង ជាពិសេសខ្មែរធ្វើការជាមួយយួនសព្វថ្ងៃ តើពីដើមជានរណា ? ធ្លាប់ធ្វើការអ្វី ? តើនរណាជាអតីតអ្នករដ្ឋការ ? នរណាជាខ្មែរក្រហម ? ម៉្យាងទៀតវាខំស្រាវជ្រាវរកមុខសមាជិកហ្វូល្ស៊ី ។

ពេលខ្ញុំចូលទៅជួបសក្តិបួនយួននោះ ខ្ញុំធ្វើជាស្ម័គ្រចិត្តទទួលមុខងារនេះយ៉ាងរីករាយ ។ ខ្ញុំត្រូវតែញញឹមផ្គាប់ចិត្តវាសិន ។ តែឥឡូវនេះខ្ញុំទើបទទួលទទួលពត៌មានមកថា អតីតអ្នករដ្ឋការបានបាត់ខ្លួនជាបន្តបន្ទាប់គ្នា ។ ខ្ញុំភ្លេចមិនបានសួរឈ្មោះអតីតអ្នករដ្ឋការដែលបាត់ខ្លួននោះទេ... នៅពេលនេះខ្ញុំសំរេចចិត្តមកបបួលបងរត់ចាកចេញពីប្រទេសខ្មែរនៅថ្ងៃស្អែកនេះ ។

ពេលនោះយាយទៀងដូចត្រូវគេវាយមួយពូថៅចំកណ្តាលក្បាល គាត់គ្រវីក្បាលដូចជីងចក់ត្រូវកំបោរ គាត់រកពាក្យឆ្លើយថា ទៅឬទេមិនឃើញ ។

តាម៉ុកយល់ថាយាយទៀងមិនព្រមទៅជាមួយគាត់ ក៏លើកដៃអង្អែលស្មាយាយទៀងព្រមទាំងផ្តាំថា ៖

- សូមបងប្រយ័ត្នខ្លួនណា៎ ! បើឃើញថាមានគ្រោះថ្នាក់ត្រូវរត់គេចភ្លាម ។

តាម៉ុកនិងយាយទៀងសុំលាគ្នាត្រឹមណោះ គឺបែកគ្នារហូត ។ យាយទៀងស្រណោះខ្លួនហើយនឹកក្នុងចិត្តថា ៖

- ឱអញអើយ ! បើអត់ពីតាម៉ុកទៅ តើបាននរណាជាគ្នា ? ។

នៅថ្ងៃទី២៨-៥-៨០ ម៉ោងប្រហែល២រសៀល ស័ក្តិបីង្វៀង-វ៉ាន់ទិញបណ្តើរ ស័ក្តិបួនវៀតណាមម្នាក់ចូលមកក្នុងកូនខ្ទមរបស់យាយទៀង ។ ចូលមកដល់ភ្លាម ស័ក្តិបួននេះចាប់ផ្តើមសួរជីវប្រវត្តិរបស់ម្ចាស់ខ្ទម ។ គាត់ឆ្លើយប្រាប់ហូរហែរដូចគាត់បានប្រាប់ស័ក្តិ៣ទិញរួចហើយ ។ ស័ក្តិបួនយួនសួរគាត់ថា ៖

- ម៉ែ ! តើម៉ែចេះអក្សរយួនអក្សរបារាំងឬទេ ? ។

យាយទៀងឆ្លើយយ៉ាថសមរម្យថា ៖

- ចេះបន្តិចបន្តួចដែរ ។

វាបែរទៅប្រាប់ទិញថា ៖

- ចាប់ពីពេលនេះទៅ ចូរមិត្តយកអង្ករនិងពោតផ្តល់ឲ្យម៉ែទៀងឲ្យបានគ្រប់គ្រាន់ ។

វាស្នើយាយទៀងសុំបំពាក់ស័ក្តិ ដោយលើកដំកើងបញ្ចោរប្រើឲ្យដើរយកការណ៍ឲ្យវា ។ វាធានារៀបចំផ្ទះមួយយ៉ាងស្អាតឲ្យគាត់សំណាក់នៅ ព្រមទាំងសន្យាថាទិញកង់ ( កាលណោះអ្នកណាមានផ្ទះនៅនិងមានកង់មួយជិះ គឺហ៊ឺហារណាស់) មួយឲ្យកូនស្រីគាត់ជិះទៅរៀន ។ វាបញ្ជាក់ទៀតថា ៖

- ម៉ែ ! កិច្ចការដែលម៉ែត្រូវធ្វើនោះ មិនពិបាកទេ គឺទី១ អង្គការលើកចាត់តែងតាំងម៉ែជាគ្រូបង្រៀនពិសេស គឺបង្រៀនកូនៗរបស់លោកឡាយ-សាម៉ុន ។ ទី២ ម៉ែត្រូវដើរហែរហមប្រពន្ធគាត់ ព្រោះគាត់មិនចេះខ្មែរទេ ។ គាត់មានឡាន មានអ្នកបើកបរជាស្រេច ។ ទី៣ អង្គការលើសុំចាត់តាំងម៉ែជាចារនារី ។

និយាយរួចហើយ វាសម្លឹងមុខយាយទៀងយ៉ាងមុតចាំស្តាប់ចម្លើយ ។ យាយទៀងញញឹមធ្វើជាល្ងង់ហើយក៏សួរថា ៖

- **Lam gi Trinh Xeac Gien ?**

- តើចារនារីមានមុខងារធ្វើអ្វីខ្លះ ?

ស័ក្តិ៤វៀតកុងពេញចិត្តនឹងសំនួរនេះណាស់ ។ វាញញឹមព្រមទាំងឆ្លើយវែកញែកពន្យល់យាយទៀងថា ៖

- ម៉ែត្រូវឈ្លបយកការណ៍ផ្តល់ឲ្យពួកខ្ញុំបូដូយថា តើចៅហ្វាយខេត្តបាត់ដំបងនេះ ធ្វើការស្មោះត្រង់ចំពោះពួកខ្ញុំឬទេ ? គឺចំពោះយួនហាណូយឬទេ ?... ម្យ៉ាងវិញទៀត ម៉ែត្រូវយកការណ៍ឲ្យដឹងថា អ្នករដ្ឋការក្នុងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតុកម្ពុជាក្នុងខេត្តបាត់ដំបងសព្វថ្ងៃ តើពីដើមលោកអ្នកទាំងអស់នោះជាអ្វី ? ខ្ញុំចង់ដឹងជាបន្ទាន់ថា តើនរណាជាអតីតអ្នករដ្ឋការ ? តើនរណាជាអតីតខ្មែរក្រហម ? តើនរណាជាសមាជិកហ្វ៊ុលរ៉ូ ? ។

ឡាយ-សាម៉ុនបានទៅរៀននៅហាណូយអស់រយៈពេលចំនួន១៧ឆ្នាំ ។ តែ...

យួនហាណូយនៅតែតាមដានអាយ៉ងរបស់វាជានិច្ច ។ ទីបំផុត នៅដើមឆ្នាំ១៩៨៤ យួនហាណូយចាប់ខ្លួនចៅហ្វាយខេត្តនេះនាំយកទៅបាត់...

លុះស្តាប់ចប់សព្វគ្រប់ យាយទៀងមានការរារែកយ៉ាងខ្លាំង គាត់ក៏ឆ្លើយដោះសារថា ចាំគាត់គិតសិនពីព្រោះគាត់ចោលអាន ចោលសរសេរជាច្រើនឆ្នាំណាស់មកហើយ ។

ស័ក្តិបីនិងស័ក្តិបួនវាពេញចិត្តចំពោះយាយទៀងណាស់ ។ មុននឹងលាថយទៅវិញ វាដើរមកអង្អែលខ្នងព្រមទាំងថ្លែងថា ៖

- កូនពេញចិត្តម៉ែណាស់ ! បើម៉ែយល់ព្រមជួយធ្វើការជាមួយកូនៗ ។

យប់នោះយាយទៀងដេកមិនលក់ទាល់តែសោះ គាត់បារម្ភជាខ្លាំងព្រោះមុខងារជាចារនារីនេះគាត់ធ្លាប់ស្គាល់ច្បាស់ពេកទៅហើយ ។ ឥឡូវនេះស័ក្តិបួនយួនមកបំពាក់ឲ្យគាត់ធ្វើជាលើកទី៣ ។ ឱទេវតាអើយ ! លើកនេះធ្ងន់ក្រៃលែងធ្ងន់ ។ ធ្វើជាគិញឈ្លបយកការណ៍រួចរាយការណ៍នេះ ។ តែធ្វេសប្រហែសបន្តិចត្រូវគេសម្លាប់ចោលទទេៗ ។ ត្រូវរកមុខអតីតអ្នករដ្ឋការ ! ត្រូវរកមុខសមាជិកហ្វ៊ុលស៊ូ !!! ឱពុទ្ធោអើយ ! បើខ្លួនឯងជាអតីតអ្នករដ្ឋការនិងជាអនុប្រធានហ្វ៊ុលស៊ូទៅហើយ តើអាចលាក់មុខជិតឬទេ ?

❑

ថ្ងៃទី១៨-៦-៨០ ម៉ោងប្រហែល៧រសៀល ស័ក្តិបួនយួនបណ្តើរគ្រូបង្រៀនជាតិខ្មែរក្រោមម្នាក់មកជួបយាយទៀង ។ មេបូដួយសួរបញ្ជាក់គាត់ថា តើគាត់ព្រមចូលធ្វើការឲ្យវាឬទេ ?

ពេលនោះយាយទៀងគ្រវីក្បាលឆ្លើយដោះសារតែដដែលថា ៖

- ចាំគាត់គិតសិន ។

បូដួយខំពន្យល់គាត់ថា ៖

- កិច្ចការទាំងនោះពុំចាំបាច់ចេះជ្រៅជ្រះទេ ។ ម៉ែចេះអានចេះនិយាយវៀត-ណាមដូចសព្វថ្ងៃនេះ គឺគ្រប់គ្រាន់ហើយ ។ ជាពិសេសពួកកូនត្រូវការមនុស្សដូចម៉ែនេះ គឺជាមនុស្សថ្មីមិនដែលទាក់ទងធ្វើការជាមួយអ្នករដ្ឋការជំនាន់មុន ។

កិច្ចការជជែកគ្នាជិតកន្លះម៉ោង ទីបំផុតយាយទៀងប្រថុយសួរថា ៖

- បើសិនជាអ្នករដ្ឋការសព្វថ្ងៃជាអតីតអ្នករដ្ឋការជំនាន់មុនៗ តើម៉េចទៅ ? ។

ពេលនោះបូដួយធ្វើមុខមាំ សម្លឹងចំមុខយាយទៀង ព្រមទាំងឆ្លើយកំបុយកំបុយថា ៖

- យើងត្រូវការមនុស្សថ្មីដូចម៉ែអីញ្ចឹង ! ។

ស័ក្តិប្អូនយួននេះបង្ហាឥរិយាបថមិនពេញចិត្តនូវសំនួរនេះ វាក៏លាយាយទៀងចេញទៅភ្លាម ។ ស្រាប់តែវាជួបស័ក្តិបីទិញកំពុងដើរពិនិត្យសង្កេតតាមភូមិស្ថិតនៅក្រោយវត្តរំដួល ។ វាក៏ប្រាប់ស័ក្តិបីទិញថា ៖

– គួរតាមដានអង្កេតពិនិត្យយាយទៀងឲ្យមែនទែន យាយនេះមិនមែនជាមនុស្សធម្មតាទេ ។ យើងហៅឲ្យគាត់ចូលមកជួយធ្វើការឲ្យយើងយ៉ាងស្រួល គាត់ឆ្លើយដោះសារមិនចេះចប់ ។ ពីរនាក់ម៉ែកូនក្ររហាម ដាំជីរស្លឹកគ្រៃម្ទេសលក់ចិញ្ចឹមជីវិត សមណាក់នៅក្នុងបន្ទប់បង្កន់ ដេកផ្ទាល់ដី ។ រាល់ៗយប់អាចោរចូលមកប្លន់ធ្វើបាបសឹងគ្មានពេលដេកសែនវេទនា ។ ហេតុអ្វីក៏គាត់មិនព្រមទទួលសំណើរបស់យើង ? ។

ស័ក្តិប្អូនយួននេះនិយាយដល់ត្រឹមហ្នឹង ទើបនឹកឃើញថាមានគ្រូបង្រៀនម្នាក់ឈរក្រោយខ្នង ។ វាក៏ឱនខ្សិបស័ក្តិបីទិញមួយសន្ទុះធំ ទើបលាបែកគ្នាទៅ ។ វាក៏បណ្តើរគ្រូបង្រៀនទៅមើលស្ថានភាពភូមិខាងក្រោយមន្ទីរពេទ្យធំបាត់ដំបង ។

លុះទៅដល់មុខមន្ទីរពេទ្យ លោកគ្រូបង្រៀនធ្វើកលសុំលាបែកចេញពីស័ក្តិប្អូនយួននេះ ដោយកុហកថា គាត់ចូលមន្ទីរពេទ្យរកសុំថ្នាំឲ្យកូនឈឺគ្រុន ។

ការពិតលោកគ្រូដ៏សប្បុរសនេះគាត់ចង់នាំដំណឹងអកុសលអម្បាញ់មិញទៅប្រាប់យាយទៀង ។ លោកគ្រូក៏ចូលទៅក្នុងមន្ទីរពេទ្យ រួចដើររហូតទៅកាន់របងខាងក្រោយជិតមន្ទីរសំរាលកូន រួចឆ្លងរបងមន្ទីរពេទ្យត្រឡប់ទៅកាន់កូនខ្ទមយាយទៀងវិញ ។

លុះប្រាប់រឿងរ៉ាវសព្វគ្រប់ លោកគ្រូក៏សុំលាយាយទៀងភ្លាម ។

❑ ❑

❑

ថ្ងៃដដែលម៉ោង៦ល្ងាច ស័ក្តិបីទិញមកជួបយាយទៀង ។ វាដើមមកអង្អែលខ្នង ព្រមទាំងនិយាយយ៉ាងទន់ភ្លន់ថា ៖

– ម៉ែអាហ៎ ! ថ្ងៃ១៦-៦-៨០ ម៉ោង៩ព្រឹកខ្ញុំមកនាំម៉ែទៅជួបស័ក្តិប្អូន ព្រមទាំងនសម៉ែទៅមើលផ្ទះមួយខ្នង ដែលប្អូនជួយរៀបចំជូនម៉ែសំណាក់នៅ ។

ថ្ងៃដដែលម៉ោង៨យប់ មានអាចោរយ៉ាងកំណាចមួយក្រុម មានគ្នាយ៉ាងច្រើនកាន់កាំភ្លើងគ្រប់ដៃ មកព័ទ្ធបន្ទប់បង្កន់ដែលយាយទៀងតែងតែនាំកូនស្រីលបលូនជ្រកប្អូនដេកជាង១១ខែមកហើយ គ្មាននរណាដឹងទេ ។ ចោរចាប់ផ្តើមស្រែកកំហែងសម្លុតយាយទៀងឲ្យនាំកូនស្រីចេញមកជួបក្រុមវា ។ សម្លេងស្រែកសម្លុ

តនៃក្រុមចោរ និងពាក្យសុំអង្វររបស់យាយទៀងលាន់រំពងជាងពីរម៉ោង ដូចសង្គ្រាមតូចមួយ ញ៉ាំងឲ្យប្រជាជនខ្មែរនៅជុំវិញនោះភ័យតក់ស្លុត នាំកូនចៅរត់ចេញចុះពួនក្នុងស្នាមភ្លោះគ្រប់ៗគ្នា ។

ពេលនោះយាយទៀងអស់សង្ឃឹម គាត់ក៏ថ្ងូរប្រកាសអំពាវនាវដល់ទេវតាថា ៖

- ឱទេវតាអើយ ! មានតែលោកទេមានព្រះនេត្រទិព្វ មានត្រចៀកទិព្វ មានតែលោកទេជាសាក្សី ខ្ញុំគ្មានបំណងរត់ចោលមាតុភូមិទី២នេះទេ ។ ឥឡូវនេះខ្ញុំអស់សង្ឃឹម អស់រំពឹងហើយ... ដូច្នេះស្អែកៗនេះ ប្រទេសកម្ពុជាត្រូវតែបាត់ប្រជាជនដ៏ស្លូតត្រង់ពីរនាក់ទៀត ។

ហេតុម៉េចយាយទៀងថ្ងូរយ៉ាងនេះ ?

ព្រោះគាត់ស្គាល់សម្លេងដែលសម្លុតនោះថាជាសម្លេងរបស់មេចោរឈ្មោះឡុង-ញ៉ន ដែលធ្វើការជាមួយបូដូយ ។ ពេលថ្ងៃវាដើរជាមួយយួនបើកអង្គប្រជុំ ឡើងវេទិកាប្រកាសអង្វរប្រជាជនខ្មែរកុំឲ្យរត់ចោលទឹកដី ប្រកាសធានាថា ក្រុមវានិងបូដូយស្ម័គ្រចិត្តជួយការពាររកសន្តិសុខឲ្យរាស្ត្រខ្មែរ ។

អស្ចារ្យ ! យប់នេះឡុង-ញ៉នជាមេចោរ !!!

បណ្តាលមកពីភ័យតក់ស្លុតខ្លាំងពេក យាយទៀងក៏ដួលសន្លប់បាត់ស្មារតីដេកស្តូកស្តឹងទៅ ។

ចំណែកអង្គរា នាងភ័យតក់ស្លុតខ្លាំងពេករកពាក្យនិយាយទៅកាន់ក្រុមចោរគ្មាន នាងយំហើយយំទៀត ។

ក្រុមចោរធ្វើអ្វីមិនកើត អាមេចោរឈ្មោះឡុង-ញ៉នក៏ស្រែកព្រមានអង្គរាថា នែនាង ! យើងថយទៅវិញ ប៉ុន្តែថ្ងៃស្អែកនេះម៉ោង៩ព្រឹក ខ្ញុំមកជួបម្តាយរបស់នាង ចូលនាងប្រាប់គាត់ឲ្យនៅរង់ចាំខ្ញុំណា៎ ។

ថ្ងៃទី១៥-៦-៨០ ម៉ោងប្រហែល៩ ឮសម្លេងម៉ូតូខាងកើតកូនខ្ទម យាយទៀងក្រឡេកភ្នែកសម្លឹងឃើញមេចោរឡុង-ញ៉ននិងស័ក្តិពីរយួនម្នាក់ លោតចុះពីម៉ូតូពណ៌ក្រហម ។ ទាំងពីរនាក់បណ្តើរគ្នាចូលមកកាន់កូនខ្ទមរបស់យាយទៀង ។ វាសើចស្ញេញស្ញាញ មានឥរិយាបថរីងឆ្អឹត របៀបអៀនខ្មាស់ ។ ឡុង-ញ៉នសួរយាយទៀងថា ៖

- មីងចេះភាសាយួនទេ ? ។

- អត់ចេះទេ ! ។

ឡុង-ញ៉នចាប់ផ្តើមនិយាយលួងលោមយ៉ាងទន់ភ្លន់ផ្អែមល្ហែមថា ៖

- សូមមីងកុំរត់ទៅណា ខ្ញុំនិងមិត្តខ្ញុំនេះសុំធានាឈប់ឲ្យគេមកធ្វើបាបមីងទៀតហើយ ។ តាំងពីថ្ងៃនេះទៅ មីងទុកចិត្តពួកខ្ញុំចុះ ។ ខ្ញុំស្រណោះនិងខ្មាស់នូវពាក្យ

ដំអូញថ្ងូររបស់មីងពីយប់មិញជាក្រៃលែង ។

វាខំនិយាយហើយនិយាយទៀត ធ្វើឲ្យមីងទុកចិត្ត និងដើម្បីលប់លាងនូវអំពើថោកទាបពីយប់មិញ ។

ចំណែកយាយទៀងអង្គុយត្របោមក្បាលជង្គង់ផ្ទាល់ដី ភ្នែកល្ងួចសម្លឹងជនឃោរឃៅ នឹកអស់សង្ឃឹម ។ គួរចម្លែកអស្ចារ្យ ពេលថ្ងៃដើរព្រោកប្រាជ្ញ ឃោសនាអួតថាក្រុមខ្លួនជាអ្នកការពារសន្តិសុខឲ្យរាស្ត្រខ្មែរ ។ ផ្ទុយទៅវិញ យប់មកដល់ប្រែក្រឡៃខ្លួនទៅជាចោរ ដើរប្លន់បាញ់សម្លាប់ និងចាប់កូនក្រមុំយកទៅរំលោភយ៉ាងព្រៃផ្សៃ ។ ពេលនោះយាយទៀងតាំងបំពងក គ្មានចម្លើយគ្មានសំនួរ គាត់អង្គុយធ្មឹងដូចមនុស្សគ ស្រាលខ្លួនដូចសំឡី ឈប់ដឹងខ្លួនគាត់ជាអ្វីទៅហើយ ។ គាត់នឹកក្នុងចិត្តថា ឱ ! ពួកឯងប្រើសំដីទន់ភ្លន់ល្អ បោកអញទេតើ ! ។

ពេលនោះស្រាប់តែឃើញ កូនស្រីពៅរបស់គាត់បណ្តើរស្រីម្នាក់អាយុប្រហែលព៧ឆ្នាំ ឈ្មោះអារឿត ចូលមកជួបយាយទៀង ។ លុះមានមនុស្សថ្មីចូលមកដល់ មេចោរឈ្មោះឡុង-ញ៉ានក៏ចាប់ដៃមេបូដូយបណ្តើរគ្នាទៅលើងម៉ូតូបរចេញទៅ...

លុះក្រុមចោរចេញផុត ទើបអារឿតលោតមកឱបយាយទៀង រួចហុចសំបុត្រមួយជូនគាត់ ព្រមទាំងនិយាយថា ៖

- បង ! នេះសំបុត្ររបស់ ជើនសា ខ្ញុំបានទទួលពីព្រំដែនខ្មែរ-ថៃជាយូរហើយ ! ខ្ញុំស៊ើបសួររកបងយូរហើយ ! ខ្ញុំមិនស្មានថាបងនៅរស់ទេ ! ។

យាយទៀងទទួលបានសំបុត្ររបស់កូនប្រុសទី៣ដោយថៃដន្យ ។ គាត់មានការរំភើបជាយ៉ាងខ្លាំង ញ័រដៃទទ្រើក ព្រោះជើនសាបាត់ខ្លួនតាំងពីខែកក្កដាឆ្នាំ១៩-៧៧ នៅពេលដែលអង្គការយកខ្លួនគាត់ទៅឃុំឃាំងដាក់ក្នុងគុកស្រីមេម៉ាយព្រៃតាបែន គាត់ទទួលដំណឹងថា ជើនសាត្រូវតំណាងរបស់អង្គការបាញ់សម្លាប់នៅខាងត្បូងភូមិកង្កួត ។ គាត់ស្មានតែស្លាប់ទៅហើយ បាត់ដំណឹងក្នុងរយៈ៣ឆ្នាំ ។ អស្ចារ្យណាស់ថ្ងៃនេះ គាត់បានទទួលសំបុត្ររបស់កូនប្រុសដ៏កំសត់ ដាក់អស័យដ្ឋាននៅប្រទេសបារាំង ។ យាយទៀងអានសំបុត្របណ្តើរ គាត់យំបណ្តើរ ដោយរំភើបចិត្តត្រេកអរយ៉ាងហួសហេតុ ។

អានសំបុត្រចប់ យាយទៀងលោតទៅឱបអារឿត ព្រមទាំងថ្លែងសេចក្តីអរគុណ ។ រួចគាត់លើកដៃសំពះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះឥន្ទ ព្រះព្រហ្ម និងទេវតាផងទាំងពួង ព្រមទាំងថ្លែងថា ៖

- ឱលោកអើយ ! លោកបង្កើតមនុស្សលោក លោកមិនលះបង់ចោលមនុស្សដែលប្រព្រឹត្តនូវអំពើល្អឡើយ ។ ខ្ញុំព្រះករុណាកំពុងដើរមកដល់ច្រកទ័ល គឺយួនហាណូយនិងក្រុមខ្មែរជាអាយ៉ងរបស់វារុញច្រានខ្ញុំ ខ្ញុំត្រូវតែរត់ចោលស្រុក ។

អារឿតអើយ ! ខ្ញុំគ្មានបំណងរត់ចោលមាតុភូមិទី២នេះទាល់តែសោះ ។ តែឥឡូវនេះដើម្បីជីវិតរបស់ខ្ញុំ និងជាពិសេសដើម្បីអនាគតរបស់អង្គារា ខ្ញុំត្រូវតែទៅតាមជើងសា ជាដាច់ខាត ។

**ស្តាយអើយសែនស្តាយ ទឹកដីព្រៃព្រឹក្សាកម្ពុជា !**

ពេលនោះស្រាប់តែឃើញអ្នកគ្រូ សុផាន ចូលមក, មានបុកពារសប្បាយប្លែកដើម្បីបបួលយាយទៀងចាកចោលស្រុកខ្មែរ ។ អ្នកគ្រូអះអាងថា សូមកុំព្រួយបារម្ភអី ព្រោះគាត់មានបងថ្លៃប្រុសម្នាក់ ជាវេជ្ជបណ្ឌិតរស់នៅសព្វថ្ងៃឯប្រទេសបែលហ្ស៊ិក ជាមួយគ្រួសារ ។ គាត់ជួយយុវជនពីរនាក់ជាជនភៀសខ្លួននៅជំរំខាវអ៊ីដាងឲ្យចូលមកទទួលខ្ញុំនិងកូនបីនាក់ នាំចេញទៅកាន់ខាវអ៊ីដាង នៅព្រឹកស្អែកនេះ ។ ដូច្នេះខ្ញុំមកបបួលបងទៅជាមួយ ។

យាយទៀងត្រេកអរជាអតិបរិមា ឧបមាដូចជាគាត់កំពុងដើររកអុសស្រាប់តែប្រទះឃើញឈើងាប់ ។ គាត់សំរេចចិត្តភ្លាមថា ត្រូវតែចាកចោលមាតុភូមិកម្ពុជា ទុកឲ្យយួនហាលលួយមួយគ្រាសិនចុះ ។

❑ ❑

❑

# ជំពូកទី២២

★ យាយទៀងចាកចេញពីប្រទេសកម្ពុជា
★ យាយទៀងចូលជំរំណងចន្ទ
★ យួនហាណូយតាមបញ្ហាឲ្យប្ញួដូយតាមសម្លាប់ប្រជាជនខ្មែរ
★ យាយទៀងទទួលរងទុក្ខ៥ជង

## យាយទៀងដើរចាកចេញពីមាតុភូមិកម្ពុជា

គួរអាសូរយាយទៀងនិងអ្នកគ្រូសូផានីជាក្រៃលែង ដោយមិនបានដឹងថាយុវជនដែលជាអ្នកនាំផ្លូវទាំងពីរនាក់នោះ ជាចោរដែលយួនហាណូយបានបង្កបង្កើតឡើងទេ ។

ព្រលឹមថ្ងៃទី១៦-៦-៨០ ម៉ោងប្រហែល៥ព្រឹក យាយទៀងបណ្តើរអង្គារាកូនស្រីរបស់គាត់ ។ រីឯអ្នកគ្រូសូផានីវិញ គាត់បណ្តើរកូនតូចៗ មានស្រីពីរនាក់និងប្រុសម្នាក់ ទៅជួបជុំគ្នានៅខាងលិចផ្សារក្បាលខ្មោច តាមផ្លូវជាតិលេខ៥ ដែលចោរ «ដាក់ទិស» ឲ្យទៅអង្គុយរង់ចាំនៅទីនោះ ។

ទាំង៦នាក់អង្គុយផ្ទាល់ដីត្របោមក្បាលជង្គង់កំប្រោនៗ រង់ចាំអ្នកនាំផ្លូវដ៏ចម្លែក អត់បាយក្រហាយទឹក ។ ភ្នែកសម្លឹងមើលខ្មែរជាច្រើនពាន់នាក់កំពុងចាកចោលមាតុភូមិកម្ពុជា ជាហូរហែដោយសេរីទៅកាន់ប្រទេសថៃ ។ គ្មានឃើញនរណានាំផ្លូវ នរណាសួរ នរណាហាមឃាត់ទេ ។

ម៉ោង១រសៀលទៅហើយ មិនទាន់ឃើញអ្នកនាំផ្លូវមកដល់ យាយទៀងមានអារម្មណ៍សង្ស័យ គាត់ហារមាត់បំរុងនិយាយនូវការសង្ស័យរបស់គាត់ប្រាប់អ្នកគ្រូសូផានី ស្រាប់តែឬហ្មាំងកង់ផ្កើត !

ទាំងអស់គ្នាក្រឡេកភ្នែកសម្លឹង ក៏ឃើញយុវជនពីរនាក់អាយុប្រហែល២០ឆ្នាំ

ឫកក្រអឺត ស្លៀកពាក់ស្អាតបាតសមរម្យ មុខមាត់ដូចយួន ជិះកង់យ៉ាងថ្មី ។ ជើងវាម្ខាងនៅលើឈ្នាន់កង់ ជើងម្ខាងទៀតជាន់ដី ។ វាបើកភ្នែកធំៗសម្លក់សម្លឹងយាយទៀងនិងអង្គារា ។ អាម្នាក់មាឌតូចលើកដៃចង្អុលយាយទៀងព្រមទាំងសួររបៀបមិនពេញចិត្តថា ៖

- អ៊ុំឯងទៅដែរឬ ? ។

ពេលនោះអ្នកគ្រូសូផានីឆ្លើយជំនួស ៖

- ចាះ ! គាត់ទៅជាមួយយើងដែរ ។

អាចោរម្នាក់មាឌធំខ្ពស់ និយាយខ្មែរមិនសូវច្បាស់ សម្លឹងអ្នកគ្រូយ៉ាងមុតព្រមទាំងស្តីបន្ទោសថា ៖

- ហេតុម៉ិតពីម៉ាស៊ីលម៉ិន មីនឯនមិនប្រាប់ញ៉ុមថាមានម៉ានុសទៅជាមួយ ? ឥឡូវមហ៍ដើរតាមញ៉ុមមក ! ។

វាជិះកង់យឺតៗពីមុខ ខ្មែរភៀសខ្លួនទាំង៦នាក់ដើរតាមក្រោយ ។ លុះចេញផុតពីផ្សារក្បាលខ្មោចបានចម្ងាយមួយគីឡូម៉ែត្រ កណ្តាលវាលយ៉ាងស្ងាត់ វាតាំងពីរនាក់ក៏បញ្ឈប់កង់ រួចប្រាប់ឲ្យយើងអង្គុយចាំនៅទីនោះ ព្រោះពួកវាបានរៀបចំរ៉ឺម៉កម៉ូតូរួចហើយ ពួកវានឹងមកយក ។

ម៉ោងជាង៧រសៀលទៅហើយ ! យាយទៀងនិងអ្នកគ្រូសូផានីអង្គុយរង់ចាំអ្នកនាំផ្លូវដ៏ចម្លែកនោះនៅលើផ្លូវជាតិលេខ៥ ។ កន្លែងនោះនៅពេលថ្មើនោះមានសភាពស្ងាត់មែនទែនណាស់ទៅហើយ ។ យូរៗទើបគេឃើញមានរ៉ឺម៉កម៉ូតូមួយបរកាត់ ។ ពីព្រោះពីទីក្រុងបាត់ដំបងទៅកាន់ជំរំណងច័ន្ទមានចម្ងាយជាង១០០គ.ម. ។ ដូច្នេះប្រជាជនភៀសខ្លួនត្រូវតែចេញដំណើរពីទីក្រុងបាត់ដំបងតាំងពីព្រលឹម ។

យាយទៀងមិនទុកចិត្តអ្នកនាំផ្លូវដ៏ចម្លែកនោះ គាត់សំរេចចិត្តជួលម៉ូតូមួយជិះជាមួយកូនស្រីអង្គារា និងអាហ៊ាញជាកូនស្រីច្បងរបស់អ្នកគ្រូសូផានី ទៅកាន់ទីប្រជុំជនស៊ីសូផុនមុន ។ គាត់សន្យានឹងអ្នកគ្រូសូផានី ថានឹងជួបគ្នានៅទំនប់ត្រង់ផ្លូវកាច់ចូលផ្សារស៊ីសូផុន ។ យាយទៀងធានាយកមាសនិងពេជ្ររបស់អ្នកគ្រូសូផានីមួយកញ្ចប់មានតម្លៃប្រហែល២០ម៉ឺនបាត នាំបណ្តោះយកទៅមុន...

លុះទៅដល់ទំនប់ហើយ អ្នកបើកបររ៉ឺម៉កក៏ចាប់ហ្វ្រាំងឈប់ ។ យាយទៀងក៏ឲ្យមាសមួយហ៊ុនជាឈ្នួល រួចក៏នាំគ្នាចុះពីរ៉ឺម៉កម៉ូតូ រួចបណ្តើរគ្នាទៅអង្គុយនៅលើចិញ្ចើមថ្នល់ខាងស្តាំដៃ អត់បាយ អត់ទឹក ។ អង្គារានិងអាហ៊ាញកំពុងញ៉ាំបាយទទេ

គ្មានម្ហូប ស្រាប់តែឃើញអាចោរទាំងពីរនាក់ ដែលបន្លំជាអ្នកនាំផ្លូវ និងបូដូយពីរនាក់ កាន់កាំភ្លើង AR-15 ពីរដើមជិះរ៉ឺម៉កម៉ូតូជាមួយគ្នារៀបឆ្លងទំនប់ ។

អាហ៊ាញនិងអង្គារារត់តាមរ៉ឺម៉កម៉ូតូនោះភ្លាម ដើម្បីសួរពត៌មានពីអ្នកគ្រូសូផានី

អាហ៊ាញស្រែកសួរក្រុមចោរថា ៖

- ពូ ! ឃើញម៉ែខ្ញុំទេ ? ។

អាចោរសាមាន្យឆ្លើយកំបុតកំបុយតបថា ៖

- អត់ដឹងអត់អីទេ ! ។

រួចវាក៏បររ៉ឺម៉កម៉ូតូឆ្លងទំនប់ទៅបាត់ទៅ ។

អាហ៊ាញស្មានថា មុខជាចោរបាញ់សម្លាប់ម្ដាយនិងប្អូនៗទៅហើយ ក៏ស្រែកយំទន្ទ្រាំជើង ។ ចំណែកយាយទៀងក៏តក់ស្លុតស្លន់ស្លោគិតអ្វីលែងឃើញទៅហើយ ។ ស្រាប់តែព្រហ្វាំងម៉ូតូង៉ឺត គាត់ក៏បែរភ្នែកសម្លឹងមកក៏ឃើញអ្នកគ្រូសូផានីនិងកូនតូចៗពីរនាក់ជិះក្នុងរ៉ឺម៉កនោះ ។ អ្នកគ្រូដឹកដៃកូនចុះពីរ៉ឺម៉ក រួចលោតឱបយាយទៀងទាំងទឹកភ្នែករហាម ។

❑ ❑

❑

ម៉ោងប្រហែលជា៥រសៀលទៅហើយ ជនភៀសខ្លួនដ៏កំសត់ទាំង៦នាក់ក៏បណ្ដើរគ្នាចូលមកកាន់ទីប្រជុំជនផ្សារស៊ីសូផុន ។ ដើរបណ្ដើរអ្នកគ្រូសូផានី ជំណាលរឿងដែលកន្លងផុតទៅអំបាញ់មិញប្រាប់យាយទៀងថា ៖

- ពេលបងជិះរ៉ឺម៉កចេញផុតទៅ ខ្ញុំនិងកូនៗអង្គុយរង់ចាំអ្នកនាំផ្លូវដ៏ចម្លែកយ៉ាងអន្ទះសារ ។ ផ្លូវនៅកន្លែងនោះ នៅម៉ោងជាង៣រសៀលមានសភាពស្ងាត់អើយសែនស្ងាត់ ។ កំពុងតែអង្គុយរង់ចាំ ស្រាប់តែអ្នកបើកបររ៉ឺម៉កម៉ូតូដែលជូនខ្ញុំមកអំបាញ់មិញនេះចាប់ហ្វ្រាំងង៉ឹត ! ខ្ញុំបែរភ្នែកសម្លឹងមើល ក៏ស្គាល់គាត់ជាមិត្តភក្ដិរបស់ប្ដីខ្ញុំ ។ គាត់ស្រែកសួរខ្ញុំថា ៖

បង, តើបងទៅណា ?

ខ្ញុំក៏ប្រាប់គាត់ត្រួសៗពីរឿងអង្គុយចាំអ្នកនាំផ្លូវដ៏ចម្លែកនោះ ។ គាត់ស្ដាប់ចប់ក៏ទះដើមទ្រូងថ្ងូរថា ៖

- ឃើបងអើយ ! កន្លែងនេះចាប់ពីម៉ោងបីរសៀលទៅ មានចោរប្លន់សម្លាប់មនុស្សសឹងរាល់ថ្ងៃ ។ មហ៍បង ! នាំកូនឡើងរ៉ឺម៉កខ្ញុំមក យើងទៅឈប់រង់ចាំនៅផ្សារថ្មគោល ។ យើងចង់ដឹងរឿងនេះយ៉ាងម៉េច ? ។ អ្នកបើករ៉ឺម៉កម៉ូតូក៏បើកយ៉ាងលឿនរួចទៅឈប់សំចតនៅមុខហាងគុយទាវកណ្ដាលផ្សារថ្មគោល ។ មួយសន្ទុះក៏ឃើញអ្នកនាំផ្លូវទាំងពីរនាក់និងបូដូយ២នាក់ទៀត មានកាំភ្លើង AR-15 ពីរដើមនៅ

ជាប់នឹងខ្លួន ជិះរ៉ឺម៉កម៉ូតូជាមួយគ្នាបរកាត់ទីនោះ ។ ដូច្នេះអ្នកបើករ៉ឺម៉កដែលខ្ញុំជិះក៏ដេញតាមរ៉ឺម៉កក្រុមចោរកិតៗប្រផិតប្រភឹងមកដល់ទីនេះ ។ល។

ពេលនោះថ្ងៃរៀបលិចទៅហើយ យប់ងងឹតរៀបចូលមកដល់ ។ ឱ ! ស្រីដ៏កំសត់ទាំងពីរនាក់អើយ ! តើនាំកូនទៅជ្រកដេកនៅឯណា ឲ្យចាកផុតពីកណ្ដាប់ដៃចោរ ? ។ យើងទាំងអស់គ្នាក៏អង្គុយអស់សង្ឃឹមអត់បាយអត់ទឹក ទៅមុខមិនរួចថយក្រោយមិនកើត នៅត្រង់កាច់ជ្រុងផ្សារស៊ីសូផុន ។ ចំណែកអ្នកបើកបររ៉ឺម៉កចិត្តសប្បុរសវិញ ខំដេញតាមរកចោរមួយល្ងាចរកមិនឃើញ ក៏បររ៉ឺម៉កវិលទៅកាន់ទីក្រុងបាត់ដំបងវិញ ស្រាប់តែឃើញជនភៀសខ្លួន៦នាក់ដដែល ។ គាត់ក៏បញ្ឈប់រ៉ឺម៉កម៉ូតូរួចក៏ទូន្មានថា ៖

– បងៗ ! សំណាក់នៅទីនេះមិនបានទេ ! ក្រុមចោរថ្ងៃមិញមុខជាតាមមកព្យាបាទបងៗហើយ ។ ពេលយប់ងងឹតមកដល់ មុខជាមានគ្រោះថ្នាក់ជាមិនខាន ។ មហ៍អញ្ជើញឡើងរ៉ឺម៉កខ្ញុំមក ! យើងវិលត្រឡប់ទៅទីក្រុងបាត់ដំបងវិញ ថ្ងៃក្រោយសឹមខ្ញុំជូនរហូតទៅដល់ផ្សារនិមិត្ត ។

ម៉ោងជាង៦រសៀល អ្នកបើករ៉ឺម៉កម៉ូតូក៏ដឹកពួកយើងចាកចេញពីផ្សារស៊ីសូផុន ។ លុះរ៉ឺម៉កបរជិតដល់ភូមិបន្ទាយនាង យាយទៀងចាប់ដៃអ្នកគ្រូសូផានីកាន់ ព្រមទាំងនិយាយជំរុញថ្ងូរថា ៖

– អូន ! បងស្ដាយណាស់ដោយយើងត្រូវបែកគ្នាក្នុងពេលនេះ ព្រោះបងបានសន្យាជាមួយនឹងស័ក្តិ៣-ស័ក្តិ៤យួនថា នឹងជួបវាកាលពីម្សិលមិញនេះ ។ ថ្ងៃណោះហួសពេលមួយថ្ងៃទៅហើយ ។ បងមិនអាចវិលទៅកាន់កូនខ្ទមរបស់បងវិញបានទេ ។

យាយទៀងនិយាយដល់ត្រឹមហ្នឹង រ៉ឺម៉កម៉ូតូក៏បរឆ្លងស្ពានភូមិបន្ទាយនាងល្មមគាត់ប្រាប់អ្នកបើកបរចិត្តធម៌ឲ្យបញ្ឈប់រ៉ឺម៉ក ព្រមទាំងថ្លែងអំណរគុណផង ។ រួចក៏នាំកូនចុះពីរ៉ឺម៉ក ។ ក្នុងឱកាសបែកគ្នាចុងក្រោយនេះ ស្រីៗទាំងពីរនាក់តឹងត្រូងស្ទើរប្រេះ គាំងមាត់រកពាក្យនិយាយគ្មាន ត្រូវបែកគ្នាកណ្ដាលស្ពានបន្ទាយនាង គឺបែកគ្នារហូត ។

យប់នោះយាយទៀងនិងកូនស្រីដេកសំរាកក្នុងកូនខ្ទមរបស់ក្មួយជីដូនមួយសង់ស្អិតជាប់នឹងក្បាលស្ពាន ។ គាត់ដេកមិនលក់ទាល់តែសោះ ព្រោះស្ដាយទឹកដីកម្ពុជាជាក្រៃលែង ។

ចម្លែកណាស់យួនហាណូយ ចូលមកលុកលុយរាតត្បាតប្រទេសខ្មែរភ្លាម វាឆ្លៃប្រឌិតខ្មែរអាយ៉ងរបស់វាឲ្យក្លាយទៅជាចោរយ៉ាងសាហាវឃោរឃៅអស្ចារ្យ ។ ដូច្នេះស្នៀតប្រើដៃចោរ គឺយួនហាណូយមានផែនការព្រាងទុកមកដើម្បីកំចាយ

ខ្មែរ ។ ពីព្រោះខ្មែរស្លូតត្រង់ជាម្ចាស់ទឹកដីពិតៗ ទើបនឹងចេញផុតពីកណ្ដាប់ដៃអង្គការអនាមិកបាតដៃទទេបាក់ស្បាតទៅហើយ ។ ស្រាប់តែចូលមកជួបប្រទះរបបគ្រប់គ្រងរបស់យួនហាណូយជារបបចោរ គ្រប់ៗគ្នាអស់សង្ឃឹម ត្រូវតែបបួលគ្នាផ្សងព្រេងរត់ភៀសខ្លួនទៅកាន់ប្រទេសថៃ ទុកទឹកដីឲ្យយួនហាណូយទៅចុះ ។

តើមានស្មៀតអ្វីប្រសើរជាងស្មៀតចោរ ?

យាយទៀងនឹកឃើញគ្រប់ជ្រុងជ្រោយ គាត់អស់សង្ឃឹមរលីង មិនដឹងថាព្រលឹមស្អែក គាត់ត្រូវដើរទៅណាវិញទេ ? ពីព្រោះបើគាត់ទៅកាន់បរទេស តើត្រូវធ្វើម្ដេចចិញ្ចឹមជីវិត ? គិតដល់ត្រឹមហ្នឹង គាត់វង្វេងស៊ុងស្មើរឆ្កួត... អស់មធ្យោបាយហើយ ! នៅពេលរៀបជិតភ្លឺគាត់ក៏សំរេចចិត្តជាសប្ដូនជីជូនមួយ រួចផ្ដាំថា ៖

- ក្មួយអើយ ! បើអត់ពីមីងទៅ ចូរក្មួយថែទាំអង្គារាផងណា ! ។

ក្មួយនោះស្មានតែមីងកើតទុកខ្លាំងពេកវង្វេងស្មារតី ក៏មិនយកចិត្តទុកដាក់អ្វីទេ គ្រាន់តែឆ្លើយថា ៖

- បាទ ! ។ រួចសម្ងំដេកលក់ទៀតទៅ ។

ថ្ងៃទី១៧-៦-៨០ ម៉ោងប្រហែល៥ព្រឹក យាយទៀងក្រោកដើរទៅកាន់ក្បាលស្ពាន ដែលទឹកស្ទឹងកំពុងជន់ហូរត្របាញ់ គាត់បំរុងលោតក្នុងទឹកសម្លាប់ខ្លួន ។ ស្រាប់តែ ! សម្លេងមួយហើរពីក្បាលស្ពានម្ខាងឯណោះថា ៖

- បងៗ ! ។

យាយទៀងក៏បែរភ្នែកសម្លឹងរកម្ចាស់សម្លេង ។

ឱ ! លោកឈឿតទេតើ ! ។

លោកឈឿតជាអតីតលេខាធិការធនាគារឥណទានជាតិខេត្តបាត់ដំបង ។ ពេលជួបគ្នាដោយចៃដន្យ លោកឈឿតលោតឱបយាយទៀងបង្ហាញកាយវិការថាគាត់នឹកយាយទៀងណាស់ ។ លោកត្រេកអរណាស់ ។ យាយទៀងត្រេកអរជាក្រៃលែងដែរ ។ អ្នកទាំងពីរក៏ចាប់សួរសុខទុក្ខគ្នាទៅវិញទៅមកគ្រប់ប្រការ ក្នុងរយៈពេល៦ឆ្នាំដែលបែកគ្នានេះ ។ ទីបញ្ចប់យាយទៀងសួរលោកឈឿតថា ៖

- តើសព្វថ្ងៃអូនសំណាក់នៅឯណា ?

លោកឈឿតមានការរារែកបន្ដិច មួយសន្ទុះទើបខ្សិបប្រាប់យាយទៀងថា ៖

- ខ្ញុំនៅជំរំណងច័ន្ទជាប់ព្រំប្រទល់ខ្មែរថៃ ! ។

ពុដ្ឋូច្នោះយាយទៀងរំភើបចិត្តត្រេកអរណាស់ គាត់ក៏ស្នើរសុំទៅតាមលោកឈឿត ទៅកាន់ជំរំណងច័ន្ទ ។

លោកឈឿតយល់ព្រមទទួលនូវសំណើររបស់យាយទៀងដោយរីករាយ ។ យាយទៀងសំរេចជួលរ៉ឺម៉កម៉ូតូមួយតម្លៃមួយជីមាស ជិះគ្នាបីនាក់ ម៉ែ-កូននិងលោ

កឈឿត ចេញដំណើរទៅកាន់ភូមិនិមិត្ត ដែលមានចម្ងាយប្រមាណ៣០គ.ម. ។ រ៉ឺ-ម៉កក៏រោទិ៍ម៉ាស៊ីនរួចបោះពួយយ៉ាងលឿនទៅកាន់ទីដៅ ។ រ៉ឺម៉កម៉ូតូត្រូវឆ្លងកាត់ប្រជាជនខ្មែរភៀសខ្លួនជាច្រើនពាន់នាក់ កំពុងតែដើរចេញចោលស្រុកដោយជើងពីព្រោះគ្មានមាសជួលរ៉ឺម៉កម៉ូតូជិះនឹងគេ - គួរឲ្យសង្វេគនិងអាណោចអធម៌ជាក្រៃលែង ។

ពីទីក្រុងបាត់ដំបងទៅកាន់ជំរំណាងច័ន្ទមានចម្ងាយជាង១០០គ.ម. ប្រជាជនខ្មែរភៀសខ្លួនដើរដោយជើង ត្រូវចេញដំណើរពីទីក្រុងបាត់ដំបងពីព្រលឹម ត្រូវដេកសំរាកនៅភូមិនិម្មិតមួយយប់ យប់ទី៣ទើបទៅដល់ជំរំណាងច័ន្ទ ។

ចំណែកប្រជាជនភៀសខ្លួនខ្មែរដែលមានមាស គេនាំគ្រួសារជួលរ៉ឺម៉កម៉ូតូជិះចេញចោលប្រទេសកម្ពុជាជាហូរហែរដូចប្រជាជនប្រទេសអឺរ៉ុបបណ្តើរគ្រួសារដើរលំហែកាយខែវិស្សមកាលរដូវក្តៅដូច្នោះដែរ ។

ពីទីក្រុងបាត់ដំបងទៅចំរំណាងច័ន្ទ យើងត្រូវធ្វើដំណើរឆ្លងកាត់ប្រជុំជនដូចជាផ្សារក្បាលខ្មោច, ថ្មគោល, ភ្នំតូច, មង្គលបូរី, ស៊ីសូផុន និងកូនផ្សារភូមិនិម្មិតជាដើម គ្មានឃើញក្រសួងមានសមត្ថកិច្ចណាមួយចេញមកសួររកហេតុផល ឬហាមឃាតអ្វីទាល់តែសោះ ។ ប្រជាជនខ្មែរដើរចេញចាកចោលប្រទេសកម្ពុជាពេលនោះ គឺដើរដោយសេរី គ្មានរត់ គ្មានគេចទេ ។

ដូច្នេះបង្ហាញឲ្យឃើញថា យួនហាណូយមានផែនការព្រាងទុកជាស្រេច ជាយូរឆ្នាំណាស់មកហើយ ។ ដូចជានៅក្នុងសម័យអង្គការអនាមិក ក្នុងរយៈ៤ឆ្នាំ វាគិតតែពីសម្លាប់រង្គាលរហូតទាល់តែខ្មែរស្លាប់ផុតពូជ ។ ចំណែកខ្មែរដែលនៅសេសសល់នៅរស់ ត្រូវបាក់ស្បាត ព្រោះអង្គការច្បូតកៀបដកហូតទ្រព្យសម្បត្តិអស់រលីងសល់តែបាតដៃទទេ ។ល។

លុះមកដល់សម័យយួនហាណូយចូលមកលុកលុយប្រទេសខ្មែរជំនួសអង្គ-ការអនាមិក វាបែរជាប្រមូលខ្មែរក្រហមដែលមាននិន្នាការយួន គឺអតីតខ្មែរវៀតមិ-ញ នាំយកមកបំពាក់ស័ក្តិនិងអាវុធឲ្យឡើងវិញ ។

វាបំពាក់គោលជំហរយ៉ាងមាំឲ្យក្រុមនេះ គឺពេលថ្ងៃប្រកាសតាំងតែងខ្លួនជាអ្នកស្នេហាជាតិ ពេលយប់ត្រូវប្រែក្រឡាជាចោរភ្លាម ។ ចោរប្លន់ក្នុងសម័យយួនហា-ណូយចូលរាតត្បាតលុកលុយប្រទេសខ្មែរ មានសភាពកាចសាហាវយ៉ាងអស្ចារ្យ គឺចាប់ចងរួចអារកម្តងបន្តិចៗ បង្ខំទារមាសពេជ្រ ។ ទោះមានឲ្យវា ក៏ស្លាប់ គ្មានឲ្យវាក៏ស្លាប់ ។ សែនវេទនាសឹងរកពាក្យខ្មែរសរសេរគ្មានទេ ។ ម្យ៉ាងទៀត, កូនស្រីខ្មែរក្រមុំសឹងមិនទាន់ពេញវ័យត្រូវពួកវារំលោភ រួចសម្លាប់ចោល ។ ទោះបងប្អូនរួមឈាមខ្មែរគ្មានបំណងរត់ចោលស្រុកក៏ដោយ ពេលនោះត្រូវតែរត់ចោលជាដាច

ខាត ព្រោះប្រទេសខ្មែរនៅពេលនោះ បានក្លាយទៅជានគរ «ចោរ» ទៅហើយ ( សូមបញ្ជាក់ថា ៖ ចោរយួនរាប់ពាន់នាក់ បានត្រូវគេដោះលែងពីគុកស្រុកយួន ឲ្យមកកកូរកកាយសន្តិសុខនៅស្រុកខ្មែរ ) ។

កាលណោះមានបងប្អូនខ្មែរដែលរងគ្រោះខ្លះ រត់ទៅប្តឹងយួនជាប្ញជួយ វាធ្វើព្រងើយគ្មានអើពើឡើយ ។ ពេលនោះ ប្រជាជនខ្មែរភ័យខ្លាចព្រឺញាក់សាច់ពីព្រោះឃើញអំពើចោរប្លន់សម្លាប់ដ៏ឃោរឃៅនេះដោយផ្ទាល់ៗភ្នែក ។

ដូច្នេះប្រជាជនខ្មែរអស់សង្ឃឹមគ្មានទីរំពឹង ត្រូវតែប្រមូលញាតិសារលោហិតដែលសល់នៅរស់ បណ្តើរគ្នាចាកចេញចោលមាតុភូមិជាទីស្រឡាញ់គួរឲ្យសោកស្តាយ ទុកឲ្យយួននិងក្រុមខ្មែរអាយ៉ងវា ជាហូរហែដូចជាកមិនទៅកាន់ស្រុកថៃ ។

ពីព្រោះគ្រប់ៗរូបធ្លាប់ត្រូវរងគ្រោះបាក់ស្បាតក្នុងរបបរបស់អង្គការអនាមិកម្តងរួចទៅហើយ ។ បច្ចុប្បន្នក្នុងសម័យយួនហាណូយចូលមកលុកលុយរាតត្បាតប្រទេសខ្មែរ ចោរចូលមកប្លន់ ចូលមកសម្លាប់ ។ គឺអតីតតំណាងអង្គការអនាមិកដដែល ដែលជាអតីតឃាតករ ។ មិនតែប៉ុណ្ណោះ ថែមទាំងមានប្ញជួយគាំទ្រទៀតផង ។ តើមានស្នៀតអ្វីប្រសើរជាងស្នៀតចោរនេះទៀត ? ។

ចំណែកយួនហាណូយវាលាក់មុខបានយ៉ាងជិតដដែល ។ មានបងប្អូនខ្មែរយើងខ្លះដែលខ្វះការត្រិះរិះពិចារណា កំពុងបណ្តើរគ្រួសារចេញចោលទឹកដីទុកឲ្យយួនទៅហើយ បែរជាធ្វើមាត់ជីបអួចៗសរសើរថា ៖

- យួនហាណូយមានឧបការគុណទៅវិញ !
- តើមានអ្វីគួរឲ្យខ្មាស់អៀនជាងនេះទៅទៀត ?

គឺនៅពេលដែលយាយទៀងបណ្តើរកូនស្រីចាកចេញពីមាតុភូមិកម្ពុជានៅថ្ងៃទី១៦-៦-៨០ ទើបគាត់ឃើញ ដឹង និងយល់ពីបញ្ហានេះ ។

ស្នៀតចោរនេះ យួនហាណូយបង្កើតឡើង ដើម្បីកំចាយខ្មែរឲ្យរត់ចោលទុកទឹកដីឲ្យវា ។

ស្នៀតវាយកំចាយត្រីនេះ យួនហាណូយជាវៀតមិញវាប្រើម្តងរួចហើយតាំងពីឆ្នាំ១៩៤៥ដល់១៩៥៤ ដើម្បីកំចាយខ្មែរកម្ពុជាក្រោម ។ វាបានទទួលលទ្ធផលដ៏គាប់ប្រសើរ វាអាចវាតទីយកនគរកម្ពុជាក្រោមបានយ៉ាងងាយ វាគ្មានហត់នឿយនឹងធ្វើសង្គ្រាមទេ ។

ឥឡូវនេះយួនហាណូយដដែល ប្រែឈ្មោះពីវៀតមិញទៅជាវៀតណាម កំពុងនាំយកស្នៀតវាយទឹកកំចាយត្រីនេះ មកសាបព្រួសពាសពេញកម្ពុជាកណ្តាលឡើងវិញ ដើម្បីកំចាយខ្មែរឲ្យរត់ចោលស្រុកទុកទឹកដីឲ្យវាទៀត ។

❑

នៅថ្ងៃទី១៧-៦-៨០ វេលាម៉ោង១១ តាមផ្លូវជាតិលេខ៥ មានរ៉ឺម៉កម៉ូតូចំនួន ១៥គ្រឿង កំពុងបោះពួយយ៉ាងលឿនដូចព្រួញសំដៅទៅកាន់ព្រំដែនខ្មែរ-ថៃ ។ រ៉ឺម៉កទាំងនោះផ្ទុកមនុស្សពេញ ដឹកជញ្ជូនខ្មែរស្លូតត្រង់ជាម្ចាស់ទឹកដីកម្ពុជាពិតៗដែលអស់មានទីរំពឹង ដែលអស់សង្ឃឹម ដែលភ័យខ្លាចចោរយួន ក៏រត់គេចយករួចខ្លួន បន្សល់ទុកទឹកដីឲ្យពួកវា ។

យាយទៀងជិះលើរ៉ឺម៉កទី៣ជាមួយកូនស្រីនិងលោកឈឿត ។ គាត់នឹកឃើញឡើងវិញ ពីរឿងគាត់ត្រូវរត់ចោលទឹកដីកម្ពុជាក្រោមពីខែកក្កដា១៩៤៨ គឺបណ្ដាលមកពីយួនហាណូយជាវៀតមិញ ដែលតាមសម្លាប់និងកំចាយគាត់ ។ គាត់រត់តែដៃទទេមកកម្ពុជាកណ្ដាល ។ ឥឡូវនៅម៉ោង១១ព្រឹកនៃថ្ងៃទី១៧-៦-៨០ ដោយសារយួនហាណូយជាវៀតណាម គាត់ត្រូវតែចាកចោលកម្ពុជាកណ្ដាលដោយបាតដៃទទេម្ដងទៀត ។

យាយទៀងនឹកឃើញសព្វគ្រប់ គាន់មានអារម្មណ៍ឈឺចាប់ក្តាន់ក្តាញ់ចំពោះយួនហាណូយ ចំពោះមេដឹកនាំខ្មែរ ទាំងសក្តិភូមិ ទាំងខ្មែរក្រហម គឺឆ្កួតលីលាបណ្ដោយខ្លួនឲ្យចាញ់បោកចិន ចាញ់បោកយួន គឺខ្វះសមត្ថភាពទាំងស្រុង ! ។

ដំណាក់ការប៉ុណ្ណឹងទៅហើយ យួនហាណូយវាយទីយកទឹកដីទាំងមូលទៅហើយ យួនបន្តុបអតីតខ្មែរវៀតមិញឲ្យត្រួតត្រាប្រទេសកម្ពុជាទាំងស្រុងទៅហើយ នៅតែបណ្ដោយឲ្យខ្មែរយល់ច្រឡំរក៏រី ដើរចាកចោលទឹកដីទុកឲ្យយួន ទុកឲ្យអតីតខ្មែរវៀតមិញទៅហើយ បែរជាអរគុណយួនជាមេឃាតករ ជាមេចោរឈ្លានពានទៅវិញ ។ ពេលនោះយាយទៀងស្រែកយ៉ាងខ្លាំង ដើម្បីបន្ធូរទ្រូងដែលកំពុងតែឈឺចុកចាប់ ។ គាត់អស់សង្ឃឹមហើយ ។

- ណ្ហើយចុះ ! លាហើយមាតុភូមិអភ័ព្វអើយ ! លាហើយទឹកដីជាកេរ្តិ៍ដំណែលដូនតា ! លាទាំងអាល័យ ! លាទាំងឈឺចាប់ ! លាហើយមិនដឹងថ្ងៃណានឹងបានវិលត្រឡប់វិញទេ...។

អ្នកបើករ៉ឺម៉កម៉ូតូចាប់ហ្វ្រាំងង៉ឹត ! ។ សម្លេងនេះដាស់សតិអារម្មណ៍យាយទៀង ឲ្យគាត់ភ្ញាក់ដឹងខ្លួន...។

យាយទៀងក៏ក្រឡេកមើលទេសភាពជុំវិញ ។ គាត់ស្គាល់ក៏លាន់មាត់ថា ៖

- ឱយើងមកដល់ភូមិនិមិត្តហើយតើ !

យើងទាំងបីនាក់ក៏នាំគ្នាចុះពីរ៉ឺម៉កម៉ូតូ ។ យាយទៀងហុចមាសមួយជីឲ្យថ្លៃឈ្នួលទៅអ្នកបើកបរ ព្រមទាំងថ្លែងអំណរគុណ ហើយនិងសូមលាអ្នកបើកបរតែត្រឹមណោះ ។

យាយទៀងក៏បណ្ដើរកូនស្រីតាមក្រោយលោកឈឿត ដើម្បីបន្តដំណើរទៅ

មុខទៀត ។ យើងដើរដោយជើង កាត់ព្រៃខាងស្តាំដៃ ។

លុះដើរចូលក្នុងព្រៃជ្រៅបានចម្ងាយប្រហែល៥គ.ម. ស្រាប់តែប្រទះចោរមួយក្រុមចំនួន២០នាក់ អាយុសឹងមិនដល់២០ឆ្នាំផង ជាយួនហាណូយ កាន់អាវុធគ្រប់ដៃ កំពុងប្លន់ កំពុងចាប់កូនក្រមុំខ្មែរប្រមូលនាំចូលព្រៃ ដើម្បីរំលោភលេងសប្បាយ រួចសម្លាប់ចោល ។ល។

ឃើញគ្រាអាសន្នដ៏ធ្ងន់ធ្ងរមកដល់យ៉ាងនេះ យាយទៀងភ័យតក់ស្លុតឥតឧបមា ។ ស្រាប់តែលោកឈឿតនឹកឃើញល្បិចមួយ !... លោកក៏កៀកកអង្គារាធ្វើដូចជាប្តីប្រពន្ធពិតៗ ហើយក៏បណ្តើរដើរកាត់ហ្វូងចោរដ៏សាមាន្យធ្វើព្រងើយ ។

អាចោរជាយួនហាណូយបែរភ្នែកសម្លឹងមើលម៉ែកូនពីរនាក់ដ៏កំសត់នេះដែរ ។ លុះវាឃើញតែសំពត់អាវជាប់នឹងខ្លួនដាច់រយ៉ៃ ដៃទទេយ៉ាងនេះ វាក៏មិនអើពើ ។ ដូច្នេះយាយទៀងនិងកូនស្រីក៏បានគេចចាកផុតគ្រោះថ្នាក់ជាលើកទីមួយ ហើយក៏បន្តដំណើរទៅមុខទៀតដោយមិនហ៊ានសំរាកទេ ។

ដើរផុតពីចោរយួនហាណូយចម្ងាយប្រហែល៣គ.ម. កំពុងតែភ័យអរស្រាប់តែជួបខ្មែរមួយក្រុម មិនដឹងជាក្រុមស្អី ឈរយាមនៅទីនោះ មានគ្នា៧នាក់អាវុធគ្រប់ដៃ ។ ក្រុមនេះសាហាវជាជាងអាចោរយួនហាណូយទៅទៀត វាស្រែកសន្ធាប់ចោទយាយទៀងថាជាយួន ។ រួចហើយពួកវាចាប់យាយទៀងនិងកូនស្រីឆែកឆេរពាសពេញខ្លួន ព្រមទាំងសំឡុតសួរថា ៖

- តើកូនស្រីនេះមានប្តីឬនៅ ? ត្រូវតែចាប់ឃុំទុកនៅទីនេះសិន ! ។

ពេលនោះយាយទៀងទៅជាគាំងមាត់ ស្លុតបំពង់កវិសដួលសន្លប់ស្លាប់តែម្តងនឹកទៅគួរឲ្យហួសចិត្តគ្មានពាក្យឆ្លើយ គាត់គ្រវីក្បាលងក់ងើកៗដូចមនុស្សវង្វេង ។

ស្រាប់តែឃើញលោកឈឿតរត់ញាប់ជើងមកជួបក្រុមស្អីគេនេះឆ្លើយប្រាប់ថា ៖

- នាងនេះជាប្រពន្ធចុងរបស់ខ្ញុំ ( ក្រុមនេះស្គាល់លោកឈឿតច្បាស់ ហើយដឹងថាលោកឈឿតមានប្រពន្ធហើយ ) ។

មីងនេះជាម្តាយរបស់នាង ។ គាត់វង្វេងស្មារតីអស់ទៅហើយ ។ លោកឈឿតលើកដៃកៀកកនាងយឺទ្រី-អង្គារាម្តងទៀត រួចបណ្តើរបន្តដំណើរទៅមុខទៀត ។

យាយទៀងនិងកូនស្រីបានរួចចាកគ្រោះថ្នាក់ជាលើកទី២ ! រួចក៏បន្តដំណើរចូលជំរំណងច័ន្ទ ។

ថ្ងៃទី១៧-៦-៨០ វេលាម៉ោង៤យប់ យាយទៀងនិងកូនស្រីបានចូលដល់ជំរំណងច័ន្ទដោយសុវត្ថិភាព គេចចាកផុតគ្រោះថ្នាក់គ្រប់បែបយ៉ាងមួយរយៈ ដោយសារសប្បុរសធម៌របស់លោកឈឿតជាភ្នាក់ងារប៉ូលីសប្រចាំការនៅជំរំណងច័ន្ទ

ជួយការពារនិងឧបត្ថម្ភ ។

❑ ❑

❑

# យាយទៀងដើរមើលជំរំណងច័ន្ទ

ព្រលឹមថ្ងៃទី១៨-៦-៨០ យាយទៀងបណ្ដើរអង្ការាមើលជំរំណងច័ន្ទ ដែលមានសុទ្ធសឹងតែប្រជាជនខ្មែរស្លូតត្រង់ ភ័យខ្លាចអាចោរជាកូនចៅរបស់យួនបា-ណ្យួយពួនសម្លាប់ ក៏នាំគ្រួសាររត់មកជ្រកកោនក្រោមម្លប់បារមីអង្គការ H.C.R. ជួយចិញ្ចឹមជួយឧបត្ថម្ភ ។

ជំរំណងច័ន្ទស្ថិតនៅលើទឹកដីខ្មែរ មានចម្ងាយ២០០ម៉ែត្រពីព្រំដែនខ្មែរ-ថៃតែប៉ុណ្ណោះ ។ ជំរំនេះមានទំហំប្រហែលទីក្រុងបាត់ដំបង មានមន្ទីរពេទ្យ មានប្រៃសណីយ៍ មានសន្តិសុខ និងមានកន្លែងចែកជំនួយជាពិសេសគឺអង្ករ ។ អង្ករទាំងនោះចែកឲ្យខ្មែរដោយសេរី នាំយកចូលរហូតដល់ផ្ទៃក្នុងនៃប្រទេសកម្ពុជា ។

ថ្ងៃនោះយាយទៀងបណ្ដើរកូនស្រីដើលចូលមើលផ្សារលក់ទំនិញជាសាធារណៈ ដែលមានលក់ប្រដាប់ប្រើប្រាស់គ្រប់ជំពូក ។ គេលក់គេទិញដោយសេរី ។ យាយទៀងឈរគយគន់សម្លឹងមើលសភាពដ៏អ៊ូរអរដែលគាត់ខានឃើញអស់រយៈ៦ឆ្នាំទៅហើយ ។ គាត់មានមនោសញ្ចេតនាកោតសរសើរនូវគុណសម្បត្តិរបស់អង្គការមនុស្សធម៌អន្តរជាតិ ដែលឈឺឆ្អាលជួយទំនុកបំរុង ឧបត្ថម្ភ ចិញ្ចឹម និងការពារជនជាតិខ្មែរដែលកំពុងរងគ្រោះនោះជាក្រៃលែង ។

លុះគាត់ដើរដល់កន្លែងលក់នំបញ្ចុក គាត់ក៏បានជួបប្អូនជីដូនមួយម្នាក់ឈ្មោះស៊ុង-ហឿន ។ ស៊ុង-ហឿនឱបបងស្រីយំផងសើចផង ព្រោះត្រេកអរជាក្រៃលែង ដែលបានឃើញបងស្រីអាចគេចផុតពីចង្កូមមច្ចុរាជ ។ ទើបតែនៅពេលនេះ ទើបស៊ុង-ហឿនដឹងថាយាយទៀងត្រូវព្រាត់ប្រាស់កូនអស់រលីង ។ ពេលនោះ ស៊ុងហឿនឱបបងស្រីយំបន្តទៅទៀត ។ មួយសន្ទុះទើបស៊ុង-ហឿនប្រាប់បងស្រីថា ៖

– បង, ខ្ញុំបានជួបឃីទ្រី-វិច្ឆិកា ( កូនប្រុសទី៥របស់យាយទៀង ) ។ ប៉ុន្តែសព្វថ្ងៃនេះមានតែឈ្មោះអៀងទេ ទើបដឹងថាវិច្ឆិកាសំណាក់នៅទីណា ។ ដូច្នេះល្ងាចនេះខ្ញុំហៅអៀងមកជួបបង ។

នៅយប់ថ្ងៃទី១៨-៦-៨០ ក្នុងកូនខ្ទមស្បូវមួយស្ថិតនៅជាប់របងខាងកើតក្នុងជំរំណងច័ន្ទ គ្រួសារស៊ុង-ហឿននិងអៀងសើចសប្បាយរីករាយទទួលយាយទៀង ។ អៀងរ៉ាយរ៉ាប់ធានាចាត់មនុស្សទៅតាមរកវិច្ឆិកា ហើយប្រាប់យាយទៀងថា ៖

– ធំ (ពាក្យសំរាប់ហៅអ្នកដែលមានអាយុលើសឪពុកឬម្ដាយរបស់ខ្លួន ។ អ្នក

ស្រុកខ្លះហៅ«អុំ») ! វិច្ឆិកាវិះតែត្រូវគេសម្លាប់ ព្រោះស្ម័គ្រចិត្តចូលបំរើរ.ជ.រ.ប.ខ. (រណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ បង្កើតឡើងដោយអតីតរដ្ឋមន្ត្រីទី១សឺន-សាន នៅប្រទេសថៃថ្ងៃទី៩-១០-១៩៧៩ ។ ជាអង្គការមិនមែនកុម្មុយនិស្តប្រឆាំងនឹងការរំលោភរបស់រដ្ឋាភិបាលវៀតណាមមកលើប្រទេសកម្ពុជា (FNLPK : Front National de Libération du Peuple Khmer) ដែលនៅពេលនោះមានលោកមូល-សារីជាមេបញ្ជាការ ។ លោកមូល-សារីជាអតីតវរសេនីយ៍ឯកផ្នែកខាងកាំភ្លើងធំ ។ លោកបានធ្វើពលិកម្មបង្កើតជំរំ០០៧មុនគេ ដើម្បីជួយឧបត្ថម្ភនិងការពារប្រជាជនខ្មែរដែលភៀសខ្លួនមកជ្រកសំណាក់នៅទីនោះ ។ លោកដឹងថា វិច្ឆិកាជាកូនរបស់ធំ ហេតុដូច្នេះហើយលោកក៏ថែទាំវិច្ឆិការទុកដូចជាកូនលោកបង្កើត ។ ប៉ុន្តែធំអើយ ! ខ្មែរយើងមិនចោលចរិតអាក្រក់ទាល់តែសោះ ! អ្នកក្រោមបង្គាប់របស់លោក បែរជាក្បត់លោកទៅវិញ ។ វាចាត់ការសម្លាប់លោកដើម្បីដណ្តើមអំណាច ។ វីរជនចិត្តធម៌នេះដឹងខ្លួនទាន់ក៏រត់ចោលជំរំ០០៧ ទៅជ្រកពួននៅណងម៉ាំង ។ លោកនាំទាំងវិច្ឆិកាទៅជាមួយផង ។

បន្តបន្ទាប់មក ប្រជាជនខ្មែរដែលស្គាល់សមត្ថភាពរបស់លោក គេក៏សុំអញ្ជើញលោកមកការពារជំរំណងច័ន្ទវិញ ។ ប៉ុន្តែធំអើយរឿងក្បត់ដណ្តើមអំណាចគ្នានៅតែមានជាបន្តមកទៀតមិនចេះចប់ ។ គឺចុងខែមេសាឆ្នាំ១៩៨០ ស្រាប់តែមានក្រុមផ្សេងចូលមកព័ទ្ធចាប់ក្រុមលោកមូល-សារីនាំយកទៅសម្លាប់ ។

លោកមូល-សារីក៏រត់គេចម្តងទៀត រួចហើយលោកក៏ចាត់មនុស្សឲ្យមកប្រាប់ខ្ញុំនូវអព្ភូតហេតុទាំងនេះ ព្រមទាំងប្រាប់ឲ្យខ្ញុំលែលកជួយសង្គ្រោះវិច្ឆិកាផង ព្រោះវិច្ឆិកាជាប់ភារកិច្ចយាមនៅខ្សែត្រៀមទី៣ ។ នៅពេលនោះខ្ញុំក៏ខ្ចប់បាយម្ហូបមួយកញ្ចប់រួចជិះកង់យកទៅឲ្យវិច្ឆិកា និងប្រាប់ឲ្យគេកប់លាក់អាវុធរួចរត់គេចចេញជាប្រញាប់ ។

ឥឡូវលោកមូល-សារីធុញទ្រាន់នូវឆាកជីវិតផ្សងព្រេងនេះ លោកក៏សំរេចចិត្តនាំគ្រួសារចាកចេញចោលប្រទេសកម្ពុជាទៅនៅឯបាងកកទៅហើយ ។ មុនលោកចេញទៅ លោកនាំវិច្ឆិកាទៅផ្ញើជំរំ០០៧ឯណោះវិញ ។ ជាឱកាសល្អណាស់ដែលធំមកទាន់ពេលដូច្នេះ ។ ធំគួរតែនាំវិច្ឆិកាចេញឲ្យផុតពីចង្កូមមច្ចុរាជនេះជាប្រញាប់ ។

សព្វថ្ងៃគ្មានច្បាប់គ្មានវិន័យប្រកាន់បក្សប្រកាន់ពួក ឃើញតែសម្លាប់គ្នាជាហូរហែ ។ ដូចជាពីយប់មិញនេះ មានអតីតវរសេនីយ៍ត្រីម្នាក់ត្រូវគេកាប់ដាច់ក្បាលស្លាប់នៅជាប់របងខាងលិចជំរំនេះ ព្រោះតែលោកនិងប្រពន្ធមានចិត្តសប្បុរស ជួយទំនុកបំរុងយុវជនខ្លះដែលគ្មានទីពឹង ។

ដើម្បីចិញ្ចឹមជីវិតនិងបានជាកំរៃសំរាប់ផ្គត់ផ្គង់អ្នកផងទាំងពួង លោកទិញដូររបស់របរពីស្រុកថ្លៃចូលមកស្រុកខ្មែរ ។ លុះជនពាលដឹងថាលោកមានមាសបង្គរយប់កើតគ្រោះថ្នាក់នោះ គឺវាមកគោះទ្វារស្រែកសុំជួបលោកដូចធម្មតា ។ ពេលលោកដើរចេញទៅជួប ចោរក៏កាប់លោកដាច់ក្បាលភ្លាម រួចវាចាប់ចងប្រពន្ធរបស់លោកកំញើញប្លន់យកមាសអស់រលីង ។

អៀងនិយាយដល់ត្រឹមហ្នឹង ស្រាប់តែឃើញយុវជនម្នាក់អាយុប្រហែល២៧ឆ្នាំទឹកមុខកាចសាហាវ សក់ក្បាលក្រញាញ់ប្រាស់ស្មា មានពាក់គ្រឿងសិលពេញកដើរចូលមកបញ្ជាឲ្យអៀងរកស្រាឲ្យផឹក ។

អៀងមានអារម្មណ៍ភ័យតក់ស្លុត ។ គ្មានហ៊ានបង្អង់ អៀងក៏រត់ទៅយកស្រាមកឲ្យវាផឹកភ្លាម ។ ពេលវាលើកដៃស្ដាំទទួលកែវស្រា យាយទៀងភ្ញាក់សម្លឹងភ្លឹកព្រោះនៅកដៃរបស់វា មានខ្សែមាសមួយខ្សែយ៉ាងធំទម្ងន់ប្រហែល៣ជីឡឹង មានក្បាច់យ៉ាងល្អអស្ចារ្យ ។ លុះវាផឹករួចហើយ វាក៏ដើរចេញទៅវិញបាត់ទៅ ។

ស៊ុន-ហឿនដកដង្ហើមយូរដើម្បីបន្ធូរដើមទ្រូង រួចនិយាយខ្សឹបៗប្រាប់យាយទៀងថា ៖

- បងអើយ ! អំបាញ់មិញនេះខ្ញុំភ័យសឹងដាច់ដង្ហើមស្លាប់ពីព្រោះមនុស្សនេះកាចសាហាវដ៏មហាអស្ចារ្យ វានៅក្នុងក្រុមមួយយ៉ាងឃោរឃៅ ។ មេក្រុមឈ្មោះច័ន្ទ-ភក្ដី (ឈ្មោះនេះអង្គការសន្មត់ដាក់ឲ្យក្រុមមួយ នៅពេលណាដែលមេម្នាក់ស្លាប់ទៅ មេថ្មីឡើងមកកាន់កាប់ក៏មានឈ្មោះច័ន្ទ-ភក្ដីដដែល) ។ បើវាដឹងថាមានប្រជាជនទើបមកដល់ជំរំណាងច័ន្ទ វាតែងតែមកចាប់យកទៅឆែកឆេររកមាសពេជ្រ ។

ខ្សែដៃដែលវាពាក់គឺជាខ្សែដៃរបស់ស្រីម្នាក់នៅក្នុងក្រុមជាមួយវា ។ ស្រីនោះកាចសាហាវណាស់ ។ វាតែងតែដើប្លន់សម្លាប់មនុស្ស ហើយអួតអាងថាខ្លួនវាខ្លាំងពូកែ កាប់មិនមុត បាញ់មិនផ្ទុះ ។ ឥឡូវត្រូវមនុស្សអំបាញ់មិញនេះសម្លាប់ចោលនៅវេលាថ្មីៗនេះ រួចវាដោះខ្សែដៃយកមកពាក់ខ្លួនវាវិញ ។ ស៊ុង-ហឿនបន្តទៅទៀតថា ៖

- បងសំណាក់នៅទីនេះយូរទៅទៀតមិនបានទេ ។ ស្អែកនេះខ្ញុំនឹងពឹងសឺន-នីឲ្យទៅកាន់ជំរំ០០៧ ហៅវិច្ឆិកាមកជួបបង ដើម្បីឲ្យបងនាំវាចាកចេញឲ្យផុតពីស្ថានយមរាជនេះជាបន្ទាន់បំផុតកុំបង្អង់ឡើយ ។

នៅថ្ងៃទី២០-៦-៨០ ម៉ោង៣រសៀល យាយទៀងបានជួបវិច្ឆិកា ។ យាយទៀងក៏និយាយពីគោលបំណងរបស់គាត់ ដែលត្រូវតែនាំកូនទាំងពីរគឺអង្គារនិងវិច្ឆិកាភៀសខ្លួនទៅតាមជើន-សា នៅឯប្រទេសបារាំង ។

វិច្ឆិកាអង្គុយគិតមួយសន្ទុះក៏គ្រវីក្បាលបដិសេធមិនព្រមចាកចេញចោលទឹកដី

កម្ពុជាឡើយ ។ វិច្ឆិការមានបំណងយ៉ាងមាំមិនមោះមុត នៅបំរើរ.ជ.រ.ប.ខ.ដើម្បីកំទេចយួនហាណូយ ជាចោរឈ្លានពានដើម្បីរំដោះទឹកដីកម្ពុជា ។ ពេលនោះ ស៊ុន-ហឿនខំពន្យល់នូវគ្រោះថ្នាក់ផ្សេងៗដែលអាចបណ្តាលឲ្យស្លាប់ ។ ទីបញ្ចប់ក៏បង្ខំថា ៖

– វិច្ឆិកាឯងត្រូវតែភៀសខ្លួនតាមម្តាយ ទៅកាន់ប្រទេសទីពាជាដាច់ខាត ។

វិច្ឆិកាគ្រវីក្បាលជដែលជាសញ្ញាថា ៖

– មិនទៅទេ ! គ្មានចម្លើយ ។

ចំណែកយាយទៀង ពេលបានជួបកូនប្រុសទី៥របស់គាត់ គាត់ត្រេកអរជាក្រៃលែង ។ លុះឮកូនប្រកែកមិនព្រមភៀសខ្លួនទៅកាន់ប្រទេសទីពាដូច្នោះ គាត់ស្រក់ទឹកភ្នែកច្រោកៗ ។ មួយសន្ទុះទើបគាត់ចាប់ផ្តើមធ្វើអត្ថាធិប្បាយ ប្រៀបធៀបពន្យល់កូនប្រុសដូចតទៅ ៖

– ឱកូនអើយ ! មកពីប៉ានិងម៉ាក់គិតជាតិគោរពទុកចិត្តទាំងស្រុងលើមេដឹកនាំប្រទេសខ្មែរយ៉ាងនេះហើយ បានជាយើងធ្លាក់ខ្លួនជាមួយខ្មែរឯទៀតរាប់លាននាក់ដូចពេលនេះ ។ អ្នកណាទៅដឹកថាអ្នកដឹកនាំខ្មែរចោលម្សៀតធ្វេសប្រហែសហ៊ានបណ្តោយខ្លួនឲ្យចាញ់បោកកុម្មុយនិស្តអញ្ចឹងនោះ ? ។

ដូចជាដើមខែមេសាឆ្នាំ១៩៧៥ មានមិត្តភក្តិនិងប្អូនៗរបស់ប៉ាម៉ាក់បបួលគ្រួសារយើងរត់ភៀសខ្លួនចេញចោលស្រុកខ្មែរ ប៉ុន្តែប៉ាម៉ាក់បែរជាពន្យល់ឃាត់អ្នកទាំងអស់គ្នាថា ត្រូវតែនៅបំរើជាតិទៅវិញ ។ ឥឡូវក្នុងគ្រួសាររបស់យើងត្រូវរងគ្រោះបាត់បង់ជីវិតសឹងផុតពូជ ត្រូវអង្គការសម្លាប់ ត្រូវបាត់ខ្លួន ។ យាយទៀងបន្តទៀតថា ៖

– មនុស្សចាស់ មានតែម៉ាក់ម្នាក់គត់ដែលសល់នៅរស់ ! ចំណែកយុវជនក្មេងៗម៉ាក់ទើបតែបានជួបកូនឯងម្នាក់គត់ ។ ដូច្នេះជីវិតរបស់កូនមានតម្លៃណាស់សំរាប់គ្រួសាររបស់យើង ដើម្បីបន្តពូជពង្សវង្សត្រកូល«ឃី»តទៅទៀត ។ ពេលនេះម៉ាក់សុំអង្វរកូនត្រូវតែភៀសខ្លួនទៅជ្រកសំណាក់នៅប្រទេសបារាំងមួយរយៈសិន ។ បើថ្ងៃក្រោយកូនបានជួបមេដឹកនាំខ្មែរណាដែលមានសតិសម្បជញ្ញៈមុតជ្រៅ ស្នេ-ហាជាតិពិតៗមិនក្លែងក្លាយ មិននិយមបក្សពួក សឹមកូនចូលខ្លួនទៅបំរើជាតិជាមួ-យគេ ។ ម៉ែចង់ណាស់ហើយឲ្យកូនបានបំរើជាតិ តែត្រូវកូនមើលមុខមើលក្រោយកុំឲ្យចូលអន្ទាក់សត្រូវម្តងទៀតណ៎ាកូនណ៎ា ! បើមិនដូច្នោះទេ កូនមុខតែស្លាប់ខ្លួនអាសារឥតការជាមិនខាន ។ យាយទៀងបន្តទៅទៀតថា ៖

– បើមេដឹកនាំខ្មែរណាដែលយល់និងស្គាល់ច្បាស់អំពីលក្ខណៈសង្គ្រាមពិតៗនៃប្រទេសខ្មែរ ថាសង្គ្រាមនេះជាសង្គ្រាមរវាងយួននិងខ្មែរ ។

- បើមេដឹកនាំខ្មែរណាដែលយល់និងស្គាល់ច្បាស់អំពីលក្ខណៈសង្គ្រាមពិតៗនៃប្រទេសខ្មែរ ថាសង្គ្រាមនេះជាសង្គ្រាមរវាងយួននិងខ្មែរ,

- បើមេដឹកនាំខ្មែរណាចេះពន្យល់ខ្មែរយល់ថា ប្រទេសខ្មែរត្រូវវិនាសអន្តរាយធ្លាក់ក្រោមសូន្យ គឺបណ្ដាលមកពីយួនហាណូយ ដែលប្រើតែកលល្បិច,

- ជាពិសេស បើមេដឹកនាំខ្មែរណាមានសមត្ថភាពយ៉ាងគ្រប់គ្រាន់ នៅពេលនោះកូនត្រូវប្ដូរជីវិតបូជារូបកាយបំរើចុះ ! កូនអាចវិលត្រឡប់ចូលកាន់មាតុភូមិយើងវិញបានទេតើ ។ តែសព្វថ្ងៃនេះ ម៉ែមើលទៅហាក់ដូចជាពេលវេលាមិនទាន់ដល់ ទេ ។ បើកូនចូលឥឡូវ វាមិនខុសគ្នាពីសត្វមមាចដែលហើរចូលភ្លើងទេណា ។

- ស្ថានការណ៍ឥឡូវនេះ វាច្របូកច្របល់ដូចសម្លរកកូរ ឬដូចឡានបាក់ចង្កូតអញ្ចឹង ។ ដូច្នេះគួរកូនឈប់ស្នេះទុករឿងរំដោះជាតិមួយអន្លើសិន ។

យាយទៀងអធិប្បាយវែកញែក នូវល្បិចកលរបស់យួនហាណូយយ៉ាងវែងយ៉ាងល្អិតល្អន់ និងយ៉ាងពិស្ដារ ទីបញ្ចប់គាត់បញ្ជាក់ថា ៖

- នែកូនអើយ ! ពីថ្ងៃមុនយួនហាណូយប្រើតែកលល្បិច នគរកម្ពុជាក្រោមត្រូវធ្លាក់ក្នុងកណ្ដាប់ដៃរបស់វាជាស្វ័យប្រវត្តិ ។ វាគ្មានឡើយហាត់នឹងធ្វើសង្គ្រាមទាល់តែសោះ ។ បច្ចុប្បន្ននេះវាកំពុងតែប្រមូលកលល្បិចទាំងអស់នោះ នាំយកមកសាបព្រួសពាសពេញប្រទេសកម្ពុជា ដើម្បីលេបទឹកដីកម្ពុជាមួយនគរទៀត ។ វាគ្រាន់តែកែទម្រង់បន្តិចៗតែប៉ុណ្ណោះ ។

ឧទាហរណ៍ដូចជា វាប្រើឈ្មោះអង្គការអនាមិក ប៉ុន្តែអង្គការមានលទ្ធភាពអាចសម្លាប់ខ្មែរ ជាពិសេសអ្នកចេះដឹង បញ្ញវ័ន្ត អស់ចំនួនរាប់លាននាក់ ។ ចំណែកឯទ្រព្យសម្បត្តិក្នុងមួយនគរខ្មែរ អង្គការប្រមូលដឹកនាំចេញអស់រលីង សេសសល់តែបន្តិចបន្តួចអង្គការបំផ្លាញចោលខ្ទេចខ្ទីអស់ ។ កូនអើយ, មានតែមនុស្សខ្វាក់ទេទើបមិនឃើញអព្ភូតហេតុនេះ ។ យាយទៀងបន្តទៀតថា ៖

ឥឡូវយួនហាណូយចេញមុខយ៉ាងច្បាស់ក្រឡែត ចូលមករាតត្បាតលុកលុយ ដើម្បីត្រួតត្រាប្រទេសកម្ពុជាឲ្យបានស្របច្បាប់អន្តរជាតិ ។

- ទី១ វាកំពុងដុតដៃដុតជើងបង្កើតខ្មែរថ្មី នាំយកមកជំនួសយើងជាខ្មែរម្ចាស់ទឹកដីកម្ពុជាពិតៗ ដែលកំពុងតែបន្តកន្ទុយគ្នាស្លាប់ ដែលកំពុងតែរត់ចោលស្រុក ។

- ទី២ ដើម្បីបំភ័ន្តមតិពិភពលោកនិងមតិខ្មែរ យួនហាណូយបំបែកខ្មែរអាយ៉ងរបស់វាជាអតីតខ្មែរវៀតមិញ និងជាអតីតខ្មែរក្រហមដែលមាននិន្នាការយួនជាពីរក្រុម ៖

★ ក្រុម(ក) មានហេង-សំរិន, ជា-ស៊ីម, ហ៊ុន-សែន, តាប៉ែត ជាដើមជាអ្នកឈ្នះ ឲ្យចេញមុខបំបាំងយួន ជាអ្នកដឹកនាំរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុ

ជា រួចប្រកាសបំភ័ន្តថា ជាក្រុមខ្មែរស្នេហាជាតិ ។

★ ក្រុម(ខ) មានប៉ុល-ពតជាមេដឹកនាំ ធ្វើជាអ្នកចាញ់បង្កប់ខ្លួនពាសពេញព្រៃពាក់ឃីហៅខ្មែរក្រហមដដែល មានចិនគាំទ្រនិងផ្តល់អាវុធដដែល ។ យួនហាណូយមានផែនការយ៉ាងសម្ងាត់ បង្កើតខ្មែរក្រហម រួចលួចបញ្ចេញសកម្មភាពស្របៗជាមួយខ្មែរក្រហមរបស់ខៀវ-សំផនជានិច្ច ដើម្បីងាយសម្លាប់បំផុតពូជខ្មែរ និងឆ្លៀតសម្លាប់បំផុតពូជខ្មែរក្រហមនិន្នាការខ្មែរ ។

ដូច្នេះកូនត្រូវតែដឹងនិងត្រូវតែប្រយ័ត្នឲ្យមែនទែនចំពោះក្រុមខ្មែរនិន្នាការយួននេះ ។ ព្រោះថាវាចំពាក់គោលជំហរយ៉ាងមាំដែលមានដំណាក់ការជាដំបូងគឺត្រូវកំទេចសក្តិភូមិនិងចក្រពត្តិ ។

យួនហាណូយដឹងថាសម្តេចសីហនុនិងលោកសឺន-សានប្រធានរណសិរ្សរ.ជ.រ.ប.ខ. ព្រមទាំងខៀវ-សំផនជាមេខ្មែរក្រហម រួបរួមកម្លាំងគ្នាកំទេចពួកវាដើម្បីរំដោះទឹកដីកម្ពុជា ។ ដូច្នេះវាក៏បង្កើតល្បិចមួយទៀតភ្លាម ដើម្បីនាំយកមកទប់ទល់នឹងកម្លាំងដែលអ្នកដឹកនាំខ្មែរទាំងពីបង្កើត ។ វាដឹងថាកុមារកំព្រាជាតិខ្មែរស្អប់ខ្ពើមហើយមានគំនុំចងសងសឹកចំពោះខ្មែរក្រហម ។ ដូច្នេះវាដុតដៃដុតជើងបើកបរទ្បានដើរប្រមូលកុមារកំព្រា រួចដឹកនាំចេញពីប្រទេសកម្ពុជាជាបន្តបន្ទាប់ ។ វាប្រាប់ថានាំយកទៅរៀននៅហាណូយ ដោយដាក់ឈ្មោះថា ៖ «ក្រុមកុមារឈានមុខ» ។ ដើម្បីបង្ហាត់ហ្វឹកហ្វឺនតាមក្បួនយុទ្ធសាស្ត្ររបស់វា រួចញុះញង់បន្ថែមខ្ចីដៃក្រុមនេះដើម្បីកំទេចខ្មែរក្រហមនិន្នាការខ្មែរ និងក្រុមខ្មែរណាដែលគាំទ្រឬសមគំនិតជាមួយ។ យាយទៀងសម្លឹងមុខកូនប្រុសមួយសន្ទុះ ហើយបន្តទៀតថា ៖

កលល្បិចយួនហាណូយមានសភាពល្អិតល្អន់ណាស់ ។ វាខ្ចីដៃខ្មែរឲ្យលោតសម្លាប់តែខ្មែរគ្នាឯង ។ យួនហាណូយជាវៀតមិញក្តី ជាវៀតកុងក្តី អួតបំពានដោយឥតអៀនខ្មាស់ថា បូដូយស្ម័គ្រចិត្តបូជាសាច់ឈាមដើម្បីមកជួយខ្មែរអស់ចំនួនបីលើករួចហើយ ។ ចូរកូនកុំជឿវាឲ្យសោះ, មិនមែនទេ, វាបោកយើងទេ ! ការពិតវាចូលមកដើម្បីប្រើគ្រប់មធ្យោបាយ ញុះញង់បំបែកបំបាក់ខ្មែរតាមចំណុចខ្សោយនានា រួចបង្កបង្កើតសង្គ្រាម ទុកឲ្យខ្មែរច្បាំងគ្នា សម្លាប់គ្នាជាហូរហែ ។ ញ៉ាំងឲ្យខ្មែរស្លាប់បន្តិចម្តងៗ រហូតផុតពូជតែប៉ុណ្ណោះ ។ យាយទៀងបែរភ្នែកសម្លឹងមុខកូនប្រុសជាលើកទី២ ព្រមទាំងបញ្ជាក់ថា ៖

– ឱ ! កូនប្រុសដ៏កំសត់អើយ ! គ្រោះថ្នាក់នៃប្រទេសនិងប្រជាជនខ្មែរនៅពេលនេះមានសភាពធ្ងន់ក្រៃលែងលើសសព្វមួយដង ។ ម្តាយសង្ឃឹមថា សេចក្តីពន្យល់ប្រៀបធៀបរបស់ម្តាយនៅពេលនេះ ល្មមគ្រប់គ្រាន់ឲ្យកូនដឹងហើយ ។ គ្មានអ្វីគួរឲ្យរារែកស្ទាក់ស្ទើរ គ្មានអ្វីគួរឲ្យសង្ស័យទៀតទេ ។

ចំណែកវិច្ឆិកាលុះបានស្តាប់នូវពាក្យពេចន៍ដ៏មានខ្លឹមសាររបស់ម្តាយវ៉ែកញ្ញែក ប្រៀបធៀបសព្វគ្រប់ហើយ ក៏នៅស្ងៀមដោយស្រមៃឃើញថា តាំងពីដើមមកម្តាយរបស់ខ្លួន ទោះជាចោរប្លន់ចាប់វាយធ្វើបាបជាច្រើនលើកច្រើនដងមកហើយក៏ដោយ នៅពេលដែលកូនៗបបួលគាត់ចាកចេញពីស្រុក គាត់តែងតែប្តូរផ្តាច់មិនរត់ចោលជាដាច់ខាត ។ តែនៅពេលនេះ បែរជាគាត់សំរេចចិត្តនាំកូនចេញចោលទឹកដីជាកេរ្តិ៍ដំណែលដូនតាទុកឲ្យយួនទៅវិញ ។ វិច្ឆិកាយល់ឃើញថា ចុះបើមេដឹកនាំខ្មែរចាញ់បោកយួនចាញ់បោកចិន លោតច្បាំងតែគ្នាឯង រួចបណ្តោយឲ្យយួនប្រើកលល្បិចបោលសំរុកចូលមកជួយជាលើកទី៤ម្តងទៀត តើវាសនានៃប្រជាជនខ្មែរក្លាយទៅជាអ្វីទៅ ? ។

វិច្ឆិកាធ្វើមុខស្លូតឈប់រារែកក៏ឆ្លើយភ្លាមថា ៖

- បាទម៉ាក់ ខ្ញុំយល់ព្រមទៅជាមួយម៉ាក់ហើយ ! ។

ពុចម្លើយយល់ព្រមរបស់វិច្ឆិកាភ្លាម ស៊ុង-ហឿននិងអៀង ជូនពរដល់គ្រួសារដ៏កំសត់នេះ ឲ្យបានសំរេចតាមសេចក្តីប្រាថ្នា ។

ស៊ុង-ហឿនរៀបបាយជូនយាយទៀង ចំណែកឯអៀងវិញក៏ថយចេញទៅទាក់ទងរកអ្នកជូនដំណើរ ។

ពេលជួបជុំបាយល្ងាច អៀងវិលត្រឡប់មកដល់ល្មម ។ អៀងប្រាប់យាយទៀងថា គាត់ត្រូវចេញដំណើរនៅម៉ោងប្រាំព្រឹក ថ្ងៃទី២៣-៦-៨០ ។

នៅពេលកំពុងបរិភោគបាយល្ងាច ដើម្បីកំដរបរិយាកាស អៀងចាប់ផ្តើមនិយាយថា ៖

- តើធំស្គាល់លោកមូល-សារីឬទេ ?

អៀងបន្តទៀតថា ៖

- គួរឲ្យស្តាយលោកមូល-សារីជាក្រៃលែង ។ លោកមានសេចក្តីក្លាហានចាប់ផ្តើមបង្កើតជំរំ០០៧មុនគេ ។ លោកជាវរជនមានចិត្តសប្បុរសដ៏គ្រប់គ្រាន់ ។ ឥឡូវបណ្តាលមកពីការដន្ទើមអំណាចគ្នា មានគេរករឿងសម្លាប់លោក ញ៉ាំងឲ្យលោកធុញទ្រាន់ លោកក៏បណ្តើរគ្រួសារភៀសខ្លួនទៅនៅឯបាងកកទៅ ។

យាយទៀងអង្គុយសញ្ជឹងគិតនឹកពីប្រវត្តិរបស់លោកបន្តិច ទើបគាត់ឆ្លើយនូវសំនួររបស់អៀង ៖

- ធំស្គាល់គ្រួសាររបស់លោកមូល-សារីច្បាស់លាស់ណាស់ ។ លោកមូល-សារីជាកូនប្រុសទោលរបស់លោកតាមូល និងលោកយាយសូវ ។ តាមូលមានសតិសម្បជញ្ញៈស្នេហាជាតិយ៉ាងមុត ។ គាត់ស្មគ្រចិត្តបូជាជីវិតនាំប្រពន្ធ-កូនចូលព្រៃបំរើក្រុមខ្មែរឥស្សរៈ ដើម្បីរំដោះខ្មែរពីនឹមបារាំង ។

ក្រុមខ្មែរឥស្សរៈសំរេចបានជោគជ័យនៅខែវិច្ឆិកាឆ្នាំ១៩៥៣ គឺបារាំងយល់ព្រមប្រគល់ឲ្យខ្មែរបានឯករាជ្យដ៏បរិបូណ៌ ។ ពេលនោះក្រុមខ្មែរឥស្សរៈក៏ស្ម័គ្រចិត្តចូលមករួបរួមធ្វើការបំរើសម្តេចសីហនុ ដើម្បីកសាងកម្ពុជាឯករាជ្យ ។

ក្នុងពេលនោះ គុណាសម្បត្តិរបស់តាមូលត្រូវបានទទួលមុខងារជាអនុសេនីយ៍ត្រី (ស័ក្តិ១) ។ បុណ្យស័ក្តិនេះនាំឲ្យក្តៅក្រហាយ កើតចិត្តច្រណែនពីក្រុមនាម៉ឺនដែលអង្គុយរង់ចាំតាមខ្យល់ ព្រោះគេមិនចង់ឃើញនរណាមានបុណ្យស័ក្តិធំ ឬល្បីជាងខ្លួនទេ ។

ដូច្នេះវាចាប់ធ្វើវិច្ឆេតកម្ម ញុះញង់ចាក់ចុចមេដឹកនាំខ្មែរ ត្រូវតែចេញប្រកាសបង្ខំឲ្យធ្វើការប្រឡងពិសោធន៍ល្បងមើលសិន មុននឹងបំពាក់ស័ក្តិឲ្យក្រុមខ្មែរឥស្សរៈ ។ តាមូលខកខូចចិត្ត គាត់ឈឺចិត្តណាស់ព្រោះគាត់ដឹងនិងយល់ជាស្រេចហើយថា ពួកនេះចង់ដេញគាត់ហើយ ។ ពួកនេះសន្និដ្ឋានទុកអ្នកតស៊ូខ្មែរដូចផ្លែពុទ្រា គេស៊ីសាច់រួចហើយ គេព្រួសគ្រាប់ចោលទៅ ។ ពួកនេះជាអ្នកបេះផ្លែ តែគេភ្លេចគុណអ្នកដាំ ភ្លេចគុណអ្នកស្រោចទឹក ។ ដូច្នេះទៅអនាគតពួកនេះត្រូវតែទទួលកម្មពៀរ ពីព្រោះពួកឯងប្រព្រឹត្តអំពើអាក្រក់បោកពួកអញ អញលាហើយ ។ល។ និង ។ល។ គាត់យល់ថាមិនបាច់ឡើយហត់ទៅធ្វើតេសទេ ។ គាត់ក៏សុំលាឈប់សំរាករួចហើយក៏វិលត្រឡប់ទៅធ្វើស្រែវិញទៅ ។

តាមូលបណ្តើរយាយសូវជាប្រពន្ធ ទៅតាំងទីលំនៅនៅឃុំរាំងកេសីស្រុកសង្កែខេត្តបាត់ដំបងវិញ ។ មុនលាចេញពីកងទ័ពបណ្តាលមកពីអំពើអយុត្តិធម៌ខុសទំនង តាមូលពនទុកកូនប្រុសទោលម្នាក់ គឺលោកមូល-សារីនេះឲ្យផ្សងព្រេងនៅបំរើកងទ័ពតទៅទៀត ។

លោកមូល-សារីស្ម័គ្រចិត្តទទួលភារកិច្ចការពារទល់ដែនខ្មែរ-យួន-លាវរហូត ។ តាំងពីពេលនោះមក លោកមូល-សារីបំពេញភារកិច្ចក្នុងមុខងារយ៉ាងពេញលេញបានគាប់ប្រសើរល្អឥតខ្ចោះ ។ដូច្នេះបុណ្យស័ក្តិជាវរៈសេនីយ៍ឯករបស់លោកគឺជារង្វាន់ដ៏ពិតប្រាកដដែលលោកត្រូវតែបាន ។ លោកមូល-សារីប្រកបដោយគុណសម្បត្តិខាងផ្លូវយុទ្ធសាស្រ្តដ៏គ្រប់គ្រាន់ មានចរិតរឹងប៉ឹងអត់ធ្មត់ មានការតស៊ូស្វិតស្វាញ ។ លោកអាចធន់ទ្រាំនូវការលំបាកគ្រប់បែបយ៉ាង ។ លោកមូល-សារីស្គាល់កលល្បិចខ្មាំងយ៉ាងច្បាស់លាស់ ព្រមទាំងប្រកបទៅដោយទេពកោសល្យខាងបញ្ជាការយ៉ាងវៀងវៃ ។ ដូចជានៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៥ ម៉ោងមួយកន្លះរសៀល អង្គការបញ្ជាឲ្យប្រមូលអស់លោកនាយទាហាននៅខេត្តបាត់ដំបងចំនួន៦ឡានកាម៉្យុងដឹកនាំយកទៅបាញ់សម្លាប់ចោល ។ លោកក៏គេចរួចនៅរស់ ។ ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ លោកមូល-សារីរស់នៅក្នុងរបបដ៏ឃោរ

យៅរបស់អង្គការ ( លោកមូល-សារីប្រាប់យាយទៀងដោយផ្ទាល់មាត់ថា លោកធ្វើបុកស្មើរឆ្កួតស្មើរជា, លោកជាគង្វាលគោដើម្បីប្តូរយកជីវិត ) ។ លោកចេះសំរបខ្លួន ចេះអត់ធ្មត់តាមកាលៈទេសៈ ខំបំរើអង្គការប្តូរយកជីវិត ។ លោកមូល-សារីបានគេចចាកផុតគ្រោះថ្នាក់មួយលើកទៀតដ៏កំរ ។

ពេលនោះយាយទៀងបែរភ្នែកសម្លឹងក្មួយអៀងព្រមទាំងបញ្ជាក់ថា ៖

- លោកមូល-សារីមិនល្បីឈ្មោះដូចមេទ័ពខ្មែរផ្សេងៗទេ ព្រោះគាត់គ្មានបក្សគ្មានពួក លោកខំតែបំពេញករណិយកិច្ចនិងភារកិច្ចរបស់លោកតែប៉ុណ្ណោះ ។ យាយទៀងបញ្ចប់ការរ៉ាយរ៉ាប់របស់គាត់ដោយនិយាយថា ៖

- ដូច្នេះគួរសរសើរលោកស័ក្តិប្រាំមូល-សារីជាក្រៃលែង !

ពេលនោះអៀងដំអូញថ្ងូរថា ៖

- គួរឲ្យស្តាយណាស់ បើខ្មែរយើងរវល់តែច្រណែនគ្នា សន្និដ្ឋានអ្នកតស៊ូ អ្នកឈ្មោះត្រង់ចំពោះជាតិ ដូចផ្លែពុទ្រាទុំ ស៊ីសាច់រួចព្រួសគ្រាប់ចោល... ឧទាហរណ៍ករណីតាមូល ហ៊ានបូជាជីវិតចូលព្រៃ រួបរួមកម្លាំងបង្កើតខ្មែរឥស្សរៈដើម្បីរំដោះទឹកដីពីបារាំង ដើម្បីកម្ពុជាឯករាជ្យ ។ លុះដល់កម្ពុជាបានឯករាជ្យហើយ គេក៏ទាត់តាមូលចោល ។ ឥឡូវនេះលោកមូល-សារីខំបង្កើតជំរំដើម្បីជួយសង្គ្រោះប្រជាជនខ្មែរ ទីបំផុតត្រូវគេតាមរកសម្លាប់ដើម្បីដណ្តើមអំណាច ។

ដូច្នេះបង្ហាញឲ្យឃើញថា ខ្មែរដេកលង់លក់ណាស់ ។ ដំណាក់ការយ៉ាងនេះទៅហើយ រវល់តែបែរក្រោយខាំតែគ្នាឯង ចរិតនៅតែដដែលៗ ។ តើធ្វើដូចម្តេចរំដោះទឹកដីកម្ពុជាកើត បើបច្ចាមិត្រជាចោរឈ្លានពានគឺយួនហាណូយ វាចេះធ្វើពុតវាប៉ិនប្រសប់ វាចេះប្រើកលល្បិចក្រឡិចក្រឡុច មានបញ្ញាស់មានបណ្តោយយ៉ាងឆ្ងើម ថែមទាំងមានកម្លាំងទ័ពយ៉ាងខ្លាំងក្លា មានការពិសោធន៍ក្នុងសង្គ្រាមជាច្រើនឆ្នាំ ព្រមទាំងមានអាវុធដ៏គ្រប់គ្រាន់យ៉ាងនោះ ? ។

អៀងបែរភ្នែកសម្លឹងយាយទៀងដោយចង់សុំយោបល់បន្ថែម ប៉ុន្តែ... យប់ជ្រៅណាស់ទៅហើយ យាយទៀងសុំឈប់បន្តរឿងគាត់ត្រឹមហ្នឹង ដោយគ្រាន់តែបញ្ជាក់ថា ៖

- គាត់ក៏យល់ដូច្នោះដែរ ព្រោះហេតុដូច្នេះហើយបានជាគាត់សុខចិត្តនាំកូនចាកចេញចោលស្រុកមួយរយៈសិន ។

❑ ❑

❑

យប់ថ្ងៃទី២២-៦-៨០ យាយទៀងមានកូនចិត្តមួយយ៉ាងសប្បាយរីករាយ ដោយបានចួបកូនប្រុសម្នាក់ និងកូនស្រីម្នាក់ មកចូលរួមដំណើរផ្សងព្រេងទៅកាន់ប្រទេសទីពី ។ យប់នោះ គាត់ដេកសំរាកនៅក្នុងកូនខ្ទមស្បូវរបស់ស៊ុង-ហឿន ស្ថិតនៅក្នុងជំរំណោងច័ន្ទ ។

គាត់ដេកមិនលក់ទេ, គាត់គំពុងញញឹមរីករាយរវើរវាយថា នៅថ្ងៃស្អែកនេះ គាត់មុខតែមានវាសនានឹងចាកចេញផុតពីស្ថានយមបាលនេះហើយ ។

ប្រហែលម៉ោង១២អាធ្រាត ស្រាប់តែឮសន្ធឹកឡានរថក្រោះបរសំដៅមកជំរំណោងច័ន្ទ កាន់តែជិតឡើងៗ ។ ម៉ោង៤ទៀបភ្លឺ យាយទៀងដាស់កូនទាំងពីរនាក់ឲ្យក្រោកឡើងដើម្បីរៀបចំចេញដំណើរ ។ ប៉ុន្តែពុទ្ធោអើយ ! ជំរំណោងច័ន្ទត្រូវចោរឈ្លានពានជាយួនហាណូយព័ទ្ធជុំជិតទៅហើយ ។ ប្រហែលកន្លះម៉ោងក្រោយមកស្រាប់តែឮស្នូរគ្រាប់កាំភ្លើងផាំងផាំងរន្ទឺជុំជិត គឺជាកាំភ្លើងរបស់ពួកយួនហាណូយដែលបាញ់បំផ្លោងមកលើជំរំណោងច័ន្ទ ដើម្បីសម្លាប់និងកំចាយខ្មែរស្លូតត្រង់ដែលគ្មានអាវុធការពារ ដែលសេសសល់ពីស្លាប់ បណ្តាលពីយួនហាណូយប្រើស្មៀតចោរកំចាយមិនឲ្យនៅស្រុកបាន ។

ពេលនោះយាយទៀងភ័យជ្រួលច្របល់តក់ស្លុតហួសហេតុសឹងដួលសន្លប់។ វិច្ឆិកាឃើញដូច្នេះ ដៃម្ខាងគ្រាម្តាយ ដៃម្ខាងទាញប្អូនស្រីចាកចេញពីជំរំជាបន្ទាន់កាត់គ្រាប់កាំផ្លើងរត់សំដៅទៅកាន់ព្រំដែនខ្មែរ-ថៃ ។ ទៅដល់កន្លែងនោះហើយ យើងទាំងបីនាក់មានការស្លន់ស្លោយ៉ាងខ្លាំង ដោយឃើញមានស្ទាមភ្លោះមួយយ៉ាងជ្រៅ មានទឹកហូរត្របាញ់ ជាទឹកន្លែងខណ្ឌបញ្ជាក់ព្រំដែន ។ នៅត្រើយម្ខាងឯណោះ មានទាហានថៃមុខមាត់កាចសាហាវ ឈរបណ្តាក់គ្នាភ្ជង់កាំភ្លើងតម្រង់ជនភៀសខ្លួនខ្មែរ ។ បើនរណាហ៊ានហែលឆ្លងកាត់ស្ទាមភ្លោះនោះ ទាហានថៃទាំងនោះនឹងបាញ់សម្លាប់ចោលភ្លាម !...

ថ្ងៃរះខ្ពស់ណាស់ទៅហើយ ខ្មែររងគ្រោះដ៏អភ័ព្វដែលកំពុងតែត្រូវបូដូយបាញ់ស្រោចគ្រាប់កាំភ្លើងមកលើ ក៏នាំគ្នាអង្គុយឱបក្បាលជង្គង់ផ្ទាល់ដីក្រោមកំដៅថ្ងៃក្តៅស្មើរឆេះ ។ ទៅមុខមិនរួច ថយក្រោយមិនកើត រង់ចាំតែស្លាប់ប៉ុណ្ណោះ ។

ចំណែកឯបូដូយវិញ វាគ្មានប្រណីដៃទេ រឹតតែសង្វើញបំផ្លោងគ្រាប់មកលើជំរំគ្មានអាក់ ។

រីឯខាងថៃវិញបានឱកាស ក៏តាំងពីតសាកល្បងកាំភ្លើងធំរបស់វា ដោយបំផ្លោងមកលើជំរំណោងច័ន្ទជួយសម្លាប់ខ្មែរដែរ ។

ពុទ្ធោ ! ពុទ្ធោ ! ម្ខាងយួនម្ខាងសៀម ! តើឲ្យខ្មែររត់ទៅខាងណា ?

ទាល់តែដល់ម៉ោងបួនល្ងាច ទើបមានបញ្ជាពីអាជ្ញាធរថៃអនុញ្ញាតឲ្យខ្មែររង

គ្រោះហែលឆ្លងស្ទឹមភ្លោះចូលមកកាន់ប្រទេសថៃ ។

វិច្ឆិកាហែលកៀកចម្លងម្ដាយទៅកាន់ត្រើយម្ខាង រួចវិលមកយកប្អូនស្រីវិញ ព្រោះស្រីៗទាំងពីរនាក់មិនចេះហែលទឹក ។ យើងក៏បានរួចផុតបីគ្រោះថ្នាក់ម្ដងទៀត ហើយបន្តដំណើរទៅកាន់ជំរំខាវ-អ៊ីដាង ។

ម៉ោងប្រហែល៦ល្ងាចស្រាប់តែជួបទាហានថៃភ្ជង់កាំភ្លើងឃាត់ឲ្យផ្អាកដំណើរនៅត្រឹមហ្នឹង ។ យប់ងងឹតល្មមត្រូវតែដេកផ្ងាល់ដី អត់កន្ទេល អត់ភួយ អត់បាយអត់ទឹក ។ ចំណែកយាយទៀងគាត់មិនហ៊ានដេកទេ គាត់អង្គុយបន់ស្រន់ព្រះសំពះទេវតា ( មកដល់ស្រុកបារាំង គាត់កោរសក់សុំលាបំណាន់នេះ ) ទល់ភ្លឺ ពីព្រោះយប់នោះ ទាហានថៃដើរប្លន់រួចចាប់កូនក្រមុំខ្មែរកំពុងរងគ្រោះ នាំយកទៅរំលោភរួចសម្លាប់ចោលយ៉ាងច្រើន ។

❑ ❑

❑

ព្រលឹមថ្ងៃទី២៨-៦-៨០ ពេលថ្ងៃរៀបរះ អង្គារអង្គុយដណ្ដាំបាយ ស្រាប់តែផាំងៗ គឺកាំភ្លើងរបស់ឃ្មួនហាណូយបាញ់បំផ្លោងតាមសម្លាប់កំចាយខ្មែរអភ័ព្វដល់ក្នុងផ្ទៃដីសៀម ។ អង្គារភ័យខ្លាំងពេកក្ដោក់បានតែគ្របឆ្នាំង រត់ចោលបាយនោះទៅ ។

ចំណែកទាហានថៃក៏បះកន្ទុយរត់ថយក្រោយដែរ ។ ប្រជាជនខ្មែរក៏រត់តាមចូលជ្រៅទៅៗដូចទឹកបាក់ទំនប់ ។ លុះទៅដល់កន្លែងមួយអាចមើលឃើញជំរំខាវ-អ៊ីដាងនៅជិតបង្កើយ ស្រាប់តែជួបទាហានថៃជាច្រើនលើសលប់ មានទាំងរថ-ក្រោះជាច្រើនគ្រឿង ភ្ជង់កាំភ្លើងធំតម្រង់ រួចស្រែកតាមមេក្រូបញ្ជាឲ្យប្រជាជនខ្មែរផ្អាកដំណើរត្រឹមហ្នឹងមួយលើកទៀត ។ ដូច្នេះត្រូវអង្គុយកណ្ដាលថ្ងៃក្ដៅ អត់បាយអត់ទឹក ដូចអ្នកជាប់ទោស ។ មានជនរងគ្រោះខ្លះ ផ្សងព្រេងចេញពីជួរទៅរកអុសឬទៅរកកាប់មែកឈើដើម្បីធ្វើជំរកឲ្យកូនតូចៗ ត្រូវទាហានថៃបាញ់សម្លាប់ចោលភ្លាមៗ ។

ម៉ោងប្រហែលជា៣រសៀល ទាហានថៃប្រកាសតាមមេក្រូម្ដងទៀត បញ្ជាដេញប្រជាជនខ្មែរអភ័ព្វទាំងអស់ឲ្យត្រឡប់វិលក្រោយវិញ ។ វាបាញ់កាំភ្លើងទៅលើអាកាសគ្រប់ទិស ព្រមទាំងស្រែកសម្លុតកំហែងថា ៖

-បើនរណារឹងទទឹងនឹងបញ្ជារបស់វា វានឹងបាញ់សម្លាប់ចោលភ្លាម ! ។

ពេលនោះប្រជាជនដ៏អភ័ព្វទាំងនោះ ត្រឡប់វិលក្រោយដូចទឹកបាក់ទំនប់ម្ដង

ទៀត ។ នៅពេលនោះ យាយទៀងដើរលែងរួចទៅហើយ ដោយមកពីការអត់បាយអត់ទឹកអស់ចំនួន២ថ្ងៃទៅហើយផង បន្ថែមពីលើការតក់ស្លុតឥតឧបមាផង ។ ក្នុងមាត់ស្ទួតរកទឹកមាត់លេបគ្មានទៅហើយ គាត់ក៏ប្រថុយលោតចុះទៅក្នុងទឹកស្ទាមភ្លោះប្រឹង !...។ ឃើញគ្រោះថ្នាក់យ៉ាងធ្ងន់មកដល់យ៉ាងហ្នឹង កូនទាំងពីរនាក់ក៏ស្រែកទ្រហោហៅម្ដាយ ៖

- ម៉ាក់អើយម៉ាក់ដើរមកៗ ! ទាហានថៃវាយម៉ាក់ស្លាប់ឥឡូវហើយ ! ដើរមកម៉ាក់ៗ ! ឱទេវតាលោកអើយជួយម៉ាក់ខ្ញុំផង ! ។

ទាហានថៃដើរវាយសំពងចំជួរយាយទៀង ! នៅដៃឆ្វេងកាន់កាំភ្លើងខ្លីមួយដើម នៅដៃស្ដាំកាន់ដំបងមួយយ៉ាងធំ សំរាប់សំពងខ្មែរណារឹងទទឹងមិនវិលត្រឡប់ក្រោយ ។

លុះវាក្រឡេកមកចំយាយទៀងដែលកំពុងតែត្រដរខ្យល់ក្នុងទឹក វាក៏ច្រត់ចង្កេះឈរមើលមួយសន្ទុះ រួចក៏ដើរហួសទៅ ។

ពេលនោះវិច្ឆិកាផ្សងព្រេងលោតចុះទឹកក្នុងស្ទាមភ្លោះលបៗដើរថយក្រោយទៅកៀកស្មាម្ដាយស្រង់ឡើងពីទឹក រួចបន្តដំណើរវិលត្រឡប់ក្រោយវិញ ។ ចំណែកយាយទៀង បន្ទាប់ពីបានត្រាំក្នុងទឹកមក គាត់មានកម្លាំងគ្រាន់បើបន្តិច អាចដើរយឺតៗទប់ខ្លួននឹងឈើច្រតបាន ។

ថ្ងៃល្ងាចនោះមានឡានរបស់កាកបាទក្រហមអន្តរជាតិដឹកជំនួយគ្រប់មុខ យកមកដាក់ទានឲ្យ ។

សំរាកទីកន្លែងមិនស្គាល់ឈ្មោះអស់ចំនួន២យប់ គឺយប់ថ្ងៃទី២៤-២៥ ខែមិថុនា ឆ្នាំ១៩៨០ ។ ស្រាប់តែព្រលឹមថ្ងៃទី២៦-៦-៨០ ព្រះសុរិយាមិនទាន់រះផង ឃើញមានឡានកាម្ម៉ុងជាច្រើនគ្រឿងមកឈប់ចតជាក្បួន ។ ពេលនោះទាហានថៃស្រែកតាមមេក្រូប្រកាសបញ្ជាឲ្យប្រជាជនខ្មែរនាំគ្នាប្រមូលគ្រួសារឡើងឡាន ។ គ្រប់ៗគ្នាត្រេកអរជាអតិបរិមា ដោយយល់ថារាជការថៃមានចិត្តសប្បុរសជួយជីវិតខ្មែរដឹកនាំយកទៅកាន់ជំរំខាវអ៊ីដាង ។ ប៉ុន្តែមិនមែនដូច្នោះឡើយ គឺរាជការថៃចិត្តសាមាន្យ បែរជាប្រមូលដឹកនាំប្រជាជនខ្មែររងគ្រោះយកទៅចាក់ចោលនៅក្បែរជំរំណងចន្ទទៅវិញ ។

ល្ងាចថ្ងៃទី២៦-៦-៨០ វិច្ឆិកាឃើញម្ដាយភ័យញ័រញាក់ជាយ៉ាងខ្លាំងគាំងមាត់ឈប់ចេះនិយាយទៅហើយ ក៏ដើរទាក់ទងភ្នាក់ងារកាកបាទក្រហមអន្តរជាតិ រំអួយថ្ងូរបកស្រាយរ៉ាយរ៉ាប់នូវជីវប្រវត្តិរបស់ម្ដាយសព្វគ្រប់ ។ ប៉ុន្តែកាកបាទក្រហមបានឆ្លើយឡើងថា ៖

- គេផ្អាកឈប់ទទួលជនភៀសខ្លួនខ្មែរហើយ តែបើជនភៀសខ្លួនយួនទើប

គេទទួលនាំយកចេញពីទីនេះភ្លាម ! ។

វិច្ឆិកាវិលត្រឡប់មកជួបម្ដាយ រួចរ៉ាយរ៉ាប់តាមដំណើរដោយអស់សង្ឃឹម ។ យប់នោះយាយទៀងនិងកូនដេកផ្ទាល់ដី ក្បាលកើយភ្លឺស្រែ កណ្ដាលវាលក្នុងប្រទេសថៃ ។ ម្នាក់ៗមានតែខោអាវមួយបន្ទះដាច់ដាចជាប់នឹងខ្លួនតែប៉ុណ្ណោះ ។ យាយទៀងដេកមិនលក់ទាល់តែសោះ ដោយមានបារម្ភទៅលើវាសនានៃកូនស្រីយ៉ាងខ្លាំង ព្រោះទាហានថៃមានចរិកកាចសាហាវជាងបូជួយទៅទៀត ។ វាដើរឆែកឆេរប្លន់យកទ្រព្យសម្បត្តិ បើមានកូនក្រមុំវាចាប់យកទៅរំលោភ រួចសម្លាប់ចោលយ៉ាងជាក់ស្ដែង ។ ក្បាលកើយភ្លឺស្រែ ភ្នែកសម្លឹងមើលមេឃដែលមានពពកខ្មៅមីរដេរដាស ជាសញ្ញាបញ្ជាក់ឲ្យដឹងថា ភ្លៀងជិតធ្លាក់មកហើយ...

យាយទៀងមានអារម្មណ៍ឆ្ងល់សែនឆ្ងល់ ទៅលើប្រជាជនថៃដែលជាអ្នកកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួនដូចប្រជាជនខ្មែរដែរ ។ សាសន៍ទាំងពីរនេះមានទំនៀមទម្លាប់ វប្បធម៌ ភាសា រូបរាងកាយ ពណ៌សម្បុរប្រហាក់ប្រហែលគ្នា ចុះហេតុអ្វីក៏ទាហានថៃ កាចយង់ឃ្នងដាក់ប្រជាជនខ្មែរដែលជាបងប្អូនយ៉ាងនេះទៅវិញ ? ពេលនោះយាយទៀងនឹកឃើញលំនាំពាក្យរបស់យួនង្វៀង-វ៉ាន់ទិញ មេវៀតមិញដែលជាប្រធានអប់រំសាលានយោបាយ និយាយវែកញែកកាលពីយប់ថ្ងៃទី២៨-២-៤៧ ដែលមានជាអាទិថា ៖

-សុំឲ្យរាជការថៃរក្សាសេចក្ដីស្ងប់ស្ងៀម កុំលូកដៃក្នុងរឿងខ្មែរ-យួន-លាវឲ្យសោះ ពេលណាកុម្មុយនិស្តឥណ្ឌូចិន ( បង្កើតឡើងដោយហូ-ជីមិញកាលពីថ្ងៃទី៣-២-៣០ ) បានសំរេចទទួលជ័យជំនះ ដោយគ្រប់គ្រងឥណ្ឌូចិនបានជាស្ថាពរហើយយួននឹងប្រគល់ខែត្តខ្មែរ ដែលថៃបានលួចយកទៅពីដើមសតវត្សទៅឲ្យថៃវិញ ។ ពាក្យគ្រោងសន្យានេះ យាយទៀងបានត្រងត្រាប់ស្ដាប់កន្លងផុតទៅជាង៣០ឆ្នាំមកហើយ... ទើបបានប្រទះឃើញផ្ទាល់ភ្នែក នូវអំពើឃោរឃៅគ្មានមេត្តានៃទាហានថៃគួរឲ្យចាប់អារម្មណ៍សង្ស័យក្នុងកាលៈទេសៈនេះថា ៖

- ទាហានយួននិងថៃ ត្រូវរ៉ូវគ្នាទេដឹង ?!?!

យាយទៀងនឹកឃើញសព្វគ្រប់ ក៏មានការក្ដៅក្រហាយនឹងយួនហាណូយជាក្រៃលែង ។ ឥឡូវនេះយួនហាណូយហ៊ានរំលោភច្បាប់អន្តរជាតិពេញទី ព្រោះបូជួយរបស់វាបានចេញមុខយ៉ាងជាក់ស្ដែងកំពុងតាមសម្លាប់និងកំចាយខ្មែរ ឲ្យភ័យខ្លាចនិងអស់សង្ឃឹម ហើយរត់ចោលទឹកដីទុកឲ្យវារាតត្បាតតាមអំពើចិត្ត ។

តើមេដឹកនាំខ្មែរទាំងខាងសក្ដិភូមិ ទាំងខាងកុម្មុយនិស្ត មានបានដឹងបានឮនូវព្រឹត្តិការណ៍ដ៏ចម្លែកទាំងនេះដែរឬទេ ? ។

ចម្លើយអាចចេញជាពីរបែប ៖

បើគេដឹង ៖ គឺមានសេចក្ដីថា អ្នកអស់នោះចចេសមានៈ សុខចិត្តឲ្យនគរខ្មែរ រលាយទៅចុះ ព្រោះម្នាក់ៗរវល់តែខំប្រឹងលើកដំកើងបុគ្គលឲ្យលើសពីឯកភាពជាតិ មិនហ៊ាននិយាយពីរឿងពិត ខ្លាចបាត់បង់កិត្យានុភាព កិត្តិនាម ខ្លាចថោកទាបខ្លួន ។ល។

បើគេមិនដឹង ៖ គឺមានសេចក្ដីថាអ្នកអស់នោះភ្លីភ្លើល្ងើពកថ្លាស ខ្វះសមត្ថភាពទាំងស្រុង ។ នៅពេលនេះទាហានយួនហាណូយចូលមកលុកលុយរាតត្បាតពាសពេញប្រទេសខ្មែរ វាតាមមកបាញ់សម្លាប់ខ្មែររហូតដល់ទឹកដីថៃទៅហើយ ហេតុដូចម្ដេចក៏មេដឹកនាំខ្មែរមិនប្ដឹងពិភពលោក មិនប្ដឹងអន្តរជាតិឲ្យគេរកខុសត្រូវ ? ។

ប៉ុណ្ណឹងៗទៅហើយនៅស្ងាត់ស្ងៀមច្រៀប បណ្ដោយឲ្យព្រឹត្តិការណ៍ប្រទេសខ្មែរនៅពេលនោះនៅតែមានសភាពងងឹតអន្ធការ គ្មានភាពពិតប្រាកដ បណ្ដោយឲ្យខ្មែរមួយភាគយ៉ាងធំយល់ច្រឡំយ៉ាងធ្ងន់ ។ នៅពេលដែលយួនហាណូយចូលមកនៅលើដីខ្មែរជំនួសជនភៀសខ្លួន ខ្មែរខ្លះបែរជាធ្វើមាត់ជីបអូចៗ អរគុណបងវៀតណាមទៅវិញ ។ តើមានអ្វីគួរឲ្យអៀនខ្មាស់ជាងនេះទៅទៀត ?

មេដឹកនាំខ្មែរនិមួយៗខំប្រឹងស្រែកដណ្ដើមត្រូវតែរៀងៗខ្លួន ។ ខំប្រឹងបង្កើតកាសែត ទស្សនាវដ្ដី ដើម្បីស្រែកជេរត្មះតិះដៀលតែគ្នាឯងដែលសេសសល់នៅរស់ «មួយជំបរស្វា» ពីការសម្លាប់រង្គាលរបស់សត្រូវទៅវិញ ។

មានមនុស្ស «រាប់មិនគ្រប់ម្រាមដៃ» ទេ ដែលហ៊ានថាយួនហាណូយជាចោរ ជាមេឃាតករ ជាអង្គការអនាមិក ។

យាយទៀងអះអាងជាសាក្សី ពីព្រោះក្នុងមួយជីវិតនេះ ខ្លួនរបស់គាត់ផ្ទាល់ត្រូវទទួលរងគ្រោះ សោកសៅ ឈឺចាប់ ស្គាល់តែវិនាសព្រាត់ប្រាស់គ្មានទីបំផុត ដែលបណ្ដាលមកពីយួនហាណូយ ។

១) តើមានទុក្ខអ្វីដែលធ្ងន់ជាងការព្រាត់ប្រាស់ម្ដាយឪពុក បងប្អូន ?

២) តើមានទុក្ខអ្វីដែលធ្ងន់ជាងការសោកស្ដាយទីលំនៅរបស់ខ្លួន ពេលដែលគេដេញឲ្យចុះចេញ ?

៣) តើមានទុក្ខអ្វីដែលធ្ងន់ជាងការស្រណោះកូនប្រុស កូនស្រីតូចៗ ដែលត្រូវគេបង្ខំបេះចេញពីដើមទ្រូងឲ្យទៅធ្វើការជាទម្ងន់ ?

៤) តើមានការតក់ស្លុតណាដែលខ្លាំងជាងការឃើញឃាតករ មកចាប់ចងប្ដីសម្លាញ់របស់ខ្លួននៅនឹងមុខ ដើម្បីយកទៅសម្លាប់ ?

៥) តើមានការតក់ស្លុតណាដែលត្រូវគេចាប់ចងវាយដំ យកទៅដាក់គុកដោយឥតដឹងហេតុផល ? ។

ទុក្ខទាំង៥បែបនេះ យាយទៀងបានស្គាល់ទាំងអស់ គឺបណ្ដាលមកពីយួនហា

ណហ្វយ ៖

- នៅខែមីនា១៩៨៨ នាងអាយុម្ភៃឆ្នាំ ត្រូវព្រាត់ប្រាស់ម្ដាយឪពុកបងប្អូនទាំងបង្ហំ ត្រូវរត់ចោលកម្ពុជាក្រោមដែលជាមាតុភូមិទី១ ព្រោះនាងទៀងគេចពីបំរើវា ។

- នៅថ្ងៃទី២៨-៤-៧៥ យួនហាណូយលួចបន្លំប្រើឈ្មោះជាអង្គការ ចេញបញ្ជាឲ្យប្រជាជនខ្មែរទាំងអស់ចេញពីទីលំនៅ លះបង់ចោលទ្រព្យសម្បត្តិយ៉ាងច្រើនឥតគណនាទុកឲ្យវា ។

- នៅក្នុងខែឧសភា១៩៧៥ អង្គការបំបែកកូនតូចៗចេញពីខ្លួន ។ កូនស្រីពៅនៅមានអាយុ១០ឆ្នាំនៅឡើយ វាបំបែកឲ្យទៅធ្វើការជាទម្ងន់ ។

- នៅយប់ថ្ងៃទី១១-១១-៧៦ ម៉ោង៨យប់ អង្គការចេញបញ្ជាឲ្យឃាតករចូលមកចាប់ប្ដីសម្លាញ់របស់ខ្លួននាំយកទៅសម្លាប់ ។

- ក្នុងខែមករា១៩៧៧ អង្គការបញ្ជាឲ្យឃាតករមកចាប់ចងខ្លួន បន្ថែមត្រួតពីលើទុក្ខ ដែលកំពុងតែឆ្កួតវង្វេង ឲ្យដាច់ពោះស្លាប់នៅក្នុងគុកព្រៃតាបែន ឬគុកស្រីមេម៉ាយ ដែលស្ថិតនៅកណ្ដាលព្រៃឆ្ងាយដាច់ស្រយាល ។

- នៅថ្ងៃ២៦-៦-៨០ បណ្ដើរកូនចាកចោលមាតុភូមិទី២ បន្សល់ទុកទឹកដីឲ្យវាទៅហើយ ស្រាប់តែសត្រូវចង្រៃតាមមកបាញ់សម្លាប់នៅលើទឹកដីថៃទៅទៀត ដោយវាយកលេសថា វាបោសសំអាតពួកខ្មែរវង្វេងជាតិ និងពួកបនប៉ុល-ពត ដើម្បីបំភ័ន្តភ្នែកអន្តរជាតិ ( សូមបញ្ជាក់ថា នៅជំរំណងច័ន្ទនិងគោកធ្យូង គ្មានខ្មែរវង្វេងឬបនប៉ុល-ពតទាល់តែសោះ ) ។

ពេលមានឧប្បត្តិហេតុដ៏ចម្លែកនេះ ពិភពលោកក៏ផ្អើលឆោឡោ, ប្រទេសដែលស្រឡាញ់សន្តិភាពនិងយុត្តិធម៌ មានបញ្ជូនតំណាងមកកាន់សមរភូមិ បានឃើញផ្ទាល់ភ្នែកជាក់ស្ដែងជាសាក្សីនូវអំពើអប្រីយរបស់យួនហាណូយ ដែលគ្មានគោរពច្បាប់អន្តរជាតិអ្វីទាល់តែសោះ ។ វាអាងកម្លាំងទ័ពកម្លាំងអាវុធ វាហ៊ានបាញ់បំផ្លោងកាំភ្លើងធំចូលប្រទេសថៃ ដើម្បីសម្លាប់ប្រជាជនខ្មែរស្លូតត្រង់ ដែលមានតែដៃទទេជាច្រើនម៉ឺននាក់ ដែលរត់មកដេកពាសវាលពាសព្រៃ នៅលើទឹកដីថៃទៅហើយ គឺវាធ្វើយ៉ាងណាកុំឲ្យខ្មែរអាចតស៊ូនៅលើទឹកដីខ្មែរតទៅទៀត ។

នៅពេលនោះអង្គការមនុស្សធម៌បានទទូចសុំដឹកនាំជំនួយចូលមកកាន់ប្រទេសខ្មែរ តែយួនហាណូយនិងពួកអាយ៉ងបែរជាបដិសេធ ។ ដូច្នេះហើយបានជាអង្គការមនុស្សធម៌ដឹកជញ្ជូនជំនួយមកកាន់ជំរំ០០៧, ណងច័ន្ទ និងគោកធ្យូង ។ ជំនួយដែលអង្គការមនុស្សធម៌អន្តរជាតិនាំយកមកនេះក៏ត្រូវពួកបូដូយមកប្លន់ ព្រមជាមួយនឹងទ្រព្យសម្បត្តិនិងទំនិញគ្រប់ជំពូកក្នុងជំរំថៃមទៀត ។ នៅពេលនោះអង្គការមនុស្សធម៌ក៏បានឃើញដោយផ្ទាល់ភ្នែកនូវអំពើដ៏ព្រៃផ្សៃរបស់យួនហាណូយ ។

« នេះហើយជាលក្ខណៈនៃសង្គ្រាមពិតៗនៅប្រទេសខ្មែរ ដែលបណ្ដាលឲ្យនគរខ្មែរមួយទាំងមូលរលាយដោយសារកណ្ដាប់ដៃយួន ហើយដែលបញ្ជាក់ថាចម្បាំងនេះគឺជាចម្បាំងរវាងខ្មែរនិងយួន » ។

យាយទៀងនឹកឡើងគួរឲ្យឈឺចាប់ណាស់ នៅពេលដែលគាត់បានដំណឹងថាភ្នាក់ងារស្នាក់ការជាន់ខ្ពស់អ.ស.ប.ទទួលបន្ទុកជនភៀសខ្លួន ( Haut Commissariat des Réfugés - HCR ) ទទួលជនជាតិយួនជាអទិភាព ( priorité ) នាំយកចេញពីជំរំជាបន្ទាន់ ។ ផ្ទុយទៅវិញជនជាតិខ្មែរដែលរងគ្រោះដោយសារកងទ័ពយួនដេញបាញ់សម្លាប់ បែរជាត្រូវឈប់លែងទទួលទៅវិញ ។

យាយទៀងយំបណ្ដើរថ្ងូរបណ្ដើរ ៖

– ឱ ! ទេវតាលោកអើយ កើតមកជាខ្មែរហេតុអ្វីក៏អភ័ព្វម្ល៉េះ ? តើថ្ងៃស្អែកទៅជាយ៉ាងណាទៅទៀត ? តើខ្ញុំត្រូវសំរេចយ៉ាងដូចម្ដេច ? កំពុងតែព្រួយខ្វាយខ្វល់ស្រាប់តែភ្លៀងមួយមេយ៉ាងធំក៏ធ្លាក់មកដូចគេចាក់ទឹក ។ តើខ្មែរទាំងនោះវេទនាយ៉ាងណា ? ។

ព្រលឹមស្អែកឡើងភ្លៀងមិនទាន់ដាច់គ្រាប់ផង ស្រាប់តែគ្រាប់កាំភ្លើងធំរបស់បូជួយផ្ដោងមកម្ដងទៀតសារជាថ្មីលើប្រជាជនខ្មែរ នៅលើផ្ទៃដីថៃ លាន់ផ្ទុងផ្ទាំងធ្វើឲ្យខ្មែរអស់សង្ឃឹម ធ្វើឲ្យខ្មែរឈប់ស្ដាយឈប់ស្រណោះអាឡោះអាល័យទឹកដីកម្ពុជា ( <u>កំណត់អ្នកនិពន្ធ</u> ៖ បងប្អូនខ្មែរអើយមើលចុះ ! យួនហាណូយតាមសម្លាប់កំចាយខ្មែរ មិនមែនបូជួយស្ម័គ្រចិត្តបូជាសាច់ស្រស់ឈាមស្រស់មកជួយខ្មែរ ទេ សុំឈប់យល់ច្រឡំទៀតទៅ សុំឈប់អរគុណយួនទៅ ! ) ។

ដើម្បីចាកចេញឲ្យផុតគ្រោះថ្នាក់ដ៏ចង្រៃនេះ យាយទៀងឈប់រារែក ហើយសំរេចចិត្តភ្លាមថា ត្រូវតែភរភ្នាក់ងារ H.C.R. ថា គាត់ជាយួនដែលទើបនឹងគេចចេញមកពីកម្ពុជាក្រោម ។

q q

q

# ជំពូកទី២៣

## ★ យាយទៀងចូលជំរំ N.W.9
## ★ យាយទៀងជួប ប៊ុយ-ថាញ់មិញ
## ★ យួនហាណូយមានគំរោងការណ៍ផ្លាស់ឈ្មោះរដ្ឋធានីភ្នំពេញ និងខេត្តនានា

អស្ចារ្យមែន, គ្រាន់តែយាយទៀងបញ្ជាក់ថា គាត់ជាជាតិយួនភ្លាម ក៏មានអនុភាពដ៏ខ្លាំងក្លា ។ ស្រាប់តែអង្គការ H.C.R. រត់ខ្វែងដៃខ្វែងជើងបញ្ចេញឡានឡង់រ៉ូវែរមួយគ្រឿងបរមកទទួលយួនក្លែងក្លាយ ដឹកនាំចេញពីស្ថាននរកលោកិយឆ្ពោះទៅជំរំ N.W.9 ជាបន្ទាន់ ។ នៅលើឡានមានយួនក្លែងក្លាយពីរគ្រួសារទៀតអង្គុយរង់ចាំជាស្រេច ។

ពេលនោះប្រជាជនខ្មែរ ដែលកំពុងត្រូវរងគ្រោះដោយបូដួយដេញបាញ់សម្លាប់ លុះក្រឡេកឃើញជនភៀសខ្លួនទាំង១០នាក់ មានវាសនាមានឡានឡង់រ៉ូវែរមកទទួល ក៏រត់ឈ្លូវឆរនាំគ្នាមកសួរពត៌មានចង់ដឹងថា ធ្វើយ៉ាងម៉េចបានជាមានឡានមកដឹកនាំចេញពីសមរភូមិយ៉ាងនេះ ? ។

ប៉ុន្តែពុទ្ធោអើយ ! យួនក្លែងក្លាយទាំង១០នាក់នេះឈប់ចេះនិយាយខ្មែរទៅហើយ ។ គ្រប់ៗគ្នាគ្រវីក្បាលរួចឆ្លើយថា ៖

- ហុងបៀកៗ ! មិនដឹងៗ ។

ឡាននេះមានភ្នាក់ងារ H.C.R. ពីរនាក់ បើកបរចាកចេញពីកន្លែងគ្រោះថ្នាក់នេះទៅ...។

ឡានកំពុងបើកបរយ៉ាងលឿនទៅមុខ យាយទៀងឆ្លៀតបង្រៀនកូនទាំងពីរឲ្យចេះពាក្យយួនសំខាន់ៗខ្លះៗដូចជា ៖ សុំភ្លើង, សុំអុស, បើកអង្ករ, បើកបាយ, ទៅបង្គន់...។

ម៉ោងប្រហែលជាមួយរសៀលទៅហើយ ថ្ងៃទី២៧-៦-៨០ ឡានមកឈប់ចត

នៅមុខជំរំ NW-9 ។ ភ្នាក់ងារ H.C.R. ក៏ហៅជនភៀសខ្លួនទាំង១០នាក់ចុះពីឡាន រួចនាំបណ្តើរទៅប្រគល់ឲ្យលោកស័ក្តិ៣ជាតិថៃដែលជាអ្នកទទួលខុសត្រូវជំរំ ។

គណកម្មការបញ្ជាដល់យួនក្លែងក្លាយទាំង១០នាក់ ឈរតាមគ្រួសាររៀងៗខ្លួន ៖

- គ្រួសារទី១ មានតែឪពុកជាអតីតអនុសេនិយឯក មានកូនស្រីម្នាក់ និងកូនប្រុស២នាក់ ។ ទាំងអស់គ្នាមានសំបុរខ្មៅបន្តិច ។ គណកម្មការចាប់អារម្មណ៍សង្ស័យថាជាខ្មែរ ក៏ចាប់ផ្តើមធ្វើតេសមុន ។ គេសាកសួរពិសោធន៍យ៉ាងល្អិតល្អន់ ។ ប៉ុន្តែជាវាសនាល្អណាស់ គ្រួសារនេះទើបមកពីខេត្តសុកទ្រាំងកម្ពុជាក្រោម ។ ទាំងឪពុកទាំងកូននិយាយភាសាយួនដូចយួន ។

- គ្រួសារទី២ មានម្តាយនិងកូនស្រី២នាក់តូចៗ ។ ប្តីរបស់គាត់ជាអតីតសាស្ត្រាចារ្យភៀសខ្លួនទៅនៅប្រទេសបារាំងមុន ។ គាត់និយាយភាសាយួនគ្មានទាស់គ្មានទាល់ ។ ចំណែកកូនស្រីពីរនាក់តូចៗ គណៈកម្មការគ្មានសាកសួរអ្វីទេ ។

លុះដល់គ្រួសារយាយទៀង មានអនុសេនីយ៍ឯកយួនខាងត្បូងម្នាក់ឈ្មោះង្វៀង-វ៉ាន់ខាញ់ ស្ម័គ្រចិត្តសុំសួរពិសោធន៍ ព្រោះវាឮថាយាយទៀងមកពីស្រុកត្រាកូវ ដែលជាស្រុកកំណើតរបស់វាដែរ ។

ពេលនោះយាយទៀងឆ្លើយតាមសំនួរថា គាត់កើតនៅឃុំភឿកហ៊ឹង ស្រុកត្រាកូវ ខេត្តកីវឡុង... ឆ្លើយបានតែប៉ុណ្ណោះក៏រញ៉េរញ៉ៃបន្តទៅទៀតលែងកើត ព្រោះបារម្ភចំពោះកូនប្រុស១៨ឆ្នាំនិងកូនស្រី១៥ឆ្នាំ ដែលមិនចេះភាសាយួនមួយម៉ាត់សោះ

ង្វៀង-វ៉ាន់ខាញ់អង្អែលខ្នងយាយទៀងលួងលោមថា ៖

- សុំម៉ែកុំភ័យ យើងមកដល់ជំរំ NW-9 ហើយ យើងរួចទុក្ខវេទនាហើយ ខ្ញុំសន្យាជួយឧបត្ថម្ភម៉ែ ។ ខ្ញុំកើតនៅឃុំតាប់ស៊ឺន ជាប់ព្រំប្រទល់ភឿកហ៊ឹង ដែលខ្ញុំស្គាល់ច្បាស់ណាស់ ។ ដូច្នេះខ្ញុំសួរម៉ែមួយម៉ាត់ទៀត ថាតើម៉ែនៅភូមិណា?

- ខ្ញុំកើតនៅភូមិត្រាម...

ង្វៀង-វ៉ាន់ខាញ់ស្រាប់តែអស់សង្ស័យ ក៏ឈប់សួរតែត្រឹមហ្នឹង ។ ខាញ់ក៏បណ្តើរយាយទៀងនិងកូនទាំងពីរទៅកាន់ឃ្លាំងតំកល់តង់ដែលអង្គការមនុស្សធម៌ផ្តល់ឲ្យ ចែកឆ្នាំងចានស្លាបព្រា កន្ទេលមុងភួយ រួចនាំទៅកាន់កន្លែងមួយទំហំ២ម៉ែត្របួនជ្រុង មានតែដំបូលដេកផ្ទាល់ដី ប្រគល់ឲ្យម៉ែកូនយួនក្លែងក្លាយសំណាក់នៅ ។

ជំរំ NW-9 ស្ថិតនៅលើដីកម្ពុជា នៅក្នុងព្រៃដាច់ស្រយាលជាប់ស្ពានភ្លោះ ដែលរាជការថៃជីកសំរាប់សំគាល់ព្រំដែនខ្មែរ-ថៃ ។ ជំរំនេះមានផ្ទៃដីប្រហែល២ហិកតារ មានទាហានថៃមុខកាចសាហាវឈរព័ត្ធជុំវិញ ចម្ងាយប្រាំម៉ែត្រពីម្នាក់ទៅម្នាក់ ។ជនភៀសខ្លួនដែលសំណាក់នៅក្នុងជំរំនេះ ត្រូវគេចាត់ទុកថាជាជនជាប់ឃុំ ព្រោះទាហានថៃហាមមិនឲ្យដើរចេញពីជំរំជាដាច់ខាត ។ នៅពេលនោះ H.C.R. សន្និដ្ឋាន

ថា ជនជាតិយួននៅក្នុងជំរំនេះមានចំនួនដល់ទៅ៤ពាន់នាក់ ដែលឧបត្ថម្ភទំនុកបំរុង គ្រប់បែបយ៉ាងពីសំណាក់សាសនាកាតូលិក ។ ក្នុងមួយថ្ងៃចែកបាយម្ហូប២ពេល និងទឹកចំនួន៤លីត្រម្នាក់ ។ ជំរំនេះគេចាយតែបារីជំនួសលុយ ។

ជាច្រើនថ្ងៃទើបដឹងថា មានយួនក្លែងក្លាយយ៉ាងច្រើនសំណាក់នៅក្នុងជំរំនេះ ពីព្រោះយាយទៀងតែងតែឃើញស័ក្តិបីជាតិថៃដែលទទួលខុសត្រូវជំរំ តែងតែឈ្លោះប្រកែកយ៉ាងតឹងសរសៃក ខាំធ្មេញដាក់ភ្នាក់ងារ H.C.R. ដែលជាអ្នកទទួលខុសត្រូវដឹកជនជាតិយួនមកកាន់ជំរំនេះ ។ ពេលគណកម្មការហៅធ្វើតេស យួនក្លែងក្លាយមិនចេះភាសាយួនឡើយ ។ យាយទៀងក៏លបលួចដើរសួរសុខទុក្ខអ្នកទាំងនោះ ដោយនិយាយភាសាយួនខ្លះ ខ្មែរខ្លះ ទើបដឹងថា មានយួនក្លែងក្លាយយ៉ាងហោចណាស់ក៏ជាងពាក់កណ្តាលដែរ ។ ព្រោះពីឆ្នាំ១៩៧៥ មានជនជាតិចិនខ្លះ ជាតិខ្មែរចេះភាសាយួនខ្លះ ពេលដែលវៀតកុងចូលមកស្រុកខ្មែរប្រមូលអាណិកជនយួនកើតនៅស្រុកខ្មែរ នាំយកទៅលាក់ទុកនៅឯប្រទេសវៀតណាម ពួកនេះបន្លំខ្លួនធ្វើជាយួនភៀសខ្លួនទៅជាមួយ ។ លុះដល់ឆ្នាំ១៩៧៩-៨០ ក៏នាំគ្រួសារត្រឡប់មកកាន់ប្រទេសខ្មែរវិញ ។ ស្រាប់តែភ្ញាក់ព្រោះឃើញយួនហាណូយចូលមកវាតត្បាតពាសពេញប្រទេសខ្មែរទៅវិញ ទើបគ្រប់ៗគ្នាអាចសន្និដ្ឋានថា អង្គការអនាមិកគឺយួនហាណូយ។ ពីព្រោះក្នុងឆ្នាំ១៩៧៥ ក្រុមនេះបានឃើញអង្គការអនាមិកសម្លាប់ខ្មែរយ៉ាងវក់វីដោយផ្ទាល់ភ្នែក ។ ខ្មែរមួយនគរដែលមិនទាន់ដល់វេនស្លាប់ ត្រូវអង្គការដេញឲ្យចេញចោលទីលំនៅ ដើរទៅដេកពាសវាលពាសព្រៃ អត់បាយអត់ទឹក ។

ផ្ទុយទៅវិញ ពេលជាមួយគ្នានេះ យួនហាណូយចូលមកកាន់ប្រទេសខ្មែរ ប្រមូលអាណិកជនយួនមានចំនួន២សែននាក់ យកទៅលាក់ទុកនៅឯប្រទេសវៀត-ណាម មានឡាន មានកាណូត សណ្តោងទូកធំៗជិះយ៉ាងស្រួល ព្រមទាំងមានបាយទឹកគ្រប់គ្រាន់ ។ល។

ក្រុមនេះវិលមកដល់ស្រុកខ្មែរ ស្រាប់តែជួបប្រទះលកល្បិចយួនហានូយប្រើស្មៀតចោរ ប្លន់ បាញ់ អារក សម្លាប់យ៉ាងសាហាវកំចាយមួយលើកទៀត ។ ដូច្នេះគ្រប់ៗរូបយល់ថា កលល្បិចរបស់អង្គការអនាមិកនិងយួនហាណូយ ចេញតែពីប្រភពជាមួយគ្នា ។ គ្រប់ៗរូបគ្មានទីពឹង ខកខូចចិត្តអស់សង្ឃឹម ក៏នាំគ្រួសាររត់រហូតមកដល់ជំរំណងចន្ទ មានបំណងចូលកាន់ជំរំខាវអ៊ីដាងប្រទេសថៃ ។ លុះដឹងថា H.C.R. ទទួលជនភៀសខ្លួនជនជាតិយួនជាអាទិភាព ប្រជាជនទាំងនោះក៏សំរេចចិត្តយកសញ្ជាតិជាយួនម្តងទៀត ត្រូវតាមពាក្យចាស់ៗដំណាលថា ៖

- គ្រូកាចសិស្សខូច !

យួនម៉្យាងទៀតគឺខ្មែរកម្ពុជាក្រោម ជាពិសេសអតីតមេទាហានអាមេរិកាំង ដែ

លត្រូវយួនហាណូយចាប់នាំទៅលត់ដំដាក់ខ្នោះឬដាក់គុកក្នុងរយៈ៣ឆ្នាំ ។ លុះមានវាសនាសេសសល់នៅរស់បានវិលត្រឡប់មកកាន់ទីលំនៅភូមិស្រុកវិញ ក៏ត្រូវយួនហាណូយឃ្លាំមើលគ្រប់ដង្ហើម អស់សង្ឃឹមក៏រត់មកកាន់ប្រទេសថៃ ។ លុះមកដល់ប្រទេសថៃ ថៃស្តាប់ការសន្ទនាភាសាខ្មែរកម្ពុជាក្រោម ថៃយល់ច្រឡំថាជាយួន ក៏បញ្ជូនយួនជំពូកនេះមកកាន់ជំរំ NW-9 មានចំនួន៤០០នាក់ ។ មានបូជ្ជីយចំនួន៤០០នាក់ ដែលខ្លះជាចារជនរបស់យួនហាណូយ ក៏រត់មកបង្កប់ខ្លួនក្នុងជំរំនេះដែរ។

ចំណែកជនជាតិយួនសុច្ចរិតស្លូតត្រង់ពិតៗ ដែលភៀសខ្លួនរត់តាមផ្លូវគោកមកកាន់ប្រទេសថៃ មានឧបសគ្គយ៉ាងច្រើន គឺត្រូវរត់ឆ្លងកាត់ប្រទេសកម្ពុជា ដែ-លមានបូជ្ជីយឃាមល្បាតយ៉ាងហ្មត់ចត់ ។ បើវាចាប់បាន វាវាយធ្វើទារុណកម្មរហូតដល់ស្លាប់ ។ បើខ្មែរក្រហមចាប់បាន វាវាយធ្វើបាបសម្លាប់ចោលមួយលើកទៀត លុះមកដល់ប្រទេសថៃ ថៃវាយធ្វើបាប ។ បើស្រីៗវាចាប់នាំយកទៅរំលោភ រួចសម្លាប់ចោល ។ បើប្រុសៗ វាចាប់យកទៅសំរាតដូរខោអាវ បញ្ច្រូកថ្នាំបញ្ចុះ ព្រោះវាដឹងថាពួកយួនអស់នេះតែងតែលាក់មាសពេជ្រតាមថ្នេរខោអាវ និងលេបលាក់ទុកក្នុងក្រពះ ។ មានខ្លះត្រូវពួកវាសម្លាប់ចោលថែមទៀត ។ ដូច្នេះគ្រួសារនិមួយៗ ដែលរត់តាមផ្លូវគោកតាមប្រទេសកម្ពុជា ទំរាំមកដល់ជំរំ NW-9 ត្រូវរងគ្រោះស្លាប់ជិតអស់ ។ មានគ្រួសារខ្លះត្រូវគេសម្លាប់ចោលអស់មួយពូជ ។ ក្នុងចំណោមជនជាតិយួនត្រឹមត្រូវពិតៗ ដែលភៀសខ្លួនមកដល់ជំរំ NW-9 នេះ មាន៥នាក់ក្លាយទៅជាឆ្កួតវក់វី, ២នាក់ទៅជាវង្វេង ។

នៅក្បែរអង្រឹងរបស់យាយទៀង មានបងប្អូនជាតិយួន២នាក់អង្គុយក្នុងអង្រឹងជាមួយគ្នា កូនយួនម្នាក់ទៀតអង្គុយក្បែរនោះផ្ទាល់ដី មានអាយុស្របាលគ្នា ឱបក្បាលជង្គង់ទល់មុខនិយាយខ្សិបខ្សៀវស្តាប់មិនច្បាស់ជាភាសាអ្វីឡើយ ស្រាប់តែសើចខ្លាំងៗរបៀបរិះគន់ពេបជ្រាយ ។

យាយទៀងក៏សួរទៅកូនយួនទាំង៣នាក់នោះជាភាសាយួនថា ៖

– តើកូនៗសើចពីរឿងអ្វី ?

ម្នាក់ឈ្មោះប៉ុយ–គីមឡុងឆ្លើយឡើងថា ៖

– ពួកខ្ញុំនឹកឃើញចង់សើចរឿងអាខ្មែរក្រហម វាកាចសាហាវណាស់ ។ វាសម្លាប់តែជាតិរបស់វា តែពេលជួបយួន វាគោរពខ្លាចយួនដូចខ្លាចខ្លា ។

ប៉ុយ–គីមឡុងក៏និទានរឿងរបស់វាបន្តទៅទៀតថា ៖

– កាលពីឆ្នាំ១៩៧៥ នៅពេលដែលអង្គការទទួលជ័យជំនះភ្លាម អង្គការបញ្ជាឲ្យខ្មែរក្រហមចាប់ម៉ែឪខ្ញុំ និងម៉ែឪ «អាឡុក» នាំយកទៅសម្លាប់ចោលភ្លាម ជាមួយនឹងប្រជាជនខ្មែរនៅខេត្តតាកែវយ៉ាងវក់វី ។ ប៉ុយ–គីមឡុងនិយាយបានតែប៉ុណ្ណោះ

ក៏បែរទៅរកបងវាហើយនិយាយជាភាសាខ្មែរថា ៖

- អាភុង ឯងនិយាយបន្តពីអញទៅ អញនិយាយយួនមិនកើតទេអ៊ើយ ។

យាយទៀងភ្ញាក់ព្រើតសើច ហើយក៏និយាយជាភាសាខ្មែរតបទៅវិញថា ៖

- ចូរក្មួយឡុងនិយាយជាភាសាខ្មែរចុះ ខ្ញុំស្តាប់បានទាំងអស់ ។ ប៊ុយ-គីមឡុង ក៏និយាយរឿងរបស់វាជាភាសាខ្មែរច្របូកច្របល់ជាមួយភាសាយួនបន្តទៅទៀត ៖

- កាលពីពួកយួនចូលមកប្រមូលពួកខ្ញុំនាំទៅកាន់ប្រទេសវៀតណាម ខ្ញុំនៅតូចណាស់ ។ ក្នុងរយៈពេល៣ឆ្នាំ ខ្ញុំក៏រត់មកកាន់ប្រទេសថៃ ។ ភាសាយួនខ្ញុំចេះបន្តិចបន្តួច ឯភាសាខ្មែរខ្ញុំភ្លេចសឹងទាំងអស់ទៅហើយ ។ ឡុងបន្តទៅទៀតថា ៖

- ខ្ញុំមានបងប្អូនប្រុស៣នាក់ ។ ម៉ែឪខ្ញុំស្លាប់អស់ហើយ ។ បងទី១ឈ្មោះប៊ុយ - ថាញ់មិញ អាយុ២៣ឆ្នាំ ។ បងទី២ឈ្មោះប៊ុយ-ថាញ់ភុង អាយុ៩ឆ្នាំ និងខ្ញុំអាយុ៨ ឆ្នាំ ។ ចំណែកអាឡុកអាយុ៨ឆ្នាំ ។ ខ្មែរក្រហមប្រមូលពួកខ្ញុំទាំង៤នាក់បញ្ចូលក្នុងកងចល័ត បង្ខំឲ្យធ្វើការទាំងយប់ទាំងថ្ងៃ ។

ក្នុងខែកក្កដាឆ្នាំ១៩៧៧ ស្រាប់តែឃើញយួនចំនួន១៥នាក់ចូលមកកាន់កន្លែងពួកខ្ញុំកំពុងតែលើកទំនប់ទឹក រួចចេញបញ្ជាក្នុងនាមជាតំណាងអង្គការបង្គាប់ឲ្យខ្មែរក្រហមប្រមូលប្រជាជនយួន ដែលនៅក្នុងកងចល័តទាំងអស់ឲ្យពួកវា ។ ពួកខ្មែរក្រហមខ្លាចពួកយួនទាំង១៥នាក់នោះណាស់ ទទួលគោរពបញ្ជាដើរប្រមូលកូនយួនក្មេងៗទាំងអស់បានចំនួន១៧នាក់ ដែលមានខ្លួនខ្ញុំនៅពេលនោះដែរ ។ អ្នកដែលមានអាយុច្រើនជាងគេ គឺបងមិញតែម្នាក់គត់ ។ ខ្មែរក្រហមត្រូវប្រមែប្រមូលរកអង្ករនិងម្ហូបឲ្យបានគ្រប់គ្រាន់ ហើយរែកជូនដំណើរពួកយើងទៅប្រទេសវៀតណាម ។ ស្បៀងត្រូវរៀបឲ្យបានគ្រប់សំរាប់បាយ២ពេល សំរាប់ចំនួនមនុស្ស៤០នាក់។

លុះធ្វើដំណើរទៅដល់ព្រំដែនយួន-ខ្មែរហើយ យួនបង្គាប់ឲ្យខ្មែរទាំងនោះកប់អាវុធក្នុងដីសិន រួចទើបវាបង្គាប់ឲ្យខ្មែរក្រហមសែងឥវ៉ាន់បន្តទៅទៀតសំដៅភូមិម៉ីឡាយ ។ ពេលបាយថ្ងៃត្រង់ យួនបង្គាប់ឲ្យខ្មែរក្រហមទៅរកទឹកមកហូប ។ ពួកវាមិនដឹងថានៅស្រុកយួនមានកន្លែងទឹកប្រៃ មានកន្លែងទឹកសាបទេ ។ វាដងទឹកប្រៃមកឲ្យពួកយើង ។ យួនឃើញដូច្នេះក៏បញ្ជាឲ្យខ្មែរក្រហមឱនក្បាលសំពះសុំទោសពួកយើង ព្រមទាំងស្តីបន្ទោសដូចសត្វអញ្ចឹង ។ គឺនឹកឃើញត្រង់កន្លែងនេះហើយ ដែលពួកយើងខ្ញុំនាំគ្នាសើចនោះ ។ រួចហើយពួកក្មេងៗយួនទាំងនោះក៏សើចកាច់កបន្តទៅទៀត...។

យាយទៀងសួរទៅក្មេងយួនទាំងនោះថា ៖

- តើបងមិញរបស់ឯងចេះនិយាយខ្មែរឬទេ ?

ប៊ុយ-ថាញ់ភុងក៏សើចម្តងទៀត ព្រមទាំងឆ្លើយថា ៖

- បងមិញចេះនិយាយ ចេះអាននិងសរសេរអក្សរខ្មែរច្បាស់លាស់ណាស់ ។ នៅឆ្នាំ១៩៧៣ គាត់ប្រឡងជាប់បាក់ឌុបនៅស្រុកខ្មែរ ។ ភុងត្រូវអាក់ខាននិយាយត្រឹមណោះ ដោយឃើញបងមិញរបស់វាដើរចូលមក ។ មិញព្ចខ្លះៗពីចម្ងាយ ក៏សម្លក់មកប្អូនប្រុសវា ។ តែភុងធ្វើមិនដឹង ក៏និយាយបន្តប់ទៅបងវាថា ៖

- បងមិញអាំ អុំទៀងចេះនិយាយភាសាខ្មែរ ! ។

នៅក្នុងជំរំ NW-9 មិញនិងយាយទៀងចងអគ្រឹងបាវដេកជិតគ្នាជាច្រើនខែ ។ ប៊ុយ-ថាន់មិញ រាប់អានស្រឡាញ់យាយទៀងដូចម្ដាយបង្កើតរបស់វា ។ វានិយាយប្រាប់យាយទៀងជាហូរហែថា ៖

- ខ្ញុំនឹកៗទៅគួរឲ្យឆ្ងល់ណាស់ថា ពួកខ្មែរក្រហមកាចសាហាវណាស់ សម្លាប់ខ្មែរជាតិឯងឥតមេត្តា ។ តែផ្ទុយទៅវិញនៅពេលណាវាជួបយួន វាគោរពស្ដាប់បញ្ជាដូចចៅហ្វាយ ។ មិញបន្តទៅទៀតថា ៖

- លុះនាំក្រុមខ្ញុំមកដល់ភូមិម៉ីឡាយហើយ យួនក៏បំបែកក្មេង១៦នាក់ចេញដើម្បីបញ្ចូលទៅក្នុងកងចល័តខ្មែរក្រហម ដែលស្ម័គ្រចិត្តកំទេចសក្តិភូមិនិងចក្រពត្តិ ។ ឯខ្លួនខ្ញុំ យួនបញ្ជូនទៅក្នុងសាលាមេយោធាជាមួយក្មេងៗអាយុស្របាលគ្នាជាច្រើនពាន់នាក់ទៀត ដែលគេប្រមូលមកពីគ្រប់ទិសទីនៅស្រុកខ្មែរ ។ ពួកនេះចេះខ្មែរយ៉ាងជ្រៅជ្រះ មានសញ្ញាប័ត្រដូចខ្ញុំ ។ លើសពីនេះទៅទៀត ពួកនេះដុះចិត្តចង់វិលចូលស្រុកខ្មែរវិញ ដើម្បីសងសឹកវាយខ្មែរដែលត្រូវគេនាំឲ្យធ្វើបាតុកម្មវាយម៉ែឪបងប្អូនវាកាលពីឆ្នាំ១៩៧០នៅភ្នំពេញ ។ លុះហាត់រៀនចេះចប់ ត្រូវផឹកទឹកសម្បថយកសញ្ជាតិជាខ្មែរ ។ ឧទាហរណ៍ចំពោះរូបខ្ញុំនេះ គេដាក់ឈ្មោះឲ្យខ្ញុំថាមិត្តម៉ាង ហើយគេបញ្ជាក់ប្រាប់ពួកខ្ញុំថា គឺពួកយើងនេះហើយដែលជាខ្មែរថ្មី ជាម្ចាស់ទឹកដីកម្ពុជាទៅអនាគត ។ យួនហាណូយបានបំពាក់ស័ក្តិឲ្យខ្ញុំជាអនុសេនីយ៍ត្រីមានភារៈជាមេកាន់ក្ដាប់យោធាខ្មែរក្រហមដែលស្ម័គ្រចិត្តកំទេចសក្តិភូមិនិងចក្រពត្តិអាមេរិកាំង ។ មូលដ្ឋានយ៉ាងធំរបស់ពួកនេះ គឺស្ថិតនៅក្បែរភូមិម៉ីឡាយ ។ ក្នុងខែកុម្ភៈឆ្នាំ១៩៧៩ យួនហាណូយបញ្ជូនខ្មែរក្រហមក្រុមនេះចូលតាំងមូលដ្ឋានពាសពេញព្រៃនៃប្រទេសកម្ពុជា ។ ក្នុងចំណោមពួកនេះ មានខ្ញុំ, ភួង, ឡុង និងឡុក ដែលត្រូវគេបញ្ជូនមកកាន់ព្រៃទាក់ធ្នឹម ខេត្តបាត់ដំបង ។ មិញបញ្ជាក់ថែមទៀតថា ៖

- ពួកខ្ញុំដើរវាងតាមប្រទេសលាវ, ប្រទេសថៃឡង់ដ៍ ហើយចូលមកកាន់ប្រទេសខ្មែរដោយកាត់តាម «ផ្លូវសម្ងាត់គីរូងភ្នំដងរែក» ។

យួនហាណូយដឹងថាខ្ញុំចេះអក្សរខ្មែរជ្រៅជ្រះ វាក៏បញ្ចូលខ្ញុំមកក្នុងជួរបញ្ញវ័ន្តដែលជាអាណិកជនយួនកើតនៅស្រុកខ្មែរ ដែលចេះសរសេរនឹងនិយាយខ្មែរយ៉ាងច្បាស់លាស់ ។

ក្នុងឆ្នាំ១៩៨០ យួនហាណូយតែងតាំងខ្ញុំឲ្យធ្វើជាចារបុរសឲ្យវាវិញ ។ ឆ្លៀតពេលដែលយួនបញ្ជូនមិត្តម៉ាងខ្ញុំ ឲ្យទៅធ្វើចារកិច្ចនៅស្រុកមង្គលបូរី មិត្តម៉ាងក៏លួចបណ្ដោះអាកុង, អាឡុង និងអាឡុក ចេញពីអង្គការយោធាខ្មែរក្រហម រួចហើយក៏បណ្ដើរគ្នាចូលកាន់ជំរំណងច័ន្ទ ហើយដែលត្រូវគេបញ្ជូនចូលកាន់ជំរំ NW-9 នេះតែម្ដង ។ មិត្តម៉ាងបញ្ជាក់ថា វាមិនចូលចិត្តបំរើយួនហាណូយទេ ព្រោះវិន័យតឹងរឹងណាស់ ។ នយោបាយរបស់វាសែនក្រឡិចក្រឡុចងងឹតអន្ធការ ។ វាឆ្អែប្រឌិតយួនឲ្យធ្វើជាខ្មែរ ចំណែកខ្មែរវាបំបែកឲ្យទៅជាក្រុមៗ រួចវាញុះញង់ក្រុមនិមួយៗឲ្យស៊ើបការណ៍ឲ្យវា ។ ដូច្នេះសព្វថ្ងៃរវល់តែស៊ើបការណ៍ខ្មែរគ្នាឯង ដើម្បីផ្គាប់ចិត្តចៅហ្វាយយួនហាណូយ ។ មិត្តម៉ាងសន្និដ្ឋានថា អង្គការគឺយួនហាណូយ ព្រោះវាបានឃើញផ្ទាល់ភ្នែកថា ខ្មែរក្រហមខ្លាចនិងគោរពបញ្ជាយួនហាណូយដូចជាចៅហ្វាយនាយ ។ ក្នុងខែធ្នូ១៩៧៩ បងប្អូនរបស់វាបានឃើញផ្ទាល់ភ្នែកថា អង្គការបញ្ជូនយោធាខ្មែរក្រហមចំនួន៧,០០០នាក់ ឲ្យដើរចូលអន្ទាក់ខ្សែត្រៀមរបស់បូដូយ ហើយដែលត្រូវបូដូយបាញ់សម្លាប់ចោលខ្ទេចនៅក្បែរភូមិម៉ឺទ្បាយ ។

មិញបញ្ជាក់ថែមជាបញ្ចប់ទៀតថា ៖

- យួនហាណូយបានព្រៀងគំរោងការណ៍ប្រែឈ្មោះរដ្ឋធានីភ្នំពេញនិងខេត្តនានាជាភាសាយួនរួចហើយ ។ មានកលល្បិចមួយដែលយួនហាណូយប្រើ ៖ ឧទាហរណ៍កាលណាយួនចាប់ខ្មែរម្នាក់បាន វាយកមកសួរចម្លើយ បើជនរងគ្រោះនោះឆ្លើយឈ្មោះខេត្តជាខេត្តខ្មែរ ជននោះត្រូវគេចោទប្រកាន់ថាជា «ចារជន» របស់ ខ្មាំងទើបនឹងមកដល់ បានជាមិនដឹងថាខេត្តខ្មែរទាំងនោះត្រូវគេដូររួចអស់ទៅហើយ ។ ដូច្នោះជននោះត្រូវគេឃុំឃាំងទុកសិន ។ មឹងឃើញទេ ? ស្ទៀតនេះយួនហាណូយធ្វើឲ្យខ្មែរខ្លាចជាប់ឃុំ ! ។

ទោះបីជាចង់ឬមិនចង់យ៉ាងណាក៏ដោយ ខ្មែរខ្លាចជាប់ឃុំ ត្រូវតែបង្ខំចិត្តហៅឈ្មោះខេត្តខ្មែរនោះតាមយួនដាក់...។

## តារាងប្រែឈ្មោះខេត្តពីឈ្មោះខ្មែរទៅឈ្មោះយួន

| ឈ្មោះខេត្តខ្មែរ | ឈ្មោះខេត្តយួនដាក់ |
|---|---|
| ១- រដ្ឋធានីភ្នំពេញ | ក្រុងហូ-ជីមិញ |
| ២- ក្រុងកណ្ដាល | ក្រុងបេនត្រែ |
| ៣- ក្រុងស្វាយរៀង | ក្រុងឡុងអាន |
| ៤- ក្រុងតាកែវ | ក្រុងអានយ៉ាង |
| ៥- ក្រុងសៀមរាប-ឧត្តរមានជ័យ | ក្រុងប៊ិញទ្រីធៀន |

| | |
|---|---|
| ៦- ក្រុងកំពង់ឆ្នាំង | ក្រុងហូវយ៉ាង |
| ៧- ក្រុងកោះកុង | ក្រុងមិញហាយ |
| ៨- ក្រុងព្រះវិហារ | ក្រុងធន់ហាយ |
| ៩- ក្រុងរតនៈគីរី | ក្រុងងាប៊ិញ |
| ១០- ក្រុងក្រចេះ | ក្រុងស៊ុងប៊ែរ |
| ១១- ក្រុងកំពង់សោម | ក្រុងហៃហ្វុង |
| ១២- ក្រុងកំពង់ចាម | ក្រុងតៃនិញ |
| ១៣- ក្រុងព្រៃវែង | ក្រុងដុងចាប |
| ១៤- ក្រុងកំពង់ធំ | ក្រុងដុងណាយ |
| ១៥- ក្រុងបាត់ដំបង | ក្រុងក្យងណាម ឬដាណាំង |
| ១៦- ក្រុងពោធិសាត់ | ក្រុងទៀងយ៉ាង |
| ១៧- ក្រុងកំពត | ក្រុងកៀនយ៉ាង |
| ១៨- ក្រុងកំពង់ស្ពឺ | ក្រុងគីវឡុង |
| ១៩- ក្រុងស្ទឹងត្រែង | ក្រុងភូខាញ់ |
| ២០- ក្រុងមណ្ឌលគីរី | ក្រុងដាឡាត់ |

មានពត៌មានខ្លះៗទៀតលេចឮមកថា អង្គការមានបញ្ជូនយោធាដែលស្រឡាញ់សម្តេចឪនាំយកទៅឲ្យបូដូយបាញ់សម្លាប់ចោល ជាបន្តបន្ទាប់នៅទីកន្លែងផ្សេងៗទៀត ។

ម៉្យាងវិញទៀត ពេលយួនហាណូយចូលមកលុកលុយរាតត្បាតប្រទេសខ្មែរភ្លាម (ខែមករាឆ្នាំ១៩៧៩) វាដើរជ្រើសរើសរកខ្មែរក្រហមសេសសល់ដែលជាឃាតករដ៏សាហាវឃោរឃៅ ដែលមានស្នាដៃធ្លាប់សម្លាប់ខ្មែរ ៖

- មានអ្នកធ្លាប់សម្លាប់ខ្មែរក្នុងមួយថ្ងៃ៥០នាក់
- មានអ្នកធ្លាប់សម្លាប់ខ្មែរក្នុងមួយថ្ងៃ១០០នាក់
- មានអ្នកធ្លាប់សម្លាប់ខ្មែរក្នុងមួយថ្ងៃ១៥០នាក់

ពួកនេះត្រូវយួនហាណូយនាំយកទៅលាក់ទុកនៅភូមិព្រៃកលីវ ស្រុកកងមាស ខេត្តកំពង់ចាម ។ ព្រោះយួនហាណូយមានគំរោងការណ៍បង្កើតឃាតករអាថ៌កំបាំង ដូចកាលជំនាន់អង្គការអនាមិក (ឆ្នាំ១៩៧០-៧៥) ឡើងវិញ ។ វាដាក់ឈ្មោះថាបង្អែកបដិវត្តន៍ ។

នៅថ្ងៃទី២-១១-១៩៨៥ ជនភៀសខ្លួនខ្មែរម្នាក់មកដល់ស្រុកបារាំង ។ គឺយាយផុន អាយុ៧១ឆ្នាំ បានអះអាងប្រាប់យាយទៀងថា ៖

- គាត់បានឃើញផ្ទាល់ភ្នែក នូវការរៀបចំរបស់យួនហាណូយពីរឿងប្រមូលឃាតករ៥០, ១០០, ១៥០នាក់ក្នុងមួយថ្ងៃនោះ ។ គាត់ឃើញនិងស្គាល់ឃាតករខ្លះៗដែលសម្លាប់ប្រជាជនខ្មែរកាលពីសម័យប៉ុល-ពត ។ ឥឡូវនេះយួនហាណូយដឹកពួកទាំងនោះ រួចហើយទំនុកបំរុងឲ្យដេកស៊ី ដើរលេង សំរាកនៅភូមិព្រែកលីវទាំងអស់មានចំនួន៥០០នាក់ ។ ប៉ុន្តែដើម្បីឆ្លៃយកទៅធ្វើជាអ្វីទៀត គាត់អត់ដឹងទេ ។

# ជំពូកទី២៤

★ ជួបលោកទ្រីវ-ចូវ
★ កលល្បិចរបស់យួនហាណូយបង្កើតរ.ជ.រ.ប.ខ.
★ រណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរក្លែងក្លាយ

## កលល្បិចរបស់យួនហាណូយបង្កើត រ.ជ.រ.ប.ខក្លែងក្លាយ

ចុងខែសីហាឆ្នាំ១៩៨០, លោកទ្រីវ-ចូវ ( លោកទ្រីវ-ចូវជាអតីតអនុសេនីយ៍ឯកកងកម្លាំងម៉ារីនអាមេរិកាំងនៅព្រៃនគរ និងជាសេរ៊ីអា ជាតិខ្មែរកម្ពុជាក្រោមកើតនៅភូមិកំពង់ខ្សាយ ស្ថិតនៅជាយក្រុងត្រាវិញ ភាគខាងត្បូង ។ អ្នកនិពន្ធដាក់ឈ្មោះគាត់ដូច្នេះ ព្រោះរឿងសន្តិសុខរបស់គាត់ ) មកជួបយាយទៀងនៅក្នុងជំរំ NW-9 ។ ពេលជួបគ្នានេះក៏ចាប់ផ្ដើមសួរសុខទុក្ខគ្នាទៅវិញទៅមក ។ លោកទ្រីវ-ចូវរ៉ាយរ៉ាប់ថា ៖

- យួនហាណូយចាប់ខ្ញុំដាក់គុកអស់ចំនួន៣ឆ្នាំ ។ ចុងឆ្នាំ១៩៧៩ ខ្ញុំរួចចេញពីពន្ធនាគារ ។ ខ្ញុំក៏វិលត្រឡប់ទៅកាន់ភូមិកំពង់ខ្សាយ ដែលជាស្រុកកំណើតវិញ ។ យួនឃ្លាំមើលខ្ញុំគ្រប់ដង្ហើមចេញចូល ។ ខ្ញុំក៏ចំរេចចិត្តរត់ចេញមកកម្ពុជាកណ្ដាលនៅចុងខែមីនាឆ្នាំ១៩៨០ ។

មកដល់ខេត្តស្វាយរៀង ខ្ញុំបានជួបលោកគៀង-ទ្រឿង ជាអតីតវរ:សេនីយ៍ឯក (ស័ក្តិ៥) កងកម្លាំងម៉ែកហ្វ័រ្ស ( Mike's Force ) ។ បច្ចុប្បន្នលោកជាមេបញ្ជាការរ.ជ.រ.ប.ខ. ភាគត្រើយខាងកើតនៃទន្លេមេគង្គ ។ ខ្ញុំក៏ចូលបំរើរណសិរ្សនេះភ្លាមដោយគ្មានរារែក ។ លោកគៀង-ទ្រឿងនាំខ្ញុំទៅកាន់ព្រៃកតាមាក់ ដើម្បីបង្ហាញសហការីរបស់លោកបីនាក់ ។

លោកពីរនាក់ជាអតីតស័ក្តិពីរភ្លេចឈ្មោះនិងលោកម្នាក់ទៀតឈ្មោះថាច់-ទ្រឿង ដែលជាអតីតអង្គរក្សរបស់លោកសឺង-ង៉ុកថាន់ ។ លោកថាច់-ទឿងទើបនឹង

រួចចេញពីខ្ទោះយួនហាណូយនៅខេត្តដាណាំង ។

យាយទៀងនិយាយកាត់ឡើងថា ៖

- ខ្ញុំបានជួបលោកថាច់-ទ្រឿង កាលពីថ្ងៃទី១៦-៤-៨០ នៅទីក្រុងបាត់ដំបង។ លោកបានទៅលាខ្ញុំដើម្បីភៀសខ្លួនចេញទៅប្រទេសថៃ ។

លុះដឹងថាលោកទ្រឿងមានវាសនាគេចចាកផុតគ្រោះថ្នាក់យ៉ាងនោះហើយ លោកចូវត្រេកអរជាក្រៃលែង ។ លោកក៏ចាប់បន្តទៅទៀតថា ៖

- ដោយលោកគៀង-ទ្រឿងដឹងថាខ្ញុំចេះច្រើនភាសាគឺខ្មែរ, បារាំង, អង់គ្លេស, យួនហាណូយ, យួនហ្វេ, យួនខាងត្បូង លោកក៏នាំខ្ញុំទៅកាន់រដ្ឋធានីភ្នំពេញ ដើម្បីបង្ហាញខ្លួនដល់មេបញ្ជាការធំនៃរណសិរ្សរ.ជ.រ.ប.ខ. ។ លុះទៅដល់ទីស្នាក់ការនោះ ខ្ញុំនឹងលោកទ្រឿងបានជួបមេបញ្ជាការរងជាស្រីចំណាស់ម្នាក់ ជាប្រពន្ធរបស់អតីតវរៈសេនីយ៍ឯកដែលអង្គការបានសម្លាប់ចោលតាំងពីឆ្នាំ១៩៧៥មកម្ល៉េះ ។ មេបញ្ជាការប្រាប់យើងថា ៖

- លោកមេបញ្ជាការធំចេញទៅបំពេញបេសកកម្មនៅភ្នំប្រសិទ្ធិផុតទៅហើយ។

លោកគៀង-ទ្រឿងមានការជាបន្ទាន់ត្រូវវិលទៅកាន់ ព្រៃកតាមាកវិញ ។ លោកក៏សរសេរសំបុត្រមួយច្បាប់ទុកជូនលោកមេបញ្ជាការធំ ដែលជាប្រវត្តិរូបបញ្ជាក់ពីសមត្ថភាពរបស់ខ្ញុំ ហើយប្រគល់ទុកលើខ្លួនខ្ញុំផ្ទាល់ជាអ្នកកាន់ ។ នៅពេលមកដល់ទីចាត់ការរបស់រណសិរ្ស ខ្ញុំសង្កេតឃើញហេតុការណ៍មិនទំនងដែលគួរឲ្យចាប់អារម្មណ៍ចំពោះវត្តមាននៃទីស្នាក់ការដែលចាប់បដិសន្ធិនៅចំកណ្ដាលទីក្រុង ។

បន្ទាប់ពីលោកគៀង-ទ្រឿងចេញផុតទៅ ខ្ញុំក៏ចាប់សាកសួរស្ទាបស្ទង់ពីពត៌មាននិងស្ថានការណ៍ខ្លះៗពីសំណាក់អ្នកស្រីមេបញ្ជាការរងនោះ ។ យាយមេបញ្ជាការរងក៏ថ្លែងអួតអាងថា ៖

- ក្រុមរបស់គាត់បានបង្កើតរណសិរ្សរ.ជ.រ.ប.ខ.នៅសឹងតែគ្រប់ខេត្តក្នុងប្រទេសកម្ពុជា ។ មេដឹកនាំភាគច្រើនមានភេទជាស្រី...

អ្នកស្រីនេះរៀបរាប់យ៉ាងវែងនូវសកម្មភាពនានា ជាទីបញ្ចប់ខ្ញុំមានការចាប់អារម្មណ៍និងពាក្យមួយឃ្លាយ៉ាងក្រអឺតរបស់មេបញ្ជាការរងនោះ ដែលនិយាយមានកាន់ខ្ញុំថា ៖

- យួនហាណូយគ្មានហ៊ានក្អកទេ !...

លោកទ្រីវ-ចូវបន្តទៅទៀតថា ៖

- ខ្ញុំពិចារណាមើលទៅ ឃើញដូចជាមិនទំនងសោះ ព្រោះគោលបំណងរបស់រណសិរ្សរ.ជ.រ.ប.ខ. គឺការវាយកំទេចយួនហាណូយ ដើម្បីរំដោះទឹកដីកម្ពុជា ។ ចុះហេតុដូចម្ដេចបានជាមានរណសិរ្សរ.ជ.រ.ប.ខ.មួយនៅក្រោមច្រមុះយួនយ៉ាងដូ

ចេ្ចះទៅវិញ ?

ក្នុងរយៈពេល២យប់៣ថ្ងៃនៃការរង់ចាំរបស់លោកទ្រីវ-ចូវ លោកបានឃើញអស់លោកអតីតស័ក្តិ១, ស័ក្តិ២, ស័ក្តិ៣ជាច្រើនចូលមកទាក់ទងមេបញ្ជាការរងនេះជាហូរហែ ។ លោកថែមទាំងឃើញថា អស់លោកអតីតនាយទាហានទាំងនោះបានទទួលមាសម្នាក់បន្តិចៗពីមេបញ្ជាការរងនោះទៀតផង សំរាប់ការចាយវាយ ។

តាមមាត់បង្អួចពីលើបន្ទប់សំរាករបស់លោកនៅជាន់ទី២ លោកទ្រីវ-ចូវឃើញមានពួកបូជួយដើរទៅដើរមកយ៉ាងព្រោងព្រាត របៀបឃ្លាំមើលតែលោកគ្មានឃើញសញ្ញាណាដែលបញ្ជាក់ថាមានការដេញដោលសាកសួរអស់លោកនាយទាហាន ដែលដើរចេញចូលចុះឡើងពីអាគារទីស្នាក់ការនោះឡើយ ។

ល្ងាចថ្ងៃទី៣ កំពុងតែអន្ទះអន្ទែងរង់ចាំលោកមេបញ្ជាការ ស្រាប់តែសម្លេងគោះទ្វារតុកៗក៏បន្លឺឡើង ។ លោកទ្រូវ-ចូវក៏ដើរទៅបើកទ្វារ ស្រាប់តែលេចមុខអ្នកស្រីមេបញ្ជាការរងនៅចំពីមុខ ។ អ្នកស្រីនេះនិយាយឡើងថា លោកមេបញ្ជាការធំទើបនឹងអញ្ជើញត្រឡប់មកវិញហើយ ។ លោកសុំអញ្ជើញលោកទ្រីវ-ចូវទៅជួប ។

ពេលទៅដល់ការិយាល័យ លោកទ្រីវ-ចូវភ្ញាក់ព្រើត ដោយឃើញលោកមេបញ្ជាការនោះជាស្ត្រីម្នាក់ដែលគាត់ស្គាល់ច្បាស់ ហើយដែលខ្លួនលោកជាភ្នាក់ងារសេអ៊ីអា មានឯកសារនិងរូបថតសម្ងាត់បញ្ជាក់ថា ស្ត្រីនេះជាយួនបន្លំធ្វើខ្មែរ និងជាអតីតមេខ្មែរវៀតមិញនៅភូមិមេមត់ ខេត្តកំពង់ចាម ។

នៅពេលជួបគ្នាជាថៃ្ងជន្យយ៉ាងនេះ លោកចូវផ្សងព្រេងផ្លាស់ចិត្តផ្លាស់យោបល់ ។ លោកក៏ចាប់ឆ្លើយឆ្លងជាមួយយាយយួននោះជាភាសាយួនហ្វេ ។ លោកនិយាយប្រាប់យាយយួននោះថា លោកទើបនឹងចេញពីសាលានយោបាយជាន់ខ្ពស់ឈ្មោះ X ( ឈ្មោះសាលាជាន់ខ្ពស់នេះនៅទីក្រុងហាណូយ ខ្ញុំភ្លេចឈ្មោះ ) នៅហាណូយ ។ លោកចេះភាសាខ្មែរខ្លះៗ ទើបលោកផាំ-វាន់ដុងបញ្ជូនលោកមកធ្វើជាចារបុរសនៅប្រទេសកម្ពុជាមួយរយៈ ។

គ្រាន់តែឮសូរឈ្មោះសាលានយោបាយជាន់ខ្ពស់នោះភ្លាម យាយយួនជាមេបញ្ជាការរបស់រណសិរ្សក្លែងក្លាយនោះ ជឿទាំងស្រុងគ្មានសង្ស័យឡើយ ព្រោះមានតែភ្នាក់ងារចារកិច្ចជាន់ខ្ពស់ទេទើបស្គាល់ ។

យាយយួនមេបញ្ជាការនេះឈ្មោះ គឹម-លៀង ។ ក្នុងរបបហេង-សំរិនយាយគឹម-លៀងមានមុខងារជាមេឃ្លាំងនៅទីក្រុងកំពង់សោម មានឈ្មោះថា លៀង-ញ៉ាន ( Liêng Nhan ) ។

យាយគឹម-លៀងក្រោកឡើងដើរទៅបិទទ្វារ រួចវិលត្រឡប់មកអង្គុយទល់មុខលោកទ្រីវ-ចូវ ហើយនិយាយខ្សិបៗល្មមតែឮពីរនាក់ថា ៖

- លោកផាំ-វាន់ដុងបានសន្យានឹងបញ្ជូនខ្ញុំទៅរៀនសូត្រនៅសាលានយោបាយជាន់ខ្ពស់នៅថ្ងៃណាមួយ ។ ខ្លួនខ្ញុំនិងសហការីភេទស្រីៗចំនួន៣៥នាក់ទៀតទើបនឹងចេញពីសាលានយោបាយជាន់មធ្យមនៅខេត្តដាណាំង ។ សាលានេះអប់រំក្រុមខ្ញុំឲ្យចេះដឹកនាំរណសិរ្សរ.ជ.រ.ប.ខ.ក្លែងក្លាយ គឺត្រូវធ្វើសកម្មភាពសំរបនឹងរ.ជ.រ.ប ខ.មែនទែនរបស់លោកសឺន-សានដែលកំពុងតែបង្កើត ។

នៅទីក្រុងភ្នំពេញ យួនហាណូយចាត់តែងតាំងខ្ញុំជាមេបញ្ជាការធំ ។ រីឯសហការីឯទៀតៗ ខ្ញុំបានចាត់ចែងបញ្ជូនឲ្យទៅបង្កើតការិយាល័យនៅតាមខេត្តនានារួចខ្លះៗហើយ ។

យាយគីម-លៀងយល់ច្រឡំថា លោកទ្រីវ-ចូវជាចារបុរសរបស់ផាំ-វាន់ដុង។ ដូច្នេះហើយបានជាយាយយួននេះមិនលាក់លៀមអ្វីទេ ។ ផ្ទុយទៅវិញគាត់ខំលាតត្រដាងប្រាប់លោកចូវឲ្យអស់ពីសកម្មភាពរបស់គាត់ ឲ្យចារបុរសផ្ទាល់ផាំ-វាន់ដុងក្លែងក្លាយនេះ ទៅរ៉ាយរ៉ាប់ប្រាប់ចៅហ្វាយ ។ ធ្វើដូច្នេះយាយយួននេះសង្ឃឹមថាទៅថ្ងៃក្រោយ គាត់មុខតែឆាប់បានទៅរៀនសូត្រនៅសាលាជាន់ខ្ពស់ X នោះជាមិនខាន ។

បន្ទាប់ពីបានស្តាប់យាយយួនគ្រប់ជ្រុងជ្រោយហើយ លោកទ្រីវ-ចូវក៏ព្រឺក្បាលនឹងផែនការនេះ ។ លោកភ័យរន្ធត់មិនតិចទេ ប៉ុន្តែលោកខំប្រមូលអារម្មណ៍នឹងនរឡើងវិញ ព្រោះលោកជាភ្នាក់ងារសេអ៊ីអាម្នាក់ ដែលមានការពិសោធន៍ក្នុងចារ-កិច្ចនិងស៊ើបអង្កេតដែរ ។

លោកចូវសួរយាយលៀងបន្ថប់ថា តើយាយមេបញ្ជាការរងនោះបានចូលរៀនសាលាអប់រំនយោបាយជាន់មធ្យមនៅខេត្តដាណាំងឬទេ ? ។

យាយលៀងគ្រវីក្បាលឆ្លើយថាអត់ទេ ហើយបន្តថា ក្រុមរបស់គាត់មានគ្នា៣៦នាក់សុទ្ធតែស្រីទាំងអស់ ជាជាតិយួនក្លែងបន្លំយកសញ្ជាតិនិងឈ្មោះជាខ្មែរដូចជាខ្លួនគាត់ យកឈ្មោះខ្មែរកម្ពុជាក្រោមត្រកូលគីមជាដើម ។ ក្រៅពីអ្នកទាំង៣៦នាក់នេះ គឺជាអ្នកបំរើរណសិរ្សរ.ជ.រ.ប.ខ.ពិតៗ ។ យាយមេបញ្ជាការរងរបស់គាត់មិនដឹងថាគាត់ជាចារនារីរបស់យួនហាណូយទេ ។ ពេលគាត់ត្រឡប់មកពីរៀនសូត្រនៅព្រៃនគរវិញ គាត់ភរយាយមេបញ្ជាការរងរបស់គាត់ថា គាត់ទើបនឹងមកពីបំពេញបេសកកម្មនៅភ្នំប្រសិទ្ធិ ។

កិច្ចចរចារវាងមេបញ្ជាការរណសិរ្សរ.ជ.រ.ប.ខ.ក្លែងក្លាយ និងចារបុរសផ្ទាល់ផាំ-វាន់ដុងក្លែងក្លាយត្រូវចប់តែប៉ុណ្ណឹងសិន ព្រោះយប់ជ្រៅណាស់ទៅហើយ ។

មុននឹងទទួលទានដំណេក លោកទ្រូវ-ចូវក៏ដុតសំបុត្ររបស់លោកគៀង-ទ្រឿងចោល ហើយសរសេរសំបុត្រក្លែងក្លាយពីរសន្លឹកជាអក្សរយួន ធ្វើជាសំបុត្រ

បេសកកម្មមួយសន្លឹក និងសំបុត្របញ្ជាបេសកកម្មមួយសន្លឹកទៀត ។

ស្អែកឡើងវេលាម៉ោង១០ព្រឹក យាយគីម-លៀងបានគោះទ្វារអញ្ជើញលោកទ្រីវ-ចូវទៅពិសារបាយ ។ លោកស្លៀកពាក់រួចជាស្រេចហើយគិតថា បើបាយរួចហើយលោកនឹងសុំលាយាយគីម-លៀងគេចចេញជាប្រញាប់ ដើម្បីនាំពត៌មានដ៏អកុសលនេះទៅប្រាប់លោកគៀង-ទ្រឿង ។ រៀបចូលកាន់តុបាយ ស្រាប់តែមានស្រីម្នាក់អាយុ៣៥ឆ្នាំ សម្បុរនិងមុខមាត់ដូចជាយួន គោះទ្វាររួចក៏បើកចូលមកនិយាយខ្សិបៗជាមួយយាយគីម-លៀងមួយសន្ទុះ ។ យាយលៀងបែរមកសុំទោសលោកទ្រីវ-ចូវ រួចក៏ចុះពីអាគារទៅតាមស្រីនោះ ដើម្បីទៅជួបគណៈកម្មាធិការពិសេសមួយក្រុម ។

ពេលយាយលៀងចុះដល់ដី កំពុងជជែកជាមួយគណៈកម្មាធិការនោះ លោកទ្រីវ-ចូវក៏ឈ្លោកលបលួចមើលតាមមាត់បង្អួច លោកឃើញឡានមែរសីដែសមួយគ្រឿងពណ៌ខ្មៅ មានមនុស្សជិះប្រាំនាក់ ។ នៅខាងមុខឡានមានមនុស្សម្នាក់មាឌមាំជិះម៉ូតូនាំផ្លូវ ។ នៅខាងក្រោយមានមនុស្ស២នាក់ជិះម៉ូតូចាំការពារ ។ ជជែកគ្នាមួយសន្ទុះធំ គណៈកម្មាធិការដ៏ចម្លែកក៏សំពះសុំលាយាយគីម-លៀង បរឡានចាកចេញពីទីនោះ ។

យាយគីម-លៀងមុខញញឹមវិលត្រឡប់ឡើងមកជួបលោកទ្រីវ-ចូវវិញ ។ យាយលៀងគ្មានចាប់អារម្មណ៍ឬសង្ស័យអ្វីបន្តិចចំពោះវត្តមានលោកទ្រីវ-ចូវនៅពេលនោះទេ ព្រោះលោកចូវមានរូបរាងសំបុរសមានឈ្មោះបន្លំយួននិងចេះភាសាយួនហ្មត់ចត់ច្បាស់លាស់ ។

ពេលឡើងមកដល់លើវិញ យាយលៀងឃើញលោកទ្រីវ-ចូវកំពុងតែមើលលិខិតក្លែងក្លាយសរសេរជាអក្សរយួន ។ យាយលៀងក៏សួរទៅលោកចូវថា តើលោកអានសំបុត្រអ្វី ? ។

លោកទ្រីវ-ចូវឆ្លើយភ្លាមថា ៖

-ខ្ញុំកំពុងតែពិនិត្យកម្មវិធីបេសកកម្មរបស់ខ្ញុំ ព្រោះថ្ងៃនេះខ្ញុំត្រូវចេញដំណើរទៅកាន់ខេត្តស្វាយរៀង ។

នៅពេលបាយ យាយលៀងទាញជើងម៉ាមកអង្គុយទល់មុខលោកចូវ រួចព្រោកប្រាជ្ញអួតនូវបេសកកម្មពួកអំបាញមិញនេះ ៖

- ក្រុមអំបាញមិញនេះ ទើបនឹងចេញពីសាលានយោបាយអប់រំជាន់មធ្យមនៅដាណាំងដែរ ។ ក្រុមនេះរៀនផ្នែកញុះញង់បំបែកធ្វើឲ្យខ្មែរយល់ច្រឡំសម្លាប់តែគ្នាទៅ ។ ឥឡូវនេះតាមរយៈរ.ជ.រ.ប.ខ. (ក្លែងក្លាយ) របស់យើង យើងបានបញ្ជូនគណកម្មាធិការមួយក្រុមមានគ្នា៤នាក់ ដែលមានមេបញ្ជាការឈ្មោះ « ច័ន្ទ-ភក្តិ »

ត្រូវទៅបំពេញបេសកកម្មតាមបណ្ដោយព្រំដែនខ្មែរ-ថៃ ។ ក្បួនអំបាញមិញនេះធ្វើដំណើរទៅកាន់ភូមិនិមិត្ត ។ យើងមានក្រុមសម្ងាត់រង់ចាំនៅទីនោះហើយ ។ គណកម្មាធិការពិសេសនេះត្រូវមានភារៈកិច្ចធ្វើការញុះញង់ប្រជល់មេដឹកនាំខ្មែរគ្រប់ៗជំរំ ដែលស្ថិតនៅតាមបណ្ដោយព្រំដែនខ្មែរ-ថៃ ឲ្យយល់ច្រឡំដណ្ដើមអំណាច ឈប់ទុកចិត្ត បែកបាក់ សម្លាប់ និងសងសឹកគ្នាជារហូតទៅ ។

នៅពេលដែលយាយលៀងកំពុងតែជក់មាត់ និយាយអួតពីកលល្បិចយួនហាណូយ ស្រាប់តែឮសូរសម្លេងគោះទ្វារ រួចក៏លេចចេញស្រីដដែលមកទៀត ។ ស្រីនេះហុចសំបុត្រមួយសន្លឹកមកយាយលៀង ។ យាយលៀងអានសំបុត្រមួយចប់ហើយ មុខញញឹម ក៏ហុចសំបុត្រនោះមកលោកចូវ...

លោកចូវអានមួយត្រួសហើយ លោកភ័យរន្ធត់ស្ទើរស្លុតស្មារតី លោកហុចសំបុត្រឲ្យយាយលៀងវិញ ព្រមទាំងនិយាយថា លោកមិនចេះមើលអក្សរខ្មែរទេ តើសំបុត្រនេះគេសរសេរពីអ្វី ? ។

យាយលៀងជាមនុស្សមានអំនួត ក៏ទទួលយកលិខិតនោះយកមកអានឲ្យលោកទ្រីវ-ចូវស្ដាប់ ។ សេចក្ដីមានជាអាទិថា មេដឹកនាំរណសិរ្សរ.ជ.រ.ប.ខ.ឈ្មោះគៀង-ទ្រឿងជាអតីតវរៈសេនីយ៍ឯកនិងអតីតអនុសេនីយ៍ទោ២នាក់ទៀត ត្រូវបូជួយចាប់ខ្លួនរួចហើយ ។ ក្រុមនេះមាន៥នាក់ ២នាក់ទៀតរត់គេចខ្លួនរួចគឺ ថាច់-ទ្រឿង និងម្នាក់ទៀតឈ្មោះទ្រីវ-ចូវ !!! សូមក្រុមយាយលៀងតាមដានតទៅទៀត ។ល។

ពេលនោះលោកទ្រីវ-ចូវសឹងដាច់បេះដូងជ្រុះពីដើមទ្រូងម្ដងទៀត ប៉ុន្តែលោកខំទប់ស្មារតីឲ្យបាននៅនឹងនរ ក្នុងកណ្ដាលហ្វូងឆ្កែចចកនេះដដែល មិនឲ្យយាយលៀងសំគាល់នូវភាពតក់ស្លុតរបស់គាត់បានទេ ។ លោកធ្វើជាសួរដោយឆ្ងល់ថា ហេតុយ៉ាងដូចម្ដេចបានជាបូជួយដឹងថាក្រុមនេះជាក្រុមរ.ជ.រ.ប.ខ. ? ។

យាយលៀងញញឹមព្រមទាំងឆ្លើយឡើងថា ៖

- ខ្ញុំជាមេបញ្ជាការរ.ជ.រ.ប.ខ.ក្លែងក្លាយ ភារៈកិច្ចរបស់ខ្ញុំត្រូវចាត់ការតាមដានរណសិរ្សរ.ជ.រ.ប.ខ.មែនទែន ។ បើដឹងថាក្រុមណាមួយមានសកម្មភាពខ្លាំងក្លា អាចបណ្ដាលឲ្យមានគ្រោះថ្នាក់ ខ្ញុំត្រូវតែរាយការណ៍ឲ្យបូជួយជាបន្ទាន់ ដើម្បីឲ្យបូជួយកំទេចឲ្យបានទាន់ពេលវេលា មានករណីលោកគៀង-ទ្រឿងនេះជាដើម ។ លោកគៀង-ទ្រឿងជាអតីតខ្មែរសេរី ទ្រឿងធ្លាប់ស្គាល់គ្រប់ជ្រុងជ្រោយប្រទេសវៀត-ណាម ទ្រឿងជាវរៈសេនីយ៍ឯកក្នុងកងទ័ពម៉ែកហ្វ័ក្ស ( Mike's Force ) ។ លោកទ្រឿងទាក់ទងនឹងរ.ជ.រ.ប.ខ.ស្ថិតនៅព្រំដែនខ្មែរ-ថៃ ទើបទទួលបានមាសប្រាំដំ-ឡឹង និងទើបទទួលបានមនុស្សសំខាន់ម្នាក់ឈ្មោះទ្រីវ-ចូវ ជាជនជាតិខ្មែរក្រោមជាភ្នាក់ងារសេអ៊ីអា ។ ដូច្នេះយើងត្រូវតែកំទេចពួកនេះចោលជាបន្ទាន់ ។

លុះបានស្តាប់គ្រប់ជ្រុងជ្រោយបែបនេះហើយ លោកទ្រីវ-ចូវត្រូវតែប្រញាប់គេចថយចេញពីយាយគីម-លៀង ។ ព្រោះលោកទ្រីវ-ចូវចាប់មានការព្រួយបារម្ភពីគ្រោះថ្នាក់របស់លោកគៀង-ទ្រឿង ដែលច្បាស់ត្រូវពួកបូជ្ជយធ្វើបាបជាមិនខាន ហើយអាចនឹងមានគ្រោះកាចរហូតដល់ខ្លួនលោកផង ដោយសារលោកគៀង-ទ្រឿងទ្រាំមិនបានពីការធ្វើទារុណកម្មនេះ ឆ្លើយប្រាប់ពីទីកន្លែងដែលលោកកំពុងតែស្នាក់នៅ ។ លោកចូវបង្ហាញសំបុត្រក្លែងក្លាយពីរសន្លឹកទៅយាយគីម-លៀង ហើយនិយាយថា ខ្ញុំមានការចាំបាច់ត្រូវទៅឲ្យដល់ខេត្តស្វាយរៀងនៅក្នុងពេលល្ងាចនេះ ។

យាយគីម-លៀងមិនយកចិត្តទុកដាក់មើលសំបុត្រនេះទេ តែបែរជាជូនពរលោកទ្រីវ-ចូវទៅវិញ ។

លោកទ្រីវ-ចូវខំស្រូតធ្វើដំណើរដោយជើងទៅកាន់ប្រទេសថៃ ។ លោកចូលដល់ជំរំណងច័ន្ទនៅចុងខែមេសា១៩៨០ សំរេចយកជាតិយួនដើម្បីទទួលសិទ្ធិអាទិភាពបានចូលកាន់ជំរំ NW-9 ដែលទើបនឹងបង្កើតឡើង ។

លោកទ្រីវចូវមានសតិសម្បជញ្ញៈជាតិយ៉ាងមុតជ្រៅ ។ លោកមានចិត្តអាណិតអាសូរដល់បងប្អូនខ្មែរខ្លះ ដែលមិនបានដឹងពីកលល្បិចរបស់យួនហាណូយ ហើ-នាំគ្នាបោលចូលរណសិរ្សរ.ជ.រ.ប.ខ.ដោយមិនដឹងខ្លួន ។ លោកដឹងយ៉ាងច្បាស់ថាមួយភាគធំច្បាស់ជាច្រឡំចូលក្នុងរ.ជ.រ.ប.ខ.ក្លែងក្លាយនោះ នាំឲ្យមានគ្រោះថ្នាក់ជាមិនខាន ។

ចាប់តាំងពីលោកមកដល់ជំរំ NW-9 ភ្លាម លោកព្យាយាមស៊ើបសួររកអ្នកណាដែលជាខ្មែរធ្លាប់ស្គាល់កលល្បិចក្រឡិចក្រឡុចរបស់យួនហាណូយ ហើយដែលបំរុងចេញទៅកាន់ប្រទេសបារាំង ដើម្បីនាំដំណឹងដូចដែលបានរៀបរាប់ខាងលើទៅជូនទីស្នាក់ការរណសិរ្សរ.ជ.រ.ប.ខ. ។

ខែសីហា១៩៨០ លោកទ្រីវចូវជួបយាយទៀងមានលក្ខណៈដូចដែលគាត់ចង់បាន ។ គាត់បានរៀបរាប់ប្រាប់យាយទៀង នូវរឿងចារកិច្ចដ៏ប្លែកៗអស្ចារ្យដែលមិនងាយមានខ្មែរស្នេហាជាតិណាអាចយកការណ៍បានងាយៗឬជួបប្រទះដូច្នេះទេ ។ លោកចូវបានរៀបរាប់ជាត្រួសៗខ្លះដូចតទៅ ៖

- យួនហាណូយជាសាសន៍ក្រឡិចក្រឡុចបោកប្រាស់ ។ នៅលើពិភពលោកគ្មានសាសន៍ណាធ្វើដូចឡើយ ។ វាមិនមែនបោកតែខ្មែរយើងទេ សូម្បីតែសាសន៍គ្នាវា ក៏វាបោកដែរ ។ ដូចជាកាលពីវាធ្វើសង្គ្រាមជាមួយបារាំងក្នុងឆ្នាំ១៩៤៥-៥៤ វាប្រើអាវុធច្បាំងសម្លាប់បារាំង ។ ចំណែកអាវុធចិត្តសាស្ត្រ វាបោកយួនខាងត្បូងដែ-លធ្វើការជាមួយបារាំងឲ្យធ្វើចារកិច្ចឲ្យវា ដែលជាហេតុធ្វើឲ្យបារាំងចុះចាញ់ត្រូវដក

ថយពីឥណ្ឌូចិន ។ ព្រមជាមួយគ្នានោះវាញុះញង់យួនខាងត្បូងឲ្យធ្វើបាបកំចាយខ្មែរនៅកម្ពុជាក្រោម ដែលមានអ្នកចេះដឹងជាពិសេស ឲ្យរត់ចោលស្រុកទុកទឹកដីឲ្យវានៅ ។ រីឯខ្លួនវាវិញ វាលាក់មុខយ៉ាងជិតដដែល ។ លុះបារាំងចាញ់ត្រូវចាកចេញពីឥណ្ឌូចិន យួនហាណូយត្រូវបាននគរ៣ គឺតុងកឹង, អណ្ណាម និងកូសាំងស៊ីន (កម្ពុជាក្រោម) ។ វាដាក់ឈ្មោះថ្មីឲ្យប្រទេសវាថា ៖ «វៀតណាម» ។ រួចហើយវាលៃលកដាក់ត្រី«រស់»ក្នុងក្រឡមួយ ត្រី«ស្អុយ»ក្នុងក្រឡមួយផ្សេង ។ ត្រី«រស់»គឺពួកយួនហាណូយគ្នាវា ឲ្យទៅខាងជើងមានហូ-ជីមិញជាអ្នកដឹកនាំ ។ ត្រី«ស្អុយ»គឺពួកយួនមួយពួកទៀតឲ្យទៅនៅខាងត្បូង មានង៉ោ-ឌិនយៀមជាមេ ដោយយកខ្សែរបន្ទាត់ស្របទី១៧ ជាព្រំប្រទល់បណ្តោះអាសន្ន ។

នៅក្នុងសង្គ្រាមយួន-អាមេរិកាំង ចាប់ពីឆ្នាំ១៩៦៣ដល់១៩៧៥ វាប្រើកលល្បិចដដែលម្តងទៀត ដោយបោកយួនខាងត្បូងឲ្យធ្វើចារកិច្ចឲ្យវា ដើម្បីវាយអាមេរិកាំងឲ្យចំៗចំណុច រហូតទាល់តែអាមេរិកាំងដកថយ ។

លុះដល់ថ្ងៃទី៣០មេសា១៩៧៥ យួនហាណូយបានសំរេចគោលដៅរបស់វាដោយប្រមូលយកបានប្រទេសយួនទាំងមូល ។ យួនហាណូយក៏«សងគុណ»យួនខាងត្បូងវិញ ។ វាចាប់អញ្ជើញអ្នករដ្ឋការយួនខាងត្បូងដោយប្រើតាមវិធីបោកបញ្ឆោតនានាទៅតាមចំណុចខ្សែរយៀងៗខ្លួន ដើម្បីគ្រមែប្រមូលយកទៅលត់ដំ ដាក់ខ្នោះធ្វើទារុណកម្មយ៉ាងឃោរឃៅ ត្រូវស្លាប់អស់ជាង១លាននាក់ ។ ទំរាំដឹងខ្លួនថា ចាញ់បោកយួនហាណូយ វាយឺតពេលណាស់ទៅហើយ ។ ម្ល៉ោះហើយអ្នកដែលមានមាសពេជ្រ ក៏ខំសូកប៉ាន់ ធ្វើទូកដាក់ម៉ាស៊ីនរត់ផ្សងព្រេងមកតាមថៅហ្វាយចាស់គឺ បារាំង និងអាមេរិកាំង (មានសក្ខីបីយួនខាងត្បូងម្នាក់ឈ្មោះ Khanh បាននិយាយប្រាប់យាយទៀងថា បើបានត្រឡប់ទៅស្រុកកំណើតវិញ គាត់នឹងសម្លាប់យួនហាណូយ មិនឲ្យសល់កូនខ្ចីម្នាក់ឡើយ) ។

នៅចំពោះមុខជាតិខ្មែរវិញ យួនហាណូយជាសាសន៍អកត្តញ្ញូ ។ កាលពីឆ្នាំ១៩-៦៥វាដឹងថា អាមេរិកាំងថបញ្ជូនទ័ពគ្រប់ផ្នែកទៅយួនខាងត្បូង មានចំនួន២សែននាក់ ។ ពេលនោះវារត់មកអែបអបសម្តេចសីហនុ ដើម្បីសុំតាំងទ័ពលើដីខ្មែរ រួចវាបញ្ជូនបួដូយឲ្យមានចំនួនស្មើនឹងទ័ពអាមេរិកាំងដែរ ។ ពេលណាអាមេរិកាំងដេញប្រកិតមក វារត់ចូលដីខ្មែរ ។ សម្តេចសីហនុ កាលណោះជាមិត្តរបស់ហូ-ជីមិញក៏ស្រែកជេរតាមវិទ្យុផ្សើលពេញពិភពលោក ។ ព្រោះហេតុនេះហើយ បានជាអាមេរិកាំងកំទេចបូដូយមិនកើតសោះ ។ អាមេរិកាំងជាមហាអំណាច គេគោរពច្បាប់យ៉ាងត្រឹមត្រូវ គេមិនរំលោភច្បាប់ទេ គេមិនហ៊ានតាមកំទេចមូលដ្ឋានបូដូយ ដែលតាំងនៅក្នុងទឹកដីខ្មែរនោះឡើយ ។

នៅដើមឆ្នាំ១៩៧០, សម្តេចសីហនុរត់ចោលតំណែង រត់ចោលរាស្ត្រ រត់ចោលស្រុក ទៅជ្រកនៅប្រទេសចិន ។ ពេលនោះ ជូ-អេនឡាយ (ចិន) និងផាំ-យ៉ាំងដុង (យួន) ស៊ីគ្រលុំគ្នាបោកសីហនុ ដោយចាប់ផ្តើមបង្កើតរណសិរ្សរួបរួមប្រជាជនទាំងបីនៃឧបទ្វីបឥណ្ឌូចិន នៅថ្ងៃទី២៥-៣-៧០ យកលេសដើម្បីបញ្ចេញបូជួយ ឲ្យវាយកំទេចទាហានខ្មែរសាធារណរដ្ឋរបស់លោកលន់-នល់ ដែលជាម្ចាស់ទឹកដីកម្ពុជាពិតៗ រួចស្រែកចោទថា ជាបរិវាររបស់ចក្រពត្តិអាមេរិកាំង ។

ចុងខែមេសា១៩៧៥, យួនហាណូយសំរេចជោគជ័យដ៏ធំធេង ត្រួតត្រាប្រទេសវៀតណាមទាំងមូល ។ ចំណែកឯប្រទេសកម្ពុជា ត្រូវយួនត្រួតត្រាយ៉ាងអាថ៌កំបាំង ដោយយកឈ្មោះអង្គការអនាមិកមកដើរតួជំនួស ។ ដើម្បី«សងគុណា» អង្គការបោកសម្តេចសីហនុឲ្យចូលស្រុក ហើយនាំយកទៅឃុំឃាំង រួចវាកែឆ្នៃប្រទេសកម្ពុជាឲ្យក្លាយទៅជានគរព្រាយស៊ីខ្មោច ។ល។ សម្តេចសីហនុឆ្លៀតឆ្លាសរសេរសំបុត្របីច្បាប់ទៅទាក់ទងអតីតមិត្តផាំ-យ៉ាំងដុង ។ តែមិត្តក្បត់នេះ ផ្ញើសំបុត្រសម្តេចសីហនុឥតបើកស្រោមត្រឡប់តបមកវិញ ។ មានអ្នកកាសែតខ្លះសួរផាំ-យ៉ាំងដុងពីរឿងនេះ ផាំ-យ៉ាំងដុងឆ្លើយតបយ៉ាងកំបុតកំបុយទៅវិញថា សីហនុគ្មានប្រយោជន៍អ្វីទេ (Sihanouk à rien !) ។

យាយទៀងសួរលោកទ្រីវចូវបញ្ជាក់ថា ៖

- ដូច្នេះចំពោះរឿងរណសិរ្ស.ជ.រ.ប.ខ.នោះ មេបញ្ជាការធំជានរណា ? ហើយអ្នកនៅក្រោមបង្គាប់ជានរណា ?

លោកត្រីវចូវឆ្លើយភ្លាមថា ៖

- មេបញ្ជាការធំគឺចារជនរបស់យួនហាណូយទាំងអស់ ។ ចំណែកអ្នកធ្វើការជាបន្តបន្ទាប់គឺសមាជិករ.ជ.រ.ប.ខ.មែនទែន ។

ពេលនោះយាយទៀងយកដៃទះថ្ងាស ហើយនិយាយថា ៖

- ខ្ញុំយល់ ខ្ញុំអស់សង្ស័យហើយ ករណីយាយយួនគឹម-លៀង ជាចារកិច្ចរបស់យួនហាណូយ លួចបន្លំធ្វើជាប្រធានរណសិរ្ស.ជ.រ.ប.ខ.ក្លែងក្លាយ គឺជាកញ្ចក់ទិព្វអាចឆ្លុះមើលឃើញស្នៀតយួនហាណូយ តាំងពីអតីតកាលរហូតដល់បច្ចុប្បន្នកាលនេះ ។ ករណីនេះ មិនខុសគ្នាពីករណីអាចារ្យអនមៀន ហៅសឺន-ង៉ុកមិញ, ឬករណីអាចារ្យសុខ ហៅទូ-សាមុត, ករណីសាឡុត-ស ហៅប៉ុល-ពតទេ ។

សភាពខាងក្រៅរបស់ខ្មែរអាយ៉ងទាំងនោះ គឺវាឆ្លៀតឆ្លាបង្ហាញឲ្យឃើញថា វាធ្វើការបំរើខ្មែរ ការពិតវាលួចបញ្ចេញសកម្មភាពស្របៗបណ្តោយបក្សខ្មែរនានា សម្ងំលាក់ពុតស្ទាបស្ទង់យកការណ៍ បើឃើញថាមានឱកាសល្អ ឬមានឧបសគ្គចំពោះបក្សវា ក្រុមចារកិច្ចនេះត្រូវរាយការណ៍ជាបន្ទាន់ យ៉ាងស្ទាត់និងច្បាស់លាស់បំផុត

ឲ្យយួនវៀតមិញឬវៀតកុង កញ្ឆក់យកជ័យជំនះឬកំទេចខ្មែរ ឲ្យទាន់ពេលវេលា ។

មូលហេតុនេះហើយទើបយួនហាណូយអាចឆ្លៃប្រឌិតព្រឹត្តិការណ៍នានានៃប្រទេសខ្មែរ ទៅជាងងឹតអន្ធការ ។ យួនហាណូលលាក់មុខបានជិតដដែល រីឯខ្មែរចេះតែយល់ច្រឡំវិវក់តទៅទៀតគ្មានថ្ងៃចប់ ។

សូមរំឭកឡើងវិញខ្លះ ពីព្រឹត្តិការណ៍សំខាន់ៗ ៖

★ ព្រឹត្តិការណ៍ថ្ងៃទី១៨ មិនា ១៩៧០ ៖

– តើនរណាវាយសម្លាប់ខ្មែរ ?

– គឺយួនហាណូយ ដែលប្រើឃីហោសម្តេចសីហនុ ឲ្យពួកបូជួយលោតវាយប្រហារទាហានរបស់ខ្មែរសាធារណរដ្ឋ ។

★ ព្រឹត្តិការណ៍ថ្ងៃទី១៧ មេសា ១៩៧៥ ៖

– លោកលន់-នល់ជាអ្នកចាញ់, សម្តេចសីហនុជាអ្នកជាប់ឃុំ ។

ដូច្នេះតើនរណាឈ្នះ ? នៅពេលនោះគេឃើញថា អ្នកច្បាំងមិនឈ្នះ ព្រោះចាញ់ទាំងអស់គ្នា ។ តែអ្នកដែលឈ្នះ គឺអង្គការទេតើ ។ ដូច្នេះតើអង្គការជានរណា ?

★ ព្រឹត្តិការណ៍ថ្ងៃទី៧ មករា ១៩៧៩ ៖

ឥឡូវនេះយើងឃើញជាក់ស្តែងថា ឃាតករជាតំណាងរបស់អង្គការ ដែលសម្លាប់ប្រជាជនខ្មែរ ក្នុងសម័យពួកបនប៉ុល-ពត ពីឆ្នាំ១៩៧៥ដល់១៩៧៩នោះ នៅរស់រវើក ហើយមានយួនហាណូយចេញមុខមកជំនួសអង្គការ មកជួយការពារ ។ មិនតែប៉ុណ្ណោះ ពួកវានេះថែមទាំងបានយួនហាណូយបំពាក់បុណ្យស័ក្តិ កាន់ក្តាប់អំណាចដដែល ហើយបានថ្កុំថ្កើងរុងរឿង សុខសាន្ត ប្រសើរជាងខ្មែរជាម្ចាស់ទឹកដីទៅទៀត ។

ដូច្នេះចំពោះអ្នកចេះតាមដាន គេឃើញកលល្បិចនេះលេចចេញនៅកណ្តាលវាល ។

ចំណែកក្រុមខ្មែរអាយ៉ងយួន លុះវាបានកាន់ក្តាប់អំណាចហើយ ពួកវាគិតតែបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរដ្ឋ វាគិតតែពីសម្លាប់កំចាយខ្មែរស្លូតត្រង់ តាមអំពើភេរវកម្មនានា មានប្លន់ លួច ឆក់ ទាំងកណ្តាលថ្ងៃត្រង់ក៏មាន ។

ដើម្បីបំភ័ន្តមតិអន្តរជាតិនិងមតិខ្មែរទូទៅឲ្យយល់ច្រឡំវិវក់ វាបញ្ជូនអាយ៉ងប៉ុល-ពតរបស់វា ទៅធ្វើជាអ្នកចាញ់នៅប្រទេសចិន រួចវាលើកបន្តុបហ៊ុន-សែន, ហេងសំរិន, ជា-ស៊ីម ធ្វើជាអ្នកឈ្នះវិញម្តង ។ ប៉ុន្តែក្នុងចំណោមខ្មែរទាំងនោះ ទាំងអ្នកឈ្នះទាំងអ្នកចាញ់ តើនរណាជាអ្នកឈ្នះមែនទែន បើយួនហាណូយនៅពីក្រោយជាអ្នកបញ្ជា ហើយថែមទាំងមានចិនជាអ្នកគាំទ្រផ្តល់អាវុធនិងមេរៀនផង ។

លោកទ្រីវចូវស្សួរយាយទៀងថា ៖

– តាមពត៌មានយ៉ាងច្បាស់ការណ៍ យើងដឹងថាក្នុងពេលនេះ ចិនកំពុងតែផ្តល់អាវុធឲ្យខ្មែរក្រហមកាត់តាមប្រទេសសៀម ។ តើខ្មែរក្រហមដែលទទួលអាវុធនោះជាខ្មែរក្រហមនៅក្នុងក្រុមណា ? ។

យាយទៀងឆ្លើយតបទៅលោកទ្រីវចូវថា ៖

– បញ្ហាខ្មែរក្រហមជារឿងមួយស្មុគស្មាញណាស់ ។ ខ្ញុំបានឃើញផ្ទាល់ភ្នែកក្នុងសម័យបនប៉ុល-ពត ឃើញថាពួកខ្មែរក្រហមនិន្នាការខ្មែរត្រូវពួកក្រុមឃាតករអាថ៌កំបាំង ចេញមកពត៌បាញ់សម្លាប់ចោលអស់ជាច្រើនលើកច្រើនសារមកហើយ ។ នៅក្នុងនោះមានទាំងមេដឹកនាំដែលគេហៅថា «កម្មាភិបាល» ក៏ត្រូវគេសម្លាប់ចោលអស់ទៅហើយដែរ ។ បើតាមខ្ញុំគិតមើលទៅ ខ្មែរក្រហមដែលសេសសល់នៅរស់ ត្រូវតែដាច់ខ្សែរយៈរប៉ាត់រប៉ាយ ត្រូវរស់នៅដោយមធ្យោបាយផ្ទាល់ខ្លួន ។ ដោយសារអស់ជំនួយនិងខ្សែរយៈពីមេកើយខាងលើ មួយចំនួនត្រូវតែធ្វើចោរដើរប្លន់អ្នកស្រុកដើម្បីរស់ផង ធ្វើជាខ្មែរក្រហមផង ។ ចំណែកឯខ្មែរក្រហមដ៏ខ្លាំងក្លាវិញ ដែលមានមេដឹកនាំនិងវិន័យយ៉ាងត្រឹមត្រូវ, មានខ្សែរយៈហ្មត់ចត់ និងមានអាវុធ គឺខ្មែរក្រហមនិន្នាការយួន ។ ដើម្បីសម្លាប់បំផុតពូជខ្មែរ យួនហាណូយព្យាយាមបង្កើត «ខ្មែរក្រហម» ឲ្យធ្វើការស្របជាមួយខ្មែរក្រហមមួយក្រុមទៀតរបស់ខៀវ-សំផន ដូចដែលមានករណីរណសិរ្ស.ជ.រ.ប.ខ.របស់លោកសឹន-សានអញ្ចឹងដែរ ។

នេះគឺជាកលល្បិចរបស់យួនហាណូយ ដែលវាតែងតែប្រើមកលើគ្រប់ៗក្រុមនិងបក្សខ្មែរ នៅគ្រប់ពេលវេលាតាំងពីយូរយារណាស់មកហើយ ។

រឿងចិនប៉េកាំងផ្តល់អាវុធឲ្យក្រុមខ្មែរក្រហមប៉ុល-ពត នោះជាភស្តុតាងជាក់ស្តែង គឺចិនស៊ីគ្រលុំជាមួយយួនហាណូយជានិច្ច ព្រោះក្រុមប៉ុល-ពតក៏ដូចជាក្រុមយាយគឹម-លៀងដែរ គឺប៉ុល-ពតជាចារបុរសរបស់បក្សកុម្មុយនិស្តឥណ្ឌូចិនតាំងពីឆ្នាំ១៩៥១មកម្ល៉េះ ។

*( សូមបើករង្វង់ក្រចកបំភ្លឺបងប្អូនខ្មែរបន្តិចពីរឿងនេះ ។ នៅឆ្នាំ១៩៨៣ នៅស្រុកបារាំង ខ្ញុំបានអានមសៀវភៅមួយដែលមានចំណងជើងថា ៖* Concerto du Fleuve jaune *របស់អ្នកបោះពុម្ព* Robert Laffont*។ សៀវភៅនេះបានរៀបរាប់ពី «ឆ្នាំក្រហម» របស់ប្រធានម៉ៅ-សេទុងជំនាន់បដិវត្តន៍វប្បធម៌ចិនឆ្នាំ១៩៦៦ ។ ការធ្វើទារុណកម្មទៅលើប្រជាជនចិន មានជាឧទាហរណ៍ទៅលើគ្រួសារអ្នកស្រីចៅ-ជិញលីមានសភាពនិងស្មៀត មិនខុសពីការធ្វើទារុណកម្មទៅលើប្រជាពលរដ្ឋខ្មែរនៅសម័យប៉ុល-ពតទេ ។ សៀវភៅមួយទៀតឈ្មោះ* «Pas de larme pour Moa» *បានរៀបរាប់ពីទារុណកម្មរបស់ឆ្នាំក្រហមទៅលើគ្រួសារអ្នកស្រី នួនួ ធ្វើឲ្យខ្ញុំឈឺចាប់ស្រក់ទឹកភ្នែកនឹកឃើញទៅដល់ទារុណកម្មរបស់តមណាងអង្គការ ធ្វើមកលើគ្រួសារខ្ញុំដែរ ។ រឿងនេះចម្លែកណា*

*ស់ មេដឹកនាំខ្មែរត្រូវតែខំរៀនសូត្រឲ្យដឹងច្បាស់លាស់ពីរឿងនេះ មិនគួរបណ្តោយខ្លួនឲ្យចាញ់បោកចិន ចាញ់បោកយួន បណ្តោយឲ្យពួកវាធ្វើទារុណកម្មទៅលើប្រជាជនខ្មែរដូច្នេះតទៅអនាគតទៀតឡើយ )* ។

លោកទ្រីវ-ចូវសួរទៀតថា ៖

- យួនហាណូយជាវៀតមិញក្តី ជាវៀតកុងក្តី វាបង្កើតចារកិច្ចបានយ៉ាងល្អិតល្អន់ រួចបញ្ជូនបញ្ចូលពួនជ្រកក្រោមសរសៃនៃបក្សនយោបាយខ្មែរនានា សម្ងំលាក់ពុតធ្វើសកម្មភាពស្របៗបណ្តោយ រួចលួចរាយការណ៍ឲ្យយួនហាណូយកំទេចខ្មែរគ្រប់ជ្រុងជ្រោយយ៉ាងនោះ តើសម្តេចនរោត្តម-សីហនុ, លោកខៀវ-សំផនក្តី ដឹងឬទេ ? ។

យាយទៀងឮសំនួរនេះ គាត់មានការឈឺចាប់ណាស់ ។ គាត់នឹកឃើញសព្វគ្រប់ទៅ មានការខ្មាស់អៀនជាក្រៃលែង ។ មួយសន្ទុះគាត់ក៏បន្តទៅទៀតថា ៖

- ឱលោកអើយ ! ខ្មែរយើងអភ័ព្វណាស់ ។ ខ្មែរកើតមកគ្រប់ៗជំនាន់ ជួបប្រទះតែមេដឹកនាំខ្វះសមត្ថភាព ។ ម្នាក់ៗចូលចិត្តតែឲ្យគេបញ្ជោរ ។ ឯងភរអញក៏ភរទៅចុះ តែបើបញ្ជើចបញ្ជើត្រូវចិត្តអញហើយ អញពេញចិត្តណាស់ ឯងធ្វើអីក៏ធ្វើទៅ ! ។

ក្នុងរយៈបួនឆ្នាំ យួនហាណូយប្រើតែឈ្មោះ «អង្គការ» វាអាចធ្វើឲ្យខ្មែរស្លាប់រាប់លាននាក់, អ្នកដែលសល់នៅរស់ ទៅជាឆ្កួតវង្វេង ទ្រព្យសម្បត្តិរលាយអស់មួយនគរខ្មែរ, អាណិកជនយួនពីរសែននាក់ត្រូវពួកវាប្រមូលយកទៅលាក់ទុកនៅស្រុកយួន សំរាប់យកមកធ្វើជា «ខ្មែរថ្មី» ។

ដំណាក់ការដល់ប៉ុណ្ណឹងហើយ មេដឹកនាំខ្មែរនៅសម្ងំស្ងៀមស្ងាត់ ហាក់ដូចជាមិនដឹងមិនយល់អ្វីទាំងអស់ ។ យួនហាណូយកំពុងតែលុកលុយពេញស្រុកខ្មែរ ហេតុយ៉ាងដូចម្តេចក៏អស់លោកអ្នកដឹកនាំទាំងនេះ មិនស្រែកអំពាវនាវពិភពលោកឲ្យគេជួយ ? ខ្ញុំមិនដែលឮលោកណានិយាយវែកញែកឲ្យខ្មែរនិងបរទេសយល់ពីលក្ខណៈពិតនៃសង្គ្រាមនៅកម្ពុជានេះសោះ ។ ឥឡូវនេះទៀត ខ្មែរកំពុងតែដើរចេញចោលទឹកដីឲ្យយួនទៀតហើយ ។

ដូច្នេះ សព្វថ្ងៃនេះក៏ដូចជាថ្ងៃមុន មេដឹកនាំខ្មែរទាំងអស់គ្មានអំណាច ឬឥទ្ធិពលអ្វីទៅលើខ្មែរក្រហម ដែលកំពុងតែបញ្ចេញសកម្មភាពពាសពេញព្រៃនៃប្រទេសខ្មែរនោះឡើយ ។

សព្វថ្ងៃនេះ, អ្នកដែលមានលទ្ធភាព អាចធ្វើតាមអំពើចិត្តក្នុងប្រទេសខ្មែរ គឺយួនហាណូយទាំងស្រុង ដែលមានចិនស៊ុំគ្រលុំយ៉ាងស្ងាត់ វាអាចបង្កើតអ្នកឈ្នះ វាអាចបង្កើតអ្នកចាញ់ វាអាចបង្កើតខ្មែរក្រហមស្រឡាញ់ស្តេច វាអាចបង្កើតខ្មែរប្រឆាំ

ងខ្មែរក្រហម ។ល។ និង ។ល។

ចំណែកវាវិញ វាពួនក្នុងទីងងឹតចាំញោក់ខ្សែ ញ៉ាំឲ្យខ្មែរយល់ច្រឡំវិវក់ លោតសម្លាប់តែជាតិឯង ។

លោកទ្រីវចូវសម្លឹងមុខយាយទៀងយ៉ាងយូរទើបសួរថា ៖

- តើចាប់តាំងពីឆ្នាំ១៩៧៥រហូតមក មានខ្មែរណាចាប់អារម្មណ៍យល់ថា អង្គការអនាមិកជាយួនហាណូយឬទេ ?

យាយទៀងបញ្ជាក់ទៅលោកចូវថា ៖

- ក្នុងកាលៈទេសៈដ៏ឧបទ្រពនោះ ប្រជាជនខ្មែរទូទៅអស់សង្ឃឹម គ្រប់ៗរូបដេកចាំតែថ្ងៃស្លាប់ ព្រោះមិនដឹងថាពេលណាតំណាងរបស់អង្គការនឹងចូលមកចាប់ចងយកទៅសម្លាប់ ។ ទុក្ខត្រួតលើទុក្ខ រាល់ថ្ងៃខែឆ្នាំគ្មានពេលស្រាក ដូច្នេះម្នាក់ៗនៅសល់តែរូបរាងកាយ តែព្រលឹងហោះហើរពីខ្លួនអស់រលីងទៅហើយ ។ តើមានសល់អ្វីសំរាប់ធ្វើការត្រិះរិះពិចារណា ? ។

~ចប់~